# ព្រះ
# ត្រៃបិដក

## ប្រែរួមនឹង
## ព្រះអដ្ឋកថា

## ភាគ២៥

បាលីប្រែ ៥០

ពុទ្ធសករាជ ២៥៥៣

ច្បាប់ពិនិត្យ លើកទី២

# ព្រះ

# សុត្តន្តបិដក

## និង

# មនោរថបូរណី អដ្ឋកថា

## សេចក្តីប្រែជាភាសាខ្មែរ

# អង្គុត្តរនិកាយ

# ឯក-ទុកនិបាត

# បឋមភាគ

# ២៥

# បាលីប្រែ ៤០

*បោះពុម្ពលើកទី ១ ពុទ្ធសករាជ ២៥៥៣*

# ក្បាលទី ២៥

# អង្គុត្តរនិកាយ ឯកនិបាត

# បឋមភាគ

*សូមនមស្ការព្រះដ៏មានព្រះភាគ ជាអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ ។*

## ចាលីសប្តែងអំពីធម៌ពួកមួយៗ ជាដើម

[ ១ ] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្នុងវត្តជេតពនរបស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយ ក្នុងទីនោះឯងថា ម្នាលភិក្ខុទាំង-ឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា

[ ២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញរូបដទៃ សូម្បីតែរូប ១ ដែលគ្របសង្កត់ចិត្តបុរសហើយស្ថិតនៅ ដូចរូបស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ រូបស្ត្រីទើបអាចគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

[ ៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសំឡេងដទៃ សូម្បីតែសំឡេង ១ ដែលគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ដូចសំឡេងស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សំឡេងស្ត្រីទើបអាចគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

[ ៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញក្លិនដទៃ សូម្បី

តែក្លិន ១ ដែលគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ដូចក្លិនស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ក្លិនស្ត្រីទើបអាចគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

[ ៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញរសដទៃ សូម្បីតែរស ១ ដែលគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ដូចរសស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ រសស្ត្រីទើបអាចគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

[ ៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញផ្សព្វដទៃ សូម្បីតែផ្សព្វ ១ ដែលគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ដូចផ្សព្វស្ត្រីនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ផ្សព្វស្ត្រីទើបអាចគ្របសង្កត់ចិត្តបុរស ហើយស្ថិតនៅ ។

[ ៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញរូបដទៃ សូម្បីតែរូប ១ ដែលគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ដូចរូបបុរសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ រូបបុរសទើបអាចគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ។

[ ៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសំឡេងដទៃ សូម្បីតែសំឡេង ១ ដែលគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ដូចសំឡេងបុរសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ សំឡេងបុរសទើបអាចគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ។

[ ៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញក្លិនដទៃ សូម្បីតែក្លិន ១ ដែលគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ដូចក្លិនបុរសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ក្លិនបុរសទើបអាចគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ។

[ ១០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញរសដទៃ សូម្បីតែរស ១ ដែលគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ដូចរសបុរសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ រសបុរសទើបអាចគ្របសង្កត់ស្ត្រី ហើយស្ថិតនៅ ។

[ ១១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញ ផ្សព្វដទៃ សូម្បីតែផ្សព្វ ១ ដែលគ្របសង្កត់ចិត្តស្ត្រីហើយស្ថិតនៅ ដូចផ្សព្វបុរសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ផ្សព្វបុរសទើបអាចគ្របសង្កត់ចិត្តស្ត្រី ហើយស្ថិតនៅ ។

**វគ្គទី ១ ចប់**

# អដ្ឋកថា

# អង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី

## ឯកនិបាត

## រូបាទិវគ្គទី ១

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

### អារម្ភកថា

ខ្ញុំ ( ព្រះពុទ្ធឃោសាចារ្យ ) សូមនមស្ការព្រះសុគត ទ្រង់រួចផុតចាកគតិ ទ្រង់មានព្រះហឫទ័យត្រជាក់ដោយព្រះករុណា មានងងឹត គឺមោហៈ ដែលពន្លឺ គឺបញ្ញាកម្ចាត់ហើយ ជាសាស្ដានៃសត្វលោក គឺមនុស្ស និងទេវតា ។

ព្រះពុទ្ធ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវគុណ ដែលនាំឲ្យបានជាព្រះពុទ្ធ ចូលដល់ធម៌ណា ដែលប្រាសចាកមន្ទិល ខ្ញុំសូមនមស្ការនូវធម៌នោះ ដែលជាធម៌ដ៏ឧត្ដម ។

ខ្ញុំសូមនមស្ការដោយសិរសា គឺត្បូង នូវព្រះអរិយសង្ឃទាំង ៨ ដែលជាឱរសរបស់ព្រះតថាគត ជាអ្នកញាំញីនូវមារ ព្រមទាំងសេនា ដោយសេចក្ដីគោរព ។

បុណ្យណា សម្រេចដោយការថ្វាយបង្គំព្រះរតនត្រ័យរបស់ខ្ញុំ ដែលមានចិត្តជ្រះថ្លា ដូចពោលមកនេះ ដោយអានុភាពនៃបុណ្យនោះ សូមជួយកម្ចាត់អន្តរាយដល់ខ្ញុំ ខ្ញុំនឹងចងការសាបាលីអំពីគម្ពីរអដ្ឋកថា ដែលព្រះអរហន្ត

អ្នកជំនាញ ៥០០ អង្គសង្គាយនាមកមុនគេបង្អស់ និងសង្គាយនាតៗ មក ក្នុងកាលជាខាងក្រោយ ដែលព្រះមហិន្ទត្ថេរនាំមកកាន់កោះសីហឡ រចនាជាសីហឡភាសា ដើម្បីប្រយោជន៍ដល់អ្នកកោះ ខ្ញុំនឹងលើកឡើងកាន់ភាសាបាលី គឺមគធភាសា មិនឲ្យជំទាស់លទ្ធិសម័យ ដែលប្រាសចាកទោសនៃព្រះថេរៈ ដែលជាប្រទីបនៃថេរវង្ស ក្នុងមហាវិហារ ដែលមានវិនិច្ឆ័យល្អិតល្អន់ វៀរនូវសេចក្ដីដែលជាន់គ្នាខ្វះ ប្រកាសអត្ថនៃគម្ពីរអង្គុត្តរនិកាយដ៏ប្រសើរ ដែលប្រដាប់ដោយឯកនិបាត ទុកនិបាត តិកនិបាតជាដើម ដើម្បីឲ្យអត្ថជាក់ច្បាស់ សម្រាប់ឲ្យកើតបដិកាណដ៏វិចិត្រ ដល់ធម្មកថិកទាំងឡាយ ។ កាលខ្ញុំពោលអត្ថនៃគម្ពីរទីឃនិកាយ និងគម្ពីរមជ្ឈិមនិកាយ ខាងក្រោយ ទើបពណ៌នារឿងរ៉ាវរបស់នគរទាំងឡាយ មាននគរសាវត្ថីជាដើម ឲ្យសាធុជនត្រេកអរ និងដើម្បីឲ្យព្រះសទ្ធម្មតាំងនៅយឺនយូរ បានឮថា រឿងឯណាដែលពោលក្នុងគម្ពីរទាំង ២ នោះ ពិស្ដារហើយ ក្នុងគម្ពីរអង្គុត្តរនិកាយនេះ ខ្ញុំមិនពោលរឿងទាំងនោះឲ្យពិស្ដារម្ដងទៀតឡើយ តែសម្រាប់សូត្រទាំងឡាយអត្ថណាវៀររឿងរ៉ាវចេញ មិនជាក់ច្បាស់ ខ្ញុំនឹងពោលរឿងរ៉ាវនោះ ដើម្បីឲ្យជាក់ច្បាស់ក្នុងសេចក្ដីទាំងនោះ ។

ព្រះពុទ្ធវចនៈ គឺសីលកថា ធុតង្គធម៌ កម្មដ្ឋានទាំងអស់ សេចក្ដីពិស្ដារនៃឈាន និងសមាបត្តិ ដែលប្រកបដោយវិធីបដិបត្តិ អភិញ្ញាទាំងឡាយ ពាក្យវិនិច្ឆ័យដែលទាក់ទងដោយបញ្ញា ខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ អរិយសច្ច ៤ បច្ចយាការទេសនា មាននយ័បរិសុទ្ធល្អិតល្អន់ ដែលមិនផុតចាក

គន្ថព្រះបាលី និងវិបស្សនាការនា ព្រោះហេតុដែលពុទ្ធវចនៈ ដែលពោលមកទាំងអស់នេះ ខ្ញុំបានពោលហើយ បរិសុទ្ធល្អក្នុងវិសុទ្ធិមគ្គ ដូច្នោះ ក្នុងទីនេះ ខ្ញុំមិនវិនិច្ឆ័យរឿងទាំងអស់នោះឲ្យក្រៃលែងទៀតឡើយ ព្រោះបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គនេះ ដែលខ្ញុំបានរចនាហើយ តាំងនៅត្រង់កណ្តាលនៃនិកាយទាំង ៤ និងប្រកាសសេចក្តីតាមដែលពោលនៅក្នុងនិកាយទាំង ៤ នោះ ដូច្នោះ ចូរសាធុជនទាំងឡាយ កាន់យកបករណ៍វិសេសឈ្មោះវិសុទ្ធិមគ្គនោះមួយអន្លើដោយអដ្ឋកថានេះ ហើយជ្រាបអត្ថក្នុងគម្ពីរ អង្គុត្តរនិកាយនេះចុះ ។

# អដ្ឋកថា សូត្រទី ១

ក្នុងគម្ពីរទាំងនោះ គម្ពីរឈ្មោះអង្គុត្តរនិកាយ មាន ១១ និបាត គឺឯកនិបាត ទុកនិបាត តិកនិបាត ចតុក្កនិបាត បញ្ចកនិបាត ឆក្កនិបាត សត្តនិបាត អដ្ឋកនិបាត នវកនិបាត ទសកនិបាត ឯកាទសកនិបាត ។

បើពោលដោយសូត្រ អង្គុត្តរនិកាយ មាន ៩៥៥៧ សូត្រ បណ្ដានិបាតនៃអង្គុត្តរនិកាយនោះ ឯកនិបាតជានិបាតដើម បណ្ដាសូត្រ ចិត្តបរិយាយសូត្រ ជាសូត្រដើម ពាក្យនិទាននៃសូត្រនោះ មានពាក្យថា **ឯវម្មេ សុតំ** ជាដើម ព្រះអានន្ទពោលក្នុងកាលមហាសង្គីតិលើកទី ១ ជាដើម ឯមហាសង្គីតិលើកទី ១ នោះ បានពោលពិស្ដារហើយខាងដើមនៃអដ្ឋកថាទីឃនិកាយ ឈ្មោះថា សុមង្គលវិលាសិនី ព្រោះដូច្នោះ មហាសង្គីតិលើកទី ១ នោះ គប្បីជ្រាបដោយពិស្ដារក្នុងអដ្ឋកថាទីឃនិកាយនោះចុះ ។

[ ១ ] បទថា **ឯវំ** ក្នុងនិទានវចនៈថា **ឯវម្មេ សុតំ** ជាដើម ជាបទនិបាត បទថា **មេ** ជានាមបទ បទថា **វិ** ក្នុងបទថា **សាវត្ថិយំ វិហរតិ** នេះ ជាបទឧបសគ្គ ។ បទថា **ហរតិ** ជាបទអាខ្យាត ។ គប្បីជ្រាបការចែកបទដោយបទនេះសិន ។

តែបើពោលដោយអត្ថ បទបឋម គឺ **ឯវំ** សព្ទ មានអត្ថច្រើនប្រភេទ ដូចជា ឧបមា គឺប្រៀបធៀប ឧបទេស គឺណែនាំ សម្បហំសនៈ គឺលើកសរសើរ គរហណៈ គឺតិះដៀល វចនសម្បដិគ្គហណៈ គឺទទួលពាក្យ អាការ គឺអាការ និទស្សនៈ គឺឧទាហរណ៍ និងអវធារណៈ គឺរាំងសេចក្ដីដទៃ ។ ពិតហើយ **ឯវំ** សព្ទនោះ មកក្នុងឧបមាប្រៀបធៀបក្នុងពាក្យជាដើម យ៉ាងនេះថា **ឯវំ**

**ជាតេន មច្ចេន កត្តព្វំ កុសលំ ពហុំ** កុសល ដែលសត្វកើតមកហើយ គួរធ្វើឲ្យច្រើនយ៉ាងនោះ ដូច្នេះ ។ មកក្នុងឧបទេស ណែនាំ ដូចក្នុងប្រយោគជាដើមថា **ឯវន្តេ អភិក្កមិតព្វំ ឯវំ បដិក្កមិតព្វំ** អ្នកត្រូវឈានដើរទៅមុខយ៉ាងនេះ អ្នកត្រូវថយក្រោយយ៉ាងនេះ ដូច្នេះ ។ មកក្នុងសម្បហំសនៈ គឺលើកសរសើរ ដូចក្នុងប្រយោគជាដើមថា **ឯវមេតំ ភគវា ឯវមេតំ សុគត** បពិត្រព្រះដ៏មានព្រះភាគ ហេតុនុ៎ះយ៉ាងនេះហើយ បពិត្រព្រះសុគត ហេតុនុ៎ះយ៉ាងនេះហើយ ដូច្នេះ ។ មកក្នុងគរហណៈ គឺតិះដៀល ដូចក្នុងប្រយោគជាដើមយ៉ាងនេះថា **ឯវមេវ បនាយំ វសលី យស្មឹ វា តស្មឹ វា តស្ស មុណ្ឌកស្ស វណ្ណំ ភាសតិ** មេចង្រៃនេះ ធ្លាប់តែអឺចឹងៗ ហ៊ានពោលសរសើរសមណៈត្រងោលក្នុងទីផ្តេសផ្តាស ដូច្នេះ ។ មកក្នុងវចនសម្បដិគ្គហណៈ គឺទទួលពាក្យ ដូចក្នុងប្រយោគជាដើមថា **ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ** ភិក្ខុទទួលពាក្យនៃព្រះដ៏មានព្រះភាគថា ករុណាព្រះអង្គ ដូច្នេះ ។ មកក្នុងអាការ ដូចក្នុងប្រយោគជាដើមថា **ឯវំ ព្យា ខោ អហំ ភន្តេ ភគវតា ធម្មំ ទេសិតំ អាជានាមិ** ខ្ញុំបានដឹងច្បាស់នូវធម៌ដែលព្រះមានព្រះភាគទ្រង់សម្តែងហើយក៏យ៉ាងនោះដែរ ដូច្នេះ ។ មកក្នុងនិទស្សនៈ គឺគំរូ ដូចក្នុងប្រយោគជាដើមថា **ឯហិ ត្វំ មាណវក យេន សមណោ អានន្ទោ ។បេ។ អនុកម្បំ ឧបាទាយ** ម្នាលមាណព ឯងចូរមកនេះ ឯងចូរទៅរកព្រះសមណៈឈ្មោះអានន្ទ លុះចូលទៅដល់ហើយ ចូរសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន មានកម្លាំង

នៅជាសុខសប្បាយ នឹងព្រះសមណៈឈ្មោះអានន្ទ តាមពាក្យរបស់អញថា សុភមាណពជាកូនតោទេយ្យព្រាហ្មណ៍ ផ្តាំឲ្យសួរនូវអាការមានអាពាធតិច មានរោគតិច ក្រោកទៅមកបានរហ័សរហួន និងកម្លាំង និងអាការនៅជាសុខសប្បាយចំពោះព្រះអានន្ទដ៏ចម្រើន រួចហើយ ឯងចូរនិមន្តថា សូមលោកម្ចាស់អានន្ទ អាស្រ័យនូវសេចក្តីអនុគ្រោះ និមន្តមកកាន់ទីលំនៅរបស់សុភមាណព ជាកូនតោទេយ្យព្រាហ្មណ៍ឲ្យទាន ដូច្នេះ ។

មកក្នុងអវធារណៈ គឺរាំងសេចក្តីដទៃ ដូចក្នុងប្រយោគជាដើមថា **តំ កឹ មញ្ញថ កាលាមា ។បេ។ ឯវំ នោ ឯត្ថ ហោតិ** ម្នាលកាលាមក្សត្រិយ៍អ្នកសម្គាល់ហេតុនោះដូចម្តេច ធម៌នេះជាកុសល ឬជាអកុសល ។ ជាអកុសល ព្រះអង្គ ។ ជាធម៌ប្រកបដោយទោស ឬមិនប្រកបដោយទោសទេ ។ ជាធម៌ប្រកបដោយទោស ព្រះអង្គ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ឬអ្នកប្រាជ្ញសរសើរ ។ ជាធម៌ដែលអ្នកប្រាជ្ញតិះដៀល ព្រះអង្គ ។ ធម៌ទាំងនេះដែលបុគ្គលសមាទានពេញលេញហើយ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ ឬមិនប្រព្រឹត្តទៅទេ ឬក៏ក្នុងដំណើរនោះ ដូចម្តេចទៅវិញ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងនេះ ដែលបុគ្គលសមាទានបរិបូណ៌ហើយ រមែងប្រព្រឹត្តទៅ ដើម្បីមិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ យើងខ្ញុំក៏យល់ក្នុងដំណើរនោះដូច្នោះដែរ ដូច្នេះ ។

ដោយ **ឯវំ** សព្ទនេះ ក្នុងទីនេះ គប្បីឃើញថា ប្រើក្នុងអត្ថថា អាការ និទស្សនៈ និងអវធារណៈ ។

បណ្ដាអត្ថ ៣ យ៉ាងនោះ ដោយ **ឯវំ** សព្ទ មានអាការជាអត្ថ ព្រះថេរៈសម្ដែងដល់អត្ថនេះថា ព្រះតម្រាស់របស់ព្រះមានព្រះភាគ ល្អិតសុខុមដោយន័យផ្សេងៗ មានអធ្យាស្រ័យដ៏ច្រើនជាសមុដ្ឋាន បរិបូណ៌ដោយអត្ថនិងព្យញ្ជនៈ មានបាដិហារ្យផ្សេងៗ ជ្រៅដោយធម៌ អត្ថ ទេសនា និងបដិវេធ មកប្រាកដតាមសោតទ្វារនៃសព្វសត្វ តាមសមគួរដល់ភាសា រៀងៗ ខ្លួន បុគ្គលណាអាចដឹងបានដោយអាការទាំងពួង តែខ្ញុំធ្វើនូវការចង់ស្ដាប់ឲ្យកើតឡើងហើយ ដោយកម្លាំងគ្រប់យ៉ាង បានស្ដាប់មកហើយដោយអាការយ៉ាងនេះ គឺខ្ញុំបានស្ដាប់មកហើយ ដោយអាការឯណានីមួយ ។

ដោយ **ឯវំ** សព្ទ មាននិទស្សនៈជាអត្ថ ព្រះថេរៈកាលនឹងដោះខ្លួនថា ខ្ញុំមិនមែនព្រះសយម្ភូ សូត្រនេះខ្ញុំមិនបានធ្វើឲ្យជាក់ច្បាស់ ទើបសម្ដែងសូត្រទាំងអស់ ដែលគួរពោលក្នុងឥឡូវនេះថា **ឯវម្មេ សុតំ** ខ្ញុំបានស្ដាប់ហើយយ៉ាងនេះ ។

ដោយ **ឯវំ** សព្ទ មានអវធារណៈជាអត្ថ ព្រះថេរៈកាលសម្ដែងកម្លាំងនៃការចងចាំរបស់ខ្លួន ដែលសមគួរដល់ភាពជាបុគ្គលដែលព្រះសព្វញ្ញូទ្រង់សរសើរហើយ យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ បណ្ដាភិក្ខុសាវ័កដែលជាពហុស្សុតរបស់តថាគត អានន្ទជាកំពូលលើសបណ្ដាភិក្ខុដែលជាសាវ័ករបស់តថាគត ដែលជាអ្នកមានសតិ មានគតិ មានធិតិ ដែលឧបដ្ឋាក អានន្ទជាកំពូល និងជាបុគ្គលដែលព្រះធម្មសេនាបតីសារីបុត្រសរសើរថា ព្រះធម្មសេនាបតី ក៏សរសើរយ៉ាងនេះថា **អាយស្មា អានន្ទោ អត្ថកុសលោ**

**ធម្មកុសលោ ព្យញ្ជនកុសលោ និរុត្តិកុសលោ បុព្វាបរកុសលោ** អានន្ទ ឈ្លាសក្នុងអត្ថ ១ ឈ្លាសក្នុងធម៌ ១ ឈ្លាសក្នុងអក្ខរប្បភេទ ១ ឈ្លាសក្នុងភាសា ១ ឈ្លាសទាំងដើម ទាំងចុង ១ ទើបញុំាងភាពជាអ្នកប្រាថ្នាដើម្បីស្តាប់នៃសត្វទាំងឡាយឲ្យកើតថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះ ឯសូត្រនោះមិនខ្វះមិនលើស ដោយអត្ថ និងដោយព្យញ្ជនៈ គប្បីឃើញយ៉ាងនេះឯង មិនគប្បីឃើញដោយប្រការដទៃ ។

**មេ** សព្ទ ប្រាកដក្នុងអត្ថ ៣ យ៉ាង ពិតហើយ **មេ** សព្ទនោះ មានអត្ថថា **មយា** គឺដែលខ្ញុំ ដូចក្នុងប្រយោគជាដើមថា **គាថាភិគីតម្មេ-អភោជនេយ្យំ** ភោជនដែលតថាគតពោលហើយដោយគាថា ( ច្រៀង ) ជាវត្ថុមិនគួរដល់ការបរិភោគទេ ។

**មេ** សព្ទ មានអត្ថថា **មយ្ហំ** គឺដល់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា **សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ** បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គសូមអង្វរ សូមព្រះមានព្រះភាគ សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំ ។

**មេ** សព្ទ មានអត្ថថា **មម** គឺរបស់ខ្ញុំ ដូចក្នុងប្រយោគជាដើមថា **ធម្ម-ទាយាទា មេ ភិក្ខវេ ភវថ** ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌កចុះ ។ តែក្នុងទីនេះ ប្រើក្នុងអត្ថទាំង ២ គឺ **មយា សុតំ** ដែលខ្ញុំបានស្តាប់មកហើយ និង **មម សុតំ** ការស្តាប់របស់ខ្ញុំ ។

សព្ទថា **សុត** ក្នុងបទថា **សុតំ** នេះ មានឧបសគ្គផង មិនមានឧបសគ្គផង មានប្រភេទនៃធម៌ដ៏ច្រើន ដូចជា **គមន** គឺទៅ **វិសុត** គឺប្រាកដ

**កិលិដ្ឋ** គឺជោកជាំ **ឧបចិត** គឺសន្សំ **អនុយុត្ត** គឺខ្វល់ខ្វាយ **សោតវិញ្ញេយ្យ** គឺសំឡេង ដែលដឹងដោយសោត និង **សោតទ្វារានុស្សារវិញ្ញាត** គឺដឹងតាមសោតទ្វារជាដើម ។

ពិតហើយ **សុតំ** សព្ទនោះ មានអត្ថថា ទៅ ដូចក្នុងប្រយោគជាដើមថា **សេនាយ បសុតោ** ទៅហើយដោយសេនា ។ មកក្នុងអត្ថថា ប្រាកដ ដូចក្នុងប្រយោគជាដើមថា **សុតធម្មស្ស បស្សតោ** បុគ្គលមានធម៌ស្ដាប់ហើយ បានឃើញច្បាស់ ។ មកក្នុងអត្ថថា ជោកជាំ ដូចក្នុងប្រយោគជាដើមថា **អវស្សុតា អវស្សុតស្ស** ( សុន្ទរីនន្ទាជាម្ចាស់ ) មានតម្រេកមិនគួរនឹងត្រេកអរឲ្យបុរសបុគ្គលដែលមានតម្រេក ... ដូច្នេះ ។ មកក្នុងអត្ថថា សន្សំ ដូចក្នុងប្រយោគជាដើមថា **តុម្ហេហិ បុញ្ញំ បសុតំ អនប្បកំ** បុណ្យ ឈ្មោះថា បានសន្សំ មិនមែនតិចឡើយ ។ មកក្នុងអត្ថថា ខ្វល់ខ្វាយ ដូចក្នុងប្រយោគជាដើមថា **យេ ឈានបសុតា ធីរា** អ្នកប្រាជ្ញឯណា ជាអ្នកប្រកបរឿយៗ ក្នុងឈាន ។ មកក្នុងអត្ថថា សំឡេងដែលដឹងដោយសោត ដូចក្នុងប្រយោគជាដើមថា **ទិដ្ឋំ សុតំ មុតំ** រូបដែលឃើញ សំឡេងដែលបានឮ អារម្មណ៍ដែលដឹង ។ មកក្នុងអត្ថថា ដឹងតាមសោតទ្វារ ដូចក្នុងប្រយោគជាដើមថា **សុតធរោ សុតសន្និចយោ** ( ភិក្ខុក្នុងសាសនានេះ ) ជាអ្នកទ្រទ្រង់នូវពុទ្ធវចនៈ សន្សំនូវពុទ្ធវចនៈ ។ តែក្នុងទីនេះ **សុត** សព្ទ មានអត្ថថា **ឧបធារិតំ** គឺទ្រទ្រង់តាម សោតទ្វារ ឬ **ឧបធារណំ** គឺទ្រទ្រង់ចាំ ។ ពិតហើយ **មេ** សព្ទ មានអត្ថថា **មយា** សេចក្ដីថា ខ្ញុំបាន

ស្តាប់មកហើយយ៉ាងនេះ គឺចូលទៅទ្រទ្រង់ចាំ តាមក្រសែនៃសោតទ្វារក៏ត្រូវ ។ មានអត្ថថា **មម** សេចក្តីថា ការស្តាប់របស់ខ្ញុំយ៉ាងនេះ គឺការទ្រទ្រង់ចាំតាមក្រសែនៃសោតទ្វារក៏ត្រូវ ។

បណ្តាបទទាំង ៣ ដូចពោលមកនេះ បទថា **ឯវំ** ជាបទសម្តែងដល់កិច្ច គឺរបស់វិញ្ញាណ មានសោតវិញ្ញាណជាដើម បទថា **មេ** ជាបទសម្តែងបុគ្គលដែលដល់ព្រមដោយវិញ្ញាណដូចពោលហើយ បទថា **សុតំ** ជាបទសម្តែងដល់ការកាន់យកមិនខ្វះ មិនលើស មិនវិបរិត ព្រោះបដិសេធភាវៈដែលមិនបានឮ ម្យ៉ាងទៀត បទថា **ឯវំ** ជាបទប្រកាសថា វិញ្ញាណវិថីដែលប្រព្រឹត្តទៅហើយតាមក្រសែនៃសោតទ្វារនោះ ប្រព្រឹត្តទៅក្នុងអារម្មណ៍ដោយប្រការផ្សេងៗ ។ បទថា **មេ** ជាបទប្រកាសខ្លួន ។ បទថា **សុតំ** ជាបទប្រកាសធម៌ ។ ក្នុងទីនេះ មានអត្ថសង្ខេបដូច្នេះថា ខ្ញុំមិនធ្វើកិច្ចដទៃ តែកិច្ចនេះ ខ្ញុំធ្វើហើយ ធម៌នេះខ្ញុំស្តាប់មកហើយ ដោយវិញ្ញាណវិថីដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ ដោយប្រការផ្សេងៗ ។

ម្យ៉ាងទៀត បទថា **ឯវំ** ជាបទប្រកាសអត្ថដែលគប្បីបង្ហាញ ។ បទថា **មេ** ជាបទប្រកាសបុគ្គល ។ បទថា **សុតំ** ជាបទប្រកាសកិច្ចរបស់បុគ្គល លោកអធិប្បាយថា ខ្ញុំចង្អុលបង្ហាញព្រះសូត្រណា ព្រះសូត្រនោះខ្ញុំស្តាប់មកហើយយ៉ាងនេះ ។

ម្យ៉ាងទៀត សព្ទថា **ឯវំ** សម្តែងអាការផ្សេងៗ របស់ចិត្តសន្តានដែលកាន់យកអត្ថ និងព្យញ្ជនៈផ្សេងៗ ព្រោះចិត្តសន្តានប្រព្រឹត្តទៅផ្សេងៗ គ្នា ពិត

ហើយ សព្ទថា **ឯវំ** នេះ សម្តែងដល់បញ្ញត្តិ គឺការដឹងដោយអាការ សព្ទថា **មេ** សម្តែងដល់អ្នកធ្វើ ។ សព្ទថា **សុតំ** សម្តែងអារម្មណ៍ ដោយពាក្យមានប្រមាណប៉ុណ្ណេះ ការសម្រេចដោយទាញអ្នកធ្វើអារម្មណ៍របស់បុគ្គលដែលដល់ព្រមដោយចិត្តសន្តាននោះ ជាការធ្វើហើយដោយចិត្តសន្តាន ដែលប្រព្រឹត្តទៅ ដោយប្រការផ្សេងៗ ។

ម្យ៉ាងទៀត **ឯវំ** សព្ទ សម្តែងកិច្ចរបស់បុគ្គល **សុតំ** សព្ទ សម្តែងកិច្ចនៃវិញ្ញាណ **មេ** សព្ទ សម្តែងបុគ្គលដែលប្រកបកិច្ចទាំង ២ ក្នុងទីនេះមានសេចក្តីសង្ខេបដូច្នេះថា ខ្ញុំជាបុគ្គលដល់ព្រមដោយវិញ្ញាណដែលមានកិច្ចគឺការស្តាប់ បានស្តាប់មកហើយ ដោយវោហារថា កិច្ច គឺការស្តាប់ដែលបានមក ទាក់ទងដោយវិញ្ញាណ ។

បណ្តាបទទាំងនោះ បទថា **ឯវំ** និងបទថា **មេ** ជាអវិជ្ជមានប្បញ្ញត្តិ គឺបញ្ញត្តិវត្ថុដែលមិនមាន ដោយអំណាចនៃសច្ចិកដ្ឋ និងបរមត្ថ ។ ពិតហើយក្នុងទីនេះ ពាក្យដែលគប្បីបាននិទ្ទេសថា **ឯវំ** ឬ **មេ** កាលពោលដោយបរមត្ថ នឹងមានដែរឬ បទថា **សុតំ** ជាវិជ្ជមានប្បញ្ញត្តិ គឺបញ្ញត្តវត្ថុដែលមានក្នុងទីនេះ វត្ថុដែលបានមកដោយសោតវិញ្ញាណនោះ មានដោយបរមត្ថ ។ បទថា **ឯវំ** និង **មេ** ជាឧបាទាយប្បញ្ញត្តិ ព្រោះអាស្រ័យវត្ថុដែលបានមកដោយសោតនោះៗ ពោលដោយប្រការនោះ ។ បទថា **សុតំ** ជាឧបនិធាយប្បញ្ញត្តិ គឺបញ្ញត្តិក្នុងការតាំងទុក ព្រោះលើកយកវត្ថុដែលឃើញហើយជាដើមមកពោល ម្យ៉ាងទៀត បណ្តាពាក្យទាំង ២ នោះ ពាក្យថា **ឯវំ**

ព្រះអានន្ទសម្តែងដល់ការមិនវង្វេង ពិតហើយ បុគ្គលវង្វេង រមែងមិនអាចយល់បាន ដោយប្រការផ្សេងៗ ។ ដោយពាក្យថា **សុតំ** ព្រះអានន្ទសម្តែងការមិនភ្លេចភ្លាំង ក្នុងអ្វីដែលស្តាប់ហើយ ។ ពិតហើយ បុគ្គលណាស្តាប់ហើយ តែភ្លេចបង់ បន្ទាប់មក បុគ្គលនោះ ក៏ជានាអះអាងមិនបានថា ខ្ញុំស្តាប់មកហើយ ដូច្នោះ ព្រះអានន្ទ ឈ្មោះថា សម្រេចដោយបញ្ញា ព្រោះការមិនវង្វេង ឈ្មោះថា សម្រេចដោយសតិ ព្រោះការមិនភ្លេច បណ្តាបញ្ញានិងសតិនោះ ការដែលសតិមានបញ្ញាជាអ្នកនាំ អាចចងចាំនូវព្យញ្ជនៈបានតាមដែលបញ្ញាមានសតិជាអ្នកនាំ អាចយល់អត្ថបាន ឈ្មោះថា សម្រេចដោយភាពជាកណ្ឌាគារិក ព្រោះអាចរក្សានូវឃ្លាំងធម៌ ដែលសម្បូរដោយអត្ថនិងព្យញ្ជនៈ ព្រោះប្រកបដោយអំណាចទាំង ២ យ៉ាងនោះ ។

ម្យ៉ាងទៀត ដោយពាក្យថា **ឯវំ** ព្រះអានន្ទសម្តែងការដាក់ចិត្តដោយឧបាយ ព្រោះកាលដាក់ចិត្តមិនមែនដោយឧបាយ ក៏មិនយល់ដោយប្រការផ្សេងៗ បានឡើយ ដោយពាក្យថា **សុតំ** ព្រះអានន្ទសម្តែងដល់ការមិនរាយមាយ បុគ្គលនោះនឹងពោលដោយត្រឹមត្រូវគ្រប់យ៉ាង ពោលថា ខ្ញុំមិនបានឮសូមលោកពោលទៀត ដោយអាការដាក់ចិត្តដោយឧបាយ ក្នុងសេចក្តីនេះរមែងឲ្យសម្រេចអត្តសម្មាបណិធិ ការតាំងខ្លួនដោយប្រពៃ និងបុព្វេកតបុញ្ញតា គឺភាពជាអ្នកមានបុណ្យបានធ្វើមកក្នុងកាលមុន ព្រោះបុគ្គលដែលមិនតម្កល់ខ្លួនដោយប្រពៃ និងមិនធ្វើបុណ្យមកក្នុងកាលមុន ក៏ទៅជាដទៃ គឺមិនមានយោនិសោមនសិការ ដោយការមិនរាយមាយ ក៏ឲ្យសម្រេចសទ្ធម្ម-

សវនៈ ការស្តាប់ព្រះសទ្ធម្ម និងសប្បុរិសូបសំសយៈ គឺការចូលទៅសេព គប់សប្បុរស ព្រោះបុគ្គលដែលមានចិត្តរាយមាយ មិនអាចស្តាប់ និងកាល មិនចូលទៅរកសប្បុរស ការស្តាប់ក៏មិនមានដែរ ។

ម្យ៉ាងទៀត ព្រោះហេតុដូចពោលហើយ សព្វថា **ឯវំ** សម្តែងអាការ ផ្សេងៗ របស់ចិត្តសន្តានដែលកាន់យកអត្ថ និងព្យញ្ជនៈផ្សេងៗ ព្រោះចិត្ត សន្តានប្រព្រឹត្តទៅផ្សេងៗ គ្នា ចិត្តសន្តាននោះ គឺអាការស្អាតយ៉ាងនេះ រមែង មិនមានដល់បុគ្គលដែលមិនតម្កល់ខ្លួនដោយប្រពៃ ឬដល់បុគ្គលមិនបានធ្វើ បុណ្យក្នុងកាលមុន ដូច្នោះ ដោយពាក្យថា **ឯវំ** នេះ ព្រះអានន្ទសម្តែង សម្បត្តិ គឺចក្កធម៌ ២ ខាងក្រោយរបស់ខ្លួនដោយអាការស្អាត សម្តែង សម្បត្តិ គឺចក្កធម៌ ២ ខាងដើម ដែលប្រកបដោយការស្តាប់ ដោយបទថា **សុតំ** ព្រោះបុគ្គលនៅក្នុងប្រទេសដែលមិនសមគួរ និងវៀរចាកការចូលទៅ គប់រកសប្បុរស ការស្តាប់ក៏មិនមាន ដូច្នោះ ទើបព្រះអានន្ទនោះសម្រេច អាសយសុទ្ធិ ការបរិសុទ្ធិនៃអាសយៈ ព្រោះការសម្រេចនៃចក្កធម៌ ២ ខាង ក្រោយ សម្រេចបយោគសុទ្ធិ ព្រោះការសម្រេចនៃចក្កធម៌ ២ ខាងដើម ហើយព្រះអានន្ទសម្រេចការជំនាញក្នុងអាគម គឺនិកាយទាំង ៥ ក៏ព្រោះ អាសយសុទ្ធិ ការបរិសុទ្ធិនៃអាសយៈនោះ ។ សម្រេចការជំនាញក្នុងអធិគម គឺមគ្គផល ក៏ព្រោះបយោគសុទ្ធិ គឺការបរិសុទ្ធិនៃបយោគ ដូច្នោះ ពាក្យរបស់ ព្រះអានន្ទដែលបរិសុទ្ធដោយបយោគ គឺការប្រកប និងអាសយៈ គឺអធ្យា- ស្រ័យបុគ្គលដល់ព្រមដោយអាគម និងអធិគម ទើបគួរជាខាងដើម គឺជាអ្នក

នាំនៃព្រះតម្រាស់របស់ព្រះមានព្រះភាគ ដូចអរុណជាបុព្វភាគនៃការរះឡើងរបស់ព្រះអាទិត្យ និងដូចយោនិសោមនសិការ ជាបុព្វភាគនៃកុសលកម្មដូច្នោះ ព្រោះដូច្នោះ ទើបព្រះអានន្ទ កាលតាំងនិទានវចនៈ ផ្ដើមពាក្យក្នុងស្ថានដែលគួរ ទើបពោលពាក្យជាដើមថា **ឯវម្មេ សុតំ** ដូច្នេះ ។

ន័យម្យ៉ាងទៀត ព្រះអានន្ទសម្ដែងភាវៈនៃសម្បត្តិ គឺអត្ថប្បដិសម្ភិទា និងបដិភាណប្បដិសម្ភិទារបស់ខ្លួន ដោយពាក្យដែលសម្ដែងដល់ការដឹងច្បាស់ ដោយប្រការផ្សេង ដោយពាក្យថា **ឯវំ** នេះ ។ សម្ដែងសភាវៈនៃសម្បត្តិ គឺធម្មប្បដិសម្ភិទា និងនិរុត្តិប្បដិសម្ភិទា ដោយពាក្យដែលសម្ដែងសេចក្ដីដល់ការដឹងច្បាស់ប្រភេទនៃធម៌ដែលគួរស្ដាប់ ដោយពាក្យថា **សុតំ** នេះ ។ កាលព្រះថេរៈពោលដល់ពាក្យដែលសម្ដែងយោនិសោមនសិការនេះថា **ឯវំ** រមែងសម្ដែងថា ធម៌ទាំងនេះ អាត្មាអញសម្លឹងពិនិត្យហើយដោយចិត្តសម្រឹតសម្រាំងល្អហើយដោយទិដ្ឋិ កាលព្រះថេរៈពោលដល់ពាក្យសម្ដែងការប្រកបរឿយៗ នូវការស្ដាប់នេះថា **សុតំ** រមែងសម្ដែងថា ធម៌ជាច្រើនអាត្មាអញស្ដាប់ហើយ ចាំទុកហើយ រត់មាត់ហើយ ដោយពាក្យទាំង ២ នោះកាលព្រះថេរៈសម្ដែងភាពបរិបូណ៌នៃអត្ថ និងព្យញ្ជនៈ ទើបធ្វើឲ្យកើតសេចក្ដីអើពើក្នុងការស្ដាប់ ។ ពិតហើយ កាលបុគ្គលមិនស្ដាប់ធម៌ ដែលបរិបូណ៌ដោយអត្ថ និងព្យញ្ជនៈ ដោយការអើពើ រមែងឆ្ងាយចាកប្រយោជន៍ជាច្រើន ព្រោះដូច្នោះ គួរធ្វើការអើពើឲ្យកើត ហើយស្ដាប់ធម៌ដោយគោរពចុះ ។

ម្យ៉ាងទៀត ដោយពាក្យទាំងអស់ថា **ឯវម្មេ សុតំ** នេះ កាលព្រះអានន្ទ

មិនតាំងធម៌ដែលព្រះតថាគតបានប្រកាសហើយ ទុកក្នុងខ្លួន ឈ្មោះថា ឈាន កន្លងភូមិអសប្បុរស កាលបេ្តជ្ញាភាពជាសាវក ឈ្មោះថា ឈមចុះកាន់ភូមិសប្បុរស ។ ម្យ៉ាងទៀត ធ្វើចិត្តឲ្យចេញចាកអសទ្ធម្ម ឈ្មោះថា តាំងចិត្តក្នុងសទ្ធម្ម ។ កាលសម្តែងថា អាស្រ័យព្រះតម្រាស់របស់ព្រះជិនស្រី ឈ្មោះថា តាំងនៅក្នុងធម្មនេតិ ។

ម្យ៉ាងទៀត កាលព្រះអានន្ទមិនបេ្តជ្ញាថា ធម៌នោះ ខ្លួនធ្វើឲ្យកើតឡើង ទើបលម្អិតពាក្យខាងដើមថា **ឯវម្មេ សុតំ** កម្ចាត់នូវការមិនមានសទ្ធា ធ្វើសទ្ធាសម្បត្តិឲ្យកើតឡើងក្នុងធម៌នេះដល់ទេវតា និងមនុស្សគ្រប់ពួកថា ព្រះតម្រាស់នេះ ខ្ញុំទទួលហើយ ក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគអង្គនោះ ដែលជាអ្នកអង់អាចក្នុងវេសារជ្ជញ្ញាណ ៤ ដែលទ្រទ្រង់នូវពលញ្ញាណ តាំងនៅក្នុងឋានៈដ៏ប្រសើរ បន្លឺសីហនាទ ជាបុគ្គលឧត្តមបំផុតជាងសត្វទាំងពួង ជាធម្មិស្សរៈ ជាធម្មរាជា ជាធម្មាធិបតី ជាធម្មទីប ជាធម្មសរណៈ ជាអ្នកបង្វិលចក្រ គឺព្រះសទ្ធម្មដ៏ប្រសើរ ជាអ្នកត្រាស់ដឹងឯងដោយប្រពៃ ទើបមិនគួរធ្វើសេចក្តីសង្ស័យ ឬការងឿងឆ្ងល់ក្នុងអត្ថ ធម៌ បទ ឬព្យញ្ជនៈក្នុងពាក្យនេះឡើយ ព្រោះហេតុនោះ ទើបលោកពោលពាក្យនេះថា

**វិនាសយតិ អស្សទ្ធំ សទ្ធំ វឌ្ឍេតិ សាសនេ**
**ឯវម្មេ សុតមិច្ចេវំ វទំ គោតមសាវកោ ។**

សាវករបស់ព្រះគោតម កាលពោលយ៉ាងនេះថា **ឯវម្មេ សុតំ** ឈ្មោះថា ធ្វើការមិនមានសទ្ធាឲ្យវិនាស ធ្វើសទ្ធាក្នុងព្រះសាសនាឲ្យចម្រើន ។

សព្ទថា **ឯកំ** សម្តែងការកំណត់ចំនួន ។ សព្ទថា **សមយំ** សម្តែងកាលដែលកំណត់ហើយ ។ ពាក្យថា **ឯកំ សមយំ** ជាពាក្យសម្តែងកាលមិនពិតប្រាកដ ។ **សមយ** សព្ទ ក្នុងពាក្យថា **ឯកំ សមយំ** នោះ ប្រើក្នុង **សមវាយ** គឺការព្រមព្រៀង ១ ខណៈ ១ កាល ១ សមុហៈ គឺប្រជុំ ១ ហេតុ ១ ទិដ្ឋិ គឺការយល់ឃើញ ១ បដិលាភ គឺការបានចំពោះ ១ បហាន គឺការលះ ១ បដិវេធ គឺការចាក់ធ្លុះ ១ ។

ពិតហើយ **សមយ** សព្ទ មានអត្ថថា **សមវាយ** គឺការព្រមព្រៀង ដូចក្នុងប្រយោគជាដើមថា **អប្បេវ នាម ស្វេបិ ឧបសង្កមេយ្យាម កាលញ្ច សមយញ្ច ឧបាទាយ** បើដូច្នោះ ចាំយើងពិចារណានូវកាល និងសម័យសិនហើយ សឹមទៅក្នុងថ្ងៃស្អែក ។

មកក្នុងអត្ថថា **ខណៈ** ដូចក្នុងពាក្យជាដើមថា **អយំ ភិក្ខវេ ឯកោវ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ** ម្នាលភិក្ខុទាំងឡាយ នេះជាខណៈ និងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ដូច្នេះ ។

មកក្នុងអត្ថថា **កាល** ដូចក្នុងប្រយោគជាដើមថា **ឧណ្ហសមយោ បរិឡាហសមយោ** សម័យក្តៅ សម័យស្អុះស្អាប់ ដូច្នេះ ។

មកក្នុងអត្ថថា **សមូហ** គឺប្រជុំ ដូចក្នុងប្រយោគជាដើមថា **មហា-សមយោ បវនស្មឹ** ថ្ងៃនេះជាថ្ងៃប្រជុំធំ ក្នុងដងព្រៃធំ ។ មកក្នុងអត្ថថា ហេតុ ដូចក្នុងប្រយោគជាដើមថា **សមយោបិ ខោ តេ ភទ្ទាលិ ។បេ។ សមយោ អប្បដិវិទ្ធោ អហោសិ ។** ម្នាលភទ្ទាលិ អ្នកមិនបានដឹងហេតុថា ព្រះមាន

ព្រះភាគគង់នៅក្នុងក្រុងសាវត្ថី តែព្រះមានព្រះភាគ គង់ជ្រាបអាត្មាអញថា ភិក្ខុឈ្មោះកទូលិ មិនបានបំពេញសិក្ខា ក្នុងសាសនារបស់ព្រះសាស្តាដូច្នេះឡើយ ម្នាលកទូលិ នេះឯងជាហេតុ ដែលអ្នកមិនបានដឹង ។

មកក្នុងអត្ថថា **លទ្ធិ** ( ទិដ្ឋិ ) ដូចក្នុងប្រយោគជាដើមថា **តេន ខោ បន សមយេន ឧគ្គាហមានោ បរិព្វាជកោ សមណមុណ្ឌិកាបុត្តោ សមយប្បវាទកេ តិណ្ឌុកាចីរេ ឯកសាលកេ មល្លិកាយ អារាមេ បដិ-វសតិ** សម័យនោះឯង បរិព្វាជកឈ្មោះឧគ្គាហមានះ ជាសមណមុណ្ឌិកាបុត្រ អាស្រ័យនៅក្នុងអារាមរបស់ព្រះនាងមល្លិកាទេវី ដែលមានសាលាមួយ មានជួរដើមទន្លាប់ព័ទ្ធជុំវិញ ជាទីសម្រាប់ប្រឹក្សានូវទិដ្ឋិ ( លទ្ធិ ) ។

មកក្នុងអត្ថថា បានចំពោះ ដូចក្នុងប្រយោគជាដើមថា

**ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ចត្ថោ សម្បរាយិកោ**
**អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ។**

បណ្ឌិត ជាអ្នកមិនប្រមាទ តែងបានចំពោះប្រយោជន៍ទាំងពីរ គឺប្រយោជន៍ណា ក្នុងបច្ចុប្បន្នក្តី ប្រយោជន៍ណាដែលមានក្នុងបរលោកក្តី ធីរជន ឈ្មោះថា បណ្ឌិត ព្រោះការបានចំពោះនូវប្រយោជន៍ទាំងពីរនោះ ។

មកក្នុងអត្ថថា **បហាន** គឺការលះ ដូចក្នុងប្រយោគជាដើមថា **សម្មា មានាភិសមយាអន្តមកាសិ ទុក្ខស្ស** ធ្វើនូវទីបំផុតកងទុក្ខ ដោយហេតុដែលបានលះបង់នូវមានះចោលដោយប្រពៃ ។

មកក្នុងអត្ថថា **បដិវេធ** គឺការបោកជ្រុះ ដូចក្នុងប្រយោគជាដើមថា **ទុក្ខស្ស បីឡនដ្ឋោ សង្ខតដ្ឋោ សន្តាបដ្ឋោ វិបរិណាមដ្ឋោ អភិសមយដ្ឋោ** ទុក្ខមានអត្ថថា បៀតបៀន មានបច្ច័យតាក់តែង ធ្វើឲ្យក្តៅក្រហាយ ប្រែប្រួល និងគួរបោកជ្រុះ ។

តែក្នុងទីនេះ **សមយ** សព្ទនោះ មានអត្ថថា **កាល** ។

ដោយពាក្យនោះ ព្រះថេរៈសម្តែងថា សម័យមួយ ក្នុងបណ្តាសម័យទាំងឡាយ ដែលជាប្រភេទនៃកាល មានឆ្នាំ រដូវ ខែ កន្លះខែ ពេលយប់ ពេលថ្ងៃ ព្រឹក ថ្ងៃត្រង់ ល្ងាច បឋមយាម មជ្ឈិមយាម បច្ឆិមយាម និងខណៈ ។

ក្នុងពាក្យថា **ឯកំ សមយំ** នោះ បណ្តាសម័យ មានឆ្នាំជាដើមនោះ ព្រះសូត្រណាទីមួយ ព្រះមានព្រះភាគត្រាស់ក្នុងឆ្នាំ រដូវ ខែ បក្ខ ចំណែកនៃរាត្រី ចំណែកថ្ងៃ ណាមួយ ទាំងអស់នោះ ព្រះថេរៈដឹងល្អហើយ កំណត់ល្អហើយ ដោយបញ្ញាដោយពិត តែកាលព្រះថេរៈពោលយ៉ាងនេះថា ខ្ញុំបានស្តាប់មកហើយយ៉ាងនេះថា ក្នុងឆ្នាំឈ្មោះនោះ រដូវឈ្មោះនោះ ខែឈ្មោះនោះ បក្ខនោះ កាលដែលជាចំណែកនៃរាត្រីនោះ ចំណែកនៃថ្ងៃនោះ បុគ្គលណាម្នាក់ ក៏មិនអាចចាំបាន ឬសម្តែងបាន ឬឲ្យអ្នកដទៃសម្តែងបានដោយងាយ នឹងជារឿងដែលត្រូវពោលច្រើន ដូច្នោះ ទើបប្រមូលអត្ថនោះ ដោយបទមួយប៉ុណ្ណោះ ហើយពោលថា **ឯកំ សមយំ** ដូច្នេះ ។

មួយវិញទៀត ព្រះអានន្ទរមែងសម្តែងថា សម័យរបស់ព្រះមានព្រះភាគ

ជាប្រភេទនៃកាលមិនមែនតិចនោះឯង ដែលប្រាកដច្រើន ក្នុងពួកទេវតា និងមនុស្សទាំងឡាយ មានជាដើមយ៉ាងនេះ គឺសម័យដែលទ្រង់ឈានចុះកាន់ព្រះគភ៌ សម័យប្រសូត សម័យទ្រង់សង្វេគ សម័យចេញបួស សម័យបំពេញទុក្ករកិរិយា សម័យឈ្នះមារ សម័យត្រាស់ដឹង សម័យប្រថាប់ជាសុខក្នុងទិដ្ឋធម៌ សម័យត្រាស់ទេសនា សម័យស្ដេចបរិនិព្វានទាំងនេះ ក្នុងបណ្ដាសម័យទាំងនោះ សម័យមួយ ( ក្នុងទីនេះ ) គឺសម័យត្រាស់ទេសនា ។

ម្យ៉ាងទៀត ក្នុងបណ្ដាសម័យនៃញាណកិច្ច និងករុណាកិច្ច សម័យនៃករុណាកិច្ចនេះឯង ក្នុងបណ្ដាសម័យទ្រង់បំពេញប្រយោជន៍ ព្រះអង្គនឹងបំពេញប្រយោជន៍ដល់អ្នកដទៃ សម័យទ្រង់បំពេញប្រយោជន៍ដល់អ្នកដទៃនេះឯង ក្នុងបណ្ដាសម័យនៃករណីទាំងឡាយដល់អ្នកប្រជុំគ្នា សម័យត្រាស់ធម្មីកថានេះឯង ក្នុងបណ្ដាសម័យនៃទេសនា និងបដិបត្តិ សម័យនៃទេសនានេះឯង ព្រះអានន្ទពោលថា សម័យមួយ ដូច្នេះ សំដៅដល់សម័យណាមួយ ក្នុងបណ្ដាសម័យទាំងឡាយនោះ ។

សួរថា ហេតុអ្វី ទើបក្នុងព្រះសូត្រនេះ លោកធ្វើនិទ្ទេសដោយទុតិយាវិភត្តិថា **ឯកំ សមយំ** ទ្រង់មិនធ្វើដូចក្នុងព្រះអភិធម្ម ដែលទ្រង់បានធ្វើនិទ្ទេសដោយសត្តមីវិភត្តិថា **យស្មឹ សមយេ កាមាវចរំ** និងក្នុងសុត្តបទដទៃៗ ចាកព្រះអភិធម្មនេះ ក៏ធ្វើនិទ្ទេសដោយសត្តមីវិភត្តិថា **យស្មឹ សមយេ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ** ចំណែកក្នុងព្រះវិន័យ លោកធ្វើនិទ្ទេសដោយតតិយាវិភត្តិថា **តេន សមយេន ពុទ្ធោ ភគវា** ។

ឆ្លើយថា ព្រោះក្នុងអភិធម្ម និងព្រះវិន័យនេះ មានអត្ថយ៉ាងនោះ ឯក្នុងព្រះសូត្រនេះ មានអត្ថដទៃ ។ ពិតហើយ បណ្ដាបិដកទាំង ៣ នោះ ក្នុងព្រះអភិធម្ម និងក្នុងសុត្តបទដទៃចាកព្រះអភិធម្មនេះ សម្រេចអត្ថនៃអធិករណៈ និងអត្ថការកំណត់កាវៈដោយកាវៈ ។ អធិករណៈ គឺសម័យដែលមានកាលជាអត្ថ និងមានប្រជុំជាអត្ថ និងកាវៈនៃធម៌ មានផស្សៈជាដើម លោកកំណត់ដោយកាវៈនៃសម័យ ពោល គឺខណៈ ការព្រមព្រៀង និងហេតុនៃធម៌ មានផស្សៈជាដើម ដែលត្រាស់ទុកក្នុងព្រះអភិធម្ម និងសុត្តបទដទៃនោះៗ ព្រោះដូច្នោះ ដើម្បីឆ្លុះបញ្ចាំងអត្ថនោះ ទើបលោកធ្វើនិទ្ទេសដោយសត្តមីវិភត្តិក្នុងព្រះអភិធម្ម និងសុត្តបទដទៃនោះ ។ ឯក្នុងព្រះវិន័យ រមែងសម្រេចអត្ថនៃហេតុ និងអត្ថនៃករណៈ ។ ពិតហើយ សម័យនៃការទ្រង់បញ្ញត្តិសិក្ខាបទនោះ សូម្បីសាវក មានព្រះសារីបុត្រជាដើម ក៏ដឹងបានលំបាក ដោយសម័យនោះដែលជាហេតុ និងជាករណៈ ព្រះមានព្រះភាគ កាលទ្រង់បញ្ញត្តិសិក្ខាបទទាំងឡាយ និងទ្រង់ពិចារណាដល់ហេតុនៃការបញ្ញត្តិសិក្ខាបទ បានប្រថាប់នៅក្នុងទីនោះៗ ព្រោះដូច្នោះ ដើម្បីឆ្លុះបញ្ចាំងអត្ថនោះ ទើបលោកធ្វើនិទ្ទេសដោយតតិយាវិភត្តិ ក្នុងព្រះវិន័យនោះ ។ ឯក្នុងព្រះសូត្រនេះ និងព្រះសូត្រដទៃ ក៏មានកំណើតយ៉ាងនេះ រមែងសម្រេចអត្ថនៃអច្ចន្តសំយុត្ត ពិតហើយ ព្រះមានព្រះភាគ ទ្រង់សម្ដែងសូត្រនេះ ឬសូត្រដទៃអស់សម័យណា ទ្រង់ប្រថាប់នៅដោយវិហារធម៌ គឺករុណាអស់សម័យនោះឯង ។ ព្រោះដូច្នោះ ដើម្បីឆ្លុះបញ្ចាំងសេចក្ដីនោះ ទើបទ្រង់ធ្វើនិទ្ទេស

ដោយទុតិយាវិភត្តិក្នុងព្រះសូត្រនេះ ព្រោះហេតុនោះ ទើបលោកពោលគាថាពន្ធដូច្នេះថា

លោកពិចារណាអត្ថនោះៗ ពោល **សមយ** សព្ទ ក្នុងបិដក ដទៃ ដោយសត្តមីវិភត្តិ និងតតិយាវិភត្តិ តែក្នុងសុត្តន្តបិដក នេះ ពោល **សមយ** សព្ទ នោះ ដោយទុតិយាវិភត្តិ ។

បុរាណាចារ្យទាំងឡាយបានពណ៌នាថា នេះផ្សេងគ្នាត្រឹមតែវោហារថា **តស្មឹ សមយេ** ក៏មាន **តេន សមយេន** ក៏មាន **តំ សមយំ** ក៏មាន ក្នុងទីគ្រប់អន្លើ មានអត្ថជាសត្តមីវិភត្តិទាំងអស់ ព្រោះដូច្នោះ ទោះបីលោកពោលថា **ឯកំ សមយំ** ក៏គប្បីជ្រាបអត្ថថា **ឯកស្មឹ សមយេ** ក្នុងសម័យមួយដូច្នេះ ។

បទថា **ភគវា** ជាពាក្យពោលដោយសេចក្តីគោរព ។ ពិតហើយ មនុស្សទាំងឡាយហៅគ្រូក្នុងលោកថា **ភគវា** ។ ព្រះមានព្រះភាគនេះ ជាគ្រូនៃសត្វទាំងពួង ព្រោះជាបុគ្គលប្រសើរវិសេសដោយគុណទាំងពួង ព្រោះដូច្នោះគប្បីជ្រាបទ្រង់ថា **ភគវា** ។ សូម្បីបុរាណាចារ្យទាំងឡាយក៏ពោលថា

ពាក្យថា **ភគវា** ជាពាក្យប្រសើរ ពាក្យថា **ភគវា** ជាពាក្យដ៏ឧត្តម ព្រះមានព្រះភាគនោះ ជាបុគ្គលគួរដល់សេចក្តីគោរពដោយឋានៈជាគ្រូ ព្រោះហេតុនោះ ទើបបណ្ឌិតថ្វាយព្រះនាមថា **ភគវា** ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបអត្ថនៃបទនោះ ដោយពិស្តារ ដោយ

អំណាចនៃគាថានេះថា

ព្រះមានព្រះភាគ ទ្រង់ជាអ្នកមានជោគ ទ្រង់កាច់បំបាក់បង់
នូវកិលេស ទ្រង់ប្រកបដោយភគធម៌ ទ្រង់ចែកធម៌ ទ្រង់
គួរសេពគប់ ទ្រង់ខ្ជាក់ចោលនូវកិលេស ដែលជាគ្រឿង
ទៅកាន់ភពទាំងឡាយបាន ព្រោះហេតុនោះ ទើបទ្រង់
ព្រះនាមថា **ភគវា ។**

អត្ថនោះបានពោលហើយដោយពិស្តារ ក្នុងពុទ្ធានុស្សតិនិទ្ទេស ក្នុងគម្ពីរវិសុទ្ធិមគ្គនោះឯង ។

ដោយបទមានប្រមាណប៉ុណ្ណេះ ព្រះថេរៈកាលសម្តែងធម៌តាមដែលស្តាប់មក ទើបធ្វើព្រះសរីរៈ គឺព្រះធម៌របស់ព្រះមានព្រះភាគឲ្យប្រចក្សដោយបទថា **ឯវម្មេ សុតំ** ក្នុងសូត្រនេះ ។ ដោយពាក្យនោះ ព្រះថេរៈឈ្មោះថា លួងលោមដល់បុគ្គលដែលសង្វេគ ព្រោះមិនបានឃើញព្រះសាស្តាថា បាវចនា គឺធម៌ និងវិន័យ ឈ្មោះថា មានសាស្តាបរិនិព្វានទៅហើយក៏មិនមែន ព្រះធម៌វិន័យនេះជាសាស្តារបស់អ្នកទាំងឡាយ ។ ដោយពាក្យថា **ឯកំ សមយំ ភគវា** ព្រះថេរៈកាលសម្តែងថា ព្រះមានព្រះភាគមិនមាននៅក្នុងសម័យនោះ ឈ្មោះថា លើកការបរិនិព្វានតាមរូបកាយឲ្យឃើញដោយពាក្យនោះ ទើបព្រះថេរៈធ្វើនូវការស្រើវឹង ព្រោះការស្រវឹងក្នុងជីវិតឲ្យកើតសេចក្តីសង្វេគ និងធ្វើឲ្យមនុស្សនោះកើតសេចក្តីឧស្សាហ៍ក្នុងព្រះសទ្ធម្មថា ព្រះមានព្រះភាគអង្គនោះ ទ្រទ្រង់នូវទសពលញ្ញាណ មានព្រះវរកាយ

ប្រៀបដូចសរីរៈពេជ្រ ទ្រង់សម្តែងអរិយធម៌យ៉ាងនេះ គង់បរិនិព្វាន បុគ្គលដទៃណាគប្បីឲ្យកើតសេចក្តីសង្ស័យក្នុងជីវិត ព្រះថេរៈកាលពោលថា **ឯវំ** ឈ្មោះថា ចង្អុលទេសនាសម្បត្តិ ។ ពោលថា **មេ សុតំ** ឈ្មោះថា ចង្អុលដល់សាវកសម្បត្តិ ។ ពោលថា **ឯកំ សមយំ** ឈ្មោះថា ចង្អុលដល់កាលសម្បត្តិ ពោលថា **ភគវា** ឈ្មោះថា ចង្អុលដល់ទេសកសម្បត្តិ ( សម្បត្តិ គឺអ្នកសម្តែង ) ។

បទថា **សាវត្ថិយំ** បានដល់ ក្បែរនគរមានឈ្មោះដូច្នេះ ។ បទថា **សាវត្ថិយំ** នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថថា ជិត ។ បទថា **វិហរតិ** នេះ ជាបទសម្តែងការដល់ព្រមនៃការនៅឯណានីមួយ ក្នុងបណ្តាឥរិយាបថវិហារ ទិព្វវិហារ ព្រហ្មវិហារ និងអរិយវិហារ ដោយមិនប្លែកគ្នា ។ តែក្នុងទីនេះ សម្តែងការប្រកបព្រមដោយឥរិយាបថឯណានីមួយ បណ្តាឥរិយាបថ មានឈរ ដើរ អង្គុយ និងដេក ដោយបទថា **វិហរតិ** នោះ ព្រះមានព្រះភាគប្រថាប់ឈរក្តី និមន្តក្តី គង់ក្តី ផ្ទំក្តី បណ្ឌិតគប្បីជ្រាបថា ប្រថាប់ទាំងអស់ ។ ពិតហើយ ព្រះមានព្រះភាគនោះ ទ្រង់កាត់បង់នូវសេចក្តីលំបាកនៃឥរិយាបថមួយ ដោយឥរិយាបថមួយ ទ្រង់នាំទៅ គឺធ្វើអត្តភាពឲ្យប្រព្រឹត្តទៅ មិនឲ្យទ្រុឌទ្រោម ព្រោះហេតុនោះ ទើបព្រះអានន្ទពោលថា **វិហរតិ** គឺប្រថាប់ ។

បទថា **ជេតវនេ** បានដល់ ក្នុងអារាមរបស់ព្រះរាជកុមារឈ្មោះជេតអារាមនោះ ព្រះរាជកុមារព្រះនាមថាជេតនោះ បានដាំដើមឈើឲ្យចម្រើនលូតលាស់ បានរក្សាយ៉ាងល្អ ព្រះអង្គបានជាម្ចាស់របស់ឧទ្យាននោះ ព្រោះដូច្នោះ

ទើបអារាមនោះ ហៅថា **ជេតវន** ។ ក្នុងជេតវននោះ ។

បទថា **អនាថបិណ្ឌិកស្ស អារាមេ** សេចក្ដីថា អារាមដែលរាប់ថា ជារបស់អនាថបិណ្ឌិក ព្រោះអារាមដែលគហបតីឈ្មោះថា អនាថបិណ្ឌិក វេរថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយបរិច្ចាគទ្រព្យជាប្រាក់ ៥៤ កោដិ ក្នុងទីនេះ សេចក្ដីសង្ខេបមានប្រមាណប៉ុណ្ណេះ ។

ឯសេចក្ដីពិស្ដារ បានពោលហើយ ក្នុងអដ្ឋកថាសព្វាសវសំវរសូត្រ អដ្ឋកថាមជ្ឈិមនិកាយ ឈ្មោះបបញ្ចសូទនី ។ ក្នុងសេចក្ដីនោះ បើមានពាក្យសួរជ្រៀតចូលមកថា បើព្រះមានព្រះភាគប្រថាប់នៅត្រង់ក្រុងសាវត្ថីមុន ព្រះថេរៈក៏មិនគួរពោលថា ព្រះវិហារឈ្មោះថាជេតពន បើព្រះអង្គប្រថាប់នៅក្នុងវត្តជេតពននោះ ក៏មិនគួរពោលថា ជិតក្រុងសាវត្ថី ។ ពិតហើយ បុគ្គលណាម្នាក់ មិនអាចនឹងនៅបានក្នុងទី ២ កន្លែង ក្នុងគ្រាតែមួយ ឆ្លើយថា សេចក្ដីនោះ មិនគប្បីឃើញយ៉ាងនោះ យើងខ្ញុំបានពោលហើយមិនមែនឬថា ពាក្យថា **សាវត្ថិយំ** ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថថា ជិត ព្រោះដូច្នោះ ក្នុងទីនេះ ព្រះមានព្រះភាគប្រថាប់នៅក្នុងព្រះវិហារ ឈ្មោះថា ជេតពន ដែលនៅជិតក្រុងសាវត្ថី ព្រះអានន្ទពោលថា ប្រថាប់នៅក្នុងវិហារ ឈ្មោះជេតពន ជិតក្រុងសាវត្ថី ដូចហ្វូងគោត្រាច់រកស៊ីជិតស្ទឹងគង្គា និងស្ទឹងយមុនាជាដើម គេក៏ហៅថា ត្រាច់រកស៊ីជិតស្ទឹងគង្គា ក្បែរស្ទឹងយមុនាដូច្នោះ ពិតហើយ ការពោលដល់ក្រុងសាវត្ថីរបស់ព្រះអានន្ទនោះ ក៏ដើម្បីសម្ដែងគោចរគ្រាម ការពោលដល់ទីដ៏សេស ក៏ដើម្បីសម្ដែងទីអាស្រ័យដែលសមគួរដល់បព្វជិត

ក្នុងពាក្យទាំងនោះ ដោយពាក្យថា **សាវត្ថិយំ** ព្រះអានន្ទសម្ដែងការដែលព្រះមានព្រះភាគទ្រង់ធ្វើការអនុគ្រោះដល់គ្រហស្ថ ។ សម្ដែងការធ្វើអនុគ្រោះដល់បព្វជិត ដោយការប្រារព្ធដល់វត្តជេតពន ។ ម្យ៉ាងទៀត ព្រះថេរៈសម្ដែងការវៀរអត្តកិលមថានុយោគ ព្រោះការទទួលបច្ច័យដោយពាក្យដើម សម្ដែងឧបាយជាគ្រឿងវៀរកាមសុខល្លិកានុយោគ ព្រោះវត្ថុកាមដោយពាក្យក្រោយ ។ ម្យ៉ាងទៀត សម្ដែងការប្រកបព្រះធម្មទេសនា ដោយពាក្យដើម សម្ដែងការបង្អោនទៅដើម្បីវិវេក ដោយពាក្យក្រោយ ។ សម្ដែងការមានករុណា ដោយពាក្យដើម សម្ដែងការមានព្រះបញ្ញាដោយពាក្យក្រោយ សម្ដែងការបង្អោនទៅក្នុងការឲ្យសម្រេចហិតសុខដល់ពួកសត្វ ដោយពាក្យដើម សម្ដែងការមិនជាប់ជំពាក់ក្នុងការធ្វើហិតសុខដល់អ្នកដទៃ ដោយពាក្យក្រោយ សម្ដែងការដែលទ្រង់នៅជាផាសុក ដោយការលះសុខដែលប្រកបដោយធម៌ជានិមិត្ត ដោយពាក្យដើម សម្ដែងការប្រកបរឿយៗ នូវឧត្តរិមនុស្សធម៌ជានិមិត្ត ដោយពាក្យក្រោយ សម្ដែងភាពដែលទ្រង់មានឧបការៈច្រើនដល់មនុស្សទាំងឡាយ ដោយពាក្យដើម សម្ដែងភាពដែលទ្រង់ជាអ្នកមានឧបការៈច្រើនដល់ទេវតាទាំងឡាយ ដោយពាក្យក្រោយ សម្ដែងការដែលទ្រង់កើតឡើងក្នុងលោក ហើយចម្រើនព្រមក្នុងលោក ដោយពាក្យដើម សម្ដែងការដែលទ្រង់មិនចូលទៅជាប់ជំពាក់ក្នុងលោក ដោយពាក្យក្រោយ ។ សម្ដែងទ្រង់ធ្វើប្រយោជន៍ ដែលទ្រង់កើតឡើងឲ្យសម្រេចរៀបរយ ដោយពាក្យដើម ដោយព្រះបាលីថា ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក

ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ បុគ្គលឯក តើជានរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ។ សម្តែងការដែលទ្រង់សមគួរដល់ទីដែលទ្រង់កើតឡើង ដោយពាក្យក្រោយ ។ ពិតហើយ ព្រះមានព្រះភាគទ្រង់កើតក្នុងព្រៃទាំងអស់ ដោយកើតទាំងលោកិយ និងលោកុត្តរ គឺដំបូង ត្រង់លុម្ពិនីវ័ន ទី ២ ត្រង់ពោធិមណ្ឌលដ្ឋាន ព្រោះហេតុនោះ ទើបព្រះថេរៈសម្តែងដល់ទីប្រថាប់របស់ព្រះអង្គ ក្នុងព្រៃទាំងអស់ ។ ក្នុងសូត្រនេះ គប្បីជ្រាបការប្រកបសេចក្តីដោយន័យដូចពោលមកហើយជាដើម ។

បទថា **តត្រ** សម្តែងទេសៈ និងកាលៈ ។ បទថា **តត្រ** នោះ ព្រះថេរៈសម្តែងថា ក្នុងសម័យដែលព្រះមានព្រះភាគប្រថាប់នៅ និងក្នុងអារាមដែលប្រថាប់នៅ ឬសម្តែងទេសៈ និងកាលៈដែលគួរពោលដល់ ។ ពិតហើយ ព្រះមានព្រះភាគមិនត្រាស់ធម៌ក្នុងប្រទេស ឬក្នុងកាលដែលមិនគួរ ។ ពាក្យថា ម្នាលពាហិយៈ នេះជាកាលមិនសមគួរ ជាឧទាហរណ៍ក្នុងរឿងនេះ ។ សព្ទថា **ខោ** ជាអវធារណៈ ប្រើក្នុងអត្ថត្រឹមតែធ្វើបទឲ្យពេញ ឬជានិបាត ប្រើក្នុងអត្ថថា កាលខាងដើម ។ បទថា **ភគវា** សម្តែងភាពដែលទ្រង់ជាគ្រូនៃសត្វលោក ។

បទថា **ភិក្ខូ** ជាពាក្យសម្តែងដល់បុគ្គលដែលគួរស្តាប់ព្រះតម្រាស់ ។ ម្យ៉ាងទៀត ក្នុងបទថា **ភិក្ខូ** នេះ គប្បីជ្រាបអត្ថនៃពាក្យជាដើមថា ឈ្មោះថា

**ភិក្ខុ** ព្រោះជាអ្នកសូម ឬឈ្មោះថា **ភិក្ខុ** ព្រោះចូលដល់ការត្រាច់សូម ។

បទថា **អាមន្តេសិ** ប្រែថា ហៅ គឺពោលជាស់តឿនឲ្យក្រាក់ ។ ក្នុងបទថា **អាមន្តេសិ** នេះ មានអត្ថដូច្នេះ ។ តែក្នុងទីដទៃ ប្រើក្នុងអត្ថថា ឲ្យដឹងក៏មាន ។ ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងប្រាប់អ្នកទាំងឡាយឲ្យដឹង តថាគតជាស់តឿនអ្នកទាំងឡាយ ។ ប្រើក្នុងអត្ថថា ហៅក៏មាន ដូចក្នុងព្រះតម្រាស់ថា ម្នាលភិក្ខុ អ្នកចូរហៅសារីបុត្រមកតាមពាក្យរបស់តថាគត ។

បទថា **ភិក្ខវោ** សម្ដែងអាការហៅ ។ បទនោះ ត្រាស់ព្រោះសម្រេចដោយការប្រកបដោយគុណ គឺភាពជាអ្នកសូមដោយប្រក្រតី ។ អ្នកចេះសទ្ទសាស្ត្រមែងសម្គាល់ថា ភិក្ខុដែលប្រកបដោយគុណ គឺភាពជាអ្នកសូមជាប្រក្រតីក៏មាន ប្រកបដោយគុណ គឺភាពជាអ្នកសូមជាធម្មតាក៏មាន ប្រកបដោយគុណ គឺភាពជាអ្នកមានប្រក្រតីធ្វើល្អក្នុងការសូមក៏មាន ។ ព្រះមានព្រះភាគ ទ្រង់នឹងប្រកាសការប្រព្រឹត្តិដែលបុគ្គលអាក្រក់ និងបុគ្គលល្អសេពហើយ ទើបទ្រង់ធ្វើការសង្កត់សង្កិនបុគ្គលដែលប្រដៅក្រ ដោយព្រះតម្រាស់នោះ ដែលសម្រេចដោយការប្រកបដោយគុណ មានភាពជាអ្នកសូមជាប្រក្រតីជាដើមរបស់ភិក្ខុទាំងនោះ ព្រះមានព្រះភាគទ្រង់ធ្វើភិក្ខុទាំងនោះឲ្យបែរមុខត្រង់ព្រះភក្ត្រព្រះអង្គ ដោយព្រះតម្រាស់ដែលទ្រង់ទតព្រះនយនាចុះដោយព្រះហឫទ័យផូរផង់ ផ្សាយទៅដោយព្រះករុណាជាខាងមុខ **ភិក្ខវោ** នេះ ទ្រង់ធ្វើឲ្យភិក្ខុទាំងនោះកើតការចង់ស្ដាប់ដោយព្រះតម្រាស់ ដែលសម្ដែង

ពុទ្ធបំណាងនឹងត្រាស់នោះឯង ហើយទ្រង់ដឹកនាំភិក្ខុទាំងនោះ ក្នុងការដាក់ចិត្ត ស្តាប់ដោយល្អ ដោយព្រះតម្រាស់នោះ ដែលមានអត្ថថា ដាស់ឲ្យភ្ញាក់នោះឯង ។ ពិតហើយ ព្រះសាសនានឹងបរិបូណ៌បាន ក៏ព្រោះការដាក់ចិត្តក្នុងការស្តាប់ដោយល្អ ។

បើមានពាក្យសួរថា កាលទេវតា និងមនុស្សដទៃមាន ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគត្រាស់ហៅចំពោះភិក្ខុប៉ុណ្ណោះ ឆ្លើយថា ព្រោះភិក្ខុទាំងនោះ ជាអ្នកចម្រើនបំផុត ប្រសើរបំផុត នៅជិត និងជាអ្នកនៅប្រចាំ ។ ពិតហើយ ព្រះធម្មទេសនារបស់ព្រះមានព្រះភាគ រមែងទូទៅដល់មនុស្សទាំងពួង ។ តែភិក្ខុទាំងឡាយឈ្មោះថា ជាអ្នកចម្រើនបំផុតនៃបរិស័ទ ព្រោះជាអ្នកកើតមុន ។ និងឈ្មោះថា ជាអ្នកប្រសើរបំផុត ព្រោះជាអ្នកដើរតាមចរិយារបស់ព្រះសាស្តា តាំងអំពីភាពជាអ្នកមិនគ្រប់គ្រងផ្ទះ និងព្រោះជាអ្នកទទួលព្រះសាសនាទាំងមូល ឈ្មោះថា ជាអ្នកជិតស្និទ្ធ ព្រោះកាលលោកអង្គុយក្នុងទីនោះៗ ក៏ជិតព្រះសាស្តាទាំងអស់ ឈ្មោះថា នៅប្រចាំ ក៏ព្រោះនៅតែក្នុងសម្នាក់ព្រះសាស្តា ។ ម្យ៉ាងទៀត ភិក្ខុទាំងនោះ ឈ្មោះថា ជាភាជនៈទ្រទ្រង់ព្រះធម្មទេសនា ព្រោះកើតដោយកិច្ចបដិបត្តិតាមដែលទ្រង់ប្រៀនប្រដៅ ព្រោះហេតុនោះ ទើបទ្រង់ត្រាស់ហៅភិក្ខុទាំងនោះ ដោយប្រការដូច្នេះ ។

សួរថា ដើម្បីប្រយោជន៍អ្វី កាលព្រះមានព្រះភាគទ្រង់សម្តែងធម៌ ទើបត្រាស់ហៅភិក្ខុជាមុន ម្តេចក៏ទ្រង់មិនសម្តែងធម៌តែម្តងទៅ ឆ្លើយថា ដើម្បីឲ្យកើតស្មារតី ។ សេចក្តីពិត ភិក្ខុទាំងឡាយគិតរឿងដទៃក៏មាន មានចិត្ត

រាយមាយក៏មាន ពិចារណាធម៌ក៏មាន អន្តរាយមនសិការកម្មដ្ឋានក៏មាន ភិក្ខុទាំងនោះ កាលមិនត្រាស់ហៅឲ្យដឹងខ្លួន ទ្រង់សម្តែងធម៌តែម្តង មិនអាចកំណត់បានថា ទេសនានេះ មានអ្វីជាហេតុ មានអ្វីជាបច្ច័យ ទ្រង់សម្តែងព្រោះអត្ថប្បហេតុដូចម្តេច គប្បីទទួលយកបានលំបាក ឬមិនទទួលយកឡើយ ។ ដើម្បីឲ្យភិក្ខុទាំងនោះកើតស្មារតីដោយព្រះតម្រាស់នោះ ទើបព្រះមានព្រះភាគត្រាស់ហៅជាមុន ហើយទ្រង់សម្តែងធម៌ឯក្រោយ ។

បទថា **ភទន្តេ** នេះ ជាពាក្យសម្តែងគោរព ឬជាការឆ្លើយតបដល់ព្រះសាស្តា ។ ម្យ៉ាងទៀត ក្នុងទីនេះ ព្រះមានព្រះភាគកាលត្រាស់ថា **ភិក្ខវោ** ឈ្មោះថា ហៅភិក្ខុទាំងនោះ ។ ភិក្ខុទាំងឡាយកាលត្រូវទូលថា **ភទន្តេ** ឈ្មោះថា ទូលស្នងព្រះតម្រាស់ព្រះមានព្រះភាគក្នុងកាលខាងក្រោយ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់ហៅថា **ភិក្ខវោ** ភិក្ខុទាំងឡាយក្រាបទូលក្នុងកាលជាខាងក្រោយថា **ភទន្តេ** ។ ព្រះមានព្រះភាគហៅឲ្យភិក្ខុឆ្លើយ ដោយព្រះតម្រាស់ថា **ភិក្ខវោ** ភិក្ខុទូលស្នងថា **ភទន្តេ** ។

បទថា **តេ ភិក្ខូ** បានដល់ ពួកភិក្ខុដែលព្រះមានព្រះភាគត្រាស់ហៅ ។ បទថា **ភគវតោ បច្ចស្សោសុំ** សេចក្តីថា ភិក្ខុទាំងឡាយបានស្តាប់ចំពោះព្រះតម្រាស់ត្រាស់ហៅរបស់ព្រះមានព្រះភាគ អធិប្បាយថា បែរមុខមកស្តាប់ គឺទទួល បានដល់ ផ្គងទទួល ។ បទថា **ភគវា ឯតទវោច** សេចក្តីថា ព្រះមានព្រះភាគបានត្រាស់ពាក្យនោះ គឺព្រះសូត្រទាំងអស់ដែលគប្បីពោលក្នុងឥឡូវនេះ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ ពាក្យផ្តើមឯណាដែលប្រកបដោយកាល អ្នកសម្តែង ទេសៈ បរិស័ទ និងប្រទេស ព្រះអានន្ទពោលហើយ ដើម្បីកំណត់យកសូត្រនេះបានដោយស្រួល ។ ពណ៌នាអត្ថនៃពាក្យផ្តើមនោះចប់បរិបូណ៌ហើយ ដូច្នេះ ។

[ ២ ] ឥឡូវនេះ មកដល់ឱកាសពណ៌នាព្រះសូត្រ ដែលព្រះមានព្រះភាគទ្រង់តាំងទុក ដោយន័យជាដើមថា **នាហំ ភិក្ខវេ អញ្ញំ ឯករូបំបិ សមនុបស្សាមិ** ដូច្នេះហើយ ។

ពណ៌នាសេចក្តីនេះ ព្រោះហេតុដែលកំពុងពោលវិចារណៈ ហេតុតាំងនៃព្រះសូត្រប្រាកដ ដូច្នោះ បណ្ឌិតគប្បីជ្រាបការពោលហេតុកើតនៃព្រះសូត្រមុន ។

ពិតហើយ ហេតុកើតនៃព្រះសូត្រ មាន ៤ យ៉ាង គឺកើតព្រោះអាស្រ័យអធ្យាស្រ័យរបស់ខ្លួន ១ កើតព្រោះអធ្យាស្រ័យរបស់អ្នកដទៃ ១ កើតដោយអំណាចពាក្យសួរ ១ កើតព្រោះអត្ថុប្បត្តិហេតុ ១ ។ ក្នុងហេតុ ៤ យ៉ាងនោះ ព្រះសូត្រទាំងឡាយណា ព្រះមានព្រះភាគ ដែលអ្នកដទៃមិនបានអារាធនា ត្រាស់ដោយព្រះអធ្យាស្រ័យរបស់ព្រះអង្គតែម្យ៉ាង ដូចជាអាកង្ខេយ្យសូត្រ វត្ថសូត្រជាដើម សូត្រទាំងនោះ ឈ្មោះថា មានហេតុកើតអំពីអធ្យាស្រ័យរបស់ព្រះអង្គ ។

ម្យ៉ាងទៀត សូត្រទាំងឡាយណា ដែលព្រះអង្គទ្រង់ប្រមើលមើលអធ្យាស្រ័យ ការគាប់ចិត្ត បុណ្យចាស់ និងការត្រាស់ដឹង ហើយត្រាស់

ដោយអធ្យាស្រ័យរបស់អ្នកដទៃយ៉ាងនេះថា ធម៌ជាគ្រឿងអប់រំបន្ទុំវិមុត្តិរបស់រាហុលចាស់ក្លាហើយ បើដូច្នោះ តថាគតគប្បីទូន្មានក្នុងធម៌ដែលជាទីអស់អាសវៈក្រៃលែងឡើងៗ ទៅ ដល់រាហុល ដូចជារាហុលោវាទសូត្រ ធម្មចក្កប្បវត្តនសូត្រជាដើម សូត្រទាំងនោះ ឈ្មោះថា មានហេតុកើតអំពីអធ្យាស្រ័យរបស់អ្នកដទៃ ។

ទេវតា និងមនុស្សទាំងនោះ ចូលទៅគាល់ព្រះមានព្រះភាគ ហើយសួរប្រស្នាដោយប្រការផ្សេងៗ ព្រះមានព្រះភាគត្រូវទេវតា និងមនុស្សទាំងនោះទូលសួរហើយ ត្រាស់សូត្រណា មានទេវតាសំយុត្ត និងពោជ្ឈង្គសំយុត្តជាដើម សូត្រទាំងនោះ ឈ្មោះថា មានហេតុកើតដោយអំណាចពាក្យសួរ ។

មួយវិញទៀត សូត្រទាំងឡាយណា ព្រះមានព្រះភាគត្រាស់ព្រោះអាស្រ័យហេតុកើតឡើង ដូចជាធម្មទាយាទសូត្រ និងបុត្តមំសូបមសូត្រជាដើម សូត្រទាំងនោះ ឈ្មោះថា មានហេតុកើត ដោយការកើតឡើងនៃរឿងរ៉ាវ ។

ក្នុងហេតុកើតសូត្រទាំង ៤ នេះ សូត្រនេះ ឈ្មោះថា មានហេតុកើតអំពីអធ្យាស្រ័យរបស់អ្នកដទៃយ៉ាងនេះ ។ មួយវិញទៀត សូត្រនេះកើតឡើងដោយអំណាចអធ្យាស្រ័យរបស់អ្នកដទៃ ។ សួរថា អធ្យាស្រ័យរបស់បុគ្គលណា ឆ្លើយថា របស់បុរសដែលធ្ងន់ក្នុងរូប ។

ក្នុងបទទាំងនោះ **ន** អក្ខរៈ ក្នុងបទថា **នាហំ ភិក្ខវេ** ជាដើម មាន

បដិសេធជាអត្ត ដោយបទថា **អហំ** សម្តែងអាងដល់ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ហៅភិក្ខុទាំងនោះថា **ភិក្ខវេ** ។ បទថា **អញ្ញំ** សេចក្តីថា នូវរូបដទៃអំពីរូបស្រី ដែលគប្បីពោលក្នុងកាលឥឡូវនេះ ។

បទថា **ឯករូបំបិ** ប្រែថា រូបឯណានីមួយ ។ បទថា **សមនុបស្សាមិ** សេចក្តីថា សមនុបស្សនា ២ យ៉ាង គឺញាណសមនុបស្សនា ១ ទិដ្ឋិសមនុបស្សនា ១ ។ ក្នុង ២ យ៉ាងនោះ អនុបស្សនា មានបទថា ភិក្ខុឃើញថាជារបស់មិនទៀង មិនមែនឃើញដោយជារបស់ទៀងឡើយ នេះឈ្មោះថា ញាណសមនុបស្សនា ។ ចំណែកអនុបស្សនា មានពាក្យជាដើមថា ភិក្ខុពិចារណាឃើញរូបថាជាអត្តា ឈ្មោះថា ទិដ្ឋិសមនុបស្សនា ។ ក្នុងអនុបស្សនា ២ យ៉ាងនោះ ក្នុងទីនេះ លោកបំណងយកញាណសមនុបស្សនា ។ តែគប្បីជ្រាបការភ្ជាប់បទនេះដោយ ៣ អក្ខរៈ ។ លោកអធិប្បាយដូច្នេះថា ម្នាលភិក្ខុទាំងឡាយ តថាគតសូម្បីរំពឹងមើលដោយសព្វញ្ញុតញ្ញាណ ក៏មិនឃើញរូបដទៃត្រឹមតែមួយ ។

បទថា **យំ ឯវំ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ** សេចក្តីថា រូបណាប្រមូលផ្តុំ ធ្វើកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិ ៤ របស់បុរសដែលធូន់ក្នុងរូបឲ្យអស់ទៅ ស្ថិតនៅ ។ ពិតហើយ ការប្រកាន់ ឈ្មោះថា ការប្រកាន់មាំ បានក្នុងពាក្យថា ប្រកាន់មាំកាយស្រីទាំងអស់ជាដើម ។ ឈ្មោះថា ឲ្យអស់ទៅ បានក្នុងពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ អនិច្ចសញ្ញាដែលភិក្ខុអប់រំហើយ ធ្វើឲ្យច្រើនហើយ ធ្វើកាមរាគៈទាំងពួងឲ្យអស់ទៅ ក្នុង

ទីនេះ ក៏ត្រូវទាំង ២ យ៉ាង ។ ក្នុងការប្រកាន់ និងការឲ្យអស់ទៅទាំង ២ យ៉ាងនោះ រូបនេះ កាលកាន់យកកុសលចិត្ត ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ឈ្មោះថា កាន់យក ដូចបុរសយកដៃកាន់ផ្កាឈូកក៏មិនមែនដែរ កាលធ្វើឲ្យអស់ទៅ ឈ្មោះថា ធ្វើឲ្យអស់ទៅ ដូចភ្លើងដែលធ្វើទឹកលើចង្ក្រានឲ្យក្តៅហើយអស់ទៅក៏មិនមែន មយ៉ាងទៀត រូបដែលឃាត់ការកើតឡើងនៃកុសលចិត្តនោះឯង គប្បីជ្រាបថា ឈ្មោះថា ប្រកាន់ និងធ្វើកុសលចិត្តដែលប្រព្រឹត្តទៅក្នុងភូមិឲ្យអស់ទៅ ។ ដោយហេតុនេះ ទើបត្រាស់ថា **បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ** ទាញចិត្តបុរសតាំងនៅ ។

បទថា **យថយិទំ** កាត់បទជា **យថា ឥទំ** ។ បទថា **ឥត្ថិរូបំ** ប្រែថា រូបរបស់ស្រី ។ ក្នុងពាក្យថា **រូប** នោះ គប្បីជ្រាបអត្ថនៃពាក្យ និងសាមញ្ញលក្ខណៈនៃរូប តាមគន្លងនៃសូត្រថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកពោលរូបអ្វី ម្នាលភិក្ខុទាំងឡាយ ធម្មជាតណារមែងបែកធ្លាយ ព្រោះហេតុនោះ ទើបធម្មជាតនោះ ហៅថា **រូប** ។ រូបរមែងបែកធ្លាយទៅ ព្រោះហេតុអ្វី រមែងបែកធ្លាយទៅ ព្រោះត្រជាក់ខ្លះ រមែងបែកធ្លាយទៅ ព្រោះក្តៅខ្លះ ។

សព្ទថា **រូប** នេះ រមែងបានអត្ថច្រើនយ៉ាង ដូចជា ខន្ធ ភព និមិត្ត បច្ច័យ សរីរៈ វណ្ណៈ សណ្ឋានជាដើម ។ ពិតហើយ សព្ទថា **រូប** នេះ ប្រើក្នុងអត្ថថា រូបក្ខន្ធ ដូចក្នុងប្រយោគជាដើមថា **យង្កិញ្ចិ រូបំ អតីតា-នាគតបច្ចុប្បន្នំ** រូបក្ខន្ធឯណានីមួយ ដែលជាអតីត អនាគត និងបច្ចុប្បន្ន ប្រើក្នុងអត្ថថា រូបភព ដូចក្នុងប្រយោគថា **រូបូបត្តិយា មគ្គំ ភាវេតិ** ចម្រើន

មគ្គ ដើម្បីកើតឡើងក្នុងរូបភព ។ ប្រើក្នុងអត្ថថា កសិណនិមិត្ត ដូចក្នុងប្រយោគជាដើមថា **អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ** កំណត់រូបខាងក្នុង ឃើញរូបកសិណខាងក្រៅ ។ ប្រើក្នុងអត្ថថា បច្ច័យ ដូចក្នុងប្រយោគជាដើមថា **សរូបា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អរូបា** ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមកទាំងឡាយ ប្រកបដោយរូប ទើបកើតឡើងបាន មិនមែនឥតរូបទេ ។ ប្រើក្នុងអត្ថថា សរីរៈ ដូចក្នុងប្រយោគជាដើមថា **អាកាសោ បរិវារិតោ រូបន្តេវ សង្ខ្យំ គច្ឆតិ** អាកាសដែលអាស្រ័យ ( ឆ្អឹងខ្ទះ ... ) រួបរួមជាមួយគ្នាហើយ ទើបហៅថា រូបបានដូច្នោះឯង ។ ប្រើក្នុងអត្ថថា វណ្ណៈ ដូចក្នុងប្រយោគជាដើមថា **ចក្ខុញ្ច បដិច្ច រូបេ ច ឧប្បជ្ជតិ ចក្ខុវិញ្ញាណំ** វិញ្ញាណកើតឡើង ព្រោះអាស្រ័យភ្នែកនិងរូប ដល់នូវកិរិយារាប់ថា **ចក្ខុវិញ្ញាណ** ។ ប្រើក្នុងអត្ថថា សណ្ឋាន ដូចក្នុងប្រយោគជាដើមថា **រូបប្បមាណោ រូបប្បសន្នោ** បុគ្គលជ្រះថ្លាក្នុងរូបឈ្មោះថា **រូបប្បមាណ** ។ គប្បីសង្គ្រោះរូបជាដើមថា **បិយរូបំ សាតរូបំ អរសរូបោ** រូបគួរស្រឡាញ់ រូបគួរត្រេកអរ បុគ្គលមានរូបមិនគួរត្រេកអរដោយ **អាទិ** សព្ទ ។ តែក្នុងទីនេះ **រូប** សព្ទនោះ ប្រើក្នុងអត្ថថា វណ្ណៈពោល គឺរូបាយតនៈដែលមានសមុដ្ឋាន ៤ របស់ស្រី ។ ម្យ៉ាងទៀត វណ្ណៈពណ៌ឯណានីមួយដែលទាក់ទងដោយកាយរបស់ស្រី មិនថា សំពត់ស្បៀកគ្រឿងប្រដាប់ ក្លិនក្រអូប និងពណ៌សម្បុរជាដើម ឬគ្រឿងប្រដាប់ និងផ្កាកម្រង រមែងសម្រេចជាអារម្មណ៍នៃចក្ខុវិញ្ញាណរបស់បុរស ។ ទាំងអស់នោះ

គប្បីជ្រាបថា ជារូបនៃស្រីដូចគ្នា ។

បទថា **ឥត្ថីរូបំ ភិក្ខវេ បុរិសស្ស ចិត្តំ បរិយាទាយ តិដ្ឋតិ** នេះ ត្រាស់ដើម្បីធ្វើពាក្យដែលត្រាស់មកអំពីមុននោះឯង ឲ្យធ្ងន់ ។ ឬពាក្យមុន ត្រាស់ដោយអំណាចឧបមាយ៉ាងនេះថា **យថយិទំ ភិក្ខវេ ឥត្ថីរូបំ** ។ តែពាក្យនេះត្រាស់ដោយអំណាចការចង្អុលភាវៈនៃការប្រកាន់ ។ ក្នុងការដែលរូបស្រីគ្របសង្កត់នោះ មានរឿងសាធកៈដូចតទៅនេះថា

## រឿង ឧម្មត្តកចិត្តត្ថេរ

បានឮថា ព្រះរាជាទ្រង់ព្រះនាមថា មហាទាឋិកនាគ ឲ្យសាងព្រះស្តូបជំ ត្រង់គុហាអម្ពត្ថិត្ថ ជិតចេតិយគិរីវិហារ ធ្វើគិរិភណ្ឌវាហនបូជា គឺបូជាដោយនាំរបស់ដែលកើតក្នុងភ្នំមក មានស្រីស្នំចោមរោម យាងទៅកាន់ចេតិយគិរីវិហារ ថ្វាយមហាទានដល់ភិក្ខុសង្ឃតាមកាលដ៏សមគួរ ។ ធម្មតាទីប្រជុំជនដែលមានមនុស្សច្រើនប្រជុំគ្នា ជនទាំងអស់មិនមានសតិ ដែលនឹងតាំងមាំបាន ។ ព្រះអគ្គមហេសីរបស់ព្រះរាជា ឈ្មោះថា ទមិឡទេវី តាំងនៅក្នុងវ័យក្មេង គួរសរសើរ គួរពិតពិលរមិលមើល កាលនោះ ព្រះថេរៈមួយរូប ឈ្មោះចិត្តៈ ជាអ្នកបួសឯចាស់ សម្លឹងមើលដោយទំនងដែលមិនសង្រួម ទាញយកនិមិត្តក្នុងរូបារម្មណ៍របស់អគ្គមហេសីនោះ ដូចមនុស្សឆ្កួត ។ ត្រាច់ពោលទៅក្នុងទីដែលខ្វះឈើ និងអង្គុយថា យាងចុះព្រះនាងទមិឡទេវី យាងចុះព្រះនាងទមិឡទេវី ។ តាំងអំពីនោះមក ភិក្ខុកំលោះ និងសាមណេរក៏ឲ្យឈ្មោះលោកថា ឧម្មត្តកចិត្តត្ថេរ ។ តមកមិនយូរ ព្រះទេវីនោះក៏សោយ

ព្រះវិហារ័យ ។ កាលភិក្ខុសង្ឃទៅពិចារណាក្នុងព្រៃខ្មោច ហើយត្រឡប់មក ភិក្ខុកំលោះ និងសាមណេរបានទៅកាន់សម្នាក់របស់លោក ពោលយ៉ាងនេះថា លោកម្ចាស់ចិត្តៈ លោកម្ចាស់រវើរវាយដល់ព្រះទេវីអង្គណា ពួកខ្ញុំទៅព្រៃខ្មោច ពិចារណាព្រះសពទេវីអង្គនោះ ត្រឡប់មកហើយ សូម្បីភិក្ខុកំលោះនិងសាមណេរទាំងឡាយពោលយ៉ាងនោះ លោកក៏មិនជឿ នៅតែពោលដូចមនុស្សឆ្កួតថា ពួកលោកទៅពិចារណាអ្នកណាក៏បាន ក្នុងព្រៃខ្មោច មុខរបស់ពួកលោក ទើបមានពណ៌ដូចផ្សែងភ្លើង ។ រូបនៃស្រីនេះ បានគ្របសង្កត់ចិត្តរបស់ព្រះចិត្តៈឲ្យឆ្កួត តាំងនៅដោយប្រការដូច្នេះ ។

# រឿង ភិក្ខុកំលោះនិងស្រីស្នំ

មានរឿងមួយទៀត បានឮថា ថ្ងៃមួយ ព្រះមហាកជាព្រះនាមថា សទ្ធាតិស្សៈ មានពួកស្រីស្នំចោមរោម យាងមកកាន់វិហារ ។ ភិក្ខុកំលោះមួយរូប ឈរនៅត្រង់ខ្លោងទ្វារនៃលោហប្រាសាទ តាំងនៅក្នុងការមិនសង្រួមសម្លឹងមើលស្រីម្នាក់ ។ ស្រីនោះក៏ឈប់ សម្លឹងមើលភិក្ខុកំលោះរូបនោះទាំង ២ នាក់ត្រូវភ្លើង គឺរាគៈតាំងឡើងក្នុងហឫទ័យដុតរោល ក៏ស្លាប់ទាំង ២ នាក់ រូបនៃស្រីគ្របសង្កត់ចិត្តរបស់ភិក្ខុកំលោះតាំងនៅ ដោយប្រការយ៉ាងនេះ ។

មានរឿងមួយទៀត បានឮថា ភិក្ខុកំលោះមួយរូប មកអំពីកល្យាណីមហាវិហារ ទៅកាន់ទ្វារស្រុកកាឡទីឃវាបិគាម ដើម្បីសម្តែងបាតិមោក្ខ ចប់ការសម្តែងបាតិមោក្ខហើយ កាលមិនជឿពាក្យរបស់បុគ្គលដែលមានបំណង

ល្អ គិតថា ក្នុងទីដែលទៅហើយ អញត្រូវកិក្ខុកំលោះ និងសាមណេរសួរ ហើយ គួរនឹងប្រាប់អាការដែលអញអាស្រ័យភូមិ ដូច្នេះហើយ ទើបត្រាច់ទៅ បិណ្ឌបាតក្នុងស្រុក ទាញយកនិមិត្តក្នុងវិសភាគារម្មណ៍ ហើយទៅកាន់លំនៅ របស់ខ្លួន ចាំសំពត់ដែលនាងស្លៀកបាន ក៏សួរថា លោកម្ចាស់ លោកបាន សំពត់នេះមកដូចម្ដេច ដឹងថា នាងស្លាប់ហើយ ក៏គិតថា ស្រីបែបនេះ ស្លាប់ ព្រោះអញ ដូច្នេះ ត្រូវភ្លើងរាគៈកើតឡើងដុតរោល ក៏អស់ជីវិតទៅ ។ បណ្ឌិត គប្បីជ្រាបថា រូបរបស់ស្រីគ្របសង្កត់ចិត្តបុរសតាំងនៅ ដោយអាការដូច្នេះ ។

## អដ្ឋកថាសូត្រទី ១ ចប់

# អដ្ឋកថា សូត្រទី ២

សូត្រទី ២ លោកពោលហើយ ដោយអំណាចនៃបុគ្គលដែលជូន់ក្នុងសំឡេង ។

[ ៣ ] បណ្ដាបទទាំងនោះ បទថា **ឥត្ថីសទ្ទោ** បានដល់ សំឡេងពោល សំឡេងច្រៀង និងប្រគំ ដែលមានចិត្តជាសមុដ្ឋានរបស់ស្រី ។ម្យ៉ាងទៀត សំឡេងពិណ ខ្លុយ ស័ង្ខ ស្គរតូចជាដើម ដែលសម្រេចដោយការប្រកបរបស់ស្រី ដែលមានគ្រឿងស្លៀកដណ្ដប់ខ្លះ មានគ្រឿងប្រដាប់ខ្លះ គប្បីជ្រាបថា សំឡេងរបស់ស្រីទាំងអស់ ។ ពិតហើយ សំឡេងស្រីទាំងអស់នោះ រមែងគ្របសង្កត់ចិត្តរបស់បុរសតាំងនៅ ដូច្នេះឯង ។ ក្នុងសូត្រនេះ គប្បីជ្រាបរឿងក្ដាមមាស ក្ងោកមាស និងភិក្ខុកំលោះជាដើម ។

## រឿង ក្ដាមមាស

បានឮថា ហ្វូងដំរីមួយហ្វូងធំ អាស្រ័យញកភ្នំ រស់នៅ ។ ក្នុងទីមិនឆ្ងាយអំពីញកភ្នំនោះ មានស្រះធំ សម្រាប់ប្រើប្រាស់ ។ ក្នុងស្រះធំនោះ មានក្ដាមមាសធំអាស្រ័យនៅ ក្ដាមនោះយកតង្កៀបចាប់ជើងសត្វ ដែលនាំគ្នាចុះក្នុងស្រះនោះ ដូចចាប់ដោយតង្កៀប ហើយឲ្យនៅក្នុងអំណាចរបស់ខ្លួន ធ្វើឲ្យស្លាប់ ។ ស្ដេចដំរីឃ្លាំមើលឱកាសរបស់ក្ដាមមាសនោះ តែងតាំងដំរីធំមួយ ឲ្យជាប្រធានត្រាច់ទៅ ។ ថ្ងៃមួយ ក្ដាមនោះ ចាប់ដំរីនោះបាន ។ ស្ដេចដំរីសម្បូរដោយកម្លាំង និងសតិ គិតថា បើអញស្រែកព្រោះខ្លាចសោតដំរីទាំងអស់ នឹងមិនលេងតាមការគាប់ចិត្ត នឹងគេចទៅ ទើបឈរស្ងៀមនោះ

ឯង កាលដឹងថា ដំរីឡើងអស់ហើយ ទើបប្រាប់ឲ្យកិរិយារបស់ខ្លួនដឹងថា ខ្លួនត្រូវក្ដាមចាប់ ទើបពោលគាថានេះថា

ម្រឹគមានសម្បុរដូចមាស ( ក្ដាម ) ជាសត្វមានភ្នែកលៀន
វែង មានធ្អឹងជាស្បែក ជាសត្វនៅក្នុងទឹក មិនមានរោម
យើងត្រូវក្ដាមនោះថ្កៀបហើយ ទើបកម្សត់ទួញយំ សូម
កិរិយាកុំលះបង់នូវខ្ញុំ ដែលស្មើដោយជីវិតឡើយ ។

កិរិយាបានស្ដាប់ដូច្នោះ ដឹងថា ប្ដីត្រូវក្ដាមកៀប ទើបផ្ដោះផ្ដងជាមួយ ដំរីខ្លះ ជាមួយក្ដាមខ្លះ ដើម្បីឲ្យប្ដីផុតអំពីភ័យនោះ ទើបពោលយ៉ាងនេះថា

បពិត្រអ្នកជាម្ចាស់ ខ្ញុំមិនលះបង់អ្នកដែលជាដំរីថមថយកម្លាំង
ក្នុងកាលនៃខ្លួនមានអាយុ ៦០ ឆ្នាំឡើយ ខ្ញុំស្រឡាញ់អ្នក
ក្រៃលែងជាងប្រឹថពីដែលទល់នឹងសមុទ្រទាំង ៤ ទៅទៀត ។
ពួកក្ដាមណា ដែលនៅក្នុងសមុទ្រក្ដី ក្នុងទន្លេគង្គាក្ដី យមុនាក្ដី
អ្នកជាសត្វទឹកប្រសើរ ជាងក្ដាមទាំងនោះ សូមអ្នកមេត្ដាលែង
ប្ដី កាលដែលខ្ញុំកំពុងទួញយំរកប្ដី សូមអ្នកមេត្ដាលែងប្ដី
( របស់ខ្ញុំ ) មកវិញ ក្នុងកាលឥឡូវនេះ ។

ក្ដាមលាដង្កៀបឲ្យធូរបន្តិច ដំណាលគ្នានឹងបានឮសំឡេងរបស់ស្រី គ្រានោះ ស្ដេចដំរីគិតថា នេះឯងជាឱកាសរបស់វា ទើបដកជើងម្ខាង ដោយអាការដែលត្រូវកៀបនោះឯង លើកជើងទី ២ ឡើងជាន់ស្នូកក្ដាមនោះ ធ្វើឲ្យបែក រលាស់ក្ដាមនោះ បោះឡើងទៅលើច្រាំង ។ លំដាប់នោះ ដំរីទាំង

អស់ប្រជុំគ្នា វាយក្ងោកនោះឲ្យស្លាប់ ដោយគិតថា ក្ងោកនេះជាសត្រូវរបស់ពួកយើង ។ សំឡេងរបស់ស្រីគ្រប់សង្កត់ចិត្តរបស់ក្ងោកមាស ដោយប្រការដូច្នេះ ។

ចំណែកក្ងោកមាស ចូលទៅកាន់ព្រៃហិមពាន្តអាស្រ័យភ្នំធំ សម្លឹងមើលព្រះអាទិត្យ ក្នុងវេលាដែលព្រះអាទិត្យរះ អស់កាលជានិច្ច កាលនឹងធ្វើការរក្សាខ្លួន ទើបពោលបរិត្តយ៉ាងនេះថា

សុរិយទេវបុត្រណា ជាឯករាជ្យ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងរះឡើង ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សាអស់វេលាថ្ងៃក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវវេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ។

ក្ងោកពោធិសត្វនោះធ្វើបរិត្តនេះ រួចហើយ ទើបត្រាច់ទៅស្វែងរកអាហារ ។

ក្ងោកនោះ ត្រាច់រកស៊ីអស់មួយថ្ងៃ ក្នុងវេលាល្ងាច ទើបចូលទៅ

លំនៅ សម្លឹងមើលព្រះអាទិត្យដែលអស្តង្គត បានពោលសរសើរយ៉ាងនេះថា

( សុរិយទេវបុត្តណា ) ជាឯករាជ្យ មានចក្ខុ មានសម្បុរដូច
ជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងអស្តង្គតទៅ ខ្ញុំ
សូមនមស្ការនូវសុរិយទេវបុត្តនោះ អ្នកមានសម្បុរដូចមាស
មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា
អស់រាត្រីក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សម្រេចនូវ
វេទក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះ ទទួលនូវការ
នមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងនោះ រក្សានូវខ្ញុំ ការ
នមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការ
នមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមាន
ដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ។

ក្ងោកនោះបានធ្វើបរិត្តនេះហើយ ទើបសម្រេចការនៅ ។ ក្ងោកនោះរស់នៅរហូត ៧០០ ឆ្នាំដោយទំនងនេះឯង ។ ថ្ងៃមួយ បានឮសំឡេង ក្ងោកញី មុនការធ្វើបរិត្ត មិនព្រមរឭកដល់ការធ្វើបរិត្ត ទើបជាប់អន្ទាក់របស់នាយព្រានដែលព្រះរាជាបញ្ជូនទៅ ។ សំឡេងរបស់ស្រីគ្របសង្កត់ចិត្តរបស់ក្ងោកមាសតាំងនៅ ដោយប្រការយ៉ាងនេះឯង ។ បានឮថា ភិក្ខុកំលោះដែលនៅត្រង់ធាតកបព៌ត និងភិក្ខុកំលោះនៅត្រង់សុជាមុណ្ឌិកវិហារ បានឮសំឡេងរបស់ស្រី ហើយក៏ដល់នូវសេចក្តីវិនាសនោះឯង ។

**អដ្ឋកថាសូត្រទី ២ ចប់**

# អដ្ឋកថាសូត្រទី ៣

[ ៤ ] ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះថា បទថា **ឥត្ថិគន្ធោ** បានដល់ គន្ធាយតនៈរបស់ស្រី មានសមុដ្ឋាន ៤ ។ ក្លិនកាយរបស់ស្រីនេះ រមែងស្អុយ តែក្លិនគ្រឿងលាបលទស្បែកជាដើមខាងក្រៅ ដែលប្រោះព្រំកាយ លោកបំណងយកក្នុងទីនេះ ។

ពិតហើយ ស្រីពួកខ្លះ មានក្លិនដូចក្លិនសេះ ពួកខ្លះ មានក្លិនដូចក្លិនពពែ ពួកខ្លះ មានក្លិនដូចញើសក្អែល ពួកខ្លះ មានក្លិនដូចក្លិនឈាម បុគ្គលពាលល្ងង់ខ្លៅពួកខ្លះ ស្រឡាញ់ក្នុងស្រីបែបនោះឯង ។ ឯក្លិនចន្ទន៍ផ្សាយចេញអំពីកាយ និងក្លិនផ្កាឧប្បលផ្សាយចេញអំពីមាត់របស់ស្រីកែវរបស់ស្តេចចក្រពត្តិ ក្លិននេះមិនមានដល់ស្រីគ្រប់ពួកឡើយ ។ ចំពោះក្លិនជាគ្រឿងប្រោះព្រំជាដើមខាងក្រៅ លោកបំណងយកក្នុងទីនេះ ។ ឯសត្វតិរច្ឆាន មានដំរី សេះ និងគោជាដើម រមែងដើរទៅអស់ផ្លូវ ១ យោជន៍ ២ យោជន៍ ៣ យោជន៍ និង ៤ យោជន៍ តាមក្លិនរដូវរបស់តិរច្ឆានញី ។ មិនថាតែក្លិនកាយស្រី ឬក្លិនគ្រឿងស្លៀកដណ្តប់ដែលស្រីស្លៀក គ្រឿងប្រោះព្រំដែលស្រីលាបនោះឡើយ គ្រឿងប្រដាប់ និងកម្រងផ្កាជាដើមរបស់ស្រីទាំងអស់ គប្បីជ្រាបថា ក្លិនស្រីទាំងអស់ ។

## អដ្ឋកថាសូត្រទី ៣ ចប់

# អដ្ឋកថាសូត្រទី ៤

[ ៥ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះថា បទថា **ឥត្ថិរសោ** បានដល់ រសាយតនៈរបស់ស្រី មានសមុដ្ឋាន ៤ ។ ព្រះចូឡាភយត្ថេរ ដែលជាអ្នកទ្រទ្រង់ព្រះត្រៃបិដកពោលថា រសនេះជារសនៃការស្ដាប់ ឬរសនៃការបរិភោគ ដោយអំណាចការបម្រើជាដើមរបស់ស្រី រសនេះ ឈ្មោះថា រសរបស់ស្រី ។ រសទឹកមាត់ដែលប្រឡាក់ត្រង់បបូរមាត់ជាដើមរបស់ស្រី សូម្បីតែរសនៃបបរ និងបាយជាដើម ដែលនាងឲ្យដល់ប្ដី ទាំងអស់នេះ គប្បីជ្រាបថា រសនៃស្រីដូចគ្នា ។ ពិតហើយ សត្វជាច្រើន កាន់យករបស់ឯណានីមួយ ដែលស្រីមេផ្ទះឲ្យដោយដៃរបស់ខ្លួនប៉ុណ្ណោះ ថាជារបស់ឆ្ងាញ់ ដល់នូវការវិនាស ដូច្នេះ ។

## អដ្ឋកថាសូត្រទី ៤ ចប់

# អដ្ឋកថាសូត្រទី ៥

[ ៦ ] ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះថា បទថា **ឥត្ថិផោដ្ឋព្វោ** សេចក្តីថា សម្ផស្សកាយនៃស្រី សូម្បីសម្ផស្សសំពត់ គ្រឿងប្រដាប់ និង កម្រងផ្កាជាដើមដែលនៅជាប់នឹងខ្លួនស្រី គប្បីជ្រាបថា ជាផោដ្ឋព្វៈស្រីទាំង អស់ ។ ផស្សៈទាំងអស់នោះ រមែងគ្របសង្កត់ចិត្តបុរសតាំងនៅ ដូចផស្សៈ ដែលជាវិសភាគារម្មណ៍របស់ភិក្ខុកំលោះ ដែលកំពុងស្វាធ្យាយជាគណៈត្រង់ លានៃមហាចេតិយ ។

ដូច្នោះ ទើបព្រះសាស្តាកាន់យកអារម្មណ៍ មានរូបារម្មណ៍ជាដើមឯណា នីមួយ ដោយអំណាចនៃអាសយៈ គឺអធ្យាស្រ័យ និងអនុសយៈរបស់សត្វ ទាំងឡាយ ទើបត្រាស់ថា តថាគតមើលមិនឃើញអារម្មណ៍ដទៃ ដែលមាន សភាពបែបនេះ ។ រូបស្ត្រីរមែងចូលដល់ចិត្តុប្បាទរបស់បុរស ដែលជូន់ក្នុង រូប រមែងជាប់ចំពាក់ ស្រវឹង ឲ្យអ័ព្ទអួ ឲ្យវង្វេង ឲ្យបាត់បង់ស្មារតី យ៉ាង ណា សំឡេងជាដើមដ៏សេស មិនមែនដូច្នោះឡើយ ។ ម្យ៉ាងទៀត សំឡេង ជាដើម រមែងចូលដល់ចិត្តុប្បាទរបស់បុរស ដែលជាអ្នកជូន់ក្នុងសំឡេង ជាដើម យ៉ាងណា អារម្មណ៍ មានរូបជាដើម មិនដូច្នោះឡើយ ព្រោះបណ្តា អារម្មណ៍ មានរូបារម្មណ៍ជាដើម អារម្មណ៍ ១ ប៉ុណ្ណោះ រមែងគ្របសង្កត់ ចិត្តរបស់បុរសពួកខ្លះ ។ សម្រាប់បុរសពួកខ្លះ អារម្មណ៍ ២ គ្របសង្កត់ ខ្លះ ៣ អារម្មណ៍ ខ្លះ ៤ អារម្មណ៍ ខ្លះ ៥ អារម្មណ៍ គ្របសង្កត់ចិត្ត ។ ដូច្នោះ សូត្រទាំង ៥ នេះ ទ្រង់ត្រាស់ហើយ ដោយអំណាចបុគ្គលដែល ជូន់ក្នុងអារម្មណ៍ ៥ យ៉ាង មិនត្រាស់ដោយអំណាចបញ្ចគរុកជាតកឡើយ ។

ឯបញ្ចគរុកជាតក ក៏គួរនាំមកពោលដើម្បីជាបន្ទាល់ ។ ពិតហើយ ក្នុងជាតកនោះ កាលពួកអមនុស្សនាំគ្នារៀបចំរានផ្សារកណ្ដាលផ្លូវកន្តារ បណ្ដាសម្លាញ់ ៥ នាក់ របស់មហាបុរស សម្លាញ់ដែលជូន់ក្នុងរូប ជាប់នៅក្នុងអារម្មណ៍ ដល់នូវសេចក្ដីវិនាស អ្នកជូន់ក្នុងសំឡេងជាដើម ជាប់នៅក្នុងសទ្ទារម្មណ៍ជាដើម ក៏ដល់នូវសេចក្ដីវិនាស ។ រឿងដែលជាអតីត គួរនាំមកពោលដើម្បីជាបន្ទាល់ ។

ក្នុងសូត្រទាំង ៥ នេះ ទ្រង់ត្រាស់ដោយអំណាចបុគ្គលដែលជូន់ក្នុងអារម្មណ៍ ៥ យ៉ាងប៉ុណ្ណោះ ព្រោះមិនមែនបុរសតែម្យ៉ាងប៉ុណ្ណោះទេ ដែលជាអ្នកជូន់ក្នុងអារម្មណ៍ទាំង ៥ សូម្បីស្រីក៏ជាអ្នកជូន់ដូចគ្នា ដូច្នោះ ទើបទ្រង់ត្រាស់ព្រះសូត្រទាំង ៥ ទៀត ដោយអំណាចស្រីដែលជូន់ក្នុងអារម្មណ៍ទាំងនោះ។ អត្ថនៃព្រះសូត្រនោះ គប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

បណ្ដារឿងទាំងឡាយ ក្នុងសូត្រទី ១ គប្បីជ្រាបរឿងស្រីស្នំរបស់ព្រះរាជាដែលសម្លឹងមើលភិក្ខុកំលោះ ឈរត្រង់ខ្លោងទ្វារនៃលោហប្រាសាទ ហើយស្លាប់ទៅ រឿងនោះ ពោលដោយពិស្ដារហើយខាងដើមនោះឯង ។

ក្នុងសូត្រទី ២ គប្បីជ្រាបរឿងស្រីដែលអាស្រ័យរូបចិញ្ចឹមជីវិតក្នុងក្រុងសាវត្ថី ។

## រឿង សំឡេងពិណ

បានឮថា អ្នកដេញពិណឈ្មោះគុត្តិលៈ បានបញ្ជូនទ្រព្យ ១០០០ ទៅឲ្យស្រីម្នាក់ នាងបែរជាចំអក មិនប្រាថ្នានឹងទទួល បុរសនោះគិតថា អញនឹងធ្វើ

វត្ថុដែលគួរធ្វើក្នុងរឿងនេះ វេលាព្រលប់ ទើបតែងខ្លួន អង្គុយត្រង់ទ្វារមួយ កន្លែងត្រង់មុខផ្ទះរបស់នាង តម្លើងពិណល្អហើយ ទើបដេញ រហូតគ្រប់សំឡេងពិណ ។ ស្រីនោះបានឮសំឡេងប្រគំរបស់បុរសនោះគិតថា អញនឹងទៅរកបុរសនោះតាមបង្អួចដែលបើក ដោយសម្គាល់ថាជាទ្វារ ក៏រអិលធ្លាក់ទៅ រហូតបាត់បង់ជីវិត ។

ក្នុងសូត្រទី ៣ គប្បីជ្រាបក្លិនចន្ទន៍ដែលផ្សាយចេញអំពីកាយ និងក្លិនឧប្បលផ្សាយចេញអំពីមាត់របស់ស្តេចចក្រពត្តិ រឿងនេះគួរនាំមកសម្តែង ។ ក្នុងសេចក្តីនេះ គប្បីជ្រាបរឿងដូចតទៅនេះ

## រឿង ក្លិនរបស់ភិក្ខុមួយរូប

បានឮមកថា ប្តីរបស់កុលធីតានៃកុដុម្ពិកៈម្នាក់ ក្នុងក្រុងសាវត្ថី ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា គិតថា អញជាគ្រហស្ថ មិនអាចបំពេញធម៌នេះបាន ទើបបួសក្នុងសម្នាក់របស់ព្រះបិណ្ឌបាតិកត្ថេរមួយរូប ។ កាលនោះព្រះបាទបសេនទិកោសល ដឹងថា កិរិយារបស់បុរសនោះ មិនមានស្វាមី ទើបឲ្យមនុស្សនាំមកនៅក្នុងរាជវាំង ថ្ងៃមួយ ទ្រង់នាំយកបាច់ផ្កាឈូកមួយបាច់ចូលទៅក្នុងព្រះរាជវាំង ប្រទានដល់ស្រីស្នំម្នាក់មួយផ្កាៗ ។ កាលចែកគ្នា ផ្កាឈូក ២ បានដល់ដៃរបស់ស្រីនោះ ស្រីនោះសម្តែងអាការត្រេកអរ បើបផ្កាហើយក៏យំ ព្រះរាជាទ្រង់ឃើញអាការ ២ របស់នាង ទើបហៅនាងមកសួរ ។ នាងក្រាបទូលហេតុដែលខ្លួនត្រេកអរ និងយំឲ្យទ្រង់ជ្រាប ។ សូម្បីទូលដល់ទៅ ៣ ដង ព្រះរាជាទ្រង់មិនជឿ ថ្ងៃស្អែកឡើង ទើបឲ្យមនុស្សជញ្ជូនយក

គ្រឿងដែលមានក្លិនយ៉ាងល្អ មានកម្រងផ្កា និងគ្រឿងលាបជាដើមសព្វយ៉ាង ក្នុងព្រះរាជនិវេសន៍ចេញទៅ ឲ្យក្រាលអាសនៈសម្រាប់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ក្នុងវេលាចប់ភត្តកិច្ច ត្រាស់សួរស្រីនោះថា ព្រះថេរៈរូបណា ។ កាលនាងក្រាបទូលថា រូបនេះ ទ្រង់ជ្រាបហើយ ថ្វាយបង្គំព្រះសាស្ដា ហើយទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមភិក្ខុសង្ឃទៅជាមួយព្រះអង្គចុះ ព្រះថេរៈអង្គនោះ ខ្ញុំព្រះអង្គនឹងធ្វើអនុមោទនា ។ ព្រះសាស្ដាវៀរភិក្ខុរូបនោះទុក ហើយយាងទៅកាន់ព្រះវិហារ ។ លុះព្រះថេរៈផ្ដើមពោលអនុមោទនា ព្រះរាជនិវេសន៍ទាំងអស់ពេញទៅដោយក្លិនក្រអូប ។ ព្រះរាជាទ្រង់ជ្រះថ្លាពោលថា នាងពោលពិតហ្ន៎ ថ្ងៃស្អែកឡើង ទើបសួរដល់ហេតុនោះនឹងព្រះសាស្ដា ព្រះសាស្ដាត្រាស់ថា ក្នុងអតីតកាល ភិក្ខុរូបនេះ ស្ដាប់ធម្មកថា បន្លឺសាធុការថា សាធុ សាធុ មិនដាច់ខ្សែ បានស្ដាប់ដោយគោរព មហាបពិត្រ ភិក្ខុនោះបានអានិសង្សនេះ មានការបន្លឺសាធុការនោះជាមូល ។

ក្នុងវេលាស្ដាប់ព្រះសទ្ធម្ម កាលភិក្ខុនោះពោលថា សាធុ សាធុ ក្លិនក្រអូបកើតអំពីមាត់ ផ្សាយទៅដូចក្លិនផ្កាឈូក ដូច្នោះ ។

ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ហើយ ក្នុងវគ្គនេះលោកពោលតែរឿងទាំងនោះ ។ បាលីពោលដោយរូប ចប់ ។

**អដ្ឋកថា សូត្រទី ៩ ចប់**

**រូបាទិវគ្គទី ១ ចប់**

# សុត្តន្តបិដក

## នីវរណបហានវគ្គ

[ ១២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងកាមច្ឆន្ទៈមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី កាមច្ឆន្ទៈដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើងជាភិយ្យោភាពក្តី ដូចសុភនិមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្ត នូវសុភនិមិត្តដោយឧបាយខុស កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង កាមច្ឆន្ទៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើងជាភិយ្យោភាពផង ។

[ ១៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញ សភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងព្យាបាទមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ព្យាបាទដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនជាភិយ្យោ-ភាពក្តី ដូចបដិឃនិមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តនូវបដិឃនិមិត្តដោយឧបាយខុស ព្យាបាទដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង ព្យាបាទដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើនឡើងជាភិយ្យោភាពផង ។

[ ១៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងថីនមិទ្ធៈមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ថីនមិទ្ធៈដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើងជា

កិរិយាភាពក្តី ដូចសេចក្តីអផ្សុក សេចក្តីខ្ជិល ការមិតពត់កាយ សេចក្តីស្រវឹងបាយ នឹងភាពនៃចិត្តរួញរាទេះនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តរួញរា ថីនមិទ្ធៈ ដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង ថីនមិទ្ធៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើងជាកិរិយាភាពផង ។

[ ១៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងឧទ្ធច្ចកុក្កុច្ចៈមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើងជាកិរិយាភាពក្តី ដូចចិត្តមិនស្ងប់នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តមិនស្ងប់ ឧទ្ធច្ចកុក្កុច្ចៈ ដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើងជាកិរិយាភាពផង ។

[ ១៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងវិចិកិច្ឆាមិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី វិចិកិច្ឆាដែលកើតឡើងហើយ ឲ្យប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើងជាកិរិយាភាពក្តី ដូចការធ្វើទុកក្នុងចិត្ត ដោយឧបាយខុសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តដោយឧបាយខុស វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏កើតឡើងបានផង វិចិកិច្ឆាដែលកើតឡើងហើយ ក៏ប្រព្រឹត្តទៅ ដើម្បីសេចក្តីចម្រើនឡើង ជាកិរិយាភាពផង ។

[ ១៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងកាមច្ឆន្ទៈមិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី កាមច្ឆន្ទៈដែលកើតឡើងហើយ ក៏ឲ្យសាបសូន្យទៅក្តី ដូចអសុភនិមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តនូវអសុភ-និមិត្តដោយឧបាយត្រូវ កាមច្ឆន្ទៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង កាមច្ឆន្ទៈដែលកើតឡើងហើយ ក៏សាបសូន្យទៅផង ។

[ ១៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងព្យាបាទមិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី ព្យាបាទដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចមេត្តាចេតោវិមុត្តិនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្ត នូវមេត្តាចេតោវិមុត្តិដោយឧបាយត្រូវ ព្យាបាទដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ព្យាបាទដែលកើតឡើងហើយ ក៏សាបសូន្យទៅផង ។

[ ១៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងថីនមិទ្ធៈ មិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី ថីនមិទ្ធៈដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចអារម្ភធាតុ និក្កមធាតុ បរក្កមធាតុនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានព្យាយាមប្រារព្ធហើយ ថីនមិទ្ធៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ថីនមិទ្ធៈដែលកើតឡើងហើយ ក៏សាបសូន្យទៅផង ។

[ ២០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ

សូម្បីតែសភាវៈ ១ ដែលញុំាងឧទ្ធច្ចកុក្កុច្ចៈមិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចចេតសោវូបសម ( ចិត្តស្ងប់ ) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានចិត្តស្ងប់ ឧទ្ធច្ចកុក្កុច្ចៈដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង ឧទ្ធច្ចកុក្កុច្ចៈដែលកើតឡើងហើយ ក៏សាបសូន្យទៅផង ។

[ ២១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញុំាងវិចិកិច្ឆាមិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី វិចិកិច្ឆាដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការធ្វើទុកក្នុងចិត្តដោយឧបាយត្រូវនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្ត ដោយឧបាយត្រូវ វិចិកិច្ឆាដែលមិនទាន់កើតឡើង ក៏មិនកើតឡើងផង វិចិកិច្ឆាដែលកើតហើយ ក៏សាបសូន្យទៅផង ។

## វគ្គទី ២ ចប់

# អដ្ឋកថា

# នីវរណបហានវគ្គទី ២

## សូត្រទី ១

[ ១២ ] ក្នុងសូត្រទី ១ នៃនីវរណបហានវគ្គទី ២ មានវិនិច្ឆ័យដូច្នេះ ក្នុងបទថា **ឯកធម្មំបិ** នេះ គប្បីជ្រាបពាក្យថា ធម៌ ដោយអត្ថថា មិនមែនសត្វ ដូចក្នុងប្រយោគជាដើមថា **តស្មឹ ខោ បន សមយេ ធម្មា ហោន្តិ** សម័យនោះឯង ធម៌ទាំងឡាយរមែងមាន ។ ព្រោះដូច្នោះ ក្នុងបទថា **ឯកធម្មំបិ** នេះ មានអត្ថដូច្នេះថា សភាវៈឯណានីមួយមិនមែនសត្វ ។ **វា** សព្ទក្នុងបទថា **អនុប្បន្នោ វា** នេះ មានសមុច្ចយជាអត្ថ មិនមែនមានវិកប្បជាអត្ថ ដូច **វា** សព្ទ ក្នុងប្រយោគយ៉ាងនេះថា **ភូតានំ សត្តានំ ឋិតិយា សម្ភវេសីនំ វា អនុគ្គហាយ យាវតា ភិក្ខវេ សត្តា អបទា វា ទ្វិបទា វា** ដើម្បីតាំងនៅនៃសត្វដែលកើតហើយផង ដើម្បីអនុគ្រោះពួកសម្ភវេសីសត្វផង ។ ម្នាលភិក្ខុទាំងឡាយ ពួកសត្វមិនមានជើង និងសត្វជើង ២ មានប្រមាណត្រឹមណា ដូច្នេះ ។ ក្នុងសេចក្ដីនេះ មានអត្ថដូច្នេះថា កាមច្ឆន្ទៈដែលមិនទាន់កើត រមែងកើតឡើង ដែលកើតឡើងហើយ រមែងប្រព្រឹត្តទៅដើម្បីបរិបូណ៌ ចម្រើនដោយធម៌ណា តថាគតមើលមិនឃើញធម៌ដទៃ ដូចសុភនិមិត្តឡើយ ។

បណ្ដាបទទាំងនោះ បទថា **អនុប្បន្នោ** សេចក្ដីថា មិនកើត មិនកើតព្រម មិនប្រាកដ មិនប្រព្រឹត្តទៅ ។ បទថា **កាមច្ឆន្ទោ** បានដល់ កាមច្ឆន្ទ-

នីវរណៈដែលពោលពិស្តារហើយ ដោយន័យជាដើមថា **យោ កាមេសុ កាមច្ឆន្ទោ កាមរាគោ កាមនន្ទិ កាមតណ្ហា** សេចក្តីប្រាថ្នាក្នុងកាម តម្រេកក្នុងកាម ការរីករាយក្នុងកាម ការអន្ទះសាក្នុងកាមឯណា ។ បទថា **ឧប្បជ្ជតិ** បានដល់ កើតឡើងប្រាកដ ។ កាមច្ឆន្ទៈនេះ គប្បីជ្រាបថា ដែលមិនទាន់កើត រមែងកើតឡើង ដោយអំណាចការផ្សាយឡើង ឬដោយអារម្មណ៍ដែលមិនបានសោយ ។ ពិតហើយ កាលពោលដោយប្រការដទៃ កាមច្ឆន្ទៈ ឈ្មោះថា មិនកើតឡើងក្នុងសង្សារ ដែលមិនប្រាកដខាងដើម និងខាងចុង មិនមាន ។ សេចក្តីនោះ កិលេសរមែងមិនផ្សាយឡើងដល់ភិក្ខុរូបខ្លះ ដោយអំណាចវត្ត រមែងមិនផ្សាយឡើងដល់ភិក្ខុរូបខ្លះ ដោយអំណាចគន្ថៈ ធុតង្គ សមាធិ វិបស្សនា និងនវកម្ម ដែលលោកធ្វើហើយឯណានីមួយ ។ ពិតហើយ ភិក្ខុរូបខ្លះ ជាអ្នកសម្បូរដោយវត្ត កាលភិក្ខុនោះធ្វើខុទ្ទកវត្ត ៨២ និងមហាវត្ត ១៤ ចេតិយង្គណវត្ត ពោធិយង្គណវត្ត បានីយមាឡកវត្ត ឧបោសថាគារវត្ត អាគន្តុកវត្ត គមិកវត្ត កិលេសរមែងមិនបានឱកាស លុះចំណេរតមក កាលលោកលះបង់វត្ត មានវត្តបែកធ្លាយហើយ ត្រាច់ទៅអាស្រ័យការដាក់ចិត្តដោយមិនមែនឧបាយ និងការបណ្តែតបណ្តោយស្មារតី កិលេសរមែងកើតឡើង កាលបើដូច្នោះ កិលេសមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។ ភិក្ខុរូបខ្លះ ជាអ្នកប្រកបដោយគន្ថៈ រៀន ១ និកាយខ្លះ ២ ខ្លះ ៣ ខ្លះ ៤ ខ្លះ ៥ ខ្លះ កាលលោករៀន ទន្ទេញ ប្រាប់ សម្តែង ប្រកាសពុទ្ធវចនៈ គឺបិដក ៣ ដោយអំណាច

អត្ថ ដោយអំណាចបាលី ដោយអំណាចអនុសន្ធិ ដោយអំណាចអក្ខរៈខាងដើម ខាងចុង កិលេសរមែងមិនមានឱកាស ។ ចំណេរតមក កាលលះបង់ការរៀនសូត្រ ខ្ជិលច្រអូស ត្រាច់ទៅអាស្រ័យអយោនិសោមនសិការ និងបណ្តែតបណ្តោយស្មារតី កិលេសរមែងកើតឡើង ។ ព្រោះដូច្នោះ កិលេសដែលមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុរូបខ្លះ ជាអ្នកទ្រទ្រង់ធុតង្គ សមាទានធុតង្គគុណ ១៣ ប្រព្រឹត្តជាប្រចាំៗ កាលលោកបរិហារ គឺរក្សាធុតង្គគុណ កិលេសរមែងមិនបានឱកាស តែបន្ទាប់មក កាលលោកលះបង់ធុតង្គ វិលមកដើម្បីការប្រាថ្នាច្រើន អាស្រ័យអយោនិសោមនសិការ និងការបណ្តែតបណ្តោយស្មារតី កិលេសរមែងកើតឡើង ។ កាលបើដូច្នេះ កិលេសដែលមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។ ភិក្ខុរូបខ្លះ មានវសីសន្សំទុកក្នុងសមាបត្តិ ៨ កាលលោកប្រកបរឿយៗ ក្នុងបឋមជ្ឈានជាដើម ដោយអំណាចវសី មានអាវជ្ជនវសី គឺជំនាញក្នុងការចូលសមាបត្តិជាដើម កិលេសរមែងមិនបានឱកាស ចំណេរមក កាលលោកវិនាសចាកឈាន ឬបោះបង់ឈានចោល ហើយប្រកបរឿយៗ ក្នុងកិច្ចមានការជជែកជាដើម អាស្រ័យអយោនិសោមនសិការ និងការបណ្តែតបណ្តោយស្មារតី កិលេសរមែងកើតឡើង កាលបើដូច្នេះ កិលេសដែលមិនទាន់កើត ព្រោះមិនទាន់ផ្សាយឡើង ឈ្មោះថា រមែងកើតឡើង ។

មួយវិញទៀត ភិក្ខុរូបខ្លះ ជាអ្នកចម្រើនវិបស្សនា ធ្វើកិច្ចក្នុងអនុបស្សនា ៧ និងមហាវិបស្សនា ១៨ ។ កាលលោករស់នៅយ៉ាងនេះ កិលេសរមែងមិនបានឱកាស លុះចំណេរតមក កាលលោកលះបង់កិច្ចក្នុងវិបស្សនា បែរមុខឆ្ពោះទៅក្នុងការធ្វើរាងកាយឲ្យរឹងមាំ អាស្រ័យអយោនិសោមនសិការ និងការបណ្តោតបណ្តោយស្មារតី កិលេសរមែងកើតឡើង កាលបើដូច្នេះ កិលេសដែលមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង ។

ភិក្ខុរូបខ្លះ ជាអ្នកប្រកបការងារនវកម្ម ធ្វើរោងឧបោសថ និងរោងឆាន់ជាដើម កាលលោកកំពុងគិតដល់គ្រឿងឧបករណ៍របស់រោងឧបោសថជាដើមនោះ កិលេសរមែងមិនបានឱកាស ចំណេរតមក កាលការងារនវកម្មរបស់លោកសម្រេចហើយ ឬលោកលះបង់ចោល អាស្រ័យអយោនិសោមនសិការ និងការបណ្តោតបណ្តោយស្មារតី កិលេសក៏កើតឡើង កាលបើដូច្នេះ កិលេសដែលមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ឈ្មោះថា រមែងកើតឡើង ។

មួយវិញទៀត ភិក្ខុរូបខ្លះ ចុតិមកអំពីព្រហ្មលោក ជាសត្វបរិសុទ្ធ ព្រោះខ្លួនមិនមានការស្និទ្ធស្នាលមកអំពីមុន ទើបកិលេសមិនបានឱកាស តែចំណេរតមក បានការសេព អាស្រ័យអយោនិសោមនសិការ និងការបណ្តោតបណ្តោយស្មារតី កិលេសរមែងកើតឡើង កាលបើដូច្នេះ កិលេសដែលមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយឡើង ក៏ឈ្មោះថា រមែងកើតឡើង គប្បីជ្រាបការកើតឡើងនៃកិលេស ដែលមិនទាន់កើតឡើង ព្រោះមិនទាន់ផ្សាយ

ឡើង ដោយប្រការដូច្នេះសិន ។

កិលេសដែលកើតឡើង ព្រោះអារម្មណ៍ដែលមិនធ្លាប់សោយដូចម្ដេច ភិក្ខុរូបខ្លះ រមែងបានអារម្មណ៍ មានរូបារម្មណ៍ដែលគួរពេញចិត្ត និងមិនគួរពេញចិត្តជាដើម ដែលខ្លួនធ្លាប់បានសោយ អាស្រ័យអយោនិសោមនសិការ និងការបណ្តែតបណ្តោយស្មារតីទៅក្នុងអារម្មណ៍នោះ រាគៈរមែងកើតឡើងដល់ភិក្ខុនោះ កាលបើដូច្នេះ កិលេសដែលមិនទាន់កើត ព្រោះអារម្មណ៍ដែលមិនធ្លាប់សោយ ឈ្មោះថា រមែងកើតឡើង ។

បទថា **ឧប្បន្នោ** បានដល់ កើតហើយ កើតព្រមហើយ កើតឡើងហើយ កើតឡើងក្រៃលែងហើយ ប្រាកដហើយ ។ បទថា **ភិយ្យោភាវាយ** បានដល់ ដើម្បីកើតមានរឿយៗ ។ បទថា **វេបុល្លាយ** បានដល់ ដើម្បីវិសាលភាព គឺដើម្បីភាពជាគំនរ ។ ក្នុងសេចក្តីនោះ សេចក្តីដែលថា កាមច្ឆន្ទៈកើតឡើងម្តង នឹងមិនរលត់ ឬរលត់ទៅតែម្តង នឹងមិនកើតឡើងទៀត ទុំះមិនមែនឋានៈដែលនឹងមានបាន ។ កាលកាមច្ឆន្ទៈឯណាមួយរលត់ទៅហើយ កាមច្ឆន្ទៈ កាលកើតបន្តៗ ទៅក្នុងអារម្មណ៍នោះ ឬអារម្មណ៍ឯណានីមួយ ឈ្មោះថា រមែងប្រព្រឹត្តទៅដើម្បីមានក្រៃលែងឡើង ដើម្បីការចម្រើនលូតលាស់ ។

បទថា **សុភនិមិត្តំ** បានដល់ អារម្មណ៍ដែលជាទីតាំងនៃរាគៈ ពិតហើយ បទថា **និមិត្តំ** ជាឈ្មោះនៃបច្ច័យ បានក្នុងប្រយោគនេះថា **សនិមិត្តា ភិក្ខវេ ឧប្បជ្ជន្តិ បាបកា អកុសលា ធម្មា នោ អនិមិត្តា** ។ ម្នាលភិក្ខុទាំង-

ឡាយ អកុសលធម៌ដ៏លាមកទាំងឡាយប្រកបដោយនិមិត្ត ( ហេតុ ) ទើបកើតឡើងបាន មិនមែនឥតនិមិត្តទេ ។ បទថា **និមិត្តំ** ជាឈ្មោះនៃហេតុ បានក្នុងប្រយោគនេះថា **អធិចិត្តមនុយុត្តេន ភិក្ខវេ ភិក្ខុនា បញ្ច និមិត្តានិ កាលេន កាលំ មនសិកាតព្វានិ** ព្រះមានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គឺសមាបត្តិ ៨ ហើយគប្បីធ្វើទុកក្នុងចិត្តនូវហេតុទាំង ៥ ប្រការសព្វៗ កាល ។ បទថា **និមិត្តំ** ជាឈ្មោះនៃសមាធិ បានក្នុងប្រយោគនេះថា **សោ តំ និមិត្តំ អាសេវតិ ភាវេតិ** សេចក្តីថា ភិក្ខុនោះរមែងសេព រមែងចម្រើនសមាធិនោះ ។ បទថា **និមិត្តំ** ជាឈ្មោះនៃវិបស្សនា បានក្នុងប្រយោគនេះថា **យំ និមិត្តំ អាគម្ម យំ និមិត្តំ មនសិករោតោ អនន្តរា អាសវានំ ខយោ ហោតិ** ( សម័យណាភិក្ខុ ) មិនដឹង មិនឃើញនូវនិមិត្ត ដែលខ្លួនអាស្រ័យនិមិត្តណា ធ្វើទុកក្នុងចិត្តនូវនិមិត្តណាហើយ អស់អាសវៈទាំងឡាយ ។ តែក្នុងទីនេះ ធម៌ដែលជាឥដ្ឋារម្មណ៍ ដែលជាទីតាំងនៃរាគៈ លោកបំណងយកសុភនិមិត្ត ។

បទថា **អយោនិសោមនសិករោតោ** សេចក្តីថា កាលភិក្ខុដាក់ចិត្តដោយអយោនិសោមនសិការ ដោយអំណាចការដាក់ចិត្តយ៉ាងនេះថា បណ្តាធម៌ទាំងនោះ ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ តើដូចម្តេច ។ ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ក្នុងរបស់ដែលមិនទៀង ថាទៀង ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ក្នុងរបស់ដែលជាទុក្ខ ថាសុខ ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ក្នុងរបស់ដែលមិនមែនខ្លួន ថាខ្លួន ការធ្វើទុកក្នុងចិត្តដោយខុស

ឧបាយ ក្នុងរបស់មិនស្អាត ថាស្អាត មួយទៀត ការរំពឹង ការរំពឹងរឿយៗ ការផ្គងចិត្តទុក ការតម្រង់ចិត្តទុក ការធ្វើទុកក្នុងចិត្ត ដោយខុសចាកសច្ចៈ នេះហៅថា ការធ្វើទុកក្នុងចិត្តដោយខុសឧបាយ ។

## អដ្ឋកថាសូត្រទី ១ ចប់

# អដ្ឋកថាសូត្រទី ២

[ ១៣ ] ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ព្យាបាទោ** ការវិបត្តិ ព្រោះលះប្រក្រតីនៃចិត្ត ដូចការវិបត្តិនៃអាហារ គឺអាហារផ្អូម ។ បទថា **ព្យាបាទោ** នេះជាឈ្មោះនៃព្យាបាទនីវរណៈ ដែលពោលពិស្តារហើយយ៉ាងនេះថា ក្នុងនីវរណៈទាំងនោះ ព្យាបាទនីវរណៈដូចម្តេច គឺការអាឃាតកើតឡើងថា បុគ្គលនេះ បានធ្វើសេចក្តីវិនាសដល់អញ ។

បទថា **បដិឃនិមិត្តំ** បានដល់ និមិត្តដែលមិនគួរប្រាថ្នា ។ ពាក្យថា **បដិឃនិមិត្តំ** នេះ ជាឈ្មោះនៃបដិឃចិត្ត គឺការអាក់អន់ក៏មាន ជាឈ្មោះនៃអារម្មណ៍ដែលធ្វើឲ្យអាក់អន់ក៏មាន សមដូចពាក្យដែលព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាថា បដិឃចិត្ត ក៏ឈ្មោះថា បដិឃនិមិត្ត ធម៌ដែលជាអារម្មណ៍របស់បដិឃចិត្ត ក៏ឈ្មោះថា បដិឃនិមិត្ត ពាក្យដ៏សេសក្នុងទីនេះ គប្បីជ្រាបដោយន័យដែលពោលក្នុងកាមច្ឆន្ទៈនោះឯង ។ ក្នុងបដិឃនីវរណៈនេះ យ៉ាងណា សូម្បីក្នុងនីវរណៈដទៃអំពីនេះក៏យ៉ាងនោះ ។ ក្នុងសូត្រនោះៗ ខ្ញុំនឹងពោលត្រឹមតែសេចក្តីប្លែកគ្នាប៉ុណ្ណោះ ។

**អដ្ឋកថាសូត្រទី ២ ចប់**

# អដ្ឋកថាសូត្រទី ៣

[ ១៤ ] ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ថីនមិទ្ធំ** បានដល់ ថីនៈ និងមិទ្ធៈ ក្នុងធម៌ ២ យ៉ាងនោះ ភាវៈដែលចិត្តមិនសមគួរដល់ការងារ ឈ្មោះថា **ថីន** ពាក្យថា **មិទ្ធ** នេះ ជាឈ្មោះនៃការខ្ជិលច្រអូស ។ ភាវៈដែលខន្ធទាំង ៣ មិនគួរដល់ការងារ ឈ្មោះថា **មិទ្ធ** ។ ពាក្យថា **មិទ្ធ** នេះ ជាឈ្មោះនៃការងោកងុយ ដូចការងោកងុយរបស់ស្វាជាធម្មជាតមិនហ្នឹងហ្ន ។ គប្បីជ្រាបសេចក្តីពិស្តារនៃថីនៈ និងមិទ្ធៈ ទាំង ២ នោះ ដោយន័យជាដើមថា បណ្តានីវរណៈទាំងនោះ ថីនមិទ្ធនីវរណៈ តើដូចម្តេច ។ ថីនៈ ( សេចក្តីធុញទ្រាន់ ) ក៏មាន មិទ្ធៈ ( សេចក្តីងោកងក់ ) ក៏មាន ។ បណ្តាធម៌ទាំងនោះ ថីនៈ តើដូចម្តេច ។ ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារ ការជ្រប់នៅ ការសម្ងំនៅ សេចក្តីរួញរា អាការរួញរា ភាពរួញរា សេចក្តីធុញទ្រាន់ ការធុញទ្រាន់ ភាពធុញទ្រាន់ឯណានៃចិត្ត នេះហៅថា **ថីន** ។ បណ្តាធម៌ទាំងនោះ **មិទ្ធ** តើដូចម្តេច ។ ភាពមិនឈ្លាសវៃ ភាពមិនគួរដល់ការងារ ការជ្រប់ ការស្រពោន ការងងឹតឈ្ងប់ខាងក្នុង ការងោកងក់ ការសុបសៅ អាការយឺតភ្លឹះៗ សេចក្តីសុបសៅ អាការសុបសៅ ភាពសុបសៅឯណានៃកាយ នេះហៅថា **មិទ្ធ** ។

បទថា **អរតិ** ជាដើម គប្បីជ្រាបដោយន័យដែលចែកទុកក្នុងវិភង្គនោះឯង សមដូចពាក្យដែលលោកពោលថា បណ្តាធម៌ទាំងនោះ សេចក្តីមិនត្រេកអរ តើដូចម្តេច ។ ការមិនត្រេកអរ អាការមិនត្រេកអរ សេចក្តីមិនត្រេកអរចំពោះ អាការមិនត្រេកអរចំពោះ ការអផ្សុក សេចក្តីសោប់សល់

ក្នុងសេនាសនៈដ៏ស្ងាត់ក្តី ក្នុងធម៌ទាំងឡាយ ជាកុសលដ៏លើសលុបឯណា នីមួយក្តី នេះហៅថា សេចក្តីមិនត្រេកអរ ។ បណ្តាធម៌ទាំងនោះ **តន្ទិ** តើដូចម្តេច ។ ការប្រអូស អាការប្រអូស សេចក្តីប្រអូសនៃចិត្ត ការខ្ជិល អាការខ្ជិល ភាពនៃសេចក្តីខ្ជិលឯណា នេះហៅថា សេចក្តីខ្ជិលប្រអូស ។ បណ្តាធម៌ទាំងនោះ **វិជម្ភិកា** តើដូចម្តេច ។ ការមីតពត់ ការមីតពត់រឿយៗ ការមីតពត់ទៅមុខ ការមីតពត់ទៅក្រោយ ការមីតពត់ជុំវិញ ការមីតពត់ឲ្យត្រង់ ការឈឺចាប់នៃកាយឯណា នេះហៅថា សេចក្តីមីតពត់ ។ បណ្តាធម៌ទាំងនោះ **ភត្តសម្មទោ** តើដូចម្តេច ។ បុគ្គលអ្នកបរិភោគ មានសេចក្តីជ្រប់ព្រោះភត្ត មានសេចក្តីលំបាក ព្រោះភត្ត មានសេចក្តីហេលហល់ ព្រោះភត្ត មានភាពនៃកាយមិនគួរដល់ការងារ ( ព្រោះអាស្រ័យភត្ត ) ឯណា នេះហៅថា សេចក្តីស្រវឹងព្រោះភត្ត ។ បណ្តាធម៌ទាំងនោះ **ចេតសោ លីនត្តំ** តើដូចម្តេច ។ ភាពនៃចិត្តមិនគួរ ភាពនៃចិត្តមិនគួរដល់ការងារ ការរួញថយ ការរួញចូល ការលីប-ល អាការលីប-ល ភាពនៃសេចក្តីលីប-ល ការក្រាញនៅ អាការក្រាញនៅ ភាពនៃសេចក្តីក្រាញនៅនៃចិត្តឯណា នេះហៅថា ភាពនៃចិត្តរួញរា ។ បណ្តាធម៌ទាំងនេះ ធម៌ ៤ ខាងដើម ជាបច្ច័យដល់ថីនមិទ្ធនីវរណៈ ដោយសហជាតបច្ច័យផង ដោយឧបនិស្សយបច្ច័យផងម្យ៉ាងទៀត ភាវៈដែលរួញរា រមែងមិនជាសហជាតបច្ច័យដោយខ្លួនរបស់ខ្លួនឯង តែរមែងជាសហជាតបច្ច័យក្នុងទីបំផុតនៃឧបនិស្សយបច្ច័យ ។

**អដ្ឋកថាសូត្រទី ៣ ចប់**

# អដ្ឋកថាសូត្រទី ៨

[ ១៥ ] ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ឧទ្ធច្ចកុក្កុច្ចំ** បានដល់ ឧទ្ធច្ចៈ និងកុក្កុច្ចៈ ។ ក្នុងធម៌ទាំង ២ យ៉ាងនោះ អាការដែលចិត្តរាយមាយ ឈ្មោះថា ឧទ្ធច្ចៈ ការក្តៅក្រហាយរបស់បុគ្គលដែលមិនបានធ្វើគុណ គឺសេចក្តីល្អ ធ្វើតែបាប ព្រោះសេចក្តីនោះជាបច្ច័យ ឈ្មោះថា កុក្កុច្ចៈ ។ បទថា **ចេតសោ អវូបសមោ** នេះ ជាឈ្មោះនៃឧទ្ធច្ចៈ និងកុក្កុច្ចៈនោះឯង ។ បទថា **អវូបសន្តចិត្តស្ស** បានដល់ បុគ្គលមានចិត្តមិនស្ងប់ ដោយឈាននិងវិបស្សនា ការមិនស្ងប់នេះជាបច្ច័យដល់ឧទ្ធច្ចៈ និងកុក្កុច្ចៈ ក្នុងទីបំផុតនៃឧបនិស្សយប្បច្ច័យ ។

## អដ្ឋកថាសូត្រទី ៨ ចប់

# អដ្ឋកថាសូត្រទី ៥

[ ១៦ ] *ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ បទថា* **វិចិកិច្ឆា** *បានដល់ វិចិកិច្ឆានីវរណៈដែលពោលពិស្តារហើយ ដោយន័យជាដើមថា រមែងសង្ស័យក្នុងព្រះសាស្ដា ការដាក់ចិត្តដោយ មិនជាឧបាយ មានលក្ខណៈដូចពោល ហើយនោះឯង ។*

## អដ្ឋកថាសូត្រទី ៥ ចប់

# អដ្ឋកថា សូត្រទី ៦

[ ១៧ ] ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អនុប្បន្នោ វា កាមច្ឆន្ទោ ឧប្បជ្ជតិ** សេចក្តីថា កាមច្ឆន្ទៈដែលមិនកើតឡើងដោយហេតុ ២ យ៉ាងប៉ុណ្ណោះ គឺដោយការមិនផ្សាយឡើង ឬដោយអារម្មណ៍ដែលមិនធ្លាប់សោយ ក៏មិនកើតឡើង ។ កាមច្ឆន្ទៈនោះ ឈ្មោះថា ភិក្ខុសង្កត់បានហើយយ៉ាងនោះ រមែងមិនបានហេតុ ឬបច្ច័យទៀត ។ ក្នុងទីនេះ បណ្ឌិតគប្បីជ្រាបការមិនផ្សាយឡើង ដោយអំណាចវត្តជាដើម ។ ពិតហើយ កាលភិក្ខុរបខ្វះប្រកបក្នុងវត្ត ធ្វើវត្តនោះឯង ដោយន័យដូចពោលហើយ កិលេសរមែងមិនបានឱកាស ព្រោះដូច្នោះ កាមច្ឆន្ទៈនោះ ឈ្មោះថា ភិក្ខុសង្កត់បានដោយអំណាចវត្ត ភិក្ខុនោះធ្វើកាមច្ឆន្ទៈនោះ ឲ្យជាការដែលខ្ទប់សង្កត់បានយ៉ាងនោះ ហើយរៀរជាសមុច្ឆេទ រមែងទាញយកអរហត្តបាន ដូចព្រះមាលកតិស្សត្ថេរ ។

## រឿង ព្រះមាលកតិស្សត្ថេរ

បានឮថា ព្រះមាលកតិស្សៈ កើតក្នុងត្រកូលព្រាន ក្នុងទីភិក្ខាចារនៃគមេណ្ឌវាសីវិហារ ក្នុងរោហនជនបទ ចម្រើនវ័យហើយ ក៏គ្រប់គ្រងផ្ទះ គិតថា នឹងចិញ្ចឹមបុត្រ និងភរិយា ដាក់អន្ទាក់ ១០០ អន្ទាក់ ១០០ រណ្តៅចម្រូង ១០០ សន្សំបាបជាច្រើន ។ ថ្ងៃមួយ កាន់យកភ្លើង និងអំបិលអំពីផ្ទះទៅព្រៃ សម្លាប់ម្រឹគដែលជាប់អន្ទាក់ ស៊ីសាច់ដែលចម្អិនដោយរងើកភ្លើង ស្រេកទឹក ក៏ចូលទៅគមេណ្ឌវាសីវិហារ មិនបានផឹកទឹក សូម្បីត្រឹមតែបន្តយការស្រេក ឃ្លាន ក្នុងក្អមប្រមាណ ១០ ក្នុងរោងទឹក ក៏លើកទោសថា ឱ ! ក្នុងទីនេះ

ភិក្ខុមានប្រមាណប៉ុណ្ណោះ មិនមានទឹកផឹកត្រឹមតែបន្ទោបង់នូវការស្រេក សម្រាប់អ្នកមកបំណងនឹងផឹក ។ ព្រះចូឡបិណ្ឌបាតិកតិស្សត្ថេរ ស្ដាប់ពាក្យរបស់ព្រានហើយ ទើបចូលទៅរក ឃើញក្អមទឹកប្រមាណ ១០ ពេញដោយទឹកក្នុងរោងទឹក គិតថា សត្វនេះ ប្រហែលជាជីវមានកប្រេត ទើបពោលថា ឧបាសក បើអ្នកស្រេកទឹក ក៏ចូរផឹកចុះ ដូច្នេះហើយ លើកក្អមឡើង ចាក់ចូលត្រង់ដៃរបស់ព្រាន ។ ព្រោះអាស្រ័យកម្មរបស់ព្រាន ទឹកដែលផឹកហើយ ក៏ខ្សោះទៅ ដូចដាក់ចូលក្នុងអំបែងក្ដៅ កាលគាត់ផឹកទឹកក្នុងក្អមទាំងអស់ ការស្រេកមិនស្បើយ លំដាប់នោះ ទើបព្រះថេរៈពោលថា នែឧបាសក អ្នកធ្វើកម្មគ្រោតគ្រាតអ្វី ទើបកើតជាប្រេតក្នុងបច្ចុប្បន្ន វិបាកនឹងដូចម្ដេច ។

គាត់ស្ដាប់ពាក្យរបស់ព្រះថេរៈហើយ បានទូវសេចក្ដីសង្វេគ ថ្វាយបង្គំព្រះថេរៈ ហើយរើគ្រឿងប្រហារ មានអន្ទាក់ជាដើមនោះចោល ប្រញាប់ប្រញាល់ទៅកាន់ផ្ទះ ពិនិត្យមើលកូន និងភរិយា ហើយទម្លាយលំពែងចោល លែងម្រឹគ និងបក្សីក្នុងព្រៃ ត្រឡប់ទៅរកព្រះថេរៈ សូមបព្វជ្ជា ព្រះថេរៈពោលថា អាវុសោ បព្វជ្ជាជាកិច្ចធ្វើបានលំបាក អ្នកនឹងបួសបានដូចម្ដេច បុរសនោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំឃើញហេតុជាក់ច្បាស់យ៉ាងនេះ នឹងមិនបួសបានដូចម្ដេច ។ ព្រះថេរៈឲ្យតចបញ្ចកកម្មដ្ឋាន ហើយឲ្យគាត់បួស ។ លោកផ្ដើមវត្តបដិបត្តិ ត្រេកអរ រៀនយកពុទ្ធវចនៈ ។ ថ្ងៃមួយ បានស្ដាប់ឋានៈក្នុងទេវទូតសូត្រថា ម្នាលភិក្ខុទាំងឡាយ ពួកនាយនិរយបាល រមែងដាក់សត្វ

ដែលសោយនូវគំនរទុក្ខ មានប្រមាណប៉ុណ្ណោះ ចូលក្នុងមហានរកទៀត ទើបពោលថា នាយនិរយបាល ដាក់សត្វដែលសោយនូវគំនរទុក្ខ មានប្រមាណប៉ុណ្ណោះហើយ ចុះក្នុងមហានរកទៀត ឱ ! មហានរកធ្ងន់ហ្ន៎ ។ ព្រះថេរៈឆ្លើយថា អើ អាវុសោ ធ្ងន់មែនហើយ ។ សាមណេរនោះសួរថា ខ្ញុំអាចមើលឃើញបានឬទេ លោកម្ចាស់ ។ ព្រះថេរៈពោលថា អ្នកមិនអាចមើលឃើញទេ តែខ្ញុំនឹងបង្ហាញហេតុ ១ ដើម្បីធ្វើឲ្យដូចជាការមើលឃើញ ហើយពោលថា អ្នកចូរបបួលពួកសាមណេរធ្វើគំនរឈើស្រស់លើផែនថ្មចុះ លោកបានធ្វើយ៉ាងនោះ ។ ព្រះថេរៈអង្គុយដូចដើម សម្តែងឫទ្ធិនាំកម្ទេចភ្លើងប្រមាណប៉ុនអំពិលអំពែកអំពីមហានរក ដាក់ចូលទៅត្រង់គំនរឧសរបស់សាមណេរដែលកំពុងអង្គុយមើលនោះឯង គ្រាន់តែកំញមភ្លើងនរកធ្លាក់ទៅក្នុងគំនរឧសនោះឯង គំនរឧសក៏ឆេះជាផេះ ប្រាកដមិនមុន មិនក្រោយឡើយ ។

លោកឃើញហេតុនោះហើយ សួរថា បពិត្រលោកម្ចាស់ ឈ្មោះថាធុរៈ ក្នុងសាសនានេះមានប៉ុន្មាន ព្រះថេរៈឆ្លើយថា អាវុសោ មាន ២ គឺវាសធុរៈ និងគន្ថធុរៈ ។ លោកពោលថា បពិត្រលោកម្ចាស់ គន្ថធុរៈ ជាភារៈរបស់អ្នកប្រតិពល តែសទ្ធារបស់ខ្ញុំ អាស្រ័យទុក្ខជាហេតុ ខ្ញុំនឹងបំពេញវាសធុរៈ សូមលោកម្ចាស់ឲ្យកម្មដ្ឋានដល់ខ្ញុំចុះ ថ្វាយបង្គំហើយក៏អង្គុយ ព្រះថេរៈតាំងនៅក្នុងបដិបទា ដោយគិតថា កិក្ខុត្រូវតែជាអ្នកសម្បូរដោយវត្តហើយទើបប្រាប់កម្មដ្ឋានដល់លោក លោកទទួលកម្មដ្ឋានហើយ ធ្វើកម្មក្នុងវិបស្សនា និងបំពេញវត្ត ធ្វើវត្តត្រង់ចិត្តលបពិតមហាវិហារមួយថ្ងៃ ធ្វើត្រង់

គមេណ្ឌវាសីមហាវិហារមួយថ្ងៃ ធ្វើត្រង់គោចរគាមមហាវិហារមួយថ្ងៃ លុះថីនមិទ្ធៈគ្របសង្កត់ ទើបធ្វើស្លឹកឈើឲ្យសើមដោយទឹក ដាក់លើក្បាល អង្គុយយកជើងត្រាំទឹក ព្រោះខ្លាចវត្តវិនាស ថ្ងៃមួយ ធ្វើវត្តអស់ ២ យាម ត្រង់ចិត្តលបពិតវិហារ កាលផ្តើមនឹងដេកលក់ ក្នុងវេលាទៀបភ្លឺ ទើបអង្គុយដាក់ស្លឹកឈើស្រស់លើក្បាល កាលសាមណេរកំពុងទន្ទេញ អរុណវតិសូត្រ នាទិសខាងកើត បានឮបាទៈនេះថា

**អារភថ និក្ខមថ យុញ្ជថ ពុទ្ធសាសនេ**
**ធុនាថ មច្ចុនោ សេនំ នឡាគារំវ កុញ្ជរោ**
**យោ ឥមស្មឹ ធម្មវិនយេ អប្បមត្តោ វិហេស្សតិ**
**បហាយ ជាតិសំសារំ ទុក្ខស្សន្តំ ករិស្សតិ ។**

អ្នកទាំងឡាយ ចូរប្រារព្ធ ចូរប្រឹងប្រែង ចូរប្រកបព្យាយាម ក្នុងព្រះពុទ្ធសាសនា ចូរកម្ចាត់បង់សេនានៃមច្ចុ ដូចជាកុញ្ជរញាំញីផ្ទះបបុស អ្នកណាមិនប្រហែសក្នុងធម្មវិន័យនេះ អ្នកនោះនឹងលះបង់នូវជាតិសង្សារ ហើយធ្វើនូវទីបំផុតទុក្ខបាន ។

ទើបកើតបីតិឡើងថា ឱ ! ពាក្យនេះ ជាពាក្យដែលព្រះសម្មាសម្ពុទ្ធត្រាស់ប្រោសភិក្ខុ ដែលប្រារព្ធសេចក្តីព្យាយាម ដូចអាត្មាអញទេតើ ដូច្នេះហើយ ធ្វើឈានឲ្យកើតឡើង ធ្វើឈាននោះឯងឲ្យជាបាទហើយ តាំងនៅក្នុងអនាគាមិផល ព្យាយាមបន្តៗ ទៅ ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ ក្នុងវេលាបរិនិព្វាន កាលសម្តែងហេតុនោះឯង ទើបពោលគាថា

យ៉ាងនេះថា

**អល្លបលាស បុញ្ជាហំ សិរេនាទាយ ចង្កមិ**
**បត្តោស្មិ តតិយដ្ឋានំ ឆត្ថិ មេ ឯត្ថ សំសយោ**

ខ្ញុំយកក្បាលទូលស្លឹកឈើ មានសតិដើរចង្ក្រម ខ្ញុំជាអ្នកដល់ឋានៈទី ៣ ( អនាគាមិផល ) ខ្ញុំមិនមានសេចក្តីសង្ស័យក្នុងរឿងនេះឡើយ ។

កិលេសដែលសង្កត់ទុក ដោយអំណាចនៃវត្តរបស់ភិក្ខុបែបនេះ ឈ្មោះថា រមែងជាការសង្កត់យ៉ាងនោះឯង កាលភិក្ខុរូបខ្វះខ្វល់ខ្វាយក្នុងគន្ថៈ រៀនសម្តែង និងប្រកាសគន្ថៈ ដោយន័យដែលពោលហើយនោះឯង កិលេសរមែងមិនបានឱកាស ជាការសង្កត់បាន ដោយអំណាចគន្ថៈនោះឯង លោកធ្វើការលះកិលេសនោះ ឲ្យជាការសង្កត់សង្កិនបានយ៉ាងនោះឯង ប្រាសចាកតម្រេកបាន ហើយក៏ទាញយកអរហត្ត ដូចព្រះមាលយទេវត្ថេរ ដូច្នោះ ។

## រឿង ព្រះមាលយទេវត្ថេរ

បានឮថា ព្រះមាលយទេវត្ថេរមានអាយុនោះ រៀនឧទ្ទេស និងធ្វើវិបស្សនាកម្មដ្ឋាន ត្រង់មណ្ឌលារាមវិហារ ក្នុងកល្លគ្រាម ក្នុងវេលាជាភិក្ខុបាន ៣ វស្សា សម័យថ្ងៃមួយ កាលលោកត្រាច់ភិក្ខាចារក្នុងកល្លគ្រាម ឧបាសិកាម្នាក់ប្រគេនបបរមួយវែក កើតសេចក្តីស្រឡាញ់ដូចបុត្រ ឲ្យព្រះថេរៈអង្គុយក្នុងនិវេសន៍ ប្រគេនភោជនដ៏ប្រណីត ហើយសួរថា លោកកូនជាអ្នកស្រុកណា លោកឆ្លើយថា ឧបាសិកា អាត្មាធ្វើកិច្ចកម្ម គឺរៀនគន្ថៈក្នុង

មណ្ឌលារាមវិហារ ឧបាសិកាពោលថា បើដូច្នោះ សូមលោកម្ចាស់ ទទួលភិក្ខាជាប្រចាំក្នុងទីនេះឯង ដរាបណារៀនគន្ថៈចប់ ។ លោកទទួលពាក្យនោះហើយទទួលភិក្ខាក្នុងទីនោះជាប្រចាំ ក្នុងវេលាស្រេចភត្តកិច្ច កាលធ្វើអនុមោទនា ទើបពោលចំពោះបទ ២ ថា **សុខំ ហោតុ ទុក្ខា មុច្ចតុ** សូមនាងបានសុខ រួចចាកទុក្ខចុះ ហើយក៏ទៅធ្វើការសង្គ្រោះដល់នាងនោះឯង អស់កាល ៣ ខែ ខាងក្នុងវស្សា ធ្វើសេចក្ដីកោតក្រែងចំពោះបិណ្ឌបាត ក្នុងថ្ងៃមហាបវារណា ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ ព្រះមហាថេរៈដែលជាម្ចាស់អាវាសពោលថា នែមហាទេវៈ ថ្ងៃនេះ មហាជននឹងប្រជុំគ្នាក្នុងវិហារ សូមលោកម្ចាស់ឲ្យធម៌ដល់មហាជននោះ ព្រះថេរៈក៏ទទួល ។ ភិក្ខុកំលោះ និងសាមណេរបានឲ្យសញ្ញាដល់ឧបាសិកាថា ថ្ងៃនេះ កូនរបស់នាងនឹងសម្ដែងធម៌ នាងគប្បីទៅឯវិហារស្ដាប់ធម៌ចុះ ។ ឧបាសិកាពោលថា ឱ ! លោកម្ចាស់ទាំងឡាយ ជនទាំងអស់ មិនដឹងធម្មកថារបស់កូនខ្ញុំសម្ដែងដល់ខ្ញុំអស់កាលមានប្រមាណប៉ុណ្ណេះ សម្ដែងចំពោះបទ ២ ប៉ុណ្ណោះថា ចូរនាងមានសេចក្ដីសុខ រួចចាកទុក្ខចុះ សូមលោកម្ចាស់ កុំបំអកចំអន់ឡើយ ។ ភិក្ខុកំលោះ និងសាមណេរពោលថា ឧបាសិកា នាងដឹង ឬមិនដឹង ក៏ចូរទៅវិហារស្ដាប់ធម៌ប៉ុណ្ណោះបានហើយ ។ ឧបាសិកាកាន់យកសក្ការៈ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើមទៅបូជា ហើយអង្គុយស្ដាប់ធម៌ខាងចុងបរិស័ទ ព្រះធម្មកថិក និងភិក្ខុ ដែលសូធ្យសរភញ្ញនៅពេលថ្ងៃ ដឹងសេចក្ដីល្មមរបស់ខ្លួន ក៏ក្រោកត្រឡប់ទៅ ។ លំដាប់នោះ ព្រះមាលយទេវត្ថេរអង្គុយលើ

ធម្មាសនៈ ចាប់ផ្ចិតវាលវីជនី ពោលបុព្វកថា ហើយគិតថា អញនឹងធ្វើអនុមោទនាដល់មហាឧបាសិកា ដោយបទ ២ មកអស់កាល ៣ ខែ ថ្ងៃនេះ អញនឹងចាប់យកមាតិកាអំពីព្រះត្រៃបិដក ហើយពោលអត្ថនៃបទទាំង ២ អស់មួយយប់ ទើបផ្ដើមសម្ដែងធម្មទេសនាអស់រាត្រី ក្នុងវេលាចប់ទេសនាថ្ងៃរះឡើង មហាឧបាសិកាបានតាំងនៅក្នុងសោតាបត្តិផល ។

# រឿង ព្រះតិស្សភូតត្ថេរ

ព្រះថេរៈមួយរូបទៀត ឈ្មោះតិស្សភូតត្ថេរ ក្នុងវិហារនោះឯង រៀនព្រះវិន័យ ចូលទៅក្នុងស្រុក ក្នុងវេលាភិក្ខាចារ បានឃើញវិសភាគារម្មណ៍កើតលោភៈឡើង លោកធ្វើជើងដែលឈរយ៉ាងនោះមិនឲ្យកម្រើកទៅណា ចាក់បបរក្នុងបាត្ររបស់ខ្លួន ចូលក្នុងបាត្ររបស់ភិក្ខុកំលោះដែលជាឧបដ្ឋាក គិតថា វិតក្កនេះ កាលចម្រើនច្រើនឡើង នឹងធ្វើឲ្យអញលិចក្នុងអបាយ ៤ ទើបត្រឡប់អំពីទីនោះ ទៅកាន់សម្នាក់របស់អាចារ្យ ថ្វាយបង្គំហើយ ឈរនៅនាចំណែកសមគួរម្ខាង ពោលថា ព្យាធិឯណានីមួយកើតឡើងដល់ខ្ញុំហើយ ខ្ញុំមិនអាចព្យាបាលបាន ទើបមករកលោកម្ចាស់ មិនបានមកដោយរឿងដទៃឡើយ សូមលោកម្ចាស់ពិនិត្យមើលខ្ញុំ តាំងឧទ្ទេសពេលថ្ងៃ និងឧទ្ទេសពេលល្ងាច តែកុំតាំងឧទ្ទេសក្នុងវេលាទៀបភ្លឺឡើយ កាលពោលយ៉ាងនេះហើយ បានទៅកាន់សម្នាក់របស់ព្រះមលយវាសិមហារក្ខិតត្ថេរ ព្រះថេរៈកំពុងធ្វើរបងព័ទ្ធសាលាស្លឹករបស់ខ្លួន មិនបានមើលលោក ពោលថា អាវុសោ ចូរទុកបាត្រ និងចីវររបស់លោកចុះ ភិក្ខុនោះពោលថា បពិត្រ

លោកម្ចាស់ ខ្ញុំមានព្យាធិម្យ៉ាង បើលោកម្ចាស់អាចព្យាបាលបានសោត ទើបខ្ញុំទុកដាក់ ។ ព្រះថេរៈពោលថា អាវុសោ លោកមកកាន់សម្នាក់របស់ខ្ញុំដែលអាចព្យាបាលរោគ ដែលកើតឡើងហើយ ចូរលោកទុកដាក់សិនចុះ ។ ភិក្ខុជាអ្នកប្រដៅងាយគិតថា អាចារ្យរបស់ពួកយើង បើមិនដឹងគង់មិនពោលយ៉ាងនោះ ហើយដាក់បាត្រ និងចីវរ សម្ដែងវត្តដល់ព្រះថេរៈ ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះថេរៈដឹងថា បុគ្គលនេះជារាគចរិតទើបប្រាប់អសុភកម្មដ្ឋាន លោកក្រោកឡើង ពាក់បាត្រ និងចីវរលើស្មាថ្វាយបង្គំព្រះថេរៈហើយ ថ្វាយបង្គំទៀត ព្រះថេរៈសួរថា មហាកូតិ ហេតុអ្វីទើបលោកសម្ដែងអាការគោរពពន់ពេកយ៉ាងនេះ ។ លោកពោលថា បពិត្រលោកម្ចាស់ បើខ្ញុំធ្វើកិច្ចរបស់ខ្លួនបានសោត សេចក្ដីនោះជាការល្អ បើមិនបានការឃើញគ្រានេះ ជាការឃើញចុងក្រោយរបស់ខ្ញុំ ព្រះថេរៈពោលថា មហាកូតិ ទៅចុះ ឈានក្ដី វិបស្សនាក្ដី មគ្គក្ដី ផលក្ដី កុលបុត្រអ្នកប្រកបព្យាយាម ដូច្នោះ បានមិនលំបាកឡើយ ភិក្ខុនោះស្ដាប់ពាក្យរបស់ព្រះថេរៈសម្ដែងអាការឱនលំទោនហើយ ទៅកាន់គល់ធ្លកដែលមានម្លប់ត្រឈៃ ដែលខ្លួនកំណត់ទុកក្នុងកាលមក អង្គុយពត់ភ្នែន ធ្វើអសុភកម្មដ្ឋានឲ្យជាបាទ ផ្ដើមតាំងវិបស្សនា តាំងនៅក្នុងអរហត្ត ទាន់សម្ដែងបាតិមោក្ខក្នុងវេលាទៀបភ្លឺ ភិក្ខុបែបនេះសង្កត់កិលេសបានដោយអំណាចគន្ទៈ ឈ្មោះថា សង្កត់បានដោយប្រការនោះដូចគ្នា ។

កាលភិក្ខុរបខ្លះបរិហារធុតង្គដូចពោលហើយនោះឯង កិលេសរមែងមិន

បានឱកាស កិលេសនោះ ឈ្មោះថា លោកសង្កត់បានដោយអំណាចធុតង្គ លោកធ្វើកិលេសនោះឲ្យជាការសង្កត់បានហើយនោះឯង ប្រាសចាកតម្រេកបាន ហើយទាញយកអរហត្តបាន ដូចព្រះមហាសិវត្ថេរ នៅត្រង់ញកក្នុងក្បែរស្រុក ។

# រឿងព្រះមហាសិវត្ថេរ

បានឮថា ព្រះមហាសិវត្ថេរ នៅក្នុងតិស្សមហាវិហារ ក្បែរមហាគាម បង្រៀនព្រះត្រៃបិដកជាមួយគណៈភិក្ខុធំ ១៨ គណៈ ដោយអត្ថផង ដោយបាលីផង ភិក្ខុ ៦០០០០ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ សម្រេចអរហត្តហើយ ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុមួយរូបប្រារព្ធធម៌ដែលខ្លួនបានចាក់ធ្លុះ ហើយកើតសោមនស្សឡើង គិតថា សេចក្ដីសុខនេះ មានដល់អាចារ្យរបស់អញខ្លះដែរឬហ្ន៎ ភិក្ខុនោះ កាលពិចារណាក៏ដឹងថា ព្រះថេរៈនៅជាបុថុជ្ជន គិតថា អញនឹងឲ្យសេចក្ដីសង្វេគកើតឡើងដល់ព្រះថេរៈ ដោយឧបាយនេះ ទើបចេញអំពីលំនៅរបស់ខ្លួន ទៅកាន់សម្នាក់របស់ព្រះថេរៈ ថ្វាយបង្គំ សំម្ដែងវត្ត ហើយអង្គុយ ។ លំដាប់នោះ ព្រះថេរៈពោលនឹងភិក្ខុនោះថា លោកម្ចាស់បិណ្ឌបាតិកមកធ្វើអ្វី ភិក្ខុនោះពោលថា បពិត្រលោកម្ចាស់ ខ្ញុំមកបំណងថា បើលោកម្ចាស់ធ្វើឱកាសដល់ខ្ញុំ ខ្ញុំក៏នឹងរៀនធម្មបទនីមួយៗ ។ ព្រះថេរៈពោលថា អាវុសោ ភិក្ខុដែលជាអ្នករៀនមានច្រើន លោកម្ចាស់មិនមានឱកាសទេ ភិក្ខុនោះ កាលមិនបានឱកាសក្នុងពេលយប់ និងពេលថ្ងៃ ទើបពោលថា បើឱកាសមិនមានយ៉ាងនោះ លោកម្ចាស់នឹងបានឱកាសមរណៈដូចម្ដេច ។ ពេល

នោះ ព្រះថេរៈគិតថា ភិក្ខុនេះមិនមកដើម្បីរៀនឧទ្ទេសទេ តែមកដើម្បីធ្វើសេចក្តីសង្វេគឲ្យកើតដល់អាត្មាអញ សូម្បីភិក្ខុនោះពោលថា បពិត្រលោកម្ចាស់ ធម្មតាភិក្ខុគប្បីជាបុគ្គលដូចខ្ញុំ ដូច្នេះហើយ ថ្វាយបង្គំព្រះថេរៈ ហោះទៅក្នុងអាកាស ដែលមានពណ៌ដូចកែវមណី ។

ព្រះថេរៈកើតការសង្វេគ តាំងអំពីកាលដែលភិក្ខុនោះទៅហើយ ប្រាប់ឧទ្ទេសពេលថ្ងៃ និងពេលល្ងាច ដាក់បាត្រ និងចីវរក្បែរហត្ថបាស ក្នុងវេលាជិតភ្លឺ ទើបរៀនឧទ្ទេស កាន់បាត្រ និងចីវរទៅជាមួយភិក្ខុដែលកំពុងចុះទៅអធិដ្ឋានធុតង្គគុណ ១៣ ឲ្យបរិបូណ៌ហើយ ទៅកាន់សេនាសនៈត្រង់ញកភ្នំក្បែរស្រុក បោសញកភ្នំ ហើយរៀបគ្រែ និងតាំង ចងចិត្តថា បើអញមិនសម្រេចអរហត្ត នឹងមិនសណ្តូកខ្នងលើគ្រែ ទើបចុះកាន់ទីចង្ក្រម កាលព្យាយាមដោយតាំងចិត្តថា អញនឹងសម្រេចអរហត្តក្នុងថ្ងៃនេះ អញនឹងសម្រេចអរហត្តក្នុងថ្ងៃនេះ ថ្ងៃបវារណាក៏មកដល់ កាលជិតថ្ងៃបវារណាលោកគិតថា អញនឹងលះបង់ភាពជាបុថុជ្ជន បវារណាជាវិសុទ្ធិបវារណា ក៏លំបាកក្រៃលែង កាលលោកមិនអាចធ្វើមគ្គ ឬផលឲ្យកើតក្នុងថ្ងៃបវារណានោះបាន ទើបពោលថា បុគ្គលប្រារព្ធវិបស្សនាដូចអញ គង់មិនបានអរហត្តនេះ ជាគុណដែលបានលំបាកពិតហ្ន៎ ទើបជាអ្នកច្រើនទៅដោយការឈរ និងការដើរ ដោយទំនងនេះឯង ធ្វើសមណធម៌រហូត ៣០ ឆ្នាំ ឃើញព្រះចន្ទពេញវង់ អណ្តែតត្រង់តិថី ថ្ងៃមហាបវារណា គិតថា ព្រះចន្ទបរិសុទ្ធ ឬសីលរបស់អញបរិសុទ្ធ ក៏ពិចារណាបានថា ក្នុងមណ្ឌលព្រះចន្ទ ក៏គង់ប្រាកដមាន

លក្ខណៈជារូបទន្សាយ តែស្នាមខ្មៅ ឬពពាលក្នុងសីលរបស់អញ តាំងអំពីអញឧបសម្បទា រហូតដល់ឥឡូវនេះ មិនមាន កើតសោមនស្ស សង្កត់បីតិព្រោះមានញាណចាស់ក្លា សម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ភិក្ខុបែបនេះសង្កត់កិលេសបាន ដោយអំណាចធុតង្គ ដែលឈ្មោះថា សង្កត់កិលេសបានហើយ ដោយប្រការនោះឯង ។

ភិក្ខុរូបខ្លះ ច្រើនទៅដោយការចូលបឋមជ្ឈានជាដើម ដោយន័យដូចពោលហើយនោះឯង កិលេសរមែងមិនបានឱកាស ជាការសង្កត់សង្កិនបានដោយអំណាចសមាបត្តិ លោកធ្វើកិលេសឲ្យជាការសង្កត់សង្កិនបាន ដោយប្រការនោះឯង ។ ប្រាសចាកតម្រេកបានហើយ រមែងទាញយកអរហត្តបានដូចព្រះមហាតិស្សត្ថេរ ដូច្នោះ ។

## រឿង ព្រះមហាតិស្សត្ថេរ

បានឮថា ព្រះមហាតិស្សត្ថេរ បានសមាបត្តិ ៨ តាំងអំពីមានវស្សា ៨ លោកពោលធម៌បានប្រហាក់ប្រហែលអរិយមគ្គ ដោយអំណាចបរិយត្តិ និងបរិបុច្ឆា ព្រោះកិលេសត្រូវបានសង្កត់ដោយសមាបត្តិ មិនផ្សាយឡើង សូម្បីក្នុងកាលដែលលោកមានវស្សា ៦០ ក៏មិនដឹងខ្លួនថា នៅជាបុថុជ្ជន ។ សម័យថ្ងៃមួយ ភិក្ខុសង្ឃមកអំពីតិស្សមហាវិហារ ក្នុងស្រុកមហាគាម បានបញ្ជូនដំណឹងដល់ព្រះធម្មទិន្នត្ថេរ ដែលនៅឯត្នោរខ្សាច់ថា សូមព្រះថេរៈមកពោលធម្មកថាដល់ពួកខ្ញុំ ។ ព្រះថេរៈទទួលពាក្យហើយ គិតថា ភិក្ខុដែលចាស់ជាងមិនមានក្នុងសម្នាក់របស់អញ តែព្រះមហាតិស្សត្ថេរក៏ជាអាចារ្យ អ្នកប្រាប់កម្មដ្ឋានដល់អញ អញនឹងតាំងលោកឲ្យជាព្រះសង្ឃត្ថេរ ហើយនឹងទៅ ។

លោកដែលភិក្ខុសង្ឃប្រចាមរោមហើយ ទៅកាន់វិហាររបស់ព្រះថេរៈ សម្តែងវត្តដល់ព្រះថេរៈក្នុងទីសម្រាកពេលថ្ងៃហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ព្រះថេរៈពោលថា ធម្មទិន្ន លោកម្ចាស់មកយូរហើយឬ ព្រះធម្មទិន្នត្ថេរពោលថា បពិត្រលោកម្ចាស់ ភិក្ខុសង្ឃបញ្ជូនដំណឹងអំពីតិស្សមហាវិហារមកដល់ខ្ញុំ តែខ្ញុំម្នាក់ឯង ក៏នឹងមិនមក តែខ្ញុំនឹងទៅជាមួយលោកម្ចាស់ ទើបបានមក ។ លោកពោលសារាណីយកថា ឲ្យកាលវេលាកន្លងទៅយឺតៗ ហើយសួរថា លោកម្ចាស់ លោកម្ចាស់សម្រេចធម៌នេះពីអង្កាល់ណា ព្រះថេរៈពោលថា ធម្មទិន្ន ប្រមាណ ៦០ ឆ្នាំហើយ ។ ព្រះធម្មទិន្នត្ថេរពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ចេះប្រើសមាធិដែរឬ ព្រះថេរៈពោលថា ចេះលោកម្ចាស់ ព្រះធម្មទិន្នត្ថេរពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និម្មិតស្រះបោក្ខរណីមួយបានឬទេ ព្រះថេរៈពោលថា សេចក្តីនេះមិនជាភារៈធ្ងន់ឡើយ ហើយនិម្មិតស្រះបោក្ខរណីឡើងក្នុងទីចំពោះមុខ ។ លោកក៏ពោលបន្តថា សូមលោកម្ចាស់និម្មិតផ្កាឈូកមួយគុម្ពក្នុងស្រះនេះ ។ ព្រះថេរៈក៏និម្មិតផ្កាឈូកមួយគុម្ព ព្រះធម្មទិន្នត្ថេរពោលថា ឥឡូវនេះ សូមលោកម្ចាស់ធ្វើផ្កាឈូកធំក្នុងគុម្ពឈូកនេះ ព្រះថេរៈក៏និម្មិតផ្កានោះ ព្រះធម្មទិន្នពោលទៀតថា សូមលោកម្ចាស់និម្មិតរូបស្រី មានអាយុប្រមាណ ១៦ ឆ្នាំក្នុងផ្កានោះ លោកក៏និម្មិតរូបស្រីក្នុងផ្កានោះ ។ គ្រានោះ ព្រះធម្មទិន្នពោលនឹងព្រះថេរៈនោះថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ដាក់ចិត្តដល់រូបស្រីនោះរឿយៗ ដោយសុភសញ្ញាចុះ ។ ព្រះថេរៈសម្លឹងមើលរូបស្រីដែលខ្លួន

និម្មិត កើតតម្រេកឡើងក្នុងវេលានោះ ទើបដឹងខ្លួនថា នៅជាបុថុជ្ជន ទើបពោលថា បពិត្រសប្បុរស សូមលោកជាទីពឹងរបស់ខ្ញុំផងចុះ ហើយអង្គុយប្រហោងក្នុងសម្នាក់របស់អន្តេវាសិក ។ ព្រះធម្មទិន្នពោលថា បពិត្រលោកម្ចាស់ ខ្ញុំមកដើម្បីប្រយោជន៍នេះឯង ហើយប្រាប់កម្មដ្ឋានស្រាលៗ ទាក់ទងដោយអសុភដល់ព្រះថេរៈ ហើយចេញទៅខាងក្រៅ ដើម្បីឲ្យឱកាសដល់ព្រះថេរៈៗ ដែលមានសន្ធារបរិកម្មល្អហើយ គ្រាន់តែព្រះធម្មទិន្នចេញទៅអំពីទីសម្រាកពេលថ្ងៃប៉ុណ្ណោះ ក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា គ្រានោះ ព្រះធម្មទិន្នត្រូវធ្វើលោកឲ្យជាព្រះសង្ឃត្ថេរ ទៅកាន់មហាតិស្សវិហារ សម្តែងធម្មកថាដល់សង្ឃ កិលេសដែលព្រះថេរៈ មានសភាពបែបនោះសង្កត់សង្កិនហើយ ឈ្មោះថា សង្កត់ហើយ ដោយប្រការនោះឯង ។

តែសម្រាប់ភិក្ខុរូបខ្លះ ធ្វើវិបស្សនាកម្មដ្ឋានដោយន័យដូចពោលហើយនោះឯង កិលេសតែងមិនបានឱកាស ឈ្មោះថា សង្កត់សង្កិនកិលេសបានដោយអំណាចវិបស្សនានោះឯង ភិក្ខុនោះធ្វើកិលេសឲ្យជាការសង្កត់សង្កិនបានដោយប្រការដូច្នេះ ប្រាសចាកតម្រេកបានហើយ រមែងចាប់យកអរហត្តបាន ដូចភិក្ខុចម្រើនវិបស្សនាប្រមាណ ៦០ រូប ក្នុងសម័យពុទ្ធកាល ។

## រឿងភិក្ខុ ៦០ រូប

បានឮថា ភិក្ខុទាំងនោះទទួលព្រះកម្មដ្ឋាន ក្នុងសម្នាក់ព្រះសាស្តាហើយចូលទៅព្រៃដែលមានសភាពស្ងប់ស្ងាត់ ធ្វើកម្មក្នុងវិបស្សនា តែមិនធ្វើសេចក្តី

ព្យាយាមដើម្បីប្រយោជន៍ដល់មគ្គផល ដោយសម្គាល់ថា អញសម្រេចមគ្គផលហើយ ព្រោះកិលេសមិនផ្សាយឡើង គិតថា អញនឹងក្រាបទូលដល់ធម៌ដែលអញសម្រេចហើយ ដល់ព្រះទសពល ទើបមកគាល់ព្រះសាស្ដា តែមុនភិក្ខុទាំងនោះមកដល់ ព្រះសាស្ដាបានត្រាស់នឹងព្រះអានន្ទថា អានន្ទ ភិក្ខុបំពេញព្យាយាមនឹងមកជួបតថាគតក្នុងថ្ងៃនេះ អ្នកកុំឲ្យឱកាសដល់ភិក្ខុទាំងនោះ ដើម្បីជួបតថាគត គប្បីបញ្ជូនទៅថា សូមពួកលោកទៅកាន់ព្រៃខ្មោច ដែលចោលសពស្រស់ ធ្វើភាវនាអសុភស្រស់ចុះ ។ ព្រះថេរៈប្រាប់ដំណឹងដែលព្រះសាស្ដាបញ្ជូនដល់ភិក្ខុទាំងនោះដែលមកហើយ ភិក្ខុទាំងនោះគិតថា ព្រះតថាគត បើទ្រង់មិនជ្រាប គង់មិនមានព្រះតម្រាស់ ប្រហែលជាមានហេតុក្នុងសេចក្ដីនេះដោយពិត ដូច្នេះហើយ ទើបទៅកាន់ព្រៃខ្មោចស្រស់ សម្លឹងអសុភស្រស់ ក៏កើតតម្រេកឡើង កើតនូវសង្វេគឡើងថា ឱ ! សេចក្ដីនេះ ព្រះសម្មាសម្ពុទ្ធគង់ទ្រង់ឃើញហើយពិត ទើបផ្ដើមកម្មដ្ឋាន តាមដែលខ្ទង់តម្កល់ទុកអំពីដើម ព្រះសាស្ដាទ្រង់ជ្រាបថា ភិក្ខុទាំងនោះផ្ដើមវិបស្សនា ប្រថាប់គង់ត្រង់ព្រះគន្ធកុដិនោះឯង បញ្ចេញឱកាស ត្រាស់គាថាថា

**យានិមានិ អបត្ថានិ អលាពូនេវ សារទេ**
**កាបោតកានិ អដ្ឋីនិ តានិ ទិស្វាន កា រតិ ។**

ឆ្អឹងទាំងឡាយណា មានសម្បុរដូចសត្វព្រាប ដែលគេចោលហើយ ដូចផ្លែឃ្លោកក្នុងសរទកាល សេចក្ដីត្រេកអរអ្វីហ្ន៎ (របស់អ្នកទាំងឡាយ) ព្រោះតែឃើញឆ្អឹងទាំងឡាយនោះ ។

ក្នុងវេលាចប់គាថា ភិក្ខុទាំងនោះ តាំងនៅក្នុងអរហត្តផល ភិក្ខុដែលមានសភាពបែបនេះ សង្កត់កិលេសបានហើយដោយអំណាចនៃវិបស្សនា ឈ្មោះថា សង្កត់បានហើយ ដោយប្រការនោះឯង ។

កាលភិក្ខុរូបខ្លះធ្វើនវកម្ម ដោយន័យដូចពោលហើយនោះឯង កិលេសរមែងមិនបានឱកាស ឈ្មោះថា លោកសង្កត់កិលេសបាន ដោយអំណាចនវកម្ម លោកធ្វើកិលេសទាំងនោះ ឲ្យជាការសង្កត់សង្កិនទុកហើយយ៉ាងនោះ ប្រាសចាកតម្រេកបានហើយ រមែងទាញយកព្រះអរហត្តបាន ដូចព្រះតិស្សៈក្នុងចិត្តលបព៌ត ដូច្នោះ ។

## រឿង ព្រះតិស្សៈក្នុងចិត្តលបព៌ត

បានឮថា ក្នុងវេលាដែលព្រះតិស្សត្ថេរ បួសបាន ៨ វស្សា កើតការចង់សឹក លោកមិនអាចបន្ទោបង់ការចង់សឹកនោះបាន បោកគក់ចីវរ គោរសក់ហើយ ថ្វាយបង្គំព្រះឧបជ្ឈាយ៍ ហើយឈរ លំដាប់នោះ ព្រះថេរៈពោលនឹងលោកថា មហាតិស្សៈ អាការរបស់លោក ដូចជាមិនត្រេកអរឬ ភិក្ខុនោះឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំចង់សឹក ខ្ញុំបន្ទោបង់មិនបានសោះ ព្រះថេរៈសម្លឹងមើលអធ្យាស្រ័យរបស់លោក ឃើញឧបនិស្ស័យអរហត្ត ទើបពោលដោយករុណាថា អាវុសោ ខ្ញុំជាមនុស្សចាស់ ចូរលោកធ្វើលំនៅសម្រាប់ខ្ញុំមួយខ្នង ។ ភិក្ខុមិនធ្លាប់ត្រូវបុគ្គលណានិយាយជាគម្រប់ ២ ទើបទទួលថា សាធុ លោកម្ចាស់ ។ លំដាប់នោះ ព្រះថេរៈពោលនឹងភិក្ខុទាំង-ឡាយថា អាវុសោ កាលអ្នកកំពុងធ្វើនវកម្ម ក៏កុំលះឧទ្ទេសបូរមនសិការ-

កម្មដ្ឋាន និងចូរធ្វើបរិកម្មកសិណតាមកាលដ៏សមគួរ ភិក្ខុនោះពោលថា ខ្ញុំនឹងធ្វើយ៉ាងនោះ លោកម្ចាស់ ថ្វាយបង្គំព្រះថេរៈហើយ សម្លឹងមើលទីញកភ្នំដែលមានសភាពបែបនោះ គិតថា ត្រង់នេះធ្វើបាន ទើបនាំឧសមកដុតជម្រះឲ្យស្អាត កឥដ្ឋ ប្រកបទ្វារ និងបង្អួច ធ្វើទីសម្រាកស្រេច កឥដ្ឋលើទីចង្ក្រមជាដើម រួចរៀបចំគ្រែ និងតាំងទុក ទៅកាន់សម្នាក់ព្រះថេរៈ ថ្វាយបង្គំហើយពោលថា បពិត្រលោកម្ចាស់ ទីសម្រាកស្រេចហើយ សូមលោកម្ចាស់នៅចុះ ព្រះថេរៈពោលថា អាវុសោ លោកធ្វើការងារនេះបានដោយលំបាកថ្ងៃនេះ ចូរនៅក្នុងទីនេះមួយថ្ងៃសិនចុះ ភិក្ខុនោះពោលថា សាធុ លោកម្ចាស់លាងជើងហើយ ចូលទៅកាន់ទីសម្ងំ អង្គុយសមាធិ រឭកដល់កម្មដែលខ្លួនធ្វើ កាលលោកគិតថា ការធ្វើការខ្វល់ខ្វាយដោយកាយ ដែលជាទីត្រូវចិត្តអញធ្វើដល់ព្រះឧបជ្ឈាយ៍ហើយ បីតិកើតឡើងខាងក្នុង លោកសង្កត់បីតិនោះបានហើយ ចម្រើនវិបស្សនា ក៏សម្រេចអរហត្ត ដែលជាអគ្គផល ភិក្ខុបែបនេះ សង្កត់សង្កិនកិលេសបាន ដោយអំណាចនវកម្ម ឈ្មោះថា លោកសង្កត់បានហើយ ដោយប្រការនោះដូចគ្នា ។

ឯភិក្ខុរូបខ្លះ មកអំពីព្រហ្មលោក ជាសត្វបរិសុទ្ធ កិលេសមិនផ្សាយឡើង ព្រោះលោកមិនមានអាសេវនៈ ដែលឈ្មោះថា លោកសង្កត់បានដោយអំណាចភព លោកកាត់ផ្តាច់កិលេសនោះ ដែលសង្កត់បានហើយ ដោយប្រការនោះ ទាញយកអរហត្តបាន ដូចព្រះមហាកស្សប ដូច្នោះ ។

ពិតហើយ ព្រះមហាកស្សបនោះ មិនបរិភោគកាម ទាំងដែលនៅគ្រប់

គ្រងផ្ទះ លះសម្បត្តិធំ ចេញបួស ព្រះសាស្តាយាងមក ដើម្បីទទួលក្នុងចន្លោះផ្លូវ ថ្វាយបង្គំហើយ បានឧបសម្បទាដោយឱវាទ ៣ សម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ក្នុងអរុណទី ៨ ភិក្ខុបែបនេះសង្កត់កិលេសបានដោយអំណាចកត ឈ្មោះថា សង្កត់កិលេសបានយ៉ាងនោះឯង ។

ម្យ៉ាងទៀត ភិក្ខុណាបានអារម្មណ៍ មានរូបជាដើម ដែលមិនធ្លាប់បានសោយ ផ្តើមចម្រើនវិបស្សនាក្នុងអារម្មណ៍នោះឯង ប្រាសចាកតម្រេកបានហើយ រមែងទាញយកអរហត្តបាន កាមច្ឆន្ទៈដែលមិនកើតឡើង ដោយអំណាចអារម្មណ៍ដែលមិនធ្លាប់សោយ ក៏ឈ្មោះថា មិនកើតឡើងដល់ភិក្ខុបែបនេះ ។

បទថា **ឧប្បន្នោ** ក្នុងបទថា **ឧប្បន្នោ វា កាមច្ឆន្ទោ បហីយតិ** នេះ បានដល់ កើតហើយ មានហើយ ផ្សាយឡើងហើយ ។

បទថា **បហីយតិ** សេចក្តីថា លោកលះបានដោយបហានទាំង ៥ នេះ គឺតទង្គប្បហាន វិក្ខម្ភនប្បហាន សមុច្ឆេទប្បហាន បដិប្បស្សទ្ធិប្បហាន និស្សរណប្បហាន អធិប្បាយថា មិនកើតឡើងទៀត ។ ក្នុងបហាន ៥ យ៉ាងនោះ កិលេសដែលលោកលះបានដោយវិបស្សនា ដោយអំណាចតទង្គប្បហាន ព្រោះហេតុនោះ វិបស្សនា គប្បីជ្រាបថា តទង្គប្បហាន ឯសមាបត្តិរមែងសង្កត់កិលេសបាន ព្រោះដូច្នោះ សមាបត្តិនោះ គប្បីជ្រាបថា វិក្ខម្ភនប្បហាន លះបានដោយការសង្កត់ មគ្គ កាត់កិលេសបានជាសមុច្ឆេទកើតឡើង ផលស្ងប់រម្ងាប់កើតឡើង ព្រះនិព្វានរលាស់ចេញចាកកិលេសទាំងពួង

មគ្គ ផល និព្វាន ទាំង ៣ ដូចពោលមកនេះ លោកហៅថា សមុច្ឆេ-ទប្បហាន បស្សទ្ធិប្បហាន និងនិស្សរណប្បហាន អធិប្បាយថា កិលេស លោកលះដោយបហាន ៥ ដែលជាលោកិយ និងលោកុត្តរទាំងឡាយនេះ ។

បទថា **អសុភនិមិត្តំ** បានដល់ បឋមជ្ឈាន ព្រមទាំងអារម្មណ៍ដែលកើតឡើងក្នុងអសុភ ១០ ដោយហេតុនោះ ទើបព្រះបុរាណាចារ្យបានពោលថា អសុភនិមិត្តមានក្នុងអសុភ ធម៌ទាំងឡាយដែលមានអសុភជាអារម្មណ៍ ឈ្មោះថា អសុភនិមិត្ត ។ បទថា **យោនិសោមនសិការោតោ** សេចក្ដីថា បុគ្គលដាក់ចិត្តដោយអំណាចមនសិការដោយឧបាយដូចពោលហើយ ដោយន័យដូច្នេះជាដើមថា ក្នុងធម៌ទាំងនោះ យោនិសោមនសិការដូចម្ដេច គឺមន-សិការក្នុងរបស់ដែលមិនទៀង ថាមិនទៀង ។ បទថា **អនុប្បន្នោ ចេវ កាមច្ឆន្ទោ នុប្បជ្ជតិ** បានដល់ កាមច្ឆន្ទៈដែលមិនទាន់ផ្សាយឡើង ក៏មិនផ្សាយឡើង ។ បទថា **ឧប្បន្នោ កាមច្ឆន្ទោ បហីយតិ** សេចក្ដីថា កាមច្ឆន្ទៈដែលកើតឡើងហើយ លោកលះបានដោយបហានទាំង ៥ ។

ម្យ៉ាងទៀត ធម៌ទាំង ៦ ប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺការរៀនអសុភនិមិត្ត ១ ការប្រកបរឿយៗ ក្នុងអសុភភាវនា ១ ភាពជាអ្នកគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ១ ភាពជាអ្នកដឹងប្រមាណក្នុងភោជន ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។ ពិតហើយ កាលភិក្ខុរៀនយកអសុភនិមិត្តទាំង ១០ ក្ដី ចម្រើនអសុភភាវនាក្ដី គ្រប់គ្រងក្នុងឥន្ទ្រិយក្ដី ដឹងប្រមាណក្នុងភោជនក្ដី ព្រោះកាលមានឱកាសទំពាលេប សល់

៤ ឬ ៥ ម៉ាត់ទៀតឆ្អែត ក៏ផឹកទឹក ញុំាងអត្តភាពឲ្យប្រព្រឹត្តទៅជាប្រក្រតីក្តី លោករមែងលះកាមច្ឆន្ទនីវរណៈបាន ដោយហេតុនោះ ទើបលោកពោលថា

**ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ**
**អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ ។**

ភិក្ខុឈប់បរិភោគ ៤ ឬ ៥ ពំនូត ( ក្នុងកាលជិតឆ្អែត )
ហើយគប្បីផឹកទឹក នេះជាការល្មមដល់កិរិយានៅជាសុខ នៃ
ភិក្ខុអ្នកមានចិត្តស្ងប់ទៅរក ( ព្រះនិព្វាន ) ។

ភិក្ខុគប់រកកល្យាណមិត្ត ដែលជាអ្នកត្រេកអរក្នុងអសុភភាវនា ដូចព្រះតិស្សត្ថេរ អ្នកបំពេញអសុភកម្មដ្ឋាន រមែងលះកាមច្ឆន្ទៈបាន ដោយសប្បាយកថា ដែលអាស្រ័យអសុភ ១០ ក្នុងការឈរ និងអង្គុយជាដើម ក៏លះកាមច្ឆន្ទៈបាន ដោយហេតុនោះ ទើបលោកពោលថា ធម៌ ៦ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ ។

**អដ្ឋកថាសូត្រទី ៦ ចប់**

# អដ្ឋកថាសូត្រទី ៧

[ ១៨ ] ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ បទថា **មេត្តាចេតោវិមុត្តិ** បានដល់ មេត្តាដែលផ្សាយប្រយោជន៍ទៅក្នុងសត្វគ្រប់ជំពូក ព្រោះហេតុដែលចិត្តប្រកបដោយមេត្តានោះ រមែងរួចផុតចាកធម៌ដែលជាសត្រូវ មាននីវរណៈជាដើម ដូច្នោះ ទើបមេត្តានោះ លោកហៅថា ចេតោវិមុត្តិ ។ ម្យ៉ាងទៀត ពោលដោយពិសេស មេត្តានោះ គប្បីជ្រាបថា ឈ្មោះថា ចេតោវិមុត្តិ ព្រោះរួចផុតចាកកិលេសដែលជាគ្រឿងរួបរឹត គឺព្យាបាទទាំងអស់ ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះ មេត្តាក្នុងពាក្យថា មេត្តាចេតោវិមុត្តិនោះ សូម្បីបដិបទាដែលជាចំណែកខាងដើមក៏ប្រើបាន ។ តែព្រោះលោកពោលថា ចេតោវិមុត្តិ ក្នុងទីនេះ បំណងយកមេត្តាចំពោះដែលជាអប្បនា ដោយអំណាចតិកជ្ឈាន និងចតុក្កជ្ឈានប៉ុណ្ណោះ ។ បទថា **យោនិសោ មនសិការោ** សេចក្តីថា កំពុងមនសិការនូវមេត្តាចេតោវិមុត្តិនោះ ដោយមនសិការ ដោយឧបាយដែលមានលក្ខណៈដូចពោលហើយ ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះព្យាបាទ គឺការរៀនមេត្តានិមិត្ត ១ ការប្រកបរឿយៗ ក្នុងមេត្តាភាវនា ១ ការពិចារណាភាពដែលសត្វមានកម្មជារបស់ខ្លួន ១ ភាពជាអ្នកច្រើនទៅដោយការពិចារណា ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។ ពិតហើយ កាលភិក្ខុកាន់យកមេត្តាដោយការផ្សាយទៅដោយចំពោះ និងមិនចំពោះ ក៏រមែងលះព្យាបាទបាន កាលពិចារណាដល់ភាពដែលខ្លួន និងបុគ្គលដទៃជាអ្នកមានកម្មរបស់ខ្លួនយ៉ាងនេះថា អ្នកក្រោធនឹងបុគ្គលនោះហើយ នឹងធ្វើអ្វី

បុគ្គលនោះបាន នឹងធ្វើសីលជាដើមរបស់បុគ្គលនោះ ឲ្យវិនាសបានឬ អ្នកមកដោយកម្មរបស់ខ្លួន ហើយក៏ទៅដោយកម្មរបស់ខ្លួនប៉ុណ្ណោះ មិនមែនឬ ឈ្មោះថា ការក្រោធអ្នកដទៃ រមែងដូចជាចាប់រងើកភ្លើងដែលប្រាសចាកអណ្តាត ជុំដែកដែលក្តៅ និងជុំលាមកជាដើម ហើយបំណងប្រហារអ្នកដទៃ បុគ្គលដែលក្រោធចំពោះអ្នកនេះ នឹងធ្វើអ្វីបាន នឹងធ្វើសីលជាដើមរបស់អ្នកឲ្យវិនាសឬ គេមកដោយកម្មរបស់ខ្លួន ហើយនឹងទៅដោយកម្មរបស់ខ្លួនប៉ុណ្ណោះ ការក្រោធនោះ នឹងធ្លាក់លើអំបែងក្បាលរបស់បុគ្គលនោះប៉ុណ្ណោះ ប្រៀបដូចអន្ទង់ទឹកធំ ដែលមិនមានអ្វីរាំង និងដូចក្តាប់ធូលី បាចទៅប្រាសខ្យល់ដូច្នោះ ដូច្នេះក្តី បុគ្គលពិចារណាភាពដែលជនទាំង ២ ជាអ្នកមានកម្មរៀងៗ ខ្លួន ហើយនៅក្នុងការពិចារណាល្អ គប់រកកល្យាណមិត្ត ជាអ្នកត្រេកអរក្នុងការចម្រើនភាវនា ដូចព្រះអស្សគុត្តត្ថេរក្តី រមែងលះព្យាបាទបានសូម្បីដោយការពោលពាក្យដែលជាសប្បាយ ដែលអាស្រ័យមេត្តាផង ក្នុងការឈរ និងអង្គុយជាដើមផង ដោយហេតុនោះ ទើបលោកពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះព្យាបាទ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយក្នុងទីនេះ និងក្នុងទីដទៃក្រៅអំពីនេះនោះឯង តែខ្ញុំនឹងពោលត្រឹមតែសេចក្តីដែលប្លែកគ្នាប៉ុណ្ណោះ ។

**អដ្ឋកថាសូត្រទី ៧ ចប់**

# អដ្ឋកថាសូត្រទី ៨

[ ១៩ ] ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ សេចក្ដីព្យាយាមដំបូង ហៅថា **អារព្ភធាតុ** ក្នុងពាក្យជាដើមថា **អារព្ភធាតុ** ។ សេចក្ដីព្យាយាមមានកម្លាំងខ្លាំងជាងនោះ ព្រោះចេញចាកសេចក្ដីខ្ជិលច្រអូស បានឈ្មោះថា **និក្កមធាតុ** ។ សេចក្ដីព្យាយាមដែលខ្លាំងក្លាជាងនោះ ព្រោះឈានទៅកាន់ឋានៈខាងមុខៗ ឈ្មោះថា **បរក្កមធាតុ** ។ តែក្នុងអដ្ឋកថាលោកពោលថា សេចក្ដីព្យាយាមដំបូង ដើម្បីបន្ទោបង់កាម ១ ការឈានចេញដើម្បីកម្ចាត់កិលេសដូចស្ពៀត ១ ការប្រឹងប្រែងដើម្បីកាត់កិលេសដូចគ្រឿងចង ១ ហើយពោលថា សេចក្ដីព្យាយាម មានប្រមាណក្រៃលែងជាងទាំង ៣ យ៉ាងនោះ ។

បទថា **អារទ្ធវីរិយស្ស** បានដល់ បុគ្គលមានសេចក្ដីព្យាយាមដែលបរិបូណ៌ និងមានសេចក្ដីព្យាយាមដែលផ្គងទុក ក្នុង ២ យ៉ាងនោះ សេចក្ដីព្យាយាមដែលប្រាសចាកទោស ៤ យ៉ាង គប្បីជ្រាបថា សេចក្ដីព្យាយាមដែលផ្ដើមហើយ តែមិនមែនរួញរាពេក មិនមែនផ្គងពេក តែមិនមែនសេចក្ដីព្យាយាមដែលរួញរាខាងក្នុង និងមិនមែនសេចក្ដីព្យាយាមដែលរាយមាយទៅខាងក្រៅ សេចក្ដីព្យាយាមនោះ មាន ២ យ៉ាង គឺសេចក្ដីព្យាយាមតាមផ្លូវកាយ ១ សេចក្ដីព្យាយាមតាមផ្លូវចិត្ត ១ ។

ក្នុង ២ យ៉ាងនោះ គប្បីជ្រាបសេចក្ដីព្យាយាមផ្លូវកាយរបស់ភិក្ខុដែលព្យាយាមផ្លូវកាយអស់ ៥ ចំណែកនៃយប់ និងថ្ងៃយ៉ាងនេះថា ភិក្ខុក្នុងធម្មវិន័យនេះ រមែងជម្រះចិត្តចេញចាកធម៌ ដែលគប្បីរាំងចិត្ត ដោយការដើរ

ការអង្គុយអស់ ១ ថ្ងៃ ។ គប្បីជ្រាបសេចក្តីព្យាយាមផ្លូវចិត្តរបស់ភិក្ខុ ដែលព្យាយាមចងចិត្ត ដោយការកំណត់ឱកាសយ៉ាងនេះថា អាត្មាអញនឹងមិនចេញទៅអំពីទីសម្ងំនេះ ដរាបណាចិត្តរបស់អញ មិនរួចផុតចាកអាសវៈ ព្រោះមិនប្រកាន់មាំ ឬដោយការកំណត់ឥរិយាបថ មានការអង្គុយជាដើមយ៉ាងនេះថា អញនឹងមិនប្តូរឥរិយាបថនេះ ដរាបណាចិត្តរបស់អញ មិនផុតចាកអាសវៈ ព្រោះមិនប្រកាន់មាំ ។ សេចក្តីព្យាយាមទាំង ២ នោះ រមែងសមគួរក្នុងទីនេះ ។ សម្រាប់បុគ្គលដែលប្រារព្ធព្យាយាម ដោយសេចក្តីព្យាយាមទាំង ២ នេះ ថីនមិទ្ធៈដែលមិនទាន់កើត ក៏មិនកើតឡើង ដែលកើតឡើងហើយ រមែងលះបាន ដូចព្រះតិស្សត្ថេរជនជាតិមិលក្ខៈ ដូចព្រះមហាសិវត្ថេរ ដែលនៅត្រង់ញកភ្នំ ជិតស្រុក ដូចព្រះបីតិមល្លកត្ថេរ និងដូចព្រះតិស្សត្ថេរកុដុម្ពិកបុត្រដូច្នោះ ។ បណ្តាព្រះថេរៈទាំងនោះ ព្រះថេរៈ ៣ រូបខាងដើម និងព្រះថេរៈដទៃបែបនោះ ជាអ្នកផ្តើមបំពេញព្យាយាមផ្លូវកាយ ព្រះតិស្សត្ថេរកុដុម្ពិកបុត្រ និងព្រះថេរៈដទៃបែបនោះ ជាអ្នកប្រារព្ធព្យាយាមផ្លូវចិត្ត ឯព្រះមហានាគត្ថេរ ដែលនៅត្រង់ឧច្ចវាលុកវិហារ ជាអ្នកប្រារព្ធព្យាយាមទាំង ២ យ៉ាង ។

បានឮថា ព្រះថេរៈដើរចង្ក្រម ១ សប្តាហ៍ ឈរ ១ សប្តាហ៍ អង្គុយ ១ សប្តាហ៍ សឹង ១ សប្តាហ៍ ។ ព្រះថេរៈមិនមានឥរិយាបថណាមួយដែលថា មិនជាទីសប្បាយ ក្នុងសប្តាហ៍ទី ៤ លោកចម្រើនវិបស្សនា តាំងនៅក្នុងអរហត្ត ។ម្យ៉ាងទៀត ធម៌ ៦ ប្រការ ដែលប្រព្រឹត្តទៅដើម្បីលះថីនមិទ្ធៈ គឺកាន់យកនិមិត្តក្នុងការបរិភោគច្រើន ១ ផ្លាស់ប្តូរឥរិយាបថជានិច្ច ១ មនសិការ

ដល់អាលោកសញ្ញា ១ ការនៅក្នុងទីវាល ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាទីសប្បាយ ១ ។ ពិតហើយ កាលភិក្ខុបរិភោគភោជន ដូចព្រាហ្មណ៍ឈ្មោះថា អាហរហត្ថកៈ ព្រាហ្មណ៍ឈ្មោះថា កុត្ត-វម្មិតកៈ ព្រាហ្មណ៍ឈ្មោះថា សត្តវដ្ដកៈ ព្រាហ្មណ៍ឈ្មោះថា អលង្សាដកៈ និងព្រាហ្មណ៍ឈ្មោះថា កាកមាសកៈជាដើម ។ អង្គុយក្នុងទីសម្រាកក្នុងពេលយប់ និងពេលថ្ងៃ ធ្វើសមណធម៌ ថីនមិទ្ធៈ រមែងគ្របសង្កត់ ដូចដំរីធំដូច្នោះ តែកាលភិក្ខុបញ្ឈប់ក្នុងខណៈដុំបាយ ៤ ឬ ៥ ពំនូតទៀតឆ្អែតហើយផឹកទឹក ល្មមធ្វើអត្តភាពឲ្យប្រព្រឹត្តទៅជាប្រក្រតី ថីនមិទ្ធៈនោះ ក៏មិនមានកាលភិក្ខុកាន់យកនិមិត្តក្នុងការបរិភោគច្រើនពេក ដូចពោលមកហើយនេះ រមែងលះថីនមិទ្ធៈបាន ថីនមិទ្ធៈឈានចុះក្នុងឥរិយាបថណា កាលលោកផ្លាស់ប្ដូរឥរិយាបថដទៃអំពីឥរិយាបថនោះក្ដី មនសិការដល់ពន្លឺនៃព្រះចន្ទ ពន្លឺនៃប្រទីប ពន្លឺនៃសេពគប់ ភ្លើងនៅពេលរាត្រី និងពន្លឺនៃព្រះអាទិត្យនៅពេលថ្ងៃក្ដី នៅកណ្ដាលវាលក្ដី សេពគប់កល្យាណមិត្តជាអ្នកលះថីនមិទ្ធៈបានហើយ ដូចជាព្រះមហាកស្សបត្ថេរក្ដី រមែងលះថីនមិទ្ធៈបាន ដោយការពោលសប្បាយកថាដែលអាស្រ័យធុតង្គគុណ ក្នុងឥរិយាបថ មានការឈរ និងការអង្គុយជាដើម ក៏រមែងលះបាន ដោយហេតុនោះ ទើបលោកពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះថីនមិទ្ធៈ ដូច្នេះ ។

## អដ្ឋកថាសូត្រទី ៨ ចប់

# អដ្ឋកថាសូត្រទី ៩

[ ២០ ] ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ បទថា **វូបសន្តចិត្តស្ស** បានដល់ បុគ្គលមានចិត្តស្ងប់ហើយ ដោយឈាន ឬវិបស្សនា ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺភាពជាពហុស្សូត ១ ភាពជាអ្នកសាកសួរច្រើន ១ ភាពជាអ្នកជំនាញក្នុងវិន័យ ១ ភាពជាអ្នកចូលទៅរកអ្នកចម្រើន ១ ភាពជាអ្នកមានកល្យាណមិត្ត ១ សប្បាយកថា ១ ។ ពិតហើយ កាលភិក្ខុរៀនបាន ១ និកាយ ២ និកាយ ៣ និកាយ ៤ និកាយ ឬ ៥ និកាយ ដោយអំណាចបាលី និងដោយអំណាចអត្ថនៃបាលី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ដោយភាពជាពហុស្សូត កាលភិក្ខុច្រើនដោយការសាកសួរ ក្នុងវត្ថុដែលគួរ និងមិនគួរ ក្នុងឥរិយាបថឈរ និងដេកជាដើមក្តី ជាអ្នកជំនាញ ព្រោះមានការជំនាញក្នុងវិនយបញ្ញត្តិក្តី ចូលទៅរកព្រះថេរៈដែលជាធំ និងមានវស្សាច្រើនក្តី សេពគប់កល្យាណមិត្តដែលទ្រទ្រង់ព្រះវិន័យ ដូចព្រះឧបាលីក្តី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន រមែងលះបានដោយពាក្យដែលជាសប្បាយ ដែលអាស្រ័យវត្ថុគួរ និងមិនគួរ ក្នុងឥរិយាបថឈរ និងអង្គុយជាដើម ដោយហេតុនោះ ទើបលោកពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ ។

**អដ្ឋកថាសូត្រទី ៩ ចប់**

# អដ្ឋកថាសូត្រទី ១០

[ ២១ ] ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ បទថា **យោនិសោមនសិការោ** សេចក្តីថា មនសិការដោយឧបាយ តាមន័យដែលពោលហើយនោះឯង ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺភាពជាពហុសូត ១ ភាពជាអ្នកសាកសួរច្រើន ១ ភាពជាអ្នកជំនាញក្នុងព្រះវិន័យ ១ ភាពជាអ្នកច្រើនដោយការបង្អោនចិត្តជឿ ១ ភាពជាអ្នកមានកល្យាណមិត្ត ១ ការពោលពាក្យដែលជាសប្បាយ ១ ។ កាលភិក្ខុរៀន ១ និកាយក្តី ២ ក្តី ៣ ក្តី ៤ ក្តី ឬ ៥ និកាយក្តី ដោយអំណាចបាលី និងដោយអំណាចអត្ថ រមែងលះវិចិកិច្ឆាបាន សូម្បីភាពជាពហុសូត កាលភិក្ខុច្រើនដោយការសាកសួរ ទាក់ទងនឹងព្រះរតនត្រ័យក្តី មានការជំនាញក្នុងព្រះវិន័យក្តី ច្រើនទៅដោយអធិមោក្ខ ពោល គឺការបង្អោនចិត្តជឿក្នុងឋានៈ ៣ ក្តី ជាអ្នកសេពគប់កល្យាណមិត្ត ដូចព្រះវក្កលិត្ថេរ បង្អោនទៅក្នុងសទ្ធាក្តី រមែងលះវិចិកិច្ឆាបាន រមែងលះបានដោយការពោលពាក្យដែលជាសប្បាយ អាស្រ័យគុណព្រះរតនត្រ័យ ក្នុងឥរិយាបថឈរ និងអង្គុយជាដើម ដោយហេតុនោះទើបលោកពោលថា ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីលះវិចិកិច្ឆា ។

ក្នុងនីវរណបហានវគ្គនេះ លោកពោលទាំងវដ្ដៈ និងវិវដ្ដៈ ដូច្នេះ ។

**អដ្ឋកថាសូត្រទី ១០ ចប់**

**អដ្ឋកថា នីវរណបហានវគ្គទី ២ ចប់**

# សុត្តន្តបិដក

## អកម្មនិយវគ្គ

[ ២២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចម្រើនហើយ ជាសភាវៈមិនគួរដល់ការងារ ( យកជាការមិនបាន ) ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចម្រើនហើយ ជាធម្មជាតមិនគួរដល់ការងារទេ ។

[ ២៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលចម្រើនហើយ ទើបជាធម្មជាតគួរដល់ការងារ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលចម្រើនហើយ ទើបជាធម្មជាតគួរដល់ការងារ ។

[ ២៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចម្រើនហើយ តែងប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចម្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ២៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានចម្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានចម្រើនហើយ តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ ។

[ ២៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចម្រើន មិនបានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចម្រើន មិនបានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ២៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានចម្រើន បានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានចម្រើន បានឲ្យកើតប្រាកដហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

[ ២៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចម្រើន មិនបានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានចម្រើន មិនបានធ្វើឲ្យចម្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ២៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យចម្រើនហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំង-ឡាយ ចិត្តដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ តែងប្រព្រឹត្តទៅ

ដើម្បីប្រយោជន៍យ៉ាងធំ ។

[ ៣០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានចម្រើន មិនបានធ្វើឲ្យច្រើនហើយ តែង នាំមកនូវសេចក្តីទុក្ខក្រៃពេក ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំង-ឡាយ ចិត្តដែលបុគ្គលមិនបានចម្រើន មិនបានធ្វើឲ្យច្រើនហើយ តែងនាំមក នូវសេចក្តីទុក្ខក្រៃពេក ។

[ ៣១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ តែងនាំ មកនូវសេចក្តីសុខក្រៃពេក ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្ត ដែលបុគ្គលបានចម្រើន បានធ្វើឲ្យច្រើនហើយ តែងនាំមកនូវសេចក្តីសុខ ក្រៃពេក ។

វគ្គទី ៣ ចប់

# អដ្ឋកថា

# អកម្មនិយវគ្គទី ៣

## សូត្រទី ១

[ ២២ ] *ក្នុងសូត្រទី ១ នៃវគ្គទី ៣ មានវិនិច្ឆ័យដូចតទៅនេះ បទថា* **អភាវិតំ** *សេចក្តីថា មិនចម្រើន គឺមិនប្រព្រឹត្តទៅ ដោយអំណាចភាវនា ។ បទថា* **អកម្មនីយំ ហោតិ** *បានដល់ រមែងមិនគួរដល់ការងារ គឺមិនគួរដល់ការងារ ។*

អដ្ឋកថាសូត្រទី ១ ចប់

# អដ្ឋកថា សូត្រទី ២

[ ២៣ ] ក្នុងសូត្រទី ២ គប្បីជ្រាបដោយបរិយាយដូចពោលហើយ ។ បទថា **ចិត្តំ** ក្នុងសូត្រទី ១ នោះ បានដល់ ចិត្តដែលកើតឡើងដោយអំណាចវដ្ដៈ ។ ក្នុងសូត្រទី ២ នេះ គប្បីជ្រាបអត្ថដែលផ្សេងគ្នាដូច្នេះ គឺវដ្ដៈ វដ្ដបាទ វិវដ្ដៈ វិវដ្ដបាទ កម្មដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ឈ្មោះថា វដ្ដៈ កម្មគឺការធ្វើដើម្បីបានវដ្ដៈ ឈ្មោះថា វដ្ដបាទ ។ លោកុត្តរធម៌ ៩ ឈ្មោះថា វិវដ្ដៈ កម្ម គឺកិច្ចបដិបត្តិដើម្បីបានវិវដ្ដៈ ឈ្មោះថា វិវដ្ដបាទ លោកពោលវដ្ដៈ និងវិវដ្ដៈ ក្នុងសូត្រទាំងនេះ ដោយប្រការដូច្នេះ ។

**អដ្ឋកថាសូត្រទី ២ ចប់**

# អដ្ឋកថាសូត្រទី ៣

[ ២៤ ] ក្នុងសូត្រទី ៣ គប្បីជ្រាបចិត្តដែលកើតឡើងដោយអំណាចវដ្ដៈនោះឯង ។ បទថា **មហតោ អនត្ថាយ សំវត្តតិ** សេចក្ដីថា ចិត្តសូម្បីឲ្យទេវសម្បត្តិ មនុស្សសម្បត្តិ និងភាពជាធំក្នុងមារ និងព្រហ្ម ញុំាងឲ្យជាតិ ជរា ព្យាធិ មរណៈ សោក បរិទេវៈ ទុក្ខទោមនស្ស និងឧបាយាសរឿយៗ និងឲ្យវដ្ដៈ គឺខន្ធ ធាតុ អាយតនៈ និងបដិច្ចសមុប្បាទ រមែងឲ្យតែកងទុក្ខតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុនោះ ទើបឈ្មោះថា រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍យ៉ាងធំ ។

## អដ្ឋកថាសូត្រទី ៣ ចប់

# អដ្ឋកថាសូត្រទី ៤

[ ២៥ ] បទថា **ចិត្តំ** ក្នុងសូត្រទី ៤ បានដល់ ចិត្តដែលកើតឡើងដោយអំណាចវិវដ្ដៈ ។

## អដ្ឋកថាសូត្រទី ៤ ចប់

# អដ្ឋកថាសូត្រទី ៥-៦

[ ២៦-២៧ ] ក្នុងសូត្រទី ៥ និងសូត្រទី ៦ មានសេចក្តីប្លែកគ្នាត្រឹមតែប៉ុណ្ណេះថា **អភាវិតំ អចាតុភូតំ** មិនអប់រំហើយ មិនប្រាកដហើយ ដូច្នេះក្នុងសេចក្តីនោះ មានអធិប្បាយដូច្នេះថា ចិត្ត សូម្បីកើតដោយអំណាចវដ្តៈក៏ឈ្មោះថា មិនអប់រំ មិនប្រាកដ ព្រោះហេតុអ្វី ព្រោះមិនអាចស្ទុះទៅក្នុងវិបស្សនាដែលមានឈានជាបាទ មគ្គ ផល និងនិព្វាន ដែលជាលោកុត្តរ ឯចិត្តដែលកើតដោយអំណាចវិវដ្តៈ ឈ្មោះថា ជាចិត្តអប់រំហើយ ប្រាកដហើយ ព្រោះហេតុអ្វី ព្រោះអាចស្ទុះទៅក្នុងធម៌ទាំងនោះបាន ឯព្រះបុស្សមិត្តត្ថេរដែលនៅកុរុន្ទកវិហារ ពោលថា អាវុសោ មគ្គចិត្តប៉ុណ្ណោះ ឈ្មោះថាជាចិត្តអប់រំហើយ ប្រាកដហើយ ។

**អដ្ឋកថាសូត្រទី ៥-៦ ចប់**

# អដ្ឋកថាសូត្រទី ៧-៨

[ ២៨-២៩ ] ក្នុងសូត្រទី ៧ និងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អពហុលីកតំ** បានដល់ មិនធ្វើរឿយៗ គប្បីជ្រាបចំពោះចិត្តដែលកើតឡើងដោយអំណាចវដ្តៈ និងវិវដ្តៈទាំង ២ ដូចនេះឯង ។

**អដ្ឋកថាសូត្រទី ៧-៨ ចប់**

# អដ្ឋកថាសូត្រទី ៩

[ ៣០ ] ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូច្នេះ ចិត្ត ឈ្មោះថា នាំទុក្ខមកឲ្យ ព្រោះទាញមក គឺនាំមកនូវវដ្តទុក្ខ ដែលបានត្រាស់ដោយន័យជាដើមថា **ជាតិបិ ទុក្ខា** គឺការកើតជាទុក្ខ ។ បាលីថា **ទុក្ខាធិវាហំ** ដូច្នេះក៏មានសេចក្តីនៃបាលីនោះ គប្បីជ្រាបថា ចិត្ត ឈ្មោះថា **ទុក្ខាធិវាហា** ព្រោះលំបាកបញ្ជូនតម្រង់ចំពោះអរិយធម៌ ដែលមានឈានជាបាទនៃលោកុត្តរជាដើម ចិត្តនេះ គឺចិត្តដែលកើតឡើងដោយអំណាចវដ្តទុក្ខនោះឯង ។ ពិតហើយ ចិត្តនោះសូម្បីឲ្យទេវសម្បត្តិ និងមនុស្សសម្បត្តិ មានប្រការដូចពោលហើយ ក៏ឈ្មោះថា នាំទុក្ខមកឲ្យ ព្រោះនាំជាតិទុក្ខមកឲ្យ និងឈ្មោះថា លំបាកដែលនឹងនាំទៅ ព្រោះបញ្ជូនទៅដើម្បីសម្រេចអរិយធម៌បាន ដោយលំបាក ។

**អដ្ឋកថាសូត្រទី ៩ ចប់**

# អដ្ឋកថាសូត្រទី ១០

[ ៣១ ] ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូច្នេះ ចិត្ត គឺចិត្តដែលកើតឡើងដោយអំណាចវិវដ្ដៈនោះឯង ពិតហើយ ចិត្តឈ្មោះថា **សុខាធិវាហ** ឬ **សុខាធិវាហា** ព្រោះអត្ថថា ទាញមក គឺនាំមកនូវទិព្វសុខដែលល្អិត ប្រណីតជាងសុខរបស់មនុស្ស នូវឈានសុខដែលល្អិត ប្រណីតជាងទិព្វសុខ នូវវិបស្សនាសុខដែលល្អិតប្រណីតជាងឈានសុខ នូវមគ្គសុខដែលល្អិតប្រណីតជាងវិបស្សនាសុខ នូវផលសុខដែលល្អិតប្រណីតជាងមគ្គសុខ នូវនិព្វានសុខដែលល្អិតប្រណីតជាងផលសុខ ។ ពិតហើយ ចិត្តនោះ ជាចិត្តងាយស្រួលដែលនឹងបញ្ជូនតម្រង់ចំពោះអរិយមគ្គ ដែលមានឈានជាបាទរបស់លោកុត្តរជាដើម ដូចវជិរាវុធរបស់ព្រះឥន្ទ្រ ដែលលែងទៅ ដូច្នោះ ។ ហេតុនោះ ទើបហៅថា **សុខាធិវាហា** ។ ក្នុងវគ្គនេះ លោកពោលវដ្ដៈនិងវិវដ្ដៈប៉ុណ្ណោះឯង ។

**អដ្ឋកថាសូត្រទី ១០ ចប់**

**អកម្មនិយវគ្គទី ៣ ចប់**

# សុត្តន្តបិដក

## អេកវគ្គទី ៤

[ ៣២] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានទូន្មានហើយ តែងប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានទូន្មានហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ៣៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលទូន្មានហើយ តែងប្រព្រឹត្តទៅដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលទូន្មានហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

[ ៣៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ៣៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែល

បុគ្គលបានគ្រប់គ្រងហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

[ ៣៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ៣៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានរក្សាហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

[ ៣៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះទេ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ៣៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

[ ៤០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលមិនបានទូន្មាន មិនបានគ្រប់គ្រង មិនបានរក្សា មិនបានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍យ៉ាងធំ ។

[ ៤១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលបានទូន្មាន បានគ្រប់គ្រង បានរក្សា បានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តដែលបុគ្គលបានទូន្មាន បានគ្រប់គ្រង បានរក្សា បានសង្រួមហើយ តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍យ៉ាងធំ ។

វគ្គទី ៤ ចប់

# អដ្ឋកថា

# អធន្តវគ្គទី ៤

## សូត្រទី ១

[ ៣២] ក្នុងសូត្រទី ១ វគ្គទី ៤ មានវិនិច្ឆ័យដូច្នេះ បទថា **អធន្តំ** បានដល់ មានការសេពខុស គឺមានពុត ដូចដីរ និងសេះជាដើមដែលមិនបានទូន្មាន ។ បទថា **ចិត្តំ** បានដល់ ចិត្តដែលកើតឡើង ដោយអំណាចវដ្តៈ ។

**អដ្ឋកថា សូត្រទី ១ ចប់**

## អដ្ឋកថា សូត្រទី ២

[ ៣៣ ] ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ធន្តំ** បានដល់ អស់ពុត គឺដូចដីរ និងសេះជាដើម ដែលទូន្មានហើយ ក្នុងសូត្រទាំង ២ នេះ លោកពោលចំពោះចិត្តដែលកើតឡើង ដោយអំណាចវដ្តៈ និងវិវដ្តៈ ក្នុងសូត្រនេះយ៉ាងណា សូម្បីក្នុងសូត្រដទៃៗ អំពីសូត្រនេះក៏យ៉ាងនោះ ។

**អដ្ឋកថាសូត្រទី ២ ចប់**

# អដ្ឋកថា សុត្រទី ៣

[ ៣៤ ] ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អគុត្តំ** បានដល់ មិនគ្រប់គ្រង គឺវៀរចាកសតិសំវរៈ ដូចដំរី និងសេះ មិនគ្រប់គ្រង គឺមិនមានម្ចាស់ ដូច្នោះ ។

**អដ្ឋកថាសុត្រទី ៣ ចប់**

# អដ្ឋកថាសុត្រទី ៤

[ ៣៥ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ បទថា **គុត្តំ** បាន ដល់ គ្រប់គ្រងហើយ គឺមិនបណ្តែតបណ្តោយសតិសំវរៈ ដូចដំរី និងសេះ ជាដើម ដែលបានគ្រប់គ្រងហើយ ។

**អដ្ឋកថាសុត្រទី ៤ ចប់**

# អដ្ឋកថាសុត្រទី ៥-៦

[ ៣៦-៣៧ ] ក្នុងសូត្រទី ៥ និងសូត្រទី ៦ លោកពោលតាម អធ្យាស្រ័យរបស់សត្វ ដែលនឹងត្រាស់ដឹង ដោយអំណាចបទថា **អរក្ខិតំ** ។ ក្នុងបទនេះ ដូចបទមុននោះឯង ។

**អដ្ឋកថាសុត្រទី ៥-៦ ចប់**

# អដ្ឋកថាសូត្រទី ៧-៨

[ ៣៨-៣៩ ] ក្នុងសូត្រទី ៧ និងសូត្រទី ៨ ក៏មានន័យដូចគ្នា ។ តែក្នុងសេចក្តីនេះ គប្បីជ្រាបឧបមាដូចទ្វារផ្ទះជាដើម ដែលមិនមានការរក្សា ។

អដ្ឋកថាសូត្រទី ៧-៨ ចប់

# អដ្ឋកថាសូត្រទី ៩-១០

[ ៤០-៤១ ] ក្នុងសូត្រទី ៩ និងសូត្រទី ១០ លោកយកបទ ៤ មកប្រកបហើយ ពោលក្នុងវគ្គនេះ លោកពោលចំពោះវដ្ដៈ និងវិវដ្ដៈ ប៉ុណ្ណោះឯង ។

អដ្ឋកថាសូត្រទី ៩-១០ ចប់

អនន្តវគ្គទី ៤ ចប់

# សុត្តន្តបិដក

## បណិហិតអច្ឆវគ្គ

[ ៤២ ] ម្នាលភិក្ខុទាំងឡាយ ចុងគ្រាប់ស្រូវខ្សាយក្តី ចុងគ្រាប់ស្រូវដំណើបក្តី ដែលបុគ្គលរៀបចំមិនត្រូវទំនង គឺមិនឲ្យមានចុងឡើងលើទេ បុគ្គលសង្កត់ដោយដៃ ឬជាន់ដោយជើង នឹងមុតដៃ ឬជើង នឹងធ្វើឈាមឲ្យផុលឡើងបាន ហេតុដូច្នេះ មិនដែលមានទេ រឿងនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ស្រូវដែលបុគ្គលរៀបចំមិនត្រូវទំនង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតម្កល់ខុស នឹងទម្លាយអវិជ្ជា នឹងធ្វើវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុដូច្នេះ មិនដែលមានទេ រឿងនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តដែលភិក្ខុនោះតម្កល់ខុស ក៏ដូច្នោះឯង ។

[ ៤៣ ] ម្នាលភិក្ខុទាំងឡាយ ចុងគ្រាប់ស្រូវខ្សាយក្តី ចុងគ្រាប់ស្រូវដំណើបក្តី ដែលបុគ្គលរៀបចំត្រូវទំនង គឺធ្វើឲ្យមានចុងឡើងលើ បុគ្គលសង្កត់ដោយដៃ ឬជាន់ដោយជើង នឹងមុតដៃ ឬជើង នឹងធ្វើឈាមឲ្យផុលឡើងបាន ហេតុនេះទើបមាន រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចុងគ្រាប់ស្រូវបុគ្គលរៀបចំត្រូវទំនង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តតម្កល់ត្រូវ នឹងទម្លាយអវិជ្ជា នឹងធ្វើវិជ្ជាឲ្យកើតឡើង នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ហេតុនេះ ទើបមាន រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះចិត្តដែលភិក្ខុនោះតម្កល់ត្រូវ ក៏ដូច្នោះឯង ។

[ ៤៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតកំណត់នូវចិត្ត ( របស់បុគ្គល )

ដោយចិត្ត ( របស់ខ្លួន ) ក៏ដឹងច្បាស់នូវបុគ្គលពួក ១ ក្នុងលោកនេះ ដែលមានចិត្តប្រទូស្តយ៉ាងនេះថា បើបុគ្គលនេះធ្វើនូវមរណកាល ក្នុងសម័យនេះ នឹងធ្លាក់ទៅក្នុងនរក ដូចគេចាប់បោះទៅដូច្នោះឯង រឿងនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះថា បុគ្គលនោះ មានចិត្តប្រទូស្ត ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សត្វទាំងឡាយពួក ១ ក្នុងលោកនេះ ទម្លាយរាងកាយស្លាប់ទៅ តែងទៅកើតក្នុងអបាយ ទុគ្គតិ វិនិបាត នរក ក៏ព្រោះតែចិត្តប្រទូស្តជាហេតុដែរ ។

[ ៤៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតកំណត់នូវចិត្ត ( របស់បុគ្គល ) ដោយចិត្ត ( របស់ខ្លួន ) ក៏ដឹងច្បាស់នូវបុគ្គលពួក ១ ក្នុងលោកនេះដែលមានចិត្តជ្រះថ្លាយ៉ាងនេះថា បើបុគ្គលនេះធ្វើមរណកាលក្នុងសម័យនេះ នឹងទៅកើតក្នុងស្ថានសួគ៌ ដូចគេនាំទៅតម្កល់ទុកដូច្នោះឯង រឿងនោះព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សត្វទាំងឡាយពួក ១ ក្នុងលោកនេះ ទម្លាយរាងកាយស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ទេវលោក ក៏ព្រោះតែចិត្តជ្រះថ្លាជាហេតុដែរ ។

[ ៤៦ ] ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹក មានទឹកល្អក់កខ្វក់ កើតជាភក់ បុរសអ្នកមានចក្ខុឈរនៅមាត់អន្លង់នោះ មិនឃើញខ្យង និងគ្រំ ឬដុំក្រួស និងអំបែង ឬហ្វូងត្រីដែលហែលទៅមក ឬក៏ស្ថិតនៅបានឡើយ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះទឹកនោះល្អក់ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តល្អក់ នឹងស្គាល់ប្រយោជន៍របស់ខ្លួនក្តី

ស្គាល់ប្រយោជន៍របស់ជនទៃក្តី ស្គាល់ប្រយោជន៍ទាំង ២ ខាងក្តី នឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ ក្រៃលែងជាងមនុស្សធម៌ក្តី ហេតុដូច្នេះ មិនដែលមានទេ ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះ មានចិត្តល្អក់ ក៏ដូច្នោះឯង ។

[ ៤៧ ] ម្នាលភិក្ខុទាំងឡាយ អន្លង់ទឹកមានទឹកថ្លាស្អាត មិនកខ្វក់ បុរសអ្នកមានចក្ខុ ឈរនៅមាត់អន្លង់នោះ ក៏ឃើញខ្យង និងគ្រំ ឬដុំក្រួស និងអំបែង ឬហ្វូងត្រី ដែលហែលទៅមក ឬក៏ស្ថិតនៅបាន ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះទឹកនោះ មិនល្អក់ ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុមានចិត្តមិនល្អក់ នឹងស្គាល់ប្រយោជន៍របស់ខ្លួនក្តី ស្គាល់ប្រយោជន៍របស់អ្នកដទៃក្តី ស្គាល់ប្រយោជន៍ទាំង ២ ខាងក្តី នឹងធ្វើឲ្យជាក់ច្បាស់នូវគុណវិសេស គឺញាណទស្សនៈដ៏ប្រសើរ ក្រៃលែងជាងមនុស្សធម៌ក្តី ហេតុដូច្នេះ ទើបមាន ដំណើរនោះ ព្រោះហេតុអ្វី ម្នាលភិក្ខុទាំងឡាយ ព្រោះភិក្ខុនោះ មានចិត្តមិនល្អក់ ក៏ដូច្នោះឯង ។

[ ៤៨ ] ម្នាលភិក្ខុទាំងឡាយ រុក្ខជាតិទាំងឡាយ ស្រេចនៅដើមចន្ទន៍ ទើបប្រសើរជាងរុក្ខជាតិទាំងនោះ ព្រោះដើមចន្ទន៍នេះទន់ផង គួរដល់ការងារផង ដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជាសភាវៈទន់ផង គួរដល់ការងារផង ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំង-ឡាយ ចិត្តដែលបុគ្គលចម្រើនហើយ ធ្វើឲ្យច្រើនហើយ ជារបស់ទន់ផង គួរ

ដល់ការផ្សាយផង ដូច្នេះឯង ។

[ ៤៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតពិចារណាមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលកើតឡើង នឹងវិលត់ទៅរហ័ស ដូចចិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ចិត្តនេះកើតឡើង នឹងវិលត់ទៅរហ័សក្រៃពេក មិនងាយនឹងធ្វើឧបមាបានឡើយ ។

[ ៥០ ] ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះមានរស្មីផ្សាយចេញ ប៉ុន្តែចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុក ចូលមកធ្វើឲ្យសៅហ្មង ។

[ ៥១ ] ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះមានរស្មីផ្សាយចេញ ដ្បិតភវង្គចិត្តនេះឯង ផុតស្រឡះចាកឧបក្កិលេសទាំងឡាយ ដែលជាអាគន្តុក ។

វគ្គទី ៥ ចប់

# អដ្ឋកថា

# បណិហិតអច្ឆវគ្គទី ៥

## សូត្រទី ១

[ ៤២ ] *ក្នុងសូត្រទី ១ វគ្គទី ៥ មានវិនិច្ឆ័យដូចតទៅនេះ សព្ទថា* **សេយ្យថាបិ** *ជានិបាត ប្រើក្នុងអត្ថថា ឧបមា ។ ក្នុងអត្ថដែលពោលដោយឧបមានោះ ទីខ្លះ ព្រះមានព្រះភាគ ទ្រង់សម្តែងយកអត្ថប្រកបឧបមា ដូចក្នុងវត្ថសូត្រ និងក្នុងបារិច្ឆត្តកោបមសូត្រ អគ្គិក្ខន្ធោបមសូត្រ ។ ក្នុងទីខ្លះ ទ្រង់សម្តែងយកឧបមាប្រកបសេចក្តី ដូចក្នុងលោណម្ពិលសូត្រ និងដូចសុវណ្ណ-ការសូត្រ និងសុរិយោបមសូត្រជាដើម តែក្នុងសាលិសូកោបមសូត្រនេះ ព្រះមានព្រះភាគ កាលទ្រង់យកឧបមាប្រកបអត្ថ ទើបត្រាស់ពាក្យថា* **សេយ្យ-ថាបិ ភិក្ខវេ** *ដូច្នេះជាដើម ។ បណ្តាបទទាំងនោះ បទថា* **សាលិសូកំ** *ប្រែថា ចុងនៃគ្រាប់ស្រូវសាលី ក្នុងចុងនៃស្រូវដំណើបក៏មានន័យនេះដូចគ្នា* **វា** *សព្ទមានអត្ថវិកប្បមិនពិតប្រាកដ ។ បទថា* **មិច្ឆាចាណិហិតំ** *ប្រែថា តម្កល់ខុស អធិប្បាយថា មិនតាំងឲ្យចុងឡើងលើ ដែលជាហេតុឲ្យអាចមុតបាន ។ បទថា* **ភិជ្ជិស្សតិ** *សេចក្តីថា នឹងទម្លាយ គឺ នឹងធ្លុតស្បែក ។*

*បទថា* **មិច្ឆាបណិហិតេន ចិត្តេន** *ប្រែថា ដោយចិត្តដែលតម្កល់ខុស ពាក្យនេះ លោកពោលសំដៅយកចិត្ត ដែលកើតឡើងដោយអំណាចវដ្ដៈ ។ បទថា* **អវិជ្ជំ** *បានដល់ ការមិនដឹងយ៉ាងធំ ច្រើនដោយកម្រាស់ជាការមិនដឹងក្នុងឋានៈ ៨ ។ បទថា* **វិជ្ជំ** *ក្នុងពាក្យថា* **វិជ្ជំ ឧប្បាទេស្សតិ**

នេះ បានដល់ ញាណដែលសម្បយុត្តដោយអរហត្តមគ្គ ។ បទថា **និព្វានំ** បានដល់ អមតៈ គុណជាតិដែលមិនស្លាប់ ដែលលោកពោលយ៉ាងនេះក៏ដោយ ជាគុណជាតិចេញអំពីកិលេសជាគ្រឿងរួបរឹត គឺតណ្ហា ។ បទថា **សច្ឆិករិស្សតិ** បានដល់ ធ្វើឲ្យប្រចក្ស ។

អដ្ឋកថាសូត្រទី ១ ចប់

## អដ្ឋកថាសូត្រទី ២

[ ៤៣ ] ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ បទថា **សម្មាបណិហិតំ** សេចក្តីថា តម្កល់ត្រូវ ព្រោះឲ្យចុងឡើងលើ ដោយអាចមុតបាន ។ ក្នុងបទថា **អក្កន្តំ** គឺជាន់នេះ រមែងឈ្មោះថា ជាន់ដោយជើងប៉ុណ្ណោះ បើយកដៃពាល់ត្រូវ គឺយកដៃសង្កត់ ។ ក៏ពោលថា ជាន់ដូចគ្នា ព្រោះជាសព្ទប្រើជំនួសគ្នារហូតស៊ាំ ។ ក្នុងសូត្រនេះ មានអរិយវោហារប្រមាណប៉ុណ្ណោះ ។

សួរថា ព្រោះហេតុអ្វី ទ្រង់មិនកាន់យកវត្ថុដទៃៗដែលធំ មានបន្លាផ្កាជាដើម កាន់យកតែត្រឹមចុងគ្រាប់ស្រូវសាលី ចុងស្រូវដំណើបប៉ុណ្ណោះដែលជារបស់ទន់មិនរឹង ។ ឆ្លើយថា ដើម្បីសម្តែងថា អកុសលកម្មមានចំនួនតិច ក៏អាចសម្លាប់កុសលកម្មបាន ដូចចុងគ្រាប់ស្រូវសាលី ឬចុងគ្រាប់ស្រូវដំណើប

ដែលទន់មិនរឹង ឬបន្លារបស់ដើមផ្កា និងបន្លារបស់ឈើ មានផ្តៅជាដើមដែលធំៗ ក៏ដោយចុះ តែបន្លាផ្តៅទាំងនោះ ផ្តៅប្រភេទណាមួយ ដែលតម្កល់ទុកខុស មិនអាចនឹងមុតដៃ ឬជើង ឬធ្វើឲ្យចេញឈាម តែដែលតម្កល់ទុកត្រូវ រមែងអាច យ៉ាងណា កុសលមានចំនួនតិច មិនថាជាការឲ្យអន្ទក់ប្រមាណមួយក្តាប់ ឬកុសលធំៗ ដូចជាការឲ្យរបស់វេលាមព្រាហ្មណ៍ជាដើម ក៏ហើយចុះ បើប្រាថ្នាវដ្តសម្បត្តិ ចិត្ត ឈ្មោះថា តម្កល់ទុកខុស ដោយអំណាចអាស្រ័យវដ្តៈ អាចនាំវដ្តៈប៉ុណ្ណោះមកឲ្យ មិនអាចនាំវិវដ្តៈមកឲ្យឡើយ ដូច្នោះដូចគ្នា ។ តែកាលបុគ្គលប្រាថ្នាវិវដ្តៈ យ៉ាងនេះថា សូមទាននៃខ្ញុំនេះ នាំមកនូវការអស់អាសវៈ ឈ្មោះថា តម្កល់ត្រូវ ដោយអំណាចវិវដ្តៈ រមែងអាចឲ្យអរហត្តផលផង បច្ចេកពោធិញ្ញាណផង សមដូចពាក្យលោកពោលថា

**បដិសម្ភិទា វិមោក្ខា ច យា ច សាវកបារមី**
**បច្ចេកពោធិ ពុទ្ធភូមិ សព្វមេតេន លព្ភតិ ។**

បដិសម្ភិទា ១ វិមោក្ខ ១ សាវកបារមី ១ បច្ចេកពោធិ ១ ពុទ្ធភូមិ ១ ទាំងអស់នោះ បុគ្គលរមែងបាន ដោយចិត្តដែលតម្កល់ត្រូវនោះ ។

ក្នុងសូត្រទាំង ២ នេះ លោកពោលវដ្តៈផង និងវិវដ្តៈផង ។

**អដ្ឋកថាសូត្រទី ២ ចប់**

# អដ្ឋកថាសូត្រទី ៣

[ ៤៤ ] ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ បទថា **បទុដ្ឋចិត្តំ** បានដល់ ចិត្តដែលទោសប្រទូស្តហើយ ។ បទថា **ចេតសា ចេតោ បរិច្ច** សេចក្តីថា កំណត់ចិត្តរបស់បុគ្គលដោយចិត្តរបស់ខ្លួន ។ បទថា **យថាភតំ និក្ខិត្តោ** សេចក្តីថា គប្បីឃើញថា តាំងនៅក្នុងនរកនោះឯង ដូចត្រូវនាំមកគឺដាក់ទុក ។ បទថា **អបាយំ** ជាដើម ជាពាក្យវេវចនៈនៃនរក ។ ពិតហើយ នរកប្រាសចាកសេចក្តីសុខ គឺសេចក្តីចម្រើន ឈ្មោះថា **អបាយ** ។ ភូមិដែលជាទីទៅ គឺជាទីស្មុះទៅនៃទុក្ខ ព្រោះដូច្នោះ ទើបឈ្មោះថា **ទុគ្គតិ** ។ ឈ្មោះថា វិនិបាត ព្រោះជាទីដែលបុគ្គលធ្វើអាក្រក់ធ្លាក់ទៅមិនមានអំណាច ។ ឈ្មោះថា **នរក** ព្រោះអត្ថថា មិនមានគុណដែលគួរត្រេកអរ ។

អដ្ឋកថាសូត្រទី ៣ ចប់

# អដ្ឋកថាសូត្រទី ៤

[ ៤៥ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ បទថា **បសន្នំ** បានដល់ ផូរផង់ដោយសេចក្តីផូរផង់ គឺសទ្ធា ។ បទថា **សុគតឹ** បានដល់ ភូមិជាទីទៅនៃសេចក្តីសុខ ។ បទថា **សគ្គំ លោកំ** បានដល់ លោកដែលក្រៃលែងដោយសម្បត្តិ មានរូបសម្បត្តិជាដើម ។

អដ្ឋកថាសូត្រទី ៤ ចប់

# អដ្ឋកថាសូត្រទី ៥

[ ៤៦ ] ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ឧទករហទោ** ប្រែថា អន្លង់ទឹក ។ បទថា **អាវិលោ** បានដល់មិនថ្លា ។ បទថា **លុឡិតោ** បានដល់មិនស្អាត ។ បទថា **កលលីភូតោ** ប្រែថាមានភក់ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សិប្បិសម្ពុកំ** ជាដើមដូចតទៅនេះថា ខ្ចៅ និងខ្យង ឈ្មោះថា **សិប្បិសម្ពុក** ។ ដុំក្រួស និងអំបែង ឈ្មោះថា **សក្ខរកឋល** ។ ហ្វូង គឺក្រុមនៃត្រីទាំងឡាយ ហេតុនោះ ទើបឈ្មោះថា **មច្ឆ-គុម្ព** គឺហ្វូងត្រី ។ បទថា **ចរន្តម្បិ តិដ្ឋម្បិ** នេះ មានអធិប្បាយថា ដុំក្រួស និងអំបែងឈប់តែម្យ៉ាង ក្រៅអំពីនេះ ឈប់ក៏មាន ហែលទៅក៏មាន ដូចជា រវាងមេគោដែលឈរក្តី ឈប់ក្តី ដេកក្តី គោក្រៅអំពីនោះ ក៏ត្រូវហៅថា ត្រាច់ទៅ ព្រោះអាស្រ័យគោដែលកំពុងត្រាច់ទៅថា គោទាំងនេះត្រាច់ទៅ យ៉ាងណា ដុំក្រួស និងអំបែងទាំង ២ ក្រៅអំពីនេះ គេហៅថា ឈប់ ព្រោះ អាស្រ័យដុំក្រួស និងអំបែងដែលឈប់ សូម្បីដុំក្រួស និងអំបែងដែលគេ ហៅថា ហែលទៅ ក៏ព្រោះអាស្រ័យហ្វូងត្រីដែលកំពុងហែលទៅ ដូច្នោះ ។ បទថា **អាវិលេន** បានដល់ ត្រូវបាននីវរណៈ ៥ ខ្ទប់ ។ ប្រយោជន៍របស់ ខ្លួនដែលលាយឡំគ្នា ជាលោកិយផង និងលោកុត្តរផង ដែលប្រព្រឹត្តទៅក្នុង បច្ចុប្បន្ន ឈ្មោះថា ប្រយោជន៍របស់ខ្លួន ក្នុងពាក្យជាដើមថា **អត្តត្ថំ វា** គឺ ប្រយោជន៍របស់ខ្លួន ដែលលាយគ្នា ទាំងដែលជាលោកិយ និងលោកុត្តរ ក្នុងសម្បរាយភព ឈ្មោះថា ប្រយោជន៍ខាងមុខ សូម្បីប្រយោជន៍ខាងមុខ ឈ្មោះថា **បរត្ថ** ព្រោះប្រកបដោយប្រយោជន៍របស់បុគ្គលដទៃ ។ ប្រយោជន៍

ទាំង ២ នោះ ឈ្មោះថា **ឧភយត្ថ** ប្រយោជន៍ទាំង ២ ។ ម្យ៉ាងទៀត ប្រយោជន៍ដែលជាចំណែកលោកិយ និងលោកុត្តរ ដែលប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន និងសម្បរាយភពរបស់ខ្លួន ឈ្មោះថា ប្រយោជន៍ខ្លួន ។ ប្រយោជន៍ដូច្នោះឯងរបស់អ្នកដទៃ ឈ្មោះថា ប្រយោជន៍អ្នកដទៃ ។ ប្រយោជន៍ទាំង ២ នោះ ក៏ឈ្មោះថា **ឧភយត្ថ** គឺប្រយោជន៍ទាំង ២ ។

បទថា **ឧត្តរឹ វា មនុស្សធម្មា** បានដល់ ដែលក្រៃលែងជាងធម៌របស់មនុស្ស ពោលគឺ កុសលកម្មបថ ១០ ប្រការ ។ ពិតហើយ ធម៌ ១០ ប្រការនេះ មិនមានអ្នកដទៃដឹកនាំ លោកហៅថា មនុស្សធម៌ ព្រោះជាធម៌ដែលមនុស្សអ្នកកើតសេចក្តីសង្វេគ សមាទានដោយខ្លួនឯង ខាងចុងនៃសត្ថន្តរកប្ប គឺកប្បដែលសម្លាប់គ្នាដោយសស្ត្រាវុធ ។ តែឈាន និងវិបស្សនា មគ្គ និងផល គប្បីជ្រាបថា ក្រៃលែងជាងមនុស្សធម៌នោះ ។

បទថា **អលមរិយញ្ញាណទស្សនវិសេសំ** សេចក្តីថា គុណវិសេស ពោល គឺញាណទស្សនៈដែលគួរដល់ព្រះអរិយៈទាំងឡាយ ឬដែលអាចធ្វើឲ្យបានជាអរិយៈ ។ ពិតហើយ ញាណនោះឯង គប្បីជ្រាបថា ញាណ ព្រោះអត្ថថា ដឹង ថា ទស្សនៈ ព្រោះអត្ថថា ឃើញ ។ បទថា **អលម-រិយញ្ញាណទស្សនវិសេសំ** នេះ ជាឈ្មោះរបស់ទិព្វចក្ខុញ្ញាណ វិបស្សនា-ញាណ មគ្គញ្ញាណ ផលញ្ញាណ និងបច្ចវេក្ខណញ្ញាណ ។

## អដ្ឋកថាសូត្រទី ៨ ចប់

# អដ្ឋកថាសូត្រទី ៦

[ ៤៧ ] ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អច្ឆោ** ប្រែថា មិនមានមន្ទិល ។ បាលីថា **បសន្នោ** ប្រែថា ថ្លា ដូច្នេះក៏គួរ ។ បទថា **វិប្បសន្នោ** ប្រែថា ថ្លាល្អ ។ បទថា **អនាវិលោ** ប្រែថា មិនល្អក់ អធិប្បាយថា បរិសុទ្ធ ។ លោកអធិប្បាយថា វៀរចាកពពុះទឹក សារាយ និងចកតូច ចកធំ ។ បទថា **អនាវិលេន** បានដល់ ប្រាសចាកនីវរណៈ ៥ ពាក្យដ៏សេសមានន័យដូចពោលហើយ ក្នុងសូត្រទី ៤ នោះឯង ។ ក្នុងសូត្រទាំង ២ នេះ លោកពោលវដ្ដៈផង វិវដ្ដៈផង ដូច្នេះឯង ។

### អដ្ឋកថាសូត្រទី ៦ ចប់

# អដ្ឋកថាសូត្រទី ៧

[ ៤៨ ] ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ បទថា **រុក្ខជាតានំ** ជាឆដ្ឋីវិភត្តិ ប្រើក្នុងអត្ថបឋមាវិភត្តិ អធិប្បាយថា **រុក្ខជាតានិ** គឺដើមឈើទាំងឡាយ ។ បទថា **រុក្ខជាតានិ** នេះ ជាឈ្មោះនៃដើមឈើទាំងឡាយ ។ បទថា **យទិទំ** ត្រឹមតែជានិបាត ។ បទថា **មុទុតាយ** បានដល់ ព្រោះជាឈើទន់ ។ ទ្រង់សម្ដែងថា ដើមឈើប្រភេទខ្លះល្អក្រៃលែង ដោយពណ៌ ប្រភេទខ្លះល្អដោយក្លិន ប្រភេទខ្លះក្រៃលែងដោយរស ប្រភេទខ្លះក្រៃលែងដោយរបស់រឹង ។ ចំណែកដើមចន្ទន៍ ជារបស់ក្រៃលែង គឺប្រសើរ ព្រោះជា

ឈើទន់ និងសមគួរដល់ការងារ ។

ក្នុងបទថា **ចិត្តំ ភិក្ខវេ ភាវិតំ ពហុលីកតំ** នេះ លោកបំណងយក ចិត្តដែលអប់រំ និងធ្វើរឿយៗ ដោយអំណាចសមថៈ និងវិបស្សនា ចំណែក ក្រុនកវាសីបុស្សមិត្តត្ថេរ ពោលថា អាវុសោ ចិត្តក្នុងចតុត្ថជ្ឈានដែលជាបាទ របស់អភិញ្ញាប៉ុណ្ណោះ ឈ្មោះថា ចិត្តទន់ភ្លន់ និងសមគួរដល់ការងារដោយ ចំណែកមួយ ។

**អដ្ឋកថាសូត្រទី ៧ ចប់**

## អដ្ឋកថាសូត្រទី ៨

[ ៤៩ ] ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ឯវំ លហុបរិវត្តំ** សេចក្ដីថា កើតរហ័ស រលត់រហ័ស ដោយអាការយ៉ាងនេះ ។ សព្ទថា **យាវញ្ច** ជានិបាត ប្រើក្នុងអត្ថប៉ុនគ្នានឹង **អធិមត្ត** មានប្រមាណ ក្រៃលែង អធិប្បាយថា មិនមែនធ្វើបានដោយងាយឡើយ ។ បទថា **ឥធំ** ត្រឹមតែជានិបាត ។ ក្នុងបទថា **ចិត្តំ** ជាបឋម អាចារ្យពួកខ្លះពោលថា ជា ភវង្គចិត្ត ។ តែលោកបដិសេធពាក្យនោះ ហើយពោលថា ចិត្តដូចឯណា នីមួយ ដោយហោចសូម្បីចក្ខុវិញ្ញាណ ក៏បំណងយកថា ជាចិត្តក្នុងទីនេះ ។

តែក្នុងទីនេះ ព្រះបាទមិលិន្ទត្រាស់សួរព្រះនាគសេន ដែលជាព្រះធម្ម-

កបិកថា បពិត្រព្រះនាគសេន ចិត្តសង្ខារដែលប្រព្រឹត្តទៅមួយខណៈផ្ទាត់ម្រាមដៃមួយ បើគិតជារូបរាង មានគំនរប៉ុនណា ព្រះនាគសេនពោលថា បពិត្រមហារាជ ស្រូវ ១០០ វាហៈ ខ្វះកន្លះវាហៈ ៧ អម្ពនៈ និង ២ តុម្ពៈ រមែងមិនដល់នូវការរាប់ រមែងមិនដល់ការគណនា រមែងមិនដល់ចំណែកនៃការគណនានៃចិត្តដែលប្រព្រឹត្តទៅមួយខណៈផ្ទាត់ម្រាមដៃមួយ ។ សួរថា កាលបើដូច្នោះ ព្រោះហេតុអ្វី ទើបព្រះសម្មាសម្ពុទ្ធត្រាស់ថា សូម្បីឧបមាក៏ធ្វើមិនបានងាយឡើយ ។ ឆ្លើយថា សូម្បីលោកបដិសេធឧបមាដោយស្រូវ ក៏បានធ្វើឧបមាប្រវែងនៃកប្ប ដោយប្រៀបធៀបជាមួយភ្នំមួយយោជន៍ និងនគរពេញទៅដោយគ្រាប់ស្ពៃ ទំហំមួយយោជន៍ ប្រៀបទុក្ខរបស់សត្វនរក ដោយប្រៀបធៀបនឹងការចាក់ដោយលំពែង ១០០ ប្រៀបសេចក្តីសុខក្នុងស្ថានសួគ៌ ដោយប្រៀបធៀបនឹងសម្បត្តិស្តេចចក្រពត្តិ យ៉ាងណា ក្នុងទីនេះ ក៏គប្បីធ្វើឧបមាយ៉ាងនោះ ។ ក្នុងមិលិន្ទបញ្ហានោះ លោកធ្វើឧបមាដោយអំណាចពាក្យសួរយ៉ាងនេះថា បពិត្រលោកម្ចាស់ លោកម្ចាស់អាចធ្វើឧបមាបានទេ តែក្នុងសូត្រនេះ លោកមិនបានធ្វើឧបមា ព្រោះមិនមានការសួរ ។ ពិតហើយ ព្រះសូត្រនេះ លោកពោលទុកខណៈចប់ព្រះធម្មទេសនា ។ ព្រះសូត្រនេះ លោកហៅឈ្មោះថា ចិត្តរាសី គឺគំនរចិត្ត ដោយប្រការដូច្នេះ ។

**អដ្ឋកថាសូត្រទី ៨ ចប់**

# អដ្ឋកថាសូត្រទី ៩

[ ៥០ ] ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ បទថា **បភស្សរំ** បានដល់ ស គឺបរិសុទ្ធ ។ បទថា **ចិត្តំ** បានដល់ ភវង្គចិត្ត ។ សួរថា ឈ្មោះថា ពណ៌របស់ចិត្តមានឬ ឆ្លើយថា មិនមាន ។ ពិតហើយ ចិត្តមានពណ៌ឯណានីមួយ មានពណ៌ខៀវជាដើម ឬជាពណ៌មាសក្តី ពណ៌ឯណានីមួយ លោកក៏ហៅថា **បភស្សរ** ព្រោះជាចិត្តបរិសុទ្ធ ។ ចិត្តនេះ ឈ្មោះថា បរិសុទ្ធ ព្រោះប្រាសចាកឧបក្កិលេស ហេតុនោះ ឈ្មោះថា **បភស្សរ** ។ បទថា **តញ្ច ខោ** បានដល់ ភវង្គចិត្តនោះ ។ បទថា **អាគន្តុកេហិ** បានដល់ ឧបក្កិលេសដែលមិនកើតរួមគ្នា បើកើតកើតក្នុងខណៈនៃជវនចិត្តខាងក្រោយ ។ បទថា **ឧបក្កិលេសេហិ** សេចក្តីថា ភវង្គចិត្តនោះ លោកហៅថា ឈ្មោះថា សៅហ្មងហើយ ព្រោះសៅហ្មងហើយដោយកិលេស មានរាគៈជាដើម ។ សៅហ្មងដូចម្តេច ឧបមាដូចមានមាតាបិតា ឬឧបជ្ឈាយ៍ អាចារ្យ បរិបូណ៌ដោយសីល ដោយអាចារ មិនកាច គឺមិនឲ្យសិក្សា មិនទូន្មាន មិនប្រៀនប្រដៅកូន ឬអន្តេវាសិក និងសទ្ធិវិហារិករបស់ខ្លួន ព្រោះកូន និងសទ្ធិវិហារិក អន្តេវាសិកជាអ្នកទ្រុស្តសីល មានការប្រព្រឹត្តមិនល្អ មិនសម្បូរដោយវត្តបដិបត្តិ រមែងបានទទួលការតិះដៀល ខូចកេរ្តិ៍ឈ្មោះ យ៉ាងណា គប្បីជ្រាបសេចក្តីឧបមេយ្យនោះ ដូច្នោះ ។ គប្បីឃើញភវង្គចិត្ត ដូចមាតាបិតា ឧបជ្ឈាយ៍ អាចារ្យដែលសម្បូរដោយអាចារ ភវង្គចិត្តនឹងបរិសុទ្ធតាមប្រក្រតី ក៏ឈ្មោះថា សៅហ្មង ព្រោះឧបក្កិលេសដែលចរមក ដែលកើតឡើងដោយអំណាចសហគតៈជាមួយលោភៈ ទោសៈ និងមោហៈ ដែលមានសេចក្តី

តម្រេក អាក់អន់ និងការវង្វេងជាសភាវៈ ក្នុងខណៈនៃជវនចិត្ត ដូចមាតាបិតាជាដើមនោះ បាននូវការខូចកេរ្តិ៍ឈ្មោះ ព្រោះកូនជាដើមដូច្នោះឯង ។

**អដ្ឋកថាសូត្រទី ៩ ចប់**

## អដ្ឋកថាសូត្រទី ១០

[ ៥១ ] ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ចិត្ត គឺកវង្គចិត្តនោះឯង ។ បទថា **វិប្បមុត្តំ** សេចក្តីថា ភវង្គចិត្តនោះ មិនត្រេកអរ មិនអាក់អន់ មិនវង្វេង ក្នុងខណៈនៃជវនចិត្ត កើតឡើងដោយអំណាចកុសលចិត្ត ដែលជាញាណសម្បយុត្ត ប្រកបដោយត្រៃហេតុជាដើម រមែងឈ្មោះថារួចផុតចាកឧបក្កិលេសទាំងឡាយដែលចរមក ។ ក្នុងទីនេះ ភវង្គចិត្ត លោកហៅថា រួចផុតហើយចាកឧបក្កិលេសទាំងឡាយដែលចរមក ដោយអំណាចកុសលចិត្តដែលកើតឡើងក្នុងខណៈនៃជវនចិត្ត ដូចមាតាជាដើម បានទទួលការសរសើរ និងកេរ្តិ៍ឈ្មោះថា ពួកលោកទាំងនេះល្អពិត ញុំាងកូនជាដើមឲ្យសិក្សាឲ្យឱវាទ ឲ្យអនុសាសន៍ ដូច្នេះ ព្រោះកូនជាដើម ជាអ្នកមានសីលសម្បូរដោយអាចារ ដូច្នោះ ។

**អដ្ឋកថា សូត្រទី ១០ ចប់**

**បណិហិតអច្ឆវគ្គទី ៥ ចប់**

# សុត្តន្តបិដក

## អច្ឆរាសង្ឃាតវគ្គទី ៦

[ ៥២ ] ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះមានរស្មីផ្សាយចេញ ប៉ុន្តែ ភវង្គចិត្តនោះឯង ត្រូវឧបក្កិលេសទាំងឡាយជាអាគន្តុក ចូលមកធ្វើឲ្យ សៅហ្មង បុថុជ្ជនជាអ្នកមិនចេះដឹង រមែងមិនស្គាល់ច្បាស់នូវភវង្គចិត្តនោះ តាមសេចក្ដីពិត ព្រោះហេតុនោះ បានជាតថាគតពោលថា បុថុជ្ជនជាអ្នក មិនចេះដឹង មិនមានការចម្រើនចិត្តទេ ។

[ ៥៣ ] ម្នាលភិក្ខុទាំងឡាយ ភវង្គចិត្តនេះមានរស្មីផ្សាយចេញ ដ្បិត ភវង្គចិត្តនោះឯង ផុតស្រឡះចាកឧបក្កិលេសទាំងឡាយ ដែលជាអាគន្តុក អរិយសាវកជាអ្នកចេះដឹង រមែងស្គាល់ច្បាស់នូវភវង្គចិត្តនោះ តាមសេចក្ដី ពិត ព្រោះហេតុនោះ បានជាតថាគតពោលថា អរិយសាវកជាអ្នកចេះដឹង ទើបមានការចម្រើនចិត្ត ។

[ ៥៤ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុគប់ប្រសព្វនឹងមេត្តចិត្តសូម្បី ១ ផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា មានឈានមិន បានលះបង់ ជាអ្នកធ្វើតាមសាសនាព្រះសាស្ដា ជាអ្នកធ្វើតាមឱវាទព្រះ-សាស្ដា បរិភោគបិណ្ឌបាតរបស់អ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុ ដែលសន្សំរឿយៗ នូវមេត្តចិត្តនោះ ។

[ ៥៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុចម្រើននូវមេត្តចិត្តសូម្បី ១ ផ្ទាត់ ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា មានឈានមិនបាន

លះបង់ ជាអ្នកធ្វើតាមសាសនាព្រះសាស្តា ជាអ្នកធ្វើតាមឱវាទព្រះសាស្តា បរិភោគបច្ច័យអ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

[ ៥៦ ] ម្នាលភិក្ខុទាំងឡាយ បើភិក្ខុត្រិះរិះនូវមេត្តាចិត្ត សូម្បី ១ ផ្ទាត់ម្រាមដៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនេះ តថាគតហៅថា មានឈានមិនបានលះបង់ ជាអ្នកធ្វើតាមសាសនាព្រះសាស្តា ជាអ្នកធ្វើតាមឱវាទព្រះសាស្តា បរិភោគបច្ច័យអ្នកដែន មិនឥតអំពើ ចាំបាច់និយាយថ្វី ដល់ពួកភិក្ខុដែលសន្សំរឿយៗ នូវមេត្តាចិត្តនោះ ។

[ ៥៧ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាអកុសល ជាចំណែកខាងអកុសល ជាពួកនៃអកុសល ធម៌ជាអកុសលទាំងអស់នោះ មានចិត្តជាប្រធាន ចិត្តរមែងកើតមុនធម៌ទាំងនោះ អកុសលធម៌ទាំងឡាយ ក៏កើតជាមួយគ្នា ។

[ ៥៨ ] ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយណានីមួយ ជាកុសល ជាចំណែកខាងកុសល ជាពួកនៃកុសល ធម៌ជាកុសលទាំងអស់នោះ មានចិត្តជាប្រធាន ចិត្តរមែងកើតមុនធម៌ទាំងនោះ ធម៌ជាកុសលទាំងឡាយ ក៏កើតជាមួយគ្នា ។

[ ៥៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈមួយ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូច

សេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលប្រមាទហើយ ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកកុសលធម៌ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

[ ៦០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈមួយដែលញ៉ាំងពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនប្រមាទហើយ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៦១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈមួយ ដែលញ៉ាំងពួកអកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលខ្ជិលច្រអូសហើយ ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

**វគ្គទី ៦ ចប់**

# អដ្ឋកថា

# អច្ឆរាសង្ឃាតវគ្គទី ៦

## សូត្រទី ១

[ ៥២ ] ក្នុងសូត្រទី ១ នៃវគ្គទី ៦ មានវិនិច្ឆ័យដូចតទៅនេះ បទថា **តំ អស្សុតវា បុថុជ្ជនោ** សេចក្តីថា បុថុជ្ជន វៀរហើយចាកការសិក្សាភវង្គចិត្តនោះ ។ ក្នុងបទថា **តំ អស្សុតវា បុថុជ្ជនោ** នោះ ឈ្មោះថា មិនបានសិក្សាញៀយ្យធម៌ ព្រោះមិនមានអាគម និកាយ ដែលនឹងរៀន និងអធិគម មគ្គផលដែលនឹងសម្រេច ។ ពិតហើយ បុគ្គលណាសាកសួរព្រះសូត្រនេះ ដោយអត្ថតាំងអំពីដើម គង់មិនដឹងដោយអំណាចនិកាយ គឺគម្ពីរដែលមករបស់សូត្រនេះ ដោយអត្ថតាំងអំពីដើម មិនទាន់ដឹងដោយអំណាចនិកាយ គឺគម្ពីរដែលមករបស់សូត្រនេះ និងដោយអំណាចមគ្គផល ដែលអ្នកបដិបត្តិគប្បីចាក់ធ្លុះថា ឈ្មោះថា ភវង្គចិត្តនេះ សូម្បីបរិសុទ្ធតាមប្រក្រតី ក៏សៅហ្មងព្រោះឧបក្កិលេស មានលោភៈជាដើម ដែលកើតឡើងហើយ ក្នុងខណៈនៃជវនចិត្ត ។ ម្យ៉ាងទៀត បុគ្គលណា មិនមាននិកាយជាទីមក ដែលនឹងពិចារណាធម៌ឲ្យយល់តាមការពិត ព្រោះវៀរការរៀន និងការសាកសួរក្នុងខន្ធ ធាតុ អាយតនៈ បច្ចយាការ និងសតិប្បដ្ឋានជាដើម និងមិនមានអធិគម ព្រោះមិនបានសម្រេចមគ្គផល ដែលគប្បីសម្រេច ដោយកិច្ចបដិបត្តិ បុគ្គលនោះ ឈ្មោះថា មិនសិក្សាញៀយ្យធម៌ ព្រោះមិនមានអាគម និងអធិគម

បុថូនំ ជនធាតីហិ ការណេហិ បុថុជ្ជនោ
បុថុជ្ជនន្តោ គធត្តា បុថុ វាយំ ជនោ ឥតិ ។

ជននេះ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងឡាយ មានធ្វើកិលេសជាច្រើនឲ្យកើតឡើងជាដើម ឬឈ្មោះថា បុថុជ្ជន ព្រោះឈមចុះខាងក្នុងនៃជន ដែលមានកិលេសក្រាស់ ។

ពិតហើយ ជននោះ ឈ្មោះថា បុថុជ្ជន ព្រោះហេតុទាំងឡាយ មានការធ្វើឲ្យកើតកិលេស មានប្រការផ្សេងៗ ជាច្រើន ដូចដែលលោកពោលថា ឈ្មោះថា បុថុជ្ជន ព្រោះធ្វើឲ្យកើតកិលេសជាច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះមាន សក្កាយទិដ្ឋិ ដែលមិនលះបង់ជាច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះតាក់តែងដោយអភិសង្ខារផ្សេងៗ ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវឱឃកិលេស ដូចអន្លង់ទឹកផ្សេងៗ ជាច្រើនកួចនាំទៅ ។ ឈ្មោះថា បុថុជ្ជន ព្រោះក្តៅក្រហាយ ដោយគ្រឿងក្តៅក្រហាយដ៏ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រេកអរ តម្រេក លោភលន់ ជប់ជ្រប់ វង្វេង ជាប់ជំពាក់ ស្អិតស្អាញក្នុងកាមគុណទាំង ៥ ច្រើន ។ ឈ្មោះថា បុថុជ្ជន ព្រោះត្រូវនីវរណៈ ៥ គ្របដណ្តប់ បិទបាំង រាំង ខ្ទាំងខ្ទប់ច្រើន ។ ម្យ៉ាងទៀត ឈ្មោះថាបុថុជ្ជន ព្រោះឈមចុះខាងក្នុងនៃជនដែលមានកិលេសក្រាស់ ប្រព្រឹត្តទៅកន្លងនូវការរាប់ ជាអ្នកបែរខ្នងក្នុងអរិយធម៌ ជាអ្នកប្រព្រឹត្តធម៌ថោកទាប ដូច្នេះក៏មាន ។ បុថុជ្ជននេះ រាប់ថាជាបុគ្គលមួយពួកនោះឯង ។ ឈ្មោះថា បុថុជ្ជន ព្រោះជាអ្នកមិនទាក់ទងនឹងព្រះអរិយៈ ដែលប្រកបដោយគុណ មានសីល និងសុតៈ

ជាដើម ។ ដោយពីរបទថា **អស្សុតវា បុថុជ្ជនោ** ដូចពណ៌នាមកយ៉ាងនេះ លោកពោលបុថុជ្ជនឯណា បុថុជ្ជននោះ មាន ២ ពួក ដូចគាថាថា

**ទុវេ បុថុជ្ជនា វុត្តា ពុទ្ធេនាទិច្ចពន្ធុនា**
**អន្ធោ បុថុជ្ជនោ ឯកោ កល្យាណោកោ បុថុជ្ជនោ ។**

ព្រះពុទ្ធ ជាផៅពង្សនៃព្រះអាទិត្យ ត្រាស់បុថុជ្ជន ២ ពួក គឺអន្ធបុថុជ្ជន ១ កល្យាណបុថុជ្ជន ១ ។

បណ្ដាបុថុជ្ជន ដែលបានពោលហើយទាំង ២ ពួកនោះ អន្ធបុថុជ្ជន គប្បីជ្រាបថា បានពោលហើយ ។ បទថា **យថាភូតំ នប្បជានាតិ** សេចក្ដីថា បុថុជ្ជនជាអ្នកមិនបានស្ដាប់ រមែងមិនដឹងតាមពិតថា ភវង្គចិត្តនេះ ឈ្មោះថា សៅហ្មងព្រោះឧបក្កិលេសទាំងឡាយដែលចរមកយ៉ាងនេះ ឈ្មោះថា រួចផុតហើយយ៉ាងនេះ ។ បទថា **តស្មា** សេចក្ដីថា ព្រោះហេតុដែលមិនដឹង ។ បទថា **ចិត្តភាវនា នត្ថិ** បានដល់ ការតាំងមាំនៃចិត្ត ការកំណត់ចិត្តមិនមាន ។ ដោយការៈដែលមិនមាននោះឯង ទ្រង់សម្ដែងថា តថាគតពោលថា មិនមាន ដូច្នេះ ។

## អដ្ឋកថាសូត្រទី ១ ចប់

# អដ្ឋកថាសូត្រទី ២

[ ៥៣ ] ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ បទថា **សុតវា** បានដល់ ដល់ព្រមដោយការសិក្សា ។ ក្នុងបទថា **សុតវា** នេះ កាលពោលដោយពិស្តារ គប្បីជ្រាបសេចក្តីដោយផ្ទុយគ្នានឹងបទថា **អស្សុតវា** ។

បទថា **អរិយសាវកោ** បានដល់ ព្រះអរិយៈដែលមិនជាព្រះសាវកក៏មាន ដូចជាព្រះពុទ្ធ និងព្រះបច្ចេកពុទ្ធ ។ ព្រះសាវកដែលមិនជាព្រះអរិយៈក៏មាន ដូចជាគ្រហស្ថដែលមិនទាន់ចាក់ធ្លុះផល ។ មិនជាព្រះអរិយៈផងមិនជាព្រះសាវកផងក៏មាន ដូចគ្នានឹងពួកតិរ្ថិយជាច្រើន ។ ព្រះអរិយៈផងព្រះសាវកផងក៏មាន ដូចព្រះសមណសក្យបុត្រ ដែលត្រាស់ដឹងផល ដឹងច្បាស់នូវពាក្យទូន្មានហើយ ។ តែក្នុងទីនេះ ទោះជាគ្រហស្ថក្តី បព្វជិតក្តីណាមួយ ដែលសម្បូរដោយការសិក្សា ដោយអំណាចនៃអត្ថ ដែលបានពោលហើយ គប្បីជ្រាបថា បុគ្គលនេះ ជាព្រះអរិយសាវក ក្នុងបទថា **សុតវា** នេះ ។

បទថា **យថាភូតំ បជានាតិ** ព្រះអរិយសាវកអ្នកបានស្តាប់ហើយរមែងដឹងច្បាស់សេចក្តីពិតថា ភវង្គចិត្តនេះ រួចផុតហើយចាកឧបក្កិលេសទាំងឡាយ ដែលចរមកដោយអាការយ៉ាងនេះ សៅហ្មងហើយដោយអាការយ៉ាងនេះ ។ បទថា **ចិត្តភាវនា អត្ថិ** សេចក្តីថា ការតាំងមាំនៃចិត្ត ការកំណត់ចិត្តមាន ដោយការៈដែលចិត្តមាននោះឯង ទ្រង់សម្តែងថាមាន ។ ក្នុងសូត្រនេះ លោកពោលដល់វិបស្សនាដែលចាស់ក្លា ។ អាចារ្យពួកខ្លះពោលថា ជាវិបស្សនាដែលខ្សោយកម្លាំង ។

# អដ្ឋកថាសូត្រទី ៣

[ ៥៤ ] ក្នុងសូត្រទី ៣ បានពោលហើយ ក្នុងអត្ថុប្បត្តិហេតុ ពោលក្នុងអត្ថុប្បត្តិហេតុណា គឺក្នុងអត្ថុប្បត្តិហេតុនៃអគ្គិក្ខន្ធោបមសូត្រ ។

បានឮថា សម័យមួយ ព្រះមានព្រះភាគ អាស្រ័យនៅនាជេតវនមហាវិហារ ក្រុងសាវត្ថី ។ ពិតហើយ ព្រះពុទ្ធទាំងឡាយ ទ្រង់នៅអាស្រ័យក្នុងទីឯណាទីមួយ ទ្រង់ក៏មិនបានលះកិច្ច ៥ យ៉ាងឡើយ ។

ឈ្មោះថា ពុទ្ធកិច្ច ៥ យ៉ាង គឺបុរេភត្តកិច្ច ១ បច្ឆាភត្តកិច្ច ១ បុរិមយាមកិច្ច ១ មជ្ឈិមយាមកិច្ច ១ បច្ឆិមយាមកិច្ច ១ ។

ក្នុងពុទ្ធកិច្ច ៥ នោះ បុរេភត្តកិច្ច កិច្ចមុនសោយអាហារ មានដូចតទៅនេះ ពិតហើយ ព្រះមានព្រះភាគ ទ្រង់តើនអំពីព្រលឹម ទ្រង់ធ្វើបរិកម្មព្រះសរីរៈ មានលុបព្រះភក្ត្រជាដើម ដើម្បីអនុគ្រោះឧបដ្ឋាក និងដើម្បីផាសុកនៃសរីរៈ ទ្រង់សម្រាកលើអាសនៈដ៏ស្ងាត់ រហូតដល់ពេលភិក្ខាចារ លុះបានពេលភិក្ខាចារ ទ្រង់ក៏ស្លៀកអន្តរវាសក ទ្រង់ចងវត្ថពន្ធចង្កេះ ដណ្តប់ចីវរកាន់បាត្រ ជួនកាលទ្រង់យាងមួយអង្គឯង ជួនកាលក៏ចោមរោមទៅដោយភិក្ខុសង្ឃ ចូលទៅបិណ្ឌបាត កាន់ស្រុក ឬនិគម ។ ជួនកាលយាងទៅតាមប្រក្រតី ជួនកាលយាងទៅដោយបាដិហារ្យជាច្រើន ។ កាលព្រះលោកនាថទ្រង់ត្រាច់បិណ្ឌបាត ខ្យល់ស្រាលៗ ក៏បក់ទៅខាងមុខ ធ្វើផែនដីឲ្យស្អាតមេឃបង្អុរភ្លៀង រម្ងាប់ធូលីលើផ្លូវ និងបាំងជាពិតានខាងលើ ។ ខ្យល់មួយពួកទៀត ក៏នាំផ្កាចូលទៅរោយរាយលើផ្លូវ ភូមិប្រទេសដែលទួលក៏ស្រុតចុះភូមិប្រទេសដែលទំនាបក៏ប៉ោងឡើង វេលាទ្រង់ឈានជំហាន ភូមិភាគរមែង

មានផ្ទៃរាបស្មើ ឬផ្កាបទុម មានសម្ផស្សដ៏ស្រទន់ រង់ចាំទទួលព្រះបាទ ។ កាល ទ្រង់ដាក់ព្រះបាទខាងស្តាំខាងក្នុងសសរខឿន ឆព្វណ្ណរង្សី គឺព្រះរស្មីមាន ពណ៌ ៦ ប្រការ ផ្សាយចេញអំពីព្រះសរីរៈ បាចសាចទៅគ្រប់ទិស ធ្វើប្រា-សាទ និងផ្ទះកំពូលជាដើម ឲ្យមានពណ៌លឿងដូចមាស និងដូចពាសដោយ សំពត់ដ៏វិចិត្រ ។ សត្វទាំងឡាយ មានដំរី សេះ និងបក្សីជាដើម ដែលនៅ ក្នុងលំនៅរបស់ខ្លួន ក៏បន្លឺសំឡេងពីរោះ ។ តូរ្យ មានស្គរធំ និងស្គរតូច ជាដើម និងគ្រឿងអាភរណៈ ដែលពាក់ជាប់នៅក្នុងកាយរបស់ពួកមនុស្ស ក៏ដូចគ្នា គឺបន្លឺសំឡេងពីរោះ ដោយសញ្ញានោះ ពួកមនុស្សរមែងដឹងថា ថ្ងៃ នេះ ព្រះសាស្តាទ្រង់ចូលទៅបិណ្ឌបាតក្នុងទីនេះ ។ មនុស្សទាំងនោះ ស្លៀក បណ្តប់ល្អល្អិត កាន់គ្រឿងសក្ការៈ មានគ្រឿងក្រអូប និងផ្កាជាដើម ចេញ អំពីផ្ទះ ដើរទៅតាមជនវិថី បូជាព្រះមានព្រះភាគ ដោយគ្រឿងក្រអូប និងផ្កា ជាដើមដោយគោរព ថ្វាយបង្គំហើយ ទូលអារាធនាថា បពិត្រព្រះអង្គដ៏ ចម្រើន សូមព្រះអង្គមេត្តាប្រទានភិក្ខុដល់ពួកខ្ញុំព្រះអង្គ ១០ រូប ដល់ពួកខ្ញុំ ព្រះអង្គ ២០ រូប ដល់ពួកខ្ញុំព្រះអង្គ ១០០ រូប ហើយទទួលបាត្ររបស់ព្រះ មានព្រះភាគ ក្រាលអាសនៈ បង្អោនថ្វាយបិណ្ឌបាតដោយគោរព ។ ព្រះ មានព្រះភាគ ទ្រង់សោយព្រះក្រយាហារស្រេចហើយ ទ្រង់ប្រមើលមើល សន្តានរបស់មនុស្សទាំងនោះ រួចទ្រង់សម្តែងធម៌ ។ បុគ្គលពួកខ្លះ តាំងនៅ ក្នុងសរណគមន៍ ពួកខ្លះតាំងនៅក្នុងសីល ៥ ពួកខ្លះតាំងនៅក្នុងសោតាបត្តិ-ផល សកទាគាមិផល និងអនាគាមិផលណាមួយ ជនពួកខ្លះដែលបួសហើយ

តាំងនៅក្នុងអរហត្ត ដែលជាអគ្គផល ដោយប្រការណា ទ្រង់អនុគ្រោះមហាជន ដោយប្រការនោះ ទ្រង់ក្រោកចាកអាសនៈ ត្រឡប់ទៅកាន់ព្រះវិហារ ។ ទ្រង់យាងទៅឯព្រះវិហារនោះហើយ ប្រថាប់គង់លើបវរពុទ្ធាសនៈដែលគេរៀបចំទុកក្នុងសាលាមូល ប្រកបដោយគ្រឿងក្រអូប ។ ក្នុងវេលាស្រេចភត្តកិច្ចរបស់ភិក្ខុទាំងឡាយ ឧបដ្ឋាកក៏ក្រាបទូលព្រះមានព្រះភាគឲ្យទ្រង់ជ្រាប ។ បន្ទាប់អំពីនោះ ទើបព្រះមានព្រះភាគចូលព្រះគន្ធកុដិ បុរេភត្តកិច្ច គឺកិច្ចមុនសោយអាហារ មានប្រមាណប៉ុណ្ណេះ ។

កាលព្រះមានព្រះភាគ ទ្រង់ធ្វើកិច្ចមុនសោយអាហារយ៉ាងនេះហើយ ក៏ប្រថាប់គង់ត្រង់យ៉មុខព្រះគន្ធកុដិ ទ្រង់លាងព្រះបាទ ទ្រង់ឲ្យឱវាទដល់ភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរញ៉ាំងកិច្ចឲ្យដល់ព្រម ដោយការមិនប្រមាទចុះ ការកើតឡើងនៃព្រះពុទ្ធ រកបានដោយកម្រ អត្តភាពជាមនុស្សរកបានដោយកម្រ ការដល់ព្រមដោយសទ្ធារកបានដោយកម្រ ការបានបព្វជ្ជាជាការក្រ ការស្តាប់ធម៌ រកបានដោយក្រក្នុងលោក បណ្តាភិក្ខុទាំងនោះ ភិក្ខុរូបខ្លះទូលសួរកម្មដ្ឋានជាមួយ ព្រះមានព្រះភាគ ព្រះអង្គក៏ប្រទានកម្មដ្ឋានដែលសមគួរដល់ការប្រព្រឹត្តរបស់ភិក្ខុទាំងនោះ បន្ទាប់អំពីនោះ ភិក្ខុទាំងអស់ថ្វាយបង្គំព្រះមានព្រះភាគ ហើយទៅកាន់ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ រៀងៗ ខ្លួន ពួកខ្លះទៅព្រៃ ពួកខ្លះនៅត្រង់គល់ឈើ ពួកខ្លះទៅត្រង់ភ្នំជាដើម ទីណាមួយ ពួកខ្លះទៅកាន់ភពរបស់ស្តេចចាតុម្មហារាជ ពួកខ្លះទៅកាន់ភពរបស់វសវត្តី ។ លំដាប់នោះ ព្រះមានព្រះភាគ យាងចូលទៅ

កាន់ព្រះគន្ធកុដិ បើទ្រង់សិង ក៏ទ្រង់មានសតិសម្បជញ្ញៈ ផ្ទំផ្អៀងស្តាំមួយស្របក់ កាលព្រះកាយស្រពន់ ទ្រង់តើនឡើង ប្រមើលមើលសត្វលោកក្នុងភាគទី ២ ។ ក្នុងភាគទី ៣ មហាជនក្នុងគាម ឬនិគម ដែលទ្រង់យាងចូលទៅអាស្រ័យប្រថាប់ ថ្វាយទានមុនភត្ត ក្នុងកាលក្រោយភត្ត ស្លៀកដណ្តប់ស្រេចបាច់ហើយ កាន់យកសក្ការៈ មានគ្រឿងក្រអូប និងផ្កាជាដើម ប្រជុំគ្នាក្នុងព្រះវិហារ ។ លំដាប់នោះ ព្រះមានព្រះភាគ យាងទៅដោយបាដិហារ្យដែលសមគួរដល់បរិស័ទកំពុងប្រជុំគ្នា ប្រថាប់គង់សម្តែងធម៌ លើបវរពុទ្ធាសនៈ ដែលតាក់តែងក្នុងធម្មសភា ឲ្យសមគួរដល់កាល សមគួរដល់សម័យ ។ កាលដល់វេលាសមគួរហើយ ទើបបញ្ជូនបរិស័ទត្រឡប់ទៅ ។ ពួកមនុស្សថ្វាយបង្គំព្រះមានព្រះភាគហើយ ចៀសចេញទៅ ។ បច្ឆាភត្តកិច្ចកិច្ចខាងក្រោយអាហារ មានដូចពោលមកនេះ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់ធ្វើបច្ឆាភត្តកិច្ចឲ្យស្រេចយ៉ាងនោះហើយ បើទ្រង់បំណងស្រពស្រង់ព្រះកាយ ក៏យាងក្រោកឡើងអំពីពុទ្ធាសនៈ ទៅកាន់ទីសម្រាប់ស្រពស្រង់ ទ្រង់ស្រពព្រះកាយដោយទឹកដែលឧបដ្ឋាករៀបចំថ្វាយ សូម្បីពុទ្ធុបដ្ឋាក ក៏នាំយកពុទ្ធាសនៈមកក្រាលថ្វាយ ក្នុងបរិវេណព្រះគន្ធកុដិ ព្រះមានព្រះភាគ ទ្រង់ស្លៀកអន្តរវាសក ២ ជាន់ ដែលជ្រលក់ល្អហើយ ទ្រង់ចងវត្ថពន្ធចង្កេះ ទ្រង់គ្រងឧត្តរាសង្គហើយ យាងមកប្រថាប់លើពុទ្ធាសនៈនោះ ទ្រង់សម្រាកមួយស្របក់ តាមអធ្យាស្រ័យរបស់ព្រះអង្គ ។ លំដាប់នោះ ភិក្ខុទាំងឡាយមកអំពីទីនោះ ទៅកាន់ទីគាល់ព្រះសាស្តា បណ្តាភិក្ខុទាំង

នោះ ពួកខ្លះសួរបញ្ហា ពួកខ្លះសូមកម្មដ្ឋាន ពួកខ្លះសូមស្តាប់ធម៌ ។ ព្រះមានព្រះភាគទ្រង់រៀបចំឲ្យសមបំណងរបស់ភិក្ខុទាំងនោះ ទ្រង់សម្រាកអស់បឋមយាម ។ បុរិមយាមកិច្ច គឺកិច្ចក្នុងយាមខាងដើម មានដូចពោលនេះ ។

វេលាស្រេចកិច្ចក្នុងយាមខាងដើម កាលភិក្ខុទាំងឡាយថ្វាយបង្គំព្រះមានព្រះភាគ ហើយចៀសចេញទៅ ទេវតាក្នុងម៉ឺនលោកធាតុ កាលបានឱកាស ទើបចូលទៅគាល់ព្រះមានព្រះភាគសួរបញ្ហា ដោយហោច សូម្បីត្រឹមតែអក្ខរៈ ៤ តួ ដែលបានចងមក ព្រះមានព្រះភាគ កាលទ្រង់វិសជ្ជនាបញ្ហាដល់ទេវតាទាំងនោះ ទ្រង់ក៏សម្រាកអស់មជ្ឈិមយាម មជ្ឈិមយាមកិច្ច មានដូចពោលមកនេះឯង ។

ព្រះមានព្រះភាគ ទ្រង់ចែកបច្ឆិមយាមជា ៣ ចំណែក ហើយទ្រង់ទុក ១ ចំណែកដោយការដើរចង្ក្រម កាលទ្រង់បន្ទោបង់នូវការនឿយព្រះវរកាយដែលប្រថាប់គង់ច្រើន តាំងអំពីបុរេភត្ត ក្នុងចំណែកទី ២ ទ្រង់ចូលទៅកាន់ព្រះគន្ធកុដិ ទ្រង់មានព្រះសតិ និងសម្បជញ្ញៈ ផ្ទំផ្អៀងទៅខាងស្តាំ ក្នុងចំណែកទី ៣ ទ្រង់ក្រោកឡើង ប្រថាប់គង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ដើម្បីទតបុគ្គលដែលបានធ្វើបុញ្ញាធិការ ដោយទាន និងសីលជាដើម ក្នុងសម្នាក់របស់ព្រះពុទ្ធទាំងឡាយក្នុងកាលមុន ក្នុងបច្ឆិយាមកិច្ច មានដូចពោលមកនេះឯង ។

ថ្ងៃនោះ ព្រះមានព្រះភាគ ទ្រង់ស្ថិតនៅក្នុងកិច្ចនេះឯង ទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញហេតុនេះថា កាលតថាគតចារិកទៅក្នុងមហា

កោសលរដ្ឋ សម្តែងសូត្រមួយ ប្រៀបធៀបដូចគំនរភ្លើង ភិក្ខុ ៦០ រូបសម្រេចអរហត្ត ភិក្ខុប្រមាណ ៦០ រូបទៀតក្អួតឈាម ភិក្ខុប្រមាណ ៦០ ដទៃទៀតសឹកជាគ្រហស្ថ ។ បណ្តាភិក្ខុទាំងនោះ ពួកភិក្ខុដែលសម្រេចអរហត្តបានស្តាប់ព្រះធម្មទេសនាណាមួយ ក៏សម្រេចបាននោះឯង ។ ព្រះមានព្រះភាគមានព្រះបំណងនឹងចារិកទៅ ដើម្បីសង្គ្រោះភិក្ខុក្រៅអំពីនេះ ទើបត្រាស់ថា ម្នាលអានន្ទ អ្នកចូរប្រាប់ដល់ភិក្ខុទាំងឡាយ ។

ព្រះថេរៈទៅតាមបរិវេណ ហើយពោលថា អាវុសោ ព្រះសាស្តាមានព្រះបំណងយាងចារិក ដើម្បីសង្គ្រោះមហាជន អ្នកណាបំណងទៅតាមព្រះអង្គ ក៏ចូរនាំគ្នាមកចុះ ។ ភិក្ខុទាំងឡាយ មានចិត្តត្រេកអរ ដូចបានលាភធំ គិតថា អញនឹងបានមើលព្រះសរីរៈដែលមានពណ៌ដូចមាស បានស្តាប់ធម្មកថាដ៏ពីរោះរបស់ព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់មហាជន បុគ្គលដែលមានសក់វែង ក៏កោរសក់ មានបាត្រប្រេះបាប់ ក៏អប់បាត្រ មានចីវរសៅហ្មង ក៏គក់ចីវរ ត្រៀមខ្លួនធ្វើដំណើរតាមព្រះមានព្រះភាគ ។ ព្រះសាស្តាចោមរោមដោយភិក្ខុសង្ឃ ដែលកំណត់ចំនួនមិនបាន យាងចារិកទៅកាន់កោសលរដ្ឋ មួយថ្ងៃ ទ្រង់ចារិកទៅ ១ គាវុត ២ គាវុត ៣ គាវុត និង ១ យោជន៍យ៉ាងក្រៃលែង តាមលំដាប់នៃគាម និងនិគម ទតឃើញដើមឈើមានប្រហោងធំមួយ ត្រូវភ្លើងឆេះសន្ធោសន្ធៅ ទ្រង់ព្រះតម្រិះថា តថាគតនឹងធ្វើដើមឈើនេះឯងឲ្យជាអត្ថុប្បត្តិហេតុ សម្តែងធម្មកថា ប្រដាប់ដោយអង្គ ៧ ទើបវៀរចាកការយាង ទ្រង់ចូលទៅកាន់គល់ឈើមួយដើម ទ្រង់សម្តែង

អាការប្រថាប់គន់ ។ ព្រះអានន្ទ ជ្រាបព្រះបំណងរបស់ព្រះសាស្ដា គិតថា ប្រហែលជាមានហេតុពិតប្រាកដ ព្រះតថាគតមិនយាងទៅ ហើយបង្អង់បំណងប្រថាប់គន់ ដោយហេតុមិនសមគួរ មិនមាន ទើបក្រាលសង្ឃាដី ៤ ជាន់ ។

ព្រះសាស្ដាប្រថាប់គន់ ត្រាស់ហៅភិក្ខុទាំងឡាយមក ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរមើលគំនរភ្លើងធំនោះ ហើយទ្រង់សម្ដែងអគ្គិក្ខន្ធោបមសូត្រ ។ កាលត្រាស់វេយ្យាករណ៍នេះ ភិក្ខុប្រមាណ ៦០ រូប ក្អួតឈាម ។ ភិក្ខុប្រមាណ ៦០ រូបលាសិក្ខាជាគ្រហស្ថ ។ ភិក្ខុប្រមាណ ៦០ រូបទៀត មានចិត្តមិនប្រកាន់មាំ ក៏រួចផុតចាកអាសវៈទាំងឡាយ ។ ព្រោះបានស្ដាប់វេយ្យាករណ៍នោះ នាមកាយរបស់ភិក្ខុប្រមាណ ៦០ រូបក៏ក្ដៅ កាលនាមកាយក្ដៅករជកាយក៏ក្ដៅ កាលករជកាយក្ដៅ ឈាមដែលក្ដៅក៏ខ្ទុះចេញអំពីមាត់ ។ ភិក្ខុប្រមាណ ៦០ រូបទៀត គិតថា ការប្រព្រឹត្តព្រហ្មចរិយៈ ឲ្យបរិសុទ្ធបរិបូណ៌ រហូតអស់ជីវិតក្នុងព្រះពុទ្ធសាសនា ធ្វើបានលំបាកហ្ន៎ ហើយនាំគ្នាលាសិក្ខាជាគ្រហស្ថ ។ ភិក្ខុប្រមាណ ៦០ រូប បញ្ជូនញាណត្រង់ធ្លោះធម្មទេសនារបស់ព្រះសាស្ដា ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។ បណ្ដាភិក្ខុទាំងនោះ ភិក្ខុពួកណាក្អួតឈាម ភិក្ខុទាំងនោះ សុទ្ធតែត្រូវអាបត្តិបារាជិក ភិក្ខុឯណាសឹកជាគ្រហស្ថ ភិក្ខុទាំងនោះ ជាអ្នកនាំគ្នាញាំញីសិក្ខាបទតូច និងសិក្ខាបទធំ ។ ភិក្ខុពួកណាសម្រេចអរហត្ត ភិក្ខុទាំងនោះ ជាអ្នកមានសីលបរិសុទ្ធ ។ ព្រះធម្មទេសនារបស់ព្រះសាស្ដា កើតមានផល ដល់

ភិក្ខុ ៣ ពួក ដូចពោលមកនេះ ។

សួរថា ព្រះធម្មទេសនាដែលកើតមានផល ដល់ភិក្ខុដែលសម្រេចអរហត្ត ស្មេះទុកសិនចុះ ចុះហេតុអ្វី ទើបកើតមានផលដល់ភិក្ខុក្រៅអំពីនេះ ឆ្លើយថា ភិក្ខុទាំងនោះ បើមិនបានស្តាប់ធម្មទេសនានេះសោត ជាអ្នកប្រមាទ មិនអាចលះឋានៈបាន បន្ទាប់អំពីនោះ បាបរបស់ភិក្ខុទាំងនោះកម្រើកឡើង នឹងធ្វើឲ្យលោកលិចចុះក្នុងអបាយតែម្យ៉ាង លុះស្តាប់ទេសនាកណ្ឌនេះហើយ កើតការសង្វេគ លះឋានៈ តាំងនៅក្នុងភូមិនៃសាមណេរ បំពេញសីល ១០ ប្រកបសេចក្តីខ្វល់ខ្វាយក្នុងយោនិសោមនសិការ ពួកខ្លះ ជាព្រះសោតាបន្ន ពួកខ្លះ ជាព្រះសកទាគាមី ពួកខ្លះ ជាអនាគាមី ពួកខ្លះ កើតក្នុងទេវលោក ។ ព្រះធម្មទេសនាមានផលដល់ភិក្ខុដែលត្រូវអាបត្តិបារាជិក ដោយអាការយ៉ាងនេះ ។ ឯភិក្ខុក្រៅអំពីនេះ បើមិនបានស្តាប់ព្រះធម្មទេសនាកណ្ឌនេះសោត ក្នុងកាលកន្លងទៅ ក៏គប្បីត្រូវអាបត្តិសង្ឃាទិសេសខ្លះ បារាជិកខ្លះ កាលបានស្តាប់ព្រះធម្មទេសនាកណ្ឌនេះហើយ គិតថា ព្រះពុទ្ធសាសនា ជុសខាត់កិលេសពិតហ្ន៎ ពួកយើងមិនអាចបំពេញបដិបទានេះ រហូតអស់ជីវិតបាន យើងលាចាកសិក្ខាហើយ ចាំបំពេញឧបាសកធម៌ នឹងផុតចាកទុក្ខបាន ដូច្នេះហើយ ទើបនាំគ្នាសឹកទៅជាគ្រហស្ថ ។ ជនទាំងនោះតាំងនៅក្នុងសរណៈ ៣ រក្សាសីល ៥ បំពេញឧបាសកធម៌ ពួកខ្លះ ជាព្រះសោតាបន្ន ពួកខ្លះ ជាសកទាគាមី ពួកខ្លះ ជាអនាគាមី ពួកខ្លះ កើតក្នុងទេវលោក ។ ធម្មទេសនាមានផលដល់ភិក្ខុទាំងនោះ ដោយអាការយ៉ាងនេះឯង ។ ម្យ៉ាងទៀត ពួក

ទេវតាបានស្ដាប់ព្រះធម្មទេសនាកណ្ឌនេះហើយ បានត្រាច់ទៅប្រាប់ដល់ភិក្ខុទាំងឡាយ ដែលមិនបានស្ដាប់គ្រប់រូបនោះឯង ។ ភិក្ខុទាំងឡាយស្ដាប់ហើយ គិតថា លោកដ៏ចម្រើន ការប្រព្រឹត្តព្រហ្មចរិយៈឲ្យបរិសុទ្ធបរិបូណ៌ រហូតអស់ជីវិតក្នុងព្រះពុទ្ធសាសនា ធ្វើបានលំបាក ។ ភិក្ខុ ១០ រូបខ្លះ ២០ រូបខ្លះ ៦០ រូបខ្លះ ១០០ រូបខ្លះ លាសិក្ខាជាគ្រហស្ថទៅមួយរំពេច ។

ព្រះសាស្ដា យាងចារិកទៅតាមអធ្យាស្រ័យ មិនយាងត្រឡប់ទៅវត្តជេតពនទៀត ទើបទ្រង់ហៅភិក្ខុមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតកាលត្រាច់ចារិកទៅប្រឡូកប្រឡំអស់កាលយូរ ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងពួនសម្ងំអស់កាលកន្លះខែ បុគ្គលណាម្នាក់ មិនត្រូវចូលទៅរកតថាគត វៀរតែភិក្ខុដែលនាំបិណ្ឌបាតមួយរូបប៉ុណ្ណោះ ទ្រង់សម្រាកតាមព្រះអធ្យាស្រ័យ អស់កន្លះខែ ទ្រង់ចេញអំពីទីពួនសម្ងំ មួយអន្លើដោយព្រះអានន្ទ ទ្រង់យាងចារិកត្រឡប់ទៅព្រះវិហារ ទ្រង់ឃើញភិក្ខុរលស់ក្នុងទីដែលទ្រង់ពិនិត្យមើលហើយមើលទៀត សូម្បីទ្រង់ជ្រាប ក៏ត្រាស់សួរព្រះអានន្ទថា ម្នាលអានន្ទ ក្នុងវេលាដទៃៗ កាលតថាគតត្រាច់ចារិក ត្រឡប់មកកាន់ជេតពន វិហារទូទៅ រុងរឿងទៅដោយសំពត់កាសាវពស្ត្រ ពពាក់ពពូនទៅដោយអ្នកស្វែងរកគុណ តែឥឡូវនេះ ប្រាកដថា ភិក្ខុថយចុះ និងដោយច្រើនភិក្ខុកើតរោគស្គមលឿង នេះ ហេតុអ្វីហ្ន៎ ។ ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុទាំងឡាយ កើតសេចក្ដីសង្វេគ ចាប់តាំងអំពីកាលដែលព្រះអង្គសម្ដែងព្រះធម្មទេសនា អគ្គិក្ខន្ធោបមសូត្រ គិតថា ពួកយើងមិន

អាចប្រណិប័តន៍ធម៌នោះ ដោយអាការទាំងពួងបាន និងការដែលភិក្ខុប្រព្រឹត្ត មិនប្រពៃ បរិភោគទេយ្យធម៌ ដែលគេឲ្យដោយសទ្ធារបស់ជន មិនគួរឡើយ ទើបសឹកជាគ្រហស្ថ ខណៈនោះ ព្រះមានព្រះភាគ ទ្រង់កើតធម្មសង្វេគ ។ លំដាប់នោះ ទើបត្រាស់នឹងព្រះថេរៈថា កាលតថាគតសម្រាកក្នុងទីសម្ងំ បុគ្គលណាម្នាក់ មិនប្រាប់ឋានៈ ដែលជាទីស្រោលចិត្តឯណាមួយ ដល់ពួកកូនរបស់តថាគតឡើយ ហេតុដែលជាទីស្រោលចិត្តក្នុងសាសនានេះមានច្រើន ដូចកំពង់ដែលជាទីចុះកាន់សាគរ និងសមុទ្រ ដូច្នោះ ម្នាលអានន្ទ ចូររៀបចំអាសនៈក្នុងបរិវេណគន្ធកុដិ ចូរឲ្យភិក្ខុសង្ឃប្រជុំគ្នា ។ ព្រះថេរៈបានធ្វើយ៉ាងនោះ ។ ព្រះសាស្តាទ្រង់ចូលកាន់បវរពុទ្ធាសនៈ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ នុ៎ះជាចំណែកខាងដើមនៃមេត្តា មិនមែនអប្បនា មិនមែនឧបេក្ខា ត្រឹមតែផ្សាយប្រយោជន៍ដល់សត្វទាំងឡាយប៉ុណ្ណោះ ។ ទើបទ្រង់សម្តែងអច្ឆរាសង្ឃាតសូត្រនេះ ដើម្បីជាអត្ថុប្បត្តិហេតុ ។

បណ្តាបទទាំងនោះ បទថា **អច្ឆរាសង្ឃាតមត្តំ** សេចក្តីថា ត្រឹមតែការផ្ទាត់ម្រាមដៃ អធិប្បាយថា ត្រឹមតែយកម្រាម ២ ផ្ទាត់ឲ្យមានសំឡេង ។ បទថា **មេត្តចិត្តំ** បានដល់ ចិត្តដែលគិតផ្សាយប្រយោជន៍ដល់សព្វសត្វ ។

បទថា **អាសេវតិ** សួរថា រមែងសេពដូចម្តេច ឆ្លើយថា នឹកដល់សេព ឃើញសេព ពិចារណាសេព ផ្គងសេចក្តីព្យាយាមសេព បង្អោនចិត្តជឿសេព ចូលទៅតាំងសតិសេព តាំងចិត្តសេព ដឹងច្បាស់ដោយបញ្ញាសេព ដឹងនូវវត្ថុដែលគួរដឹងក្រៃលែងសេព កំណត់ដឹងនូវវត្ថុដែលគួរកំណត់ដឹងសេព លះ

វត្ថុដែលគួរលះសេព ចម្រើនវត្ថុដែលគួរចម្រើនសេព ធ្វើឲ្យជាក់ច្បាស់នូវវត្ថុដែលគួរធ្វើឲ្យជាក់ច្បាស់សេព តែក្នុងទីនេះ គប្បីជ្រាបថា សេពដោយហេតុត្រឹមតែប្រព្រឹត្តទៅដោយការផ្សាយ ប្រយោជន៍ក្នុងចំណែកខាងដើមនៃមេត្តា ។

បទថា **អរិត្តជ្ឈានោ** បានដល់ មានឈានមិនដាក់ចុះ គឺមិនលះបង់ឈាន ។ បទថា **វិហរតិ** សេចក្តីថា ផ្លាស់ប្តូរប្រព្រឹត្តទៅ រក្សាប្រព្រឹត្តទៅឯង ឲ្យប្រព្រឹត្តទៅ ត្រាច់ទៅ ដោយហេតុនោះ ទើបលោកពោលថា **វិហរតិ** ដោយបទនេះ ទើបលោកពោលការនៅដោយឥរិយាបថរបស់ភិក្ខុដែលសេពមេត្តា ។

បទថា **សត្ថុសាសនករោ** បានដល់ ដែលធ្វើតាមអនុសាសនីរបស់ព្រះសាស្តា ។ បទថា **ឱវាទប្បដិករោ** បានដល់ ធ្វើតាមឱវាទ ។

ក្នុងរឿងនេះ ការពោលម្តង ឈ្មោះថា ឱវាទ ការពោលរឿយៗ ឈ្មោះថា អនុសាសនី ។ ការពោលចំពោះមុខ ឈ្មោះថា ឱវាទ ការបញ្ជូនដំណឹងទៅ នាំដំណឹងត្រឡប់ ឈ្មោះថា អនុសាសនី ។ ការពោលក្នុងកាល រឿងកើតឡើងហើយ ឈ្មោះថា ឱវាទ ឯការពោលក្នុងកាលរឿងកើតឡើង ឬមិនទាន់កើតឡើង ឈ្មោះថា អនុសាសនី ។ គប្បីជ្រាបការប្លែកគ្នាយ៉ាងនេះ ។ តែកាលពោលដោយបរមត្ថ ពាក្យថា ឱវាទ ឬអនុ-សាសនីនោះ ក៏ដូចគ្នាតែមួយ មានអត្ថតែមួយ ស្មើគ្នា ចូលគ្នាបាន កើតរួមគ្នានោះឯង ក្នុងទីនេះ ពាក្យថា ភិក្ខុទាំងឡាយ បើភិក្ខុសេពមេត្តាចិត្ត សូម្បីត្រឹមតែផ្ទាត់ម្រាមដៃម្តង នេះឯងជាពាក្យប្រៀនប្រដៅ និងជាឱវាទរបស់ព្រះ

សាស្តា គប្បីជ្រាបថា ភិក្ខុនោះ ឈ្មោះថា ធ្វើតាមពាក្យប្រៀនប្រដៅ និង បុគ្គលដែលស្អងឱវាទ ព្រោះបដិបត្តិពាក្យប្រៀនប្រដៅ និងឱវាទនោះ ។

បទថា **អមោឃំ** ប្រែថា មិនទទេ ។ បទថា **រដ្ឋបិណ្ឌំ** សេចក្តីថា បិណ្ឌបាតនោះឯង ហៅថា **រដ្ឋបិណ្ឌ** គឺដុំបាយរបស់អ្នកដែន ព្រោះអាហារនោះ ភិក្ខុលះបង់សាច់ញាតិ អាស្រ័យអ្នកដែន បួសហើយ បានអំពីផ្ទះនៃអ្នកដទៃ ។

បទថា **បរិភុញ្ជតិ** សេចក្តីថា បរិភោគមាន ៤ យ៉ាង គឺថេយ្យ-បរិភោគ ឥនបរិភោគ ទាយជ្ជបរិភោគ សាមិបរិភោគ ។ ក្នុងបរិភោគ ៤ យ៉ាងនោះ ការបរិភោគរបស់អ្នកទ្រុស្តសីល ឈ្មោះថា ថេយ្យបរិភោគ ។ ការបរិភោគបច្ច័យដែលមិនបានពិចារណា របស់អ្នកមានសីល ឈ្មោះថា ឥនបរិភោគ ការបរិភោគរបស់សេក្ខបុគ្គល ៧ ពួក ឈ្មោះថា ទាយជ្ជ-បរិភោគ ការបរិភោគរបស់ព្រះខីណាស្រព ឈ្មោះថា សាមិបរិភោគ ។ ក្នុង ៤ យ៉ាងនោះ ការបរិភោគដុំបាយរបស់អ្នកស្រុកនេះ របស់ភិក្ខុនេះ រមែងមិនទទេដោយហេតុ ២ ប្រការ ។ ភិក្ខុដែលសេពមេត្តាចិត្តត្រឹមតែផ្ទាត់ម្រាមដៃម្តង ឈ្មោះថា ជាម្ចាស់ដុំបាយរបស់អ្នកបរិភោគ ព្រោះហេតុនោះ ការបរិភោគដុំបាយរបស់អ្នកដែននៃភិក្ខុនោះ ឈ្មោះថា មិនទទេ ។ ទានដែលបុគ្គលឲ្យដល់ភិក្ខុសេពមេត្តា សូម្បីមួយផ្ទាត់ក្រចក រមែងមានសេចក្តីសម្រេចច្រើន មានផលច្រើន មានអានិសង្សច្រើន មានការរុងរឿងច្រើន មានការទូលំទូលាយច្រើន ព្រោះហេតុនោះ ការបរិភោគបាយរបស់អ្នកដែន

នៃភិក្ខុនោះ មិនជាមោឃៈ មិនទទេ ។ បទថា **កោ បន វាទោ យេ នំ ពហុលីករោន្តិ** សេចក្ដីថា គួរពោលបានពិត ក្នុងសេចក្ដីនេះថា ភិក្ខុពួកណាសេព ចម្រើនឲ្យច្រើន ធ្វើរឿយៗ នូវមេត្តាចិត្តនេះ ភិក្ខុទាំងនោះ រមែងបរិភោគដុំបាយរបស់អ្នកដែនមិនទទេឡើយ ព្រោះភិក្ខុបែបនេះ រមែងជាម្ចាស់នៃដុំបាយអ្នកស្រុក មិនជាបំណុល ជាទាយាទបរិភោគ ។

**អដ្ឋកថាសូត្រទី ៣ ចប់**

# អដ្ឋកថាសូត្រទី ៤

[ ៥៥ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ភាវេតិ** បានដល់ ឲ្យកើតឡើង គឺឲ្យចម្រើន ។

**អដ្ឋកថាសូត្រទី ៤ ចប់**

# អដ្ឋកថាសូត្រទី ៥

[ ៥៦ ] ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ បទថា **មនសិ-ករោតិ** ប្រែថា ធ្វើទុកក្នុងចិត្ត ។ ពាក្យដ៏សេសក្នុងសូត្រទាំង ២ នេះ គប្បីជ្រាបដោយន័យដូចពោលក្នុងសូត្រទី ៣ ។ ភិក្ខុណាមែងសេព ភិក្ខុនេះឯងឈ្មោះថា រមែងចម្រើន ភិក្ខុនេះឈ្មោះថា ធ្វើទុកក្នុងចិត្ត ។ ភិក្ខុរមែងសេពដោយចិត្តណា ឈ្មោះថា រមែងចម្រើនដោយចិត្តនោះឯង ឈ្មោះថា រមែងធ្វើទុកក្នុងចិត្តដោយចិត្តនោះ ។ ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ជាអ្នកសម្បូរដោយលីលានៃទេសនា ព្រោះទ្រង់ចាក់ធ្លុះធម្មធាតុណា ទ្រង់អាស្រ័យលីលានៃទេសនា ១ ភាពជាធំក្នុងធម៌ ១ ភាពឈ្លាសក្នុងប្រភេទនៃបដិសម្ភិទា ១ ព្រះសព្វញ្ញុតញ្ញាណដែលមិនទើសទាក់របស់ព្រះអង្គ ១ ព្រោះទ្រង់ជាអ្នកចាក់ធ្លុះធម្មធាតុនោះ ទើបទ្រង់បែក សម្ដែងចិត្ត ១ ដួង ដែលកើតឡើងក្នុងខណៈ ១ ប៉ុណ្ណោះ ដោយចំណែកទាំង ៣ ។

### អដ្ឋកថាសូត្រទី ៥ ចប់

# អដ្ឋកថាសូត្រទី ៦

[ ៥៧ ] ក្នុងសូត្រទី ៦ មានវិនិច្ឆ័យដូចតទៅនេះ បទថា **យេ កេចិ** ជាពាក្យកំណត់មិនពិតប្រាកដ ។ បទថា **អកុសលា** ជាពាក្យកំណត់ពិតប្រាកដនៃអកុសលទាំងនោះ ។ ដោយពាក្យមានប្រមាណប៉ុណ្ណោះ អកុសល-

ធម៌ទាំងអស់ ជាការកំណត់ដោយមិនសេសសល់ ពាក្យថា **អកុសល-ភាគិយា អកុសលបក្ខិកា** នេះ ជាឈ្មោះនៃអកុសលធម៌ទាំងនោះ ពិតហើយ អកុសលនោះឯង ពួកខ្លះជាអកុសលចិត្ត ដោយអំណាចជាសហ-ជាតធម៌ ពួកខ្លះចូលគ្នាបាន ដោយអំណាចឧបនិស្សយប្បច្ច័យ និងជាចំណែកនៃអកុសលធម៌ទាំងនោះ ព្រោះដូច្នោះ ទើបលោកពោលថា ជាចំណែកនៃអកុសល ជាបក្ខពួកនៃអកុសល ។

បទថា **សព្វេ តេ មនោបុព្វង្គមា** សេចក្តីថា ចិត្តជាប្រធាន គឺដល់មុននៃធម៌ទាំងនោះ ព្រោះដូច្នោះ ធម៌ទាំងនោះ ឈ្មោះថា មានចិត្តជាប្រធាន ។ ពិតហើយ ធម៌ទាំងនោះ កើតព្រមគ្នា មានវត្ថុតែមួយដូចគ្នា រលត់ព្រមគ្នា មានអារម្មណ៍ដូចគ្នាជាមួយចិត្តក៏ពិត សូម្បីយ៉ាងនោះ ព្រោះហេតុដែលចិត្តញ៉ាំងធម៌ទាំងនោះឲ្យកើតឡើង ធ្វើឲ្យកើត ឲ្យតាំងឡើង ឲ្យឧប្បត្តិឡើង ដូច្នោះ ទើបធម៌ទាំងនោះ មានចិត្តជាប្រធាន ។

បទថា **បឋមំ ឧប្បជ្ជតិ** សេចក្តីថា កាលបុគ្គលពោលថា ព្រះរាជាយាងចេញទៅហើយ ក៏មិនមានហេតុដែលគប្បីពោលថា ទ័ពព្រះរាជាដ៏សេសចេញទៅហើយ ឬមិនចេញទៅ គេរមែងដឹងទូទៅថា ទ័ពព្រះរាជាចេញទៅអស់ហើយ យ៉ាងណា ចិត្តក៏ដូច្នោះដូចគ្នា រមែងមិនមានហេតុដែលគប្បីពោលថា ចាប់តាំងអំពីកាលដែលគេពោលថា កើតឡើងហើយ ធម៌ដ៏សេសកើតរួមគ្នា លាយឡំគ្នា ប្រកបគ្នា កើតឡើងហើយ ឬមិនទាន់កើតឡើង ធម៌ទាំងអស់នោះ រមែងប្រាកដថា កើតឡើងហើយទាំងអស់ អាស្រ័យ

អំណាចនៃប្រយោជន៍នេះ ចិត្តដែលលាយឡំ ដែលប្រកបគ្នា ធម៌ទាំងនោះ សូម្បីកើតព្រមគ្នា និងរលត់ព្រមគ្នា លោកក៏ហៅថា កើតមុនធម៌ទាំងនោះ ។ បទថា **អន្វេវ** ប្រែថា តាមគ្នា រួមគ្នា អធិប្បាយថា ព្រមគ្នានោះឯង ។ តែកាលកាន់យកមូលនៃព្យញ្ជនៈ មិនគួរកាន់យកថា ចិត្តកើតមុន ចេតសិកកើតឯក្រោយឡើយ ។ ពិតហើយ អត្ថ គឺភាពជាទីអាស្រ័យ ព្យញ្ជនៈទាំងឡាយ ក្នុងគាថាថា **មនោបុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា** ក៏មានន័យនេះដូចគ្នា ៕

**អដ្ឋកថាសូត្រទី ៦ ចប់**

## អដ្ឋកថាសូត្រទី ៧

[ ៥៨ ] ក្នុងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ កុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ លោកពោលថា **កុសល** ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងសូត្រទី ៦ នោះឯង ៕

**អដ្ឋកថាសូត្រទី ៧ ចប់**

# អដ្ឋកថាសូត្រទី ៨

[ ៥៩ ] ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ភិក្ខវេ** ក្នុងពាក្យថា **យថយិទំ ភិក្ខវេ បមាទោ** នេះ ជាអាលបនៈ សេចក្ដីថា **យថា អយំ បមាទោ** ដូចសេចក្ដីប្រមាទនេះ ។ បទថា **បមាទោ** បានដល់ អាការគឺការប្រមាទ ។ សមដូចពាក្យដែលលោកពោលថា បណ្ដាធម៌ទាំងនោះ សេចក្ដីប្រមាទ តើដូចម្ដេច ។ ការបណ្ដោយចិត្ត ការឲ្យកម្លាំងដល់ការបណ្ដោយចិត្ត ក្នុងកាយទុច្ចរិតក្ដី ក្នុងវចីទុច្ចរិតក្ដី ក្នុងមនោទុច្ចរិតក្ដី ក្នុងកាមគុណ ៥ ក្ដី ឬការធ្វើដោយមិនគោរព ការធ្វើមិនឲ្យរឿយៗ ការធ្វើមិនខ្ជាប់ខ្ជួន ការប្រព្រឹត្តទម្រន់ ការដាក់ចុះនូវឆន្ទៈ ការដាក់ចុះនូវធុរៈ ការមិនគប់រក ការមិនអប់រំ ការមិនធ្វើឲ្យច្រើន ការមិនតាំងមាំ ការមិនប្រកបរឿយៗ ការធ្វេសប្រហែស ក្នុងការចម្រើននូវពួកធម៌ជាកុសល ការធ្វេសប្រហែស អាការធ្វេសប្រហែស ភាពនៃសេចក្ដីធ្វេសប្រហែស មានសភាពយ៉ាងនេះ នេះហៅថា សេចក្ដីប្រមាទ ។

បទថា **ឧប្បន្នា ច កុសលា ធម្មា បរិហាយន្តិ** ប្រែថា កុសលធម៌ដែលកើតឡើងហើយ រមែងវិនាសទៅផង នេះលោកពោលទាក់ទងដោយឈាន និងវិបស្សនា ។ តែមគ្គផលដែលកើតឡើងហើយម្ដង មិនវិនាសវិញឡើយ ៕ល៕

## អដ្ឋកថាសូត្រទី ៨ ចប់

## អដ្ឋកថាសូត្រទី ៩

[ ៦០ ] ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ ការមិនប្រមាទ គប្បីជ្រាបដោយពិស្តារ ដោយផ្ទុយគ្នានឹងការប្រមាទ ។

### អដ្ឋកថាសូត្រទី ៩ ចប់

## អដ្ឋកថាសូត្រទី ១០

[ ៦១ ] ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ ភាពជាអ្នកខ្ជិលច្រអូស ឈ្មោះថា **កោសជ្ជ** ។ ពាក្យដ៏សេស ក៏មានន័យដូចពោលហើយនោះឯង ។

### អដ្ឋកថាសូត្រទី ១០ ចប់

### អច្ឆរាសង្ឃាតវគ្គទី ៦ ចប់

# សុត្តន្តបិដក

# វីរិយារម្ភាទិវគ្គទី ៧

[ ៦២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការផ្តងព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលផ្តងព្យាយាមហើយ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង។

[ ៦៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីប្រាថ្នាច្រើននេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្តីប្រាថ្នាច្រើន ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៦៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីប្រាថ្នាតិចនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្តីប្រាថ្នាតិច ពួកកុសលធម៌ ដែលមិនទាន់កើតឡើង រមែងកើតឡើងផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៦៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីមិនសន្តោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមិនមានសន្តោស ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៦៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសេចក្តីសន្តោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសេចក្តីសន្តោស ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៦៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការធ្វើទុកក្នុងចិត្តខុសទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តខុសទំនង ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៦៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការធ្វើទុកក្នុងចិត្តត្រូវទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តត្រូវទំនង ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៦៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកអកុសលធម៌មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចអសម្បជញ្ញៈ ( សេចក្តីមិនដឹងខ្លួន ) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានអសម្បជញ្ញៈ ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

[ ៧០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចសម្បជញ្ញៈ ( សេចក្តីដឹងខ្លួន ) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានសម្បជញ្ញៈ ពួកកុសលធម៌ ដែលមិនទាន់កើតឡើង រមែង

កើតឡើងបានផង ពួកអកុសលធម៌ ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

[ ៧១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញ៉ាំងពួកអកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការមានបាបមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានបាបមិត្ត ពួកអកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ។

**វគ្គទី ៧ ចប់**

# អដ្ឋកថា

# វិរិយារម្ភាទិវគ្គទី ៧

## សូត្រទី ១

[ ៦២ ] ក្នុងសូត្រទី ១ នៃវគ្គទី ៧ មានវិនិច្ឆ័យដូចតទៅនេះ បទថា **វិរិយារម្ភោ** បានដល់ ការផ្តើមសេចក្តីព្យាយាម គឺសម្មប្បធាន ដែលមានកិច្ច ៤ អធិប្បាយថា ភាពជាអ្នកមានសេចក្តីព្យាយាមដែលផ្គងបរិបូណ៌ ។

**អដ្ឋកថាសូត្រទី ១ ចប់**

## អដ្ឋកថាសូត្រទី ២

[ ៦៣ ] ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ បទថា **មហិច្ឆតា** បានដល់ ការប្រាថ្នាធំ លោកសំដៅពោលថា បណ្តាធម៌ទាំងនោះ សេចក្តីប្រាថ្នាធំ តើដូចម្តេច ។ សេចក្តីប្រាថ្នាដ៏ក្រៃលែងនៃបុគ្គលមិនសន្តោស ដោយចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនាសនប្បច្ច័យ និងគិលានប្បច្ចយ-ភេសជ្ជបរិក្ខារ តាមមាន តាមបាន ឬដោយកាមគុណទាំង ៥ សេចក្តីប្រាថ្នា ការប្រព្រឹត្តទៅដោយសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាធំ តម្រេក តម្រេកខ្លាំង ។បេ។ តម្រេកខ្លាំងនៃចិត្ត មានសភាពយ៉ាងនេះ នេះហៅថា សេចក្តីប្រាថ្នាធំ ។

**អដ្ឋកថា សូត្រទី ២ ចប់**

# អដ្ឋកថាសូត្រទី ៣

# អប្បិច្ចកថា

[ ៦៤ ] ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អប្បិច្ចតា** បានដល់ ប្រាថ្នាតិច ។ បទថា **អប្បិច្ចស្ស** បានដល់ មិនប្រាថ្នា ក្នុងទីនេះ ព្យញ្ជនៈ ហាក់ដូចជានៅមានចំណែកសេសសល់ គឺនៅមានប្រាថ្នាខ្លះ ឯអត្ថ មិនមានចំណែកសេសសល់ គឺមិនប្រាថ្នាសូម្បីតិចតួច ពិតហើយ បុគ្គល លោកហៅថា អ្នកមានសេចក្តីប្រាថ្នាតិច ព្រោះភាវៈដែលមានសេចក្តីប្រាថ្នា មានប្រមាណតិចក៏មិនមែន តែលោកហៅថា មានការប្រាថ្នាតិច ព្រោះមិន មានសេចក្តីប្រាថ្នា គឺភាវៈដែលមិនមានការលោភ ដែលបុគ្គលនោះសេព រឿយៗ នោះឯង ។

ម្យ៉ាងទៀត ក្នុងទីនេះ គប្បីជ្រាបសេចក្តីផ្សេងគ្នាដូច្នេះថា **អត្រិច្ឆតា** ការប្រាថ្នាហួសហេតុ **ចាបិច្ឆតា** ការប្រាថ្នាលាមក **មហិច្ឆតា** ការប្រាថ្នាធំ ។ ក្នុង ៣ យ៉ាងនោះ ការមិនឆ្អែតក្នុងលាភរបស់ខ្លួន នៅប្រាថ្នាក្នុងលាភរបស់ អ្នកដទៃ ឈ្មោះថា ការប្រាថ្នាហួសហេតុ ។ សម្រាប់បុគ្គលប្រកបដោយការ ប្រាថ្នាហួសហេតុនោះ សូម្បីនំឆ្អិនក្នុងភាជនៈ ១ គេដាក់ក្នុងភាជនៈរបស់ខ្លួន រមែងប្រាកដដូចនំដែលឆ្អិនមិនល្អ និងដូចមានតិច នំនោះឯង គេដាក់ក្នុង ភាជនៈរបស់អ្នកដទៃ ប្រាកដដូចឆ្អិនល្អ និងដូចមានច្រើន ។ ការប្រកាស គុណដែលមិនមាន និងការមិនដឹងប្រមាណក្នុងការទទួល ឈ្មោះថា ប្រាថ្នា លាមក ។ ការប្រាថ្នាលាមកនោះ មកហើយក្នុងអភិធម្មដោយន័យជាដើមថា បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកមិនមានសទ្ធា រមែងប្រាថ្នាថា ចូរជនស្គាល់នូវ

អញថា ជាអ្នកមានសទ្ធា ។ បុគ្គលដែលប្រកបដោយសេចក្តីប្រាថ្នាលាមក នោះ រមែងតាំងនៅក្នុងការបោកបញ្ឆោត ។ ចំណែកការប្រកាសគុណដែលមាន និងភាពជាអ្នកមិនដឹងប្រមាណក្នុងការទទួល ឈ្មោះថា ជាអ្នកមានការប្រាថ្នាច្រើន ។ ការប្រាថ្នាច្រើននោះ ក៏មកហើយដោយន័យនេះដូចគ្នានោះឯងថា បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានសទ្ធា រមែងប្រាថ្នាថា ចូរជនដឹងនូវអញថា ជាអ្នកមានសទ្ធា ។ បុគ្គលខ្លះជាអ្នកមានសីល រមែងប្រាថ្នាថា ចូរជនដឹងនូវអញថា ជាអ្នកមានសីល ។ បុគ្គលដែលប្រកបដោយការប្រាថ្នាធំនោះ ជាបុគ្គលដែលឆ្អែតបានលំបាក សូម្បីម្តាយបង្កើតក៏មិនអាចទាញចិត្តបុគ្គលនោះបាន ដោយហេតុនោះ ទើបលោកពោលពាក្យនេះថា

**អគ្គិក្ខន្ធោ សមុទ្ទោ ច មហិច្ឆោ ចាបិ បុគ្គលោ**
**សកដេន បច្ចយេ ទេន្តុ តយោបេតេ អតប្បិយា ។**

គំនរភ្លើង ១ សមុទ្រ ១ បុគ្គលប្រាថ្នាធំ ១ ឲ្យបច្ច័យទាំងរទេះ បុគ្គល ៣ ប្រភេទនោះ ក៏មិនឆ្អែតឡើយ ។

ចំណែកការលាក់បាំងគុណ ដែលមានភាពជាអ្នកស្គាល់ប្រមាណក្នុងការទទួល ឈ្មោះថា ភាពជាអ្នកប្រាថ្នាតិច ។ បុគ្គលដែលប្រកបដោយភាពជាអ្នកប្រាថ្នាតិចនោះ រមែងប្រាថ្នាថា ចូរជនដឹងនូវអញថា ជាអ្នកមានសទ្ធា ជាអ្នកមានសីល ពេញចិត្តក្នុងសេនាសនៈស្ងាត់ ជាពហុស្សូត ជាអ្នកប្រារព្ធព្យាយាម ដល់ព្រមដោយសមាធិ ជាអ្នកមានបញ្ញា ជាព្រះខីណាស្រព រមែងមិនប្រាថ្នាថា ចូរជនដឹងនូវអញថា ជាព្រះខីណាស្រព ដូចព្រះមជ្ឈន្តិកៈ

ដូច្នោះ ។

# រឿង ព្រះមជ្ឈន្តិកត្ថេរ

បានឮថា ព្រះថេរៈបានជាព្រះខីណាស្រពធំ ។ តែបាត្រ និងចីវររបស់លោក មានតម្លៃត្រឹម ១ បាទប៉ុណ្ណោះ ។ លោកបានជាព្រះសង្ឃត្ថេរក្នុងថ្ងៃឆ្លងព្រះវិហាររបស់ព្រះបាទធម្មាសោករាជ ។ គ្រានោះ មនុស្សទាំងឡាយឃើញថា លោកជាបុគ្គលកខ្វក់ពេក ទើបពោលថា សូមលោកម្ចាស់នៅខាងក្រៅមួយសន្ទុះចុះ ។ ព្រះថេរៈគិតថា ព្រះខីណាស្រពដូចអាត្មាអញ មិនធ្វើការសង្គ្រោះព្រះរាជា អ្នកដទៃណាទៅនឹងធ្វើបាន ដូច្នេះហើយ ទើបមុជចុះក្នុងផែនដី ផុសឡើងទទួលដុំបាយ ដែលគេលើកឡើងដើម្បីព្រះសង្ឃត្ថេរបានល្មម ។ លោកជាព្រះខីណាស្រព រមែងមិនប្រាថ្នាថា ចូរមនុស្សដឹងនូវអាត្មាអញថា ជាព្រះខីណាស្រព ដោយប្រការយ៉ាងនេះ ។

ឯភិក្ខុដែលប្រាថ្នាតិចយ៉ាងនេះ រមែងធ្វើលាភដែលមិនទាន់កើត ឲ្យកើតឡើង ឬរមែងធ្វើលាភដែលកើតឡើងហើយឲ្យមាំទាំ រមែងធ្វើចិត្តរបស់ទាយកឲ្យត្រេកអរ ។ ភិក្ខុនោះ រមែងកាន់យកតែតិចតួច ព្រោះខ្លួនជាអ្នកប្រាថ្នាតិច ដោយប្រការណាមួយ មនុស្សទាំងឡាយជ្រះថ្លាក្នុងវត្តរបស់លោក ដោយប្រការនោះៗ រមែងឲ្យច្រើន ។

ការប្រាថ្នាតិចម្យ៉ាងទៀត មាន ៤ ប្រការ គឺប្រាថ្នាតិចក្នុងបច្ច័យ ១ ប្រាថ្នាតិចក្នុងធុតង្គ ១ ប្រាថ្នាតិចក្នុងបរិយត្តិ ១ ប្រាថ្នាតិចក្នុងអធិគម ១ បណ្ដាការប្រាថ្នាតិច ៤ យ៉ាងនោះ ការប្រាថ្នាតិចក្នុងបច្ច័យ ៤ ឈ្មោះថា

ប្រាថ្នាតិចក្នុងបច្ច័យ ។ ភិក្ខុនោះ រមែងដឹងកម្លាំងរបស់ទាយក រមែងដឹងកម្លាំងរបស់ទេយ្យធម៌ រមែងដឹងកម្លាំងរបស់ខ្លួន បើទេយ្យធម៌មានច្រើន ទាយកបំណងប្រគេនតិច រមែងទទួលតែបន្តិចបន្តួច ដោយអំណាចទាយក ទេយ្យធម៌មានតិច ទាយកបំណងប្រគេនច្រើន រមែងទទួលតែបន្តិច ដោយអំណាចទេយ្យធម៌ សូម្បីទេយ្យធម៌មានច្រើន ទាំងទាយកក៏បំណងនឹងប្រគេនច្រើន រមែងស្គាល់កម្លាំងរបស់ខ្លួន ហើយទទួលតែល្មមប្រមាណ ។ ភិក្ខុមិនបំណងនឹងឲ្យអ្នកដទៃដឹងនូវការសមាទានធុតង្គជាក់ច្បាស់ គប្បីជ្រាបរឿងនេះជាឧទាហរណ៍ ។

បានឮថា ព្រះមហាកុមារកស្សបត្ថេរ ដែលសមាទានសោសានិកង្គធុតង្គ នៅក្នុងព្រៃខ្មោចអស់កាល ៦០ ឆ្នាំ ។ ភិក្ខុដទៃសូម្បីតែមួយអង្គក៏មិនដឹង ដោយហេតុនោះឯង ទើបលោកពោលថា

ខ្ញុំនៅក្នុងព្រៃខ្មោច មកអស់កាល ៦០ ឆ្នាំគត់ ភិក្ខុដែលជាសម្លាញ់ ក៏មិនដឹងនូវខ្ញុំ ឱ ! ខ្ញុំជាកំពូលនៃអ្នកសមាទានការនៅព្រៃខ្មោច ជាវត្តហ្ន៎ ។

ព្រះថេរៈ ២ រូប ជាបងប្អូននឹងគ្នា នៅត្រង់ចេតិយបព៌ត ។ ប្អូនប្រុសកាន់យកកំណាត់អំពៅ ដែលឧបដ្ឋាកបញ្ជូនទៅប្រគេន ទៅកាន់សម្នាក់ព្រះថេរៈជាបង ពោលថា បពិត្រលោកម្ចាស់ សូមនិមន្តឆាន់ចុះ ។ ខណៈដែលពោល ជាពេលដែលព្រះថេរៈធ្វើភត្តកិច្ចស្រេច ហើយខ្ពុរមាត់ ព្រះថេរៈពោលថា កុំឡើយ លោកម្ចាស់ ។ ព្រះថេរៈជាប្អូនពោលថា លោកម្ចាស់សមាទាន

ឯកាសនិកង្គធុតង្គឬ ។ ព្រះថេរៈពោលថា យកកំណាត់អំពៅមកចុះ សូម្បីកាន់ឯកាសនិកង្គធុតង្គអស់ ៥០ ឆ្នាំ ក៏គង់បិទបាំងនូវធុតង្គ ឆាន់ហើយ ខ្ពុរមាត់ អធិដ្ឋានធុតង្គជាថ្មី រួចទៅ ។ ភិក្ខុណាដូចជាព្រះសាកេតតិស្សៈ មិនប្រាថ្នានឹងឲ្យអ្នកដទៃដឹងថា ខ្លួនជាពហុសូត ឈ្មោះថា ភិក្ខុជាអ្នកប្រាថ្នាតិចក្នុងបរិយត្តិ ។

បានឮថា ព្រះថេរៈគិតថា ពេលមិនមាន ទើបមិនធ្វើឱកាសក្នុងឧទ្ទេសនិងបរិបុច្ឆា ត្រូវចោទសួរថា លោកម្ចាស់ កាលណាលោកម្ចាស់នឹងបានមរណក្ខណៈ គឺពេលស្លាប់ ទើបលះគណៈ ទៅកាន់កណិការវាលិកសមុទ្ទវិហារ ។ ក្នុងទីនោះ លោកមានឧបការៈដល់ព្រះថេរៈ នវកភិក្ខុ និងមជ្ឈិមភិក្ខុអស់ខាងក្នុងវស្សា ក្នុងបវារណានាថ្ងៃឧបោសថ ។ ឲ្យអ្នកជនបទភ្ញាក់ផ្អើលដោយធម្មកថាហើយ ក៏ទៅ ។

ឯភិក្ខុណាជាព្រះអរិយៈលំដាប់ណានីមួយ មានព្រះសោតាបន្នជាដើម មិនប្រាថ្នាឲ្យអ្នកដទៃដឹងថា ខ្លួនជាព្រះសោតាបន្នឡើយ ភិក្ខុនេះឈ្មោះថា ជាអ្នកមានការប្រាថ្នាតិចក្នុងអធិគម ដូចកុលបុត្រ ៣ នាក់ និងដូចស្មូនឆ្នាំងឈ្មោះឃដិការ ។ ក្នុងអត្ថនេះ សូម្បីបុថុជ្ជនដែលសិក្សាប្រកបដោយការមិនមានលោភ មានកម្លាំងខ្លាំងក្លា បានអាសេវនៈហើយ ក៏គប្បីជ្រាបថា ជាអ្នកប្រាថ្នាតិច ។៚

**អដ្ឋកថាសូត្រទី ៣ ចប់**

## អដ្ឋកថា សូត្រទី ៤

[ ៦៥ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អសន្តុដ្ឋិតា** បានដល់ សេចក្ដីលោភ ពោល គឺការមិនសន្ដោស ដែលកើតដល់បុគ្គលអ្នកសេពគប់ អ្នកចូលទៅអង្គុយជិតបុគ្គលដែលមិនសន្ដោសនោះ ។

### អដ្ឋកថា សូត្រទី ៤ ចប់

## អដ្ឋកថា សូត្រទី ៥

## សន្ដោសកថា

[ ៦៦ ] ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ បទថា **សន្តុដ្ឋិតា** បានដល់ ការសន្ដោស ពោល គឺការមិនលោភដែលកើតដល់បុគ្គលអ្នកសេពគប់ ចូលទៅអង្គុយជិតបុគ្គលដែលសន្ដោស ។

បទថា **សន្តុដ្ឋស្ស** បានដល់ ប្រកបដោយការសន្ដោសក្នុងបច្ច័យតាមមាន តាមបាន ការសន្ដោសនោះ មាន ១២ យ៉ាង គឺការសន្ដោសក្នុងចីវរ ៣ យ៉ាង គឺយថាលាភសន្ដោស ១ យថាពលសន្ដោស ១ យថាសារុប្ប-សន្ដោស ១ ក្នុងបិណ្ឌបាតជាដើមក៏ដូចគ្នា ។ សន្ដោសនោះ មានពណ៌នាតាមប្រភេទដូចតទៅនេះ ភិក្ខុក្នុងសាសនានេះ បានចីវរល្អក្ដី មិនល្អក្ដី លោកញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរនោះឯង មិនប្រាថ្នាចីវរដទៃ សូម្បីបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្ដោសក្នុងចីវររបស់ភិក្ខុនោះ ។ ឯភិក្ខុ

ដទៃមួយរូបទៀត ជាអ្នកមានកម្លាំងទុព្វលតាមប្រក្រតី ឬត្រូវអាពាធ និង ជរាគ្របសង្កត់ ដណ្តប់ចីវរធ្ងន់ រមែងលំបាក លោកប្តូរចីវរនោះនឹងភិក្ខុដែលត្រូវអធ្យាស្រ័យគ្នា ទោះបីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយចីវរស្រាល ក៏ជាអ្នកសន្តោស នេះឈ្មោះថា យថាពលសន្តោសក្នុងចីវររបស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត ជាអ្នកបានបច្ច័យប្រណីត បានផ្ទាំងចីវរដែលនាំមកពីក្រុងសោមារជាដើមឯណានីមួយ ដែលមានតម្លៃច្រើន ឬបានចីវរជាច្រើន ឲ្យទៅដោយគិតថា ចីវរនេះ សមគួរដល់ព្រះថេរៈដែលជាអ្នកបួសយូរ នេះសមគួរដល់ភិក្ខុដែលជាពហុសូត នេះសមគួរដល់ភិក្ខុដែលមានជំងឺ នេះសមគួរដល់ភិក្ខុដែលមានលាភតិច ហើយទើបជ្រើសយកចីវរចាស់របស់ភិក្ខុទាំងនោះ ឬសំពត់ប្រឡាក់ប្រឡូសអំពីគំនរសំរាមជាដើម ធ្វើជាសង្ឃាដីដោយសំពត់ទាំងនោះ សូម្បីគ្រងឯង ក៏ជាអ្នកសន្តោសនោះឯង នេះឈ្មោះថា យថាសារុប្ប-សន្តោសរបស់ភិក្ខុនោះ ។ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ បានបិណ្ឌបាតដែលសៅហ្មង ឬប្រណីត លោករមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយបិណ្ឌបាតនោះឯង មិនប្រាថ្នាបិណ្ឌបាតដទៃ សូម្បីបានក៏មិនទទួល នេះឈ្មោះថា យថាលាភសន្តោសរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត ភិក្ខុណាបានបិណ្ឌបាតដែលស្វែងចំពោះប្រក្រតីរបស់ខ្លួន ឬស្វែងដល់ជំងឺ បរិភោគហើយ មិនសប្បាយ លោកឲ្យបិណ្ឌបាតនោះដល់ភិក្ខុដែលស្និទ្ធស្នាលនឹងគ្នា ហើយឆាន់ភោជនដែលជាសប្បាយអំពីដៃរបស់ភិក្ខុនោះ ធ្វើសមណធម៌ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា យថាពលសន្តោស ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។ ភិក្ខុ

មួយរូបទៀត បានបិណ្ឌបាតដែលប្រណីតជាច្រើន លោកឲ្យបិណ្ឌបាតនោះ ដល់ព្រះថេរៈដែលបួសយូរ ជាពហុស្សូត ជាអ្នកមានលាភតិច និងភិក្ខុមានជំងឺ ដូចក្នុងចីវរដែរ សូម្បីឆាន់អាហារអំពីសម្នាក់របស់ភិក្ខុទាំងនោះ ឬអាហារដែលលាយគ្នា ព្រោះត្រាច់បិណ្ឌបាតមក ក៏ឈ្មោះថា ជាអ្នកសន្តោសពិត ។ នេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងបិណ្ឌបាតរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុក្នុងសាសនានេះ បានសេនាសនៈដែលគួរពេញចិត្តក្ដី មិនគួរពេញចិត្តក្ដី ។ លោកមិនឲ្យសេចក្ដីត្រេកអរកើតឡើង មិនឲ្យការអាក់អន់កើតឡើង រមែងត្រេកអរដោយសេនាសនៈ តាមមាន តាមបានប៉ុណ្ណោះ ដោយហោចសូម្បីកម្រាលដែលធ្វើដោយស្មៅ ។ នេះឈ្មោះថា យថាលាភសន្តោស ក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ភិក្ខុបានសេនាសនៈស្ទើងដល់ប្រក្រតីរបស់ខ្លួន ឬស្ទើងដល់ជំងឺរបស់ខ្លួន បើលោកនៅ មិនមានផាសុក លោកឲ្យសេនាសនៈនោះដល់ភិក្ខុដែលស្និទ្ធស្នាលនឹងគ្នា ហើយនៅក្នុងសេនាសនៈដែលជាសប្បាយ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា យថាពលសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ភិក្ខុមួយរូបទៀត ជាអ្នកមានបុណ្យច្រើន បានសេនាសនៈដ៏ប្រណីតដ៏ច្រើន មានគុហា មណ្ឌប ឬផ្ទះកំពូល លោកឲ្យសេនាសនៈទាំងនោះ ដល់ព្រះថេរៈដែលជារត្តញ្ញូ ភិក្ខុដែលជាពហុស្សូត ភិក្ខុដែលមានលាភតិច និងភិក្ខុមានជំងឺ ដូចក្នុងចីវរដែរ ទោះបីនៅក្នុងទីណាមួយ ក៏ជាអ្នកសន្តោសពិត នេះ

ឈ្មោះថា យថាសារុប្បសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។ ភិក្ខុណា ពិចារណាថា ធម្មតាសេនាសនៈប្រសើរជាទីតាំងនៃសេចក្តីប្រមាទ ថីនមិទ្ធៈ រមែងគ្របសង្កត់ បុគ្គលដែលអង្គុយក្នុងទីនោះ សម្រាប់ភិក្ខុដែលសិងលក់ ហើយភ្ញាក់ឡើង អកុសលវិតក្ករមែងប្រាកដ លោកមិនទទួលសេនាសនៈ បែបនោះ ទោះបីសេនាសនៈបែបនោះមកដល់ហើយ លោកបដិសេធសេនា-សនៈនោះ ហើយនៅក្នុងទីវាល មានគល់ឈើជាដើម ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា យថាសារុប្បសន្តោសក្នុងសេនាសនៈរបស់ភិក្ខុនោះ ។

ម្យ៉ាងទៀត ក្នុងព្រះសាសនានេះ បានភេសជ្ជៈសៅហ្មង ឬប្រណីត លោករមែងត្រេកអរដោយភេសជ្ជៈដែលខ្លួនបាននោះឯង មិនប្រាថ្នាភេសជ្ជៈដទៃដែលបានទទួលហើយ នេះឈ្មោះថា យថាលាភសន្តោស ក្នុងគិលា-នប្បច្ច័យរបស់ភិក្ខុនោះ ។ ម្យ៉ាងទៀត ភិក្ខុណាត្រូវការប្រេង បែរជាបានទឹកអំពៅ ទោះបីលោកឲ្យទឹកអំពៅនោះដល់ភិក្ខុដែលស្និទ្ធស្នាលគ្នា កាន់យកប្រេងអំពីដៃរបស់ភិក្ខុនោះ ឬស្វែងរកប្រេងដទៃធ្វើភេសជ្ជៈ ក៏ជាអ្នកសន្តោសពិត នេះឈ្មោះថា យថាពលសន្តោស ក្នុងគិលានប្បច្ច័យរបស់ភិក្ខុនោះ ។ ភិក្ខុមួយរូបទៀត មានបុណ្យច្រើន បាននូវភេសជ្ជៈប្រណីត មានប្រេង និងទឹកអំពៅជាដើមជាច្រើន លោកឲ្យភេសជ្ជៈនោះ ដល់ព្រះថេរៈដែលបួសយូរ ភិក្ខុដែលជាពហុស្សូត ភិក្ខុដែលមានលាភតិច និងភិក្ខុឈឺជាដើម ដូចក្នុងចីវរប្បច្ច័យដែរ ទោះបីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ ដោយភេសជ្ជៈឯណានីមួយ ដែលគេនាំមកហើយដើម្បីភិក្ខុទាំងនោះ ក៏ជាអ្នកសន្តោសពិត ។

ម្យ៉ាងទៀត ភិក្ខុណា កាលដាក់សម៉ត្រាំទឹកមូត្រក្នុងភាជនៈមួយ ដាក់វត្ថុមានរសឆ្ងាញ់ ៤ យ៉ាងចូលក្នុងភាជនៈ ១ ហើយពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ត្រូវការវត្ថុណា សូមកាន់យកវត្ថុនោះចុះ បើរោគរបស់លោកស្ងប់ទៅស្បើយទៅ ដោយភេសជ្ជៈទាំង ២ ណាមួយសោត កាលបើដូច្នោះ ឈ្មោះថា សម៉ត្រាំទឹកមូត្រ បណ្ឌិតទាំងឡាយ មានព្រះពុទ្ធជាដើមសរសើរហើយ ទើបបដិសេធរបស់មានរសឆ្ងាញ់ ៤ យ៉ាង កាន់យកភេសជ្ជៈដែលត្រាំដោយទឹកមូត្រ នេះក៏ឈ្មោះថា ជាអ្នកសន្តោសយ៉ាងក្រៃលែង នេះឈ្មោះថា យថាសារុប្បសន្តោស ក្នុងគិលានបច្ច័យរបស់ភិក្ខុនោះ ។ បណ្ដាសន្តោស ៣ ក្នុងបច្ច័យដោយចំពោះនីមួយៗ នោះ យថាសារុប្បសន្តោស ជាសន្តោសដែលក្រៃលែងជាងសន្តោសណាៗ ទាំងអស់ ។

## អដ្ឋកថាសូត្រទី ៥ ចប់

## អដ្ឋកថាសូត្រទី ៦-៧

[ ៦៧-៦៨ ] *ក្នុងសូត្រទី ៦ នឹងសូត្រទី ៧ មានវិនិច្ឆ័យដូចតទៅនេះ អយោនិសោមនសិការ និងយោនិសោមនសិការ មានលក្ខណៈដូចពោលហើយខាងដើម ពាក្យដ៏សេសក្នុងសូត្រនេះ មានអត្ថងាយហើយ ។ល។*

**អដ្ឋកថាសូត្រទី ៦-៧ ចប់**

## អដ្ឋកថាសូត្រទី ៨

[ ៦៩ ] *ក្នុងសូត្រទី ៨ មានវិនិច្ឆ័យដូចតទៅនេះ បទថា* **អសម្បជញ្ញំ** *បានដល់ ការមិនដឹងខ្លួន ។ បទថា* **អសម្បជញ្ញំ** *នេះ ជាឈ្មោះនៃមោហៈ ។ បទថា* **អសម្បជានស្ស** *បានដល់ អ្នកមិនដឹងខ្លួន គឺអ្នកវង្វេង ។ល។*

**អដ្ឋកថាសូត្រទី ៨ ចប់**

## អដ្ឋកថាសូត្រទី ៩

[ ៧០ ] *ក្នុងសូត្រទី ៩ មានវិនិច្ឆ័យដូចតទៅនេះ បទថា* **សម្បជញ្ញំ** *បានដល់ សេចក្តីដឹងខ្លួន ។ បទថា* **សម្បជញ្ញំ** *នេះ ជាឈ្មោះនៃបញ្ញា ។ បទថា* **សម្បជានស្ស** *បានដល់ បុគ្គលអ្នកដឹងខ្លួន ។ល។*

**អដ្ឋកថាសូត្រទី ៩ ចប់**

# អដ្ឋកថាសូត្រទី ១០

[ ៧១ ] ក្នុងសូត្រទី ១០ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ទាបមិត្តតា** សេចក្ដីថា មិត្រអាក្រក់ គឺបាបមិត្រ មានដល់បុគ្គលណា បុគ្គលនោះ ឈ្មោះថា មានមិត្រអាក្រក់ ។ ការមានមិត្រអាក្រក់ ឈ្មោះថា **ទាបមិត្តតា** ភាពជាអ្នកមានមិត្រអាក្រក់ ។ បទថា **ទាបមិត្តតា** នេះ ជាឈ្មោះនៃខន្ធ ៤ ដែលប្រព្រឹត្តទៅដោយអាការនោះ ។ សមដូចពាក្យដែលលោកពោលថា បណ្ដាធម៌ទាំងនោះ ភាពជាអ្នកមានមិត្រអាក្រក់ តើដូចម្ដេច ។ បុគ្គលទាំងឡាយណា ជាអ្នកមិនមានសទ្ធា ទ្រុស្ដសីល ចេះដឹងតិច មានសេចក្ដីកំណាញ់ ឥតប្រាជ្ញា ការសេព ការសេពមិនដាច់ ការសេពរឿយៗ ការគប់រក ការគប់រករឿយៗ ការគប់ ប្រសព្វ ការគប់ប្រសព្វរឿយៗ នូវបុគ្គលទាំងឡាយនោះ ការបែរទៅរកបុគ្គលនោះ នេះហៅថា ភាពជាអ្នកមានមិត្រអាក្រក់ ៕៚

**អដ្ឋកថាសូត្រទី ១០ ចប់**

**វីរិយារម្ភាទិវគ្គទី ៧ ចប់**

# សុត្តន្តបិដក

## កល្យាណមិត្តតាទិវគ្គទី ៨

[ ៧២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកអកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលមានកល្យាណមិត្ត ពួកកុសលធម៌ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ រមែងសាបសូន្យទៅផង ។

[ ៧៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញុំាងពួកអកុសលធម៌ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពួកកុសលធម៌ ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចកិរិយាប្រកបរឿយៗ នូវអកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ពួកអកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ព្រោះកិរិយាប្រកបរឿយៗ នូវអកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ ។

[ ៧៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញុំាងពួកកុសលធម៌មិនទាន់កើតឡើង ឲ្យកើត

ឡើងបាន ពួកអកុសលធម៌ដែលកើតឡើងហើយ ឲ្យសាបសូន្យទៅក្តី ដូចកិរិយាប្រកបរឿយៗ នូវកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ ពួកកុសលធម៌ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពួកអកុសលធម៌ដែលកើតឡើងហើយ ក៏រមែងសាបសូន្យទៅផង ព្រោះកិរិយាប្រកបរឿយៗ នូវកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ ។

[ ៧៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញុំាងពោជ្ឈង្គទាំងឡាយមិនទាន់កើតឡើង មិនឲ្យកើតឡើងបានក្តី ពោជ្ឈង្គទាំងឡាយដែលកើតឡើងហើយ ក៏មិនឲ្យដល់នូវការបរិបូណ៌ ដោយភាវនាក្តី ដូចការធ្វើទុកក្នុងចិត្តខុសទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តខុសទំនង ពោជ្ឈង្គទាំងឡាយ ដែលមិនទាន់កើតឡើង ក៏កើតឡើងមិនបានផង ពោជ្ឈង្គទាំងឡាយដែលកើតឡើងហើយ ក៏មិនដល់នូវការបរិបូណ៌ដោយភាវនាផង ។

[ ៧៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃសូម្បីតែសភាវៈ ១ ដែលញុំាងពោជ្ឈង្គទាំងឡាយ មិនទាន់កើតឡើង ឲ្យកើតឡើងបានក្តី ពោជ្ឈង្គទាំងឡាយ ដែលកើតឡើងហើយ ឲ្យដល់នូវការបរិបូណ៌ ដោយភាវនាក្តី ដូចការធ្វើទុកក្នុងចិត្តត្រូវទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ កាលបើបុគ្គលធ្វើទុកក្នុងចិត្តត្រូវទំនង ពោជ្ឈង្គទាំងឡាយ ដែលមិនទាន់កើតឡើង ក៏រមែងកើតឡើងបានផង ពោជ្ឈង្គទាំង-

ឡាយ ដែលកើតឡើងហើយ ក៏រមែងដល់នូវការបរិបូណ៌ដោយការនាផង ។

[ ៧៧ ] ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យចាកញាតិនេះ ជាការសាបសូន្យបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯការសាបសូន្យចាកបញ្ញានេះ ទើបជាការសាបសូន្យដ៏លាមក ជាងការសាបសូន្យទាំងអស់ ។

[ ៧៨ ] ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនដោយញាតិនេះ ជាសេចក្ដីចម្រើនបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯសេចក្ដីចម្រើនដោយបញ្ញានេះ ទើបជាសេចក្ដីចម្រើនប្រសើរ ជាងសេចក្ដីចម្រើនទាំងអស់ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងចម្រើនដោយបញ្ញាវុឌ្ឍិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ គួរសិក្សាយ៉ាងនេះឯង ។

[ ៧៩ ] ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យចាកទ្រព្យនេះ ជាការសាបសូន្យបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯការសាបសូន្យចាកបញ្ញានេះ ទើបជាការសាបសូន្យដ៏លាមក ជាងការសាបសូន្យទាំងអស់ ។

[ ៨០ ] ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនដោយទ្រព្យនេះ ជាសេចក្ដីចម្រើនបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯសេចក្ដីចម្រើនដោយបញ្ញានេះ ទើបជាសេចក្ដីចម្រើនប្រសើរ ជាងសេចក្ដីចម្រើនទាំងអស់ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងចម្រើនដោយបញ្ញាវុឌ្ឍិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ គួរសិក្សាយ៉ាងនេះឯង ។

[ ៨១ ] ម្នាលភិក្ខុទាំងឡាយ ការសាបសូន្យចាកយសនេះ ជាការសាបសូន្យបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯការសាបសូន្យចាកបញ្ញានេះ ទើបជាការសាបសូន្យដ៏លាមក ជាងការសាបសូន្យទាំងអស់ ។

[ ៨២ ] ម្នាលភិក្ខុទាំងឡាយ សេចក្ដីចម្រើនដោយយសនេះ ជាសេចក្ដីចម្រើនបន្តិចបន្តួចទេ ម្នាលភិក្ខុទាំងឡាយ ឯសេចក្ដីចម្រើនដោយបញ្ញានេះ ទើបជាសេចក្ដីចម្រើនប្រសើរ ជាងសេចក្ដីចម្រើនទាំងអស់ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គួរសិក្សាយ៉ាងនេះថា យើងទាំងឡាយនឹងចម្រើនដោយបញ្ញាវុឌ្ឍិ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ គួរសិក្សាយ៉ាងនេះឯង ។

វគ្គទី ៨ ចប់

# អដ្ឋកថា
# កល្យាណមិត្តតាទិវគ្គទី ៨

## សូត្រទី ១

[ ៧២ ] ក្នុងសូត្រទី ១ នៃវគ្គទី ៨ មានវិនិច្ឆ័យដូចតទៅនេះ បទថា **កល្យាណមិត្តតា** សេចក្ដីថា ឈ្មោះថា កល្យាណមិត្រ ព្រោះមានមិត្រល្អ ភាវៈនៃភាពជាអ្នកមានកល្យាណមិត្រនោះ ឈ្មោះថា **កល្យាណមិត្តតា** គឺ ភាពជាអ្នកមានមិត្រល្អ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលផ្ទុយគ្នា នឹងពាក្យដែលពោលនេះ ។ល។

**អដ្ឋកថាសូត្រទី ១ ចប់**

## អដ្ឋកថា សូត្រទី ២

[ ៧៣ ] ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អនុយោគោ** បានដល់ ការប្រកបការប្រកបទូទៅ ។ បទថា **អននុយោគោ** បានដល់ ការមិនប្រកបការមិនប្រកបទូទៅ ។ បទថា **អនុយោគា** ប្រែថា ព្រោះការប្រកបរឿយៗ ។ បទថា **អននុយោគា** ប្រែថា ព្រោះមិនប្រកបរឿយៗ ។ បទថា **កុសលានំ ធម្មានំ** បានដល់ កុសលធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ។ល។

**អដ្ឋកថា សូត្រទី ២ ចប់**

# អដ្ឋកថា សូត្រទី ៣

[ ៧៤ ] ក្នុងសូត្រទី ៣ មានអត្ថងាយយល់ទាំងអស់ហើយ ។ល។

## អដ្ឋកថា សូត្រទី ៣ ចប់

# អដ្ឋកថា សូត្រទី ៤

[ ៧៥ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ពោជ្ឈង្គា** បានដល់ ធម៌ ៧ ប្រការ ដែលជាអង្គគុណរបស់អ្នកត្រាស់ដឹង ។ ម្យ៉ាងទៀត ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃធម្មសាមគ្គី គ្រឿងត្រាស់ដឹងដែលជាហេតុចេញចាកវដ្ដៈ ឬធ្វើឲ្យជាក់ច្បាស់នូវសច្ចៈ ៤ របស់សត្វដែលត្រាស់ដឹងនោះ ។ បទថា **ពោជ្ឈង្គា** សេចក្ដីថា ឈ្មោះថា ពោជ្ឈង្គ ដោយអត្ថដូចម្ដេច ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃធម្មសាមគ្គី គឺគ្រឿងត្រាស់ដឹង ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃធម្មសាមគ្គី គ្រឿងត្រាស់ដឹងតាម ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃធម្មសាមគ្គី គ្រឿងត្រាស់ដឹងចំពោះ ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះជាអង្គនៃធម្មសាមគ្គី គ្រឿងត្រាស់ដឹងព្រម ។ ឈ្មោះថា ពោជ្ឈង្គ ព្រោះប្រព្រឹត្តទៅព្រមដោយបញ្ញាជាគ្រឿងត្រាស់ដឹងព្រម បទថា **ពោជ្ឈង្គ** នេះ លោកចែកទុកហើយ ដោយប្រការដូច្នេះ ។ល។

## អដ្ឋកថាសូត្រទី ៤ ចប់

# អដ្ឋកថាសូត្រទី ៥

[ ៧៦ ] ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ ដោយបទនេះថា **ភាវនាចារិប្បូរឹ គច្ឆន្តិ** រមែងដល់នូវការចម្រើនបរិបូណ៌ ដូច្នេះ លោកពោលដល់ភូមិ និងដោយកិច្ច តាមសេចក្តីពិតនៃពោជ្ឈង្គ ។ ភូមិមាន ៤ យ៉ាង គឺវិបស្សនា ១ ឈានដែលជាបាទនៃវិបស្សនា ១ មគ្គ ១ ផល ១ ក្នុង ៤ យ៉ាងនោះ ក្នុងវេលាដែលកើតក្នុងវិបស្សនា ពោជ្ឈង្គចាត់ជាកាមាវចរ ។ ក្នុងវេលាដែលកើតក្នុងឈាន ឈ្មោះថា ជាបាទនៃវិបស្សនា ពោជ្ឈង្គជារូបាវចរ និងអរូបាវចរ ។ ក្នុងវេលាដែលកើតក្នុងមគ្គ និងផល ពោជ្ឈង្គជាលោកុត្តរ ។ ដូច្នោះ ទើបក្នុងសូត្រនេះ លោកពោលពោជ្ឈង្គថា ប្រព្រឹត្តទៅក្នុងភូមិទាំង ៤ ៕ ✍

## អដ្ឋកថាសូត្រទី ៥ ចប់

# អដ្ឋកថាសូត្រទី ៦

[ ៧៧ ] ក្នុងសូត្រទី ៦ មានសេចក្តីសង្ខេបនៃអត្ថុប្បត្តិហេតុ គឺហេតុកើតនៃរឿង លោកពោលដូចតទៅនេះថា

ភិក្ខុច្រើនរូបអង្គុយប្រជុំគ្នា ក្នុងធម្មសភា សន្ទនាប្រារព្ធពន្ធុល មល្ល-សេនាបតីក្នុងចន្លោះ ដូច្នេះថា អាវុសោ ត្រកូលឈ្មោះនោះ ក្នុងកាលមុនមានញាតិច្រើន មានបក្ខពួកច្រើន ឥឡូវនេះ មានញាតិតិច មានសមាជិកតិច ។ គ្រានោះ ព្រះមានព្រះភាគ ទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងនោះ ទ្រង់

ជ្រាបថា កាលតថាគតទៅក្នុងទីនោះ នឹងមានធម្មទេសនាដ៏ធំ ទើបយាង ចេញអំពីព្រះគន្ធកុដិ គង់លើបវរពុទ្ធាសនៈ ដែលគេក្រាលទុកក្នុងធម្មសភា ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អម្បាញ់មិញនេះ ពួកអ្នកអង្គុយប្រជុំគ្នា ដោយរឿងអ្វី ។ ពួកភិក្ខុក្រាបទូលថា បពិត្រព្រះមានព្រះភាគ រឿងគាមនិគម ជាដើមដទៃ រមែងមិនមាន តែត្រកូលឈ្មោះនោះ ពីមុនមានសាច់ញាតិច្រើន មានបក្ខពួកច្រើន ឥឡូវនេះ មានញាតិតិច មានគ្នាតិច ពួកខ្ញុំព្រះអង្គអង្គុយ ប្រជុំសន្ទនាគ្នាដូច្នេះ ។ ព្រះសាស្តាទ្រង់ប្រារព្ធសូត្រនេះថា ម្នាលភិក្ខុទាំង-ឡាយ ការវិនាសនេះ មានប្រមាណតិចតួចទេ ដូច្នេះ ជាអត្ថុប្បត្តិហេតុ ក្នុងរឿងនេះ ។

បណ្តាបទទាំងនោះ បទថា **អប្បមត្តិកា** បានដល់ តិច គឺមាន ប្រមាណតិច ។ ពិតហើយ ដោយសេចក្តីវិនាសនេះ លោកពោលពាក្យ ជាដើមថា ការវិនាសចាកស្ថានសួគ៌ ឬវិនាសចាកមគ្គរមែងមិនមាន ទុំះគ្រាន់ តែជាការវិនាសក្នុងបច្ចុប្បន្នប៉ុណ្ណោះ ។ បទថា **ឯតំ បតិកិដ្ឋំ** សេចក្តីថា នេះ ជារបស់អាក្រក់ នេះជារបស់ថោកទាប ។ បទថា **យទិទំ បញ្ញាបរិហានិ** សេចក្តីថា ការវិនាសនៃកម្មស្សកតប្បញ្ញា ឈានបញ្ញា វិបស្សនាបញ្ញា មគ្គបញ្ញា និងផលបញ្ញាក្នុងសាសនារបស់តថាគត ទើបជាការវិនាសដ៏ អាក្រក់ ជាការវិនាសដែលថោកទាប ជាការវិនាសដែលគួរលះបង់ ។

## អដ្ឋកថាសូត្រទី ៦ ចប់

# អដ្ឋកថាសូត្រទី ៧

[ ៧៨ ] ក្នុងសូត្រទី ៧ លោកពោលទុកហើយ ក្នុងហេតុកើតនៃរឿងដូចគ្នា ។ បានឮថា បណ្តាភិក្ខុសង្ឃដែលអង្គុយប្រជុំគ្នាក្នុងធម្មសភាពួកខ្លះពោលយ៉ាងនេះថា ត្រកូលឈ្មោះនោះអំពីមុនមានញាតិតិច បក្ខពួកតិចឥឡូវនេះ ត្រកូលនោះ មានញាតិច្រើន មានគ្នាច្រើន សំដៅយកត្រកូលនោះ ទើបពោលយ៉ាងនេះឯង សេចក្តីនេះ សំដៅដល់នាងវិសាខាឧបាសិកានិងស្តេចលិច្ឆវី ក្នុងក្រុងវេសាលី ។ ព្រះសាស្តាទ្រង់ជ្រាបវារៈចិត្តរបស់ភិក្ខុទាំងនោះ ទើបយាងមកដោយន័យមុននោះឯង ប្រថាប់គង់លើធម្មាសនៈត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយសន្ទនាគ្នាដោយរឿងអ្វី ភិក្ខុទាំងនោះក្រាបទូលឲ្យទ្រង់ជ្រាបតាមសេចក្តីពិតហើយ ។ ព្រះសាស្តា ទ្រង់ផ្តើមសូត្រនេះ ព្រោះអត្ថុប្បត្តិហេតុនេះ ។

បណ្តាបទទាំងនោះ បទថា **អប្បមត្តិកា** សេចក្តីថា ឈ្មោះថា តិច ព្រោះមិនមានអ្នកអាស្រ័យសម្បត្តិនោះ ហើយដល់ស្ថានសួគ៌ ឬមគ្គបានឡើយ ។ បទថា **យទិទំ បញ្ញាវុឌ្ឍិ** បានដល់ ការចម្រើននៃកម្មស្សកតប្បញ្ញាជាដើម ។ បទថា **តស្មា** សេចក្តីថា ព្រោះឈ្មោះថា ការចម្រើននៃញាតិត្រឹមតែជាបច្ចុប្បន្ន ជារឿងតូចតាច មិនអាចឲ្យដល់ស្ថានសួគ៌ ឬបាននូវមគ្គឡើយ ។ បទថា **បញ្ញាវុឌ្ឍិយា** បានដល់ ដោយសេចក្តីចម្រើននៃបញ្ញា មានកម្មស្សកតប្បញ្ញាជាដើម ។

## អដ្ឋកថាសូត្រទី ៧ ចប់

## អដ្ឋកថាសូត្រទី ៨

[ ៧៩ ] ក្នុងសូត្រទី ៨ លោកពោលអត្ថុប្បត្តិហេតុដូចគ្នា ។ បានឮថា ភិក្ខុច្រើនរូបអង្គុយប្រជុំគ្នា ក្នុងធម្មសភា ប្រារព្ធកូនរបស់សេដ្ឋី ដែលមានទ្រព្យច្រើន ពោលថា ត្រកូលឈ្មោះនោះ កាលមុនមានភោគៈច្រើន មានប្រាក់ និងមាសច្រើន ឥឡូវនេះ បែរជាមានភោគៈតិច ។ ព្រះសាស្តាស្តេចយាងមក ដោយន័យមុននោះឯង ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ហើយ ទើបទ្រង់ផ្តើមសូត្រនេះ ។l៚

### អដ្ឋកថាសូត្រទី ៨ ចប់

## អដ្ឋកថាសូត្រទី ៩

[ ៨០ ] ក្នុងសូត្រទី ៩ លោកក៏ពោលព្រោះអត្ថុប្បត្តិហេតុដូចគ្នា ។ បានឮថា ពួកភិក្ខុអង្គុយប្រជុំគ្នាក្នុងធម្មសភា ប្រារព្ធកាកវល្លិយសេដ្ឋី និងបុណ្ណសេដ្ឋី ពោលថា ត្រកូលឈ្មោះនោះ កាលមុនមានភោគៈតិច ឥឡូវនេះ ត្រកូលទាំងនេះ មានភោគៈច្រើន ។ ព្រះសាស្តាទ្រង់យាងមក ដោយន័យមុននោះឯង ។ ទ្រង់ស្តាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបផ្តើមព្រះសូត្រនេះ ។ ពាក្យដ៏សេស ក្នុងសូត្រទាំង ២ នេះ គប្បីជ្រាបដោយន័យ ដូចពោលខាងដើមនោះឯង ។l៚

### អដ្ឋកថាសូត្រទី ៩ ចប់

## អដ្ឋកថាសូត្រទី ១០

[ ៨១ ] ក្នុងសូត្រទី ១០ លោកពោលហើយ ក្នុងអត្ថុប្បត្តិហេតុដូចគ្នា ។ បានឮថា ភិក្ខុទាំងឡាយ អង្គុយប្រជុំគ្នាក្នុងធម្មសភា ប្រារព្ធព្រះបាទកោសលមហារាជ ពោលថា ត្រកូលឈ្មោះនោះ កាលមុនមានយសច្រើន មានបរិវារច្រើន ឥឡូវនេះ មានយសតិច មានបរិវារតិច ។ ព្រះសាស្ដាយាងមកដោយន័យមុននោះឯង ទ្រង់ស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះ ក៏ផ្ដើមទេសនានេះ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ៕

### អដ្ឋកថាសូត្រទី ១០ ចប់

## អដ្ឋកថាសូត្រទី ១១

[ ៨២ ] ក្នុងសូត្រទី ១ នៃវគ្គទី ៩ លោកពោលហើយក្នុងអត្ថុប្បត្តិហេតុនោះឯង ។ បានឮថា ភិក្ខុច្រើនរូបអង្គុយប្រជុំគ្នាក្នុងធម្មសភា ប្រារព្ធដល់កុម្ភឃោសក ពោលថា ត្រកូលឈ្មោះនោះ អំពីមុនមានយសតិច មានបរិវារតិច ឥឡូវនេះ មានយសច្រើន មានបរិវារច្រើន ។ ព្រះសាស្ដាយាងមកដោយន័យមុននោះឯង ទ្រង់បានស្ដាប់ពាក្យរបស់ភិក្ខុទាំងនោះ ទើបផ្ដើមព្រះសូត្រនេះ អត្ថនៃព្រះសូត្រនោះ គប្បីជ្រាបដោយន័យដូចពោលហើយខាងដើមនោះឯង ៕

### អដ្ឋកថា សូត្រទី ១១ ចប់

### កល្យាណមិត្តតាទិវគ្គទី ៨ ចប់

# សុត្តន្តបិដក

## បមាទាទិវគ្គទី ៩

[ ៨៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៨៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ៨៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីខ្ជិលច្រអូស ទើបប្រព្រឹត្តទៅដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៨៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការផ្តួងព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការផ្តួងព្យាយាម ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ៨៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ

សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីប្រាជ្ញាច្រើននេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាជ្ញាច្រើន ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៨៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីប្រាជ្ញាតិចនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាជ្ញាតិច ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ៨៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីមិនសន្តោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៩០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីសន្តោសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ៩១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចការធ្វើទុកក្នុងចិត្តខុសទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តខុសទំនង ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៩២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការធ្វើទុកក្នុងចិត្តត្រូវទំនងនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តត្រូវទំនង ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ៩៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចអសម្បជញ្ញៈ ( សេចក្ដីមិនដឹងខ្លួន ) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែអសម្បជញ្ញៈ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៩៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅដើម្បីប្រយោជន៍ច្រើន ដូចសម្បជញ្ញៈ ( សេចក្ដីដឹងខ្លួន ) នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសម្បជញ្ញៈ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ៩៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចការមានបាបមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានបាបមិត្ត ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៩៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានកល្យាណ-

មិត្ត ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ៩៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចកិរិយាប្រកបរឿយៗ នូវអកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវអកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ៩៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចកិរិយាប្រកបរឿយៗ នូវកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌នេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវកុសលធម៌ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

**វគ្គទី ៩ ចប់**

# អដ្ឋកថា

# បមាទាទិវគ្គទី ៩

## សូត្រទី ១

[ ៨៣ ] *ក្នុងសូត្រទី ១ មានវិនិច្ឆ័យដូចតទៅនេះ បទថា* **មហតោ អនត្ថាយ** *បានដល់ ដើម្បីប្រយោជន៍ដល់ការវិនាសយ៉ាងធំ ។ ពាក្យដ៏សេសក្នុងសូត្រនេះ ងាយយល់ទាំងអស់ហើយ ។*

អដ្ឋកថាសូត្រទី ១ ចប់

បមាទាទិវគ្គទី ៩ ចប់

# សុត្តន្តបិដក

## ទុតិយបមាទាទិវគ្គទី ១០

[ ៩៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ១០០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១០១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីខ្ជិលច្រអូស ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ១០២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការប្រារព្ធព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការប្រារព្ធព្យាយាម ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១០៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ

ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាជ្ញាច្រើន ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ១០៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាជ្ញាតិច ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១០៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ១០៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១០៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តខុសទំនង ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន។

[ ១០៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តត្រូវទំនង ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១០៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ

មានតែអសម្បជញ្ញៈ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ១១០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសម្បជញ្ញៈ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១១១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្រៅ ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចការមានបាបមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានបាបមិត្ត ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ១១២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្រៅ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចការមានកល្យាណមិត្តនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែការមានកល្យាណមិត្ត ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១១៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ ដែលជាអង្គខាងក្នុង ដែលប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ដូចកិរិយាប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ ទើបប្រព្រឹត្តទៅ ដើម្បីឲ្យខូចប្រយោជន៍ច្រើន ។

[ ១១៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញអង្គដទៃ

ដែលជាអង្គខាងក្នុង សូម្បីតែអង្គ ១ ដែលប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ដូចកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលទាំងឡាយនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ ទើបប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ច្រើន ។

[ ១១៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ដូចសេចក្តីប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១១៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្ម ដូចសេចក្តីមិនប្រមាទនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិនប្រមាទ ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្មឡើយ ។

[ ១១៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ដូចសេចក្តីខ្ជិលច្រអូសនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីខ្ជិលច្រអូស ទើបប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១១៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ

សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធាន ព្រះសទ្ធម្ម ដូចកិរិយាប្រារព្ធព្យាយាមនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រារព្ធព្យាយាម ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅមិនវិនាស មិន អន្តរធានព្រះសទ្ធម្មឡើយ ។

[ ១១៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នា ច្រើន ទើបប្រព្រឹត្តទៅ ដើម្បីសេចក្តីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១២០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីប្រាថ្នា តិច ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្មឡើយ ។

[ ១២១ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីមិន សន្តោស ទើបប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១២២ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសេចក្តីសន្តោស ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្មឡើយ ។

[ ១២៣ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុង ចិត្តខុសទំនង ទើបប្រព្រឹត្តទៅដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១២៤ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការធ្វើទុកក្នុងចិត្តត្រូវទំនង ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្មឡើយ ។

[ ១២៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែអសម្បជញ្ញៈ ទើបព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១២៦ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែសម្បជញ្ញៈ ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្មឡើយ ។

[ ១២៧ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការមានបាបមិត្ត ទើបប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១២៨ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែការមានកល្យាណមិត្ត ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្មឡើយ ។

[ ១២៩ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ សោះ ។បេ។ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកប

រឿយៗ នូវអកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ ទើបប្រព្រឹត្តទៅ ដើម្បីវិនាស ដើម្បីអន្តរធានព្រះសទ្ធម្ម ។

[ ១៣០ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញសភាវៈដទៃ សូម្បីតែសភាវៈ ១ ដែលប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្ម ដូចកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយនេះសោះឡើយ ម្នាលភិក្ខុទាំងឡាយ មានតែកិរិយាប្រកបរឿយៗ នូវកុសលធម៌ទាំងឡាយ និងកិរិយាមិនប្រកបរឿយៗ នូវអកុសលធម៌ទាំងឡាយ ទើបប្រព្រឹត្តទៅ ដើម្បីឋិតនៅ មិនវិនាស មិនអន្តរធានព្រះសទ្ធម្មឡើយ ។

### វគ្គទី ១០ ចប់

# អដ្ឋកថា

## ទុតិយបមាទាទិវគ្គទី ១០

[ ៩៩ ] ក្នុងទុតិយបមាទិវគ្គទី ១ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អជ្ឈត្តិកំ** បានដល់ របស់ដែលប្រព្រឹត្តទៅខាងក្នុង ដោយអំណាចកើតចំពោះខាងក្នុងខ្លួន ។ បទថា **អង្គំ** ប្រែថា ហេតុ ។ បទថា **ឥតិ ករិត្វា** ប្រែថា ធ្វើយ៉ាងនេះ ។ ព្រះមានព្រះភាគត្រាស់អធិប្បាយថា ម្នាលភិក្ខុទាំង-ឡាយ តថាគតធ្វើវត្ថុដែលប្រព្រឹត្តទៅសន្តតខ្លួន គឺចំពោះខ្លួន ដែលតាំងឡើងក្នុងសន្តានរបស់ខ្លួនថាជាហេតុ ហើយរមែងមិនឃើញហេតុដទៃត្រឹមតែ ១ ដូច្នេះ ។

[ ១១១ ] បទថា **ពាហិរំ** បានដល់ វត្ថុដែលជាខាងក្រៅអំពីសន្តានខាងក្នុងខ្លួន ។

[ ១១៥ ] បទថា **សទ្ធម្មស្ស** បានដល់ ព្រះសទ្ធម្ម អធិប្បាយថាព្រះសាសនា ។ បទថា **សម្មោសាយ** បានដល់ ដើម្បីសេចក្តីវិនាស ។ បទថា **អន្តរធានាយ** បានដល់ ដើម្បីការមិនប្រាកដ ។

[ ១១៦ ] បទថា **ឋិតិយា** បានដល់ ដើម្បីការតាំងនៅអស់កាលយូរ ។

[ ១១៨ ] បទថា **អសម្មោសាយ អន្តរធានាយ** គប្បីជ្រាបដោយន័យផ្ទុយគ្នានឹងពោលហើយនោះឯង ។ ពាក្យដ៏សេស ក្នុងសូត្រនេះ មានន័យដូចពោលហើយ ក្នុងធម៌ដែលមាន ៤ ចំណុចនោះឯង ។

ក្នុងបទថា **អធម្មំ ធម្មោតិ ទីបេន្តិ** ជាដើម ក្នុងសូត្រខាងមុខ[១] ។ កុសលកម្មបថ ១០ ឈ្មោះថា **ធម៌** អកុសលកម្មបថ ឈ្មោះថា **អធម៌** ។ ម្យ៉ាងទៀត ពោធិបក្ខិយធម៌ ៣៧ ប្រការ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ ឈ្មោះថា **ធម៌** ។ ធម៌ គឺសតិប្បដ្ឋាន ៣ សម្មប្បធាន ៣ ឥទ្ធិបាទ ៣ ឥន្ទ្រិយ ៦ ពល ៦ ពោជ្ឈង្គ ៨ មគ្គមានអង្គ ៩ និងឧបាទាន ៤ នីវរណៈ ៥ អនុស័យ ៧ មិច្ឆត្ត ៨ ឈ្មោះថា **អធម៌** ។ បណ្តាបទទាំងនោះ បទថា **អធម្មោ** សេចក្តីថា ភិក្ខុទាំងឡាយ កាលកាន់យកចំណែកនៃអធម៌ឯណានីមួយហើយ សម្តែងថា អញនឹងធ្វើអធម៌នេះឲ្យជាធម៌ កុសលចិត្តរបស់អាចារ្យពួកយើង នឹងជានិយ្យានិកធម៌ជាគ្រឿងនាំចេញ ហើយពួកយើងនឹងប្រាកដក្នុងលោក ដោយអាការយ៉ាងនេះ ទើបពោលអធម៌នេះ ថាជាធម៌ ឈ្មោះថា សម្តែងអធម៌ ថាជាធម៌ ។ កាលកាន់យក ១ ចំណែក ក្នុងចំណែកនៃធម៌ដូច្នោះដូចគ្នា ហើយសម្តែងថា នេះជាអធម៌ ឈ្មោះថា សម្តែងធម៌ ថាអធម៌ ។ តែកាលពោលដោយបរិយាយនៃព្រះវិន័យ កម្មដែលចោទដោយរឿងដែលពិត ឲ្យរឭកបានហើយ កាត់អាបត្តិតាមប្តេជ្ញា ឈ្មោះថា **ធម៌** ។ កម្មដែលមិនបានចោទ មិនឲ្យរឭកបាន ដោយរឿងដែលមិនពិត ហើយកាត់អាបត្តិដែលមិនបានប្តេជ្ញា ឈ្មោះថា **អធម៌** ។

---

១- ក្នុងវគ្គទី ១១ ។

កាលពោលដោយបរិយាយនៃព្រះសូត្រ ធម៌នេះ គឺការកម្ចាត់រាគៈ ការកម្ចាត់ទោសៈ ការកម្ចាត់មោហៈ ការសង្រួម ការលះ ការពិចារណា ឈ្មោះថា **វិន័យ** ការមិនកម្ចាត់រាគៈជាដើម ការមិនសង្រួម ការមិនលះ និងការមិនពិចារណា ឈ្មោះថា **អវិន័យ** ។ កាលពោលដោយបរិយាយព្រះវិន័យ ធម៌នេះ គឺវត្ថុសម្បត្តិ ញត្តិសម្បត្តិ អនុសាវនាសម្បត្តិ សីមា-សម្បត្តិ បរិសសម្បត្តិ ឈ្មោះថា **វិន័យ** ។ វត្ថុវិបត្តិ បរិសវិបត្តិ ឈ្មោះថា **អវិន័យ** ។

កាលពោលដោយបរិយាយនៃព្រះសូត្រ ពាក្យនេះថា សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ អរិយមគ្គមានអង្គ ៨ ព្រះតថាគត ទ្រង់បានភាសិត បានត្រាស់ ។ ពាក្យនេះថា សតិប្បដ្ឋាន ៣ សម្មប្បធាន ៣ ឥទ្ធិបាទ ៣ ឥន្ទ្រិយ ៦ ពល ៦ សម្ពោជ្ឈង្គ ៨ មគ្គមានអង្គ ៩ ទ្រង់មិនបានភាសិត មិនបានត្រាស់ ។ កាលពោលដោយបរិយាយព្រះវិន័យ ពាក្យនេះថា បារាជិក ៤ សង្ឃាទិសេស ១៣ អនិយត ២ និស្សគ្គិយបាចិត្តិយៈ ៣០ ព្រះតថាគតទ្រង់បានភាសិត បានត្រាស់ ។ ពាក្យនេះថា បារាជិក ៣ សង្ឃាទិសេស ១៤ អនិយត ៣ និស្សគ្គិយបាចិត្តិយៈ ៣១ ព្រះតថាគតទ្រង់មិនបានភាសិត មិនបានត្រាស់ ។

កាលពោលដោយបរិយាយនៃព្រះសូត្រ កិច្ចនេះ គឺការចូលផល-សមាបត្តិ ការចូលមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលលោកដោយពុទ្ធចក្ខុ ទ្រង់សម្ដែងព្រះសូត្រដែលទាក់ទងដោយអត្ថុប្បត្តិហេតុ ការត្រាស់

ជាតកពាល់ៗ ថ្ងៃ ព្រះតថាគតធ្លាប់ប្រព្រឹត្តមក ។ កិច្ចនេះ គឺការមិនចូលផលសមាបត្តិ ។បេ។ ការមិនត្រាស់ជាតកពាល់ៗ ថ្ងៃ ព្រះតថាគតមិនធ្លាប់ប្រព្រឹត្តមក ។ កាលពោលដោយបរិយាយនៃព្រះវិន័យ កិច្ចនេះ គឺកាលត្រូវនិមន្តនៅចាំវស្សាហើយ ត្រូវពោលលា ទើបចៀសទៅកាន់ទីចារិកបវារណាហើយ ទើបចៀសចេញទៅកាន់ទីចារិក ធ្វើបដិសណ្ឋារៈមុន មួយអន្លើដោយភិក្ខុអាគន្តុកៈ ព្រះតថាគតធ្លាប់ប្រព្រឹត្តមក ។ ការមិនធ្វើកិច្ចដែលព្រះតថាគត ធ្លាប់ប្រព្រឹត្តមកនោះ ឈ្មោះថា មិនធ្លាប់ប្រព្រឹត្តហើយ ។ កាលពោលដោយបរិយាយនៃព្រះសូត្រ សតិប្បដ្ឋាន ៤ អរិយមគ្គមានអង្គ ៨ នេះឈ្មោះថា ព្រះតថាគតទ្រង់បញ្ញត្ត ។ សតិប្បដ្ឋាន ៣ មគ្គមានអង្គ ៩ នេះឈ្មោះថា តថាគតទ្រង់មិនបានបញ្ញត្ត ។ កាលពោលដោយបរិយាយនៃព្រះវិន័យ បារាជិក ៤ និស្សគ្គិយបាចិត្តិយៈ ៣០ ឈ្មោះថា តថាគតទ្រង់បញ្ញត្ត ។ បារាជិក ៣ និស្សគ្គិយបាចិត្តិយៈ ៣១ នេះ ឈ្មោះថា តថាគតទ្រង់មិនបានបញ្ញត្ត ។

## អន្តរធានមាន ៥ យ៉ាង

ក្នុងពាក្យដែលត្រាស់ក្នុងទីបំផុតនៃសូត្រទាំងពួងថា ភិក្ខុទាំងនោះរមែងញុំាងធម៌នេះ ឲ្យអន្តរធានទៅនោះ ឈ្មោះថា អន្តរធានមាន ៥ យ៉ាង គឺ អធិគមអន្តរធាន គឺអន្តរធានការត្រាស់ដឹង ១ បដិបត្តិអន្តរធាន គឺអន្តរធានបដិបត្តិ ១ បរិយត្តិអន្តរធាន គឺអន្តរធាននៃបរិយត្តិ ១ លិង្គអន្តរធាន គឺអន្តរធានភេទ ១ ធាតុអន្តរធាន គឺអន្តរធានព្រះធាតុ ១ ។ ក្នុង ៥ យ៉ាង

នោះ មគ្គ ៤ ផល ៤ បដិសម្ភិទា ៤ វិជ្ជា ៨ អភិញ្ញា ៦ ឈ្មោះថា អធិគម ។ អធិគមនោះ កាលវិនាស រមែងវិនាសទៅតាំងអំពីបដិសម្ភិទារៀងទៅ ។ ពិតហើយ រាប់អំពីព្រះសម្មាសម្ពុទ្ធបរិនិព្វានបាន ១០០០ ឆ្នាំប៉ុណ្ណោះ ភិក្ខុមិនអាចឲ្យបដិសម្ភិទាកើតបានឡើយ បន្ទាប់ពីនោះ ក៏អន្តរធានអភិញ្ញា ៦ ។ បន្ទាប់អំពីនោះ កាលមិនអាចធ្វើអភិញ្ញាឲ្យកើតឡើងបាន រមែងធ្វើវិជ្ជា ៣ ឲ្យកើតឡើង ។ លុះកាលកន្លងទៅ កាលមិនអាចធ្វើវិជ្ជា ៣ ឲ្យកើតឡើង ក៏ជាព្រះអរហន្តសុក្ខវិបស្សក: ដោយឧបាយនេះឯង ក៏ជាព្រះអនាគាមី ព្រះសកទាគាមី និងព្រះសោតាបន្ន ។ កាលលោកទាំងនោះនៅមានជីវិតនៅឡើយ អធិគម ឈ្មោះថា មិនទាន់វិនាស អធិគម ឈ្មោះថា វិនាសទៅ ព្រោះការអស់ទៅនៃជីវិតរបស់ព្រះអរិយបុគ្គល ដែលជាសោតាបន្នចុងក្រោយ ដូចពោលមកនេះ ឈ្មោះថា អន្តរធាននៃអធិគម ។

ភិក្ខុមិនអាចឲ្យឈាន វិបស្សនា មគ្គ និងផលកើតបាន រក្សាត្រឹមតែចតុប្បារិសុទ្ធិសីល ឈ្មោះថា អន្តរធានបដិបត្តិ កាលកន្លងយូរៗ ទៅ ភិក្ខុទាំងឡាយគិតថា អញរក្សាសីលឲ្យបរិបូណ៌ និងប្រកបព្យាយាមរឿយៗ តែអញមិនអាចធ្វើឲ្យជាក់ច្បាស់មគ្គ ឬផលបាន ឥឡូវនេះ មិនមានការត្រាស់ដឹងអរិយធម៌ ទើបរួញរា ច្រើនទៅដោយសេចក្ដីខ្ជិលច្រអូស មិនជាស់តឿនគ្នានិងគ្នា មិនរង្កៀសក្នុងការធ្វើបាប តាំងអំពីនោះ ក៏នាំគ្នាញាំញីសិក្ខាបទតូចតាច ក្នុងកាលកន្លងយូរៗ ទៅ ត្រូវអាបត្តិបាចិត្តិយ: ថុល្លច្ច័យ បន្ទាប់អំពីនោះ ក៏ត្រូវគរុកាបត្តិ ។ អាបត្តិបារាជិកប៉ុណ្ណោះដែលតាំងនៅ កាលភិក្ខុ ១០០ រូប

ខ្ទះ ១០០០ រូបខ្ទះ ដែលរក្សាអាបត្តិបារាជិក នៅមានជីវិតនៅឡើយ បដិបត្តិឈ្មោះថា មិនទាន់អន្តរធាន ហើយនឹងអន្តរធានទៅ ព្រោះភិក្ខុចុងក្រោយទម្លាយសីល ឬអស់ជីវិត ដូចពោលមកនេះឈ្មោះថា អន្តរធាននៃបដិបត្តិ ។

ពាក្យថា **បរិយត្តិ** បានដល់ បាលី ព្រមទាំងអដ្ឋកថាក្នុងពុទ្ធវចនៈ គឺព្រះត្រៃបិដកបាលីនោះ គង់នៅដរាបណា បរិយត្តិក៏ឈ្មោះថា នៅបរិបូណ៌ដរាបនោះ កាលកន្លងរឿយៗទៅ ព្រះរាជា និងឧបរាជ ក្នុងកលិយុគ មិនតាំងនៅក្នុងធម៌ កាលព្រះរាជា និងឧបរាជទាំងនោះ មិនតាំងនៅក្នុងធម៌ រាជអមាត្យជាដើមក៏មិនតាំងនៅក្នុងធម៌ បន្ទាប់អំពីនោះ អ្នកស្រុក និងអ្នកជនបទ ក៏មិនតាំងនៅក្នុងធម៌ ភ្លៀងរមែងមិនធ្លាក់ត្រូវតាមរដូវកាល ព្រោះមនុស្សទាំងនោះ មិនតាំងនៅក្នុងធម៌ ។ ស្រូវរមែងមិនបរិបូណ៌ កាលស្រូវទាំងនោះមិនបរិបូណ៌ ទាយកដែលប្រគេនបច្ច័យ ក៏មិនអាចប្រគេនបច្ច័យដល់ភិក្ខុសង្ឃបាន ភិក្ខុទាំងឡាយលំបាកដោយបច្ច័យ ក៏មិនអាចសង្គ្រោះពួកអន្តេវាសិកបាន កាលវេលាកន្លងយូរៗ ទៅ បរិយត្តិរមែងវិនាស ភិក្ខុទាំងឡាយមិនអាចចងចាំអត្ថបាន ចាំត្រឹមតែព្រះបាលីប៉ុណ្ណោះ ។ បន្ទាប់អំពីនោះ កាលកន្លងទៅ ក៏មិនអាចទ្រទ្រង់បាលីបានទាំងអស់ ។ ព្រះអភិធម្មបិដកក៏វិនាសទៅមុន កាលវិនាស ក៏វិនាសអំពីខាងចុងមក ។ ពិតហើយ បដ្ឋានមហាបករណ៍ រមែងវិនាសមុន កាលបដ្ឋានមហាបករណ៍វិនាស យមកកថាវត្ថុ បុគ្គលប្បញ្ញត្តិ ធាតុកថា ធម្មសង្គណី ក៏វិនាស កាលអភិធម្មបិដកវិនាសទៅយ៉ាងនេះ សុត្តន្តបិដក ក៏វិនាសតាំងអំពីខាងចុងមក អង្គុត្តរនិកាយ

មុន កាលអង្គុត្តរនិកាយវិនាសមុន ឯកាទសកនិបាតវិនាសមុន បន្ទាប់អំពីនោះ ទសកនិបាតក៏វិនាស ។បេ។ បន្ទាប់អំពីនោះ ឯកនិបាតក៏វិនាស ។ កាល អង្គុត្តរនិកាយវិនាសទៅយ៉ាងនេះ សំយុត្តនិកាយក៏វិនាសចាប់ពីខាងចុងមក ។ ពិតហើយ មហាវគ្គវិនាសមុន បន្ទាប់អំពីនោះ សឡាយតនវគ្គ ខន្ធវារវគ្គ និទានវគ្គ សគាថវគ្គ ក៏វិនាសជាលំដាប់ កាលសំយុត្តនិកាយវិនាសទៅយ៉ាង នេះ មជ្ឈិមនិកាយ រមែងវិនាសអំពីខាងចុងមក ។ ពិតហើយ ឧបរិ-បណ្ណាសកវិនាសមុន បន្ទាប់អំពីនោះ មជ្ឈិមបណ្ណាសក បន្ទាប់ពីនោះ មូលបណ្ណាសក ។ កាលមជ្ឈិមនិកាយវិនាសយ៉ាងនេះ ទីឃនិកាយវិនាស តាំងអំពីចុងមក ។ ពិតហើយ បាដិកវគ្គវិនាសមុន បន្ទាប់អំពីនោះ មហាវគ្គ បន្ទាប់អំពីនោះ សីលក្ខន្ធវគ្គក៏វិនាសជាលំដាប់ កាលទីឃនិកាយវិនាសយ៉ាង នេះ សុត្តន្តបិដក ឈ្មោះថា អន្តរធាន ទ្រទ្រង់ទុកចំពោះជាតក និងវិនយបិដក ប៉ុណ្ណោះ ។ ភិក្ខុដែលជាលជ្ជីប៉ុណ្ណោះ ទ្រទ្រង់ព្រះវិនយបិដក ចំណែកភិក្ខុ ដែលប្រាថ្នាក្នុងលាភ គិតថា កាលពោលតែព្រះសូត្រ ក៏មិនមានអ្នកកំណត់ បាន ទើបទ្រទ្រង់ទុកចំពោះជាតកប៉ុណ្ណោះ ។ ក្នុងកាលកន្លងយូរទៅ សូម្បី តែជាតកក៏មិនអាចចាំបាន កាលនោះ បណ្ដាជាតកទាំងនោះ វេស្សន្តរជាតក វិនាសមុន បន្ទាប់អំពីនោះ បុណ្ណកជាតក ( វិធុរជាតក ) មហានារទជាតក វិនាសទៅតាមលំដាប់ ក្នុងទីបំផុតក៏វិនាសអបណ្ណកជាតក ។ កាលជាតក វិនាសទៅយ៉ាងនេះ ភិក្ខុទាំងឡាយ ទ្រទ្រង់ទុកចំពោះព្រះវិនយបិដកប៉ុណ្ណោះ ។

កាលកន្លងយូរៗ ទៅ ក៏មិនអាចទ្រទ្រង់បាន សូម្បីតែវិនយបិដក បន្ទាប់

អំពីនោះ ក៏វិនាសអំពីខាងចុងមកមុន ។ គម្ពីរបរិវារវិនាសមុន បន្ទាប់ពីនោះ ខន្ធកៈ ភិក្ខុនីវិភង្គក៏វិនាស បន្ទាប់អំពីនោះ ក៏ទ្រទ្រង់ទុកត្រឹមឧបោសថក្ខន្ធកៈ ប៉ុណ្ណោះតាមលំដាប់ ។ ក្នុងកាលនោះ បរិយត្តិក៏ឈ្មោះថា មិនទាន់វិនាស គាថា ៤ បាទ នៅវិលទៅក្នុងពួកមនុស្សជរាបណា បរិយត្តិក៏ឈ្មោះថា មិនទាន់អន្តរធានជរាបនោះ ។ ក្នុងកាលណាព្រះរាជាអ្នកមានសទ្ធាទ្រង់ឲ្យដាក់ទ្រព្យមួយសែនក្នុងប្រអប់មាសលើ-កដរី ហើយឲ្យវាយស្គរប្រកាសទៅក្នុងព្រះនគរថា នរជនឯណា ចេះត្រឹមគាថា ៤ បាទ ដែលព្រះពុទ្ធត្រាស់ហើយ ចូរកាន់យកទ្រព្យមួយសែននេះទៅ ក៏មិនមានបុគ្គលណាមួយដែលទទួលយកទៅ ដោយការឲ្យត្រាច់វាយស្គរប្រកាសម្តង រមែងមានអ្នកបានឮខ្លះ មិនបានឮខ្លះ ទើបឲ្យវាយស្គរប្រកាសអស់វារៈ ៣ ដង ក៏មិនមានបុគ្គលទទួលទ្រព្យយកទៅ ។ ទើបរាជបុរសទាំងឡាយជញ្ជូនប្រអប់ប្រាក់មួយសែននោះ ត្រឡប់ទៅកាន់រាជត្រកូលវិញ ។ ក្នុងកាលនោះ បរិយត្តិ ឈ្មោះថា រមែងវិនាសទៅដូចពោលមកនេះ ឈ្មោះថា ការអន្តរធាននៃព្រះបរិយត្តិ ។

ក្នុងកាលកន្លងយូរៗ ទៅ ការទទួលចីវរ ការទទួលបាត្រ ការបត់អង្គុញ ការលាតសណ្តូក ការក្រឡេកមើលស្តាំឆ្វេង មិនជាទីនាំមកនូវការជ្រះថ្លា ។ ភិក្ខុទាំងឡាយដាក់បាត្រទុកត្រង់ចុងដៃ កាន់ត្រាច់ទៅ ដូចនិគ្រន្ថសមណៈកាន់បាត្រឃ្លោកដើរទៅ សូម្បីអាការមានប្រមាណប៉ុណ្ណេះ ភេទក៏ឈ្មោះថា មិនទាន់អន្តរធាន កាលកន្លងយូរៗ ទៅ យកបាត្រដាក់ចុះអំពីចុងដៃ យួរដោយដៃ ឬដោយសង្រែក ត្រាច់ទៅ សូម្បីចីវរ ក៏មិនធ្វើការជ្រលក់ឲ្យត្រឹមត្រូវ ធ្វើ

ឲ្យមានពណ៌ក្រហមប្រេី ។ កាលកន្លងយូរទៅ ការជ្រលក់ចីវរក្ដី ការកាត់ជាយសំពត់ក្ដី ការរបោះក្រវិលក្ដី រមែងមិនមាន ធ្វើត្រឹមតែគ្រឿងចំណាំ ហើយប្រើប្រាស់តមកទៀត លែងប្រើក្រវិលក្ដី មិនធ្វើគ្រឿងចំណាំ តមកទៀត មិនធ្វើទាំង ២ យ៉ាង កាត់ជាយសំពត់ត្រាច់ទៅ ដូចពួកបរិព្វាជក ។ កាលកន្លងយូរទៅ ក៏គិតថា ពួកយើងត្រូវការអ្វី ដោយការធ្វើដូច្នេះ ទើបចងកាសាវពស្ត្រដែលជ្រៀកតូចៗ ត្រង់ដៃ ឬត្រង់ក ឬត្រង់សក់ ធ្វើការចិញ្ចឹមប្រពន្ធ ក្ដួររាស់ចិញ្ចឹមជីវិត ។ ក្នុងកាលនោះ ជូនកាលឲ្យទក្ខិណា រមែងឲ្យដល់ជនទាំងនោះ ឧទ្ទិសសង្ឃ ព្រះមានព្រះភាគទ្រង់សំដៅយកសេចក្ដីនេះ ទើបត្រាស់ថា ម្នាលអានន្ទ ក្នុងអនាគតកាល នឹងមានគោត្រភូបុគ្គល ដែលមានកាសាវពស្ត្រព័ទ្ធក ជាអ្នកទ្រុស្តសីល ជាអ្នកមានធម៌ដ៏លាមក ជនទាំង-ឡាយឲ្យទានក្នុងបុគ្គលទ្រុស្តសីល ដែលមានធម៌លាមកទាំងនោះ ឧទ្ទិសសង្ឃ ម្នាលអានន្ទ ក្នុងកាលនោះ តថាគតពោលថា ទក្ខិណាទៅហើយក្នុងសង្ឃ មានផលរាប់មិនបាន ប្រមាណមិនបាន ។ បន្ទាប់អំពីនោះ ក្នុងកាលកន្លងយូរៗ ទៅ ជនទាំងនោះគិតថា នេះឈ្មោះថា ធម៌ជាគ្រឿងយឺតយូរ ពួកយើងត្រូវការអ្វី ដោយធម៌ជាគ្រឿងយឺតយូរនេះ ទើបបោះបោលចម្រៀកសំពត់ទៅក្នុងព្រៃ ។ ក្នុងកាលនោះ ភេទឈ្មោះថា អន្តរធានទៅ ។ បានឮថា ការដណ្ដប់សំពត់ស ត្រាច់ទៅ ជាការប្រព្រឹត្តរបស់មនុស្សទាំងនោះ តាំងអំពីគ្រាព្រះកស្សបទសពល ដូចពោលមកនេះ ឈ្មោះថា ការអន្តរធានទៅដោយភេទ ។

ឈ្មោះថា អន្តរធានទៅនៃធាតុ គប្បីជ្រាបយ៉ាងនេះថា បរិនិព្វានមាន ៣ គឺកិលេសបរិនិព្វាន ការបរិនិព្វាននៃកិលេស ១ ខន្ធបរិនិព្វាន បរិនិព្វាននៃខន្ធ ១ ធាតុបរិនិព្វាន ការបរិនិព្វាននៃធាតុ ១ បណ្តាបរិនិព្វាន ៣ យ៉ាងនោះ កិលេសបរិនិព្វាន មានត្រង់ពោធិបល្ល័ង្ក ខន្ធបរិនិព្វាន មានត្រង់នគរកុសិនារា ធាតុបរិនិព្វាន នឹងមានក្នុងអនាគត ។ តើមាននោះ មានដូចម្តេច គឺកាលនោះ ធាតុទាំងឡាយ ដែលមិនបានទទួលសក្ការៈ និងការគោរពក្រែងក្នុងទីនោះៗ ក៏ទៅកាន់ទីដែលមានសក្ការៈ និងការគោរពក្រែង ដោយកម្លាំងអធិដ្ឋានរបស់ព្រះពុទ្ធទាំងឡាយ ។ ក្នុងកាលកន្លងយូរៗ ទៅ សក្ការៈ និងការគោរពក្រែងមិនមានក្នុងទីទាំងពួង ។ វេលាព្រះសាសនាអន្តរធាន ព្រះធាតុទាំងឡាយ ក្នុងតម្ពបណ្ណិទ្វីប នឹងប្រជុំគ្នា ហើយទៅកាន់មហាចេតិយ ចេញអំពីមហាចេតិយ ទៅកាន់នាគចេតិយ បន្ទាប់អំពីនោះ ទៅកាន់ពោធិបល្ល័ង្ក ។ ព្រះធាតុទាំងឡាយចាកនាគពិភពខ្លះ ចាកទេវលោកខ្លះ ចាកព្រហ្មលោកខ្លះ ទៅកាន់ពោធិបល្ល័ង្កតែមួយកន្លែង ។ ព្រះធាតុប្រមាណប៉ុនគ្រាប់ស្ពៃក៏មិនវិនាសទៅក្នុងចន្លោះ ព្រះធាតុទាំងអស់ នឹងមកប្រជុំគ្នាត្រង់មហាពោធិមណ្ឌលដ្ឋាន បានជាព្រះពុទ្ធរូប សម្តែងពុទ្ធសរីរៈ ប្រថាប់គង់សមាធិ នាពោធិមណ្ឌល ។ មហាបុរិសលក្ខណៈ ៣២ អនុព្យញ្ជនៈ ៨០ ព្រះរស្មីប្រមាណ ១ ព្យាម គ្រប់បរិបូណ៌ទាំងអស់នោះឯង ។ បន្ទាប់អំពីនោះ ក៏ធ្វើបាដិហារ្យ ដូចក្នុងថ្ងៃសម្តែងយមកប្បាដិហារ្យ ដូច្នោះ ។ ក្នុងកាលនោះ សត្វ គឺមនុស្សមិនមានក្នុងទីនោះ ទេវតាក្នុងចក្កវាឡមួយម៉ឺនប្រជុំគ្នាទាំងអស់

កន្ទក់កន្ទេញថា ឱ ! ថ្ងៃនេះ ព្រះទសពលបរិនិព្វាន អំណើះតទៅ នឹងមាន តែងងឹត ។ លំដាប់នោះ តេជោធាតុឆេះឡើងអំពីសរីរធាតុ ធ្វើឲ្យសរីរៈនោះ ដល់នូវការបញ្ញត្តិមិនបាន ។ អណ្ដាតភ្លើងដែលឆេះឡើងអំពីសរីរធាតុ ផ្សាយ ឡើងរហូតដល់ព្រហ្មលោក កាលព្រះធាតុសូម្បីប៉ុនគ្រាប់ស្ពៃនៅមាន ក៏នឹង មានអណ្ដាតភ្លើងមួយប៉ុណ្ណោះ កាលព្រះធាតុអស់ទៅ អណ្ដាតភ្លើងក៏បាត់ ទៅ ។ ព្រះធាតុទាំងឡាយសម្ដែងអានុភាពធំយ៉ាងនេះហើយ ក៏អន្តរធាន ទៅ ។ ក្នុងកាលនោះ ពួកទេវតាធ្វើសក្ការៈដោយគ្រឿងក្រអូប ផ្កា និងទិព្វ-តន្ត្រីជាដើម ដូចក្នុងថ្ងៃដែលព្រះពុទ្ធទាំងឡាយបរិនិព្វាន ធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គសូម បានឃើញព្រះពុទ្ធ ដែលកើតឡើងក្នុងអនាគត ដូច្នេះហើយ ក៏ត្រឡប់ទៅ លំនៅ រៀងៗ ខ្លួន នេះឈ្មោះថា អន្តរធាននៃព្រះធាតុ ។

ការអន្តរធាននៃបរិយត្តិនោះឯង ជាមូលនៃអន្តរធាន ៥ យ៉ាងនេះ ពិត ហើយ កាលបរិយត្តិអន្តរធានទៅ បដិបត្តិក៏រមែងអន្តរធាន កាលបរិយត្តិគង់ នៅ បដិបត្តិក៏គង់នៅ ព្រោះហេតុនោះឯង ក្នុងគ្រាមានភ័យធំ ក្នុងកាលព្រះ បាទចណ្ឌាលតិស្សៈ ក្នុងទ្វីបនេះ សក្កទេវរាជនិម្មិតជាក្បូនធំ ហើយប្រាប់ដល់ ភិក្ខុទាំងឡាយថា ភ័យធំ នឹងមាន ភ្លៀងនឹងមិនធ្លាក់ត្រូវតាមរដូវកាល ភិក្ខុ ទាំងឡាយនាំគ្នាលំបាកដោយបច្ច័យ ៤ មិនអាចទ្រទ្រង់ព្រះបរិយត្តិទុកបាន លោកម្ចាស់ទាំងឡាយ គួរទៅកាន់ត្រើយនាយ រក្សាជីវិត សូមឡើងក្បូនធំ នេះចុះ ទីអង្គុយលើក្បូននេះ មិនគ្រប់គ្រាន់ដល់ភិក្ខុពួកណា ភិក្ខុទាំងឡាយ

នោះ សូមទំត្រង់អង្កត់ឧស ធ្វើដំណើរទៅចុះ ភ័យនឹងមិនមានដល់ភិក្ខុទាំងពួង ។ ក្នុងកាលនោះ ភិក្ខុ ៦០ រូប ទៅដល់ច្រាំងសមុទ្រ ហើយធ្វើកតិកាគ្នាថា មិនមានកិច្ចដែលពួកយើងនឹងទៅក្នុងទីនោះ ពួកយើងនឹងនៅក្នុងទីនេះឯង នឹងរក្សាព្រះត្រៃបិដក ដូច្នេះហើយ ទើបត្រឡប់អំពីទីនោះ ទៅកាន់ទក្ខិណមលយជនបទ ចិញ្ចឹមជីវិតដោយឫសឈើ និងស្លឹកឈើ ។ កាលសរីរកាយនៅប្រព្រឹត្តទៅ ក៏នាំគ្នាធ្វើការស្វាធ្យាយ កាលរាងកាយប្រព្រឹត្តទៅមិនបាន រមែងពូនខ្សាច់ព័ទ្ធជុំវិញសរីរៈក្នុងទីជាមួយគ្នា ពិចារណាព្រះបរិយត្តិ ។ ដោយទំនងនេះ ភិក្ខុទាំងឡាយ ទ្រទ្រង់ព្រះត្រៃបិដក ព្រមទាំងអដ្ឋកថាឲ្យបរិបូណ៌អស់ ១២ ឆ្នាំ ។

កាលភ័យស្ងប់ ភិក្ខុ ៧០០ រូប មិនធ្វើអក្ខរៈ ១ តួ ព្យញ្ជនៈ ១ តួ ក្នុងព្រះត្រៃបិដក ព្រមទាំងអដ្ឋកថា ចាកទីដែលខូនទៅហើយឲ្យវិនាស មកដល់កោះនេះឯង ទៅកាន់មណ្ឌលារាមវិហារ ក្នុងកល្យាណគាមជនបទ ភិក្ខុ ៦០ រូប ដែលនៅសល់ក្នុងកោះនេះ បានស្តាប់រឿងការមករបស់ព្រះថេរៈទាំងឡាយ គិតថា នឹងសួរសុខទុក្ខព្រះថេរៈទាំងឡាយ ទើបទៅផ្ទៀងផ្ទាត់ព្រះត្រៃបិដកជាមួយព្រះថេរៈទាំងឡាយ មិនជួបអក្ខរៈ ១ ព្យញ្ជនៈ ១ ដែលថាមិនដូចគ្នា ។

ព្រះថេរៈទាំងឡាយ កើតការសន្ទនាគ្នាក្នុងទីនោះថា បរិយត្តិជាមូលនៃព្រះសាសនា ឬបដិបត្តិជាមូល ។ ព្រះថេរៈដែលកាន់យកសំពត់បង្សុកូលជាវត្ត ពោលថា បដិបត្តិជាមូលនៃព្រះសាសនា ឯព្រះធម្មកថិកទាំងឡាយពោល

ថា ព្រះបរិយត្តិជាមូល ។ លំដាប់នោះ ព្រះថេរៈទាំងនោះពោលថា ខ្ញុំមិនជឿ ត្រឹមតែពាក្យរបស់លោកទាំង ២ ចំណែកប៉ុណ្ណោះ សូមពួកលោកអានព្រះសូត្រ ដែលព្រះជិនស្រី ទ្រង់សម្តែង ។ ព្រះថេរៈ ២ ពួកនោះពោលថា ការនាំព្រះសូត្រមកអាន មិនជាការៈធ្ងន់ឡើយ ។ ព្រះថេរៈខាងអ្នកទ្រទ្រង់សំពត់បង្សុកូល ទើបអានព្រះសូត្រថា ម្នាលសុភទ្ទ មួយទៀត ភិក្ខុទាំងនេះគប្បីនៅដោយប្រពៃ លោកនឹងមិនបានសាបសូន្យចាកពួកអរហន្តឡើយ ។ និងមួយសូត្រទៀតថា មហាបពិត្រ សាសនារបស់ព្រះសាស្តា មានបដិបត្តិជាមូល មានបដិបត្តិជាសារៈ កាលទ្រង់នៅក្នុងបដិបត្តិ ក៏ឈ្មោះថា តាំងនៅ ។ ឯពួកព្រះធម្មកថិក បានស្តាប់ព្រះសូត្រនោះហើយ ដើម្បីអះអាងវាទៈរបស់ខ្លួន ទើបអានព្រះសូត្រនេះថា

ព្រះសូត្រតាំងនៅដរាបណា ព្រះវិន័យរុងរឿងដរាបណា ភិក្ខុទាំងឡាយ រមែងឃើញពន្លឺ ដូចព្រះអាទិត្យរះឡើងដរាបនោះ កាលព្រះសូត្រមិនមាន ទោះព្រះវិន័យក៏ឱនថយទៅ ក្នុងលោកក៏នឹងមានតែងងឹត ដូចព្រះអាទិត្យអស្តង្គត កាលភិក្ខុនៅរក្សាព្រះសូត្រនៅឡើយ រមែងឈ្មោះថា រក្សាបដិបត្តិទុកផងដែរ អ្នកប្រាជ្ញតាំងនៅក្នុងបដិបត្តិ រមែងមិនឃ្លាតចាកធម៌ដែលក្សេមចាកយោគៈ ដូច្នេះ ។

កាលព្រះធម្មកថិក នាំព្រះសូត្រនេះមកអាន ព្រះថេរៈដែលទ្រទ្រង់សំពត់បង្សុកូលទាំងឡាយ ក៏នៅស្ងៀម ។ ពាក្យរបស់ព្រះថេរៈដែលជាធម្មកថិកនោះឯង កាន់យកបាន ។ ឧបមាដូចក្នុងគោឈ្មោល ១០០ ឬ ១០០០ កាល

*មិនមានមេគោ ដែលនឹងរក្សាពូជ វង្សត្រកូលក៏មិនបន្តគ្នា យ៉ាងណា កាល ភិក្ខុផ្តើមវិបស្សនា រាប់រយ រាប់ពាន់រូបមាន តែបរិយត្តិមិនមាន ឈ្មោះថា ត្រាស់ដឹងអរិយមគ្គមិនមាន យ៉ាងនោះឯង ។ មួយវិញទៀត កាលបុគ្គលចារឹក អក្សរលើបន្ទះថ្ម ដើម្បីឲ្យដឹងទីកប់ទ្រព្យ អក្សរតាំងនៅដរាបណា កំណប់ ទ្រព្យទាំងឡាយ ឈ្មោះថា មិនវិនាសដរាបនោះ យ៉ាងណា កាលបរិយត្តិ តាំងនៅ ព្រះសាសនា ក៏ឈ្មោះថា មិនអន្តរធានទៅ ក៏ដូច្នោះដូចគ្នា ។*

## អដ្ឋកថាវគ្គទី ១០ ចប់

# សុត្តន្តបិដក

## អធម្មវគ្គទី ១១

[ ១៣១ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវសភាព មិនមែនជាធម៌ថាជាធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បី មិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីសេចក្តីទុក្ខ ដល់ ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាន នូវបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យ អន្តរធានទៅ ។

[ ១៣២ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សំដែងនូវធម៌ថា មិនមែនជាធម៌ ។បេ។ សំដែងនូវសភាពមិនមែនវិន័យ ថាជាវិន័យ ។បេ។ សំដែងនូវវិន័យថាមិនមែនជាវិន័យ ។បេ។ សំដែងនូវពាក្យដែលព្រះតថាគត មិនសំដែង មិនពោលសោះ ថាជាពាក្យដែលព្រះតថាគតបានសំដែង បាន ពោលហើយ ។បេ។ សំដែងនូវពាក្យដែលព្រះតថាគតបានសំដែង បាន ពោលហើយ ថាជាពាក្យដែលព្រះតថាគតមិនសំដែង មិនពោលទេ ។បេ។ សំដែងនូវវត្តដែលព្រះតថាគតមិនសន្សំសោះ ថាជាវត្តដែលព្រះតថាគតបាន សន្សំហើយ ។បេ។ សំដែងនូវវត្តដែលព្រះតថាគតបានសន្សំហើយ ថាជាវត្ត ដែលព្រះតថាគតមិនសន្សំទេ ។បេ។ សំដែងនូវសិក្ខាបទ ដែលព្រះតថាគត មិនបញ្ញត្តសោះ ថាជាសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តហើយ ។បេ។

សម្តែងនូវសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តហើយ ថាជាសិក្ខាបទដែលព្រះតថាគតមិនបញ្ញត្តទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយនោះ ឈ្មោះថាប្រតិបត្តិដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីខូចប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីសេចក្តីទុក្ខដល់ទេវតានិងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យអន្តរធានទៅ ។

[ ១៣៣ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សម្តែងនូវសភាពមិនមែនជាធម៌ ថាជាសភាពមិនមែនជាធម៌ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះរមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថាធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅ ។

[ ១៣៤ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សម្តែងធម៌ថាជាធម៌ ។បេ។ សម្តែងនូវសភាពមិនមែនវិន័យ ថាមិនមែនជាវិន័យ ។បេ។ សម្តែងវិន័យថាជាវិន័យ ។បេ។ សម្តែងនូវពាក្យដែលព្រះតថាគតមិនសម្តែងមិនពោលសោះ ថាជាពាក្យដែលព្រះតថាគតមិនសម្តែង មិនពោល ។បេ។ សម្តែងនូវពាក្យដែលព្រះតថាគតបានសម្តែង បានពោលហើយ ថាជាពាក្យ

ដែលព្រះតថាគតបានសម្ដែង បានពោល ។បេ។ សម្ដែងនូវវត្ថុដែលព្រះតថាគតមិនសន្សំសោះ ថាជាវត្ថុដែលព្រះតថាគត មិនបានសន្សំ ។បេ។ សម្ដែងនូវវត្ថុដែលព្រះតថាគត បានសន្សំហើយ ថាជាវត្ថុដែលព្រះតថាគតបានសន្សំ ។បេ។ សម្ដែងនូវសិក្ខាបទដែលព្រះតថាគតមិនបញ្ញត្តសោះ ថាជាសិក្ខាបទដែលព្រះតថាគតមិនបញ្ញត្តិ ។បេ។ សម្ដែងនូវសិក្ខាបទ ដែលព្រះតថាគត បានបញ្ញត្តហើយ ថាជាសិក្ខាបទដែលព្រះតថាគតបានបញ្ញត្តិហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្ដីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្ដីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យឋិតនៅ ។

**វគ្គទី ១១ ចប់**

# អដ្ឋកថា

## អធម្មវគ្គទី ១១

[ ១៣២ ] ក្នុងអធម្មវគ្គទី ១១ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អធម្មំ អធម្មោ** ជាដើម គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ពាក្យដ៏សេសក្នុងទីនេះ មានអត្ថងាយយល់ហើយ ៕

**អដ្ឋកថា អធម្មវគ្គទី ១១ ចប់**

# សុត្តន្តបិដក

## អនាបត្តិវគ្គទី ១២

[ ១៣៥ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សម្តែងនូវអនាបត្តិ ថាជាអាបត្តិ ។បេ។ សម្តែងនូវអាបត្តិថាជាអនាបត្តិ ។បេ។ សម្តែងនូវលហុកាបត្តិ ថាជាគរុកាបត្តិ ។បេ។ សម្តែងនូវគរុកាបត្តិ ថាជាលហុកាបត្តិ ។បេ។ សម្តែងនូវទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ។បេ។ សម្តែងនូវអទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ។បេ។ សម្តែងនូវសាវសេសាបត្តិ ថាជាអនវសេសាបត្តិ ។បេ។ សម្តែងនូវអនវសេសាបត្តិ ថាជាសាវសេសាបត្តិ ។បេ។ សម្តែងនូវសប្បដិកម្មាបត្តិ ថាជាអប្បដិកម្មាបត្តិ ។បេ។ សម្តែងនូវអប្បដិកម្មាបត្តិ ថាជាសប្បដិកម្មាបត្តិវិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីមិនជាគុណដល់ជនច្រើន ដើម្បីមិនជាសុខដល់ជនច្រើន ដើម្បីមិនជាប្រយោជន៍ដល់ជនច្រើន ដើម្បីមិនជាគុណ ដើម្បីសេចក្តីទុក្ខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបាបច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យអន្តរធានទៅ ។

[ ១៣៦ ] ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុណា សម្តែងនូវអនាបត្តិ ថាជាអនាបត្តិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំង

នោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យបិតនៅ ។

[ ១៣៧ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សម្តែងនូវអាបត្តិ ថាជាអាបត្តិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យបិតនៅ ។

[ ១៣៨ ] ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយណា សម្តែងនូវលហុកាបត្តិ ថាជាលហុកាបត្តិ ។បេ។ សម្តែងនូវគរុកាបត្តិ ថាជាគរុកាបត្តិ ។បេ។ សម្តែងនូវទុដ្ឋុល្លាបត្តិ ថាជាទុដ្ឋុល្លាបត្តិ ។បេ។ សម្តែងនូវអទុដ្ឋុល្លាបត្តិ ថាជាអទុដ្ឋុល្លាបត្តិ ។បេ។ សម្តែងនូវសាវសេសាបត្តិ ថាជាសាវសេសាបត្តិ ។បេ។ សម្តែងនូវអនវសេសាបត្តិ ថាជាអនវសេសាបត្តិ ។បេ។ សម្តែងនូវសប្បដិកម្មាបត្តិ ថាជាសប្បដិកម្មាបត្តិ ។បេ។ សម្តែងនូវអប្បដិកម្មាបត្តិ ថាជាអប្បដិកម្មាបត្តិ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ ឈ្មោះថា ប្រតិបត្តិដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីប្រយោជន៍ដល់ជនច្រើន ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងនោះ រមែងបាននូវបុណ្យច្រើន មិនតែប៉ុណ្ណោះ ភិក្ខុទាំងនោះ ឈ្មោះថា ធ្វើព្រះសទ្ធម្មនេះឲ្យបិតនៅ ។

**វគ្គទី ១២ ចប់**

# អដ្ឋកថា

# អនាបត្តិវគ្គទី ១២

[ ១៣៥ ] ក្នុងអនាបត្តិវគ្គទី ១២ មានវិនិច្ឆ័យដូចតទៅនេះ ក្នុងបទថា **អនាបត្តី អាបត្តិ** ជាដើម អានាបត្តិដែលលោកពោលក្នុងទីនោះៗ ថា មិនជាអាបត្តិដល់ភិក្ខុដែលមិនដឹង មិនមានថេយ្យចិត្ត មិនបំណងនឹងឲ្យស្លាប់ មិនបំណងនឹងអួត មិនបំណងនឹងបញ្ចេញ ( សុក្ក ) ដូច្នេះ ឈ្មោះថា អនាបត្តិ ។ អាបត្តិដែលលោកពោលដោយន័យជាដើមថា ជាអាបត្តិដល់ភិក្ខុដែលជាអ្នកដឹង ដែលមានថេយ្យចិត្ត ដូច្នេះ ឈ្មោះថា អាបត្តិ ។ អាបត្តិ ៥ កង ឈ្មោះថា លហុកាបត្តិ ។ អាបត្តិ ២ កង ឈ្មោះថា គរុកាបត្តិ ។ អាបត្តិ ២ កង ឈ្មោះថា ទុដ្ឋុល្លាបត្តិ គឺអាបត្តិគ្រោតគ្រាត អាបត្តិ ៥ កង ឈ្មោះថា អទុដ្ឋុល្លាបត្តិ ។ អាបត្តិ ៦ កង ឈ្មោះថា សាវសេសាបត្តិ គឺអាបត្តិដែលមានចំណែកសល់ អាបត្តិបារាជិក ១ កង ឈ្មោះថា អនាវសេសាបត្តិ អាបត្តិដែលមានចំណែកសល់នោះឯង ឈ្មោះថា អាបត្តិដែលសម្តែងបាន អាបត្តិដែលមិនមានចំណែកសល់នោះឯង ឈ្មោះថា អាបត្តិដែលសម្តែងមិនបាន ។ ពាក្យដ៏សេសក្នុងទីទាំងពួង ងាយយល់ហើយ ៕

**អដ្ឋកថាអនាបត្តិវគ្គទី ១២ ចប់**

# សុត្តន្តបិដក

## ឯកបុគ្គលបាលិ ១៣

[ ១៣៩ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ បុគ្គលឯក តើគឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើង ដើម្បីជាគុណដល់ជនច្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ដើម្បីអនុគ្រោះដល់សត្វលោក ដើម្បីប្រយោជន៍ ដើម្បីជាគុណ ដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សទាំងឡាយ ។

[ ១៤០ ] ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯក បានដោយកម្រក្នុងលោក ការកើតប្រាកដនៃបុគ្គលឯក តើគឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯកនេះឯងរកបានដោយកម្រក្នុងលោក ។

[ ១៤១ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងជាមនុស្សអស្ចារ្យ បុគ្គលឯក តើគឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងជាមនុស្សអស្ចារ្យ ។

[ ១៤២ ] ម្នាលភិក្ខុទាំងឡាយ កាលកិរិយានៃបុគ្គលឯក ជាទីសោក

ស្តាយនៃជនច្រើន កាលកិរិយានៃបុគ្គលឯក តើគឺនរណា គឺព្រះតថាគត អរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ កាលកិរិយានៃបុគ្គលឯកនេះឯង ជាទីសោកស្តាយនៃជនច្រើន ។

[ ១៤៣ ] ម្នាលភិក្ខុទាំងឡាយ បុគ្គលឯក កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងឥតមានពីរ មិនមានសម្លាញ់ មិនមានបុគ្គលមានអត្តភាពដូច មិនមានបុគ្គលមានអត្តភាពស្មើ ជាអ្នកបែងភាគធម៌ ឥតមានបុគ្គលចាប់កំហុសបាន មិនមានបុគ្គលប្រៀបផ្ទឹមបាន មិនមានបុគ្គលស្មើ ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ប្រសើរបំផុតជាងពួកសត្វមានជើង ២ បុគ្គលឯក តើគឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ បុគ្គលឯកនេះឯង កាលកើតឡើងក្នុងលោក ក៏រមែងកើតឡើងឥតមានពីរ មិនមានសម្លាញ់ មិនមានបុគ្គលមានអត្តភាពដូច មិនមានបុគ្គលមានអត្តភាពស្មើ ជាអ្នកបែងភាគធម៌ ឥតមានបុគ្គលចាប់កំហុសបាន មិនមានបុគ្គលប្រៀបផ្ទឹមបាន មិនមានបុគ្គលស្មើ ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ប្រសើរបំផុតជាងពួកសត្វមានជើង ២ ។

[ ១៤៤ ] ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯក ជាការកើតប្រាកដនៃចក្ខុដ៏ប្រសើរ ជាការកើតប្រាកដនៃពន្លឺដ៏ប្រសើរ ជាការកើតប្រាកដនៃរស្មីដ៏ប្រសើរ ជាការកើតប្រាកដនៃអនុត្តរិយៈ ៦ ប្រការ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា ៤ ប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុច្រើនប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុផ្សេងៗ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា

និងវិមុត្តិ និងផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ជាកិរិយាធ្វើឲ្យជាក់នូវអគាមិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ការកើតប្រាកដនៃបុគ្គលឯក តើគឺនរណា គឺព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ការកើតប្រាកដនៃបុគ្គលឯកនេះឯង ជាការកើតប្រាកដនៃចក្ខុដ៏ប្រសើរ ជាការកើតប្រាកដនៃពន្លឺដ៏ប្រសើរ ជាការកើតប្រាកដនៃរស្មីដ៏ប្រសើរ ជាការកើតប្រាកដនៃអនុត្តរិយៈ ៦ ប្រការ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទា ៤ ប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុច្រើនប្រការ ជាកិរិយាត្រាស់ដឹងនូវធាតុផ្សេងៗ ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវវិជ្ជា និងវិមុត្តិ និងផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ជាកិរិយាធ្វើឲ្យជាក់ច្បាស់នូវអរហត្តផល ។

[ ១៨៥ ] ម្នាលភិក្ខុទាំងឡាយ តថាគតរំពឹងរកមិនឃើញបុគ្គលដទៃសូម្បីតែបុគ្គលម្នាក់ អ្នកញុំាងធម្មចក្រដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាមដោយត្រឹមត្រូវ ដូចសារីបុត្តនេះសោះ ម្នាលភិក្ខុទាំងឡាយ មានតែសារីបុត្ត ទើបញុំាងធម្មចក្រដ៏ប្រសើរ ដែលតថាគតឲ្យប្រព្រឹត្តទៅហើយ ឲ្យប្រព្រឹត្តទៅតាមដោយត្រឹមត្រូវបាន ។

បុគ្គលវគ្គ ចប់

# អដ្ឋកថា

# ឯកបុគ្គលវគ្គទី ១៣

## សូត្រទី ១

[ ១៣៩ ] ក្នុងសូត្រទី ១ នៃឯកបុគ្គលវគ្គទី ១៣ មានវិនិច្ឆ័យដូច្នេះ បទថា **ឯកបុគ្គលោ** ប្រែថា បុគ្គលឯក ។ បទថា **ឯកោ** ក្នុងបទថា **ឯក-បុគ្គលោ** នេះ ជាការកំណត់ចំនួនដែលមានអត្ថបដិសេធបុគ្គល ២ ជាដើម ។ បទថា **បុគ្គលោ** ជាពាក្យនិយាយដោយសន្មុត មិនមែនវាចាដោយបរមត្ថឡើយ ។

ពិតហើយ ទេសនារបស់ព្រះមានព្រះភាគមាន ២ យ៉ាង គឺសម្មតិ-ទេសនា ១ បរមត្ថទេសនា ១ ។ ក្នុងទេសនា ២ យ៉ាងនោះ ទេសនាទំនងនេះថា បុគ្គល សត្វ ស្រី ប្រុស ក្សត្រ ព្រាហ្មណ៍ ទេវតា មារ ឈ្មោះថា សម្មតិទេសនា ។ ទេសនាទំនងនេះថា មិនទៀង ជាទុក្ខ ជាអនត្តា ខន្ធ ធាតុ អាយតនៈ សតិប្បដ្ឋាន ឈ្មោះថា បរមត្ថទេសនា ។ ក្នុងទេសនា ២ យ៉ាងនោះ ជនពួកណាស្តាប់ទេសនា ទាក់ទងដោយសម្មតិ អាចយល់អត្ថ ការលះមោហៈ សម្រេចគុណវិសេសបាន ព្រះមានព្រះភាគទ្រង់សម្តែងសម្មតិទេសនា ដល់ជនទាំងនោះ ។ ឯជនទាំងឡាយឯណាស្តាប់ទេសនាទាក់ទងដោយបរមត្ថ ហើយអាចយល់អត្ថ លះមោហៈ សម្រេចគុណវិសេសបាន ព្រះមានព្រះភាគ ទ្រង់សម្តែងបរមត្ថទេសនាដល់ជនទាំងនោះ ។

ក្នុងសេចក្តីនោះ គប្បីជ្រាបឧបមាដូចតទៅនេះ

ឧបមាដូចអាចារ្យអ្នកឈ្លាសក្នុងភាសាតាមតំបន់ ដែលបរិយាយអត្ថនៃវេទទាំង ៣ ជនពួកណា កាលពោលដោយភាសាទមិឡ រមែងយល់សេចក្តីបាន ក៏បង្រៀនជនទាំងនោះ ដោយភាសាទមិឡ ជនពួកណា កាលពោលដោយភាសាណានីមួយ ក្នុងបណ្តាភាសារបស់អ្នកអន្ធៈជាដើម រមែងយល់អត្ថបាន ក៏បង្រៀនដោយភាសានោះៗ ដល់ជនទាំងនោះ កាលបើដូច្នោះ មាណពទាំងនោះ អាស្រ័យអាចារ្យអ្នកឈ្លាស មុតស្រួច រមែងរៀនសិប្បៈបានដោយឆាប់រហ័សនោះឯង ។ ឧបមានោះគប្បីជ្រាបថា ព្រះមានព្រះភាគប្រៀបដូចអាចារ្យ ។ បិដក ៣ តាំងនៅក្នុងការៈដែលនឹងត្រូវបង្រៀន ប្រៀបដូចវេទ ៣ ភាពជាអ្នកឈ្លាសក្នុងសម្មតិ និងបរមត្ថ ដូចភាពជាអ្នកឈ្លាសក្នុងភាសាតំបន់ វេនេយ្យសត្វដែលអាចយល់អត្ថបាន ដោយអំណាចនៃសម្មតិ និងបរមត្ថ ដូចមាណពដែលដឹងភាសាតំបន់ផ្សេងៗ គ្នា ទេសនាដោយអំណាចសម្មតិ និងបរមត្ថរបស់ព្រះមានព្រះភាគ ប្រៀបដូចការបង្រៀនដោយភាសាមានភាសាទមិឡជាដើមរបស់អាចារ្យ ។ សមដូចលោកពោលក្នុងទីនេះថា

ព្រះសម្ពុទ្ធ ជាកំពូលនៃអ្នកទូន្មានទាំងឡាយ បានត្រាស់សច្ចៈ ២ យ៉ាង គឺសម្មតិសច្ច និងបរមត្ថសច្ច មិនត្រាស់សច្ចៈទី ៣ ឡើយ ពាក្យដែលសត្វលោកសន្មតដើម្បីដឹងគ្នានិងគ្នា ក៏ជាសច្ចៈ ព្រោះមានលោកសម្មតិជាហេតុ ពាក្យដែលប្រារព្ធដល់វត្ថុដែលជាបរមត្ថ ក៏ជាសច្ចៈ ព្រោះមានសេចក្តីពិតនៃធម៌ទាំងឡាយជាហេតុ ព្រោះដូច្នោះ ទើបមុសាវាទមិនកើតដល់ព្រះលោកនាថដ៏ជាសាស្តា ជាអ្នកឈ្លាសក្នុងវោហារ ជាអ្នកត្រាស់តាម

សម្មតិ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគត្រាស់បុគ្គលកថា ពោលដោយបុគ្គល ដោយហេតុ ៨ ប្រការ គឺដើម្បីសម្តែងហិរិ គឺការខ្មាសបាប និងឱត្តប្បៈ គឺការខ្លាចបាប ១ ដើម្បីទ្រង់សម្តែងកម្មស្សកតា ១ ដើម្បីទ្រង់សម្តែងបុគ្គលដែលធ្វើចំពោះខ្លួន ១ ដើម្បីទ្រង់សម្តែងដល់អនន្តរិយកម្ម ១ ដើម្បីទ្រង់សម្តែងដល់ព្រហ្មវិហារធម៌ ១ ដើម្បីទ្រង់សម្តែងដល់បុព្វេនិវាសញ្ញាណ ១ ដើម្បីទ្រង់សម្តែងដល់ទក្ខិណាវិសុទ្ធិ ១ និងដើម្បីមិនលះលោកសម្មុតិ ១ ។ កាលទ្រង់ត្រាស់ថា ខន្ធ ធាតុ អាយតនៈទាំងឡាយ រមែងខ្មាស រមែងខ្លាច ដូច្នេះ មហាជន រមែងមិនយល់ រមែងងឿងឆ្ងល់ បែរជាសត្រូវ ជំទាស់ថា នេះអ្វីហ្ន៎ ខន្ធ ធាតុ អាយតនៈ រមែងខ្មាសបាប រមែងខ្លាចបាប ។ តែបើត្រាស់ថា ស្ត្រី បុរស ក្សត្រ ព្រាហ្មណ៍ ទេវតា និងមារ រមែងខ្មាសបាប រមែងខ្លាចបាប មហាជន រមែងយល់ រមែងមិនងឿងឆ្ងល់ មិនត្រឡប់ជាសត្រូវ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីទ្រង់សម្តែងហិរិ និងឱត្តប្បៈ ។ ក្នុងពាក្យដែលពោលថា ខន្ធទាំងឡាយ ធាតុទាំងឡាយ អាយតនៈទាំងឡាយ មានកម្មជារបស់ខ្លួន ក៏មានន័យដូចគ្នា ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់បុគ្គលកថា ដើម្បីទ្រង់សម្តែងភាពដែលសត្វមានកម្មជារបស់ខ្លួន ក្នុងពាក្យដែលពោលថា មហាវិហារទាំងឡាយ មានវេឡុវ័នជាដើម ដែលខន្ធ ធាតុ អាយតនៈសាងហើយ ក៏ន័យនេះដូចគ្នា ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែង

បុគ្គលកថា ដើម្បីទ្រង់សម្តែងដល់បុគ្គលដែលធ្វើចំពោះខ្លួន ។

ក្នុងពាក្យដែលពោលថា ខន្ធ ធាតុ អាយតនៈ រមែងផ្តាច់ជីវិតមាតាបិតា ព្រះអរហន្ត ធ្វើកម្ម គឺញ៉ាំងព្រះលោហិតឲ្យពុរពង និងធ្វើសង្ឃភេទក៏ន័យនេះដូចគ្នា ព្រោះដូច្នោះ ព្រះមានព្រះភាគទ្រង់សម្តែងបុគ្គលកថា ដើម្បីទ្រង់សម្តែងអនន្តរិយកម្ម ។

ក្នុងពាក្យដែលពោលថា ខន្ធ ធាតុ អាយតនៈ មានមេត្តាក៏ន័យនេះដូចគ្នា ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងបុគ្គលកថា ដើម្បីទ្រង់សម្តែងព្រហ្មវិហារធម៌ ។ ក្នុងពាក្យដែលពោលថា ខន្ធ ធាតុ អាយតនៈ រមែងរឭកដល់បុព្វេនិវាសញ្ញាណ ក៏ន័យនេះដូចគ្នា ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងបុគ្គលកថា ដើម្បីទ្រង់សម្តែងបុព្វេនិវាសញ្ញាណ ។ កាលពោលថា ខន្ធ ធាតុ អាយតនៈ ទទួលទាន មហាជន រមែងមិនយល់ រមែងងឿងឆ្ងល់ ត្រឡប់ជាសត្រូវថា នេះជាអ្វីហ្ន៎ ខន្ធ ធាតុ អាយតនៈ រមែងទទួលទាន ។ កាលពោលថា បុគ្គលមានសីល មានកល្យាណធម៌ជាដើម មហាជនរមែងយល់ រមែងមិនងឿងឆ្ងល់ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគទ្រង់សម្តែងបុគ្គលកថា ដើម្បីទ្រង់សម្តែងបរិសុទ្ធនៃទក្ខិណា ។

ពិតហើយ ព្រះមានព្រះភាគ ដ៏ជាពុទ្ធទាំងឡាយ ទ្រង់មិនលះលោកសន្មត តាំងនៅក្នុងឈ្មោះរបស់សត្វលោក ក្នុងភាសារបស់សត្វលោក ក្នុងពាក្យនិយាយគ្នារបស់សត្វលោកនោះឯងសម្តែងធម៌ ។ ព្រោះដូច្នោះ ទើបព្រះមានព្រះភាគ ទ្រង់សម្តែងបុគ្គលកថា ដើម្បីមិនលះលោកសន្មត ។

ដូច្នោះ ទើបឈ្មោះថា ជាបុគ្គលឯក ព្រោះបុគ្គលនោះផង ជាឯកផង ។ ដែលឈ្មោះថា បុគ្គលឯក ព្រោះអត្ថដូចម្តេច ព្រោះអត្ថថា មិនមានអ្នកដទៃដូច ព្រោះអត្ថថា វិសេសដោយគុណ ព្រោះអត្ថថា ស្មើនឹងព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ។ ពិតហើយ ព្រះមានព្រះភាគអង្គនោះ មិនដូចមហាជនទូទៅដោយគុណ គឺពោធិសម្ភារ រាប់តាំងអំពីទ្រង់រំពឹងដល់បារមី ១០ តាមលំដាប់ និងដោយព្រះពុទ្ធគុណ ព្រោះដូច្នោះ ទើបឈ្មោះថា បុគ្គលឯក ព្រោះអត្ថថា មិនមានបុគ្គលណាដូច ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់មានគុណវិសេសជាងគុណនៃពួកសត្វដែលមានគុណទូទៅ ព្រោះហេតុនោះ ទើបឈ្មោះថា បុគ្គលឯក ព្រោះអត្ថថា មានសេចក្តីវិសេសដោយគុណ ។ ព្រះសម្មាសម្ពុទ្ធអង្គមុនៗ មិនស្មើដោយសត្វគ្រប់ជំពូក តែព្រះមានព្រះភាគអង្គនេះមួយអង្គប៉ុណ្ណោះ ជាអ្នកស្មើនឹងព្រះសម្មាសម្ពុទ្ធទាំងនោះដោយព្រះគុណ គឺរូបកាយ និងព្រះគុណ គឺនាមកាយ ព្រោះហេតុនោះ ទើបឈ្មោះថា បុគ្គលឯក ព្រោះអត្ថថា ស្មើគ្នានឹងព្រះពុទ្ធដែលមិនមានបុគ្គលស្មើ ។

បទថា **លោកេ** បានដល់ លោក ៣ គឺសត្វលោក ឱកាសលោក សង្ខារលោក ។ កថាពោលដោយសេចក្តីពិស្តារនៃលោកទាំង ៣ នោះ លោកបានពោលហើយ ក្នុងវិសុទ្ធិមគ្គ ។ បណ្តាលោក ៣ នោះ សត្វលោក លោកបំណងយកក្នុងទីនេះ ។ ពិតហើយ ព្រះតថាគតនោះ កាលកើតក្នុងលោក មិនមែនកើតក្នុងទេវលោក និងក្នុងព្រហ្មលោកឡើយ រមែងកើតតែ

ក្នុងមនុស្សលោកប៉ុណ្ណោះ ។ សូម្បីក្នុងមនុស្សលោកសោត ក៏មិនកើតក្នុងចក្កវាឡដទៃ កើតតែចក្កវាឡនេះប៉ុណ្ណោះ សូម្បីក្នុងចក្កវាឡនេះ ក៏មិនកើតក្នុងទីគ្រប់កន្លែង ។

ក្នុងទិសខាងកើត មាននិគមឈ្មោះកជង្គលៈ ខាងនាយកជង្គលនិគមនោះ ខាងនាយមាននិគមឈ្មោះមហាសាលនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសអាគ្នេយ៍ មានស្ទឹងឈ្មោះសល្លវតី ខាងនាយស្ទឹងសល្លវតីនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងត្បូង មាននិគមឈ្មោះសេតកណ្ណិកៈ ខាងនាយសេតកណ្ណិកនិគមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងលិចមានស្រុកព្រាហ្មណ៍ ឈ្មោះថូនគ្រាម ខាងនាយស្រុកថូនគ្រាមនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមកជាមជ្ឈិមជនបទ ។ ក្នុងទិសខាងជើង មានភ្នំឈ្មោះឧសីរធជៈ ខាងនាយភ្នំនោះ ហៅថា បច្ចន្តិមជនបទ ខាងអាយចូលមក ជាមជ្ឈិមជនបទ ។ ព្រះតថាគតរមែងកើតក្នុងមជ្ឈិមប្រទេស ដែលលោកកំណត់ដូចពោលមកហើយនោះ ឯបណ្តោយវាស់បាន ៣០០ យោជន៍ ឯទទឹងវាស់បាន ១៥០ យោជន៍ វាស់ដោយជុំវិញបាន ៩០០ យោជន៍ ។ មួយវិញទៀត ព្រះតថាគតមិនកើតឡើងតាមទំនើងចិត្តតែម្យ៉ាងឡើយ ព្រះបច្ចេកពុទ្ធទាំងឡាយ ព្រះអគ្គសាវកព្រះអសីតិមហាថេរៈ អ្នកមានបុណ្យដទៃៗ ក៏រមែងកើតឡើង ។ ព្រះពុទ្ធ-មាតា ព្រះពុទ្ធបិតា ស្តេចចក្រពត្តិ និងព្រាហ្មណគហបតី ដែលជាបុគ្គល

សំខាន់ៗ ដទៃ ក៏រមែងកើតក្នុងមជ្ឈិមប្រទេសនេះដូចគ្នា ។

បទថា **ឧប្បជ្ជមានោ ឧប្បជ្ជតិ** ទាំង ២ នេះ ជាពាក្យពោលជំទាស់ប៉ុណ្ណោះ ។ ក្នុងពាក្យនេះគប្បីជ្រាបអត្ថយ៉ាងនេះថា ព្រះតថាគត កាលកើតឡើង រមែងកើតដើម្បីប្រយោជន៍ដល់ជនច្រើន មិនកើតឡើងដោយហេតុដទៃឡើយ ។ ក្នុងអធិការនេះ លក្ខណៈបែបនេះ បុគ្គលណាម្នាក់ មិនអាចជំទាស់ពាក្យទាំង ២ នោះ ដោយលក្ខណសព្ទដទៃឡើយ ។

ម្យ៉ាងទៀត គប្បីជ្រាបសេចក្ដីផ្សេងគ្នាក្នុងពាក្យនេះដូច្នេះថា **ឧប្បជ្ជមានោ នាម** ប្រែថា ឈ្មោះថា កាលនឹងកើតឡើង **ឧប្បជ្ជតិ នាម** ប្រែថា ឈ្មោះថា កំពុងកើតឡើង **ឧប្បន្នោ នាម** ឈ្មោះថា កើតឡើងហើយ ពិតហើយ ព្រះពុទ្ធអង្គបានទទួលពាក្យព្យាករ ទៀបបាទមូលនៃព្រះពុទ្ធព្រះនាមទីបង្ករ កាលស្វែងរកពុទ្ធការកធម៌ ទ្រង់ឃើញបារមី ១០ ទើបទ្រង់ដាក់ព្រះហឫទ័យថា អាត្មាអញគួរបំពេញធម៌ទាំងនេះ សូម្បីកំពុងបំពេញទានបារមីក៏ឈ្មោះថា កាលនឹងកើតឡើង ។ កាលទ្រង់បំពេញបារមីទាំង ១០ នេះ គឺសីលបារមី ។បេ។ ឧបេក្ខាបារមីក្ដី ទ្រង់បំពេញឧបបារមី ១០ ក្ដី ក៏ឈ្មោះថា កាលនឹងកើតឡើង ។ សូម្បីកាលទ្រង់បំពេញបរមត្ថបារមី ១០ ក៏ឈ្មោះថា កាលនឹងកើតឡើង កាលបរិច្ចាគនូវមហាបរិច្ចាគ ៥ ប្រការ ក៏ឈ្មោះថា កាលនឹងកើតឡើង ។ កាលទ្រង់បំពេញញាតត្ថចរិយា លោកត្ថចរិយា និងពុទ្ធត្ថចរិយា ក៏ឈ្មោះថា កាលនឹងកើតឡើង កាលទ្រង់បំពេញពុទ្ធការកធម៌ឲ្យដល់ទីបំផុត អស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប ក៏ឈ្មោះថា កាល

នឹងកើតឡើង ។ កាលទ្រង់លះអត្តភាពជាព្រះវេស្សន្តរ បដិសន្ធិក្នុងតុសិតបុរី តាំងនៅអស់ ៥៧ កោដិ និង ៦ លានឆ្នាំ ក៏ឈ្មោះថា កាលនឹងកើតឡើង ។ ព្រះពោធិសត្វ កាលទេវតាអារាធនាហើយ ទ្រង់ប្រមើលមើលមហាវិលោកនៈ ៥ ប្រការ ទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះទេវីព្រះនាមមហាមាយាក្តី ទ្រង់នៅក្នុងព្រះគភ៌ ១០ ខែក្តី ក៏ឈ្មោះថា កាលនឹងកើតឡើងដូចគ្នា ។ សូម្បីទ្រង់តាំងនៅក្នុងការគ្រប់គ្រងផ្ទះ ២៩ ឆ្នាំ ក៏ឈ្មោះថា កាលនឹងកើតឡើងដូចគ្នា ។ កាលទ្រង់ឃើញទោសក្នុងកាមទាំងឡាយ ឃើញអានិសង្សក្នុងការចេញចាកកាម មាននាយឆន្នជាសម្លាញ់ ទ្រង់ឡើងផែលសេះកណ្ឋកៈដ៏ប្រសើរ ចេញបួសក្នុងថ្ងៃរាហុលកុមារប្រសូត ក៏ឈ្មោះថា កាលនឹងកើតឡើងដូចគ្នា ។ ទ្រង់ឆ្លងរាជាណាចក្រទាំង ៣ ទៅសាងព្រះផ្នួសត្រង់អនោមានទីក្តី ក៏ឈ្មោះថា កាលនឹងកើតឡើងដូចគ្នា ។ សូម្បីទ្រង់ធ្វើបធាន ព្យាយាម ៦ វស្សា ក៏ឈ្មោះថា កាលនឹងកើតឡើងដូចគ្នា ។ កាលព្រះញាណចាស់ក្លាហើយ សោយព្រះក្រយាហារគ្រោតគ្រាតក្តី ក៏ឈ្មោះថា កាលនឹងកើតឡើងដូចគ្នា ។ កាលឡើងកាន់មហាពោធិមណ្ឌលដ្ឋាន ក្នុងវិសាខបុណ្ណមី ក្នុងវេលាល្ងាច ទ្រង់កម្ចាត់មារ និងរេហ៍ពល ទ្រង់រឭកដល់បុព្វេនិវាសញ្ញាណក្នុងបឋមយាម ទ្រង់ជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាម ទ្រង់ពិចារណាអង្គបដិច្ចសមុប្បាទអង្គ ១២ ដោយអនុលោម និងបដិលោម ក្នុងវេលាជាប់តគ្នាជាមួយបច្ឆិមយាមហើយ ចាក់ធ្លុះនូវសោតាបត្តិមគ្គក្តី ឈ្មោះថា កាលនឹងកើតឡើងដូចគ្នា ។ ក្នុងខណៈនៃសោតាបត្តិផលក្តី ក្នុងខណៈនៃសកទាគាមិមគ្គក្តី

ក្នុងខណៈនៃសកទាគាមិផលក្តី ក្នុងខណៈនៃអនាគាមិមគ្គក្តី ក្នុងខណៈនៃអនាគាមិផលក្តី ឈ្មោះថា កាលកើតឡើងដូចគ្នា ។ ឯក្នុងខណៈនៃអរហត្តមគ្គ ឈ្មោះថា កំពុងកើតឡើង ។ ក្នុងខណៈនៃអរហត្តផល ឈ្មោះថា កើតឡើងហើយ ។ ពិតហើយ ឥន្ទ្រិយញ្ញាណជាដើមរបស់ព្រះពុទ្ធទាំងឡាយ រមែងមិនកើតឡើងតាមលំដាប់ ដូចរបស់ព្រះសាវកទាំងឡាយឡើយ ឯគំនរនៃគុណ មានសព្វញ្ញុតញ្ញាណទាំងអស់ជាដើម ឈ្មោះថា រមែងមកព្រមគ្នាជាមួយអរហត្តមគ្គ ។ ព្រោះដូច្នោះ លោកទាំងនោះ ឈ្មោះថា កើតហើយក្នុងខណៈនៃអរហត្តផល ព្រោះមានកិច្ចទាំងពួងដែលសម្រេចហើយ ។ ក្នុងសូត្រនេះ គប្បីជ្រាបថា កំពុងកើត សំដៅយកខណៈនៃអរហត្តផលនោះឯង ។ សេចក្តីពិតក្នុងបទថា **ឧប្បជ្ជតិ** នេះ មានអត្ថដូច្នេះថា **ឧប្បន្នោ ហោតិ** រមែងជាអ្នកកើតឡើង ។

បទថា **ពហុជនហិតាយ** សេចក្តីថា ទ្រង់កើតឡើងដើម្បីប្រយោជន៍ដល់ជនច្រើន ។ បទថា **ពហុនោ ជនស្ស សុខាយ** សេចក្តីថា រមែងសម្រេចការកើតឡើងដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ពួកជនច្រើន ។ បទថា **លោកានុកម្បាយ** សេចក្តីថា ទ្រង់កើតឡើងព្រោះអាស្រ័យសេចក្តីករុណាដល់សត្វលោក ។ សួរថា ដល់សត្វលោកពួកណា ឆ្លើយថា ដើម្បីប្រយោជន៍ដល់សត្វលោក ដែលស្តាប់ព្រះធម្មទេសនារបស់ព្រះតថាគតបានផឹកនូវអមតៈ ហើយត្រាស់ដឹងធម៌ ។ កាលព្រះមានព្រះភាគនៅជាសុខអស់ ៧ សប្តាហ៍ ក្នុងពោធិមណ្ឌលដ្ឋាន ហើយយាងចេញអំពីពោធិមណ្ឌលដ្ឋាន

មកកាន់ព្រៃឥសិបតនមិគទាយវ័ន ហើយទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រថា ម្នាលភិក្ខុទាំងឡាយ អន្តធម៌ ២ យ៉ាងនេះ បព្វជិតមិនគួរសេពជាដើម ព្រហ្មរាប់បាន ១៨ កោដិ មួយអន្លើដោយព្រះអញ្ញាកោណ្ឌញ្ញត្ថេរ បានផឹកនូវអមតៈហើយ ។ ព្រះអង្គទ្រង់កើតឡើងដើម្បីសេចក្តីអនុគ្រោះដល់សត្វលោកនេះ ។ ក្នុងថ្ងៃទី ៥ ក្នុងវេលាចប់អនត្តលក្ខណសូត្រ បញ្ចវគ្គិយត្ថេរ តាំងនៅក្នុងអរហត្តហើយ ។ ព្រះអង្គទ្រង់កើតឡើង ដើម្បីសេចក្តីអនុគ្រោះដល់សត្វលោកយ៉ាងនេះ ។ គ្រានោះ ទ្រង់ឲ្យបុរស ៥៥ នាក់ មានយសកុលបុត្រជាប្រធាន តាំងនៅក្នុងអរហត្ត ។ បន្ទាប់អំពីនោះ ទ្រង់ឲ្យភទ្ទវគ្គិយ-កុមារ ៣០ នាក់ ក្នុងព្រៃកប្បាស បានសម្រេចមគ្គ ៣ និងផល ៣ ។ ទ្រង់កើតឡើងដើម្បីអនុគ្រោះដល់សត្វលោក ដូច្នេះ ។ ក្នុងវេលាចប់អាទិត្ត-បរិយាយសូត្រ ទ្រង់ឲ្យជដិល ១០០០ នាក់ តាំងនៅក្នុងអរហត្ត នាគ-យាសីសប្រទេស ។ម្យ៉ាងទៀត ព្រាហ្មណ៍ និងគហបតី ១១ ម៉ឺននាក់ មានព្រះបាទពិម្ពិសារជាប្រធាន ក្នុងព្រៃត្នោតជំទង់ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយ តាំងនៅក្នុងសោតាបត្តិផល ១ ម៉ឺននាក់តាំងនៅក្នុងសរណៈ ក្នុងវេលាចប់អនុមោទនា ដោយតិរោកុឌ្ឌសូត្រ សត្វប្រមាណ ៨៤០០០ នាក់ បានផឹកនូវអមតៈហើយ ។ ក្នុងសមាគមនៃនាយសុមន-មាលាការ សត្វប្រមាណ ៨៤០០០ បានផឹកអមតៈហើយ ។ ក្នុងសមាគមនៃធនបាល សត្វប្រមាណ ១ ម៉ឺននាក់ បានផឹកអមតៈហើយ ។ ក្នុងសមាគមនៃខទិរង្គារជាតក សត្វប្រមាណ ៨៤០០០ នាក់ ផឹកអមតៈហើយ

ក្នុងសមាគមនៃជម្ពុកាជីវក សត្វប្រមាណ ៨៤០០០ នាក់ ផឹកអមត: ។ ក្នុងសមាគមនៃអានន្ទសេដ្ឋី សត្វ ៨៤០០០ នាក់ បានផឹកនូវអមត: ។ ក្នុងថ្ងៃសម្តែងបារាយនសូត្រ ក្នុងបាសាណកចេតិយ សត្វ ១៤ កោដិ ផឹកអមត: ហើយ ក្នុងថ្ងៃសម្តែងយមកប្បាដិហារ្យ សត្វ ២០ កោដិ បានផឹកនូវអមត: ។ កាលព្រះសាស្តាប្រថាប់គង់លើបណ្ឌុកម្ពលសិលាអាសនៈ ក្នុងតាវត្តិង្ស ទ្រង់ធ្វើព្រះមាតាឲ្យជាកាយសក្ខី សម្តែងព្រះអភិធម្ម ៧ គម្ពីរ សត្វ ៨០ កោដិ បានផឹកអមត: ។ ក្នុងថ្ងៃទ្រង់យាងចុះអំពីទេវលោក សត្វ ៣០ កោដិ បានផឹកនូវអមត: ។ ក្នុងសក្កប្បញ្ហាសូត្រ ទេវតាប្រមាណ ៨ ម៉ឺន បានផឹកអមត:ហើយ ក្នុងឋាន:ទាំង ៤ នេះ គឺក្នុងមហាសមយសូត្រ ក្នុងមង្គលសូត្រ ក្នុងចូឡរាហុលោវាទសូត្រ ក្នុងសមចិត្តបដិបទាសូត្រ សត្វដែលបានត្រាស់ដឹងធម៌ មិនអាចកំណត់បានឡើយ ។ ព្រះមានព្រះភាគកើតឡើង ដើម្បីអនុគ្រោះដល់សត្វលោកយ៉ាងនេះឯង ។ ក្នុងកាលខាងមុខអំពីថ្ងៃនេះទៅក្នុងអនាគតកាលគប្បីជ្រាបសេចក្តីក្នុងអធិការនេះ ដូចពោលមកនេះ ដោយអំណាចនៃពួកសត្វដែលអាស្រ័យព្រះសាសនា ហើយតាំងនៅក្នុងផ្លូវនៃស្ថានសួគ៌ និងព្រះនិព្វាន ។

បទថា **ទេវមនុស្សានំ** សេចក្តីថា ព្រះមានព្រះភាគកើតឡើង ដើម្បីប្រយោជន៍ ដើម្បីចម្រើន និងដើម្បីសេចក្តីសុខដល់ទេវតា និងមនុស្សតែម្យ៉ាងប៉ុណ្ណោះក៏មិនមែន តែទ្រង់កើតឡើងដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់សត្វដ៏សេស មាននាគ និងគ្រុឌជាដើមផងដែរ ។ ដើម្បី

សម្តែងបុគ្គលដែលបដិសន្ធិជាសហេតុកៈ ដែលសមគួរធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផល ទើបពោលយ៉ាងនោះ ។ ព្រោះហេតុនោះ គប្បីជ្រាបថា ទ្រង់កើតឡើងដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់សត្វទាំងនោះ ។

## បុច្ឆាមាន ៥ យ៉ាង

បទថា **កតមោ ឯកបុគ្គលោ** មានបុច្ឆាដូច្នេះ ឈ្មោះថា បុច្ឆាមាន ៥ យ៉ាង គឺអទិដ្ឋជោតនាបុច្ឆា ១ ទិដ្ឋសំសន្ទនាបុច្ឆា ១ វិមតិច្ឆេទនាបុច្ឆា ១ អនុមតិបុច្ឆា ១ កថេតុកម្យតាបុច្ឆា ១ ។ បណ្តាបុច្ឆា ៥ យ៉ាងនោះ មានសេចក្តីផ្សេងគ្នាដូចតទៅនេះ

អទិដ្ឋជោតនាបុច្ឆាដូចម្តេច លក្ខណៈតាមប្រក្រតី ជារបស់មិនដឹង មិនទាន់ឃើញ មិនទាន់ថ្លឹងថ្លែងបាន មិនទាន់បានពិចារណា មិនទាន់ប្រាកដច្បាស់ មិនទាន់ជាក់ច្បាស់ បុគ្គលរមែងសួរបញ្ហាដើម្បីដឹង ដើម្បីឃើញ ដើម្បីថ្លឹងថ្លែង ដើម្បីពិចារណា ដើម្បីឲ្យប្រាកដច្បាស់ ដើម្បីភាពជាក់ច្បាស់នៃលក្ខណៈនោះ នេះឈ្មោះថា **អទិដ្ឋជោតនាបុច្ឆា** គឺសួរដើម្បីឲ្យជាក់ច្បាស់ក្នុងវត្ថុដែលខ្លួនមិនឃើញ ។

ទិដ្ឋសំសន្ទនាបុច្ឆាដូចម្តេច លក្ខណៈតាមប្រក្រតី ដែលបុគ្គលដឹងហើយ ឃើញ ថ្លឹងថ្លែង ពិចារណា ប្រាកដច្បាស់ និងជាក់ច្បាស់ហើយ បុគ្គលតែងសួរបញ្ហា ដើម្បីផ្ទៀងផ្ទាត់នឹងបណ្ឌិតដទៃ នេះឈ្មោះថា **ទិដ្ឋ-សំសន្ទនាបុច្ឆា** គឺសួរដើម្បីប្រៀបធៀបវត្ថុដែលខ្លួនឃើញហើយ ។

វិមតិច្ឆេទនាបុច្ឆាដូចម្ដេច តាមប្រក្រតី បុគ្គលរមែងស្ទុះទៅកាន់សេចក្ដីសង្ស័យ កើតសេចក្ដីអល់អែកឡើងថា យ៉ាងនេះឬហ្ន៎ មិនមែនយ៉ាងនេះឬហ្ន៎ ជាអ្វីហ្ន៎ ដូចម្ដេចហ្ន៎ ទើបសួរបញ្ហា ដើម្បីកាត់សេចក្ដីសង្ស័យ នេះឈ្មោះថា **វិមតិច្ឆេទនាបុច្ឆា** គឺសួរដើម្បីកាត់សេចក្ដីងឿងឆ្ងល់ ។

អនុមតិបុច្ឆាដូចម្ដេច ពិតហើយ ព្រះមានព្រះភាគត្រាស់ប្រស្នាតាមការឃើញប្រពៃនៃភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកសម្គាល់សេចក្ដីនោះដូចម្ដេច រូប ទៀង ឬមិនទៀង ។ មិនទៀងទេ ព្រះអង្គ ។ រូបណាមិនទៀង រូបនុ៎ះ ជាទុក្ខ ឬជាសុខ ។ ជាទុក្ខ ព្រះអង្គ ។ រូបណាមិនទៀង ជាទុក្ខ មានសេចក្ដីប្រែប្រួលទៅជាធម្មតា គួរឬ ដែលឃើញរូបថា នុ៎ះជារបស់អញ នុ៎ះជាអញ នុ៎ះជាខ្លួនរបស់អញ ។ សេចក្ដីនោះ មិនគួរឃើញយ៉ាងនុ៎ះទេ ព្រះអង្គ នេះឈ្មោះថា **អនុមតិបុច្ឆា** គឺសួរដើម្បីសម្រេច ។

កថេតុកម្យតាបុច្ឆាដូចម្ដេច ព្រះមានព្រះភាគត្រាស់សួរបញ្ហាដោយព្រះអង្គឯង មានបំណងនឹងឆ្លើយឯង ដល់ភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋានទាំងឡាយ ៤ នេះ សតិប្បដ្ឋាន ៤ ដូចម្ដេច នេះឈ្មោះថា **កថេតុកម្យតាបុច្ឆា** គឺសួរដោយប្រាថ្នានឹងឆ្លើយឯង ។

ក្នុងបុច្ឆាទាំង ៥ នោះ បុច្ឆា ៣ ខាងដើម មិនមានដល់ព្រះពុទ្ធទាំង-ឡាយ ព្រោះហេតុអ្វី ព្រោះថា វត្ថុណាមួយក្នុងកាលដ៏យូរលង់ទាំង ៣ កាល ដែលបច្ច័យតាក់តែង ឬផុតចាកកាលដែលបច្ច័យតាក់តែងមិនបាន ឈ្មោះថា ទ្រង់មិនឃើញ ទ្រង់មិនជ្រាប ទ្រង់ថ្លឹងថ្លែងមិនបាន ទ្រង់មិនពិចារណា មិន

ប្រាកដច្បាស់ មិនជាក់ច្បាស់ រមែងមិនមានដល់ព្រះពុទ្ធទាំងឡាយ ព្រោះដូច្នោះ ទើបអទិដ្ឋជោតនាបុច្ឆា មិនមានដល់ព្រះពុទ្ធទាំងនោះ ។ វត្ថុណាដែលព្រះមានព្រះភាគទ្រង់ដឹងហើយ ដោយព្រះញាណរបស់ព្រះអង្គ កិច្ច គឺការប្រៀបធៀបវត្ថុនោះជាមួយអ្នកដទៃ ទោះជាសមណៈ ព្រាហ្មណ៍ ទេវតា មារ ឬព្រហ្ម រមែងមិនមាន ដោយហេតុនោះ ទិដ្ឋសំសន្ទនាបុច្ឆា រមែងមិនមានដល់ព្រះមានព្រះភាគ ។ ព្រោះទ្រង់មិនមានសេចក្តីសង្ស័យឲ្យជាហេតុពោលបានជាអ្នកឆ្លងផុតសេចក្តីងឿងឆ្ងល់ កម្ចាត់សេចក្តីសង្ស័យ ក្នុងធម៌ទាំងពួងបានហើយ ដោយហេតុនោះ ទើបវិមតិច្ឆេទនាបុច្ឆា មិនមានដល់ព្រះអង្គ ។ ឯបុច្ឆា ២ ក្រៅអំពីនេះ រមែងមានដល់ព្រះមានព្រះភាគ ។ ក្នុងបុច្ឆាទាំងនោះបុច្ឆានេះ គប្បីជ្រាបថា ជាកថេតុកម្យតាបុច្ឆា ។

ឥឡូវនេះ ព្រះមានព្រះភាគ កាលទ្រង់ចម្លើយបុគ្គលឯក ដែលគេសួរដោយសំណួរនោះឲ្យជាក់ច្បាស់ ទើបត្រាស់ថា ព្រះតថាគតអរហន្តសម្មាសម្ពុទ្ធ ដូច្នេះ ។

## តថាគត ៨ យ៉ាង

បណ្តាបទទាំងនោះ បទថា **តថាគតោ** សេចក្តីថា ព្រះមានព្រះភាគទ្រង់ព្រះនាមថា **តថាគត** ព្រោះហេតុ ៨ ប្រការ គឺទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់យាងមកយ៉ាងនោះ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់យាងទៅយ៉ាងនោះ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់យាងមកកាន់លក្ខណៈដែលពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិតតាមការ

ពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះមានព្រះវាចាពិត ។ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ធ្វើឯង និងឲ្យអ្នកដទៃធ្វើ ។ ទ្រង់ព្រះនាមថា តថាគត ព្រោះអត្ថថា ទ្រង់គ្របសង្កត់បាន គឺជាធំ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកយ៉ាងនោះ តើដូចម្តេច ។

ព្រះសម្មាសម្ពុទ្ធអង្គមុនៗ ទ្រង់ខ្នះខ្នែងដើម្បីប្រយោជន៍ដល់លោកទាំងពួង យាងមកហើយ ដូចព្រះមានព្រះភាគវិបស្សីយាងមក ដូចព្រះមានព្រះភាគសិខីយាងមក ដូចព្រះមានព្រះភាគវេស្សភូយាងមក ដូចព្រះមានព្រះភាគកកុសន្ធៈយាងមក ដូចព្រះមានព្រះភាគកោនាគមនៈយាងមក ដូចព្រះមានព្រះភាគកស្សបយាងមក សេចក្តីនេះ អធិប្បាយដូចម្តេច អធិប្បាយថា ព្រះមានព្រះភាគទាំងនោះ យាងមកដោយអភិនីហារណា ព្រះមានព្រះភាគនៃយើង ក៏យាងមកដោយអភិនីហារនោះដូចគ្នា ។

ម្យ៉ាងទៀត ព្រះមានព្រះភាគវិបស្សី ។បេ។ ព្រះមានព្រះភាគកស្សប ទ្រង់បំពេញទានបារមី ទ្រង់បំពេញសីលបារមី នេក្ខម្មបារមី បញ្ញាបារមី វីរយ-បារមី ខន្តិបារមី សច្ចបារមី អធិដ្ឋានបារមី មេត្តាបារមី និងឧបេក្ខាបារមី ទ្រង់បំពេញបារមីទាំង ៣០ នេះ គឺបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ មហាបរិច្ចាគ ៥ គឺបរិច្ចាគអវយវៈ បរិច្ចាគទ្រព្យ បរិច្ចាគកូន បរិច្ចាគភរិយា បរិច្ចាគជីវិត ទ្រង់បំពេញបុព្វប្បយោគ បុព្វចរិយា ការសម្តែងធម៌ និង

ញាតត្ថចរិយាជាដើម ទ្រង់ដល់នូវទីបំផុតនៃពុទ្ធចរិយា យាងមកហើយ យ៉ាងណា ព្រះមានព្រះភាគនៃយើង ក៏យាងមកយ៉ាងនោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគវិបស្សី ។បេ។ ព្រះមានព្រះភាគកស្សប ទ្រង់ចម្រើនសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពល ៥ ពោជ្ឈង្គ ៧ អរិយមគ្គមានអង្គ ៨ យាងមកហើយយ៉ាងណា ព្រះមានព្រះភាគនៃយើង ក៏យាងមកយ៉ាងនោះ ព្រះសាស្តា ទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកយ៉ាងនោះ យ៉ាងនេះឯង ។

ព្រះមុនីទាំងឡាយ មានព្រះវិបស្សីជាដើម យាងមកកាន់ភាពជា
សព្វញ្ញូ ក្នុងលោកនេះ យ៉ាងណា ព្រះសក្យមុនីអង្គនេះ ក៏
យាងមកយ៉ាងនោះ ដោយហេតុនោះ ទើបព្រះមានចក្ខុ ទ្រង់ព្រះ
នាមថា តថាគត ដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកយ៉ាងនោះ ដូច្នេះឯង ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់ទៅយ៉ាងនោះ តើដូចម្តេច ។

ព្រះមានព្រះភាគវិបស្សី ប្រសូតភ្លាម ទ្រង់យាងទៅ ។បេ។ ព្រះមានព្រះភាគកស្សប ប្រសូត្រភ្លាមក៏យាងទៅ ព្រះមានព្រះភាគអង្គនោះ យាងទៅដូចម្តេច ពិតហើយ ព្រះមានព្រះភាគអង្គនោះ ប្រសូតភ្លាមនោះឯង ប្រថាប់ឈរលើប្រឹថពី ដោយយុគលបាទដ៏ស្មើ បែរព្រះភក្ត្រទៅទិសឧត្តរ យាងទៅ

ដោយព្រះបាទ ៧ ជំហាន ដូចព្រះបាលីត្រាស់ថា ម្នាលអានន្ទ ព្រះពោធិ-សត្វប្រសូតភ្លាមនោះឯង ក៏ប្រថាប់ឈរដោយព្រះយុគលបាទដ៏ស្មើ បែរព្រះភក្ត្រទៅទិសឧត្តរ យាងទៅដោយព្រះបាទ ៧ ជំហាន កាលមហាព្រហ្មបាំងស្វេតច្ឆត្រ ទ្រង់សម្លឹងមើលគ្រប់ទិស ទ្រង់បន្លឺអាសភិវាចាថា យើងជាកំពូលនៃលោក យើងជាបុគ្គលប្រសើរបំផុតក្នុងលោក យើងជាច្បងក្នុងលោក ការកើតលើកនេះ ជាការកើតចុងក្រោយ ភពថ្មីមិនមានតទៅទៀតឡើយ ដូច្នេះ ។ ការយាងទៅរបស់ព្រះមានព្រះភាគអង្គនោះ ក៏បានជាអាការពិតមិនប្រែប្រួលដោយភាពជាបុព្វនិមិត្ត នៃការសម្រេចគុណវិសេសច្រើនប្រការ គឺព្រះអង្គប្រសូតភ្លាមនោះឯង ក៏បានប្រថាប់ឈរដោយព្រះយុគលបាទដ៏ស្មើ នេះជាបុព្វនិមិត្តនៃការបានឥទ្ធិបាទ ៤ របស់ទ្រង់ ។ ម្យ៉ាងទៀត ការដែលព្រះអង្គបែរព្រះភក្ត្រទៅទិសឧត្តរ ជាបុព្វនិមិត្តនៃភាពជាលោកុត្តរធម៌ទាំងពួង ។ ការឈានព្រះបាទ ៧ ជំហាន ជាបុព្វនិមិត្តនៃការបានរតនៈ គឺពោជ្ឈង្គ ៧ ប្រការ ការបាំងស្វេតច្ឆត្រជាបុព្វនិមិត្តនៃការបានស្វេតច្ឆត្រដ៏បរិសុទ្ធ ដ៏ប្រសើរ គឺអរហត្តផលវិមុត្តិធម៌ ។ ការទតមើលទិសទាំងពួង ជាបុព្វនិមិត្តនៃការបានព្រះអនាវរណញ្ញាណ គឺភាពជាព្រះសព្វញ្ញូ ។ ការបន្លឺអាសភិវាចា ជាបុព្វ-និមិត្តនៃការប្រកាសធម្មចក្រដ៏ប្រសើរ ដែលគ្មានបុគ្គលណាម្នាក់បង្វិលបាន ។ ព្រះមានព្រះភាគអង្គនេះ ទ្រង់យាងទៅយ៉ាងនោះ ការយាងទៅរបស់ព្រះមានព្រះភាគអង្គនោះ ក៏បានជាអាការដែលពិត មិនប្រែប្រួលដោយភាពជាបុព្វ-និមិត្តនៃការសម្រេចគុណវិសេសទាំងនោះ ។ ហេតុនោះ ទើបបុរាណាចារ្យ

ពោលថា

ព្រះគវម្បតីគោតមអង្គនោះ ទ្រង់ប្រសូត្រហើយភ្លាម ក៏ទ្រង់ជាន់ផែនដីដោយព្រះយុគលបាទដ៏ស្មើ ទ្រង់យាងព្រះបាទបាន ៧ ជំហាន មានពួកទេវតា បាំងស្វេតច្ឆត្រ ព្រះគោតមនោះ កាលយាងទៅបាន ៧ ជំហាន ក៏ទតមើលទិសដោយជុំវិញ ទ្រង់បន្លឺសូរសៀងប្រកបដោយអង្គ ៨ ប្រការ ក្រាងក្រអៅ ដូចរាជសីហ៍ ឈរលើកំពូលបព៌ត ដូច្នោះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងទៅយ៉ាងនោះ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគវិបស្សីយាងទៅហើយ ។បេ។ ព្រះមានព្រះភាគកស្សបយាងទៅហើយ យ៉ាងណា ព្រះមានព្រះភាគអង្គនេះ ក៏យាងទៅហើយដូចគ្នា ទ្រង់លះកាមច្ឆន្ទៈដោយនេក្ខម្មៈ យាងទៅហើយ ទ្រង់លះព្យាបាទ ដោយការមិនព្យាបាទ ទ្រង់លះថីនមិទ្ធៈ ដោយអាលោកសញ្ញា ទ្រង់លះឧទ្ធច្ចកុក្កុច្ចៈ ដោយការមិនរាយមាយ ទ្រង់លះវិចិកិច្ឆាដោយការកំណត់ធម៌ ទ្រង់យាងទៅហើយ ទ្រង់ទម្លាយអវិជ្ជាដោយព្រះបញ្ញាញាណ ទ្រង់បន្ទោបង់ការមិនត្រេកអរដោយបាមោជ្ជ ទ្រង់បើកទ្វារ គឺនីវរណៈដោយបឋមជ្ឈាន ទ្រង់ស្ងប់វិតក្កវិចារដោយទុតិយជ្ឈាន ទ្រង់នឿយណាយនូវបីតិដោយតតិយជ្ឈាន ទ្រង់លះសុខទុក្ខដោយចតុត្ថជ្ឈាន ទ្រង់ឈានកន្លងបង់នូវរូបសញ្ញា បដិឃសញ្ញា និងនានត្តសញ្ញាដោយអាកាសានញ្ចាយតនសមាបត្តិ

ទ្រង់ឈានកន្លងអាកាសានញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ ទ្រង់ឈានកន្លងវិញ្ញាណញ្ញាយតនសញ្ញា ដោយអាកិញ្ចញ្ញាយតនសមាបត្តិ ទ្រង់ឈានកន្លងអាកិញ្ចញ្ញាយតនសញ្ញា ដោយនេវសញ្ញានាសញ្ញាយតន-សមាបត្តិ យាងទៅហើយ ។

ទ្រង់លះនិច្ចសញ្ញា ដោយអនិច្ចានុបស្សនា ទ្រង់លះសុខសញ្ញា ដោយទុក្ខានុបស្សនា ទ្រង់លះអត្តសញ្ញា ដោយអនត្តានុបស្សនា ទ្រង់លះនន្ទិ ដោយនិព្វិទានុបស្សនា ទ្រង់លះរាគៈ ដោយវិរាគានុបស្សនា ទ្រង់លះសមុទយៈ ដោយនិរោធានុបស្សនា ទ្រង់លះការប្រមាន់មាំ ដោយឧបសមា-នុបស្សនា ទ្រង់លះឃនសញ្ញា គឺការសម្គាល់ថាជាដុំ ដោយខយានុបស្សនា ទ្រង់លះអាយូហនា គឺការប្រមូលមក ដោយវយានុបស្សនា ទ្រង់លះធុវ-សញ្ញា គឺការសម្គាល់ថា ស្ថិតស្ថេរ ដោយវិបរិណាមានុបស្សនា ទ្រង់លះនិមិត្តសញ្ញា ដោយអនិមិត្តានុបស្សនា ទ្រង់លះការតាំងមាំនៃកិលេស ដោយអប្បណិហិតានុបស្សនា ទ្រង់លះអភិនិវេស គឺការប្រកាន់ស្អិត ដោយសុញ្ញតានុបស្សនា ទ្រង់លះសារាទានាភិនិវេស គឺការប្រកាន់ថាជាសារៈ ដោយអធិប្បញ្ញាធម្មវិបស្សនា គឺការឃើញច្បាស់នូវធម៌ដោយបញ្ញាដ៏ក្រៃលែង ទ្រង់លះសម្មោហាភិនិវេស គឺការប្រកាន់មាំដោយការវង្វេង ដោយយថាភូ-តញ្ញាណទស្សនៈ ទ្រង់លះអាលយាភិនិវេស គឺការប្រកាន់មាំក្នុងអាល័យ ដោយអាទីនវានុបស្សនា លះអប្បដិសង្ខា គឺ ការមិនពិចារណាដោយបដិ-សង្ខានុបស្សនា លះសំយោគាភិនិវេស គឺ ការប្រកាន់មាំក្នុងការប្រកប

កិលេស ដោយវិវដ្ដានុបស្សនា ទ្រង់លះកិលេសដែលតាំងនៅក្នុងស្ថានជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ ទ្រង់លះកិលេសគ្រោតគ្រាត ដោយសកទាគាមិមគ្គ ទ្រង់ដកកិលេសយ៉ាងល្អិត ដោយអនាគាមិមគ្គ ទ្រង់កាត់កិលេសទាំងពួងបានជាសមុច្ឆេទ ដោយអរហត្តមគ្គ យាងទៅហើយ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងទៅយ៉ាងនោះ ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះទ្រង់មកដល់លក្ខណៈដែលពិតដូចម្ដេច ។ បឋវីធាតុមានលក្ខណៈរឹងជាលក្ខណៈពិត មិនប្រែប្រួល អាបោធាតុមានលក្ខណៈហូរជ្រួតជ្រាប តេជោធាតុមានលក្ខណៈក្ដៅ វាយោធាតុមានលក្ខណៈកម្រើកទៅមក អាកាសធាតុមានលក្ខណៈប៉ះពាល់មិនបាន វិញ្ញាណមានលក្ខណៈដឹងច្បាស់ រូបមានលក្ខណៈបែកធ្លាយ វេទនាមានលក្ខណៈសោយអារម្មណ៍ សញ្ញាមានលក្ខណៈចាំអារម្មណ៍ សង្ខារមានលក្ខណៈតាក់តែងអារម្មណ៍ វិញ្ញាណមានលក្ខណៈដឹងអារម្មណ៍ វិតក្កមានលក្ខណៈលើកចិត្តឡើងកាន់អារម្មណ៍ វិចារមានលក្ខណៈតាមពិចារណាអារម្មណ៍ បីតិមានលក្ខណៈផ្សាយទៅ សុខមានលក្ខណៈមិនលំបាក ឯកគ្គតាចិត្តមានលក្ខណៈមិនរាយមាយ ផស្សៈមានលក្ខណៈពាល់ត្រូវអារម្មណ៍ សទ្ធិន្ទ្រិយមានលក្ខណៈបង្អោនចិត្តជឿ វីរិយិន្ទ្រិយមានលក្ខណៈផ្គងសតិន្ទ្រិយមានលក្ខណៈរឭកបាន សមាធិន្ទ្រិយមានលក្ខណៈមិនរាយមាយ បញ្ញិន្ទ្រិយមានលក្ខណៈដឹងច្បាស់ សទ្ធាពលមានលក្ខណៈមិនញាប់ញ័រក្នុង

ការជឿ វីរិយពលមានលក្ខណៈមិនញាប់ញ័រក្នុងការខ្ជិលច្រអូស សតិពលមានលក្ខណៈមិនញាប់ញ័រក្នុងភាពជាអ្នកភ្លេចស្មារតី សមាធិពលមានលក្ខណៈមិនញាប់ញ័រក្នុងការមិនរាយមាយ បញ្ញាពលមានលក្ខណៈមិនញាប់ញ័រក្នុងអវិជ្ជា សតិសម្ពោជ្ឈង្គមានលក្ខណៈរឭកបាន ធម្មវិចយសម្ពោជ្ឈង្គមានលក្ខណៈជ្រើសរើស វីរិយសម្ពោជ្ឈង្គមានលក្ខណៈផ្គង បីតិសម្ពោជ្ឈង្គមានលក្ខណៈផ្សាយទៅ បស្សទ្ធិសម្ពោជ្ឈង្គមានលក្ខណៈចូលទៅស្ងប់ សមាធិសម្ពោជ្ឈង្គមានលក្ខណៈមិនរាយមាយ ឧបេក្ខាសម្ពោជ្ឈង្គមានលក្ខណៈពិចារណា សម្មាទិដ្ឋិមានលក្ខណៈឃើញប្រពៃ សម្មាសង្កប្បៈមានលក្ខណៈលើកចិត្តឡើងកាន់អារម្មណ៍ សម្មាវាចាមានលក្ខណៈកំណត់កាន់យក សម្មាកម្មន្តៈមានលក្ខណៈក្រោកឡើងព្រម សម្មាអាជីវៈមានលក្ខណៈបរិសុទ្ធ សម្មាវាយាមៈមានលក្ខណៈផ្គង សម្មាសតិមានលក្ខណៈទំនុកបម្រុង សម្មាសមាធិមានលក្ខណៈមិនរាយមាយ អវិជ្ជាមានមានលក្ខណៈមិនដឹង សង្ខារមានលក្ខណៈនឹកគិត វិញ្ញាណមានលក្ខណៈដឹងអារម្មណ៍ នាមមានលក្ខណៈបង្អោនទៅ រូបមានលក្ខណៈបែកធ្លាយ សឡាយតនៈមានលក្ខណៈតភ្ជា ផស្សៈមានលក្ខណៈពាល់ត្រូវអារម្មណ៍ វេទនាមានលក្ខណៈសោយអារម្មណ៍ តណ្ហាមានលក្ខណៈជាហេតុ ឧបាទានមានលក្ខណៈប្រកាន់ ភពមានលក្ខណៈប្រមូលមក ជាតិមានលក្ខណៈកើតឡើង ជរាមានលក្ខណៈទ្រុឌទ្រោម មរណៈមានលក្ខណៈចុតិទៅ ធាតុមានលក្ខណៈទទេ អាយតនៈមានលក្ខណៈតភ្ជា សតិប្បដ្ឋានមានលក្ខណៈទំនុកបម្រុង សម្មប្បធានមានលក្ខណៈផ្តើមតាំងព្យាយាម

ឥទ្ធិបាទមានលក្ខណៈសម្រេច ឥន្ទ្រិយមានលក្ខណៈជាធំ ពលមានលក្ខណៈមិនញាប់ញ័រ ពោជ្ឈង្គមានលក្ខណៈនាំចេញចាកទុក្ខ មគ្គមានលក្ខណៈជាគួរហេតុ សច្ចៈមានលក្ខណៈជារបស់ពិត សមថៈមានលក្ខណៈមិនរាយមាយ វិបស្សនាមានលក្ខណៈតាមឃើញ សមថៈ និងវិបស្សនាមានលក្ខណៈនៃកិច្ចជាមួយគ្នា យុគនទ្ធធម៌មានលក្ខណៈមិនវិលត្រឡប់ សីលវិសុទ្ធិមានលក្ខណៈសង្រួម ចិត្តវិសុទ្ធិមានលក្ខណៈមិនរាយមាយ ទិដ្ឋិវិសុទ្ធិមានលក្ខណៈឃើញ ខយញ្ញាណមានលក្ខណៈកាត់ផ្ដាច់ អនុប្បាទញ្ញាណមានលក្ខណៈរម្ងាប់ ឆន្ទៈមានលក្ខណៈជាឫសគល់ មនសិការមានលក្ខណៈជាសមុដ្ឋានដែលកើតឡើង ផស្សៈមានលក្ខណៈជាទីប្រជុំគ្នា វេទនាមានលក្ខណៈប្រជុំចុះ សមាធិមានលក្ខណៈជាប្រធាន សតិមានលក្ខណៈជាអធិបតេយ្យ បញ្ញាមានលក្ខណៈក្រៃលែងជាងនោះ វិមុត្តិមានលក្ខណៈជាសារៈ និព្វានដែលឈមចុះកាន់អមតៈ មានលក្ខណៈជាទីអស់ទៅ ជារបស់ពិត មិនប្រែប្រួល ឈ្មោះថាតថាគត ព្រោះទ្រង់មកដល់លក្ខណៈដែលពិតដោយញាណគតិ គឺចាក់ធ្លុះមិនខុសភ្លាំងភ្លាត់ ដោយប្រការយ៉ាងនេះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះយាងមកដល់លក្ខណៈដែលពិត ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត តាមសេចក្ដីពិតដូចម្ដេច ឈ្មោះថា ធម៌ដែលពិត បានដល់ អរិយសច្ច ៤ ។ ដូចព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ ជារបស់

ពិត មិនខុស មិនប្រែប្រួលទៅជាដទៃ អរិយសច្ច ៤ ដូចម្តេចខ្លះ ។ ម្នាល ភិក្ខុទាំងឡាយ ទុក្ខនេះជារបស់ពិត នុ៎ះមិនខុស នុ៎ះមិនក្លាយទៅជាដទៃ ។ គប្បីជ្រាបសេចក្តីពិស្តារដូចតទៅ ព្រះមានព្រះភាគ ត្រាស់ដឹងក្រៃលែងឯង នូវអរិយសច្ច ៤ នោះ ព្រោះដូច្នោះ ទើបបានទទួលព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិត ឯ **គត** សព្ទក្នុងទីនេះ មានការត្រាស់ដឹងក្រៃលែងឯងជាអត្ថ ។

ម្យ៉ាងទៀត សភាវៈជរា និងមរណៈដែលកើត និងប្រជុំឡើង ព្រោះជាតិជាបច្ច័យ ជាការពិតមិនប្រែប្រួល មិនដទៃឡើយ ។បេ។ សភាវៈសង្ខារទាំងឡាយកើត និងប្រជុំឡើង ព្រោះអវិជ្ជាជាបច្ច័យ ជាការពិតមិនប្រែប្រួល មិនទៅជាដទៃឡើយ ។ សភាវៈអវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ ក៏ដូចគ្នា សភាវៈដែលសង្ខារជាបច្ច័យដល់វិញ្ញាណ ។បេ។ សភាវៈជាតិជាបច្ច័យដល់ជរា និងមរណៈ ជាការពិតមិនប្រែប្រួលទៅជាដទៃឡើយ ។ ព្រះមានព្រះភាគត្រាស់ដឹងធម៌ដែលពិតទាំងអស់នោះ ព្រោះហេតុនោះ ទើបហៅថា តថាគត ព្រោះត្រាស់ដឹងក្រៃលែងឯង នូវធម៌ពិត ធម៌មែន ។ ព្រះមានព្រះភាគ ទ្រង់ព្រះនាមថា តថាគត ព្រោះត្រាស់ដឹងធម៌ដែលពិតតាមយ៉ាងនេះ ។

ឈ្មោះថា តថាគត ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិតដូចម្តេច ព្រះមានព្រះភាគ ទ្រង់ឃើញរូបារម្មណ៍ដោយអាការគ្រប់យ៉ាង ដែលមកប្រាកដតាមចក្ខុទ្វាររបស់ពួកសត្វ មិនមានប្រមាណក្នុងលោកធាតុ មិនមានប្រមាណក្នុងលោក ព្រមទាំងទេវលោក ក្នុងពួកសត្វ ព្រមដោយទេវតា និងមនុស្ស ។

រូបារម្មណ៍នោះ ព្រះមានព្រះភាគទ្រង់ឃើញយ៉ាងនេះ ទ្រង់ចែកដោយអំណាចឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ជាដើមក្តី ដោយអំណាចគន្លងដែលបានក្នុងការឃើញ បានឮ ជ្រាប និងដឹងច្បាស់ក្តី ដោយឈ្មោះមិនមែនតិចដោយវារៈ ១៣ ដោយន័យ ៥២ តាមន័យជាដើមថា រូបណា ព្រោះអាស្រ័យមហាភូតរូប ៤ មានពណ៌ និងពន្លឺ ឃើញបាន ប៉ះខ្ទប់បាន ជាពណ៌ខៀវ ពណ៌លឿង រូបនោះ គឺរូបាយតនៈយ៉ាងណា ដូច្នេះ ជារបស់ពិតទាំងអស់ ដែលមិនពិតមិនមាន ។ ក្នុងសទ្ទារម្មណ៍ជាដើម ដែលមកប្រាកដក្នុងសោតទ្វារជាដើម ក៏ន័យនេះដូចគ្នា ។ សមដូចពាក្យដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក ។បេ។ និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ម្នាលភិក្ខុទាំងឡាយ អារម្មណ៍ណាដែលលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក និងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ និងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស បានឃើញ ឮ ពាល់ត្រូវ ដឹងច្បាស់ បានដល់ ស្វែងរក ពិចារណារឿយៗ ដោយចិត្ត តថាគតដឹងច្បាស់នូវអារម្មណ៍នោះ ឯអារម្មណ៍នោះ តថាគតដឹងប្រាកដហើយ អារម្មណ៍នោះមិនស្ថិតនៅក្នុងតថាគតទេ ។ ឈ្មោះថា តថាគត ព្រោះទ្រង់ឃើញអារម្មណ៍ដែលពិត ដោយប្រការដូច្នេះ ។ គប្បីជ្រាបការកើតនៃបទថា

តថាគត គឺអ្នកឃើញអារម្មណ៍ដែលពិត ដូច្នេះ ។

ឈ្មោះថា តថាគត ព្រោះមានវាចាពិតដូចម្ដេច ។

រាត្រីណា ព្រះមានព្រះភាគ ប្រថាប់គង់លើអបរាជិតបល្ល័ង្ក ក្នុងពោធិមណ្ឌលដ្ឋាន ទ្រង់ញាំញីអំបែងក្បាលរបស់មារទាំង ៣ ត្រាស់ដឹងក្រៃលែងឯង នូវអនុត្តរសម្មាសម្ពោធិញ្ញាណ និងរាត្រីណា ទ្រង់បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ត្រង់ដើមសាលព្រឹក្សទាំងគូ ក្នុងចន្លោះរាត្រីនោះ ក្នុងវេលាដែលទ្រង់មានវស្សាប្រមាណ ៤៥ វស្សា ព្រះមានព្រះភាគត្រាស់ពុទ្ធវចនៈឯណា ក្នុងបឋមពោធិកាលក្ដី មជ្ឈិមពោធិកាលក្ដី បច្ឆិមពោធិកាលក្ដី គឺសុត្តៈ គេយ្យៈ ។បេ។ វេទល្លៈ ព្រះពុទ្ធវចនៈទាំងអស់នោះ បុគ្គលណាតិះដៀលមិនបាន ទាំងដោយអត្ថ និងដោយព្យញ្ជនៈ មិនខ្វះមិនលើស បរិបូណ៌ដោយអាការទាំងពួង ជាគ្រឿងញាំញីរាគៈ ក្នុងព្រះពុទ្ធវចនៈនោះ មិនមានការខុសក្លាំងក្លាត់ សូម្បីត្រឹមប៉ុនចុងរោមទ្រាយ ព្រះពុទ្ធវចនៈទាំងអស់នោះ ដូចប្រថាប់ដោយត្រាតែមួយដូចគ្នា ដូចវាល់ដោយនាឡិតែមួយដូចគ្នា ដូចថ្លឹងដោយជញ្ជីងតែមួយដូចគ្នា ទើបជារបស់ពិតទាំងអស់ មិនមានមិនពិត ដោយហេតុនោះ ទើបទ្រង់ត្រាស់ថា ម្នាលចុន្ទ តថាគតត្រាស់ដឹងនូវសម្មាសម្ពោធិដ៏ប្រសើរ ក្នុងវេលាយប់ណាផង បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ក្នុងវេលាយប់ណាផង រមែងសម្ដែង ហៅ ចង្អុលបង្ហាញនូវហេតុណា ក្នុងចន្លោះនុ៎ះ ហេតុទាំងអស់នោះ សុទ្ធតែពិត មិនមែនត្រឡប់ទៅជាដទៃឡើយ ហេតុដូច្នោះហើយ បានជាគេហៅថា

ព្រះតថាគត ។ ពិតហើយ **គត** សព្ទ ក្នុងបទថា **តថាគតោ** នេះ មាន **គទ** ជាអត្ថ ។ ឈ្មោះថា តថាគត ព្រោះមានវាចាពិត ដោយប្រការយ៉ាងនេះ ។ ម្យ៉ាងទៀត ការនិយាយ អធិប្បាយថា ការពោល ឈ្មោះថា **អាគទ ។** ការត្រាស់របស់ព្រះអង្គជាពាក្យពិត មិនវិបរិត ព្រោះហេតុនោះ ទើបឈ្មោះថា តថាគត ព្រោះផ្លាស់ **ទ** ជា **ត** ។ គប្បីជ្រាបការភ្ជាប់បទក្នុងអត្ថនោះ ដោយប្រការដូច្នេះឯង ។

ឈ្មោះថា តថាគត ព្រោះជាអ្នកមានប្រក្រតីធ្វើដូចដែលត្រាស់នោះដូចម្ដេច ព្រោះថា កាយរបស់ព្រះមានព្រះភាគ រមែងអនុលោមដល់ព្រះវាចា ព្រះវាចាក៏អនុលោមដល់ព្រះកាយ ព្រោះហេតុនោះ ទ្រង់ត្រាស់យ៉ាងណា ក៏ទ្រង់ធ្វើយ៉ាងនោះ ទ្រង់ធ្វើយ៉ាងណា ក៏ត្រាស់យ៉ាងនោះ ។ ព្រះវាចារបស់ទ្រង់យ៉ាងនោះ ត្រាស់យ៉ាងណា ព្រះកាយក៏ទៅយ៉ាងនោះ អធិប្បាយថា ប្រព្រឹត្តទៅយ៉ាងនោះ ។ ម្យ៉ាងទៀត ព្រះកាយទ្រង់ធ្វើយ៉ាងណា ព្រះវាចាក៏ត្រាស់យ៉ាងនោះ ព្រោះហេតុនោះ ទើបឈ្មោះថា តថាគត ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលយ៉ាងណា ធ្វើយ៉ាងនោះ ធ្វើយ៉ាងណា ក៏ពោលយ៉ាងនោះ ព្រោះដូច្នោះ ទើបហៅថា តថាគត ។ ឈ្មោះថា តថាគត ព្រោះជាអ្នកមានប្រក្រតីធ្វើដូចព្រះតម្រាស់នោះ ដោយប្រការដូច្នេះ ។

ឈ្មោះថា តថាគត ព្រោះអត្ថថា គ្របសង្កត់បានដូចម្ដេច ព្រោះព្រះអង្គទ្រង់គ្របសង្កត់សត្វទាំងពួងក្នុងលោកធាតុមិនមានប្រមាណ ខាងលើដល់

ភវគ្គព្រហ្ម ខាងក្រោមដល់អវិចីមហានរក ខាងទទឹង កំណត់ទីបំផុតជុំវិញ ដោយសីលខ្ទះ សមាធិខ្ទះ បញ្ញាខ្ទះ វិមុត្តិខ្ទះ ព្រះអង្គមិនមានការថ្លឹង ឬការ រាប់ ទ្រង់ថ្លឹងមិនបាន រាប់មិនបាន ជាកំពូល ជាស្តេចនៃស្តេច ជាទេវតានៃ ទេវតា ជាសក្កៈនៃពួកសក្កៈ ជាព្រហ្មនៃពួកព្រហ្ម ដោយហេតុនោះ ទើបទ្រង់ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ តថាគតជាអ្នកគ្របសង្កត់ពួកសត្វក្នុងលោក ព្រមទាំងទេវតា ។បេ។ ព្រមទាំងទេវតា និងមនុស្ស ដែលបុគ្គលណាម្នាក់ គ្របសង្កត់មិនបាន ជាអ្នកឃើញដោយពិត ធ្វើឲ្យអ្នកដទៃនៅក្នុងអំណាច ព្រោះដូច្នោះ ទើបហៅថា តថាគត ។ គប្បីជ្រាបបទសន្ធិក្នុងពាក្យថា **តថាគតោ** នោះយ៉ាងនេះ ។

ការត្រាស់ គប្បីឃើញដូចថ្នាំដ៏ប្រសើរ ព្រះតម្រាស់នោះ គឺអ្វី គឺ លីលានៃទេសនា និងការចម្រើនឡើងនៃបុណ្យ ។ ព្រោះហេតុនោះឯង ទើប ទ្រង់គ្របសង្កត់បុគ្គលដែលជាបរប្បវាទទាំងអស់ និងសត្វលោក ព្រមទាំង ទេវតា ដូចគ្រូដែលមានអំណាចច្រើន គ្របសង្កត់ពស់ទាំងឡាយដោយថ្នាំទិព្វ ដូច្នោះ ។ ដូច្នេះ ព្រះអង្គមានព្រះតម្រាស់ គឺលម្អនៃទេសនា និងការចម្រើន ឡើងនៃបុណ្យ តាមសេចក្តីពិត មិនវិបរិត ព្រោះទ្រង់គ្របសង្កត់សត្វលោក បាន ព្រោះដូច្នោះ គប្បីជ្រាបថា តថាគត ព្រោះផ្លាស់ **ឧ** អក្ខរៈ ជា **ត** អក្ខរៈ ។ ឈ្មោះថា តថាគត ព្រោះអត្ថថា ទ្រង់គ្របសង្កត់ ដោយ ប្រការដូច្នេះ ។

ម្យ៉ាងទៀត ឈ្មោះថា តថាគត ព្រោះយាងទៅដោយសេចក្តីពិត ព្រោះ

ទ្រង់ដល់នូវសេចក្តីពិត ដូច្នេះក៏មាន ។ អធិប្បាយថា ត្រាស់ដឹង ទ្រង់កន្លង ហើយ ទ្រង់ចាក់ចុះ ទ្រង់ប្រព្រឹត្តទៅ ។ ក្នុងបណ្តាពាក្យទាំងនោះ ឈ្មោះថា តថាគត ព្រោះយាងទៅ គឺត្រាស់ដឹងលោកទាំងមូល ដោយសេចក្តីពិត គឺ តីរណបរិញ្ញា ។ ឈ្មោះថា តថាគត ព្រោះយាងទៅ គឺទ្រង់កន្លងលោក-សមុទយៈ ដោយសេចក្តីពិត គឺបហានបរិញ្ញា ។ ឈ្មោះថា តថាគត ព្រោះយាងទៅ គឺសម្រេចការរលត់ឥតមានសេសសល់នៃលោកដោយសេចក្តីពិត គឺសច្ឆិកិរិយា ។ ឈ្មោះថា តថាគត ព្រោះយាងទៅ គឺប្រព្រឹត្តទៅកាន់ការពិត គឺបដិបទាដែលញុំាងសត្វ ឲ្យដល់នូវការរម្ងត់លោក ។ ដោយហេតុនោះ ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោក ( គឺទុក្ខសច្ច ) តថាគតបាន ត្រាស់ដឹងហើយ តថាគតផុតចាកលោក ( គឺទុក្ខសច្ច ) ហើយ ម្នាលភិក្ខុ ទាំងឡាយ លោកសមុទយៈ តថាគតបានត្រាស់ដឹងហើយ លោកសមុទយៈ តថាគតបានលះបង់ហើយ ម្នាលភិក្ខុទាំងឡាយ លោកនិរោធ តថាគតបាន ត្រាស់ដឹងហើយ លោកនិរោធតថាគតបានធ្វើឲ្យជាក់ច្បាស់ហើយ ម្នាលភិក្ខុ ទាំងឡាយ លោកនិរោធគាមិនីបដិបទា តថាគតបានត្រាស់ដឹងហើយ លោក និរោធគាមិនីបដិបទា តថាគតបានចម្រើនហើយ ។ ម្នាលភិក្ខុទាំងឡាយ អា-រម្មណ៍ណាដែលលោក ព្រមទាំងទេវលោក ។បេ។ តថាគតបានដឹងជាក់ស្តែង ហើយដោយសារចិត្ត ព្រោះហេតុនោះ បានជាគេហៅថា តថាគត ។ អត្ថ នៃពាក្យថា តថាគតនោះ បណ្ឌិតគប្បីជ្រាបដោយប្រការយ៉ាងនេះ ។ ពាក្យ នេះ ក៏ត្រឹមតែជាគន្លងក្នុងការសម្តែងភាពដែលតថាគតជាតថាគត ។ ព្រះ

តថាគតប៉ុណ្ណោះ ទើបទឹងពណ៌នាភាពដែលតថាគតជាតថាគតបានសព្វគ្រប់ប្រការ ។

ក្នុងពីរបទថា **អរហំ សម្មាសម្ពុទ្ធោ** ជំបូង គប្បីជ្រាបថា **អរហំ** ដោយហេតុទាំងនេះ គឺព្រោះជាអ្នកឆ្ងាយចាកសត្រូវ គឺកិលេស ព្រោះជាអ្នកកាច់បំបាក់នូវកាំ និងខ្នងកង់នៃសង្សារចក្របេញបាន ព្រោះគួរដល់សក្ការៈ មានបច្ច័យជាដើម និងព្រោះមិនមានការធ្វើបាបក្នុងទីកំបាំង ។ ឯដែលឈ្មោះថា **សម្មាសម្ពុទ្ធ** ព្រោះត្រាស់ដឹងធម៌ទាំងពួងដោយប្រពៃ និងដោយព្រះអង្គឯង ។ សេចក្ដីសង្ខេបក្នុងសេចក្ដីនេះមានប្រមាណប៉ុណ្ណោះ ។ ទាំង ២ បទនេះពោលទុកដោយពិស្ដារ ក្នុងពណ៌នាពុទ្ធានុស្សតិ ក្នុងគម្ពីរវិសុទ្ធិមគ្គហើយ ។ល។

## អដ្ឋកថាសូត្រទី ១ ចប់

# អដ្ឋកថាសូត្រទី ២

[ ១៤០ ] ក្នុងសូត្រទី ២ មានវិនិច្ឆ័យដូចតទៅនេះ បទថា **ឆាតុភាវោ** បានដល់ ការកើតឡើង គឺការសម្រេច ។ បទថា **ទុល្លភោ លោកស្មឹ** បានដល់ រកបានលំបាក គឺរកបានលំបាកក្រៃលែងក្នុងសត្វលោកនេះ ។ ឈ្មោះថា រកបានលំបាក ព្រោះហេតុអ្វី ព្រោះព្រះអង្គមិនអាចបំពេញទាន-បារមីតែម្តង ហើយបានជាព្រះពុទ្ធនោះទេ ។ ម្យ៉ាងទៀត ទ្រង់មិនអាចបំពេញទានបារមី ២ ដង ១០ ដង ២០ ដង ៥០ ដង ១០០ ដង ១០០០ ដង ១ កោដិដង ១ សែនកោដិដង ទ្រង់មិនអាចបំពេញ ទានបារមីបាន ១ ថ្ងៃ ២ ថ្ងៃ ១០ ថ្ងៃ ២០ ថ្ងៃ ៥០ ថ្ងៃ ១០០ ថ្ងៃ ១០០០ ថ្ងៃ ១ សែនថ្ងៃ ១ សែនកោដិថ្ងៃ ។បេ។ ១ ខែ ១ ឆ្នាំ ២ ឆ្នាំ ។បេ។ ១ សែនកោដិឆ្នាំ ១ កប្ប ២ កប្ប ។បេ។ ១ សែនកោដិកប្ប ទ្រង់មិនអាចបំពេញបានទានបារមី ១ អសង្ខេយ្យ ២ អសង្ខេយ្យ ៣ អសង្ខេយ្យនៃកប្ប ហើយបានជាព្រះពុទ្ធបាននៅឡើយ សូម្បីក្នុងសីលបារមី នេក្ខម្មបារមី ។បេ។ ឧបេក្ខាបារមី ក៏ន័យនេះដូចគ្នា ។ តែគ្រាចុងក្រោយ ទ្រង់បំពេញបារមី ១០ អស់ ៤ អសង្ខេយ្យ និងមួយសែនកប្ប ទើបអាចត្រាស់ជាព្រះពុទ្ធបានដោយហេតុដូចពោលមកនេះ ទើបទ្រង់ឈ្មោះថា រកបានដោយកម្រ ។៙

## អដ្ឋកថាសូត្រទី ២ ចប់

# អដ្ឋកថាសូត្រទី ៣

[ ១៤១ ] ក្នុងសូត្រទី ៣ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អច្ឆរិយ-មនុស្សោ** ប្រែថា មនុស្សដែលអស្ចារ្យ ។

បទថា **អច្ឆរិយោ** សេចក្តីថា មិនមានជានិច្ច ដូចមនុស្សខ្វាក់ឡើងភ្នំ ។ ន័យនៃសព្ទប៉ុណ្ណោះជាបឋម តែន័យនៃអដ្ឋកថាដូចតទៅនេះថា ឈ្មោះថា **អច្ឆរិយ** ព្រោះគួរដល់ការទះដៃ អធិប្បាយថា គួរទះដៃហើយសម្លឹងមើល ។

ម្យ៉ាងទៀត ឈ្មោះថា មនុស្សអស្ចារ្យ ព្រោះប្រកបដោយធម៌ដែលមិនធ្លាប់មាន គួរអស្ចារ្យច្រើនប្រការ ដូចក្នុងសូត្រថា ម្នាលភិក្ខុទាំងឡាយ ហេតុអស្ចារ្យចម្លែក ៤ យ៉ាង រមែងកើតប្រាកដ ព្រោះការកើតនៃព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធជាដើម ។ ឈ្មោះថា **អច្ឆរិយមនុស្ស** ព្រោះជាមនុស្សដែលធ្លាប់សន្សំមកក៏មាន ។

ពិតហើយ ការដែលទ្រង់ប្រជុំធម៌ ៨ ប្រការ ដែលនឹងធ្វើឲ្យអភិនីហារដល់ព្រម ហើយទ្រង់ចងព្រះមនស្ស ប្រថាប់គង់ក្នុងមហាពោធិមណ្ឌលដ្ឋានចំពោះព្រះភក្ត្ររបស់ព្រះមានព្រះភាគមួយអង្គ បុគ្គលដទៃណា មិនបានធ្លាប់សន្សំមកឡើយ ព្រះសព្វញ្ញូពោធិសត្វមួយអង្គប៉ុណ្ណោះសន្សំមក ។ ម្យ៉ាងទៀត សូម្បីការដែលព្រះអង្គបានទទួលព្យាករ ក្នុងសម្នាក់ព្រះពុទ្ធទាំងឡាយដែលជាអ្នកមិនវិលត្រឡប់ អធិដ្ឋានសេចក្តីព្យាយាម ហើយបំពេញពុទ្ធការកធម៌ បុគ្គលដទៃណាមិនធ្លាប់បានសន្សំមកឡើយ ព្រះសព្វញ្ញូពោធិសត្វប៉ុណ្ណោះធ្លាប់សន្សំមក ។ ម្យ៉ាងទៀត ព្រះអង្គទ្រង់បំពេញព្រះបារមីឲ្យចាស់ក្លា ញុំាងព្រះបារមីឲ្យកាន់យកបន្ទប់ ស្ថិតនៅក្នុងអត្តភាព ដូចជាក្នុងកាលសោយព្រះ

ជាតិជាព្រះវេស្សន្តរ បំពេញសត្តសតកមហាទាន គឺរបស់ ៧ មុខ មួយមុខ ៧០០ មានដំរី ៧០០ សេះ ៧០០ ប្រដាប់ដោយគ្រឿងអលង្ការគ្រប់យ៉ាង ប្រគល់ព្រះឱរស គឺជាលិកុមារ ព្រះធីតា គឺកណ្ហាជិនា ព្រះទេវី គឺព្រះនាងមទ្រីជាដើមទុកក្នុងប្រមុខនៃទាន តាំងនៅរហូតអស់អាយុ ក្នុងអត្តភាពទី ២ ទ្រង់បដិសន្ធិក្នុងតុសិតពិភព ដែលបុគ្គលដទៃណាម្នាក់មិនធ្លាប់សន្សំមកឡើយ ព្រះសព្វញ្ញូពោធិសត្វប៉ុណ្ណោះធ្លាប់សន្សំមក សូម្បីការដែលព្រះអង្គទ្រង់បំពេញនៅក្នុងភពជាន់តុសិតរហូតអស់អាយុ ទ្រង់ទទួលការអារាធនារបស់ទេវតាទាំងឡាយ ទ្រង់ទតមើលមហាវិលោកនៈ ៥ យ៉ាង ទ្រង់មានព្រះសតិនិងសម្បជញ្ញៈ ចុតិអំពីតុសិត បដិសន្ធិក្នុងត្រកូលដែលមានភោគៈច្រើន ដែលបុគ្គលដទៃណាម្នាក់មិនធ្លាប់សន្សំមកឡើយ ព្រះសព្វញ្ញូពោធិសត្វប៉ុណ្ណោះធ្លាប់សន្សំមក ម្យ៉ាងទៀត លោកធាតុមួយម៉ឺនញាប់ញ័រ ក្នុងថ្ងៃបដិសន្ធិក្តី ការដែលព្រះអង្គទ្រង់មានសតិសម្បជញ្ញៈក្នុងព្រះគភ៌របស់ព្រះមាតាក្តី ការដែលលោកធាតុមួយម៉ឺនញាប់ញ័រក្នុងថ្ងៃដែលព្រះអង្គទ្រង់មានព្រះសតិសម្បជញ្ញៈ ស្តេចចេញចាកព្រះគភ៌របស់ព្រះមាតាក្តី ការដែលព្រះអង្គប្រសូតភ្លាម ហើយទ្រង់ឈានជើងបាន ៧ ជំហានក្តី ការបាំងស្វេតច្ឆត្រដែលជាទិព្វក្តី ការបក់ដោយផ្លិតវាលវីជនីដែលជាទិព្វក្តី ការដែលព្រះអង្គទ្រង់ក្រឡេកមើលដូចសីហៈ ទៅក្នុង ៤ ទិស ទ្រង់មិនឃើញសត្វណាម្នាក់ដែលស្មើដូចព្រះអង្គ ហើយទ្រង់បន្លឺសីហនាទយ៉ាងនេះថា យើងជាកំពូលនៃលោកក្តី ការដែលម៉ឺនលោកធាតុញាប់ញ័រក្នុងខណៈដែលទ្រង់លះរាជសម្បត្តិ កាល

ព្រះញាណចាស់ក្លា ហើយស្ដេចចេញមហាភិនេស្រ្កមណ៍ក្ដី ការដែលព្រះអង្គប្រថាប់គង់សមាធិ ក្នុងមហាពោធិមណ្ឌលដ្ឋាន ទ្រង់ឈ្នះមារជាដើមទៅហើយ ទ្រង់ជម្រះបុព្វេនិវាសានុស្សតិញ្ញាណ និងទិព្វចក្ខុញ្ញាណ ទ្រង់ធ្វើម៉ឺនលោកធាតុឲ្យញាប់ញ័រ ខណៈទ្រង់ចាក់ធ្លុះនូវគំនរគុណ គឺព្រះសព្វញ្ញុតញ្ញាណក្នុងវេលាជិតភ្លឺក្ដី ការប្រកាសធម្មចក្រដ៏កំពូលដែលមានបរិវដ្ដៈ ៣ ដោយបឋម-ទេសនាក្ដី ការអស្ចារ្យទាំងអស់ ដូចពោលមកយ៉ាងនេះជាដើម បុគ្គលដទៃណា មិនធ្លាប់បានសន្សំមកឡើយ ព្រះសព្វញ្ញុពុទ្ធប៉ុណ្ណោះធ្លាប់សន្សំមក ។ ឈ្មោះថា មនុស្សអស្ចារ្យ ព្រោះជាមនុស្សធ្លាប់សន្សំមក ដូច្នេះ ដោយប្រការយ៉ាងនេះ ។

**អដ្ឋកថាសូត្រទី ៣ ចប់**

# អដ្ឋកថាសូត្រទី ៤

[ ១៤២ ] ក្នុងសូត្រទី ៤ មានវិនិច្ឆ័យដូចតទៅនេះ បទថា **កាល-កិរិយា** សេចក្ដីថា ឈ្មោះថា កាលកិរិយា ព្រោះកិរិយាដែលប្រាកដក្នុងកាលមួយ ៗ ពិតហើយ ព្រះតថាគតទ្រង់តាំងនៅ ៤៥ វស្សា ទ្រង់ប្រកាសបិដក ៣ និកាយ ៥ សត្ថុសាសនៈមានអង្គ ៩ ព្រះធម្មក្ខន្ធ ៨៤០០០ ព្រះធម្មក្ខន្ធ ទ្រង់ធ្វើមហាជនឲ្យបង្អោនទៅក្នុងព្រះនិព្វាន ប្រព្រឹត្តទៅក្នុងព្រះនិព្វាន

ផ្ចុំត្រង់ចន្លោះសាលព្រឹក្សទាំងគូ ត្រាស់ហៅភិក្ខុសង្ឃមក ទ្រង់ទូន្មានដោយសេចក្តីមិនប្រមាទ ទ្រង់មានព្រះសតិសម្បជញ្ញៈ ទ្រង់បរិនិព្វានដោយអនុ-បាទិសេសនិព្វានធាតុ កាលកិរិយានេះរបស់ព្រះតថាគតនោះ ប្រាកដមករហូតដល់សព្វថ្ងៃនេះ ព្រោះដូច្នោះ ទើបឈ្មោះថា កាលកិរិយា ព្រោះជាកិរិយាដែលប្រាកដក្នុងវេលាមួយ ៗ បទថា **អនុតប្បា ហោតិ** ប្រែថា ធ្វើនូវការក្តៅក្រហាយតាម គឺក្នុងកាលក្រោយ ៗ ក្នុងសេចក្តីនោះ កាលកិរិយារបស់ស្តេចចក្រពត្តិ ទ្រង់ធ្វើការក្តៅក្រហាយតាមដល់ទេវតា និងមនុស្សក្នុងម៉ឺនចក្កវាឡ ។ កាលកិរិយារបស់ព្រះពុទ្ធទាំងឡាយ ធ្វើនូវការក្តៅក្រហាយតាមដល់ទេវតា និងមនុស្សទាំងឡាយក្នុងម៉ឺនចក្កវាឡ ដោយហេតុនោះ ទើបត្រាស់ថា ធ្វើនូវការក្តៅក្រហាយតាមដល់ជនច្រើន ដូច្នេះ ។ល។

**អដ្ឋកថា សូត្រទី ៤ ចប់**

# អដ្ឋកថា សូត្រទី ៥
# ពុទ្ធ ៤ យ៉ាង

[ ១៤៣ ] ក្នុងសូត្រទី ៥ មានវិនិច្ឆ័យដូចតទៅនេះ បទថា **អទុតិយោ** សេចក្តីថា ដែលឈ្មោះថា **អទុតិយោ** ព្រោះមិនមានព្រះពុទ្ធអង្គទី ២ ៗ ពិតហើយ ព្រះពុទ្ធមាន ៤ អង្គ គឺសុតពុទ្ធ ១ ចតុសច្ចពុទ្ធ ១ បច្ចេកពុទ្ធ ១

សព្វញ្ញុពុទ្ធ ១ ។ ក្នុង ៤ ពុទ្ធៈនោះ ភិក្ខុដែលជាពហុស្សុត ឈ្មោះថា **សុតពុទ្ធ** ។ ភិក្ខុដែលជាខីណាស្រព ឈ្មោះថា **ចតុសច្ចពុទ្ធ** ។ បុគ្គលដែលបំពេញបារមីអស់ ២ អសង្ខេយ្យ និង ១ សែនកប្ប ហើយចាក់ធ្លុះបច្ចេកពោធិញ្ញាណ ឈ្មោះថា **បច្ចេកពុទ្ធ** ។ បុគ្គលដែលបំពេញបារមី ៤ អសង្ខេយ្យ ៨ អសង្ខេយ្យ ១៦ អសង្ខេយ្យ និង ១ សែនកប្ប ហើយញាំញីអំបែងក្បាលនៃមារទាំង ៣ ចាក់ធ្លុះនូវសព្វញ្ញុតញ្ញាណ ឈ្មោះថា **សព្វញ្ញុពុទ្ធ** ។ ក្នុងពុទ្ធៈទាំង ៤ នេះ ព្រះសព្វញ្ញុពុទ្ធ ឈ្មោះថា មិនមានអង្គទី ២ ធម្មតាថា ព្រះសព្វញ្ញុពុទ្ធអង្គដទៃ ទ្រង់កើតឡើងរួមជាមួយព្រះសព្វញ្ញុពុទ្ធអង្គនោះមិនមាន ។

បទថា **អសហាយោ** សេចក្តីថា ឈ្មោះថា មិនមានសម្លាញ់ ព្រោះទ្រង់មិនមានសម្លាញ់ដែលស្មើដោយអត្តភាព ឬដោយធម៌ដែលទ្រង់ត្រាស់ដឹងហើយ ។ ព្រះសេក្ខៈ និងព្រះអសេក្ខៈ ឈ្មោះថា ជាសម្លាញ់នៃព្រះពុទ្ធទាំងឡាយ ដោយបរិយាយនេះថា ព្រះមានព្រះភាគអង្គនោះ ទ្រង់បានសេក្ខប្បដិបទា និងអសេក្ខប្បដិបទាជាសម្លាញ់ ។

បទថា **អប្បដិមោ** មិនមានបុគ្គលមានអត្តភាពដូច សេចក្តីថា អត្តភាព ហៅថា បដិមា ឈ្មោះថា បដិមា ព្រោះបដិមាដទៃ ដូចគ្នានឹងអត្តភាពរបស់ទ្រង់មិនមាន ។ ម្យ៉ាងទៀត មនុស្សទាំងឡាយធ្វើបដិមាណាដែលសម្រេចដោយមាស នឹងប្រាក់ជាដើមក្នុងបណ្តាបដិមាទាំងនោះ ឈ្មោះថា អ្នកអាចធ្វើឱកាសសូម្បីប៉ុនចុងរោមទ្រាយ ឲ្យដូចអត្តភាពព្រះតថាគត

រមែងមិនមាន ព្រោះហេតុនោះ ទើបឈ្មោះថា មិនមានបុគ្គលមានអត្តភាពដូច ដោយប្រការទាំងពួង ។

បទថា **អប្បដិសមោ** មិនមានបុគ្គលមានអត្តភាពស្មើ សេចក្តីថា ឈ្មោះថា មិនមានបុគ្គលមានអត្តភាពស្មើ ព្រោះបុគ្គលណាម្នាក់ ឈ្មោះថា នឹងប្រៀបធៀបជាមួយនឹងអត្តភាពរបស់ព្រះតថាគតនោះមិនមាន ។

បទថា **អប្បដិភាគោ** ជាអ្នកបែងភាគធម៌ សេចក្តីថា ឈ្មោះថា ជាអ្នកបែងភាគធម៌ ព្រោះធម៌ឯណា ដែលព្រះតថាគតទ្រង់សម្តែងដោយន័យជាដើមថា សតិប្បដ្ឋានមាន ៤ ឈ្មោះថា បុគ្គលអាចបែងភាគក្នុងធម៌ទាំងនោះ ដោយន័យជាដើមថា **ន ចត្តារោ សតិប្បដ្ឋានា តយោ វា បញ្ច វា** សតិប្បដ្ឋានមិនមែន ៤ សតិប្បដ្ឋានមាន ៣ ឬ ៥ ។

បទថា **អប្បដិបុគ្គលោ** មិនមានបុគ្គលប្រណាំងប្រជែងបាន សេចក្តីថា ឈ្មោះថា មិនមានបុគ្គលប្រណាំងប្រជែងបាន ព្រោះមិនមានបុគ្គលណាម្នាក់ អាចឲ្យប្តេជ្ញាយ៉ាងនេះថា ខ្ញុំជាព្រះពុទ្ធ ដូច្នេះ ។

បទថា **អសមោ** សេចក្តីថា ឈ្មោះថា មិនមានបុគ្គលស្មើ ដោយសត្វទាំងពួង ព្រោះមិនមានបុគ្គលប្រៀបផ្ទឹមនោះឯង ។ បទថា **អសមសមោ** គឺស្មើតែនឹងបុគ្គលដែលឥតគេស្មើ សេចក្តីថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយដែលជាអតីត និងអនាគត លោកហៅថា មិនមានបុគ្គលស្មើ បុគ្គលស្មើដោយព្រះសព្វញ្ញុពុទ្ធ ដែលមិនមានបុគ្គលណាស្មើទាំងនោះ ព្រោះដូច្នោះ ទើបឈ្មោះថា ស្មើតែនឹងបុគ្គលដែលឥតគេស្មើ ។

បទថា **ទ្វិបទានំ អគ្គោ** សេចក្ដីថា ព្រះសម្មាសម្ពុទ្ធជាកំពូលនៃសត្វដែលមិនមានជើង មានជើង ២ មានជើង ៤ មានជើងច្រើន សត្វដែលមានរូប មិនមានរូប សត្វមានសញ្ញា មិនមានសញ្ញា មានសញ្ញាក៏មិនមាន មិនមានសញ្ញាក៏មិនមែន ។ ព្រោះហេតុអ្វី ក្នុងទីនេះ ទើបលោកពោលថា ប្រសើរបំផុតជាងពួកសត្វមានជើង ២ ។ ព្រោះទាក់ទងដោយព្រះអង្គជាបុគ្គលប្រសើរជាង ។ ពិតហើយ ធម្មតាបុគ្គលប្រសើរ កាលកើតក្នុងលោកនេះ មិនកើតក្នុងសត្វមិនមានជើង សត្វមានជើង ៤ និងសត្វមានជើងច្រើនឡើយ រមែងកើតចំពោះក្នុងសត្វជើង ២ ប៉ុណ្ណោះ ។ សួរថា ក្នុងសត្វជើង ២ ប្រភេទណា ឆ្លើយថា ក្នុងមនុស្ស និងទេវតាទាំងឡាយ ។ កាលទ្រង់កើតក្នុងពួកមនុស្ស រមែងកើតជាព្រះពុទ្ធដែលជាអ្នកធ្វើលោកធាតុ ៣០០០ និងច្រើនពាន់លោកធាតុ ឲ្យនៅក្នុងអំណាចបាន ។ កាលកើតក្នុងពួកទេវតា រមែងកើតជាមហាព្រហ្ម ដែលធ្វើលោកធាតុមួយម៉ឺនឲ្យនៅក្នុងអំណាចបាន មហាព្រហ្មនោះ ប្រហែលគ្នានឹងកប្បិយការក ឬជាអារាមិករបស់ព្រះអង្គ ដូច្នោះទើបលោកហៅថា ជាបុគ្គលប្រសើរបំផុតជាងសត្វមានជើង ២ ដោយអំណាចជាបុគ្គលប្រសើរជាងមនុស្ស និងទេវតានោះឯង ។៙

## អដ្ឋកថាសូត្រទី ៥ ចប់

## អដ្ឋកថា សូត្រទី ៦ ជាដើម

[ ១៤៤ ] *ក្នុងសូត្រទី ៦ ជាដើមមានវិនិច្ឆ័យដូចតទៅនេះ បទថា* **ឯកបុគ្គលស្ស ភិក្ខវេ ចាតុភាវោ មហតោ ចក្ខុស្ស ចាតុភាវោ ហោតិ** *សេចក្ដីថា ម្នាលភិក្ខុទាំងឡាយ ចក្ខុធំរមែងប្រាកដព្រោះព្រះតថាគតអរហន្ត-សម្មាសម្ពុទ្ធជាបុគ្គលឯកប្រាកដ កាលបុគ្គលនោះប្រាកដហើយ សូម្បីចក្ខុក៏រមែងប្រាកដដូចគ្នា ព្រោះវៀរបុគ្គលប្រាកដចេញ ចក្ខុក៏ប្រាកដមិនបាន ។ បទថា* **ចាតុភាវោ** *បានដល់ ការកើតឡើង គឺការសម្រេច ។ សួរថា ចក្ខុប្រភេទណា ឆ្លើយថា ចក្ខុ គឺបញ្ញា ។ សេចក្ដីនេះដូចអ្វី ដូចវិបស្សនាបញ្ញារបស់ព្រះសារីបុត្រត្ថេរ ដូចសមាធិបញ្ញារបស់ព្រះមហាមោគ្គល្លានត្ថេរ ។ ក្នុងអាលោក គឺការឃើញជាដើមក៏មានន័យនេះដូចគ្នា ។ ពិតហើយ ក្នុងការសម្លឹងឃើញជាដើមនេះ លោកបំណងយកការមើលឃើញ ដូចការមើលដោយបញ្ញា និងពន្លឺ ដូចគ្នានឹងពន្លឺនៃបញ្ញារបស់អគ្គសាវកទាំង ២ ។ បទទាំង ៣ នេះ គឺការប្រាកដនៃចក្ខុដ៏ប្រសើរ ការកើតប្រាកដនៃពន្លឺដ៏ប្រសើរ ការកើតប្រាកដនៃរស្មីដ៏ប្រសើរ គប្បីជ្រាបថា ត្រាស់លាយឡំគ្នា ទាំងលោកិយ និងលោកុត្តរ ។*

## អនុត្តរិយៈ ៦

*បទថា* **ឆន្នំ អនុត្តរិយានំ** *បានដល់ អនុត្តរិយៈ ៦ យ៉ាង ដែលមិនមានធម៌ដទៃក្រៃលែងជាង ក្នុងពាក្យនោះ មានអធិប្បាយថា អនុត្តរិយៈទាំង ៦ នេះ គឺទស្សនានុត្តរិយៈ ១ សវនានុត្តរិយៈ ១ លាភានុត្តរិយៈ ១ សិក្ខា-នុត្តរិយៈ ១ បារិចរិយានុត្តរិយៈ ១ អនុស្សតានុត្តរិយៈ ១ ។ ការប្រាកដ*

ឡើងនៃអនុត្តរិយៈទាំង ៦ នេះ ទើបមាន ។

ម្យ៉ាងទៀត ព្រះអានន្ទ រមែងបានឃើញព្រះតថាគត ដោយចក្ខុ-វិញ្ញាណ ទាំងព្រឹក ទាំងល្ងាច នេះឈ្មោះថា ទស្សនានុត្តរិយៈ ។ បុគ្គលដទៃ ទោះជាព្រះសោតាបន្ន ព្រះសកទាគាមី ព្រះអនាគាមី ក៏រមែងបានឃើញព្រះតថាគតដូចព្រះអានន្ទ នេះក៏ឈ្មោះថា ទស្សនានុត្តរិយៈ ។ ម្យ៉ាងទៀត បុគ្គលដទៃទៀត ដែលជាកល្យាណបុថុជ្ជន ក៏បានឃើញព្រះទសពលដូចព្រះអានន្ទ ធ្វើការឃើញនោះឲ្យចម្រើន រមែងសម្រេចសោតាបត្តិមគ្គ នេះក៏ឈ្មោះថា ទស្សនៈដូចគ្នា ចំណែកមូលទស្សនៈ ឈ្មោះថា ទស្សនានុត្តរិយៈ ។

ពិតហើយ បុគ្គលរមែងបានស្តាប់ព្រះតម្រាស់របស់ព្រះទសពលរឿយៗ ដោយសោតវិញ្ញាណដូចព្រះអានន្ទ នេះឈ្មោះថា សវនានុត្តរិយៈ ។ សូម្បីព្រះអរិយបុគ្គលដទៃ មានព្រះសោតាបន្នជាដើម រមែងបានស្តាប់ព្រះតម្រាស់របស់ព្រះតថាគតដូចព្រះអានន្ទដែរ នេះក៏ឈ្មោះថា សវនានុត្តរិយៈ ។ ឯបុគ្គលដទៃទៀត ដែលជាកល្យាណបុថុជ្ជន បានស្តាប់ព្រះតម្រាស់របស់ព្រះតថាគតដូចព្រះអានន្ទ ចម្រើនសវនៈនោះ រមែងសម្រេចសោតាបត្តិមគ្គ នេះក៏ឈ្មោះថា សវនៈដូចគ្នា ចំណែកមូលសវនៈ ឈ្មោះថា សវនានុត្តរិយៈ ។

បុគ្គលរមែងបានចំពោះនូវសទ្ធាក្នុងព្រះទសពលដូចព្រះអានន្ទត្ថេរ នេះឈ្មោះថា លាភានុត្តរិយៈ ។ បុគ្គលដទៃ មានព្រះសោតាបន្នជាដើម បានលាភចំពោះ គឺសទ្ធាក្នុងព្រះទសពលដូចព្រះអានន្ទ រមែងបានលាភចំពោះនេះក៏ឈ្មោះថា លាភនុត្តរិយៈ ។ ឯបុគ្គលដទៃទៀត ជាកល្យាណបុថុជ្ជន

បានលាភចំពោះ គឺសទ្ធាក្នុងព្រះទសពលដូចព្រះអានន្ទ ចម្រើនលាភនោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថា ការបានដូចគ្នា ឯមូលលាភនោះ ឈ្មោះថា លាភានុត្តរិយៈ ។

ម្យ៉ាងទៀត បុគ្គលសិក្សាសិក្ខា ៣ ក្នុងព្រះសាសនារបស់ព្រះទសពល ដូចព្រះអានន្ទ ឈ្មោះថា សិក្ខានុត្តរិយៈ ។ សូម្បីព្រះអរិយបុគ្គលដទៃ មានព្រះសោតាបន្នជាដើម រមែងសិក្សាសិក្ខា ៣ ក្នុងព្រះសាសនារបស់ព្រះសម្ពុទ្ធ ដូចព្រះអានន្ទ នេះក៏ឈ្មោះថា សិក្ខានុត្តរិយៈ ។ ឯបុគ្គលដទៃទៀត ដែលជាកល្យាណបុថុជ្ជនសិក្សាសិក្ខា ៣ ក្នុងព្រះសាសនារបស់ព្រះទសពលដូចព្រះអានន្ទត្ថេរ ចម្រើនសិក្ខា ៣ នោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថា ការសិក្សាដូចគ្នា ចំណែកមូលសិក្ខា ឈ្មោះថា សិក្ខានុត្តរិយៈ ។

ម្យ៉ាងទៀត បុគ្គលប្រណិប័តន៍ព្រះទសពលរឿយៗ ដូចព្រះអានន្ទត្ថេរ នេះឈ្មោះថា បារិចរិយានុត្តរិយៈ ។ សូម្បីព្រះអរិយបុគ្គលដទៃ មានព្រះសោតាបន្នជាដើម រមែងប្រណិប័តន៍ព្រះទសពលរឿយៗ នេះក៏ឈ្មោះថា បារិចរិយានុត្តរិយៈ ។ ឯបុគ្គលដទៃៗ ដែលជាកល្យាណបុថុជ្ជន ប្រណិប័តន៍ព្រះទសពលដូចព្រះអានន្ទ ចម្រើនការប្រណិប័តន៍នោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថា ការប្រណិប័តន៍ដូចគ្នា ចំណែកមូលបារិចរិយៈ ឈ្មោះថា បារិចរិយានុត្តរិយៈ ។

បុគ្គលរឭកដល់រឿយៗ នូវគុណដែលជាលោកិយ និងលោកុត្តររបស់ព្រះទសពលដូចព្រះអានន្ទ នេះឈ្មោះថា អនុស្សតានុត្តរិយៈ ។ សូម្បីព្រះ-

អរិយបុគ្គលដទៃ មានព្រះសោតាបន្នជាដើម រឭករឿយៗ ដល់គុណដែលជាលោកិយ និងលោកុត្តររបស់ព្រះទសពលដូចព្រះអានន្ទត្ថេរ នេះក៏ឈ្មោះថាអនុស្សតានុត្តរិយៈ ។ ឯបុគ្គលដទៃទៀត ជាកល្យាណបុថុជ្ជន រឭករឿយៗដល់គុណដែលជាលោកិយ និងលោកុត្តររបស់ព្រះទសពលដូចព្រះអានន្ទ ចម្រើនការរឭករឿយៗ នោះ រមែងសម្រេចសោតាបត្តិមគ្គ នេះឈ្មោះថាអនុស្សតិដូចគ្នា ឯមូលអនុស្សតិ ឈ្មោះថា អនុស្សតានុត្តរិយៈ ដូចពណ៌នាមកនេះ គឺអនុត្តរិយៈ ៦ ។ អនុត្តរិយៈទាំង ៦ នេះរមែងប្រាកដ អនុត្តរិយៈទាំង ៦ នេះ គប្បីជ្រាបថា លោកពោលលាយឡំគ្នា ទាំងជាលោកិយ និងទាំងលោកុត្តរ ។

បទថា **ចតុន្នំ បដិសម្ភិទានំ សច្ឆិកិរិយា ហោតិ** សេចក្តីថា បដិសម្ភិទា ៤ គឺអត្ថប្បដិសម្ភិទា ធម្មប្បដិសម្ភិទា និរុត្តិប្បដិសម្ភិទា បដិភាណប្បដិសម្ភិទា ក្នុងបដិសម្ភិទា ៤ នោះ ការដឹងក្នុងអត្ថ ឈ្មោះថា **អត្ថប្បដិសម្ភិទា** ។ ការដឹងក្នុងធម៌ ឈ្មោះថា **ធម្មប្បដិសម្ភិទា** ។ ការដឹងក្នុងការពោលភាសាដែលជាអត្ថ និងធម៌ ឈ្មោះថា **និរុត្តិប្បដិសម្ភិទា** ។ ការដឹងក្នុងញាណទាំងឡាយ ឈ្មោះថា **បដិភាណប្បដិសម្ភិទា** ។ សេចក្តីសង្ខេបក្នុងទីនេះ មានប្រមាណប៉ុណ្ណេះ ។ ឯសេចក្តីពិស្តារនៃបដិសម្ភិទាទាំងនោះ មកហើយក្នុងអភិធម្មនោះឯង ។ អធិប្បាយថា ការធ្វើឲ្យជាក់ច្បាស់ប្រចក្សនូវបដិសម្ភិទាទាំង ៤ នេះ រមែងមានក្នុងពុទ្ធុប្បាទកាល ។ ការធ្វើឲ្យជាក់ច្បាស់នូវបដិសម្ភិទានោះ វៀរពុទ្ធុប្បាទកាលចេញ រមែងមិនមាន ។ បដិសម្ភិទាទាំងនេះ

គប្បីជ្រាបថា លោកពោលថា កើតបានទាំងលោកិយ និងលោកុត្តរ ។

បទថា **អនេកធាតុប្បដិវេធោ** សេចក្តីថា ការចាក់ធ្លុះនូវធាតុ ១៨ មានពាក្យថា ចក្ខុធាតុ រូបធាតុ ដូច្នេះជាដើម រមែងមានក្នុងពុទ្ធុប្បាទកាល ប៉ុណ្ណោះ វៀរពុទ្ធុប្បាទកាលចេញ រមែងមិនមាន ។ ក្នុងបទថា **នានាធាតុប្បដិវេធោ ហោតិ** ការចាក់ធ្លុះនូវធាតុផ្សេងៗ ទើបមាននេះ ធាតុ ១៨ នេះឯង គប្បីជ្រាបថា នានាធាតុ ព្រោះមានសភាវៈផ្សេងៗ ។ ការចាក់ធ្លុះណានូវធាតុទាំងនោះ ដោយហេតុផ្សេងៗ យ៉ាងនេះថា ធាតុទាំងនេះ មានសភាវៈផ្សេងគ្នាក្នុងសេចក្តីនេះ នេះឈ្មោះថា ការចាក់ធ្លុះនូវធាតុផ្សេងៗ ។

បទថា **វិជ្ជា** ក្នុងបទថា **វិជ្ជាវិមុត្តិផលសច្ឆិកិរិយា** នេះ បានដល់ផលញ្ញាណ ។ បទថា **វិមុត្តិ** បានដល់ ធម៌ដែលសម្បយុត្តដោយសោតាបត្តិផល ក្រៅអំពីវិជ្ជានោះ ។ បទថា **សោតាបត្តិផលសច្ឆិកិរិយា** សេចក្តីថា បឋមមគ្គ ឈ្មោះថា សោត ។ ឈ្មោះថា សោតាបត្តិផល ព្រោះជាផលដែលបុគ្គលគប្បីសម្រេចដោយសោតនោះ ។ សកទាគាមិផលជាដើមប្រាកដច្បាស់ហើយនោះឯង ។

[ ១៤៥ ] បទថា **អនុត្តរំ** ប្រែថា កំពូល ។ បទថា **ធម្មចក្កំ** បានដល់ ចក្រដ៏ប្រសើរ ។ ពិតហើយ **ចក្ក** សព្ទនេះ មកក្នុងអត្ថថា **ឧរចក្រ** គឺចក្រប្រហារជីវិត ក្នុងដូចក្នុងប្រយោគជាដើមថា

**ចតុព្ភិ អដ្ឋជ្ឈគមា អដ្ឋាភិ ចេវ សោឡស្ស**
**សោឡសាភិ ច ពាត្តឹស្ស អត្រិច្ឆំ ចក្កមាសទោ**

**ឥច្ឆាហតស្ស បោសស្ស ចក្កំ ភមតិ មត្ថកេ។**

អ្នក ( ចេញ ) អំពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨ ( ចេញ ) អំពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦ ( ចេញ ) អំពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២ ( ក៏នៅតែមិនស្កប់ស្កល់ ) ចក្រក៏វិលលើក្បាលនៃបុរស កាលប្រាថ្នាក្នុងទីនោះៗ ទើបមកដល់កងចក្រ កងចក្ររមែងវិលលើក្បាលបុគ្គលដែលមានសេចក្ដីប្រាថ្នាគ្របសង្កត់ ។

ចក្ក មកក្នុងអត្ថថា ឥរិយាបថ ដូចក្នុងប្រយោគជាដើមថា **ចតុចក្កំ នវទ្វារំ** សរីរៈមានចក្ក ៤ មានទ្វារ ៩ ។

ចក្ក មកក្នុងអត្ថថា **ទារុច** ( ចក្កឈើ ) ដូចក្នុងប្រយោគជាដើមថា **អថខោ សោ ភិក្ខវេ រថការោ យំតំ ចក្កំ ឆហិ ទិវសេហិ និដ្ឋិតំ តំ បវត្តេសិ** ម្នាលភិក្ខុទាំងឡាយ លំដាប់នោះឯង ជាងរថបង្វិលចក្កដែលធ្វើឲ្យសម្រេចអស់ត្រឹម ៦ ថ្ងៃឲ្យវិលទៅ[១] ចក្ក មកក្នុងអត្ថថា លក្ខណៈ ដូចក្នុងប្រយោគជាដើមថា **អទ្ទសា ខោ ទោណោ ព្រាហ្មណោ ភគវតោ បាទេសុ ចក្កានិ សហស្សារានិ** ទោណព្រហ្មក៏បានឃើញកងចក្រទាំងឡាយ ( ដែលមានកាំ ) មួយពាន់ ក្នុងស្នាមព្រះបាទទាំងគូរបស់ព្រះដ៏មានព្រះភាគ ។ ចក្ក មកក្នុងអត្ថថា សម្បត្តិ ដូចក្នុងប្រយោគជាដើមថា **ចត្តារិមានិ ភិក្ខវេ ចក្កានិ យេហិ សមន្នាគតានំ ទេវមនុស្សានំ ចតុចក្កំ បវត្តតិ** ម្នាលភិក្ខុទាំងឡាយចក្កនេះមាន ៤ ចក្ក ៤ តែងប្រព្រឹត្តទៅ ( ដើម្បីជាប្រយោជន៍ )

---

១- បិដកខ្មែរលេខ ៤១ ទំព័រ ២៦ ។

ដល់ពួកទេវតា និងមនុស្ស ដែលប្រកបដោយចក្ក ។ ចក្ក មកក្នុងអត្ថថា រតនៈ ដូចក្នុងប្រយោគជាដើមថា **ទិព្វំ ចក្ករតនំ បាតុភវតិ** ចក្ក គឺ រតនៈដ៏ជាទិព្វប្រាកដ ។ តែក្នុងទីនេះចុះក្នុងអដ្ឋថា ធម្មចក្រ ។

ក្នុងបទថា **បវត្តិតំ** នេះ គប្បីជ្រាបប្រភេទដូច្នេះថា ឈ្មោះថា កំពុងប្រាថ្នាយ៉ាងពិតប្រាកដនូវព្រះធម្មចក្រ ធម្មចក្រ ឈ្មោះថា ប្រាថ្នាយ៉ាងពិតប្រាកដហើយ ឈ្មោះថា កំពុងធ្វើព្រះធម្មចក្រឲ្យកើតឡើង ព្រះធម្មចក្រឈ្មោះថា ទ្រង់ធ្វើឲ្យកើតឡើងហើយ ឈ្មោះថា កំពុងប្រកាសធម្មចក្រ ធម្មចក្រ ឈ្មោះថា ទ្រង់ប្រកាសហើយ ។

ឈ្មោះថា កំពុងប្រាថ្នាយ៉ាងក្រៃលែងនូវព្រះធម្មចក្រ តាំងអំពីកាលណា កាលដែលព្រះអង្គនៅជាសុមេធព្រាហ្មណ៍ ឃើញទោសក្នុងកាមទាំង-ឡាយ និងអានិសង្សក្នុងនេក្ខម្មៈ ថ្វាយសត្តសតកមហាទាន ហើយបួសជាឥសី ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើត តាំងអំពីនោះមក ឈ្មោះថា កំពុងប្រាថ្នាយ៉ាងពិតប្រាកដនូវព្រះធម្មចក្រ ។

ឈ្មោះថា ប្រាថ្នាយ៉ាងពិតប្រាកដហើយ តាំងអំពីអន្លាល់ណា ។ កាលព្រះអង្គប្រជុំធម៌ ៨ ប្រការ ហើយទ្រង់ចងចិត្តដើម្បីប្រយោជន៍ដល់ការធ្វើព្រះមហាពោធិញ្ញាណឲ្យជួរផង់ ទៀបបាទមូលនៃព្រះពុទ្ធ ព្រះនាមទីបង្ករ ទ្រង់អធិដ្ឋានព្រះវីរិយៈថា បើអាត្មាអញមិនបានទទួលព្យាករ នឹងមិនក្រោកឡើង ទើបក្រាបចុះ បានទទួលព្យាករអំពីសម្នាក់ព្រះទសពលហើយ តាំងអំពីនោះមក ធម្មចក្រ ឈ្មោះថា ប្រាថ្នាយ៉ាងពិតប្រាកដហើយ ។

ឈ្មោះថា កំពុងឲ្យធម្មចក្រកើតឡើងតាំងពីពេលណា តាំងអំពីទ្រង់បំពេញទានបារមី ឈ្មោះថា កំពុងញ៉ាំងធម្មចក្រឲ្យកើតឡើង ។ កាលទ្រង់បំពេញសីលបារមីក្តី ។បេ។ ទ្រង់បំពេញឧបបារមីក្តី ឈ្មោះថា កំពុងញ៉ាំងធម្មចក្រឲ្យកើតឡើង កាលទ្រង់បំពេញបារមី ១០ ឧបបារមី ១០ បរមត្ថបារមី ១០ ក្តី កាលទ្រង់បំពេញមហាបរិច្ចាគ ៥ ក្តី កាលទ្រង់បំពេញញាតត្ថចរិយាក្តី ឈ្មោះថា ទ្រង់ញ៉ាំងធម្មចក្រឲ្យកើតឡើង ។ ទ្រង់នៅក្នុងភាវៈជាព្រះវេស្សន្តរ ទ្រង់ថ្វាយសត្តសតកមហាទាន ទ្រង់ដាក់ទានបុត្រនិងភរិយា ក្នុងទានមុខ ទ្រង់កាន់យកកំពូល គឺបារមីកើតក្នុងស្ថានសួគ៌ ជាន់តុសិត ទ្រង់តាំងនៅក្នុងតុសិតនោះ រហូតអស់ព្រះជន្ម ដែលទេវតាទូលអារាធនាហើយ ក៏ឲ្យនូវបដិញ្ញា ទ្រង់ពិចារណាមើលនូវមហាវិលោកនៈ ៥ ឈ្មោះថា កំពុងញ៉ាំងធម្មចក្រឲ្យកើតឡើងដូចគ្នា ។ កាលទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះមាតាក្តី កាលទ្រង់ធ្វើចក្កវាឡមួយម៉ឺនឲ្យញាប់ញ័រ ក្នុងខណៈបដិសន្ធិក្តី កាលទ្រង់ធ្វើលោកឲ្យញាប់ញ័រយ៉ាងនោះឯង ក្នុងថ្ងៃយាងចេញអំពីព្រះគភ៌របស់មាតាក្តី កាលប្រសូតភ្លាមនោះឯង ទ្រង់ឈានទៅ ៧ ជំហាន ទ្រង់បន្លឺសីហនាទថា យើងជាអគ្គបុគ្គលក្តី កាលទ្រង់នៅគ្រប់គ្រងផ្ទះអស់ ២៩ ឆ្នាំក្តី យាងចេញដើម្បីស្វែងរកគុណធំក្តី ទ្រង់បព្វជ្ជាត្រង់ឆ្នេរស្ទឹងអនោមានទីក្តី ទ្រង់ធ្វើមហាបធាន ៦ វស្សាក្តី សោយមធុបាយាសដែលនាងសុជាតាថ្វាយ ហើយទ្រង់បណ្តែតថាសមាសក្នុងស្ទឹង ហើយយាងទៅកាន់ពោធិមណ្ឌលដ្ឋានដ៏ប្រសើរ ក្នុងពេលល្ងាច ប្រថាប់គង់មើលលោក-

ជាតុទិសខាងកើត ទ្រង់កម្ចាត់មារ និងសេនា ក្នុងកាលព្រះអាទិត្យមិនទាន់លិចនោះឯង ទ្រង់រម្លឹកដល់បុព្វេនិវាសញ្ញាណក្នុងបឋមយាមក្តី ជម្រះទិព្វចក្ខុក្នុងមជ្ឈិមយាមក្តី ទ្រង់ពិចារណាបច្ចយាការក្នុងវេលាជាប់គ្នា រហូតដល់ជិតភ្លឺ ហើយទ្រង់ត្រាស់ដឹងសោតាបត្តិមគ្គក្តី ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលក្តី ទ្រង់ធ្វើឲ្យជាក់ច្បាសនូវសកទាគាមិមគ្គ សកទាគាមិផល អនាគាមិមគ្គ អនាគាមិផលក្តី កាលទ្រង់ចាក់ធ្លុះអរហត្តមគ្គក្តី ឈ្មោះថា កំពុងធ្វើធម្មចក្រឲ្យកើតឡើងដូចគ្នា ។

ធម្មចក្រ ឈ្មោះថា ព្រះអង្គទ្រង់ឲ្យកើតឡើងហើយ ក្នុងខណៈនៃព្រះអរហត្តផល ។ ពិតហើយ គុណរាសី គឺគំនរនៃគុណទាំងអស់ព្រះពុទ្ធទាំងឡាយ រមែងសម្រេចព្រមជាមួយនឹងអរហត្តផលនោះឯង ។ ព្រោះដូច្នោះទើបធម្មចក្រនោះ ឈ្មោះថា ទ្រង់ឲ្យកើតហើយ ក្នុងខណៈនោះ ។

ព្រះអង្គទ្រង់ប្រកាសធម្មចក្រអំពីពេលណា ។ កាលទ្រង់សម្រាកសម្រាន្តនៅអស់ ៧ សប្តាហ៍ ក្នុងពោធិមណ្ឌលដ្ឋាន ទ្រង់សម្តែងធម្មចក្កប្បវត្តនសូត្រ ធ្វើព្រះអញ្ញាកោណ្ឌញ្ញត្ថេរឲ្យជាកាយសក្ខី ត្រង់ឥសិបតនមិគទាវ័ន ឈ្មោះថា ទ្រង់ប្រកាសធម្មចក្រ ។

ក្នុងកាលណាព្រះអញ្ញាកោណ្ឌញ្ញត្ថេរបាននូវការស្តាប់ ដែលកើតដោយអានុភាពនៃទេសនាញាណរបស់ព្រះទសពល ហើយសម្រេចធម៌មុនបុគ្គលណាទាំងអស់ ចាប់ពីកាលនោះមក គប្បីជ្រាបថា ធម្មចក្រ ឈ្មោះថា ទ្រង់ប្រកាសហើយ ។

ពិតហើយ ពាក្យថា ធម្មចក្រ នេះជាឈ្មោះនៃទេសនាញាណខ្លះ ជាឈ្មោះនៃបដិវេធញ្ញាណខ្លះ ។ ក្នុង ២ យ៉ាងនោះ ទេសនាញាណជាលោកិយ បដិវេធញ្ញាណជាលោកុត្តរ ។ សួរថា ទេសនាញាណ បដិវេធញ្ញាណ ជារបស់អ្នកណា ឆ្លើយថា មិនមែនរបស់អ្នកណាដទៃ គប្បីជ្រាបថា ទេសនាញាណ និងបដិវេធញ្ញាណ ជារបស់ព្រះសម្មាសម្ពុទ្ធប៉ុណ្ណោះ ។

បទថា **សម្មទេវ** បានដល់ ដោយហេតុ គឺដោយន័យ ដោយការណ៍នោះឯង ។ បទថា **អនុប្បវត្តេតិ** សេចក្តីថា ព្រះថេរៈឈ្មោះថា រមែងប្រកាសតាមធម្មចក្រ ដែលព្រះសាស្តាទ្រង់ប្រកាសមុនហើយ ដូចកាលព្រះសាស្តាយាងទៅខាងមុខ ព្រះថេរៈដើរទៅខាងក្រោយ ឈ្មោះថា ដើរតាមព្រះសាស្តា ដូច្នោះ ។ សួរថា ប្រកាសតាមដូចម្តេច ឆ្លើយថា ព្រះសាស្តាកាលទ្រង់សម្តែងថា ម្នាលភិក្ខុទាំងឡាយ សតិប្បដ្ឋាន ៤ នេះ សតិប្បដ្ឋាន ៤ តើដូចម្តេច ឈ្មោះថា ទ្រង់ប្រកាសធម្មចក្រ ។ ព្រះធម្មសេនាបតី-សារីបុត្រនោះឯង កាលសម្តែងថា នៃអាវុសោ សតិប្បដ្ឋានមាន ៤ នេះ ឈ្មោះថា ប្រកាសតាមនូវធម្មចក្រ ។ សូម្បីក្នុងសម្មប្បធានជាដើម ក៏ន័យនេះដូចគ្នា ។ មិនមែនតែក្នុងពោធិបក្ខិយធម៌តែម្យ៉ាងប៉ុណ្ណោះឡើយ សូម្បីក្នុងពាក្យថា ម្នាលភិក្ខុទាំងឡាយ អរិយសច្ច ៤ នេះ អរិយវង្ស ៤ នេះ ជាដើម គប្បីជ្រាបន័យនេះដូចគ្នា ។ ដោយប្រការដូចពោលមកនេះ ព្រះសម្មាសម្ពុទ្ធ ឈ្មោះថា ទ្រង់ប្រកាសធម្មចក្រ ព្រះថេរៈឈ្មោះថា ប្រកាសតាមព្រះធម្មចក្រ ដែលព្រះទសពលទ្រង់ប្រកាសហើយ ។

ព្រះធម៌ ដែលព្រះថេរៈប្រកាសតាមធម្មចក្រយ៉ាងនេះ សម្តែងហើយក្តី ប្រកាសហើយក្តី រមែងឈ្មោះថា ព្រះសាស្តាទ្រង់សម្តែងហើយ ប្រកាសហើយនោះឯង ។ បុគ្គលឯណានីមួយ ទោះជាភិក្ខុក្តី ភិក្ខុនីក្តី ឧបាសកក្តី ឧបាសិកាក្តី ជាទេវតាក្តី ជាសក្កៈក្តី ជាមារ ឬជាព្រហ្មក្តី សម្តែងធម៌ ធម៌ទាំងអស់នោះ ឈ្មោះថា ព្រះសាស្តាទ្រង់សម្តែងហើយ ទ្រង់ប្រកាសហើយ ឯជនក្រៅអំពីនោះ ឈ្មោះថា តាំងនៅក្នុងចំណែកនៃបុគ្គលដែលដើរតាមស្នាម សេចក្តីនេះដូចម្តេច ឧបមាដូចជនទាំងឡាយ អានព្រះរាជហស្តលេខា ដែលព្រះរាជាទ្រង់ប្រទាន ហើយធ្វើការងារណាមួយ ការងារនោះៗ ទោះបុគ្គលណាមួយ ធ្វើឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ក៏ហៅថា ព្រះរាជាឲ្យធ្វើទាំងអស់ដូចគ្នា សេចក្តីពិត ព្រះសម្មាសម្ពុទ្ធ ដូចព្រះរាជាធំ ។ ព្រះពុទ្ធវចនៈ គឺបិដក ៣ ដូចព្រះរាជហស្តលេខា ការឲ្យដោយមុខ គឺន័យក្នុងព្រះត្រៃបិដក ដូចការដែលទ្រង់ព្រះរាជទានស្នាមព្រះហស្តលេខា ។ ការឲ្យបរិស័ទ ៤ រៀនពុទ្ធវចនៈតាមកម្លាំងរបស់ខ្លួន ហើយសម្តែងប្រកាសដល់ជនដទៃ ដូចអានព្រះហស្តលេខាហើយធ្វើការងារ ។ ក្នុងធម៌ទាំងនោះ ធម៌ដែលបុគ្គលណាម្នាក់សម្តែងក្តី ប្រកាសក្តី គប្បីជ្រាបថា ឈ្មោះថា ធម៌ដែលព្រះសាស្តាសម្តែងហើយ ប្រកាសហើយ ដូចបុគ្គលណាម្នាក់អានព្រះហស្តលេខា ធ្វើការងារណាមួយដោយខ្លួនឯងក្តី ឲ្យអ្នកដទៃធ្វើក្តី ការងារនោះៗ ឈ្មោះថា ព្រះរាជាប្រើឲ្យធ្វើហើយដូចគ្នា ។ ពាក្យដ៏សេសក្នុងបទទាំងពួង ងាយយល់ទាំងអស់ហើយ ៕

**អដ្ឋកថា សូត្រទី ៦ ជាដើម ចប់**

**ឯកបុគ្គលវគ្គទី ១៣ ចប់**

# សុត្តន្តបិដក

# ឯតទគ្គបាលិវគ្គទី ៤

## វគ្គទី ១

[ ១៤៦ ] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវ័ករបស់តថាគត ស្រេចនឹងអញ្ញាកោណ្ឌញ្ញៈប្រសើរជាងគេ ។ បណ្តាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងសារីបុត្ត ។ ពួកភិក្ខុអ្នកមានឫទ្ធិ ស្រេចនឹងមហាមោគ្គល្លាន ។ ពួកភិក្ខុអ្នកពោលពាក្យកម្ចាត់បង់កិលេស ស្រេចនឹងមហាកស្សបៈ ។ ពួកភិក្ខុអ្នកមានទិព្វចក្ខុស្រេចនឹងអនុរុទ្ធ ។ ពួកភិក្ខុអ្នកមានត្រកូលខ្ពស់ ស្រេចនឹងភទ្ទិយកាឡិគោធាយបុត្ត ។ ពួកភិក្ខុអ្នកមានសំឡេងពីរោះ ស្រេចនឹងលកុណ្តកភទ្ទិយៈ ។ ពួកភិក្ខុអ្នកបន្លឺសីហនាទ ស្រេចនឹងបិណ្ឌោលភារទ្វាជៈ ។ ពួកភិក្ខុជាធម្មកថិក ស្រេចនឹងបុណ្ណមន្តានីបុត្ត ។ ពួកភិក្ខុអ្នកចែកសេចក្តីធម៌ដែលតថាគត សម្តែងដោយសង្ខេបឲ្យពិស្តារបាន ស្រេចនឹងមហាកច្ចានៈ ។

វគ្គទី ១ ចប់

# អដ្ឋកថា

# ឯកនិបាតវគ្គទី ៤

## វគ្គទី ១

## សូត្រទី ១

[ ១៤៦ ] ក្នុងសូត្រទី ១ វគ្គទី ១ នៃឯកទុកវគ្គ គប្បីជ្រាបវិនិច្ឆ័យដូចតទៅ បទថា **ឯកទគ្គំ** កាត់បទជា **ឯតំ អគ្គំ ។ អគ្គ** សព្ទនេះ ក្នុងបទថា **ឯតទគ្គំ** នោះ ប្រាកដក្នុងអត្ថថា ខាងដើម ខាងចុង ចំណែក និងប្រសើរបំផុត ។ **អគ្គ** សព្ទ ប្រាកដក្នុងអត្ថថា ខាងដើម ដូចក្នុងប្រយោគជាដើមថា **អជ្ជតគ្គេ សម្ម ទោវារិក អាវរាមិ ទ្វារំ និគណ្ឋានំ** ម្នាលអ្នករក្សាទ្វារជាសម្លាញ់ ពីថ្ងៃនេះជាដើមរៀងទៅ ខ្ញុំបិទទ្វារចំពោះពួកនិគ្រន្ថ ។

មកក្នុងអត្ថថា ខាងចុង ដូចក្នុងប្រយោគជាដើមថា **តេនេវ អង្គុលគ្គេន តំ អង្គុលគ្គំ បរាមសេយ្យ ឧច្ឆុគ្គំ វេឡគ្គំ** បុគ្គលស្ទាបអង្អែលចុងអំពៅ ចុងឫស្សី ដោយម្រាមដៃនោះឯង ។

មកក្នុងអត្ថថា ចំណែក ដូចក្នុងប្រយោគជាដើមថា **អម្ពិលគ្គំ វា មធុរគ្គំ វា តិត្តកគ្គំ វា អនុជានាមិ ភិក្ខវេ វិហារគ្គេន វា បរិវេណគ្គេន វា ភាជេតុំ** ម្នាលភិក្ខុទាំងឡាយ តថាគតអនុញ្ញាតឲ្យរំលែកអំពីចំណែករបស់ដែលមានរសជូរ ដែលមានរសផ្អែម ឬរបស់ដែលមានរសល្វីង តាមចំណែកវិហារ ឬតាមចំណែកបរិវេណ ។

មកក្នុងអត្ថថា ប្រសើរបំផុត ដូចក្នុងប្រយោគជាដើមថា **យាវតា ភិក្ខវេ សត្តា អបទា វា ។បេ។ តថាគតោ តេសំ អគ្គមក្ខាយតិ** ម្នាល ភិក្ខុទាំងឡាយ ពួកសត្វទាំងប៉ុន្មាន ដែលជាសត្វមិនមានជើងក្តី ។បេ។ ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ ប្រាកដជាប្រសើរជាងពួកសត្វទាំងនោះ ។

ក្នុងទីនេះ **អគ្គ** សព្ទនេះ រមែងប្រើបាន ទាំងក្នុងអត្ថថា ចុង ទាំងក្នុងអត្ថថា ប្រសើរបំផុត ។ ពិតហើយ ព្រះថេរៈទាំងនោះ ឈ្មោះថា **អគ្គ** ជាទីបំផុតខ្លះ ព្រោះប្រសើរបំផុតខ្លះ ក្នុងតំណែងដ៏ប្រសើរបំផុតរៀងៗ ខ្លួន ព្រោះដូច្នោះ អត្ថក្នុងបទថា **ឯតទគ្គំ** នេះ មានដូច្នេះថា នេះជាទីបំផុត នេះប្រសើរបំផុត ។ ក្នុងសូត្រទាំងពួង ក៏មានន័យនេះដូចគ្នា ។

ធម្មតាការតែងតាំងក្នុងតំណែងឯតទគ្គៈនេះ រមែងបានដោយហេតុ ៤ ប្រការ គឺដោយអត្ថុប្បត្តិហេតុ ១ ដោយការមកអំពីមុន ១ ដោយភាពជាអ្នកជំនាញ ១ ដោយភាពជាអ្នកក្រៃលែងដោយគុណ ១ ក្នុងហេតុ ៤ យ៉ាងនោះ ព្រះថេរៈរូបខ្លះ រមែងបានតំណែងឯតទគ្គៈដោយហេតុ ១ រូបខ្លះដោយហេតុ ២ រូបខ្លះបានដោយហេតុ ៣ រូបខ្លះបានដោយហេតុទាំង ៤ នោះឯង ដូចព្រះសារីបុត្រជាដើម ។ ពិតហើយ ព្រះសារីបុត្តត្ថេរនោះ បានតំណែងឯតទគ្គៈ ព្រោះជាអ្នកមានបញ្ញាច្រើនផង ដោយអត្ថុប្បត្តិហេតុផង ដោយហេតុ គឺការមកពីមុនផង ។ សេចក្តីនេះដូចម្តេច សម័យមួយ ព្រះសាស្តាប្រថាប់គង់នៅក្នុងវត្តជេតពន ទ្រង់សម្តែងយមកប្បាដិហារ្យ ធ្វើពួក

តិរិយឲ្យរាបទាប ត្រង់គល់គណ្ឌាម្ពព្រឹក្ស គឺស្វាយក្រអូប ទ្រង់ត្រិះរិះថា ព្រះពុទ្ធក្នុងអតីតកាល ទ្រង់ធ្វើយមកបា្បដិហារ្យ ហើយចូលចាំវស្សា ក្នុងទីណាហ្ន៎ ក៏ទ្រង់ជ្រាបថា ក្នុងតាវត្តិង្សពិភព ទ្រង់សម្តែងស្នាមព្រះបាទទុក ២-៣ ស្នាម នាស្ថានតាវត្តិង្ស សក្កទេវរាជបានទតឃើញព្រះមានព្រះភាគ ក្រោកអំពីបណ្ឌុកម្ពលសិលាអាសនៈ យាងទៅទទួល មួយអន្លើដោយពួកទេវតា ។ ទេវតាទាំងឡាយគិតគ្នាថា សក្កទេវរាជ ហែហមទៅដោយពួកទេវតា ប្រថាប់គង់លើបណ្ឌុកម្ពលសិលាអាសនៈ ប្រវែង ៦០ យោជន៍ សោយមហាសម្បត្តិ ។ ចាប់តាំងអំពីព្រះពុទ្ធទាំងឡាយប្រថាប់គង់ហើយ ជនដទៃមិនអាចដាក់សូម្បីតែដៃ លើព្រះទែននេះបាន ចំណែកព្រះសាស្តាប្រថាប់គង់ក្នុងទីនោះហើយ ទ្រង់ជ្រាបវារៈចិត្តរបស់ពួកទេវតាទាំងនោះហើយ គង់ប្រថាប់ពេញថ្មបណ្ឌុកម្ពលសិលាអាសនៈទាំងអស់ ដូចបុគ្គលដែលទ្រទ្រង់សំពត់មហាបង្សុកូល អង្គុយពេញតាំងតូច ដូច្នោះ ។

តែបុគ្គលណាម្នាក់ មិនគួរកំណត់ថា ព្រះសាស្តាកាលប្រថាប់គង់យ៉ាងនេះ ទ្រង់និម្មិតព្រះសរីរៈរបស់ព្រះអង្គឲ្យធំ ឬទ្រង់ធ្វើបណ្ឌុកម្ពលសិលា-អាសនៈឲ្យតូច ។ ព្រោះថា ពុទ្ធវិស័យជាអចិន្តេយ្យ លុះព្រះអង្គប្រថាប់គង់យ៉ាងនេះហើយ ធ្វើព្រះមាតាឲ្យជាកាយសក្ខីប្រចក្សជាបន្ទាល់ ទ្រង់ផ្តើមសម្តែងអភិធម្មបិដកជាដើមថា **កុសលា ធម្មា អកុសលា ធម្មា** ប្រោសទេវតាក្នុងម៉ឺនចក្កវាឡ ។

ក្នុងទីដែលទ្រង់ធ្វើយមកបា្បដិហារ្យ បរិស័ទទាំងអស់ប្រមាណ ១២

យោជន៍ ចូលទៅរកព្រះអនុរុទ្ធ សួរថា លោកដ៏ចម្រើន ព្រះទសពលប្រថាប់នៅក្នុងទីណា ព្រះអនុរុទ្ធឆ្លើយថា ព្រះទសពលចាំវស្សាក្នុងបណ្ឌុកម្ពលសិលាអាសនៈ ក្នុងតាវត្តិង្សពិភព សម្ដែងអភិធម្មបិដក បរិស័ទសួរថា បពិត្រលោកម្ចាស់ ពួកខ្ញុំមិនឃើញព្រះសាស្ដា ក៏នឹងមិនត្រឡប់ទៅ សូមលោកម្ចាស់ទាំងឡាយ ដឹងកាលដែលព្រះសាស្ដាយាងមកថា តើកាលណាព្រះសាស្ដាយាងមក ។ ព្រះអនុរុទ្ធពោលថា ពួកអ្នកចូរទុកនាទីដល់មហាមោគ្គល្លានត្ថេរចុះ លោកទៅគាល់ព្រះសម្មាសម្ពុទ្ធហើយ នឹងនាំដំណឹងមក ។ បរិស័ទសួរថា កម្លាំងរបស់ព្រះថេរៈដែលនឹងទៅក្នុងទីនោះ មិនមានឬ ព្រះអនុរុទ្ធពោលយ៉ាងនេះថា មាន ។ តែសូមបរិស័ទមើលគុណវិសេសចុះ ។ មហាជនចូលទៅរកព្រះមហាមោគ្គល្លានត្ថេរ អង្វរសូមឲ្យលោកទទួលដំណឹងរបស់ព្រះសាស្ដាយាងមក ។ កាលមហាជនកំពុងឃើញនោះឯង ព្រះថេរៈក៏មុជក្នុងមហាប្រឹថពី ទៅខាងក្នុងភ្នំព្រះសិនេរុ ថ្វាយបង្គំព្រះសាស្ដាទូលថា បពិត្រព្រះអង្គដ៏ចម្រើន មហាជនមានបំណងគាល់ព្រះអង្គ ចង់ដឹងថ្ងៃដែលព្រះអង្គយាង ។ ព្រះសាស្ដាត្រាស់ថា បើយ៉ាងនោះ អ្នកចូរប្រាប់ថា អ្នកទាំងឡាយចូរឃើញតថាគតត្រង់ទ្វារក្រុងសង្កស្សៈ ។ ចំណែកព្រះសាស្ដា ទ្រង់សម្ដែងធម៌ ៧ គម្ពីរ ហើយទ្រង់សម្ដែងអាការ ដើម្បីយាងត្រឡប់មកកាន់មនុស្សលោក ។ សក្កទេវរាជត្រាស់ហៅវិស្សុកម្មទេវបុត្រមក មានទេវឱង្ការឲ្យនិម្មិតជណ្ដើរដើម្បីព្រះតថាគតយាងចុះ វិស្សុកម្មទេវបុត្រ និម្មិតជណ្ដើរមាសម្ខាង ជណ្ដើរប្រាក់ម្ខាង ហើយនិម្មិតជណ្ដើរកែវមណីត្រង់កណ្ដាល ។ ព្រះ

សាស្តាប្រថាប់លើជណ្តើរកែវមណី ទ្រង់អធិដ្ឋានថា ចូរមហាជនឃើញតថាគត ទ្រង់អធិដ្ឋានដោយអានុភាពរបស់ព្រះអង្គថា ចូរមហាជនឃើញអវីចីមហានរក ទ្រង់ជ្រាបថា មហាជនកើតការសង្វេគ ព្រោះឃើញនរក ទើបទ្រង់បង្ហាញទេវលោក ។ លំដាប់នោះ កាលទ្រង់យាងចុះ មហាព្រហ្មបាំងឆត្រ សក្កទេវរាជទ្រង់កាន់បាត្រ សុយាមទេវរាជបក់ផ្លិតវាលវីជនីជាទិព្វ បញ្ច-សិខគន្ធព្វទេវបុត្រដេញពិណពណ៌លឿង ដូចផ្លែព្នៅឲ្យរណ្តំ ដោយមុច្ឆនាសំឡេង ប្រជុំគ្នាចំនួន ៥០ ដង្ហែព្រះមានព្រះភាគចុះមក ។ ក្នុងវេលាដែលព្រះសម្ពុទ្ធប្រថាប់ឈរលើផែនដី មហាជនអធិដ្ឋានថា អាត្មាអញនឹងថ្វាយបង្គំមុនគេ ព្រមដោយការជាន់មហាប្រឹថពី របស់ព្រះមានព្រះភាគ ទាំងមហាជនទាំងព្រះអសីតិមហាសាវក មិនទាន់បានថ្វាយបង្គំព្រះមានព្រះភាគនៅឡើយ ។ ព្រះធម្មសេនាបតីសារីបុត្រប៉ុណ្ណោះ បានទាន់ក្នុងការថ្វាយបង្គំ ។

តាំងអំពីនោះកន្លងទៅ ៣ ខែ ព្រះថេរៈនាំដំណឹងរបស់ព្រះមានព្រះភាគមកប្រាប់ដល់មហាជន ។ មហាជនបោះជំរំ តាំងនៅក្នុងទីនោះឯង ៣ ខែ ។ ចូឡអនាថបិណ្ឌិកសេដ្ឋីបានឲ្យ និងប្រគេនបបរ និងភត្ត ដល់បរិស័ទប្រមាណ ១២ យោជន៍ អស់កាល ៣ ខែ ។

លំដាប់នោះ ព្រះសាស្តាទ្រង់ផ្តើមបុថុជ្ជនបញ្ហកបញ្ហា ក្នុងវាងបរិស័ទ ១២ យោជន៍ ដោយបំណងថា ចូរមហាជនដឹងអានុភាពបញ្ញារបស់ព្រះថេរៈ ដំបូងត្រាស់សួរបុថុជ្ជន ដោយបំណងថា លោកិយមហាជន នឹងកំណត់បាន ជនពួកណាកំណត់បាន ជនទាំងនោះ ក៏ឆ្លើយបាន ក្នុងគ្រាទី ២ ត្រាស់សួរ

បញ្ហាក្នុងសោតាបត្តិមគ្គ កន្លងបង់នូវវិស័យបុថុជ្ជន ។ បុថុជ្ជនទាំងឡាយ ក៏នៅស្ងៀម ព្រះសោតាបន្នប៉ុណ្ណោះឆ្លើយបាន ។ លំដាប់នោះ ទើបត្រាស់សួរបញ្ហាក្នុងសកទាគាមិមគ្គ កន្លងវិស័យព្រះសោតាបន្ន ។ ព្រះសោតាបន្ន ក៏ស្ងៀម ។ ព្រះសកទាគាមិបុគ្គលប៉ុណ្ណោះឆ្លើយបាន ។ ត្រាស់សួរបញ្ហា ក្នុងអនាគាមិមគ្គ កន្លងវិស័យនៃព្រះសកទាគាមិបុគ្គលទាំងនោះ ព្រះសកទាគាមិបុគ្គលក៏នៅស្ងៀម ។ ព្រះអនាគាមិបុគ្គលប៉ុណ្ណោះឆ្លើយបាន ។ ត្រាស់សួរបញ្ហាក្នុងអរហត្តមគ្គ កន្លងវិស័យរបស់អនាគាមិបុគ្គលទាំងនោះ ។ ព្រះអនាគាមីក៏នៅស្ងៀម ។ ព្រះអរហន្តប៉ុណ្ណោះឆ្លើយបាន ។ តាំងអំពីកំណួចបញ្ហាខាងក្រោយជាងនោះ ត្រាស់សួរព្រះសាវ័កដែលដឹងក្រៃលែង ។ ព្រះសាវ័កទាំងនោះតាំងនៅក្នុងវិស័យនៃបដិសម្ភិទារៀងៗ ខ្លួន ក៏ឆ្លើយបាន ។ គ្រានោះទើបត្រាស់សួរព្រះមហាមោគ្គល្លានត្ថេរ ព្រះសាវ័កក្រៅពីនោះ ក៏ស្ងៀម ព្រះថេរៈប៉ុណ្ណោះឆ្លើយបាន ។ ទ្រង់កន្លងវិស័យរបស់ព្រះថេរៈនោះ ត្រាស់សួរប្រស្នាក្នុងវិស័យរបស់ព្រះសារីបុត្រ ព្រះមហាមោគ្គល្លាននៅស្ងៀម ព្រះសារីបុត្រប៉ុណ្ណោះឆ្លើយបាន ។ ទ្រង់កន្លងវិស័យរបស់ព្រះថេរៈ ត្រាស់សួរបញ្ហាក្នុងពុទ្ធវិស័យ ព្រះធម្មសេនាបតីសូម្បីនឹកគិតក៏មិនអាចឃើញ សម្លឹងមើលក្នុងទិសជុំវិញ គឺទិសធំ ៤ មានទិសខាងកើត ខាងលិច ខាងជើង ខាងត្បូង និងទិសតូចទាំង ៤ ក៏មិនអាចកំណត់ស្ថាន ទីកើតបញ្ហាបាន ។

ព្រះសាស្តាទ្រង់ជ្រាបថា ព្រះថេរៈលំបាក ទើបទ្រង់ត្រិះរិះថា សារីបុត្រលំបាក តថាគតនឹងបង្ហាញគន្លងដល់សារីបុត្រ ទើបត្រាស់ថា ម្នាលសារីបុត្រ

អ្នកចូរបន្អន់សិន ហើយត្រាស់ប្រាប់ថា បញ្ហានោះ ជាវិស័យរបស់ព្រះពុទ្ធ ដោយព្រះតម្រាស់ថា បញ្ហានេះ មិនមែនវិស័យរបស់អ្នកឡើយ ជាវិស័យរបស់ព្រះសព្វញ្ញុពុទ្ធដ៏មានយស ហើយត្រាស់ថា ម្នាលសារីបុត្រ អ្នកចូរឃើញភូតកាយនេះ ។ ព្រះថេរៈដឹងថា ព្រះមានព្រះភាគត្រាស់ប្រាប់ការកំណត់កាយ ដែលប្រកបដោយមហាភូតរូប ៤ ហើយទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គដឹងហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងហើយ ។ កើតការសន្ទនាឡើងក្នុងទីនោះ ដូច្នេះថា អាវុសោទាំងឡាយ សារីបុត្រជាអ្នកមានបញ្ញាច្រើនហ្ន៎ ឆ្លើយបញ្ហាដែលមនុស្សទាំងពួងមិនដឹង តាំងនៅក្នុងន័យដែលព្រះពុទ្ធប្រទានហើយ ឆ្លើយបញ្ហាក្នុងពុទ្ធវិស័យបាន ដូច្នោះ ។ បញ្ញានុភាពរបស់ព្រះថេរៈ ទើបល្បីខ្ចរខ្ចាយទៅ គ្របសង្កត់ឋានៈទាំងពួង ដូចគ្នានឹងព្រះកិត្តិសព្ទរបស់ព្រះពុទ្ធខ្ចរខ្ចាយទៅ ដូច្នោះ ។ ព្រះថេរៈបានតំណែងឯតទគ្គៈ ព្រោះមានបញ្ញាច្រើន ដោយអត្ថុប្បត្តិហេតុ ដោយប្រការដូច្នេះ ។

បានតំណែងឯតទគ្គៈ ដោយការមកមុនដូចម្ដេច ដោយន័យនៃអត្ថុប្បត្តិហេតុនេះឯង ព្រះសាស្ដាត្រាស់ថា សារីបុត្រជាអ្នកមានបញ្ញា តែក្នុងបច្ចុប្បន្ននេះប៉ុណ្ណោះក៏មិនមែន ក្នុងអតីតកាល សារីបុត្របួសជាឥសី ៥០០ ជាតិ ក៏បានជាអ្នកមានបញ្ញាច្រើនដូចគ្នា ។

សាវ័ករូបណា លះកាមដែលគួរជាទីត្រេកអរ បួសដល់ទៅ
៥០០ ជាតិ អ្នកទាំងឡាយ ចូរថ្វាយបង្គំសាវ័ករូបនោះ ដែល

ប្រាសចាករាគៈ ដែលមានឥន្ទ្រិយតាំងមាំល្អហើយ ដែលរលត់ឥតមានសេសសល់ហើយ គឺសារីបុត្រនេះឯង ។

លោកចម្រើននូវការបួសយ៉ាងនេះ សម័យមួយ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងនគរពារាណសី រៀនត្រៃវេទ មិនឃើញសារៈក្នុងត្រៃវេទនោះ ទើបកើតការគិតឡើងថា អញគួរតែបួសស្វែងរកមោក្ខធម៌ណាមួយ ។ គ្រានោះ ព្រះពោធិសត្វកើតក្នុងត្រកូលឧទិច្ចព្រាហ្មណមហាសាល ចម្រើនវ័យហើយ រៀនសិប្បៈ ឃើញទោសក្នុងកាមទាំងឡាយ និងអានិសង្សក្នុងនេក្ខម្មៈ លះការគ្រប់គ្រងផ្ទះ ចូលព្រៃហិមពាន្ត ធ្វើបរិកម្មកសិណ ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតឡើង មានផ្លែស្វា មានឫសឈើក្នុងព្រៃជាអាហារ នៅត្រង់ហិមវន្តប្រទេស មាណពទាំងនោះក៏បួសហើយ ក្នុងសម្នាក់ព្រះពោធិសត្វនោះឯង លោកមានបរិវារច្រើន មានឥសីប្រមាណ ៥០០ ជាបរិវារ ។ លំដាប់នោះ ប្រធានអន្តេវាសិករបស់លោកបាននាំបរិស័ទមួយចំណែក ទៅកាន់ទីកដីមនុស្ស ដើម្បីបរិភោគរសប្រៃ និងរសជូរ ។

សម័យនោះ ព្រះពោធិសត្វបានធ្វើកាលកិរិយា ក្នុងហិមវន្តប្រទេសនោះឯង ។ ក្នុងវេលាមុនធ្វើកាលកិរិយា អន្តេវាសិកទាំងឡាយ ប្រជុំគ្នាសួរថា គុណវិសេសណាមួយដែលលោកម្ចាស់បានសម្រេចមានឬ ។ ព្រះពោធិសត្វឆ្លើយថា អ្វីមួយមិនមាន ជាអ្នកមិនវិនាសចាកឈាន កើតក្នុងព្រហ្មលោកជាន់អាភស្សរ ។ លោកបានអាកិញ្ចញ្ញាយតនសមាបត្តិក៏ពិត តែធម្មតាព្រះពោធិសត្វទាំងឡាយ មិនបដិសន្ធិក្នុងអរូបាវចរភូមិឡើយ សេចក្តីនេះ ព្រោះ

ហេតុអ្វី ព្រោះជាឋានៈដែលមិនសមគួរ ។ ដូច្នោះ ទោះបីលោកបានអរូបសមាបត្តិ ក៏កើតក្នុងរូបាវចរភូមិ ។ ឯអន្តេវាសិករបស់លោក មិនធ្វើសក្ការៈនិងសេចក្តីរាប់អានណាមួយ ដោយគិតថា អាចារ្យពោលថា អ្វីមួយមិនមាន ការធ្វើកាលកិរិយារបស់លោក ជាមោឃៈទទេ ។ លំដាប់នោះ ប្រធាននៃអន្តេវាសិករូបនោះ កាលវស្សាកន្លងហើយ ទើបត្រឡប់មក ហើយសួរថា លោកអាចារ្យទៅណា អន្តេវាសិកទាំងឡាយឆ្លើយថា ធ្វើកាលកិរិយាហើយ ។ លោកសួរថា ពួកអ្នកសួរដល់គុណដែលអាចារ្យបានដែរឬ អន្តេវាសិកឆ្លើយថា ពួកខ្ញុំសួរហើយ ។ ប្រធានអន្តេវាសិកសួរថា លោកពោលដូចម្តេចដែរ ពួកអន្តេវាសិកឆ្លើយថា អាចារ្យពោលថា អ្វីមួយមិនមាន ពួកខ្ញុំក៏គិតថា ឈ្មោះថា គុណដែលអាចារ្យបានហើយ រមែងមិនមាន ទើបមិនធ្វើសក្ការៈនិងការគោរពកោតក្រែងដល់លោក ។ ប្រធានអន្តេវាសិកពោលថា ពួកលោកមិនដឹងអត្ថរបស់ភាសិត លោកអាចារ្យបានអាកិញ្ចញ្ញាយតនសមាបត្តិ ។ អន្តេវាសិកទាំងនោះ ក៏មិនជឿពាក្យរបស់ប្រធានអន្តេវាសិក ។ សូម្បីប្រធានអន្តេវាសិកពោលរឿយៗ ក៏មិនអាចឲ្យពួកអន្តេវាសិកជឿបាន ។ លំដាប់នោះ ព្រះពោធិសត្វរឭកដល់គិតថា មហាជនល្ងង់ខ្លៅ មិនជឿពាក្យរបស់ប្រធានអន្តេវាសិករបស់អញ អញនឹងធ្វើហេតុនេះឲ្យប្រាកដ ដូច្នេះហើយ ចុះអំពីព្រហ្មលោក ឈរខាងចុងអាស្រម នាផ្ទៃអាកាសនោះឯង ពណ៌នាអានុភាពនៃបញ្ញារបស់ប្រធានអន្តេវាសិក បានពោលគាថានេះថា

**បរោសហស្សំបិ សមាគតានំ**

**កាមេ្ហយ្យុំ តេ វស្សសតំ អបញ្ញា**
**ឯកោវ សេយ្យោ បុរិសោ សបញ្ញោ**
**យោ ភាសិតស្ស វិជានាតិ អត្ថំ ។**

*ជនទាំងឡាយ មកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជន*
*ទាំងនោះឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញ អស់ ១០០ ឆ្នាំ*
*បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់ នូវអត្ថនៃ*
*ភាសិត បុរសនោះនៅតែម្នាក់ឯង ប្រសើរជាង ។*

*ព្រះពោធិសត្វ ធ្វើឲ្យពួកឥសីយល់យ៉ាងនេះហើយ ត្រឡប់ទៅព្រហ្មលោក សូម្បីឥសីដ៏សេស មិនសូន្យចាកឈាន ធ្វើកាលកិរិយាហើយ មានព្រហ្មលោកជាទីទៅខាងមុខ ។ ក្នុងបណ្តាបុគ្គលទាំងនោះ ព្រះពោធិសត្វសម្រេចព្រះសព្វញ្ញុតញ្ញាណ ប្រធានអន្តេវាសិក បានជាព្រះសារីបុត្រ ឥសីដ៏សេស ជាពុទ្ធបរិស័ទ សូម្បីក្នុងអតីតកាល ក៏គប្បីជ្រាបថា ព្រះសារីបុត្រមានបញ្ញាច្រើន អាចដឹងអត្ថនៃភាសិត ដែលត្រាស់ដោយសង្ខេប ដោយពិស្តារបាន ដោយប្រការដូច្នេះ ។*

*មយ៉ាងទៀត ព្រះមានព្រះភាគ ទ្រង់ធ្វើបុថុជ្ជនបញ្ចកបញ្ញាឲ្យជាអត្ថុប្បត្តិហេតុកើតរឿង ហើយត្រាស់ជាតកនេះថា*

**បរោសតំ វេបិ សមាគតានំ**
**ឈាយេយ្យុំ តេ វស្សសតំ អបញ្ញា**
**ឯកោវ សេយ្យោ បុរិសោ សបញ្ញោ**

**យោ ភាសិតស្ស វិជានាតិ អត្ថំ ។**

ជនទាំងឡាយប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះ ឥតប្រាជ្ញា គប្បីពិចារណា ( នូវអត្ថនៃភាសិត ) អស់ ១០០ ឆ្នាំ បុរសណាប្រកបដោយប្រាជ្ញា ដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ នៅតែម្នាក់ឯងប្រសើរវិញ ។

អត្ថនៃជាតកនោះ គប្បីជ្រាបដោយន័យដូចពោលហើយ ក្នុងជាតកមុន នោះឯង ទ្រង់ធ្វើបុថុជ្ជនបញ្ហកបញ្ហានេះឯងមួយទៀត ឲ្យជាអត្ថុប្បត្តិហេតុ ហើយ ទ្រង់សម្តែងអនង្គណជាតក ( ឈានសោធនជាតក ) នេះថា

**យេ សញ្ញិនោ តេបិ ទុគ្គតា**
**យេបិ អសញ្ញិនោ តេបិ ទុគ្គតា**
**ឯតំ ឧភយំ វិវជ្ជយ**
**តំ សមាបត្តិ សុខំ អនង្គណំ ។**

ពួកសត្វណា មានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត ( មិន បានសមាបត្តិ ) ពួកសត្វណាមិនមានសញ្ញា ពួកសត្វ នោះ ក៏ទុគ៌ត អ្នកចូរវៀរសត្វទាំងពីរពួកនោះចេញ សុខ ដែលកើតអំពីសមាបត្តិនោះ ឈ្មោះថា មិនមានទីទួល គឺ កិលេសឡើយ ។

ក្នុងជាតកនេះ អាចារ្យកាលធ្វើកាលកិរិយា ត្រូវអន្តេវាសិកទាំងឡាយ សួរ ទើបពោលថា បុគ្គលមានសញ្ញាក៏មិនមែន មិនមានសញ្ញាក៏មិនមែន ។

ពាក្យដ៏សេស គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ទ្រង់ធ្វើបុថុជ្ជនបញ្ចកបញ្ហាជាទៃទៀត ឲ្យជាអត្ថុប្បត្តិហេតុហើយ ត្រាស់ចន្ទាភជាតកនេះថា

**ចន្ទាភំ សុរិយាភញ្ច យោធ បញ្ញាយ គាធតិ**
**អវិតក្កេន ឈានេន ហោតិ អាភស្សរូបគោតិ ។**

បុគ្គលណាក្នុងលោកនេះ បាននូវកសិណ មានពន្លឺដូចព្រះចន្ទ
( ឱទាតកសិណ ) មានពន្លឺដូចព្រះអាទិត្យ ( បីតកសិណ )
ដោយបញ្ញា បុគ្គលនោះ រមែងទៅកើតក្នុង អាភស្សរព្រហ្ម-
លោក ដោយឈានមិនមានវិតក្ក ( ទុតិយជ្ឈាន ) ។

ក្នុងជាតកនេះ អាចារ្យកាលធ្វើកាលកិរិយា ត្រូវអន្តេវាសិកទាំងឡាយសួរ ទើបពោលថា **ចន្ទាភំ សុរិយាភំ** សេចក្តីថា បុគ្គលណាឈមចុះ គឺចូលទៅ ស្ទុះទៅកាន់កសិណទាំង ២ នោះ គឺឱទាតកសិណ ឈ្មោះថា ចន្ទាភៈ បីតកសិណ ឈ្មោះថា សុរិយាភៈ បុគ្គលនោះ ក៏ចូលដល់អាភស្សរព្រហ្ម ដោយទុតិយជ្ឈាន ដែលមិនមានវិតក្ក ខ្ញុំក៏ដូច្នោះ ។ ពាក្យដ៏សេសគប្បីជ្រាបដោយន័យមុននោះឯង ។ ទ្រង់ធ្វើបុថុជ្ជនបញ្ចកបញ្ហានេះឯង ឲ្យជាអត្ថុប្បត្តិហេតុ ទើបត្រាស់សរភជាតក ក្នុងតេរសនិបាតថា

បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួនសម្រេច ដូចសេចក្តីប្រាថ្នា ។

បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួន ដែលគេស្រង់អំពីទឹក មកលើគោក ។

បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញ ឃើញខ្លួន សម្រេចដូចសេចក្តីប្រាថ្នា ។

បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញ ឃើញខ្លួន ដែលសារកម្រឹតស្រង់អំពីទឹក មកលើគោក ។

នរជនដែលប្រកបដោយប្រាជ្ញា សូម្បីដល់សេចក្តីទុក្ខ ក៏មិនកាត់បង់ សេចក្តីប៉ុនប៉ង ដើម្បីឲ្យបានសុខ ព្រោះថា ផស្សៈទាំងឡាយ មានច្រើន មិនជាប្រយោជនក៏មាន ជាប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែង ចូលទៅរកសេចក្តីស្លាប់ ។

ហេតុដែលយើងមិនបានគិតក៏ប្រែជាមាន ហេតុដែលយើងបានគិត ហើយក៏ប្រែជាវិនាសទៅវិញ គោគៈទាំងឡាយរបស់ស្ត្រីក្តី របស់បុរសក្តី មិនមែនសម្រេចមកពីការគិតឡើយ ។

ពីដើម ព្រះអង្គជាប់តាមសារកម្រឹតក្នុងជង្គង់ ព្រះអង្គបានរស់រួចព្រះជន្ម ដោយសារសេចក្តីព្យាយាម របស់សារកម្រឹត ដែលមានចិត្តមិនរួញរា ។

សារកម្រឹតណា ធ្វើនូវការប្រគោងថ្ម បានស្រង់ព្រះអង្គឡើងអំពីរណ្តៅ ដែលមិនងាយឡើងរួច ហើយបានដោះព្រះអង្គ ដែលដល់នូវសេចក្តីទុក្ខ ឲ្យ រួចពីមាត់សេចក្តីស្លាប់ ព្រះអង្គពណ៌នាសរសើរសារកម្រឹត ដែលជាសត្វមាន ចិត្តមិនរួញរានោះឯង ។

ក្នុងពេលនោះ អ្នកឯងបាននៅក្នុងទីនោះដែរឬ ឬនរណាមួយប្រាប់ ដំណើរនោះដល់អ្នក ឬក៏អ្នកជាបុគ្គលមានដំបូល គឺកិលេសបើកហើយ ជាអ្នក

ឃើញហេតុសព្វ ម្នាលព្រាហ្មណ៍ អ្នកមានញាណ ដ៏មានកម្លាំងក្លៀវក្លាឬ ។

ក្នុងពេលនោះ ទូលព្រះបង្គំជាខ្ញុំ មិនបាននៅក្នុងព្រៃនោះទេ ទាំងគ្មាននរណាមួយ ប្រាប់ដំណើរនោះ ដល់ទូលបង្គំជាខ្ញុំឡើយ បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំងឡាយ តែងពិចារណាសេចក្តីនៃបទនៃគាថា និងសុភាសិតទាំងឡាយនោះ ។

ជាតកទាំង ៥ នេះ ព្រះសាស្តាត្រាស់ដើម្បីប្រកាសអានុភាពនៃបញ្ញារបស់ព្រះធម្មសេនាបតីសារីបុត្តត្ថេរប៉ុណ្ណោះថា ក្នុងអតីតកាល បុត្ររបស់តថាគតក៏ដឹងអត្ថនៃធម៌ ដែលតថាគតពោលដោយសង្ខេប ឲ្យពិស្តារបាន ព្រោះដូច្នោះ ព្រះថេរៈបានតំណែងឯតទគ្គៈ ព្រោះភាពដែលខ្លួនមានបញ្ញាច្រើនដោយការមកអំពីមុន ដោយប្រការយ៉ាងនេះ ។

ដោយភាពជាអ្នកជំនាញដូចម្តេច បានឮថា សេចក្តីនោះ ជាការជំនាញរបស់ព្រះថេរៈ ។ ព្រះថេរៈកាលសម្តែងធម៌ដល់ចំណោមបរិស័ទ ៤ រមែងសម្តែងមិនផុតសច្ចៈ ៤ ព្រោះដូច្នោះ ព្រះថេរៈបានឯតទគ្គៈ ព្រោះជាអ្នកមានបញ្ញាច្រើន ដោយជាអ្នកជំនាញ ដោយប្រការដូច្នេះ ។

ដោយក្រៃលែងដោយគុណដូចម្តេច ពិតហើយ វៀរព្រះទសពលចេញ បុគ្គលដទៃណា សូម្បីជាសាវកឯក ដែលស្មើព្រះធម្មសេនាបតីសារីបុត្រ រមែងមិនមាន ព្រោះលោកជាអ្នកមានបញ្ញាច្រើន ព្រោះដូច្នោះ ព្រះថេរៈបានតំណែងឯតទគ្គៈ ព្រោះមានបញ្ញាច្រើន ក្រៃលែងដោយគុណ ដោយប្រការដូច្នេះ ។

សូម្បីព្រះមហាមោគ្គល្លាន ក៏ដូចព្រះសារីបុត្តត្ថេរដែរ បានតំណែងជា

ឯតទគ្គៈ ដោយហេតុ ៤ ប្រការទាំងអស់ តើបានដូចម្តេច ព្រះថេរៈមានឫទ្ធិច្រើន មានអានុភាពច្រើន ទូន្មាននាគរាជ ដូចជានន្ទោបនន្ទនាគរាជ ព្រោះដូច្នោះ ព្រះថេរៈរមែងបានដោយអត្ថុប្បត្តិហេតុយ៉ាងនេះ ជាលំដាប់ដំបូង ។ ព្រះថេរៈនេះ មិនមែនជាអ្នកមានឫទ្ធិច្រើនតែក្នុងបច្ចុប្បន្នប៉ុណ្ណោះទេ សូម្បីក្នុងអតីតកាល លោកបួសជាឥសី ក៏ជាអ្នកមានឫទ្ធិច្រើន មានអានុភាពច្រើនដល់ទៅ ៥០០ ជាតិដែរ ។

> សាវកណា លះកាមទាំងឡាយ ដែលជាទីត្រេកអរនៃចិត្ត
> បួស ៥០០ ជាតិ អ្នកទាំងឡាយចូរថ្វាយបង្គំសាវកនោះ ដែល
> ប្រាសចាករាគៈ មានឥន្ទ្រិយតាំងមាំហើយ រលត់ស្និទ្ធហើយ
> គឺមោគ្គល្លាននេះឯង ។

ឯលោកបានដោយការមកអំពីមុនយ៉ាងនេះ ក្នុងសេចក្តីនោះ ជាការជំនាញរបស់ព្រះថេរៈ ។ ព្រះថេរៈទៅនរក អធិដ្ឋានភាពត្រជាក់ ដើម្បីឲ្យកើតការស្រោកស្រាន្តចិត្ត ដល់សត្វទាំងឡាយក្នុងនរក ដោយកម្លាំងឫទ្ធិរបស់ខ្លួនហើយនិម្មិតផ្កាបទុមប៉ុនកង់រទេះ គង់ក្នុងត្របកឈូក សម្តែងធម្មកថា ។ លោកទៅកាន់ទេវលោក ធ្វើទេវតាឲ្យដឹងគតិនៃកម្ម ហើយសម្តែងសច្ចកថា ព្រោះដូច្នោះ ទើបលោកបានជាអ្នកជំនាញយ៉ាងនេះ ។

បានដោយក្រៃលែងដោយគុណដូចម្តេច វៀរព្រះសម្មាសម្ពុទ្ធចេញហើយ សាវកដទៃណា រមែងមិនមាន ព្រោះដូច្នោះ ព្រះថេរៈបានតំណែងឯតទគ្គៈ ដោយក្រៃលែងដោយគុណយ៉ាងនេះ ។

សូម្បីព្រះមហាកស្សបត្ថេរ ក៏បានតំណែងឯតទគ្គៈ ដោយហេតុទាំង អស់នេះ ដូចព្រះមហាមោគ្គល្លានដែរ ។ តើបានដូចម្តេច សេចក្តីពិត ព្រះសម្ពុទ្ធ ទ្រង់ធ្វើការទទួលព្រះថេរៈអស់ចម្ងាយផ្លូវ ៣ គាវុត ទ្រង់ឲ្យឧបសម្បទាដោយឱវាទ ៣ ទ្រង់ប្តូរចីវរប្រទានឲ្យ ។ ក្នុងសម័យនោះ មហាប្រឹថពីញាប់ញ័រដល់ទឹកទ្រផែនដី ។ កិត្តិគុណរបស់ព្រះថេរៈ ក៏ខ្ចរខ្ចាយទៅក្នុងរវាងមហាជន ។ លោកបានដោយអត្ថុប្បត្តិហេតុយ៉ាងនេះថា

សាវកណា លះកាមទាំងឡាយ ដែលជាទីរីករាយចិត្ត បួស ៥០០ ជាតិ ចូរអ្នកទាំងឡាយ ថ្វាយបង្គំសាវកនោះ ដែលប្រាសចាករាគៈ ដែលមានឥន្ទ្រិយតាំងមាំល្អហើយ ដែលរលត់មិនមានសេសសល់ គឺកស្សបនេះឯង ។

លោកបានដោយការពោលមកយ៉ាងនេះ ។ សេចក្តីពិត ក្នុងប្រការនោះ ជាការជំនាញរបស់ព្រះថេរៈ ។ លោកនៅក្នុងកណ្តាលបរិស័ទ ៤ កាលសម្តែងធម៌ រមែងសម្តែងមិនវៀរកថាវត្ថុ ១០ ឡើយ ព្រោះដូច្នោះ ព្រះថេរៈបានដោយភាពជាអ្នកជំនាញយ៉ាងនេះ ។ វៀរព្រះសម្មាសម្ពុទ្ធហើយ សាវកដទៃមិនមានបុគ្គលណាម្នាក់ ប្រៀបស្មើព្រះមហាកស្សប ដោយធុតង្គគុណ ១៣ ព្រោះដូច្នោះ ព្រះថេរៈបានដោយក្រៃលែងដោយគុណយ៉ាងនេះ ។ គួរប្រកាសគុណរបស់ព្រះថេរៈទាំងឡាយនោះៗ តាមដែលបានដោយទំនងនេះ ។ ពិតហើយ កាលពោលដោយអំណាចគុណនោះឯង ស្តេចចក្រពត្តិទ្រង់សោយសិរីរាជសម្បត្តិ ក្នុងផ្ទៃចក្រវាល ដោយអានុភាពនៃចក្ករ័តន៍ ទ្រង់

មិនបានខ្វល់ខ្វាយគិតថា វត្ថុដែលគួរសម្រេច អញក៏សម្រេចហើយ ឥឡូវនេះ នឹងត្រូវការអ្វីដោយមហាជន ដែលអញមើលថែហើយ ទើបសោយចំពោះតែសិរីរាជសម្បត្តិប៉ុណ្ណោះក៏ទេ តែទ្រង់ប្រថាប់គង់ក្នុងរោងសភា តាមកាលដែលសមគួរ ទ្រង់សង្កត់សង្កិនបុគ្គលដែលគួរសង្កត់សង្កិន សរសើរបុគ្គលដែលគួរសរសើរ ទ្រង់តាំងទុកក្នុងឋានន្តរទាំងឡាយ ចំពោះឋានន្តរដែលគួរតែងតាំងប៉ុណ្ណោះ យ៉ាងណា ព្រះមានព្រះភាគសម្មាសម្ពុទ្ធ ក៏ដូច្នោះដូចគ្នា ជាព្រះធម្មរាជា ជាអ្នកសម្រេចភាពជាព្រះរាជា ព្រោះធម៌ដោយលំដាប់ ដោយអានុភាពនៃព្រះសព្វញ្ញុតញ្ញាណ ដែលទ្រង់សម្រេចក្នុងមហាពោធិមណ្ឌលដ្ឋាន ទ្រង់មិនខ្វល់ខ្វាយគិតថា ឥឡូវនេះ តថាគតនឹងត្រូវការអ្វីដោយសត្វលោក ដែលតថាគតត្រូវប្រមើលមើល តថាគតនឹងសោយសុខក្នុងផលសមាបត្តិដ៏កំពូល នៅតែប្រថាប់គង់លើបវរពុទ្ធាសនៈដែលគេផ្ចិតផ្ចង់ត្រង់កណ្តាលបរិស័ទ ៤ ទ្រង់បន្លឺព្រះសូរសៀង ដូចសំឡេងព្រហ្ម ដែលប្រកបដោយអង្គ ៨ ហើយទ្រង់សម្តែងធម៌ ទ្រង់សង្កត់សង្កិនបុគ្គលដែលមានធម៌ចំណែកខ្មៅ បុគ្គលគួរសង្កត់សង្កិនដោយការសង្កត់សង្កិនដោយភ័យក្នុងអបាយ ដូចទ្រង់បោះទៅក្នុងជ្រោះនៃភ្នំសិនេរុ ទ្រង់សរសើរបុគ្គលដែលមានធម៌ល្អ ដែលគួរសរសើរ ដូចលើកឡើងឲ្យអង្គុយក្នុងភវគ្គព្រហ្ម ទ្រង់តាំងសាវ័ក មានព្រះអញ្ញាកោណ្ឌញ្ញត្ថេរជាដើម ដែលគួរតាំងទុកក្នុងឋានន្តរទាំង-ឡាយ ឲ្យតាំងនៅក្នុងឋានន្តរទាំងឡាយ ដោយអំណាចគុណ ព្រមដោយកិច្ចគឺនាទីតាមសេចក្តីពិតនោះឯង ទើបត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំង-

ឡាយ បណ្ដាពួកភិក្ខុអ្នកដឹងរាត្រី ដែលជាសាវ័ករបស់តថាគត ស្រេចនឹង អញ្ញាកោណ្ឌញ្ញប្រសើរជាងគេ ។

## ប្រវត្តិព្រះអញ្ញាកោណ្ឌញ្ញត្ថេរ

បទថា **ឯតទគ្គំ** ក្នុងបាលីនោះ មានអត្ថដូចពោលហើយនោះឯង ។ បទថា **រត្តញ្ញូនំ** ប្រែថា អ្នកដឹងរាត្រី ។ ពិតហើយ វៀរព្រះសម្មាសម្ពុទ្ធចេញ សាវ័កដទៃ ឈ្មោះថា បួសមុនព្រះអញ្ញាកោណ្ឌញ្ញត្ថេរមិនមាន ព្រោះដូច្នោះ ព្រះថេរៈរមែងដឹងរាត្រីអស់កាលយូរ ចាប់តាំងពីបួស ហេតុនោះ ទើបលោកពោលថា ជារត្តញ្ញូ ។ ព្រោះលោកចាក់ធ្លុះធម៌មុនបុគ្គលណាទាំងអស់ លោកដឹងរាត្រី ដឹងធម៌នោះមកយូរ ព្រោះដូច្នោះ ទើបឈ្មោះថា រត្តញ្ញូ ។ម្យ៉ាងទៀត ការកំណត់យប់ និងថ្ងៃរបស់លោកដែលអស់អាសវៈទាំងឡាយ ជារបស់ប្រាកដច្បាស់ ។ ព្រះអញ្ញាកោណ្ឌញ្ញត្ថេរនេះ ជាអ្នកអស់អាសវៈមុន ព្រោះហេតុនោះ ព្រះអញ្ញាកោណ្ឌញ្ញៈនេះឯង ជាបុគ្គលឯក ជាបុគ្គលកំពូល ជាបុគ្គលប្រសើរជាងពួកសាវ័កដែលជារត្តញ្ញូ ដោយប្រការយ៉ាងនេះ ព្រោះហេតុនោះ ទើបត្រាស់ថា **រត្តញ្ញូនំ យទិទំ អញ្ញា-កោណ្ឌញ្ញោ** ដូច្នេះ ។

សព្ទថា **យទិទំ** ក្នុងបាលីនេះ ជានិបាត បើសម្ព័ន្ធយកព្រះថេរៈនោះ មានអត្ថថា **យោ ឯសោ** បើសម្ព័ន្ធ **អគ្គ** សព្ទ មានអត្ថថា **យំ ឯតំ** ។ បទថា **អញ្ញាកោណ្ឌញ្ញោ** ប្រែថា កោណ្ឌញ្ញៈដឹងទូទៅហើយហ្ន៎ កោណ្ឌញ្ញៈចាក់ធ្លុះហើយហ្ន៎ ។ ដោយហេតុនោះឯង ទើបព្រះមានព្រះភាគត្រាស់ថា **អញ្ញាសិ**

**វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ ឥតិ ហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ អហោសិ**

*អញ្ញាកោណ្ឌញ្ញៈដឹងទូទៅហើយហ្ន៎ អញ្ញាកោណ្ឌញ្ញៈដឹងទូទៅហើយហ្ន៎ ព្រោះហេតុនោះ ទើបព្រះអញ្ញាកោណ្ឌញ្ញៈមានឈ្មោះថា អញ្ញាកោណ្ឌញ្ញៈ ដូច្នេះ ។*

*គប្បីជ្រាបបញ្ហាកម្មក្នុងព្រះសាវកដែលជាឯតទគ្គៈគ្រប់រូប ដោយន័យនេះថា ព្រះថេរៈនេះធ្វើសេចក្ដីប្រាថ្នាក្នុងកាលមុន ឲ្យជាការប្រាថ្នាដ៏ក្រៃលែងក្នុងពុទ្ធុប្បាទព្រះសម្មាសម្ពុទ្ធអង្គណា លោកបួសក្នុងកាលណា លោកសម្រេចធម៌ដំបូងក្នុងកាលណា បានទទួលស្ថាបនាក្នុងតំណែងនាកាលណា បណ្ដាព្រះថេរៈដែលជាឯតទគ្គៈទាំងនោះ ជាបឋម ក្នុងបញ្ហាកម្មរបស់ព្រះថេរៈនេះ មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ*

*គប្បីជ្រាបបញ្ហាកម្មក្នុងព្រះសាវក ដែលជាឯតទគ្គៈគ្រប់រូប ដោយន័យនេះថា ព្រះថេរៈនេះបានធ្វើសេចក្ដីប្រាថ្នាក្នុងកាលមុន ឲ្យជាសេចក្ដីប្រាថ្នាដ៏ធំក្រៃលែង ក្នុងពុទ្ធុប្បាទនៃព្រះសម្មាសម្ពុទ្ធអង្គណា លោកបួសក្នុងកាលណា សម្រេចធម៌ដំបូងក្នុងកាលណា បានទទួលស្ថាបនាក្នុងតំណែងក្នុងកាលណា ។ បណ្ដាព្រះថេរៈដែលជាឯតទគ្គៈទាំងនោះ ជាបឋម ក្នុងបញ្ហាកម្មរបស់ព្រះថេរៈនេះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះថា*

*ខាងចុងនៃមួយសែនកប្ប រាប់អំពីភទ្ទកប្បនេះថយក្រោយ ព្រះពុទ្ធទ្រង់ព្រះនាមថា បទុមុត្តរៈកើតឡើងក្នុងលោក កាលត្រាស់ដឹងព្រះសព្វញ្ញុ-តញ្ញាណ ទ្រង់ក្រោកអំពីមហាពោធិបល្ល័ង្ក គ្រាន់តែលើកព្រះបាទឡើង ដើម្បី*

ដាក់លើមហាប្រឹថពី ផ្កាឈូកធំផុសឡើងទទួលព្រះបាទ ។ ផ្កាឈូកនោះមានត្របកវែងដល់ទៅ ៩០ ហត្ថ កេសរ ៣០ ហត្ថ សំណុំ ( ផ្លែខ្ចីខាងក្នុង ) ១២ ហត្ថ ដែលប្រតិស្ឋានព្រះបាទ ១១ ហត្ថ ។ ព្រះសរីរៈរបស់ព្រះមានព្រះភាគអង្គនោះកម្ពស់ ៥៨ ហត្ថ កាលព្រះបាទស្តាំរបស់ព្រះអង្គប្រតិស្ឋាននៅលើសំណុំឈូក លម្អងកេសរប្រមាណ ១ នាឡិធំ ផ្សាយឡើងបាចសាចលើព្រះសរីរៈ ។ ក្នុងវេលាដាក់ព្រះបាទឆ្វេង ផ្កាឈូកនោះឯង ក៏ផុសឡើងទទួលព្រះបាទ លម្អងមានប្រមាណដូចពោលហើយនោះឯង ផ្សាយឡើងអំពីទីនោះ ស្រោចស្រពព្រះសរីរៈរបស់ព្រះមានព្រះភាគអង្គនោះ ។ រស្មីព្រះសរីរៈរបស់ព្រះមានព្រះភាគផ្សាយចេញ គ្របដណ្តប់លម្អងនោះ ធ្វើទីប្រមាណ ១២ យោជន៍ដោយជុំវិញ ឲ្យមានពន្លឺតែមួយ ដូចខ្សែទឹកមាសដែលផ្សាយចេញអំពីនាឡិយន្ត ។ ក្នុងវេលាឈានព្រះបាទទី ៣ ផ្កាឈូកដែលផុសឡើងមុនក៏បាត់ទៅ ។ ផ្កាឈូកថ្មីក៏ផុសឡើងទទួលព្រះបាទ ដោយទំនងនេះឯង ព្រះអង្គបំណងយាងទៅក្នុងទីណាមួយ ផ្កាឈូកធំក៏ផុសឡើងក្នុងទីនោះៗ គ្រប់ជំហានព្រះបាទ ។ ដោយហេតុនោះឯង ទើបទ្រង់ព្រះនាមថា បទុមុត្តរ-សម្មាសម្ពុទ្ធ ។

ព្រះមានព្រះភាគអង្គនោះ ទ្រង់កើតឡើងក្នុងលោកយ៉ាងនេះ មានភិក្ខុមួយសែនរូបជាបរិវារ ទ្រង់និមន្តបិណ្ឌបាតក្នុងគាមនិគម និងរាជធានី ដើម្បីសង្គ្រោះមហាជន ទ្រង់យាងដល់ក្រុងហង្សវតី មហារាជាជាពុទ្ធបិតា ទ្រង់ជ្រាបដំណឹងថា ព្រះសាស្តាទ្រង់យាងមក ទើបចេញទៅទទួល ។ ព្រះសាស្តា

បានត្រាស់ធម្មកថាដល់ពុទ្ធបិតា ។ ចប់ទេសនា ពួកខ្លះជាព្រះសោតាបន្ន ពួកខ្លះ ជាព្រះសកទាគាមី ពួកខ្លះជាព្រះអនាគាមី ពួកខ្លះសម្រេចអរហត្ត ។ ព្រះរាជាទ្រង់និមន្តព្រះទសពល ដើម្បីសោយភត្តាហារក្នុងថ្ងៃស្អែក ។ លុះព្រឹកឡើង ទ្រង់ឲ្យប្រាប់ភត្តកាល ហើយបានថ្វាយមហាទានក្នុងព្រះរាជ-និវេសន៍របស់ព្រះអង្គ ដល់ព្រះមានព្រះភាគ ដែលមានភិក្ខុមួយសែនរូបជាបរិវារ ព្រះសាស្តាទ្រង់ធ្វើភត្តានុមោទនាហើយ យាងទៅកាន់វិហារតាមធម្មតា ។ ដោយទំនងនោះឯង បានថ្វាយទានអស់កាលដ៏យូរ គឺមួយថ្ងៃ អ្នកស្រុកថ្វាយមួយថ្ងៃ ព្រះរាជាថ្វាយ ។ កាលនោះ ព្រះថេរៈនេះកើតក្នុងត្រកូលគហបតីមហាសាល ក្នុងក្រុងហង្សវតី ។ ថ្ងៃមួយ ក្នុងវេលាដែលព្រះពុទ្ធទ្រង់សម្តែងធម៌ ឃើញអ្នកក្រុងហង្សវតី នាំគ្នាកាន់គ្រឿងក្រអូប និងផ្កាជាដើម បង្អោនទៅទោរទៅចំពោះព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ហើយបានទៅកាន់ទីសម្តែងធម៌ មួយអន្លើជាមួយមហាជនទាំងនោះឯង ។ សម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់ស្ថាបនាភិក្ខុមួយរូប ដែលត្រាស់ដឹងធម៌មុនគេក្នុងសាសនារបស់ព្រះអង្គ ក្នុងតំណែងឯតទគ្គៈ ។ កុលបុត្រនោះ បានស្តាប់ហេតុនោះហើយ គិតថា ភិក្ខុនេះជាបុគ្គលធំហ្ន៎ បានឮថា វៀរព្រះសម្មាសម្ពុទ្ធចេញ បុគ្គលដទៃដែលត្រាស់ដឹងធម៌មុនភិក្ខុនេះ មិនមាន អញគប្បីជាអ្នកត្រាស់ដឹងធម៌មុន ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ។ ក្នុងវេលាចប់ទេសនា ទើបចូលគាល់ព្រះមានព្រះភាគ និមន្តថា ស្អែកនេះ សូមទ្រង់មេត្តាទទួលភិក្ខារបស់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តា ទ្រង់ទទួលនិមន្តន៍

ហើយ កុលបុត្រនោះ ថ្វាយអភិវាទព្រះមានព្រះភាគហើយ ធ្វើប្រទក្សិណ ហើយ ទៅកាន់លំនៅរបស់ខ្លួន រៀបចំអាសនៈសម្រាប់ព្រះពុទ្ធ ដោយគ្រឿងក្រអូប និងផ្កាកម្រងជាដើម ឲ្យរៀបចំខាទនីយ និងភោជនីយាហារដ៏ប្រណីត រហូតដល់ថ្ងៃរះ ។ កន្លងរាត្រីនោះ បានថ្វាយបាយស្រូវសាលីក្រអូប មានសម្ល និងម្ហូប មានរសផ្សេងៗ មានបបរ និងរបស់ទំពាដ៏វិចិត្រជាបរិវារដល់ព្រះមានព្រះភាគ ដែលមានភិក្ខុមួយសែនរូបជាបរិវារ ក្នុងលំនៅរបស់ខ្លួន ក្នុងវេលាស្រេចភត្តកិច្ច បានដាក់គូសំពត់ល្អធ្វើចីវរបានចំនួន ៣ ផ្ទាំង ទៀបបាទមូលរបស់ព្រះតថាគត គិតថា អាត្មាអញមិនបានសូមដើម្បីប្រយោជន៍ដល់តំណែងតិចតួច អាត្មាអញប្រាថ្នាតំណែងធំ អញមិនអាចឲ្យទានត្រឹមតែមួយថ្ងៃប៉ុណ្ណោះ ហើយប្រាថ្នាតំណែងនោះឡើយ ទើបគិតថា នឹងថ្វាយទានអស់ ៧ ថ្ងៃជាប់គ្នា រួចសឹមប្រាថ្នា ។ ដោយទំនងនោះឯង ទើបបុរសនោះថ្វាយមហាទានអស់ ៧ ថ្ងៃ ក្នុងវេលាស្រេចភត្តកិច្ច បានឲ្យបើកឃ្លាំងសំពត់ ដាក់សំពត់សាច់ម៉ដ្ឋល្អក្រៃលែង ទៀបបាទមូលនៃព្រះមានព្រះភាគ ឲ្យភិក្ខុមួយសែនរូបគ្រងត្រៃចីវរ រួចចូលទៅគាល់ព្រះមានព្រះភាគក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខាងចុង ៧ ថ្ងៃ បន្ទាប់អំពីនេះ ខ្ញុំព្រះអង្គគប្បីបួសក្នុងសាសនារបស់ព្រះពុទ្ធដែលកើតក្នុងអនាគត ហើយដឹងច្បាស់នូវធម៌មុនគេដូចភិក្ខុនេះ ហើយឱនក្បាលចុះក្បែរព្រះបាទរបស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ស្តាប់ពាក្យនោះហើយ ទ្រង់បញ្ជូនអនាគតំសញ្ញាណ ប្រមើលមើលថា កុលបុត្រនេះបានធ្វើបុញ្ញាធិការច្រើន ការប្រាថ្នា

របស់សត្វនេះ នឹងសម្រេចក្នុងកាលឯណាហ្ន៎ កាលទ្រង់ប្រមើលមើល ក៏ឃើញសេចក្តីសម្រេច ។ ពិតហើយ កាលព្រះពុទ្ធទាំងឡាយ ទ្រង់ប្រមើលមើលដល់អតីត អនាគត ឬបច្ចុប្បន្ន រមែងមិនមានអ្វីរាំងទេ ។ ទោះហេតុជាអតីត ឬហេតុដែលជាអនាគត ដែលប្រព្រឹត្តទៅខាងក្នុងរវាងសែនកោដិកប្បដ៏ច្រើនក្តី បច្ចុប្បន្ន រវាងមួយសែនចក្កវាឡក្តី រមែងទាក់ទងដោយការនឹក ទាក់ទងដោយមនសិការទាំងអស់ ។

ព្រះមានព្រះភាគអង្គនេះ ទ្រង់បានឃើញហេតុនេះ ដោយញាណដែលមិនមានបុគ្គលណាម្នាក់ ឲ្យប្រព្រឹត្តទៅបានថា ក្នុងអនាគត ក្នុងទីបំផុតមួយសែនកប្ប ព្រះពុទ្ធព្រះនាមថា គោតមនឹងកើតឡើងក្នុងលោក កាលនោះសេចក្តីប្រាថ្នារបស់កុលបុត្រនេះ នឹងសម្រេច ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់នឹងកុលបុត្រនោះយ៉ាងនេះថា ម្នាលកុលបុត្រដ៏ចម្រើន ក្នុងអនាគត ទីបំផុតមួយសែនកប្ប ព្រះពុទ្ធទ្រង់ព្រះនាមថាគោតម នឹងកើតឡើងក្នុងលោក អ្នកនឹងតាំងនៅក្នុងសោតាបត្តិផល ដែលដល់ព្រមដោយន័យមួយពាន់ មួយអន្លើដោយព្រហ្ម ១៨ កោដិ ក្នុងកាលចប់ព្រះធម្មចក្កប្បវត្តនសូត្រ ដែលមានបរិវដ្ដៈ ៣ ដោយការសម្តែងព្រះធម្មទេសនារបស់ព្រះគោតមសម្ពុទ្ធអង្គនោះ ។

ព្រះសាស្តា ទ្រង់ព្យាករកុលបុត្រនោះដូច្នេះហើយ ទ្រង់សម្តែងធម៌ ៨ ម៉ឺន ៤ ពាន់ព្រះធម្មក្ខន្ធ ហើយបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ សរីរៈរបស់ព្រះអង្គ ដែលបរិនិព្វានហើយ នៅជាដុំតែមួយ ដូចដុំមាសដូច្នោះ ។ ជនទាំងឡាយ បានធ្វើចេតិយបញ្ចុះព្រះសរីរៈរបស់ព្រះអង្គ កម្ពស់

៧ យោជន៍ ឥដ្ឋទាំងឡាយ សម្រេចហើយដោយមាសសុទ្ធ ជនទាំងឡាយប្រើហរិតាល និងមនោសិលាជំនួសដីស្អិត ប្រើប្រេងល្ងជំនួសទឹក ។ ក្នុងកាលដែលព្រះពុទ្ធទាំងឡាយគង់ព្រះជន្មនៅឡើយ រស្មីនៃព្រះសរីរៈផ្សាយទៅ ១២ យោជន៍ កាលព្រះពុទ្ធទាំងឡាយបរិនិព្វានហើយ រស្មីនោះ ផ្សាយចេញទៅគ្រប់ដណ្តប់ទីប្រមាណ ១០០ យោជន៍ដោយជុំវិញ សេដ្ឋីនោះឲ្យសាងរបស់គួរដល់តម្លៃ ស្មើនឹងរតនៈ ១០០០ ព័ទ្ធព្រះចេតិយបញ្ចុះព្រះសរីរៈរបស់ព្រះពុទ្ធទាំងឡាយ ។ ក្នុងថ្ងៃប្រតិស្ឋានព្រះចេតិយ ឲ្យសាងផ្ទះកែវខាងក្នុងចេតិយ ។ សេដ្ឋីនោះបានធ្វើកល្យាណកម្ម សម្រេចហើយដោយមហាទានអស់មួយសែនឆ្នាំ ឃ្លាតចាកអត្តភាពនោះហើយ កើតក្នុងស្ថានសួគ៌ កាលសេដ្ឋីនោះអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយនោះឯង កន្លងទៅ ៩៩៩០៩ កប្ប កាលកន្លងទៅប៉ុណ្ណោះ ក្នុងកប្បទី ៩១ អំពីកន្លកប្បនេះ កុលបុត្រនេះកើតឡើងក្នុងផ្ទះនៃកុដុម្ពិកៈ នាភមគ្រាម ជិតទ្វារក្រុងពន្ធុមតី បានឈ្មោះថា មហាកាល ឯប្អូនប្រុសរបស់គាត់ ឈ្មោះថា ចូឡកាល ។

សម័យនោះ ព្រះពោធិសត្វព្រះនាមថា វិបស្សី ចុតិអំពីតុសិតបុរី កើតក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីរបស់ព្រះបាទពន្ធុមៈ ក្រុងពន្ធុមតី សម្រេចព្រះសព្វញ្ញុតញ្ញាណដោយលំដាប់ ដែលសហម្បតីព្រហ្មអារាធនា ដើម្បីប្រយោជន៍ដល់ការសម្តែងធម៌ ទើបត្រិះរិះថា តថាគតគួរសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ឃើញព្រះរាជកុមារព្រះនាមខណ្ឌៈ ជាព្រះកនិដ្ឋារបស់ព្រះអង្គ និងបុត្របុរោហិត ឈ្មោះតិស្សៈ ថាជាអ្នកអាចត្រាស់ដឹងធម៌មុន ទើបទ្រង់

ត្រិះរិះថា តថាគតនឹងសម្តែងធម៌ដល់ជនទាំង ២ នោះ នឹងសង្គ្រោះពុទ្ធបិតា ទើបហោះអំពីពោធិមណ្ឌលដ្ឋាន ចុះត្រង់ខេមមិគទាយវ័ន ត្រាស់ហៅជនទាំង ២ នោះមក ហើយសម្តែងធម៌ ក្នុងវេលាចប់ទេសនា ជនទាំង ២ តាំងនៅក្នុងអរហត្តផល មួយអន្លើដោយសត្វលោកប្រមាណ ៨៤០០០ នាក់ បុគ្គលមួយពួកទៀត ដែលបួសតាមក្នុងវេលាព្រះអង្គជាព្រះពោធិសត្វ ស្តាប់រឿងនោះហើយ ក៏មកគាល់ព្រះសាស្តា ស្តាប់ធម្មទេសនា តាំងនៅក្នុងអរហត្តផលក្នុងទីនោះឯង ព្រះសាស្តាទ្រង់ស្ថាបនាព្រះខណ្ឌត្ថេរ ក្នុងតំណែងព្រះអគ្គបឋមសាវ័ក ទ្រង់ស្ថាបនាព្រះតិស្សត្ថេរ ក្នុងតំណែងអគ្គទុតិយសាវ័ក ។

ឯព្រះរាជាទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ព្រះតម្រិះថា នឹងសាកសួរសុខទុក្ខបុត្រ ទើបយាងទៅកាន់ព្រះរាជឧទ្យាន ទ្រង់ស្តាប់ព្រះធម្មទេសនា តាំងនៅក្នុងរតនៈ ៣ និមន្តព្រះសាស្តា ដើម្បីសោយភត្តាហារ ថ្វាយបង្គំហើយធ្វើប្រទក្សិណ រួចយាងត្រឡប់ ព្រះរាជាឡើងកាន់ប្រាសាទដ៏ប្រសើរ ហើយប្រថាប់គង់ ទ្រង់ព្រះតម្រិះថា កូនច្បងរបស់អញចេញបួស បានត្រាស់ជាព្រះពុទ្ធ កូនទី ២ របស់អញ ក៏បានជាអគ្គសាវ័ក កូនបុរោហិតជាទុតិយសាវ័ក ភិក្ខុដ៏សេសទាំងនេះ ក្នុងវេលាជាគ្រហស្ថគ្រាច់ចោមរោមកូនរបស់អញប៉ុណ្ណោះ ភិក្ខុទាំងនេះ ក្នុងកាលមុនក្តី ឥឡូវនេះក្តី ជាភារៈរបស់អញតែម្យ៉ាងអាត្មាអញប៉ុណ្ណោះ នឹងទំនុកបម្រុងភិក្ខុទាំងនោះ ដោយបច្ច័យ ៤ នឹងមិនឲ្យឱកាសដល់ជនដទៃ ទើបឲ្យធ្វើរបងគគីរសងខាង តាំងខ្លោងទ្វារព្រះវិហាររហូតដល់ទ្វារព្រះរាជដំណាក់ព្រះរាជនិវេសន៍ ឲ្យពាសដោយសំពត់ ឲ្យសាង

ពិតានកម្រងផ្កា មានពណ៌ផ្សេងៗ ទំហំប៉ុនដើមត្នោត វិចិត្រដោយផ្កាយមាស សំយុងជារំយោល ឲ្យក្រាលដីដោយកម្រាលដ៏វិចិត្រ ឲ្យតាំងក្អមទឹកពេញ ទុកក្បែរគល់មាល័យ និងគ្រឿងក្រអូបទាំងសងខាង ដាក់ផ្កាក្នុងចន្លោះគ្រឿងក្រអូប ដាក់គ្រឿងក្រអូបក្នុងចន្លោះផ្កា ដើម្បីឲ្យក្លិនក្រអូបជៀសមករកផ្លូវ ហើយក្រាបទូលកត្តកាលដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគ ដែលពួកភិក្ខុចោមរោមហើយ យាងទៅកាន់ព្រះរាជមន្ទីរ ធ្វើភត្តកិច្ចហើយ ត្រឡប់មកកាន់វិហារខាងក្នុងរាំងននោះឯង ។ បុគ្គលណាម្នាក់ ចង់មើលក៏មើលមិនឃើញ ចាំបាច់ពោលថ្វីដល់បានថ្វាយភិក្ខាហារ និងការបូជានោះ ។

អ្នកនគរគិតថា ព្រះសាស្ដាកើតឡើងក្នុងលោកអស់ ៧ ឆ្នាំ ៧ ខែ ក្នុងថ្ងៃនេះ ពួកយើងមិនបានគាល់ នឹងពោលទៅថ្វីដល់ការថ្វាយភិក្ខា ការបូជា និងការស្ដាប់ធម៌នោះ ព្រះរាជាហួងហែងថា ព្រះពុទ្ធជារបស់អញ ព្រះសង្ឃជារបស់អញ ទើបទ្រង់ទំនុកបម្រុងតែម្នាក់ឯង ព្រះសាស្ដា កាលកើតឡើងគឺកើតដើម្បីប្រយោជន៍ដល់មនុស្សលោក និងទេវលោក មិនមែនកើតដើម្បីប្រយោជន៍សម្រាប់តែព្រះរាជាប៉ុណ្ណោះទេ នរកជារបស់ក្ដៅ សម្រាប់ព្រះរាជាមួយព្រះអង្គឯង ហើយអ្នកដទៃដូចជាផ្កាឧប្បលខៀវឬ ព្រោះដូច្នោះ ពួកយើងនឹងក្រាបទូលដល់ព្រះរាជាយ៉ាងនេះថា បើព្រះរាជាប្រទានព្រះសាស្ដាដល់ពួកយើងសោត ទុំះជាការល្អ បើមិនឲ្យ ពួកយើងនឹងច្បាំងជាមួយព្រះ-រាជា ហើយទទួលយកព្រះសង្ឃទៅធ្វើបុណ្យទានជាដើម ។ អ្នកនគរមិនអាចធ្វើយ៉ាងនេះបាន ពួកយើងនឹងកាន់យកមនុស្សម្នាក់ ឲ្យជាប្រធាន ដូច្នេះហើយ

ចូលទៅរកសេនាបតី ប្រាប់សេចក្តីនោះដល់លោក ហើយពោលថា នែលោក លោកនៅខាងខ្ញុំ ឬនៅខាងព្រះរាជា សេនាបតីពោលថា ខ្ញុំនៅខាងពួកអ្នក តែពួកអ្នកត្រូវឲ្យខ្ញុំក្នុងថ្ងៃដំបូង ។ ពួកអ្នកនគរក៏ទទួលពាក្យ ។ សេនាបតីចូលគាល់ព្រះរាជា ក្រាបទូលថា បពិត្រសម្មតិទេព អ្នកនគរនឹងសម្បានឹងព្រះអង្គ ។ ព្រះរាជាសួរថា នឹងសម្បារឿងអ្វី ។ សេនាបតីក្រាបទូលថា បានឮថា ព្រះអង្គមួយអង្គឯងប៉ុណ្ណោះទំនុកបម្រុងព្រះសាស្តា ពួកគេមិនបានទំនុកបម្រុង ។ ហើយទូលបន្តទៀតថា បើពួកគេបាន ពួកគេមិនក្រោធ បើមិនបានបំណងនឹងច្បាំងជាមួយព្រះអង្គ ។ ព្រះរាជាត្រាស់ថា អើ ច្បាំងក៏ច្បាំងចុះ ខ្ញុំមិនឲ្យភិក្ខុសង្ឃទេ ។ សេនាបតីទូលថា បពិត្រសម្មតិទេព ពួកទាសៈរបស់ព្រះអង្គពោលថា នឹងច្បាំងជាមួយព្រះអង្គ តើព្រះអង្គយកអ្នកណាទៅច្បាំង ។ ព្រះរាជាត្រាស់ថា ចុះលោក ជាសេនាបតីមិនមែនឬ ។ សេនាបតីទូលថា បើវៀរអ្នកនគរចេញទូលបង្គំអាច ។ លំដាប់នោះ ព្រះរាជាជ្រាបថា ពួកអ្នកនគរមានកម្លាំងសូម្បីសេនាបតីក៏ជាគ្នីគ្នារបស់អ្នកនគរទាំងនោះដែរ ទើបត្រាស់ថា ពួកអ្នកនគរ ចូរឲ្យភិក្ខុសង្ឃដល់ខ្ញុំ ៧ ឆ្នាំ និង ៧ ខែចុះ ។ ពួកអ្នកនគរមិនទទួល ព្រះរាជាទ្រង់បានបន្ថយចុះយ៉ាងនេះ គឺ ៦ ឆ្នាំ ៥ ឆ្នាំ រហូតដល់ ៧ ថ្ងៃ ។ អ្នកនគរអនុញ្ញាតដោយយល់ឃើញថា ការដែលខ្លួនធ្វើកម្មដ៏គ្រោតគ្រាតជាមួយព្រះរាជាក្នុងឥឡូវនេះ មិនសមគួរឡើយ ។ ព្រះរាជា ទ្រង់រៀបចំទានមុខសម្រាប់ ៧ ឆ្នាំ ៧ ខែ មកបូជាឲ្យអស់ក្នុង ៧ ថ្ងៃប៉ុណ្ណោះ កាលបុគ្គលណាមិនឃើញឲ្យទាន ៦ ថ្ងៃ ក្នុងទី ៧ ទើបហៅអ្នកនគរមកត្រាស់ថា

នៃបាទាំងឡាយ ពួកអ្នកអាចឲ្យទានដែលមានសភាពបែបនេះបានឬ ។ អ្នកនគរទាំងនោះក្រាបទូលថា ទាននោះ កើតឡើងដល់ព្រះអង្គ ព្រោះអាស្រ័យពួកទូលបង្គំប៉ុណ្ណោះមិនមែនឬ ព្រោះដូច្នោះ ពួកទូលបង្គំនឹងអាចថ្វាយទានបាន ។ ព្រះរាជាទ្រង់យកខ្នងដៃជូតទឹកភ្នែក ហើយក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គគិតថា នឹងធ្វើភិក្ខុ ៦ លាន ៨ សែនរូប ឲ្យជាភារៈរបស់អ្នកដទៃ ហើយទំនុកបម្រុងដោយបច្ច័យ ៤ ដរាបដល់អស់ជីវិត ឥឡូវនេះ ខ្ញុំព្រះអង្គអនុញ្ញាតឲ្យដល់អ្នកនគរហើយ បពិត្រព្រះមុនី អ្នកនគរខឹងសម្បាថា ខ្ញុំព្រះអង្គមិនបានថ្វាយទាន តាំងអំពីថ្ងៃនេះទៅ សូមទ្រង់អនុគ្រោះដល់ពួកអ្នកនគរទាំងនោះចុះ ។ ក្នុងថ្ងៃទី ២ សេនាបតីបានថ្វាយមហាទាន ។ បន្ទាប់ពីនោះ អ្នកនគរធ្វើសក្ការៈ និងសេចក្តីគោរពកោតក្រែងក្រៃលែងជាងសក្ការៈ ដែលព្រះរាជាទ្រង់ធ្វើហើយ បានថ្វាយទានដោយទំនងនោះឯង កាលដល់លំដាប់របស់អ្នកនគរ អ្នកនគរដែលនៅជិតទ្វារ បានត្រៀមសក្ការៈ និងការគោរពកោតក្រែងហើយ ។

កុដុម្ពិកមហាកាល ពោលនឹងកុដុម្ពិកចូឡកាលថា សក្ការៈ និងការគោរពរាប់អាននៃព្រះទសពល ដល់ពួកយើងក្នុងថ្ងៃស្អែកនេះ យើងនឹងធ្វើសក្ការៈដូចម្តេចហ្ន៎ ចូឡកាលពោលថា នែបងប្រុស បងប៉ុណ្ណោះ ចូរដឹង ។ មហាកាលពោលថា បើឯងធ្វើតាមការពេញចិត្តរបស់ខ្ញុំ ស្រូវសាលីដែលផើមហើយ នៅក្នុងស្រែ ប្រមាណ ១៦ ករីសរបស់យើង ខ្ញុំនឹងឲ្យគេហែកដង្ហើមស្រូវសាលី យកមកចម្អិនឲ្យសមគួរដល់ព្រះពុទ្ធទាំងឡាយ ចូឡកាលពោល

ថា បើយ៉ាងនេះ រមែងមិនជាឧបការៈដល់បុគ្គលណាម្នាក់ ព្រោះដូច្នោះ ទើបខ្ញុំមិនពេញចិត្តក្នុងសេចក្តីនោះ ។ មហាកាលពោលថា បើឯងពោលយ៉ាងនេះខ្ញុំក៏ធ្វើតាមគាប់ចិត្តរបស់ខ្ញុំ ហើយទើបបែងចែកស្រែ ១៦ ករីស ត្រង់ពាក់កណ្តាលជា ២ ចំណែកស្មើៗ គ្នា បោះព្រំក្នុងទី ៨ ករីស បកដង្ហើមស្រូវទៅកិនលាយដោយទឹកដោះ ដាក់របស់មធុរស ៤ ប្រភេទ ហើយថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ កាលហែកដង្ហើមស្រូវសាលីនោះហើយកាន់យក កាន់យកហើយ ក៏ត្រឡប់ពេញដូចដើម ។ ក្នុងកាលអំបុកបានថ្វាយទានដ៏លើសក្នុងអំបុក ក្នុងកាលស្រូវទុំ បានឲ្យទានដ៏លើស ព្រមជាមួយអ្នកស្រុក ក្នុងកាលច្រូត បានថ្វាយទានដ៏លើសជាមួយអ្នកស្រុកក្នុងកាលច្រូត ក្នុងកាលចង បានឲ្យទានដ៏លើសក្នុងកាលចង ក្នុងកាលជញ្ជូនជាដើម ក៏ថ្វាយទានដ៏លើសក្នុងកាលជញ្ជូន កាលស្រូវដល់លានក៏ឲ្យទានដ៏លើសក្នុងកាលស្រូវដល់លាន ក្នុងកាលបោកបែនបានឲ្យទានដ៏លើសក្នុងកាលបោកបែន ក្នុងកាលជញ្ជូនស្រូវដាក់ជង្រុក បានឲ្យទានដ៏លើសក្នុងកាលជញ្ជូនស្រូវដាក់ជង្រុក បានថ្វាយទានតាមកាល ៩ ដង សម្រាប់សន្ទូងតែមួយរដូវប៉ុណ្ណោះ ដូចពោលមកនេះ សន្ទូងទាំងនោះក៏នៅតាំងឡើងដដែល ។ លោកធ្វើសុចរិតកម្មតាមទំនងនោះឯង ដរាបណាដែលព្រះសម្មាសម្ពុទ្ធគង់ព្រះជន្មនៅ និងដរាបដែលមានព្រះសង្ឃគង់នៅ ។ ចុតិចាកអត្តភាពនោះហើយកើតក្នុងទេវលោក ។ អន្ទោលទៅក្នុងទេវតា និងមនុស្ស សោយសម្បត្តិអស់ ៩១ កប្ប ក្នុងវេលាដែលព្រះសាស្តានៃយើង ទ្រង់កើតឡើងក្នុងលោក កើត

ក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងស្រុកព្រាហ្មណទោណវត្ថុ មិនឆ្ងាយអំពីក្រុងកបិលពស្តុ ។ ក្នុងថ្ងៃដាក់ឈ្មោះ ពួកញាតិឲ្យឈ្មោះលោកថា កោណ្ឌញ្ញមាណព ។ លោកចម្រើនវ័យហើយ រៀនចប់ត្រៃវេទក្នុងលក្ខណៈមន្តទាំងឡាយ ។

សម័យនោះ ព្រះពោធិសត្វនៃយើងទ្រង់ចុតិអំពីជាន់តុសិត កើតក្នុងក្រុងកបិលពស្តុ ក្នុងថ្ងៃថ្វាយព្រះនាម ពួកញាតិបានអញ្ជើញព្រាហ្មណ៍ ១០៨ នាក់ ឲ្យស្លៀកសំពត់ថ្មី ឲ្យបរិភោគមធុបាយាសដែលមានទឹកតិច ហើយជ្រើសរើសយកព្រាហ្មណ៍ ៨ នាក់ ក្នុងរវាងព្រាហ្មណ៍ ១០៨ នោះ ឲ្យអង្គុយលើកម្រាលធំ ឲ្យព្រះពោធិសត្វប្រដាប់តាក់តែងហើយ ដាក់ឲ្យផ្ទំលើកែបដែលធ្វើអំពីសំពត់សាច់ម៉ដ្ឋ នាំមកកាន់សម្នាក់របស់ព្រាហ្មណ៍ទាំងនោះ ដើម្បីពិនិត្យមើលលក្ខណៈ ។ ព្រាហ្មណ៍អង្គុយលើអាសនៈធំ ពិនិត្យមើលសម្បត្តិនៃសរីរៈរបស់ព្រះមហាបុរសហើយ លើកឡើងនូវម្រាមដៃ ២ ។ មនុស្ស ៧ នាក់ លើកឡើងតាមលំដាប់យ៉ាងនេះ ។ បណ្តាព្រាហ្មណ៍ ៨ នាក់នោះ កោណ្ឌញ្ញមាណពដែលក្មេងជាងគេ លើកម្រាមដៃ ១ ឡើងថា មិនមានហេតុដែលព្រះអង្គទ្រង់នៅគ្រប់គ្រងផ្ទះ ព្រះរាជកុមារនេះ នឹងបានជាព្រះពុទ្ធ មានកិលេសដូចដំបូលបើកហើយ ដោយចំណែកមួយ ឯព្រាហ្មណ៍ទាំង ៧ នាក់ ឃើញគតិ ២ ថា បើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រ-ពត្តិ បើចេញបួស នឹងបានជាព្រះពុទ្ធ ទើបលើកឡើងនូវម្រាមដៃ ២ ។ ព្រះអញ្ញាកោណ្ឌញ្ញៈនេះ បានសាងបុញ្ញាធិការ ជាសត្វកើតក្នុងបច្ឆិមភព ក្រៃលែង

ជាងព្រាហ្មណ៍ទាំង ៧ ដោយបញ្ញា បានឃើញគតិត្រឹមតែមួយថា ឈ្មោះថា បុគ្គលប្រកបដោយលក្ខណៈទាំងនេះ មិនទៅគ្រប់គ្រងផ្ទះ នឹងបានជាព្រះពុទ្ធ ដោយឥតសង្ស័យ ព្រោះដូច្នោះ ទើបលើកម្រាមដៃ ១ ។

លំដាប់នោះ ព្រាហ្មណ៍ទាំងនោះទៅកាន់ផ្ទះរៀងៗខ្លួន ប្រឹក្សាជាមួយកូនទាំងឡាយថា នែកូន ឪពុកចាស់ហើយ បានឃើញ ឬមិនបានឃើញព្រះឱរសព្រះបាទសុទ្ធោទនមហារាជ ដែលជាអ្នកត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណពួកបា កាលព្រះរាជកុមារបានសម្រេចសព្វញ្ញុតញ្ញាណហើយ គប្បីបួសក្នុងសាសនារបស់ព្រះអង្គចុះ ។

ចំណែកព្រះបាទសុទ្ធោទនមហារាជ ទ្រង់ចាត់ការបរិហារ ដូចជាតែងតាំងមេដោះជាដើមសម្រាប់មើលថែព្រះពោធិសត្វ ឲ្យធំចម្រើនលូតលាស់ ឯព្រះពោធិសត្វទ្រង់ចម្រើនវ័យហើយ សោយសម្បត្តិដូចទេវតា កាលព្រះញាណចាស់ក្លាហើយ ទ្រង់ឃើញទោសក្នុងកាម ឃើញអានិសង្សក្នុងការចេញចាកកាម ទើបក្នុងថ្ងៃដែលរាហុលកុមារប្រសូត មាននាយឆន្នជាសម្លាញ់ ទ្រង់ឡើងផែលសេះកណ្ឋកៈ ចេញមហាភិនេស្រ្កមណ៍ តាមទ្វារដែលទេវតាបើកឲ្យ ទ្រង់យាងរំលង ៣ រាជអាណាខេត្ត ដោយមួយរាត្រីនោះឯង ទ្រង់បព្វជ្ជាត្រង់ប្រាំងស្ទឹងអនោមានទី លុះទ្រង់ទទួលទង់ជ័យនៃព្រះអរហន្ត ដែលឃដិការមហាព្រហ្មនាំមកថ្វាយប៉ុណ្ណោះ ដូចព្រះថេរៈមានវស្សា ១០០ ទ្រង់យាងដល់ក្រុងរាជគ្រឹះ ដោយព្រះឥរិយាបថដែលគួរជ្រះថ្លា ស្តេចត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះនោះ សោយបិណ្ឌបាតត្រង់ម្លប់នៃភ្នំ ឈ្មោះថា

បណ្ឌវៈ ត្រូវព្រះបាទមគធៈ ទ្រង់យាងឲ្យគ្រងរាជសម្បត្តិ ទ្រង់បដិសេធ ទ្រង់យាងដល់ឧរុវេលាប្រទេសដោយលំដាប់ ទ្រង់កើតព្រះតម្រិះ បែរមុខចំពោះសេចក្តីព្យាយាមថា ភូមិភាគនេះ គួរជាទីត្រេកអរហ្ន៎ ទីនេះ សមគួរធ្វើសេចក្តីព្យាយាមរបស់កុលបុត្រ ដែលត្រូវការធ្វើសេចក្តីព្យាយាមហ្ន៎ ដូច្នេះហើយ ទើបទ្រង់ប្រថាប់នៅក្នុងទីនោះ ។

សម័យនោះ ព្រាហ្មណ៍ ៧ នាក់ បានទៅតាមយថាកម្ម ឯកោណ្ឌញ្ញមាណព អ្នកពិនិត្យមើលលក្ខណៈនៅក្មេងជាងគេទាំងអស់ ជាអ្នកប្រាសចាកជំងឺតម្កាត់ ។ លោកជ្រាបថា ព្រះមហាបុរសទ្រង់ព្រះផ្នួសហើយ ទើបចូលទៅរកពួកកូនព្រាហ្មណ៍ទាំងនោះ ពោលយ៉ាងនេះថា បានឮថា ព្រះសិទ្ធត្ថរាជកុមារ ទ្រង់ព្រះផ្នួសហើយ នឹងបានជាព្រះពុទ្ធដោយឥតសង្ស័យ បើឪពុករបស់អ្នកទាំងឡាយ មិនមានជំងឺតម្កាត់រស់នៅសោត ថ្ងៃនេះ ក៏គប្បីចេញបួស បើអ្នកទាំងឡាយមានបំណងសោត មកចុះ ពួកយើងនឹងបួសតាមព្រះមហាបុរសនោះ បុត្រព្រាហ្មណ៍ទាំងនោះ ក៏មិនអាចនឹងមានឆន្ទៈតែមួយ ។ ៣ នាក់មិនបួស ៤ នាក់ទៀត មានកោណ្ឌញ្ញព្រាហ្មណ៍ជាប្រធានបួសហើយ ។ បព្វជិតទាំង ៥ នេះ ត្រាច់បិណ្ឌបាតក្នុងគាមនិគម និងរាជធានី បានទៅកាន់សម្នាក់ព្រះពោធិសត្វ ។ បព្វជិតទាំងនោះ កាលព្រះពោធិសត្វផ្តើមតាំងមហាបធានអស់ ៦ ឆ្នាំ គិតថា ឥឡូវនេះ ព្រះពោធិសត្វនឹងជាព្រះពុទ្ធ ឥឡូវនេះ ព្រះពោធិសត្វនឹងជាព្រះពុទ្ធ ទើបបម្រើព្រះមហាសត្វ បានជាអ្នកត្រាច់ទៅ ត្រាច់មក ក្នុងសម្នាក់ព្រះពោធិសត្វនោះ ។ កាលណាព្រះពោធិសត្វទ្រង់ឈប់

បន្អន់ដោយល្អ និងបាយមួយគ្រាប់ជាដើម ព្រោះទ្រង់ដឹងថា មិនអាចចាក់ធ្លុះចំពោះអរិយធម៌ ដោយទុក្ករកិរិយា ទើបសោយព្រះក្រយាហារគ្រោតគ្រាត កាលនោះ បព្វជិតទាំងនោះ ក៏ត្រឡប់ទៅកាន់ព្រៃឥសិបតនមិគទាយវ័ន ។

កាលនោះ ព្រះពោធិសត្វសោយក្រយាហារគ្រោតគ្រាត ធ្វើព្រះឆវីវណ្ណ ព្រះមំសៈ និងព្រះលោហិតឲ្យបរិបូណ៌ហើយ ។ ក្នុងថ្ងៃវិសាខបុណ្ណមី ទ្រង់សោយភោជនដ៏ល្អ ដែលនាងសុជាតាថ្វាយ ទ្រង់បណ្តែតថាសមាសទៅ ថាសមាសអណ្តែតច្រាសខ្សែទឹក ទើបទ្រង់ដាក់ព្រះហឫទ័យថា អាត្មាអញនឹងបានជាព្រះពុទ្ធក្នុងថ្ងៃនេះ អាត្មាអញនឹងបានជាព្រះពុទ្ធក្នុងថ្ងៃនេះ ។ ក្នុងវេលាល្ងាច កាលនាគរាជសរសើរដោយការសរសើរច្រើនរយ ។ ទ្រង់ឡើងកាន់មហាពោធិមណ្ឌលដ្ឋាន បែរព្រះភក្ត្រទៅកាន់លោកធាតុទិសខាងកើត អង្គុយពត់ភ្នែន ក្នុងទីដែលមិនញាប់ញ័រ អធិដ្ឋានសេចក្តីព្យាយាមប្រកបដោយអង្គ ៤ កាលព្រះអាទិត្យនៅគោចរនោះឯង ទ្រង់កម្ចាត់មារ និងសេនា បឋមយាម ទ្រង់រម្លឹកដល់បុព្វេនិវាសញ្ញាណ មជ្ឈិមយាម ទ្រង់ជម្រះទិព្វចក្ខុញាណ ក្នុងវេលាជាប់គ្នានៃបច្ចូសសម័យ ទ្រង់ដាក់ញាណចុះក្នុងបដិច្ចសមុប្បាទ ពិចារណាបច្ចយាការ ទាំងអនុលោម និងបដិលោម ត្រាស់ដឹងចំពោះព្រះសព្វញ្ញុតញ្ញាណ ដែលជាអសាធារណញ្ញាណ ដែលព្រះពុទ្ធគ្រប់អង្គទ្រង់ត្រាស់ដឹងហើយ ទ្រង់សម្រាកសម្រាន្តក្នុងពោធិមណ្ឌលនោះឯង អស់ ៧ ថ្ងៃ ដោយផលសមាបត្តិ ដែលមានព្រះនិព្វានជាអារម្មណ៍ ។

ដោយឧបាយនោះឯង ទ្រង់ប្រថាប់នៅនាពោធិមណ្ឌលដ្ឋាន ៧ សប្តាហ៍

សោយសជូវជុំត្រង់គល់កែស ហើយយាងត្រឡប់មកត្រង់គល់អជបាលនិគ្រោធ ប្រថាប់ក្នុងទីនោះ ទ្រង់ពិចារណាធម៌ដ៏ជ្រាលជ្រៅ កាលទ្រង់បង្អោនទៅក្នុងភាពជាអ្នកខ្វល់ខ្វាយតិច ដែលសហម្បតីមហាព្រហ្មអារាធនាហើយ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ទ្រង់ឃើញសត្វទាំងឡាយ មានសភាពផ្សេងៗ សត្វខ្លះ មានឥន្ទ្រិយចាស់ក្លា និងមានឥន្ទ្រិយទន់ខ្ចីជាដើម ទើបប្រទានបដិញ្ញាដល់សហម្បតីព្រហ្ម ដើម្បីសម្តែងធម៌ ទ្រង់ព្រះតម្រិះថា តថាគតនឹងសម្តែងធម៌ដល់អ្នកណាមុនហ្ន៎ ទ្រង់ជ្រាបថា អាឡារតាបស និងឧទកតាបស ធ្វើកាលកិរិយាហើយ កាលទ្រង់ត្រិះតទៅ ក៏កើតព្រះតម្រិះឡើងថា បញ្ចវគ្គិយ-ភិក្ខុ បម្រើតថាគត ក្នុងកាលដែលតថាគតប្រារព្ធសេចក្តីព្យាយាម រាប់ថាជាអ្នកមានឧបការៈច្រើនដល់តថាគត បើដូច្នោះ តថាគតគប្បីសម្តែងធម៌ដល់បញ្ចវគ្គិយមុន ។ សេចក្តីទាំងអស់នេះ ត្រឹមតែជាព្រះបរិវិតក្កនៃព្រះពុទ្ធប៉ុណ្ណោះ ។ វៀរកោណ្ឌញ្ញព្រាហ្មណ៍ចេញ បុគ្គលណាម្នាក់ ឈ្មោះថា អាចចាក់ធ្លុះធម៌មុនមិនមាន ។ ពិតហើយ កោណ្ឌញ្ញព្រាហ្មណ៍នេះបានធ្វើកម្ម គឺបុញ្ញាធិការមួយសែនកប្ប ដើម្បីប្រយោជន៍នេះឯង ដែលបានថ្វាយទានស្រូវសាលីដ៏លើសអស់វារៈ ៩ ដងដល់សង្ឃ មានព្រះពុទ្ធជាប្រធាន ។

លំដាប់នោះ ព្រះសាស្តាទ្រង់កាន់បាត្រ និងចីវរ យាងទៅព្រៃឥសិ-បតនមិគទាយវ័នដោយលំដាប់ ទ្រង់ចូលទៅរកបញ្ចវគ្គិយ ។ បញ្ចវគ្គិយទាំងនោះ ឃើញព្រះតថាគតយាងមក មិនអាចតាំងនៅក្នុងកតិការបស់ខ្លួន មួយអង្គលាងព្រះបាទ មួយអង្គបក់ផ្លិតស្ទឹកត្នោត ។ កាលបញ្ចវគ្គិយទាំងនោះ

សម្តែងវត្តយ៉ាងនេះហើយ អង្គុយក្នុងទីជិតព្រះសាស្តា ទ្រង់ធ្វើកោណ្ឌញ្ញត្ថេរឲ្យជាកាយសក្ខី ហើយទ្រង់ផ្តើមធម្មក្កប្បវត្តនសូត្រ មានបរិវដ្ដ: ៣ ដ៏កំពូល ។ មនុស្សបរិស័ទ គឺជនទាំង ៥ ព្រះសាស្តា ទ្រង់ធ្វើព្រះអញ្ញាកោណ្ឌញ្ញ:ប៉ុណ្ណោះ និងទេវបរិស័ទឲ្យតាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយពួកមហាព្រហ្ម ១៨ កោដិ ។ គ្រានោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា កោណ្ឌញ្ញ:ដឹងទូទៅដល់ធម៌ដែលតថាគតបាន គឺបានមកដោយការធ្វើសេចក្តីព្យាយាមដ៏តឹងតែងមុនបុគ្គលណាទាំងអស់ កាលទ្រង់ហៅព្រះថេរៈថា ភិក្ខុនេះ ឈ្មោះអញ្ញាកោណ្ឌញ្ញ: ទើបត្រាស់ថា **អញ្ញាសិ វត ភោ កោណ្ឌញ្ញោ អញ្ញាសិ វត ភោ កោណ្ឌញ្ញោ** កោណ្ឌញ្ញ:ដឹងទូទៅហើយហ្ន៎ កោណ្ឌញ្ញ:ដឹងទូទៅហើយហ្ន៎ ដូច្នេះ ។ ពាក្យនោះ ទើបជាឈ្មោះរបស់លោក ។ ដោយហេតុនោះ ទើបលោកពោលថា **ឥតិ ហិទំ អាយស្មតោ កោណ្ឌញ្ញស្ស អញ្ញាកោណ្ឌញ្ញោត្វេវ នាមំ អហោសិ** ដូច្នោះ ពាក្យថា **កោណ្ឌញ្ញ** ទើបបានជាឈ្មោះរបស់លោក ដូច្នោះ ព្រះថេរៈតាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃអាសាឡ្ហបុណ្ណមី ថ្ងៃ ១ រោច ព្រះភទ្ទិយត្ថេរ ថ្ងៃ ២ រោច ព្រះវប្បត្ថេរ ថ្ងៃ ៣ រោច ព្រះមហានាមត្ថេរ ថ្ងៃ ៤ រោច ព្រះអស្សជិត្ថេរ តាំងនៅក្នុងសោតាបត្តិផល ។ ឯថ្ងៃ ៥ រោច ចប់អនត្តលក្ខណសូត្រ ក៏តាំងនៅក្នុងភាពជាព្រះអរហន្តគ្រប់រូប ។ សម័យនោះឯង ក្នុងលោកមានព្រះអរហន្ត ៦ អង្គ ។

តាំងអំពីនោះមក ព្រះសាស្តា ទ្រង់ឲ្យមហាជនចុះកាន់អរិយភូមិយ៉ាងនេះ គឺបុរស ៥៥ រូប មានយសកុលបុត្រជាប្រធាន ភទ្ទវគ្គិយកុមារចំនួន

៣០ រូប ត្រង់ព្រៃកប្បាស បុរាណជដិលចំនួន ១០០០ រូប ត្រង់ជុំថ្ម នាគយាសីសប្រទេស ទ្រង់ឲ្យរាជបរិវារ ១១ ម៉ឺន មានព្រះបាទពិម្ពិសារជាប្រធាន តាំងនៅក្នុងសោតាបត្តិផល ១ ម៉ឺនតាំងនៅក្នុងសរណៈ ទ្រង់ធ្វើព្រះសាសនា ឲ្យចេញផ្កាផ្លែ ទូទៅពេញជម្ពូទ្វីប ទ្រង់ធ្វើមណ្ឌលជម្ពូទ្វីប ឲ្យរុងរឿងដោយកាសាវពស្ត្រ ដេរដាសទៅដោយអ្នកស្វែងរកបុណ្យ ។ សម័យមួយ ទ្រង់យាងដល់វត្តជេតពនមហាវិហារ ទ្រង់ស្ថិតនៅក្នុងទីនោះ ទ្រង់ប្រថាប់លើពុទ្ធាសនៈដែលគេក្រាលទុក ហើយទ្រង់សម្តែងធម៌នៅកណ្តាលពួកភិក្ខុសង្ឃ ដើម្បីប្រកាសថា កោណ្ឌញ្ញៈ បុត្រតថាគត ជាកំពូលជាងពួកភិក្ខុដែលត្រាស់ដឹងធម៌មុនគេ ទើបទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈ ។

ព្រះថេរៈឃើញព្រះអគ្គសាវកទាំង ២ ធ្វើសេចក្តីគោរព កោតក្រែងបំណងនឹងចៀសចេញទៅអំពីសម្នាក់របស់ព្រះពុទ្ធ ព្រោះឃើញថា បុណ្ណ-មាណពបួសហើយ នឹងបានជាកំពូលនៃធម្មកថិកក្នុងព្រះសាសនា ទើបត្រឡប់ទៅកាន់ស្រុកព្រាហ្មណ៍ឈ្មោះទោណវត្ថុ ដែលជាភូមិកំណើតរបស់លោក ឲ្យបុណ្ណៈជាក្មួយប្រុសបព្វជ្ជាហើយ គិតថា បុណ្ណមាណពនេះ នឹងនៅក្នុងសម្នាក់របស់ព្រះពុទ្ធ ទើបបានបញ្ជូនបុណ្ណៈនោះ ទៅក្នុងសម្នាក់របស់ព្រះសម្ពុទ្ធ ឯខ្លួនលោក ចូលទៅគាល់ព្រះទសពល សូមអនុញ្ញាតព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ សេនាសនៈក្បែរស្រុកភូមិ មិនជាសប្បាយសម្រាប់ខ្ញុំព្រះអង្គឡើយ ខ្ញុំព្រះអង្គមិនអាចនៅប្រឡូកប្រឡំ នឹងទៅកាន់ស្រះឆទ្ទន្ត ព្រះអង្គ ។ ក្រោកចាកអាសនៈ ថ្វាយបង្គំហើយ ទៅកាន់ស្រះឆទ្ទន្ត

អាស្រ័យហ្វូងដំរីត្រកូលឆទ្ទន្ត សម្រាកសម្រាន្តនៅអស់ ១២ ឆ្នាំ បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងទីនោះឯង ៗល។

## អដ្ឋកថា សូត្រទី ១ ចប់

# អដ្ឋកថា សូត្រទី ២-៣

# ប្រវត្តិព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានត្ថេរ

ក្នុងសូត្រទី ២ និងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **មហាបញ្ញានំ** បានដល់ ប្រកបដោយបញ្ញាដ៏ច្រើន ។ បទថា **ឥទ្ធិមន្តានំ** បានដល់ ដែលសម្បូរដោយឫទ្ធិ ។ ពាក្យថា **សារីបុត្ត** និង **មោគ្គល្លាន** ជាឈ្មោះរបស់ព្រះថេរៈទាំង ២ នោះ ។ ក្នុងបញ្ហាកម្មរបស់ព្រះថេរៈទាំង ២ រូបនេះ មានរឿងដែលពោលតាមលំដាប់ដូច្នេះ

ក្នុងទីបំផុតមួយអសង្ខេយ្យ និងមួយសែនកប្ប រាប់អំពីកប្បនេះទៅក្រោយ ព្រះសារីបុត្រកើតក្នុងត្រកូលព្រាហ្មណមហាសាល ឈ្មោះសរទ-មាណព ។ ឯព្រះមោគ្គល្លានកើតក្នុងត្រកូលគហបតីមហាសាល ឈ្មោះសិរីវឌ្ឍកុដុម្ពិកៈ ជនទាំង ២ ជាសម្លាញ់លេងដីជាមួយគ្នាមក កាលបិតាអនិច្ចកម្មទៅ សរទមាណពក៏បានទ្រព្យជាច្រើន ដែលជាសម្បត្តិនៃត្រកូល ថ្ងៃមួយ នៅក្នុងទីសម្ងំ គិតថា អញមិនដឹងអត្តភាពក្នុងលោកនេះ មិនដឹង

អត្តភាពក្នុងលោកដទៃ ឈ្មោះថា សេចក្ដីស្លាប់ជារបស់ពិត សម្រាប់ពួកសត្វដែលកើតមកហើយ ។ គួរតែអញកាន់យកភេទជាអ្នកបួសឯណានីមួយស្វែងរកមោក្ខធម៌ ។ សរទមាណពនោះ ទៅរកសម្លាញ់ ពោលថា សិរីវឌ្ឍសម្លាញ់ ខ្ញុំនឹងចេញបួសស្វែងរកមោក្ខធម៌ ឯងបួសជាមួយខ្ញុំដែរឬទេ ។ សិរីវឌ្ឍកុដុម្ពិកៈឆ្លើយថា មិនបានទេ សម្លាញ់ ឯងបួសម្នាក់ឯងចុះ ។ សរទមាណពគិតថា មនុស្សកាលទៅបរលោក មិនមែននាំសម្លាញ់ ឬញាតិមិត្តទៅផងឡើយ កម្មដែលខ្លួនធ្វើជារបស់ខ្លួនតែម្នាក់គត់ ។ បន្ទាប់អំពីនោះ ក៏ប្រាប់ឲ្យបើកទ្វារឃ្លាំងរតនៈ ឲ្យមហាទានដល់ជនកំព្រា អ្នកដើរផ្លូវឆ្ងាយ វណិពកៈ និងយាចកទាំងឡាយ ហើយបួសជាឥសី មានមនុស្សបួសតាមសរទមាណពនោះយ៉ាងនេះ គឺម្នាក់ខ្លះ ពីរនាក់ខ្លះ បីនាក់ខ្លះ បានជាក្រុមជដិលប្រមាណ ៧៤០០០ នាក់ ។ សរទឥសីនោះ ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតហើយ ក៏បង្រៀនកសិណបរិកម្មដល់ជដិលទាំងនោះ ។ ជដិលទាំងនោះក៏ធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតឡើងគ្រប់រូប ។

សម័យនោះ ព្រះពុទ្ធទ្រង់ព្រះនាមថា អនោមទស្សី ទ្រង់កើតឡើងក្នុងលោក ។ មាននគរឈ្មោះចន្ទវតី ព្រះពុទ្ធបិតាជាក្សត្រ ព្រះនាមថា យសវន្ត ។ ព្រះពុទ្ធមាតា ជាព្រះទេវីព្រះនាមថា យសោធរា ។ ដើមឈើដែលត្រាស់ដឹងឈ្មោះថា អជ្ជុនព្រឹក្ស គឺដើមអង្គ្រែង ។ ព្រះអគ្គសាវកទាំង ២ ឈ្មោះថា ព្រះនិសភត្ថេរ និងព្រះអនោមត្ថេរ ។ ពុទ្ធុបដ្ឋាក ឈ្មោះវរុណត្ថេរ ។ អគ្គសាវិកាទាំង ២ ឈ្មោះសុន្ទរា និងសុមនា ។ ទ្រង់មានព្រះជន្មាយុ ១ សែន

ឆ្នាំ ។ ព្រះវរកាយកម្ពស់ ៥៨ ហត្ថ រស្មីផ្សាយចេញអំពីព្រះវរកាយ ១២ យោជន៍ ។ មានភិក្ខុជាបរិវារ ១ សែន ។ ថ្ងៃមួយ ព្រះអនោមទស្សីសម្ពុទ្ធ ចេញអំពីព្រះមហាករុណាសមាបត្តិ ទ្រង់ប្រមើលមើលលោកក្នុងពេលជិតភ្លឺ ទ្រង់ឃើញសរទតាបស ទ្រង់ព្រះតម្រិះថា ថ្ងៃនេះ ព្រោះតថាគតទៅរកសរទៈ ជាបច្ច័យ នឹងមានធម្មទេសនាយ៉ាងធំ ហើយសរទតាបសនោះ នឹងប្រាថ្នាតំណែងអគ្គសាវក សិរិវឌ្ឍកុដុម្ពិកៈរបស់គេ នឹងប្រាថ្នាតំណែងទុតិយសាវក ចប់ទេសនា ជដិល ៧៤០០០ រូបដែលជាបរិវាររបស់សរទៈ នឹងសម្រេចអរហត្ត គួរតែតថាគតទៅក្នុងទីនោះ ។ ដូច្នេះហើយ ទ្រង់កាន់បាត្រ និងចីវររបស់ទ្រង់ មិនហៅភិក្ខុដទៃ យាងទៅមួយព្រះអង្គឯង ដូចរាជសីហ៍ ។ កាលពួកអន្តេវាសិកសិស្សរបស់សរទតាបស ចេញទៅស្វែងរកផ្លែឈើ ទ្រង់អធិដ្ឋានថា ចូរសរទតាបសដឹងថា តថាគតជាព្រះពុទ្ធ ក្នុងកាលសរទ-តាបសកំពុងមើលនោះឯង ក៏ចុះអំពីអាកាស ប្រថាប់ឈរលើផែនដី ។

សរទតាបសឃើញព្រះពុទ្ធានុភាព និងព្រះសរីរសម្បត្តិរបស់ព្រះអង្គ ទើបពិចារណាលក្ខណមន្ត ក៏ដឹងថា ធម្មតាបុគ្គលដែលប្រកបដោយលក្ខណៈទាំងនេះ កាលនៅគ្រប់គ្រងផ្ទះ ក៏នឹងបានជាស្តេចចក្រពត្តិ កាលបួស ក៏នឹងបានជាព្រះសព្វញ្ញូពុទ្ធ ទ្រង់បើកកិលេស ដូចដំបូលចេញហើយក្នុងលោក មហាបុរសនេះ ពិតជាព្រះពុទ្ធដោយឥតសង្ស័យ ទើបចេញទៅទទួល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាលអាសនៈថ្វាយ ។ ព្រះមានព្រះភាគប្រថាប់គង់លើអាសនៈដែលក្រាលហើយ ។ សរទតាបសក៏កាន់យកអាសនៈដែលសម

គួរដល់ខ្លួន អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ សម័យនោះ ជដិល ៧ ម៉ឺន ៤ ពាន់នាក់ ក៏កាន់ផលាផល មានឱជៈប្រណីតៗ មកដល់សម្នាក់របស់អាចារ្យ សម្លឹងមើលអាសនៈដែលព្រះពុទ្ធ និងអាចារ្យអង្គុយហើយ ពោលថា លោកអាចារ្យ ពួកខ្ញុំត្រាច់ទៅដោយយល់ថា មិនមាននរណាជាធំជាងលោកអាចារ្យក្នុងលោកនេះ តែបុរសនេះ ប្រហែលជាធំជាងលោកអាចារ្យពិត ។ សរទតាបសពោលថា បាអើយ អ្នកនិយាយអ្វី ពួកអ្នកបំណងនឹងប្រៀបធៀបស្តេចភ្នំសិនេរុដែលមានកម្ពស់ ៦ លានយោជន៍ ធ្វើឲ្យប៉ុនគ្នានឹងគ្រាប់ស្ពៃឬ នែបា អ្នកកុំប្រៀបធៀបខ្ញុំនឹងព្រះសព្វញ្ញុពុទ្ធឡើយ ។ គ្រានោះ ជដិលទាំងនោះគិតថា បើបុរសនេះជាសត្វថោកថយសោត អាចារ្យរបស់អញ មិននាំមកប្រៀបធៀបដូច្នេះឡើយ ឱ ! បុរសនេះជាធំហ្ន៎ ទើបមាណពគ្រប់រូបឱនក្បាលទៀបព្រះយុគលបាទ ថ្វាយបង្គំដោយសិរសា គឺត្បូង ។ លំដាប់នោះ ទើបអាចារ្យពោលនឹងជដិលទាំងនោះថា បាអើយ ទេយ្យធម៌របស់យើងដែលគួរដល់ព្រះសម្មាសម្ពុទ្ធមិនមានឡើយ ។ ក្នុងវេលាភិក្ខាចារ ព្រះសាស្តាយាងមកហើយក្នុងទីនេះ ពួកយើងនឹងថ្វាយទេយ្យធម៌តាមកម្លាំង ចូរពួកអ្នកនាំផលាផលដែលប្រណីតៗ របស់យើងមក ហើយឲ្យនាំមក លាងដៃហើយ ដាក់ក្នុងបាត្ររបស់ព្រះតថាគតដោយខ្លួនឯង ។ ព្រះសាស្តាទ្រង់ទទួលផលាផល ទេវតាទាំងឡាយក៏ដាក់ទិព្វឱជៈចូល ។ តាបសត្រងទឹកថ្វាយដោយខ្លួនឯង ។ លំដាប់នោះ កាលព្រះសាស្តាប្រថាប់គង់សោយស្រេចហើយ តាបសក៏ហៅអន្តេវាសិកគ្រប់គ្នាមក អង្គុយពោលតែវាចា ដែលជា

សាវណីយកថា ក្នុងសម្នាក់ព្រះសាស្តា ។

ព្រះសាស្តាទ្រង់ត្រិះរិះថា អគ្គសាវកទាំង ២ ចូរមក មួយអន្លើដោយភិក្ខុសង្ឃ ។ ព្រះអគ្គសាវកដឹងព្រះតម្រិះរបស់ព្រះសាស្តា មានព្រះខីណាស្រពមួយសែនអង្គជាបរិវារ មកថ្វាយបង្គំព្រះសាស្តា ហើយឈរក្នុងទីសមគួរ នាចំណែកម្ខាង ។

លំដាប់នោះ សរទតាបសហៅពួកអន្តេវាសិកមកពោលថា បាទាំងឡាយ អាសនៈដែលព្រះពុទ្ធប្រថាប់គង់ក៏ទាប អាសនៈដែលសមណៈមួយសែនអង្គ គង់ក៏មិនមាន ថ្ងៃនេះ គួរតែអ្នកទាំងឡាយធ្វើពុទ្ធសក្ការៈឲ្យខ្ពស់ អ្នកទាំងឡាយចូរនាំផ្កាដែលសម្បូរដោយពណ៌ និងក្លិនអំពីជើងភ្នំមក ។ ក្នុងខណៈដែលពោលហាក់ដូចជាយឺតយូរ តែវិស័យរបស់អ្នកមានឫទ្ធិជាអចិន្តេយ្យ ព្រោះដូច្នោះ ទើបតាបសទាំងនោះ នាំផ្កាដែលសម្បូរដោយពណ៌ និងក្លិនមក ត្រឹមតែមួយសន្ទុះប៉ុណ្ណោះ តាក់តែងអាសនៈផ្កាប្រមាណមួយយោជន៍ សម្រាប់ព្រះពុទ្ធ ៣ គាវុតសម្រាប់អគ្គសាវកទាំងឡាយ កន្លះយោជន៍សម្រាប់ភិក្ខុដ៏សេសជាដើម ១ ឧសភៈសម្រាប់ភិក្ខុថ្មីក្នុងសង្ឃ ។ កាលតាក់តែងអាសនៈស្រេចបាច់ហើយ សរទតាបសឈរផ្គងអញ្ជលីចំពោះព្រះភក្ត្រព្រះតថាគត ហើយក្រាបលទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ឡើងកាន់អាសនៈផ្កានេះ ដើម្បីប្រយោជន៍ និងសេចក្តីសុខដល់ខ្ញុំព្រះអង្គអស់កាលយូរចុះ ។ ហើយទើបពោលគាថាពន្ធដូច្នេះថា

**នានាបុប្ផញ្ច គន្ធញ្ច សម្បាទេត្វាន ឯកតោ**
**បុប្ផាសនំ បញ្ញាបេត្វា ឥទំ វចនមព្រវី ។បេ។**

ខ្ញុំព្រះអង្គនាំគ្នាប្រមូលផ្កាផ្សេងៗ និងគ្រឿងក្រអូប មកតាក់តែងអាសនៈផ្កា បានក្រាបទូលពាក្យនេះថា បពិត្រមហាវីរៈ អាសនៈនេះ តាក់តែងដើម្បីព្រះអង្គ សមគួរដល់ព្រះអង្គ សូមព្រះអង្គញុំាងចិត្តរបស់ខ្ញុំព្រះអង្គ ឲ្យផូរផង់ ប្រថាប់គង់លើអាសនៈផ្កាចុះ ។ ព្រះពុទ្ធបានប្រថាប់គង់លើអាសនៈផ្កាអស់ ៧ ថ្ងៃ ៧ យប់ ធ្វើចិត្តខ្ញុំឲ្យផូរផង់ ធ្វើមនុស្សលោកព្រមទាំងទេវលោកឲ្យត្រេកអរ ។

កាលព្រះសាស្តាប្រថាប់គង់យ៉ាងនេះហើយ អគ្គសាវកទាំង ២ និងភិក្ខុដ៏សេស គង់លើអាសនៈដែលសមគួររៀងៗ ខ្លួន ។ សរទតាបសកាន់ឆត្រផ្កាធំ ឈរបាំងលើព្រះសីសៈព្រះតថាគត ។ ព្រះសាស្តា ទ្រង់ចូលនិរោធសមាបត្តិ ដោយព្រះតម្រិះថា សក្ការៈនេះ ចូរមានផលច្រើនដល់ជដិលទាំងឡាយ ។ អគ្គសាវកទាំង ២ ក្តី ភិក្ខុដ៏សេសក្តី ដឹងថា ព្រះសាស្តាទ្រង់ចូលសមាបត្តិ ក៏នាំគ្នាចូលសមាបត្តិ ។ កាលព្រះតថាគតគង់ចូលនិរោធសមាបត្តិអស់ ៧ ថ្ងៃ ពួកអន្តេវាសិក កាលដល់វេលាភិក្ខាចារ ក៏បរិភោគមូលផលាហារ ដែលជារបស់កើតនៅក្នុងព្រៃ ក្នុងវេលាដ៏សេស ក៏ឈរផ្គងអញ្ជលីដល់ព្រះសម្ពុទ្ធ ។ ឯសរទតាបស សូម្បីភិក្ខាចារក៏មិនទៅ សម្រាកសម្រាន្តនៅដោយបីតិ និងសុខអស់ ៧ ថ្ងៃ ដោយនៅកាន់ឆត្រផ្កានោះឯង ។

ព្រះសាស្តា ទ្រង់ចេញអំពីនិរោធសមាបត្តិហើយ ត្រាស់ហៅព្រះនិសភត្ថេរអគ្គសាវក ដែលអង្គុយនៅខាងស្តាំ ហើយត្រាស់ថា និសភៈ អ្នកចូរធ្វើបុប្ផសនានុមោទនាដល់តាបសទាំងឡាយ ដែលធ្វើសក្ការៈ ។ ព្រះថេរៈសប្បាយចិត្ត ដូចទាហានធំបានលាភមកអំពីសម្នាក់របស់ស្តេចចក្រពត្តិ តាំងនៅក្នុងសាវកបារមីញាណ ផ្តើមអនុមោទនាទាក់ទងដោយការថ្វាយអាសនៈផ្កា ។ ក្នុងវេលាចប់ទេសនារបស់អគ្គសាវកនោះ ទើបត្រាស់ហៅទុតិយសាវកថា ម្នាលភិក្ខុ សូម្បីអ្នកក៏ចូរសម្តែងធម៌ ។ ឯព្រះអនោមត្ថេរពិចារណាព្រះត្រៃបិដក ពុទ្ធវចនៈច្រើន ពោលធម្មកថា ។ ដោយទេសនានៃព្រះអគ្គសាវកទាំង ២ ជដិល សូម្បីត្រឹមតែមួយរូប ក៏មិនបានត្រាស់ដឹង ។ លំដាប់នោះ ព្រះសាស្តាទ្រង់តាំងនៅក្នុងពុទ្ធវិស័យ ដែលមិនមានប្រមាណទ្រង់ផ្តើមព្រះធម្មទេសនា ។ ក្នុងវេលាចប់ទេសនា វៀរសរទតាបស ជដិលទាំងអស់ ៧៤០០០ រូប សម្រេចអរហត្ត ។ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា ចូរជាភិក្ខុចុះ ។ ក្នុងខណៈនោះឯង សក់ និងពុកមាត់របស់ជដិលទាំងនោះក៏បាត់ទៅ បរិក្ខារ ៨ បានស្រោបចូលកាយមួយរំពេច ។

សួរថា ព្រោះហេតុអ្វី ទើបសរទតាបសមិនសម្រេចអរហត្ត ឆ្លើយថាព្រោះចិត្តរាយមាយ ។ បានឮថា ចាប់តាំងអំពីស្តាប់ព្រះធម្មទេសនារបស់ព្រះអគ្គសាវកដែលគង់លើអាសនៈទី ២ របស់ព្រះពុទ្ធ ដែលតាំងនៅក្នុងសាវក-បារមីញាណសម្តែងធម៌ សរទតាបសនោះ កើតការគិតឡើងយ៉ាងនេះថា ឱហ្ន៎ ! អញក៏គួរបាននាទីជាសាវកនេះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ

ដែលកើតឡើងក្នុងអនាគត សរទតាបសនោះ មិនអាចធ្វើឲ្យជាក់ច្បាស់នូវមគ្គផល ព្រោះបរិវិតក្កនោះ ទើបថ្វាយបង្គំព្រះតថាគត ហើយឈរចំពោះព្រះភក្ត្រក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលអង្គុយលើអាសនៈ ជាប់នឹងព្រះអង្គឈ្មោះអ្វី ក្នុងសាសនារបស់ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ភិក្ខុនេះ ជាអ្នកប្រកាសធម្មចក្រ ដែលតថាគតប្រកាសហើយ ដល់នូវទីបំផុតនៃសាវកបារមីញាណ ចាក់ធ្លុះនូវសោឡសបញ្ញា ឈ្មោះថា និសភត្ថេរអគ្គសាវក ក្នុងសាសនារបស់តថាគត ។ សរទតាបសបានស្តាប់ហើយ ទើបបានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបាំងឆត្រផ្កាអស់ ៧ ថ្ងៃ ធ្វើសក្ការៈនេះ ដោយផលរបស់សក្ការៈនេះ ខ្ញុំព្រះអង្គមិនបានប្រាថ្នាជាព្រះឥន្ទ្រ ឬជាព្រហ្មណាទីមួយឡើយ តែក្នុងអនាគត ខ្ញុំព្រះអង្គគប្បីបានជាអគ្គសាវករបស់ព្រះពុទ្ធអង្គណាមួយ ដូចព្រះនិសភត្ថេរនេះ ។

ព្រះសាស្តា ទ្រង់បញ្ជូនអនាគតំសញ្ញាណទៅ ប្រមើលមើលថា សេចក្តីប្រាថ្នារបស់តាបសនេះ នឹងសម្រេចឬទេហ្ន៎ ក៏ទ្រង់បានឃើញថា មួយអសង្ខេយ្យ ក្រៃលែងដោយសែនកប្បនឹងបានសម្រេច កាលទ្រង់ឃើញហើយ ទើបត្រាស់នឹងសរទតាបសថា ការប្រាថ្នានេះ របស់អ្នកមិនជារបស់ទទេ ក្នុងអនាគតកន្លងទៅមួយអសង្ខេយ្យ និងសែនកប្ប ព្រះពុទ្ធព្រះនាមគោតមនឹងកើតឡើងក្នុងលោក មានពុទ្ធមាតា ព្រះនាមមហាមាយាទេវី ព្រះពុទ្ធបិតា ព្រះនាមសុទ្ធោទនមហារាជ មានព្រះឱរស ព្រះនាមរាហុល មានឧបដ្ឋាកឈ្មោះអានន្ទ មានទុតិយសាវកឈ្មោះមោគ្គល្លាន ឯអ្នកនឹងបាន

ជាអគ្គសាវករបស់ព្រះគោតមនោះ ឈ្មោះថា ធម្មសេនាបតីសារីបុត្រ កាល ទ្រង់ព្យាករតាបសនោះយ៉ាងនេះហើយ ត្រាស់ធម្មកថា មានភិក្ខុសង្ឃជា បរិវារ ទ្រង់ហោះទៅតាមអាកាស ។

ឯសរទតាបសទៅកាន់សម្នាក់របស់ព្រះថេរៈ ដែលធ្លាប់ជាអន្តេវាសិក ហើយឲ្យបញ្ជូនដំណឹងដល់សិរីវឌ្ឍកុដុម្ពិកៈជាសម្លាញ់ថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ប្រាប់សម្លាញ់របស់ខ្ញុំថា សរទតាបសសម្លាញ់របស់អ្នក ប្រាថ្នាតំណែងឯតទគ្គៈ ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ដែលទ្រង់កើត ឡើងក្នុងអនាគត ទៀបបាទមូលរបស់ព្រះអនោមទស្សីសម្ពុទ្ធ ឯអ្នកចូរប្រាថ្នា តំណែងជាទុតិយសាវកចុះ កាលពោលយ៉ាងនេះហើយ ក៏ទៅមុនព្រះថេរៈ ទាំងឡាយ បានឈរនៅត្រង់ទ្វារនិវេសរបស់សិរីវឌ្ឍកុដុម្ពិកៈ ។

សិរីវឌ្ឍកុដុម្ពិកៈប្រាស្រ័យថា យូរហើយហ្ន៎ លោកម្ចាស់មិនបានមក រួចឲ្យអង្គុយលើអាសនៈ ឯខ្លួនអង្គុយលើអាសនៈទាបជាងសួរថា អន្តេវា-សិកដែលជាបរិស័ទរបស់លោកម្ចាស់ ហាក់ដូចជាមិនប្រាកដ សរទតាបស ពោលថា ចម្រើនពរសម្លាញ់ ព្រះអនោមទស្សីសម្ពុទ្ធយាងមកក្នុងអាស្រម របស់ពួកអាត្មាភាព ពួកអាត្មាភាពបានធ្វើសក្ការៈដល់ព្រះអង្គតាមកម្លាំង រៀងៗ ខ្លួន ព្រះសាស្ដាទ្រង់សម្ដែងធម៌ដល់តាបសទាំងអស់ ក្នុងវេលាចប់ ទេសនា តាបសដ៏សេសសម្រេចអរហត្ត វៀរតែអាត្មាម្នាក់ប៉ុណ្ណោះ ។ សិរី-វឌ្ឍកុដុម្ពិកៈសួរថា ចុះហេតុអ្វី ទើបលោកម្ចាស់មិនបួស ។ សរទតាបស ពោលថា អាត្មាឃើញព្រះនិសភត្ថេរអគ្គសាវករបស់ព្រះសាស្ដា ហើយបាន

ប្រាថ្នាតំណែងអគ្គសាវក ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមថាគោតម ដែលទ្រង់កើតឡើងក្នុងអនាគត សូម្បីអ្នកក៏ចូរប្រាថ្នាតំណែងទុតិយសាវក ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធអង្គនោះ ។ សិរិវឌ្ឍកុដុម្ពិកៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនមានការស្និទ្ធស្នាលជាមួយព្រះសម្ពុទ្ធ ។ សរទតាបសពោលថា ការក្រាបទូលព្រះសម្ពុទ្ធ ទុកជាភារៈរបស់អាត្មាភាពចុះ ចូរអ្នកត្រៀមអធិការ គឺសក្ការៈដ៏កំពូលចុះ ។ សិរិវឌ្ឍកុដុម្ពិកៈស្ដាប់ពាក្យរបស់សរទតាបសហើយ ទើបឲ្យរៀបចំទីប្រមាណ ៨ ករីស ដោយឈើដើងដីរឲ្យមានផ្ទៃដីស្មើគ្នា ក្នុងនិវេសន៍របស់ខ្លួន ហើយឲ្យរោយខ្សាច់ រោយផ្កាដែលមានលាជជាគម្រប់ ៥ ឲ្យធ្វើមណ្ឌបប្រក់ដោយផ្កាឈូក តាក់តែងពុទ្ធាសនៈរៀបចំអាសនៈសម្រាប់ភិក្ខុដ៏សេស ត្រៀមគ្រឿងសក្ការៈ ធ្វើសក្ការៈធំ ឲ្យសញ្ញាដល់សរទតាបស ដើម្បីទូលនិមន្តព្រះសម្ពុទ្ធ តាបសបានស្ដាប់ពាក្យរបស់សិរិវឌ្ឍកុដុម្ពិកៈនោះហើយ ទើបនាំភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានទៅកាន់និវេសន៍របស់សិរិវឌ្ឍកុដុម្ពិកៈនោះ ។ សិរិវឌ្ឍកុដុម្ពិកៈធ្វើការទទួលពុទ្ធដំណើរ ទទួលបាត្រអំពីព្រះហស្តរបស់ព្រះតថាគត និមន្តឲ្យចូលទៅកាន់មណ្ឌប ថ្វាយទក្ខិណោទកដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អង្គុយក្នុងអាសនៈដែលបានរៀបចំហើយ អង្គាសដោយភោជនដ៏ប្រណីត ក្នុងវេលាស្រេចភត្តកិច្ច ឲ្យភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន គ្រងសំពត់ដែលគួរដល់តម្លៃច្រើន ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ការផ្ដើមនេះ ដើម្បីឋានៈដែលមានប្រមាណតូចតាចក៏មិនមែន សូមទ្រង់ធ្វើសេចក្ដីអនុគ្រោះ អស់

កាល ៧ ថ្ងៃ ដោយទំនងនេះផងចុះ ព្រះសាស្តា ទ្រង់ទទួលនិមន្តន៍ហើយ សិរីវឌ្ឍកុដុម្ពិកៈនោះ ញុំាងមហាទានឲ្យប្រព្រឹត្តទៅមិនដាច់ អស់ ៧ ថ្ងៃ ដោយទំនងនោះឯង ហើយថ្វាយបង្គំព្រះមានព្រះភាគ ឈរផ្គងអញ្ជលីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សរទតាបស សម្លាញ់របស់ខ្ញុំព្រះអង្គ ប្រាថ្នាសូមឲ្យបានជាអគ្គសាវ័ករបស់ព្រះសាស្តាអង្គណា ខ្ញុំព្រះអង្គ សូមបានជាទុតិយសាវ័ករបស់ព្រះសាស្តាអង្គនោះដូចគ្នា ។ ព្រះសាស្តាទ្រង់ប្រមើលមើលអនាគត ទ្រង់ឃើញថា ការប្រាថ្នារបស់ជននេះ នឹងសម្រេច ទើបទ្រង់ព្យាករថា ក្នុងកាលកន្លងទៅមួយអសង្ខេយ្យ និងមួយសែនកប្បអំពីកប្បនេះទៅ អ្នកនឹងបានជាទុតិយសាវ័ករបស់ព្រះគោតមសម្ពុទ្ធ ។ សិរីវឌ្ឍកុដុម្ពិកៈបានស្តាប់ពាក្យព្យាកររបស់ព្រះពុទ្ធហើយ ជាអ្នកត្រេកអរ ។ ចំណែកព្រះសាស្តាទ្រង់ធ្វើកត្តានុមោទនាហើយ មួយអន្លើដោយបរិវារយាងត្រឡប់ទៅកាន់ព្រះវិហារ ។ តាំងអំពីនោះមក សិរីវឌ្ឍកុដុម្ពិកៈធ្វើសុចរិតកម្មរហូតដល់អស់ជីវិត ហើយទៅកើតក្នុងទេវលោកជាន់កាមាវចរក្នុងវារៈចិត្តទី ២ ។

សរទតាបសចម្រើនព្រហ្មវិហារធម៌ ៤ បានទៅកើតក្នុងព្រហ្មលោក ។ តាំងអំពីនោះមក លោកមិនពោលដល់កម្មក្នុងរវាងលោកទាំង ២ នេះ ។

មុនការកើតឡើងនៃព្រះពុទ្ធរបស់យើងនោះឯង សរទតាបសបដិសន្ធិក្នុងគភ៌របស់សារីព្រាហ្មណី ក្នុងស្រុកឧបតិស្សគ្រាម មិនឆ្ងាយអំពីក្រុងរាជគ្រឹះ ។ ក្នុងថ្ងៃនោះឯង សម្លាញ់របស់សរទតាបសនោះ ក៏កាន់យកបដិសន្ធិក្នុងគភ៌នៃមោគ្គល្លីព្រាហ្មណី ក្នុងស្រុកកោលិតគ្រាម ដែលមិនឆ្ងាយ

អំពីក្រុងរាជគ្រឹះដូចគ្នា បានឮថា ត្រកូលទាំង ២ នោះ បានជាសម្លាញ់ជាប់តគ្នាមក ៧ ជួរត្រកូលនោះឯង ។

ញាតិទាំងឡាយ បានឲ្យការបរិហារគភ៌ដល់មនុស្សទាំង ២ នោះក្នុងថ្ងៃតែមួយ បាននាំមេដោះ ៦៦ នាក់ ចូលទៅឲ្យដល់ជនទាំង ២ នោះ បុគ្គលដែលកើតហើយ កាលកន្លងទៅ ១០ ខែ ។ ក្នុងថ្ងៃដាក់ឈ្មោះ ញាតិទាំងឡាយបានដាក់ឈ្មោះកូនសារីព្រាហ្មណីថា ឧបតិស្សៈ ព្រោះជាកូនរបស់ប្រធាននៃត្រកូលក្នុងស្រុកឧបតិស្សគ្រាម តាំងឈ្មោះបុត្រក្រៅអំពីនេះថា កោលិតៈ ព្រោះជាកូនរបស់ប្រធានត្រកូលក្នុងស្រុកកោលិតគ្រាម ជនទាំង ២ នោះចម្រើនវ័យហើយ ក៏សម្រេចសិល្បសាស្ត្រគ្រប់យ៉ាង ។

ក្នុងវេលាទៅកាន់ស្ទឹង ឬឧទ្យាន ដើម្បីលេង ឧបតិស្សមាណព មានវមាស ៥០០ ជាគ្រឿងសែង កោលិតមាណព មានរថដែលទឹមដោយសេះអាជានេយ្យ ៥០០ ដែលជាគ្រឿងហែហម ជនទាំង ២ មានមាណពម្នាក់ ៥០០ ជាបរិវារ ។ ក្នុងក្រុងរាជគ្រឹះ មានមហោស្រពលើកំពូលភ្នំប្រចាំឆ្នាំ ។ ជនទាំងឡាយ ចងគ្រែទុកក្នុងទីតែមួយសម្រាប់មាណពទាំង ២ នោះ មាណពទាំង ២ ក៏អង្គុយរួមគ្នាមើលមហោស្រព ត្រេកអរក្នុងឋានៈដែលគួរត្រេកអរ សង្វេគក្នុងឋានៈដែលគួរសង្វេគ ដាក់រង្វាន់ក្នុងឋានៈដែលគួរដាក់រង្វាន់ ថ្ងៃមួយកាលជនទាំង ២ នោះ មើលមហោស្រពដោយទំនងនេះឯង មិនមានការត្រេកអរក្នុងឋានៈដែលគួរត្រេកអរ សង្វេគក្នុងឋានៈដែលគួរសង្វេគ ឬដាក់រង្វាន់ក្នុងឋានៈដែលគួរដាក់ ព្រោះញាណចាស់ក្លាហើយ ។ ជនទាំង ២ គិត

យ៉ាងនេះថា មានអ្វីដែលយើងគួរមើលក្នុងមហោស្រពនេះ មនុស្សទាំងអស់នោះ នៅមិនដល់ ១០០ ឆ្នាំ ក៏នឹងដាច់ខ្យល់ស្លាប់ព្រាត់ប្រាសគ្នាទៅ យើងទាំងឡាយ គួរស្វែងរកមោក្ខធម៌ឯណាមួយ ដូច្នេះហើយ អង្គុយនឹកយកជាអារម្មណ៍ លំដាប់នោះ កោលិតៈពោលនឹងឧបតិស្សៈថា សម្លាញ់ឧបតិស្សៈ អ្នកមិនត្រេកអរដូចថ្ងៃមុនៗ ចិត្តអណ្តែតអណ្តូង អ្នកគិតអ្វីឬ ឧបតិស្សៈពោលថា កោលិតៈសម្លាញ់ ខ្ញុំអង្គុយគិតរឿងនេះថា ក្នុងការមើលរបស់មនុស្សទាំងនេះ មិនមានខ្លឹមសារឡើយ ការមើលនេះ មិនមានប្រយោជន៍ គួរស្វែងរកធម៌ជាគ្រឿងរួចផុតសម្រាប់ខ្លួន ចុះអ្នកវិញ ព្រោះហេតុអ្វី ទើបចិត្តអណ្តែតអណ្តូង សូម្បីកោលិតៈនោះ ក៏ពោលយ៉ាងនោះដូចគ្នា កាលឧបតិស្សៈដឹងថា កោលិតៈនោះមានអធ្យាស្រ័យដូចគ្នា ទើបពោលយ៉ាងថា វត្ថុដែលយើងទាំង ២ គិត ជាការគិតល្អ កាលនឹងស្វែងរកមោក្ខធម៌ គួរនឹងបានការបួសណាមួយ ដូច្នោះ ពួកយើងនឹងបួសក្នុងសម្នាក់អ្នកណា ។

សម័យនោះ សញ្ជយបរិព្វាជកអាស្រ័យនៅក្នុងក្រុងរាជគ្រឹះ មួយអន្លើនឹងបរិព្វាជកបរិស័ទ មាណពទាំង ២ ព្រមព្រៀងគ្នាថា នឹងបួសក្នុងសម្នាក់របស់សញ្ជយបរិព្វាជកនោះ ទើបបួសក្នុងសម្នាក់របស់សញ្ជយបរិព្វាជកមួយអន្លើនឹងមាណព ៥០០ នាក់ តាំងអំពីកាលដែលមាណពទាំង ២ នោះបួសហើយ សញ្ជយបរិព្វាជកបានលាភ បានយសដ៏ច្រើន ។ មាណពទាំង ២ នោះរៀនចប់លទ្ធិរបស់សញ្ជយបរិព្វាជកនោះទាំងអស់ ត្រឹមតែ ២ ឬ ៣ ថ្ងៃប៉ុណ្ណោះ ហើយសួរថា លទ្ធិដែលជាការដឹងរបស់លោកអាចារ្យមានប៉ុណ្ណោះ

ឬ ឬមានក្រៃលែងជាងនេះទៀត សញ្ជយបរិព្វាជកពោលថា មានប៉ុណ្ណេះឯង ពួកអ្នកដឹងអស់ហើយ ។ មាណពទាំងនោះ ស្តាប់ពាក្យរបស់សញ្ជយ-បរិព្វាជកនោះហើយ គិតថា កាលបើដូច្នេះ ការនៅប្រព្រឹត្តព្រហ្មចរិយៈក្នុងសម្នាក់របស់សញ្ជយបរិព្វាជកនេះ ក៏មិនមានប្រយោជន៍ ពួកយើងចេញបួសក៏ដើម្បីស្វែងរកមោក្ខធម៌ ពួកយើងមិនអាចឲ្យកើតឡើងក្នុងសម្នាក់របស់សញ្ជយបរិព្វាជកនេះ ។ ជម្ពូទ្វីបនេះធំ ពួកយើងត្រាច់ទៅកាន់គាមនិគម និងរាជធានី នឹងបានអាចារ្យណាម្នាក់ ដែលស្វែងរកមោក្ខធម៌បានពិតប្រាកដតាំងអំពីនោះ មាណពទាំង ២ នោះ បានស្តាប់ថាសមណព្រាហ្មណ៍ដែលជាបណ្ឌិត មានក្នុងទីណាមួយ ក៏ទៅក្នុងទីនោះៗ ធ្វើការសន្ទនាបញ្ហា ។ បញ្ហាដែលមាណពនោះសួរហើយ អ្នកដទៃណាម្នាក់ មិនមានសមត្ថភាពអាចដោះស្រាយបាន ។ តែមាណពទាំង ២ នោះស្រាយបញ្ហារបស់ជនទាំងនោះបាន មាណពទាំង ២ នោះ ត្រាច់សាកសួរពេញជម្ពូទ្វីប ដោយអាការយ៉ាងនេះហើយត្រឡប់មកលំនៅរបស់ខ្លួនវិញ បានធ្វើកតិកាគ្នាថា កោលិតៈសម្លាញ់ បុគ្គលណាសម្រេចអមតធម៌មុន បុគ្គលនោះ ចូរប្រាប់ដល់គ្នា ។

សម័យនោះ ព្រះសាស្តានៃយើងទាំងឡាយ សម្រេចព្រះបរមាភិ-សម្ពោធិញ្ញាណ ហើយប្រកាសព្រះធម្មចក្រដ៏បវរ យាងដល់ក្រុងរាជគ្រឹះដោយលំដាប់ ។ គ្រានោះ ព្រះអស្សជិក្នុងចំនួនបញ្ចវគ្គិយភិក្ខុ ក្នុងបណ្តាភិក្ខុទាំងឡាយ ដែលទ្រង់បញ្ជូនទៅប្រកាសគុណរបស់ព្រះរតនត្រ័យថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរត្រាច់ទៅដើម្បីប្រយោជន៍ដល់ជនដ៏ច្រើន

ដូច្នេះ ក្នុងសម័យដែលពោលថា ព្រះអរហន្ត ៦១ អង្គកើតឡើងហើយក្នុងលោក ដូច្នេះ លោកវិលត្រឡប់មកកាន់ក្រុងរាជគ្រឹះ ។ ក្នុងថ្ងៃស្អែកឡើងកាន់បាត្រ និងចីវរចូលទៅបិណ្ឌបាត ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះអំពីព្រលឹម ។ សម័យនោះ ឧបតិស្សបរិព្វាជក ធ្វើកត្តកិច្ចអំពីព្រលឹម ហើយដើរទៅកាន់អារាមបរិព្វាជក បានឃើញព្រះថេរៈ គិតថា បព្វជិតដែលមានសភាពបែបនេះ អញមិនធ្លាប់ឃើញសោះ ភិក្ខុនេះ ពិតជាភិក្ខុណាមួយអង្គក្នុងបណ្ដាភិក្ខុដែលជាអរហន្ត ឬអ្នកសម្រេចអរហត្តមគ្គក្នុងលោក បើដូច្នោះ អញគួរចូលទៅរកភិក្ខុនេះ ហើយសួរបញ្ហា ដោយពាក្យថា បពិត្រលោកម្ចាស់ លោកម្ចាស់បួសចំពោះអ្នកណា អ្នកណាជាសាស្ដារបស់លោកម្ចាស់ លោកម្ចាស់គាប់ចិត្តក្នុងធម៌របស់អ្នកណា ។

លំដាប់នោះ មាណពគិតថា មិនមែនកាលដែលត្រូវសួរបញ្ហាជាមួយភិក្ខុនេះទេ ព្រោះលោកកំពុងនៅក្នុងចន្លោះស្រុកដើម្បីបិណ្ឌបាត បើដូច្នោះ អញ គប្បីដើរតាមក្រោយភិក្ខុនេះទៅ ព្រោះការដើរតាមភិក្ខុនេះទៅ ជាផ្លូវដែលគប្បីចូលទៅដឹងហើយ ។ ឧបតិស្សបរិព្វាជក ឃើញព្រះថេរៈបានបិណ្ឌបាត ហើយទៅកាន់ឱកាសមួយកន្លែង និងដឹងថា ព្រះថេរៈនោះត្រូវការអង្គុយ ទើបបានលាតតាំងបរិព្វាជករបស់ខ្លួនប្រគេន ក្នុងវេលាស្រេចភត្តកិច្ចក៏បានប្រគេនទឹកក្នុងឃ្លោករបស់ខ្លួនដល់ព្រះថេរៈនោះ ធ្វើអាចរិយវត្តយ៉ាងនេះហើយ ធ្វើបដិសណ្ឋារៈទន់ភ្លន់ជាមួយព្រះថេរៈ ដែលធ្វើភត្តកិច្ចស្រេចហើយសួរថា បពិត្រលោកម្ចាស់ ឥន្ទ្រិយទាំងឡាយរបស់លោកម្ចាស់ ផូរផង់

ពន់ពេក ឆវីវណ្ណបរិសុទ្ធក្រៃលែង លោកម្ចាស់បួសចំពោះនរណា នរណាជាសាស្តារបស់លោលម្ចាស់ លោកម្ចាស់គាប់ចិត្តក្នុងធម៌របស់អ្នកណា ព្រះថេរៈពោលថា អាវុសោ ព្រះមហាសមណសក្យបុត្រ ចេញអំពីសក្យត្រកូល ខ្ញុំបួសចំពោះព្រះមានព្រះភាគអង្គនោះ ព្រះមានព្រះភាគអង្គនោះ ជាសាស្តារបស់ខ្ញុំ ខ្ញុំគាប់ចិត្តក្នុងធម៌របស់ព្រះមានព្រះភាគអង្គនោះ ។ លំដាប់នោះ ទើបឧបតិស្សបរិព្វាជកសួរព្រះថេរៈថា ព្រះសាស្តារបស់លោកម្ចាស់មានវាទៈដូចម្តេច ពោលដូចម្តេច ។ ព្រះថេរៈគិតថា ធម្មតាបរិព្វាជកទាំងឡាយនេះ ជាបដិបក្ខចំពោះព្រះសាសនា អញនឹងសម្តែងជម្រៅក្នុងព្រះសាសនាដល់បរិព្វាជកនេះ ។ កាលនឹងសម្តែងខ្លួនថា ជាអ្នកបួសថ្មី ទើបពោលថា អាវុសោ ខ្ញុំជាអ្នកបួសថ្មី មិនទាន់ជាថេរៈ ទើបតែនឹងមកកាន់ធម្មវិន័យនេះ ខ្ញុំមិនអាចសម្តែងធម៌ ដោយពិស្តារបានទេ ។ បរិព្វាជកពោលថា ខ្ញុំឈ្មោះឧបតិស្សៈ លោកម្ចាស់ពោលតិច ឬច្រើន តាមសមត្ថភាព ការចាក់ធ្លុះធម៌នោះ រាប់រយរាប់ពាន់ន័យ ជាភារៈរបស់ខ្ញុំ ទើបពោលថា

**អប្បំ វា ពហុំ វា ភាសស្សុ អត្ថំយេវ មេ ព្រូហិ អត្ថេនេវ មេ អត្ថោ កឹ កាហសិ ព្យញ្ជនំ ពហុំ** សូមលោកម្ចាស់ពោលចុះ តិចក្តី ច្រើនក្តី សូមពោលតែចំពោះតែអត្ថដល់ខ្ញុំ ខ្ញុំត្រូវការអត្ថប៉ុណ្ណោះ លោកម្ចាស់ធ្វើព្យញ្ជនៈឲ្យច្រើនធ្វើអ្វី ។

កាលពោលយ៉ាងនេះហើយ ទើបព្រះថេរៈពោលគាថាថា **យេ ធម្មា ហេតុប្បភវា** ដូច្នេះជាដើម ។ បរិព្វាជកស្តាប់ចំពោះ ២ បាទដំបូងប៉ុណ្ណោះ

ក៏តាំងនៅក្នុងសោតាបត្តិមគ្គ ដែលបរិបូរដោយន័យ ១០០០ ។ ធ្វើ ២ បទ ខាងក្រោយឲ្យចប់ក្នុងវេលាជាព្រះសោតាបន្នហើយ ។ បរិព្វាជកនោះ បាន ជាព្រះសោតាបន្នហើយ កាលគុណវិសេសជាន់ខ្ពស់មិនទាន់កើត ទើបកំណត់ ថា ហេតុក្នុងពាក្យទូន្មាននេះនឹងមាន ទើបពោលនឹងព្រះថេរៈថា បពិត្រលោក ម្ចាស់ សូមលោកម្ចាស់ កុំបរិយាយធម្មទេសនាឲ្យខ្ពស់ទៀតឡើយ ពាក្យ មានប្រមាណប៉ុណ្ណេះឯងគ្រប់គ្រាន់ហើយ ព្រះសាស្តានៃយើងទាំងឡាយ ប្រថាប់នៅទីណា ។ ព្រះថេរៈប្រាប់ថា ប្រថាប់នៅក្នុងវត្តវេឡុវ័ន បរិព្វាជក ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់និមន្តទៅមុនចុះ ខ្ញុំមានសម្លាញ់ ម្នាក់ទៀត ហើយបានធ្វើកតិកាថា បុគ្គលណាដល់នូវអមតៈមុន បុគ្គលនោះ ចូរប្រាប់ដល់គ្នា ខ្ញុំនឹងដោះពាក្យប្តេជ្ញានោះ ហើយនាំសម្លាញ់ទៅកាន់សម្នាក់ របស់ព្រះសាស្តា តាមផ្លូវដែលលោកម្ចាស់ទៅនោះឯង ហើយក្រាបចុះទៀប បាទជើងព្រះថេរៈ ដោយបញ្ចង្គប្រតិស្ឋាន ធ្វើប្រទក្សិណ ៣ ជុំ ហើយបញ្ជូន ព្រះថេរៈទៅ ឯខ្លួនក៏ដើរតម្រង់ទៅកាន់អារាមរបស់បរិព្វាជក ។ កោលិត-បរិព្វាជកឃើញឧបតិស្សបរិព្វាជកដើរមកអំពីចម្ងាយ គិតថា ថ្ងៃនេះ សម្លាញ់ របស់អញ មានទឹកមុខ មិនដូចថ្ងៃមុន ប្រហែលជាបានសម្រេចអមតធម៌ពិត ទើបសួរដល់ការសម្រេចអមតៈ ។ ឧបតិស្សបរិព្វាជកនោះ បានប្តេជ្ញាដល់ កោលិតបរិព្វាជកនោះថា អាវុសោ ខ្ញុំសម្រេចអមតៈហើយ ទើបបានពោល គាថានោះឯង ។ ក្នុងវេលាចប់គាថា កោលិតៈតាំងនៅក្នុងសោតាបត្តិផល ហើយពោលថា នែសម្លាញ់ ព្រះសាស្តាប្រថាប់នៅទីណា ។ ឧបតិស្សៈ

ពោលថា បានឮថា ព្រះសាស្តាប្រថាប់នៅក្នុងវត្តវេឡុវ័ន ។ ព្រះអស្សជិអាចារ្យរបស់ពួកយើង បានប្រាប់យ៉ាងនេះ ដោយប្រការដូច្នេះ ។ កោលិតះពោលថា សម្លាញ់ បើដូច្នោះ ពួកយើងនឹងគាល់ព្រះសាស្តា ។ ធម្មតាព្រះសារីបុត្តត្ថេរនេះ ជាអ្នកបូជាអាចារ្យក្នុងកាលគ្រប់កាល ព្រោះដូច្នោះ ទើបពោលនឹងកោលិតមាណព ដែលជាសម្លាញ់យ៉ាងនេះថា សម្លាញ់ យើងនឹងប្រាប់អមតៈដែលយើងសម្រេច ដល់សញ្ជយបរិព្វាជក ដែលជាអាចារ្យរបស់យើង កាលលោកដឹងក៏នឹងចាក់ធ្លុះ បើមិនចាក់ធ្លុះទេ ពួកយើងនឹងទៅកាន់សម្នាក់របស់ព្រះសាស្តា ស្តាប់ធម្មទេសនារបស់ព្រះពុទ្ធហើយ នឹងធ្វើការសម្រេចមគ្គផល ។ បន្ទាប់អំពីនោះ ជនទាំង ២ ទៅកាន់សម្នាក់របស់សញ្ជ័យពោលថា បពិត្រលោកអាចារ្យ លោកនឹងធ្វើដូចម្តេច ព្រះពុទ្ធកើតឡើងហើយក្នុងលោក ព្រះធម៌ក៏ព្រះពុទ្ធត្រាស់ល្អហើយ ព្រះសង្ឃជាអ្នកបដិបត្តិល្អហើយ មកចុះ ពួកយើងនឹងទៅគាល់ព្រះអង្គ សញ្ជយបរិព្វាជកពោលថា នែបា បាពោលអ្វី ហើយឃាត់ជនទាំង ២ នោះ សម្តែងតែការបានលាភ និងយសដ៏លើសប៉ុណ្ណោះដល់ជនទាំង ២ នោះ ។ ជនទាំង ២ នោះពោលថា ការនៅជាអន្តេវាសិកបែបនេះរបស់ពួកយើងទាំងឡាយ ជាប្រចាំមកហើយ ចូរលើកទុកសិនចុះ តែលោកអាចារ្យចូរដឹងខ្លួនឯងថា ទៅឬមិនទៅ ។ សញ្ជយបរិព្វាជកដឹងថា ជនទាំងនេះដឹងសេចក្តីត្រូវការ មានប្រមាណប៉ុណ្ណោះហើយ នឹងមិនជឿ មិនស្តាប់វាចារបស់អញឡើយ ទើបពោលថា ទៅចុះបាទាំងឡាយ ខ្ញុំមិនអាចធ្វើជាអន្តេវាសិករបស់អ្នកណាម្នាក់

បានឡើយ ក្នុងកាលដែលខ្ញុំជាមនុស្សចាស់ ។ ជនទាំង ២ នោះ មិនអាចឲ្យសញ្ជយបរិព្វាជកនោះយល់ដោយហេតុដ៏ច្រើន ទើបនាំជនដែលប្រព្រឹត្តតាមឱវាទរបស់ខ្លួនទៅកាន់វត្តវេឡុវ័ន ។ គ្រានោះ ក្នុងបណ្តាអន្តេវាសិក ៥០០ នាក់របស់ជនទាំង ២ នោះ ២៥០ នាក់ត្រឡប់ក្រោយ ២៥០ នាក់ទៀត បានទៅជាមួយជនទាំង ២ នោះ ។

ព្រះសាស្តាទ្រង់កំពុងសម្តែងធម៌ ត្រង់កណ្តាលបរិស័ទ ៤ ទ្រង់ឃើញជនទាំងនោះអំពីចម្ងាយ ទើបត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ សម្លាញ់ ២ នាក់នោះ គឺកោលិតៈ និងឧបតិស្សៈកំពុងដើរមក គូនៃសាវ័កនេះឯង ជាគូសាវ័កដ៏កំពូល ដ៏ចម្រើន ។ ហើយពង្រីកព្រះធម្មទេសនា ទាក់ទងដោយចរិយានៃបរិស័ទរបស់សម្លាញ់ ២ នាក់នោះ ។ វៀរអគ្គសាវ័កទាំង ២ បរិព្វាជក ២៥០ នាក់នោះ សម្រេចអរហត្ត ។ ព្រះសាស្តាទ្រង់លាព្រះហស្ត ត្រាស់ថា ចូរជាភិក្ខុចុះ ។ សក់ និងពុកមាត់ ពុកចង្ការបស់បរិព្វាជកទាំងនោះក៏អស់ទៅ បាត្រ និងចីវរដែលសម្រេចហើយដោយឫទ្ធិ ក៏មានដល់អគ្គសាវ័កទាំង ២ តែកិច្ចដោយមគ្គទាំង ៣ ខាងលើមិនទាន់សម្រេច ។ ព្រោះហេតុអ្វី ព្រោះសាវកបារមីញាណជារបស់ធំ ។ ក្នុងថ្ងៃទី ៧ បន្ទាប់ពីបួស ព្រះមហាមោគ្គល្លានចូលទៅអាស្រ័យស្រុកកល្លវាលគាម ដែនមគធៈ ធ្វើសមណធម៌ កាលត្រូវថីនមិទ្ធៈគ្របសង្កត់ ព្រះសាស្តាទ្រង់ធ្វើឲ្យសង្វេគ បន្ទោបង់ថីនមិទ្ធៈចេញបាន កំពុងស្តាប់ធាតុកម្មដ្ឋានដែលព្រះតថាគតប្រទាននោះឯង ធ្វើកិច្ចនៃមគ្គ ៣ ខាងលើឲ្យសម្រេចដល់ទីបំផុត

នៃសាវកបារមីញាណ ។ ព្រះសារីបុត្តត្រេកនូវធូរបានកន្លះខែ តាំងអំពីថ្ងៃបួស ចូលទៅអាស្រ័យក្រុងរាជគ្រឹះនោះឯង នៅក្នុងគុហាសូករខាតាជាមួយនឹងព្រះសាស្តា កាលព្រះសាស្តាទ្រង់សម្តែងវេទនាបរិគ្គហសូត្រ ដល់ទីឃនខបរិព្វាជកដែលជាក្មួយរបស់លោក បានបញ្ជូនញាណទៅតាមក្រសែព្រះសូត្រ ក៏បានសម្រេចដល់ទីបំផុតសាវកបារមីញាណ ដូចបរិភោគបាយដែលដួសទុកដើម្បីអ្នកដទៃ ឯក្មួយរបស់លោក តាំងនៅក្នុងសោតាបត្តិផលក្នុងកាលចប់ទេសនា ។ ដូច្នោះ កាលព្រះតថាគតប្រថាប់នៅក្នុងក្រុងរាជគ្រឹះនោះឯង កិច្ចនៃសាវកបារមីញាណរបស់ព្រះអគ្គសាវកទាំង ២ បានដល់ទីបំផុតហើយ ។ ក្នុងកាលបន្ទាប់មកទៀត ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពន ទ្រង់បានស្ថាបនាព្រះមហាសាវកទាំង ២ ក្នុងតំណែងឯតទគ្គៈថា បណ្តាពួកភិក្ខុអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងសារីបុត្ត ។ ពួកភិក្ខុអ្នកមានឫទ្ធិច្រើន ស្រេចនឹងមហាមោគ្គល្លាន ។ល។

## អដ្ឋកថាសូត្រទី ២-៣ ចប់

# អដ្ឋកថា សូត្រទី ៤

# ប្រវត្តិព្រះមហាកស្សបត្ថេរ

[ ១៤៩ ] ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ក្នុងបទថា **ធុតវាទានំ** នេះ គប្បីជ្រាបថា ធុតបុគ្គល គឺបុគ្គលកម្ចាត់កិលេស ធុតវាទ គឺការទូន្មានរឿងការកម្ចាត់កិលេស ធុតធម៌ គឺធម៌ជាគ្រឿងកម្ចាត់កិលេស ធុតង្គ គឺអង្គអ្នកកម្ចាត់កិលេស ។

បណ្តាបទទាំងនោះ បទថា **ធុតោ** បានដល់ បុគ្គលដែលកម្ចាត់កិលេស ឬធម៌ដែលកម្ចាត់កិលេស ។

ក្នុងបទថា **ធុតវាទោ** នេះ គប្បីជ្រាបថា មានបុគ្គលកម្ចាត់កិលេស តែមិនមានការទូន្មានរឿងកម្ចាត់កិលេស ១ មានបុគ្គលមិនកម្ចាត់កិលេស តែមានការទូន្មានរឿងកម្ចាត់កិលេស ១ មានបុគ្គលមិនកម្ចាត់កិលេសផង មិនមានការទូន្មានរឿងកម្ចាត់កិលេសផង ១ មានបុគ្គលកម្ចាត់កិលេសផង និងមានការទូន្មានរឿងកម្ចាត់កិលេសផង ១ ក្នុងបណ្តាបុគ្គលទាំងនោះ បុគ្គលណាកម្ចាត់កិលេសរបស់ខ្លួនដោយធុតង្គ តែមិនទូន្មាន មិនប្រៀនប្រដៅអ្នកដទៃដោយធុតង្គ ដូចជាព្រះពកុលត្ថេរ បុគ្គលនេះឈ្មោះថា ជាអ្នកកម្ចាត់កិលេស តែមិនមានការប្រៀនប្រដៅក្នុងរឿងកម្ចាត់កិលេស ដូចលោកពោលថា ព្រះពកុលៈជាអ្នកកម្ចាត់កិលេស តែមិនមានការប្រៀនប្រដៅក្នុងការកម្ចាត់កិលេស ។ បុគ្គលណាមិនកម្ចាត់កិលេសរបស់ខ្លួនដោយធុតង្គ តែប្រៀនប្រដៅអ្នកដទៃដោយធុតង្គ ដូចជាព្រះឧបនន្ទត្ថេរ បុគ្គលនេះឈ្មោះថា មិនជាអ្នកកម្ចាត់កិលេស តែមានការប្រៀនប្រដៅក្នុងរឿងកម្ចាត់កិលេស ដូចលោក

ពោលថា ព្រះឧបនន្ទសក្យបុត្រ មិនជាអ្នកកម្ចាត់កិលេស តែមានការទូន្មានរឿងកម្ចាត់កិលេស ។ បុគ្គលណាមិនកម្ចាត់កិលេសរបស់ខ្លួនដោយធុតង្គ មិនទូន្មានមិនប្រៀនប្រដៅអ្នកដទៃដោយធុតង្គ ដូចព្រះលោឡុទាយិត្ថេរ បុគ្គលនេះឈ្មោះថា មិនជាអ្នកកម្ចាត់កិលេសផង មិនមានការប្រៀនប្រដៅរឿងកម្ចាត់កិលេសផង ដូចលោកពោលថា ព្រះមហាលោឡុទាយី មិនជាអ្នកកម្ចាត់កិលេសផង មិនមានការប្រៀនប្រដៅក្នុងរឿងកម្ចាត់កិលេសផង ។ ឯបុគ្គលណាសម្បូរដោយការកម្ចាត់កិលេស និងមានការទូន្មានរឿងកម្ចាត់កិលេស ដូចព្រះមហាកស្សបៈ បុគ្គលនេះឈ្មោះថា ជាអ្នកកម្ចាត់កិលេស និងមានការប្រៀនប្រដៅក្នុងរឿងកម្ចាត់កិលេស ដូចលោកពោលថា ព្រះមហាកស្សបៈជាអ្នកកម្ចាត់កិលេសផង មានការទូន្មានរឿងកម្ចាត់កិលេសផង ដូច្នេះ ។

បទថា **ធុតធម្មា វេទិតព្វា** សេចក្តីថា ធម៌ ៥ ប្រការដែលជាបរិវារនៃធុតង្គចេតនាទាំងនេះ គឺភាពជាអ្នកប្រាថ្នាតិច ១ ភាពជាអ្នកសន្តោស ១ ភាពជាអ្នកជុសខាត់ ១ ភាពជាអ្នកស្ងាត់ ១ ភាពជាអ្នកមានវត្ថុនេះ ១ ឈ្មោះថា ធម៌ជាគ្រឿងកម្ចាត់កិលេស ព្រោះព្រះបាលីថា **អប្បិច្ឆំយេវ និស្សាយ** អាស្រ័យការប្រាថ្នាតិចប៉ុណ្ណោះ ដូច្នេះជាដើម ។ ក្នុងធម៌ ៥ ប្រការនោះ ការប្រាថ្នាតិច និងការសន្តោស ជាអលោភៈ ការជុសខាត់កិលេស និងការស្ងាត់កាយ ស្ងាត់ចិត្ត ចាត់ចូលក្នុងធម៌ ២ ប្រការ គឺអលោភៈ និងអមោហៈ ។ ភាពជាអ្នកមានវត្ថុនេះ គឺបញ្ញានោះឯង ។ បណ្តា

អលោភៈ និងអមោហៈទាំងនោះ កម្ចាត់លោភៈក្នុងវត្ថុដែលត្រូវឃាត់ដោយអលោភៈ កម្ចាត់មោហៈដែលបិទបាំងទោសក្នុងវត្ថុ ដែលត្រូវឃាត់ទាំងនោះឯងដោយអមោហៈ ម្យ៉ាងទៀត កម្ចាត់កាមសុខល្លិកានុយោគ ដែលប្រព្រឹត្តទៅដោយមុខ គឺការសេពវត្ថុដែលទ្រង់អនុញ្ញាតដោយអលោភៈ កម្ចាត់អត្តកិលមថានុយោគ ដែលប្រព្រឹត្តដោយមុខ គឺការជុសខាត់កិលេសក្រៃលែងក្នុងធុតង្គទាំងឡាយដោយអមោហៈ ព្រោះដូច្នោះ ធម៌ទាំងនេះ គប្បីជ្រាបថាជាគ្រឿងកម្ចាត់កិលេស ។

បទថា **ធុតង្គានិ វេទិតព្វានិ** សេចក្ដីថា គប្បីជ្រាបធុតង្គ ១៣ គឺបំសុកូលិកង្គ អង្គនៃភិក្ខុដែលទ្រទ្រង់សំពត់បង្សុកូលជាវត្ត ។បេ។ នេសជ្ជិកង្គ គឺអង្គនៃភិក្ខុដែលសមាទានការអង្គុយជាវត្ត ។

បទថា **ធុតវាទានំ យទិទំ មហាកស្សបោ** សេចក្ដីថា ទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈ ក្នុងវាងភិក្ខុដែលទូន្មានធុតង្គថា មហាកស្សបត្ថេរនេះជាកំពូល ។ បទថា **មហាកស្សបោ** សេចក្ដីថា លោកពោលថា ព្រះមហាកស្សបៈអង្គនេះ ព្រោះប្រៀបធៀបជាមួយព្រះថេរៈតូចតាចទាំងនេះ គឺឧរុវេលកស្សបៈ ព្រះនទីកស្សបៈ ព្រះគយាកស្សបៈ ព្រះកុមារកស្សបៈ ។

ក្នុងបញ្ហាកម្មរបស់ព្រះមហាកស្សបនេះ មានរឿងដែលពោលតាមលំដាប់ដូចតទៅថា

បានឮថា ក្នុងអតីតកាល ខាងចុងនៃមួយសែនកប្ប ព្រះសាស្ដាព្រះនាមថាបទុមុត្តរៈ កើតឡើងក្នុងលោក កាលទ្រង់យាងទៅអាស្រ័យក្រុង

*ហង្សវតី ប្រថាប់នៅក្នុងខេមមិគទាយវ័ន សម័យនោះ កុដុម្ពិកៈ ឈ្មោះថា វេទេហៈ មានទ្រព្យសម្បត្តិ ៨០ កោដិ បរិភោគអាហារមានរសល្អអំពីព្រលឹម អធិដ្ឋានអង្គឧបោសថ កាន់យកគ្រឿងក្រអូប និងផ្កាជាដើមទៅព្រះវិហារ បូជាព្រះសាស្តា ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ខណៈនោះ ព្រះសាស្តាទ្រង់ស្ថាបនាសាវ័កអង្គទី ៣ ឈ្មោះថា មហានិសភត្ថេរក្នុងតំណែងឯតទគ្គៈថា ម្នាលភិក្ខុទាំងឡាយ និសភៈ ជាកំពូលនៃភិក្ខុដែលជាសាវ័ករបស់តថាគត ខាងប្រៀនប្រដៅធុតង្គ ។ ឧបាសកស្តាប់ព្រះតម្រាស់នោះហើយ ជ្រះថ្លា ក្នុងកាលចប់ធម្មកថា មហាជនក្រោកចេញទៅហើយ ទើបថ្វាយបង្គំព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ។ ព្រះសាស្តាត្រាស់ថា ឧបាសក ភិក្ខុសង្ឃមានច្រើន ។ ឧបាសកទូលសួរថា បពិត្រព្រះមានព្រះភាគ ភិក្ខុសង្ឃមានប្រមាណប៉ុនណា ព្រះសាស្តាត្រាស់ថា មានប្រមាណ ៦ លាន ៨ សែនអង្គ ។ ឧបាសកក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទទួលភិក្ខា សូម្បីសាមណេរមួយរូបក៏កុំបីមានសេសសល់ក្នុងវិហារឡើយ ។ ព្រះសាស្តាទ្រង់ទទួលនិមន្តដោយតុណ្ហីភាព ។ ឧបាសកដឹងថា ព្រះសាស្តាទ្រង់ទទួលនិមន្តហើយ ទើបទៅផ្ទះ ត្រៀមរៀបចំមហាទាន ។ ក្នុងថ្ងៃស្អែកឡើង បញ្ជូនមនុស្សទៅក្រាបទូលភត្តកាលដល់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់កាន់យកបាត្រ និងចីវរ មានភិក្ខុសង្ឃហែហមទៅកាន់ផ្ទះរបស់ឧបាសក ប្រថាប់គង់លើអាសនៈដែលគេរៀបចំថ្វាយ ។ ក្នុងកាលសម្រេចការប្រេចទឹក*

ទក្ខិណោទក ទ្រង់ទទួលបបរជាដើម ទ្រង់បានលះបង់នូវបាយ ឧបាសកក៏អង្គុយក្នុងទីជិតព្រះសាស្តា ។

ក្នុងចន្លោះនោះ ព្រះមហានិសភត្ថេរ កំពុងត្រាច់បិណ្ឌបាត និមន្តទៅកាន់ផ្លូវនោះឯង ។ ឧបាសកឃើញហើយ ក្រោកឡើង ទៅថ្វាយបង្គំព្រះថេរៈពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឲ្យបាត្រមកចុះ ព្រះថេរៈបានឲ្យបាត្រ ឧបាសកពោលថា បពិត្រលោកម្ចាស់ សូមនិមន្តចូលទៅក្នុងផ្ទះព្រះសាស្តា ក៏ទ្រង់ប្រថាប់គង់នៅក្នុងផ្ទះដែរ ។ ព្រះថេរៈពោលថា មិនគួរទេឧបាសក ។ ឧបាសកទទួលបាត្ររបស់ព្រះថេរៈ ដាក់ចង្ហាន់ពេញហើយ បាននាំចេញទៅប្រគេន ។ បន្ទាប់ពីនោះ បានដើរជូនដំណើរព្រះថេរៈទៅ ហើយត្រឡប់មកអង្គុយក្នុងទីជិតព្រះសាស្តា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមហានិសភត្ថេរ សូម្បីខ្ញុំព្រះអង្គពោលថា ព្រះសាស្តាប្រថាប់នៅក្នុងផ្ទះ ក៏មិនប្រាថ្នានឹងចូលមក ព្រះមហានិសភត្ថេរនោះ មានគុណក្រៃលែងជាងទ្រង់ឬហ្ន៎ ជាធម្មតានៃព្រះពុទ្ធទាំងឡាយ មិនមានវណ្ណមច្ឆរិយៈ គឺកំណាញ់គុណរបស់អ្នកដទៃឡើយ ។ លំដាប់នោះ ព្រះសាស្តាត្រាស់យ៉ាងនេះថា ម្នាលឧបាសក តថាគតអង្គុយរង់ចាំភិក្ខានៅក្នុងផ្ទះ តែភិក្ខុនោះមិនអង្គុយរង់ចាំភិក្ខាក្នុងផ្ទះឡើយ តថាគតនៅក្នុងសេនាសនៈស្រុក ភិក្ខុនោះ អង្គុយតែក្នុងព្រៃប៉ុណ្ណោះ តថាគតនៅក្នុងទីប្រក់បាំង ភិក្ខុនោះ នៅតែក្នុងទីវាលប៉ុណ្ណោះ ដូច្នោះភិក្ខុនេះមានគុណយ៉ាងនេះៗ ទ្រង់ត្រាស់ដូចធ្វើមហាសមុទ្រឲ្យពេញ ដូច្នោះ ។ ឧបាសក តាមប្រក្រតីជាអ្នកជ្រះថ្លាក្រៃលែងស្រាប់ហើយ ទើបហាក់ដូចជួន

ប្រទីបដែលឆេះសន្ទោសន្ទៅ ត្រូវចាក់ដោយប្រេង ដូច្នោះ គិតថា អាត្មាអញ ត្រូវការអ្វីដោយសម្បត្តិដទៃ អញនឹងធ្វើសេចក្តីប្រាថ្នា ដើម្បីការបានជាកំពូលនៃភិក្ខុទាំងឡាយ ដែលជាធុតវាទក្នុងសម្នាក់របស់ព្រះពុទ្ធអង្គណាមួយអង្គក្នុងអនាគត ។ ទើបឧបាសកនោះ និមន្តព្រះសាស្តាទៀត ថ្វាយមហាទានទំនងនោះឯងអស់ ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ ថ្វាយត្រៃចីវរដល់ភិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ហើយក្រាបទៀបបាទមូលរបស់ព្រះសាស្តា ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ដោយមេត្តាកាយកម្ម មេត្តាវចីកម្ម មេត្តាមនោកម្មរបស់ខ្ញុំព្រះអង្គ ដែលថ្វាយទានអស់ ៧ ថ្ងៃ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិទេវតា ឬសម្បត្តិព្រះឥន្ទ្រ មារ និងព្រហ្មណាទីមួយឡើយ កុសលកម្មរបស់ខ្ញុំព្រះអង្គនេះ សូមបានជាបច្ច័យដល់ភាពជាកំពូលនៃភិក្ខុដែលទ្រទ្រង់នូវធុតង្គ ១៣ ដើម្បីបានតំណែងដែលព្រះមហានិសភត្ថេរដល់ហើយ ក្នុងសម្នាក់របស់ព្រះពុទ្ធអង្គណាទីមួយ ក្នុងអនាគត ។ ព្រះសាស្តាប្រមើលមើលថា ឧបាសកនេះ ប្រាថ្នានូវតំណែងធំ តើសម្រេចដែរឬទេហ្ន៎ ទ្រង់ឃើញថា សម្រេច ទើបត្រាស់ថា អ្នកប្រាថ្នាអគ្គដ្ឋានដ៏ធំ ព្រះពុទ្ធព្រះនាមគោតមនឹងកើតឡើងក្នុងទីបំផុតនៃមួយសែនកប្ប ក្នុងអនាគត អ្នកនឹងបានជាសាវកទី ៣ នៃព្រះគោតមសម្ពុទ្ធអង្គនោះ ឈ្មោះមហាកស្សបត្ថេរ ។ ឧបាសកបានស្តាប់ពុទ្ធព្យាករនោះហើយ គិតថា ធម្មតាព្រះពុទ្ធទាំងឡាយមិនត្រាស់ពាក្យបែកជា ២ ឡើយ ទើបបានសម្គាល់សម្បត្តិនោះហាក់ដូចជាបានក្នុងថ្ងៃស្អែក ឧបាសកនោះ តាំងនៅរហូតអស់អាយុ ថ្វាយទានមានប្រការ

ផ្សេងៗ រក្សាសីល ធ្វើកុសលកម្មច្រើនប្រការ ស្លាប់ទៅក្នុងអត្តភាពនោះហើយ កើតក្នុងស្ថានសួគ៌ ។

ចាប់តាំងអំពីកាលនោះ ឧបាសកនោះសោយសម្បត្តិក្នុងទេវតាផង ក្នុងមនុស្សផង ក្នុងកប្បទី ៩១ បន្ទាប់អំពីកទ្ទកប្បនេះ កាលព្រះវិបស្សីសម្មាសម្ពុទ្ធ ទ្រង់អាស្រ័យក្រុងពន្ធុមតី ប្រថាប់នៅក្នុងមិគទាយវ័នដ៏ក្សេម ចុតិពីទេវលោក ទៅកើតក្នុងត្រកូលព្រាហ្មណ៍បុរាណមួយ ។

ក្នុងគ្រានោះ ព្រះមានព្រះភាគព្រះនាមវិបស្សី ត្រាស់ព្រះធម្មទេសនារៀងរាល់ ៧ ឆ្នាំម្តង មានមហាកោលាហលធំក្រៃលែង ។ ទេវតាទាំងឡាយពេញជម្ពូទ្វីប បានប្រាប់ព្រាហ្មណ៍នោះថា ព្រះសាស្តាទ្រង់សម្តែងធម៌ ព្រាហ្មណ៍បានស្តាប់ដំណឹងនោះ ។ ព្រាហ្មណ៍នោះ មានសំពត់ស្លៀកតែមួយផ្ទាំង នាងព្រាហ្មណីក៏ដូចគ្នា ទាំង ២ នាក់ មានសំពត់ដណ្តប់តែមួយផ្ទាំងប៉ុណ្ណោះ ទើបប្រាកដទូទៅពេញព្រះនគរថា ឯកសាដកព្រាហ្មណ៍ ។ កាលពួកព្រាហ្មណ៍ប្រជុំគ្នាដោយកិច្ចឯណានីមួយ ឲ្យនាងព្រាហ្មណីនៅផ្ទះ ខ្លួនឯងទៅ កាលដល់វេនពួកព្រាហ្មណីប្រជុំគ្នា ខ្លួនឯងក៏នៅផ្ទះ នាងព្រាហ្មណីដណ្តប់សំពត់នោះទៅក្នុងថ្ងៃនោះ ព្រាហ្មណ៍ពោលនឹងព្រាហ្មណីថា នែនាងដ៏ចម្រើន នាងស្តាប់ធម៌ពេលយប់ ឬពេលថ្ងៃ ។ ព្រាហ្មណីពោលថា ខ្ញុំជាស្រីមេផ្ទះ មិនអាចស្តាប់ពេលយប់បានទេ ខ្ញុំស្តាប់ពេលថ្ងៃចុះ ហើយឲ្យព្រាហ្មណ៍នៅចាំផ្ទះ ខ្លួនឯងដណ្តប់សំពត់នោះទៅក្នុងពេលថ្ងៃ មួយអន្លើដោយពួកឧបាសិកា ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរក្នុងចំណែកម្ខាង ។ ស្តាប់ធម៌ហើយ ត្រឡប់

មកជាមួយពួកឧបាសិកា កាលនោះ ព្រាហ្មណ៍បានឲ្យព្រាហ្មណីនៅផ្ទះ ខ្លួនឯងដណ្តប់សំពត់នោះទៅវិហារ ។ សម័យនោះ ព្រះសាស្តាប្រថាប់គង់លើធម្មាសនៈ ដែលគេតាក់តែងទុកត្រង់កណ្តាលបរិស័ទ ទ្រង់ចាប់ផ្តិតដ៏វិចិត្រ ត្រាស់ធម្មកថា ប្រៀបដូចធ្វើសត្វឲ្យចុះអាកាសគង្គា និងហាក់ដូចទ្រង់ធ្វើភ្នំសិនេរុឲ្យជាត្បាល់កូរនូវសមុទ្រ ដូច្នោះ ។ កាលព្រាហ្មណ៍អង្គុយស្តាប់ធម៌ខាងចុងបរិស័ទ បីតិ ៥ ប្រការកើតឡើងពេញសរីរៈ ក្នុងបឋមយាមនោះឯង ព្រាហ្មណ៍នោះទាញសំពត់ ដែលខ្លួនដណ្តប់ចេញមក គិតថា នឹងថ្វាយព្រះទសពល ។ គ្រានោះ ការកំណាញ់ចង្អុលបង្ហាញទោសរាប់ពាន់ប្រការដល់ព្រាហ្មណ៍នោះថា ព្រាហ្មណី និងអញ មានសំពត់ដណ្តប់តែមួយផ្ទាំងប៉ុណ្ណោះ សំពត់ដណ្តប់ផ្ទាំងដទៃៗ មិនមាន ធម្មតាការមិនដណ្តប់សំពត់ ហើយចេញទៅខាងក្រៅ ជាការប្រព្រឹត្តទៅមិនបាន ទើបសម្រេចចិត្តមិនថ្វាយ ដោយប្រការទាំងពួង កាលបឋមយាមកន្លងទៅ បីតិដែលមានសភាពបែបនោះកើតឡើងដល់ព្រាហ្មណ៍នោះ ក្នុងមជ្ឈិមយាម ព្រាហ្មណ៍ក៏គិតយ៉ាងនោះ ហើយមិនបានថ្វាយដូចគ្នា ។ កាលមជ្ឈិមយាមកន្លងទៅ បីតិដែលមានសភាពបែបនោះ កើតឡើងដល់ព្រាហ្មណ៍នោះក្នុងបច្ឆិមយាម ។ ព្រាហ្មណ៍នោះ គិតថា ណ្ហើយចុះ យ៉ាងណាសឹមដឹងគ្នាជាក្រោយ ដូច្នេះហើយ ទាញសំពត់មកដាក់ទៀបព្រះបាទាព្រះបរមសាស្តា បន្ទាប់អំពីនោះ ក៏លើកដៃឆ្វេង យកដៃស្តាំទះ ៣ ដង ហើយបន្លឺឡើង ៣ វារៈថា **ជិតំ មេ ជិតំ មេ ជិតំ មេ** ខ្ញុំឈ្នះហើយ ខ្ញុំឈ្នះហើយ ខ្ញុំឈ្នះហើយ ។

សម័យនោះ ព្រះបាទពន្ធុមរាជគង់ប្រថាប់ស្តាប់ព្រះធម៌នៅខាងក្នុងវាំងនន ក្រោយធម្មាសនៈ ។ ជាធម្មតា ព្រះរាជាទ្រង់មិនពេញចិត្តនឹងសំឡេងថា **ជិតំ មេ ជិតំ មេ** ទើបបញ្ជូនរាជបុរសទៅ ដោយព្រះតម្រាស់ថា អ្នកចូរទៅសួរព្រាហ្មណ៍នោះថា ព្រាហ្មណ៍និយាយអ្វី ។ ព្រាហ្មណ៍នោះ ត្រូវរាជ-បុរសសួរ ទើបពោលថា បុគ្គលដទៃក្រៅអំពីខ្ញុំ ឡើងយាន គឺដំរីជាដើម កាន់ដាវ និងខែលស្បែកជាដើម ទើបបាននូវជ័យជម្នះលើកងទ័ពសត្រូវ ជ័យជម្នះនោះ មិនគួរអស្ចារ្យ ឯខ្ញុំបានញាំញីចិត្តកំណាញ់ ហើយថ្វាយសំពត់ដែលកំពុងដណ្តប់ដល់ព្រះទសពល ដូចបុគ្គលយកដំបងវាយក្បាលគោកាចដែលតាមមកអំពីក្រោយ ធ្វើឲ្យវាគេចទៅ ទើបជ័យជម្នះរបស់ខ្ញុំគួរអស្ចារ្យ ។ រាជបុរស ទៅក្រាបទូលរឿងនោះដល់ព្រះរាជា ។ ព្រះរាជាបញ្ជាថា អើ នាយពួកយើងមិនដឹងវត្ថុដែលសមគួរដល់ព្រះទសពល ព្រាហ្មណ៍នេះដឹង ទើបបញ្ជូនគូសំពត់មួយគូ ទៅព្រះរាជទានដល់ព្រាហ្មណ៍ ។ ព្រាហ្មណ៍នោះឃើញគូសំពត់នោះហើយ គិតថា ព្រះរាជានេះ មិនព្រះរាជទានអ្វីអំពីដំបូងដល់អញដែលអង្គុយស្ងៀមៗ កាលអញពោលគុណទាំងឡាយរបស់ព្រះបរមសាស្តា ទើបបានព្រះរាជទាន នឹងមានប្រយោជន៍អ្វីដល់អញ ដោយគូសំពត់ដែលអាស្រ័យគុណរបស់ព្រះបរមសាស្តាកើតឡើង ទើបបានថ្វាយសំពត់គូនោះដល់ព្រះទសពល ព្រះរាជាត្រាស់សួរថា ព្រាហ្មណ៍ធ្វើអ្វី ទ្រង់បានឮថា ព្រាហ្មណ៍ថ្វាយគូសំពត់នោះដល់ព្រះតថាគត ទើបបញ្ជាឲ្យបញ្ជូនគូសំពត់ ២ ដទៃទៅព្រះរាជទាន ។ ព្រាហ្មណ៍នោះបានថ្វាយគូសំពត់ ២ គូនោះ ។ ព្រះ

រាជាទ្រង់បញ្ជូនគូសំពត់ ៤ គូដទៃទៅព្រះរាជទាន ទ្រង់បញ្ជូនទៅព្រះរាជទាន រហូតដល់ទៅ ៣២ គូ ដោយប្រការយ៉ាងនេះ ។ លំដាប់នោះ ព្រាហ្មណ៍គិតថា ការធ្វើដូច្នេះ ហាក់ដូចជាឲ្យបន្ថែមឡើងហើយ ទើបទទួលយកសំពត់ ២ គូ ដើម្បីប្រយោជន៍ដល់ខ្លួន ១ គូ ដើម្បីនាងព្រាហ្មណី ១ គូ ហើយថ្វាយចំពោះព្រះទសពល ៣០ គូ ។ ចាប់តាំងអំពីនោះ ព្រាហ្មណ៍ក៏បានជាអ្នកស្និទ្ធស្នាលជាមួយព្រះបរមសាស្តា ។ ថ្ងៃមួយ ព្រះរាជាទ្រង់ស្តាប់ធម៌ ក្នុងសម្នាក់របស់ព្រះបរមសាស្តាក្នុងរដូវរងា បានព្រះរាជទានសំពត់កម្ពលក្រហមសម្រាប់ដណ្តប់ផ្ទាល់ខ្លួនព្រះអង្គ ដែលមានតម្លៃ ១០០០ ដល់ព្រាហ្មណ៍ ហើយប្រាប់ថា ចាប់ពីពេលនេះតទៅ អ្នកចូរដណ្តប់នូវសំពត់កម្ពលក្រហមមួយផ្ទាំងនេះស្តាប់ធម៌ ព្រាហ្មណ៍នោះគិតថា ប្រយោជន៍អ្វីសម្រាប់អញដោយសំពត់កម្ពលក្រហម ដែលនាំចូលទៅដណ្តប់ក្នុងកាយស្អុយនេះ ទើបបានធ្វើជាពិតាន លើគ្រែរបស់ព្រះតថាគត ខាងក្នុងព្រះគន្ធកុដិហើយ ក៏ទៅ ។ ថ្ងៃមួយ ព្រះរាជាយាងទៅព្រះវិហារអំពីព្រលឹម ប្រថាប់គង់ក្នុងទីជិតព្រះបរម-សាស្តាក្នុងព្រះគន្ធកុដិ ក្នុងខណៈនោះ ព្រះពុទ្ធរស្មីមានពណ៌ ៦ ប៉ះខ្ទប់ត្រង់សំពត់កម្ពល ក៏ចែងចាំងឡើង ព្រះរាជាទ្រង់ទតឃើញក៏ចាំបាន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សំពត់កម្ពលនេះរបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គឲ្យដល់ឯកសាដកព្រាហ្មណ៍ ។ ព្រះមានព្រះភាគត្រាស់ថា មហាបពិត្រ ទ្រង់បូជាព្រាហ្មណ៍ ព្រាហ្មណ៍បូជាតថាគត ។ ព្រះរាជាទ្រង់ជ្រះថ្លាថា ព្រាហ្មណ៍ដឹងវត្ថុដែលសមគួរ អាត្មាអញមិនដឹង ទើបព្រះរាជទានវត្ថុដែលជារបស់

ឧបការៈដល់មនុស្សគ្រប់យ៉ាង ក្នុងមួយមុខៗ ៨ ប្រាំបីដង ឲ្យជារបស់ព្រះរាជទាន ឈ្មោះថា សព្វដ្ឋកទាន ហើយទ្រង់តាំងឲ្យធ្វើជាបុរោហិត ។ ព្រាហ្មណ៍នោះគិតថា ឈ្មោះថា របស់ ៨ មុខ ៨ ដងជា ៦៤ មុខ ទើបរៀបចំសលាកភត្ត ៦៤ សម្រាប់ ឲ្យទាន រក្សាសីលដរាបអស់ជីវិត ចុតិអំពីជាតិនោះហើយ ទៅកើតក្នុងស្ថានសួគ៌ ចុតិអំពីស្ថានសួគ៌ មកកើតក្នុងផ្ទះរបស់កុដុម្ពិកៈ ក្នុងក្រុងពារាណសី ក្នុងចន្លោះកាលនៃព្រះពុទ្ធ ២ ព្រះអង្គ គឺព្រះមានព្រះភាគកោនាគមនៈ និងព្រះកស្សបទសពល ក្នុងកប្បនេះ កុលបុត្រនោះចម្រើនវ័យ ក៏រៀបការគ្រប់គ្រងផ្ទះ ថ្ងៃមួយ ដើរលម្ហែទៅក្នុងព្រៃ ។

សម័យនោះ ព្រះបច្ចេកពុទ្ធធ្វើចីវរកម្មនៅត្រង់ប្រាំងស្ទឹង សំពត់អនុវាតមិនគ្រប់គ្រាន់ ទើបបត់ទុក កុលបុត្រនោះឃើញ ទើបចូលទៅសួរថា ព្រោះហេតុអ្វី ទើបលោកម្ចាស់បត់ទុក ។ ព្រះបច្ចេកពុទ្ធពោលថា សំពត់អនុវាតមិនគ្រប់គ្រាន់ កុដុម្ពិកៈពោលថា សូមលោកម្ចាស់ទទួលសំពត់សាដកនេះធ្វើចុះ ។ កុលបុត្រនោះប្រគេនសំពត់សាដកហើយ តាំងសេចក្តីប្រាថ្នាថា ក្នុងទីដែលខ្ញុំកើតហើយ ការវិនាសណាមួយ កុំបីមានឡើយ ។ កាលនោះព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាតក្នុងផ្ទះរបស់កុលបុត្រនោះ ក្នុងខណៈដែលភរិយា និងប្អូនស្រីកំពុងទាស់គ្នា ។ ពេលនោះ ប្អូនស្រីរបស់កុលបុត្រនោះប្រគេនបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធហើយ ពោលសំដៅដល់ភរិយារបស់គាត់ថា អំណឹះតទៅ សូមឲ្យខ្ញុំឆ្ងាយអំពីស្រីពាលបែបនេះ ១០០ យោជន៍ ។ ភរិយារបស់គាត់ឈរនៅត្រង់ធ្លាផ្ទះ បានឮ ទើបគិតថា សូមភិក្ខុរូបនេះ កុំបាន

ឆាន់អាហារដែលស្រីនេះប្រគេនឡើយ ទើបចាប់បាត្រមកចាក់បិណ្ឌបាតចោល រួចយកកក់មកដាក់រហូតពេញ ។ ស្រីជាប្អូនឃើញ ទើបពោលថា ឱស្រីពាល ចូរនាងជេរបរិភាសយើងចុះ ការចាក់កត្តាហារអំពីបាត្ររបស់លោក ដែលបានបំពេញបារមីមកអស់ ២ អសង្ខេយ្យបែបនេះ ដាក់កក់ឲ្យ មិនសមគួរឡើយ គ្រានោះ ភរិយារបស់បុរសនោះ មានស្មារតីឡើង ទើបពោលថា សូមឈប់បន្តិចសិនលោកម្ចាស់ ហើយចាក់កក់ចេញ លាងបាត្រ អប់ដោយគ្រឿងក្រអូប ហើយដាក់មធុរស ៤ ប្រការពេញបាត្រ ហើយប្រគេនបាត្រដែលផូរផង់ដោយសប្បិ មានពណ៌ដូចត្របកឈូកដែលរោយអំពីខាងលើ ដាក់ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធ តាំងសេចក្ដីប្រាថ្នា សូមសរីរៈរបស់ខ្ញុំ ផូរផង់ដូចបិណ្ឌបាតដ៏ផូរផង់នេះចុះ ។ ព្រះបច្ចេកពុទ្ធអនុមោទនាហើយ ហោះទៅកាន់អាកាស ។

ស្វាមីភរិយាទាំង ២ នោះ តាំងនៅរហូតអស់អាយុហើយ ទៅកើតក្នុងស្ថានសួគ៌ ចុតិអំពីស្ថានសួគ៌នោះម្ដងទៀត ឧបាសកជាស្វាមីកើតជាកូនសេដ្ឋីមានសម្បត្តិ ៨០ កោដិ ក្នុងក្រុងពារាណសី ឯភរិយាកើតជាធីតារបស់សេដ្ឋីដូចគ្នា ក្នុងពុទ្ធុប្បាទនៃព្រះកស្សបទសពលសម្មាសម្ពុទ្ធ ។ កាលចម្រើនវ័យពួកញាតិក៏នាំធីតារបស់សេដ្ឋីនោះឯងមក ។ ដោយអានុភាពនៃកម្មដែលមានវិបាកមិនគួរប្រាថ្នាក្នុងជាតិមុន គ្រាន់តែនាងត្រូវបញ្ជូនចូលទៅកាន់ត្រកូលរបស់ប្ដី សរីរៈទាំងមូល ក៏មានក្លិនស្អុយដូចបង្គន់ដែលគេបើកចំហ តាំងអំពីឈានចូលទៅខាងក្នុងធរណីទ្វារ ។ សេដ្ឋីកុមារសួរថា នេះក្លិនរបស់នរណា

បានស្តាប់ថា របស់កូនស្រីសេដ្ឋី ទើបពោលថា នាំចេញទៅៗ ហើយបញ្ជូនត្រឡប់ទៅកាន់ផ្ទះត្រកូល ដោយទំនងដែលមក នាងទារិកាត្រូវបញ្ជូនត្រឡប់ទៅមកអស់ ៧ ដង ដោយទំនងនេះឯង ។

សម័យនោះ ព្រះកស្សបទសពល ទ្រង់បរិនិព្វានហើយ ពុទ្ធសាសនិកផ្តើមសាងចេតិយកម្ពស់មួយយោជន៍ដោយឥដ្ឋមាសចូទ់ផង ក្រាស់ផង មានតម្លៃមួយដុំដល់ទៅមួយសែន ។ កាលគេកំពុងសាងចេតិយ សេដ្ឋីធីតានោះគិតថា អញត្រូវបញ្ជូនទៅបញ្ជូនមកអស់ ៧ ដងហើយ ប្រយោជន៍អ្វីដោយជីវិតរបស់អញ ទើបឲ្យដោះគ្រឿងអលង្ការ ធ្វើឥដ្ឋមាស បណ្តោយមួយហត្ថទទឹង ១ ចំអាម កម្រាស់ ៤ ធ្នាប់ បន្ទាប់អំពីនោះ កាន់យកដុំហរិតាល និងមនោសិលា កាន់យកផ្កាឈូក ៨ ក្តាប់ ទៅកាន់ទីសាងព្រះចេតិយ ។ គ្រានោះ ជួរនៃដុំឥដ្ឋមួយដុំ ដែលតម្រៀបមកជាប់ពីគ្នា ទើបនាងពោលនឹងជាងថា សូមលោកដាក់ឥដ្ឋមួយដុំនេះត្រង់នេះ ។ មេជាងពោលថា នាងដ៏ចម្រើន នាងមកទាន់ពេល ចូរនាងដាក់ឯងចុះ ។ ទើបនាងឡើងទៅយកប្រេងផ្សំនឹងហរិតាលនិងមនោសិលា ដាក់ឥដ្ឋបិទភ្ជាប់ដោយបាយអនោះ ហើយបូជាដោយផ្កាឧប្បល ៨ ក្តាប់ ខាងលើឥដ្ឋ ថ្វាយបង្គំហើយ តាំងសេចក្តីប្រាថ្នាថា ក្នុងទីដែលខ្ញុំកើតសូមក្លិនចន្ទន៍ផ្សាយចេញអំពីខ្លួន ក្លិនឧប្បលផ្សាយអំពីមាត់ ហើយថ្វាយបង្គំព្រះចេតិយ ធ្វើប្រទក្សិណស្រេចហើយ ត្រឡប់ទៅ ។ ក្នុងខណៈនោះឯងសេដ្ឋីបុត្រក៏កើតសតិប្រារព្ធដល់សេដ្ឋីធីតា ដែលគេនាំមកផ្ទះក្នុងកាលមុន ។ ក្នុងព្រះនគរក៏មាននក្ខត្តឫក្សសំឡេងអឺងកង ទើបសេដ្ឋីបុត្រពោលនឹងអ្នកបម្រើ

ថា ក្នុងកាលមុន គេនាំសេដ្ឋីធីតាមកក្នុងទីនេះ ចុះនាងនៅឯណា ។ អ្នកបម្រើពោលថា នៅឯត្រកូលរបស់នាង សេដ្ឋីបុត្រពោលថា ពួកអ្នកចូរនាំមក ខ្ញុំនឹងលេងនក្ខត្តឫក្សជាមួយនាង ។ ពួកអ្នកបម្រើទៅសំពះនាង ហើយឈរត្រូវនាងសួរថា អ្នកទាំងឡាយមកធ្វើអ្វី ទើបប្រាប់ដំណើររឿងដែលមកនោះ នាងពោលថា អ្នកទាំងឡាយ ខ្ញុំយកគ្រឿងអាភរណៈបូជាព្រះចេតិយអស់ហើយ ខ្ញុំមិនមានគ្រឿងអាភរណៈទេ ទើបអ្នកបម្រើទាំងនោះ ទៅប្រាប់ដល់សេដ្ឋីបុត្រ សេដ្ឋីបុត្រពោលថា ចូរនាំមកចុះ នាងនឹងបានគ្រឿងប្រដាប់នោះ ទើបពួកគេនាំនាងមក ក្លិនចន្ទន៍ និងក្លិនឧប្បលផ្សាយទូទៅពេញផ្ទះ ដំណាលគ្នានឹងនាងដែលចូលទៅក្នុងផ្ទះ ។ ទើបសេដ្ឋីបុត្រសួរនាងថា ដំបូងក្លិនស្អុយផ្សាយចេញអំពីខ្លួន តែឥឡូវនេះ ក្លិនចន្ទន៍ផ្សាយចេញអំពីខ្លួន ក្លិនឧប្បលផ្សាយចេញពីមាត់របស់នាង តើសេចក្តីនេះដូចម្តេច ។ ទើបសេដ្ឋីធីតាប្រាប់កម្មដែលខ្លួនធ្វើតាំងអំពីដើមដល់ចប់ ។ សេដ្ឋីបុត្រជ្រះថ្លា ពោលថា ពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ ជានិយ្យានិកធម៌ហ្ន៎ ទើបយកគ្រឿងដណ្តប់ដែលធ្វើដោយសំពត់កម្ពលស្រោបព្រះចេតិយមាស មានប្រមាណមួយយោជន៍ ហើយយកផ្កាបទុមមាស ទំហំប៉ុនកង់រទេះ ប្រដាប់ត្រង់ចេតិយមាសនោះ ។ ផ្កាបទុមមាសដែលគេព្យួរសំយុង មានទំហំ ១២ ហត្ថ ។ សេដ្ឋីបុត្រនោះ តាំងនៅដរាបអស់អាយុក្នុងមនុស្សលោកនេះ ហើយកើតក្នុងស្ថានសួគ៌ ច្យុតអំពីស្ថានសួគ៌នោះ កើតក្នុងត្រកូលអមាត្យមួយ ក្នុងទីចម្ងាយប្រមាណមួយយោជន៍អំពីក្រុងពារាណសី ឯសេដ្ឋីធីតា ច្យុតិអំពីទេវលោក

កើតជាព្រះរាជធីតាច្បង ក្នុងរាជត្រកូល ។

កាលជនទាំង ២ នោះចម្រើនវ័យ គេប្រកាសលេងនក្ខត្តឫក្សក្នុងស្រុកដែលកុមារនៅ ។ កុមារនោះពោលនឹងម្តាយថា បពិត្រអ្នកម៉ែ សូមម៉ែឲ្យសំពត់សាដកខ្ញុំ ខ្ញុំនឹងលេងនក្ខត្តឫក្ស ម្តាយបាននាំសំពត់ដែលប្រើហើយមកឲ្យ ។ កុមារបដិសេធថា សំពត់នេះគ្រោតគ្រាតណាស់ ។ នាងក៏នាំសំពត់ដទៃមកឲ្យ សូម្បីសំពត់នោះ គេក៏បដិសេធ ។ ពេលនោះ ទើបម្តាយពោលនឹងកុមារថា នែបា យើងកើតក្នុងផ្ទះដូច្នេះ ពួកយើងមិនមានបុណ្យដែលអាចបានសំពត់សាច់ម៉ដ្ឋជាងនេះឡើយ កុមារពោលថា បពិត្រអ្នកម៉ែ បើដូច្នោះខ្ញុំនឹងទៅទីដែលនឹងបានសំពត់នេះ ។ ម្តាយពោលថា នែកូន ម៉ែប្រាថ្នាឲ្យកូនបានរាជសម្បត្តិ ក្នុងក្រុងពារាណសីថ្ងៃនេះឯង ។

កុមារថ្វាយបង្គំម្តាយហើយ ពោលថា ខ្ញុំទៅហើយម៉ែ មាតាពោលថា ទៅចុះកូន ។ បានឮថា ម្តាយរបស់កុមារមានគំនិតយ៉ាងនេះថា កូនរបស់អញមិនទៅណាឡើយ គង់អង្គុយក្នុងទីនេះ ទីនោះ ក្នុងផ្ទះនេះឯង ។ កុមារនោះចេញទៅតាមកំណត់នៃបុណ្យ ទៅដល់ក្រុងពារាណសី ដេកទទូរក្បាលលើមង្គលសិលាអាសនៈ ក្នុងព្រះរាជឧទ្យាន ។ ព្រះបាទពារាណសីនោះសោយទិវង្គតអស់ ៧ ថ្ងៃ អមាត្យទាំងឡាយធ្វើការថ្វាយព្រះភ្លើង អង្គុយប្រឹក្សាត្រង់លានព្រះរាជវាំងថា ព្រះរាជាមានតែព្រះធីតា មិនមានព្រះរាជឱរសរាជសម្បត្តិមិនមានព្រះរាជា មិនសមគួរឡើយ អ្នកណាហ្ន៎ជាព្រះរាជា ក៏ជជែកគ្នាថា លោកខាងនោះ លោកខាងនោះ ។ បុរោហិតពោលថា មិនគួរ

ជ្រើសរើសច្រើនពេកទេ ពួកយើងនឹងអញ្ជើញទេវតា ហើយផ្សងបុស្សរថ ដើម្បីរកបុគ្គលដែលសមគួរគ្រងរាជ្យ ។ អមាត្យទាំងនោះ ទឹមសេះសិន្ធព ៤ មានពណ៌ដូចផ្កាកោមុទ ហើយរៀបចំគ្រឿងរាជកកុធភណ្ឌ ៥ យ៉ាង មួយអន្លើដោយស្វេតច្ឆត្រ ដាក់លើបុស្សរថនោះឯង លែងបុស្សរថនោះទៅ ឲ្យប្រគំតន្ត្រីទៅតាមក្រោយ ។ រថចេញទៅតាមទ្វារទិសខាងកើត បែរមុខទៅកាន់ព្រះរាជឧទ្យាន ។ អមាត្យពួកខ្លះពោលថា រថបែរមុខទៅកាន់ព្រះរាជ-ឧទ្យាន ព្រោះសេះធ្លាប់ទៅ ពួកអ្នកចូរឲ្យសេះត្រឡប់ បុរោហិតពោលថា កុំឲ្យត្រឡប់ឡើយ ។ រថធ្វើប្រទក្សិណកុមារហើយ ក៏ឈប់មានអាការដូចជាឲ្យឡើង ។ បុរោហិតបើកជាយសំពត់ដណ្តប់ ពិនិត្យមើលផ្ទៃបាតជើងហើយពោលថា ទ្វីបនេះចូរលើកទុកចុះ បុគ្គលនេះសមគួរគ្រងរាជ្យក្នុងទ្វីបទាំង ៤ មានទ្វីប ២០០០ ជាបរិវារ ហើយបញ្ជាឲ្យប្រគំតន្ត្រីឡើង ៣ ដងថា ពួកអ្នកចូរប្រគំតន្ត្រីឡើង ។

គ្រានោះ កុមារបើកមុខ សម្លឹងមើលហើយ ពោលថា អ្នកទាំងឡាយពួកអ្នកមកដោយកិច្ចកម្មអ្វីឬ ។ ពួកអមាត្យពោលថា បពិត្រសម្មតិទេព រាជ-សម្បត្តិដល់ព្រះអង្គហើយ ។ កុមារពោលថា ចុះព្រះរាជារបស់អ្នកទៅណា ។ អមាត្យពោលថា ទ្រង់សោយទិវង្គតហើយ ។ កុមារពោលថា កន្លងទៅប៉ុន្មានថ្ងៃហើយ ។ អមាត្យពោលថា ថ្ងៃនេះ ជាថ្ងៃទី ៧ ហើយ ។ កុមារពោលថា ចុះព្រះរាជឱរស និងព្រះរាជធីតា មិនមានទេឬ ។ អមាត្យពោលថា បពិត្រសម្មតិទេព មានតែព្រះរាជធីតា ព្រះរាជឱរសមិនមានឡើយ ។ កុមារ

ពោលថា បើដូច្នោះ ខ្ញុំនឹងគ្រងរាជ្យ ។ អមាត្យទាំងនោះ សាងមណ្ឌបសម្រាប់អភិសេកក្នុងខណៈនោះមួយរំពេច តាក់តែងព្រះរាជធីតាដោយគ្រឿងអលង្ការគ្រប់យ៉ាង នាំមកកាន់ព្រះរាជឧទ្យាន ធ្វើការអភិសេកជាមួយកុមារ ។

គ្រានោះ កាលព្រះកុមារ ធ្វើការអភិសេកហើយ ប្រជាជននាំសំពត់មានតម្លៃមួយសែនមកថ្វាយ ។ ព្រះកុមារពោលថា នេះជាអ្វី ។ អមាត្យទូលថា បពិត្រសម្មតិទេព សំពត់ស្លៀកព្រះអង្គ ។ ព្រះកុមារពោលថា សំពត់នេះសាច់គ្រោតគ្រាតមិនមែនឬ សំពត់ដទៃដែលមានសាច់ល្អិតជាងនេះ មិនមានឬ អមាត្យទូលថា បពិត្រសម្មតិទេព ក្នុងបណ្ដាសំពត់ដែលមនុស្សទាំង-ឡាយប្រើប្រាស់ សំពត់ដែលសាច់ល្អិតជាងនេះមិនមានទេ ព្រះអង្គ ។ ព្រះកុមារពោលថា ព្រះរាជារបស់ពួកអ្នក ទ្រង់ស្លៀកសំពត់បែបនេះឬ ។ អមាត្យពោលថា បពិត្រសម្មតិទេព ពិតហើយ ។ ព្រះរាជកុមារពោលថា ព្រះរាជារបស់ពួកអ្នកប្រហែលជាមិនមានបុណ្យ ពួកអ្នកចូរនាំកុណ្ឌីមាសមក ខ្ញុំនឹងបានសំពត់ ។ អមាត្យទាំងនោះយកកុណ្ឌីមាសមកថ្វាយ ។ ព្រះកុមារនោះក្រោកឡើង លុបព្រះភក្ត្រ ខ្ពុរព្រះឱស្ឋ យកដៃកូរទឹក បាចទៅទិសខាងកើតក្នុងខណៈនោះឯង ដើមកប្បព្រឹក្សក៏ជ្រែកផែនដីផុសឡើងមក ៨ ដើម ទ្រង់កូរទឹកបាចទៅទៀត គ្រប់ទិសទាំង ៤ យ៉ាងនេះ គឺទិសខាងត្បូង ទិសខាងលិច ទិសខាងជើង ។ ដើមកប្បព្រឹក្សផុសឡើងក្នុងទិសទាំង ៤ មួយទិស ៨ ដើម រួមជា ៣២ ដើម ។ ព្រះកុមារនោះស្លៀកសំពត់ទិព្វមួយផ្ទាំង ដណ្ដប់មួយផ្ទាំង ហើយប្រាប់ថា អ្នកទាំងឡាយ ចូរត្រាច់វាយស្គរ ប្រកាសយ៉ាងនេះ

ថា ក្នុងដែនរបស់ព្រះបាទនន្ទរាជ ពួកស្ត្រីដែលធ្វើកិច្ចត្បាញវវៃ កុំបាច់ត្បាញវវៃឡើយ ដូច្នេះហើយ ឲ្យលើកឆត្រឡើង ទ្រង់ប្រដាប់គាក់តែងព្រះអង្គ ឡើងកាន់ដំរីដ៏ប្រសើរចូលព្រះនគរ ឡើងកាន់ប្រាសាទ សោយមហាសម្បត្តិ ។

ក្នុងកាលកន្លងទៅដោយអាការយ៉ាងនេះ ថ្ងៃមួយ ព្រះទេវីឃើញមហាសម្បត្តិរបស់ព្រះរាជាហើយ នាងសម្តែងអាការនៃសេចក្តីករុណាថា ឱ! លោកអ្នកមានតបៈ ។ ព្រះរាជាត្រាស់សួរថា នែទេវី មានរឿងអ្វី ។ ទើបទូលថា បពិត្រសម្មតិទេព សម្បត្តិរបស់ព្រះអង្គធំក្រៃលែង ក្នុងអតីតកាល ទ្រង់បានជឿចំពោះព្រះពុទ្ធទាំងឡាយ បានធ្វើកុសលកម្ម ឥឡូវនេះ ទ្រង់មិនធ្វើកុសលដែលជាបច្ច័យដល់អនាគត ព្រះរាជាត្រាស់ថា យើងនឹងឲ្យដល់អ្នកណា បើអ្នកមានសីលមិនមាន ។ ព្រះទេវីទូលថា បពិត្រសម្មតិទេព ជម្ពូទ្វីប មិនសូន្យចាកព្រះអរហន្តទាំងឡាយទេ សូមព្រះអង្គត្រៀមរៀបចំទានចុះ ខ្ញុំម្ចាស់នឹងសូម គឺនិមន្តព្រះអរហន្តក្នុងថ្ងៃស្អែក ព្រះរាជាបញ្ជាឲ្យត្រៀមទាន ត្រង់ទ្វារទិសខាងកើត ។ ព្រះទេវីទ្រង់អធិដ្ឋានអង្គឧបោសថអំពីព្រលឹម បែរមុខទៅទិសខាងកើត ក្រាបចុះលើប្រាសាទជាន់លើ ហើយពោលថា បើព្រះអរហន្តមានក្នុងទិសនេះ ស្អែកនេះ សូមនិមន្តមកទទួលភិក្ខាហាររបស់យើងខ្ញុំចុះ ក្នុងទិសនេះ មិនមានព្រះអរហន្ត ក៏បានឲ្យសក្ការៈដែលត្រៀមទុកនោះដល់មនុស្សកំព្រា និងយាចក ។ ក្នុងថ្ងៃស្អែកឡើង ត្រៀមរៀបចំទានត្រង់ទ្វារទិសខាងត្បូង ហើយបានធ្វើយ៉ាងនោះទៀត ។ ក្នុងថ្ងៃស្អែកឡើង ត្រៀមរៀបចំត្រង់ទ្វារទិសខាងលិច ក៏បានធ្វើយ៉ាងនោះ ។ ក្នុងថ្ងៃដែលទ្រង់ត្រៀមរៀបចំ

ត្រង់ទ្វារទិសខាងជើង ព្រះមហាបទុមបច្ចេកពុទ្ធ ដែលជាបងប្រុសរបស់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ដែលជាឱរសរបស់ព្រះនាងបទុមវតី នៅក្នុងព្រៃហិមពាន្ត ត្រូវព្រះទេវីនិមន្តយ៉ាងនោះ ហៅព្រះបច្ចេកពុទ្ធ ដែលជាប្អូនប្រុសមកថា លោកនិទ្ទុក្ខទាំងឡាយ ព្រះបាទនន្ទរាជនិមន្តអ្នកទាំងឡាយ ។ ចូរទទួលនិមន្តរបស់ព្រះរាជាចុះ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ទទួលនិមន្តហើយ ក្នុងថ្ងៃស្អែកឡើង លុបមុខត្រង់អនោតត្តស្រះ ហោះទៅចុះត្រង់ទ្វារទិសខាងជើង ពួកមនុស្សក្រាបទូលដល់ព្រះរាជាថា បពិត្រសម្មតិទេព ព្រះបច្ចេកពុទ្ធ ៥០០ អង្គ និមន្តមកហើយ ព្រះអង្គ ។ ព្រះរាជាយាងទៅ មួយអន្លើដោយព្រះទេវីថ្វាយបង្គំហើយ ទទួលបាត្រ និមន្តព្រះបច្ចេកពុទ្ធទាំងឡាយឡើងកាន់ប្រាសាទ ថ្វាយទានដល់ព្រះបច្ចេកពុទ្ធទាំងនោះ លើប្រាសាទនោះ ក្នុងវេលាស្រេចភត្តកិច្ច ព្រះរាជាក្រាបទៀបបាតជើងព្រះបច្ចេកពុទ្ធដែលជាប្រធាន ព្រះទេវីក្រាបទៀបបាតជើងរបស់ព្រះសង្ឃនវក ហើយពោលថា បពិត្រលោកម្ចាស់ទាំងឡាយ លោកម្ចាស់ទាំងឡាយ កុំលំបាកដោយរឿងបច្ច័យ យើងខ្ញុំទាំងឡាយនឹងមិនធ្វើបុណ្យឲ្យវិនាស សូមលោកម្ចាស់ទាំងឡាយឲ្យបដិញ្ញា ដើម្បីគង់នៅក្នុងទីនេះដរាបដល់អស់អាយុ នៃយើងខ្ញុំទាំងឡាយចុះ ។ កាលឲ្យលោកទទួលបដិញ្ញាហើយ ទើបឲ្យតាក់តែងទីកន្លែងសម្រាប់នៅអាស្រ័យ ដល់ព្រះបច្ចេកពុទ្ធទាំងនោះក្នុងឧទ្យាន ដោយអាការទាំងពួង គឺបណ្ណសាលា ៥០០ ទីចង្ក្រម ៥០០ ហើយនិមន្តលោកឲ្យគង់នៅក្នុងទីនោះឯង ។ កាលវេលាកន្លងទៅ ដោយប្រការយ៉ាងនេះ អ្នកជាយដែនរបស់ព្រះរាជាធ្វើនូវការបះបោរ

ឡើង ។ ព្រះរាជាទ្រង់ឲ្យឱវាទដល់ព្រះទេវីថា ខ្ញុំទៅរម្ងាប់ខាងជាយដែន នាង កុំលះបង់ព្រះបច្ចេកពុទ្ធទាំងឡាយ ហើយយាងចេញអំពីព្រះនគរទៅ កាល ទ្រង់មិនទាន់យាងត្រឡប់ ព្រះបច្ចេកពុទ្ធទាំងឡាយ ក៏អស់នូវអាយុសង្ខារ ។

ព្រះមហាបទុមបច្ចេកពុទ្ធចូលឈានអស់រាត្រីទាំង ៣ យាម ក្នុងវេលា ទៀបភ្លឺ ឈរផ្អែកបន្ទះក្តារសម្រាប់គោងបរិនិព្វាន ដោយអនុបាទិសេសនិព្វាន-ធាតុ ព្រះបច្ចេកពុទ្ធដ៏សេស ក៏បរិនិព្វានហើយដោយវិធីនោះ ។ ក្នុងថ្ងៃស្អែក ឡើង ព្រះទេវីឲ្យធ្វើទីអង្គុយសម្រាប់ព្រះបច្ចេកពុទ្ធទាំងឡាយ រំលេចដោយ របស់ពណ៌ខៀវ រោយនូវផ្កាឈើ ប្រោះគ្រឿងក្រអូប អង្គុយរង់ចាំព្រះ បច្ចេកពុទ្ធទាំងឡាយនិមន្តមក កាលមិនឃើញ បញ្ជូនរាជបុរសទៅថា ចូរបា ទៅ ហើយចូរដឹងថា លោកម្ចាស់ទាំងឡាយមិនមានផាសុក ឬដូចម្តេច រាជ-បុរសនោះទៅហើយ បើកទ្វារបណ្ណសាលារបស់ព្រះមហាបទុមបច្ចេកពុទ្ធ កាលមិនជួបក្នុងបណ្ណសាលានោះ ទើបទៅកាន់ទីចង្ក្រម ឃើញលោកឈរ ផ្អែកក្តារសម្រាប់គោង ទើបថ្វាយបង្គំ ហើយពោលថា កត្តកាលដល់ហើយ លោកម្ចាស់ ។ សរីរៈរបស់បុគ្គលដែលបរិនិព្វានហើយ នឹងពោលបានដូច ម្តេច ។ រាជបុរសនោះគិតថា ប្រហែលលោកសិងលក់ ទើបដើរទៅយកដៃ ស្ទាបត្រង់ខ្នងជើង ដឹងថា បរិនិព្វានហើយ ព្រោះជើងទាំង ២ ត្រជាក់ និង រឹង ទើបទៅកាន់សម្នាក់របស់ព្រះបច្ចេកពុទ្ធអង្គទី ២ កាលដឹងថា អង្គទី ២ បរិនិព្វានហើយយ៉ាងនោះ ក៏ទៅកាន់សម្នាក់របស់ព្រះបច្ចេកពុទ្ធអង្គទី ៣ ដឹង ថា ព្រះបច្ចេកពុទ្ធគ្រប់អង្គបរិនិព្វានហើយ ដោយប្រការដូច្នេះ ។ ទើបទៅកាន់

រាជត្រកូល ព្រះទេវីត្រាស់សួរថា ព្រះបច្ចេកពុទ្ធទាំងឡាយទៅណាហើយបា ទើបក្រាបទូលថា បពិត្រព្រះទេវី ព្រះបច្ចេកពុទ្ធទាំងឡាយបរិនិព្វានហើយ ។ ព្រះទេវីទ្រង់ព្រះកន្សែងសោយសោក យាងចេញទៅកាន់បណ្ណសាលានោះ មួយអន្លើដោយអ្នកស្រុក បញ្ជាឲ្យលេងសាធុកីឡា គឺការលេងដែលទាក់ទង ដោយរឿងអនិច្ចំ ទុក្ខំ អនត្តា ធ្វើឈាបនកិច្ចសរីរៈរបស់ព្រះបច្ចេកពុទ្ធទាំង-ឡាយ ហើយសាងព្រះចេតិយបញ្ចុះព្រះធាតុ ។ ព្រះរាជាទ្រង់បង្ក្រាបជាយ ដែនឲ្យស្ងប់ហើយ យាងត្រឡប់មក សាកសួរព្រះទេវី ដែលមកទទួលថា នែនាង នាងមិនប្រមាទក្នុងព្រះបច្ចេកពុទ្ធទាំងឡាយទេឬ ព្រះបច្ចេកពុទ្ធទាំង-ឡាយមានសេចក្តីសុខដែរឬ ។ ព្រះទេវីទូលថា បពិត្រសម្មតិទេព លោក ម្ចាស់ទាំងឡាយបរិនិព្វានហើយ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា មរណៈគង់ កើតដល់បណ្ឌិតទាំងឡាយ ដែលមានសភាពបែបនេះ ពួកយើងនឹងរួចផុត អំពីទីណា ទ្រង់ក៏មិនយាងទៅព្រះនគរ យាងទៅកាន់ព្រះរាជឧទ្យាននោះឯង ។ ត្រាស់ឲ្យហៅព្រះរាជឱរសច្បងមកហើយ ប្រគល់រាជសម្បត្តិដល់ព្រះឱរស នោះហើយឲ្យឱវាទ ។ ឯព្រះអង្គទ្រង់ព្រះផ្នួសជាសមណៈ ។ ចំណែកព្រះ ទេវី កាលព្រះរាជាទ្រង់ព្រះផ្នួសហើយ មានព្រះតម្រិះថា អាត្មាអញនឹងនៅ ធ្វើអ្វី ទើបព្រះនាងបួសនៅក្នុងព្រះរាជឧទ្យាននោះឯង ។ ព្រះរាជា និងព្រះ ទេវីទាំង ២ ព្រះអង្គនោះ បំពេញឈាន បានចុតិអំពីអត្តភាពនោះ ទៅកើត ក្នុងព្រហ្មលោក ។

កាលជនទាំង ២ នោះ នៅក្នុងព្រហ្មលោកនោះឯង ព្រះសាស្តានៃ

យើងទាំងឡាយ កើតឡើងក្នុងលោក ប្រកាសធម្មចក្រដ៏ប្រសើរ ចូលទៅកាន់ក្រុងរាជគ្រឹះដោយលំដាប់ ។ កាលព្រះសាស្តាប្រថាប់នៅក្នុងក្រុងរាជគ្រឹះនោះ បិប្ផលិមាណពនេះ កើតក្នុងផ្ទៃករិយាធំរបស់កបិលព្រាហ្មណ៍ ក្នុងព្រាហ្មណគាម ឈ្មោះថា មហាតិត្ថៈ ក្នុងមគធរដ្ឋ ។ នាងកញ្ញាកាបិឡានីនេះកើតក្នុងផ្ទៃនៃករិយាធំរបស់ព្រាហ្មណ៍កោលិយគោត្រ ក្នុងសាគលនគរ ក្នុងមទ្ទរដ្ឋ ។ កាលជនទាំង ២ នោះ ធំឡើងដោយលំដាប់ នាងកញ្ញាមានអាយុ ១៦ ឆ្នាំ បិប្ផលិមាណពមានអាយុ ២០ ឆ្នាំ មាតាបិតាសម្លឹងមើលបុត្រហើយ និយាយបែបបន្ទឹថា នែបា កូនធំហើយ ធម្មតាវង្សត្រកូល ចាំបាច់ឲ្យតាំងនៅ មាណពពោលថា លោកទាំង ២ កុំពោលពាក្យបែបនេះ កូនមិនចង់ស្តាប់ឡើយ កូននឹងបដិបត្តិដរាបណា លោកទាំង ២ នៅមានជីវិតនៅឡើយ លុះលោកទាំងពីរអនិច្ចកម្មហើយ កូននឹងបួស ។ មាតាបិតាឲ្យកាលវេលាកន្លងទៅ ២-៣ ថ្ងៃ ក៏ពោលទៀត មាណពនោះក៏បដិសេធដូចមុននោះឯង តាំងអំពីនោះ មាតាបានពោលដល់ការរៀបការរឿយៗ នោះឯង ។

មាណពគិតថា អញនឹងញ៉ាំងមាតាឲ្យយល់ព្រម ទើបឲ្យយកមាសទឹកដប់ ឲ្យជាងធ្វើរូបស្រីម្នាក់ ក្នុងវេលាធ្វើស្រេច មានការដុសខាត់ និងលាបលនជាដើមនូវរូបស្រីនោះ ទើបឲ្យរូបស្រីនោះ ស្លៀកសំពត់ក្រហម ប្រដាប់ដោយផ្កាដ៏សម្បូរដោយពណ៌ និងគ្រឿងប្រដាប់ផ្សេងៗ ហើយហៅមាតាមកពោលថា អ្នកម៉ែ បើកូនបានអារម្មណ៍បែបនេះ ទើបព្រមរៀបការ បើមិនបានខ្ញុំមិនរៀបការទេ ។ នាងព្រាហ្មណីជាអ្នកមានបញ្ញា ទើបគិតថា កូនរបស់អញ

ជាអ្នកមានបុណ្យ បានឲ្យទានហើយ សាងអភិនីហារមកហើយ កាលនឹងធ្វើបុណ្យ គង់មិនធ្វើម្នាក់ឯង ស្រីដែលធ្វើបុណ្យរួមជាមួយកូនរបស់អញនេះ នឹងមានចំណែកប្រៀបដូចមាសពិត ទើបហៅព្រាហ្មណ៍ ៨ នាក់មក ឲ្យឆ្អែតស្កប់ស្កល់ដោយវត្ថុដែលត្រូវការគ្រប់យ៉ាង ឲ្យលើករូបមាសឡើងដាក់លើរថ ហើយបញ្ជូនទៅថា បាទាំងឡាយ ចូរនាំគ្នាទៅ បើឃើញទារិកាដែលមានរូបបែបនេះ ក្នុងត្រកូលស្មើគ្នាជាមួយពួកយើង ដោយជាតិ គោត្រ និងភោគទ្រព្យ ក្នុងទីណា ចូរឲ្យរូបមាសនេះឯងជាបណ្ណាការក្នុងទីនោះ ។

ព្រាហ្មណ៍ទាំងនោះ នាំគ្នាចេញទៅ ដោយគិតថា នេះជាកិច្ចកម្មរបស់ពួកយើង ទើបគិតថា យើងគួរទៅទីណាហ្ន៎ ក៏យល់ស្របគ្នាថា ធម្មតា មទ្ទរដ្ឋជាប្រភពកើតនៃស្ត្រី ពួកយើងនឹងទៅមទ្ទរដ្ឋ ដូច្នេះហើយ ទើបបានទៅកាន់សាគលនគរ ក្នុងមទ្ទរដ្ឋ ។ គ្រានោះ មេដោះរបស់នាងកទ្ទា ឲ្យនាងកទ្ទាងូតទឹក ហើយតែងខ្លួនឲ្យអង្គុយក្នុងបន្ទប់ដ៏ស្អាត ហើយខ្លួនឯងទៅងូតទឹក ឃើញរូបនោះ ទើបគិតដោយចិត្តថា កូនស្រីរបស់អញ មកក្នុងទីនេះ ពោលថា នែហងក្បាលរឹង មកក្នុងទីនេះធ្វើអ្វី ហើយងាដៃវាយត្រង់ថ្ពាល់ ព្រមទាំងវាចាថា ចូរប្រញាប់ទៅ ។ ដៃខ្ទរដូចវាយដុំថ្ម មេដោះនោះដឹងថា ជារបស់រឹងដោយអាការយ៉ាងនេះ ទើបចៀសចេញទៅ ហើយពោលថា ខ្ញុំឃើញរូបមាស ក៏ស្មានថា ជាធីតារបស់ម្ចាស់ខ្លួនឯង ឯរូបនេះ សូម្បីជាអ្នកទទួលសំពត់ស្លៀករបស់កូនស្រីម្ចាស់ខ្ញុំ ក៏មិនសម ។ ពេលនោះ ពួកមនុស្សទាំងនោះនាំគ្នាចោមរោមនាង ហើយសួរថា ធីតារបស់ម្ចាស់នាង មានរូបយ៉ាង

នេះឬ ស្រីមេដោះពោលថា រូបនេះស្អាត ធីតានៃម្ចាស់របស់ខ្ញុំ ស្អាតជាងនេះរាប់រយដង ពាន់ដង កាលនាងអង្គុយក្នុងបន្ទប់ប្រមាណ ១២ ហត្ថ កិច្ចដោយពន្លឺប្រទីបមិនមាន នាងកម្ចាត់ងងឹតដោយពន្លឺដែលចេញអំពីសរីរៈនោះឯង ពួកមនុស្សទាំងនោះពោលថា បើយ៉ាងនោះ ចូរមកចុះ ហើយកាន់គ្រឿងបូជា លើករូបមាសឡើងដាក់លើរថ ហើយឈប់នៅត្រង់ទ្វារផ្ទះរបស់ព្រាហ្មណកោសិយគោត្រ ហើយប្រាប់ឲ្យជ្រាបដល់ការមក ។

ព្រាហ្មណ៍ធ្វើបដិសណ្ឋារៈ ហើយសួរថា ពួកលោកមកអំពីណា ជនទាំងនោះឆ្លើយថា មកអំពីផ្ទះកបិលព្រាហ្មណ៍ ក្នុងមហាតិត្ថគាម ក្នុងមគធរដ្ឋ ។ ព្រាហ្មណ៍សួរថា មកព្រោះហេតុអ្វី ជនទាំងនោះឆ្លើយថា ព្រោះហេតុឈ្មោះនេះ ព្រាហ្មណ៍ពោលថា ល្អណាស់ អ្នកទាំងឡាយ ព្រាហ្មណ៍របស់ពួកយើងមានជាតិ គោត្រ និងទ្រព្យសម្បត្តិស្មើគ្នា យើងនឹងឲ្យទារិកា ដូច្នេះហើយទទួលគ្រឿងបណ្ណាការ ។ ជនទាំងនោះ បញ្ជូនដំណឹងដល់កបិលព្រាហ្មណ៍ថា បានទារិកាហើយ សូមលោកធ្វើវត្ថុដែលត្រូវធ្វើ ។ កបិលព្រាហ្មណ៍បានស្ដាប់ដំណឹងនោះហើយ ទើបប្រាប់ដល់បិប្ផលិមាណពថា បានឮថា រកទារិកាបានហើយ ។ មាណពគិតថា អញគិតថា មិនបាន មនុស្សទាំងនោះពោលថា រកបានហើយ អញមិនត្រូវការ អញនឹងបញ្ជូនសំបុត្រទៅ ហើយទៅក្នុងទីស្ងាត់ សរសេរសំបុត្រថា កទ្ទា នាងចូរបានគូគ្រប់គ្រង ដែលសមគួរដល់ជាតិ គោត្រ និងទ្រព្យសម្បត្តិរបស់ខ្លួន ខ្ញុំនឹងចេញបួស ទើបមិនក្ដៅក្រហាយក្នុងកាលជាក្រោយ ។ សូម្បីនាងកទ្ទាបានដំណឹងថា មាតាបិតាប្រាថ្នានឹងឲ្យ

ដល់បុគ្គលនោះ ទើបទៅក្នុងទីស្ងាត់ សរសេរសំបុត្រថា សូមអយ្យបុត្របាននូវគូគ្រប់គ្រងផ្ទះ ដែលសមគួរដល់ជាតិ គោត្រ និងទ្រព្យសម្បត្តិរបស់ខ្លួន ខ្ញុំនឹងចេញបួស ទើបមិនក្តៅក្រហាយក្នុងកាលជាក្រោយ ។ សំបុត្រទាំង ២ ច្បាប់ជួបគ្នាក្នុងវវាងផ្លូវ ។ ជនទាំងនោះ កាលត្រូវអ្នករត់សំបុត្ររបស់នាងកុម្ភាសួរថា នេះសំបុត្ររបស់អ្នកណា ក៏ពោលថា បិប្ផលិមាណពផ្ញើឲ្យនាងកុម្ភា កាលអ្នករត់សំបុត្ររបស់បិប្ផលិមាណពសួរថា នេះជារបស់អ្នកណា ក៏ពោលថា នាងកុម្ភាផ្ញើឲ្យបិប្ផលិមាណព ទើបនាំគ្នាអានសំបុត្រទាំង ២ ច្បាប់ ហើយពោលថា អ្នកទាំងឡាយចូរមើលការធ្វើរបស់ក្មេងៗ ហើយហែកចោលទៅក្នុងព្រៃ សរសេរសំបុត្រដែលមានសេចក្តីស្មើគ្នា បញ្ជូនទៅទាំងសងខាងទាំងខាងនេះ និងខាងនោះ ។ ជនទាំង ២ នោះ មិនប្រាថ្នាសោះ ក៏បានមកនៅរួមគ្នា ។

ក្នុងថ្ងៃនោះឯង មាណពក៏យកកម្រងផ្កាមួយដាក់ត្រង់កណ្តាល សូម្បីនាងកុម្ភាកាបិលានី ក៏យកកម្រងផ្កាមួយដាក់ដែរ ។ ជនទាំង ២ បរិភោគអាហារល្ងាចហើយ ដាក់កម្រងផ្កានោះត្រង់កណ្តាលដំណេក មកព្រមគ្នាដោយបំណងថា នឹងឡើងដេក មាណពឡើងដំណេកខាងស្តាំ នាងកុម្ភាឡើងដំណេកខាងឆ្វេង ហើយពោលថា ផ្ការបស់អ្នកណាស្វិតស្រពោន ពួកយើងនឹងដឹងបានថា រាគៈចិត្តកើតឡើងដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបមិនប៉ះពាល់កម្រងផ្កានោះ ។ ជនទាំង ២ នោះ ដេកមិនលក់អស់រាត្រីទាំង ៣ យាមព្រោះខ្លាចប៉ះគ្នានិងគ្នា រហូតរាត្រីកន្លងទៅ ។ម្យ៉ាងទៀត ក្នុងពេលថ្ងៃក៏មិន

មានសូម្បីត្រឹមតែការញញឹមញញែម ជនទាំង ២ នោះ មិនជាប់ជំពាក់ដោយរឿងលោកាមិស មិនចាត់ចែងទ្រព្យសម្បត្តិ ដរាបណា មាតាបិតានៅមានជីវិត លុះមាតាបិតាធ្វើកាលកិរិយាទៅហើយ ទើបចាត់ចែង ។ បិប្ផលិមាណពមានសម្បត្តិ គិតជាប្រាក់ ៨៧ កោដិ គ្រាន់តែលម្អិតមាសដែលប្រើដុសសរីរៈ ហើយចោលទៅ មួយថ្ងៃៗ ប្រមាណ ១២ នាឡិ ដោយនាឡិមគធៈ មានស្រះទឹកប្រមាណ ៦០ កន្លែង បំពាក់គ្រឿងយន្ត មានការដ្ឋានប្រមាណ ១២ យោជន៍ មានស្រុកទាសៈ ១៤ ស្រុក ទំហំប៉ុនក្រុងអនុរាធបុរី មានហត្ថានិក គឺកងដំរី ១៤ កង មានអស្សានិក គឺក្រុមសេះ ១៤ ក្រុម មានរថានិក គឺកងរថ ១៤ កង ។

ថ្ងៃមួយ បិប្ផលិមាណពនោះ ជិះសេះដែលប្រដាប់តាក់តែងហើយ ហែហមដោយមហាជន ទៅកាន់ទីធ្វើការ ឈរនៅត្រង់ចុងស្រែ ឃើញពួកបក្សី មានក្អែកជាដើមចឹកសត្វ មានជន្លេនជាដើមអំពីគន្លងនង្គ័លមកស៊ី ទើបសួរថា នែបាទាំងឡាយ សត្វទាំងនេះស៊ីអ្វី មហាជនឆ្លើយថា សត្វទាំងនេះស៊ីជន្លេន ។ មាណពសួរថា បាបដែលសត្វទាំងនេះធ្វើ ជារបស់អ្នកណា ។ មហាជនឆ្លើយថា បាបជារបស់លោកម្ចាស់ មាណពគិតថា បើបាបដែលសត្វទាំងនេះធ្វើ ធ្លាក់ជារបស់អញសោត ទ្រព្យ ៨៧ កោដិ នឹងធ្វើអ្វីដល់អញបាន ការងារ ១២ យោជន៍ ស្រះទឹកបំពាក់គ្រឿងយន្ត ៦០ កន្លែង ស្រុកទាសៈ ១៤ នឹងធ្វើអ្វីដល់អញ អញនឹងប្រគល់ទ្រព្យសម្បត្តិទាំងអស់នេះ ដល់នាងភទ្ទាកាបិលានី ហើយចេញបួស ។ ខណៈនោះ នាងភទ្ទា-

កាបិលានីឲ្យព្រោះគ្រាប់ល្ង ៣ ក្អម ក្នុងចម្ការ ដោយមានពួកមេដោះអង្គុយចោមរោម ឃើញពួកក្អែកស៊ីសត្វក្នុងគ្រាប់ល្ង ទើបសួរថា នាងទាំងឡាយសត្វទាំងនេះស៊ីអ្វី ។ ពួកមេដោះឆ្លើយថា បពិត្រអ្នកនាង ពួកវាស៊ីសត្វ ។ កញ្ញាកាបិលានីសួរថា អកុសលនឹងជារបស់អ្នកណា ពួកមេដោះឆ្លើយថា ជារបស់អ្នកនាងនោះឯង ។ នាងគិតថា អញបានសំពត់ ៤ ហត្ថ និងបាយប្រមាណមួយនាឡិក៏គួរ បើអកុសលនេះដែលជនមានប្រមាណប៉ុណ្ណេះធ្វើ ជារបស់អញសោត អញមិនអាចងើបក្បាលឡើងអំពីវដ្តៈ រាប់ពាន់កព កាលណាអយ្យបុត្រមកដល់ អញនឹងប្រគល់ទ្រព្យសម្បត្តិទាំងអស់ ដល់អយ្យបុត្រនោះ ហើយចេញបួស ។

មាណពមកហើយ ងូតទឹក ឡើងប្រាសាទ អង្គុយលើទែនសយនាដែលមានតម្លៃច្រើន ។ គ្រានោះ ពួកអ្នកវិសេស ( ចុងភៅ ) ចាត់ចែងភោជនដែលសមគួរដល់ស្តេចចក្រពត្តិ ជនទាំង ២ បរិភោគហើយ កាលបរិវារជនចេញទៅហើយ ក៏ទៅក្នុងទីរហោដ្ឋាន អង្គុយក្នុងទីដែលមានផាសុក ។ គ្រានោះ មាណពពោលនឹងនាងកញ្ញាថា ហៃកញ្ញា កាលនាងមកផ្ទះនេះ នាងនាំយកទ្រព្យមកប៉ុន្មាន ។ នាងកញ្ញាពោលថា បពិត្រអយ្យបុត្រ នាំមក ៥ ម៉ឺន ៥ ពាន់រទេះ ។ មាណពពោលថា ទ្រព្យទាំងអស់នោះ និងទ្រព្យ ៨៧ កោដិក្នុងផ្ទះនេះ និងសម្បត្តិ មានស្រះ ៦០ ជាដើមដែលបំពាក់គ្រឿងយន្តទាំងអស់នេះ ខ្ញុំសូមប្រគល់ដល់នាងប៉ុណ្ណោះ ។ នាងកញ្ញាពោលថា អយ្យបុត្រ ចុះអ្នកនឹងទៅណា មាណពពោលថា ខ្ញុំនឹងបួស ។ នាងកញ្ញាពោលថា

ខ្ញុំក៏អង្គុយរង់ចាំការមករបស់អ្នក ខ្ញុំក៏នឹងបួស ។ ភពទាំង ៣ ប្រាកដដល់ជនទាំង ២ នោះ ដូចកុដិស្លឹកឈើដែលត្រូវភ្លើងឆេះ ដូច្នោះ ។ ជនទាំង ២ នោះឲ្យនាំកាសាវពស្ត្រ និងបាត្រដីមកអំពីផ្សារ កោរសក់ឲ្យគ្នានិងគ្នា ពោលថា ការបួសរបស់យើងទាំង ២ ឧទ្ទិសព្រះអរហន្តក្នុងលោក ហើយស៊កបាត្រចូលក្នុងស្លោក រួចស្ពាយត្រង់ស្មា ចុះអំពីប្រាសាទ បណ្តាទាសៈ ឬកម្មករទាំងឡាយក្នុងផ្ទះ បុគ្គលណាម្នាក់ក៏ចាំមិនបាន ។ គ្រានោះ ជនទាំង ២ នោះចេញអំពីស្រុកព្រាហ្មណ៍ កំពុងដើរទៅតាមទ្វារស្រុកទាសៈ ពួកអ្នកស្រុកទាសៈចាំបានដោយអាកប្បកិរិយា ជនទាំងនោះទ្រហោយំ ក្រាបចុះត្រង់ជើងពោលថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើឲ្យពួកខ្ញុំឥតទីពឹងឬ ។ ជនទាំង ២ ពោលថា នែអ្នកទាំងឡាយ ពួកខ្ញុំឃើញថា ភពទាំង ៣ ដូចបណ្ណសាលាដែលត្រូវភ្លើងឆេះ ទើបបានបួស បើខ្ញុំធ្វើបណ្តាពួកអ្នកទាំងឡាយម្នាក់ៗ ឲ្យជាអ្នកជា សូម្បី ១០០ ឆ្នាំ ក៏មិនគ្រប់គ្រាន់ ដូច្នេះ ពួកអ្នកចូរលាងក្បាលរបស់ពួកអ្នក ធ្វើជាអ្នកជាចិញ្ចឹមជីវិតចុះ កាលអ្នកស្រុកទាសៈទាំងនោះកំពុងកន្ទក់កន្ទេញនោះឯង ក៏ចៀសចេញទៅហើយ ។ ព្រះថេរៈដើរទៅខាងមុខ បែរមកសម្លឹងមើលបណ្តើរគិតថា ភទ្ទាកាបិលានីនេះ ជាស្រីមានតម្លៃស្មើនឹងជម្ពូទ្វីបទាំងមូល ដើរមកខាងក្រោយអញ មានឋានៈដែលបុគ្គលណាម្នាក់គប្បីគិតថា ជនទាំងនេះ បួសហើយ ក៏មិនអាចបែកពីគ្នា ធ្វើនូវការមិនសមគួរ ដូច្នេះ ក៏គិតថា បុគ្គលណាម្នាក់ ធ្វើចិត្តឲ្យប្រទូស្តក្នុងពួកយើង គប្បីពេញក្នុងអបាយ ដូច្នេះ គួរអញលះបង់នាង ហើយទៅ ។

ព្រះថេរៈដើរទៅខាងមុខ ឃើញផ្លូវបែកជា ២ បានឈប់នៅត្រង់ផ្លូវបំបែកនោះ ។ ឯនាងកន្ទាមកហើយ ថ្វាយបង្គំឈរនៅ ។ គ្រានោះ ព្រះថេរៈពោលនឹងនាងកន្ទាថា នែនាង មហាជនឃើញស្រ្តីដូចនាង ដើរមកខាងក្រោយ គិតថា ជនទាំងនេះ បួសហើយក៏មិនអាចបែកគ្នា ហើយមានចិត្តប្រទូស្តក្នុងពួកយើង គប្បីពេញក្នុងអបាយ ពួកយើងឈរហើយក្នុងផ្លូវ ២ នេះ ចូរនាងកាន់យកផ្លូវមួយ ខ្ញុំនឹងទៅផ្លូវមួយទៀត ។ នាងកន្ទាពោលថា ពិតហើយ អយ្យបុត្រ ធម្មតាមាតុគ្រាមជាមន្ទិលរបស់បព្វជិតទាំងឡាយ ជនទាំងឡាយ នឹងសម្តែងទោសរបស់ពួកយើងថា ជនទាំងនេះ សូម្បីបួសហើយ ក៏បែកគ្នាមិនបាន សូមលោកម្ចាស់កាន់យកផ្លូវមួយ ខ្ញុំកាន់យកផ្លូវមួយ ពួកយើងនឹងបែកគ្នា ដូច្នេះហើយ ធ្វើប្រទក្សិណ ៣ ជុំ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្នុងទីទាំង ៤ អន្លើ គឺស្តាំ ឆ្វេង មុខ ក្រោយ ផ្គងអញ្ជលីដែលលម្អដោយម្រាមដៃ ១០ ហើយពោលថា ការស្និទ្ធស្នាលក្នុងឋានៈជាមិត្រដែលបានធ្វើហើយ អស់កាលយូរប្រមាណមួយសែនកប្ប សូមអស់ថ្ងៃនេះ ហើយពោលថា លោកម្ចាស់មានជាតិខាងស្តាំ ផ្លូវខាងស្តាំសមគួរដល់លោកម្ចាស់ ខ្ញុំឈ្មោះថា ជាមាតុគ្រាម មានជាតិខាងឆ្វេង ផ្លូវខាងឆ្វេងសមគួរដល់ខ្ញុំ ដូច្នេះ ថ្វាយបង្គំហើយ ធ្វើដំណើរទៅ ។ ក្នុងវេលាដែលអ្នកទាំង ២ នោះបែកផ្លូវគ្នា មហាប្រឹថពីនេះ បានកក្រើកខ្ទរខ្ទារ ហាក់ដូចជានិយាយថា ខ្ញុំអាចទ្រទ្រង់ភ្នំកណ្តាប់ចក្រវាល និងភ្នំសិនេរុបាន តែមិនអាចទទួលគុណទាំងឡាយរបស់ពួកអ្នកបានទេ ។ ក្នុងអាកាសមានសំឡេងដូចផ្គរ

លាន់ ភ្នំកណ្ដាប់ចក្រវាលក៏ទោរទន់ចុះ ។

ព្រះសម្មាសម្ពុទ្ធ ប្រថាប់គង់ក្នុងព្រះគន្ធកុដិ នាវេឡុវនមហាវិហារ បានឮសំឡេងផែនដីកម្រើក ទើបទ្រង់ពិចារណាថា ផែនដីកម្រើកដើម្បីអ្នកណាហ្ន៎ ទ្រង់ជ្រាបថា បិប្ផលិមាណព និងនាងភទ្ទកាបិលានី លះសម្បត្តិដែលរាប់មិនបាន ហើយបួសឧទ្ទិសតថាគត ផែនដីកម្រើកនេះ កើតដោយកម្លាំងនៃគុណរបស់ជនទាំង ២ ក្នុងគ្រាដែលជនទាំង ២ នោះបែកផ្លូវគ្នា តថាគតគួរធ្វើការសង្គ្រោះជនទាំង ២ នោះ ទើបទ្រង់យាងចេញអំពីព្រះគន្ធកុដិមួយអង្គឯង ទ្រង់កាន់បាត្រ និងចីវរ មិនត្រាស់ហៅបុគ្គលណាមួយរូប ក្នុងបណ្ដាមហាសាវ័ក ៨០ អង្គ ទ្រង់យាងទៅទទួលអស់ចម្ងាយផ្លូវ ៣ គាវុត ប្រថាប់គង់ពត់ភ្នែន ត្រង់ដើមពហុបុត្តកនិគ្រោធ ចន្លោះក្រុងរាជគ្រឹះ និងក្រុងនាលន្ទា ។ កាលប្រថាប់គង់ មិនបានប្រថាប់គង់ដូចភិក្ខុដែលសមាទានបង្សុកូលជាវត្តមួយរូបឡើយ ទ្រង់កាន់យកភេទជាព្រះពុទ្ធ ប្រថាប់គង់បញ្ចេញព្រះរស្មីដែលមានប្រមាណ ៨០ ហត្ថ ដូច្នោះ ។ ក្នុងខណៈនោះ ព្រះពុទ្ធរស្មីមានប្រមាណប៉ុនឆត្រស្លឹកឈើ កង់រថ និងផ្ទះកំពូលជាដើម ឆ្វៀលឆ្វាត់ទៅជុំទិស ធ្វើឲ្យដូចកាលព្រះចន្ទ និងអាទិត្យរះរាប់ពាន់ដួង ធ្វើឲ្យដងព្រៃនោះមានពន្លឺតែមួយដូចគ្នា ។ ផ្ទៃមេឃហាក់បីដូចជេរជាសដោយហ្វូងផ្កាយ រុងរឿងដោយព្រះសិរីនៃមហាបុរិសលក្ខណៈ ៣២ ប្រការ ដងព្រៃរុងរឿងដូចទឹកដែលមានផ្កាឈូករីកស្គុសស្គាយ ។ ធម្មតាដើមនិគ្រោធមានដើមស មានស្លឹកខៀវ ផ្លែក្រហម ។ តែថ្ងៃនោះ ដើមនិគ្រោធមានមែកពណ៌ស បែរជា

មានពណ៌ដូចមាស ។

ព្រះមហាកស្សបត្ថេរគិតថា បុគ្គលនេះ ជាព្រះសាស្តារបស់អាញ អាញបួសឧទ្ទិសព្រះសាស្តាអង្គនេះ ដូច្នេះ ចាប់អំពីទីដែលមើលឃើញ បានបង្អោនកាយដើរទៅ ថ្វាយបង្គំក្នុងទី ៣ កន្លែង ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវ័ក ។ លំដាប់នោះ ព្រះមានព្រះភាគ បានត្រាស់នឹងមហាកស្សបត្ថេរថា ម្នាលកស្សបៈ បើអ្នកគប្បីធ្វើការឱនលំទោននេះ ក្នុងមហាប្រឹថពីសោតមហាប្រឹថពីនោះ មិនអាចទ្រទ្រង់បានឡើយ នមស្ការដែលអ្នកធ្វើ មិនអាចធ្វើរោមរបស់តថាគតឲ្យកម្រើក ព្រោះតថាគតមានគុណធំយ៉ាងនេះ ។ អង្គុយចុះកស្សបៈ តថាគតនឹងឲ្យទ្រព្យដែលជាមត៌កដល់អ្នក ។ លំដាប់នោះ ព្រះមានព្រះភាគបានប្រទានឧបសម្បទាដល់ព្រះមហាកស្សបត្ថេរ ដោយឱវាទ ៣ ប្រការ កាលប្រទានហើយ ស្តេចចេញអំពីដើមពហុបុត្តកនិគ្រោធ ទ្រង់ពុទ្ធដំណើរ មានព្រះថេរៈជាបច្ឆាសមណៈ ។ ព្រះសរីរៈរបស់ព្រះសាស្តាល្អត្រកាល ដោយមហាបុរិសលក្ខណៈ ៣២ ប្រការ សរីរៈរបស់ព្រះមហាកស្សបៈប្រដាប់ដោយមហាបុរិសលក្ខណៈ ៧ ប្រការ ។ ព្រះមហាកស្សបៈនោះ ធ្វើដំណើរតាមព្រះសាស្តា ដូចទូកតូច អណ្តែតតាមទូកធំពណ៌មាស ដូច្នោះព្រះសាស្តាទ្រង់យាងទៅបានបន្តិចហើយ ចៀសចេញទៅក្នុងទីក្បែរផ្លូវ សម្តែងអាការប្រថាប់គង់ត្រង់គល់ឈើមួយកន្លែង ព្រះថេរៈដឹងថា ព្រះសាស្តាមាន

បំណាងប្រថាប់គង់ ទើបធ្វើសង្ឃាដីដែលជាសំពត់ចាស់ ដែលខ្លួនដណ្តប់ឲ្យជា ៤ ជាន់ក្រាលថ្វាយ ។

ព្រះសាស្តាប្រថាប់គង់លើសំពត់សង្ឃាដីនោះហើយ យកព្រះហស្ត ស្ទាបសាច់សំពត់ត្រាស់ថា ម្នាលកស្សបៈ សង្ឃាដីដែលធ្វើដោយសំពត់ចាស់មួយផ្ទាំងនេះរបស់អ្នកទន់ល្អ ។ ព្រះថេរៈដឹងថា ព្រះសាស្តាត្រាស់ដល់សង្ឃាដីរបស់ខ្លួនថាទន់ ប្រាកដជាទ្រង់បំណងនឹងដណ្តប់ ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះមានព្រះភាគ ទ្រង់ដណ្តប់សង្ឃាដីចុះ ។ ព្រះសាស្តាត្រាស់ថា កស្សបៈ អ្នកដណ្តប់អ្វី ព្រះថេរៈក្រាបទូលថា បពិត្រព្រះអង្គ ខ្ញុំព្រះអង្គបានអន្តរវាសិករបស់ទ្រង់នឹងដណ្តប់ ។ ព្រះសាស្តាត្រាស់ថា កស្សបៈ អ្នកអាចទ្រទ្រង់សំពត់បង្សុកូលមួយផ្ទាំងនេះ ប្រើរហូតដល់ចាស់យ៉ាងនេះបានឬ ព្រោះថា មហាប្រឹថពីកម្រើកដល់ទឹកទ្រផែនដី ក្នុងថ្ងៃដែលតថាគតបោកសំពត់បង្សុកូលមួយផ្ទាំងនេះ ធម្មតាចីវរដែលចាស់ ព្រោះការប្រើរបស់ព្រះសម្ពុទ្ធទាំងឡាយនេះ រហូតដល់ចាស់ហើយ បុគ្គលមានគុណតិចតួច មិនអាចគ្រងបានឡើយ ។ ចីវរចាស់ដូចពោលហើយនេះ ដែលបុគ្គលអាចក្នុងការបំពេញបដិបទា ដែលកាន់យកសំពត់បង្សុកូលមកអំពីខាងដើម ទើបគួរទទួលយក ហើយទ្រង់ប្តូរចីវរជាមួយព្រះថេរៈ ។

ព្រះមានព្រះភាគ ទ្រង់ប្តូរចីវរយ៉ាងនេះហើយ ទ្រង់ដណ្តប់ចីវរដែលព្រះថេរៈដណ្តប់ហើយ ព្រះថេរៈក៏ដណ្តប់ចីវររបស់ព្រះសាស្តា ។ ក្នុងសម័យនោះ មហាប្រឹថពីនេះ សូម្បីមិនមានចិត្ត ក៏កម្រើកញាប់ញ័រ រហូត

ដល់ទឹកទៅផែនដី ហាក់ដូចជាពោលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះអង្គធ្វើវត្ថុដែលធ្វើបានលំបាក ចីវរដែលព្រះអង្គដណ្តប់ហើយ ឈ្មោះថា ធ្លាប់ប្រទានដល់សាវកដទៃមិនមាន ខ្ញុំព្រះអង្គមិនអាចទ្រទ្រង់នូវគុណ របស់ព្រះអង្គបានទេ ។ ព្រះថេរៈក៏មិនបានលើកតម្កើងខ្លួនថា ឥឡូវនេះ អញបានចីវរសម្រាប់ប្រើប្រាស់របស់ព្រះពុទ្ធទាំងឡាយ វត្ថុដែលអញគប្បីធ្វើឲ្យក្រៃលែងឡើងជាងនេះ ក្នុងឥឡូវនេះ មានឬ ទើបបានសមាទានធុតង្គ ១៣ ក្នុងសម្នាក់របស់ព្រះពុទ្ធនោះឯង ។ នៅជាបុថុជ្ជនត្រឹមតែ ៧ ថ្ងៃ ក្នុងថ្ងៃទី ៨ បានសម្រេចអរហត្ត ដំណាលគ្នានឹងសូត្រទាំងឡាយជាដើមយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ មានឧបមាដូចជាព្រះចន្ទ្រ ចូរដកកាយ ដកចិត្តចេញ ធ្វើដូចជាអាគន្តុកភិក្ខុ មិនឃ្នើសឃ្នងក្នុងត្រកូលទាំងឡាយ ហើយចូលទៅកាន់ត្រកូលចុះ ។ ក្នុងកាលជាខាងក្រោយ ទ្រង់ធ្វើកស្សបសំយុត្តនោះឯងឲ្យជាអត្ថុប្បត្តិហេតុកើតឡើង ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈដោយព្រះតម្រាស់ថា មហាកស្សបៈ ជាកំពូលនៃភិក្ខុទាំងឡាយ ដែលជាអ្នកសមាទានធុតង្គ និងប្រៀនប្រដៅធុតង្គ ក្នុងសាសនារបស់តថាគតដូច្នេះឯង ៕ល៚

## អដ្ឋកថា សូត្រទី ៤ ចប់

# អដ្ឋកថា សូត្រទី ៥

# ប្រវត្តិព្រះអនុរុទ្ធត្ថេរ

ក្នុងសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ទិព្វចក្ខុកានំ យទិទំ អនុរុទ្ធោ** សេចក្តីថា ព្រះអនុរុទ្ធត្ថេរជាកំពូលនៃភិក្ខុទាំងឡាយ ដែលមានទិព្វចក្ខុ គប្បីជ្រាបថា ព្រះអនុរុទ្ធត្ថេរជាឯតទគ្គៈ ព្រោះជាអ្នកមានវសីសន្សំទុកល្អហើយ ។ បានឮថា ព្រះថេរៈ វៀរតែខណៈឆាន់ប៉ុណ្ណោះ គ្រប់កាលដ៏សេស ចម្រើនអាលោកកសិណ មើលពួកសត្វដោយទិព្វចក្ខុតែម្យ៉ាង ដូច្នោះ ទើបថេរៈនេះជាកំពូលនៃភិក្ខុទាំងឡាយ ដែលមានទិព្វចក្ខុ ព្រោះជាអ្នកមានវសីសន្សំអស់ថ្ងៃ និងយប់ ។ ម្យ៉ាងទៀត ជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុដ៏សេស ព្រោះប្រាថ្នាមកអស់សែនកប្ប ។ ក្នុងរឿងបុព្វកម្មរបស់លោក មានរឿងដែលពោលជាអនុសន្ធិដូចតទៅនេះថា

សេចក្តីពិស្តារថា កាលព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ កុលបុត្រនេះបានទៅជាមួយមហាជន ទៅកាន់វិហារដើម្បីស្តាប់ធម៌ ខាងក្រោយភត្តាហារ ។ គ្រានោះ កុលបុត្រនេះបានជាកុដុម្ពិកៈធំ មិនប្រាកដឈ្មោះម្នាក់ ។ ថ្វាយបង្គំព្រះទសពលហើយ ឈរខាងចុងបរិស័ទស្តាប់ធម្មកថា ។ ព្រះសាស្តាទ្រង់បន្តព្រះធម្មទេសនាតាមអនុសន្ធិ ហើយទ្រង់ស្ថាបនាភិក្ខុដែលមានទិព្វចក្ខុមួយរូបក្នុងតំណែងឯតទគ្គៈ ។ លំដាប់នោះ កុដុម្ពិកៈត្រិះរិះថា ភិក្ខុនេះធំហ្ន៎ ព្រះសាស្តាទ្រង់តាំងទុកក្នុងភាពជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុ ដោយប្រការយ៉ាងនេះ ឱហ្ន៎ ! សូម្បីអញ ក៏គប្បីជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុ ក្នុងសាសនារបស់ព្រះពុទ្ធ ដែលកើតឡើងក្នុងអនាគត ដូច្នេះហើយ មានគំនិត

នេះឡើង ដើរចូលទៅត្រង់ចន្លោះបរិស័ទ ទូលនិមន្តព្រះមានព្រះភាគ និងភិក្ខុមួយសែន ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ លុះស្អែកឡើង ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន គិតថា អាត្មាអញប្រាថ្នាតំណែងធំ ទើបទូលនិមន្តក្នុងថ្ងៃនេះ ដើម្បីសោយក្នុងថ្ងៃស្អែក ហើយធ្វើមហាទានឲ្យប្រព្រឹត្តទៅអស់ ៧ ថ្ងៃ ដោយទំនងនោះឯង ថ្វាយសំពត់យ៉ាងល្អដល់ព្រះមានព្រះភាគ ព្រមទាំងភិក្ខុបរិស័ទ ហើយធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គធ្វើសក្ការៈនេះ ដើម្បីប្រយោជន៍ដល់ទិព្វសម្បត្តិ ឬមនុស្សសម្បត្តិក៏មិនមែន ទ្រង់តាំងភិក្ខុណា ក្នុងតំណែងជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុ ក្នុង ៧ ថ្ងៃកន្លងមុនអំពីថ្ងៃនេះ ខ្ញុំព្រះអង្គគប្បីប្រាថ្នាជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុ ដូចភិក្ខុអង្គនោះ ក្នុងសាសនាព្រះពុទ្ធអង្គណាទីមួយ ក្នុងអនាគតកាល ដូច្នេះហើយ ក្រាបចុះទៀបព្រះបាទរបស់ព្រះសាស្តា ។ ព្រះសាស្តាទ្រង់ប្រមើលមើលក្នុងអនាគត ទ្រង់ជ្រាបថា ការប្រាថ្នារបស់កុលបុត្រនេះនឹងសម្រេច ទើបត្រាស់យ៉ាងថា ម្នាលបុរសដ៏ចម្រើន ក្នុងទីបំផុតមួយសែនកប្ប ក្នុងអនាគត ព្រះពុទ្ធព្រះនាមគោតមកើតឡើង អ្នកនឹងមានឈ្មោះថាអនុរុទ្ធ ជាកំពូលនៃភិក្ខុដែលមានទិព្វចក្ខុ ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធនោះ ។ កាលត្រាស់យ៉ាងនេះហើយ ទ្រង់ធ្វើភត្តានុមោទនាត្រឡប់ទៅព្រះវិហារ ។ ឯកុដុម្ពិកៈធ្វើសុចរិតកម្មមិនដាច់ឡើយ ដរាបដែលព្រះពុទ្ធគង់ព្រះជន្មនៅ កាលព្រះសាស្តាបរិនិព្វានហើយ វេលាសាងព្រះចេតិយមាសប្រមាណ ៧ យោជន៍សម្រេចហើយ ទើបចូលទៅរកភិក្ខុសង្ឃ

សួរថា អ្វីជាបរិកម្មនៃទិព្វចក្ខុ លោកម្ចាស់ ។ ភិក្ខុសង្ឃប្រាប់ថា គួរឲ្យប្រទីបឧបាសក ។ ឧបាសក ពោលថា សាធុ ខ្ញុំនឹងធ្វើ ជាបឋមឲ្យសាងប្រទីប ១០០០ បន្ទាប់អំពីនោះ ធ្វើឲ្យតិចជាងនោះ បន្ទាប់អំពីនោះ ធ្វើឲ្យតិចជាងនោះ សរុបសេចក្តី បានសាងប្រទីបច្រើនពាន់ដើម ។ ឯប្រទីបដ៏សេសប្រមាណមិនបាន ។ កុដុម្ពិកៈធ្វើកល្យាណកម្មយ៉ាងនេះរហូតដល់អស់ជីវិតអន្ទោលទៅក្នុងទេវតា និងមនុស្សទាំងឡាយ កន្លងទៅមួយសែនកប្ប ក្នុងកាលនៃព្រះកស្សបសម្មាសម្ពុទ្ធ កើតឡើងក្នុងផ្ទះកុដុម្ពិកៈ ជិតក្រុងពារាណសី ។ កាលព្រះសាស្តាបរិនិព្វាន គេនាំគ្នាសាងចេតិយប្រមាណមួយយោជន៍សម្រេចហើយ ឲ្យសាងភាជនៈសំរឹទ្ធជាច្រើន ដាក់សប្បិរហូតពេញ ឲ្យធ្វើប្រឆេះចង្កៀងចន្លោះមួយអង្គុលីៗ ត្រង់កណ្តាល ដុតភ្លើងឡើងជុំវិញព្រះចេតិយ ឲ្យកណ្តាប់មាត់ទល់គ្នានឹងកណ្តាប់មាត់ ឲ្យសាងភាជនៈសំរឹទ្ធធំជាងសម្រាប់ខ្លួនដាក់សប្បិពេញ ធ្វើប្រឆេះចង្កៀង ១០០០ ជុំវិញកណ្តាប់មាត់ភាជនៈសំរឹទ្ធនោះ យកសំពត់ចាស់ហ៊ុមត្រង់កណ្តាល ទូលភាជនៈសំរឹទ្ធ ដើរប្រទក្សិណចេតិយប្រមាណមួយយោជន៍ រហូតទល់ភ្លឺ ។ កុលបុត្រនោះ ធ្វើកល្យាណកម្មរហូតអស់ជីវិត ដោយអត្តភាពនោះ ដោយអាការយ៉ាងនេះ ហើយកើតក្នុងទេវលោក ។ កាលព្រះពុទ្ធមិនទាន់កើតឡើង បដិសន្ធិនៅក្នុងផ្ទះរបស់ត្រកូលក្រីក្រមួយ ក្នុងនគរនោះឯងទៀត ជាអ្នករែកស្មៅ អាស្រ័យសុមនសេដ្ឋីចិញ្ចឹមជីវិត បុរសនោះ មានឈ្មោះថា អន្នភារៈ ។ ឯសុមនសេដ្ឋីនោះ ឲ្យមហាទានត្រង់ទ្វារ ដល់មនុស្សកំព្រា អ្នកធ្វើដំណើរ វណិពកៈ

និងយាចករាល់ៗ ថ្ងៃ ។

ថ្ងៃមួយ ព្រះបច្ចេកពុទ្ធឈ្មោះថាឧបរិដ្ឋៈ ចូលនិរោធសមាបត្តិត្រង់ភ្នំគន្ធមាទន៍ ចេញអំពីសមាបត្តិនោះហើយ ពិចារណាថា ថ្ងៃនេះ គួរធ្វើការអនុគ្រោះដល់អ្នកណា ។ ធម្មតាព្រះបច្ចេកពុទ្ធទាំងឡាយ រមែងអនុគ្រោះជនក្រីក្រ ដោយគិតថា ថ្ងៃនេះ អាត្មាអញគួរធ្វើអនុគ្រោះអន្នភារបុរស បានឮថា នាយអន្នភារៈនឹងចេញអំពីព្រៃមកកាន់ផ្ទះរបស់ខ្លួន ទើបកាន់បាត្រ និងចីវរអំពីភ្នំគន្ធមាទន៍ ហោះឡើងកាន់វេហាស៍ មកប្រាកដចំពោះមុខនាយអន្នភារៈត្រង់ទ្វារផ្ទះនោះឯង ។ នាយអន្នភារៈឃើញព្រះបច្ចេកពុទ្ធកាន់បាត្រទទេ ទើបធ្វើអភិវាទព្រះបច្ចេកពុទ្ធ ហើយសួរថា លោកម្ចាស់បានភិក្ខាខ្លះដែរឬទេ ។ ព្រះបច្ចេកពុទ្ធពោលថា នឹងបាន អ្នកមានបុណ្យច្រើន ។ បុរសនោះពោលថា សូមលោកម្ចាស់ បង្អង់ចាំទីនេះសិន ហើយរូតរះទៅសួរមេផ្ទះក្នុងផ្ទះរបស់ខ្លួនថា នាងដ៏ចម្រើន ភត្តដែលជាចំណែកទុកដើម្បីខ្ញុំ មានឬមិនមាន ។ នាងឆ្លើយថា មាន ។ បុរសនោះចូលទៅទីនោះ ទទួលបាត្រអំពីដៃព្រះបច្ចេកពុទ្ធ ហើយពោលថា នាងដ៏ចម្រើន ព្រោះយើងមិនបានធ្វើកល្យាណកម្មទុកក្នុងជាតិមុន ទើបយើងទាំង ២ សង្ឃឹមលើតែការស៊ីឈ្នួល កាលសេចក្តីប្រាថ្នាដើម្បីឲ្យរបស់ពួកយើងមាន បែរជាទេយ្យធម៌មិនមាន កាលទេយ្យធម៌មានក៏មិនមានបដិគ្គាហកៈ ថ្ងៃនេះ ខ្ញុំជួបព្រះឧបរិដ្ឋបច្ចេកពុទ្ធ ហើយភត្តដែលចែករំលែកក៏មាន ចូរនាងដាក់ភត្តដែលជាចំណែករបស់ខ្ញុំក្នុងបាត្រនេះ ។ ស្រីអ្នកឈ្លាសគិតថា កាលណាប្តីរបស់អញឲ្យភត្តដែលជាចំណែកខ្លួន កាលនោះ

អញក៏គប្បីមានចំណែកក្នុងទាននេះ ទើបដាក់ភត្តរបស់ខ្លួនចូលក្នុងបាត្រប្រគេនដល់ព្រះឧបរិដ្ឋបច្ចេកពុទ្ធ ។ អន្នភារៈនាំបាត្រដែលដាក់ភត្តមកដាក់ក្នុងដៃរបស់ព្រះបច្ចេកពុទ្ធ ហើយពោលថា សូមពួកខ្ញុំព្រះអង្គរួចផុតអំពីភាពទុគ៌តនេះចុះ ព្រះបច្ចេកពុទ្ធអនុមោទនាថា ចូរសម្រេចយ៉ាងនោះចុះ អ្នកមានបុណ្យច្រើន ។ គេលាតសំពត់ដណ្តប់របស់ខ្លួនចុះក្នុងចំណែកម្ខាង ហើយពោលថា សូមលោកម្ចាស់ឆាន់ទីនេះចុះ ព្រះបច្ចេកពុទ្ធគង់ក្នុងអាសនៈនោះហើយ ពិចារណាភាពជារបស់បដិកូល ៩ យ៉ាង ហើយទើបឆាន់ លុះឆាន់ស្រេចហើយ ទើបនាយអន្នភារៈប្រគេនទឹកសម្រាប់លាងបាត្រ ព្រះបច្ចេកពុទ្ធសម្រេចភត្តកិច្ចហើយ ធ្វើអនុមោទនាថា

វត្ថុដែលអ្នកត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេចដោយរួសរាន់ តម្រិះត្រូវទាំងឡាយ ចូរពេញដូចព្រះចន្ទ ១៥ កើត ដូច្នោះ វត្ថុដែលអ្នកត្រូវការហើយ ប្រាថ្នាហើយ ចូរសម្រេចដោយរួសរាន់ទាន់ចិត្ត តម្រិះត្រូវចូរពេញដូចកែវមណីមានរស្មីដ៏រុងរឿង ដូច្នោះ ។

ហើយក៏និមន្តទៅ ។ ទេវតាដែលអាស្រ័យត្រង់ឆត្ររបស់សុមនសេដ្ឋីពោលថា គួរអស្ចារ្យហ្ន៎ ទានដែលតម្កល់ល្អហើយ ក្នុងព្រះបច្ចេកពុទ្ធ ឈ្មោះថា ឧបរិដ្ឋៈ ជាទានដ៏ក្រៃលែង ហើយបានឲ្យសាធុការអស់វារៈ ៣ ដង ។ សុមនសេដ្ឋីពោលថា អ្នកមិនឃើញខ្ញុំដែលឲ្យទានអស់កាលមានប្រមាណប៉ុណ្ណោះទេឬ ទេវតាពោលថា ខ្ញុំមិនឲ្យសាធុការក្នុងទានរបស់លោកទេ ខ្ញុំជ្រះថ្លាក្នុងបិណ្ឌបាតដែលនាយអន្នភារៈ ប្រគេនដល់ព្រះបច្ចេកពុទ្ធ ឈ្មោះថា

ឧបរិដ្ឋៈ ទើបឲ្យសាធុការ សុមនសេដ្ឋីគិតថា រឿងនេះគួរអស្ចារ្យហ្ន៎ អញឲ្យទាន អស់កាលមានប្រមាណប៉ុណ្ណេះ ក៏មិនអាចធ្វើឲ្យទេវតាឲ្យសាធុការបាន អន្នភារៈនេះអាស្រ័យអញរស់នៅ ឲ្យបិណ្ឌបាតម្តងប៉ុណ្ណោះ ធ្វើទេវតាឲ្យសាធុការបាន ព្រោះបានបុគ្គលជាបដិគ្គាហកៈដែលសមគួរ អញនឹងឲ្យទ្រព្យដ៏សមគួរដល់នាយអន្នភារៈ ហើយធ្វើបិណ្ឌបាតនោះឲ្យជារបស់អញ ទើបគួរ ដូច្នេះហើយ ហៅនាយអន្នភារៈមកហើយ សួរថា ថ្ងៃនេះ ឯងឲ្យទានដល់បុគ្គលណាម្នាក់ឬ ។ អន្នភារៈឆ្លើយថា បាទ លោកម្ចាស់ ខ្ញុំបានប្រគេនភត្តដែលជាចំណែករបស់ខ្ញុំដល់ព្រះបច្ចេកពុទ្ធឈ្មោះថា ឧបរិដ្ឋៈ ។ សេដ្ឋីពោលថា ណ្ហើយចុះ សូមអ្នកទទួលកហាបណៈនេះ ហើយឲ្យបិណ្ឌបាតនោះដល់ខ្ញុំចុះ ។ អន្នភារៈពោលថា ខ្ញុំឲ្យមិនបានទេ ។ សេដ្ឋីបន្ថែមទ្រព្យឡើងរហូតដល់ ១០០០ កហាបណៈ នាយអន្នភារៈក៏នៅតែពោលថា សូម្បី ១០០០ កហាបណៈក៏នៅតែឲ្យមិនបាន សេដ្ឋីពោលថា ណ្ហើយចុះ បើអ្នកមិនឲ្យបិណ្ឌបាត ក៏ចូរទទួលទ្រព្យ ១០០០ កហាបណៈទៅ ហើយឲ្យចំណែកបុណ្យដល់ខ្ញុំចុះ ។ នាយអន្នភារៈពោលថា ខ្ញុំមិនដឹងថា ចំណែកបុណ្យនោះគួរឲ្យ ឬមិនគួរឲ្យ តែខ្ញុំនឹងសួរព្រះបច្ចេកពុទ្ធព្រះនាមថាឧបរិដ្ឋៈមើលសិន បើគួរក៏នឹងឲ្យ បើមិនគួរ ក៏នឹងមិនឲ្យ ។ នាយអន្នភារៈរត់ទៅទាន់ព្រះបច្ចេកពុទ្ធ សួរថា បពិត្រលោកម្ចាស់ សុមនសេដ្ឋីឲ្យទ្រព្យដល់ខ្ញុំ ១០០០ សូមចំណែកបុណ្យក្នុងបិណ្ឌបាត ដែលប្រគេនដល់លោកម្ចាស់ ខ្ញុំគួរឲ្យ ឬមិនឲ្យ ។ ព្រះបច្ចេកពុទ្ធពោលថា នែបណ្ឌិត អាត្មានឹងធ្វើឧបមាដល់អ្នក

ឧបមាថា ក្នុងស្រុកនេះ មាន ១០០ ត្រកូល អាត្មាអុជប្រទីបទុកក្នុងផ្ទះមួយប៉ុណ្ណោះ ត្រកូលពួកនេះ យកប្រេងចាក់ឲ្យពេញចង្កៀង ហើយមកបន្តភ្លើងយកទៅ ពន្លឺរបស់ប្រទីបដើមនៅមាន ឬក៏បាត់ទៅ នាយអន្នភារៈពោលថា បពិត្រលោកម្ចាស់ ពន្លឺប្រទីបក៏រឹងរឹតតែភ្លឺឡើងទៀត សេចក្តីនេះឧបមាយ៉ាងណា នែបណ្ឌិត បបរមួយត្រឡោក បាយមួយវែក ចូរលើកទុកសិនចុះ កាលអ្នកឲ្យចំណែកបុណ្យដល់ជនដទៃក្នុងបិណ្ឌបាតរបស់ខ្លួន ១ ពាន់ ឬ ១ សែននាក់ក៏ដោយ ឲ្យដល់បុគ្គលប៉ុនណា បុណ្យក៏ចម្រើនឡើងដល់ខ្លួន មានប្រមាណប៉ុណ្ណោះ កាលអ្នកឲ្យក៏ឲ្យបិណ្ឌបាតតែមួយនោះឯង លុះអ្នកឲ្យចំណែកបុណ្យដល់សុមនសេដ្ឋីទៀត បិណ្ឌបាតក៏រីកចម្រើនទៅទ្វេដង គឺរបស់អ្នកមួយចំណែក របស់សេដ្ឋីមួយចំណែក ដូច្នេះ នាយអន្នភារៈថ្វាយបង្គំព្រះបច្ចេកពុទ្ធហើយ ត្រឡប់ទៅកាន់សម្នាក់សុមនសេដ្ឋីពោលថា សូមលោកសេដ្ឋីទទួលចំណែកបុណ្យក្នុងបិណ្ឌបាតទានចុះ ។ សេដ្ឋីពោលថា ចូរអ្នកទទួលទ្រព្យ ១០០០ កហាបណៈ ។ នាយអន្នភារៈពោលថា ខ្ញុំមិនបានលក់បិណ្ឌបាតទាន តែខ្ញុំឲ្យចំណែកបុណ្យដល់លោកសេដ្ឋីដោយសទ្ធា សេដ្ឋីពោលថា នែបាអន្នភារៈ បាឲ្យចំណែកបុណ្យដល់ខ្ញុំដោយសទ្ធា តែខ្ញុំបូជាគុណរបស់បា ខ្ញុំឲ្យ ១០០០ កហាបណៈនេះ ចូរបាអន្នភារៈទទួលយកចុះ ។ នាយអន្នភារៈពោលថា យ៉ាងនោះក៏យ៉ាងនោះចុះ ទើបកាន់យកទ្រព្យ ១០០០ កហាបណៈទៅ សេដ្ឋីពោលថា នែបាអន្នភារៈ តាំងអំពីបាបានទ្រព្យ ១០០០ កហាបណៈហើយ បានមិនចាំបាច់ធ្វើកិច្ចទាក់ទងដល់កម្មករ ដោយដៃរបស់ខ្លួន

ចូរសង់ផ្ទះនៅក្បែរផ្លូវចុះ បើបាត្រូវការវត្ថុណា ខ្ញុំនឹងប្រគល់វត្ថុនោះឲ្យ បា ចូរនាំយកទៅចុះ ។

ធម្មតាបិណ្ឌបាតដែលបុគ្គលប្រគេនដល់ព្រះបច្ចេកពុទ្ធ ដែលចេញអំពីនិរោធសមាបត្តិ រមែងឲ្យផលក្នុងថ្ងៃនោះឯង ព្រោះដូច្នោះ សុមនសេដ្ឋី ក្នុងថ្ងៃដទៃ ទៅកាន់រាជត្រកូល មិនធ្លាប់បបួលអន្នភារៈទៅជាមួយឡើយ តែក្នុងថ្ងៃនោះ បានបបួលទៅដែរ ព្រោះអាស្រ័យបុណ្យរបស់នាយអន្នភារៈ ព្រះរាជាមិនសម្លឹងមើលសេដ្ឋីឡើយ ទ្រង់សម្លឹងមើលតែនាយអន្នភារៈប៉ុណ្ណោះ ទើបសេដ្ឋីទូលសួរថា បពិត្រសម្មតិទេព ហេតុអ្វី ទើបព្រះអង្គទ្រង់សម្លឹងមើលតែបុរសនេះ ។ ព្រះរាជាត្រាស់ថា ខ្ញុំសម្លឹងមើល ព្រោះមិនធ្លាប់ឃើញគាត់ក្នុងថ្ងៃដទៃៗ ។ សេដ្ឋីទូលថា បពិត្រសម្មតិទេព បុរសនេះសមគួរសម្លឹងមើលដូចម្តេច គុណដែលគួរសម្លឹងមើលរបស់គេ គឺអ្វី ព្រោះថ្ងៃនេះ គេមិនបរិភោគភត្តដែលជាចំណែករបស់ខ្លួនដោយខ្លួនឯង តែប្រគេនដល់ព្រះបច្ចេកពុទ្ធព្រះនាមថា ឧបរិដ្ឋៈ គេបានទ្រព្យ ១០០០ កហាបណៈអំពីដៃទូលបង្គំ ។ ព្រះរាជាត្រាស់សួរថា បុរសនេះឈ្មោះអ្វី ។ លោកសេដ្ឋីពោលថា ឈ្មោះអន្នភារៈ ក្រាបទូល ។ ព្រះរាជាត្រាស់ថា បុរសនេះបានទ្រព្យអំពីដៃរបស់អ្នក ក៏គួរបានអំពីដៃរបស់ខ្ញុំដែរ ខ្ញុំនឹងធ្វើសក្ការបូជាបុរសនេះ ទើបព្រះរាជទានទ្រព្យ ១ ពាន់កហាបណៈ ហើយត្រាស់ថា នែរាជបុរស អ្នកចូរពិនិត្យមើលដីធ្វើផ្ទះ ដែលបុគ្គលនេះអាចនៅបាន ។ រាជបុរសទូលថា ករុណាថ្ងៃវិសេសព្រះអង្គ ។ រាជបុរសទាំងឡាយ រៀបចំក្តារទីកន្លែងសម្រាប់សង់ផ្ទះនោះ បាន

ជួបកំណប់ទ្រព្យឈ្មោះបិន្តុលៈ ក្នុងទីដែលចបប៉ះហើយ តម្រៀបគ្នា ទើបមកក្រាបទូលព្រះរាជាឲ្យទ្រង់ជ្រាប ។ ព្រះរាជាត្រាស់ថា បើដូច្នោះ ចូរទៅជីកយកមក កាលរាជបុរសទាំងនោះកំពុងជីក កំណប់ទ្រព្យក៏លិចចុះទៅ រាជបុរសនោះទៅក្រាបទូលដល់ព្រះរាជាទៀត ។ ព្រះរាជាត្រាស់ថា ចូរទៅជីកតាមពាក្យរបស់នាយអន្នភារៈ ។ រាជបុរសក៏ទៅជីកតាមពាក្យប្រើ កំណប់ទ្រព្យដូចផ្សិតក្រពុំ ផុសឡើងក្នុងទីដែលចបប៉ះហើយ រាជបុរសទាំងនោះជញ្ជូនទ្រព្យមកគរក្នុងព្រះសម្នាក់ ព្រះរាជាទ្រង់ប្រជុំអមាត្យទាំងឡាយ ហើយត្រាស់សួរថា ក្នុងក្រុងនេះ អ្នកណាមានទ្រព្យប្រមាណប៉ុណ្ណេះដែរឬទេ អមាត្យក្រាបទូលថា មិនមានទេ ព្រះអង្គ ។ ព្រះរាជាត្រាស់ថា បើដូច្នោះ នាយអន្នភារៈ ចូរបានឈ្មោះថា ធនសេដ្ឋីក្នុងព្រះនគរនេះ គាត់បានឆត្រប្រចាំតំណែងសេដ្ឋីក្នុងថ្ងៃនោះឯង ។

តាំងអំពីថ្ងៃនោះ លោកសេដ្ឋីធ្វើតែសុចរិតកម្ម រហូតដល់អស់ជីវិត ចុតិអំពីភពនោះ ទៅកើតក្នុងទេវលោក វិលវល់នៅក្នុងទេវតា និងមនុស្សអស់កាលដ៏យូរ ។ កាលដែលព្រះសាស្ដានៃយើងកើតឡើង ក៏មកបដិសន្ធិក្នុងនិវេសន៍របស់សក្យរាជ ព្រះនាមថា អមិតោទនៈ ក្នុងក្រុងកបិលពស្តុ ក្នុងថ្ងៃដាក់ឈ្មោះ ញាតិទាំងឡាយឲ្យឈ្មោះថា អនុរុទ្ធ ជាកនិដ្ឋភាតា គឺប្អូនរបស់សក្យរាជមហានាម ជាឱរសរបស់ព្រះបិតុលានៃព្រះសាស្ដា ជាស្ដេចសុខុមាលជាតិដ៏ក្រៃលែង ជាអ្នកមានបុណ្យច្រើន កត្តកើតឡើងក្នុងជាសរបស់ទ្រង់នោះឯង ។ ក្រោយមក ព្រះមាតារបស់លោកគិតថា នឹងឲ្យកូន

របស់ខ្លួនស្គាល់ពាក្យថា មិនមាន យកជាសមាសបិទជាសមាសមួយទៀត រួចបញ្ចូនជាសទទទៅ ក្នុងចន្លោះផ្លូវ ទេវតាធ្វើឲ្យពេញដោយទំនិញ ។ លោកមានបុណ្យច្រើនយ៉ាងនេះ មានស្រីរបាំដែលប្រដាប់តាក់តែងហើយ ហែហមសោយសម្បត្តិលើប្រាសាទ ៣ សមគួរដល់រដូវទាំង ៣ ដូចទេវតា ។

ឯព្រះពោធិសត្វនៃយើង ចុតិអំពីតុសិតក្នុងសម័យនោះ មកបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះបាទសុទ្ធោទនមហារាជ ។ ទ្រង់ចម្រើនវ័យដោយលំដាប់ ទ្រង់នៅគ្រប់គ្រងផ្ទះអស់ ២៩ ឆ្នាំ ហើយទ្រង់ចេញមហាភិនេស្រ្កមណ៍ ទ្រង់ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណដោយលំដាប់ ។ ទ្រង់សម្រាកសម្រាន្តនៅត្រង់ពោធិមណ្ឌលដ្ឋានអស់ ៧ សប្តាហ៍ ប្រកាសព្រះធម្មចក្រក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ធ្វើការអនុគ្រោះសត្វលោក ទ្រង់ឲ្យអមាត្យ ១០ នាក់ មួយអន្លើដោយបរិវារម្នាក់ ១០០០ ដែលព្រះរាជបិតាទ្រង់ឮដំណឹងថា បុត្ររបស់យើងមកកាន់ក្រុងរាជគ្រឹះហើយ ត្រាស់ថា ទៅចុះអ្នក ពួកអ្នកចូរនាំកូនរបស់យើងមក ដូច្នេះ ឲ្យបួសដោយឯហិភិក្ខុបព្វជ្ជាហើយ ត្រូវកាឡុទាយិត្ថេរទូលអារាធនាឲ្យទ្រង់ចារិក ទើបមានភិក្ខុ ២ ម៉ឺនរូបជាបរិវារយាងចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងកបិលពស្តុ ទ្រង់ធ្វើធម្មទេសនាដ៏វិចិត្រ មានបាដិហារ្យ ដោយឥទ្ធិប្បាដិហារ្យដ៏ច្រើន ក្នុងសមាគមនៃពួកញាតិ ញ៉ាំងមហាជនឲ្យផឹកនូវទឹកអម្រឹតហើយ ។ ក្នុងថ្ងៃទី ២ ទ្រង់កាន់បាត្រ និងចីវរ ទៅប្រថាប់ឈរត្រង់ទ្វារព្រះនគរ ទ្រង់អាវជ្ជនៈថា ព្រះសព្វញ្ញុពុទ្ធទាំងឡាយ ទ្រង់ប្រព្រឹត្តការយាងត្រឡប់ចូលកាន់ព្រះនគរនៃត្រកូលដូចម្តេច

ហ្ន៎ ដូច្នេះ ដឹងថា ទ្រង់ប្រព្រឹត្តបិណ្ឌបាតតាមលំដាប់ច្រក ទើបទ្រង់យាងបិណ្ឌបាតតាមលំដាប់ច្រក ទ្រង់ត្រាស់ធម្មកថាថ្វាយព្រះរាជា ដែលទ្រង់បានដំណឹងថា កូនរបស់យើងត្រាច់បិណ្ឌបាត ទ្រង់យាងមកហើយ បុគ្គលមានសក្ការៈ គោរព កោតក្រែង ដែលព្រះរាជបិតាទូលអារាធនាឲ្យយាងមកហើយ ទូលឲ្យយាងចូលនិវេសន៍ ទ្រង់ធ្វើហើយ ទ្រង់អនុគ្រោះព្រះញាតិដែលទ្រង់គប្បីធ្វើក្នុងទីនោះ ទ្រង់ធ្វើហើយ ទ្រង់អនុគ្រោះព្រះញាតិ ដែលទ្រង់គប្បីធ្វើក្នុងទីនោះ ហើយឲ្យរាហុលកុមារបព្វជ្ជា មិនយូរប៉ុន្មានទ្រង់ក៏យាងចេញអំពីក្រុងកបិលពស្តុ ទៅក្នុងមល្លរដ្ឋ ហើយទ្រង់យាងត្រឡប់មកកាន់អនុបិយអម្ពវ័ន ។ សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ប្រជុំសក្យ-ត្រកូលទាំងឡាយ ត្រាស់ថា បើកូនរបស់យើងគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ ប្រកបដោយរតនៈ ៧ សូម្បីរាហុលកុមារចៅរបស់យើង នឹងហែហមស្តេចចក្រពត្តិនោះ ទៅជាមួយពួកក្សត្រ ។ ម្យ៉ាងទៀត ចូរពួកអ្នកទាំងឡាយ ជ្រាបសេចក្តីនេះចុះ តែឥឡូវនេះ កូនរបស់យើង ទ្រង់ត្រាស់ជាព្រះពុទ្ធហើយ ខត្តិយកុមារ ចូរជាបរិវាររបស់ទ្រង់ចុះ ពួកអ្នកចូរឲ្យទារកម្នាក់អំពីត្រកូលមួយបួសចុះ ។ កាលព្រះបាទសុទ្ធោទនៈ ត្រាស់យ៉ាងនេះហើយ ខត្តិយកុមាររហូតដល់ពាន់អង្គ ចេញបួសដោយព្រះតម្រាស់ត្រឹមតែម្តងប៉ុណ្ណោះ ។ សម័យនោះ មហានាមជាម្ចាស់នៃកុដុម្ពិកៈ ចូលទៅរកស្តេចសក្យៈឈ្មោះអនុរុទ្ធ បានពោលពាក្យនេះថា បាអនុរុទ្ធ ឥឡូវនេះ សក្យកុមារដែលមានឈ្មោះល្បី ចេញបួសតាមព្រះមានព្រះភាគដែលទ្រង់ព្រះផ្នួស

ហើយ មិនមានបុគ្គលណាម្នាក់ ចេញបួសអំពីត្រកូលយើងឡើយ បើដូច្នោះ អ្នកបួស ឬខ្ញុំបួស អនុរុទ្ធបានស្តាប់ព្រះតម្រាស់ម្ចាស់បងហើយ មិនត្រេកអរក្នុងការគ្រប់គ្រងផ្ទះ បានចេញបួសជាគម្រប់ ៧ អង្គ លំដាប់នៃការបួសរបស់ព្រះអង្គម្ចាស់អនុរុទ្ធនោះមកហើយ ក្នុងគម្ពីរសង្ឃភេទក្ខន្ធកៈ ។ ស្តេចអនុរុទ្ធយាងទៅកាន់អនុបិយអម្ពវ័ន បួសហើយ ដោយប្រការដូច្នេះ ។ បណ្តាសក្យៈទាំងនោះ ព្រះភទ្ទិយត្ថេរសម្រេចអរហត្តខាងក្នុងវស្សានោះឯង ព្រះអនុរុទ្ធត្ថេរធ្វើទិព្វចក្ខុឲ្យកើតឡើង ទេវទត្តធ្វើសមាបត្តិ ៨ ឲ្យកើតឡើង ព្រះអានន្ទត្ថេរតាំងនៅក្នុងសោតាបត្តិផល ព្រះភគុត្ថេរ និងព្រះកិម្ពិលត្ថេរបានសម្រេចអរហត្ត ក្នុងកាលជាក្រោយ អភិនីហារនៃសេចក្តីប្រាថ្នា អំពីកាលមុនរបស់ព្រះថេរៈរូបនោះ មកដល់ក្នុងរឿងនៃបុគ្គលម្នាក់ ។

ព្រះអនុរុទ្ធត្ថេរនេះ រៀនកម្មដ្ឋានក្នុងសម្នាក់នៃព្រះធម្មសេនាបតីហើយ ទៅបំពេញសមណធម៌ នៅបាចីនវំសទាយវ័ន ដែនចេតិយ ក៏ត្រិះរិះហើយ ដល់មហាបុរិសវិតក្ក ៧ ប្រការ លំបាកក្នុងវិតក្កទី ៨ ព្រះសាស្តាទ្រង់ជ្រាបថា អនុរុទ្ធលំបាកក្នុងមហាបុរិសវិតក្កទី ៨ ទ្រង់ព្រះតម្រិះថា តថាគតនឹងធ្វើសេចក្តីត្រិះរិះរបស់អនុរុទ្ធឲ្យពេញ ទើបយាងទៅក្នុងទីនោះ ប្រថាប់គង់លើពុទ្ធាសនៈដែលគេក្រាលទុកដ៏ប្រសើរ ទ្រង់ធ្វើមហាបុរិសវិតក្កទី ៨ ឲ្យពេញ ហើយត្រាស់មហាអរិយវង្សប្បដិបទា ប្រដាប់ទៅដោយការសន្តោសដោយបច្ច័យ ៤ និងមានភាវនាជាទីមកត្រេកអរហើយ ទ្រង់ហោះទៅដល់ភេសកឡាវ័ននោះឯង លុះព្រះតថាគតយាងទៅហើយប៉ុណ្ណោះ ព្រះថេរៈមានវិជ្ជា ៣ ជាព្រះមហា

ទីណាស្រេចធំ គិតថា ព្រះសាស្តាដឹងចិត្តរបស់អាត្មាអញ ទ្រង់យាងមកប្រទាន មហាបុរិសវិតក្កទី ៨ ឲ្យពេញ ។ ម្យ៉ាងទៀត មនោរថរបស់អាត្មាអញដល់ទីបំផុត ហើយប្រារព្ធធម្មទេសនាដ៏ពីរោះរបស់ព្រះពុទ្ធទាំងឡាយ និងធម៌ដែលខ្ទនបាក់ជ្ជុះ ហើយបានភាសិតឧទានគាថាទាំងនេះថា

ព្រះសាស្តា ជាបុគ្គលប្រសើរក្នុងលោក ទ្រង់ជ្រាបនូវសេចក្តីត្រិះរិះរបស់ខ្ញុំ ក៏យាងមកដោយឫទ្ធិ ដោយព្រះកាយដែលសម្រេចអំពីចិត្ត ។ ខ្ញុំមានសេចក្តីត្រិះរិះក្នុងកាលណា ព្រះសាស្តាទ្រង់បានសម្តែងនូវធម៌ ( មហាបុរិសវិតក្ក ) ដ៏លើសលប់ ក្នុងកាលនោះ ព្រះពុទ្ធទ្រង់ត្រេកអរក្នុងធម៌ដែលមិនមានដំណើរយឺតយូរ សម្តែងនូវធម៌ដែលមិនមានដំណើរយឺតយូរ ។ ខ្ញុំដឹងនូវធម្មទេសនារបស់ព្រះសាស្តានោះហើយ ត្រេកអរក្នុងសាសនា វិជ្ជា ៣ ខ្ញុំបានសម្រេចហើយ ពុទ្ធសាសនា ខ្ញុំបានធ្វើហើយ ។

ក្នុងកាលជាខាងក្រោយ ព្រះសាស្តាប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈថា អនុរុទ្ធជាកំពូលនៃពួកភិក្ខុសាវ័ក ដែលមានទិព្វចក្ខុ ក្នុងសាសនារបស់តថាគត ៕

## អដ្ឋកថាសូត្រទី ៨ ចប់

# អដ្ឋកថា សូត្រទី ៦

## ប្រវត្តិ ព្រះភទ្ទិយកាលិគោធាបុត្រ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៦ ដូចតទៅនេះ បទថា **ឧច្ចាកុលិកានំ** សេចក្តីថា ដែលកើតក្នុងត្រកូលខ្ពស់ ។ បទថា **ភទ្ទិយោ** បានដល់ ស្តេចសក្យៈដែលជាព្រះរាជាចេញបួស មួយអន្លើនឹងព្រះអនុរុទ្ធត្ថេរ ។ បទថា **កាលិគោធាយបុត្តោ** សេចក្តីថា ព្រះទេវីនោះជាអ្នកមានសម្បុរខ្មៅ ។ ឯពាក្យថា **គោធា** ជាឈ្មោះរបស់ព្រះទេវីនោះ ព្រោះដូច្នោះ ទើបហៅថា **កាលិគោធា** អធិប្បាយថា ជាបុត្ររបស់នាង កាលិគោធាទេវីនោះ ។ សួរថា ព្រះថេរៈនេះ លោកពោលថា ជាកំពូលនៃភិក្ខុសាវក ដែលមានត្រកូលខ្ពស់ ព្រោះហេតុអ្វី បុគ្គលមានត្រកូលខ្ពស់ជាងព្រះភទ្ទិយៈនោះមិនមានឬ ។ ឆ្លើយថា មិនមាន ។ ពិតហើយ ព្រះមាតារបស់លោក ជាធំជាងគេបង្អស់នៃម្ចាស់ស្រ្តីទាំងឡាយដោយវ័យ ក្នុងវាំងសាកិយានីទាំងឡាយ លោកលះបង់រាជសម្បត្តិ ដែលមកដល់ក្នុងសាកិយត្រកូលយ៉ាងនោះចេញបួស ព្រោះដូច្នោះ ទើបពោលថា ជាកំពូលនៃភិក្ខុដែលមានត្រកូលខ្ពស់ទាំងឡាយ ។ មួយប្រការទៀត ព្រះភទ្ទិយៈនេះ ដោយអនុភាពនៃការប្រាថ្នាក្នុងកាលមុន កើតឡើងក្នុងរាជត្រកូល ហើយគ្រងរាជសម្បត្តិ ៥០០ ជាតិជាប់តគ្នាដោយលំដាប់ ដោយហេតុនេះ ទើបលោកពោលថា ព្រះភទ្ទិយៈនោះ ជាកំពូលនៃភិក្ខុដែលមានត្រកូលខ្ពស់ ក្នុងបញ្ញាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ

សេចក្តីពិស្តារថា ក្នុងអតីតកាល ព្រះភទ្ទិយៈនេះ កាលព្រះពុទ្ធព្រះ

នាមបទុមុត្តរៈ កើតឡើងក្នុងត្រកូលមានភោគសម្បត្តិច្រើន ទៅស្តាប់ព្រះធម៌តាមន័យដែលពោលហើយនោះឯង ក្នុងថ្ងៃនោះ បានឃើញព្រះសាស្តា ទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងជាកំពូល នៃពួកភិក្ខុដែលមានត្រកូលខ្ពស់ ទើបគិតថា អាត្មាអញ គួរជាកំពូលនៃពួកភិក្ខុ ដែលមានត្រកូលខ្ពស់ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ក្នុងអនាគត ដូច្នេះ ។ ទើបនិមន្តព្រះមុនីថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ក្រាបទៀបបាទមូល តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិដទៃ ដោយផលនៃទាននេះ តែក្នុងអនាគតកាល ខ្ញុំព្រះអង្គសូមបានជាកំពូលនៃពួកភិក្ខុ ដែលមានត្រកូលខ្ពស់ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាទីមួយចុះ ។ ព្រះសាស្តាទ្រង់ប្រមើលមើលអនាគត ឃើញការសម្រេចទើបទ្រង់ព្យាករថា កម្មនេះរបស់សត្វនេះ នឹងសម្រេចក្នុងទីបំផុតនៃមួយសែនកប្ប បន្ទាប់អំពីនេះទៅ នឹងមានព្រះពុទ្ធព្រះនាមថា គោតម ទ្រង់កើតឡើងអ្នកនឹងបានជាកំពូលនៃពួកភិក្ខុដែលមានត្រកូលខ្ពស់ ក្នុងសាសនារបស់ព្រះអង្គ ។ ដូច្នេះហើយ ទ្រង់ធ្វើអនុមោទនាភត្តហើយ ទ្រង់ត្រឡប់ទៅវិហារ ។ កាលបុរសនោះបានស្តាប់ព្យាករហើយ ទើបទូលសួរកម្មដែលឲ្យប្រព្រឹត្តទៅសម្រាប់ភិក្ខុអ្នកកើតក្នុងត្រកូលខ្ពស់ បានធ្វើសុចរិតកម្មជាច្រើន រហូតដល់អស់ជីវិតយ៉ាងនេះ គឺសាងធម្មាសនៈ ក្រាលកម្រាលលើធម្មាសនៈនោះ បក់ផ្លិតសម្រាប់អ្នកសម្តែងធម៌ បវារណាបច្ច័យសម្រាប់ធម្មកថិក រៀងឧបោសថ ធ្វើកាលកិរិយាក្នុងអត្តភាពនោះហើយ អន្ទោលទៅមកក្នុងទេវតា

និងមនុស្សទាំងឡាយ ក្នុងចន្លោះព្រះទសពលព្រះនាមកស្សបៈ និងព្រះមានព្រះភាគនៃយើង មកកើតក្នុងផ្ទះរបស់កុដុម្ពិកៈ ក្នុងក្រុងពារាណសី ។

សម័យនោះ ព្រះបច្ចេកពុទ្ធច្រើនអង្គ មកអំពីភ្នំគន្ធមាទន៍ គង់ចាន់បិណ្ឌបាតក្នុងទីដែលជាទីសប្បាយ ក្បែរស្ទឹងគង្គា នាក្រុងពារាណសី ។ កុដុម្ពិកៈជ្រាបថា ព្រះបច្ចេកពុទ្ធទាំងនោះ ធ្វើការបែកកត្តនោះ ក្នុងទីត្រង់នោះជាប្រចាំនោះឯង ទើបតម្រៀបបន្ទះថ្ម ៨ បន្ទះ ទំនុកបម្រុងព្រះបច្ចេកពុទ្ធរហូតដល់អស់ជីវិត ។ បន្ទាប់អំពីនោះ លោកអន្ទោលទៅក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ កាលនោះ ក្នុងពុទ្ធុប្បាទកាលនេះ ទើបមកកើតក្នុងខត្តិយនគរ នាក្រុងកបិលពស្តុ ។ ក្នុងថ្ងៃថ្វាយព្រះនាម ពួកញាតិទាំងឡាយថ្វាយព្រះនាមរបស់លោកថា ភទ្ទិយកុមារ ។ ភទ្ទិយកុមារនោះអាស្រ័យបុណ្យ កើតជាក្សត្រមួយអង្គក្នុងរវាងក្សត្រ ៦ អង្គ តាមន័យដែលពោលក្នុងអនុរុទ្ធសូត្រ ក្រោយមក កាលព្រះសាស្តាប្រថាប់នៅក្នុងអនុបិយអម្ពវ័ន ។ ទ្រង់បួសក្នុងសម្នាក់របស់ព្រះសាស្តាហើយ បានសម្រេចអរហត្ត ។ ថ្ងៃមួយព្រះសាស្តា កាលប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់បានស្ថាបនាក្នុងតំណែងឯតទគ្គៈថា ពួកភិក្ខុអ្នកមានត្រកូលខ្ពស់ ស្រេចនឹងភទ្ទិយកាឡិគោធាយបុត្ត ៕

**អដ្ឋកថាសូត្រទី ៦ ចប់**

# អដ្ឋកថា សូត្រទី ៧

## ប្រវត្តិ ព្រះលកុណ្ឌកភទ្ទិយត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ដូចតទៅនេះ បទថា **មញ្ជុស្សរានំ** ប្រែថា មានសំឡេងពីរោះ ។ បទថា **លកុណ្ឌកភទ្ទិយោ** សេចក្តីថា លោកពោលដោយចំណែកខ្ពស់ជាមនុស្សតឿ ដោយឈ្មោះ ឈ្មោះថា ភទ្ទិយៈ ។ ក្នុងបញ្ហាកម្មរបស់ព្រះភទ្ទិយៈនោះ មានរឿងដែលគប្បីពោលតាមលំដាប់ដូចតទៅនេះថា

ពោលដោយពិស្តារ ព្រះថេរៈនេះ កើតក្នុងត្រកូលមានភោគៈច្រើនក្នុងក្រុងហង្សវតី កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ទៅព្រះវិហារស្តាប់ធម៌តាមន័យដែលពោលហើយនោះឯង ។ សម័យនោះ គាត់ឃើញព្រះភិក្ខុ មានសំឡេងពីរោះមួយរូប ដែលព្រះសាស្តាទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ កើតចិត្តគិតថា អស្ចារ្យហ្ន៎ តទៅក្នុងអនាគត អញគប្បីបានជាលំពូលនៃពួកភិក្ខុដែលមានសំឡេងពីរោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដូចភិក្ខុនេះ ទើបនិមន្តព្រះសាស្តា ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ហើយក្រាបទៀបបាទមូលរបស់ព្រះសាស្តា តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ដោយផលនៃទាននេះ ក្នុងអនាគតកាលខ្ញុំព្រះអង្គ មិនបានប្រាថ្នាសម្បត្តិដទៃ ខ្ញុំព្រះអង្គគប្បីបានជាកំពូលនៃភិក្ខុដែលមានសំឡេងពីរោះក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយចុះ ។ ព្រះសាស្តាទ្រង់ប្រមើលមើលក្នុងអនាគត ក៏ទ្រង់ឃើញការសម្រេច ទើបទ្រង់ព្យាករថា កម្មរបស់អ្នក នឹងសម្រេចក្នុងទីបំផុតនៃមួយសែនកប្បអំពីកប្បនេះ ព្រះពុទ្ធ

ព្រះនាមគោតម ទ្រង់នឹងកើតឡើងក្នុងលោក អ្នកនឹងបានជាកំពូលនៃពួកភិក្ខុ ដែលមានសំឡេងពីរោះ ក្នុងសាសនារបស់ព្រះតថាគតអង្គនោះ ហើយទ្រង់យាងត្រឡប់ទៅកាន់ព្រះវិហារ ។ លោកបានព្យាករនោះហើយ ធ្វើសុចរិតកម្មដរាបអស់ជីវិត ។ ធ្វើកាលកិរិយាក្នុងអត្តភាពនោះហើយ អន្ទោលក្នុងទេវតា និងមនុស្សទាំងឡាយ កាលព្រះសម្មាសម្ពុទ្ធព្រះនាមវិបស្សីកើតឡើងលោក ក៏កើតជាសត្វតាវៅ មានរោម និងស្លាបស្អាត ក្នុងខេមមិគទាយវ័ន ។ ថ្ងៃមួយ ទៅកាន់ហិមវន្តប្រទេស យកចំពុះពាំផ្លែស្វាយផ្អែមទុំមួយមក ឃើញព្រះសាស្ដាមានភិក្ខុសង្ឃចោមរោម ថ្វាយបង្គំ ( ដោយស្លាបទាំងឡាយ ) ហើយគិតថា ក្នុងថ្ងៃដទៃអញមានខ្លួនទទេជួបព្រះតថាគត តែក្នុងថ្ងៃនេះ អញនាំផ្លែស្វាយទុំនេះមកដើម្បីផ្ញើកូនរបស់អញ តែសម្រាប់កូននោះ អញទៅយកផ្លែដទៃមកក៏បាន តែផ្លែស្វាយនេះ អញគួរថ្វាយព្រះទសពល ដូច្នេះទើបហើរសំកាំងក្នុងអាកាស ។ ព្រះសាស្ដាទ្រង់ជ្រាបចិត្តរបស់សត្វ ទើបសម្លឹងមើលឧបដ្ឋាកព្រះនាមអសោកត្ថេរ ទើបព្រះថេរៈនាំបាត្រថ្វាយព្រះសាស្ដា ។ សត្វតាវៅនាំយកផ្លែស្វាយទុំដាក់ក្នុងបាត្រ របស់ព្រះទសពល ។ ព្រះសាស្ដាប្រថាប់គង់សោយក្នុងទីនោះឯង ។ សត្វតាវៅមានចិត្តជ្រះថ្លា នឹកដល់ពុទ្ធគុណរបស់ព្រះទសពលរឿយៗ ថ្វាយបង្គំព្រះទសពលដោយស្លាប ហើយទៅកាន់សម្បុករបស់ខ្លួន សម្រាកសម្រាន្តនៅដោយសុខ និងបីតិ ៧ ថ្ងៃ ។ ក្នុងអត្តភាពនោះ លោកធ្វើកល្យាណកម្ម មានប្រមាណប៉ុណ្ណោះ ដោយកម្មនេះ ទើបមានសំឡេងពីរោះ ។

កាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ កាលជនទាំងឡាយ ប្រារព្ធធ្វើចេតិយ ក៏នាំគ្នាពោលថា យើងគួរធ្វើទំហំប៉ុនណាហ្ន៎ ។ ក៏គិតថា យើងគួរធ្វើទំហំ ៧ យោជន៍ ក៏ធំពេកបើដូច្នោះកសាងទំហំ ៦ យោជន៍ ។ សូម្បី ៦ យោជន៍នេះក៏ធំដែរ យើងគួរសាង ៥ យោជន៍ ។ យើងគួរសាង ៤ យោជន៍ ៣ យោជន៍ ... ២ យោជន៍ ដូច្នេះ ។ ព្រះភទ្ទិយៈនេះ កាលនោះជាមេជាងធំពោលថា អ្នកដ៏ចម្រើនទាំងឡាយ ការសាងក៏គួរគិតដល់ការដែលទំនុកបម្រុងបានងាយ ក្នុងអនាគតកាលខ្លះផង ហើយពោលថា យើងធ្វើមុខមួយទំហំមួយគាវុត ចេតិយចំណែកមូលមួយយោជន៍ កម្ពស់មួយយោជន៍ ដូច្នេះ ជនទាំងនោះក៏ស្ដាប់តាម ។ លោកបានធ្វើតែល្មមប្រមាណដល់ព្រះពុទ្ធដែលទ្រង់ប្រមាណមិនបាន ដោយកម្មដូចពោលមកនេះ ទើបលោកជាបុគ្គលមានកម្ពស់ទាបជាងជនដទៃ ក្នុងទីដែលខ្លួនកើតហើយ ដោយប្រការដូច្នេះ ។

កាលព្រះសាស្ដានៃយើងកើតឡើងក្នុងលោកលោកមកកើតក្នុង ត្រកូលអ្នកមានភោគៈច្រើន ក្នុងក្រុងសាវត្ថី ពួកញាតិថ្វាយព្រះនាមរបស់លោកថា ភទ្ទិយៈ ។ លោកចម្រើនវ័យហើយ កាលព្រះសាស្ដាប្រថាប់គង់ក្នុងវត្តជេតពនមហាវិហារ ទើបទៅកាន់ព្រះវិហារ ស្ដាប់ធម្មទេសនា បាននូវសទ្ធាហើយ ទទួលកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដា ចម្រើនវិបស្សនា សម្រេចអរហត្តហើយ ។ ក្នុងកាលក្រោយមក ព្រះសាស្ដាប្រថាប់គង់ត្រង់កណ្ដាលព្រះអរិយសង្ឃ ទ្រង់ស្ថាបនាលោកទុកក្នុងតំណែងជាបុគ្គលកំពូលនៃភិក្ខុដែល

មានសំឡេងពីរោះ ។

## អដ្ឋកថា សូត្រទី ៧ ចប់

# អដ្ឋកថា សូត្រទី ៨
# ប្រវត្តិ ព្រះបិណ្ឌោលភារទ្វាជត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ដូចតទៅនេះ បទថា **សីហនាទិកានំ** សេចក្ដីថា ជាអ្នកបន្លឺសីហនាទ គឺព្រះបិណ្ឌោលភារទ្វាជៈជាកំពូល បានឮថា ក្នុងថ្ងៃសម្រេចអរហត្ត លោកកាន់យកសំពត់និសីទនៈអំពីវិហារនេះ ទៅកាន់វិហារនោះ ចេញអំពីបរិវេណនេះ ទៅកាន់បរិវេណនោះ ត្រាច់បន្លឺសីហនាទថា បុគ្គលណាមានសេចក្ដីសង្ស័យក្នុងមគ្គ និងផល បុគ្គលនោះ ចូរសួរខ្ញុំចុះ ។ លោកឈរចំពោះព្រះភក្ត្រព្រះពុទ្ធ បន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន កិច្ចដែលគួរធ្វើក្នុងសាសនានេះ ខ្ញុំព្រះអង្គដល់ទីបំផុតហើយ ដូច្នេះ ឈ្មោះថា ជាកំពូលនៃភិក្ខុដែលបន្លឺសីហនាទ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ

បានឮថា ក្នុងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះបិណ្ឌោលភារទ្វាជៈនេះ កើតក្នុងកំណើតសីហៈ នាជើងភ្នំមួយ ។ ព្រះសាស្ដាទ្រង់ប្រមើលលោក ទ្រង់ឃើញហេតុសម្បត្តិរបស់លោក ទើបទ្រង់យាងបិណ្ឌបាតក្នុងក្រុងសាវត្ថី

ខាងក្រោយកត្តាហារ ។ ក្នុងវេលាជិតភ្លឺ កាលសីហៈចេញទៅរកចំណី ទើបទ្រង់ចូលទៅកាន់គុហា ដែលជាលំនៅរបស់សីហៈនោះ ប្រថាប់គង់ពត់ភ្នែនក្នុងអាកាស ចូលនិរោធសមាបត្តិ ។ ស្តេចរាជសីហ៍បានចំណីហើយ ត្រឡប់មកឈរត្រង់ទ្វារគុហា ឃើញព្រះទសពលប្រថាប់គង់ខាងក្នុងគុហា ត្រិះរិះថា មិនមានសត្វដទៃ ដែលអាចមកអង្គុយក្នុងលំនៅរបស់អាត្មាអញបានឡើយ បុរសនេះធំពិតហ្ន៎ មកអង្គុយពត់ភ្នែនខាងក្នុងគុហាបាន សូម្បីស្នើសរីរៈរបស់លោក ក៏ផ្សាយទៅដោយជុំវិញ អញមិនធ្លាប់ឃើញវត្ថុដែលគួរអស្ចារ្យ មានប្រមាណប៉ុណ្ណេះឡើយ បុរសនេះពិតជាកំពូលនៃបូជនីយបុគ្គលក្នុងលោកនេះ ដូច្នេះ អញគួរធ្វើសក្ការៈតាមសតិ តាមកម្លាំងថ្វាយព្រះអង្គ ។ ទើបទៅនាំផ្កាផ្សេងៗ ដែលដុះនៅក្នុងទឹក ទាំងដែលកើតលើគោក ធ្វើជាអាសនៈផ្កា តាំងអំពីដី រហូតដល់ទីប្រថាប់ពត់ភ្នែនរបស់ព្រះមានព្រះភាគ ឈរនមស្ការព្រះតថាគត ក្នុងទីចំពោះព្រះភក្ត្រអស់មួយយប់ទល់ភ្លឺ ។ លុះស្អែកឡើង ក៏នាំយកផ្កាចាស់ចេញ យកផ្កាថ្មីក្រាលអាសនៈដោយទំនងនេះ ខំស្វះស្វែងតាក់តែងបុប្ផាសនៈអស់ ៧ ថ្ងៃ កើតបីតិសោមនស្សដ៏ខ្លាំងក្លា ឈរយាមត្រង់ទ្វារគុហា ក្នុងថ្ងៃ ទី ៧ ព្រះសាស្តាចេញអំពីនិរោធ ប្រថាប់ឈរត្រង់ទ្វារគុហា ស្តេចសីហមិគរាជ ធ្វើប្រទក្សិណព្រះតថាគត ៣ ជុំ ថ្វាយបង្គំក្នុងទីទាំង ៤ ហើយថយចេញទៅឈរ ។ ព្រះសាស្តាទ្រង់ត្រិះរិះថា សត្វនេះធ្វើកម្មប៉ុណ្ណេះល្មមបានជាឧបនិស្ស័យដល់គេ ក៏ហោះទៅកាន់ព្រះវិហារវិញ ។ ឯស្តេចរាជសីហ៍នោះ កើតទុក្ខព្រោះព្រាត់ប្រាសអំពីព្រះពុទ្ធអង្គ ធ្វើកាលកិរិយា

ហើយ បដិសន្ធិក្នុងត្រកូលមហាសាល នាក្រុងហង្សវតី ចម្រើនវ័យហើយ ថ្ងៃមួយ ទៅកាន់វិហារជាមួយអ្នកក្រុង ស្តាប់ព្រះធម្មទេសនា បំពេញមហាទាន ៧ ថ្ងៃ ដោយន័យដែលពោលហើយខាងដើម ។ ធ្វើកាលកិរិយាក្នុងកពនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ មកកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងរាជគ្រឹះ ក្នុងពុទ្ធុប្បាទកាលយើងនេះ ដោយឈ្មោះ មានឈ្មោះថា ភារទ្វាជៈ លោកចម្រើនវ័យហើយ សិក្សាត្រៃវេទ ត្រាច់បង្រៀនមន្តដល់មាណព ៥០០ នាក់ លោកទទួលកិច្ចារបស់មាណពគ្រប់គ្នាដោយខ្លួនឯង ត្រាច់ទៅក្នុងទីដែលគេអញ្ជើញ ព្រោះខ្លួនជាប្រធាន ។ បានឮថា ភារទ្វាជៈនេះ ជាបុគ្គលល្មោះល្មោភបន្តិចបន្តួច គឺត្រាច់ស្វែងរកបបរបាយ និងរបស់ទំពា ក្នុងទីណាមួយជាមួយមាណពទាំងនោះ ក្នុងទីដែលលោកទៅហើយ ដើម្បីបាយមួយវែកប៉ុណ្ណោះ ដូច្នោះ ទើបប្រាកដឈ្មោះថា បិណ្ឌោលភារទ្វាជៈ ។ ថ្ងៃមួយ កាលព្រះសាស្តាយាងដល់ក្រុងរាជគ្រឹះ លោកបានស្តាប់ធម្មកថា បាននូវសទ្ធាហើយ បួសបំពេញវិបស្សនា បានសម្រេចអរហត្តហើយ ក្នុងវេលាដែលលោកសម្រេចអរហត្តនោះឯង លោកកាន់យកសំពត់ដែលក្រាលអង្គុយចេញអំពីវិហារនេះ ទៅវិហារនោះ ចេញអំពីបរិវេណនេះ ទៅកាន់បរិវេណនោះ ត្រាច់បន្លឺសីហនាទថា អ្នកណាសង្ស័យក្នុងមគ្គ ឬផល បុគ្គលនោះ ចូរសួរខ្ញុំចុះ ។

ថ្ងៃមួយ សេដ្ឋីក្នុងក្រុងរាជគ្រឹះ យកដើមឫស្សីបន្តគ្នាឲ្យវែងទៅព្យួរបាត្រខ្លឹមចន្ទន៍ មានពណ៌ដូចផ្កាជ័យព្រឹក្សទុកក្នុងអាកាស លោកហោះទៅកាន់យក

ដោយឫទ្ធិ ជាបុគ្គលដែលមហាជនឲ្យសាធុការ ហែហមទៅកាន់ព្រះវិហារ ដាក់ក្នុងព្រះហស្តរបស់ព្រះតថាគតហើយ ព្រះសាស្តាទ្រង់ជ្រាប សាកសួរថា ភារទ្វាជៈ អ្នកបានបាត្រនេះមកអំពីណា ទើបលោកនិទានហេតុការណ៍ដែលបានមក ថ្វាយព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា អ្នកសម្តែងឧត្តរិមនុស្ស-ធម្ម បែបនេះដល់មហាជន អ្នកធ្វើកម្មក្នុងវត្ថុដែលមិនគួរធ្វើ ទ្រង់តិះដៀលដោយអនេកបរិយាយ ហើយទ្រង់បញ្ញត្តសិក្ខាបទថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនត្រូវសម្តែងឥទ្ធិប្បាដិហារ្យដែលជាធម៌របស់មនុស្សជាន់ខ្ពស់ ដល់ពួកគ្រហស្ថទេ ភិក្ខុណាសម្តែង ត្រូវអាបត្តិទុក្កដ ដូច្នេះ ។ ខណៈនោះ ក៏កើតពាក្យចរចាគ្នាក្នុងកណ្តាលភិក្ខុសង្ឃថា ព្រះថេរៈដែលបន្លឺសីហនាទក្នុងថ្ងៃដែលខ្លួនសម្រេចអរហត្ត ក្នុងកណ្តាលភិក្ខុសង្ឃថា អ្នកណាមានសេចក្តីសង្ស័យក្នុងមគ្គ ឬផល បុគ្គលនោះចូរសួរខ្ញុំចុះ ដូច្នេះ ក្នុងទីចំពោះព្រះភក្រ្តព្រះសម្ពុទ្ធ ក៏ទូលដល់ការសម្រេចអរហត្តរបស់ខ្លួន ព្រះសាវកដទៃក៏នៅស្ងៀម ដោយភាពដែលលោកពេញចិត្តបន្លឺសីហនាទនោះឯង ធ្វើមហាជនឲ្យកើតសេចក្តីជ្រះថ្លា ហោះទៅទទួលបាត្រខ្លឹមចន្ទន៍ ភិក្ខុទាំងនោះធ្វើគុណទាំង ៣ នេះជំណាលគ្នា ក្រាបទូលដល់ព្រះសាស្តាហើយ ធម្មតាព្រះពុទ្ធទាំងឡាយទ្រង់រមែងតិះដៀលបុគ្គលដែលគួរតិះដៀល រមែងសរសើរបុគ្គលដែលគួរសរសើរ ក្នុងឋានៈនេះ ព្រះសាស្តាទ្រង់កាន់យកថា ភាពជាកំពូលរបស់ព្រះថេរៈដែលសមគួរសរសើរនោះឯង ហើយសរសើរព្រះថេរៈថា ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុតែបានចម្រើន បានធ្វើឲ្យក្រាស់ក្រែលនូវឥន្ទ្រិយ ៣ យ៉ាង

*ទើបបិណ្ឌោលភារទ្វាជភិក្ខុ ប្រកាសនូវអរហត្តផលថា អាត្មាអញដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តរួចហើយ សោឡសកិច្ច អាត្មាអញបានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃ ប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ដូច្នេះ ទើបទ្រង់ស្ថាបនាទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ខាងបន្លឺសីហនាទ ដូច្នេះ ។*

**អដ្ឋកថា សូត្រទី ៨ ចប់**

## អដ្ឋកថា សូត្រទី ៩
## ប្រវត្តិ ព្រះបុណ្ណមន្តានីបុត្តត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៩ ដូចតទៅនេះ បទថា* **បុណ្ណមន្តានីបុត្ត** *គឺព្រះថេរៈឈ្មោះថា បុណ្ណៈ ដោយឈ្មោះ តែលោកជាកូននាងមន្តានីព្រាហ្មណី ទើបឈ្មោះថា បុណ្ណមន្តានីបុត្រ ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ បានឮថា មុនព្រះទសពលព្រះនាមបទុមុត្តរៈ ទ្រង់កើតឡើងក្នុងលោក ព្រះបុណ្ណៈកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងហង្សវតី ក្នុងពេលដាក់ឈ្មោះ ពួកញាតិបានឲ្យឈ្មោះថា គោតម លោកចម្រើនវ័យហើយ រៀនត្រៃវេទ ជាអ្នកឈ្លាសក្នុងសិប្បៈទាំងពួង មានមាណព ៥០០ ជាបរិវារត្រាច់ទៅ ទើបពិចារណា*

ត្រៃវេទ ក៏មិនឃើញមោក្ខធម៌ជាគ្រឿងរួចផុត គិតថា ធម្មតាត្រៃវេទនេះដូចជាដើមចេក ខាងក្រៅរលើបរលើង ខាងក្នុងមិនមានសារៈ ការកាន់យកត្រៃវេទនេះ ត្រាច់ទៅ ដូចគ្នានឹងការបរិភោគអង្កាម អញត្រូវការអ្វីដោយសិប្បៈនេះ ទើបចេញបួសជាឥសី ធ្វើព្រហ្មវិហារឲ្យកើតឡើង ជាអ្នកមានឈានមិនសាបសូន្យ ក៏ចូលដល់ព្រហ្មលោក ដូច្នេះ ទើបបបួលមាណព ៥ រយ ទៅកាន់ជើងភ្នំ បួសជាឥសីហើយ លោកមានជដិល ១៨០០០ ជាបរិវារ លោកធ្វើអភិញ្ញា ៥ សមាបត្តិ ៨ ឲ្យកើតហើយ ប្រាប់កសិណបរិកម្មដល់ជដិលទាំងនោះផងដែរ ។ ជដិលនោះ តាំងនៅក្នុងឱវាទរបស់លោក បំពេញព្យាយាម រហូតបានអភិញ្ញា ៥ សមាបត្តិ ៨ គ្រប់រូប ។

ចំណេរកាលកន្លងទៅក្នុងវេលាដែលគោតមតាបសនោះ ជាបុគ្គលចាស់ជរា ព្រះបទុមុត្តរទសពល ក៏ទ្រង់សម្រេចបរមាភិសម្ពោធិញ្ញាណ ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ មានភិក្ខុមួយសែនរូបជាបរិវារ ទ្រង់អាស្រ័យក្នុងហង្សវតីគន់ប្រថាប់ ។ ថ្ងៃមួយ ព្រះទសពលទ្រង់ប្រមើលមើលសត្វលោកក្នុងពេលទៀបភ្លឺ ឃើញអរហត្តូបនិស្ស័យរបស់បរិស័ទគោតមតាបសនោះ និងសេចក្ដីប្រាថ្នារបស់គោតមតាបស ទើបជម្រះសរីរៈអំពីព្រលឹម កាន់បាត្រ និងចីវរដោយព្រះអង្គឯង ទ្រង់យាងទៅដោយភេទ ដែលបុគ្គលណាមួយមិនស្គាល់ក្នុងកាលអន្តេវាសិករបស់គោតមតាបសទៅ ដើម្បីស្វែងរកមហាផល មានឫសឈើជាដើមក្នុងព្រៃ ទៅប្រថាប់ឈរត្រង់ទ្វារបណ្ណសាលារបស់គោតមតាបស ឯគោតមតាបសមិនជ្រាបថា ព្រះពុទ្ធទ្រង់កើតឡើងហើយ ឃើញ

ព្រះទសពលយាងមកអំពីចម្ងាយ ក៏ជ្រាបបានថា បុរសនេះ ពិតជាបុគ្គលដែលផុតចាកលោកហើយ ដូចការសម្រេចនៃសរីរៈរបស់ព្រះអង្គដែលប្រកបដោយចក្កលក្ខណៈ បើនៅគ្រប់គ្រងផ្ទះ នឹងបានជាស្តេចចក្រពត្តិ បើចេញបួស ក៏នឹងបានជាព្រះសព្វញ្ញុពុទ្ធ ជាអ្នកមានកិលេសដូចដំបូលបើកហើយ ដូច្នេះ ទើបថ្វាយបង្គំព្រះទសពល ដោយការជួបគ្រាដំបូងប៉ុណ្ណោះ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រថាប់ត្រង់នេះ ក្រាលអាសនៈថ្វាយហើយ ព្រះតថាគតប្រថាប់គង់ សម្តែងធម៌ដល់គោតមតាបស ។ ខណៈនោះ ពួកជដិលទាំងនោះ មកដោយបំណងថា នឹងឲ្យផ្លែឈើ ឫសឈើក្នុងព្រៃ ដែលប្រណីតៗ ដល់អាចារ្យ ចំណែកដ៏សេសនឹងបរិភោគឯង ដូច្នោះ ឃើញព្រះទសពលប្រថាប់គង់លើអាសនៈខ្ពស់ តែអាចារ្យអង្គុយលើអាសនៈទាបសន្ទនាគ្នាថា ពួកយើងគិតគ្នាថា ក្នុងលោកនេះ មិនមានអ្នកណាដែលក្រៃលែងជាងអាចារ្យរបស់យើង តែឥឡូវនេះ បុរសនេះឲ្យអាចារ្យរបស់យើងអង្គុយលើអាសនៈទាប ខ្លួនឯងអង្គុយលើអាសនៈខ្ពស់ នេះប្រហែលជាបុគ្គលធំហ្ន៎ ដូច្នេះ ក៏នាំគ្នាកាន់កំប្រោងចូលមក ។ គោតមតាបសក្រែងជដិលទាំងនេះថ្វាយបង្គំខ្លួន ក្នុងសម្នាក់ព្រះទសពល ទើបពោលថា បាទាំងឡាយ កុំថ្វាយបង្គំខ្ញុំឡើយ អគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ជាបុគ្គលគួរអ្នកទាំង-ឡាយថ្វាយបង្គំ អ្នកទាំងឡាយចូរថ្វាយបង្គំបុរសនេះ តាបសទាំងឡាយគិតថា លោកអាចារ្យគង់មិនពោលផ្តេសផ្តាស ទើបថ្វាយបង្គំព្រះបាទនៃព្រះតថាគតគ្រប់អង្គ គោតមតាបសពោលថា បាទាំងឡាយ យើងមិនមានភោជន

ដទៃ ដែលសមគួរថ្វាយដល់ព្រះទសពល យើងនឹងថ្វាយផលានុផល ក្នុងព្រៃនេះ ទើបជ្រើសរើសផ្លែដែលប្រណីតៗ ផ្ចិតផ្ចង់ដាក់ក្នុងបាត្ររបស់ព្រះពុទ្ធ ថ្វាយហើយ ព្រះសាស្តាសោយផលានុផល ក្នុងព្រៃហើយ បន្ទាប់អំពីនោះ តាបសឯង និងអន្តេវាសិក ទើបឆាន់ជាក្រោយ ។ ព្រះសាស្តាសោយស្រេចហើយ ទ្រង់ព្រះតម្រិះថា សាវកទាំង ២ ចូរនាំភិក្ខុមួយសែនរូបមក ក្នុងខណៈនោះ ព្រះមហាវិមលត្ថេរអគ្គសាវកអាវជ្ជនៈថា ព្រះសាស្តាទ្រង់និមន្តទៅឯណាហ្ន៎ ក៏ដឹងថា ព្រះសាស្តាទ្រង់បំណងឲ្យអាត្មាអញទៅ ទើបនាំភិក្ខុមួយសែនរូបទៅគាល់ ហើយថ្វាយបង្គំ ។ តាបសពោលនឹងអន្តេវាសិកថា បាទាំងឡាយ ពួកយើងមិនមានសក្ការៈដទៃ ភិក្ខុសង្ឃក៏ឈរលំបាក យើងនឹងក្រាលបុប្ផាសនៈប្រគេនភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន អ្នកទាំងឡាយចូរនាំយកផ្កាដែលកើតលើគោកផង ក្នុងទឹកផងមកចុះ ។ រំពេចនោះឯង តាបសទាំងនោះ នាំយកផ្កាដែលសម្បូរដោយពណ៌ និងក្លិន មកអំពីជើងភ្នំដោយឫទ្ធិ ក្រាលអាសនៈទាំងឡាយ ដោយន័យដូចពោលទុកក្នុងរឿងរបស់ព្រះសារីបុត្តេរនោះឯង ការចូលនិរោធសមាបត្តិក្តី ការបាំងឆត្រក្តី គប់រឿងគប្បីជ្រាបដោយន័យដែលពោលហើយនោះឯង ។

ក្នុងថ្ងៃទី ៧ ព្រះសាស្តាក៏ទ្រង់ចេញពីនិរោធសមាបត្តិ ទ្រង់ឃើញតាបសទាំងឡាយឈរជុំវិញ ទើបត្រាស់ហៅសាវកដែលសម្រេចឯតទគ្គៈ ក្នុងភាពជាព្រះធម្មកថិក ត្រាស់ថា ម្នាលភិក្ខុ ពួកឥសីទាំងនេះបានធ្វើសក្ការៈធំ ចូរអ្នកអនុមោទនាបុប្ផាសនៈដល់ពួកឥសីទាំងនេះ ភិក្ខុនោះទទួលព្រះពុទ្ធតម្រាស់

ហើយ ពិចារណាព្រះត្រៃបិដក ធ្វើអនុមោទនា ក្នុងកាលចប់ទេសនារបស់ភិក្ខុនោះ ព្រះសាស្តាទ្រង់បន្ទឺព្រះសូរសៀងដូចសំឡេងព្រហ្ម សម្តែងធម៌ដោយព្រះអង្គឯង កាលចប់ទេសនា វៀរគោតមតាបសចេញ ជដិល ១ ម៉ឺន ៨ ពាន់រូបដ៏សេសបានសម្រេចអរហត្ត ឯគោតមតាបសមិនអាចធ្វើការចាក់ធ្លុះដោយអត្តភាពនោះ ទើបក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះមានព្រះភាគ ភិក្ខុដែលសម្តែងធម៌មុននេះ មានឈ្មោះដូចម្តេចក្នុងសាសនារបស់ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលគោតមតាបស ភិក្ខុនេះ ជាកំពូលនៃពួកភិក្ខុដែលជាធម្មកថិក ក្នុងសាសនាតថាគត ។ គោតមតាបសក្រាបទៀបបាទមូល ធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ដោយផលនៃបុណ្យដែលខ្ញុំព្រះអង្គធ្វើមក ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គគប្បីជាកំពូលនៃពួកភិក្ខុដែលជាធម្មកថិកក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូចភិក្ខុរូបនេះ ។ ព្រះសាស្តាទ្រង់ប្រមើលមើលអនាគតកាល ក៏ទ្រង់ជ្រាបថា ការប្រាថ្នារបស់ព្រះគោតមតាបសនោះ សម្រេចដោយមិនមានអន្តរាយ ទ្រង់ព្យាករថា ក្នុងទីបំផុតនៃមួយសែនកប្ប ក្នុងអនាគតកាល ព្រះពុទ្ធព្រះនាមគោតម ទ្រង់នឹងកើតឡើង អ្នកនឹងបានជាកំពូល នៃពួកភិក្ខុដែលជាធម្មកថិក ក្នុងសាសនារបស់ព្រះអង្គ ហើយត្រាស់នឹងតាបស ដែលសម្រេចអរហត្តថា **ឯថ ភិក្ខវោ** ចូរជាភិក្ខុចុះដូច្នេះ ។ តាបសគ្រប់រូបមានសក់ និងពុកមាត់អន្តរធានទៅ ទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ដូចគ្នានឹងព្រះថេរៈមានវស្សា ១០០ ព្រះសាស្តាទ្រង់នាំភិក្ខុសង្ឃត្រឡប់ទៅកាន់វិហារ ឯគោតមតាបសក៏ទំនុកបម្រុងព្រះមុនី

ដរាបដល់អស់ជីវិត បំពេញតែកល្យាណកម្មតាមកម្លាំង អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ អស់មួយសែនកប្ប ។ ក្នុងពុទ្ធុប្បាទកាលព្រះមានព្រះភាគនៃយើង មកកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងស្រុកព្រាហ្មណ៍ឈ្មោះទោណវត្ថុ មិនឆ្ងាយអំពីក្រុងកបិលពស្តុ ក្នុងថ្ងៃដាក់ឈ្មោះរបស់លោក ពួកញាតិឲ្យឈ្មោះលោកថា បុណ្ណមាណព ។ កាលព្រះសាស្ដាទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ទ្រង់យាងមកដោយលំដាប់ អាស្រ័យនៅក្នុងក្រុងរាជគ្រឹះ ព្រះអញ្ញាកោណ្ឌញ្ញៈមកកាន់ក្រុងកបិលពស្តុ ឲ្យបុណ្ណមាណពក្មួយប្រុសរបស់ខ្លួនបួសហើយ ស្អែកឡើងទើបមកគាល់ព្រះទសពល ថ្វាយបង្គំហើយ ទូលលាទៅកាន់ស្រះឆទ្ទន្ត ដើម្បីសម្រាកក្នុងពេលថ្ងៃ ឯព្រះបុណ្ណមន្តានីបុត្រ មកគាល់ព្រះទសពល មួយអន្លើដោយព្រះអញ្ញាកោណ្ឌញ្ញៈដែលជាអ៊ំ គិតថា អញនឹងធ្វើកិច្ចនៃបព្វជិតរបស់អញ ឲ្យដល់ទីបំផុតហើយ ទើបទៅគាល់ព្រះទសពល ដូច្នេះ ទើបត្រូវទុកក្នុងក្រុងកបិលពស្តុនោះឯង ធ្វើយោនិសោមនសិការកម្មដ្ឋាន មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត ។ មានកុលបុត្រចេញបួសក្នុងសម្នាក់របស់លោក ដល់ទៅ ៥០០ រូប ព្រះថេរៈឯង បានទូន្មានដល់បព្វជិតទាំងនោះដោយកថាវត្ថុ ១០ ទើបទូន្មានដល់បព្វជិតទាំងនោះ ដោយកថាវត្ថុ ១០ បព្វជិតទាំងនោះ តាំងនៅក្នុងឱវាទរបស់លោក ក៏បានសម្រេចអរហត្តគ្រប់រូបនោះឯង ។ ភិក្ខុទាំងនោះដឹងថា កិច្ចនៃបព្វជិតនៃខ្លួនដល់ទីបំផុតហើយ ទើបចូលទៅរកព្រះឧបជ្ឈាយ៍ ពោលថា លោកម្ចាស់ដ៏ចម្រើន កិច្ចរបស់ពួកខ្ញុំ និងអ្នកបានមហាកថាវត្ថុ ១០ ដល់ទីបំផុតហើយ

ជាសម័យដែលពួកខ្ញុំចូលគាល់ព្រះទសពល ព្រះថេរៈស្តាប់វាចារបស់ភិក្ខុទាំងនោះហើយ ទើបគិតថា ព្រះសាស្តាទ្រង់ជ្រាបថា អាត្មាបាននូវកថាវត្ថុ ១០ បើអញសម្តែងធម៌ ក៏សម្តែងមិនផុតអំពីកថាវត្ថុ ១០ កាលអាត្មាអញទៅ ភិក្ខុទាំងនេះ ក៏នឹងចោមរោមទៅ ការទៅដោយប្រឡូកប្រឡំជាមួយពួកគណៈយ៉ាងនេះ ដើម្បីចូលគាល់ព្រះទសពល ក៏មិនគួរដល់អញ ភិក្ខុទាំងនេះ ចូរទៅគាល់មុនចុះ ដូច្នេះ ទើបពោលនឹងភិក្ខុទាំងនោះថា អាវុសោ លោកទាំងឡាយ ចូរផ្តោះមុខទៅគាល់ព្រះតថាគត ហើយចូរក្រាបទៀបព្រះបាទារបស់ព្រះអង្គតាមពាក្យរបស់ខ្ញុំ ឯខ្ញុំនឹងទៅតាមផ្លូវដែលអ្នកទៅហើយ ដូច្នេះ ភិក្ខុគ្រប់រូបទាំងនោះ សុទ្ធតែនៅក្នុងដែនដែលជាជាតិភូមិជាមួយនឹងព្រះទសពលទាំងអស់ សុទ្ធសឹងតែជាព្រះខីណាស្រព បាននូវកថាវត្ថុ ១០ គ្រប់រូប ត្រេកអរក្រៃលែងនូវឱវាទរបស់ឧបជ្ឈាយ៍របស់ខ្លួន ថ្វាយបង្គំព្រះថេរៈហើយត្រាច់ចារិកទៅដោយលំដាប់ អស់ចម្ងាយផ្លូវ ៦០ យោជន៍ រហូតដល់វត្តជេតពនមហាវិហារ ក្នុងក្រុងរាជគ្រឹះ ថ្វាយបង្គំព្រះបាទារបស់ទសពលហើយនាំគ្នាអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

នេះជាអាចិណ្ណវត្តរបស់ព្រះមានព្រះភាគទាំងឡាយ ដែលទ្រង់ចូលចិត្តរាក់ទាក់ជាមួយអាគន្តុកភិក្ខុទាំងឡាយ ដូច្នោះ ទើបព្រះមានព្រះភាគទ្រង់ធ្វើបដិសណ្ឋារៈដោយមធុរវាចាជាមួយភិក្ខុទាំងនោះ ដោយន័យជាដើមថា **កច្ចិ ភិក្ខវេ ខមនីយំ** ម្នាលភិក្ខុទាំងឡាយ អ្នកអត់ធន់បានដែរឬទេ ហើយត្រាស់សួរថា ពួកអ្នកមកអំពីណា កាលភិក្ខុទាំងនោះទូលស្នងថា មកអំពីជាតិភូមិ

ហើយ ទើបត្រាស់សួរភិក្ខុដែលបានកថាវត្ថុ ១០ ថា ម្នាលភិក្ខុទាំងឡាយ ពួកភិក្ខុដែលជាសព្រហ្មចារី អ្នកជាតិភូមិជាមួយគ្នា បានសរសើរបុគ្គលណាហ្ន៎ យ៉ាងនេះថា ខ្លួនឯងក៏ប្រាថ្នាតិចផង ប្រៀនប្រដៅភិក្ខុទាំងឡាយ អំពីការប្រាថ្នាតិចផង ដូច្នេះ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ លោកឈ្មោះថា ព្រះបុណ្ណមន្តានីបុត្រ ។ ចំណែកព្រះសារីបុត្រ បានស្តាប់ពាក្យនោះ ទើបជាអ្នកប្រាថ្នាដើម្បីជួបព្រះថេរៈ គ្រានោះ ព្រះសាស្តា បានចេញអំពីក្រុងរាជគ្រឹះ ទៅកាន់ក្រុងសាវត្ថី ។ ព្រះបុណ្ណត្ថេរបានឮថា ព្រះទសពលមកក្រុងសាវត្ថី ទើបគិតថា អញនឹងគាល់ព្រះសាស្តា ទើបចេញដំណើរទៅគាល់ព្រះសាស្តាខាងក្នុងព្រះគន្ធកុដិនោះឯង ។ ព្រះសាស្តា ទ្រង់សម្តែងធម៌ដល់លោក ព្រះថេរៈស្តាប់ធម៌ហើយ ថ្វាយបង្គំព្រះទសពល ហើយ ទៅកាន់ព្រៃអន្ធវ័នដើម្បីពួនសម្ងំ គង់សម្រាកពេលថ្ងៃ ត្រង់គល់ឈើមួយដើម ។ ព្រះសារីបុត្រជ្រាបថា ព្រះបុណ្ណៈនិមន្តមក សម្លឹងមើលទិស និងផ្លូវ ហើយនិមន្តទៅ កំណត់ឱកាសចូលទៅគល់ឈើនោះ ហើយសន្ទនាជាមួយព្រះថេរៈ សួរដល់លំដាប់នៃវិសុទ្ធិ ៧ ។ ព្រះថេរៈក៏ព្យាករនូវពាក្យដែលព្រះសារីបុត្រសួរហើយ ។ ព្រះថេរៈទាំង ២ នោះ អនុមោទនាភាសិតនៃគ្នានិងគ្នា បន្ទាប់មក ក្នុងកាលក្រោយ ព្រះសាស្តាទ្រង់ប្រថាប់គង់ត្រង់ចន្លោះភិក្ខុសង្ឃ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុដែលជាធម្មកថិក ។ល។

## អដ្ឋកថាសូត្រទី ៩ ចប់

# អដ្ឋកថា សូត្រទី ១០

# ប្រវត្តិ ព្រះមហាកច្ចាយនត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ដូចតទៅនេះ បទថា **សង្ខិត្តេន ភាសិតស្ស** សេចក្តីថា នៃធម៌ដែលត្រាស់ដោយសង្ខេប ។ បទថា **វិត្ថារេន អត្ថំ វិភជន្តានំ** សេចក្តីថា ចែកអត្ថចេញ ធ្វើទេសនានោះឲ្យពិស្តារ ។ បានឮថា ពួកភិក្ខុដទៃ មិនអាចធ្វើព្រះតម្រាស់ដោយសង្ខេបនៃព្រះតថាគត ឲ្យបរិបូណ៌ដោយអត្ថផង ដោយព្យញ្ជនៈផងបានឡើយ តែព្រះថេរៈនេះអាចធ្វើឲ្យបរិបូណ៌បានទាំង ២ យ៉ាង ព្រោះដូច្នោះ ទើបលោកពោលថាជាកំពូល ។ សូម្បីសេចក្តីប្រាថ្នាអំពីមុនរបស់ព្រះថេរៈ ក៏ប្រាថ្នាតែម្យ៉ាងយ៉ាងនេះ ។ ម្យ៉ាងទៀត ក្នុងបញ្ហាកម្មរបស់ព្រះថេរៈនោះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ

បានឮថា កាលព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះថេរៈនោះកើតក្នុងត្រកូលគហបតីមហាសាល ចម្រើនវ័យហើយ ថ្ងៃមួយ ទៅវិហារតាមន័យដែលពោលហើយនោះឯង ឈរស្តាប់ធម៌ខាងក្រោយបរិស័ទ ឃើញភិក្ខុមួយរូបដែលព្រះសាស្តាទ្រង់ស្ថាបនាក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ដែលចែកអត្ថនៃព្រះតម្រាស់ ដែលទ្រង់ត្រាស់ដោយសង្ខេបឲ្យពិស្តារ ទើបគិតថា ភិក្ខុដែលព្រះសាស្តាទ្រង់សរសើរយ៉ាងនេះ ជាធំហ្ន៎ ក្នុងអនាគតកាល អញក៏គួរមានសភាពដូចភិក្ខុអង្គនេះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយ ដូច្នេះ ។ ទើបនិមន្តព្រះសាស្តាថ្វាយមហាទានអស់ ៧ ថ្ងៃ តាមន័យដែលពោលមក ។ ក្រាបចុះទៀបបាទមូលរបស់ព្រះសាស្តា ធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏

ចម្រើន ដោយផលនៃសក្ការៈនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ តែក្នុងអនាគតកាល ខ្ញុំព្រះអង្គគប្បីបានតំណែងនោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គឯណាទីមួយ ដូចភិក្ខុដែលទ្រង់ស្ថាបនាក្នុងតំណែង កាលពី ៧ ថ្ងៃមុន ព្រះសាស្តាទ្រង់ប្រមើលមើលអនាគតកាល ទ្រង់ឃើញថា សេចក្តីប្រាថ្នារបស់កុលបុត្រនេះនឹងសម្រេច ទើបព្យាករថា ម្នាលកុលបុត្រដ៏ចម្រើន ក្នុងទីបំផុតនៃមួយសែនកប្ប ក្នុងអនាគត ព្រះពុទ្ធព្រះនាមគោតមទ្រង់កើតឡើង អ្នកនឹងបានជាកំពូលនៃពួកភិក្ខុ ដែលចែកអត្ថនៃពាក្យ ដែលត្រាស់ដោយសង្ខេបឲ្យពិស្តារ ក្នុងសាសនារបស់ព្រះមានព្រះភាគអង្គនោះ ដូច្នេះ ទ្រង់ធ្វើអនុមោទនាហើយ យាងត្រឡប់ទៅ ។

ចំណែកកុលបុត្រនោះ បំពេញកុសលដរាបអស់ជីវិតហើយ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយអស់មួយសែនកប្ប កាលសាសនាព្រះកស្សបសម្ពុទ្ធមកដល់ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងពារាណសី ។ កាលព្រះសាស្តាបរិនិព្វានហើយ ក៏ទៅកាន់ស្ថានទីសាងព្រះចេតិយមាស ទើបយកឥដ្ឋមាស មានតម្លៃមួយសែនបូជា តាំងសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ សរីរៈរបស់ខ្ញុំព្រះអង្គ សូមមានពណ៌ដូចមាស ក្នុងទីដែលខ្ញុំកើតហើយ បន្ទាប់អំពីនោះ ក៏ធ្វើកុសលកម្មដរាបដល់អស់ជីវិត វិលវល់ក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ កាលព្រះទសពលនៃយើងកើតឡើង លោកក៏កើតក្នុងត្រកូលនៃបុរោហិត ក្នុងក្រុងឧជ្ជេនី ក្នុងថ្ងៃដាក់ឈ្មោះ មាតាបិតាប្រឹក្សាគ្នាថា កូនរបស់យើងមានពណ៌ដូចមាស គង់នឹងនាំយកឈ្មោះមក

ជាមួយផង ទើបដាក់ឈ្មោះថា កាញ្ចនមាណព ដូច្នេះ ។

លុះលោកធំឡើងហើយ ក៏សិក្សាត្រៃវេទ កាលបិតាអស់ជីវិតហើយ ក៏បានតំណែងបុរោហិតជំនួស ដោយគោត្រ ឈ្មោះថា កច្ចាយនៈ ព្រះបាទចណ្ឌប្បជ្ជោត ទ្រង់ប្រជុំអមាត្យហើយ មានព្រះរាជតម្រាស់ថា ព្រះពុទ្ធទ្រង់កើតឡើងក្នុងលោកហើយ ពួកអ្នក ជាអ្នកអាចទូលអារាធនាព្រះអង្គមកបាន ក៏ចូរនាំព្រះអង្គមក ។ អមាត្យទូលថា បពិត្រសម្មតិទេព អ្នកដទៃ ឈ្មោះថា ជាអ្នកអាចនាំព្រះទសពលមកមិនមាន អាចារ្យកាញ្ចនព្រាហ្មណ៍ប៉ុណ្ណោះ ទើបជាអ្នកអាច សូមទ្រង់បញ្ជូនគាត់ទៅចុះ ព្រះអង្គ ។ ព្រះរាជាត្រាស់ហៅកច្ចាយនៈមក ត្រាស់ថា នែបា ចូរអ្នកទៅកាន់សម្នាក់របស់ព្រះទសពល ។ កច្ចាយនព្រាហ្មណ៍ទូលថា បពិត្រសម្មតិទេព បើខ្ញុំព្រះអង្គទៅហើយ បានបួស ទើបខ្ញុំព្រះអង្គទៅ ព្រះរាជាត្រាស់ថា អ្នកនឹងធ្វើអ្វីក៏ធ្វើចុះ ឲ្យតែនាំព្រះតថាគតមក ។ កច្ចាយនអមាត្យនោះគិតថា សម្រាប់អ្នកទៅកាន់សម្នាក់របស់ព្រះពុទ្ធ មិនចាំបាច់ធ្វើដោយចំនួនមនុស្សច្រើន ទើបទៅត្រឹមតែ ៨ នាក់ កាលនោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់អមាត្យនោះ ចប់ទេសនា លោកក៏បានសម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ជាមួយនឹងជនទាំង ៧ នាក់ ព្រះសាស្តាទ្រង់លាព្រះហស្តត្រាស់ថា **ឯថ ភិក្ខវោ** អ្នកទាំងឡាយចូរជាភិក្ខុចុះ ក្នុងខណៈនោះឯង ជនទាំងនោះក៏មានសក់ និងពុកមាត់បាត់ទៅទ្រទ្រង់បាត្រ និងចីវរ ដែលសម្រេចដោយឫទ្ធិ ដូចជាព្រះថេរៈមានវស្សា ១០០ ដូច្នោះ ។ ព្រះថេរៈកាលកិច្ចរបស់ខ្លួនដល់ទីបំផុតហើយ មិនគង់ស្ងៀម

ពោលសរសើរការយាងទៅកាន់ក្រុងឧជ្ជេនី ថ្វាយព្រះសាស្ដាដូចគ្នានឹងព្រះកាឡុទាយិត្ថេរដែរ ។ ព្រះសាស្ដាស្ដាប់វាចារបស់លោកហើយ ទ្រង់ជ្រាបថា កច្ចាយនៈបំណងការទៅរបស់តថាគត ក្នុងជាតិភូមិរបស់ខ្លួន តែធម្មតាព្រះពុទ្ធទាំងឡាយ អាស្រ័យហេតុឯណានីមួយ ទើបមិនយាងទៅកាន់ទីដែលមិនគួរយាង ។ ព្រោះដូច្នោះ ទើបត្រាស់ជាមួយព្រះថេរៈថា ម្នាលភិក្ខុ អ្នកនុ៎ះឯងចូរទៅ កាលអ្នកទៅហើយ ព្រះរាជាទ្រង់នឹងជ្រះថ្លា ។ ព្រះថេរៈគិតថា ព្រះពុទ្ធទាំងឡាយ មិនត្រាស់វាចាបែកជា ២ ឡើយ ដូច្នេះ ទើបថ្វាយបង្គំព្រះតថាគត ទៅកាន់ក្រុងឧជ្ជេនី មួយអន្លើដោយភិក្ខុទាំង ៧ រូបដែលមកជាមួយខ្លួននោះឯង ក្នុងរវាងផ្លូវ ភិក្ខុទាំងនោះបានត្រាច់បិណ្ឌបាត ក្នុងនិគមឈ្មោះថា នាលិនិគម ។

ក្នុងនិគមនោះ មានសេដ្ឋីធីតា ២ នាក់ មួយកើតក្នុងត្រកូលសេដ្ឋីបុរាណ ជាអ្នកក្រីក្រ កាលមាតាបិតាអនិច្ចកម្មទៅហើយ អាស្រ័យមេដោះចិញ្ចឹមជីវិត តែអត្តភាពរបស់នាងមោះមុត សក់វែងជាងអ្នកដទៃៗ ។ ក្នុងនិគមនោះមានសេដ្ឋីធីតាត្រកូលឥស្សរសេដ្ឋីម្នាក់ទៀត ជាអ្នកមិនមានសក់កាលអំពីមុននោះ មកពោលថា នាង សូមនាងឲ្យសក់ដល់ខ្ញុំ ខ្ញុំនឹងឲ្យទ្រព្យ ១០០ ឬ ១០០០ ដល់នាង ក៏នាងមិនអាចឲ្យបាន ។ ក្នុងថ្ងៃនោះ ធីតាសេដ្ឋីនោះឃើញព្រះមហាកច្ចយនៈ មានភិក្ខុ ៧ រូបជាបរិវារ និមន្តមកមានបាត្រទទេ គិតថា ភិក្ខុដែលជាពូជពង្សព្រាហ្មណ៍ម្នាក់ មានសម្បុរដូចមាសអង្គនេះដើរទៅ មានបាត្រទទេ ទ្រព្យដទៃរបស់អញមិនមាន ។ តែធីតាសេដ្ឋីស្រុក

ឯណោះ ធ្លាប់បញ្ជូនមនុស្សមក ដោយត្រូវការសក់ ពេលនេះ អញអាចឲ្យទេយ្យធម៌ដល់ព្រះថេរៈបាន ដោយទ្រព្យដែលកើតអំពីការលក់សក់នេះ ដូច្នេះទើបបញ្ជូនអ្នកបម្រើទៅនិមន្តព្រះថេរៈទាំងឡាយ ឲ្យគង់ក្នុងផ្ទះ លុះព្រះថេរៈគង់ហើយ ក៏ចូលបន្ទប់ កាត់សក់របស់ខ្លួន ពោលថា នែនាង ចូរយកសក់ខ្ញុំនេះឲ្យដល់ធីតាសេដ្ឋីនៅស្រុកឯណោះ ហើយយករបស់ដែលនាងឲ្យមក ខ្ញុំនឹងថ្វាយបិណ្ឌបាតដល់លោកម្ចាស់ទាំងឡាយ ។ អ្នកបម្រើយកខ្នងដៃជូតទឹកភ្នែក យកដៃម្ខាងទៀត ខ្ទប់ដើមទ្រូង បិទបាំងក្នុងសម្នាក់ព្រះថេរៈទាំងឡាយ កាន់សក់នោះទៅសម្នាក់របស់សេដ្ឋីធីតា ។ ធម្មតារបស់ដែលលក់សូម្បីមានសារៈ គឺតម្លៃដែលម្ចាស់ទ្រព្យនាំទៅឯង ក៏មិនធ្វើឲ្យកើតការខ្វាចក្រែងរអែងចិត្ត ។ ដូច្នោះ ទើបសេដ្ឋីធីតាគិតថា កាលមុន អញមិនអាចឲ្យនាំសក់ទាំងនេះមកបានដោយទ្រព្យដ៏ច្រើន តែឥឡូវនេះ តាំងអំពីកាលដែលកាត់ចេញហើយ ក៏មិនបានតម្លៃដូចមុន ទើបពោលនឹងអ្នកបម្រើថា ពីមុនខ្ញុំមិនអាចឲ្យនាំសក់មកដោយទ្រព្យដ៏ច្រើន តែសក់នេះនាំទៅទីណាក៏បាន មិនមែនសក់នៃមនុស្សរស់ មានតម្លៃត្រឹមតែ ៨ កហាបណៈ ទើបឲ្យ ៨ កហាបណៈប៉ុណ្ណោះ ។ អ្នកបម្រើនាំកហាបណៈមកឲ្យដល់សេដ្ឋីធីតា ។ សេដ្ឋីធីតារៀបចំបិណ្ឌបាតតែមួយសម្រាប់ឲ្យមានតម្លៃមួយកហាបណៈ ឲ្យទានដល់ព្រះថេរៈទាំងឡាយហើយ ។ ព្រះថេរៈពិចារណាហើយ ឃើញឧបនិស្ស័យសេដ្ឋីធីតា ទើបសួរថា សេដ្ឋីធីតាទៅណា ។ អ្នកបម្រើឆ្លើយថា នៅក្នុងបន្ទប់លោកម្ចាស់ ព្រះថេរៈពោលថា ចូរហៅនាងមក ។ ព្រះថេរៈពោលត្រឹមតែម្តង នាងមកដោយសេចក្តីគោរពក្នុងព្រះថេរៈ ថ្វាយបង្គំព្រះថេរៈ

ហើយ កើតនូវសទ្ធាដ៏ខ្លាំងក្លា បិណ្ឌបាតក៏តាំងទុកក្នុងស្រែដ៏បរិសុទ្ធ តែង ឲ្យវិបាកក្នុងបច្ចុប្បន្នជាតិនោះឯង ។ ព្រោះដូច្នោះ ដំណាលគ្នានឹងការថ្វាយបង្គំ ព្រះថេរៈ ទើបសក់ទាំងឡាយតាំងឡើងដូចប្រក្រតី ។

ឯព្រះថេរៈទាំងឡាយ កាន់យកបិណ្ឌបាតនោះ ហោះឡើងទៅ ទាំង សេដ្ឋីធីតានោះឃើញ ក៏ចុះត្រង់ព្រះរាជឧទ្យាន ឈ្មោះកញ្ចនៈ អ្នកយាមព្រះ រាជឧទ្យានឃើញព្រះថេរៈនោះហើយ ទើបចូលគាល់ព្រះរាជា ក្រាបទូលថា បពិត្រសម្មតិទេព លោកម្ចាស់កច្ចាយនបុរោហិតរបស់យើងបួសហើយ ត្រឡប់មក កាន់ឧទ្យានហើយ ។ ទើបព្រះបាទចណ្ឌប្បជ្ជោតយាងទៅកាន់ ឧទ្យាន ថ្វាយបង្គំព្រះថេរៈ ដែលធ្វើភត្តកិច្ចហើយ ដោយបញ្ចង្គប្រតិស្ឋាន រួចប្រថាប់គង់ក្នុងទីដ៏សមគួរ នាចំណែកម្ខាង ត្រាស់សួរថា បពិត្រលោកម្ចាស់ ព្រះមានព្រះភាគប្រថាប់នៅទីណា ។ ព្រះថេរៈទូលថា បពិត្រមហារាជ ទ្រង់ មិនបានយាងមកឯង ទ្រង់បញ្ជូនអាត្មាភាពមក ។ ព្រះរាជាត្រាស់សួរថា បពិត្រលោកម្ចាស់ ថ្ងៃនេះ លោកម្ចាស់បានភិក្ខាក្នុងទីណា ។ ព្រះថេរៈ ទូលរឿងដែលធ្វើបានដោយលំបាក ដែលសេដ្ឋីធីតាធ្វើគ្រប់យ៉ាងឲ្យព្រះរាជា ទ្រង់ជ្រាប តាមពាក្យដែលគួរដល់ព្រះតម្រាស់ ។ ព្រះរាជាត្រាស់ឲ្យរៀបចំទី នៅដល់ព្រះថេរៈហើយ និមន្តព្រះថេរៈទៅកាន់និវេសន៍ ហើយបញ្ជាឲ្យទៅនាំ សេដ្ឋីធីតាមកតាំងទុកក្នុងតំណែងអគ្គមហេសី ។ ការបានយសក្នុងបច្ចុប្បន្ន-ជាតិមានហើយដល់ស្រីនេះ ចាប់តាំងអំពីកាលនោះ ព្រះរាជាទ្រង់ធ្វើសក្ការៈ ធំដល់ព្រះថេរៈ មហាជនជ្រះថ្លាក្នុងធម្មកថារបស់ព្រះថេរៈ បួសក្នុងសម្នាក់នៃ

ព្រះថេរៈ ។ ចាប់តាំងអំពីកាលនោះ ព្រះនគរក៏រុងរឿង ពេញទៅដោយកាសាវពស្ត្រតែមួយដូចគ្នា ដេរដាសទៅដោយពួកឥសី ។ ឯព្រះទេវីទ្រង់ព្រះគភ៌ លុះកន្លងទសមាស ក៏ប្រសូតព្រះឱរស ក្នុងថ្ងៃថ្វាយព្រះនាមឱរសនោះ ព្រះញាតិទាំងឡាយ បានថ្វាយព្រះនាមឲ្យដូចនាមសេដ្ឋីជីតាថា គោបាលកុមារ ។ ព្រះមាតាក៏មានព្រះនាមថា គោបាលមាតាទេវី តាមឈ្មោះរបស់ព្រះឱរស ។ ព្រះនាងជ្រះថ្លាក្នុងព្រះថេរៈក្រៃលែង សូមព្រះរាជានុញ្ញាតសាងវិហារប្រគេនព្រះថេរៈ ក្នុងកញ្ចនរាជឧទ្យាន ។ ព្រះថេរៈញុំាងអ្នកក្រុងឧជ្ជេនីឲ្យជ្រះថ្លា រួចចូលគាល់ព្រះសាស្តាម្តងទៀត បន្ទាប់មក ព្រះសាស្តា កាលប្រថាប់នៅក្នុងជេតពនមហាវិហារ ទ្រង់ធ្វើព្រះសូត្រ ៣ សូត្រ គឺមធុបិណ្ឌិកសូត្រ កញ្ចាយនបេយ្យាលសូត្រ បារាយនសូត្រ ឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូល នៃពួកភិក្ខុដែលចែកអត្ថនៃព្រះតម្រាស់ ដែលទ្រង់ត្រាស់ដោយសង្ខេប ឲ្យពិស្តារហើយ ។

**អដ្ឋកថា សូត្រទី ១០ ចប់**

**វគ្គទី ១ ចប់**

# ឯតទគ្គបាលិ

## វគ្គទី ២

[ ១៤៧ ] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកនិមិត្តកាយ សម្រេចតាមចិត្តបាន ដែលជាសាវ័ករបស់តថាគត ស្រេចនឹងចុល្លបន្ថកៈប្រសើរជាងគេ ។ ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកចិត្ត ស្រេចនឹងចុល្លបន្ថកៈ ។ ពួកភិក្ខុអ្នកឈ្លាសក្នុងការបើកប្រាជ្ញា ស្រេចនឹងមហាបន្ថកៈ ។ ពួកភិក្ខុអ្នកនៅដោយឥតកិលេស ស្រេចនឹងសុភូតិ ។ ពួកភិក្ខុអ្នកគួរដល់ទក្ខិណាទាន ស្រេចនឹងសុភូតិ ។ ពួកភិក្ខុអ្នកនៅក្នុងព្រៃ ស្រេចនឹងរេវតខទិរវនិយៈ ។ ពួកភិក្ខុអ្នកបានឈាន ស្រេចនឹងកង្ខារេវតៈ ។ ពួកភិក្ខុអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងសោណកោលិវិសៈ ។ ពួកភិក្ខុអ្នកពោលពាក្យពីរោះ ស្រេចនឹងសោណកុដិកណ្ណៈ ។ ពួកភិក្ខុអ្នកមានលាភ ស្រេចនឹងសីវលិ ។ ពួកភិក្ខុអ្នកមានសទ្ធាស៊ប់ ស្រេចនឹងវក្កលិ ។

*វគ្គទី ២ ចប់*

# វគ្គទី ២

# អដ្ឋកថា សូត្រទី ១ និងទី ២

## ប្រវត្តិ ព្រះចូឡបន្ថកត្ថេរ និងព្រះមហាបន្ថកត្ថេរ

[ ១៤៧ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ និងសូត្រទី ២ នៃវគ្គទី ២ ដូចតទៅនេះ បទថា **មនោមយំ** សេចក្តីថា កាយដែលកើតឡើងដោយចិត្ត ក្នុងអាគតដ្ឋានដែលត្រាស់ថា ចូលទៅរកហើយ ដោយមនោមយិទ្ធិផ្លូវកាយ ឈ្មោះថា កាយមនោមយ ។ កាយដែលកើតឡើងដោយចិត្ត ក្នុងអាគតដ្ឋាន ដែលត្រាស់ថា រមែងចូលដល់កាយដែលសម្រេចដោយចិត្តឯណានីមួយ ក៏ឈ្មោះថា កាយមនោមយ ក្នុងទីនេះ បំណងយកកាយមនោមយនេះ ។

ក្នុងកាយទាំង ២ យ៉ាងនេះ ភិក្ខុទាំងឡាយដទៃ កាលធ្វើមនោមយកាយឲ្យកើតឡើង ក៏ធ្វើឲ្យកើតឡើង ៣ ខ្ទះ ៤ ខ្ទះ តែធ្វើមនុស្សម្នាច្រើនឲ្យកើតដូចគ្នាតែមួយមិនបាន ។ ឈ្មោះថា ធ្វើកម្មបានតែម្យ៉ាងប៉ុណ្ណោះ ។ ចំណែកព្រះថេរៈឈ្មោះថា ចូឡបន្ថកៈនិម្មិតភិក្ខុ ១០០០ រូបបាន ដោយអាវជ្ជនៈ ១ តែធ្វើមនុស្ស ២ នាក់ឲ្យដូចគ្នាតែមួយមិនបាន ឈ្មោះថា ធ្វើកម្មតែម្យ៉ាងមិនបាន ។ ព្រោះដូច្នោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលនិម្មិតមនោមយកាយ ព្រះចូឡបន្ថកៈរាប់ថាជាកំពូលនៃពួកភិក្ខុ គឺភិក្ខុដែលឈ្លាសក្នុងចេតោវិវដ្ដៈ ។ ឯព្រះមហាបន្ថកត្ថេរ លោកពោលថា ជាកំពូលនៃពួកភិក្ខុដែលឈ្លាសក្នុងបញ្ញាវិវដ្ដៈ ។ បណ្តាភិក្ខុ ២ រូបនោះ ព្រះចូឡបន្ថកត្ថេរ

លោកពោលថា ជាអ្នកឈ្លាសក្នុងចេតោវិវដ្ដៈ ព្រោះបានរូបាវចរជ្ឈាន ៤ ។ ព្រះមហាបន្ថកត្ថេរ លោកពោលថា ជាអ្នកឈ្លាសក្នុងបញ្ញាវិវដ្ដៈ ព្រោះជាអ្នកឈ្លាសក្នុងសមាបត្តិ ។ ព្រះមហាបន្ថកៈ ឈ្មោះថា ជាអ្នកឈ្លាសក្នុងបញ្ញាវិវដ្ដៈ ព្រោះជាអ្នកឈ្លាសក្នុងវិបស្សនា ។ ម្យ៉ាងទៀត ក្នុងភិក្ខុ ២ រូបនេះ មួយរូបឈ្លាសក្នុងលក្ខណៈសមាធិ មួយរូបឈ្លាសក្នុងលក្ខណៈនៃវិបស្សនា មួយរូបឈ្លាសក្នុងការឈានចុះកាន់សមាធិ មួយរូបឈ្លាសក្នុងការចុះកាន់វិបស្សនា ម្យ៉ាងទៀត ក្នុងភិក្ខុ ២ រូបនេះ មួយរូបឈ្លាសក្នុងការសង្ខេបអង្គ មួយរូបឈ្លាសក្នុងសង្ខេបអារម្មណ៍ ។ ម្យ៉ាងទៀត មួយអង្គឈ្លាសក្នុងការកំណត់អង្គ មួយអង្គទៀតឈ្លាសក្នុងការកំណត់អារម្មណ៍ គប្បីធ្វើការប្រកបសេចក្ដីក្នុងភិក្ខុ ២ រូបនេះ ដោយប្រការដូចពោលមកនេះ ម្យ៉ាងទៀត ព្រះចូឡបន្ថកត្ថេរជាអ្នកបានរូបាវចរជ្ឈាន ចេញអំពីអង្គឈានហើយសម្រេចអរហត្ត ដូច្នោះ ទើបឈ្មោះថា ជាអ្នកឈ្លាសក្នុងចេតោវិវដ្ដៈ ព្រះមហាបន្ថកៈជាអ្នកបានអរូបាវចរជ្ឈាន ចេញអំពីអង្គឈានហើយ សម្រេចអរហត្ត ដូច្នោះ ទើបឈ្មោះថា ជាអ្នកឈ្លាសក្នុងបញ្ញាវិវដ្ដៈ ។ ព្រះថេរៈទាំង ២ រូប ដែលមានឈ្មោះថា បន្ថកៈ ព្រោះលោកកើតត្រង់ផ្លូវ ។ ទាំង ២ រូបនោះ ព្រះថេរៈដែលកើតមុន ឈ្មោះថា មហាបន្ថកៈ មួយរូបទៀតឈ្មោះថា ចូឡបន្ថកៈ ក្នុងបញ្ហាកម្មនៃព្រះថេរៈទាំង ២ រូបនេះ មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះថា

ក្នុងអតីតកាល ក្នុងកាលព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ មានកុដុម្ពិកៈ ២

នាក់បងប្អូន ជាអ្នកក្រុងហង្សវតី ជ្រះថ្លាក្នុងព្រះសាស្តា ទៅស្តាប់ធម៌ ក្នុងសម្នាក់ព្រះសាស្តាជានិច្ច ។ ក្នុងកុដុម្ពិក: ២ នាក់បងប្អូននោះ ថ្ងៃមួយ បងប្រុសឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូប ដែលប្រកបដោយអង្គ ២ ទុកក្នុងតំណែងឯតទគ្គ:ថា ភិក្ខុរូបនេះ ជាកំពូលនៃពួកភិក្ខុ ដែលនិម្មិតកាយកាយមនោមយ និងជាអ្នកឈ្លាសក្នុងចេតោវិវដ្ដ: ក្នុងសាសនារបស់តថាគត ទើបគិតថា គួរអស្ចារ្យហ្ន៎ ភិក្ខុនេះជាបុគ្គលតែមួយ ធ្វើអង្គ ២ ឲ្យបរិបូណ៌ប្រព្រឹត្តទៅបាន ឯអាត្មាអញ ក៏គួរជាបុគ្គលបំពេញអង្គ ២ ត្រាច់ទៅក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូច្នេះ ទើបបុរសនោះនិមន្តព្រះសាស្តា ថ្វាយមហាទានដោយន័យមុននោះឯង ហើយទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុដែលទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គ:ថា ជាកំពូលក្នុងសាសនារបស់ព្រះអង្គ ដោយអង្គមនោមយ និងដោយភាពជាអ្នកឈ្លាសក្នុងចេតោវិវដ្ដ: កាលពី ៧ ថ្ងៃមុន ឯខ្ញុំព្រះអង្គ ក៏គប្បីជាអ្នកបំពេញអង្គ ២ ឲ្យបរិបូណ៌ដូចភិក្ខុនោះ ដោយផលនៃកម្មដែលជាអធិការនេះចុះ ព្រះសាស្តាទ្រង់សម្លឹងមើលអនាគត ក៏ទ្រង់ឃើញថា ការប្រាថ្នានឹងសម្រេចដោយមិនមានអន្តរាយឡើយ ទ្រង់ព្យាករថា ក្នុងអនាគត ក្នុងទីបំផុតនៃមួយសែនកប្ប ព្រះពុទ្ធព្រះនាមគោតម ទ្រង់នឹងកើតឡើង ទ្រង់នឹងស្ថាបនាអ្នកក្នុងឋាន: ២ នេះ ដូច្នេះ ទ្រង់ធ្វើអនុមោទនា ហើយយាងត្រឡប់ទៅ ។

ឯបងប្រុសរបស់លោក ក្នុងថ្ងៃមួយ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុដែលឈ្លាសក្នុងបញ្ញាវិវដ្ដ: ទុកក្នុងតំណែងឯតទគ្គ: ក៏ធ្វើបុណ្យកុសល

យ៉ាងនោះ ធ្វើសេចក្ដីប្រាថ្នាហើយ ព្រះសាស្ដាក៏ទ្រង់ព្យាករលោកហើយ ។ ទាំង ២ នាក់បងប្អូននោះ កាលព្រះសាស្ដាគង់ព្រះជន្មាយុនៅឡើយ ធ្វើកុសលកម្មហើយ កាលព្រះសាស្ដាបរិនិព្វានហើយ បានបូជាដោយមាសត្រង់ព្រះចេតិយ បញ្ចុះព្រះសរីរៈ ចុតិអំពីភពនោះហើយ ទៅកើតក្នុងទេវលោក កាល ២ នាក់ បងប្អូនអន្ទោលទៅមកក្នុងទេវតា និងមនុស្ស កន្លងទៅអស់សែនកប្ប ក្នុងជនទាំង ២ នោះ ខ្ញុំមិនពោលកល្យាណកម្មដែលមហាបន្ថកៈធ្វើក្នុងអន្តរភព ឯចូឡបន្ថកៈ បេញបួសក្នុងសាសនារបស់ព្រះមានព្រះភាគព្រះនាមកស្សបៈ ចម្រើនឱទាតកសិណ កន្លងទៅ ២ ម៉ឺនឆ្នាំ ទៅកើតក្នុងស្ថានសួគ៌ ខាងក្រោយកាលព្រះសាស្ដានៃយើង ទ្រង់ត្រាស់ដឹងអភិសម្ពោធិញ្ញាណ ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ហើយទ្រង់អាស្រ័យក្រុងរាជគ្រឹះប្រថាប់នៅក្នុងជេតពនមហាវិហារ គួរនឹងពោលដល់ការកើតឡើងនៃជនទាំង ២ នោះ ។

បានឮថា កុលធីតារបស់ធនសេដ្ឋី ក្នុងក្រុងរាជគ្រឹះ ធ្វើការប្រព្រឹត្តខុសក្នុងទាសៈរបស់ខ្លួនឯង ខ្លាចអ្នកដទៃដឹងកម្មរបស់ខ្លួន ទើបពោលយ៉ាងនេះថា យើងមិនអាចនៅក្នុងទីនេះបានទេ បើមាតាបិតារបស់យើងដឹងនូវការធ្វើខុសនេះ នឹងធ្វើយើងឲ្យជាចម្រៀកតូច-ធំ ដូច្នេះ យើងទៅកាន់ទឹកដីដទៃជាមួយគ្នាចុះ ហើយកាន់យកតែរបស់សំខាន់ជាប់ដៃទៅ ហើយនាំគ្នាចេញតាមទ្វារធំទៅកាន់លំនៅដែលមិនមានអ្នកដទៃស្គាល់ ។ ជនទាំង ២ ក៏នាំគ្នាចេញទៅ កាលជនទាំង ២ នោះ នៅក្នុងទីមួយកន្លែង អាស្រ័យការនៅរួមគ្នា នាងក៏

មានគភ៌ហើយ លុះគភ៌ចាស់ខែ ទើបនាងប្រឹក្សាជាមួយប្តីថា គភ៌យើងចាស់ហើយ ធម្មតាការប្រសូតិក្នុងទីដែលមិនមានញាតិសាលោហិត ជាការលំបាកដល់យើងទាំង ២ ពិត យើងទៅផ្ទះត្រកូលជាមួយគ្នាចុះ ។ស្វាមីពោលបណ្តោះបណ្តែថា ថ្ងៃនេះនឹងទៅ ស្អែកនេះសឹមទៅ រហូតកន្លងទៅច្រើនថ្ងៃ ទើបនាងគិតថា បុរសនេះ ជាអ្នកល្ងង់ខ្លៅ មិនមានការក្លាហាន ណ្ហើយចុះអញគួរទៅ ។ កាលប្តីចេញអំពីផ្ទះទៅ ក៏ទុកដាក់របស់របរក្នុងផ្ទះ ប្រាប់ដល់អ្នកជិតខាងថា ខ្ញុំទៅផ្ទះត្រកូលហើយ ក៏ចេញដើរទៅ ។ ខណៈពេលបុរសនោះត្រឡប់មកផ្ទះ មិនឃើញនាង សួរអ្នកជិតខាង ដឹងថា ទៅផ្ទះត្រកូលទើបប្រញាប់ប្រញាល់រត់តាម ទាន់ក្នុងរវាងផ្លូវ នាងក៏ប្រសូតបុត្រ ក្នុងទីនោះឯង ។ បុរសនោះសួរថា នេះជាអ្វី នាងដ៏ចម្រើន ។ នាងឆ្លើយថា នែអ្នកកូនយើងកើតម្នាក់ហើយ ។ បុរសនោះសួរថា ឥឡូវនេះ យើងនឹងធ្វើអ្វី នាងពោលថា យើងទៅកាន់ផ្ទះត្រកូលដើម្បីប្រយោជន៍ណា ប្រយោជន៍នោះសម្រេចហើយក្នុងចន្លោះ យើងទៅទីនោះនឹងធ្វើដូចម្តេច ណ្ហើយចុះ យើងត្រឡប់ទៅវិញជាមួយគ្នាចុះ ។ ពីរនាក់ប្តីប្រពន្ធមានចិត្តត្រូវគ្នា ទើបវិលត្រឡប់ ។ ពីរនាក់ភរិយាស្វាមីបានដាក់ឈ្មោះកូនថា បន្ថក: ព្រោះទារកនោះកើតត្រង់ផ្លូវ មិនយូរប៉ុន្មាននាងក៏តាំងគភ៌ម្តងទៀត រឿងទាំងអស់គប្បីពោលឲ្យពិស្តារ ដោយន័យមុននោះឯង ។ ជនទាំងទាំង ២ ដាក់ឈ្មោះបុត្រដែលកើតមុនថា មហាបន្ថក: បុត្រដែលកើតក្រោយថា ចូឡបន្ថក: ព្រោះទារកទាំង ២ នោះ កើតត្រង់ផ្លូវ ជនទាំង ២ នោះនាំទារកទាំង ២ ទៅកាន់លំនៅ

របស់ខ្លួនដូចមុន ។

កាលជនទាំងនោះនៅក្នុងទីនោះ កុមារមហាបន្ថកៈបានឮក្មេងដទៃហៅពូ អ៊ំ តា យាយ ទើបសួរម្តាយថា បពិត្រអ្នកម៉ែ កុមារដទៃហៅតា ហៅយាយ ញាតិនៃពួកយើងក្នុងទីនេះមិនមានខ្លះទេឬ នាងឆ្លើយថា ពិតហើយកូន ញាតិរបស់យើងក្នុងទីនេះ មិនមានទេ តែក្នុងក្រុងរាជគ្រឹះ តារបស់ឯងឈ្មោះធនសេដ្ឋី ក្នុងក្រុងរាជគ្រឹះនោះ ញាតិរបស់ឯងមានច្រើន ។ កុមារសួរថា ហេតុអ្វី ទើបមិនទៅកាន់ក្រុងរាជគ្រឹះនោះ ។ នាងមិនបានពោលរឿងរ៉ាវអំពីដើមដល់បុត្រ កាលបុត្រពោលរឿយៗ ទើបប្រាប់ប្តីថា ទារកទាំងនេះរំខានយើងពន់ពេក មាតាបិតារបស់យើងឃើញហើយនឹងស៊ីសាច់ឬ ណ្ហើយចុះ យើងនឹងបង្ហាញត្រកូលតាយាយដល់ទារក ។ ស្វាមីពោលថា ខ្ញុំមិនអាចជួបមុខគាត់បានទេ តែអាចជូនទៅបាន នាងពោលថា សាធុ យើងគួរឲ្យកូនឃើញត្រកូលជីតា ដោយឧបាយឯណាមួយ ទើបគួរ ។ ទើបជនទាំង ២ នាំទារកទៅរហូតដល់ក្រុងរាជគ្រឹះដោយលំដាប់ សម្រាកត្រង់សាលាមួយកន្លែង ក្បែរទ្វារនគរ ម្តាយរបស់ទារកបញ្ជូនដំណឹងទៅប្រាប់ដល់មាតាបិតាថា ខ្លួននាំកុមារ ២ នាក់មក ជម្មតាសត្វដែលអន្ទោលទៅមកក្នុងសង្សារវដ្តឈ្មោះថា មិនធ្លាប់ជាបុត្រ មិនធ្លាប់ជាធីតាមិនមាន ។ មាតាបិតានោះបានស្តាប់ដំណឹងហើយ បញ្ជូនពាក្យតបទៅថា ជនទាំង ២ បានធ្វើខុសចំពោះយើងច្រើន មិនអាចនៅក្នុងគន្លងចក្ខុនៃយើងបានទេ ទាំង ២ នាក់ចូរកាន់យកទ្រព្យមានប្រមាណប៉ុណ្ណេះ ទៅនៅទីណាដែលជាផាសុកចុះ តែចូរបញ្ជូន

ទារកមកឲ្យយើង ។ ធីតាសេដ្ឋីទទួលយកទ្រព្យដែលមាតាបិតាបញ្ជូនទៅ ហើយប្រគល់ក្មេងទាំង ២ ទុកក្នុងដៃទូត ដែលមកហើយនោះឯង ក្មេងទាំង ២ នោះ ធំចម្រើនវ័យក្នុងត្រកូលនៃជីតា ។

ពីរនាក់បងប្អូននោះ ចូឡបន្ថកៈនៅតូចពេក ឯមហាបន្ថកៈទៅស្តាប់ធម្មកថារបស់ព្រះទសពល មួយអន្លើជាមួយជីតា កាលកំពុងស្តាប់ធម៌ចំពោះព្រះភក្ត្រព្រះសាស្តា ចិត្តក៏បង្អោនទៅក្នុងបព្វជ្ជា ទើបពោលនឹងជីតាថា បើលោកតាអនុញ្ញាត ចៅនឹងចេញបួស ជីតាពោលថា ចៅនិយាយអ្វី ការចេញបួសរបស់ចៅ ជាការចម្រើនដល់តាផង ដល់លោកទាំងមូលផង បើចៅអាច ក៏ចូរបួសចុះ ដូច្នេះ ទទួលពាក្យហើយ នាំគ្នាទៅកាន់សម្នាក់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា លោកសេដ្ឋី អ្នកបានទារកហើយឬ សេដ្ឋីពោលថា ករុណា ព្រះអង្គ ទារកនេះជាចៅរបស់ខ្ញុំព្រះអង្គ គេប្រាប់ថា ចង់បួសក្នុងសម្នាក់នៃព្រះអង្គ ។ ទើបព្រះសាស្តាត្រាស់នឹងភិក្ខុដែលសមាទានបិណ្ឌបាតជាវត្តមួយរូបថា អ្នកចូរឲ្យទារកនេះបួសចុះ ព្រះថេរៈប្រាប់តចបញ្ចកកម្មដ្ឋានដល់ទារកនោះហើយ ឲ្យបព្វជ្ជាហើយ ។ លោករៀនពុទ្ធវចនៈបានច្រើន មានវស្សាគ្រប់ហើយ ក៏ឧបសម្បទា លុះឧបសម្បទាហើយ ក៏ធ្វើកិច្ចកម្មក្នុងការដាក់ចិត្ត ដោយយោនិសោមនសិការ រហូតបានអរូបាវចរជ្ឈាន ៤ ចេញអំពីអង្គឈានហើយ បានសម្រេចអរហត្ត ដូច្នោះ ទើបលោកជាកំពូលនៃបណ្តាភិក្ខុដែលឈ្លាសក្នុងបញ្ញាវិវដ្ដៈ ។

លោកសម្រាកសម្រាន្តនៅ ដោយសេចក្តីសុខក្នុងឈាន សេចក្តីសុខ

ក្នុងមគ្គ សេចក្តីសុខក្នុងនិព្វាន ទើបគិតថា អាត្មាអញអាចឲ្យសេចក្តីសុខនេះ ដល់ចូឡបន្ថកៈបានឬទេហ្ន៎ បន្ទាប់ពីនោះ ទើបទៅកាន់សម្នាក់របស់សេដ្ឋីជាជីតា ពោលថា លោកមហាសេដ្ឋី បើលោកអនុញ្ញាត អាត្មានឹងឲ្យចូឡបន្ថកៈបួស សេដ្ឋីពោលថា សូមលោកម្ចាស់ឲ្យបួសចុះ ព្រះថេរៈឲ្យចូឡបន្ថកៈបួសហើយ តាំងនៅក្នុងសីល ១០ សាមណេរចូឡបន្ថកៈរៀនគាថា ក្នុងសម្នាក់របស់លោកបងថា ដូច្នេះ

**បទុមំ យថា កោកនុទំ សុគន្ធំ**

**បាតោ សិយា ផុល្លមវីតគន្ធំ**

**អង្គីរសំ បស្ស វិរោចមានំ**

**តបន្តមាទិច្ចមិវន្តលិក្ខេ ។**

ផ្កាឈូកឈ្មោះកោកនុទៈ មានក្លិនក្រអូប រីកអំពីព្រឹក មានក្លិនមិនបានទៅប្រាស យ៉ាងណាមិញ អ្នកចូរមើល ព្រះដ៏មានព្រះភាគ មានរស្មីផ្សាយចេញពីព្រះអង្គដ៏រុងរឿង ដូចព្រះអាទិត្យដែលរុងរឿង ក្នុងកណ្តាលពពក ក៏យ៉ាងនោះឯង ។

បទដែលលោករៀនហើយក៏បាត់ទៅ កាលរៀនបទខាងមុខៗ បទខាងក្រោយក៏ភ្លេចទៅ លោកព្យាយាមរៀនគាថានេះតែមួយ អស់កាល ៤ ខែ ។ គ្រានោះ ព្រះមហាបន្ថកៈពោលនឹងលោកថា បន្ថកៈ អ្នកជាអភព្វបុគ្គលក្នុងសាសនានេះ អ្នកចាំគាថាមួយបាទក៏មិនបាន សូម្បីអស់កាល ៤ ខែ អ្នក

ធ្វើកិច្ចរបស់បព្វជិតឲ្យសម្រេចបានដូចម្តេច អ្នកចូរចេញទៅអំពីទីនេះ ។ លោកត្រូវព្រះថេរៈបណ្តេញ ទើបឈរយំខាងចុងព្រះវិហារ ។

សម័យនោះ ព្រះសាស្តាទ្រង់ចូលអាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងជីវកម្ពវ័ន គឺចម្ការស្វាយរបស់ពេទ្យជីវក ។ គ្រានោះ ពេទ្យជីវកប្រើបុរសទៅនិមន្តព្រះសាស្តា មួយអន្លើដោយភិក្ខុ ៥០០ សម័យនោះ ព្រះមហាបន្ថកៈ ជាអ្នកចាត់ចែងភត្ត កាលបុរសនោះពោលនិមន្តថា បពិត្រលោកម្ចាស់ សូមនិមន្តភិក្ខុ ៥០០ រូប លោកក៏ពោលថា អាត្មាទទួលសម្រាប់ភិក្ខុដ៏សេស វៀរតែចូឡបន្ថកៈចេញ ។ ព្រះចូឡបន្ថកៈបានស្តាប់ពាក្យនោះ ក៏ទោមនស្សពន់ពេក ព្រះសាស្តាឃើញព្រះចូឡបន្ថកៈកំពុងយំ ទ្រង់ព្រះតម្រិះថា ចូឡបន្ថកៈ កាលតថាគតទៅ ក៏នឹងបានត្រាស់ដឹង ទើបទ្រង់យាងទៅបង្ហាញខ្លួនក្នុងទីមិនឆ្ងាយ ហើយត្រាស់ថា បន្ថកៈ អ្នកយំអ្វី ព្រះចូឡបន្ថកៈពោលថា បពិត្រព្រះអង្គដ៏ចម្រើន បងប្រុសបណ្តេញខ្ញុំព្រះអង្គ ព្រះមានព្រះភាគត្រាស់ថា ម្នាលបន្ថកៈ បងប្រុសរបស់អ្នក មិនមានអាសយានុសយញ្ញាណសម្រាប់បុគ្គលដទៃ អ្នកឈ្មោះថា ជាពុទ្ធវេនេយ្យបុគ្គល ដូច្នេះ ទ្រង់បណ្តាលឫទ្ធិប្រគល់សំពត់ស្អាតមួយផ្ទាំងតូច ត្រាស់ថា ម្នាលបន្ថកៈ អ្នកចូរយកសំពត់នេះ បរិកម្មថា **រជោ ហរណំ រជោ ហរណំ** ដូច្នេះ ។

លោកអង្គុយយកដៃអង្អែលកំណាត់សំពត់ ដែលព្រះសាស្តាប្រទាននោះ ភាវនាថា **រជោ ហរណំ រជោ ហរណំ** កាលលោកកំពុងអង្អែលសំពត់នោះក៏សៅហ្មង កាលលោកអង្អែលរឿយៗ ក៏ក្លាយដូចជាសំពត់ជូត

ឆ្នាំងបាយ ។ លោកអាស្រ័យការចាស់ក្លានៃញាណ ផ្ដើមទុកក្នុងចិត្តដោយការអស់ទៅ និងសូន្យទៅក្នុងសំពត់នោះ គិតថា សំពត់នេះ ដោយប្រក្រតីស្អាតបរិសុទ្ធ ព្រោះអាស្រ័យឧបាទិន្នកសរីរៈ ទើបសៅហ្មង ចិត្តនេះក៏មានគតិយ៉ាងនេះដូចគ្នា រួចចម្រើនសមាធិ ធ្វើរូបាវចរជ្ឈាន ៤ ឲ្យប្រាកដ សម្រេចអរហត្ត ព្រមដោយបដិសម្ភិទា ហើយលោកជាអ្នកបានឈានដោយមនោមយិទ្ធិនោះឯង អាចធ្វើមនុស្សម្នាក់ ឲ្យជាច្រើននាក់បាន ច្រើននាក់ឲ្យជាម្នាក់បាន ព្រះត្រៃបិដក និងអភិញ្ញា ៦ មកដល់លោកព្រមនឹងអរហត្តមគ្គនោះឯង ។

ស្អែកឡើង ព្រះសាស្ដាយាងទៅមួយអន្លើដោយភិក្ខុ ៥០០ ប្រថាប់គង់ក្នុងនិវេសន៍នៃពេទ្យជីវក ឯព្រះចូឡបន្ថកៈមិនបានទៅ ព្រោះខ្លួនមិនបានទទួលនិមន្តនោះឯង ។ ជីវកផ្ដើមថ្វាយបបរ ព្រះសាស្ដាទ្រង់យកព្រះហស្ដបិទបាត្រ ជីវកទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន តើព្រោះហេតុអ្វី ទើបទ្រង់មិនទទួល ព្រះមានព្រះភាគត្រាស់ថា នៅមានភិក្ខុមួយរូបទៀតក្នុងវិហារ ទេព្យជីវកបញ្ជូនបុរសទៅថា នែបា អ្នកចូរទៅនិមន្តលោកម្ចាស់ដែលនៅក្នុងវិហារមក ។ ព្រះចូឡបន្ថកត្ថេរនិម្មិតភិក្ខុ ១០០០ រូប ក្នុងវេលាទៀបបុរសនោះមកដល់ ធ្វើមិនឲ្យដូចគ្នា គឺមួយអង្គៗ ធ្វើកិច្ចរបស់សមណៈ ដូចជាគក់ចីវរ គឺមិនឲ្យដូចគ្នានឹងអង្គដទៃៗ ។ បុរសនោះ ឃើញភិក្ខុមានច្រើនក្នុងវិហារ ទើបត្រឡប់ទៅប្រាប់ពេទ្យជីវកថា លោកម្ចាស់ ភិក្ខុក្នុងវិហារនេះមានច្រើន ខ្ញុំមិនស្គាល់លោកដែលគប្បីនិមន្តមកអំពីវិហារនោះ ។ ទើបពេទ្យជីវក

សួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុនៅក្នុងវិហារឈ្មោះអ្វី ព្រះសាស្តាត្រាស់ថា ឈ្មោះចូឡបន្ថកៈ ។ ពេទ្យជីវកពោលនឹងបុរសនោះថា នែបា អ្នកចូរទៅសួរថា អង្គណា ឈ្មោះចូឡបន្ថកៈ ហើយនាំមក ។

បុរសនោះទៅកាន់វិហារ សួរថា លោកម្ចាស់អង្គណា ឈ្មោះចូឡ-បន្ថកៈ លោកពោលថា អាត្មាឈ្មោះចូឡបន្ថកៈ អាត្មាឈ្មោះចូឡបន្ថកៈ ទាំង ១០០០ អង្គ ។ បុរសនោះត្រឡប់មកប្រាប់ពេទ្យជីវកទៀតថា ភិក្ខុប្រមាណ ១០០០ រូប គ្រប់អង្គប្រាប់ថា អាត្មាឈ្មោះចូឡបន្ថកៈ អាត្មាឈ្មោះចូឡបន្ថកៈ ខ្ញុំមិនដឹងថា អង្គណាចូឡបន្ថកៈ ដែលលោកឲ្យនិមន្ត ។ ពេទ្យជីវកជ្រាបបានដោយន័យថា ភិក្ខុមានឫទ្ធិ ព្រោះត្រាស់ដឹងសច្ចៈហើយ ទើបពោលថា នែបា អ្នកចូរចាប់ជាយចីវរភិក្ខុអង្គណាដែលពោលមុន បុរសនោះទៅកាន់វិហារធ្វើយ៉ាងនោះហើយ ខណៈនោះ ភិក្ខុប្រមាណ ១០០០ រូបក៏អន្តរធានទៅ ។ បុរសនោះនាំព្រះថេរៈមកហើយ ទើបព្រះសាស្តាទ្រង់ទទួលបបរក្នុងខណៈនោះ ។

កាលព្រះសាស្តា ធ្វើភត្តកិច្ចស្រេចហើយ ទ្រង់ត្រឡប់ទៅកាន់វិហារ ក៏កើតការសន្ទនាគ្នាឡើងក្នុងធម្មសភាថា ធម្មតាព្រះពុទ្ធទាំងឡាយ ធំដល់ម្ល៉ោះហ្ន៎ ទ្រង់ធ្វើភិក្ខុដែលមិនអាចចាំគាថា សូម្បីតែមួយបាទអស់ ៤ ខែ ឲ្យជាអ្នកមានឫទ្ធិច្រើនយ៉ាងនេះបាន ព្រះសាស្តាទ្រង់ជ្រាបវារៈចិត្តនៃភិក្ខុទាំងនោះ គង់លើអាសនៈដែលគេរៀបចំហើយត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អ្នកចរចាគ្នាអំពីរឿងអ្វី ភិក្ខុទាំងនោះក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពួក

ខ្ញុំព្រះអង្គមិនបានពោលរឿងអ្វីដទៃ ពោលតែគុណរបស់ព្រះអង្គប៉ុណ្ណោះថា ព្រះចូឡបន្ថកៈបានលាភធំអំពីសម្នាក់ព្រះអង្គ ដូច្នេះ ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ចូឡបន្ថកៈនេះ ធ្វើតាមឱវាទរបស់តថាគតហើយ បាននូវភាពជាទាយាទខាងលោកុត្តរក្នុងឥឡូវនេះ មិនគួរអស្ចារ្យឡើយ ក្នុងអតីត ចូឡបន្ថកៈធ្វើតាមឱវាទរបស់តថាគត ដែលតាំងនៅក្នុងញាណមិនទាន់ចាស់ក្លា ក៏បាននូវភាពជាទាយាទ តាមផ្លូវលោកិយហើយ ។

ទើបភិក្ខុទាំងឡាយ ទូលអារាធនាថា តើជាទាយាទតាមផ្លូវលោកិយនោះពីអង្កាល់ណា ព្រះអង្គ ។ ព្រះសាស្ដាទ្រង់នាំអតីតនិទានមកសម្ដែងដល់ភិក្ខុទាំងនោះថា

ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ព្រះរាជាព្រះនាមព្រហ្មទត្ត គ្រងរាជសម្បត្តិក្នុងក្រុងពារាណសី ។ សម័យនោះ បណ្ឌិតឈ្មោះចូឡកសេដ្ឋី ជាបុគ្គលឈ្លាស ដឹងនិមិត្តទាំងពួង ថ្ងៃមួយកំពុងធ្វើដំណើរទៅគាល់ព្រះរាជា ឃើញកណ្ដុរងាប់មួយ ក្នុងចន្លោះផ្លូវ ទើបកំណត់នក្ខត្តឫក្សក្នុងខណៈនោះហើយពោលពាក្យនេះថា កុលបុត្រដែលមានភ្នែក មានបញ្ញា អាចយកកណ្ដុរនេះទៅចិញ្ចឹមកិរិយា និងប្រកបការងារបាន កុលបុត្រទុគ៌តម្នាក់ស្ដាប់ពាក្យសេដ្ឋីនោះហើយ គិតថា បុរសនេះមិនដឹងគង់មិនពោល ដូច្នេះ ទើបយកកណ្ដុរទៅត្រង់រានផ្សារមួយ លក់ឲ្យអ្នកចិញ្ចឹមឆ្មា បានទ្រព្យមួយកាកណិក ហើយទិញទឹកអំពៅដោយទ្រព្យមួយកាកណិកនោះ យកឆ្នាំងមួយដាក់ទឹកពេញដើរទៅ ឃើញនាយមាលាការដើរមកអំពីព្រៃ ក៏ឲ្យទឹកអំពៅហើយយកបោយ

ជួសទឹកឲ្យ ។ នាយមាលាការទាំងនោះឲ្យផ្កាដល់បុរសនោះម្នាក់មួយក្ដាប់ ។ ក្នុងថ្ងៃស្អែកឡើង បុរសនោះយកតម្លៃផ្កានោះ ទៅទិញទឹកអំពៅ និងក្អមទឹក ហើយទៅកាន់សួនផ្កានោះឯង ។ ថ្ងៃនោះ នាយមាលាការក៏ឲ្យផ្កាដែលខ្ទង់បេះពាក់កណ្ដាល ហើយក៏ទៅ មិនយូរប៉ុន្មានបុរសនោះ ក៏បានទ្រព្យដល់ទៅ ៨ កហាបណៈដោយឧបាយនេះ ។ ថ្ងៃមួយ មានខ្យល់ និងភ្លៀងធ្លាក់ខ្លាំង បុរសនោះធ្វើមែកឈើដែលបាក់ហើយ ឲ្យជាពំនូក ទើបបានទ្រព្យ ១៦ កហាបណៈទៀត អំពីនាយសួនផ្កាំងរបស់ព្រះរាជា ។ កាលគាត់បានទ្រព្យ ២៤ កហាបណៈហើយ គិតថា ឧបាយនេះមានប្រយោជន៍ដល់អញ ទើបតម្កល់ក្អមទឹកមួយទុកមិនឆ្ងាយអំពីទ្វារក្រុង ផ្គត់ផ្គង់អ្នកប្រូតស្មៅ ៥០០ នាក់ អ្នករែកស្មៅទាំងនោះពោលថា សម្លាញ់ អ្នកមានឧបការៈច្រើនដល់ពួកខ្ញុំ ពួកខ្ញុំនឹងធ្វើអ្វីដល់អ្នកខ្លះ បុរសនោះឆ្លើយថា កាលមានកិច្ចកើតឡើងសឹមធ្វើដល់ខ្ញុំចុះ ត្រាច់ទៅទីនោះ ទីនេះ ធ្វើការចងមិត្រជាមួយអ្នកធ្វើការផ្លូវគោក និងផ្លូវទឹក ។ អ្នកធ្វើការផ្លូវគោកប្រាប់ដល់បុរសនោះថា ស្អែកនេះ ឈ្មួញសេះ នាំសេះ ៥០០ មកកាន់ក្រុងនេះ ។ បុរសនោះបានស្ដាប់ពាក្យនោះហើយ ឲ្យសញ្ញាដល់អ្នកប្រូតស្មៅ ឲ្យធ្វើបាច់ស្មៅម្នាក់មួយបាច់ៗ ឲ្យជា ២ ចំណែក ហើយនាំមក ។ ក្នុងកាលដែលសេះទាំងឡាយមកសម្រាកក្នុងក្រុងហើយ គាត់ក៏មកអង្គុយធ្វើបាច់ស្មៅទាំង ១០០០ គរទុកត្រង់ទ្វារខាងក្នុង ។ ឈ្មួញសេះរកស្មៅស្រស់ឲ្យសេះ ទូទៅទាំងក្រុងមិនបាន ត្រូវឲ្យទ្រព្យ ១០០០ ដល់បុរសនោះ ទិញស្មៅនោះទៅ ។ បន្ទាប់អំពីនោះទៅ ២-៣ ថ្ងៃ សម្លាញ់ធ្វើការឯសមុទ្រ

ប្រាប់ថា មានទូកធំចូលមកចតត្រង់កំពង់ ។ បុរសនោះគិតថា ឧបាយនេះមាន ទើបយកទ្រព្យ ៨ កហាបណៈជួលរទេះ ព្រមដោយគ្រឿងឧបករណ៍គ្រប់ប្រភេទ ទៅកាន់កំពង់ទូក ឲ្យសញ្ញាដល់នាយកំពង់ ប្រថាប់ត្រាមដៃទុកត្រង់ទូកហើយ ឲ្យបាំងវាំងននក្នុងទីមិនឆ្ងាយ អង្គុយខាងក្នុងវាំងននទោះប្រាប់បុរសអ្នកបម្រើថា កាលឈ្មួញខាងក្រៅមកដល់ ចូរមកប្រាប់ដំណឹងដល់ទ្វារទី ៣ កាលអ្នកបម្រើនោះដឹងថា ទូកមកដល់ហើយ ទើបប្រាប់ថាមានអ្នកជំនួញប្រមាណ ១០០ មកអំពីក្រុងពារាណសីមកទិញនូវទំនិញនាយទ្វារទី ៣ ពោលថា ពួកអ្នកមិនបានទំនិញទេ ព្រោះនាយពាណិជធំក្នុងទីនោះ ធ្វើសញ្ញាទុកហើយ ។ ឈ្មួញទាំងនោះស្តាប់ពាក្យបុរសនោះហើយទើបនាំគ្នាទៅកាន់សម្នាក់របស់ឈ្មួញធំនោះ ។ ឯបុរសអ្នកស្និទ្ធស្នាលប្រាប់ថា ឈ្មួញទាំងនោះ មកតាមទ្វារទី ៣ តាមសញ្ញាច្បាប់អំពីមុន ឈ្មួញទាំង ១០០ នាក់នោះត្រូវឲ្យទ្រព្យម្នាក់ ១០០០ ហើយ ទើបធ្វើដំណើរទៅកាន់ទូកជាមួយបុរសនោះ ហើយចំណាយទ្រព្យម្នាក់ៗ ១០០០ ឲ្យលះបង់ថ្លៃកក់ទើបធ្វើទំនិញឲ្យជារបស់ខ្លួនបាន បុរសនោះកាន់យកទ្រព្យ ២ សែនត្រឡប់មកកាន់ក្រុងពារាណសី គិតថា អញគួរជាបុគ្គលកតញ្ញូ ទើបកាន់យកទ្រព្យមួយសែន ទៅកាន់សម្នាក់នៃចូឡកសេដ្ឋី ។

គ្រានោះ សេដ្ឋីសួរបុរសនោះថា បាធ្វើដូចម្តេច ទើបបានទ្រព្យនេះមក បុរសនោះពោលថា ខ្ញុំតាំងនៅក្នុងឧបាយដែលលោកម្ចាស់ពោលហើយ ទើបបានទ្រព្យមកខាងក្នុង ៤ ខែប៉ុណ្ណោះ សេដ្ឋីបានស្តាប់ពាក្យរបស់បុរសនោះ

ទើបគិតថា ឥឡូវនេះ អញមិនគួរធ្វើក្មេងបែបនេះឲ្យជាសម្បត្តិអ្នកដទៃឡើយ ទើបលើកធីតាដែលចម្រើនវ័យ ឲ្យធ្វើជាម្ចាស់នៃទ្រព្យសម្បត្តិទាំងមូល កុល-បុត្រនោះ កាលស្លាប់ទៅហើយ ទើបទទួលតំណែងសេដ្ឋីជំនួសក្នុងព្រះនគរនោះ តាំងនៅរហូតអស់អាយុ ហើយទៅតាមយថាកម្ម ។

ព្រះសាស្តាត្រាស់រឿងទាំង ២ នេះហើយ ទ្រង់បន្តអនុសន្ធិទេសនាក្នុងខណៈដែលត្រាស់ដឹងអនុត្តរសម្មាសម្ពោធិញ្ញាណ ហើយត្រាស់ព្រះគាថាថា

**អប្បកេនបិ មេធាវី ចាភដេន វិចក្ខណោ**
**សមុដ្ឋាបេតិ អត្តានំ អណុំ អគ្គឹវ សន្ធមន្តិ ។**

អ្នកប្រាជ្ញ ឈ្លាសវៃ រមែងតាំងខ្លួនបាន ដោយទ្រព្យជាដើម
ទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច ។

ព្រះសាស្តាទ្រង់សម្តែងហេតុនេះ ដល់បណ្តាភិក្ខុដែលអង្គុយប្រជុំគ្នាក្នុងធម្មសភា ដោយប្រការដូច្នេះ ។ នេះជារឿងរាវដែលមកតាមលំដាប់ចាប់តាំងពីការតាំងសេចក្តីប្រាថ្នា អំពីខាងដើមរបស់មហាសាវ័កទាំងពីរ ។ បន្ទាប់មក ព្រះសាស្តាមានពួកព្រះអរិយៈចោមរោមហើយ ប្រថាប់គង់លើធម្មាសនៈ ទ្រង់ស្ថាបនាព្រះចូឡបន្ថកត្ថេរ ក្នុងតំណែងឯតទគ្គៈនៃពួកភិក្ខុដែលឈ្លាសក្នុងចេតោវិវដ្ដៈ ដែលនិមិត្តកាយមនោមយបាន ទ្រង់ស្ថាបនាព្រះមហាបន្ថកត្ថេរ ក្នុងតំណែងឯតទគ្គៈកំពូលជាងភិក្ខុអ្នកឈ្លាស ក្នុងបញ្ញា-វិវដ្ដៈ ដោយប្រការដូច្នេះ ។៚

**អដ្ឋកថាសូត្រទី ១-២ ចប់**

# អដ្ឋកថា សូត្រទី ៣

# ប្រវត្តិ ព្រះសុភូតិត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៣ ដូចតទៅនេះ បទថា **អរណាវិហារីធំ** បានដល់ អ្នកមានប្រក្រតីនៅដោយមិនមានកិលេស ។ ពិតហើយ កិលេសទាំងឡាយ មានរាគៈជាដើម លោកហៅថា **រណា** ឈ្មោះថា មានប្រក្រតីនៅដោយមិនមានកិលេស ព្រោះមិនមានកិលេសដែលឈ្មោះថា **រណា** នោះឈ្មោះថា អ្នកមានប្រក្រតីនៅដោយមិនមានកិលេស អរណាវិហារនោះមានដល់ភិក្ខុពួកណា ភិក្ខុទាំងនោះឈ្មោះថា មានប្រក្រតីនៅដោយមិនមានកិលេស ព្រះសុភូតិត្ថេរជាកំពូលនៃពួកភិក្ខុ ដែលមានប្រក្រតីនៅដោយមិនមានកិលេសទាំងនោះ ពិតហើយ ព្រះខីណាស្រពដទៃ ក៏ឈ្មោះថា អរណាវិហារីក៏ពិត តែព្រះថេរៈបានឈ្មោះយ៉ាងនោះ ដោយព្រះធម្មទេសនា ភិក្ខុដទៃកាលសម្តែងធម៌ រមែងធ្វើចោះចំពោះ ពោលគុណខ្លះ ទោសខ្លះ ឯព្រះថេរៈកាលសម្តែងធម៌ ក៏សម្តែងមិនចេញអំពីគោលកំណត់ ដែលព្រះសាស្តាសម្តែងហើយ ព្រោះដូច្នោះ ទើបឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលមានប្រក្រតីនៅដោយមិនមានកិលេស ។

**អដ្ឋកថា សូត្រទី ៣ ចប់**

# អដ្ឋកថា សូត្រទី ៨

# ប្រវត្តិ ព្រះសុភូតិត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ដូចតទៅនេះ បទថា **ទក្ខិណេយ្យានំ** ប្រែថា គួរដល់ទក្ខិណា ព្រះខីណាស្រពទាំងឡាយដទៃៗ ក៏ឈ្មោះថា ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើរ ក្នុងបទថា **ទក្ខិណេយ្យានំ** នោះ ក៏ពិត សូម្បីយ៉ាងនោះ ព្រះថេរៈកំពុងបិណ្ឌបាត ក៏ចូលឈានមានមេត្តាជាអារម្មណ៍ ចេញអំពីសមាបត្តិហើយ ទើបទទួលភិក្ខាក្នុងផ្ទះគ្រប់ខ្នង ដោយទាយកដែលថ្វាយភិក្ខា នឹងមានផលច្រើន ព្រោះដូច្នោះ ទើបលោកហៅថា បុគ្គលគួរដល់ទក្ខិណា ។ អត្តភាពរបស់លោកស្អាតល្អ រុងរឿងក្រៃលែង ដូចក្លោងទ្វារដែលគេរចនាហើយ និងដូចបន្ទះសំពត់វិចិត្រ ដូច្នោះ ទើបហៅថា សុភូតិ ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ

បានឮថា ព្រះសុភូតិនេះ កាលព្រះមានព្រះភាគ ព្រះនាមបទុមុត្តរៈ មិនទាន់កើតឡើងក្នុងលោក បានកើតក្នុងត្រកូលព្រាហ្មណមហាសាល ក្នុងក្រុងហង្សវតី ញាតិទាំងឡាយថ្វាយព្រះនាមថា នន្ទមាណព លោកចម្រើនវ័យហើយ រៀនត្រៃវេទ មិនឃើញសារៈក្នុងត្រៃវេទនោះ មួយអន្លើដោយបរិវារនៃខ្លួនមានប្រមាណ ៤៤០០០ នាក់ ចេញបួសជាឥសី នៅនាជើងភ្នំ ធ្វើអភិញ្ញា ៥ និងសមាបត្តិ ៨ ឲ្យកើតហើយ បានធ្វើអន្តេវាសិកទាំងឡាយឲ្យបានឈានហើយ ។ ក្នុងសម័យនោះ ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ ទ្រង់កើតក្នុងលោក ទ្រង់អាស្រ័យក្រុងហង្សវតីប្រថាប់នៅ ។ ថ្ងៃមួយ ក្នុងវេលាទៀបភ្លឺ ទ្រង់ប្រមើលមើលសត្វលោក ទ្រង់ឃើញអរហត្តូបនិស្ស័យ

របស់ពួកជដិលដែលជាអន្តេវាសិករបស់នទ្ទតាបស និងសេចក្តីប្រាថ្នាតំណែងសាវកដែលប្រកបដោយអង្គ ២ របស់នទ្ទតាបស ទើបទ្រង់បដិបត្តិសរីរៈអំពីព្រលឹម ទ្រង់កាន់បាត្រ និងចីវរក្នុងវេលាព្រឹក ស្តេចទៅកាន់អាស្រមរបស់នទ្ទតាបស ដោយន័យដែលបានពោលហើយ ក្នុងរឿងរបស់ព្រះសារីបុត្រ ។ ក្នុងទីនោះ គប្បីជ្រាបការថ្វាយផ្លែឈើតូចធំក្តី ការតាក់តែងបុប្ផាសនៈក្តី ការចូលនិរោធសមាបត្តិក្តី ដោយន័យដែលពោលហើយ ។

ព្រះសាស្តាចេញអំពីនិរោធសមាបត្តិ ទ្រង់បញ្ជូនសាវកមួយអង្គ ដែលប្រកបដោយអង្គ ២ គឺអរណវិហារអង្គ ១ ទក្ខិណេយ្យអង្គ ១ ថា អ្នកចូរធ្វើអនុមោទនាបុប្ផាសនៈដល់គណៈឥសី ដូច្នេះ ។ ព្រះថេរៈនោះនៅក្នុងវិស័យរបស់ខ្លួន ពិចារណាព្រះត្រៃបិដក ធ្វើអនុមោទនា កាលចប់ទេសនារបស់លោកហើយ ទើបព្រះសាស្តាទ្រង់សម្តែងធម៌ដោយព្រះអង្គឯង កាលចប់ទេសនា តាបសទាំង ៤៤០០០ បានសម្រេចអរហត្តគ្រប់រូប ឯនទ្ទតាបសកាន់និមិត្តនៃភិក្ខុដែលអនុមោទនា មិនអាចបញ្ជូនញាណទៅតាមគន្លងនៃទេសនារបស់ព្រះសាស្តាបាន ព្រះសាស្តាទ្រង់លាព្រះហស្តទៅកាន់ភិក្ខុដ៏សេសថា **ឯថ ភិក្ខវោ** អ្នកចូរជាភិក្ខុចុះ ភិក្ខុទាំងអស់មានសក់ និងពុកមាត់អន្តរធានហើយគ្រងបរិក្ខារដែលសម្រេចដោយឫទ្ធិ ប្រាកដដូចព្រះថេរៈ ១០០ វស្សា ។

នទ្ទតាបសថ្វាយបង្គំព្រះតថាគតហើយឈរចំពោះព្រះភក្ត្រ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ភិក្ខុដែលធ្វើអនុមោទនាបុប្ផាសនៈដល់គណៈឥសី មានឈ្មោះដូចម្តេច ក្នុងសាសនារបស់ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ភិក្ខុ

នេះ ជាឯតទគ្គៈ ដោយអង្គ គឺការមានប្រក្រតីនៅដោយមិនមានកិលេស ១ ដោយអង្គនៃភិក្ខុដែលគួរដល់ទក្ខិណា ១ ។ នន្ទតាបសបានតាំងសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន ដោយកម្ម គឺកុសលដ៏ក្រៃលែងដែលបានធ្វើមក ៧ ថ្ងៃនេះ ខ្ញុំព្រះអង្គ មិនបានប្រាថ្នាសម្បត្តិដទៃទេ តែខ្ញុំព្រះអង្គគប្បីជាអ្នកប្រកបដោយអង្គ ២ ដូចព្រះថេរៈនេះ ក្នុងសាសនានៃព្រះទសពលអង្គឯណានីមួយ នាអនាគតចុះ ។ ព្រះសាស្តាទ្រង់ឃើញការមិនមានអន្តរាយ ទើបទ្រង់ព្យាករ ហើយយាងត្រឡប់ទៅ ។ ឯនន្ទតាបសស្តាប់ធម៌ក្នុងសម្នាក់ព្រះទសពល តាមសមគួរដល់កាល មិនសាបសូន្យចាកឈាន ហើយទៅកើតក្នុងព្រហ្មលោក ។ ព្រះអដ្ឋកថាចារ្យ មិនបានពោលដល់កល្យាណកម្មរបស់តាបសនេះក្នុងចន្លោះ ។ លុះកន្លងទៅមួយសែនកប្ប លោកមកកើតក្នុងផ្ទះនៃសុមនសេដ្ឋី ក្នុងក្រុងសាវត្ថី ពួកញាតិបានឲ្យឈ្មោះលោកថា សុភូតិ ។

បន្ទាប់មក ព្រះសាស្តានៃយើងទ្រង់កើតឡើងក្នុងលោក អាស្រ័យក្រុងរាជគ្រឹះប្រថាប់នៅ ។ គ្រានោះ អនាថបិណ្ឌិកសេដ្ឋីនាំទំនិញដែលផលិតនៅក្នុងក្រុងសាវត្ថី ទៅកាន់ផ្ទះរបស់រាជហសេដ្ឋី ដែលជាសម្លាញ់របស់ខ្លួន ដឹងថា ព្រះសាស្តាទ្រង់កើតហើយ ទើបចូលទៅគាល់ព្រះសាស្តាដែលប្រថាប់នៅត្រង់សីតវ័ន ដោយការគាល់គ្រាដំបូងនោះឯង បានតាំងនៅក្នុងសោតាបត្តិផល ហើយទូលអារាធនាព្រះសាស្តា ឲ្យយាងមកកាន់ក្រុងសាវត្ថី បានសាងវិហារដោយការបរិច្ចាគទ្រព្យមួយសែនរាល់ៗ មួយយោជន៍ អស់ចម្ងាយផ្លូវ ៤៥ យោជន៍ បានទិញឧទ្យានរបស់ព្រះរាជកុមារព្រះនាមជេត ប្រមាណ

៨ ករីស ដោយគ្រឿងរាប់របស់ស្តេចក្នុងក្រុងសាវត្ថី ដោយចំណាយទ្រព្យមួយកោដិសាងវិហារក្នុងទីឈ្មោះនោះ ថ្វាយដល់ព្រះមានព្រះភាគហើយ ក្នុងថ្ងៃឆ្លងវិហារ សុភូតិកុដុម្ពិកៈក៏បានទៅស្តាប់ធម៌ជាមួយអនាថបិណ្ឌិកសេដ្ឋី បាននូវសទ្ធា ទើបបួស លោកឧបសម្បទាហើយ ធ្វើមាតិកា ២ បទឲ្យស្ទាត់ជំនាញ ឲ្យប្រាប់កម្មដ្ឋាន បំពេញសមណធម៌ក្នុងព្រៃ ចម្រើនវិបស្សនា ធ្វើមេត្តាឈានឲ្យជាបាទ សម្រេចអរហត្តហើយ កាលសម្តែងធម៌ ក៏ពោលធម៌ដោយន័យដែលពោលហើយនោះឯង កាលត្រាច់បិណ្ឌបាត ចេញអំពីមេត្តាឈានហើយ ទើបទទួលភិក្ខា ដោយន័យដែលពោលហើយដូចគ្នា គ្រានោះព្រះសាស្តាទ្រង់អាស្រ័យហេតុ ២ យ៉ាងនេះ ទើបស្ថាបនាលោកទុកក្នុងភិក្ខុដែលគួរដល់ទក្ខិណា និងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុដែលមានប្រក្រតី នៅដោយមិនមានកិលេស ។ល។

## អដ្ឋកថាសូត្រទី ៤ ចប់

# អដ្ឋកថា សូត្រទី ៥

# ប្រវត្តិ ព្រះរេវតត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៥ ដូចតទៅនេះ បទថា **អារញ្ញកានំ** បានដល់ មានប្រក្រតីនៅព្រៃជាវត្ត ។ បទថា **រេវតោ ខទិរវនិយោ** បានដល់ ជាប្អូនប្រុសនៃព្រះធម្មសេនាបតី លោកមិនបាននៅដូចព្រះថេរៈដទៃ កាលនៅក្នុងព្រៃ ក៏ត្រូវជ្រើសរើសព្រៃ ទឹក និងកិច្ចាចារដែលត្រូវចិត្ត ទើបនៅក្នុងព្រៃ តែលោកមិនប្រកាន់របស់ដែលត្រូវចិត្តទាំងនេះ អាស្រ័យនៅក្នុងព្រៃគគីរ ដែលរជិបរជុបដោយដុំក្រួស និងដុំថ្ម លើទីទួល ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលនៅព្រៃជាវត្ត ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលគួរពោលតាមលំដាប់ដូចតទៅ

បានឮថា ក្នុងអតីតកាល នាសាសនាព្រះបទុមុត្តរសម្ពុទ្ធ ព្រះរេវតៈនេះ កើតក្នុងហង្សវតី អាស្រ័យការឆ្លងផ្លូវទឹកត្រង់កំពង់បយាគបតិដ្ឋាន ក្នុងស្ទឹងគង្គា ។ សម័យនោះ ព្រះសាស្ដាមានភិក្ខុមួយសែនជាបរិវារ ទ្រង់ចារិកទៅរហូតដល់កំពង់បយាគបតិដ្ឋាន ។ គាត់ឃើញព្រះទសពលហើយ គិតថា អញមិនបានឃើញព្រះពុទ្ធយូរមកហើយ ខណៈនេះ ជាខណៈដែលអញនឹងបាននូវការខ្វល់ខ្វាយក្នុងកល្យាណកម្ម ទើបឲ្យចងទូកតគ្នា បាំងពិតានសំពត់ខាងលើ សំយុងកម្រងផ្កា គ្រឿងក្រអូបជាដើម ក្រាលនូវកម្រាលដ៏វិចិត្រ ដែលធ្វើអំពីសំពត់សម្បកឈើ និមន្តព្រះសាស្ដា ព្រមទាំងបរិវារឲ្យឆ្លងប្រាំង ។ ក្នុងសម័យនោះ ព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុដែលនៅព្រៃជាវត្តមួយអង្គ ក្នុងតំណែងឯតទគ្គៈ នាយទូកនោះ ឃើញភិក្ខុនោះ ទើបគិតថា ឯអាត្មា

អញក៏គួរជាកំពូលនៃពួកភិក្ខុដែលនៅក្នុងព្រៃជាវត្ត ក្នុងសាសនានៃព្រះពុទ្ធអង្គឯណានីមួយ ក្នុងអនាគតដូច្នេះដូចគ្នា ។ ទើបនិមន្តព្រះសាស្តាថ្វាយមហាទានអស់ ៧ ថ្ងៃ ក្រាបចុះទៀបបាទមូលរបស់ព្រះសាស្តា ធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គដ៏ចម្រើន សូមឲ្យខ្ញុំព្រះអង្គក៏គប្បីជាកំពូលនៃពួកភិក្ខុដែលនៅព្រៃជាវត្ត ក្នុងសាសនារបស់ព្រះពុទ្ធអង្គឯណានីមួយ ក្នុងអនាគតដូចភិក្ខុដែលទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈនេះចុះ ព្រះសាស្តាទ្រង់ឃើញថាមិនមានអន្តរាយណាមួយឡើយ ទ្រង់ព្យាករថា ក្នុងអនាគត អ្នកនឹងបានជាកំពូល ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ហើយទ្រង់យាងត្រឡប់ទៅ ។ ក្នុងទីនេះ មិនបានពោលដល់កម្មក្នុងអន្តរភពទេ ។

លោកធ្វើកល្យាណកម្មរហូតដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវលោក និងមនុស្សលោក ក្នុងពុទ្ធុប្បាទកាលនេះ ទើបមកបដិសន្ធិក្នុងផ្ទៃនៃនាងសារីព្រាហ្មណី ក្នុងស្រុកព្រាហ្មណ៍ឈ្មោះនាលកៈ ដែនមគធៈ កើតជាប្អូនពៅរបស់បងប្រុស ៣ នាក់ បងស្រី ៣ នាក់ មាតាបិតាដាក់ឈ្មោះថា រេវតៈ ។ គ្រានោះ មាតាបិតារបស់លោកគិតថា កាលកូនរបស់អញចម្រើនវ័យហើយ ពួកព្រះសមណសក្យបុត្រក៏មកនាំយកទៅបំបួសបង់ទៀត អញនឹងចងរេវតៈ កូនពៅរបស់អញដោយចំណង គឺផ្ទះ ដូច្នេះ ហើយនាំទារិកាអំពីត្រកូលដែលស្មើ មកឲ្យថ្វាយបង្គំយាយរបស់រេវតៈ ហើយពោលថា នៃនាង នាងចូរជាមនុស្សចាស់ជាងយាយរបស់នាង ។ រេវតៈស្តាប់ពាក្យរបស់ជនទាំងនោះហើយ គិតថា ទារិកានេះនៅក្នុងបឋមវ័យ រូបនេះ នៃទារិកានេះ

នឹងដូចរូបយាយនៃអញ អញនឹងសួរបំណងរបស់មនុស្សទាំងនោះមុន ហើយទើបពោលថា អ្នកទាំងឡាយធ្វើអ្វី មាតាបិតាឆ្លើយថា ខ្ញុំប្រាប់ថា នែបា ស្រីនេះនឹងដល់នូវភាពជរាដូចយាយរបស់បា ។ រេវតៈសួរថា រូបរបស់ស្រីនេះនឹងក្លាយទៅជាយ៉ាងនេះឬ ។ មាតាបិតាឆ្លើយថា នែបា អ្នកពោលអ្វី អ្នកមានបុណ្យច្រើនក៏នឹងទៅយ៉ាងនេះ ។ រេវតៈនោះគិតថា បានឮថា រូបនេះនឹងមានស្បែកជ្រីវជ្រួញដោយទំនងនេះ នឹងមានសក់ស្កូវ ធ្មេញបាក់ ដោយទំនងនេះ អញត្រេកអរក្នុងរូបដូច្នេះនឹងធ្វើអ្វីបាន អញនឹងទៅតាមផ្លូវដែលបងប្រុសរបស់អញទៅហើយនោះឯង ។ ទើបធ្វើជាឈរនិយាយជាមួយក្មេងកំលោះៗ ស្រែករគ្នាថា មកពួកយើង យើងរត់ប្រណាំងគ្នា ហើយរត់ទៅតែម្តង ។ មាតាបិតាពោលថា នែបា ក្នុងថ្ងៃមង្គល អ្នកកុំទៅខាងក្រៅឡើយ ។

រេវតៈធ្វើដូចជាលេងជាមួយក្មេងទាំងឡាយ លុះដល់វារៈខ្លួនរត់ ក៏រត់ទៅបន្តិច ហើយដើរត្រឡប់មកយឺតៗ លុះដល់វារៈទៀត ក៏ទៅឆ្ងាយជាងនោះ ហើយត្រឡប់មក កាលដល់វារៈ ៣ ដង ក៏ដឹងថា គ្រានេះ ជាពេលរបស់អញគេចទៅក្នុងទីចំពោះមុខនោះឯង ទៅរហូតដល់ព្រៃដែលជាលំនៅរបស់ភិក្ខុដែលសមាទានបង្សុកូលជាវត្ត អភិវាទព្រះថេរៈហើយ សូមបព្វជ្ជា ព្រះថេរៈពោលថា នែសប្បុរស អាត្មាមិនស្គាល់អ្នក អ្នកជាកូនចៅរបស់អ្នកណា ហើយមកទាំងតែងខ្លួនបែបនេះ អ្នកណាអាចឲ្យអ្នកបួសបាន ។ រេវតៈលើកដើមដៃទាំង ២ ឡើង ស្រែកសំឡេងខ្លាំងថា គេប្លន់ខ្ញុំៗ ដូច្នេះ ។ ពួកភិក្ខុក៏មកចោមរោមទាំងខាងនោះ ទាំងខាងនេះ ពោលថា សប្បុរស ក្នុងទី

នេះ មិនមានអ្នកណាដែលឈ្មោះថា ប្ចូន់សំពត់ ឬគ្រឿងប្រដាប់របស់អ្នក ឡើយ អ្នកពោលថា គេប្ចូន់ដូចម្តេច ។ រេវតៈពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនបានពោលសំដៅដល់សំពត់ និងគ្រឿងប្រដាប់ តែពោលសំដៅដល់ ពួកលោកម្ចាស់ប្ចូន់សម្បត្តិខាងក្នុង មិនបំបួសខ្ញុំមុន សូមប្រាប់បងប្រុសខ្ញុំ ជ្រាបមុនចុះ ភិក្ខុសួរថា បងប្រុសរបស់អ្នកឈ្មោះអី ។ រេវតៈពោលថា កាលនៅជាគ្រហស្ថឈ្មោះឧបតិស្សៈ តែក្នុងពេលនេះ មនុស្សទាំងឡាយ ហៅថា សារីបុត្រ ។ ភិក្ខុទាំងឡាយពោលថា អាវុសោ កុលបុត្រនេះជាប្អូន ពៅរបស់ពួកយើង ព្រះធម្មសេនាបតីជាបងប្រុសច្បងរបស់យើង បានពោល ហើយថា ពួកញាតិរបស់ខ្ញុំ សុទ្ធតែជាមិច្ឆាទិដ្ឋិ ញាតិរបស់ខ្ញុំណាមួយមក សូម ឲ្យគេបួសដោយឧបាយឯណានីមួយចុះ ដូច្នោះ ទើបពោលថា កុល-បុត្រនេះ ជាប្អូនបង្កើតរបស់ព្រះថេរៈ អ្នកទាំងឡាយចូរឲ្យលោកបួសចុះ ដូច្នេះហើយ ប្រាប់តចបញ្ចកកម្មដ្ឋានហើយ ។ ព្រះថេរៈរៀនកម្មដ្ឋានហើយ ចូលទៅកាន់ព្រៃគគីរ ដែលមានប្រការដូចពោលក្នុងទីមិនឆ្ងាយអំពីឧបជ្ឈាយ៍ និងអាចារ្យ បំពេញសមណធម៌ កាលលោកកំពុងព្យាយាមដោយតាំងចិត្តថា បើអញមិនទាន់សម្រេចអរហត្ត នឹងមិនទៅគាល់ព្រះទសពល ឬព្រះថេរៈ ដែលជាបងប្រុស លុះកន្លងទៅ ៣ ខែ ជាសត្វសុខុមាលជាតិ បរិភោគ ភោជនដែលអន់ថយ ចិត្តក៏មិនប្រណីត មិនបែរមុខក្នុងព្រះកម្មដ្ឋាន ដោយ កន្លងទៅ ៣ ខែ បវារណាចេញវស្សាហើយ ទើបបំពេញសមណធម៌ក្នុង ទីនោះឯង កាលលោកបំពេញសមណធម៌ ចិត្តក៏មានអារម្មណ៍តែមួយហើយ

លោកចម្រើនវិបស្សនា ហើយសម្រេចអរហត្ត ។

គ្រានោះ ព្រះសារីបុត្រទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា រេវតៈប្អូនប្រុសពៅរបស់ខ្ញុំព្រះអង្គចេញបួស លោកត្រេកអរ ឬមិនត្រេកអរ ខ្ញុំព្រះអង្គនឹងទៅសួរសុខទុក្ខលោក ព្រះមានព្រះភាគទ្រង់ជ្រាបថា រេវតៈផ្តើមចម្រើនវិបស្សនា ទើបទ្រង់ឃាត់អស់វារៈ ២ ដង ក្នុងគ្រាទី ៣ លោកទូលសូមទៀត ទ្រង់ជ្រាបថា សម្រេចអរហត្តហើយ ទើបត្រាស់ថា ម្នាលសារីបុត្រ ឯតថាគតក៏នឹងទៅដែរ អ្នកចូរប្រាប់ភិក្ខុទាំងឡាយចុះ ព្រះថេរៈប្រជុំភិក្ខុសង្ឃហើយ ប្រាប់ដល់ភិក្ខុទាំងពួងថា អាវុសោ ព្រះសាស្តាមានបំណងយាងចារិក ភិក្ខុអង្គណាបំណងនឹងទៅ ក៏ចូរមក ។ ក្នុងវេលាដែលព្រះទសពលយាងចារិក ភិក្ខុដែលរារែកមានតិច ដោយច្រើនភិក្ខុជាច្រើនបំណងនឹងទៅ ព្រោះគិតថា នឹងឃើញព្រះសរីរៈរបស់ព្រះសាស្តាដែលមានវណ្ណៈដូចមាស ឬនឹងស្តាប់ធម្មកថាដ៏ពីរោះ ដោយប្រការដូច្នេះ ។ ព្រះសាស្តាមានមហាភិក្ខុសង្ឃជាបរិវារ យាងចេញទៅ ដោយបំណងសួរសុខទុក្ខព្រះរេវតៈ ព្រះអានន្ទនិមន្តដល់ផ្លូវបែកជា ២ ក្នុងទីមួយកន្លែង គ្រានោះ ទើបទូលសួរព្រះមានព្រះភាគថា ទីនេះ ផ្លូវបែកជា ២ ភិក្ខុសង្ឃនឹងទៅផ្លូវណា ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់សួរថា ម្នាលអានន្ទ ផ្លូវណាជាផ្លូវត្រង់ ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ផ្លូវត្រង់មានចម្ងាយ ៣០ យោជន៍ ជាផ្លូវនៃអមនុស្ស ឯផ្លូវវាង មានចម្ងាយ ៦០ យោជន៍ ជាផ្លូវផុតភ័យ រកភិក្ខាបានងាយ ព្រះមានព្រះភាគត្រាស់ថា ម្នាលអានន្ទ សីវលីមកជាមួយ

យើងហើយឬ ព្រះថេរៈពោលថា មកដែរព្រះអង្គ ព្រះសាស្តាត្រាស់ថា បើយ៉ាងនោះ សង្ឃចូរទៅផ្លូវត្រង់ យើងនឹងល្បងបុណ្យរបស់សីវលី ។ ព្រះសាស្តាមានភិក្ខុសង្ឃជាបរិវារ ទ្រង់យាងកាត់ព្រៃដើម្បីល្បងបុណ្យរបស់ព្រះសីវលី ។ តាំងអំពីព្រះសាស្តាទ្រង់យាងកាន់ផ្លូវ ពួកទេវតានិម្មិតនគរក្នុងទីគ្រប់មួយយោជន៍ តាក់តែងវិហារ ដើម្បីជាលំនៅថ្វាយភិក្ខុសង្ឃ មានព្រះមានព្រះភាគជាប្រធាន ពួកទេវបុត្រ ដូចជាពួកកម្មករដែលព្រះរាជាបញ្ជូនទៅកាន់បាយ បបរ និងរបស់ទំពាជាដើមទៅ សួរថា លោកម្ចាស់សីវលីនៅឯណា លោកម្ចាស់សីវលីនៅឯណា ព្រះថេរៈឲ្យទទួលគ្រឿងសក្ការៈទៅកាន់សម្នាក់ព្រះសាស្តា ។ ព្រះសាស្តា មួយអន្លើដោយភិក្ខុសង្ឃ ទ្រង់សរសើរគ្រឿងសក្ការៈ និងការគោរព រាប់អាន ដោយទំនងនេះឯង ទ្រង់យាងទៅអស់ចម្ងាយផ្លូវ មួយថ្ងៃ ១ យោជន៍យ៉ាងឆ្ងាយ ឆ្លងផ្លូវកន្តារដល់ទៅ ៣០ យោជន៍ រហូតដល់ទីអាស្រ័យរបស់ព្រះខទិរវនិយត្ថេរ ។

ព្រះថេរៈដឹងថា ព្រះសាស្តាយាងមក ទើបនិម្មិតវិហារជាទីនៅរបស់ខ្លួនឲ្យគ្រប់គ្រាន់ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន និងព្រះគន្ធកុដិ ទីសម្រាកពេលយប់ ទីសម្រាកពេលថ្ងៃជាដើម ថ្វាយព្រះទសពលដោយឫទ្ធិ ចេញទៅទទួលព្រះតថាគតហើយ ព្រះសាស្តាចូលកាន់វិហារ ដោយផ្លូវដែលប្រដាប់ហើយ តាក់តែងហើយ ។ គ្រានោះ កាលព្រះតថាគតយាងចូលព្រះគន្ធកុដិ ភិក្ខុទាំងឡាយ ក៏ចូលទៅកាន់សេនាសនៈ ដែលដល់ហើយតាមលំដាប់វស្សា ទេវតាគិតថា ពេលនេះ មិនមែនជាភត្តកាល ទើបនាំយកទឹកអដ្ឋបានមកថ្វាយ

ព្រះសាស្តាទ្រង់ឆាន់ទឹកអង្គបាន មួយអន្លើដោយភិក្ខុសង្ឃ ដោយទំនងនេះ កាលព្រះតថាគតទ្រង់សរសើរសក្ការៈ និងការរាប់អាន កន្លងទៅអស់កន្លះខែ គ្រានោះ ភិក្ខុដែលអង្គុយក្រុមក្នុងទីជាមួយគ្នា សន្ទនាគ្នាថា ព្រះ-ទសពលសាស្តាត្រាស់ថា ប្អូនប្រុសរបស់អគ្គសាវកនៃយើង ទ្រង់យាងមកសួរសុខទុក្ខ ដែលជានវកម្មិក គឺអ្នកកសាងបែបនេះ គិតថា ជេតពនមហាវិហារ ឬវេឡុវនមហាវិហារជាដើម នឹងធ្វើអ្វីក្នុងសម្នាក់នៃវិហារនេះបាន ភិក្ខុនេះ ជាអ្នកធ្វើនវកម្មបែបនេះ នឹងធ្វើសមណធម៌អ្វីបាន ដូច្នេះ ។

គ្រានោះ ព្រះសាស្តាទ្រង់តម្រិះថា កាលតថាគតនៅយូរ ទីនេះក៏នឹងវឹកវរ ធម្មតាភិក្ខុដែលនៅព្រៃជាវត្ត រមែងមានសេចក្តីត្រូវការនូវភាពស្ងប់ស្ងាត់ រេវតៈនឹងនៅដោយមិនមានផាសុក បន្ទាប់អំពីនោះ ទើបយាងទៅកាន់ទីសម្រាកពេលថ្ងៃរបស់ព្រះរេវតៈ ។

ព្រះថេរៈអង្គុយលើជុំថ្ម ផ្អែកបន្ទះក្តារដែលលំយុងចុះ ក្នុងទីបំផុតនៃទីចង្ក្រមតែមួយព្រះអង្គឯង ឃើញព្រះសាស្តាយាងមកអំពីចម្ងាយ ទើបថ្វាយបង្គំ ខណៈនោះ ព្រះសាស្តាត្រាស់សួរថា ម្នាលរេវតៈ ទីនេះជាទីប្រកបដោយម្រឹគសាហាវ អ្នកបានឮសំឡេងដំរី និងសេះជាដើមដែលកាច បានធ្វើដូចម្តេចក្នុងសំឡេងនោះ ។ ព្រះរេវតៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលខ្ញុំព្រះអង្គបានឮសំឡេងសត្វទាំងនោះ រមែងកើតបីតិនៅក្នុងព្រៃ ព្រះសាស្តាត្រាស់ព្រះតម្រាស់ ឈ្មោះអារញ្ញបសំសកថា ដោយគាថា ៥០០ ដល់ព្រះរេវតត្ថេរ ។ ស្អែកឡើង ទ្រង់យាងទៅដើម្បីបិណ្ឌបាតក្នុងទីមិនឆ្ងាយ

ហើយហៅព្រះរេវតៈមក ទ្រង់ធ្វើឲ្យពួកភិក្ខុដែលតិះដៀលព្រះថេរៈ ឲ្យភ្លេចឈើច្រត់ ស្បែកជើង ត្រឡោក ប្រេង និងឆត្រជាដើម ភិក្ខុទាំងនោះ ក៏ត្រឡប់មកដើម្បីយកបរិក្ខាររបស់ខ្លួន ដើរទៅផ្លូវដែលខ្លួនមកហើយនោះឯង ក៏កំណត់ទីកន្លែងដែលខ្លួនទុកដាក់មិនបាន ដំបូងភិក្ខុទាំងឡាយ ដើរទៅតាមផ្លូវដែលគេប្រដាប់តាក់តែងហើយ តែក្នុងថ្ងៃនោះ បែរជាដើរទៅតាមផ្លូវរដិបរដុប ត្រូវដើរចំអើតជើង ត្រូវដើរទៅដោយជន្គង់ក្នុងទីនោះៗ ភិក្ខុទាំងនោះ ខ្លះក៏ជាប់គុម្ពឈើ ជន្ទត់ឈើ និងបន្លា ក្នុងទីដែលទៅដល់ ត្រូវអធ្យាស្រ័យដែលខ្លួនធ្លាប់នៅ ក៏ជួបឆត្ររបស់ខ្លួនលើដើមគគីរនោះៗ ចាំស្បែកជើងឈើច្រត់ និងនាឡិប្រេងរបស់ខ្លួនបាន ក្នុងពេលនោះ ទើបពួកលោកដឹងថាភិក្ខុនេះជាអ្នកមានឫទ្ធិ កាលកាន់បរិក្ខាររៀងៗ ខ្លួន ហើយ ទើបពោលថាឈ្មោះថា សក្ការៈដែលខ្លួនតាក់តែងថ្វាយព្រះទសពល រមែងមានប្រមាណដល់ម៉្លេះ ហើយនាំគ្នាទៅ ។

នាងវិសាខាមហាឧបាសិកា សួរពួកភិក្ខុដែលទៅខាងមុខ ក្នុងវេលាដែលលោកគង់ក្នុងផ្ទះរបស់ខ្លួនថា បពិត្រលោកម្ចាស់ ទីលំនៅរបស់ព្រះរេវតៈ គួរជាទីពេញចិត្តដែរឬ ។ ភិក្ខុទាំងនោះឆ្លើយថា គួរពេញចិត្ត ឧបាសិកា សេនាសនៈនោះប្រៀបដូចសួនននន្ទវ័ន និងសួនចិត្តលតាជាដើម ។ ខណៈនោះ ទើបនាងសួរភិក្ខុដែលមកដល់តាមក្រោយភិក្ខុទាំងនោះថា បពិត្រលោកម្ចាស់ ទីលំនៅរបស់ព្រះរេវតៈគួរពេញចិត្តឬទេ ភិក្ខុទាំងនោះឆ្លើយថា កុំសួរឡើយ ឧបាសិកា ទីនោះជាទីដែលមិនគួរពោលដល់ ជាទីទួល មានដុំ

គ្រួស ដុំថ្ម ព្រៃគគីរយ៉ាងនេះ ភិក្ខុនោះគង់នៅក្នុងទីនោះបាន ។ មហាឧបាសិកាវិសាខាស្តាប់ពាក្យរបស់ភិក្ខុដែលមកមុន និងមកក្រោយហើយ គិតថា ពាក្យរបស់ភិក្ខុពួកណាជាពាក្យពិតហ្ន៎ ។ ក្នុងកាលក្រោយកត្ត កាន់យកគ្រឿងក្រអូប និងផ្កាទៅកាន់ទីគាល់ព្រះទសពល ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរ នាចំណែកម្ខាង ទើបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន លោកម្ចាស់អង្គខ្លះសរសើរលំនៅរបស់ព្រះរេវតៈ អង្គខ្លះតិះដៀលសេចក្តីនេះដូចម្តេចដែរ ព្រះអង្គ ។ ព្រះសាស្តាត្រាស់ថា ម្នាលវិសាខាមហាឧបាសិកា ទីដែលព្រះអរិយៈនៅ ជាទីគួរត្រេកអរ ឬមិនជាទីត្រេកអរ ចូរលើកទុកចុះ ចិត្តរបស់ព្រះអរិយៈ តែងត្រេកអរទាំងអស់ ទីនោះ ឈ្មោះថា ជាទីគួរត្រេកអរពិត ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**គាមេ វា យទិ វារញ្ញេ និន្នេ វា យទិ វា ថលេ**
**យត្ថ អរហន្តោ វិហរន្តិ តំ ភូមិរាមណេយ្យកំ។**

ព្រះអរហន្តទាំងឡាយ នៅក្នុងទីណា ទោះជាស្រុកក្តី ព្រៃក្តី
ទីទាបក្តី ទីទួលក្តី ទីនោះឯង ជាភូមិគួរត្រេកអរ ។

បន្ទាប់មក ក្នុងពេលខាងក្រោយ ព្រះសាស្តាប្រថាប់គង់ក្នុងកណ្តាលពួកព្រះអរិយៈ ក្នុងជេតពនមហាវិហារ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងជាកំពូលនៃពួកភិក្ខុទាំងឡាយ ដែលជាអ្នកមានប្រក្រតីនៅព្រៃជាវត្ត ដោយប្រការដូច្នេះ ។\ ល។

**អដ្ឋកថា សូត្រទី ៥ ចប់**

# អដ្ឋកថា សូត្រទី ៦

# ប្រវត្តិ ព្រះកង្ខារេវតត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៦ ដូចតទៅនេះ បទថា **ឈាយីនំ** បានដល់ អ្នកបានឈាន គឺអ្នកត្រេកអរក្រៃលែងក្នុងឈាន បានឮថា ព្រះថេរៈនោះ ឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលបានឈាន លោកចូលឈានដោយចំណែកច្រើន គឺតិចជាងព្រះទសពលដែលចូលសមាបត្តិតិចតួចប៉ុណ្ណោះ ព្រោះដូច្នោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលចូលឈាន ។ លោកបានឈ្មោះថា កង្ខារេវតៈ ព្រោះជាអ្នកច្រើនដោយសេចក្តីងឿងឆ្ងល់ សេចក្តីរំខាន អធិប្បាយថា កុក្កុច្ចកា បុគ្គលដែលមានសេចក្តីរំខាន ឈ្មោះថា សង្ស័យ ។ សួរថា ភិក្ខុដទៃមានសេចក្តីសង្ស័យមិនមានឬ ឆ្លើយថា មាន តែព្រះថេរៈនេះ ក្នុងវត្ថុដែលសមគួរ ក៏សង្ស័យ ព្រោះដូច្នោះ ភាពដែលព្រះថេរៈនោះ ជាអ្នកមានសេចក្តីសង្ស័យជាប្រក្រតីប្រាកដច្បាស់ហើយ ព្រោះហេតុនោះ ទើបឈ្មោះថា កង្ខារេវតៈ ។ ក្នុងបញ្ហាកម្មនោះ មានអនុសន្ធិដូចតទៅនេះ

បានឮថា ក្នុងពុទ្ធុប្បាទព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះថេរៈនេះទៅវិហារជាមួយមហាជន ដោយន័យខាងដើមនោះឯង ឈរស្តាប់ធម៌ ខាងចុងបរិស័ទ ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ គឺជាកំពូលនៃពួកភិក្ខុដែលត្រេកអរក្នុងឈាន ទើបគិតថា អាត្មាអញក៏គួរមានសភាពដូចភិក្ខុនេះក្នុងអនាគត ។ ចប់ទេសនា ទើបនិមន្តព្រះសាស្តាថ្វាយគ្រឿងសក្ការៈធំ ៧ ថ្ងៃ ដោយន័យមុននោះឯង ក្រាបទូលព្រះមានព្រះ

ភាគថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គមិនបានប្រាថ្នាសម្បត្តិដទៃ ដោយកម្ម គឺការធ្វើកុសលដ៏ក្រៃលែងនេះ តែខ្ញុំព្រះអង្គគប្បីជាកំពូលនៃពួកភិក្ខុដែលបានឈាន ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាមួយក្នុងអនាគត ដូចភិក្ខុដែលព្រះអង្គទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុអ្នកបានឈានកាលពីថ្ងៃ ៧ ថ្ងៃមុន លោកបានធ្វើសេចក្ដីប្រាថ្នាដូចបានពោលមកនេះ ព្រះសាស្ដាទ្រង់ប្រមើលអនាគត ទ្រង់ឃើញសេចក្ដីសម្រេច ទើបទ្រង់ព្យាករថា នាអនាគត ក្នុងទីបំផុតនៃមួយសែនកប្ប ព្រះពុទ្ធទ្រង់ព្រះនាមគោតម ទ្រង់នឹងកើតឡើង អ្នកនឹងបានជាកំពូលរបស់ពួកភិក្ខុអ្នកបានឈាន ក្នុងសាសនារបស់ព្រះអង្គ ដូច្នេះហើយ ទ្រង់យាងត្រឡប់ ។

បុរសនោះ ធ្វើសុចរិតកម្មដរាបដល់អស់ជីវិត វិលវល់នៅក្នុងទេវតានិងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទព្រះមានព្រះភាគនៃយើង លោកមកកើតក្នុងត្រកូលដែលមានភោគៈច្រើន ក្នុងក្រុងសាវត្ថី ទៅវិហារជាមួយមហាជន ដើម្បីស្ដាប់ធម៌ក្នុងបច្ឆាភត្ត ឈរស្ដាប់ធម្មកថារបស់ព្រះទសពលខាងចុងបរិស័ទ បាននូវសទ្ធា បព្វជ្ជាឧបសម្បទាហើយ ឲ្យព្រះមានព្រះភាគត្រាស់ប្រាប់កម្មដ្ឋាន ហើយធ្វើបរិកម្មក្នុងឈាន ជាអ្នកបានឈាន ធ្វើឈាននោះឯងឲ្យជាបាទ សម្រេចអរហត្តផល លោកសម្រាកតិចជាងសមាបត្តិដែលព្រះទសពលចូល ចូលសមាបត្តិដោយចំណែកច្រើន ទើបមានការជំនាញ ដែលសន្សំក្នុងឈានទាំងឡាយ ទាំងពេលថ្ងៃ និងពេលយប់ តមកខាងក្រោយ ព្រះសាស្ដាទ្រង់កាន់យកគុណនេះ ស្ថាបនាលោកក្នុងតំណែង

ជាកំពូលនៃពួកភិក្ខុអ្នកបានឈាន ។ លោកឈ្មោះថា កង្ខារេវតៈ ព្រោះជាអ្នកមានសេចក្តីសង្ស័យ ពោល គឺការរំខាន មានការវង្វេសកើតឡើងក្នុងវត្ថុទាំងឡាយ ដែលជាកប្បិយនោះឯង យ៉ាងនេះថា អាវុសោ ទឹកអំពៅជាអកប្បិយ ទឹកមូត្រ ជាអកប្បិយ ។

**អដ្ឋកថា សូត្រទី ៦ ចប់**

# អដ្ឋកថា សូត្រទី ៧

# ប្រវត្តិ ព្រះសោណកោឡិវិសត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ដូចតទៅនេះ បទថា **អារទ្ធវីរិយានំ** សេចក្តីថា បុគ្គលតាំងសេចក្តីព្យាយាមហើយ ជាអ្នកមានសេចក្តីព្យាយាមបរិបូណ៌ហើយ ។ បទថា **សោណោ កោឡិវិសោ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ បទថា **កោឡិវិសោ** ជាគោត្រ ។ ម្យ៉ាងទៀត សេចក្តីថា ឈ្មោះថា **កោឡិវេសោ** អធិប្បាយថា ក្មេងនៃត្រកូលវេស្សៈ ជាអ្នកដល់នូវទីបំផុតនៃឥស្សរៈ ព្រោះហេតុថា សេចក្តីព្យាយាមនៃពួកភិក្ខុដទៃ រមែងត្រូវធ្វើឲ្យចម្រើន តែរបស់ព្រះថេរៈ គប្បីអប់រំប៉ុណ្ណោះ ព្រោះដូច្នោះ ព្រះថេរៈនេះឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលមានសេចក្តីព្យាយាមប្រារព្ធហើយ ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលគប្បីពោលតាមលំដាប់ដូចតទៅនេះ

បានឮថា ក្នុងអតីតកាល ព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ ព្រះថេរៈនេះកើតក្នុងត្រកូលសេដ្ឋី ពួកញាតិដាក់ឈ្មោះរបស់លោកថា សិរិវឌ្ឍកុមារ។ លោកចម្រើនវ័យហើយ ទៅកាន់វិហារដោយន័យមុននោះឯង ឈរស្តាប់ធម៌ខាងចុងបរិស័ទ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈជាកំពូលនៃពួកភិក្ខុដែលមានសេចក្តីព្យាយាមប្រារព្ធហើយ ទើបគិតថា ឯអញក៏គួរមានសភាពដូចភិក្ខុនេះក្នុងអនាគត ចប់ទេសនា ទើបនិមន្តព្រះទសពលថ្វាយមហាទានអស់ ៧ ថ្ងៃ បានធ្វើសេចក្តីប្រាថ្នា ដោយន័យដែលពោលហើយនោះឯង ។ ព្រះសាស្តាទ្រង់ឃើញថា សេចក្តីប្រាថ្នារបស់បុរសនេះសម្រេច ទើបទ្រង់ព្យាករដោយន័យមុននោះឯង ទ្រង់ត្រឡប់ទៅកាន់វិហារ ឯសិរិវឌ្ឍសេដ្ឋីនោះ ធ្វើកុសលជាបអស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស កន្លងទៅអស់មួយសែនកប្ប កាលព្រះកស្សបទសពលបរិនិព្វានហើយ ក្នុងកប្បនេះ ព្រះសម្មាសម្ពុទ្ធនៃយើង ទ្រង់មិនទាន់កើតឡើង ក៏មកបដិសន្ធិក្នុងត្រកូលមួយ នាក្រុងពារាណសី លោកទៅលេងទឹកក្នុងស្ទឹងគង្គាមួយអន្លើដោយពួកសម្លាញ់របស់ខ្លួន កាលនោះ ព្រះបច្ចេកពុទ្ធមួយអង្គមានចីវរចាស់គ្រាំគ្រា ចូលអាស្រ័យក្រុងពារាណសី សាងបណ្ណសាលាត្រង់ច្រាំងស្ទឹងគង្គា តាំងចិត្តថា នឹងចាំវស្សា ទើបទៅរើសយកកំណាត់ឈើ និងវល្លិដែលទឹកនាំមក ។ កុមារនេះ មួយអន្លើដោយសម្លាញ់ដើរទៅ ហើយឈរអភិវាទ សួរថា លោកម្ចាស់ធ្វើអ្វី ព្រះបច្ចេកពុទ្ធពោលថា កៀកចូលវស្សាហើយ ជម្មតាបព្វជិត គួរបានទីលំនៅ កុមារពោលថា បពិត្រលោកម្ចាស់

ថ្ងៃនេះ សូមលោកម្ចាស់បន្ទន់ចាំមួយថ្ងៃសិន ស្អែកនេះ ខ្ញុំនឹងធ្វើលំនៅប្រគេនលោកម្ចាស់ ព្រះបច្ចេកពុទ្ធសម្រាកសម្រាន្តនៅ ព្រោះជាបុគ្គលមកហើយដោយតាំងចិត្តថា នឹងធ្វើសេចក្តីសង្គ្រោះកុមារនេះដូចគ្នា ។ កុមារនោះដឹងថាព្រះបច្ចេកពុទ្ធ ទ្រង់ទទួលនិមន្តន៍ហើយ ស្អែកឡើង ចាត់ចែងគ្រឿងសក្ការៈទៅឈរវង់ចាំព្រះបច្ចេកពុទ្ធដែលនិមន្តមក ។ ឯព្រះបច្ចេកពុទ្ធ ទ្រង់ប្រមើលមើលថា ថ្ងៃនេះ អាត្មាអញនឹងត្រាច់រកអាហារក្នុងទីណាហ្ន៎ ទើបទៅកាន់ទ្វារផ្ទះរបស់កុមារនោះ កុមារឃើញព្រះបច្ចេកពុទ្ធហើយ ក៏មានសេចក្តីស្រឡាញ់ទទួលបាត្រថ្វាយអាហារ និមន្តថា ខាងក្នុងវស្សានេះ សូមលោកម្ចាស់និមន្តមកកាន់ទ្វារផ្ទះរបស់ខ្ញុំប៉ុណ្ណោះ ។ ព្រះបច្ចេកពុទ្ធទទួលពាក្យនោះ ឆាន់ស្រេចហើយ ក៏ចៀសចេញទៅ ទើបទៅជាមួយសម្លាញ់របស់ខ្លួន ជួយគ្នាសាងបណ្ណសាលា ទីចង្ក្រម ទីសម្រាកពេលថ្ងៃ និងពេលយប់ ប្រគេនព្រះបច្ចេកពុទ្ធហើយស្រេចក្នុងមួយថ្ងៃប៉ុណ្ណោះ ។ កុមារនោះគិតថា ពេលព្រះបច្ចេកពុទ្ធចូលបណ្ណសាលា កក់ត្រង់ផ្ទៃដីដែលបូកដោយរបស់ពណ៌ខៀវស្រស់ កុំបីប្រឡាក់ជើងលោកឡើយ ទើបលាតសំពត់កម្ពលក្រហម មានតម្លៃមួយពាន់ ដែលជាសំពត់ដណ្តប់របស់ខ្លួន ក្រាលត្រង់ផែនដី ឃើញរស្មីសរីរៈរបស់ព្រះបច្ចេកពុទ្ធ ដូចគ្នានឹងពណ៌របស់សំពត់កម្ពល ក៏ជ្រះថ្លាក្រៃលែង ពោលថា ចាប់អំពីកាលដែលលោកម្ចាស់ជាន់ហើយ ពន្លឺនៃសំពត់កម្ពលនេះចាំងចែងក្រៃលែង យ៉ាងណា សូម្បីពណ៌នៃដៃ និងជើងរបស់ខ្ញុំ ក៏សូមមានពណ៌ដូចផ្កាសិរមាន់ ក្នុងទីដែលខ្ញុំកើតហើយ ដូច្នោះ សូម

ឲ្យផស្សៈទន់ដូចសំឡីដែលគេថ្ពចហើយអស់ ៧ ដង ។ កុមារនោះផ្គត់ផ្គង់ព្រះបច្ចេកពុទ្ធអស់ត្រៃមាស បានប្រគេនត្រៃចីវរ លុះបវារណាហើយ ព្រះបច្ចេកពុទ្ធមានបាត្រ និងចីវរបរិបូណ៌ហើយ ទើបទៅកាន់ភ្នំគន្ធមាទន៍វិញ ។

ឯកុលបុត្រនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្ស បដិសន្ធិក្នុងផ្ទះរបស់ឧសភសេដ្ឋី ក្នុងក្រុងកាលចម្បាក ។ ក្នុងពុទ្ធុប្បាទព្រះសម្មាសម្ពុទ្ធនៃយើងតាំងអំពីកុលបុត្រនោះបដិសន្ធិ គ្រឿងបណ្ណាការច្រើនពាន់មកក្នុងត្រកូលសេដ្ឋី ក្នុងថ្ងៃដែលកើតនោះឯង នគរទាំងមូលមានគ្រឿងសក្ការៈតែមួយដូចគ្នាបន្ទាប់មក ក្នុងថ្ងៃដាក់ឈ្មោះកុមារនោះ ឪពុកម្តាយគិតថា កូនរបស់យើងបាននាំឈ្មោះរបស់ខ្លួនមកហើយ ស្មើសរីរៈរបស់កូនយើង ដូចលាបដោយមាសឆ្អិនឆ្អៅ ព្រោះដូច្នោះ ទើបដាក់ឈ្មោះកុមារនោះថា សោណកុមារ ។ គ្រានោះសេដ្ឋីឲ្យកីលៀងទំនុកបម្រុងបុត្រនោះ ឲ្យចម្រើនដោយសេចក្តីសុខ ប្រៀបដូចទេវកុមារ ។ ការចាត់ចែងអាហារសម្រាប់កុមារនោះ មានហើយយ៉ាងនេះ គឺដំបូង ព្រោះស្រូវក្នុងទីប្រមាណ ៦០ ករីស ស្រោចដោយទឹក ៣ យ៉ាង យកផើងដាក់ទឹកដោះ និងទឹកក្រអូបច្រើនពាន់ផើង ចាក់ក្នុងប្រឡាយទឹកដែលបង្ហូរចូលទៅក្នុងស្រែទួល ក្នុងកាលក្ដួរស្រូវដាក់ទឹកដោះ ក៏បោះបង្គោលជុំវិញ និងក្នុងចន្លោះៗ ដើម្បីការពារសត្វទាំងឡាយ មានសេកជាដើម ធ្វើជាទួល និងដើម្បីឲ្យក្ដួរស្រូវមានគ្រាប់ល្អ លាតសំពត់កម្ពលទុកលើបង្គោល យកសំពត់ពាសខាងលើ បាំងដោយកន្ទេលផែង បាំងរាំងននដោយជុំវិញ រៀបចំការរក្សា ក្នុងទីជុំវិញគ្រប់ចំណែក កាលស្រូវទុំ ជញ្ជូនដាក់ជង្រុក ក៏

ប្រោះព្រំដោយគន្ធជាតិ ៤ យ៉ាង អប់ដោយគ្រឿងក្រអូបដ៏ល្អទុកខាងលើ ។ ពួកមនុស្សច្រើនសែននាំគ្នាច្រូតស្រូវសាលី ធ្វើជាបាច់ៗ ចងដោយខ្សែហាលឲ្យស្ងួត បន្ទាប់អំពីនោះ ក្រាលគ្រឿងក្រអូបត្រង់បាតជង្រុក ដាក់កួរស្រូវទុកខាងលើ ផ្សាយទៅឲ្យមានចន្លោះយ៉ាងនេះ រហូតពេញជង្រុក ទើបបិទទ្វារកាលគ្រប់ ៣ ឆ្នាំ ទើបបើកជង្រុក កាលបើកក៏មានក្លិនក្រអូបឈ្ងុយពេញព្រះនគរ កាលបោកបែនស្រូវសាលី ពួកអ្នកលេងកីឡា ក៏នាំគ្នាមកទិញអង្កាមយកទៅ ឯកន្ទក់ចុល្លុបដ្ឋាកបានយកទៅ វេលាបុកដោយអង្រែ ក៏មកកើបយកអង្ករទៅ មនុស្សទាំងនោះដាក់អង្ករនោះក្នុងកំប្រោងស្ពាមាស ជ្រមុជចុះម្តងក្នុងជាតិរស ដាក់អង្ករក្នុងកំប្រោង ដែលត្បាញដោយស្ពាមាស ដាក់ជាតិរស គឺទឹកច័នដែលនៅក្តៅ ដែលត្រងអស់ ៧ ដង យកមកម្តងហើយក៏លើកឡើង ទឹកផ្ទៃច័នដែលក្តៅហើយ ដែលគេត្រងអស់ ៧ ដង ហើយលើកឡើងត្រងអង្ករផុតពីទឹកហើយ ក៏ដូចជាផ្កាម្លិះ ទើបជនទាំងឡាយដាក់ភោជនទោះក្នុងថាសមាស តម្រួតលើថាសប្រាក់ដែលពេញដោយមធុបាយាសមានទឹកតិច ដែលនៅក្តៅ កាន់យកទៅទុកខាងមុខសេដ្ឋីបុត្រ ។ សេដ្ឋីបុត្រនោះបរិភោគល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅសម្រាប់ខ្លួន លាងមាត់ដោយទឹកដែលអប់ដោយគ្រឿងក្រអូប ហើយលាងដៃ និងជើង ពេលនោះ ទើបនាំគ្រឿងអប់មាត់ មានប្រការផ្សេងៗ មកឲ្យដល់សេដ្ឋីបុត្រនោះ ដែលបានលាងដៃ និងជើងហើយ លាតនូវកម្រាលដ៏វិចិត្រ ដោយសំពត់សម្បកឈើយ៉ាងល្អ ក្នុងទីដែលសេដ្ឋីនោះជាន់ ។ បាតដៃ និងបាតជើងរបស់សេដ្ឋីនោះ

មានពណ៌ដូចផ្កាសិរមាន់ រោមដែលមានពណ៌ដូចពណ៌កែវមណី និងកែវកុណ្ឌលកើតត្រង់បាតជើង មានសម្បុរទន់ ដូចសំឡីដែលគេថ្ពចអស់ ៧ ដង សេដ្ឋីបុត្រនោះអាក់អន់ចិត្តនឹងបុគ្គលណា ក៏ពោលថា ចូរជើង ខ្ញុំនឹងជាន់ផែនដី ។ កាលលោកចម្រើនវ័យហើយ ឲ្យសាងប្រាសាទ ៣ ដែលសមគួរដល់រដូវ ៣ ហើយឲ្យអ្នករបាំបម្រើសេដ្ឋីបុត្រនោះ សោយមហាសម្បត្តិ នៅអាស្រ័យដូចទេវតា ។

បន្ទាប់មក កាលព្រះសាស្តានៃយើង ទ្រង់ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណ ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរហើយ អាស្រ័យក្រុងរាជគ្រឹះប្រថាប់នៅ សេដ្ឋីបុត្រនោះ កាលព្រះបាទមគធៈត្រាស់ហៅមក ដើម្បីទតរោមដែលដុះត្រង់បាតជើង ហើយបញ្ជូនទៅគាល់ព្រះសាស្តា មួយអន្លើដោយពួកអ្នកស្រុក ៨ ម៉ឺននាក់ ស្តាប់ព្រះធម្មទេសនា បាននូវសទ្ធា ទើបសូមបព្វជ្ជាជាមួយព្រះសាស្តា កាលនោះ ព្រះមានព្រះភាគត្រាស់សួរថា មាតាបិតារបស់អ្នកអនុញ្ញាតហើយឬ ។ ទ្រង់បានឮថា មិនទាន់អនុញ្ញាត ទើបទ្រង់ហាមថា ម្នាលសោណៈ តថាគតមិនឲ្យកុលបុត្រ ដែលមាតាបិតាមិនអនុញ្ញាតឲ្យបួសឡើយ ។ សេដ្ឋីបុត្រនោះទទួលព្រះតម្រាស់របស់ព្រះតថាគតដោយសិរសា គឺត្បូង ពោលថា សាធុ ព្រះអង្គ ទើបទៅរកមាតាបិតា ញុំាងលោកឲ្យអនុញ្ញាតហើយ ទើបត្រឡប់មកគាល់ព្រះតថាគត បានបួសក្នុងសម្នាក់នៃភិក្ខុមួយរូប នេះជាការសង្ខេបក្នុងរឿងនេះ ដោយពិស្តារពិធីបព្វជ្ជារបស់លោក មកហើយក្នុងបាលីនោះឯង ។

កាលលោកបានបព្វជ្ជាឧបសម្បទាហើយ នៅក្នុងក្រុងរាជគ្រឹះ ពួកញាតិ និងសាច់សាលោហិត មួយអន្លើដោយមិត្រសម្លាញ់ជាច្រើន នាំគ្រឿងសក្ការៈមក ពោលសរសើរការសម្រេចនៃរូប សូម្បីអ្នកដទៃក៏នាំគ្នាមកមើលព្រះថេរៈគិតថា ជនជាច្រើនមកកាន់សម្នាក់របស់អាត្មាអញ អញនឹងធ្វើកិច្ចកម្មក្នុងកម្មដ្ឋាន ឬក្នុងវិបស្សនាបានដូចម្ដេច បើដូច្នោះ អាត្មាអញគប្បីរៀនកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដា ហើយទៅកាន់ព្រៃសីតវ័ន បំពេញសមណធម៌ ព្រោះបុគ្គលជាច្រើន ស្អប់ព្រៃសីតវ័ននោះ នឹងមិនទៅ កាលបើយ៉ាងនេះ កិច្ចរបស់អញនឹងដល់ទីបំផុតបាន ទើបទទួលកម្មដ្ឋានក្នុងសម្នាក់របស់ព្រះសាស្ដា ហើយទៅកាន់សីតវ័ន ផ្ដើមបំពេញសមណធម៌ លោកគិតថា សរីរៈរបស់អញសុខុមក្រៃលែង តែមិនអាចឲ្យដល់សេចក្ដីសុខ ដោយការសម្រាន្តនោះឯង ទោះបីលំបាកកាយ ក៏គួរបំពេញសមណធម៌ បន្ទាប់ពីនោះ ទើបអធិដ្ឋានការឈរ និងការចង្ក្រម មានតែលោហិតតែម្យ៉ាង កាលដើរដើរមិនបាន ក៏ព្យាយាមចង្ក្រមដោយជង្គង់ខ្លះ ដោយដៃខ្លះ សូម្បីធ្វើសេចក្ដីព្យាយាមយ៉ាងមាំទាំដល់ម្ល៉េះ ក៏មិនអាចធ្វើគុណត្រឹមតែឱកាសឲ្យកើតឡើង ទើបគិតថា បើអ្នកដទៃគប្បីប្រារព្ធសេចក្ដីព្យាយាម គប្បីជាបុគ្គលដូចអញនេះឯង តែអាត្មាអញព្យាយាមយ៉ាងនេះ ក៏មិនអាចធ្វើមគ្គ ឬផលឲ្យកើតឡើងបាន អញមិនមែនឧគ្ឃដិតញ្ញូបុគ្គល ឬមិនមែនវិបចិតញ្ញូបុគ្គល មិនមែនទេយ្យបុគ្គល អញជាបទបរមបុគ្គលពិត ប្រយោជន៍អ្វីដោយបព្វជ្ជា អញនឹងសឹកទៅបរិភោគភោគៈ និងធ្វើបុណ្យ គ្រានោះ ព្រះសាស្ដាទ្រង់ជ្រាប

បរិវិតក្ករបស់ព្រះថេរៈ ពេលល្ងាច ទ្រង់មានពួកភិក្ខុហែហមទៅក្នុងស្មសាន សីតវ័ននោះ ទតឃើញទីចង្ក្រមប្រឡាក់ឈាម ទ្រង់ប្រទានឱវាទព្រះថេរៈ ដោយឱវាទដែលប្រៀបធៀបដោយពិណា ត្រាស់ប្រាប់កម្មដ្ឋានដល់ព្រះថេរៈ ដើម្បីឲ្យប្រកបសេចក្តីព្យាយាមធូរថយចុះមកខ្លះ រួចទ្រង់យាងទៅកាន់ភ្នំគិជ្ឈ-កូដ ឯព្រះសោណត្ថេរបានឱវាទ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះទសពល មិនយូរប៉ុន្មានក៏តាំងនៅក្នុងអរហត្តផល ។ បន្ទាប់មក ក្នុងកាលឯក្រោយ ព្រះសាស្តាមានពួកភិក្ខុចោមរោម ទ្រង់សម្តែងធម៌ក្នុងជេតវ័នវិហារ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងជាកំពូល នៃពួកភិក្ខុដែលប្រារព្ធព្យាយាម ។

## អដ្ឋកថាសូត្រទី ៧ ចប់

# អដ្ឋកថា សូត្រទី ៨

## ប្រវត្តិ ព្រះសោណកុដិកណ្ណត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ដូចតទៅ ពាក្យសម្តី លោកហៅថា **វាក្ករណា** ក្នុងបទថា **កល្យាណវាក្ករណានំ** អធិប្បាយថា ពាក្យសម្តីដ៏វិចិត្រ គឺពាក្យដ៏ពីរោះ ៗ ពិតហើយ ព្រះថេរៈនេះ ពោលធម្មកថាដោយសំឡេងដ៏ពីរោះដល់ព្រះតថាគតក្នុងព្រះគន្ធកុដិ ដូចគ្នានឹងព្រះទសពល ។ គ្រានោះ ព្រះសាស្តាបានប្រទានសាធុការដល់លោក ព្រោះដូច្នោះ ទើបព្រះថេរៈឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលមានវាចាពីរោះ ៗ បទថា **សោណា** ជាឈ្មោះរបស់លោក តែដោយលោកទ្រទ្រង់នូវកុណ្ឌលដែលមានតម្លៃដល់មួយកោដិ ព្រោះដូច្នោះ ទើបហៅថា **កុដិកណ្ណា** ដោយសេចក្តីថា ព្រះសោណៈមានកុណ្ឌលតម្លៃមួយកោដិ ។ ក្នុងបញ្ហាកម្មរបស់លោក មានវត្ថុដែលគប្បីពោលតាមលំដាប់ដូចតទៅនេះ

ព្រះថេរៈនេះ ក្នុងពុទ្ធកាលព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ បានទៅវិហារជាមួយមហាជនដោយន័យមុននោះឯង ឈរស្តាប់ធម៌ខាងចុងបរិស័ទ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាឯតទគ្គៈរបស់ពួកភិក្ខុ ដែលមានវាចាពីរោះ ទើបគិតថា ឯអាត្មាអញ គួរជាកំពូលនៃពួកភិក្ខុដែលមានវាចាពីរោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គឯណានីមួយ ក្នុងអនាគត ទើបនិមន្តព្រះទសពល ថ្វាយទានអស់ ៧ ថ្ងៃ បានធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ទ្រង់តាំងភិក្ខុណាទុកក្នុងតំណែងភិក្ខុមានវាចាពីរោះ កាលពី ៧ ថ្ងៃមុន សូមឱ្យខ្ញុំព្រះអង្គគប្បីបានដូចភិក្ខុនោះ ក្នុងសាសនារបស់ព្រះពុទ្ធអង្គឯណា

ទីមួយក្នុងអនាគត ដោយផលនៃកុសលកម្មនេះ ។ ព្រះសាស្តាទ្រង់ឃើញថា មិនមានអន្តរាយសម្រាប់លោក ទើបទ្រង់ព្យាករថា អ្នកនឹងបានជាកំពូលនៃពួកភិក្ខុដែលមានវាចាពីរោះ ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ក្នុងអនាគតកាល ហើយទ្រង់ត្រឡប់ទៅ ។ ឯលោកក៏ធ្វើកុសលកម្មរហូតដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ចុតិអំពីទេវលោក មកបដិសន្ធិក្នុងផ្ទៃនៃឧបាសិកាដែលជាមេផ្ទះ របស់ត្រកូលមួយឈ្មោះថា កាលិ មុនព្រះទសពលទ្រង់កើតឡើង នាងមានគភ៌គ្រប់ហើយ មកកាន់និវេសន៍នៃត្រកូលរបស់ខ្លួន ក្នុងក្រុងរាជគ្រឹះ ។

សម័យនោះ ព្រះសាស្តានៃយើង ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ រួចទ្រង់ប្រកាសធម្មចក្រក្នុងជង្រៃឥសិបតនៈហើយ ទេវតាក្នុងម៉ឺនចក្កវាឡ មកប្រជុំគ្នាហើយក្នុងទីប្រជុំនោះ យក្ខម្នាក់ឈ្មោះសាតាគិរយក្ខ ក្នុងចំណោមយក្ខសេនាបតី ២៨ នាក់ ស្តាប់នូវធម្មកថារបស់ព្រះទសពល តាំងនៅក្នុងសោតាបត្តិផល ហើយត្រិះរិះថា ធម្មកថាដ៏ពីរោះនេះ ហេមវតយក្ខសម្លាញ់របស់អញបានស្តាប់ ឬមិនបានស្តាប់ហ្ន៎ ។ យក្ខនោះរកមើលក្នុងពពួកទេវតា ក៏មិនឃើញសម្លាញ់របស់ខ្លួន ទើបគិតថា សម្លាញ់របស់អញមិនដឹងថា រតនៈទាំង ៣ កើតឡើងហើយពិត អញនឹងទៅពោលគុណនៃព្រះទសពលដល់គេ នឹងប្រាប់ដល់ធម៌ដែលអញសម្រេចផងដែរ ទើបទៅរកហេមវតយក្ខនោះ ដោយហោះកាត់ខាងលើក្រុងរាជគ្រឹះ ជាមួយបរិស័ទខ្លួន ។

ឯហេមវតយក្ខឃើញព្រៃហិមពាន្ត ទំហំដល់ទៅ ៣ ពាន់យោជន៍ មាន

ផ្កាឈើរីកស្គុសស្គាយពុំដូកាល គិតថា អញនឹងលេងក្នុងព្រៃហិមពាន្តជាមួយសម្លាញ់របស់អញ ទើបទៅជាមួយបរិស័ទរបស់ខ្លួន កាត់ខាងលើក្រុងរាជគ្រឹះដូចគ្នា ។ យក្ខទាំងនោះ ក៏មកជួបគ្នាខាងលើនិវេសន៍របស់ឧបាសិកា ក្នុងខណៈនោះ ក៏សួរគ្នាថា ពួកអ្នកជាបរិស័ទរបស់អ្នកណា យក្ខម្ខាងទៀតពោលថា ពួកយើងជាបរិស័ទរបស់សាតាគិរយក្ខ ចុះពួកអ្នកជាបរិស័ទរបស់អ្នកណា យក្ខម្ខាងទៀតពោលថា យើងជាបរិស័ទរបស់ហេមវតយក្ខ ដូច្នេះ ពួកយក្ខទាំងនោះត្រេកអររីករាយរកគ្នានិងគ្នាហើយ ទៅប្រាប់ដល់យក្ខសេនាបតីទាំងនោះ សាតាគិរយក្ខពោលនឹងហេមវតយក្ខថា អើ សម្លាញ់ អ្នកទៅណា ហេមវតយក្ខឆ្លើយថា អើ សម្លាញ់ ខ្ញុំទៅកាន់សម្នាក់ឯង សាតាគិរយក្ខពោលថា ព្រោះហេតុអ្វី ហេមវតយក្ខពោលថា ខ្ញុំឃើញព្រៃហិមពាន្ត មានផ្ការីកស្គុសស្គាយ យើងនឹងទៅលេងក្នុងព្រៃហិមពាន្តជាមួយឯង ។ សាតាគិរីយក្ខពោលថា អើ សម្លាញ់ ឯងទៅបានដូចម្តេច ឯងដឹងថា ព្រៃហិមពាន្តមានផ្ការីកស្គុសស្គាយ ដោយហេតុអ្វីទេ ហេមវតៈពោលថា ខ្ញុំមិនដឹងទេ សាតាគិរយក្ខពោលថា សិទ្ធត្ថកុមារជាកូនរបស់ព្រះបាទសុទ្ធោទនមហារាជញុំាងលោកធាតុមួយម៉ឺនឲ្យញាប់ញ័រហើយ ត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណទ្រង់ប្រកាសធម្មចក្រដ៏កំពូល ក្នុងកណ្តាលពួកទេវតាក្នុងម៉ឺនចក្កវាឡ ឯងមិនដឹងថា ធម្មចក្រនោះទ្រង់ប្រកាសហើយទេឬ ។ ហេមវតៈពោលថា ខ្ញុំមិនដឹងទេ សម្លាញ់ ។ សាតាគិរយក្ខពោលថា ឯងសម្គាល់ថា ទីមានប្រមាណប៉ុណ្ណោះ មានផ្ការីកស្គុសស្គាយ តែម៉ឺនចក្កវាឡទូទៅដូចផ្កាមួយគំនរក្នុងថ្ងៃ

នេះ ដើម្បីសក្ការៈមហាបុរសនោះ ។ ហេមវតៈពោលថា ព្រះសាស្តានោះ អ្នកឃើញនឹងភ្នែកហើយឬ សាតាគិរយក្ខពោលថា អើ ហេមវតៈសម្លាញ់ ខ្ញុំឃើញព្រះសាស្តាហើយ ខ្ញុំស្តាប់ធម៌ហើយ ខ្ញុំផឹកអមតៈហើយ ខ្ញុំនឹងធ្វើអ្នកឲ្យដឹងអមតធម៌នោះដែរ ទើបខ្ញុំមកកាន់សម្នាក់របស់ឯង ។ កាលយក្ខទាំងនោះកំពុងចរចាគ្នា ឧបាសិកាក្រោកឡើងអំពីដំណេកដ៏មានសិរី អង្គុយស្តាប់ការសន្ទនានោះ កាន់យកនិមិត្តក្នុងសំឡេង កំណត់ថា សំឡេងនេះជាសំឡេងខាងលើ មិនមែនខាងក្រោម ជាសំឡេងអមនុស្សនិយាយ មិនមែនសំឡេងមនុស្សនិយាយ ទើបផ្ទៀងនូវសោតៈ ផ្គងចិត្ត ។ បន្ទាប់ពីនោះ សាតា-គិរីយក្ខពោលថា

**អជ្ជ បណ្ណរសោ ឧបោសថោ ទិព្វា រត្តិ ឧបដ្ឋិតា**
**អនោមនាមំ សត្ថារំ ហន្ទ បស្សាម គោតមំ ។**

នេះជាថ្ងៃ ១៥ កើតឧបោសថ រាត្រីដ៏ជាទិព្វប្រាកដហើយ មកយើងទាំងពីរទៅគាល់ព្រះគោតម ដែលមានព្រះនាមមិនថោកថយចុះ ។ សាតាគិរយក្ខពោលដូច្នេះហើយ ហេមវតយក្ខពោលថា

**កច្ចិ មនោ សុបណិហិតោ សព្វភូតេសុ តាទិនោ**
**កច្ចិ ឥដ្ឋេ អនិដ្ឋេ ច សង្កប្បស្ស វសីកតា ។**

ព្រះគោតមជាតាទិបុគ្គល ទ្រង់តម្កល់ព្រះហឫទ័យទុកល្អហើយ ក្នុងសត្វទាំងពួងឬ ព្រះគោតមទ្រង់ធ្វើសេចក្តីត្រិះរិះក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ឲ្យនៅក្នុងអំណាចឬ ។

ហៅមវតយក្ខសួរដល់កាយសមាចារ អាជីវៈ និងមនោសមាចាររបស់ព្រះសាស្តាយ៉ាងនេះហើយ សាតាគិរយក្ខវិសជ្ជនាសេចក្តីដែលហេមវតយក្ខសួរហើយ កាលចប់ហេមវតសូត្រហើយ តាមការពេញចិត្ត ដោយការពោលគុណនៃសរីរវណ្ណៈរបស់ព្រះសាស្តាយ៉ាងនេះហើយ ហេមវតយក្ខបញ្ជូនញាណទៅតាមក្រសែនៃធម្មទេសនារបស់សម្ចាញ់ តាំងនៅក្នុងសោតាបត្តិផលហើយ គ្រានោះ នាងកាឡីឧបាសិកា សូម្បីមិនធ្លាប់ឃើញព្រះតថាគត ក៏កើតសេចក្តីជ្រះថ្លា ដែលបានស្តាប់ក្នុងធម៌ ដែលគេសម្តែងដល់បុគ្គលដទៃ តាំងនៅក្នុងសោតាបត្តិផលហើយ ដូចបរិភោគភោជនដែលគេរៀបចំសម្រាប់អ្នកដទៃដូច្នោះ ឧបាសិកានោះ ជាព្រះសោតាបន្នដំបូងក្នុងរវាងស្រីទាំងឡាយ និងជាប្រធាននៃស្រីទាំងអស់ ។ ក្នុងយប់នោះ នាងក៏ប្រសូត្របុត្រ ដំណាលគ្នានឹងការសម្រេចសោតាបត្តិផល ក្នុងថ្ងៃដាក់ឈ្មោះទារកដែលបានមកហើយ ក៏ឲ្យឈ្មោះថា សោណៈ ឧបាសិកានោះ នៅក្នុងផ្ទះនៃត្រកូលតាមការពេញចិត្តហើយ បានទៅកាន់កុលឃរនគរ ។

សម័យនោះ ព្រះមហាកច្ចាយនត្ថេរអាស្រ័យក្រុងនោះ នៅត្រង់ភ្នំឧបវត្ត ឧបាសិកាបានឧបដ្ឋាកព្រះថេរៈៗ ទៅកាន់និវេសន៍របស់នាងជាប្រចាំ កុមារសោណៈ ក៏ត្រាច់លេងក្នុងសម្នាក់របស់ព្រះថេរៈជាប្រចាំ ទើបមានការស្និទ្ធស្នាល បន្ទាប់មក កុមារនោះបព្វជ្ជាក្នុងសម្នាក់របស់ព្រះថេរៈៗ បំណងនឹងឲ្យលោកឧបសម្បទា ស្វែងរកភិក្ខុអស់ ៣ ឆ្នាំ ទើបគ្រប់គណៈឲ្យឧបសម្បទាបាន លោកឧបសម្បទាហើយ ឲ្យព្រះថេរៈប្រាប់កម្មដ្ឋាន ចម្រើន

វិបស្សនា សម្រេចអរហត្តហើយ រៀនគម្ពីរសុត្តនិបាត ក្នុងសម្នាក់របស់ព្រះថេរៈ ចេញវស្សា បវារណាហើយ បំណងនឹងគាល់ព្រះសាស្តា ទើបលាព្រះឧបជ្ឈាយ៍ ព្រះថេរៈពោលថា សោណៈ កាលអ្នកទៅហើយ ព្រះសាស្តានឹងឲ្យអ្នកនៅក្នុងព្រះគន្ធកុដិ និងនិមន្តឲ្យអ្នកពោលធម៌ ព្រះសាស្តាទ្រង់ជ្រះថ្លាក្នុងធម្មកថារបស់អ្នក នឹងប្រទានពរដល់អ្នក កាលអ្នកទទួលពរ ចូរទទួលយកពរយ៉ាងនេះ ចូរថ្វាយបង្គំព្រះបាទរបស់ព្រះទសពលតាមពាក្យខ្ញុំ ។ ព្រះសោណៈនោះ កាលព្រះឧបជ្ឈាយ៍អនុញ្ញាតហើយ ទើបទៅប្រាប់ដល់ញោមឧបាសិកា សូម្បីឧបាសិកានោះក៏ពោលថា សាធុ លោកម្ចាស់ កាលលោកម្ចាស់ទៅគាល់ព្រះទសពល សូមយកសំពត់កម្ពលនេះទៅ សូមក្រាលធ្វើឲ្យជាសំពត់ទ្រនាប់ផ្ទៃក្នុងព្រះគន្ធកុដិ ជាទីប្រថាប់របស់ព្រះសាស្តា ហើយថ្វាយសំពត់កម្ពលផ្ទាំងធំទៅ ព្រះសោណត្ថេរទទួលសំពត់នោះទៅ ហើយទុកដាក់សេនាសនៈ ទៅដល់ទីប្រថាប់របស់ព្រះសាស្តាដោយលំដាប់ ចូលទៅគាល់ក្នុងវេលាដែលព្រះទសពល ប្រថាប់គង់លើពុទ្ធាសនៈ ថ្វាយបង្គំហើយ បានឈរក្នុងទីសមគួរ នាចំណែកម្ខាង ។

ព្រះសាស្តា ទ្រង់ធ្វើបដិសណ្ឋារៈនឹងព្រះថេរៈនោះហើយ ត្រាស់ហៅព្រះអានន្ទមក ត្រាស់ថា អានន្ទ ចូររៀបចំសេនាសនៈសម្រាប់ភិក្ខុរូបនេះ ព្រះថេរៈដឹងព្រះបំណងនៃព្រះសាស្តា បានលាតសំពត់ហើយ លាតសំពត់កម្រាលផ្ទៃទុកត្រង់កណ្តាល ខាងក្នុងព្រះគន្ធកុដិ ។ គ្រានោះឯង ព្រះមានព្រះភាគទ្រង់សម្រាកសម្រាន្តក្នុងទីវាល អស់រាត្រីដ៏ច្រើន ទើបយាងចូលព្រះវិហារ

សូម្បីព្រះសោណៈក៏សម្រាកក្នុងទីវាល អស់រាត្រីដ៏ច្រើនដូចគ្នា ទើបចូលវិហារ ព្រះសាស្តាទ្រង់ផ្ទំសីហសេយ្យាសនៈ ក្នុងមជ្ឈិមយាម ទ្រង់តើនឡើងប្រថាប់គង់ក្នុងសម័យទៀបភ្លឺ ទ្រង់ជ្រាបថា សេចក្តីលំបាកកាយរបស់ព្រះសោណៈនឹងស្ងប់រម្ងាប់ ដោយហេតុមានប្រមាណប៉ុណ្ណេះ ហើយនិមន្តឲ្យពោលធម៌ ។ ព្រះសោណត្ថេរបានពោលព្រះសូត្រ ដែលទាក់ទងដោយអដ្ឋកវគ្គ ព្យញ្ជនៈមួយក៏មិនខូច ដោយសំឡេងដ៏ពីរោះ កាលចប់គាថា ព្រះមានព្រះភាគ ទ្រង់ប្រទានសាធុការ ប្រកាសដល់សេចក្តីជ្រះថ្លាថា ម្នាលភិក្ខុ ធម៌អ្នករៀនល្អហើយ ទេសនាក្នុងពេលដែលតថាគតសម្តែងហើយក្តី ក្នុងថ្ងៃនេះក្តី ដូចគ្នាតែមួយ មិនខ្វះ មិនលើសឡើយ ។ ឯព្រះសោណៈកំណត់ថា នេះជាឱកាស ហើយថ្វាយបង្គំព្រះទសពលតាមពាក្យរបស់ព្រះឧបជ្ឈាយ៍ ទូលសូមពរគ្រប់យ៉ាង ចាប់ផ្តើមតាំងអំពីការឧបសម្បទា ដោយគណៈ មានព្រះវិនយធរជាគម្រប់ ៥ ព្រះសាស្តាទ្រង់ប្រទានហើយ បន្ទាប់មក ព្រះថេរៈថ្វាយបង្គំតាមពាក្យរបស់ឧបាសិកាជាមាតាថា បពិត្រព្រះមានព្រះភាគ ឧបាសិកាបញ្ជូនសំពត់កម្ពលនេះមក ដើម្បីក្រាលផ្ទៃក្នុងព្រះគន្ធកុដិ ដែលប្រថាប់របស់ព្រះអង្គ ហើយថ្វាយសំពត់កម្ពល ក្រោកឡើងអំពីអាសនៈ ថ្វាយបង្គំព្រះ-សាស្តា ធ្វើប្រទក្សិណ ចៀសចេញទៅហើយ ។ ក្នុងរឿងនេះ មានសេចក្តីសង្ខេបប៉ុណ្ណេះ តែដោយពិស្តារ រឿងតាំងអំពីការចេញបព្វជ្ជារបស់ព្រះថេរៈទាំងអស់ មកក្នុងព្រះសូត្រហើយ ។

ដូចពោលមកនេះ ព្រះថេរៈបានពរ ៨ ប្រការអំពីសម្នាក់ព្រះសាស្តា

ហើយ ត្រឡប់ទៅកាន់សម្នាក់ព្រះឧបជ្ឈាយ៍ ពោលបវត្តិហេតុទាំងពួងនោះហើយ ។ ថ្ងៃស្អែកឡើង ទៅកាន់ទ្វារនិវេសន៍របស់ញោមឧបាសិកា ឈររង់ចាំអាហារ ឧបាសិកាស្តាប់ដំណឹងថា កូនរបស់ខ្លួនមកឈរត្រង់ទ្វារ ទើបប្រញាប់មកអភិវាទហើយ ទទួលបាត្រអំពីដៃ និមន្តឲ្យគង់ក្នុងនិវេសន៍របស់ខ្លួន ថ្វាយភោជនហើយ ។ លុះឆាន់ស្រេច ឧបាសិកាពោលថា លោកម្ចាស់បានជួបព្រះទសពលហើយឬ ។ ព្រះថេរៈពោលថា ជួបហើយឧបាសិកា ។ ឧបាសិកាពោលថា លោកម្ចាស់បានថ្វាយបង្គំតាមពាក្យរបស់ញោមហើយឬ។ ព្រះថេរៈពោលថា បានថ្វាយបង្គំហើយ សំពត់កម្ពលរបស់យើងនោះ បានក្រាលឲ្យជាសំពត់កម្រាលផ្លូវ ក្នុងទីប្រថាប់របស់ព្រះតថាគតហើយ ។ ឧបា-សិកាពោលថា បពិត្រលោកម្ចាស់ បានឮថា លោកម្ចាស់ពោលធម្មកថាថ្វាយព្រះសាស្តាៗ ទ្រង់បានប្រទានសាធុការដល់លោកម្ចាស់ឬ ។ ព្រះថេរៈដេញដោលសួរថា ញោមដឹងបានដូចម្តេច ។ ឧបាសិកាពោលថា ទេវតាដែលស្ថិតនៅក្នុងផ្ទះរបស់ញោមប្រាប់ថា ទេវតាក្នុងម៉ឺនចក្កវាឡបានថ្វាយសាធុការកាលព្រះសាស្តាប្រទានសាធុការដល់លោក ហើយពោលថា បពិត្រលោកម្ចាស់ ញោមសង្ឃឹមថា លោកម្ចាស់គួរពោលធម៌ ដូចដែលលោកម្ចាស់ពោលហើយដល់ញោមខ្លះ ដោយទំនងដែលបានពោលដល់ព្រះសម្ពុទ្ធ ។ ព្រះថេរៈទទួលពាក្យរបស់ញោមហើយ ។ នាងដឹងថា ព្រះថេរៈទទួលពាក្យហើយ ទើបឲ្យធ្វើមណ្ឌបក្បែរទ្វារ និមន្តឲ្យពោលធម៌ដល់ខ្លួន ដោយទំនងដែលពោលដល់ព្រះទសពលហើយ ។ រឿងបានកើតហើយក្នុងទីនេះ ។ បន្ទាប់មក ព្រះ

សាស្តាប្រថាប់គង់ក្នុងចំណោមពួកព្រះអរិយៈ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ដែលមានវាចាពីរោះហើយ ។

**អដ្ឋកថា សូត្រទី ៨ ចប់**

## អដ្ឋកថា សូត្រទី ៩
## ប្រវត្តិ ព្រះសីវលិត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៩ ដូចតទៅនេះ បទថា **លាភីនំ យទិទំ សីវលិ** ទ្រង់សម្តែងថា វៀរព្រះតថាគត ព្រះសីវលិត្ថេរជាកំពលនៃពួកភិក្ខុខាងមានលាភ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលដោយលំដាប់ដូចតទៅនេះ

ព្រះថេរៈនេះ ក្នុងអតីត ក្នុងពុទ្ធកាលនៃព្រះមានព្រះភាគព្រះនាមថាបទុមុត្តរៈ បានទៅកាន់វិហារ អង្គុយស្តាប់ធម៌ខាងចុងបរិស័ទ ដោយន័យដូចពោលហើយនោះឯង ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងជាកំពូលរបស់ពួកភិក្ខុដែលមានលាភ គិតថា សូម្បីអាត្មាអញ ក៏គួរជាបុគ្គលមានសភាពយ៉ាងនេះមួយរូប ក្នុងអនាគត ទើបនិមន្តព្រះទសពលថ្វាយមហាទានអស់ ៧ ថ្ងៃ ធ្វើសេចក្តីប្រាថ្នាថា ដោយការធ្វើកុសលនេះ ខ្ញុំព្រះអង្គមិនប្រាថ្នាសម្បត្តិដទៃ តែខ្ញុំព្រះអង្គគប្បីជាកំពូលនៃពួកភិក្ខុដែលមានលាភ ដូច

ភិក្ខុដែលទ្រង់ស្ថាបនាទុកក្នុងតំណែងឯតទគ្គៈ ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាទីមួយ ក្នុងអនាគតកាល ។ ព្រះសាស្តាទ្រង់ឃើញថា មិនមានអន្តរាយសម្រាប់លោក ទើបទ្រង់ព្យាករថា សេចក្តីប្រាថ្នារបស់អ្នក នឹងសម្រេចក្នុងសម្នាក់របស់ព្រះពុទ្ធព្រះនាមគោតម ក្នុងអនាគត ហើយយាងត្រឡប់ទៅ ។ កុលបុត្រនោះ ធ្វើកុសលដរាបអស់ជីវិត ហើយអន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយ កាលព្រះវិបស្សីសម្ពុទ្ធកើតឡើងក្នុងលោក កុលបុត្រនោះមកបដិសន្ធិក្នុងតំបន់មួយ មិនឆ្ងាយអំពីពន្ធុមតីនគរ ។ សម័យនោះ អ្នកពន្ធុមតីសន្ទនាជាមួយព្រះរាជា ថ្វាយទានដល់ព្រះទសពល ថ្ងៃមួយ មនុស្សទាំងនោះរួមគ្នាតែមួយថ្វាយទាន គិតថា ក្នុងមុខទានរបស់ពួកយើង មិនមានអ្វីខ្វះហ្ន៎ ដូច្នេះ មិនឃើញទឹកឃ្មុំ និងទឹកដោះខាប់ ទើបមនុស្សទាំងនោះ ចាត់បុរសទៅស្កាត់ផ្លូវមួយអំពីជនបទ ចូលទៅកាន់ក្រុង ដោយតាំងចិត្តថា នឹងនាំរបស់ពីរយ៉ាងនោះ អំពីខាងនោះ អំពីខាងនេះមក ។ គ្រានោះ កុលបុត្រនេះកាន់យកបំពង់នវនីតមកអំពីផ្ទះរបស់ខ្លួន គិតថា នឹងនាំមកបន្តិចប៉ុណ្ណោះកាលទៅដល់ព្រះនគរ ក៏សម្លឹងរកទីសប្បាយ ដោយតាំងចិត្តថា នឹងលាងមាត់ លាងដៃ និងជើង ហើយទើបចូលទៅ ឃើញសម្បុកឃ្មុំឥតមេប៉ុនយាមនង្គ័ល គិតថា របស់នេះកើតឡើង ដោយបុណ្យរបស់អញ ទើបកាន់យកហើយចូលទៅកាន់នគរ បុរសដែលអ្នកក្រុងដាក់ការៈឲ្យ ឃើញកុលបុត្រទើបសួរថា នែអ្នក អ្នកនាំទឹកឃ្មុំមកឲ្យអ្នកណា បុរសនោះឆ្លើយថា មិនបាននាំមកឲ្យអ្នកណាទេ បុរសនោះពោលថា បើដូច្នោះ សូមលក់ឲ្យខ្ញុំចុះ ហើយ

សូមអ្នកកាន់យកកហាបណៈនេះទៅ ហើយឲ្យទឹកឃ្មុំ និងនវនីតនោះមក ។ កុលបុត្រនោះគិតថា របស់នេះមិនមានតម្លៃច្រើនទេ បុរសនេះឲ្យតម្លៃច្រើន តែម្ដងប៉ុណ្ណោះ គួរអញល្បងមើល ទើបបុរសនោះពោលថា ខ្ញុំមិនឲ្យដោយកហាបណៈ ១ ។ បុរសម្នាក់ទៀតពោលថា បើដូច្នោះ ចូរអ្នកទទួលយក ២ កហាបណៈ ហើយចូរឲ្យខ្ញុំចុះ កុលបុត្រនោះឆ្លើយថា ២ កហាបណៈក៏ខ្ញុំមិនឲ្យ ។ ទើបបុរសនោះបន្ថែមដោយឧបាយនេះរឿយៗ រហូតដល់ ១០០០ កហាបណៈ ។ ទើបកុលបុត្រនោះគិតថា អញមិនគួរបោកបញ្ឆោតជននេះឡើយចុះ អញនឹងធ្វើតាមកិច្ចដែលគប្បីធ្វើរបស់បុរសនេះ ពេលនោះ ទើបគាត់ពោលនឹងបុរសនោះថា របស់នេះមិនមានតម្លៃច្រើនទេ តែអ្នកឲ្យតម្លៃច្រើន អ្នកយករបស់នេះទៅដោយកិច្ចកម្មអ្វី ។ បុរសនោះពោលថា នែអ្នក អ្នកក្រុងប្រណាំងជាមួយព្រះរាជា ថ្វាយទានដល់ព្រះវិបស្សីទសពល កាលមិនឃើញរបស់ ២ មុខនេះក្នុងទេយ្យទាន ទើបនាំគ្នាស្វែងរក បើមិនបានវត្ថុនេះ អ្នកស្រុកនឹងចាញ់ ព្រោះដូច្នោះ ទើបខ្ញុំឲ្យ ១០០០ សូមទទួលយកចុះ ។ កុលបុត្រនោះពោលថា វត្ថុនេះ អ្នកក្រុងប៉ុណ្ណោះគួរឲ្យ ឬជនដទៃក៏គួរឲ្យ បុរសនោះពោលថា របស់ដែលនាំមកនេះបុគ្គលណាឲ្យក៏បាន ។ កុលបុត្រនោះពោលថា មានបុគ្គលណាឲ្យទ្រព្យ ១០០០ ក្នុងថ្ងៃតែមួយ ក្នុងទានរបស់អ្នកក្រុងដែរឬ បុរសនោះពោលថា មិនមានទេសម្លាញ់ ។ កុលបុត្រពោលថា អ្នកដឹងថា របស់ ២ មុខនេះមានតម្លៃ ១០០០ ឬ បុរសនោះពោលថា ខ្ញុំដឹង ។ កុលបុត្រពោលថា បើដូច្នោះ អ្នកចូរទៅប្រាប់ដល់អ្នក

ក្រុងចុះថា បុរសម្នាក់មិនឲ្យរបស់ ២ នេះដោយតម្លៃ តែគាត់បំណាងនឹងឲ្យដោយដៃឯង ពួកអ្នកកុំខ្វល់ខ្វាយ ព្រោះហេតុនៃរបស់ ២ មុខនេះឡើយ ។

បុរសនោះពោលថា អ្នកចូរជាកាយសក្ខីនៃភាពជាប្រធាន គឺទានរបស់អ្នកចុះ ។

បុរសនោះយកមាសកដែលខ្លួនទុក ដើម្បីប្រើប្រាស់ត្រង់ស្រុក ទិញរបស់ហឺរ ៥ យ៉ាង បុករហូតល្អិត ត្រងយកទឹកខ្មេះអំពីទឹកក្រូច ហើយដាក់សម្បុកឃ្មុំក្នុងនោះ ផ្សំជាមួយគ្រឿងហឺរ ៥ យ៉ាង ហើយទុកក្នុងស្លឹកឈូក ១ រៀបចំកញ្ចប់នោះហើយ កាន់មកអង្គុយក្នុងទីមិនឆ្ងាយអំពីព្រះទសពល រង់ចាំមើលវារៈដែលដល់សម្រាប់ខ្លួន ក្នុងរវាងគ្រឿងសក្ការៈដែលមហាជននាំមក បានឱកាសហើយ ទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះមានព្រះភាគ នេះជាទុគ្គតបណ្ណាការរបស់ខ្ញុំព្រះអង្គ សូមព្រះអង្គមេត្តាទទួលរបស់នេះនៃខ្ញុំព្រះអង្គចុះ ព្រះសាស្តាទ្រង់អាស្រ័យការអាណិតអាសូរដល់បុរសនោះ ទ្រង់ទទួលបណ្ណាការនោះដោយបាត្រថ្ម ដែលមហារាជទាំង ៤ ថ្វាយហើយ ទ្រង់អធិដ្ឋានដោយអាការ ដែលគ្រឿងបណ្ណាការនោះប្រគេនដល់ភិក្ខុ ៦ ម៉ឺន ៨ ពាន់អង្គ ក៏មិនអស់រលស់ឡើយ ។ កុលបុត្រនោះថ្វាយបង្គំព្រះមានព្រះភាគ ដែលសោយស្រេចហើយ ឈរនៅក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលថា ខ្ញុំព្រះអង្គជួបព្រះមានព្រះភាគហើយ ថ្ងៃនេះអ្នកនគរពន្ធុមតី នាំសក្ការៈមកថ្វាយព្រះអង្គ សូម្បីខ្ញុំព្រះអង្គគប្បីជាអ្នកដល់នូវភាពជាកំពូលខាងលាភ និងជាកំពូលខាងយសក្នុងភពដែលកើតហើយ

ដោយផលនៃកម្មនេះ ។ ព្រះសាស្ដាត្រាស់ថា ម្នាលកុលបុត្រ សេចក្ដីប្រាថ្នា ចូរសម្រេចយ៉ាងនោះចុះ ហើយទ្រង់ធ្វើអនុមោទនាកត្ដដល់កុលបុត្រនោះ និង ដល់អ្នកនគរហើយ ទ្រង់យាងត្រឡប់ទៅ ។

ឯកុលបុត្រនោះ ធ្វើកុសលកម្មដរាបដល់អស់ជីវិតហើយ អន្ទោលទៅ មកក្នុងទេវតា និងមនុស្ស មកបដិសន្ធិក្នុងព្រះគភ៌របស់ព្រះរាជធីតាព្រះនាម ថា សុប្បវាសា ក្នុងពុទ្ធុប្បាទកាលនេះ តាំងអំពីបដិសន្ធិ ព្រះនាងសុប្បវាសា ទទួលគ្រឿងបណ្ណាការដល់ទៅ ៥០០ ទាំងព្រឹកទាំងល្ងាច ។ គ្រានោះ ពួក ព្រះញាតិត្រូវការនឹងល្បងបុណ្យ ទើបឲ្យព្រះនាងយកព្រះហស្ដពាល់ត្រូវកញ្ជើ ពូជ ពន្ធកក៏ដុះចេញអំពីគ្រាប់ពូជគ្រប់ប្រភេទ ១០០ ខ្លះ ១០០០ ខ្លះ ស្រូវ កើតឡើងអំពីស្រែ ១ ករីស ៥០ រទេះ ៦០ រទេះខ្លះ ក្នុងពេលធ្វើជង្រុកឲ្យ ពេញ ព្រះនាងក៏យកព្រះហស្ដពាល់ត្រូវទ្វារជង្រុក ត្រង់ទីដែលព្រះរាជធីតា ចាប់ហើយចាប់ទៀត ក៏ទៅជាពេញព្រោះបុណ្យ មនុស្សទាំងឡាយពោលថា បុណ្យរបស់ព្រះរាជធីតា ហើយឲ្យជួសបាយអំពីឆ្នាំងដែលពេញ ឲ្យដល់ បុគ្គលណាម្នាក់ បើមិនដកព្រះហស្ដចេញទេ បាយក៏មិនអស់ទៅដរាបនោះ ។

កាលទារកនៅក្នុងគភ៌នោះឯង ពេលវេលាកន្លងទៅអស់ ៧ ឆ្នាំ កាល គភ៌ចាស់ នាងសោយទុក្ខអស់ ៧ ថ្ងៃ នាងប្រឹក្សានឹងស្វាមីថា មុននឹងស្លាប់ ខ្ញុំម្ចាស់នឹងថ្វាយទាន ទាន់មានជីវិតនៅឡើយ ទើបបញ្ជូនស្វាមីទៅគាល់ព្រះ សាស្ដា ដោយពោលថា សូមអយ្យបុត្រទៅក្រាបទូលរឿងនេះដល់ព្រះ សាស្ដា ហើយនិមន្ដព្រះសាស្ដា កាលព្រះសាស្ដាត្រាស់ពាក្យណា សូមអ្នក

តាំងចិត្តកំណត់ពាក្យនោះឲ្យល្អ ហើយត្រឡប់មកប្រាប់ខ្ញុំម្ចាស់ ។ ស្វាមីទៅហើយក្រាបទូលដល់ព្រះសាស្តា ព្រះសាស្តាត្រាស់ថា ព្រះនាងសុប្បវាសា កោលិយធីតា ចូរមានសេចក្តីសុខ ចូរមានសេចក្តីសប្បាយ កុំបីមានរោគ ចូរប្រសូតបុត្រដោយមិនមានរោគចុះ ព្រះរាជាទ្រង់ស្តាប់ដំណឹងនោះ ទើបថ្វាយបង្គំលាព្រះសាស្តា ទ្រង់យាងត្រឡប់មកព្រះរាជនិវេសន៍ កុមារក៏ប្រសូតចាកគភ៌របស់ព្រះនាងសុប្បវាសា ង៉ាយដូចចាក់ទឹកចេញអំពីធម្មក្រក ដូច្នោះ ។ មនុស្សដែលអង្គុយជុំវិញ ចាប់ផ្តើមសើច ទាំងមានមុខជោកដោយទឹកភ្នែក មហាជនត្រេកអរហើយ ត្រេកអរីករាយ បានទៅក្រាបទូលដំណឹងដែលគួរត្រេកអរដល់ព្រះរាជា ព្រះរាជាទ្រង់ឃើញអាការរបស់ជនទាំងនោះ ទ្រង់ព្រះតម្រិះថា ព្រះតម្រាស់ដែលព្រះទសពលត្រាស់ហើយ ប្រហែលជាឲ្យផលហើយ ទ្រង់យាងមកប្រាប់ដំណឹងដល់ព្រះរាជធីតាអំពីព្រះទសពល ព្រះរាជធីតាត្រាស់ថា អាហារសម្រាប់បុគ្គលដែលអយ្យបុត្រនិមន្ត គឺជាអាហារមង្គល សូមទ្រង់ទៅនិមន្តព្រះទសពល ៧ ថ្ងៃចុះ ។ ព្រះរាជាទ្រង់ឃើញដូច្នោះ ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ទារករម្ងាត់ចិត្តដែលក្តៅក្រហាយរបស់ពួកញាតិបានទាំងអស់ ព្រោះដូច្នោះ ទើបពួកញាតិថ្វាយព្រះនាមរបស់កុមារនោះថា សីវលីទារក ។ សីវលីទារកនោះជាអ្នកអត់ធន់នូវកម្មតាំងអំពីកើត ព្រោះនៅក្នុងគភ៌ដល់ទៅ ៧ ឆ្នាំ ព្រះធម្មសេនាបតីសារីបុត្រ បានសន្ទនាប្រាស្រ័យជាមួយសីវលីនោះ ក្នុងថ្ងៃទី ៧ ព្រះសាស្តាបានភាសិតគាថា ក្នុងធម្មបទថា

យោ ឥមំ បលិបថំ ទុគ្គំ សំសារំ មោហមច្ចគា
តិណ្ណោ ចារគតោ ឈាយី អនេជោ អកថង្កថី
អនុបាទាយ និព្វុតោ តមហំ ព្រូមិ ព្រាហ្មណំ ។

បុគ្គលណា កន្លងផ្លូវវាង គឺរាគៈ និងភក់ដែលគេឆ្លងបានដោយកម្រ គឺកិលេស និងសង្សារវដ្ត និងមោហៈទាំងនេះបាន ជាអ្នកឆ្លងអន្លង់ទាំង ៤ បានដល់ត្រើយ គឺព្រះនិព្វាន ជាអ្នកមានឈានមិនញាប់ញ័រដោយតណ្ហា មិនមានសេចក្ដីសង្ស័យ មិនប្រកាន់មាំ ជាអ្នករលត់កិលេសហើយ តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

គ្រានោះ ព្រះថេរៈពោលនឹងសីវលីទារកនោះយ៉ាងនេះថា នែសីវលី អ្នកបានសោយគំនរទុក្ខបែបនេះហើយ បួសមិនសមគួរទេឬ ។ សីវលីកុមារឆ្លើយថា បពិត្រលោកម្ចាស់ ខ្ញុំកាលបានក៏គប្បីបួស ។ ព្រះនាងសុប្បវាសាឃើញទារកនោះចរចាជាមួយព្រះថេរៈ គិតថា កូនរបស់អញនិយាយអ្វីជាមួយនឹងព្រះធម្មសេនាបតីហ្ន៎ ទើបចូលទៅរកព្រះថេរៈ សួរថា កូនរបស់ខ្ញុំនិយាយអ្វីនឹងលោកម្ចាស់ ព្រះថេរៈពោលថា កូនរបស់នាងនិយាយដល់សេចក្ដីទុក្ខដែលនៅក្នុងគភ៌ដែលខ្លួនសោយ ហើយពោលថា នាងអនុញ្ញាតហើយ នឹងបួស ។ ព្រះនាងសុប្បវាសាត្រាស់ថា សាធុ លោកម្ចាស់ សូមឲ្យកូនខ្ញុំបព្វជ្ជាចុះ ព្រះថេរៈនាំទារកនោះទៅវិហារ ឲ្យតចបញ្ចកកម្មដ្ឋានកាលឲ្យបព្វជ្ជា ពោលថា នែសីវលី ខ្ញុំមិនចាំបាច់ឲ្យឱវាទទេ អ្នកចូរពិចា-

វណោទុក្ខដែលអ្នកសោយមកអស់ ៧ ឆ្នាំនោះឯង សីវលីពោលថា ការឲ្យបួសប៉ុណ្ណោះ ជាកិច្ចរបស់លោកម្ចាស់ ចំណែកខ្ញុំនឹងដឹងកិច្ចដែលខ្ញុំធ្វើបាន ។ សីវលីនោះតាំងនៅក្នុងសោតាបត្តិផល ក្នុងខណៈដែលកាំបិតកោរទី ១ កោរហើយនោះឯង ខណៈកាំបិតទី ២ តាំងនៅក្នុងសកទាគាមិផល ក្នុងខណៈកោរសក់កាំបិតទី ៣ តាំងនៅក្នុងអនាគាមិផល លុះកោរសក់អស់ ក៏ធ្វើឲ្យជាក់ច្បាស់នូវអរហត្ត មិនមុនមិនក្រោយ ។ តាំងអំពីថ្ងៃដែលលោកបួសហើយ បច្ច័យ ៤ កើតឡើងដល់ភិក្ខុសង្ឃតាមសេចក្ដីត្រូវការ ។ រឿងដែលកើតឡើងក្នុងទីនេះ ដោយប្រការដូច្នេះ ។

បន្ទាប់មក ព្រះសាស្ដាបានយាងទៅកាន់ក្រុងសាវត្ថី ព្រះថេរៈថ្វាយបង្គំព្រះសាស្ដា ហើយទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងល្បងបុណ្យរបស់ខ្ញុំព្រះអង្គ សូមទ្រង់ប្រទានភិក្ខុ ៥០០ ដល់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលសីវលីអ្នកចូរទទួលចុះ ។ ទេវតាដែលអាស្រ័យនៅនាដើមនិគ្រោធ បានឃើញដំបូង បានថ្វាយទានដល់ព្រះថេរៈនោះអស់ ៧ ថ្ងៃ ដូច្នោះ ទើបលោកពោលថា

និគ្រោធំ បឋមំ បស្សិ ទុតិយំ បណ្ឌវបព្វតំ
តតិយំ អចិរវតិយំ ចតុត្ថំ វរសាគរំ
បញ្ចមំ ហិមវន្តំ សោ ឆដ្ឋំ ឆទ្ទន្តុបាគមិ
សត្តមំ គន្ធមាទនំ អដ្ឋមំ អថ រេវតំ ។

ឃើញគ្រាដំបូង ត្រង់ដើមនិគ្រោធ ឃើញគ្រាទី ២ ត្រង់ភ្នំ

បណ្ឌវៈ គ្រាទី ៣ ត្រង់ស៊ឹងអចិរវតី គ្រាទី ៤ ត្រង់សមុទ្រ គ្រាទី ៥ ត្រង់ព្រៃហិមពាន្ត គ្រាទី ៦ ស្រះឆទ្ទន្ត គ្រាទី ៧ ភ្នំគន្ធមាទន៍ គ្រាទី ៨ ក្នុងលំនៅព្រះរេវតៈ ។

ក្នុងទីគ្រប់អន្លើ ទេវតាបានថ្វាយទាន ៧ ថ្ងៃៗ ត្រង់ភ្នំគន្ធមាទន៍ ទេវតាឈ្មោះនាគទត្ត ក្នុង ៧ ថ្ងៃ បានថ្វាយបិណ្ឌបាតលាយដោយទឹកដោះ ១ ថ្ងៃ បានប្រគេនបិណ្ឌបាតលាយដោយសប្បិ ១ ថ្ងៃ ភិក្ខុសង្ឃពោលថា អាវុសោ ទឹកដោះគោរបស់ទេវរាជនេះមិនប្រាកដថា រូបនៅទីណា ការរម្ងាស់ ក៏មិនមានបពិត្រមហារាជ ផលនេះកើតឡើងដល់ព្រះអង្គបានដូចម្តេច ។ ទេវរាជពោលថា បពិត្រលោកម្ចាស់ នេះជាផលនៃការថ្វាយសលាកភត្តលាយដោយទឹកដោះដល់ព្រះទសពល កាលព្រះទសពលកស្សបសម្មាសម្ពុទ្ធ ។ ខាងក្រោយព្រះសាស្តាទ្រង់ធ្វើការដែលទេវតាធ្វើការទទួលព្រះថេរៈនោះ នៅក្នុងព្រៃគគីរឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងជាកំពូល នៃពួកភិក្ខុដែលមានលាភដ៏ក្រៃលែង ក្នុងសាសនារបស់ព្រះអង្គ ។

**អដ្ឋកថាសូត្រទី ៩ ចប់**

# អដ្ឋកថា សូត្រទី ១០
# ប្រវត្តិ ព្រះវក្កលិត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ដូចតទៅនេះ ដោយបទថា **សទ្ធាធិមុត្តានំ** ទ្រង់សម្តែងថា ព្រះវក្កលិត្ថេរជាកំពូលនៃភិក្ខុដែលបង្អោនចិត្តដោយសទ្ធា មានសទ្ធាចាស់ក្លា ។ ពិតហើយ សទ្ធានៃបុគ្គលដទៃ មានតែធ្វើឲ្យបម្រើន ចំណែករបស់ព្រះថេរៈត្រូវស្រកចុះ ព្រោះដូច្នោះ ទើបព្រះថេរៈនោះ ព្រះមានព្រះភាគត្រាស់ថា ជាកំពូលនៃពួកភិក្ខុ ដែលបង្អោនចិត្តទៅដោយសទ្ធា ។ ពាក្យថា **វក្កលិ** ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ក្នុងបញ្ហាកម្មរបស់ព្រះថេរៈនោះ មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ

នឹងពោលដោយសង្ខេប ក្នុងអតីតកាល ក្នុងពុទ្ធុប្បាទព្រះបទុមុត្តរសម្ពុទ្ធ ព្រះថេរៈនេះទៅវិហារឈរស្តាប់ធម៌ខាងចុងបរិស័ទ ដោយន័យដែលពោលហើយនោះឯង ។ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ដែលបង្អោនចិត្តទៅដោយសទ្ធា ទើបគិតថា សូម្បីអាត្មាអញ ក៏គួរជាបុគ្គលមានសភាពដូច្នេះ ក្នុងអនាគតកាល ទើបនិមន្តព្រះសាស្តាដោយន័យដែលពោលហើយនោះឯង ថ្វាយមហាទានអស់ ៧ ថ្ងៃ ថ្វាយបង្គំព្រះទសពល ហើយធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ដោយកុសលកម្មនេះ ខ្ញុំព្រះអង្គគប្បីបានជាកំពូលនៃពួកភិក្ខុដែលបង្អោនចិត្តទៅដោយសទ្ធា ក្នុងសាសនារបស់ព្រះសម្ពុទ្ធអង្គណាមួយ ក្នុងអនាគត ដូចភិក្ខុដែលទ្រង់ស្ថាបនាក្នុងតំណែងឯតទគ្គៈ របស់ពួកភិក្ខុដែលបង្អោនចិត្តទៅដោយសទ្ធា ។ ព្រះសាស្តាទ្រង់ឃើញថា មិនមានអន្តរាយ ទើបព្យាករហើយ

យានត្រឡប់ទៅ ។

លោកធ្វើកុសលកម្មដរាបដល់អស់ជីវិត ហើយអន្ទោលក្នុងទេវតា និង មនុស្ស បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍នាក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទព្រះសាស្តា នៃយើង ។ ញាតិទាំងឡាយបានដាក់ឈ្មោះរបស់លោកថា វក្កលិ ។ លោក ចម្រើនវ័យហើយ រៀនត្រៃវេទ ឃើញព្រះទសពល មានភិក្ខុសង្ឃចោម រោម ទ្រង់ចារិកក្នុងក្រុងសាវត្ថី សម្លឹងមើលសិរីសម្បត្តិរបស់ព្រះសាស្តា មិនឆ្អែតដោយការឃើញសិរីសម្បត្តិ ទើបត្រាច់ទៅ មួយអន្លើជាមួយព្រះ ទសពលនោះឯង ទ្រង់យាងទៅកាន់វិហារ ក៏ទៅជាមួយព្រះទសពល ឈរ សម្លឹងមើលសេចក្តីសម្រេចនៃសិរីសម្បត្តិនោះឯង ឈរស្តាប់ធម៌ក្នុងទី ចំពោះព្រះភក្ត្រនៃព្រះសាស្តា ដែលប្រថាប់គង់សម្តែងធម៌ក្នុងធម្មសភា ។ លោកបាននូវសទ្ធា ហើយគិតថា អញនៅគ្រប់គ្រងផ្ទះ មិនបានឃើញព្រះ ទសពលជានិច្ចទេ ទើបទូលសូមបព្វជ្ជា បួសហើយក្នុងសម្នាក់នៃព្រះសាស្តា ។ បន្ទាប់អំពីនោះ វៀរតែពេលធ្វើភត្តាហារ ក្នុងកាលដ៏សេស ឈរក្នុងទីដែល អាចមើលឃើញព្រះទសពល លះបង់នូវយោនិសោមនសិការចោល មើល ព្រះទសពលតែម្យ៉ាង ។ ព្រះសាស្តាទ្រង់រង់ចាំឲ្យញាណរបស់លោកចាស់ក្លា សិន ។ កាលលោកត្រាច់ទៅមើលរូបក្នុងទីនោះៗ អស់កាលយូរ ទ្រង់ក៏មិន ត្រាស់ថាដូចម្តេច ទ្រង់ជ្រាបថា ឥឡូវនេះ ញាណរបស់លោកចាស់ក្លាហើយ លោកអាចត្រាស់ដឹងបាន ទើបត្រាស់យ៉ាងនេះថា ម្នាលវក្កលិ ប្រយោជន៍អ្វី ដែលអ្នកមើលរូបកាយស្អុយនេះ ម្នាលវក្កលិ បុគ្គលណាឃើញធម៌ បុគ្គល

នោះឈ្មោះថា ឃើញតថាគត បុគ្គលណាឃើញតថាគត បុគ្គលនោះឈ្មោះថា ឃើញធម៌ បុគ្គលណាឃើញធម៌ ទើបឈ្មោះថា ឃើញតថាគត ។ កាល ព្រះសាស្តាទ្រង់ឲ្យឱវាទយ៉ាងនេះ ព្រះថេរៈក៏មិនអាចលះបង់ការមើល ព្រះ ទសពលបាន ហើយទៅក្នុងទីដទៃ ។ បន្ទាប់អំពីនោះ ព្រះសាស្តាទ្រង់ត្រិះរិះ ថា ភិក្ខុនេះមិនបាននូវសេចក្តីសង្វេគ ទើបមិនត្រាស់ដឹង កាលកៀកនឹងចូល វស្សា ទ្រង់ប្រកាសបណ្តេញព្រះថេរៈនោះថា ម្នាលវក្កលិ អ្នកចូរចៀស ចេញទៅ ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មានព្រះតម្រាស់ដែលគប្បីកាន់យក ព្រោះដូច្នោះ ទើបព្រះថេរៈឈរឆ្លើយជាមួយព្រះសាស្តាមិនបាន មិនអាចមក ចំពោះព្រះភក្ត្រព្រះទសពល គិតថា ឥឡូវនេះ អញធ្វើដូចម្តេចបាន អញ ត្រូវព្រះតថាគតបណ្តេញហើយ អញមិនបាននៅចំពោះមុខព្រះអង្គ ប្រយោជន៍ អ្វីដោយជីវិតនៃអញ ទើបឡើងកាន់ភ្នំគិជ្ឈកូដដែលមិនមានជម្រេល ព្រះ សាស្តាទ្រង់ជ្រាបថា ព្រះថេរៈនោះដល់នូវសេចក្តីលំបាក ទ្រង់ត្រិះរិះថា ភិក្ខុ នេះ បើមិនបានការលួងលោមចិត្តអំពីតថាគត ក៏គប្បីទម្លាយឧបនិស្ស័យនៃ មគ្គ និងផល ទើបទ្រង់ផ្សាយរស្មីទៅសម្តែងព្រះកាយឲ្យឃើញ ។ គ្រានោះ តាំងអំពីព្រះវក្កលិនោះឃើញព្រះសាស្តា ក៏លះនូវសេចក្តីសោកដ៏ធំ ដោយ ប្រការដូច្នេះ ។ ព្រះសាស្តា កាលនឹងឲ្យព្រះវក្កលិកើតបីតិសោមនស្សខ្លាំងក្លា ឡើង ដូចក្រសែទឹកដែលធ្លាក់ចុះក្នុងស្រះដែលស្ងួត ទើបត្រាស់ព្រះគាថា ក្នុងធម្មបទថា

**បាមោជ្ជពហុលោ ភិក្ខុ បសន្នោ ពុទ្ធសាសនេ**

**អធិគច្ឆេ បទំ សន្តំ សង្ខារុបសមំ សុខំ ។**

ភិក្ខុអ្នកក្រាស់ដោយសេចក្ដីរីករាយ ជ្រះថ្លាក្នុងព្រះពុទ្ធសាសនា
រមែងបាននូវបទដ៏ស្ងប់ជាទីរម្ងាប់នូវសង្ខារ នាំមកនូវសេចក្ដីសុខ ។

ម្យ៉ាងទៀត ព្រះសាស្ដាទ្រង់លាព្រះហស្ដប្រទានដល់ព្រះវក្កលិថា ម្នាលវក្កលិ អ្នកចូរមកចុះ ។ ព្រះថេរៈកើតបីតិដ៏ខ្លាំងក្លាថា អញឃើញព្រះទសពលហើយ បានទទួលព្រះតម្រាស់ថា មកចុះវក្កលិ ទាំងមិនដឹងការទៅរបស់ខ្លួនថា នឹងទៅផ្លូវណា ទើបលោតទៅក្នុងអាកាសចំពោះព្រះភក្ត្រព្រះទសពល ជើងមួយជាប់លើភ្នំ នឹកដល់ព្រះតម្រាស់ដែលព្រះសាស្ដាត្រាស់ហើយ សង្កត់បីតិក្នុងអាកាសនោះឯង សម្រេចព្រះអរហត្ត ព្រមទាំងបដិសម្ភិទា ចុះមកថ្វាយបង្គំព្រះតថាគត ។ ក្រោយមក ព្រះសាស្ដាប្រថាប់គង់ត្រង់កណ្ដាលពួកព្រះអរិយៈ ទ្រង់ស្ថាបនាព្រះថេរៈ ក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ដែលបង្អោនចិត្តទៅដោយសទ្ធា ។៚

**អដ្ឋកថា សូត្រទី ១០ ចប់**

**វគ្គទី ២ ចប់**

# ឯកទគ្គបាលិ

## វគ្គទី ៣

[ ១៤៨ ] ម្នាលភិក្ខុទាំងឡាយ បណ្ដាពួកភិក្ខុអ្នកស្រឡាញ់សិក្ខា ដែលជាសាវ័ករបស់តថាគត ស្រេចនឹងរាហុលប្រសើរជាងគេ ។ ពួកភិក្ខុអ្នកបួសដោយសទ្ធា ស្រេចនឹងរដ្ឋបាល ។ ពួកភិក្ខុអ្នកចាប់ស្លាកជំបូងបង្អស់ ស្រេចនឹងកុណ្ឌធាន ។ ពួកភិក្ខុអ្នកមានបដិភាណ ស្រេចនឹងវង្គីសៈ ។ ពួកភិក្ខុអ្នកមានសេចក្ដីជ្រះថ្លាគ្រប់គ្រាន់ ស្រេចនឹងឧបសេនវង្គន្តបុត្ត ។ ពួកភិក្ខុអ្នកក្រាលសេនាសនៈ ស្រេចនឹងទព្វមល្លបុត្ត ។ ពួកភិក្ខុជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ ស្រេចនឹងបិលិន្ទវច្ឆៈ ។ ពួកភិក្ខុអ្នកត្រាស់ដឹងរហ័ស ស្រេចនឹងពាហិយទារុចីរិយៈ ។ ពួកភិក្ខុអ្នកចេះសម្ដីដ៏វិចិត្ត ស្រេចនឹងកុមារកស្សបៈ ។ ពួកភិក្ខុអ្នកបានបដិសម្ភិទា ស្រេចនឹងមហាកោដ្ឋិតៈ ។

*វគ្គទី ៣ ចប់*

# វគ្គទី ៣

## អដ្ឋកថា សូត្រទី ១

## ប្រវត្តិ ព្រះរាហុលត្ថេរ

[ ១៤៨ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ វគ្គទី ៣ ដូចតទៅនេះ បទថា **សិក្ខាកាមានំ** សេចក្តីថា បុគ្គលប្រាថ្នា ដោយអត្ថថា ជាអ្នកស្រឡាញ់ការសិក្សានូវសិក្ខា ៣ ។ ព្រះសាស្តាសម្តែងព្រះរាហុលដែលជាឱរសរបស់ព្រះអង្គថា រាហុលោ បានឮថា ព្រះថេរៈក្រោកឡើងអំពីព្រលឹមតាំងអំពីថ្ងៃដែលបួសហើយ កើបខ្សាច់ពេញដៃប្រាថ្នាថាអស្ចារ្យហ្ន៎ អញគប្បីបានឱវាទ និងអនុសាសនីមានប្រមាណប៉ុណ្ណេះ អំពីព្រះទសពល និងព្រះឧបជ្ឈាយ៍ ឬអាចារ្យទាំងឡាយក្នុងថ្ងៃនេះ ព្រោះដូច្នោះ ទើបលោកឈ្មោះថាជាកំពូលនៃពួកភិក្ខុដែលប្រាថ្នាចំពោះការសិក្សា ។

**អដ្ឋកថាសូត្រទី ១ ចប់**

# អដ្ឋកថា សូត្រទី ២

## ប្រវត្តិ ព្រះរដ្ឋបាលត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ២ ដូចតទៅនេះ បទថា **សទ្ធាបព្វជិតានំ** ប្រែថា ជាអ្នកបួសដោយសទ្ធា ។ បទថា **រដ្ឋបាលោ** បានដល់ ការរាប់ថា រដ្ឋបាល ព្រោះអត្ថថា ជាអ្នករក្សារដ្ឋបាន ឬអ្នកកើតក្នុងត្រកូលដែលអាចបង្រួបបង្រួមរដ្ឋដែលបែកបាក់គ្នាបាន ពិតហើយ រដ្ឋបាលនោះ ស្តាប់ធម្មទេសនារបស់ព្រះសាស្តា បាននូវសទ្ធា ធ្វើការអត់បាយអស់ ១៤ ថ្ងៃ ។ ទើបឲ្យមាតាបិតាអនុញ្ញាតឲ្យបួស ទើបបួសហើយ ព្រោះដូច្នោះ ទើបលោកជាកំពូលនៃភិក្ខុដែលបួសដោយសទ្ធា ។

### ប្រវត្តិ ព្រះរាហុល និងព្រះរដ្ឋបាល

ក្នុងបញ្ហាកម្មរបស់ព្រះថេរៈទាំង ២ រូបនេះ មានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ

បានឮមកថា ក្នុងអតីតកាល គ្រាព្រះបទុមុត្តរសម្ពុទ្ធ ព្រះថេរៈទាំង ២ នេះ កើតក្នុងត្រកូលគហបតីមហាសាល ក្នុងក្រុងហង្សវតី ក្នុងវេលាដែលលោកនៅជាកុមារ មិនមានអ្នកណាពោលដល់ឈ្មោះ និងគោត្រ តែលុះលោកចម្រើនវ័យហើយ តាំងនៅក្នុងឃរាវាស កាលបិតាអនិច្ចកម្មទៅហើយ ទើបលោកទាំង ២ ហៅមេការដែលគ្រប់គ្រងឃ្លាំងរតនៈរបស់ខ្លួនមកហើយ ឃើញទ្រព្យមានប្រមាណមិនបាន គិតថា ជនទាំងឡាយ គឺជីតា និងតាទួតជាដើម នាំយកគំនរទ្រព្យមានប្រមាណប៉ុណ្ណេះទៅជាមួយខ្លួនមិនបាន ឥឡូវនេះ អញគួរកាន់យកទ្រព្យទៅដោយឧបាយណាមួយ ដូច្នេះ ទើបជនទាំង ២

នោះ ផ្ដើមឲ្យមហាទានដល់មនុស្សកំព្រា និងអ្នកដំណើរជាដើម ក្នុងទី ៤ កន្លែង បុគ្គលម្នាក់សាកសួរបុគ្គលដែលមកហើយក្នុងរោងទានរបស់ខ្លួន បុគ្គលណាពេញចិត្តរបស់ណា ដូចជាបាយ បបរ របស់ទំពា ក៏ឲ្យវត្ថុនោះដល់បុគ្គលនោះ ព្រោះហេតុនោះ ទើបបុគ្គលនោះមានឈ្មោះថា ជាអ្នកពោលនឹងបុគ្គលដែលមកហើយ ម្នាក់ទៀតមិនសួរ យកភាជនៈដែលគេកាន់មកហើយដាក់ឲ្យពេញ ហើយទើបឲ្យ ដោយហេតុនោះឯង ទើបបុគ្គលនោះឈ្មោះថា មិនពោលនឹងបុគ្គលដែលមកហើយ អធិប្បាយថា សួរដោយការមិនប្រមាទ ថ្ងៃមួយ ជនទាំង ២ នោះចេញទៅខាងក្រៅស្រុក ដើម្បីលាងមាត់អំពីព្រលឹម ។

សម័យនោះ តាបសអ្នកមានឫទ្ធិច្រើន ២ រូប ហោះមកអំពីព្រៃហិមពាន្ត ដើម្បីភិក្ខាចារ ចុះមិនឆ្ងាយអំពីសម្លាញ់ទាំង ២ នោះ ឈរក្នុងទីម្ខាង ដោយគិតថា ជនទាំង ២ នោះ កាលតាបសទាំង ២ នោះ ចាត់ចែងបរិក្ខារ មានភាជនៈឃ្លោកជាដើម ដើរត្រោះទៅខាងក្នុងស្រុក ទើបមកថ្វាយបង្គំក្បែរៗ គ្រានោះ តាបសពោលនឹងជនទាំង ២ នោះថា អ្នកមានបុណ្យធំ អ្នកមកក្នុងវេលាណា ។ ជនទាំង ២ នោះឆ្លើយថា មកអម្បាញ់មិញនេះឯង លោកម្ចាស់ ហើយទទួលភាជនៈឃ្លោកអំពីដៃរបស់តាបសទាំង ២ នោះ នាំទៅផ្ទះរៀងៗខ្លួន ក្នុងវេលាស្រេចភត្តកិច្ច ទើបសូមឲ្យទទួលសំណូមពរថា នឹងមកទទួលភិក្ខាជាប្រចាំ ។

ក្នុងតាបសទាំង ២ នោះ មួយរូបជាអ្នកមានធាតុក្ដៅ ទើបហែកទឹកមហាសមុទ្រចេញជា ២ ចំណែក ដោយអានុភាពរបស់ខ្លួន ហើយទៅកាន់

ភពរបស់បឋវិន្ទរនាគរាជ អង្គុយសម្រាកពេលថ្ងៃ ។ តាបសកាន់យកឧតុតាមសប្បាយហើយ ទើបត្រឡប់មក កាលធ្វើអនុមោទនាភត្ត ក្នុងផ្ទះនៃឧបដ្ឋាករបស់ខ្លួន ក៏ពោលថា សូមសម្រេចដូចភពបឋវិន្ទរនាគរាជ ។ ថ្ងៃមួយឧបដ្ឋាកសួរតាបសនោះថា បពិត្រលោកម្ចាស់ លោកម្ចាស់ធ្វើអនុមោទនាថា ចូរសម្រេចដូចភពបឋវិន្ទរនាគរាជ សូមប្រាប់សេចក្តីដល់ពួកខ្ញុំដែលមិនជ្រាបអត្ថគាថានេះ ពាក្យនេះ លោកម្ចាស់សំដៅដល់អ្វី ។ តាបសពោលថា ពិតហើយ កុដុម្ពិកៈ ខ្ញុំពោលថា សម្បត្តិរបស់អ្នក ចូរដូចសម្បត្តិរបស់ស្តេចនាគ ឈ្មោះបឋវិន្ទរៈ តាំងអំពីនោះមក កុដុម្ពិកៈក៏តាំងចិត្តទុកក្នុងភពនៃស្តេចនាគឈ្មោះថា បឋវិន្ទរៈ ។

តាបសមួយរូប ទៅកាន់តាវត្តិង្សពិភព ធ្វើការសម្រាកពេលថ្ងៃ ក្នុងសេរិសកវិមាន គឺវិមានដើមប្រេសដែលមិនមានម្ចាស់ ។ តាបសនោះត្រាច់ទៅមក ឃើញសម្បត្តិរបស់សក្កទេវរាជ កាលទឹងធ្វើអនុមោទនាដល់ឧបដ្ឋាករបស់ខ្លួន ក៏ពោលថា សម្បត្តិរបស់អ្នក ចូរដូចជាសក្កវិមាន ។ គ្រានោះកុដុម្ពិកៈនោះក៏សួរតាបសនោះ ដូចសម្លាញ់ម្នាក់ទៀតសួរតាបសនោះដែរ ។ កុដុម្ពិកៈស្តាប់ពាក្យរបស់តាបសនោះ ទើបតាំងចិត្តទុកក្នុងភពរបស់សក្កៈ ។ ទើបជនទាំង ២ នោះ កើតក្នុងទីដែលខ្លួនប្រាថ្នានោះឯង ។

បុគ្គលដែលកើតក្នុងភពរបស់បឋវិន្ទរនាគរាជ ក៏មានឈ្មោះថា **បឋវិន្ទរនាគរាជា** ។ ព្រះរាជានោះ ក្នុងខណៈដែលខ្លួនកើតហើយ ឃើញអត្តភាពនៃខ្លួន មានសេចក្តីក្តៅក្រហាយថា តាបសដែលចូលកាន់ត្រកូល សរសើរ

គុណនៃឋានៈរបស់អញ មិនគួរពេញចិត្តឡើយ ទីនេះ ជាទីដែលត្រូវលួនទៅ ដោយពោះ តាបសនោះមិនដឹងទីដទៃៗ ដោយពិត ។ ក្នុងខណៈនោះឯង ពួកនាគរបាំតែងខ្លួនហើយ បានប្រគំតន្ត្រីក្នុងទីគ្រប់ទិសដល់ស្តេចនាគនោះ ខណៈនោះឯង ស្តេចនាគនោះ ក៏លះអត្តភាពនោះ ក្លាយជាមាណពតូច ។ ស្តេចមហារាជទាំង ៤ ចូលគាល់សក្កទេវរាជ រៀងរាល់កន្លះខែម្តង ព្រោះដូច្នោះ សូម្បីស្តេចនាគនោះ ក៏ត្រូវទៅគាល់សក្កៈ មួយអន្លើដោយស្តេចនាគឈ្មោះវិរូបក្ខៈផងដែរ សក្កទេវរាជឃើញស្តេចនាគនោះមកអំពីចម្ងាយ ក៏ចាំបាន ទើបសួរស្តេចនាគនោះក្នុងវេលាដែលឈរក្នុងទីជិតថា នែសម្លាញ់ អ្នកទៅកើតទីណា ស្តេចនាគពោលថា បពិត្រមហារាជ សូមកុំសួរឡើយ ខ្ញុំទៅកើតក្នុងទីដែលលូនទៅដោយពោះ ឯអ្នកបាននិមិត្តល្អហើយ ។ សក្កៈត្រាស់ថា នែសម្លាញ់ អ្នកកុំសោយសោកឡើយ ថាកើតក្នុងទីមិនសមគួរ ព្រះទសពលព្រះនាមថា បទុមុត្តរៈទ្រង់កើតឡើងក្នុងលោកហើយ អ្នកចូរធ្វើកុសលកម្មដល់ទ្រង់ហើយ ប្រាថ្នាឋានៈនេះ យើងទាំង ២ នឹងនៅរួមគ្នាជាសុខ ។ ស្តេចនាគនោះ ពោលថា បពិត្រទេវៈ ខ្ញុំនឹងធ្វើយ៉ាងនោះ ទៅនិមន្តព្រះបទុមុត្តរទសពល ចាត់ចែងគ្រឿងសក្ការៈ និងការគោរពរាប់អានមួយយប់ទល់ភ្លឺ ជាមួយនាគបរិស័ទ ក្នុងភពនាគរបស់ខ្លួន ។ ស្អែកឡើង កាលអរុណរះ ព្រះសាស្តាត្រាស់ហៅព្រះសុមនថេរៈដែលជាឧបដ្ឋាករបស់ព្រះអង្គថា សុមនៈ ថ្ងៃនេះ តថាគតនឹងទៅកិក្ខាចារក្នុងទីឆ្ងាយ ភិក្ខុបុថុជ្ជនចូរកុំមក ចូរមកតែអ្នកបានបដិសម្ភិទា ជាអ្នកទ្រទ្រង់ព្រះត្រៃបិដក មានអភិញ្ញា ៦

ប៉ុណ្ណោះ ព្រះថេរៈស្ដាប់ព្រះតម្រាស់របស់ព្រះសាស្ដាហើយ ប្រាប់ដល់ភិក្ខុទាំងពួង ភិក្ខុប្រមាណមួយសែនហោះទៅព្រមជាមួយព្រះសាស្ដា ស្ដេចនាគបឋវិន្ទរៈ និងនាគបរិស័ទមកទទួលព្រះទសពល សម្លឹងមើលភិក្ខុសង្ឃដែលចោមរោមព្រះសាស្ដា ដែលកំពុងនិមន្តមក មានពណ៌ដូចកែវមណី លើផ្ទាំងវលក ឃើញព្រះសាស្ដាខាងដើម ព្រះសង្ឃនវក រហូតដល់សាមណេរឈ្មោះឧបរេវតៈ ដែលជាឱរសរបស់ព្រះតថាគត ទើបកើតបីតិបាមោជ្ជថា ពុទ្ធានុភាពបែបនេះរបស់ព្រះសាវ័កដ៏សេស មិនគួរអស្ចារ្យ តែពុទ្ធានុភាពនៃទារកតូចនេះ គួរអស្ចារ្យពន់ពេកហ្ន៎ ដូច្នេះ ។

គ្រានោះ កាលព្រះទសពលប្រថាប់គង់ត្រង់កពនៃស្ដេចនាគនោះហើយ កាលភិក្ខុក្រៅអំពីនេះគង់តាំងអំពីទីបំផុត មកដល់អាសនៈរបស់សាមណេរឧបរេវតៈ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះសាស្ដា ស្ដេចនាគ កាលថ្វាយបបរក្ដី កាលថ្វាយរបស់ទំពាក្ដី សម្លឹងមើលព្រះទសពលម្ដង មើលឧបរេវត-សាមណេរម្ដង ឃើញមហាបុរិសលក្ខណៈ ៣២ ប្រការ ក្នុងសរីរៈនៃសាមណេរនោះ រមែងប្រាកដដូចព្រះសម្ពុទ្ធ សេចក្ដីនេះដូចម្ដេចហ្ន៎ ដូច្នេះ ទើបសួរភិក្ខុមួយរូប ដែលអង្គុយមិនឆ្ងាយថា បពិត្រលោកម្ចាស់ សាមណេរនេះជាអ្វីនឹងព្រះទសពល ភិក្ខុនោះឆ្លើយថា ជាឱរស មហាបពិត្រ ទើបស្ដេចនាគត្រិះរិះថា សាមណេររូបនេះធំហ្ន៎ ទើបបាននូវភាពជាឱរសរបស់ព្រះតថាគតដ៏ត្រកាលបែបនេះ សូម្បីសរីរៈរបស់លោក ក៏ប្រាកដដូចសរីរៈរបស់ព្រះពុទ្ធដោយចំណែកមួយ ឯខ្ញុំនអញ ក៏គួរមានសភាពយ៉ាងនេះក្នុងអនាគត-

កាល ទើបថ្វាយទានអស់ ៧ ថ្ងៃ ហើយធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះអង្គ ដោយអានុភាពនៃកុសលកម្មនេះ ខ្ញុំព្រះអង្គគប្បីជាឱរសរបស់ព្រះពុទ្ធអង្គណានីមួយ ក្នុងអនាគត ដូចឧបរេវតសាមណេរនេះ ។ ព្រះសាស្តាទ្រង់ឃើញថា មិនមានអន្តរាយ ទើបទ្រង់ព្យាករថា ក្នុងអនាគត មហាបពិត្រនឹងបានជាឱរសនៃព្រះពុទ្ធព្រះនាមថា គោតម ដូច្នេះហើយ ទើបទ្រង់យាងត្រឡប់ទៅ ។

ឯបឋវិន្ទរនាគរាជ កាលដល់កន្លះខែម្តង ក៏ទៅគាល់សក្កទេវរាជ ជាមួយស្តេចនាគឈ្មោះវិរូបក្ខ ។ គ្រានោះ សក្កៈត្រាស់សួរស្តេចនាគដែលមកឈរ ក្នុងទីជិតថា នែសម្លាញ់ អ្នកប្រាថ្នាទេវលោកហើយឬ ស្តេចនាគពោលថា ខ្ញុំមិនបានប្រាថ្នាទេសម្លាញ់ សក្កៈពោលថា អ្នកឃើញទោសអ្វីឬ ស្តេចនាគពោលថា ទោសមិនមានទេ មហារាជ តែខ្ញុំឃើញសាមណេរឧបរេវតៈ ឱរសរបស់ព្រះទសពល តាំងអំពីខ្ញុំបានឃើញសាមណេរនោះ ក៏មិនបានបង្អោនចិត្តទៅក្នុងទីដទៃ ខ្ញុំធ្វើសេចក្តីប្រាថ្នាថា ក្នុងអនាគតកាល ខ្ញុំគប្បីបានជាឱរសដែលមានសភាពបែបនេះរបស់ព្រះពុទ្ធអង្គណានីមួយ បពិត្រមហារាជ សូម្បីព្រះអង្គ ក៏សូមធ្វើសេចក្តីប្រាថ្នាឯណាមួយចុះ យើងទាំង ២ នឹងមិនព្រាត់គ្នាក្នុងទីដែលកើតហើយ សក្កទេវរាជទទួលពាក្យនៃស្តេចនាគនោះហើយ ឃើញភិក្ខុដែលមានអានុភាពច្រើនមួយរូប ទើបនឹកថា កុលបុត្រនេះ ចេញបួសអំពីត្រកូលណាហ្ន៎ ដឹងថា កុលកុត្រនេះ ជាបុត្រនៃត្រកូលអ្នកអាចបង្រួបបង្រួមរដ្ឋដែលបែកគ្នាហើយ ធ្វើការអត់អាហារអស់ ១៤ ថ្ងៃ

ឲ្យមាតាបិតាអនុញ្ញាត ឲ្យបព្វជ្ជាហើយ បួសហើយ កាលជ្រាបហើយ ទើបធ្វើដូចជាមិនជ្រាប ទូលសួរព្រះទសពល ហើយធ្វើមហាសក្ការៈអស់ ៧ ថ្ងៃ ធ្វើសេចក្តីប្រាថ្នាថា បពិត្រព្រះមានព្រះភាគ ដោយផលនៃកល្យាណកម្មនេះ ខ្ញុំព្រះអង្គ គប្បីជាកំពូលនៃពួកភិក្ខុដែលបួសដោយសទ្ធា ក្នុងសាសនារបស់ព្រះពុទ្ធអង្គណាទីមួយក្នុងអនាគត ដូចកុលបុត្រនេះ ក្នុងសាសនារបស់ព្រះអង្គចុះ ។ ព្រះមុនី ទ្រង់ឃើញសេចក្តីប្រាថ្នាមិនមានអន្តរាយ ទើបព្យាករថា មហាបពិត្រ ព្រះអង្គនឹងជាកំពូលនៃពួកភិក្ខុដែលបួសដោយសទ្ធា ក្នុងសាសនារបស់ព្រះពុទ្ធព្រះនាមគោតមក្នុងអនាគត ហើយទ្រង់យាងត្រឡប់ទៅ ឯសក្កទេវរាជក៏យាងត្រឡប់ទៅកាន់ទេវបុរីរបស់ព្រះអង្គដូចដើមវិញ ។

ជនទាំង ២ នោះ ចុតិអំពីទីដែលខ្លួនកើតហើយ អន្ទោលក្នុងទេវតានិងមនុស្សច្រើនពាន់កប្ប ក្នុងទីបំផុតនៃកប្បទី ៩២ រាប់អំពីកប្បនេះ ព្រះពុទ្ធព្រះនាមផុស្សៈ ទ្រង់កើតឡើងក្នុងលោក ព្រះពុទ្ធបិតាជាព្រះរាជា ព្រះនាមមហិន្ទ មានប្អូនប្រុសមាតាដទៃ ៣ អង្គ ។ ព្រះរាជាទ្រង់ហួងហែងថា ព្រះពុទ្ធជារបស់អញប៉ុណ្ណោះ ព្រះធម៌ ព្រះសង្ឃជារបស់អញ រាល់ៗ ថ្ងៃ ទ្រង់ឲ្យព្រះទសពលសោយភោជន ដោយព្រះអង្គឯងជាប្រចាំ ។

ថ្ងៃមួយ កាលជាយដែនរបស់ព្រះអង្គបះបោរ ទ្រង់ត្រាស់ហៅឱរសមកប្រាប់ថា នែកូន ជាយដែនមានការបះបោរ ពួកអ្នក ឬយើង គួរទៅ បើយើងទៅ អ្នកត្រូវទំនុកបម្រុងព្រះទសពលដោយទំនងនេះ ព្រះរាជឱរសទាំង ៣ នោះ ទូលជាសំឡេងតែមួយថា បពិត្រព្រះជនក ព្រះអង្គមិនចាំបាច់យាង

ទៅទេ ពួកទូលបង្គំនឹងនាំគ្នាបង្ក្រាបចោរ ដូច្នេះ ទើបថ្វាយបង្គំព្រះជនក ហើយទៅកាន់បច្ចន្តជនបទ បង្ក្រាបចោរហើយ មានជ័យជម្នះលើសត្រូវ ហើយក៏យាងត្រឡប់ ។ ព្រះរាជកុមារទាំងនោះប្រឹក្សាជាមួយពួកអ្នកជិតស្និទ្ធ ក្នុងចន្លោះផ្លូវថា នែបា ក្នុងពេលដែលយើងមកគាល់ព្រះជនក ទ្រង់នឹងប្រទានពរ យើងគួរទទួលពរអ្វី ពួកបាទមូលិការទូលថា បពិត្រអយ្យបុត្រ បើព្រះជនករបស់ព្រះអង្គ សោយទិវង្គតទៅ មិនមានអ្វីដែលឈ្មោះថា បានលំបាកទេ តែសូមព្រះអង្គទទួលពរ គឺការប្រណិប័តន៍ព្រះផុស្សសម្ពុទ្ធដែលជាព្រះជេដ្ឋភាតារបស់អយ្យបុត្រចុះ ។ ព្រះរាជកុមារទាំងនោះពោលថា ពួកអ្នកនិយាយល្អ ទើបស្រុះស្រួលគ្នាគ្រប់អង្គចូលគាល់ព្រះជនក ។ ក្នុងកាលនោះ ព្រះជនកទ្រង់ជ្រះថ្លាក្នុងព្រះរាជកុមារទាំងនោះ ហើយទ្រង់ប្រទានពរ ។ ព្រះរាជកុមារទាំងនោះទូលសូមពរថា ពួកទូលបង្គំនឹងប្រណិប័តន៍ព្រះសាស្តាអស់ ៣ ខែ ។ ព្រះរាជាត្រាស់ថា ពរនេះ យើងឲ្យមិនបានទេ ចូរយកពរដទៃចុះ ។ ព្រះរាជកុមារក្រាបទូលថា បពិត្រព្រះជនក ពួកទូលបង្គំមិនត្រូវការពរដទៃឡើយ បើទ្រង់បំណងព្រះរាជទាន សូមព្រះរាជទានពរនោះឯងដល់ពួកទូលបង្គំចុះ ។ ព្រះរាជា កាលព្រះឱរសទាំងនោះទូលស្នើរឿយៗ ទ្រង់ត្រិះរិះថា បើអញមិនឲ្យមិនកើត ព្រោះអញបានប្តេជ្ញាហើយ ទើបត្រាស់ថា នែបា យើងឲ្យពរដល់ឯង តែធម្មតាព្រះសម្ពុទ្ធ បុគ្គលណាក៏ចូលគាល់បានលំបាក ទ្រង់មានប្រក្រតីត្រាច់ទៅមួយព្រះអង្គឯង ដូចសីហៈ ពួកបា ចូរកុំប្រមាទ ទំនុកបម្រុងព្រះទសពលចុះ ។

ព្រះរាជកុមារទាំងនោះត្រិះរិះថា កាលពួកយើងប្រណិប័តន៍ព្រះតថាគត ក៏គួរប្រណិប័តន៍ឲ្យសមគួរ ទើបស្រុះស្រួលគ្នាសមាទានសីល ១០ ជាអ្នកមិនមានកិច្ចធុរៈ ។ តាំងបុរស ៣ នាក់ឲ្យមើលថែរក្សាទានសម្រាប់ព្រះសាស្តា ។ បណ្តាបុរស ៣ នាក់នោះ បុរសម្នាក់ចាត់ចែងការងារប្រាក់ បាយ ត្រីអាហារ ម្នាក់ទៀត មានមុខងារខាងវាល់អង្ករ ម្នាក់ទៀត មាននាទីខាងរៀបចំទាន ក្នុងបុរស ៣ នាក់នោះ អ្នកចាត់ចែងប្រាក់ និងបាយ មកកើតជាព្រះបាទពិម្ពិសារមហារាជក្នុងបច្ចុប្បន្ន អ្នកវាល់អង្ករមកកើតជាវិសាខឧបាសក អ្នករៀបចំទាន មកកើតជាព្រះរដ្ឋបាលត្ថេរ ដូច្នេះ ។ កុលបុត្រនោះ បំពេញកុសលក្នុងភពនោះដរាបដល់អស់ជីវិតហើយ ទៅកើតក្នុងទេវលោក ឯព្រះរាហុលត្ថេរកើតជាព្រះជេដ្ឋោរសរបស់ព្រះបាទកិកិ ក្នុងកាលពុទ្ធុប្បាទព្រះ-កស្សបសម្ពុទ្ធ ព្រះញាតិទាំងឡាយថ្វាយព្រះនាមព្រះអង្គថា បឋវិន្ធរកុមារ ព្រះអង្គមានកគិនី ៧ អង្គ កគិនីទាំងនោះសាងបរិវេណ ថ្វាយព្រះទសពល ៧ កន្លែង ។ បឋវិន្ធរកុមារទ្រង់បានតំណែងជាឧបរាជ ទ្រង់ត្រាស់នឹងកគិនីទាំងនោះថា ក្នុងបណ្តាបរិវេណដែលព្រះនាងបានសាងនោះ ចូរឲ្យដល់ខ្ញុំមួយកន្លែង ។ កគិនីទាំងនោះទូលថា បពិត្រព្រះជេដ្ឋៈ ទ្រង់តាំងនៅក្នុងឋានៈជាឧបរាជ ទ្រង់គប្បីប្រទានដល់ខ្ញុំម្ចាស់ទេតើ សូមទ្រង់ធ្វើបរិវេណដទៃចុះ ព្រះរាជកុមារនោះបានស្តាប់ពាក្យរបស់កគិនីទាំងនោះហើយ ទើបធ្វើវិហារ ៥០០ កន្លែង ។ អាចារ្យពួកខ្លះពោលថា បរិវេណ ៥០០ កន្លែងក៏មាន ។ ព្រះរាជកុមារនោះទ្រង់បំពេញកុសលដរាបដល់អស់ជីវិតក្នុងអត្តភាពនោះ ទៅកើតក្នុងទេវ-

លោក ក្នុងពុទ្ធុប្បាទកាលនេះ បបរិទ្ធរកុមារបដិសន្ធិក្នុងព្រះគភ៌របស់ព្រះអគ្គមហេសីនៃព្រះពោធិសត្វរបស់យើង ។ សម្លាញ់របស់លោក កើតក្នុងផ្ទះនៃរដ្ឋបាលសេដ្ឋី ក្នុងថុល្លកោដ្ឋិតនិគម ដែនកុរុ ។

គ្រានោះ ព្រះទសពលនៃយើង ទ្រង់សម្រេចអភិសម្ពោធិញ្ញាណ ហើយប្រកាសធម្មចក្រដ៏ប្រសើរ ហើយយាងមកកាន់ក្រុងកបិលពស្តុដោយលំដាប់ ទ្រង់ឲ្យរាហុលកុមារបព្វជ្ជាហើយ ។ វិធីបព្វជ្ជារាហុលកុមារមកហើយ ក្នុងព្រះបាលី ។ ព្រះសាស្តាបានត្រាស់រាហុលោវាទសូត្រ ជាឱវាទរឿយៗ ដល់ព្រះរាហុលនោះ ដែលបព្វជ្ជាហើយយ៉ាងនេះ ។ ឯរាហុលក្រោកឡើងអំពីព្រលឹម យកដៃក្បង់ខ្សាច់ឡើង ពោលថា ថ្ងៃនេះ អញគប្បីបានឱវាទមានប្រមាណប៉ុណ្ណេះអំពីព្រះទសពល និងឧបជ្ឈាយាចារ្យទាំងឡាយ កើតការសន្ទនាក្នុងកណ្តាលជំនុំសង្ឃថា រាហុលសាមណេរអត់ធន់ចំពោះឱវាទហ្ន៎ ជាឱរសគួជាមួយព្រះជនក ។ ព្រះសាស្តាទ្រង់ជ្រាបវារៈចិត្តនៃភិក្ខុទាំងឡាយ ទ្រង់ព្រះតម្រិះថា កាលតថាគតទៅហើយ ធម្មទេសនាមួយនឹងផ្តើមឡើង គុណរបស់រាហុលនឹងប្រាកដ ទើបយាងទៅប្រថាប់គង់លើពុទ្ធាសនៈ ក្នុងធម្មសភា ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកអង្គុយប្រជុំសន្ទនាគ្នាដោយរឿងអ្វីហ្ន៎ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកខ្ញុំព្រះអង្គសន្ទនាដល់គាពដែលរាហុលសាមណេរជាអ្នកអត់ធន់ចំពោះឱវាទ ។ ព្រះសាស្តាទ្រង់តាំងនៅក្នុងឋានៈនេះ ដើម្បីទ្រង់សម្តែងដល់គុណរបស់រាហុលសាមណេរ ទើបទ្រង់នាំមិគជាតក ( តិបល្លត្ថ-

មិគជាតក ) មកត្រាស់ថា

**មិគំ តិបល្លត្ថមនេកមាយំ**

**អដ្ឋក្ខុរំ អឌ្ឍរត្តាបបាយឹ**

**ឯកេន សោតេន ឆមាស្សសន្តោ**

**ឆហិ កលាហាតិ ភោតិ ភាគិនេយ្យាតិ ។**

អញបានញុំងម្រឹគមានដំណេក ៣ មានក្រចក ៨ ជាសត្វផឹកទឹកក្នុងពេលអធ្រាត្រ ឲ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយ បានដកដង្ហើមខ្ទប់នឹងផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោត ( ព្រានព្រៃ ) ដោយកល ៦ យ៉ាង ។

បន្ទាប់មក ក្នុងវេលាដែលសាមណេរមានអាយុ ៧ វស្សា ទ្រង់សម្តែងអម្ពលដ្ឋិយរាហុលោវាទ ដល់រាហុលសាមណេរនោះថា រាហុល កុំពោលសម្បជានមុសាវាទ ទោះបីលេងដោយភាពជាក្មេងឡើយ ដូច្នេះជាដើម ។ ក្នុងវេលាដែលសាមណេរមានអាយុ ១៨ ឆ្នាំ ត្រាស់មហារាហុលោវាទសូត្រដោយន័យថា រាហុល រូបឯណានីមួយ ដូច្នេះជាដើមដល់រាហុល ដែលចូលទៅបិណ្ឌបាតតាមក្រោយព្រះតថាគត សម្លឹងរូបសម្បត្តិរបស់ព្រះសាស្តា និងរបស់ខ្លួន ត្រិះរិះដោយគេហសិតវិតក្ក ។ ចំណែករាហុលោវាទក្នុងសំយុត្តនិកាយក្តី ក្នុងអង្គុត្តរនិកាយក្តី ជាអាចារ្យនៃវិបស្សនារបស់ព្រះថេរៈទាំងអស់ ។

ខាងក្រោយ ព្រះសាស្តាទ្រង់ជ្រាបថា ញាណរបស់លោកចាស់ក្លា

ក្នុងកាលដែលរាហុលជាភិក្ខុ មិនទាន់មានវស្សា ប្រថាប់គង់ត្រង់អន្ធវ័ន ត្រាស់ចូឡរាហុលោវាទសូត្រហើយ លុះចប់ទេសនា ព្រះរាហុលត្ថេរសម្រេចអរហត្ត មួយអន្លើដោយទេវតាមួយសែនពាន់កោដិ ។ ទេវតាដែលជាព្រះសោតាបន្ន ព្រះសកទាគាមី និងព្រះអនាគាមីរាប់មិនអស់ ។ បន្ទាប់មក ព្រះសាស្តាទ្រង់ប្រថាប់គង់ត្រង់កណ្តាលព្រះអរិយសង្ឃ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងជាកំពូលនៃពួកភិក្ខុដែលប្រាថ្នាចំពោះការសិក្សាក្នុងសាសនានេះ ។ កាលព្រះសាស្តាទ្រង់យាងចារិកទៅក្នុងកុរុរដ្ឋ ទ្រង់សម្រេចដល់ថុល្លកោដ្ឋិត-និគមដោយលំដាប់ កុលបុត្រឈ្មោះរដ្ឋបាល ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បានទូវសទ្ធា ឲ្យមាតាបិតា អនុញ្ញាតហើយ ចូលគាល់ព្រះទសពលបួសហើយក្នុងសម្នាក់នៃព្រះថេរៈមួយរូប តាមពាក្យរបស់ព្រះសាស្តា តាំងអំពីថ្ងៃដែលលោកបួសហើយ សេដ្ឋីគហបតីឃើញភិក្ខុទាំងឡាយទៅកាន់ទ្វារនិវេសន៍របស់ខ្លួន រមែងជេរបរិភាសថា មានការអ្វីរបស់លោកក្នុងផ្ទះនេះ ខ្ញុំមានកូនតែមួយប៉ុណ្ណោះ ពួកលោកក៏នាំទៅបួសបាត់ ឥឡូវនេះ ចង់ធ្វើអ្វីទៀត ។ ព្រះសាស្តាប្រថាប់នៅត្រង់ថុល្លកោដ្ឋិតតាមអស់កន្លះខែហើយ យាងមកកាន់ក្រុងសាវត្ថីទៀត ។ គ្រានោះ រដ្ឋបាលធ្វើកិច្ចក្នុងយោនិមនសិការចម្រើនវិបស្សនា សម្រេចនូវអរហត្តហើយ លោកទូលសូមអនុញ្ញាតអំពីព្រះសាស្តា ហើយទៅកាន់ថុល្លកោដ្ឋិតនិគម ដើម្បីសួរសុខទុក្ខញោមប្រុសស្រី ។ ត្រាច់បិណ្ឌបាតទៅតាមលំដាប់ប្រកក្នុងនិគមនោះ បានទំកុម្មាសផ្អូមដែលទុកកន្លងរាត្រី ក្នុងនិវេសន៍នៃបិតា កើតអសុភសញ្ញាក្នុងពួកស្រីដែលតែងខ្លួន

ហើយ ទើបឈរសម្តែងធម៌ ហោះទៅហើយ ដូចព្រួញក្សើងដែលផុតអំពីបន្ទោះធ្នូ ទៅកាន់មិគាចិរឧទ្យាននៃព្រះបាទកោរព្យៈ ។ គង់ត្រង់ផ្ទាំងថ្មដ៏ជាមង្គល សម្តែងធម៌ដែលប្រដាប់ហើយ ដោយសេចក្តីជ្រះថ្លា ៤ ប្រការ ដល់ព្រះរាជាដែលយាងមកសំណេះសំណាល ។ ចារិកទៅដោយលំដាប់ ហើយមកគាល់ព្រះសាស្តាទៀត ។ រឿងនេះកើតឡើងហើយ ដោយអាការយ៉ាងនេះ ។ ក្រោយមក ព្រះសាស្តា ប្រថាប់គង់ត្រង់កណ្តាលព្រះអរិយសង្ឃ ទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងជាកំពូលនៃពួកកុលបុត្រ ដែលបួសដោយសទ្ធា ក្នុងសាសនានេះឯង ។

## អដ្ឋកថាសូត្រទី ២ ចប់

# អដ្ឋកថា សូត្រទី ៣
# ប្រវត្តិ ព្រះកោណ្ឌញ្ញត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៣ ដូចតទៅនេះ បទថា **បឋមំសលាកំ គណ្ហន្តានំ** ព្រះសាស្តាទ្រង់សម្តែងថា ព្រះកោណ្ឌធានត្ថេរជាកំពូលនៃពួកភិក្ខុដែលចាប់ស្លាកបានមុនភិក្ខុដទៃ ។

បានឮមកថា ព្រះថេរៈនោះ កាលព្រះតថាគតយាងទៅឧគ្គនគរ ក្នុងថ្ងៃនាងមហាសុភទ្ទានិមន្ត កាលភិក្ខុពោលថា ថ្ងៃនេះ ព្រះសាស្តាយាងភិក្ខាចារឆ្ងាយ ភិក្ខុបុថុជ្ជនកុំបីចាប់ស្លាកឡើយ ព្រះខីណាស្រព ៥០០ អង្គប៉ុណ្ណោះចូរចាប់ ក៏បន្លឺសីហនាទ ចាប់ស្លាកបានទី ១ នោះឯង កាលព្រះតថាគតនិមន្តទៅកាន់ក្រុងសាកេត ក្នុងថ្ងៃនាងចូឡសុភទ្ទានិមន្ត ក៏ចាប់ស្លាកបានទី ១ ដូចគ្នា ក្នុងវាងភិក្ខុ ៥០០ រូប ។ ក្នុងកាលព្រះសាស្តាទៅកាន់សុណាបរន្តជនបទក៏ដូចគ្នា ដោយហេតុទាំងនេះ ទើបព្រះថេរៈឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលចាប់ស្លាកបានទី ១ ។ ម្យ៉ាងទៀត ពាក្យថា **កុណ្ឌធាន** ជាឈ្មោះរបស់លោក ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ

បានឮថា ក្នុងកាលព្រះបទុមុត្តរៈកើតឡើង ព្រះថេរៈអង្គនេះកើតក្នុងផ្ទះត្រកូលមួយ ក្នុងក្រុងហង្សវតី ទៅវិហារស្តាប់ធម៌ដោយន័យដូចពោលហើយនោះឯង ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុដែលចាប់ស្លាកបានទី ១ ទើបធ្វើកុសលកម្មដល់ព្រះសម្ពុទ្ធ ប្រាថ្នាតំណែងនោះ ។ ព្រះសាស្តាទ្រង់ឃើញថា មិនមានសេចក្តីអន្តរាយ ទើប

ព្យាករហើយ បំពេញកុសលជរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និង មនុស្ស លុះព្រះកស្សបសម្ពុទ្ធកើតឡើង ក៏កើតជាភុម្មទេវតា ធម្មតាព្រះពុទ្ធ ដែលមានព្រះជន្មាយុវែង មិនបានធ្វើឧបោសថរៀងរាល់កន្លះខែទេ ។ គឺព្រះ វិបស្សីទសពល ក្នុងរវាង ៦ ឆ្នាំ ទើបមានឧបោសថម្តង ។ ចំណែកព្រះ កស្សបទសពលទ្រង់ឲ្យសូត្របាតិមោក្ខរៀងរាល់ ៦ ខែម្តង ។ ក្នុងថ្ងៃសូត្រ បាតិមោក្ខនោះ ភិក្ខុ ២ រូប ដែលនៅក្នុងទិសមកដោយតាំងចិត្តថា នឹងធ្វើ ឧបោសថ ។ ភុម្មទេវតានេះគិតថា ការមានមេត្រីរបស់ភិក្ខុ ២ រូបនេះ មាំទាំ ពន់ពេក កាលមានមនុស្សធ្វើឲ្យបែកគ្នា លោកនឹងបែកគ្នា ឬមិនបែកហ្ន៎ ទើប សម្លឹងរកឱកាសរបស់ភិក្ខុទាំង ២ នោះ ដើរទៅក្បែរៗ ភិក្ខុទាំង ២ រូបនោះ គ្រានោះ ព្រះថេរៈមួយរូបផ្ញើបាត្រ និងចីវរជាមួយព្រះថេរៈមួយរូបទៀត ទៅ កាន់ទីដែលមានផាសុក ដោយទឹកដើម្បីជម្រះលាងសរីរៈ កាលលាងដៃ ជើងហើយ ក៏ចេញមកអំពីម្លប់ឈើដែលគាប់ចិត្ត ភុម្មទេវតាកាឡាខ្លួនជាស្រី មានរូបស្អាតនៅខាងក្រោយព្រះថេរៈនោះ ទើបធ្វើឲ្យមានសក់កន្រ្ទើង ហើយ រៀបចំសក់ជាថ្មី ធ្វើប្រឡាក់ធូលីខាងខ្នង ហើយរៀបចំសំពត់ជាថ្មី ដើរប្រជ្រៀត ព្រះថេរៈចេញអំពីគុម្ពឈើ មកឈរក្នុងទីសមគួរ នាចំណែកម្ខាង ព្រះថេរៈ ជាសម្លាញ់ឃើញហេតុការណ៍នោះ ទើបកើតការទោមនស្សគិតថា ការស្និទ្ធ ស្នាលដែលជាប់តាមគ្នាមកអស់កាលយូរ ជាមួយភិក្ខុនោះរបស់អញ វិនាស ហើយក្នុងកាលឥឡូវនេះ បើអញដឹងមារយាទយ៉ាងនេះ អញមិនធ្វើសេចក្តី ស្និទ្ធស្នាលជាមួយភិក្ខុនេះ ឲ្យយូរដល់ម៉្លេះឡើយ ។ គ្រាន់តែព្រះថេរៈនោះមក

ដល់ប៉ុណ្ណោះ ក៏ពោលថា និមន្តចុះអាវុសោ នេះបាត្រ ចីវររបស់លោក ខ្ញុំមិនដើរផ្លូវមួយជាមួយសម្លាញ់ដូចលោកទៀតទេ ។ កាលបានស្តាប់ពាក្យនោះ ហឫទ័យរបស់ភិក្ខុដែលមានការខ្មាសនោះ ដូចត្រូវលំពែងចាក់ទម្លុះដូច្នោះ ទើបពោលនឹងព្រះថេរៈនោះថា អាវុសោ លោកពោលអ្វីយ៉ាងនេះ ខ្ញុំមិនដឹងអាបត្តិ សូម្បីត្រឹមទុក្កដមកអស់កាល មានប្រមាណប៉ុណ្ណេះ ។ លោកម្ចាស់ពោលថា ខ្ញុំជាមនុស្សអាក្រក់ក្នុងថ្ងៃនេះ លោកម្ចាស់ឃើញអ្វីឬ ។ ព្រះថេរៈនោះពោលថា ប្រយោជន៍ដោយកម្មដទៃដែលខ្ញុំឃើញហើយ លោកចេញមកក្នុងទីតែមួយជាមួយស្រីដែលតែងខ្លួនយ៉ាងនេះៗ ព្រោះហេតុអ្វី ។ ទើបព្រះថេរៈឆ្លើយថា អាវុសោ កម្មនោះរបស់ខ្ញុំមិនមាន ខ្ញុំមិនបានឃើញស្រីបែបនេះ លោកពោលរហូត ៣ ដង ។ ព្រះថេរៈមួយរូបទៀតក៏មិនបានជឿពាក្យ កាន់យកហេតុដែលខ្លួនឃើញហើយប៉ុណ្ណោះជាសំខាន់ មិនដើររួមផ្លូវជាមួយព្រះថេរៈនោះ ទៅគាល់ព្រះសាស្តាដោយផ្លូវដទៃ ។ ភិក្ខុមួយរូបទៀត ក៏ទៅគាល់ព្រះសាស្តាដោយផ្លូវដទៃដូចគ្នា ។

បន្ទាប់អំពីនោះ ក្នុងកាលភិក្ខុសង្ឃផ្តើមធ្វើឧបោសថ ភិក្ខុនោះចាំភិក្ខុនោះបានក្នុងរោងឧបោសថ ទើបពោលថា ក្នុងរោងឧបោសនេះ មានភិក្ខុលាមកឈ្មោះនេះ អាត្មាអញមិនធ្វើឧបោសថជាមួយភិក្ខុនោះ ទើបចេញទៅឈរខាងក្រៅ ។ ភុម្មទេវតាគិតថា អញធ្វើកម្មធ្ងន់ហើយ ទើបកាឡាខ្លួនជាឧបាសកចាស់ ទៅរកភិក្ខុនោះពោលថា ហេតុអ្វី ទើបលោកម្ចាស់ឈរក្នុងទីនេះ ។ ព្រះថេរៈពោលថា អើ ឧបាសក ភិក្ខុលាមកចូលមកកាន់រោង

ឧបោសថនេះ អាត្មាមិនធ្វើឧបោសថជាមួយភិក្ខុនោះ ទើបចេញមកឈរខាងក្រៅ ឧបាសកចាស់នោះពោលថា បពិត្រលោកម្ចាស់ កុំយល់យ៉ាងនោះឡើយ ភិក្ខុនេះជាអ្នកមានសីលបរិសុទ្ធ ខ្ញុំ គឺស្រីដែលលោកម្ចាស់ឃើញនោះ ខ្ញុំឃើញសេចក្តីល្អ ការខ្មាស និងការមិនខ្មាស ធ្វើកម្មហើយដោយគិតថា ការមេត្រីរបស់ព្រះថេរៈមាំទាំ ឬមិនមាំទាំ ក៏សាកល្បងលោកម្ចាស់ទាំង-ឡាយមើល ។ ភិក្ខុនោះសួរថា នែសប្បុរស លោកជាអ្នកណា ឧបាសកឆ្លើយថា ខ្ញុំជាកុម្មទេវតា ។ ទេវបុត្រឈរផង ពោលផង ដោយអានុភាពដែលជាទិព្វ ក្រាបចុះទៀបបាតជើងរបស់ព្រះថេរៈពោលថា សូមលោកម្ចាស់អត់នូវទោសនោះដល់ខ្ញុំ ព្រះថេរៈមិនដឹងរឿង សូមលោកម្ចាស់ធ្វើឧបោសថចុះ និមន្តព្រះថេរៈឲ្យចូលទៅកាន់រោងឧបោសថហើយ ។ ព្រះថេរៈនោះធ្វើឧបោសថក្នុងទីជាមួយគ្នាហើយ ក៏នៅក្នុងទីជាមួយគ្នាជាមួយព្រះថេរៈនោះដោយអំណាចនៃការចងមេត្រីទៀតផង ។ កម្មរបស់ព្រះថេរៈនេះ លោកមិនបានពោល ចំណែកភិក្ខុដែលត្រូវចោទ បំពេញវិបស្សនាបន្តៗ មក ក៏បានសម្រេចអរហត្តហើយ ។

កុម្មទេវតាក៏មិនផុតភ័យក្នុងអបាយ រហូតអស់មួយពុទ្ធន្តរ ព្រោះផលនៃកម្មនោះ លុះមកកើតជាមនុស្សតាមសមគួរដល់កាល ទោសដែលអ្នកដទៃទោះជាណាអ្នកធ្វើក៏ដោយ ក៏ធ្លាក់ដល់បុគ្គលនោះប៉ុណ្ណោះ លោកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី នាពុទ្ធុប្បាទកាលនៃព្រះមានព្រះភាគរបស់យើង ញាតិរបស់លោកឲ្យឈ្មោះថា ធានមាណព ចម្រើនវ័យហើយ រៀន

ត្រៃវេទ ក្នុងវេលាស្តាប់ធម៌របស់ព្រះសាស្តា បានទូវសទ្ធាហើយ បួស តាំង អំពីថ្ងៃដែលលោកបួសហើយ ស្រីអ្នកតែងខ្លួនម្នាក់ កាលលោកចូលស្រុក ក៏ចូលទៅតាមលោកដែរ កាលចេញក៏ចេញដែរ កាលចូលវិហារក៏ចូលដែរ កាលឈរក៏ឈរដែរ ដូច្នោះ រមែងប្រាកដថា ជាប់នៅជានិច្ចយ៉ាងនេះ ព្រះថេរៈក៏មិនឃើញ តែដោយផលនៃកម្មចាស់របស់ព្រះថេរៈនោះ ទើបស្រីនោះ ប្រាកដដល់អ្នកដទៃៗ ស្រីទាំងឡាយដែលប្រគេនបបរ និងភិក្ខុក្នុងស្រុក ក៏ធ្វើការចំអកចំអន់ថា បពិត្រលោកម្ចាស់ បបរមួយវែកនេះ សម្រាប់លោកម្ចាស់ មួយវែកទៀតនេះ សម្រាប់មិត្តស្រីលោកម្ចាស់ ទើបព្រះថេរៈមានការក្តៅក្រហាយ រំខានចិត្តយ៉ាងធំ សាមណេរ និងភិក្ខុកំលោះចោមរោមលោក ទៅវិហារក៏ធ្វើចំអកថា **ធានោ កោណ្ឌោ ជាតោ** ព្រះធានជាបុគ្គលអាក្រក់ ។

ក្រោយមក លោកមានឈ្មោះថា កោណ្ឌធានត្ថេរ ព្រោះហេតុនោះឯង ព្រះថេរៈព្យាយាមហើយព្យាយាមទៀត កាលមិនអាចអត់ធន់ចំពោះការចំអកដែលពួកសាមណេរ និងភិក្ខុកំលោះទាំងនោះធ្វើបាន ក៏កើតសេចក្តីតតាំងឡើងពោលថា ឧបជ្ឈាយ៍របស់លោកនោះឯងអាក្រក់ អាចារ្យរបស់លោកនោះឯងអាក្រក់ ។ គ្រានោះ ទើបភិក្ខុទាំងឡាយក្រាបទូលរឿងនោះដល់ព្រះសាស្តាថា ព្រះកុណ្ឌធានពោលគ្រោតគ្រាតយ៉ាងនេះៗ ជាមួយភិក្ខុកំលោះ និងសាមណេរទាំងឡាយ ។ ព្រះសាស្តាឲ្យហៅភិក្ខុនោះមក ត្រាស់សួរថា ម្នាលភិក្ខុ ពិតឬ ។ កាលទូលថា ពិតព្រះមានព្រះភាគត្រាស់ថា ហេតុអ្វី ទើបអ្នកពោលយ៉ាងនោះ ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនអាច

អត់ធ្មត់ដល់ការចាក់ដោតជាប្រចាំបានទេ ទើបពោលយ៉ាងនោះ ។ ព្រះសាស្តាត្រាស់ថា ខ្លួនអ្នកមិនអាចប្រើកម្មដែលធ្វើទុកក្នុងកាលមុនឲ្យអស់ទៅរហូតដល់សព្វថ្ងៃនេះ តទៅអ្នកកុំពោលគ្រោតគ្រាតបែបនោះទៀតឡើយ ដូច្នេះហើយ ត្រាស់ព្រះគាថានេះថា

**មាវោច ផរុសំ កញ្ចិ វុត្តា បដិវទេយ្យុ តំ**
**ទុក្ខា ហិ សារម្ភកថា បដិទណ្ឌា ផុសេយ្យុ តំ**
**សចេ ន នេសិ អត្តានំ កំសោ ឧបហតោ យថា**
**ឯស បត្តោសិ និព្វានំ សារម្ភោតេ ន វិជ្ជតីតិ ។**

អ្នកកុំនិយាយពាក្យអាក្រក់នឹងអ្នកណាមួយឡើយ ជនទាំងឡាយដែលអ្នកស្តីថាឲ្យហើយ គេគប្បីស្តីថាតបមកអ្នកវិញ ព្រោះថា ការពោលពាក្យប្រណាំងប្រជែង ជាហេតុនាំឲ្យកើតទុក្ខ ការតស៊ូទាំងឡាយ គប្បីប៉ះពាល់នូវអ្នក ។ បើអ្នកធ្វើខ្លួនមិនឲ្យញាប់ញ័រ ដូចរគាំងដែលចៀរមាត់ចេញហើយ ( រមែងមិនលាន់ឮសូរ ) ដូច្នោះ អ្នកនុ៎ះជាបុគ្គលដល់នូវព្រះនិព្វាន ការប្រណាំងប្រជែង មិនមានដល់អ្នកដូច្នេះ ។

បុគ្គលទាំងឡាយ ក្រាបទូលសេចក្តីដែលព្រះថេរៈនោះត្រាច់ទៅជាមួយមាតុគ្រាមនេះដល់ព្រះបាទកោសល ព្រះរាជាបញ្ជូនអមាត្យទៅថា នែនាយអ្នកចូរទៅសាកល្បងមើល សូម្បីព្រះរាជាក៏យាងទៅកាន់លំនៅរបស់ព្រះថេរៈ

នោះ ព្រមដោយរាជបរិវារដ៏ច្រើន ប្រថាប់ឈរមើលក្នុងទីដែលសមគួរ នាចំណែកម្ខាង ខណៈនោះ ព្រះថេរៈកំពុងដេរចីវរ ស្រីនោះក៏ប្រាកដដូចជាឈរក្នុងទីមិនឆ្ងាយអំពីព្រះថេរៈនោះ ព្រះរាជាឃើញហើយ ទ្រង់ព្រះតម្រិះថា មានហេតុនេះឬ ទើបទៅកាន់ទីដែលស្រីនោះកំពុងឈរ កាលព្រះរាជាមកដល់ ស្រីនោះហាក់ដូចចូលទៅកាន់បណ្ណសាលា ដែលជាលំនៅរបស់ព្រះថេរៈ សូម្បីព្រះរាជាក៏ចូលទៅកាន់បណ្ណសាលា មួយអន្លើជាមួយស្រីនោះ ពិនិត្យមើលគ្រប់កន្លែងក៏មិនឃើញ ទើបសន្និដ្ឋានក្នុងព្រះហឫទ័យថា នេះមិនមែនមាតុគ្រាម ជាវិបាកនៃកម្មតែម្យ៉ាងរបស់ព្រះថេរៈ ដំបូងកាលមកដល់ជិតព្រះថេរៈក៏ទ្រង់មិនថ្វាយបង្គំព្រះថេរៈ កាលទ្រង់ជ្រាបថា ហេតុនោះមិនពិត ទើបយាងមកថ្វាយបង្គំព្រះថេរៈ ប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង ត្រាស់សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់មិនលំបាកដោយបិណ្ឌបាតទេឬ ។ ព្រះថេរៈទូលថា បពិត្រមហារាជ ល្មមប្រព្រឹត្តទៅបាន ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ញោមដឹងរឿងរ៉ាវរបស់លោកម្ចាស់ កាលលោកម្ចាស់ត្រាច់ទៅជាមួយវត្ថុដែលធ្វើឲ្យសៅហ្មងបែបនេះ ឈ្មោះថា អ្នកណាគេនឹងជ្រះថ្លា តាំងអំពីនេះទៅ លោកម្ចាស់មិនចាំបាច់ទៅកាន់ទីណាឡើយ ញោមនឹងឧបត្ថម្ភដោយបច្ច័យ ៤ លោកម្ចាស់កុំប្រមាទដោយយោនិសោមនសិការចុះ ហើយបញ្ជូនភិក្ខាទៅប្រគេនជាប្រចាំ ។ ព្រះថេរៈបានរាជូបត្ថម្ភ ជាបុគ្គលមានឯកគ្គតាចិត្ត ព្រោះមានភោជនជាទីសប្បាយ ចម្រើនវិបស្សនា សម្រេចព្រះអរហត្តផលហើយ តាំងអំពីនោះទៅ ស្រីនោះក៏បាត់ទៅ ។

នាងមហាសុភទ្ទានៅក្នុងត្រកូលមិច្ឆាទិដ្ឋិ ក្នុងឧគ្គនគរគិតថា ព្រះសាស្ដាសូមទ្រង់អនុគ្រោះខ្ញុំព្រះអង្គ ទើបអធិដ្ឋានឧបោសថ ជាអ្នកមិនមានក្លិនធ្លាប នៅលើប្រាសាទជាន់លើ ធ្វើសច្ចកិរិយាថា ផ្កាទាំងនេះ ចូរកុំនៅក្នុងវាងផ្លូវ ចូរបាំងជាពិតានខាងលើនៃព្រះទសពលចុះ សូមព្រះទសពលទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គ មួយអន្លើដោយពួកភិក្ខុ ៥០០ រូប ដោយសញ្ញានេះចុះ រួចបាចផ្កា ៨ ក្ដាប់ទៅ ផ្កាក៏ទៅបាំងជាពិតានខាងលើព្រះសាស្ដាក្នុងពេលសម្ដែងធម៌ ។ ព្រះសាស្ដាទតឃើញពិតានផ្កាម្លិះនោះ ទ្រង់ទទួលភិក្ខារបស់នាងសុភទ្ទាដោយចិត្តនោះឯង ។ ថ្ងៃស្អែកឡើង កាលអរុណរះ ទើបត្រាស់ប្រាប់ព្រះអានន្ទថា ម្នាលអានន្ទ ថ្ងៃនេះ តថាគតទៅភិក្ខាចារក្នុងទីឆ្ងាយ ចូរកុំឲ្យស្លាកដល់ភិក្ខុបុថុជ្ជន ចូរឲ្យដល់ព្រះអរិយៈប៉ុណ្ណោះ ព្រះថេរៈប្រាប់ដល់ភិក្ខុទាំងឡាយថា អាវុសោ ថ្ងៃនេះ ព្រះសាស្ដាទ្រង់នឹងភិក្ខាចារក្នុងទីឆ្ងាយ ភិក្ខុបុថុជ្ជន កុំចាប់ស្លាកឡើយ ព្រះអរិយៈប៉ុណ្ណោះចូរចាប់ ។ ព្រះកុណ្ឌធានពោលថា អ្នកមានអាយុ ចូរនាំស្លាកមក ហើយលាដៃចេញទៅមុន កាលព្រះអានន្ទពោលថា ព្រះសាស្ដាមិនឲ្យប្រទានស្លាកដល់ភិក្ខុដូចលោកទេ ទ្រង់ឲ្យប្រទានចំពោះភិក្ខុដែលជាអរិយៈប៉ុណ្ណោះ កើតវិតក្កឡើង ទើបទៅក្រាបទូលព្រះសាស្ដា ។ ព្រះសាស្ដាត្រាស់ថា អ្នកចូរទៅឲ្យស្លាកដល់ភិក្ខុដែលប្រាប់ឲ្យនាំស្លាកមកចុះ ។ ទើបព្រះថេរៈគិតថា បើមិនគួរឲ្យដល់ព្រះកុណ្ឌធាន ម្ល៉េះព្រះសាស្ដាគប្បីឃាត់លោក នឹងមានហេតុមួយពិត ទើបរូតរះនាំមក ដោយគិតថា នឹងឲ្យស្លាកដល់ព្រះកុណ្ឌធាន ព្រះកុណ្ឌធានត្រៀមុនព្រះអានន្ទមក

*ចូលចតុត្ថជ្ឈានដែលជាបាទនៃអភិញ្ញា ឈរនៅក្នុងអាកាសដោយឫទ្ធិ ពោល ថា លោកម្ចាស់អានន្ទបូរនាំស្លាកមក ព្រះសាស្ដាទ្រង់ស្គាល់ខ្ញុំ ព្រះសាស្ដា មិនឃាត់ ភិក្ខុដូចខ្ញុំដែលចាប់ស្លាកបានមុន ហើយលាដៃចេញ ទៅចាប់ស្លាក ហើយ ព្រះសាស្ដាទ្រង់ធ្វើរឿងនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាព្រះ ថេរៈទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុដែលចាប់ស្លាកបានទី ១ ក្នុងសាសនា ដូច្នេះ ។*

**អដ្ឋកថាសូត្រទី ៣ ចប់**

# អដ្ឋកថា សូត្រទី ៤

# ប្រវត្តិ ព្រះវង្គីសត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៤ ដូចតទៅនេះ បទថា **បដិភាណវន្តានំ** ព្រះមានព្រះភាគទ្រង់សម្តែងថា ព្រះវង្គីសៈ ជាកំពូលនៃពួកភិក្ខុដែលមានបដិភាណសម្បូរ បានឮថា ព្រះថេរៈនេះ កាលចូលទៅគាល់ព្រះទសពល តាំងអំពីគន្លងនៃចក្ខុ ក៏ពោលសរសើរគុណព្រះសាស្តា ឧបមាដូចព្រះចន្ទ ឧបមាដូចព្រះអាទិត្យ និងអាកាស និងមហាសមុទ្រ និងស្តេចដំរី និងស្តេចសីហម្រឹគ ច្រើនរយច្រើនពាន់បទ ទើបចូលគាល់ ព្រោះដូច្នោះ ទើបលោកជាកំពូលរបស់ពួកភិក្ខុដែលមានបដិភាណ ។ ក្នុងបញ្ហាកម្មរបស់លោកមានរឿងដែលនឹងពោលតាមលំដាប់ដូចតទៅនេះ

បានឮថា កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះថេរៈរូបនេះ បដិសន្ធិក្នុងត្រកូលដែលមានភោគសម្បត្តិច្រើន ក្នុងក្រុងហង្សវតី ទៅកាន់វិហារស្តាប់ធម៌ ដោយន័យមុននោះឯង ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុដែលមានបដិភាណ ទើបធ្វើកុសលកម្មដល់ព្រះសាស្តា ធ្វើសេចក្តីប្រាថ្នាថា ក្នុងអនាគតកាល ខ្ញុំព្រះអង្គគប្បីជាកំពូលនៃពួកភិក្ខុដែលមានបដិភាណ ជាបុគ្គលដែលព្រះសាស្តាទ្រង់ព្យាករ ហើយធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ ក៏មកកើតក្នុងត្រកូលព្រាហ្មណ៍ក្រុងសាវត្ថី ញាតិទាំងឡាយដាក់ឈ្មោះថា វង្គីសមាណព ។ លោកចម្រើនវ័យហើយ រៀនត្រៃវេទ ធ្វើឲ្យអាចារ្យឲ្យពេញចិត្ត ហើយសិក្សាមន្តឈ្មោះថា ឆវសីសមន្ត គឺមន្តដឹងក្បាលមនុស្ស

យកក្រចក គោះលលាដ៍ក្បាលខ្មោចហើយ ក៏ដឹងថា សត្វនេះកើតក្នុងកំណើតឈ្មោះនោះ ព្រាហ្មណ៍ទាំងឡាយជ្រាបថា មន្តនេះ ជាផ្លូវសម្រាប់អញចិញ្ចឹមជីវិត ទើបឲ្យវង្គីសមាណព អង្គុយក្នុងរថដែលបិទបាំងហើយ ទៅកាន់គាមនិគម និងរាជធានីទាំងឡាយ ឈប់ត្រង់ទ្វារក្រុង ឬទ្វារនិគម ដឹងថាមហាជនមកជុំគ្នាហើយ ក៏ពោលថា អ្នកណាឃើញវង្គីសៈ អ្នកនោះនឹងបានទ្រព្យ ឬបានយស ឬបានទៅស្ថានសួគ៌ ដូច្នេះ ជនជាច្រើនស្ដាប់ពាក្យរបស់ព្រាហ្មណ៍ទាំងនោះហើយ ឲ្យតម្លៃដើម្បីមើល ។ ព្រះរាជា និងអមាត្យរបស់ព្រះរាជាទៅកាន់សម្នាក់របស់ព្រាហ្មណ៍ទាំងនោះ សួរថា គុណវិសេស គឺការដឹងរបស់អាចារ្យដូចម្ដេច អ្នកទាំងឡាយមិនដឹងឬ ឈ្មោះថា បណ្ឌិតដទៃដូចគ្នានឹងអាចារ្យរបស់ពួកយើង មិនមានក្នុងជម្ពូទ្វីបទាំងមូល ឲ្យបុគ្គលនាំលលាដ៍ក្បាលរបស់អ្នកស្លាប់ទៅហើយ អស់ ៣ ឆ្នាំ យកក្រចកគោះ ក៏ដឹងថា សត្វនេះទៅកើតក្នុងទីនោះ ឯវង្គីសៈ កាលកាត់សេចក្ដីសង្ស័យរបស់មហាជន ទើបឲ្យនាំជនទាំងនោះមកហើយ ឲ្យប្រាប់គតិរៀងៗ ខ្លួន អាស្រ័យហេតុនោះ បានទ្រព្យអំពីដៃរបស់មហាជន ១ រយខ្លះ ១ ពាន់ខ្លះ ។

ពួកព្រាហ្មណ៍នាំវង្គីសមាណព ត្រាច់ទៅតាមគាប់ចិត្ត ហើយក៏មកដល់ក្រុងសាវត្ថី ។ វង្គីសៈនៅមិនឆ្ងាយអំពីជេតពនមហាវិហារ គិតថា ជនទាំងឡាយពោលថា ព្រះសមណគោតមជាបណ្ឌិត តែអញមិនគួរត្រាច់ទៅ ធ្វើតាមពាក្យព្រាហ្មណ៍ទាំងនេះតែម្យ៉ាងគ្រប់ពេល អញគួរទៅកាន់សម្នាក់របស់បណ្ឌិតទាំងឡាយខ្លះ វង្គីសមាណពនោះ ពោលនឹងព្រាហ្មណ៍ទាំងឡាយថា

អ្នកទាំងឡាយចូរទៅចុះ ខ្ញុំមិនទៅគាល់ព្រះសមណគោតមជាមួយមនុស្សច្រើនឡើយ ព្រាហ្មណ៍ទាំងនោះប្រាប់ថា លោកអាចារ្យវង្គីសៈកុំគាប់ចិត្ត ក្នុងការគាល់ព្រះសមណគោតមឡើយ ព្រោះបុគ្គលណា ឃើញព្រះសមណៈនោះៗ ក៏នឹងបង្វែរចិត្តបុគ្គលនោះដោយកលមាយា ។ វង្គីសៈមិនជឿពាក្យព្រាហ្មណ៍ទាំងនោះ ទៅគាល់ព្រះសាស្តា ធ្វើបដិសណ្ឋារៈដោយពាក្យដ៏ពីរោះ អង្គុយក្នុងទីដ៏សមគួរ នាចំណែកម្ខាង ។

កាលនោះ ព្រះសាស្តាសួរថា ម្នាលវង្គីសៈ អ្នកចេះសិប្បៈអ្វី វង្គីសៈទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងឆវសីសមន្ត ។ ព្រះសាស្តាត្រាស់សួរថា មន្តនោះធ្វើអ្វី វង្គីសៈទូលថា រាយមន្តនោះហើយ យកក្រចកគោះសីសៈរបស់មនុស្សស្លាប់ទៅហើយអស់ ៣ ឆ្នាំ ក៏ដឹងទីដែលសត្វនោះកើត ។ ព្រះសាស្តាទ្រង់បង្ហាញសីសៈរបស់បុគ្គលដែលកើតក្នុងនរកមួយដល់វង្គីសៈនោះ របស់អ្នកកើតក្នុងមនុស្សមួយ អ្នកកើតក្នុងទេវលោកមួយ របស់អ្នកបរិនិព្វានហើយមួយ ។ វង្គីសៈនោះគោះលលាដ៍ដំបូង ក្រាបទូលថា បពិត្រព្រះគោតម សត្វនេះទៅកាន់នរក ព្រះសាស្តាត្រាស់ថា សាធុ សាធុ អ្នកឃើញប្រពៃហើយ ហើយត្រាស់សួរថា ម្នាលវង្គីសៈ សត្វនេះទៅទីណា ។ វង្គីសៈទូលតបថា បពិត្រព្រះគោតម ទៅកាន់មនុស្សលោក ។ ព្រះសាស្តាត្រាស់ថា សត្វនេះទៅណា វង្គីសៈទូលថា សត្វនេះទៅទេវលោក វង្គីសៈក្រាបទូលដល់ទីទៅរបស់មនុស្សទាំង ៣ ពួក ដោយប្រការដូច្នេះ ។ តែលុះយកក្រចកគោះសីសៈរបស់បុគ្គលដែលបរិនិព្វាន ក៏មិនឃើញខាងចុងផង ខាង

ដើមផង ។ ពេលនោះ ទើបព្រះសាស្តាត្រាស់សួរវង្គីសៈនោះថា អ្នកមិនអាចឃើញឬ វង្គីសៈ ។ វង្គីសមាណពទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គពិនិត្យពិច័យមើលសិន ហើយប្រមៀលទៅមក តើវង្គីសៈនឹងដឹងគតិរបស់ព្រះខីណាស្រពដោយមន្តរបស់លទ្ធិខាងក្រៅបានដូចម្តេច កាលបើដូច្នោះញើសក៏ហូរចេញអំពីថ្ងាសរបស់គាត់ គាត់ខ្មាសហើយ ក៏ឈរស្ងៀម កាលនោះព្រះសាស្តាត្រាស់ថា ម្នាលវង្គីសៈ អ្នកលំបាកឬ វង្គីសៈទូលថា បពិត្រព្រះគោតម ខ្ញុំព្រះអង្គមិនដឹងគតិរបស់សត្វនេះ បើទ្រង់ជ្រាប សូមត្រាស់ប្រាប់ចុះ ។ ព្រះសាស្តាត្រាស់ថា វង្គីសៈ តថាគតដឹងសីសៈនេះ ទោះបីក្រៃលែងជាងនេះក៏ដឹង ដូច្នេះហើយ ភាសិតគាថា ២ ក្នុងធម្មបទថា

**ចុតឹ យោ វេទិ សត្តានំ ឧបបត្តិញ្ច សព្វសោ**
**អសត្តំ សុគតំ ពុទ្ធំ តមហំ ព្រូមិ ព្រាហ្មណំ**
**បស្ស គតឹ ន ជានន្តិ ទេវា គន្ធព្វមានុសា**
**ខីណាសវំ អរហន្តំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា ដឹងច្បាស់ចុតិ និងបដិសន្ធិរបស់ពួកសត្វ ដោយអាការទាំងពួងបាន តថាគតហៅបុគ្គលដែលជាអ្នកមិនជាប់នៅក្នុងកាម អ្នកមានដំណើរល្អ ដោយសេចក្តីប្រតិបត្តិ អ្នកត្រាស់ដឹងនូវសច្ចៈ ៤ នោះ ថាជាព្រាហ្មណ៍ ។

ទេវតា គន្ធព្វ និងពួកមនុស្សទាំងឡាយ មិនដឹងគតិរបស់បុគ្គលណា តថាគតហៅបុគ្គល ដែលជាអ្នកមានអាសវៈអស់ហើយ ជាព្រះអរហន្តនោះ

ថាជាព្រាហ្មណ៍ ។

បន្ទាប់អំពីនោះ វង្គីសៈពោលថា បពិត្រព្រះគោតម បុគ្គលប្តូរវិជ្ជា និង វិជ្ជា មិនមានសេចក្តីវិនាស ខ្ញុំព្រះអង្គនឹងថ្វាយមន្តដែលខ្ញុំព្រះអង្គដឹងដល់ទ្រង់ សូមព្រះអង្គមេត្តាត្រាស់ប្រាប់មន្តនោះដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាត្រាស់ ថា ម្នាលវង្គីសៈ តថាគតមិនប្តូរមន្តដោយមន្តទេ តថាគតនឹងឲ្យតែម្យ៉ាង ប៉ុណ្ណោះ ។ វង្គីសៈទូលថា សាធុ ព្រះគោតម សូមទ្រង់ប្រទានដល់ខ្ញុំព្រះអង្គ ហើយសម្តែងការឱនលំទោន អង្គុយផ្គងអញ្ជលីហើយ ។ ព្រះសាស្តាត្រាស់ ថា ម្នាលវង្គីសៈ ក្នុងសម័យអ្នករៀនមន្ត ដែលមានតម្លៃច្រើន ឬមន្តណា មួយ មិនចាំបាច់មានការអប់រំ មានឬ ។ វង្គីសៈពោលថា មិនមានទេព្រះ គោតម ។ ព្រះសាស្តាត្រាស់ថា អ្នកសម្គាល់ថា មន្តរបស់តថាគត មិនមាន ការអប់រំឬ ។ ឈ្មោះថា ព្រាហ្មណ៍ទាំងឡាយជាអ្នកមិនឆ្អែតដោយមន្ត ព្រោះ ដូច្នោះ ទើបវង្គីសៈនោះក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះគោតម ខ្ញុំ ព្រះអង្គនឹងធ្វើសេចក្តីកំណត់ដែលទ្រង់បានត្រាស់ ។ ព្រះសាស្តាត្រាស់ថា ម្នាលវង្គីសៈ តថាគតកាលនឹងឲ្យមន្តនេះ រមែងឲ្យដល់បុគ្គលដែលមានភេទ ស្មើគ្នាជាមួយតថាគត ។ វង្គីសៈពោលនឹងព្រាហ្មណ៍ទាំងឡាយថា ខ្ញុំគួរធ្វើ កិច្ចណាមួយ ហើយទៅរៀនមន្តនេះ អ្នកទាំងឡាយ បើខ្ញុំចេញបួសហើយ អ្នកកុំគិតឡើយ ខ្ញុំរៀនមន្តហើយ នឹងបានជាធំក្នុងជម្ពូទ្វីប កាលបើដូច្នោះ អ្នកទាំងឡាយ ក៏នឹងមានសេចក្តីចម្រើនផងដែរ ទើបបួសក្នុងសម្នាក់ព្រះ សាស្តា ដើម្បីរៀនមន្ត ។

*ព្រះសាស្តាត្រាស់ថា អ្នកចូរនៅអប់រំដើម្បីរៀនមន្តចុះ ហើយត្រាស់ប្រាប់អាការ ៣២ ។ សត្វដែលមានបញ្ញា កាលស្វាធ្យាយអាការ ៣២ ក៏មនសិការការអស់ទៅ និងសូន្យទៅក្នុងអាការ ៣២ នោះ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត កាលលោកសម្រេចអរហត្តហើយ ពួកព្រាហ្មណ៍ទាំងឡាយ ក្នុងសម្នាក់របស់លោកគិតថា តើវង្គីសៈដូចម្តេចទៅហើយហ្ន៎ អញនឹងទៅសួរសុខទុក្ខ ហើយសួរថា លោកម្ចាស់វង្គីសៈ លោកម្ចាស់រៀនសិប្បៈក្នុងសម្នាក់ព្រះគោតមហើយឬ ។ ព្រះវង្គីសត្ថេរពោលថា អើអាត្មារៀនហើយ ព្រាហ្មណ៍ពោលថា បើដូច្នោះ មកចុះយើងនឹងទៅជាមួយគ្នា ។ ព្រះថេរៈពោលថា អ្នកចូរទៅចុះ កិច្ចដែលទៅជាមួយអ្នក ខ្ញុំធ្វើស្រេចហើយ ព្រាហ្មណ៍ទាំងឡាយពោលថា ពួកខ្ញុំប្រាប់លោកម្ចាស់ហើយថា ព្រះសមណគោតមធ្វើអ្នកដែលមករកខ្លួនឲ្យត្រឡប់ចិត្តដោយកលមាយា ឥឡូវនេះ ខ្លួនលោកម្ចាស់ នៅក្នុងអំណាចព្រះគោតមហើយ ពួកខ្ញុំនឹងធ្វើអ្វីក្នុងសម្នាក់លោកម្ចាស់ ហើយនាំគ្នាចៀសចេញទៅតាមផ្លូវដែលមកនោះឯង ចំណែកព្រះវង្គីសត្ថេរទៅគាល់ព្រះទសពលក្នុងកាលណា ធ្វើនូវសរសើរឯណាមួយក្នុងវេលានោះៗ ព្រោះហេតុនោះ ទើបព្រះសាស្តាប្រថាប់គង់ត្រង់កណ្តាលជំនុំសង្ឃ ទ្រង់ស្ថាបនាលោកទុកក្នុងតំណែងជាឯតទគ្គៈនៃពួកភិក្ខុដែលមានបដិភាណ ។*

**អដ្ឋកថាសូត្រទី ៤ ចប់**

# អដ្ឋកថា សូត្រទី ៥

# ប្រវត្តិ ព្រះឧបសេនវង្គន្តបុត្តត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៥ ដូចតទៅនេះ បទថា **សមន្តប្បាសាទិកានំ** បានដល់ អ្នកនាំសេចក្តីជ្រះថ្លាមកដល់ជនទាំងពួង ។ ពាក្យថា ឧបសេន ជាឈ្មោះរបស់ព្រះថេរៈនោះ ។ ព្រះថេរៈនោះជាកូនរបស់ព្រាហ្មណ៍ ឈ្មោះវង្គន្តព្រាហ្មណ៍ ដូច្នោះ ទើបហៅថា វង្គន្តបុត្រ ។ ព្រះថេរៈនេះ មិនមែនជាអ្នកនាំសេចក្តីជ្រះថ្លាមកដោយខ្លួនឯងតែម្យ៉ាងប៉ុណ្ណោះទេ សូម្បីបរិស័ទរបស់លោកក៏ជាអ្នកនាំសេចក្តីជ្រះថ្លាមកដែរ ដូច្នោះ ទើបលោកឈ្មោះថាជាកំពូលនៃពួកភិក្ខុ ដែលមានសេចក្តីជ្រះថ្លាមកដោយជុំវិញ ដោយអំណាចនៃឈ្មោះដែលបានព្រោះអាស្រ័យបរិស័ទ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ

ព្រះថេរៈនេះកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី ក្នុងបទុមុត្តរពុទ្ធុប្បាទ កាលចម្រើនវ័យហើយ ចូលគាល់ព្រះសាស្តា ស្តាប់ព្រះធម៌ដោយន័យមុននោះឯង ឃើញព្រះសាស្តាទ្រង់តាំងភិក្ខុមួយរូប ក្នុងតំណែងជាកំពូលនៃពួកភិក្ខុដែលនាំសេចក្តីជ្រះថ្លាមកជុំវិញ ធ្វើកុសលធម៌ក្រៃលែងឡើងៗ ចំពោះព្រះសាស្តា ប្រាថ្នាតំណែងនោះ ធ្វើកុសលដរាបដល់អស់ជីវិត វិលវល់ក្នុងទេវតា និងមនុស្សទាំងឡាយ ក្នុងពុទ្ធុប្បាទកាលនេះ បានបដិសន្ធិក្នុងគភ៌នៃនាងសារីព្រាហ្មណី ពួកញាតិដាក់ឈ្មោះឲ្យលោកថា ឧបសេនទារក ។ ឧបសេនទារកចម្រើនវ័យហើយ រៀនត្រៃវេទ ស្តាប់ព្រះធម៌ក្នុងសម្នាក់ព្រះសម្ពុទ្ធ បាននូវសទ្ធា បួសហើយ ។ លោកឧបសម្បទាបាន

១ វស្សា គិតថា អាត្មាអញនឹងពង្រីកអាណាចក្ររបស់ព្រះអរិយៈ ទើបឲ្យកុលបុត្រម្នាក់បព្វជ្ជាឧបសម្បទាក្នុងសម្នាក់របស់ខ្លួន លុះចេញវស្សាបវារណាហើយ ក្នុងវេលាដែលសទ្ធិវិហារិកមានវស្សា ១ វស្សា ខ្លួនឯង ២ វស្សា លោកគិតថា ព្រះទសពល ទ្រង់ឃើញអាត្មាអញហើយ នឹងត្រេកអរ ទើបនាំសទ្ធិវិហារិកមកគាល់ព្រះទសពល ។ ព្រះសាស្តាត្រាស់សួរលោកដែលថ្វាយបង្គំហើយ អង្គុយក្នុងទីមួយកន្លែងថា ម្នាលភិក្ខុ អ្នកមានវស្សាប៉ុន្មាន ។ ព្រះឧបសេនទូលស្នងថា បពិត្រព្រះអង្គដ៏ចម្រើន ២ វស្សា ។ ព្រះសាស្តាត្រាស់ថា ចុះភិក្ខុនេះមានវស្សាប៉ុន្មាន ព្រះថេរៈតបថា បពិត្រព្រះអង្គដ៏ចម្រើន ១ វស្សា ។ ព្រះសាស្តាត្រាស់ថា ភិក្ខុនេះជាអ្វីរបស់អ្នក ព្រះថេរៈឆ្លើយថា ជាសទ្ធិវិហារិករបស់ខ្ញុំព្រះអង្គ ។

គ្រានោះ ព្រះសាស្តាត្រាស់ថា ម្នាលមោឃបុរស ហេតុអ្វី អ្នកបំបួសកុលបុត្រឆាប់ម្ល៉េះ អ្នកវិលមកដើម្បីភាពជាអ្នកប្រាថ្នាច្រើន ហើយទ្រង់តិះដៀលដោយអនេកបរិយាយ ។ ព្រះថេរៈត្រូវតិះដៀលក្នុងសម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះមានព្រះភាគ លោកមានទឹកមុខផូរផង់ដូចដួងចន្ទ ក្នុងថ្ងៃ ១៥ កើត គិតថា អាត្មាអញនឹងឲ្យព្រះសាស្តាប្រទានសាធុការ ព្រោះអាស្រ័យបរិស័ទនេះឯង ដូច្នេះហើយ ទៅកាន់ទីមួយក្នុងថ្ងៃនោះឯង ចម្រើនវិបស្សនាកម្មដ្ឋានមិនយូរប៉ុន្មាន ក៏បានសម្រេចអរហត្ត ។

លំដាប់នោះ ព្រះថេរៈចេញបួសអំពីត្រកូលធំ ជាធម្មកថិក ឈ្លាសក្នុងការប្រៀនប្រដៅ ដូច្នោះ ទើបមានទារកក្នុងត្រកូលជាច្រើន ជ្រះថ្លាក្នុងធម្មកថា

របស់លោក ហើយចេញអំពីត្រកូលមិត្តអមាត្យ និងញាតិដ៏ច្រើន នាំគ្នាទៅបួសក្នុងសម្នាក់ព្រះថេរៈ លោកពោលថា អាត្មាជាអ្នកនៅព្រៃជាវត្ត បើពួកអ្នកអាចនៅព្រៃជាវត្ត ចូរបួសចុះ ដូច្នេះហើយ ប្រាប់ធុតង្គ ១៣ ឲ្យកុលបុត្រទាំងនោះដែលពោលថា ពួកខ្ញុំនឹងសិក្សា ដូច្នេះហើយ បំបួសកុលបុត្រទាំងនោះអធិដ្ឋានធុតង្គនោះៗ តាមកម្លាំងរបស់ខ្លួន ។ សូម្បីព្រះថេរៈក្នុងកាលដែលលោកមានវស្សា ១០ វស្សា សិក្សាវិន័យស្ទាត់ជំនាញហើយ ឲ្យសាមណេរទាំងអស់ឧបសម្បទា ភិក្ខុប្រមាណ ៥០០ រូប ដែលឧបសម្បទាហើយ បានជាបរិវាររបស់លោក ដោយប្រការដូច្នេះ ។

សម័យនោះ ព្រះសាស្តាប្រថាប់គង់នៅក្នុងជេតពនមហាវិហារ ត្រាស់ប្រាប់ភិក្ខុសង្ឃថា ម្នាលភិក្ខុទាំងឡាយ តថាគតប្រាថ្នានឹងពួនសម្ងំកន្លះខែ រួចនៅប្រថាប់មួយព្រះអង្គឯង ។ ភិក្ខុសង្ឃក៏បានធ្វើកតិកាគ្នាថា ភិក្ខុរូបណាចូលគាល់ព្រះមានព្រះភាគ ត្រូវភិក្ខុរូបនោះសម្តែងអាបត្តិបាចិត្តិយៈ ។ គ្រានោះព្រះឧបសេនគិតថា នឹងគាល់ព្រះមានព្រះភាគ ទើបទៅមួយអន្លើនឹងបរិស័ទរបស់ខ្លួន ដល់ព្រះវិហារជេតពនហើយ ចូលគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ក៏អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ដើម្បីផ្តើមការសន្ទនា ព្រះសាស្តាត្រាស់ហៅសទ្ធិវិហារិករបស់ព្រះថេរៈមួយរូបថា ម្នាលភិក្ខុ អ្នកគាប់ចិត្តក្នុងបង្សុកូលចីវរឬ ។ សទ្ធិវិហារិករូបនោះក្រាបទូលថា ខ្ញុំព្រះអង្គមិនគាប់ចិត្តក្នុងសំពត់បង្សុកូលចីវរឡើយ ហើយក្រាបទូលដល់ព្រះសាស្តាដល់រឿងដែលពួកខ្លួនគ្រងបង្សុកូលចីវរ ដោយសេចក្តីគោរពក្នុងព្រះឧបជ្ឈាយ៍ ។

ក្នុងឋានៈនេះ ព្រះសាស្តាបានប្រទានសាធុការដល់ព្រះថេរៈថា សាធុ សាធុ ឧបសេន រួចត្រាស់ពណ៌នាគុណដោយអនេកបរិយាយ សេចក្តីសង្ខេបក្នុងរឿងនេះដូច្នេះ តែសេចក្តីពិស្តារនៃរឿងនេះ មកហើយក្នុងព្រះបាលីនោះឯង ។

ក្នុងកាលបន្ទាប់មក ព្រះសាស្តាប្រថាប់គង់ក្នុងកណ្តាលពួកព្រះអរិយៈ ទ្រង់តាំងព្រះថេរៈទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ដែលនាំសេចក្តីជ្រះថ្លាមកដោយជុំវិញក្នុងសាសនានេះឯង ។l៙

## អដ្ឋកថាសូត្រទី ៩ ចប់

# អដ្ឋកថា សូត្រទី ៦

# ប្រវត្តិ ព្រះទព្វមល្លបុត្តត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៦ ដូចតទៅនេះ បទថា **សេនាសនប្បញ្ញាបកានំ** សេចក្តីថា ភិក្ខុដែលជាប្រធាន ក្នុងការរៀបចំសេនាសនៈ ។ បានឮថា ក្នុងកាលព្រះថេរៈរៀបចំសេនាសនៈ ក្នុងបណ្តាវិហារទាំង ១៨ កន្លែង មិនមានបរិវេណដែលមិនបានបោសសម្អាតឲ្យល្អរៀបរយ សេនាសនៈដែលមិនបានបដិបត្តិ គ្រែ តាំង ដែលមិនទាន់បានជម្រះឲ្យស្អាត ទឹកផឹក ទឹកប្រើប្រាស់ ដែលមិនទាន់បានតាំងទុក ព្រោះដូច្នោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុដែលជាអ្នករៀបចំសេនាសនៈ ។ ពាក្យថា **ទព្វ** ជាឈ្មោះរបស់លោក តែព្រោះលោកកើតក្នុងត្រកូលរបស់ស្តេចមល្លៈ ទើបឈ្មោះថា **មល្លបុត្រ** ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលទៅតាមលំដាប់ដូច្នេះ

សេចក្តីនេះ នឹងពោលដោយសង្ខេប ក្នុងបទុមុត្តរពុទ្ធុប្បាទកាល ព្រះថេរៈនេះ កើតក្នុងត្រកូលមួយ ក្នុងក្រុងហង្សវតី ចម្រើនវ័យហើយ ទៅកាន់វិហារស្តាប់ធម៌ ដោយន័យដូចពោលហើយនោះឯង ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ដែលមានតួនាទីរៀបចំសេនាសនៈ ធ្វើកុសលកម្មប្រាថ្នាតំណែងនោះ ។ ព្រះសាស្តាទ្រង់ព្យាករហើយ ធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្ស ក្នុងកាលព្រះសាសនានៃព្រះកស្សបទសពលអន្តរធានហើយ ទើបបួសហើយ ។ គ្រានោះ អ្នកដទៃ ៦ រូបទៀត ជាមួយភិក្ខុនោះ រួមជា ៧ រូប មានចិត្តដូចគ្នា ឃើញ

បុគ្គលដទៃៗ នោះ មិនធ្វើសេចក្ដីគោរពក្នុងព្រះសាស្ដា ប្រឹក្សាគ្នាថា ក្នុងកាលនេះ យើងនឹងធ្វើអ្វី យើងនឹងបំពេញសមណធម៌ក្នុងទីសមគួរចំណែកមួយ នឹងធ្វើទីបំផុតទុក្ខបាន ទើបចងជណ្ដើរឡើងកំពូលភ្នំខ្ពស់ ពោលថា បុគ្គលដែលដឹងកម្លាំងចិត្តរបស់ខ្លួន ចូរប្រានជណ្ដើរឲ្យធ្លាក់ទៅ បុគ្គលដែលនៅមានសេចក្ដីក្ដៅក្រហាយក្នុងកាលជាក្រោយ ចូរនៅចុះ ទើបស្រុះស្រួលគ្នាប្រានជណ្ដើរឲ្យធ្លាក់ទៅ ទូន្មានគ្នានិងគាថា អាវុសោ អ្នកចូរជាបុគ្គលមិនប្រមាទចុះ អង្គុយក្នុងទីគាប់ចិត្ត ផ្ដើមបំពេញសមណធម៌ បណ្ដាភិក្ខុទាំង ៧ រូបនោះ ព្រះថេរៈមួយរូប សម្រេចអរហត្តក្នុងថ្ងៃទី ៥ គិតថា កិច្ចនៃអាត្មាអញសម្រេចហើយ អញនឹងធ្វើអ្វីក្នុងទីនេះ ទើបទៅនាំបិណ្ឌបាតមកអំពីឧត្តរកុរុទ្វីបដោយឫទ្ធិ ពោលថា អាវុសោទាំងឡាយ ចូរឆាន់បិណ្ឌបាតនេះចុះ រឿងភិក្ខាចារជាភារៈរបស់ខ្ញុំ អ្នកទាំងឡាយ ចូរបំពេញសមណធម៌ចុះ ។ ភិក្ខុទាំងនោះពោលថា អាវុសោ ពួកយើងប្រានជណ្ដើរឲ្យធ្លាក់ទៅ បាននិយាយគ្នាយ៉ាងនេះឬថា អ្នកណាធ្វើឲ្យជាក់ច្បាស់នូវធម៌មុន អ្នកនោះចូរនាំភិក្ខាមក ភិក្ខុក្រៅអំពីនេះឆាន់ភិក្ខាដែលអ្នកនាំមកហើយ នឹងធ្វើសមណធម៌ឬ ភិក្ខុនោះពោលថា អាវុសោ មិនដូច្នោះទេ ។ ព្រះថេរៈពោលថា អ្នកទាំងឡាយបានហើយ ដោយហេតុដែលមានក្នុងកាលមុនរបស់ខ្លួន ។ ភិក្ខុពោលថា យើងទាំងឡាយអាចនៅ ក៏នឹងធ្វើទីបំផុតនៃវដ្ដៈបាន សូមលោកម្ចាស់និមន្តទៅចុះៗ ព្រះថេរៈកាលមិនអាចញ៉ាំងភិក្ខុទាំងនោះឲ្យយល់បាន ឆាន់បិណ្ឌបាតក្នុងទីដែលជាផាសុក ហើយក៏ទៅ ។ ក្នុងថ្ងៃទី ៧ ព្រះថេរៈមួយអង្គទៀត ចាក់ធ្លុះ

អនាគាមិផល ចុតិអំពីអត្តភាពនោះ ទៅកើតក្នុងព្រហ្មលោកក្នុងជាន់សុទ្ធាវាស ។

ឯព្រះថេរៈក្រៅអំពីនេះ ចុតិអំពីអត្តភាពនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ កើតក្នុងត្រកូលនោះៗ មួយអង្គកើតក្នុងព្រះរាជនិវេសន៍ក្នុងក្រុងតក្កសិលា ដែនគន្ធារៈ មួយអង្គកើតក្នុងផ្ទៃនាងបរិព្វាជិកា ក្នុងបច្ចន្តរដ្ឋ មួយអង្គកើតក្នុងផ្ទះកុដុម្ពិកៈ ក្នុងពាហិយរដ្ឋ មួយអង្គកើតក្នុងផ្ទះនៃកុដុម្ពិកៈ ក្រុងរាជគ្រឹះ ឯព្រះទព្វមល្លៈនេះ កើតក្នុងនិវេសន៍នៃស្តេចមល្លរដ្ឋមួយអង្គ ក្នុងអនុបិយនគរមល្លរដ្ឋ ក្នុងវេលាទៀបប្រសូត មាតារបស់លោកក៏ធ្វើកាលកិរិយា ញាតិទាំងឡាយនាំសរីរៈរបស់អ្នកស្លាប់ទៅកាន់ទីប៉ាឆា លើកឡើងកាន់ជើងថ្ករ ហើយឆួលភ្លើង ។ ភ្លើងកាលឆេះដល់ផ្ទៃរបស់នាងនោះ ក៏ញែកចេញជា ២ ចំណែក ទារកបង្រះឡើង ធ្លាក់ទៅត្រង់សសរមួយ ដោយកម្លាំងបុណ្យរបស់ខ្លួន មនុស្សទាំងឡាយពទារកនោះទៅឲ្យដល់ព្រះអយ្យិកាហើយ ព្រោះហេតុនោះ កាលដាក់ឈ្មោះទារកនោះ ក៏ដាក់ឈ្មោះរបស់លោកថា **ទព្វៈ** ព្រោះលោករមៀលទៅត្រង់សសរឈើទើបរួចជីវិត ។

កាលលោកមានអាយុគ្រប់ ៧ ឆ្នាំ ព្រះសាស្តាមានភិក្ខុសង្ឃជាបរិវារចារិកទៅក្នុងមល្លរដ្ឋ លុះដល់អនុបិយនិគម ប្រថាប់នៅក្នុងអនុបិយអម្ពវ័ន ។ ទព្វកុមារឃើញព្រះសាស្តា ជ្រះថ្លាក្នុងពុទ្ធសាសនានោះឯង ក៏ចង់បួស ទើបលាព្រះអយ្យិកាថា ចៅនឹងបួសក្នុងសម្នាក់ព្រះទសពល ជីដូនពោលថា ល្អណាស់ បា នាំទព្វកុមារទៅគាល់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏

ចម្រើន សូមទ្រង់ឲ្យកុមារនេះបួសចុះ ។ ព្រះសាស្តាទ្រង់ប្រទានសញ្ញាដល់ភិក្ខុមួយរូបថា ម្នាលភិក្ខុ អ្នកចូរឲ្យទារកនេះបួសចុះ ។ ព្រះថេរៈនោះទទួលព្រះពុទ្ធតម្រាស់ហើយ ក៏ឲ្យទព្វកុមារបព្វជ្ជា ប្រាប់តចបញ្ចកកម្មដ្ឋាន សត្វដែលសម្បូរដោយបុញ្ញហេតុ បានបំពេញបារមីមកហើយ ក្នុងខណៈដែលកោរសក់កាំបិតដំបូង តាំងនៅក្នុងសោតាបត្តិផល កាំបិតទី ២ តាំងនៅក្នុងសកទាគាមិផល កាំបិតទី ៣ តាំងនៅក្នុងអនាគាមិផល ៣ លុះកោរសក់ស្រេច ក៏ធ្វើឲ្យជាក់ច្បាស់អរហត្តផល មិនមុនមិនក្រោយ គឺព្រមគ្នា ។

ព្រះសាស្តា ប្រថាប់នៅក្នុងមល្លរដ្ឋតាមពុទ្ធអធ្យាស្រ័យហើយ យាងទៅកាន់ក្រុងរាជគ្រឹះ សម្រាកសម្រាន្តឥរិយាបថក្នុងវេឡុវនមហាវិហារ ពេលនោះ ព្រះទព្វមល្លបុត្រនៅក្នុងទីស្ងាត់ ពិចារណាមើលការសម្រេចកិច្ចរបស់ខ្លួន បំណងនឹងប្រកបកាយក្នុងការធ្វើសេចក្តីខ្វល់ខ្វាយដល់ព្រះសង្ឃ គិតថា បើដូច្នោះ អញគប្បីរៀបចំសេនាសនៈ និងចាត់ចែងអាហារថ្វាយសង្ឃ ទើបលោកចូលគាល់ព្រះសាស្តា ក្រាបទូលដល់បរិវិតក្ករបស់ខ្លួន ព្រះសាស្តាទ្រង់ប្រទានសាធុការដល់លោក ហើយទ្រង់ប្រទាននាទីខាងរៀបចំសេនាសនៈ និងចាត់ចែងភត្តដល់លោក ។ គ្រានោះ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ទព្វៈនេះនៅជាកុមារ តែតាំងនៅក្នុងតំណែងធំ ទើបទ្រង់ឲ្យលោកឧបសម្បទាហើយ ក្នុងកាលដែលលោកមានអាយុ ៧ ឆ្នាំប៉ុណ្ណោះ តាំងអំពីលោកឧបសម្បទាហើយ ព្រះថេរៈរៀបចំសេនាសនៈ និងចាត់ចែងភត្តប្រគេនភិក្ខុគ្រប់រូបដែលនៅក្នុងក្រុងរាជគ្រឹះ ភាពដែលលោកមាននាទីរៀបចំសេនាសនៈ បានប្រាកដ

ទៅក្នុងទិសទាំងពួងថា បានឮថា ព្រះទព្វមល្លបុត្ររមែងយល់ក្នុងការរៀបចំសេនាសនៈសម្រាប់ភិក្ខុត្រូវតាមអធ្យាស្រ័យ គឺរៀបចំសេនាសនៈក្នុងទីឆ្ងាយពួកភិក្ខុដែលមិនអាចទៅបាន លោកនាំទៅដោយឫទ្ធិ ។

កាលនោះ ភិក្ខុទាំងឡាយ ប្រាប់ឲ្យលោករៀបចំសេនាសនៈយ៉ាងនេះថា អាវុសោ ចូររៀបចំសេនាសនៈដល់ពួកខ្ញុំក្នុងជីវកម្ពវ័ន ចូររៀបចំសេនាសនៈឲ្យដល់ពួកខ្ញុំ ក្នុងមទ្ទកុច្ឆិមិគទាយវ័ន ហើយឃើញឫទ្ធិរបស់លោកក្នុងកាលខ្លះ ក្នុងវិកាលខ្លះ ព្រះទព្វៈនោះ ក៏បណ្ដាលកាយ មនោមយដោយឫទ្ធិនិម្មិតជាភិក្ខុឲ្យដូចគ្នានឹងខ្លួន សម្រាប់ព្រះថេរៈមួយរូបៗ កាន់ភ្លើងទៅខាងមុខប្រាប់ថា នេះគ្រែ នេះតាំងជាដើម រៀបចំសេនាសនៈហើយ ទើបត្រឡប់មកកាន់លំនៅរបស់ខ្លួន នេះជាសេចក្ដីសង្ខេបក្នុងរឿងនេះ ។ តែដោយពិស្ដាររឿងនេះ មកក្នុងព្រះបាលីហើយដូចគ្នា ។ ព្រះសាស្ដាទ្រង់ធ្វើហេតុនោះឯងឲ្យជាអត្ថុប្បត្តិហេតុ គឺហេតុកើតនៃរឿង កាលលោកគង់ក្នុងកណ្ដាលពួកព្រះអរិយៈ ព្រះមានព្រះភាគ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុ ខាងរៀបចំសេនាសនៈ ដូច្នេះ ។៚

## អដ្ឋកថាសូត្រទី ៦ ចប់

# អដ្ឋកថា សូត្រទី ៧
# ប្រវត្តិ ព្រះបិលិន្ទវច្ឆត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ដូចតទៅនេះ បទថា **ទេវានំ បិយ-មនាបានំ** ទ្រង់សំដែងថា ព្រះបិលិន្ទវច្ឆត្ថេរ ជាកំពូលនៃពួកភិក្ខុ ដែលជាទីស្រឡាញ់ និងជាទីគាប់ចិត្តរបស់ទេវតាទាំងឡាយ បានឮថា កាលព្រះពុទ្ធទ្រង់មិនទាន់កើតឡើង ព្រះថេរៈនោះជាស្តេចចក្រពត្តិ ទ្រង់ឲ្យមហាជនតាំងនៅក្នុងសីល ៥ ទ្រង់បានធ្វើកុសល ដែលសង្ឃឹមផលខាងមុខ គឺស្ថានសួគ៌ដោយច្រើន ពួកទេវតាដែលកើតក្នុងឆកាមាវចរសួគ៌ ៦ ជាន់ បាននូវឱវាទរបស់ព្រះរាជានោះ សម្លឹងមើលសម្បត្តិរបស់ខ្លួន ក្នុងទីដែលកើតហើយ នឹករឭកថា អញបានសគ្គសម្បត្តិនេះ ព្រោះអាស្រ័យអ្នកណាហ្ន៎ ក៏ដឹងថា ព្រោះអាស្រ័យព្រះថេរៈ ទើបនមស្ការព្រះថេរៈក្នុងវេលាព្រឹកផង វេលាល្ងាចផង ព្រោះដូច្នោះ ទើបលោកជាកំពូលនៃពួកភិក្ខុដែលជាទីស្រឡាញ់ ជាទីពេញចិត្តរបស់ទេវតាទាំងឡាយ ។ ពាក្យថា **បិលិន្ទ** ជាឈ្មោះរបស់លោក ពាក្យថា **វច្ឆ** ជាគោត្ររបស់លោក បញ្ចូលពាក្យទាំង ២ នោះចូលគ្នា ទើបហៅថា **បិលិន្ទវច្ឆ** ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ

បានឮថា កាលព្រះបទុមុត្តរសម្ពុទ្ធកើតឡើងក្នុងលោក ព្រះថេរៈនេះកើតក្នុងត្រកូលរបស់អ្នកមានភោគសម្បត្តិច្រើន ក្នុងក្រុងហង្សវតី ស្តាប់ធម្ម-ទេសនារបស់ព្រះសាស្តា ដោយន័យដែលមានក្នុងកាលមុននោះឯង ។ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាទីស្រឡាញ់ ជាទីពេញ

ចិត្តរបស់ទេវតាទាំងឡាយ ក៏ប្រាថ្នាតំណែងនោះ ធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ មកកើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី ញាតិទាំងឡាយឲ្យឈ្មោះលោកថា បិលិន្ទវច្ឆៈ ។ សម័យដទៃពីនោះមក លោកស្តាប់ធម្មទេសនារបស់ព្រះសាស្តា បានទូវសទ្ធា បព្វជ្ជាឧបសម្បទាហើយ ចម្រើនវិបស្សនា សម្រេចអរហត្តហើយ លោកកាលពោលជាមួយគ្រហស្ថក្តី ភិក្ខុក្តី ប្រើវោហារថា ថោកទាបគ្រប់ម៉ាត់ថា មកចុះអ្នកថោកទាប ទៅចុះអ្នកថោកទាប នាំទៅអ្នកថោកទាប កាន់យកចុះអ្នកថោកទាប ។ ភិក្ខុទាំងឡាយស្តាប់រឿងនោះហើយ ក៏នាំទៅទូលសួរព្រះតថាគតថា បពិត្រព្រះអង្គ ធម្មតាព្រះអរិយៈ រមែងមិនពោលពាក្យគ្រោតគ្រាត ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ធម្មតាព្រះអរិយៈទាំងឡាយមិនពោលផរុសវាចា សង្កត់សង្កិនអ្នកដទៃ តែផរុសវាចានោះ គប្បីមានដោយឧបនិស្ស័យក្នុងភពដទៃ ។ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះបិលិន្ទវច្ឆត្ថេរព្យាយាមហើយព្យាយាមទៀត គ្រាពោលនឹងគ្រហស្ថក្តី នឹងភិក្ខុទាំងឡាយក្តី ក៏ពោលថា អ្នកថោកទាប អ្នកថោកទាប បពិត្រព្រះមានព្រះភាគ ក្នុងរឿងនេះមានហេតុដូចម្តេច ។ ព្រះមុនីត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ការពោលដូច្នោះនៃបុត្ររបស់តថាគត ព្រោះប្រព្រឹត្តរហូត ទៅជាទម្លាប់ក្នុងបច្ចុប្បន្នប៉ុណ្ណោះក៏មិនមែន តែក្នុងអតីតកាល កូននៃតថាគតនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ជាអ្នកច្រើនដោយការពោលថា អ្នកថោកទាប ដល់ទៅ ៥០០ ជាតិ ដូច្នោះ ទើបកូន

របស់តថាគតនេះ ពោលព្រោះធ្លាប់ មិនបានពោលដោយចេតនាគ្រោតគ្រាតទេ ។ ពិតហើយ ក្នុងវោហាររបស់ព្រះអរិយៈទាំងឡាយ ទោះបីគ្រោតគ្រាតក៏ឈ្មោះថា បរិសុទ្ធពិត ព្រោះចេតនាមិនគ្រោតគ្រាត មិនជាបាប មានប្រមាណតិចតួច ព្រោះការពោលនេះ ដូច្នេះហើយ ទើបត្រាស់គាថាក្នុងធម្មបទថា

**អកក្កសំ វិញ្ញាបនឹ គិរំ សច្ចំ ឧទីរយេ**
**យាយ នាភិសជេ កញ្ចិ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណាពោលពាក្យមិនអាក្រក់ ពាក្យជាហេតុឲ្យដឹងសេចក្តីបាន ជាពាក្យពិត ជាពាក្យដែលមិនធ្វើអ្នកណា ឲ្យទាស់ចិត្ត តថាគតហៅបុគ្គលនោះថា ជាព្រាហ្មណ៍ ។

បន្ទាប់មក ថ្ងៃមួយ ព្រះថេរៈចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ជួបបុរសម្នាក់ កាន់ដីប៉ីមកពេញថាស កំពុងចូលទៅកាន់ក្រុង ទើបសួរថា អើអ្នកថោកទាប ក្នុងភាជនៈរបស់អ្នកមានអ្វី ។ បុរសនោះគិតថា សមណៈអង្គនេះ ពោលពាក្យគ្រោតគ្រាតនឹងអញទាំងព្រឹកតែម្តង អញក៏គួរពោលពាក្យដែលសមគួរដល់សមណៈរូបនេះដូចគ្នា ទើបឆ្លើយថា ក្នុងភាជនៈរបស់ខ្ញុំមានអាចម៍កណ្តុរ លោកម្ចាស់ ។ ព្រះថេរៈពោលថា អើ អ្នកថោកទាបប្រហែលជាយ៉ាងនោះឯង ។ កាលព្រះថេរៈបែរក្រោយទៅ ដីប៉ីក៏ក្លាយជាអាចម៍កណ្តុរទាំងអស់ បុរសនោះគិតថា ដីប៉ីទាំងនេះប្រាកដជាអាចម៍កណ្តុរពិតឬហ្ន៎ សាកល្បងយកដៃឈ្ងីមើល ក៏ដឹងថា ជាអាចម៍កណ្តុរពិតៗ ក៏កើត

ទោមនស្សក្រៃលែង ។ បុរសនោះគិតថា ចំពោះតែដីប៉ូទាំងនេះប៉ុណ្ណោះឬ ឬដីប៉ូក្នុងរទេះក៏យ៉ាងនេះដែរ ទើបដើរទៅពិនិត្យមើល ក៏ឃើញថា ដីប៉ូទាំងអស់មានសភាពយ៉ាងនេះដូចគ្នា យកដៃរឹតទ្រូង ហើយគិតថា ឱ ! នេះមិនមែនកម្មរបស់អ្នកដទៃឡើយ ជាការធ្វើរបស់ភិក្ខុដែលអញជួបពីព្រឹកនោះឯង ព្រះថេរៈពិតជាចេះមាយាកលឯណានីមួយពិត ដូច្នេះ អញនឹងតាមរកទីដែលភិក្ខុនោះដើរទៅ ទើបដឹងហេតុ ដូច្នេះហើយ ទើបដើរទៅតាមផ្លូវដែលព្រះថេរៈនិមន្តទៅ ។ គ្រានោះ បុរសម្នាក់ជួបបុរសនោះកំពុងដើរលោស់លោំង ទើបសួរថា នែសម្លាញ់ អ្នកដើរលឿនម្ល៉េះ អ្នកដើរទៅព្រោះធុរៈអ្វីឬ ។ ទើបបុរសនោះប្រាប់រឿងនោះដល់បុរសនោះ ។ បុរសនោះស្តាប់រឿងរ៉ាវរបស់បុរសនោះហើយ ក៏ពោលយ៉ាងនេះថា នែសម្លាញ់ អ្នកកុំគិតថ្វីឡើយ គឺពិតជាព្រះបិលិន្ទវច្ឆៈដែលជាលោកម្ចាស់របស់ខ្ញុំនេះឯង អ្នកចូរកាន់ដីប៉ូដែលពេញភាជនៈនោះ ទៅឈរខាងមុខព្រះថេរៈ កាលព្រះថេរៈពោលថា នុ៎ះជាអ្វីអ្នកថោកទាប ចូរពោលថា ដីប៉ូ លោកម្ចាស់ ព្រះថេរៈនឹងពោលថា អើប្រហែលជាយ៉ាងនោះឯង របស់នោះ នឹងក្លាយជាដីប៉ូទាំងអស់ ។ បុរសនោះបានធ្វើយ៉ាងនោះ ចំណោរមកខាងក្រោយ ព្រះសាស្តាទ្រង់ធ្វើរឿងដែលព្រះថេរៈជាទីស្រឡាញ់ពេញចិត្តនៃពួកទេវតាជាហេតុ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវក ដែលជាទីស្រឡាញ់ពេញចិត្តរបស់ទេវតា ដូច្នេះ ។៙

**អដ្ឋកថាសូត្រទី ៧ ចប់**

# អដ្ឋកថា សូត្រទី ៨

# ប្រវត្តិ ព្រះពាហិយទារុចីរិយត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ដូចតទៅនេះ បទថា **ខិប្បាភិញ្ញានំ** លោកសម្តែងថា ទារុចីរិយត្ថេរ ជាកំពូលនៃភិក្ខុសាវកដែលត្រាស់ដឹងរហ័ស ។ ពិតហើយ ព្រះថេរៈនេះ សម្រេចអរហត្ត កាលចប់ព្រះធម្មទេសនាដោយសង្ខេប មិនមានកិច្ចដែលនឹងត្រូវបរិកម្មមគ្គផលទាំងឡាយ ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃភិក្ខុសាវក អ្នកត្រាស់ដឹងរហ័ស ។ មនុស្សទាំងឡាយដាក់ឈ្មោះលោកថាពាហិយៈ ព្រោះលោកកើតក្នុងពាហិយរដ្ឋ ។ បន្ទាប់មក ក្នុងកាលជាក្រោយ លោកស្លៀកសំពត់ធ្វើដោយឈើ ព្រោះហេតុនោះ ទើបឈ្មោះថា ទារុចីរិយៈ ។ ក្នុងបញ្ហាកម្មរបស់លោកមានអនុសន្ធិដូចតទៅនេះ

ពិតហើយ ព្រះពាហិយទារុចីរិយៈនេះ ក្នុងពុទ្ធុប្បាទកាលព្រះបទុមុត្តរ-សម្ពុទ្ធ លោកកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្តាប់ធម៌របស់ព្រះទសពល ឃើញព្រះសាស្តា ទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវកដែលត្រាស់ដឹងឆាប់ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ធ្វើកុសលកម្មដរាបដល់អស់ជីវិត អន្ទោលក្នុងទេវតា និងមនុស្ស ។ ក្នុងកាលព្រះសាសនាព្រះកស្សបទសពលកំពុងរៀវចុះ ធ្វើសមណ-ធម៌ជាមួយភិក្ខុដែលពោលទុកខាងដើមហើយ ជាអ្នកមានសីលបរិបូណ៌ អស់ជីវិតហើយ ទៅកើតក្នុងទេវលោក ។

លោកនៅក្នុងទេវលោកអស់មួយពុទ្ធន្តរ ក្នុងពុទ្ធកាលនេះ ក៏កើតក្នុង

ផ្ទះត្រកូលមួយ ក្នុងពាហិយរដ្ឋ ចម្រើនវ័យក៏គ្រប់គ្រងផ្ទះ ត្រិះរិះថា នឹង ធ្វើការជួញដូរ ទើបឡើងសំពៅដែលឆ្ពោះទៅកាន់សុវណ្ណភូមិ មិនទាន់ដល់ ទីដែលប្រាថ្នា សំពៅក៏បែកធ្លាយត្រង់កណ្តាលសមុទ្រ ។ មហាជនក្លាយជា ចំណីរបស់អណ្តើក និងត្រី ឯពាហិយៈនេះ តោងលើឈើមួយកំណាត់អស់ ៧ ថ្ងៃ ទើបដល់កំពង់ឈ្មោះសុប្បារកៈ បានដឹងថា ជាទីកដីរបស់មនុស្ស គិតថា នឹងចូលទៅរកមនុស្សដោយមិនមានសំពត់ គឺអាក្រាតកាយ មិន សមគួរ ទើបយកសារាយ ដែលត្រាំទឹកមួយកន្លែង ក្នុងទីមិនឆ្ងាយមករុំខ្លួន កាន់យកកាជនៈមួយដែលធ្លាក់នៅក្បែរទីបូជាទេវតា ចូលទៅរកកិក្ខា មនុស្ស ទាំងឡាយឃើញហើយ នាំគ្នាគិតថា បើក្នុងលោកនេះនៅមានព្រះអរហន្តពិត គប្បីមានដោយវិធីយ៉ាងនេះ លោកម្ចាស់អង្គនេះ មិនទទួលសំពត់ ព្រោះកាន់ យកយ៉ាងឧក្រិដ្ឋឬហ្ន៎ ឬយកសំពត់ដែលគេឲ្យ ដូច្នេះ ទើបសាកល្បងឲ្យ សំពត់ទាំងឡាយអំពីទិសផ្សេងៗ គាត់គិតថា បើមិនមកដោយបែបនេះ មនុស្សទាំងនេះ ក៏មិនជ្រះថ្លាក្នុងអញ អញនឹងពោលពាក្យណាមួយបិទបាំង មនុស្សទាំងនេះ ធ្វើឧបាយចិញ្ចឹមជីវិតក៏សមគួរ ទើបមិនទទួលយកសំពត់ទាំង ឡាយ ពួកមនុស្សក៏ជ្រះថ្លាក្រៃលែងឡើងៗ ។ កាលបរិភោគអាហារ ក៏ត្រូវ ទៅកាន់ទេវស្ថានដែលមិនឆ្ងាយ មហាជនដ៏ដើរទៅជាមួយគាត់ ទំនុកបម្រុង ទេវស្ថានឲ្យទាន ពាហិយៈគិតថា មនុស្សទាំងនេះ ជ្រះថ្លាត្រឹមតែការស្លៀក សារាយរបស់អញ ធ្វើសក្ការៈយ៉ាងនេះ អញនឹងធ្វើឲ្យឧក្រិដ្ឋឡើងទៅ ក៏គួរ ដល់ជនទាំងនេះ ដូច្នេះហើយ ក៏កាន់យកបន្ទះក្តារដែលស្រាលៗ ស្មោះឲ្យ

ស្តើង ចងសម្បកឈើធ្វើជាសំពត់ស្លៀកដណ្តប់ ចិញ្ចឹមជីវិត ។

គ្រានោះ បណ្តាជន ៧ នាក់ ដែលធ្វើសមណធម៌ ក្នុងកាលព្រះពុទ្ធព្រះនាមកស្សបៈ ជនម្នាក់ជាភិក្ខុកើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស សម្តីងសិរីសម្បត្តិរបស់ខ្លួន រឭកដល់ទីកន្លែងជន ៧ នាក់ ក៏ឃើញទីកន្លែងជន ៧ នាក់ឡើងភ្នំធ្វើសមណធម៌ រឭកដល់ទីដែលជនទាំង ៦ ទៅកើត ក៏ដឹងថាម្នាក់បរិនិព្វាន ហើយ ៥ នាក់ទៅកើតក្នុងទេវលោក ជាន់កាមាវចរ ។ រឭកដល់ជន ៥ នាក់ ជាដំបូង កាលរឭកថា ក្នុងពេលនេះ ពួកគេនៅឯណាហ្ន៎ ក៏ឃើញទារុចីរិយៈ អាស្រ័យកំពង់ឈ្មោះសុប្បារកៈ ចិញ្ចឹមជីវិតដោយការបោកបញ្ឆោត ក៏គិតថា អន្តរធានហើយហ្ន៎ ទារុចីរិយៈល្ងង់នេះ ធ្វើសមណធម៌មកអំពីមុន មិនព្រមឆាន់បិណ្ឌបាត ដែលព្រះអរហន្តនាំមក ព្រោះជាអ្នកគោរពសទ្ធាដ៏ឧក្រិដ្ឋ តែឥឡូវនេះ មិនមែនជាព្រះអរហន្ត ក៏ប្តេជ្ញាថាជាព្រះអរហន្ត ដើរបោកបញ្ឆោតសត្វលោក ព្រោះតែផ្ទៃផង មិនដឹងថា ព្រះទសពលកើតឡើងហើយផង អញនឹងទៅធ្វើឲ្យសត្វនេះសង្វេគ ឲ្យដឹងថា ព្រះទសពលកើតហើយ ។ ក្នុងវេលានោះឯង ក៏បាត់អំពីព្រហ្មលោក ទៅប្រាកដខ្លួនចំពោះមុខទារុចីរិយៈ ក្នុងគ្រាកណ្តាលរាត្រី ត្រង់កំពង់សុប្បារកៈ ។ ទារុចីរិយៈឃើញឱភាសភ្លឺស្វាងក្នុងទីលំនៅរបស់ខ្លួន ទើបចេញមកខាងក្រៅ ឃើញមហាព្រហ្ម ក៏ផ្គងអញ្ជលីសួរថា លោកជាអ្នកណា ។ មហាព្រហ្មឆ្លើយថា ខ្ញុំជាសម្លាញ់ចាស់របស់អ្នក បានទូវអនាគាមិផល កើតក្នុងព្រហ្មលោក លោកម្ចាស់មួយអង្គដែលជាប្រធានរបស់ពួកយើង សម្រេចអរហត្ត

បរិនិព្វានហើយ ពួកអ្នក ៥ នាក់ កើតក្នុងទេវលោក ខ្ញុំឃើញអ្នកចិញ្ចឹមជីវិតដោយការបោកបញ្ឆោតអ្នកស្រុកក្នុងទីនេះ ទើបមកដើម្បីទូន្មាន ហើយទើបពោលហេតុនេះថា នែ ពាហិយៈ អ្នកមិនមែនជាព្រះអរហន្ត មិនបដិបត្តិដល់អរហត្តមគ្គ អ្នកមិនមានបដិបទាដែលនឹងបានជាអរហត្ត ឬបដិបត្តិដល់អរហត្តមគ្គទេ ។ លំដាប់នោះ មហាព្រហ្មក៏ប្រាប់ថា ព្រះសាស្តាកើតហើយប្រថាប់នៅក្នុងក្រុងសាវត្ថី អ្នកចូរទៅកាន់សម្នាក់របស់ព្រះសាស្តា ហើយបញ្ជូនទៅ ខ្លួនឯងក៏ត្រឡប់ទៅកាន់ព្រហ្មលោក ។

ទារុចីរិយៈ ត្រូវមហាព្រហ្មធ្វើឲ្យសង្វេគ ហើយក៏គិតស្វែងរកនូវផ្លូវរួចផុត ទើបធ្វើដំណើរ ១២០ យោជន៍ ដោយសម្រាកត្រឹមតែមួយយប់ប៉ុណ្ណោះ ។ លុះជួបព្រះសាស្តាកំពុងចូលទៅបិណ្ឌបាតត្រង់ចន្លោះស្រុក ក្រាបចុះទៀបព្រះយុគលបាទរបស់ព្រះសាស្តា ទូលអារាធនាអស់វារៈ ៣ ដងថា សូមព្រះមានព្រះភាគ ទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គចុះ សូមព្រះសុគត ទ្រង់សម្តែងធម៌ប្រោសខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាទ្រង់ជ្រាបថា ញាណរបស់ពាហិយៈចាស់ក្លាហើយ ដោយហេតុប៉ុណ្ណោះ ទើបទ្រង់ទូន្មានដោយឱវាទថា ម្នាលពាហិយៈ ព្រោះហេតុនេះ អ្នកគប្បីសិក្សាយ៉ាងនេះថា រូបដែលឃើញហើយត្រឹមតែរូបដែលឃើញហើយ ដូច្នេះជាដើម ។ ចប់ទេសនា ពាហិយៈនោះបញ្ជូនញាណទៅតាមក្រសែទេសនា ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ពាហិយៈនោះដល់នូវទីបំផុតកិច្ចរបស់ខ្លួនហើយ ទូលសូមបព្វជ្ជានឹងព្រះមានព្រះភាគ ស្វែងរកបាត្រ និងចីវរ ព្រោះមានបាត្រ និង

ចីវរមិនគ្រប់គ្រាន់ កំពុងទាញចម្រៀកសំពត់ទាំងឡាយអំពីគំនរសំរាម គ្រានោះ អមនុស្សដែលមានពៀរនឹងគ្នាមកអំពីមុន ចូលសណ្ឋិតក្នុងសរីរៈរបស់មេគោកូនខ្ចីមួយ ធ្វើលោកឲ្យដាច់ជីវិត ។ ព្រះសាស្តាយាងចេញអំពីក្រុងសាវត្ថី ទតឃើញពាហិយៈ ដួលចុះត្រង់គំនរសំរាមក្នុងចន្លោះផ្លូវ ត្រាស់ប្រាប់ពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរជួយលើកសរីរៈរបស់ពាហិយៈ ហើយនាំទៅធ្វើឈាបនកិច្ច សាងចេតិយក្នុងផ្លូវធំ ដែលមានមុំ ៤ បន្ទាប់អំពីនោះ ក៏កើតការសន្ទនាក្នុងកណ្តាលជំនុំសង្ឃថា ព្រះតថាគតត្រាស់ឲ្យភិក្ខុសង្ឃធ្វើឈាបនកិច្ចរបស់ពាហិយៈ រក្សាធាតុមក ហើយសាងចេតិយទុក ពាហិយៈនោះធ្វើឲ្យជាក់ច្បាស់នូវមគ្គអ្វីហ្ន៎ ភិក្ខុទាំងឡាយកើតចិត្តគិតដូច្នេះ ។ ព្រះសាស្តាទ្រង់ប្រារព្ធពាក្យនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពាហិយៈជាបណ្ឌិត ទ្រង់ពន្យល់ធម្មទេសនាហើយប្រកាសថា ពាហិយៈនោះបរិនិព្វានហើយ រឿងដែលពោលនោះកើតឡើងកណ្តាលសង្ឃទៀតថា ព្រះសាស្តាទ្រង់មិនបានសម្តែងធម៌ច្រើនឡើយ ត្រាស់ថា ពាហិយៈ សម្រេចអរហត្ត តើរឿងនេះដូចម្តេច ព្រះសាស្តាត្រាស់ថា ធម៌តិច ឬច្រើនមិនជាហេតុ ធម៌នោះក៏ដូចថ្នាំកែរោគ ដល់បុគ្គលដែលផឹកថ្នាំពិស ហើយត្រាស់គាថាក្នុងធម្មបទថា

**សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា**
**ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើគាថា សូម្បី ១ ពាន់ ជាគាថាប្រកបដោយបទឥត

ប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្តាប់
បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថា
នោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

ចប់ទេសនា សត្វ ៨៤០០០ ក៏នាំគ្នាផឹកអមតៈ ។ តែរឿងរបស់ព្រះពាហិយៈនេះ មិនចាំបាច់ពោលឲ្យពិស្តារ ព្រោះមកក្នុងព្រះសូត្រហើយ ។ តែបន្ទាប់មក ព្រះសាស្តាប្រថាប់គង់ក្នុងជំនុំសង្ឃ ទ្រង់ស្ថាបនាព្រះពាហិយៈក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវកដែលត្រាស់ដឹងរហ័សនោះឯង ។

## អដ្ឋកថាសូត្រទី ៨ ចប់

# អដ្ឋកថា សូត្រទី ៩

# ប្រវត្តិ ព្រះកុមារកស្សបត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៩ ដូចតទៅនេះ បទថា **ចិត្តកថិកានំ** បានដល់ អ្នកពោលធម៌បានវិចិត្រ ។ ពិតហើយ ព្រះថេរៈ កាលនឹងពោលធម៌ដល់មនុស្សម្នាក់ក្តី ពីរនាក់ក្តី ក៏ប្រដាប់ដោយឧបមា និងហេតុដ៏ច្រើនឲ្យបុគ្គលនោះដឹង ទើបពោល ព្រោះហេតុនោះ ទើបព្រះថេរៈជាកំពូលនៃភិក្ខុសាវ័ក អ្នកពោលធម៌ដ៏វិចិត្រ បញ្ហាកម្មរបស់លោកមានអនុសន្ធិដូចតទៅនេះ

ពិតហើយ ព្រះកុមារកស្សបៈនេះ កាលព្រះពុទ្ធព្រះនាមថា បទុមុត្តរៈ បដិសន្ធិក្នុងត្រកូលមួយ ក្នុងក្រុងហង្សវតី ចម្រើនវ័យ កំពុងស្តាប់ធម្មកថានៃព្រះទសពល ឃើញព្រះសាស្តា ទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈជាកំពូលនៃពួកភិក្ខុសាវ័កដែលពោលធម៌ដ៏វិចិត្រ ទើបធ្វើកុសលកម្មឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្ស កាលសាសនារបស់ព្រះកស្សបសម្មាសម្ពុទ្ធសាបសូន្យចុះ ជាភិក្ខុមួយរូបក្នុងរវាងភិក្ខុ ៧ រូប ធ្វើសមណធម៌លើកំពូលភ្នំ មានសីលមិនវិនាស ចុតិអំពីភពនោះហើយ កើតក្នុងទេវលោក សោយសម្បត្តិអស់មួយពុទ្ធន្តរ ។ ក្នុងពុទ្ធុប្បាទកាលព្រះសាស្តានៃយើង ក៏មកកើតក្នុងគភ៌របស់ស្រ្តីក្នុងត្រកូលមួយ ក្នុងក្រុងរាជគ្រឹះ ។ ស្រីនៃត្រកូលនោះ អង្វរឪពុកម្តាយ តែមិនបានបព្វជ្ជាកាលទៅកាន់ផ្ទះនៃត្រកូលប្តី ក៏មានគភ៌ តែខ្លួនមិនដឹង ទើបប្រាប់ប្តីសូមបព្វជ្ជា ស្វាមីអនុញ្ញាតហើយ ក៏បព្វជ្ជាក្នុងសម្នាក់ភិក្ខុនី ។ ពួកភិក្ខុនីឃើញគភ៌នាងធំឡើងៗ ទើបនាំគ្នាទៅសួរទេវទត្ត ភិក្ខុទេវទត្តនោះក៏ពោលថា នាង

មិនមែនជាសមណៈ ទើបពួកភិក្ខុនីនាំគ្នាទៅទូលសួរព្រះទសពល ។ ព្រះសាស្តាទ្រង់ប្រគល់រឿងឲ្យព្រះឧបាលិត្ថេរ ។ ព្រះថេរៈឲ្យហៅពួកត្រកូលអ្នកក្រុងសាវត្ថី និងនាងវិសាខាឧបាសិកាមក ជួយធ្វើកោសលវិច័យ ពោលថា នាងមានគភ៌មកអំពីមុនកាលបួស ទើបបព្វជ្ជារបស់នាងមិនខូចខាត ។ ព្រះសាស្តាបានប្រទានសាធុការដល់ព្រះថេរៈថា អធិករណ៍ ឧបាលីវិនិច្ឆ័យប្រពៃហើយ ។ ភិក្ខុនីនោះប្រសូតបុត្រដ៏ល្អប្រិមប្រិយ ដូចរូបមាស ព្រះបាទបសេនទិកោសល ទ្រង់ទទួលក្មេងនោះដល់ពួកកីលៀង ព្រះរាជទានព្រះនាមថា កស្សបៈ ។ បន្ទាប់មក ទ្រង់ចិញ្ចឹមចម្រើនវ័យហើយ ក៏នាំទៅកាន់សម្នាក់របស់ព្រះសាស្តា សូមឲ្យបព្វជ្ជា ។ តែព្រោះលោកបួសក្នុងភាពជាកុមារ កាលព្រះមានព្រះភាគត្រាស់ថា ពួកអ្នកចូរហៅកស្សបៈមក ចូរឲ្យផ្លែឈើ ឬរបស់ទំពានេះដល់កស្សបៈ ពួកភិក្ខុសង្ស័យ ក៏ទូលសួរថា បពិត្រព្រះអង្គ កស្សបៈអង្គណា ។ ព្រះមានព្រះភាគត្រាស់ថា កុមារកស្សបៈ ។ ព្រោះបាននាមយ៉ាងនេះ តាំងពីនោះមក លោកក៏ត្រូវហៅថា កុមារកស្សបៈ ក្នុងវេលាដែលលោកចាស់ហើយ ក៏នៅតែហៅថា កុមារកស្សបៈ ។ម្យ៉ាងទៀត មនុស្សទាំងឡាយស្គាល់លោកថា ជាកុមារកស្សបៈ ព្រោះជាបុត្រចិញ្ចឹមរបស់ព្រះរាជាក៏មាន ។ តាំងអំពីបួសហើយ លោកធ្វើការចម្រើនវិបស្សនា និងរៀនព្រះពុទ្ធវចនៈ ។

គ្រានោះ មហាព្រហ្មដែលធ្វើសមណធម៌លើកំពូលភ្នំជាមួយព្រះថេរៈនោះ សម្រេចអនាគាមិផល កើតក្នុងព្រហ្មលោកជាន់សុទ្ធាវាសនោះ ពួក

ក្នុងគ្រានោះ ឃើញព្រះកុមារកស្សបៈ គិតថា សម្លាញ់របស់អញ កំពុងលំបាកក្នុងការចម្រើនវិបស្សនា អញនឹងទៅបង្ហាញគន្លងនៃវិបស្សនាដល់លោក ធ្វើឧបាយឲ្យសម្រេចមគ្គផល ដូច្នេះហើយ តាំងនៅក្នុងព្រហ្មលោកនោះឯង ចងប្រស្នា ១៥ ចំណុច ហើយទៅប្រាកដក្នុងលំនៅនៃកុមារកស្សបត្ថេរ ។ បន្ទាប់អំពីកណ្ដាលយប់ ព្រះថេរៈឃើញពន្លឺ ទើបសួរថា អ្នកណានៅទីនោះ ។ មហាព្រហ្មឆ្លើយថា ខ្ញុំ គឺព្រហ្ម អ្នកធ្វើសមណធម៌ជាមួយលោកម្ចាស់មកអំពីមុន សម្រេចអនាគាមិផលហើយ កើតក្នុងព្រហ្មលោកជាន់សុទ្ធាវាស ។ ព្រះថេរៈសួរថា ចុះអ្នកមកដោយកិច្ចការអ្វី ។ មហាព្រហ្មប្រាប់ប្រស្នាទាំងនោះ ដើម្បីបង្ហាញហេតុដែលខ្លួនមក ហើយពោលថា សូមលោកម្ចាស់រៀនប្រស្នាទាំងនេះ កាលអរុណរះ ចូលទៅគាល់ព្រះតថាគត ថ្វាយបង្គំហើយ ទូលសួរចុះ ព្រោះថា វៀរព្រះតថាគតចេញ អ្នកដទៃដែលអាចស្រាយប្រស្នាទាំងនេះបាន មិនមាន ហើយក៏ត្រឡប់ទៅព្រហ្មលោកវិញ ។ លុះស្អែកឡើង ព្រះថេរៈក៏ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ ក៏ទូលសួរបញ្ហាដោយទំនងដែលមហាព្រហ្មពោល ។ ព្រះសាស្ដាទ្រង់ឆ្លើយប្រស្នាឲ្យកុមារកស្សបត្ថេរសម្រេចអរហត្ត ។ ព្រះថេរៈកាន់យកដោយទំនងដែលព្រះសាស្ដាត្រាស់ ទៅកាន់ព្រៃអន្ធវ័ន ចម្រើនវិបស្សនា ក៏សម្រេចអរហត្ត ។ តអំពីនោះមក កាលលោកពោលធម្មកថាដល់បរិស័ទ ៤ ទោះច្រើនក្ដី តិចក្ដី ប្រដាប់ដោយឧបមា និងហេតុទាំងឡាយ ទើបពោលដ៏វិចិត្រនោះឯង គ្រានោះ កាលលោកសម្ដែងសូត្រប្រដាប់ដោយបញ្ហា ១៥

ចំណុចដល់ស្តេចបាយាសិ ព្រះសាស្តាទ្រង់ធ្វើសូត្រនោះឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាលោកទុកក្នុងតំណែងឯតទគ្គៈជាងពួកភិក្ខុសាវក អ្នកពោលធម៌ដ៏វិចិត្រ ក្នុងព្រះសាសនា ។៚

## អដ្ឋកថា សូត្រទី ៩ ចប់

## អដ្ឋកថា សូត្រទី ១០
## ប្រវត្តិ ព្រះមហាកោដ្ឋិកត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១០ ដូចតទៅនេះ ពាក្យថា **បដិសម្ភិទប្បត្តានំ** ទ្រង់សម្តែងថា ព្រះមហាកោដ្ឋិកត្ថេរ ជាកំពូលនៃពួកភិក្ខុសាវក ដែលសម្រេចបដិសម្ភិទា ៤ ។ ពិតហើយ ព្រះថេរៈនេះ កាលចូលទៅរកព្រះមហាសាវកដែលមានឈ្មោះល្បី សួរបញ្ហាក្តី ចូលទៅគាល់ព្រះទសពល ទូលសួរបញ្ហាក្តី រមែងសួរបញ្ហាក្នុងរឿងបដិសម្ភិទាទាំងឡាយប៉ុណ្ណោះ ព្រោះលោកជាអ្នកជំនាញក្នុងបដិសម្ភិទាទាំងឡាយ ដូច្នោះ ទើបលោកពោលថា ជាកំពូលនៃពួកភិក្ខុសាវក ដែលបាននូវបដិសម្ភិទា ដោយអំណាចភាពជាអ្នកជំនាញនេះ ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ

សេចក្តីពិត ព្រះថេរៈនេះ កើតក្នុងត្រកូលមានភោគសម្បត្តិច្រើន ក្នុង

ក្រុងហង្សវតី កាលព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ ។ សម័យតមក កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុជាសាវកខាងបដិសម្ភិទា ទើបធ្វើកុសលកម្មទុកឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ ធ្វើកុសលរហូតដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស កើតក្នុងត្រកូលព្រាហ្មណ៍ នាក្រុងសាវត្ថី ក្នុងពុទ្ធុប្បាទកាលនេះ ។ ពួកញាតិបានដាក់ឈ្មោះថា កោដ្ឋិតមាណព ។ មាណពចម្រើនវ័យហើយ រៀនទូវវេទទាំង ៣ ថ្ងៃមួយ ស្តាប់ធម្មកថារបស់ព្រះសាស្តា បានទូវសទ្ធាហើយ ក៏បួស ។ តាំងអំពីបួសហើយលោកធ្វើកម្មក្នុងវិបស្សនា សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទាទាំងឡាយ ជាអ្នកជំនាញក្នុងបដិសម្ភិទាទាំងឡាយប៉ុណ្ណោះ អស់កាលជានិច្ចកាលសាកសួរបញ្ហា ក៏សួរក្នុងបដិសម្ភិទាទាំងឡាយប៉ុណ្ណោះ ។ ក្រោយមកព្រះសាស្តាទ្រង់ធ្វើមហាវេទល្លសូត្រឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវក អ្នកសម្រេចបដិសម្ភិទា ដូច្នេះ ៕

## អដ្ឋកថា សូត្រទី ១០ ចប់

## វគ្គទី ៣ ចប់

# ឯតទគ្គបាលិ

## វគ្គទី ៤

[ ១៤៩ ] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុអ្នកចេះដឹងច្រើន ដែលជាសាវករបស់តថាគត ស្រេចនឹងអានន្ទប្រសើរជាងគេ ។ ពួកភិក្ខុអ្នកមានស្មារតី ស្រេចនឹងអានន្ទ ។ ពួកភិក្ខុអ្នកមានគតិ ស្រេចនឹងអានន្ទ ។ ពួកភិក្ខុអ្នកមានប្រាជ្ញា ស្រេចនឹងអានន្ទ ។ ពួកភិក្ខុជាឧបដ្ឋាក ក៏ស្រេចនឹងអានន្ទដែរ ។ ពួកភិក្ខុអ្នកមានបរិសទ្យច្រើន ស្រេចនឹងឧរុវេលកស្សបៈ ។ ពួកភិក្ខុអ្នកញុំាងត្រកូលឲ្យជ្រះថ្លា ស្រេចនឹងកាឡុទាយិ ។ ពួកភិក្ខុអ្នកគ្មានអាពាធ ស្រេចនឹងពក្កុលៈ ។ ពួកភិក្ខុអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងសោភិតៈ ។ ពួកភិក្ខុអ្នកទ្រទ្រង់វិន័យ ស្រេចនឹងឧបាលី ។ ពួកភិក្ខុអ្នកឲ្យឱវាទភិក្ខុនី ស្រេចនឹងនន្ទកៈ ។ ពួកភិក្ខុអ្នករក្សាទ្វារក្នុងឥន្ទ្រិយទាំងឡាយ ស្រេចនឹងនន្ទៈ ។ ពួកភិក្ខុអ្នកឲ្យឱវាទភិក្ខុ ស្រេចនឹងមហាកប្បិន ។ ពួកភិក្ខុអ្នកឈ្លាសវៃក្នុងតេជោធាតុ ស្រេចនឹងសាគតៈ ។ ពួកភិក្ខុអ្នកឈ្លាសវៃក្នុងបដិភាណ ស្រេចនឹងរាធៈ ។ ពួកភិក្ខុអ្នកទ្រទ្រង់ចីវរសៅហ្មង ស្រេចនឹងមោឃរាជ ។

វគ្គទី ៤ ចប់

# វគ្គទី ៤

## អដ្ឋកថា សូត្រទី ១

## ប្រវត្តិ ព្រះអានន្ទត្ថេរ

[ ១៤៩ ] គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១ នៃវគ្គទី ៤ ដូចតទៅនេះ គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ពហុស្សុតានំ** ជាដើមដូច្នេះ ។ ព្រះថេរៈដទៃៗ ជាពហូសូត មានធិតិ ទ្រទ្រង់ចាំ និងឧបដ្ឋាកក៏មាន ។ ឯព្រះអានន្ទនេះ រៀនព្រះពុទ្ធវចនៈក៏ទ្រទ្រង់ក្នុងបរិយត្តិ ដូចអ្នករក្សាឃ្លាំង ក្នុងសាសនានៃព្រះទសពល ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុសាវ័កដែលជាពហូសូត ។ ម្យ៉ាងទៀត សតិដែលរៀនសូត្រព្រះពុទ្ធវចនៈ ហើយចាំរបស់ព្រះថេរៈនេះប៉ុណ្ណោះ មានកម្លាំងជាងព្រះថេរៈដទៃៗ ព្រោះហេតុនោះ ទើបលោកជាកំពូលនៃពួកភិក្ខុសាវ័ក ដែលមានសតិចងចាំ ។ ម្យ៉ាងទៀត ព្រះអានន្ទនេះឯង ទ្រទ្រង់ ១ បទ ក៏កាន់យកសេចក្តីបានដល់ទៅ ៦ ម៉ឺនបទ ចាំបានគ្រប់បទ ដោយទំនងដែលព្រះសាស្តាត្រាស់ទុកនោះឯង ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុសាវ័កដែលមានគតិ ។ ម្យ៉ាងទៀត ការព្យាយាម រៀនសូត្រ ការព្យាយាមទន្ទេញ ការព្យាយាមក្នុងការចងចាំ និងការព្យាយាមបម្រើព្រះសាស្តារបស់ព្រះអានន្ទនេះប៉ុណ្ណោះ ដែលភិក្ខុដទៃៗ ប្រៀបមិនបាន ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុសាវ័កដែលមានធិតិ ។ ម្យ៉ាងទៀត ព្រះអានន្ទនេះ កាលឧបដ្ឋាកព្រះទសពល ក៏មិនឧបដ្ឋាកដោយការឧបដ្ឋាកដូចពួកភិក្ខុដែលឧបដ្ឋាក

ដទៃៗ ព្រោះថា ភិក្ខុដទៃៗ កាលឧបដ្ឋាកព្រះតថាគត ក៏មិនបានយូរ ឧបដ្ឋាកដោយទាញព្រះហឫទ័យរបស់ព្រះសម្ពុទ្ធមិនបាន ។ ឯព្រះថេរៈរាប់តាំងអំពីថ្ងៃដែលបានតំណែងជាឧបដ្ឋាក ក៏ជាអ្នកប្រារព្ធសេចក្តីព្យាយាមឧបដ្ឋាកទាញព្រះហឫទ័យរបស់ព្រះមុនីបាន ព្រោះហេតុនេះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុសាវ័កខាងឧបដ្ឋាក ។ ក្នុងបញ្ហាកម្មរបស់លោក មានអនុសន្ធិដូចតទៅនេះ

បានឮថា ក្នុងកប្បចុងក្រោយ មួយសែនកប្បអំពីកប្បនេះទៅ ព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ កើតឡើងក្នុងលោក ទ្រង់មាននគរឈ្មោះហង្សវតី មានព្រះរាជបិតាព្រះនាមនន្ទៈ ព្រះរាជមាតាជាព្រះទេវីព្រះនាមសុមេធា មានព្រះពោធិសត្វព្រះនាមឧត្តរកុមារ ។ ព្រះអង្គចេញអភិនេស្រ្កមណ៍ ទ្រង់ព្រះផ្នួសក្នុងថ្ងៃព្រះរាជឱរសប្រសូត ទ្រង់ប្រកបព្យាយាមរឿយៗ ហើយទ្រង់សម្រេចសព្វញ្ញុតញ្ញាណតាមលំដាប់ ទ្រង់បន្លឺព្រះពុទ្ធឧទានថា **អនេកជាតិសំសារំ** ជាដើម ប្រថាប់នៅលើពោធិបល្ល័ង្កអស់ ៧ ថ្ងៃ ទ្រង់ដាក់ព្រះបាទលើផែនដីដោយបំណង យាងទៅ គ្រានោះ ផ្កាឈូកមានទំហំដូចបានពោលហើយខាងដើម ទម្លុះផែនដីទទួល ព្រោះសំដៅដល់ផ្កាឈូកនោះ ទើបព្រះមានព្រះភាគ ប្រាកដនាមថា បទុមុត្តរៈនោះឯង ។ ទ្រង់មានអគ្គសាវ័កព្រះនាមទេវិលមួយអង្គ សុជាតមួយអង្គ មានពួកអគ្គសាវិកាឈ្មោះថា អមិតាមួយអង្គ អសមាមួយអង្គ ទ្រង់មានឧបដ្ឋាកឈ្មោះថា សុមនៈ ។ ព្រះបទុមុត្តរៈដ៏មានព្រះភាគ កាលទ្រង់សង្គ្រោះពុទ្ធបិតា មានភិក្ខុមួយសែនរូបជាបរិវារ

ប្រជាប់ក្នុងក្រុងហង្សវតីរាជធានី ។ ឯកនិដ្ឋភាតារបស់ព្រះអង្គ ព្រះនាមថា សុមនកុមារ ព្រះរាជាប្រទានស្រុកសួយ ២០០០ យោជន៍ អំពីក្រុងហង្សវតី ដល់សុមនរាជកុមារនោះ ។ សុមនរាជកុមារនោះ មកគាល់ព្រះរាជបិតា និង ព្រះសាស្ដាម្ដងម្កាល ។

ថ្ងៃមួយ ជនបទជាយដែនមានការបះបោរ ទើបសុមនរាជកុមារបញ្ជូន ដំណឹងថ្វាយព្រះរាជាៗ ទ្រង់បញ្ជូនតបទៅថា បិតាតែងតាំងបុត្រក្នុងតំណែង នោះ ព្រោះហេតុអ្វី ។ សុមនរាជកុមារនោះបង្ក្រាបការបះបោររាបទាបហើយ បញ្ជូនដំណឹងក្រាបទូលព្រះរាជាថា បពិត្រទេវៈ ជនបទរាបទាបហើយ ។ ព្រះរាជាទ្រង់ត្រេកអរ ទ្រង់ត្រាស់ថា ចូរបុត្រប្រញាប់មក សុមនរាជកុមារ នោះមានអមាត្យ ១០០០ នាក់ ទ្រង់ប្រឹក្សានឹងអមាត្យទាំងនោះក្នុងចន្លោះផ្លូវ ថា ព្រះរាជបិតារបស់ខ្ញុំទ្រង់ត្រេកអរ បើទ្រង់ប្រទានពរដល់ខ្ញុំ យើងគួរទទួល ពរអ្វី ។ គ្រានោះ អមាត្យពួកខ្លះទូលព្រះរាជាថា សូមទ្រង់ទទួលដំរី ទទួល សេះ ទទួលជនបទ ទទួលរតនៈ ៧ ប្រការ មួយពួកទៀតទូលថា ព្រះអង្គ ជារាជឱរសរបស់ស្ដេចផែនដី ទ្រព្យព្រះអង្គបានដោយមិនលំបាកឡើយ តែ ទ្រព្យនោះ ទោះបីបាន ក៏ត្រូវលះបង់ចោលទាំងអស់ បុណ្យឯណោះទេតើ ដែលព្រះអង្គនាំទៅបាន ព្រោះដូច្នោះ បើសម្មតិទេពព្រះរាជទានពរ សូមព្រះ អង្គទទួលពរ មានការឧបដ្ឋាកព្រះមានព្រះភាគព្រះបទុមុត្តរៈ អស់ត្រៃមាស ចុះ ។ ព្រះរាជកុមារនោះទទួលថា ពួកអ្នកជាកល្យាណមិត្តរបស់ខ្ញុំ ពួកអ្នក ធ្វើចិត្តគិតយ៉ាងនេះឲ្យកើតដល់ខ្ញុំ ខ្ញុំនឹងធ្វើយ៉ាងនេះ ហើយយាងទៅថ្វាយបង្គំ

ព្រះរាជបិតា ត្រូវព្រះរាជបិតាឱបថើបត្រង់សីសៈ ហើយត្រាស់ថា នែបុត្រ បិតាឲ្យពរដល់បា ដូច្នេះ ទើបក្រាបទូលថា បពិត្រព្រះរាជា ទូលបង្គំប្រាថ្នាឧបដ្ឋាកព្រះមានព្រះភាគដោយបច្ច័យ ៤ អស់ត្រៃមាស ដើម្បីធ្វើជីវិតកុំឲ្យឥតប្រយោជន៍ ។ ព្រះពុទ្ធបិតាត្រាស់ថា បិតាមិនអាចឲ្យពរនេះដល់បុត្របានទេ បិតានឹងឲ្យពរដទៃដល់បុត្រ ។ ព្រះរាជកុមារក្រាបទូលថា បពិត្រទេវៈ ធម្មតាក្សត្រ មិនត្រាស់ពាក្យ ២ ឡើយ សូមទ្រង់ព្រះរាជទានពរនេះដល់ទូលបង្គំចុះ ពរដទៃ ទូលបង្គំមិនត្រូវការឡើយ ។ ព្រះពុទ្ធបិតាត្រាស់ថា ធម្មតាព្រះហឫទ័យព្រះពុទ្ធទាំងឡាយ ដឹងបានលំបាក បើព្រះមានព្រះភាគទ្រង់មិនបំណង បើបិតាឲ្យពរដល់បុត្រហើយ នឹងមានប្រយោជន៍អ្វី ។ ព្រះរាជកុមារក្រាបទូលថា សាធុទេវៈ ទូលបង្គំនឹងជ្រាបព្រះហឫទ័យរបស់ព្រះមានព្រះភាគ ដូច្នេះហើយ យាងទៅកាន់វិហារ ។

សម័យនោះ ព្រះមានព្រះភាគ សោយស្រេចហើយ ទ្រង់យាងចូលព្រះគន្ធកុដិ ទើបព្រះកុមារយាងទៅកាន់សម្នាក់ភិក្ខុទាំងឡាយ ដែលប្រជុំគ្នាក្នុងសាលាមូល ។ ភិក្ខុទាំងនោះទូលសួរព្រះរាជកុមារថា ថ្វាយព្រះពរព្រះរាជបុត្រ ទ្រង់យាងមកព្រោះហេតុអ្វី ។ ព្រះរាជកុមារត្រាស់ថា ដើម្បីគាល់ព្រះមានព្រះភាគ សូមលោកម្ចាស់ទូលព្រះមានព្រះភាគដល់ខ្ញុំចុះ ។ ពួកភិក្ខុទូលថា ព្រះរាជបុត្រ ពួកអាត្មាភាពចូលគាល់ព្រះសាស្តាក្នុងវេលាតាមត្រូវការមិនបានទេ ។ ព្រះរាជបុត្រសួរថា តើអ្នកណា ទើបគាល់ព្រះមានព្រះភាគបាន ពួកភិក្ខុឆ្លើយថា ថ្វាយព្រះពរព្រះរាជបុត្រ គឺព្រះថេរៈព្រះនាម

សុមនត្ថេរ ព្រះរាជកុមារត្រាស់សួរដល់អាសនៈរបស់ព្រះថេរៈថា ព្រះថេរៈនោះនៅទីណាលោកម្ចាស់ ហើយព្រះរាជាយាងទៅ ត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំបំណាងគាល់ព្រះមានព្រះភាគ សូមលោកម្ចាស់បង្ហាញព្រះមានព្រះភាគដល់ខ្ញុំចុះ ។ កាលព្រះរាជកុមារកំពុងទតនោះឯង ព្រះថេរៈចូលអាបោកសិណជ្ឈាន អធិដ្ឋានមហាប្រឹថពីឲ្យទៅជាទឹក ជ្រែកផែនដីទៅប្រាកដត្រង់ព្រះគន្ធកុដិរបស់ព្រះសាស្តា ។ គ្រានោះ ព្រះមានព្រះភាគត្រាស់នឹងព្រះសុមនត្ថេរថា ម្នាលសុមនៈ ព្រោះហេតុអ្វី ទើបអ្នកមក ។ ព្រះថេរៈទូលថា ព្រះរាជបុត្រយាងមកបំណាងនឹងគាល់ព្រះមានព្រះភាគ ។ ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុ បើដូច្នោះ អ្នកចូររៀបចំអាសនៈចុះ ។ កាលព្រះរាជកុមារកំពុងទតនោះឯង ព្រះថេរៈក៏កាន់យកពុទ្ធអាសនៈ មុជចុះក្នុងព្រះគន្ធកុដិ ទៅប្រាកដត្រង់ក្រៅបរិវេណ រៀបចំអាសនៈត្រង់បរិវេណ ។ ព្រះរាជកុមារទ្រង់ឃើញហេតុគួរអស្ចារ្យទាំង ២ នេះហើយ ទ្រង់ត្រិះរិះថា ភិក្ខុនេះធំហ្ន៎ សូម្បីព្រះមានព្រះភាគ ក៏ទ្រង់ចេញអំពីព្រះគន្ធកុដិ ហើយប្រថាប់គង់លើអាសនៈដែលគេរៀបចំ កាលត្រាស់សួរថា ម្នាលរាជបុត្រ ទ្រង់មកក្នុងកាលណា ព្រះរាជកុមារទូលថា បពិត្រព្រះអង្គដ៏ចម្រើន កាលព្រះអង្គយាងចូលព្រះគន្ធកុដិ តែភិក្ខុទាំងឡាយប្រាប់ថា លោកចូលគាល់មិនបានតាមខណៈដែលប្រាថ្នា ទើបបញ្ជូនខ្ញុំព្រះអង្គទៅកាន់សម្នាក់របស់ព្រះថេរៈ ចំណែកព្រះថេរៈពោលតែមួយម៉ាត់ ព្រះថេរៈនេះស្និទ្ធស្នាលក្នុងព្រះសាសនារបស់ព្រះអង្គឬ ។ ព្រះសាស្តាត្រាស់ថា មែនហើយ ព្រះរាជកុមារ ភិក្ខុនេះជាទីស្និទ្ធស្នាលក្នុង

សាសនារបស់តថាគត ។ ព្រះរាជកុមារទូលថា ភិក្ខុនេះធ្វើដូចម្តេច ទើបជាទីប្រោសប្រាណក្នុងព្រះសាសនារបស់ព្រះពុទ្ធទាំងឡាយ ។ ព្រះមានព្រះភាគត្រាស់ថា ថ្វាយទាន រក្សាសីល ធ្វើឧបោសថកម្ម ។ ព្រះរាជកុមារក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គបំណងធ្វើជាអ្នកស្និទ្ធស្នាល ក្នុងព្រះពុទ្ធសាសនាដូចព្រះថេរៈដែរ ស្អែកនេះ សូមទ្រង់ទទួលភិក្ខារបស់ខ្ញុំព្រះអង្គចុះ ។ ព្រះមានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ព្រះរាជកុមារទ្រង់ទៅកាន់ទីប្រថាប់របស់ទ្រង់ រៀបចំមហាសក្ការៈមួយយប់ទល់ភ្លឺ បានថ្វាយខន្ធវារកត្ត គឺអាហារដែលថ្វាយក្នុងរោងបោះព្រះពន្លាសម្រាក ។ ក្នុងថ្ងៃទី ៧ ថ្វាយបង្គំព្រះសាស្តាទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានទទួលពរ គឺការឧបដ្ឋាកព្រះអង្គអស់ត្រៃមាស ខាងក្នុងវស្សាអំពីសម្នាក់ព្រះរាជបិតា សូមទ្រង់ទទួលចាំវស្សាអស់ត្រៃមាស ដើម្បីខ្ញុំព្រះអង្គផងចុះ ។ ព្រះមានព្រះភាគទ្រង់ប្រមើលមើលថា ប្រយោជន៍ដោយសេចក្តីនោះ មានឬទេហ្ន៎ ទ្រង់ឃើញថា មាន ទើបត្រាស់ថា ម្នាលរាជកុមារ ព្រះតថាគតទាំងឡាយរមែងត្រេកអរក្នុងផ្ទះស្ងាត់ ។ ព្រះរាជកុមារត្រាស់ថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គដឹងហើយ បពិត្រព្រះសុគត ខ្ញុំព្រះអង្គដឹងហើយ ហើយក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនឹងទៅមុន ដើម្បីឲ្យគេសាងវិហារ កាលខ្ញុំព្រះអង្គបញ្ជូនមនុស្សមកទូល សូមទ្រង់យាង មួយអន្លើដោយភិក្ខុមួយសែនរូប ។ ទ្រង់កាន់យកបដិញ្ញាហើយ ទៅកាន់សម្នាក់ព្រះរាជបិតា ក្រាបទូលថា បពិត្រទេវៈ ព្រះមានព្រះភាគប្រទានបដិញ្ញាដល់ទូលបង្គំហើយ បើទូលបង្គំ

បញ្ជូនមនុស្សមកក្រាបទូល សូមទ្រង់បញ្ជូនព្រះមានព្រះភាគផង ។ ព្រះកុមារថ្វាយបង្គំព្រះរាជបិតាហើយ យាងចេញទៅ ទ្រង់សាងវិហារគ្រប់ចម្ងាយមួយយោជន៍ យាងទៅអស់ចម្ងាយផ្លូវ ២០០០ យោជន៍ កាលយាងដល់ហើយ ទ្រង់ជ្រើសរើសទីតាំងព្រះវិហារ ក្នុងនគររបស់ព្រះអង្គ ទ្រង់ឃើញឧទ្យានរបស់កុដុម្ពិកៈឈ្មោះសោភៈ ទ្រង់ទិញដោយទ្រព្យមួយសែន លះបង់ព្រះរាជទ្រព្យមួយសែនឲ្យសាងវិហារ ក្នុងវិហារ ឲ្យសាងព្រះគន្ធកុដិសម្រាប់ព្រះមានព្រះភាគ កុដិសម្រាប់ពួនសម្ងំ និងមណ្ឌប ជាទីសម្រាកពេលយប់ និងពេលថ្ងៃ សម្រាប់ពួកភិក្ខុក្រៅអំពីនោះ រៀបចំសាងកំពែងព័ទ្ធជុំវិញ និងខ្លោងទ្វារ ហើយទ្រង់បញ្ជូនមនុស្សទៅកាន់សម្នាក់ព្រះរាជាបិតា ក្រាបទូលថា កិច្ចរបស់ទូលបង្គំចប់សព្វគ្រប់ហើយ សូមទ្រង់បញ្ជូនព្រះសាស្តាមកចុះ ។ ព្រះរាជបិតាឲ្យព្រះមានព្រះភាគសោយហើយ ទូលថា បពិត្រព្រះមានព្រះភាគ កិច្ចរបស់សុមនៈសម្រេចហើយ គេទន្ទឹងការយាងទៅរបស់ទ្រង់ ។ ព្រះមានព្រះភាគ មានភិក្ខុមួយសែនរូបចោមរោម ប្រថាប់នៅក្នុងវិហារទាំងឡាយមួយយោជន៍មួយៗ យាងទៅ ។ ព្រះរាជកុមារទ្រង់ជ្រាបថា ព្រះសាស្តាកំពុងយាងមក ទ្រង់ក៏ចេញទៅធ្វើបដិសណ្ឋារៈអស់ចម្ងាយផ្លូវមួយយោជន៍ បូជាគ្រឿងក្រអូប និងផ្កាជាដើម នាំព្រះមានព្រះភាគចូលទៅកាន់វិហារ ទ្រង់វេរព្រះវិហារថ្វាយថា

**សតសហស្សេន មេ កីតំ　　សតសហស្សេន មាបិតំ**

**សោភនំ នាម ឧយ្យានំ　　បដិគ្គណ្ហ មហាមុនិ ។**

បពិត្រមហាមុនី សូមទ្រង់ទទួលឧទ្យានឈ្មោះសោភនៈ ដែលខ្ញុំព្រះអង្គទិញមកដោយទ្រព្យមួយសែន សាងវិហារដោយទ្រព្យមួយសែនផងចុះ ។

ព្រះរាជកុមារនោះ ក្នុងថ្ងៃចូលវស្សា ថ្វាយទានហើយ ហៅបុត្រភរិយារបស់ខ្លួន និងពួកអមាត្យមកហើយ ប្រាប់ថា ព្រះសាស្តាយាងមកកាន់សម្នាក់របស់ពួកយើង ដោយផ្លូវឆ្ងាយ ព្រះពុទ្ធនៃយើងទាំងឡាយ ទ្រង់ធ្ងន់ក្នុងធម៌ មិនឃើញដល់អាមិស ព្រោះដូច្នោះ ខ្ញុំនឹងស្លៀកសំពត់ ២ ផ្ទាំងអស់ ៣ ខែនេះ សមាទានសីល ១០ នៅក្នុងទីនេះឯង ពួកអ្នកគប្បីឲ្យទានអស់ត្រៃមាសដោយទំនងនេះដល់ព្រះខីណាស្រពមួយសែនរូប សុមនរាជកុមារនោះប្រថាប់នៅក្នុងឋានៈដែលត្រូវគ្នាជាមួយទីលំនៅរបស់ព្រះសុមនត្ថេរ ឃើញកិច្ចកម្មគ្រប់យ៉ាងដែលព្រះថេរៈធ្វើវត្តដល់ព្រះមានព្រះភាគ ត្រិះរិះថា ព្រះថេរៈនេះជាទីស្និទ្ធស្នាលក្នុងព្រះតថាគត អញគួរប្រាថ្នាតំណែងរបស់ព្រះថេរៈនោះ កាលកៀកថ្ងៃបវារណាចេញវស្សា ទើបយាងទៅកាន់ផ្ទះ ថ្វាយមហាទានអស់ ៧ ថ្ងៃ ថ្ងៃទី ៧ ទ្រង់ដាក់ត្រៃចីវរទៀបបាទាភិក្ខុមួយសែនរូប ថ្វាយបង្គំព្រះសាស្តាហើយ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុណ្យឯណាដែលខ្ញុំព្រះអង្គធ្វើមក តាំងអំពីថ្វាយទានក្នុងរវាងទីសម្រាកតាមផ្លូវមកអស់ ៧ ថ្ងៃ បុណ្យនោះ ខ្ញុំព្រះអង្គមិនប្រាថ្នាសក្កសម្បត្តិ មិនបានប្រាថ្នាព្រហ្មសម្បត្តិ តែខ្ញុំព្រះអង្គប្រាថ្នាជាឧបដ្ឋាករបស់ព្រះពុទ្ធ ទើបធ្វើ បពិត្រព្រះមានព្រះភាគ មួយទៀតសោត ខ្ញុំព្រះអង្គសូមបានជាឧបដ្ឋាកដូចព្រះសុមនៈ

ក្នុងអនាគតកាល ។ ព្រះសាស្តាទ្រង់ឃើញថា មិនមានអន្តរាយសម្រាប់ព្រះរាជកុមារនោះ ទើបទ្រង់ព្យាករហើយត្រឡប់ទៅ ។ ព្រះរាជកុមារទ្រង់ត្រឡប់ហើយ ទ្រង់ត្រិះរិះថា ធម្មតាព្រះពុទ្ធទាំងឡាយ មិនត្រាស់ពាក្យបែកជា ២ ហាក់ដូចជាបានកាន់បាត្រ ចីវររបស់ព្រះគោតមសម្ពុទ្ធតាមក្រោយព្រះបិដ្ឋិរបស់ទ្រង់ក្នុងថ្ងៃស្អែក ។

ព្រះរាជកុមារនោះ ក្នុងពុទ្ធុប្បាទកាលនោះ ថ្វាយទានហើយ កើតក្នុងស្ថានសួគ៌អស់មួយសែនឆ្នាំ ។ កាលព្រះពុទ្ធព្រះនាមថាកស្សបៈ បានថ្វាយសំពត់ដណ្តប់ដើម្បីជាទម្របាត្រដល់ព្រះថេរៈដែលត្រាច់ទៅបិណ្ឌបាត បានធ្វើការបូជា កើតក្នុងស្ថានសួគ៌ទៀត ចុតិអំពីភពនោះ កើតជាស្តេចពារាណសីទ្រង់ឡើងប្រាសាទជាន់លើដ៏ប្រសើរ ទតឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ ដែលមកអំពីភ្នំគន្ធមាទន៍ ឲ្យគេនិមន្តមកហើយ ឲ្យឆាន់ ឲ្យសាងបណ្ណសាលា ៨ ខ្នងសម្រាប់ព្រះបច្ចេកពុទ្ធទាំងនោះ ក្នុងមង្គលឧទ្យានរបស់ព្រះអង្គ ទ្រង់រៀបចំតាំង ធ្វើដោយរតនៈសុទ្ធ គ្រែធ្វើដោយកែវមណីមួយមុខ ៨ និងទម្រជើងកែវមណី បានធ្វើការឧបដ្ឋាកអស់មួយម៉ឺនឆ្នាំ ។ ទាំងនេះជាឋានៈដែលប្រាកដហើយ លោកថ្វាយទានអស់មួយសែនកប្ប កើតក្នុងស្ថានសួគ៌ជាន់តុសិតជាមួយព្រះពោធិសត្វនៃយើង ចុតិអំពីតុសិតនោះហើយ ក៏កើតក្នុងប្រាសាទរបស់ព្រះបាទអមិតោទនសក្យៈ ។ លំដាប់នោះ លោកកើតហើយ ធ្វើព្រះញាតិទាំងអស់ឲ្យត្រេកអររីករាយ ព្រោះដូច្នោះ ទើបពួកព្រះញាតិថ្វាយព្រះនាមដល់លោកថា អានន្ទ ។ កាលព្រះមានព្រះភាគចេញអភិនេស្រ្កមណ៍តាមលំដាប់

សម្រេចសម្មាសម្ពោធិញ្ញាណហើយ ទ្រង់យាងចូលក្រុងកបិលពស្តុគ្រាដំបូង ទ្រង់ចេញអំពីក្រុងកបិលពស្តុ កាលពួកព្រះរាជកុមារចេញបព្វជ្ជា ដើម្បីជាបរិវាររបស់ព្រះមានព្រះភាគ លោកក៏ចេញបួសក្នុងសម្នាក់ព្រះសាស្តា មួយអន្លើនឹងពួកសក្យៈ មានភទ្ទិយៈជាដើម មិនយូរប៉ុន្មានបានស្តាប់ធម្មកថារបស់ព្រះបុណ្ណមន្តានីបុត្រ ក៏តាំងនៅក្នុងសោតាបត្តិផល ។

សម័យនោះឯង ព្រះមានព្រះភាគ ទ្រង់មានឧបដ្ឋាកមិនប្រាកដអស់ ២០ ឆ្នាំ ក្នុងបឋមពោធិកាល ជួនកាលព្រះនាគសមាលៈ កាន់បាត្រ ចីវរតាមទ្រង់ទៅ ជួនកាលព្រះនាគិតៈ ជួនកាលព្រះឧបវាណៈ ជួនកាលព្រះសុនក្ខត្ត ជួនកាលព្រះចុន្ទសមណុទ្ទេស ជួនកាលព្រះសាគតៈ ជួនកាលព្រះរាធៈ ជួនកាលព្រះមេឃិយៈ ។ បណ្តាឧបដ្ឋាកមិនប្រចាំទាំងនោះ សម័យមួយ ព្រះមានព្រះភាគទ្រង់ធ្វើដំណើរឆ្ងាយ ជាមួយព្រះនាគសមាលត្ថេរ ដល់ផ្លូវបែកជា ២ ព្រះថេរៈចុះអំពីផ្លូវទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់យាងផ្លូវនេះ លំដាប់នោះ ទើបព្រះមានព្រះភាគត្រាស់នឹងលោកថា មកចុះភិក្ខុ យើងទៅជាមួយគ្នាផ្លូវនេះ ព្រះថេរៈទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់កាន់យកផ្លូវរបស់ទ្រង់ចុះ ខ្ញុំព្រះអង្គនឹងទៅផ្លូវនេះ ហើយដាក់បាត្រចីវរចុះលើផែនដី ព្រះមានព្រះភាគត្រាស់ថា ឲ្យមកចុះភិក្ខុ ទ្រង់ទទួលបាត្រនិងចីវរយាងទៅ ។ លុះភិក្ខុរូបនោះធ្វើដំណើរទៅដោយទំនើងខ្លួនឯង ពួកចោរក៏ដណ្តើមយកបាត្រ និងចីវរ វាយសីសៈបែក លោកគិតថា ឥឡូវនេះ មានតែព្រះមានព្រះភាគ ទើបជាទីពឹងរបស់អញបាន មិនមានអ្នកដទៃឡើយ

ហើយមកកាន់សម្នាក់ព្រះមានព្រះភាគ ទាំងមានឈាមហូរ កាលព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុ អ្នកមានរឿងអ្វី ក៏ទូលរឿងរ៉ាវថ្វាយ ។ ព្រះមានព្រះភាគត្រាស់លួងលោមថា ម្នាលភិក្ខុ មិនថ្វីឡើយ តថាគតហាមអ្នកព្រោះហេតុនោះឯងម្យ៉ាងទៀត ក្នុងកាលមួយនោះ ព្រះមានព្រះភាគយាងទៅកាន់ស្រុកជន្តុគាម ក្បែរបាចីនវង្សមិគទាយវ័នជាមួយព្រះមេឃិយត្ថេរ ក្នុងទីនោះ ព្រះមេឃិយៈត្រាច់បិណ្ឌបាតទៅក្នុងជន្តុគាម ជួបចម្ការស្វាយគួរជាទីជ្រះថ្លាត្រង់ច្រាំងស្ទឹង ក៏ទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ទទួលបាត្រ និងចីវររបស់ទ្រង់ចុះ ខ្ញុំព្រះអង្គធ្វើសមណធម៌ត្រង់ព្រៃស្វាយនេះ ព្រះមានព្រះភាគទ្រង់ឃាត់អស់វារៈ ៣ ដង ក៏នៅតែចចេសទៅ ត្រូវអកុសលវិតក្កគ្របសង្កត់ ត្រឡប់មកទូលរឿងរ៉ាវថ្វាយព្រះមានព្រះភាគៗ ត្រាស់នឹងលោកថា តថាគតកំណត់ដល់ហេតុរបស់អ្នកនេះឯង ទើបឃាត់ ហើយទ្រង់យាងទៅកាន់ក្រុងសាវត្ថីតាមលំដាប់ ក្នុងក្រុងសាវត្ថីនោះ ព្រះមានព្រះភាគប្រថាប់គង់លើពុទ្ធាសនៈដ៏ប្រសើរ ដែលរៀបចំទុកត្រង់បរិវេណព្រះគន្ធកុដិមានភិក្ខុសង្ឃចោមរោមហើយ ហៅភិក្ខុទាំងឡាយមកត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ តថាគតចាស់ជរាហើយ ភិក្ខុពួកខ្លះពោលថា ខ្ញុំព្រះអង្គទៅផ្លូវនេះហើយ ក៏ទៅបាត់ ពួកខ្លះក៏ដាក់បាត្រចីវររបស់តថាគតលើផែនដី ពួកអ្នកចូរជួយជ្រើសរើសភិក្ខុដែលឧបដ្ឋាកប្រចាំដល់តថាគតចុះ ។ ភិក្ខុដល់នូវសេចក្តីសង្វេគ កាលនោះ ព្រះសារីបុត្រក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះមានព្រះភាគ ក្រាបទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គកាលប្រាថ្នា

( នឹងឃើញ ) ព្រះអង្គមួយអង្គ ទើបបំពេញបារមីទាំងឡាយ អស់មួយអសង្ខេយ្យ និងមួយសែនកប្ប បុគ្គលមានបញ្ញាច្រើនដូចខ្ញុំព្រះអង្គ ឈ្មោះថា ឧបដ្ឋាកក៏គួរ មិនមែនឬ ខ្ញុំព្រះអង្គនឹងឧបដ្ឋាក ព្រះមានព្រះភាគត្រាស់ឃាត់ថា កុំឡើយ សារីបុត្រ តថាគតនៅទិសណា ទិសនោះក៏មិនទំនេរឡើយ ឱវាទរបស់អ្នក ក៏ដូចឱវាទរបស់ព្រះពុទ្ធទាំងឡាយ កិច្ចដែលអ្នកឧបដ្ឋាកតថាគតមិនមានទេ ។ ព្រះអសីតិមហាសាវ័ក ចាប់តាំងអំពីព្រះមហាមោគ្គល្លានឡើងទៅ ក៏ក្រោកឡើងដោយឧបាយនោះដូចគ្នា ព្រះមានព្រះភាគក៏ទ្រង់ហាម ។ ឯព្រះអានន្ទអង្គុយស្ងៀម ។ លំដាប់នោះ ភិក្ខុទាំងឡាយពោលនឹងព្រះអានន្ទថា នែអានន្ទ ភិក្ខុសង្ឃទូលសូមតំណែងឧបដ្ឋាកគ្រប់រូប ចូរអ្នកទូលសូមចុះ ព្រះថេរៈពោលថា អាវុសោ ធម្មតាតំណែងដែលទូលសូមបានហើយ ជារបស់មិនសំខាន់ ព្រះសាស្តាទ្រង់មិនឃើញខ្ញុំឬ បើទ្រង់ពេញព្រះហឫទ័យ មុខជាត្រាស់ថា អានន្ទ ចូរអ្នកឧបដ្ឋាកតថាគត ដូច្នេះ ។ លំដាប់នោះ ព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ អានន្ទ មិនចាំបាច់មានអ្នកដទៃដឹកនាំឲ្យកើតឧស្សាហ៍ទេ នឹងដឹងខ្លួនឯង ហើយឧបដ្ឋាកតថាគត ។ បន្ទាប់ពីនោះ ភិក្ខុទាំងឡាយពោលថា ចូរក្រោកឡើងចុះ អានន្ទ ចូរទូលសូមតំណែងឧបដ្ឋាកនឹងព្រះទសពលចុះ ។

---

ព្រះថេរៈក្រោកឡើងទូលសូមពរ ៨ ប្រការ គឺពរដែលត្រូវឃាត់ ៤ ពរដែលសូម ៤ ។ ព្រះថេរៈទូលថា ឈ្មោះថា ពរដែលត្រូវឃាត់ ៤ គឺ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់កុំប្រទានចីវរ ១ កុំប្រទានបិណ្ឌបាតដ៏ប្រណីត

ដែលទ្រង់បានមកហើយដល់ខ្ញុំព្រះអង្គ ១ សូមកុំប្រទានឲ្យខ្ញុំព្រះអង្គនៅក្នុងព្រះគន្ធកុដិជាមួយព្រះអង្គ ១ សូមទ្រង់កុំនាំខ្ញុំព្រះអង្គទៅក្នុងទីនិមន្ត ១ យ៉ាងនេះ ទើបខ្ញុំព្រះអង្គឧបដ្ឋាក ។ ព្រះមានព្រះភាគកាលត្រាស់សួរថា ម្នាលអានន្ទ អ្នកឃើញទោសដូចម្តេចក្នុងសេចក្តីនេះ ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើខ្ញុំព្រះអង្គបានវត្ថុបំណងទាំងនេះសោត នឹងមានបុគ្គលពោលបានថា អានន្ទបរិភោគចីវរ បរិភោគបិណ្ឌបាតដ៏ប្រណីត នៅក្នុងព្រះគន្ធកុដិជាមួយព្រះមានព្រះភាគ ទៅកាន់ទីតែមួយជាមួយព្រះទសពល ព្រោះបានលាភនេះ ទើបឧបដ្ឋាកព្រះតថាគត កិច្ចរបស់អ្នកឧបដ្ឋាកយ៉ាងនេះ នឹងមានប្រយោជន៍អ្វី ។ ព្រោះដូច្នោះ ទើបលោកទូលសូមពរដែលជាចំណែកឃាត់ ៤ ប្រការនេះ ។ ព្រះថេរៈទូលសូមពរដែលមិនឃាត់ ៤ គឺបពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ទៅកាន់ទីនិមន្ត ដែលខ្ញុំព្រះអង្គបានទទួល ១ បើខ្ញុំព្រះអង្គនាំបុគ្គលដែលមកអំពីរដ្ឋឆ្ងាយ ជនបទឆ្ងាយ ចូលគាល់បានក្នុងខណៈដែលជននោះមកហើយ ១ ខណៈណាខ្ញុំព្រះអង្គកើតសេចក្តីសង្ស័យ ខណៈនោះសូមឲ្យខ្ញុំព្រះអង្គចូលគាល់ព្រះមានព្រះភាគបាន ១ បើព្រះមានព្រះភាគទ្រង់សម្តែងធម៌ណា កំបាំងអំពីខ្ញុំព្រះអង្គ សូមទ្រង់ប្រាប់ធម៌នោះដល់ខ្ញុំព្រះអង្គ ១ យ៉ាងនេះ ទើបខ្ញុំព្រះអង្គឧបដ្ឋាកព្រះអង្គ ។ កាលព្រះមានព្រះភាគត្រាស់សួរថា ម្នាលអានន្ទ ក្នុងសេចក្តីនេះ អ្នកឃើញអានិសង្សដូចម្តេច ទើបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ពួកកុលបុត្រមានសទ្ធា ក្នុងលោកនេះ កាលមិនបានឱកាសរបស់ព្រះមានព្រះភាគហើយ ទើបពោលនឹងខ្ញុំព្រះអង្គយ៉ាងនេះថា

លោកម្ចាស់អានន្ទ ស្អែកនេះ សូមលោកម្ចាស់ មួយអន្ទើដោយព្រះមានព្រះភាគ ទទួលភិក្ខាក្នុងផ្ទះរបស់ខ្ញុំ បើទ្រង់មិនយាងទៅក្នុងទីនោះ ខ្ញុំព្រះអង្គមិនបានឱកាសនាំបុគ្គលអ្នកចូលគាល់ ក្នុងខណៈដែលជននោះប្រាថ្នា នឹងបន្ទោបង់សេចក្តីសង្ស័យ ពួកគេនឹងពោលបានថា អានន្ទ ឧបដ្ឋាកព្រះទសពលធ្វើអ្វី ព្រះមានព្រះភាគទ្រង់មិនអនុគ្រោះយ៉ាងនេះ ម្យ៉ាងទៀត ពួកគេនឹងសួរខ្ញុំព្រះអង្គកំបាំងមុខព្រះមានព្រះភាគថា លោកម្ចាស់អានន្ទ គាថានេះ សូត្រនេះ ជាតកនេះ ព្រះមានព្រះភាគទ្រង់សម្តែងក្នុងទីណា បើខ្ញុំព្រះអង្គមិនបានពរនោះ ពួកគេនឹងពោលបានថា លោកម្ចាស់ជាប់តាមព្រះមានព្រះភាគអស់កាលយូរ មិនលះបង់ ដូចជាស្រមោល ហេតុអ្វី ទើបលោកម្ចាស់មិនដឹងព្រះតម្រាស់ប៉ុណ្ណោះ សេចក្តីនោះ ខ្ញុំព្រះអង្គត្រូវការពោលធម៌ ដែលព្រះមានព្រះភាគទ្រង់សម្តែងកំបាំងមុខទៀត ព្រោះដូច្នោះ ទើបលោកទូលសូមពរ ៤ ប្រការនេះ ។ ព្រះមានព្រះភាគ ក៏បានប្រទានពរដល់លោក ។ លោកទទួលពរ ៨ ប្រការយ៉ាងនេះ ទើបបានជាឧបដ្ឋាកជាប្រចាំ ។

ផលនៃបារមីទាំងឡាយ ដែលបំពេញមកអស់សែននៃកប្ប ក៏មកដល់បុគ្គលដែលប្រាថ្នាតំណែងពុទ្ធុបដ្ឋាកនោះឯង ។ តាំងអំពីថ្ងៃដែលបានតំណែងជាពុទ្ធុបដ្ឋាកហើយ លោកឧបដ្ឋាកព្រះទសពលដោយកិច្ចទាំងឡាយជាដើមយ៉ាងនេះ គឺដោយទឹក ២ យ៉ាង ដោយឈើស្ទន់ ៣ យ៉ាង ដោយការប្រេបាច់ព្រះហស្ត និងព្រះបាទ ដោយការប្រេបាច់ព្រះបិដ្ឋិ ដោយការបោសបរិវេណព្រះគន្ធកុដិ គិតថា ព្រះសាស្តាគួរបានកិច្ចនេះក្នុងពេលនេះ ហើយកាន់ប្រទីបធំ

បន្ទាប់អំពីកណ្ដាលយប់ ក៏ដើរមើលជុំវិញបរិវេណព្រះគន្ធកុដិ មួយរាត្រី ៩ ដង ទើបលោកមានសេចក្ដីត្រិះរិះថា បើអាត្មាអញងុយដេកសោត អញមិនអាចទូលឆ្លើយ កាលព្រះទសពលត្រាស់ហៅ ។ ព្រោះដូច្នោះ ទើបលោកមិនលែងប្រទីបឲ្យផុតអំពីដៃ រហូតដល់ភ្លឺ ។ ក្នុងសេចក្ដីនេះ មានវត្ថុនិទានដូចពោលនេះ តែខាងក្រោយមក ព្រះសាស្ដាប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់សរសើរព្រះអានន្ទថាជាឃ្លាំងធម៌ ដោយអនេកបរិយាយ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកសាវ័កដែលជាពហូសូត ជាអ្នកមានសតិ ជាអ្នកមានគតិ ជាអ្នកមានធិតិ និងពុទ្ធុប្បដ្ឋាកក្នុងសាសនានេះឯង ៕

## អដ្ឋកថាសូត្រទី ១ ចប់

# អដ្ឋកថា សូត្រទី ២

# ប្រវត្តិ ព្រះឧរុវេលកស្សបត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ២ ដូចតទៅនេះ បទថា **មហាបរិសានំ** លោកសម្ដែងថា ព្រះឧរុវេលកស្សបៈ ជាកំពូលនៃពួកភិក្ខុសាវក មានបរិវារច្រើន ។ ពិតហើយ ព្រះថេរៈដទៃៗ ជួនកាល ក៏មានបរិវារច្រើន ជួនកាលក៏មានបរិវារតិច ចំណែកព្រះថេរៈនេះ និងប្អូនប្រុសទាំង ២ មានបរិវារប្រចាំជាសមណៈដល់ទៅ ១០០០ រូប បណ្ដាជដិលភិក្ខុ ៣ រូបនោះ កាលមួយរូបឲ្យបព្វជ្ជាម្ដងមួយរូប ក៏បានសមណៈ ២០០០ រូប បើឲ្យបព្វជ្ជាមួយអន្លើ ២ រូប ក៏បានសមណៈ ៣០០០ រូប ព្រោះដូច្នោះ ទើបឧរុវេលកស្សបជាកំពូលនៃពួកភិក្ខុសាវក ដែលមានបរិវារច្រើន ។ ពាក្យថា **កស្សប** ជាគោត្ររបស់លោក ។ ប្រាកដឈ្មោះថា **ឧរុវេលកស្សប** ព្រោះលោកបួសក្នុងឧរុវេលាសេនានិគម ។ ក្នុងបញ្ហាកម្មរបស់លោក មានអនុសន្ធិដូច្នេះ

ក្នុងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ឧរុវេលកស្សបៈនេះ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ចម្រើនវ័យហើយ ស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុដែលមានបរិស័ទច្រើន គិតថា សូម្បីអាត្មាអញ ក៏គួរមានសភាពដូចភិក្ខុនេះ ក្នុងអនាគតកាល ទើបថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ឲ្យគ្រងត្រៃចីវរ ថ្វាយបង្គំព្រះសាស្ដា ហើយបានធ្វើសេចក្ដីប្រាថ្នាក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវកដែលមានបរិស័ទច្រើន ។ ព្រះសាស្ដាទ្រង់ឃើញថា មិនមានអន្តរាយ ទើបទ្រង់ព្យាករថា

បុគ្គលនេះនឹងបានជាកំពូលនៃពួកភិក្ខុជាសាវ័ក ដែលមានបរិស័ទច្រើន ក្នុងសាសនារបស់ព្រះគោតមសម្ពុទ្ធ ក្នុងអនាគតកាល ហើយទ្រង់យាងត្រឡប់ កុលបុត្រនោះធ្វើកល្យាណកម្ម ដរាបដល់អស់ជីវិត អន្ទោលក្នុងទេវតា និងមនុស្ស ក្នុងទីបំផុត ៩២ កប្ប បានកើតជាព្រះកនិដ្ឋភាតាមាតាដទៃរបស់ព្រះសម្ពុទ្ធព្រះនាមផុស្សៈ ព្រះរាជបិតាព្រះនាមមហិន្ទរាជា ។ លោកមានបងប្អូនដទៃៗ ពីរអង្គទៀត ។ បងប្អូនទាំង ៣ អង្គនោះ បានតំណែងមួយអង្គ មួយផ្នែកយ៉ាងនេះ ទ្រង់បង្ក្រាបជនបទជាយដែនដែលបះបោរ ដោយន័យបានពោលហើយខាងដើម ទ្រង់បានពរអំពីសម្នាក់ព្រះរាជបិតា ទ្រង់ទទួលពរថា ពួកខ្ញុំព្រះអង្គនឹងទំនុកបម្រុងព្រះទសពលអស់ ៣ ខែ ។ គ្រានោះ បងប្អូនទាំង ៣ អង្គ ត្រិះរិះថា ពួកយើងទំនុកបម្រុងព្រះទសពល ធ្វើឲ្យសម ទើបគួរ ទើបតាំងអមាត្យម្នាក់ទុកក្នុងតំណែងកាន់ប្រាក់ តែងតាំងអមាត្យម្នាក់ជាអ្នកចាយ តែងតាំងអមាត្យម្នាក់ទុកក្នុងតំណែងជាអ្នកអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន សមាទានសីល ១០ សម្រាប់ព្រះអង្គ រក្សាសិក្ខាបទទាំងឡាយអស់ត្រៃមាស អមាត្យទាំង ៣ នាក់នោះ កើតជាព្រះបាទពិម្ពិសារ វិសាខឧបាសក និងរដ្ឋបាលត្ថេរ ក្នុងពុទ្ធុប្បាទកាលនេះ ដោយន័យដែលពោលមកហើយខាងដើម ឯព្រះរាជកុមារទាំងនោះ កាលព្រះទសពលចាំវស្សាហើយ ទ្រង់បូជាដោយបច្ច័យដោយដៃឯង ធ្វើកល្យាណកម្មដរាបដល់អស់ជីវិត កើតក្នុងត្រកូលព្រាហ្មណ៍ មុនព្រះទសពលនៃយើងទ្រង់កើតឡើង មានឈ្មោះថា កស្សបៈ ទាំង ៣ នាក់ តាមគោត្ររបស់ខ្លួន ជនទាំង ៣ នោះ ចម្រើនវ័យ រៀន

ត្រៃវេទ ជាអ្នកធំ មានមាណពជាបរិវារ ៥០០ នាក់ ប្អូនកណ្តាល ៣០០ នាក់ ប្អូនពៅ ២០០ នាក់ ។ ទាំង ៣ នាក់បងប្អូន ពិនិត្យមើលសារៈក្នុងគម្ពីរត្រៃវេទ ឃើញតែប្រយោជន៍ចំណែកបច្ចុប្បន្នប៉ុណ្ណោះ មិនឃើញប្រយោជន៍ចំណែកខាងមុខ ចំណែកបងប្រុសធំទៅកាន់តំបន់ឧរុវេលា បួសជាឥសី ព្រមដោយបរិវាររបស់ខ្លួន ឈ្មោះថា ឧរុវេលកស្សបៈ ។ ប្អូនកណ្តាលទៅបួសត្រង់គង្គាមហានទី ក៏ឈ្មោះថា នទីកស្សបៈ ប្អូនពៅទៅបួសត្រង់គយាសីសប្រទេស ឈ្មោះថា គយាកស្សបៈ ។

កាលកស្សបៈបងប្អូនបួសជាឥសី នៅក្នុងទីនោះ កន្លងថ្ងៃទៅជាច្រើន ព្រះពោធិសត្វនៃយើង ទ្រង់ចេញមហាភិនេស្រ្កមណ៍ ទ្រង់បានព្រះសព្វញ្ញុតញ្ញាណ ប្រកាសធម្មចក្រតាមលំដាប់ ទ្រង់ស្តាបនាបញ្ចវគ្គិយត្ថេរទុកក្នុងព្រះអរហត្ត ទ្រង់ប្រោសសម្លាញ់ ៥៥ នាក់ មានយសកុលបុត្រជាប្រធាន ទ្រង់បញ្ជូនព្រះអរហន្ត ៦០ អង្គ ឲ្យចារិកទៅដើម្បីប្រយោជន៍ដល់ជនច្រើន ដោយព្រះតម្រាស់ថា ម្នាលភិក្ខុទាំងឡាយ ពួកអ្នកចូរចារិកទៅ ដូច្នេះជាដើម ទ្រង់ប្រោសភទ្ទវគ្គិយ ទ្រង់ឃើញហេតុនៃឧរុវេលកស្សបៈ ទ្រង់ជ្រាបថា កាលតថាគតទៅ ជន ៣ នាក់បងប្អូន មួយអន្លើដោយបរិវារ នឹងសម្រេចអរហត្ត ។ ទ្រង់យាងទៅមួយព្រះអង្គឯង មិនមានសម្លាញ់ ដល់លំនៅរបស់ឧរុវេលកស្សបៈ ទ្រង់សូមរោងភ្លើងដើម្បីនៅប្រថាប់ ។ ទ្រង់នាំឧរុវេលកស្សបៈ ព្រមដោយបរិវារ តាំងអំពីទ្រង់ទូន្មានពស់ដែលនៅក្នុងរោងភ្លើងនោះ ដោយបាដិហារ្យទាំងឡាយ ចំនួន ៣៥០០ បាដិហារ្យ ហើយទ្រង់ឲ្យបួស ។ បង

ប្អូន ២ នាក់ទៀត ដឹងថា បងប្រុសបួស ក៏មកបួស មួយអន្លើដោយបរិវារ ។ ពួកជដិលទាំងអស់ ជាឯហិភិក្ខុ ទ្រទ្រង់បាត្រ និងចីវរដែលកើតអំពីឫទ្ធិ ។ ព្រះសាស្ដាទ្រង់នាំសមណៈ ១០០០ រូបនោះ ទៅកាន់គយាសីសប្រទេស ប្រថាប់គង់លើផ្ទាំងថ្ម ទ្រង់ប្រមើលមើលថា ជនទាំងនេះបួសបម្រើភ្លើង គួរសម្ដែងភពទាំង ៣ ឲ្យដូចជាផ្ទះភ្លើងឆេះ ដល់ជនទាំងនេះ ទើបទ្រង់សម្ដែងអាទិត្តបរិយាយសូត្រ ។ ចប់ទេសនា ក៏សម្រេចអរហត្តគ្រប់រូប ។ ព្រះសាស្ដា មានជដិលភិក្ខុទាំងនោះចោមរោម ទ្រង់ជ្រាបដល់បដិញ្ញា ដែលថ្វាយដល់ព្រះបាទពិម្ពិសារតាមលំដាប់ ទ្រង់យាងដល់ព្រះរាជឧទ្យានលដ្ឋិវ័ន ក្រុងរាជគ្រឹះ ។ ព្រះរាជាទ្រង់ជ្រាបថា ព្រះទសពលយាងមកដល់ហើយ មួយអន្លើដោយព្រាហ្មណ៍ និងគហបតី ១២ ម៉ឺន យាងទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្ដាទ្រង់ប្រមើលមើលបរិស័ទទាំងអស់ ទ្រង់ឃើញមហាជនធ្វើការគោរពកោតក្រែងក្នុងឧរុវេលកស្សបៈ ទ្រង់ត្រិះរិះថា មនុស្សទាំងនេះមិនដឹងថា តថាគត ឬកស្សបៈជាធំ ជនទាំងនេះមានវិតក្ក មិនអាចទទួលទេសនាបាន ទើបទ្រង់ប្រទានសញ្ញាដល់ព្រះថេរៈថា កស្សបៈ អ្នកចូរកាត់វិតក្ករបស់ឧបដ្ឋាកអ្នកចេញ ។ ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះសាស្ដាហើយ ក្រោកអំពីអាសនៈ ថ្វាយបង្គំព្រះសាស្ដាដោយបញ្ចង្គប្រតិស្ឋាន ហោះឡើងកាន់អាកាសប្រមាណមួយដូរដើមត្នោត សម្ដែងឫទ្ធិផ្សេងៗ ប្រកាសថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ជាសាស្ដារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក

បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ជាសាស្តារបស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គជាសាវក ហើយចុះមកថ្វាយបង្គំព្រះយុគលបាទព្រះទសពលដោយឧបាយនេះ ក្នុងគ្រាទី ៧ ហោះឡើងកាន់អាកាស ៧ ដូវដើមត្នោត ហើយថ្វាយបង្គំព្រះយុគលបាទរបស់ព្រះទសពល អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ វេលានោះ មហាជនអស់វិតក្កក្នុងព្រះសាស្តាថា បុគ្គលនេះជាមហាសមណៈក្នុងលោក ។ លំដាប់នោះ ទើបព្រះសាស្តាទ្រង់សម្តែងធម៌ប្រោស ។ ចប់ធម្មទេសនា ព្រះរាជា មួយអន្លើដោយព្រាហ្មណ៍ និងគហបតី ១១ ម៉ឺន តាំងនៅក្នុងសោតាបត្តិផល ១ ម៉ឺន ប្រកាសខ្លួនជាឧបាសក ភិក្ខុចំនួន ១០០០ រូបដែលជាបរិវាររបស់ឧរុវេលកស្សបៈទាំងនោះ គិតដោយការស្និទ្ធស្នាលរបស់ខ្លួនថា កិច្ចបព្វជិតរបស់ពួកយើងដល់ទីបំផុតហើយ ពួកយើងនឹងទៅខាងក្រៅធ្វើអ្វី ។ ទើបចោមរោមឧរុវេលកស្សបៈតែម្យ៉ាង ។ បណ្តាជដិលភិក្ខុទាំង ៣ នោះ កាលជដិលភិក្ខុមួយអង្គទទួលនិស្សិតបានម្តងមួយអង្គ ក៏ត្រូវជា ២០០០ កាលទទួលម្តងពីរអង្គ ក៏ត្រូវជា ៣០០០ ។ តាំងពីនោះមកនិស្សិតរបស់ជដិលភិក្ខុទាំងនោះ មានប៉ុនណា នឹងពោលដល់និស្សិតប៉ុណ្ណោះក៏គួរដូច្នេះ ។

ក្នុងសេចក្តីនោះ មានវត្ថុនិទានដូច្នេះ ។ សម័យក្រោយមក ព្រះសាស្តាប្រថាប់ក្នុងជេតពនមហាវិហារ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈជាកំពូលនៃពួកភិក្ខុសាវក ដែលមានបរិស័ទច្រើន ដូច្នេះឯង ។៚

**អដ្ឋកថា សូត្រទី ២ ចប់**

# អដ្ឋកថាសូត្រទី ៣

## ប្រវត្តិ ព្រះកាឡុទាយិត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៣ ដូចតទៅនេះ បទថា **កុលប្បសា-ទកានំ** បានដល់ ធ្វើត្រកូលឲ្យជ្រះថ្លា ។ ពិតហើយ ព្រះថេរៈនេះធ្វើរាជ-និវេសន៍របស់ព្រះបាទសុទ្ធោទនមហារាជ ដែលមិនទាន់ជួបព្រះពុទ្ធប៉ុណ្ណោះឲ្យជ្រះថ្លា ព្រោះហេតុនោះ ទើបលោកជាកំពូលនៃពួកភិក្ខុសាវ័កដែលធ្វើត្រកូលឲ្យជ្រះថ្លា ក្នុងបញ្ហាកម្មរបស់លោក មានរឿងពោលតាមលំដាប់ដូច្នេះ

កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះថេរៈនេះកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្តាប់ធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវ័ក ដែលធ្វើត្រកូលឲ្យជ្រះថ្លា ទើបធ្វើកុសលកម្មឲ្យក្រៃលែងឡើង ហើយប្រាថ្នានូវតំណែងនោះ លោកធ្វើកុសលរាបដល់អស់ជីវិត វិលវល់ក្នុងទេវតា និងមនុស្សទាំងឡាយ បដិសន្ធិក្នុងផ្ទះរបស់អមាត្យ នាក្រុងកបិលពស្តុ ក្នុងថ្ងៃដែលព្រះពោធិសត្វនៃយើង ទ្រង់បដិសន្ធិក្នុងគភ៌នៃព្រះមាតា ក្នុងថ្ងៃកើត ក៏កើតជំណាលគ្នានឹងព្រះពោធិសត្វនោះឯង ក្នុងថ្ងៃនោះ ញាតិទាំងឡាយ ក៏ឲ្យដេកលើកែប គឺសំពត់ ហើយនាំទៅថ្វាយខ្លួន ដើម្បីបម្រើព្រះពោធិសត្វ ។

ដើមពោធិព្រឹក្ស រាហុលមាតា កំណប់ទ្រព្យទាំង ៤ ដំរីទ្រង់គ្រឿងសេះកណ្ឋកៈ នាយឆន្នៈ កាឡុទាយិអមាត្យ ៧ នេះ ឈ្មោះថា សត្តសហជាតព្រោះកើតថ្ងៃជំណាលគ្នានឹងព្រះពោធិសត្វ ។

ក្នុងថ្ងៃដាក់ឈ្មោះទារកនោះ ពួកញាតិឲ្យឈ្មោះថា ឧទាយី ព្រោះកើត

ក្នុងថ្ងៃដែលអ្នកនគរទូទៅ មានចិត្តផ្សាយខ្ពស់ឡើង ។ តែព្រោះលោកជាមនុស្សខ្មៅបន្តិច ទើបកើតឈ្មោះថា កាឡុទាយី ។ កាឡុទាយីនោះលេងវត្ថុសម្រាប់លេងរបស់ក្មេងប្រុសជាមួយព្រះពោធិសត្វរហូតចម្រើនវ័យ ។ តមកព្រះពោធិសត្វចេញមហាភិនេស្រ្កមណ៍ សម្រេចព្រះសព្វញ្ញុតញ្ញាណតាមលំដាប់ ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ទ្រង់ធ្វើការអនុគ្រោះលោក ទ្រង់អាស្រ័យក្រុងរាជគ្រឹះ នៅប្រថាប់ ។ សម័យនោះ ព្រះបាទសុទ្ធោទនមហារាជទ្រង់បានដំណឹងថា សុទ្ធត្ថកុមារសម្រេចអភិសម្ពោធិញ្ញាណ អាស្រ័យក្រុងរាជគ្រឹះ ប្រថាប់នៅក្នុងវេឡុវនវិហារ ទើបទ្រង់បញ្ជូនអមាត្យម្នាក់ មានបុរស ១០០០ ជាបរិវារ ទៅដោយព្រះតម្រាស់ថា អ្នកចូរនាំកូនរបស់ខ្ញុំមកក្នុងទីនេះ ។ អមាត្យនោះធ្វើដំណើរអស់ ៦០ យោជន៍ ចូលទៅកាន់ព្រះវិហារ ក្នុងវេលាដែលព្រះទសពលប្រថាប់គង់កណ្តាលបរិស័ទ ៤ ទ្រង់សម្តែងធម៌ អមាត្យនោះគិតថា រាជសារដែលព្រះរាជាទ្រង់បញ្ជូនទៅផ្អាកសិនចុះ ហើយឈរខាងចុងបរិស័ទ ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ក៏សម្រេចអរហត្ត មួយអន្លើដោយបុរស ១០០០ នាក់ ត្រង់ទីដែលឈរនោះឯង កាលព្រះមុនីទ្រង់លាព្រះហស្តដល់អមាត្យ និងបុរស ១០០០ នោះ ដោយព្រះតម្រាស់ថា ពួកអ្នកចូរជាភិក្ខុចុះ រំពេចនោះឯង បាត្រ និងចីវរសម្រេចអំពីឫទ្ធិកើតដល់បុគ្គលគ្រប់គ្នា ហាក់ដូចជាព្រះថេរៈដែលមានវស្សា ១០០ រាប់តាំងអំពីកាលសម្រេចអរហត្តហើយ ធម្មតាព្រះអរិយៈទាំងឡាយ រមែងជាអ្នកព្រងើយកន្តើយ ព្រោះដូច្នោះ ទើបអមាត្យមិនបានទូលដំណឹងដែលព្រះរាជាទ្រង់បញ្ជូន

មកដល់ព្រះទសពល ព្រះរាជាទ្រង់ព្រះតម្រិះថា អមាត្យមិនត្រឡប់មកអំពីទីនោះ ដំណឹងក៏មិនបានឮ ទើបបញ្ជូនអមាត្យដទៃៗ ទៅដោយទំនងនោះឯង អមាត្យនោះទៅហើយ ក៏សម្រេចអរហត្ត មួយអន្លើដោយបរិស័ទ ដោយន័យមុននោះឯង ហើយក៏នៅស្ងៀម ។ ទ្រង់បញ្ជូនបុរស ៩០០០ នាក់ មួយអន្លើដោយអមាត្យ ៩ នាក់ ដោយប្រការដូច្នេះ ។ គ្រប់ៗ គ្នាសម្រេចកិច្ចរបស់ខ្លួន ហើយក៏នៅស្ងៀម ។

គ្រានោះ ព្រះរាជាទ្រង់ព្រះតម្រិះថា បុគ្គលមានចំនួនប៉ុណ្ណេះ មិនប្រាប់ពាក្យណាមួយដល់ព្រះទសពល ដើម្បីយាងមកក្នុងទីនេះ ព្រោះគេមិនស្រឡាញ់ក្នុងអញ អ្នកដទៃៗ សូម្បីទៅ ក៏មិនអាចនាំព្រះទសពលមកបាន តែឧទាយីកូនរបស់អញ ឆ្នាំតែមួយដូចគ្នានឹងព្រះទសពល លេងដីជាមួយគ្នាមក គង់ស្រឡាញ់អញខ្លះ ទើបត្រាស់ឲ្យហៅមក ហើយប្រើថា នែកូន កូនចូរមានបុរស ១ ពាន់ជាបរិវារ ហើយចូរនាំព្រះទសពលមក ។ កាឡុទាយីក្រាបទូលថា បពិត្រទេវៈ ទូលបង្គំបានបព្វជ្ជាដូចពួកបុរសដែលទៅគ្រាដំបូង ទើបនាំមក ។ ព្រះរាជាត្រាស់ថា អ្នកធ្វើកិច្ចឯណានីមួយហើយ ចូរនាំកូនរបស់ខ្ញុំមក ក៏តាមចិត្តចុះ ។ កាឡុទាយីទទួលព្រះរាជឱង្ការថា សាធុ ព្រះអង្គ ហើយកាន់រាជសាសន៍ទៅកាន់ក្រុងរាជគ្រឹះ ឈរស្តាប់ធម៌ខាងក្រោយបរិស័ទក្នុងវេលាព្រះសាស្តាទ្រង់សម្តែងធម៌ហើយ សម្រេចអរហត្ត តាំងនៅដោយភាពជាឯហិភិក្ខុ មួយអន្លើដោយវារ ។ បន្ទាប់អំពីនោះ ក៏ត្រិះរិះថា នេះមិនមែនកាលៈទេសៈ ដែលព្រះទសពលត្រូវយាងទៅកាន់នគរនៃត្រកូលទេ លុះ

វស្សន្តរដូវ កាលដងព្រៃមានផ្ការីកស្គុសស្គាយ ផែនដីក្រាលដោយស្មៅពណ៌បៃតង ទើបជាកាលៈទេសៈ ទើបវង់ចាំ ដឹងថា កាលៈទេសៈដល់ហើយ ទើបទូលពណ៌នាផ្លូវ ដើម្បីព្រះទសពល ទ្រង់យាងទៅកាន់នគរនៃត្រកូល ដោយគាថាប្រមាណ ៦០ មានគាថាជាដើមថា

**នាតិសីតំ នាតិឧណ្ហំ នាតិទុព្ភិក្ខឆាតកំ**
**សទ្ទលា ហរិតា ភូមិ ឯស កាលោ មហាមុនិ ។**

បពិត្រព្រះមហាមុនី ទឹកទ្វេងមិនត្រជាក់ពេក មិនក្ដៅពេក
មិនមែនជាទីដែលរកអាហារបានលំបាក និងអត់ឃ្លានឡើយ
ផែនដីខៀវខ្ចី គ្របដណ្ដប់ដោយស្មៅ នេះជាកាលសមគួរ ។

ព្រះសាស្ដាទ្រង់ជ្រាបថា ឧទាយីពោលសរសើរការដើរទៅថា ជាកាលៈទេសៈដែលគួរយាងទៅកាន់ក្រុងកបិលពស្ដុ មានភិក្ខុ ២ ម៉ឺនរូបជាបរិវារ ទ្រង់យាងចារិកទៅ ដោយមិនប្រញាប់ប្រញាល់ ។ ព្រះឧទាយីដឹងថា ព្រះសាស្ដាទ្រង់យាងទៅហើយ គិតថា គួរនឹងថ្វាយការយល់ព្រះហឫទ័យដល់ព្រះមហារាជពុទ្ធបិតា ទើបហោះទៅប្រាកដក្នុងព្រះរាជនិវេសន៍របស់ព្រះរាជា ព្រះរាជាទតឃើញព្រះថេរៈ ក៏មានព្រះហឫទ័យត្រេកអរ និមន្តឲ្យគង់លើបល្ល័ង្កដ៏សមគួរ ដាក់បាត្រឲ្យពេញដោយភោជនមានរសដ៏ប្រសើរផ្សេងៗ ហើយប្រគេន ព្រះថេរៈក្រោកឡើងសម្ដែងអាកប្បកិរិយាថា នឹងទៅ ទើបព្រះរាជាត្រាស់ថា និមន្តឆាន់ចុះកូន ព្រះថេរៈទូលថា បពិត្រមហារាជ អាត្មានឹងទៅឆាន់ក្នុងសម្នាក់ព្រះសាស្ដា ត្រាស់សួរថា ព្រះសាស្ដានៅទីណា លោក

ម្ចាស់ ព្រះថេរៈទូលថា បពិត្រមហារាជ ព្រះសាស្ដាមានភិក្ខុ ២ ម៉ឺនជាបរិវារ ទ្រង់ចារិកដើម្បីសួរសុខទុក្ខមហាបពិត្រហើយ ព្រះរាជាត្រាស់ថា លោកម្ចាស់ឆាន់បិណ្ឌបាតនេះហើយ សូមនាំបិណ្ឌបាតក្រៅអំពីនេះទៅថ្វាយទម្រាំកូនរបស់ញោមមកដល់នគរនេះ ព្រះថេរៈ ទទួលអាហារដែលគប្បីនាំទៅថ្វាយព្រះទសពល រួចពោលធម្មកថា ធ្វើព្រះរាជនិវេសន៍ទាំងមូលឲ្យបាននូវសទ្ធា ដោយមិនទាន់ឃើញព្រះទសពលឡើយ កាលមនុស្សគ្រប់គ្នាកំពុងមើលនោះឯង ក៏បោះបាត្រទៅក្នុងអាកាស ខ្លួនឯងក៏ហោះទៅ នាំបិណ្ឌបាតដាក់ដល់ព្រះហស្ដនៃព្រះសាស្ដាៗ ទ្រង់សោយបិណ្ឌបាតនោះរាល់ៗ ថ្ងៃ ។ ព្រះថេរៈនាំអាហារពីព្រះរាជនិវេសន៍មកថ្វាយដល់ព្រះសាស្ដា ដែលកំពុងធ្វើដំណើរក្នុងចម្ងាយផ្លូវ ៦០ យោជន៍ មួយថ្ងៃមួយយោជន៍យ៉ាងក្រៃលែងគប្បីជ្រាបរឿងដូចពោលមក ដូច្នេះ ។

ក្នុងកាលជាខាងក្រោយ ព្រះសាស្ដាទ្រង់ព្រះតម្រិះថា ឧទាយី ធ្វើព្រះរាជនិវេសន៍ទាំងមូលរបស់ព្រះមហារាជបិតានៃតថាគតឲ្យជ្រះថ្លាហើយ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវ័កដែលធ្វើត្រកូលឲ្យជ្រះថ្លា ដូច្នេះឯង ។

## អដ្ឋកថាសូត្រទី ៣ ចប់

# អដ្ឋកថា សូត្រទី ៤

# ប្រវត្តិ ព្រះពក្កុលត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៤ ដូចតទៅនេះ បទថា **អប្បាពាធានំ** បានដល់ ជាអ្នកមិនមានអាពាធ ។ បទថា **ពាក្កុលោ** បានដល់ ព្រះថេរៈបានឈ្មោះយ៉ាងនេះ ព្រោះចម្រើនធំធាត់ក្នុងត្រកូលទាំង ២ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ថា

បានឮមកថា ក្នុងអតីតកាល ព្រះថេរៈបដិសន្ធិក្នុងត្រកូលព្រាហ្មណ៍មុនសាស្តាព្រះនាមអនោមទស្សីទសពល ខាងចុងមួយអសង្ខេយ្យ និងមួយសែនកប្ប រាប់អំពីកប្បនេះ ចម្រើនវ័យហើយ រៀនត្រៃវេទ មើលមិនឃើញសារៈនៃគម្ពីរត្រៃវេទ គិតថា នឹងស្វែងរកប្រយោជន៍ដែលប្រព្រឹត្តទៅខាងមុខទើបបួសជាឥសី បាននូវអភិញ្ញា ៥ និងសមាបត្តិ ៨ ញុំាងកាលឲ្យកន្លងទៅដោយការលេងឈាន ។ សម័យនោះ ព្រះអនោមទស្សីពោធិសត្វសម្រេចសព្វញ្ញុតញ្ញាណ មានពួកព្រះអរិយៈចោមរោម ហើយយាងចារិកទៅ ។ តាបសបានឮថា រតនៈ ៣ កើតឡើងហើយ ទើបទៅកាន់សម្នាក់ព្រះសាស្តាស្តាប់ធម៌ ចប់ទេសនា ក៏តាំងនៅក្នុងសរណៈ តែមិនអាចលះឋានៈ គឺភេទរបស់ខ្លួនបាន ។ លោកទៅគាល់ព្រះសាស្តា និងស្តាប់ធម៌ម្តងម្កាល ។ គ្រាមួយ ព្រះតថាគតកើតរោគខ្យល់ក្នុងព្រះឧទរ ។ តាបសមកដើម្បីគាល់ព្រះសាស្តា ដឹងថា ព្រះសាស្តាប្រឈួន ទើបសួរថា បពិត្រព្រះអង្គ ទ្រង់ប្រឈួនរោគអ្វី កាលភិក្ខុទាំងឡាយពោលថា រោគខ្យល់ក្នុងព្រះឧទរ ទើបគិតថានេះជាកាលដែលអញត្រូវបំពេញបុណ្យ ទើបទៅកាន់ជើងភ្នំ ផ្សំថ្នាំផ្សេងៗ

ហើយប្រគេនព្រះថេរៈដែលជាអ្នកឧបដ្ឋាក ដោយពោលថា សូមលោកម្ចាស់ថ្វាយថ្នាំនេះដល់ព្រះសាស្តា រោគខ្យល់ក្នុងព្រះឧទរក៏ស្ងប់ មួយអន្លើដោយការប្រើថ្នាំ ។ តាបសនោះទៅគាល់ក្នុងកាលដែលព្រះសាស្តា ទ្រង់ជាសះស្បើយ ទូលយ៉ាងនេះថា សេចក្តីផាសុកកើតដល់ព្រះតថាគត ព្រោះថ្នាំរបស់ខ្ញុំព្រះអង្គនេះ យ៉ាងណា ដោយផលនៃការថ្វាយថ្នាំរបស់ខ្ញុំព្រះអង្គនោះ សូមជំងឺតម្កាត់ក្នុងសរីរៈ សូម្បីត្រឹមតែការដកសក់ ក៏សូមកុំបីមានក្នុងភពដែលខ្ញុំព្រះអង្គកើតហើយ ។ នេះជាកល្យាណកម្ម ក្នុងអត្តភាពនោះរបស់លោក ។ លោកចុតិអំពីភពនោះ កើតក្នុងព្រហ្មលោក អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយអសង្ខេយ្យ ក្នុងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈបដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ គឺជាកំពូលនៃពួកភិក្ខុសាវក ដែលមានអាពាធតិចធ្វើកុសលកម្មក្រៃលែងឡើងទៅ ក៏ប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅមក ក្នុងទេវតា និងមនុស្ស កើតក្នុងត្រកូលព្រាហ្មណ៍ នាក្រុងពន្ធុមតី មុនព្រះទសពល ព្រះនាមវិបស្សីកើតឡើង បួសជាឥសី ដោយន័យមុននោះឯង ជាអ្នកបានឈាន អាស្រ័យនៅត្រង់ជើងភ្នំ ។ ព្រះវិបស្សីពោធិសត្វសម្រេចព្រះសព្វញ្ញុតញ្ញាណ មានភិក្ខុ ៦ លាន ៨ សែន ជាបរិវារ ទ្រង់អាស្រ័យក្រុងពន្ធុមតី ទ្រង់ធ្វើការសង្គ្រោះព្រះមហារាជដែលជាពុទ្ធបិតា ហើយប្រថាប់នៅក្នុងខេមមិគទាយវ័ន ។ គ្រានោះ តាបសនេះជ្រាបថា ព្រះទសពលកើតឡើងក្នុងលោក ទើបមកស្តាប់ធម្មកថារបស់

ព្រះសាស្តា តាំងនៅក្នុងសរណៈ មិនអាចលះបព្វជ្ជារបស់ខ្លួន តែក៏មកឧបដ្ឋាកព្រះសាស្តាម្តងម្កាល ។ សម័យមួយ ភិក្ខុទាំងឡាយ វៀរព្រះសាស្តា និងព្រះអគ្គសាវកកើតរោគត្រង់សីសៈ ព្រោះត្រូវខ្យល់របស់ដើមឈើពុលដែលចេញផ្កាក្នុងព្រៃហិមពាន្ត ។ តាបសមកគាល់ព្រះសាស្តា ជួបភិក្ខុអង្គុយទទូរសីសៈ ទើបសួរថា បពិត្រលោកកម្ចាស់ ភិក្ខុសង្ឃកើតអ្វី ភិក្ខុទាំងឡាយឆ្លើយថា អ្នកមានអាយុ ពួកភិក្ខុកើតរោគព្រោះផ្កាឈើពុល តាបសគិតថា នេះជាកាលដែលនឹងធ្វើការខ្វល់ខ្វាយតាមផ្លូវកាយដល់ភិក្ខុសង្ឃ ឲ្យបុណ្យកើតដល់អញ ទើបបេះថ្នាំប្រភេទផ្សេងៗ ដោយអំណាចរបស់ខ្លួន ហើយផ្សំធ្វើជាថ្នាំប្រគេន រោគរបស់ភិក្ខុគ្រប់រូបក៏ស្ងប់ទៅភ្លាម ។ តាបសនោះតាំងនៅដរាបដល់អស់អាយុ ក៏កើតក្នុងព្រហ្មលោក វិលវល់នៅក្នុងទេវតា និងមនុស្ស អស់ ៩១ កប្ប ។ កាលព្រះពុទ្ធព្រះនាមកស្សបៈកើតឡើងក្នុងក្រុងពារាណសី គ្រប់គ្រងផ្ទះ គិតថា លំនៅរបស់អាត្មាអញទ្រុឌទ្រោម នឹងត្រូវទៅជាយដែន នាំទព្វសម្ភារៈមកធ្វើផ្ទះ ទើបទៅជាមួយពួកជាងឈើ ជួបវិហារជំគ្រាំគ្រាក្នុងចន្លោះផ្លូវ ក៏គិតថា ការធ្វើផ្ទះរបស់អញផ្អាកសិនចុះ ការធ្វើផ្ទះនោះ នឹងមិនទៅជាមួយអញ តែការទៅជាមួយគ្នា ជួយគ្នាធ្វើអ្វីមួយមុនគួរ បុរសនោះឲ្យជាងទាំងនោះ កាន់យកទព្វសម្ភារៈ ឲ្យសាងរោងឧបោសថក្នុងវិហារនោះ ឲ្យសាងរោងឆាន់ ទីចង្ក្រម រោងភ្លើង កប្បិយកុដិ គឺរោងព្យាបាល ទីសម្រាកពេលយប់ និងទីសម្រាកពេលថ្ងៃ វច្ចកុដិ រៀបចំថ្នាំសម្រាប់ប្រើ និងសម្រាប់ឆាន់ដល់ភិក្ខុសង្ឃគ្រប់យ៉ាង ។

បុរសនោះធ្វើកុសលកម្ម រហូតដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ បដិសន្ធិក្នុងផ្ទះសេដ្ឋី ក្រុងកោសម្ពី មុនព្រះមុនី នៃយើងកើតឡើង តាំងអំពីថ្ងៃដែលលោកបដិសន្ធិ ត្រកូលសេដ្ឋីនោះ ក៏ជួបនូវលាភដ៏ប្រសើរ យសដ៏ប្រសើរ គ្រានោះ មាតារបស់លោកប្រសូតបុត្ររួច គិតថា កុមារនេះមានបុណ្យ ធ្វើទុកក្នុងកាលមុន ជាអ្នកមិនមានរោគ ជាអ្នកមានអាយុវែង តាំងទៅអស់កាលដរាបណា ក៏នឹងជាអ្នកឲ្យសម្បត្តិដល់អញអស់កាល មានប្រមាណត្រឹមនោះ ក្មេងទាំងឡាយដែលងូតទឹកក្នុងស្ទឹងយមុនាក្នុងថ្ងៃកើតនោះឯង រមែងជាអ្នកមិនមានរោគ ទើបបញ្ជូនក្មេងនោះទៅងូតទឹក ។ លោកអាចារ្យអ្នករចនាគម្ពីរមជ្ឈិមនិកាយពោលថា នាងឲ្យកក់ក្បាលក្នុងថ្ងៃទី ៥ ហើយបញ្ជូន ក្មេងនោះទៅលេងទឹកក្នុងទីនោះ កាលភីលៀង និងស្រីស្នំកំពុងឲ្យក្មេង លេងមុជ និងផុសឡើង ត្រីមួយឃើញទារកនោះ សម្គាល់ថាចំណី ក៏ហាមាត់ពាំយកទៅ ។ ពួកភីលៀងភិតភ័យ ក៏លះបង់ក្មេងគេចទៅ ត្រីក៏លេបកុមារនោះ សត្វមានបុណ្យ មិនជួបនូវទុក្ខ ដូចគេដាក់ក្នុងបន្ទប់ ហើយដេក ដោយតេជះបុណ្យនៃទារក ត្រីក៏ដូចជាលេបកាជនៈដែលក្តៅ ក៏ក្តៅក្រហាយ ហែលទៅដោយរហ័សអស់ ៣០ យោជន៍ ក៏ជាប់អួនរបស់អ្នកប្រមង់ ក្រុងពារាណសី ធម្មតាត្រីធំជាប់អួនរមែងស្លាប់ តែតេជះបុណ្យរបស់កុមារ ត្រីនេះ លុះដោះចេញអំពីអួន ទើបស្លាប់ ។ អ្នកប្រមង់ទាំងឡាយបានត្រីស្លាប់ រមែងពន្លះសាច់លក់ តែបែរជាប្រើអម្រែកវែក ទៅទាំងមូល ត្រាច់ពពាយនាយទៅក្នុងក្រុង

ប្រាប់ថាយកទ្រព្យ ១០០០ មក នឹងឲ្យត្រីនេះ បុគ្គកណាម្នាក់ក៏មិនទិញ ។

ក្នុងក្រុងនោះ មានត្រកូលសេដ្ឋីម្នាក់ មានសម្បត្តិ ៨០ កោដិ ពួកអ្នកប្រមង់ដល់ក្បែរទ្វារផ្ទះត្រកូលសេដ្ឋីនោះ ត្រូវសេដ្ឋីសួរថា ពួកអ្នកយកអ្វី ទើបឲ្យត្រីនោះ អ្នកប្រមង់ឆ្លើយថា យកកហាបណៈ សេដ្ឋីឲ្យកហាបណៈហើយទទួលយកត្រីទៅ ភរិយាសេដ្ឋីលេងជាមួយត្រីក្នុងថ្ងៃដទៃៗ តែថ្ងៃនោះ ដាក់ត្រីលើជ្រញ់ វះដោយខ្លួនឯង ធម្មតាមនុស្សទាំងឡាយ រមែងពន្លះត្រីខាងពោះ តែភរិយាសេដ្ឋីនោះ វះខាងខ្នង ឃើញទារកមានសម្បុរដូចមាស ក្នុងពោះត្រី ក៏ស្រែកដោយសំឡេងខ្លាំងថា ខ្ញុំបានកូនក្នុងពោះត្រី ទើបនាំទារកទៅរកស្វាមី គ្រានោះឯង សេដ្ឋីក៏ឲ្យវាយស្គរប្រកាស ហើយនាំក្មេងទៅកាន់សម្នាក់ព្រះរាជា ក្រាបទូលថា បពិត្រទេវៈ ទូលបង្គំបានក្មេងក្នុងពោះត្រី ទូលបង្គំនឹងធ្វើដូចម្តេច ព្រះរាជាត្រាស់ថា កុមារនេះមានបុណ្យ នៅក្នុងពោះត្រីក៏មិនមានរោគ អ្នកចូរចិញ្ចឹមចុះ ។ ត្រកូលមួយទៀត បានឮថា ត្រកូលសេដ្ឋីមួយ ក្នុងក្រុងពារាណសីបានក្មេងក្នុងពោះត្រី សេដ្ឋី ស្វាមីភរិយានោះក៏ទៅក្រុងពារាណសី សម័យនោះ មាតារបស់ក្មេងនោះ ឃើញក្មេងតែងខ្លួនប្រលែងលេង ក៏សួរថា ក្មេងនេះត្រូវចិត្តពិតហ្ន៎ ទើបប្រាប់រឿងនោះ ។ មាតាម្ខាងពោលថា នេះជាកូនរបស់ខ្ញុំ ។ ម្តាយបង្កើតសួរថា នាងបានបុត្រនេះអំពីណា ក៏ឆ្លើយថា ក្នុងពោះត្រី ម្តាយដើមប្រាប់ថា មិនមែនកូនរបស់នាងជាកូនរបស់ខ្ញុំទេ ម្តាយចិញ្ចឹមសួរថា នាងបានមកដូចម្តេច ក៏ឆ្លើយថា ខ្ញុំពពោះអស់ ១០ ខែ គ្រាមួយ ទារកកំពុងលេងទឹកក្នុងស្ទឹង ត្រីក៏ត្របាក់យក

ទៅ ។ មាតាបិតាញ៉ឹមប្រាប់ថា កូនរបស់នាង ប្រហែលជាត្រីដទៃត្របាក់យកទៅ ឯកុមារនេះ ខ្ញុំបានក្នុងពោះត្រី ទាំង ២ នាក់ក៏នាំគ្នាទៅកាន់រាជត្រកូល ។ ព្រះរាជាកាត់ក្ដីថា ស្រីនេះមិនមែនជាមាតាក៏មិនមែន ព្រោះពពោះមកអស់ ១០ ខែ ពួកអ្នកប្រមង់ ទោះបីចាប់ត្រីបាន ឈ្មោះថា ចាប់បានតែខាងក្រៅមិនមានថ្លើមប្រមាត់ជាដើម ឯស្រីនេះមិនមែនជាមាតាក៏មិនអាចថាបាន ព្រោះបានក្មេងក្នុងពោះត្រី ព្រោះដូច្នោះ ក្មេងនេះចូរជាទាយាទរបស់ជនទាំង ២ ត្រកូល បន្ទាប់ពីនោះមក ត្រកូលទាំង ២ ក៏ជួបនូវលាភដ៏ប្រសើរ យសដ៏ប្រសើរក្រៃលែង ទើបនាំគ្នាដាក់ឈ្មោះថា ពាកុលកុមារ ព្រោះត្រកូលទាំង ២ ចិញ្ចឹមឲ្យធំធាត់ ។ កាលលោកដឹងក្ដីហើយ ត្រកូលទាំង ២ ធ្វើប្រាសាទ ៣ ក្នុងនគរទាំង ២ រៀបចំនាដកៈ លោកនៅ ២ ខែ ក្នុងនគរនីមួយៗ លុះគ្រប់ ៤ ខែហើយ គេសាងមណ្ឌបលើក្បូនឲ្យលោក និងពួកនាដកៈចូលទៅក្នុងមណ្ឌបនោះ ។ លោកសោយសម្បត្តិ ( ក្នុងមណ្ឌបនោះ ) ទៅកាន់នគរមួយទៀត ៤ ខែ ។ ពួកនាដកៈអ្នកនគរចេញទៅទទួលលោក ដោយគិតថា លោកនឹងមកពាក់កណ្ដាលផ្លូវ ២ ខែ ហើយចោមរោមលោកនាំទៅកាន់នគររបស់ខ្លួន ២ ខែ ។ ពួកនាដកៈមួយពួកទៀតក៏ត្រឡប់ទៅនគររបស់ខ្លួន ។ លោកនៅក្នុងនគរនោះ ២ ខែហើយ ក៏ទៅកាន់នគរមួយទៀត ដោយទំនងនោះឯង លោកសោយសម្បត្តិយ៉ាងនេះ ៨០ ឆ្នាំបរិបូណ៌ ។

សម័យនោះ ព្រះពោធិសត្វនៃយើង ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណ ប្រកាសធម្មចក្រដ៏ប្រសើរ ទ្រង់ចារិកមកដោយលំដាប់ ដល់ក្រុងកោសម្ពី ព្រះ

មជ្ឈិមភាណកាចារ្យពោលថា ក្រុងពារាណសី ។ ពាកុលសេដ្ឋីបានដំណឹងថា ព្រះទសពលយាងមកហើយ ទើបកាន់យកគ្រឿងក្រអូប និងកម្រងផ្កាទៅកាន់សម្នាក់ព្រះសាស្តា ស្តាប់ធម៌បាននូវសទ្ធា ក៏បួស លោកជាបុថុជ្ជនអស់ ៧ ថ្ងៃ អរុណថ្ងៃទី ៧ ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា កាលនោះពួកស្រីមេផ្ទះដែលលោកធ្លាប់រួមរស់កាលគ្រាជាគ្រហស្ថក្នុងនគរទាំង ២ ក៏ត្រឡប់ទៅកាន់ផ្ទះត្រកូលរបស់ខ្លួន នៅក្នុងផ្ទះត្រកូលនោះឯង ធ្វើចីវរបញ្ជូនទៅប្រគេន ។ ព្រះថេរៈប្រើប្រាស់ចីវរមួយផ្ទាំង ដែលអ្នកក្រុងកោសម្ពីបញ្ជូនទៅប្រគេនកន្លះខែ ចីវរមួយផ្ទាំង ដែលអ្នកក្រុងពារាណសីបញ្ជូនទៅប្រគេនកន្លះខែ ដោយទំនងនេះឯង អ្នកនគរក៏នាំចីវរតែប្រភេទល្អៗ ក្នុងនគរទាំង ២ មកប្រគេនដល់ព្រះថេរៈមួយរូប ។ ព្រះថេរៈគ្រប់គ្រងផ្ទះ ៨០ ឆ្នាំ ជំងឺតម្កាត់ណាមួយមិនមានសព្វកាល ដោយហោច សូម្បីត្រឹមតែមួយរយៈប្រើម្រាមដៃ ២ ចាប់ដុំគ្រឿងក្រអូបហិត ។ ក្នុងឆ្នាំទី ៨០ ក៏ចូលបព្វជ្ជាដោយងាយស្រួល ទោះលោកបួសហើយ អាពាធតិចតួច ឬការខ្វះខាតដោយបច្ច័យ ៤ មិនមានឡើយ សូម្បីសម័យបរិនិព្វាន ក្នុងបច្ឆិមកាល លោកក៏ពោលពាកុលសូត្រទាំងមូល ដោយសម្តែងសុខតាមផ្លូវកាយ និងផ្លូវចិត្តរបស់ខ្លួនដល់អចេលកស្សបៈជាសម្លាញ់ចាស់របស់ខ្លួន កាលនៅជាគ្រហស្ថ ហើយក៏បរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ ។ អត្ថុប្បត្តិហេតុតាំងឡើងដូចពោលមកដូច្នេះ ទើបព្រះសាស្តាស្ថាបនាព្រះថេរៈទាំងឡាយក្នុងតំណែងផ្សេងៗ តាមលំដាប់ក៏ទ្រង់ស្ថាបនាព្រះពាកុលត្ថេរទុក ក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវក

*ខាងមានអាពាធតិច ក្នុងព្រះសាសនានេះ កាលព្រះថេរៈនៅមានជីវិតនៅឡើយ ។ ៙*

## អដ្ឋកថា សូត្រទី ៤ ចប់

# អដ្ឋកថា សូត្រទី ៥
# ប្រវត្តិ ព្រះសោភិតត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៥ ដូចតទៅនេះ បទថា* **បុព្វេនិវាសំ អនុស្សរន្តានំ** *លោកសម្តែងថា ព្រះសោភិតត្ថេរ ជាកំពូលនៃពួកភិក្ខុសាវក ដែលអាចរឭកដល់ខន្ធសន្តាន តំណនៃខន្ធដែលអាស្រ័យនៅក្នុងជាតិមុនៗ បាន ។ បានឮថា ព្រះថេរៈនោះកាលរឭកដល់ខន្ធដែលអាស្រ័យក្នុងជាតិមុនៗ ទៅតាមលំដាប់ ក៏កាន់យកដោយន័យ គឺគិតដល់អចិត្តកបដិសន្ធិក្នុងអសញ្ញីភព ៥០០ កប្ប ដូចបង្ហាញស្នាមជើងក្នុងអាកាស ព្រោះដូច្នោះទើបលោកឈ្មោះថា ជាកំពូលនៃភិក្ខុសាវកដែលរឭកដល់ខន្ធ ដែលនៅអាស្រ័យក្នុងជាតិមុនៗ ក្នុងបញ្ញាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ដូចតទៅនេះ*

*បានឮថា ព្រះសោភិតៈនេះ កាលព្រះពុទ្ធព្រះនាមថា បទុមុត្តរៈ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ចម្រើនវ័យ កំពុងស្តាប់ព្រះធម្មទេសនានៃ*

ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវក ខាងបានបុព្វេនិវាសញ្ញាណ ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលដរាបអស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស លុះមកដល់ពុទ្ធុប្បាទកាលនេះ ក៏កើតក្នុងត្រកូលព្រាហ្មណ៍ក្នុងក្រុងសាវត្ថី មាតាបិតាដាក់ឈ្មោះថា សោភិតៈ ។ សម័យខាងក្រោយ លោកស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បានទូវសទ្ធា ក៏បួស ចម្រើនវិបស្សនា សម្រេចអរហត្ត ជាអ្នកជំនាញក្នុងបុព្វេនិវាសញ្ញាណ ។ លោករឭកដល់ទីដែលខ្លួនកើតទៅតាមលំដាប់ បានឃើញត្រឹមតែអចិត្តកបដិសន្ធិក្នុងអសញ្ញីភព ។ ក្នុងលំដាប់បន្ទាប់អំពីនោះ ក៏មិនឃើញបវត្តិ ៥០០ ជាតិ ឃើញចុតិក្នុងភពចុងក្រោយ រឭកថា នេះអ្វីហ្ន៎ ក៏កំណត់បានថា ជាអសញ្ញីភព ដោយការគិត ព្រះសាស្តាទ្រង់ធ្វើហេតុនេះ ឲ្យជាអត្ថុប្បត្តិហេតុទ្រង់ស្ថាបនាព្រះថេរៈទុក ក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវកដែលរឭកដល់ខន្ធ ដែលធ្លាប់អាស្រ័យនៅក្នុងជាតិមុន ដោយប្រការដូច្នេះ ៕

## អដ្ឋកថា សូត្រទី ៩ ចប់

# អដ្ឋកថា សូត្រទី ៦

## ប្រវត្តិ ព្រះឧបាលិត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៦ ដូចតទៅនេះ ពាក្យថា **វិនយធរានំ យទិទំ ឧបាលិ** លោកសម្តែងថា ព្រះឧបាលិត្ថេរ ជាកំពូលនៃភិក្ខុសាវក ដែលទ្រទ្រង់វិន័យ បានឮថា ព្រះថេរៈទទួលកម្មដ្ឋានក្នុងសម្នាក់ព្រះតថាគត មួយអង្គឯង ចម្រើនវិបស្សនាហើយ សម្រេចព្រះអរហត្ត រៀនវិនយបិដក ក្នុងសម្នាក់ព្រះតថាគតមួយអង្គឯង ពោលរឿងទាំង ៣ គឺរឿងព្រះភារុកច្ឆកៈ រឿងព្រះអជ្ជុកៈ និងរឿងព្រះកុមារកស្សបៈ ប្រៀបធៀបជាមួយនឹងព្រះសព្វញ្ញុ-តញ្ញាណ ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃភិក្ខុសាវកអ្នក ទ្រទ្រង់វិន័យ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ ដូច្នេះ

បានឮថា ព្រះថេរៈនេះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ បានកើតនៅ ក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ថ្ងៃ មួយ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ នៃ ភិក្ខុសាវកអ្នកទ្រទ្រង់វិន័យ បំពេញកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែង នោះ លោកធ្វើកុសលដរាបអស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងត្រកូល ខ្ញុំព្រះកេស មាតាបិតា ដាក់ ឈ្មោះថា ឧបាលិកុមារ ។ លោកជាអ្នកតាក់តែងព្រះកាយរបស់ក្សត្រទាំង ៦ អង្គ ។ កាលព្រះតថាគតប្រថាប់នៅត្រង់អនុបិយអម្ពវ័ន ចេញបួស មួយ អន្លើជាមួយក្សត្រ ៦ អង្គ ដែលកំពុងចេញសាងព្រះផ្នួស ។ ឯការចេញ

បព្វជ្ជារបស់លោក មកហើយក្នុងព្រះបាលី ។ លោកបព្វជ្ជាឧបសម្បទាហើយ សូមឲ្យព្រះតថាគតប្រៀនប្រដៅកម្មដ្ឋាន ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់អនុញ្ញាតឲ្យខ្ញុំព្រះអង្គនៅព្រៃចុះ ។ ព្រះសាស្ដាត្រាស់ថា ម្នាលភិក្ខុ បើអ្នកនៅព្រៃ នឹងចម្រើនតែធុរៈតែម្យ៉ាង តែបើអ្នកនៅក្នុងសម្នាក់តថាគត វាសធុរៈ គឺការអប់រំ គន្ថធុរៈ គឺការរៀនសូត្រ ក៏នឹងបរិបូណ៌ ។ ព្រះថេរៈទទួលព្រះតម្រាស់របស់ព្រះសាស្ដាហើយ ចម្រើនវិបស្សនា មិនយូរប៉ុន្មានក៏សម្រេចអរហត្ត គ្រានោះ ព្រះសាស្ដាទ្រង់ឲ្យលោករៀនព្រះវិនយបិដកទាំងអស់ ដោយព្រះអង្គឯង ។ ចំណេរកាលតមក លោកវិនិច្ឆ័យក្ដី ៣ រឿង ដែលពោលហើយខាងដើម ព្រះសាស្ដាប្រទានសាធុការទទួលយល់ព្រមក្នុងរឿងនីមួយៗ ដែលលោកវិនិច្ឆ័យហើយ ធ្វើរឿងទាំង ៣ ដែលលោកវិនិច្ឆ័យហើយ ឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាព្រះថេរៈក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវក ដែលទ្រទ្រង់វិន័យ ដូច្នេះ ។៚

## អដ្ឋកថាសូត្រទី ៦ ចប់

# អដ្ឋកថា សូត្រទី ៧

# ប្រវត្តិ ព្រះនន្ទកត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៧ ដូចតទៅនេះ ពាក្យថា **ភិក្ខុនោ-វាទកានំ** បានដល់ អ្នកឲ្យឱវាទដល់ភិក្ខុនី ។ ពិតហើយ ព្រះថេរៈនេះ កាលពោលធម្មកថា ក៏ធ្វើភិក្ខុនី ៥០០ រូប ឲ្យសម្រេចអរហត្ត ក្នុងការប្រជុំត្រឹមតែម្តង ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលរបស់ភិក្ខុសាវក ដែលទូន្មានភិក្ខុនី ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ ដូច្នេះថា

ព្រះថេរៈរូបនេះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ លោកកើតឡើងក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាស្ថាបនាភិក្ខុមួយរូប ក្នុងតំណែងជាឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវក ដែលឲ្យឱវាទដល់ភិក្ខុនី ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នានូវតំណែងនោះ លោកធ្វើកុសលជាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស លុះដល់ពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងត្រកូលមួយ នាក្រុងសាវត្ថី ចម្រើនវ័យហើយ ស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា បាននូវសទ្ធា ក៏បួសក្នុងសម្នាក់ព្រះសាស្តា ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ជាអ្នកជំនាញក្នុងបុព្វេនិវាសញ្ញាណ កាលបរិស័ទ ៤ មកដល់ហើយ លោកអាចដឹងចិត្តរបស់បរិស័ទបានទាំងអស់ ហើយពោលធម្មកថា ព្រោះដូច្នោះ ទើបលោកឈ្មោះថា ធម្មកថិកនន្ទកៈ ។ សូម្បីព្រះតថាគត កាលសាកិយកំលោះ ៥០០ អង្គ ចេញបួសអំពីត្រកូលព្រោះរឿងម្ជុង កើតនូវការអផ្សុក លាសិក្ខា

ទ្រង់នាំពួកភិក្ខុសាកិយៈទាំងនោះទៅកាន់ស្រះកុណាល ទ្រង់ជ្រាបថា ភិក្ខុទាំងនោះសង្វេគ ព្រោះត្រាស់រឿងកុណាលជាតក ទើបត្រាស់កថា ពោលដោយសច្ចៈ ៤ ឲ្យលោកតាំងនៅក្នុងសោតាបត្តិផល តមក ត្រាស់មហាសមយសូត្រ ឲ្យលោកសម្រេចអរហត្ត ដែលជាអគ្គផល ។ ភរិយានៃព្រះថេរៈទាំងនោះ មានចិត្តដូចគ្នាតែម្យ៉ាងថា ថ្ងៃនេះ អញធ្វើអ្វីក្នុងទីនេះ ទើបនាំគ្នាទៅរកព្រះមហាបជាបតិថេរី សូមបព្វជ្ជា ។ ភរិយាទាំង ៥០០ បានបំពេញបព្វជ្ជាឧបសម្បទាក្នុងសម្នាក់ព្រះថេរីហើយ ។ តែក្នុងអតីតជាតិ ភរិយាទាំងអស់បានជាបាទបរិចារិការបស់ព្រះនន្ទកត្ថេរ កាលតាំងនៅក្នុងអត្តភាពជាព្រះរាជា សម័យនោះ ព្រះសាស្តាត្រាស់ប្រាប់ថា ពួកភិក្ខុចូរទូន្មានភិក្ខុនី ។ ព្រះថេរៈ កាលដល់វារៈ ក៏ដឹងថា ភិក្ខុនីទាំងនោះ ជាបាទបរិចារិការបស់ខ្លួនក្នុងភពមុន ទើបគិតថា ភិក្ខុដែលបានបុព្វេនិវាសញ្ញាណ ឃើញអាត្មាអញអង្គុយកណ្តាលភិក្ខុនីសង្ឃ ក៏នឹងទាញយកឧបមាហេតុជាដើមមកពោលពិចារណាហេតុនេះហើយ គប្បីពោលបញ្ជិតបញ្ជៀងថា លោកម្ចាស់នន្ទកៈមិនព្រមលះពួកស្រីស្នំមកទល់នឹងថ្ងៃនេះ លោកមានពួកស្រីស្នំចោមរោម រុងរឿង ព្រោះហេតុនោះ ទើបលោកមិនទៅឯង បញ្ជូនភិក្ខុដទៃទៅជំនួស ។ តែភិក្ខុនី ៥០០ រូបនោះបំណងចំពោះឱវាទរបស់ព្រះថេរៈ ដោយហេតុនេះ គ្រាដល់វារៈរបស់លោក ទើបព្រះមានព្រះភាគទ្រង់មិនបញ្ជូនភិក្ខុរូបដទៃទៅជំនួសត្រាស់នឹងលោកថា អ្នកចូរទៅឯង ដើម្បីទូន្មានភិក្ខុនីសង្ឃ លោកមិនអាចជំទាស់ព្រះតម្រាស់របស់ព្រះសាស្តាបាន កាលដល់វារៈរបស់ខ្លួន ទើបឲ្យ

ឱវាទភិក្ខុនីសង្ឃ ក្នុងថ្ងៃ ១៤ កើត ឲ្យភិក្ខុនីគ្រប់រូបតាំងនៅក្នុងសោតាបត្តិ-ផល ដោយធម្មទេសនាដែលប្រដាប់ដោយសឡាយតនៈ ។ ភិក្ខុនីទាំងនោះត្រេកអរចំពោះព្រះធម្មទេសនារបស់ព្រះថេរៈ នាំគ្នាទៅកាន់សម្នាក់ព្រះសាស្តាទូលប្រាប់គុណដែលខ្លួនបាន ព្រះសាស្តាទ្រង់ពិចារណាថា អ្នកណាសម្តែងធម៌ទើបភិក្ខុនីទាំងនោះ សម្រេចមគ្គផលខ្ពស់ឡើងៗ ។ ទ្រង់ឃើញថា ភិក្ខុនីទាំង ៥០០ រូប ស្តាប់ធម្មទេសនារបស់នន្ទកៈទៀត ក៏នឹងសម្រេចអរហត្ត ។ ស្អែកឡើង ទើបទ្រង់បញ្ជូនភិក្ខុនីទាំងនោះទៅ ដើម្បីស្តាប់ធម្មទេសនាក្នុងសម្នាក់ព្រះថេរៈនោះឯង ។ ស្អែកឡើង ភិក្ខុនីទាំងនោះស្តាប់ធម៌ហើយ ក៏សម្រេចអរហត្តទាំងអស់ ។ ថ្ងៃនោះ កាលដែលភិក្ខុនីទាំងនោះ មកគាល់ព្រះមានព្រះភាគ ទ្រង់ដឹងថា ធម្មទេសនាមានផល ទើបត្រាស់ថា កាលពីម្សិលមិញ ធម្មទេសនារបស់នន្ទកៈ ដូចព្រះចន្ទ ១៤ កើត ថ្ងៃនេះដូចព្រះចន្ទ ១៥ កើត ហើយទ្រង់ធ្វើហេតុនោះឯងឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវកខាងឲ្យឱវាទភិក្ខុនីដូច្នេះ ៕

## អដ្ឋកថាសូត្រទី ៧ ចប់

# អដ្ឋកថា សូត្រទី ៨
# ប្រវត្តិ ព្រះនន្ទត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៨ ដូចតទៅនេះ បទថា **ឥន្ទ្រិយេសុ គុត្តទ្វារានំ** លោកសម្តែងថា ព្រះនន្ទត្ថេរ ជាកំពូលនៃពួកភិក្ខុដែលជាសាវក ខាងគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយ ៦ ។ សេចក្តីពិត សាវកទាំងឡាយរបស់ព្រះសាស្តា ឈ្មោះថា មិនគ្រប់គ្រងទ្វារ មិនមាន តែព្រះនន្ទ សម្លឹងមើលទិសណាមួយ ក្នុងទិសទាំង ១០ មិនមែនសម្លឹងមើលទិសនោះៗ ដោយប្រាសចាកសតិសម្បជញ្ញៈទេ ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកសាវកដែលគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ក្នុងបញ្ហាកម្មរបស់លោកមានអនុសន្ធិដូចតទៅនេះថា

ព្រះថេរៈ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ លោកបដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ចម្រើនវ័យហើយ កំពុងស្តាប់ធម៌ក្នុងសម្នាក់ព្រះមុនី ឃើញព្រះសម្ពុទ្ធទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ នៃពួកភិក្ខុសាវក ខាងគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ ធ្វើកុសលដរាបអស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាបជាបតិគោតមី ក្នុងក្រុងកបិលពស្តុ ។ គ្រានោះ ក្នុងថ្ងៃដាក់ព្រះនាម លោកធ្វើពួកព្រះញាតិឲ្យត្រេកអរ ព្រោះហេតុនោះ ទើបពួកញាតិថ្វាយព្រះនាមរបស់លោកថា នន្ទកុមារ ។ ព្រះមហាសត្វទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ប្រកាសធម្មចក្រដ៏ប្រសើរ ទ្រង់អនុគ្រោះលោក ទ្រង់ចេញអំពីក្រុងរាជគ្រឹះ ទៅកាន់

ក្រុងកបិលពស្តុ ទ្រង់ធ្វើពុទ្ធបិតា ឲ្យតាំងនៅក្នុងសោតាបត្តិផល ដោយទ្រង់គាល់គ្រាដំបូងប៉ុណ្ណោះ ស្អែកឡើង ទ្រង់យាងទៅព្រះរាជនិវេសន៍របស់ព្រះពុទ្ធបិតា ប្រទានឱវាទដល់ព្រះមាតារបស់ព្រះរាហុល សម្តែងធម៌ដល់ជនក្រៅអំពីនោះ លុះស្អែកឡើង គ្រាអាវាហមង្គលដង្ហែនន្ទកុមារចូលរោងអភិសេកកំពុងប្រព្រឹត្តទៅ ព្រះមានព្រះភាគទ្រង់យាងទៅកាន់និវេសន៍របស់នន្ទកុមារនោះ ទ្រង់ឲ្យនន្ទកុមារកាន់បាត្រ ទ្រង់បែរព្រះភក្ត្រទៅកាន់ព្រះវិហារ ដើម្បីឲ្យនន្ទបួស ។ មង្គលអភិសេកក៏រារាំងនន្ទកុមារនោះមិនបាន កាលនន្ទកុមារកាន់បាត្រ យាងតាមព្រះមានព្រះភាគ នាងជនបទកល្យាណីជាកូនក្រមុំ ក៏ឡើងប្រាសាទជាន់លើ បើកសីហបញ្ជរ ស្រែកប្រាប់ថា បពិត្រអយ្យបុត្រ សូមទ្រង់ប្រញាប់ត្រឡប់មក ។ នន្ទកុមារនោះបានឮសំឡេងនាង ក៏បានសម្លឹងមើលដោយរំជួលចិត្ត មិនអាចធ្វើនិមិត្តឆ្លើយឆ្លងបានតាមគាប់ចិត្ត ព្រោះគោរពក្នុងព្រះសាស្តា ។ ដោយហេតុនោះ ទើបនន្ទកុមារក្តៅក្រហាយចិត្ត ។ ខណៈនោះ នន្ទកុមារគិតតែម្យ៉ាងថា ព្រះមុនី នឹងឲ្យអញត្រឡប់ត្រង់នេះ ព្រះសាស្តានឹងឲ្យអញត្រឡប់ត្រង់នេះ ។ ព្រះសាស្តាទ្រង់ក៏នាំទៅកាន់វិហារឲ្យបព្វជ្ជា ។ នន្ទកុមារបានបំពេញបព្វជ្ជាហើយ ក៏កម្ចាត់មិនបាន បានត្រឹមតែនៅស្ងៀម ។ តាំងអំពីថ្ងៃបព្វជ្ជាហើយ ក៏នៅតែរឭកដល់វាចារបស់នាងជនបទកល្យាណីនោះឯង ។ ខណៈនោះ ហាក់ដូចនាងជនបទកល្យាណីនោះមកឈរមិនឆ្ងាយ នន្ទកុមារនោះត្រូវសេចក្តីអផ្សុក ចង់លាសិក្ខាគ្របសង្កត់ខ្លាំងឡើងៗ ក៏ដើរទៅបន្តិច កាលដើរឆ្លងគុម្ពឈើ ឬដង្កត់ឈើ ក៏ហាក់ដូច

ព្រះទសពលមកប្រាកដឈរខាងមុខ លោកមានសភាពដូចរោមមាន់ដែលដុត ដោយគំនរភ្លើង ទើបត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា ននូនេះប្រមាទពន់ពេក មិនអាចរម្ងាប់ការ អផ្សុកចង់សឹកបាន ទើបធ្វើការរម្ងត់ការក្តៅនៃចិត្តរបស់លោក ។ ពេលនោះ ក៏ត្រាស់នឹងននូថា ម្នាលននូ អ្នកចូរមកអាយ យើងនឹងទៅកាន់ទេវលោក ។ ននូទូលថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គនឹងទៅកាន់ស្ថានទីដែលពួកភិក្ខុ អ្នកមានឫទ្ធិទៅបានដូចម្តេច ។ ព្រះសាស្តាត្រាស់ឆ្លើយថា អ្នកចូរធ្វើចិត្តគិត នឹងទៅតែម្យ៉ាង ទៅហើយនឹងឃើញ ។ ព្រះននូនោះ និមន្តចារិកទៅកាន់ ទេវលោកជាមួយព្រះតថាគត ដោយអានុភាពព្រះទសពល សម្លឹងមើល ទេវនិវេសន៍របស់សក្កទេវរាជ ក៏ឃើញទេពអប្សរ ៥០០ ព្រះសាស្តាទ្រង់ ឃើញននូគ្គរសម្លឹងមើលដោយសុភនិមិត្ត ទើបត្រាស់សួរថា ម្នាលននូ ទេពអប្សរទាំងនេះ ឬនាងជនបទកល្យាណីដែលជាទីពេញចិត្តរបស់អ្នក ។ ននូទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងជនបទកល្យាណី បើប្រៀបធៀប នឹងទេពអប្សរទាំងនេះ ក៏ប្រាកដដូចជាពានរញីដែលកំបុតត្រចៀក និងច្រមុះ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលននូ ទេពអប្សរទាំងនេះបានមិនលំបាកឡើយ សម្រាប់អ្នកធ្វើសមណធម៌ ។ ព្រះថេរៈទូលថា បពិត្រព្រះអង្គដ៏ចម្រើន បើ ព្រះមានព្រះភាគ ទ្រង់ធានាដល់ខ្ញុំព្រះអង្គៗ នឹងធ្វើសមណធម៌ ។ ព្រះមាន ព្រះភាគត្រាស់ថា ម្នាលននូ អ្នកចូរដាក់ចិត្តធ្វើសមណធម៌ចុះ បើអ្នកធ្វើ កាលកិរិយា ដូចសត្វដែលមានបដិសន្ធិ តថាគតក៏ធានាថា នឹងបាននាងទេព-

អប្សរទាំងនេះ ។

ព្រះសាស្តា ចារិកទៅកាន់ទេវលោកតាមពុទ្ធអធ្យាស្រ័យហើយ ទើបយាងត្រឡប់មកវត្តជេតពនវិញ ។ តាំងអំពីនោះមក ព្រះនន្ទត្ថេរធ្វើសមណ-ធម៌ទាំងឡាយ ទាំងពេលយប់ ពេលថ្ងៃ ព្រោះចង់បានស្រីទេពអប្សរ ។ ព្រះសាស្តាទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា លំនៅរបស់នន្ទ ពួកអ្នកចូរត្រាច់និយាយក្នុងទីនោះៗ ថា បានឮថា ភិក្ខុមួយរូប ឲ្យព្រះទសពល ទទួលធានាហើយ ទើបធ្វើសមណធម៌ ព្រោះចង់បានស្រីទេពអប្សរទាំងឡាយ ។ ភិក្ខុទាំងនោះទទួលព្រះពុទ្ធតម្រាស់ហើយ ក៏ត្រាច់ពោលថា បានឮថា លោកម្ចាស់នន្ទ ជាកូនឈ្នួល បានឮថា លោកម្ចាស់នន្ទ ត្រូវព្រះមានព្រះភាគទិញមកប្រព្រឹត្តព្រហ្មចរិយៈ ព្រោះចង់បានស្រីទេពអប្សរទាំងឡាយ បានឮថា ព្រះមានព្រះភាគទ្រង់ធានាលោកម្ចាស់នន្ទនោះ ដែលនឹងបានទេពអប្សរ ៥០០ ដែលមានជើងពណ៌ដូចជើងព្រាប ។ ភិក្ខុទាំងនោះឈរក្នុងទីក្បែរៗ នន្ទ លុះបានឃើញបានឮ ក៏ត្រាច់ពោលទៅ ។ ព្រះនន្ទត្ថេរបានដឹងរឿងនោះ គិតថា ភិក្ខុទាំងនេះ មិននិយាយដល់អ្នកដទៃ និយាយប្រារព្ធដល់អញ ការធ្វើរបស់អញមិនត្រឹមត្រូវហ្ន៎ ក៏គិតបញ្ច្រាសមកវិញ ហើយចម្រើនវិបស្សនា សម្រេចអរហត្ត ។ ខណៈដែលលោក សម្រេចអរហត្តនោះឯង ទេវតាមួយអង្គក៏ទូលរឿងនោះដល់ព្រះមានព្រះភាគ ។ ព្រះមានព្រះភាគទ្រង់បានជ្រាបដោយព្រះអង្គឯង ។ ស្អែកឡើង ព្រះនន្ទត្ថេរចូលទៅគាល់ព្រះមានព្រះភាគ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ធានាខ្ញុំព្រះអង្គ ដើម្បីបានស្រីទេពអព្សរ ៥០០

មានជើងដូចជើងព្រាបឯណា ខ្ញុំព្រះអង្គសូមដោះព្រះមានព្រះភាគ អំពីបដិស្សវៈ គឺការទទួលពាក្យនោះ ។ រឿងកើតឡើងដូចពោលមក ដូច្នេះ ។ បន្ទាន់មក ក្នុងកាលជាខាងក្រោយ ព្រះសាស្តាប្រថាប់នៅក្នុងជេតពនមហាវិហារ ទ្រង់ស្ថាបនាព្រះថេរៈទុកក្នុងតំណែងឯតទគ្គៈ គឺជាកំពូលនៃពួកភិក្ខុសាវក ដែលគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដូច្នេះឯង ។៚

អដ្ឋកថា សូត្រទី ៨ ចប់

# អដ្ឋកថា សូត្រទី ៩

# ប្រវត្តិ ព្រះមហាកប្បិនត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ៩ ដូចតទៅនេះ បទថា **ភិក្ខុឱវាទកានំ** លោកសម្តែងថា ព្រះមហាកប្បិនត្ថេរ ជាកំពូលនៃពួកភិក្ខុសាវកអ្នកឲ្យឱវាទភិក្ខុ ។ បានឮថា ព្រះថេរៈនេះ ពោលធម្មកថា ក្នុងការប្រជុំតែម្តងប៉ុណ្ណោះ ក៏ធ្វើភិក្ខុ ១០០០ រូបឲ្យសម្រេចអរហត្ត ព្រោះដូច្នោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុសាវក អ្នកឲ្យឱវាទដល់ភិក្ខុ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ដូច្នេះថា

ពិតហើយ ព្រះថេរៈរូបនេះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ លោកកើតឡើងក្នុងត្រកូលមួយ នាក្រុងហង្សវតី ។ បន្ទាប់មក កំពុងស្តាប់ធម្មកថា

របស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈដែលជាកំពូលនៃពួកភិក្ខុសាវក ខាងឲ្យឱវាទដល់ភិក្ខុ ធ្វើកុសលឲ្យក្រៃលែងឡើង ទើបប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស ។ ក្នុងកាលព្រះសម្មាសម្ពុទ្ធព្រះនាមកស្សបៈ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងពារាណសី ជាប្រធាននៃគណៈរបស់បុរស ១ ពាន់នាក់ សាងបរិវេណធំ ប្រដាប់ដោយបន្ទប់ ១ ពាន់ ។ ជនទាំងអស់នោះ ធ្វើកុសលដរាបដល់អស់ជីវិត លើកកប្បិនឧបាសក ឲ្យជាប្រធាន មួយអន្លើដោយបុត្រភរិយា កើតហើយក្នុងទេវលោក វិលវល់ក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ។ គ្រានោះ មុនព្រះសាស្តានៃយើងកើតឡើង កប្បិននេះបដិសន្ធិក្នុងរាជនិវេសន៍ ក្នុងនគរកុក្កុដវតី ក្នុងបច្ចន្តប្រទេស ។ បរិស័ទក្រៅអំពីនោះ កើតក្នុងត្រកូលអមាត្យ ក្នុងនគរនោះឯង ។ បណ្តាអ្នកទាំងនោះ កប្បិនកុមារ កាលព្រះរាជបិតាសោយទិវង្គតទៅ ក៏លើកស្វេតច្ឆត្រ សោយរាជ្យជាព្រះរាជាព្រះនាមថា កប្បិន ។ ស្ត្រីដែលជាមេផ្ទះរបស់ព្រះអង្គ កាលសាងកល្យាណកម្មក្នុងជាតិមុន ក៏កើតក្នុងរាជត្រកូលមានជាតិ និងភោគសម្បត្តិប្រហាក់ប្រហែលគ្នា ជាព្រះអគ្គមហេសីរបស់ព្រះមហាកប្បិនរាជនោះ ។ តែព្រោះព្រះនាងមានព្រះឆវីវណ្ណដូចផ្កានោរាង ទើបមានព្រះនាមថា អនោជាទេវី ។ ព្រះមហាកប្បិនទ្រង់ដាក់ព្រះហឫទ័យក្នុងសុតៈ តើនអំពីព្រលឹម ទ្រង់បញ្ជូនទូតចេញអំពីទ្វារទាំង ៤ ដោយព្រះតម្រាស់ថា បើពួកអ្នកជួបជនជាពហូសូត ទ្រទ្រង់នូវសុតៈ ក្នុងទីណា ចូរ

ត្រឡប់អំពីទីនោះ ហើយមកប្រាប់ដល់ខ្ញុំ ដូច្នេះ ។

សម័យនោះ ព្រះសាស្តានៃយើងកើតក្នុងលោកហើយ ទ្រង់អាស្រ័យក្រុងសាវត្ថី ប្រថាប់នៅ ។ ក្នុងពេលនោះ ពួកឈ្មួញ អ្នកក្រុងសាវត្ថី ទទួលទំនិញដែលកើតឡើងក្នុងក្រុងសាវត្ថី ទៅកាន់នគរនោះ ដាក់ទំនិញទុកហើយ ក៏កាន់បណ្ណាការបំណាំងគាល់ព្រះរាជា ។ ទៅដល់ទ្វារព្រះរាជនិវេសន៍ បានដឹងថា ព្រះរាជាយាងទៅកាន់ព្រះរាជឧទ្យាន ទើបទៅឯព្រះរាជឧទ្យាន ឈរក្បែរទ្វារ ប្រាប់អ្នកយាមទ្វារព្រះរាជឧទ្យាន ។ កាលទូលឲ្យទ្រង់ជ្រាបហើយ ព្រះរាជាឲ្យចូលគាល់ ។ ពួកឈ្មួញថ្វាយបណ្ណាការហើយ ឈរថ្វាយបង្គំ ព្រះរាជាត្រាស់សួរថា នែបា ពួកអ្នកនាំគ្នាមកអំពីណា ។ ពួកឈ្មួញក្រាបទូលថា ទូលបង្គំមកអំពីក្រុងសាវត្ថី ។ ព្រះរាជាត្រាស់សួរថា ក្នុងដែនទាំងនោះ មានអាហាររកបានងាយឬ ព្រះរាជាទ្រទ្រង់ធម៌ដែរឬ ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះអង្គ យ៉ាងនោះឯង ។ ព្រះរាជាត្រាស់សួរថា ក្នុងស្រុកនិគមរបស់អ្នក មានដំណឹងចម្លែកអ្វីខ្លះឬទេ ។ ពួកឈ្មួញក្រាបទូលថា បពិត្រព្រះអង្គ មាន តែមិនអាចក្រាបទូលបានទាំងមាត់ដែលមិនស្អាត ។ ទើបព្រះរាជាប្រទានទឹកដោយព្រះកុណ្ឌីមាស ។ ឈ្មួញទាំងនោះខ្ពុរមាត់ហើយ បែរមុខទៅរកព្រះទសពលផ្គងអញ្ជលី ក្រាបទូលថា បពិត្រសម្មតិទេព ក្នុងស្រុករបស់ទូលបង្គំ ព្រះពុទ្ធរតនៈកើតឡើងហើយ ។ គ្រាន់តែស្តាប់ពាក្យថា **ពុទ្ធោ** ប៉ុណ្ណោះ ព្រះរាជាក៏ទ្រង់កើតបីតិ ជ្រួតជ្រាបពេញព្រះវរកាយ ។ បន្ទាប់អំពីនោះត្រាស់ថា នែបា ពួកអ្នកពោលថា **ពុទ្ធោ** ឬ ។

ពួកឈ្មួញក្រាបទូលថា បពិត្រព្រះអង្គ ពួកទូលព្រះបង្គំពោលថា **ពុទ្ធោ** ។ ទ្រង់ឲ្យពួកឈ្មួញពោលយ៉ាងនោះអស់ ៣ ដង ។ បទថា **ពុទ្ធោ** មិនមានប្រមាណ បុគ្គលណាមិនអាចធ្វើឲ្យមានប្រមាណបានឡើយ ។ ព្រះរាជាទ្រង់ជ្រះថ្លាក្នុងបទថា ព្រះពុទ្ធរតនៈកើតឡើងហើយនោះ ក៏ប្រទានទ្រព្យមួយសែនហើយត្រាស់សួរថា មានដំណឹងដទៃទៀតឬទេ ។ ពួកឈ្មួញក្រាបទូលថា បពិត្រសម្មតិទេព ព្រះធម្មរតនៈកើតឡើងហើយ ។ ទ្រង់ស្តាប់ដំណឹងនោះហើយ ទ្រង់កាន់យកប្តេជ្ញាយ៉ាងនោះដូចគ្នា ព្រះរាជទានទ្រព្យមួយសែនទៀតហើយត្រាស់សួរថា មានដំណឹងដទៃៗ ទៀតដែរឬទេ ។ ពួកឈ្មួញក្រាបទូលថា បពិត្រទេវៈ ព្រះសង្ឃរតនៈកើតឡើងហើយ ។ ទ្រង់ស្តាប់ដំណឹងនោះហើយ ទ្រង់កាន់យកប្តេជ្ញាយ៉ាងនោះដូចគ្នា ព្រះរាជទានទ្រព្យមួយសែន ទ្រង់សរសេរលិខិតដែលព្រះរាជទានទ្រព្យក្នុងចុតហ្មាយ បញ្ជូនទៅដោយព្រះតម្រាស់ថា នែបា ពួកអ្នកចូរទៅកាន់សម្នាក់របស់ព្រះរាជទេវីចុះ ។ កាលពួកឈ្មួញទៅហើយ ត្រាស់សួរពួកអមាត្យថា នែបា ព្រះពុទ្ធកើតឡើងក្នុងលោកហើយ ពួកអ្នកនឹងធ្វើដូចម្តេច ។ ពួកអមាត្យទូលសួរថា បពិត្រសម្មតិទេព ចុះព្រះអង្គទ្រង់ធ្វើដូចម្តេច ។ ព្រះរាជាត្រាស់ថា ខ្ញុំនឹងបួស ។ ពួកអមាត្យក្រាបទូលថា ទូលបង្គំនឹងបួសទាំងអស់ ។ ក៏មិននាំគ្នាជាប់ជំពាក់ក្នុងផ្ទះ ឬទ្រព្យសម្បត្តិ នាំគ្នាឡើងផែលសេះ បំបោលចេញទៅ ។

ពួកឈ្មួញទៅគាល់ព្រះនាងអនោជាទេវី បង្ហាញលិខិត ។ ព្រះនាងអានលិខិតនោះហើយ ត្រាស់សួរថា នែបា ព្រះរាជាប្រទានកហាបណៈដ៏ច្រើន

ដល់ពួកអ្នកៗ ធ្វើអ្វីដល់ព្រះរាជា ។ ពួកឈ្នួញក្រាបទូលថា បពិត្រព្រះទេវី ទូលបង្គំនាំដំណឹងជាទីស្រឡាញ់មកថ្វាយ ។ ព្រះនាងត្រាស់សួរថា ពួកអ្នកអាចឲ្យខ្ញុំស្តាប់ដំណឹងនោះបានឬទេ ។ ពួកឈ្នួញក៏ក្រាបទូលថា បពិត្រព្រះទេវី បីមិនអាច តែពួកទូលបង្គំមិនអាចក្រាបទូលទាំងមាត់មិនស្អាតបានទេ ។ ទើបព្រះនាងព្រះរាជទានទឹក ដោយព្រះកុណ្ឌីមាស ។ ឈ្នួញទាំងនោះខ្ពុរមាត់ហើយ ក៏ក្រាបទូលទំនងដូចទូលដល់ព្រះរាជាមកហើយ ។ ព្រះនាងទ្រង់ក៏កើតនូវបាមោជ្ជ ឲ្យពួកឈ្នួញទទួលប្តេជ្ញា ៣ ដង ក្នុងបទនីមួយៗ ដោយន័យនោះដូចគ្នា ។ ព្រះរាជទានទ្រព្យមួយបទ ៣ សែន រួមជាទ្រព្យ ៩ សែន ។ ពួកឈ្នួញបានទ្រព្យទាំងអស់ដល់ទៅ ១២ សែន ។ គ្រានោះ ព្រះនាងត្រាស់សួរពួកឈ្នួញថា ព្រះរាជាទ្រង់យាងទៅណា ។ ពួកឈ្នួញក្រាបទូលថា បពិត្រព្រះទេវី ព្រះរាជាទ្រង់ចេញទៅ ទ្រង់បំណងនឹងបួស ។ ព្រះនាងទ្រង់បញ្ជូនពួកឈ្នួញទៅ ដោយព្រះតម្រាស់ថា នែបា បើដូច្នោះ ពួកអ្នកចូរត្រឡប់ទៅចុះ ឲ្យហៅពួកមេផ្ទះរបស់អមាត្យដែលទៅជាមួយព្រះរាជា មកហើយ សួរថា ពួកនាងដឹងទីដែលពួកស្វាមីរបស់ពួកនាងទៅឬទេ ។ ស្ត្រីទាំងនោះក្រាបទូលថា បពិត្រព្រះនាង ពួកខ្ញុំម្ចាស់មិនជ្រាបឡើយ ។ ពួកស្វាមីខ្ញុំម្ចាស់ទៅលេងឧទ្យានជាមួយព្រះរាជា ។ ព្រះនាងត្រាស់ថា នែនាងពួកគេទៅហើយក្នុងឧទ្យាននោះ បានដឹងដំណឹងថា ព្រះពុទ្ធកើតឡើងហើយ ព្រះធម៌កើតឡើងហើយ ព្រះសង្ឃកើតឡើងហើយ ក៏បំណងនឹងបួសក្នុងសម្នាក់ព្រះទសពល ពួកអ្នកនឹងធ្វើដូចម្តេច ។ ស្ត្រីទាំងនោះក្រាបទូលថា

បពិត្រព្រះនាង ចុះព្រះនាងបំណងនឹងធ្វើដូចម្តេច ។ ព្រះទេវីត្រាស់ឆ្លើយថា ខ្ញុំក៏នឹងបួស ។ ស្រ្តីទាំងនោះក្រាបទូលថា បើដូច្នោះ ពួកខ្ញុំម្ចាស់ក៏នឹងបួស ។ ទាំងអស់គ្នាក៏ទឹមរថ នាំគ្នាចេញទៅ ។

ឯព្រះរាជា ដល់ច្រាំងស្ទឹងគង្គា មួយអន្លើនឹងអមាត្យ ១០០០ នាក់ ។ ខណៈនោះ ស្ទឹងគង្គាពេញប្រៀបដោយទឹក ឃើញស្ទឹងគង្គានោះហើយ ក៏នាំគ្នាត្រិះរិះ និងអធិដ្ឋានថា ស្ទឹងគង្គាពេញប្រៀបដោយទឹក ជេរជាសដោយត្រីកាច មិនមានទាសៈ ឬមនុស្សដែលមកជាមួយពួកយើង ដែលគប្បីឲ្យទូក ឬក្បូនដល់ពួកយើងក្នុងទីនេះ ។ តែធម្មតាព្រះគុណទាំងឡាយរបស់ព្រះសាស្តាផ្សាយទៅខាងក្រោមដល់អវិចីមហានរក ខាងលើដល់ភវគ្គព្រហ្ម បើព្រះមុនីទ្រង់ជាព្រះសម្មាសម្ពុទ្ធសោត សូមខ្នងក្រចកជើងសេះទាំងនេះ កុំសើមដល់ទឹកឡើយ ហើយក៏បញ្ឆោសេះឲ្យឆ្លងទឹក ។ ត្រឹមតែខ្នងជើងសេះមួយ ក៏មិនសើមដោយទឹកឡើយ ។ ដល់ត្រើយនាយ ដូចទៅដោយរាជមាគ៌ា ហើយក៏ដល់មហានទីដទៃៗ ខាងមុខ ។ ព្រះរាជាត្រាស់សួរថា ស្ទឹងទី ២ ឈ្មោះអ្វី ។ ក្រាបទូលថា ឈ្មោះថា នីលវាហិនី មានប្រមាណកន្លះយោជន៍ដោយជម្រៅនិងទទឹង ។ ក្នុងស្ទឹងនោះ មិនមានសច្ចកិរិយាដទៃ នាំគ្នាឆ្លងស្ទឹងដែលមានទទឹងកន្លះយោជន៍ ដោយសច្ចកិរិយានោះ ហើយក៏ដល់មហានទីទី ៣ ឈ្មោះថា ចន្ទភាគា ក៏នាំគ្នាឆ្លងដោយសច្ចកិរិយានោះឯង ។

ក្នុងថ្ងៃនោះ ព្រះសាស្តាទ្រង់ចេញអំពីមហាករុណាសមាបត្តិ ប្រមើលមើលសត្វលោកក្នុងវេលាទៀបភ្លឺ ទ្រង់ឃើញថា ថ្ងៃនេះ ព្រះបាទកប្បិនទ្រង់

លះរាជសម្បត្តិ មានអមាត្យជាបរិវារយាងមកអស់ចម្ងាយផ្លូវ ៣០០ យោជន៍ ដើម្បីបួសក្នុងសម្នាក់តថាគត ទ្រង់ព្រះតម្រិះថា គួរតថាគតធ្វើនូវការទទួលជនទាំងនោះ ទើបទ្រង់បដិបត្តិសរីរកិច្ចអំពីព្រលឹម មានភិក្ខុសង្ឃជាបរិវារយាងបិណ្ឌបាតក្នុងក្រុងសាវត្ថី ក្រោយអំពីសោយភត្តស្រេចហើយ ត្រឡប់មកពីបិណ្ឌបាត មួយព្រះអង្គឯង ហោះទៅប្រថាប់គង់ពត់ភ្នែននាដើមជ្រៃធំដែលមានត្រង់កំពង់ដែលជនទាំងនោះ ឆ្លងត្រង់ប្រាំងស្ទឹងចន្ទភាគា ទ្រង់តាំងសតិចំពោះមុខ បញ្ចេញព្រះពុទ្ធរស្មី ជនទាំងនោះឆ្លងកំពង់នោះ ឃើញព្រះពុទ្ធរស្មីធ្លៀលធ្វាត់ទៅមក ជួបព្រះភក្ត្ររបស់ព្រះទសពល មានព្រះសិរីដូចព្រះចន្ទ ១៥ កើត ក៏ដាក់ចិត្តដោយការឃើញប៉ុណ្ណោះថា ពួកយើងបួសឧទ្ទិសចំពោះព្រះសាស្តាអង្គណា ព្រះសាស្តាអង្គនោះជាសាស្តាអង្គនេះពិត ។ ក៏បង្អោនកាយថ្វាយបង្គំ តាំងអំពីទីដែលជួបព្រះសាស្តា ព្រះរាជាចាប់កព្រះបាទព្រះសាស្តា ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាងមួយអន្ទើជាមួយអមាត្យ ១ ពាន់ ព្រះសាស្តាត្រាស់ធម្មកថាប្រោសជនទាំងនោះ ចប់ទេសនា បុគ្គលទាំងអស់តាំងនៅក្នុងអរហត្ត ហើយសូមបព្វជ្ជា ។ ព្រះសាស្តាទ្រង់ជ្រាបថា ព្រោះជនទាំងនេះថ្វាយចីវរទានក្នុងជាតិមុន ទើបមកទទួលបាត្រចីវររបស់ខ្លួន ហើយទ្រង់លាព្រះហស្តមានពណ៌ដូចមាស ត្រាស់ថា ចូរជាភិក្ខុចុះ ធម៌តថាគតពោលល្អហើយ ពួកអ្នកចូរប្រព្រឹត្តព្រហ្មចរិយៈដើម្បីធ្វើទីបំផុតទុក្ខដោយប្រពៃចុះ ។ ព្រះថេរៈទាំងនោះបព្វជ្ជា និងឧបសម្បទាហើយ នាំគ្នាចោមរោមព្រះសាស្តា ដូចព្រះថេរៈ ១០០ វស្សា ។

ចំណែកព្រះនាងអនោជាទេវី មានរថ ១០០០ ជាបរិវារ យាងដល់ប្រាំងស្ទឹងគង្គា មិនឃើញទូក និងក្បូនដែលនឹងនាំឆ្លងទៅ តែព្រោះព្រះនាងជាអ្នកឈ្លាស ទើបព្រះតម្រិះថា ព្រះរាជាពិតជាទ្រង់ធ្វើសច្ចកិរិយាយាងទៅ ព្រះសាស្តានោះទ្រង់មិនមែនកើតមក ដើម្បីជនទាំងនោះតែម្យ៉ាង បើទ្រង់ជាព្រះសម្មាសម្ពុទ្ធ រថទាំងឡាយរបស់ពួកយើង ចូរកុំលិចទឹក ទើបព្រះនាងបររថលើផ្ទៃទឹកទៅ ។ ត្រឹមតែដុំ និងកង់រថទាំងឡាយក៏មិនបានសើមដោយទឹក ។ សូម្បីស្ទឹងទី ២ ទី ៣ ក៏ព្រះនាងឆ្លងទៅដោយធ្វើសច្ចកិរិយានោះឯង ។ កាលព្រះនាងឆ្លងទៅបានហើយ ឃើញព្រះសាស្តាត្រង់គល់ជ្រៃ ។ សូម្បីព្រះសាស្តា ក៏ទ្រង់ព្រះតម្រិះថា ស្រីទាំងនេះឃើញប្តីរបស់ខ្លួន នឹងកើតឆន្ទរាគៈ ក៏គប្បីធ្វើអន្តរាយចំពោះមគ្គផល ទាំងមិនអាចស្តាប់ធម៌បាន ទើបទ្រង់ធ្វើដោយវិធីការដែលពួកជនទាំងនោះមិនឃើញគ្នានិងគ្នា ។ ស្ត្រីទាំងអស់ឡើងអំពីកំពង់ទឹកហើយ ថ្វាយបង្គំព្រះទសពល ហើយអង្គុយ ។ ព្រះសាស្តាត្រាស់ធម្មកថាប្រោសស្ត្រីទាំងនោះ ។ ចប់ទេសនា ស្ត្រីគ្រប់គ្នាក៏តាំងនៅក្នុងសោតាបត្តិផល ទើបឃើញគ្នានិងគ្នា ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ឧប្បលវណ្ណាចូរមក ព្រះថេរីក៏មក ឲ្យស្រីទាំងអស់បព្វជ្ជា ហើយនាំទៅកាន់សម្នាក់ភិក្ខុនី ។ ព្រះសាស្តាទ្រង់នាំភិក្ខុ ១០០០ រូប យាងទៅកាន់វត្តជេតពនតាមអាកាស ។ គ្រានោះ ព្រះមហាកប្បិនត្រេរដឹងថា កិច្ចរបស់ខ្លួនដល់ទីបំផុតហើយ ក៏ជាអ្នកខ្វល់ខ្វាយតិច ធ្វើកាលវេលាឲ្យកន្លងទៅដោយសុខក្នុងផលសមាបត្តិ នៅព្រៃក្តី នៅត្រង់គល់ឈើក្តី នៅក្នុងផ្ទះស្ងាត់ក្តី ក៏

បន្លឺឧទានរឿយៗ ថា **អហោ សុខំ អហោ សុខំ** ឱ! សុខហ្ន៎ ឱ! សុខហ្ន៎ ភិក្ខុទាំងឡាយក៏កើតការពោលឡើងថា ព្រះមហាកប្បិនត្ថេរ រឭកដល់សុខក្នុងរាជសម្បត្តិ ទើបបន្លឺឧទាន នាំគ្នាទៅក្រាបទូលព្រះតថាគត ព្រះមានព្រះភាគត្រាស់ថា បុត្ររបស់តថាគតប្រារព្ធសុខក្នុងមគ្គ សុខក្នុងផល ទើបបន្លឺឧទាន ហើយត្រាស់ព្រះគាថាក្នុងធម្មបទ ដូច្នេះថា

**ធម្មបីតិ សុខំ សេតិ វិប្បសន្នេន ចេតសា**
**អរិយប្បវេទិតេ ធម្មេ សទា រមតិ បណ្ឌិតោ ។**

បណ្ឌិតដែលមានសេចក្តីឆ្អែតក្នុងធម៌ មានចិត្តជ្រះថ្លាហើយ រមែងដេកជាសុខ រមែងត្រេកអរក្នុងធម៌ ដែលព្រះអរិយៈប្រកាសទុកហើយ គ្រប់ពេល ។

ថ្ងៃមួយ ព្រះសាស្តាទ្រង់ហៅភិក្ខុ ១០០០ រូប ដែលជាអន្តេវាសិករបស់លោកមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ អាចារ្យនៃពួកអ្នកសម្តែងធម៌ខ្លះដែរឬទេ ភិក្ខុទាំងឡាយក្រាបទូលថា បពិត្រព្រះមានព្រះភាគ អាចារ្យរបស់ខ្ញុំព្រះអង្គមិនបានសម្តែងធម៌ឡើយ លោកជាអ្នកខ្វល់ខ្វាយតិចប្រកបសេចក្តីព្យាយាមរឿយដល់សុខវិហារធម៌ក្នុងបច្ចុប្បន្ន មិនឲ្យត្រឹមតែឱវាទដល់បុគ្គលណាម្នាក់ទេ ។ ព្រះសាស្តា ត្រាស់ឲ្យហៅលោកមកហើយសួរថា ម្នាលកប្បិន បានឮថា អ្នកមិនឲ្យសូម្បីត្រឹមតែឱវាទដល់អន្តេវាសិកទាំងឡាយឬហ្ន៎ ។ ទើបលោកក្រាបទូលថា បពិត្រព្រះមានព្រះភាគ ពិតហើយ ព្រះអង្គ ។ ព្រះមានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ អ្នកកុំធ្វើយ៉ាង

យ៉ាងនេះ តាំងអំពីថ្ងៃនេះទៅ អ្នកចូរសម្ដែងធម៌ដល់អន្តេវាសិកទាំងឡាយ ។ លោកទទួលព្រះពុទ្ធតម្រាស់ដោយសិរសា គឺត្បូង ពោលថា សាធុ ព្រះអង្គ ហើយសម្ដែងធម៌ទូន្មានសមណៈ ១០០០ រូប ក្នុងការប្រជុំត្រឹមតែមួងប៉ុណ្ណោះ ឲ្យសម្រេចអរហត្តគ្រប់រូប ។ បន្ទាប់មក ព្រះសាស្ដាប្រថាប់គង់កណ្ដាលជំនុំសង្ឃ កំពុងស្ថាបនាព្រះថេរៈទាំងឡាយ ទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះមហាកប្បិនត្ថេរ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃភិក្ខុសាវក ខាងឲ្យឱវាទដល់ភិក្ខុ ដូច្នេះឯង ។៚

**អដ្ឋកថា សូត្រទី ៩ ចប់**

## អដ្ឋកថា សូត្រទី ១០
## ប្រវត្តិ ព្រះសាគតត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី១០ ដូចតទៅនេះ បទថា **តេជោធាតុកុសលានំ** លោកសម្ដែងថា ព្រះសាគតត្ថេរជាកំពូលនៃពួកភិក្ខុសាវក អ្នកឈ្លាសក្នុងតេជោធាតុ សេចក្ដីពិត ព្រះថេរៈនេះ ប្រើតេជះគ្របសង្កត់តេជះរបស់នាគ ឈ្មោះអម្ពតិដ្ឋៈ ធ្វើឲ្យអស់ព្យសន៍កំណាច ព្រោះហេតុនោះ ទើបលោកឈ្មោះថា ជាកំពូលនៃពួកភិក្ខុសាវកដែលឈ្លាសក្នុងតេជោធាតុ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលពោលតាមលំដាប់ ដូច្នេះថា

ព្រះថេរៈរូបនេះ ក្នុងពុទ្ធកាលព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ បដិសន្ធិក្នុងត្រកូល នាក្រុងហង្សវតី ។ បន្ទាប់មក កំពុងស្តាប់ធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈជាកំពូលនៃពួកភិក្ខុសាវក ដែលឈ្លាសក្នុងតេជោធាតុ ទើបធ្វើកុសលកម្មដ៏ធំប្រាថ្នាតំណែងនោះ ។ បុរសនោះធ្វើកុសលដរាបដល់អស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី មាតាបិតាដាក់ឈ្មោះថា សាគតមាណព ។ បន្ទាប់មក សាគតមាណពនោះ ស្តាប់ធម៌របស់ព្រះសាស្តាបាននូវសទ្ធា ទើបបួស ធ្វើសមាបត្តិ ៨ ឲ្យកើតហើយ សម្រេចភាពជាអ្នកជំនាញក្នុងសមាបត្តិនោះ ។ បន្ទាប់មក ព្រះសាស្តាយាងចារិកទៅ បានទៅដល់ទីជិតក្រុងកោសម្ពី ។ សម័យនោះ បុគ្គលដែលមក ដែលទៅជាច្រើន ដែលជាសត្រូវរបស់នាយទូកចាស់ ត្រង់កំពង់ទឹក វាយនាយទូកនោះស្លាប់ ។ នាយទូកនោះ តាំងសេចក្តីប្រាថ្នាទាំងចិត្តថ្នាំងថ្នាក់ កើតជានាគរាជ មានអានុភាពច្រើន ត្រង់កំពង់នោះឯង ព្រោះមានចិត្តថ្នាំងថ្នាក់ ។ ទើបនាគនោះធ្វើភ្លៀងឲ្យធ្លាក់ក្នុងកាលដែលមិនមែនរដូវភ្លៀង មិនឲ្យភ្លៀងធ្លាក់ក្នុងកាលរដូវភ្លៀង ។ សន្ទូងក៏មិនសម្បូរ ។ អ្នកដែនទាំងមូលធ្វើការសែនព្រេនរាល់ឆ្នាំ ដើម្បីឲ្យនាគនោះស្ងប់ ធ្វើផ្ទះមួយខ្នងឲ្យនាគរាជនៅ ។ ព្រះសាស្តាទ្រង់យាងកាត់តាមផ្លូវនោះ មានភិក្ខុសង្ឃចោមរោម ទ្រង់មានបំណងនឹងប្រថាប់មួយយប់ក្នុងទីនោះ ។ គ្រានោះ ព្រះថេរៈនេះដឹងថា បានឮថា មាននាគរាជកាចនៅក្នុងទីនោះ ទើបគិតថា គួរទូន្មាន

នាគរាជនេះឲ្យអស់ព្យសកំណាច ហើយរៀបចំទីប្រថាប់សម្រាប់ព្រះសាស្តា ។ ដូច្នេះហើយ ចូលទៅកាន់លំនៅរបស់នាគនោះ អង្គុយពត់ភ្នែន នាគក្រោធ គិតថា សមណៈត្រងោលនេះ ឈ្មោះអ្វី ទើបអង់អាចចូលទៅអង្គុយក្នុង លំនៅរបស់អញ រួចទើបបង្ហុយផ្សែងឡើង ។ ព្រះថេរៈក៏បង្ហុយផ្សែង ក្រៃលែងជាង ។ ស្តេចនាគក៏ធ្វើភ្លើងឲ្យឆេះឡើង ។ ព្រះថេរៈក៏ធ្វើភ្លើងឲ្យឆេះ ឡើងក្រៃលែងជាង គ្របសង្កត់តេជៈនាគនោះ ។ នាគគិតថា ភិក្ខុនេះធំពិតហ្ន៎ ទើបក្រាបចុះទៀបបាតជើងព្រះថេរៈ ពោលថា បពិត្រលោកម្ចាស់ ខ្ញុំសូម ដល់លោកម្ចាស់ជាសរណៈ ។ ព្រះថេរៈប្រាប់ថា កិច្ចដោយសរណៈ សម្រាប់ អាត្មាមិនមានទេ អ្នកចូរកាន់យកព្រះទសពលជាសរណៈចុះ ។ នាគនោះ ទទួលថា សាធុ ហើយជាអ្នកដល់សរណៈ ។

( នាគនោះបានដល់ព្រះទសពលដែលមានព្រះសិរសា គឺសព្វញ្ញុតញ្ញាណដ៏ប្រសើរ ជាអ្នកមានសិរសាល្អ គឺនិព្វានារម្មណ៍ដ៏ប្រសើរ ដែលមាន ព្រះនលាដ គឺចតុត្ថញ្ញាណដ៏ប្រសើរ ជាអ្នកមានឧណ្ណាលោម គឺសមាបត្តិញ្ញាណ ដូចវជិរៈដ៏ប្រសើរ មានព្រះចិញ្ចើមទាំងគូដ៏ប្រសើរជាងលម្អនៃនីលកសិណ ជាអ្នកមានគូនៃចក្ខុ គឺទិព្វចក្ខុ បញ្ញាចក្ខុ និងសមន្តចក្ខុដ៏ប្រសើរ ជាអ្នកមានគូសោតៈ គឺទិព្វសោតញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះនាសិកល្អ គឺគោត្រភូញាណដ៏ប្រសើរ ជាអ្នកមានគូនៃព្រះគណ្ឌ ( ថ្ពាល់ ) គឺមគ្គផលញ្ញាណ និងវិមុត្តិញ្ញាណដ៏ប្រសើរ ជាអ្នកមានគូព្រះឱស្ឋ គឺលោកិយញ្ញាណ និងលោកុត្តរញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះទន្តល្អ គឺសត្តិសពោធិបក្ខិ-

យញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះចង្កូម គឺចតុមគ្គញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះជិវ្ហា គឺចតុសច្ចញ្ញាណដ៏ប្រសើរ ជាអ្នកមានហនុ គឺអប្បដិហតញ្ញាណ គឺញាណមិនមានអ្វីដែលរាំងដ៏ប្រសើរ ជាអ្នកមានព្រះសុរង គឺញាណជាគ្រឿងសម្រេចវិមោក្ខដ៏កំពូលដ៏ប្រសើរ ជាអ្នកមានគូព្រះពាហា គឺចតុវេសារជ្ជញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះអង្គុលីមូលល្អ គឺទសានុស្សតិញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះឧរៈពេញ គឺសត្តពោជ្ឈង្គ ជាអ្នកមានគូនៃដោះ គឺអាសយានុសញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះវរកាយកំណាត់កណ្តាល គឺទសពលញ្ញាណដ៏ប្រសើរ ជាអ្នកមានព្រះជង្ឃ គឺបញ្ចិន្ទ្រិយ និងបញ្ចពលដ៏ប្រសើរ ជាអ្នកមានគូព្រះឩរុ ( ភ្លៅ ) គឺទសកុសលកម្មបថដ៏ប្រសើរ ជាអ្នកមានសង្ឃាដី គឺសីល សមាធិ បញ្ញាដ៏ប្រសើរ ជាអ្នកមានបង្សុកូលចីវរជាគ្រឿងបិទបាំងព្រះវរកាយ គឺហិរិឱត្តប្បៈដ៏ប្រសើរ ជាអ្នកមានអន្តរវាសក គឺអដ្ឋង្គិកមគ្គញ្ញាណដ៏ប្រសើរ ជាអ្នកមានវត្ថពន្ធចង្កេះ គឺចតុសតិប្បដ្ឋានដ៏ប្រសើរជាសរណៈ ព្រះពុទ្ធទ្រង់ឲ្យជាក់ច្បាស់ហើយ ដូចពោលមកនេះ ព្រះមានព្រះភាគ ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ ។ តាំងអំពីនោះ នាគក៏មិនបៀតបៀនបុគ្គលណាម្នាក់ឡើយ នាំភ្លៀងផ្គរឲ្យធ្លាក់ត្រូវតាមរដូវកាល សន្ទូងទាំងឡាយ ក៏សម្បូរភោគផល ។

ពួកអ្នកក្រុងកោសម្ពីបានដំណឹងថា ព្រះសាគតៈទូន្មានអម្ពតិត្ថនាគរាជបានហើយ ទទឹងការនិមន្តន៍មករបស់ព្រះសាស្តា ចាត់ចែងសក្ការៈដ៏ច្រើនថ្វាយព្រះទសពល អ្នកក្រុងទាំងនោះ កាលថ្វាយសក្ការៈជាច្រើនដល់ព្រះ

ទសពលហើយ ក៏តាក់តែងទឹកថ្លាពណ៌សទុកក្នុងផ្ទះគ្រប់ខ្នង តាមពាក្យ ណែនាំរបស់ពួកឆព្វគ្គិយភិក្ខុ ។ ស្អែកឡើង កាលព្រះសាគតត្ថេរត្រាច់ បិណ្ឌបាត ក៏នាំគ្នាប្រគេនទឹកនោះមួយផ្ទះបន្តិចៗ ព្រះថេរៈត្រូវមនុស្សទាំង-ឡាយស្ងើចសរសើរ ព្រោះទ្រង់មិនទាន់បានបញ្ញត្តសិក្ខាបទ ក៏ផឹកគ្រប់ផ្ទះ មួយផ្ទះបន្តិចៗ ដើរទៅមិនឆ្ងាយប៉ុន្មាន ក៏ដួលត្រង់គំនរសំរាម ព្រោះមិនមាន អាហារទ្រាប់ពោះ ។ ព្រះសាស្តាសោយស្រេចហើយ យាងចេញទៅឃើញ ព្រះសាគតត្ថេរនោះ ក៏ឲ្យនាំទៅកាន់វិហារ ទ្រង់តិះដៀល ហើយបញ្ញត្ត សិក្ខាបទ ។ ស្អែកឡើង លោកបានទូវសតិ ស្តាប់គេនិទានដល់ហេតុដែល ខ្លួនធ្វើហើយ ក៏សម្តែងទោសដែលប្រព្រឹត្តល្មើស សូមឲ្យព្រះទសពលអត់ ទោសហើយ កើតសេចក្តីសង្វេគ ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ។ រឿងប្រាកដក្នុងព្រះវិន័យដូចពោលមកនេះ ។ គប្បីជ្រាបរឿងពិស្តារតាមន័យ ដែលពោលមកហើយក្នុងវិន័យនោះឯង ។ ក្រោយមក ព្រះសាស្តាប្រថាប់ គង់ក្នុងវត្តជេតពនមហាវិហារ កំពុងស្ថាបនាព្រះថេរៈទាំងឡាយ ទុកក្នុង តំណែងទាំងឡាយតាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះសាគតត្ថេរទុក ក្នុង តំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុដែលជាសាវក អ្នកឈ្លាសក្នុងការចូល តេជោធាតុ ដូច្នេះ ៕ ១០

## អដ្ឋកថា សូត្រទី ១០ ចប់

# អដ្ឋកថា សូត្រទី ១១

# ប្រវត្តិ ព្រះរាធត្ថេរ

គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១១ ដូចតទៅនេះ បទថា **បដិភាណេយ្យកានំ** បានដល់ ដែលឲ្យបដិភាណកើតឡើងបាន ដែលរាប់ជាហេតុឲ្យលោកសម្ដែងដដែលនូវព្រះធម្មទេសនារបស់ព្រះសាស្ដាបានភ្លាមៗ ។ ក្នុងបញ្ហាកម្មរបស់លោក មានរឿងដែលនឹងពោលតាមលំដាប់ ដូច្នេះថា

ព្រះថេរៈរូបនេះ ក្នុងពុទ្ធកាលនៃព្រះសុមុទ្ទបទុមុត្តរៈ កើតក្នុងត្រកូលមួយ នាក្រុងហង្សវតី ។ ក្រោយមក កំពុងស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវក ដែលមានបដិភាណ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ លោកបដិបត្តិព្រះតថាគតដរាបដល់អស់ជីវិត វិលវល់នៅក្នុងទេវតា និងមនុស្ស ពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ នាក្រុងរាជគ្រឹះ ទើបមាតាបិតាដាក់ឈ្មោះថា រាធមាណព ។ ក្នុងកាលចាស់ជរា គិតថា អាត្មាអញជាបុគ្គលដែលកូន និងភរិយាបោះបង់ចោល នឹងបួសឲ្យកាលវេលាកន្លងទៅ ទើបទៅព្រះវិហារ សូមបព្វជ្ជាជាមួយព្រះថេរៈទាំង-ឡាយ ។ ព្រះថេរៈពួកខ្លះ មិនចង់ឲ្យបួស ព្រោះឃើញថាជាមនុស្សចាស់ជាព្រាហ្មណ៍ចាស់ជរា ។ ថ្ងៃមួយ ព្រាហ្មណ៍ទៅកាន់សម្នាក់របស់ព្រះសាស្ដា ធ្វើបដិសណ្ឋារៈហើយ អង្គុយក្នុងទីដ៏សមគួរ នាចំណែកម្ខាង ។ ព្រះសាស្ដាទ្រង់ឃើញឧបនិស្ស័យសម្បត្តិ ដល់ព្រមដោយឧបនិស្ស័យ បំណងលើករឿងនេះឡើង ទើបត្រាស់សួរថា ម្នាលព្រាហ្មណ៍ បុត្រភរិយានៅប្រតិបត្តិអ្នកឬ

ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម ប្រតិបត្តិមកអំពីណា ពួកកូន និង ភរិយាឲ្យខ្ញុំព្រះអង្គចេញទៅអំពីផ្ទះ ដោយគិតថា ខ្ញុំព្រះអង្គចាស់ហើយ ។ ព្រះមានព្រះភាគត្រាស់សួរថា ចុះអ្នកបួសមិនគួរឬព្រាហ្មណ៍ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតម អ្នកណានឹងឲ្យខ្ញុំព្រះអង្គបួស បុគ្គលណាម្នាក់ ក៏មិនត្រូវការខ្ញុំព្រះអង្គដែរ ព្រោះខ្ញុំព្រះអង្គជាមនុស្សចាស់ហើយ ។ ព្រះសាស្តាបានប្រទានសញ្ញាដល់ព្រះសារីបុត្រ ព្រះថេរៈទទួលព្រះពុទ្ធតម្រាស់ ដោយសិរសា ឲ្យរាធព្រាហ្មណ៍បួស លោកគិតថា ព្រះសាស្តាទ្រង់ឲ្យព្រាហ្មណ៍នេះបួសដោយអើពើ មិនសមគួរមើលព្រាហ្មណ៍នេះ ដោយការមិនអើពើ ទើបនាំព្រះរាធៈទៅកាន់លំនៅក្បែរស្រុក ក្នុងទីនោះ លោកមានលាភដែលគេរកបានដោយលំបាក ព្រោះជាអ្នកបួសថ្មី ទើបព្រះថេរៈឲ្យលំនៅដែលដល់ខ្លួន ដែលជារបស់ប្រសើរ ឲ្យបិណ្ឌបាតដ៏ប្រណីត ដែលដល់លំដាប់ខ្លួនដល់ព្រះរាធត្ថេរនោះ ត្រាច់ទៅបិណ្ឌបាតឯង ។ ព្រះរាធត្ថេរ បានសេនាសនៈជាទីសប្បាយ និងភោជនដ៏សប្បាយ ទទួលកម្មដ្ឋានក្នុងសម្នាក់ព្រះសារីបុតត្ថេរ មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត ។ គ្រានោះ ព្រះសារីបុត្រក៏នាំលោកទៅគាល់ព្រះទសពល ព្រះសាស្តាក៏ទ្រង់ជ្រាប ទើបត្រាស់សួរថា ម្នាលសារីបុត្រ និស្សិតដែលតថាគតឲ្យសញ្ញាដល់អ្នកដូចម្តេចទៅហើយ មិនចង់សឹកទេឬ ព្រះសារីបុត្រទូលថា បពិត្រព្រះអង្គដ៏ចម្រើន ធម្មតាកិច្ចដែលអភិរម្យត្រេកអរក្រៃលែងក្នុងព្រះសាសនា គប្បីមានសភាពដូច្នេះ ។ គ្រានោះក៏កើតពាក្យចរចាកណ្តាលជំនុំសង្ឃថា ព្រះសារីបុត្តត្ថេរជាកតញ្ញូកតវេទីបុគ្គល

ព្រះមុនីទ្រង់ស្តាប់រឿងនោះហើយ ទ្រង់ហៅភិក្ខុទាំងឡាយមកហើយ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សារីបុត្រជាអ្នកមានកតញ្ញូកតវេទីក្នុងជាតិនេះ មិនជាអស្ចារ្យទេ ក្នុងជាតិមុន សូម្បីបដិសន្ធិក្នុងអហេតុកសត្វក៏ជាកតញ្ញូកតវេទីបុគ្គលហើយដូចគ្នា ។ ភិក្ខុទាំងឡាយទូលសួរថា បពិត្រព្រះមានព្រះភាគ តើដឹងគុណក្នុងកាលណា ។ ទើបព្រះមានព្រះភាគត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ក្នុងអតីតកាល ជាងឈើប្រមាណ ៥០០ នាក់ ចូលទៅកាន់ព្រៃធំក្បែរជើងភ្នំ កាប់ទព្វសម្ភារៈបានហើយ ចងក្បូនធំ រុញចុះកាន់ស្ទឹង ។ មានស្តេចដំរីមួយយកប្រមោយចាប់មែកឈើដែលមិនរៀបរយមួយកន្ទេង មិនអាចទាញមែកឈើឲ្យបាក់បាន ក៏យកជើងជាន់ត្រង់ជន្លត់ស្រួច ។ ជើងត្រូវបួសដល់នូវទុក្ខវេទនា មិនអាចដើរទៅបាន ក៏ដេកត្រង់ទីនោះឯង ។ កន្លងទៅ ២-៣ ថ្ងៃ ស្តេចដំរីនោះ ឃើញពួកជាងឈើដើរមកក្បែរខ្លួន ក៏គិតថា អញអាស្រ័យជាងឈើទាំងនេះ គង់នឹងបានរួចជីវិតពិត ទើបដើរទៅតាមស្នាមជើងជាងឈើទាំងនោះ ពួកជាងក្រឡេកក្រោយឃើញដំរី ក៏ភ្លាច ទើបគេចទៅ ស្តេចដំរីនោះដឹងថា គេគេចក៏ឈប់ ដើរតាមទៅទៀត ក្នុងកាលដែលគេឈប់ ។ មេជាងគិតថា ដំរីនេះ កាលអញឈប់ ក៏ឈប់ដែរ កាលអញគេច ក៏ឈប់ គង់នឹងមានហេតុក្នុងទីនោះពិត គ្រប់គ្នា ទើបនាំគ្នាស្រវាឡើងដើមឈើ អង្គុយរង់ចាំដំរីមក ។ ស្តេចដំរីនោះ ដើរមកក្បែរជាងឈើទាំងនោះ ក៏ដេកផ្អៀងបង្ហាញជើងរបស់ខ្លួន ។ ជាងឈើយល់សេចក្តីបាន ពោលថា អ្នកដ៏ចម្រើន ដំរីនោះមកព្រោះមានជំងឺ មិនមែនមកព្រោះហេតុដទៃឡើយ ទើបនាំគ្នាចូល

ទៅជិតស្តេចដំរីនោះ ឃើញដង្កត់ចូលទៅក្នុងជើង ក៏ដឹងថា ព្រោះហេតុនេះឯង ទើបដំរីនេះមក ទើបយកកាំបិតដ៏មុតលាក់ត្រង់ចុងដង្កត់ ហើយយកខ្សែចងឲ្យជាប់ ទាញចេញមកបាន ប្របាច់របួស យកខ្ទុះ និងឈាមចេញ លាងដោយទឹកចត់ បិទថ្នាំដែលខ្លួនស្គាល់ មិនយូរប៉ុន្មាន ក៏ធ្វើឲ្យដំរីជាសះស្បើយ ស្តេចដំរីបាត់ឈឺហើយ គិតថា ជាងឈើទាំងនេះមានឧបការៈដល់អញច្រើន អញអាស្រ័យជាងឈើទាំងនេះ ទើបរួចជីវិត អញគួរដឹងគុណចំពោះពួកគេ ទើបត្រឡប់ទៅកាន់លំនៅរបស់ខ្លួន ហើយនាំយកកូនដំរីត្រកូលគន្ធៈមក ។ ពួកជាងឈើឃើញកូនដំរី ក៏មានចិត្តត្រេកអរក្រៃលែងថា ដំរីរបស់យើងនាំកូនមក ។ ស្តេចដំរីគិតថា កាលអញឈរ ធ្វើម្តេចហ្ន៎ កូនដំរីនេះទើបមិនមក កូនដំរី គង់មិនដឹងហេតុដែលអញមក ទើបដើរចេញទៅអំពីទីដែលឈរ កូនដំរីក៏ដើរតាមតិចៗ ទៅអំពីខាងក្រោយឪពុក ។ ស្តេចដំរីដឹងថា កូនមកតាម ទើបប្រើសំឡេងឲ្យសញ្ញាត្រឡប់ទៅ ។ កូនដំរីបានឮសំឡេងបា ក៏ត្រឡប់ទៅរកពួកជាងឈើៗ ដឹងថា ដំរីនេះមកដើម្បីឲ្យកូនដំរីនេះដល់ខ្លួន ទើបពោលថា ខ្ញុំមិនមានកិច្ចដែលនឹងឲ្យអ្នកធ្វើក្នុងសម្នាក់ខ្ញុំទេ ចូរទៅរកបារបស់អ្នកចុះ ហើយ បញ្ជូនកូនដំរីត្រឡប់ទៅ ។ ស្តេចដំរីក៏បញ្ជូនកូនដំរីមកអស់ ៣ ដង ទៅនៅជិតពួកជាងឈើទៀត ។ តាំងអំពីនោះមក ពួកជាងឈើក៏នាំគ្នាចិញ្ចឹមកូនដំរីទុកក្នុងសម្នាក់របស់ខ្លួន ។ ក្នុងវេលាស៊ី ក៏នាំគ្នាឲ្យដុំបាយម្នាក់មួយដុំគ្រប់គ្រាន់ដល់តម្រូវការរបស់កូនដំរីនោះ ។ គ្រានោះ កូនដំរីនោះក៏ជញ្ជូនទព្វសម្ភារៈដែលពួកជាងឈើកាត់ទុកក្នុងព្រៃ មកធ្វើជាគំនរទុកត្រង់ទីលាន

កូនដំរីក៏ធ្វើឧបការៈដទៃៗ ដោយទំនងនេះឯង ។

ព្រះសាស្ដា ទ្រង់ទាញហេតុនេះក្នុងជាតិមុនមកសម្ដែង ព្រះសារីបុត្រក៏ជាបុគ្គលកតញ្ញូកតវេទី ។ គ្រានោះ ព្រះសារីបុត្របានជាដំរីធំ ភិក្ខុដែលមានព្យាយាមធូរថយ ដែលមកក្នុងអត្ថុប្បត្តិហេតុ បានជាកូនដំរី តែគម្ពីរសំយុត្តនិកាយ គួរពោលរាធសំយុត្តទាំងមូល និងគាថាក្នុងធម្មបទថា

**និធីនំវ បវត្តារំ យំ បស្សេ វជ្ជទស្សិនំ**

**និគ្គយ្ហវាទី មេធាវី តាទិសំ បណ្ឌិតំ ភជេ**

**តាទិសំ ភជមានស្ស សេយ្យោ ហោតិ ន បាបិយោ ។**

បុគ្គលគួរឃើញនូវអ្នកប្រាជ្ញណា ដែលជាអ្នកពោលសង្កត់សង្កិន ចង្អុលប្រាប់ទោស ថាដូចជាបុគ្គលអ្នកប្រាប់កំណប់ទ្រព្យឲ្យដូច្នោះ គួរគប់អ្នកប្រាជ្ញបែបនោះ ( ព្រោះថា ) កាលបុគ្គលគប់អ្នកប្រាជ្ញបែបនោះហើយ រមែងមានសេចក្ដីគាប់ប្រសើរ ឥតមានទោសដ៏លាមកឡើយ ។

ឈ្មោះថា ធម្មទេសនារបស់ព្រះថេរៈ តែបន្ទាប់មក ព្រះសាស្ដាក៏ពុំងទ្រង់ស្ថាបនាព្រះថេរៈទាំងឡាយ ទុកក្នុងតំណែងទាំងឡាយតាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះរាធត្ថេរ ក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុជាសាវកដែលប្រកបដោយបដិភាណ ដូច្នេះ ៕

**អដ្ឋកថាសូត្រទី ១១ ចប់**

# អដ្ឋកថា សូត្រទី ១២

# ប្រវត្តិ ព្រះមោឃរាជត្ថេរ

*គប្បីជ្រាបវិនិច្ឆ័យក្នុងសូត្រទី ១២ ដូចតទៅនេះ បទថា* **លូខចីវរធរានំ** *លោកសម្តែងថា ព្រះមោឃរាជជាកំពូលនៃពួកភិក្ខុដែលជាសាវ័ក ទ្រទ្រង់ចីវរសៅហ្មង ។ ពិតហើយ ព្រះថេរៈអង្គនេះ ទ្រទ្រង់សំពត់បង្សុកូលចីវរដែលប្រកបដោយការសៅហ្មង ៣ យ៉ាង គឺសៅហ្មងដោយសំពត់ ១ សៅហ្មងដោយអំបោះ ១ សៅហ្មងដោយគ្រឿងជ្រលក់ ១ ព្រោះហេតុនោះ ទើបលោកជាកំពូលនៃពួកភិក្ខុសាវ័ក ដែលទ្រទ្រង់ចីវរសៅហ្មង ។ ក្នុងបញ្ហាកម្មរបស់លោក មានអនុសន្ធិដូចតទៅនេះថា*

*ព្រះមោឃរាជនេះ ក្នុងសាសនាព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី បន្ទាប់អំពីនោះ កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុមួយរូប ទុកក្នុងតំណែងជាកំពូលនៃពួកភិក្ខុសាវ័កខាងទ្រទ្រង់ចីវរសៅហ្មង ក៏ធ្វើកុសលឲ្យក្រៃលែងឡើងប្រាថ្នាតំណែងនោះ ។ លោកធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតា និងមនុស្ស បដិសន្ធិក្នុងផ្ទះអមាត្យ ក្នុងនគរកដ្ឋវាហនៈ មុនព្រះទសពលព្រះនាមកស្សបៈទ្រង់កើតឡើង ។ បន្ទាប់មក កាលចម្រើនវ័យហើយ ចូលគាល់ព្រះបាទកដ្ឋវាហនៈ ក៏បានតំណែងជាអមាត្យ ។ សម័យនោះ ព្រះកស្សបទសពលទ្រង់កើតឡើងក្នុងលោកហើយ ព្រះបាទកដ្ឋវាហនៈទ្រង់បានដំណឹងថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ត្រាស់ហៅអមាត្យនោះមកត្រាស់ថា នែបា ព្រះពុទ្ធកើតឡើងហើយក្នុងលោក បុគ្គលណាម្នាក់ មិនអាច*

ធ្វើនគរបច្ចន្តប្រទេសនេះឲ្យទំនេរចាកយើងទាំង ២ ព្រមៗ គ្នាបានឡើយ ដូច្នេះ អ្នកចូរទៅកាន់មជ្ឈិមប្រទេស ចូរដឹងថា ព្រះពុទ្ធកើតឡើងហើយ ហើយនាំព្រះទសពលមកកាន់នគរបច្ចន្តប្រទេសនេះ ហើយទ្រង់បញ្ជូនអមាត្យនោះទៅមួយអន្លើដោយបុរស ១០០០ នាក់ ។ អមាត្យនោះទៅកាន់សម្នាក់ព្រះមុនីស្តាប់ធម្មកថា បាននូវសទ្ធាហើយ ក៏បួសក្នុងទីនោះតាមលំដាប់ ក៏បានធ្វើសមណធម៌អស់ ២ ម៉ឺនឆ្នាំ ឯបុរសដែលទៅជាមួយអមាត្យនោះត្រឡប់មកកាន់សម្នាក់ព្រះរាជាទាំងអស់ ។ ព្រះថេរៈនេះ មានសីលបរិបូណ៌ ធ្វើកាលកិរិយាហើយ អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ បដិសន្ធិក្នុងត្រកូលព្រាហ្មណ៍ ក្នុងក្រុងសាវត្ថី មុនព្រះទសពលនៃយើងកើតឡើង មាតាបិតាបានដាក់ឈ្មោះថា មោឃរាជមាណព ឯព្រះបាទកដ្ឋវាហនៈទ្រង់ធ្វើកុសលឲ្យក្រៃលែងឡើងដល់ព្រះមានព្រះភាគកស្សបៈ មួយអន្លើដោយបរិវារ វិលវល់ក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ បដិសន្ធិក្នុងត្រកូលបុរោហិតនាក្រុងសាវត្ថី មុនព្រះទសពលនៃយើងទ្រង់កើតឡើង មាតាបិតាដាក់ឈ្មោះថា ពាវរីមាណព សម័យក្រោយមក ពាវរីមាណពរៀនត្រៃវេទ ត្រាច់បង្រៀនសិប្បៈដល់មាណព ១៦០០០ នាក់ ។ គ្រានោះ ពាវរីមាណពក៏បានទទួលតំណែងបុរោហិតជំនួស កាលឪពុកធ្វើកាលកិរិយាទៅ ។ ក្នុងសម័យដែលព្រះបាទបសេនទិកោសលប្រសូត ។ មោឃរាជមាណពនេះ ក៏រៀនសិប្បៈក្នុងសម្នាក់ពាវរីព្រាហ្មណ៍ ។

សម័យមួយ ពាវរីព្រាហ្មណ៍នៅក្នុងទីស្ងាត់ ពិនិត្យមើលសារៈក្នុង

សិប្បៈ ក៏មិនឃើញសារៈដែលប្រព្រឹត្តទៅខាងមុខ គិតថា អញនឹងបួសបែបណាមួយ ស្វែងរកសារៈដែលប្រព្រឹត្តទៅខាងមុខ ហើយក៏ចូលគាល់ព្រះបាទកោសល ឲ្យទ្រង់អនុញ្ញាតការបួសដល់ខ្លួន ។ ពាវរីព្រាហ្មណ៍នោះបានទទួលព្រះរាជានុញ្ញាតហើយ មានមាណព ១៦០០០ នាក់ចោមរោម ក៏ចេញទៅដើម្បីបួស ។ ព្រះបាទកោសលទ្រង់បញ្ជូនព្រះរាជទ្រព្យ ១ ពាន់កហាបណៈទៅ មួយអន្លើដោយពាវរីព្រាហ្មណ៍នោះ ដោយព្រះតម្រាស់ថា អាចារ្យបួសក្នុងទីណា ពួកអ្នកចូរទៅកាន់លំនៅរបស់អាចារ្យ ហើយឲ្យទ្រព្យក្នុងទីនោះ ។ ពាវរីព្រាហ្មណ៍បំណងពិនិត្យមើលទីដែលមានផាសុក ក៏ចេញទៅអំពីមជ្ឈិមប្រទេស សាងលំនៅរបស់ខ្លួនត្រង់ប្រាំងស្ទឹងគោធាវរី ។ ត្រង់រវាងព្រំដែនរបស់ព្រះបាទអស្សកៈ និងព្រះបាទមឡុៈ ។ គ្រានោះ បុរសម្នាក់ធ្វើដំណើរទៅដើម្បីមើលជដិលទាំងឡាយ កាលជដិលទាំងនោះអនុញ្ញាតហើយ ក៏ធ្វើលំនៅរបស់ខ្លួន លើផ្ទៃដីរបស់ជដិលទាំងនោះ ។ បុរសនោះឃើញកិច្ចកម្មដែលពាវរីព្រាហ្មណ៍ធ្វើហើយ ក៏ឲ្យធ្វើត្រកូល ១០០ ផ្ទះ ១០០ ខ្នងទៀត ។ មនុស្សទាំងអស់ប្រជុំគ្នា ពិភាក្សាគ្នាថា ពួកយើងនៅក្នុងទឹកដីដែលជារបស់លោកម្ចាស់ទាំងឡាយ ការនៅទទេៗ មិនមែនជាហេតុដែលគួរឡើយ ពួកយើងនឹងឲ្យពួកលោកម្ចាស់នៅជាសុខ ។ ទើបបុគ្គលម្នាក់ដាក់កហាបណៈម្នាក់ ១ កហាបណៈទុកក្នុងលំនៅរបស់ពាវរីព្រាហ្មណ៍ កហាបណៈដែលពួកគេទាំងអស់នាំមកទុក ក៏កើនឡើងដល់មួយសែនកហាបណៈ ។ ពាវរីព្រាហ្មណ៍សួរថា កហាបណៈទាំងនេះ ពួកអ្នកនាំមកដើម្បីអ្វី ។ ជនទាំងនោះ ឆ្លើយថា

ដើម្បីឲ្យពួកលោកម្ចាស់នៅជាសុខ ។ ពាវរីព្រាហ្មណ៍ពោលថា បើខ្ញុំត្រូវការមាសប្រាក់ ក៏មិនគប្បីលះគំនរទ្រព្យដ៏ធំចេញបួសទេ ពួកអ្នកទទួលកហាបណៈរបស់ពួកអ្នកទៅចុះ ។ ពួកជនទាំងនោះប្រាប់ថា ពួកខ្ញុំមិនទទួលទ្រព្យដែលពួកខ្ញុំបរិច្ចាគហើយវិញទេ តែពួកខ្ញុំនឹងនាំមក មានទំនងយ៉ាងនេះ រាល់ៗ ឆ្នាំ សូមលោកម្ចាស់ទទួលកហាបណៈទាំងនេះ ទុកឲ្យទានចុះ ទើបព្រាហ្មណ៍ព្រមទទួលទុកឲ្យក្មេងកំព្រា អ្នកដើរផ្លូវឆ្ងាយ វនិព្វក និងយាចក ភាវៈដែលពាវរីព្រាហ្មណ៍នោះជាទាយក ក៏ល្បីតគ្នាមក ប្រាកដពេញជម្ពូទ្វីប ។

គ្រានោះ ព្រាហ្មណីជាភរិយារបស់ព្រាហ្មណ៍ ដែលកើតមកក្នុងវង្សរបស់ជូជកព្រាហ្មណ៍ ក្នុងស្រុកទុន្នវិត្ថៈ ក្នុងដែនកលិង្គ ។ ក្រោកឡើងដាស់ព្រាហ្មណ៍ជាប្តីថា បានឮថា ពាវរីកំពុងឲ្យទាន អ្នកចូរទៅនាំយកមាសប្រាក់អំពីទីនោះមក ព្រាហ្មណ៍នោះត្រូវព្រាហ្មណីរំអុក មិនអាចអត់ធន់បាន កាលទៅកាន់សម្នាក់ពាវរី ក៏ទៅក្នុងកាលពាវរីឲ្យទានកាលពីម្សិល ហើយចូលទៅកាន់បណ្ណសាលា កំពុងដេកគិតដល់ទាន ។ បុរសនោះចូលទៅដល់ក៏ពោលថា នែព្រាហ្មណ៍ សូមលោកឲ្យទានដល់ខ្ញុំចុះ នែព្រាហ្មណ៍ សូមលោកឲ្យទានដល់ខ្ញុំចុះ ។ ពាវរីព្រាហ្មណ៍ពោលថា នែព្រាហ្មណ៍ អ្នកមកមិនត្រូវកាល ខ្ញុំឲ្យទានដល់ពួកយាចកដែលមកដល់អស់ហើយ ឥឡូវនេះ មិនមានកហាបណៈទេ ។ ព្រាហ្មណ៍ពោលថា នែព្រាហ្មណ៍ ខ្ញុំមិនត្រូវការកហាបណៈច្រើនឡើយ កាលអ្នកឲ្យទានមានប្រមាណ ៥០០ កហាបណៈប៉ុណ្ណោះ អ្នកមិនមានឬ ។ អាចារ្យពាវរីពោលថា កហាបណៈ ៥០០ ខ្ញុំក៏មិនមាន កាលឲ្យទានលើក

ក្រោយអ្នកនឹងបាន ។ ព្រាហ្មណ៍ស្តូមពោលថា កាលដែលអ្នកឲ្យទាន ខ្ញុំនឹងមកបានដូចម្តេច ហើយទើបពូនខ្សាច់ជាស្តូប ក្បែរទ្វារបណ្ណសាលា រោយផ្កាមានពណ៌ក្រហមជុំវិញ ធ្វើមាត់អូចៗ ហាក់ដូចរាយមន្ត ហើយពោលថា ក្បាលចូរបែក ៧ ភាគ ។ ពាវរីព្រាហ្មណ៍គិតថា ព្រាហ្មណ៍នេះមានតេជះច្រើន កាន់ការប្រព្រឹត្តតបៈ ជាចរណកព្រាហ្មណ៍ ពោលថា ខាងចុង ៧ ថ្ងៃក្បាលរបស់អញ ចូរបែកជា ៧ ចម្រៀក កហាបណៈ ៥០០ ដែលអញគប្បីឲ្យដល់ព្រាហ្មណ៍នេះក៏មិនមាន ព្រាហ្មណ៍នេះនឹងសម្លាប់អញអសារបង់ ។

កាលពាវរីព្រាហ្មណ៍នោះដេកកើតទុក្ខ ដោយទោមនស្សយ៉ាងនោះ ក្នុងពេលរាត្រី ម្តាយរបស់ពាវរីព្រាហ្មណ៍ក្នុងអត្តភាពមុន កើតជាទេវតា នាងឃើញកូនដេកកើតទុក្ខទោមនស្សផ្ទូវចិត្ត ទើបមកពោលថា នែកូន ជីព្រាហ្មណ៍នោះ មិនដឹងក្បាលបែក ឬមិនបែក កូនមិនដឹងថា ព្រះពុទ្ធទាំងឡាយកើតឡើងក្នុងលោក បើអ្នកមានសេចក្តីសង្ស័យ ចូរទៅគាល់ព្រះសាស្តា ហើយទូលសួរចុះ ព្រះសាស្តាទ្រង់ប្រាប់ហេតុនោះដល់កូនបាន ។ ពាវរីព្រាហ្មណ៍តាំងអំពីបានឮសំឡេងទេវតាហើយ ក៏មានចិត្តត្រេកអរ លុះបានអរុណ ក៏ហៅសិស្សគ្រប់រូបមកហើយ ពោលថា នែបា បានឮថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក ពួកអ្នកចូរប្រញាប់ទៅ ចូរដឹងថា ជាព្រះពុទ្ធ ឬក៏មិនមែនហើយចូរមកប្រាប់ដល់ខ្ញុំ ខ្ញុំនឹងទៅគាល់ព្រះសាស្តា ព្រោះថា ការអន្តរាយដល់ជីវិតដឹងបានលំបាក ព្រោះខ្ញុំចាស់ជរាហើយ ពួកអ្នកទៅគាល់ព្រះសាស្តា ពួកអ្នកចូរទៅគាល់ព្រះសាស្តាទូលសួរបញ្ហា ដោយទំនងយ៉ាងនេះ យ៉ាងនេះនឹង

ព្រះអង្គ ទើបចងបញ្ហាឈ្មោះមុទ្ធផាលនៈឲ្យទៅ ។ បន្ទាប់អំពីនោះ ពាវរី-ព្រាហ្មណ៍គិតថា ពួកមាណពទាំងនេះជាបណ្ឌិត ស្តាប់ធម្មកថារបស់ព្រះសាស្តាហើយ កាលកិច្ចរបស់ខ្លួនដល់ទីបំផុតហើយ គប្បីត្រឡប់មករកអាត្មាអញឬហ្ន៎ ដូច្នេះ ទើបឲ្យសញ្ញាដល់អជិតមាណព ក្មួយរបស់ខ្លួនថា អ្នកគួរត្រឡប់មកតែម្នាក់ឯង មកប្រាប់គុណដែលខ្លួនបានដល់ខ្ញុំ ។ លំដាប់នោះ ជដិល ១ ម៉ឺន ៦ ពាន់ លើកអជិតមាណពជាប្រធាន ចារិកទៅជាមួយអន្តេវាសិកជាប្រធាន ១៦ នាក់ ដោយបំណងថា នឹងទូលសួរប្រស្នាជាមួយនឹងព្រះសាស្តា ។ ក្នុងទីដែលទៅ ត្រូវសួរថា លោកម្ចាស់ទៅណា ក៏ឆ្លើយថា ពួកខ្ញុំទៅគាល់ព្រះទសពលសួរបញ្ហា កាលនឹងទាញយកតាំងអំពីចុងមក គ្រប់បរិស័ទ ក៏ធ្វើដំណើរបានច្រើនរយយោជន៍ ។

ព្រះសាស្តា ទ្រង់ព្រះតម្រិះថា ក្នុងថ្ងៃដែលមាណពទាំងនោះមក ឱកាសនឹងមិនមានដល់អ្នកដទៃ ទើបទីនេះ មិនជាទីគួរសម្រាប់បរិស័ទនេះ ទើបយាងទៅប្រថាប់គង់លើផ្ទាំងថ្ម ត្រង់បាសាណចេតិយ ។ អជិតមាណពនោះមួយអន្លើដោយបរិស័ទ ក៏ឡើងលើផ្ទាំងថ្មនោះ ឃើញសម្បត្តិនៃព្រះសរីរៈរបស់ព្រះសាស្តា ក៏គិតថា បុរសនេះគង់ជាព្រះពុទ្ធ ដែលជាអ្នកមានដំបូលបើកហើយក្នុងលោកនេះ ទើបទៅបំណងសាកសួរបញ្ហាដែលអាចារ្យឲ្យដល់ខ្លួន។ ថ្ងៃនោះ បរិស័ទមកដល់ទីនោះប្រមាណ ១២ យោជន៍ ក្នុងវាងសិស្ស ១៦ នាក់នោះ មោឃរាជមាណពប្រកាន់ខ្លួនថា ជាបណ្ឌិតជាងគេទាំងអស់ ទើបត្រិះរិះថា អជិតមាណពនេះ ជាប្រធានរបស់សិស្សគ្រប់គ្នា មិនគួរសួរ

បញ្ហាមុន មោឃរាជមាណពខ្មាស់ចំពោះអជិតមាណពនោះ ទើបមិនសួរបញ្ហាមុន ។ កាលអជិតមាណពនោះសួរបញ្ហាហើយ ទើបសួរបញ្ហានឹងព្រះសាស្ដា ជាបុគ្គលទី ២ ។ ព្រះសាស្ដា ទ្រង់ពិចារណាថា មោឃរាជមាណពជាអ្នកប្រកាន់ខ្លួនផង ញាណរបស់សត្វនេះក៏មិនទាន់ចាស់ក្លាផង គួរដកនូវមានះរបស់សត្វនេះចេញ ទើបត្រាស់ថា ម្នាលមោឃរាជ អ្នកចូរបង្អង់សិនអ្នកដទៃៗ សួរបញ្ហាមុន ។ មោឃរាជមាណពនោះបាននូវការរំខានអំពីសម្នាក់ព្រះសាស្ដា គិតថា អាត្មាអញ ត្រាច់ទៅអស់កាលមានប្រមាណប៉ុណ្ណោះដោយយល់ថា មិនមានបុគ្គលដែលជាបណ្ឌិតក្រៃលែងជាងអញ ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់មិនជ្រាបសេចក្ដីក្នុងចិត្តរមែងមិនត្រាស់ ។ ព្រះសាស្ដាទ្រង់ឃើញទោសក្នុងការសួររបស់អញ ទើបនៅស្ងៀម ។ មោឃរាជមាណពនោះ កាលមាណពទី ៨ សួរបញ្ហាទៅតាមលំដាប់ ក៏អត់ធន់មិនបាន ក្រោកឡើងទៀត ជាបុគ្គលទី ៩ ព្រះសាស្ដា ក៏ទ្រង់ហាមឃាត់ទៀត ។ មោឃ-រាជមាណពក៏ត្រូវស្ងៀម គិតថា ឥឡូវនេះ អាត្មាអញមិនអាចជានវកក្នុងសង្ឃបាន ហើយទើបទូលសួរបញ្ហាក្នុងបុគ្គលទី ១៥ ។ លំដាប់នោះ ព្រះសាស្ដាទ្រង់ជ្រាបថា ញាណរបស់លោកចាស់ក្លាហើយ ទើបទ្រង់ដោះស្រាយបញ្ហា ។ ចប់ទេសនា លោកក៏សម្រេចអរហត្ត មួយអន្លើដោយជដិល ១០០០ នាក់ ដែលជាបរិវាររបស់ខ្លួន ។ ដោយទំនងនេះឯង ជដិល ១៥០០០ នាក់ដ៏សេស ក៏សម្រេចអរហត្តទាំងអស់ បានជាឯហិភិក្ខុ ទ្រទ្រង់បាត្រ និងចីវរដែលសម្រេចមកអំពីឫទ្ធិ តែជនដ៏សេស លោកមិនបានពោលដល់ ឯព្រះ

មោឃរាជត្ថេរនេះ ក៏ទ្រទ្រង់ចីវរប្រកបដោយការសៅហ្មង ៣ តាំងអំពីកាល នោះ ។ រឿងតាំងឡើងក្នុងបាវាយនវគ្គយ៉ាងនេះ ។ ខាងក្រោយមក ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពន ទ្រង់ស្តាបនាព្រះថេរៈទាំងឡាយ ទុកក្នុងតំណែងឯតទគ្គៈតាមលំដាប់ ទើបទ្រង់ស្តាបនាព្រះមោឃរាជ ក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុសាវក ដែលទ្រទ្រង់ចីវរសៅហ្មង ទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោឃរាជ ជាកំពូលនៃពួកភិក្ខុសាវករបស់តថាគត ដែលទ្រទ្រង់ចីវរសៅហ្មង ។ល។

## អដ្ឋកថា សូត្រទី ១២ ចប់

## វគ្គទី ៤ ចប់

## អដ្ឋកថា ថេរបាលីមានប្រមាណ ៤១ សូត្រ ចប់

## ប្រវត្តិភិក្ខុសាវកឯតទគ្គៈ ចប់

# ឯតទគ្គបាលិ

## វគ្គទី ៥

[ ១៥០ ] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកភិក្ខុនីអ្នកដឹងរាត្រី ដែលជាសាវិការបស់តថាគត ស្រេចនឹងមហាបជាបតិគោតមីប្រសើរជាងគេ ។ ពួកភិក្ខុនីអ្នកមានប្រាជ្ញាច្រើន ស្រេចនឹងនាងខេមា ។ ពួកភិក្ខុនីអ្នកមានឫទ្ធិ ស្រេចនឹងនាងឧប្បលវណ្ណា ។ ពួកភិក្ខុនីអ្នកទ្រទ្រង់វិន័យស្រេចនឹងនាងបដាចារា ។ ពួកភិក្ខុនីជាធម្មកថិកា ស្រេចនឹងនាងធម្មទិន្នា ។ ពួកភិក្ខុនីអ្នកមានឈាន ស្រេចនឹងនាងនន្ទា ។ ពួកភិក្ខុនីអ្នកមានព្យាយាមបរិបូណ៌ ស្រេចនឹងនាងសោណា ។ ពួកភិក្ខុនីអ្នកមានទិព្វចក្ខុ ស្រេចនឹងនាងសកុលា ។ ពួកភិក្ខុនីបានត្រាស់ដឹងរហ័ស ស្រេចនឹងនាងភទ្ទាកុណ្ឌលកេសា ។ ពួកភិក្ខុនីអ្នករឭកឃើញបុព្វេនិវាស ស្រេចនឹងនាងភទ្ទាកបិលានី ។ ពួកភិក្ខុនីអ្នកបានអភិញ្ញាដ៏ធំ ស្រេចនឹងភទ្ទាកច្ចានា ។ ពួកភិក្ខុនីអ្នកទ្រទ្រង់ចីវរដ៏សៅហ្មង ស្រេចនឹងនាងកិសាគោតមី ។ ពួកភិក្ខុនីអ្នកមានសទ្ធាស៊ប់ ស្រេចនឹងនាងសិគាលមាតា ។

# វគ្គទី ៥

## អដ្ឋកថា សូត្រទី ១

## ប្រវត្តិ ព្រះនាងមហាបជាបតីគោតមីថេរី

[ ១៥០ ] *ក្នុងសូត្រទី ១ នោះ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា* **យទិទំ មហាបជាបតីគោតមី** *លោកសម្តែងថា ព្រះនាងមហាបជាបតីគោតមី ជាកំពូលជាងភិក្ខុនីសាវិកា អ្នកដឹងរាត្រីយូរ ក្នុងបញ្ញាកម្មរបស់នាងមានរឿងដែលពោលតាមលំដាប់ដូច្នេះ*

*បានឮថា ព្រះនាងបជាបតីគោតមីនេះ ក្នុងពុទ្ធកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ បដិសន្ធិក្នុងផ្ទះត្រកូល នាក្រុងហង្សវតី ។ សម័យតមក កំពុងស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាងពួកភិក្ខុនីសាវិកា អ្នកដឹងរាត្រីយូរ ក៏ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងធ្វើទាន រក្សាសីលដរាបដល់អស់ជីវិត ចុតិអំពីភពនោះហើយ កើតក្នុងទេវលោក ចុតិអំពីទេវលោក ក្នុងពុទ្ធន្តរមួយទៀត កើតជាប្រធានទាសីចំនួន ៥០០ នាក់ ក្នុងក្រុងពារាណសី ។ គ្រានោះ សម័យចូលវស្សា ព្រះបច្ចេកពុទ្ធ ៥០០ អង្គចុះអំពីញកភ្នំនន្ទមូលកៈ ទៅកាន់ព្រៃឥសិបតនៈ និមន្តបិណ្ឌបាតក្នុងក្រុងហើយត្រឡប់មកព្រៃឥសិបតនៈ ត្រិះរិះថា អាត្មាអញ គួរសូមហត្ថកម្ម ដើម្បីធ្វើកុដិសម្រាប់ចាំវស្សា ។ ព្រោះហេតុអ្វី ព្រោះនឹងចូលចាំវស្សាក្នុងវេជ្ជរក្សៀង ផង ជាអ្នកបដិបត្តិនាលកបដិបទាផង ចាំបាច់ចូលក្នុងសេនាសនៈប្រចាំ ត្រង់*

ទីប្រក់ដោយគ្រឿងប្រក់ ៥ យ៉ាងណាមួយ ។ សមដូចព្រះពុទ្ធតម្រាស់នេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុមិនមានសេសនាសនៈ មិនគប្បីចាំវស្សា ភិក្ខុណាចាំវស្សា ត្រូវអាបត្តិទុក្កដ ដូច្នេះ ។ ព្រោះហេតុនោះ កាលកៀករដូវភ្លៀង បើបានសេនាសនៈ នុ៎ះក៏ជាការល្អ បើមិនបាន ក៏ចាំបាច់ស្វែងរកហត្ថកម្ម បើមិនបានហត្ថកម្ម គប្បីធ្វើឯង ។ ភិក្ខុមិនមានសេសនាសនៈ មិនគួរនៅចាំវស្សាឡើយ នេះជាបវេណី ។ ព្រោះហេតុនោះ ព្រះបច្ចេកពុទ្ធទាំងនោះគិតថា អាត្មាអញនឹងត្រូវសូមហត្ថកម្ម ទើបឃ្លុំចីវរចូលទៅកាន់នគរក្នុងពេលល្ងាច ឈរត្រង់ទ្វារផ្ទះរបស់សេដ្ឋី ។ នាងទាសីដែលជាប្រធានកាន់ក្អមទឹក កំពុងដើរទៅកំពង់ទឹក ឃើញព្រះបច្ចេកពុទ្ធទាំងឡាយនិមន្តចូលព្រះនគរ ។ សេដ្ឋីដឹងហេតុដែលព្រះបច្ចេកពុទ្ធទាំងនោះមកហើយ ក៏ពោលថា ខ្ញុំមិនមានពេលទេ សូមលោកម្ចាស់និមន្តទៅចុះ ។ គ្រានោះ ទាសីដែលជាប្រធានកាន់ក្អមទឹកចូលទៅ ឃើញព្រះបច្ចេកពុទ្ធទាំងនោះ កំពុងនិមន្តអំពីព្រះនគរ ទើបដាក់ក្អមទឹកចុះថ្វាយបង្គំ សួរថា ហេតុអ្វីហ្ន៎ ទើបលោកម្ចាស់ទាំងឡាយ គ្រាន់តែចូលទៅហើយ ក៏ចេញមកវិញ ។ ព្រះបច្ចេកពុទ្ធឆ្លើយថា អាត្មានាំគ្នាមកដើម្បីសូមហត្ថកម្ម ធ្វើកុដិសម្រាប់នៅចាំវស្សា ។ ទើបនាងសួរថា បានដែរឬលោកម្ចាស់ ។ ព្រះបច្ចេកពុទ្ធឆ្លើយថា មិនបានទេ ឧបាសិកា ។ នាងសួរថា ចាំបាច់ឬដែលមនុស្សអ្នកមានៗ ប៉ុណ្ណោះ ទើបធ្វើកុដិនោះបាន ឬអ្នកក្រីក្រក៏ធ្វើបាន ។ ព្រះបច្ចេកពុទ្ធពោលថា បុគ្គលណាក៏ធ្វើបាន ។ ទើបនាងពោលថា សាធុ លោកម្ចាស់ ពួកខ្ញុំនឹងនាំគ្នាធ្វើ សូមលោកម្ចាស់ទទួលអាហារ

របស់ខ្ញុំក្នុងថ្ងៃស្អែកនេះ និមន្តហើយ ក៏កាន់ក្អមទឹក ដាក់ត្រង់កំពង់ទឹកដែលមកហើយ ពោលនឹងទាសីទាំងឡាយថា ពួកនាងនៅត្រង់នេះឯង ពេលទាសីទាំងនោះមក ក៏ពោលថា ពួកនាងទាំងឡាយ ពួកយើងនឹងធ្វើការងារជាទាសីសម្រាប់អ្នកដទៃរហូតឬ ឬចង់ផុតចាកភាពជាទាសី ។ ពួកទាសីក៏ឆ្លើយថា ពួកខ្ញុំចង់ផុតអំពីទាសីក្នុងថ្ងៃនេះឯង ។ ទើបនាងពោលថា បើដូច្នោះ ព្រះបច្ចេកពុទ្ធ ៥០០ ដែលមិនទាន់បានហត្ថកម្ម ខ្ញុំក៏និមន្តឲ្យឆាន់ក្នុងថ្ងៃស្អែកនេះហើយ ពួកនាងចូរឲ្យប្តីរបស់ពួកនាង ឲ្យហត្ថកម្មមួយថ្ងៃ ពួកទាសីក៏ពោលថា សាធុ ហើយប្រាប់ប្តី ក្នុងកាលដែលប្តីទាំងនោះចេញមកអំពីព្រៃ ក្នុងពេលល្ងាច ។ ប្តីទាំងនោះយល់ព្រមហើយ ក៏មកប្រជុំគ្នាត្រង់ទ្វារផ្ទះទាសីដែលជាប្រធាន ។ គ្រានោះ ទើបទាសីដែលជាប្រធានពោលថា នែអ្នកទាំងឡាយ ស្អែកនេះពួកអ្នកចូរឲ្យហត្ថកម្មដល់ព្រះបច្ចេកពុទ្ធទាំងឡាយផង ហើយប្រាប់អានិសង្ស បន្ទំបុគ្គលដែលមិនចង់ធ្វើដោយឱវាទដ៏ធ្ងន់ ឲ្យគ្រប់គ្នាយល់ព្រម ។ ស្អែកឡើង នាងប្រគេនអាហារដល់ព្រះបច្ចេកពុទ្ធហើយ ឲ្យសញ្ញាដល់កូនទាសៈគ្រប់គ្នា រំពេចនោះឯង កូនទាសៈទាំងនោះ ក៏នាំគ្នាចូលព្រៃប្រមូលទព្វសម្ភារៈហើយ ធ្វើកុដិម្នាក់មួយៗ រៀបចំបរិវេណ មានទីចង្ក្រមជាដើម ដាក់គ្រែ តាំង ទឹកឆាន់ ទឹកប្រើប្រាស់ជាដើម ឲ្យព្រះបច្ចេកពុទ្ធទាំងឡាយទទួលបដិញ្ញា នៅចាំវស្សាក្នុងទីនោះអស់ត្រៃមាស ហើយដាក់វេនថ្វាយកត្តាហារ ។ ទាសីណា មិនអាចថ្វាយក្នុងថ្ងៃវេនរបស់ខ្លួនបាន ទាសីជាប្រធាន នាំអាហារអំពីផ្ទះរបស់ខ្លួនថ្វាយជំនួសទាសីនោះ ។ ទាសីជាប្រធាន

ផ្គត់ផ្គង់អស់ត្រៃមាសយ៉ាងនេះ ឲ្យទាសីម្នាក់ៗ រៀបចំសំពត់សាដកម្នាក់មួយផ្ទាំង រួមជាសំពត់សាដកសាច់គ្រោតគ្រាត ៥០០ ផ្ទាំង ។ នាងឲ្យផ្លាស់ប្តូរសំពត់សាដកសាច់គ្រោតគ្រាតទាំងនោះ ធ្វើជាត្រៃចីវរថ្វាយព្រះបច្ចេកពុទ្ធ ៥ រយអង្គ ។ ព្រះបច្ចេកពុទ្ធទាំងឡាយ ទៅកាន់ភ្នំគន្ធមាទន៍តាមអាកាស ដោយឲ្យទាសីទាំងនោះឃើញនោះឯង ។

ទាសីទាំងនោះធ្វើកុសលដរាបដល់អស់ជីវិត កើតក្នុងទេវលោក ។ បណ្តាទាសីទាំងនោះ ទាសីប្រធានចុតិអំពីកពនោះហើយ កើតក្នុងផ្ទះរបស់មេជាងតម្បាញ មិនឆ្ងាយអំពីក្រុងពារាណសី ។ ថ្ងៃមួយ ព្រះបច្ចេកពុទ្ធ ៥ រយអង្គ ជាបុត្ររបស់នាងបទុមវតី ដែលព្រះបាទក្រុងពារាណសីនិមន្តមកដល់ទ្វារព្រះរាជនិវេសន៍ មិនជួបបុគ្គលណាម្នាក់មើលថែ ទើបត្រឡប់ចេញទៅតាមទ្វារក្រុង ទៅកាន់ភូមិជាងតម្បាញនោះ ។ ស្រីនោះឃើញព្រះបច្ចេកពុទ្ធទាំងឡាយ នឹកអាណិតអាសូរ ក៏ថ្វាយបង្គំគ្រប់អង្គ ហើយប្រគេនភត្ត ព្រះបច្ចេកពុទ្ធទាំងឡាយឆាន់អាហារស្រេចហើយ ក៏ទៅកាន់ភ្នំគន្ធមាទន៍វិញ ។

ស្រីនោះ ធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលទៅមកក្នុងទេវតានិងមនុស្ស បដិសន្ធិក្នុងផ្ទះរបស់ព្រះបាទសុប្បពុទ្ធ នានគរទេវទហៈ មុនព្រះសាស្តានៃយើងកើតឡើង ។ ព្រះញាតិថ្វាយព្រះនាមនាងថា គោតមី ជាកនិដ្ឋកតិនី គឺប្អូនស្រីរបស់ព្រះនាងមហាមាយា ។ ពួកព្រាហ្មណ៍ដែលជំនាញក្នុងមន្ត ពិនិត្យមើលលក្ខណៈហើយ ព្យាករណ៍ថា ទារកដែលនៅក្នុងព្រះគភ៌

របស់ព្រះនាងទាំង ២ អង្គ នឹងបានជាស្តេចចក្រពត្តិ ។ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ធ្វើមង្គលអភិសេកជាមួយព្រះនាងទាំង ២ អង្គ ក្នុងកាលដែលទ្រង់ចម្រើនវ័យហើយ ទ្រង់នាំទៅកាន់ព្រះរាជនិវេសន៍របស់ព្រះអង្គ ។ ចំណេរតមក ព្រះពោធិសត្វនៃយើង ចុតិអំពីស្ថានសួគ៌ ជាន់តុសិត ទ្រង់បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាមាយាទេវី ក្នុងថ្ងៃទី ៧ តាំងអំពីថ្ងៃដែលព្រះពោធិសត្វប្រសូតហើយ ព្រះនាងមហាមាយាទេវីក៏សោយទិវង្គត-ល័យ កើតក្នុងស្ថានសួគ៌ជាន់តុសិត ព្រះបាទសុទ្ធោទនមហារាជ ក៏ទ្រង់ស្ថាបនាព្រះនាងមហាបជាបតីគោតមីព្រះមាតុច្ឆារបស់ព្រះមហាសត្វ ទុកក្នុងតំណែងព្រះអគ្គមហេសី វេលានោះ នន្ទកុមារក៏ប្រសូត ព្រះមហាបជាបតីនេះ ប្រគល់នន្ទកុមារដល់ស្រីគីលៀង ទ្រង់បីបាច់រក្សាព្រះមហាសត្វដោយព្រះអង្គឯង ។ សម័យតមក ព្រះពោធិសត្វចេញមហាភិនេស្ក្រមណ៍ សម្រេចព្រះសព្វញ្ញុតញ្ញាណ ទ្រង់អនុគ្រោះលោក យាងដល់នគរកបិលពស្តុ យាងចូលទៅបិណ្ឌបាតក្នុងព្រះនគរ ។ គ្រានោះ ព្រះបាទសុទ្ធោទនមហារាជពុទ្ធបិតា ទ្រង់ស្តាប់ធម្មកថាក្នុងរវាងផ្លូវ បានជាព្រះសោតាបន្ន ។ ក្នុងថ្ងៃទី ២ ព្រះនន្ទកុមារក៏ទ្រង់ផ្នួស ថ្ងៃទី ៧ ព្រះរាហុលក៏ទ្រង់ផ្នួស បន្ទាប់មក ព្រះសាស្តាទ្រង់អាស្រ័យក្រុងវេសាលី ប្រថាប់នៅនាកូដាគារសាលា ។ សម័យនោះ ព្រះបាទសុទ្ធោទនមហារាជ ទ្រង់ធ្វើឲ្យជាក់ច្បាស់នូវព្រះអរហត្ត ហើយបរិនិព្វានខាងក្រោមមហាសេ្វតច្ឆត្រ ។

គ្រានោះ ព្រះនាងមហាបជាបតីមានព្រះហឫទ័យចង់បួស បន្ទាប់អំពី

នោះ នាងបាទបរិចារិការបស់ព្រះរាជកុមារ ៥០០ អង្គ ដែលទ្រង់យាងចេញផ្នួស ក្នុងកាលចប់កលហវិវាទសូត្រ ត្រង់ប្រាំងស្ទឹងរោហិណី ទាំងអស់គ្នាជាអ្នកមានចិត្តតែមួយថា ពួកយើងនឹងចូលទៅគាល់ព្រះនាងមហាបជាបតី ហើយបួសក្នុងសម្នាក់របស់ព្រះសាស្ដាទាំងអស់គ្នា ទើបឲ្យព្រះនាងមហាបជាបតីជាប្រធាន បំណងនឹងទៅគាល់ព្រះសាស្ដា ។ ព្រះនាងមហាបជាបតីទ្រង់ទូលសូមបព្វជ្ជានឹងព្រះសាស្ដាក្នុងលើកទី ១ មិនបាន ព្រោះហេតុនោះទើបព្រះនាងប្រើឲ្យហៅខ្មាន់ព្រះកេសមកហើយ ឲ្យកោរព្រះកេសា ទ្រទ្រង់សំពត់កាសាវពស្ត្រ ទ្រង់នាំពួកនាងសាកិយានីទាំងអស់នោះ ធ្វើដំណើរដល់ក្រុងវេសាលី ឲ្យព្រះអានន្ទទូលសូមព្រះទសពល ព្រះនាងបានបព្វជ្ជាឧបសម្បទាដោយគរុធម៌ ៨ ប្រការ ។ ចំណែកសាកិយានីទាំងអស់ ក៏បានឧបសម្បទាព្រមគ្នា នេះជាសេចក្ដីសង្ខេបក្នុងរឿងនេះ ។ ឯរឿងនេះ ដោយពិស្ដារមកហើយក្នុងព្រះបាលី ។ ព្រះនាងមហាបជាបតី កាលឧបសម្បទាយ៉ាងនេះហើយ ចូលគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ ប្រថាប់ក្នុងទីសមគួរ នាចំណែកម្ខាង កាលនោះ ព្រះសាស្ដាទ្រង់សម្ដែងធម៌ប្រោសព្រះនាងៗ ទទួលកម្មដ្ឋានក្នុងសម្នាក់ព្រះសាស្ដាមួយព្រះអង្គឯង ក៏សម្រេចអរហត្ត ។ ភិក្ខុនី ៥០០ ក្រៅអំពីនោះ ក៏សម្រេចអរហត្ត កាលចប់នន្ទកោវាទសូត្រ ។ រឿងនេះកើតឡើងដោយប្រការដូច្នេះ ចំណោរតមក ព្រះសាស្ដាប្រថាប់គង់ក្នុងជេតពនមហាវិហារ កាលទ្រង់ស្ថាបនាភិក្ខុនី ទាំងឡាយក្នុងតំណែងឯតទគ្គៈច្រើនតំណែង ទើបទ្រង់ស្ថាបនាព្រះនាងមហាបជាបតីទុកក្នុងតំណែងឯតទគ្គៈ

ជាកំពូលជាងភិក្ខុនីសាវិកាដែលជារត្តញ្ញូ គឺជាអ្នកដឹងរាត្រីយូរ ដូច្នេះ ។

## អដ្ឋកថា សូត្រទី ១ ចប់

# អដ្ឋកថា សូត្រទី ២
# ប្រវត្តិ ព្រះនាងខេមាថេរី

ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ខេមា** បានដល់ភិក្ខុនីមានឈ្មោះយ៉ាងនេះ ។ តាំងអំពីនេះទៅ ខ្ញុំនឹងពោលក្នុងបញ្ហាកម្មរបស់នាង មានរឿងពោលតាមលំដាប់ដូច្នេះ ហើយនឹងពោលសេចក្តីនេះ គួរពោលតាំងអំពីអភិនីហារជាដើមទៅគ្រប់យ៉ាង ។

បានឮមកថា ក្នុងអតីតកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ ព្រះនាងខេមានេះកើតទាក់ទងជាមួយមនុស្សដទៃ ក្នុងក្រុងហង្សវតី ។ ថ្ងៃមួយ នាងជួបព្រះនាងសុជាតថេរី អគ្គសាវិការបស់ព្រះមានព្រះភាគអង្គនោះ កំពុងត្រាច់បិណ្ឌបាត ទើបប្រគេននំ ៣ ដុំក្នុងថ្ងៃនោះឯង ក៏រៀបចំផ្ទះរបស់ខ្លួន រួចថ្វាយទាន នាងក៏ធ្វើសេចក្តីប្រាថ្នាថា ខ្ញុំគប្បីមានបញ្ញាច្រើន ដូចព្រះនាងម្ចាស់ក្នុងពុទ្ធុប្បាទកាលព្រះពុទ្ធអង្គណាមួយ ក្នុងអនាគត ជាអ្នកមិនប្រមាទ ក្នុងកុសលកម្មទាំងឡាយ ដរាបដល់អស់ជីវិត អន្ទោលទៅក្នុងទេវតា និងមនុស្សមួយសែនកប្ប លុះព្រះសម្ពុទ្ធព្រះនាមកស្សបៈកើតឡើង ក៏បដិសន្ធិក្នុងព្រះ

រាជនិវេសន៍របស់ព្រះបាទកិកិ ជាបុត្រីក្នុងរវាងបងប្អូន ៧ អង្គ ព្រះនាងប្រព្រឹត្ត កុមារិព្រហ្មចរិយៈ ក្នុងព្រះរាជនិវេសន៍អស់ ២ ម៉ឺនឆ្នាំ មួយអន្លើដោយបងប្អូនរបស់នាងទាំងនោះ សាងបរិវេណទីគង់ប្រថាប់របស់ព្រះទសពល អន្ទោលទៅក្នុងទេវតា និងមនុស្ស អស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងរាជត្រកូល សាគលនគរ ក្នុងមទ្ទរដ្ឋ ព្រះញាតិថ្វាយព្រះនាមរបស់នាងថា ខេមា ព្រះនាងមានព្រះឆវីវណ្ណនៃព្រះវរកាយរុងរឿងដូចទឹកមាស លុះចម្រើនព្រះជន្មវស្សា ក៏យាងទៅកាន់ព្រះរាជនិវេសន៍ គឺជាព្រះទេវីរបស់ព្រះបាទពិម្ពិសារ ។ កាលព្រះតថាគត ទ្រង់អាស្រ័យក្រុងរាជគ្រឹះ គង់ប្រថាប់នៅនាវេឡុវនមហាវិហារ ព្រះនាងទ្រង់បានឮថា ព្រះសាស្តាទ្រង់សម្តែងទោសក្នុងរូប ដោយព្រះនាងជាអ្នកស្រវឹងក្នុងរូប មិនហ៊ានទៅគាល់ព្រះទសពល ដោយព្រះនាងខ្លាចព្រះសាស្តាទ្រង់សម្តែងទោសក្នុងរូប ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អាត្មាអញ ជាអគ្គឧបដ្ឋាករបស់ព្រះសាស្តា តែអគ្គមហេសីរបស់អរិយសាវកដូចអាត្មាអញ ក៏មិនទៅគាល់ព្រះទសពល សេចក្តីនេះអាត្មាអញមិនពេញចិត្តឡើយ ទើបទ្រង់ឲ្យពួកកវីនិពន្ធគុណសម្បត្តិរបស់វេឡុវនឧទ្យានថា ពួកអ្នកចូរប្រគំក្បែរៗ ព្រះនាងល្មមនាងបានឮ ព្រះនាងទ្រង់ស្តាប់ពាក្យពណ៌នាគុណរបស់ព្រះរាជឧទ្យាន ក៏មានបំណងយាងទៅ ទើបក្រាបទូលសាកសួរព្រះរាជា ព្រះរាជាត្រាស់ថា ទៅឧទ្យានបាន តែបើមិនបានគាល់ព្រះសាស្តា កុំត្រឡប់មក ព្រះនាងមិនថ្វាយចម្លើយដល់ព្រះរាជាក៏យាងទៅតាមផ្លូវ ។ ព្រះរាជាបញ្ជាពួកបុរសដែលទៅជាមួយព្រះនាងថា បើព្រះទេវីត្រឡប់អំពីឧទ្យាន គាល់

ព្រះទសពលបាន យ៉ាងនេះក៏ជាការល្អ បើមិនបានគាល់ ពួកអ្នកចូរប្រើរាជ-អាជ្ញាបង្ហាញដល់ព្រះនាង ។ គ្រានោះ ព្រះនាងយាងទតព្រះឧទ្យានអស់មួយថ្ងៃ កាលយាងត្រឡប់ ក៏មិនចូលគាល់ព្រះទសពល ផ្តើមយាងត្រឡប់ ។ តែពួករាជបុរស នាំព្រះនាងទៅកាន់សម្នាក់ព្រះសាស្តា ទាំងដែលព្រះនាងមិនពេញព្រះហឫទ័យ ។

ព្រះសាស្តាទ្រង់ឃើញព្រះនាងកំពុងយាងមក ទើបទ្រង់ប្រើឫទ្ធិនិម្មិតទេពអប្សរមួយរូប ដែលកំពុងកាន់ផ្លិតស្លឹកត្នោតបក់ថ្វាយ ។ ព្រះនាងខេមាទេវី ឃើញទេពអប្សរនោះហើយ ព្រះតម្រិះថា វិនាសហើយអញ ពួកស្ត្រីដែលស្អាតដូចទេពអប្សរបែបនេះ គង់នៅមិនឆ្ងាយអំពីព្រះទសពល ឯអញប្រៀបដូចស្រីបម្រើរបស់ស្រីទាំងនោះ មិនសមគួរសោះ ហេតុអ្វី ទើបអាត្មាអញជាអ្នកវិនាសដោយអំណាចចិត្តដែលគិតអាក្រក់ ព្រោះអាស្រ័យការស្រវឹង ហើយក៏កាន់យកនិមិត្តនោះ ទតស្ត្រីនោះ ។ កាលនាងកំពុងពិចារណាស្រីនោះឯង កម្លាំងនៃការអធិដ្ឋានរបស់ព្រះតថាគត ស្រីនោះកន្លងបឋមវ័យទៅ តាំងនៅក្នុងមជ្ឈិមវ័យ កន្លងមជ្ឈិមវ័យទៅ តាំងនៅក្នុងបច្ឆិមវ័យ ជាអ្នកមានស្បែកជ្រួញជ្រីវ ធ្មេញបាក់ សក់ស្កូវ ។ បន្ទាប់អំពីនោះ ខណៈព្រះនាងកំពុងមើលនោះឯង ស្រីនោះក៏ដួលចុះ ព្រមទាំងផ្លិតស្លឹកត្នោត ។ សម័យនោះ ព្រះនាងខេមា កាលអារម្មណ៍នោះមកកាន់វិថី ព្រោះជាអ្នកសម្បូរដោយបុព្វហេតុ ទើបព្រះតម្រិះយ៉ាងនេះថា សរីរៈមានសភាពយ៉ាងនេះ គង់ដល់នូវការវិបរិតយ៉ាងនេះបាន ឯសរីរៈរបស់អញ ក៏នឹងមានគតិយ៉ាងនេះដូចគ្នា ។ គ្រា

ដែលព្រះនាងមានព្រះតម្រិះយ៉ាងនេះ ទើបព្រះសាស្តាត្រាស់ព្រះគាថាក្នុងធម្មបទថា

**យេ រាគរត្តានុបតន្តិ សោតំ សយំ កតំ មក្កដកោវ ជាលំ**
**ឯតម្បិ ឆេត្វាន វជន្តិ ធីរា អនបេក្ខិនោ សព្វទុក្ខំ បហាយ ។**

*ពួកជនណា ត្រេកអរដោយអំណាចរាគៈ ពួកជននោះ តែងធ្លាក់ចុះកាន់ខ្សែតណ្ហា ដូចពីងពាងទម្លាក់ខ្លួនចុះកាន់សំណាញ់ដែលធ្វើហើយ ដោយខ្លួនឯង អ្នកប្រាជ្ញទាំងឡាយ តែងកាត់ខ្សែតណ្ហានោះ ជាអ្នកមិនមានសេចក្តីអាឡោះអាល័យ លះទុក្ខទាំងពួងចេញទៅ ។*

ចប់ព្រះគាថា ព្រះនាងប្រថាប់ឈរ ក្នុងឥរិយាបថឈរនោះឯង ក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ធម្មតាអ្នកគ្រប់គ្រងផ្ទះ សម្រេចអរហត្ត ចាំបាច់ត្រូវបរិនិព្វាន ឬបួសក្នុងថ្ងៃនោះឯង ។ ព្រះនាងដឹងថា អាយុសង្ខាររបស់ព្រះនាងនៅប្រព្រឹត្តទៅបាន ព្រះនាងត្រិះរិះថា អាត្មាអញនឹងឲ្យព្រះរាជាទ្រង់អនុញ្ញាតការបួស ទើបយាងត្រឡប់មកព្រះរាជនិវេសន៍ មិនថ្វាយបង្គំព្រះរាជា ប្រថាប់ឈរ ។ ព្រះរាជាក៏ទ្រង់ជ្រាបដោយសញ្ញា គឺព្រះអាការថា ព្រះនាងគង់សម្រេចអរិយធម៌ហើយ ។ ទើបព្រះរាជាត្រាស់នឹងព្រះនាងថា ព្រះទេវីយាងទៅគាល់ព្រះសាស្តាហើយឬ ព្រះនាងទូលថា បពិត្រមហារាជ ខ្ញុំម្ចាស់ប្រព្រឹត្តទស្សនៈ ដូចដែលទ្រង់ឃើញហើយ ខ្ញុំម្ចាស់បានធ្វើព្រះទសពលឲ្យជាបុគ្គលដែលខ្ញុំម្ចាស់ឃើញល្អហើយ សូមទ្រង់អនុញ្ញាត

*ការបំពេញបព្វជ្ជាដល់ខ្ញុំម្ចាស់ចុះ ។ ព្រះរាជាត្រាស់ថា សាធុ ព្រះទេវី ហើយទ្រង់នាំទៅកាន់សម្នាក់ ភិក្ខុនីដោយវមាស ឲ្យព្រះនាងបួស ។ គ្រានោះ ភាពដែលព្រះនាងមានព្រះបញ្ញាច្រើន ប្រាកដថា ព្រះនាងខេមាថេរីសម្រេចអរហត្តតាំងអំពីនៅក្នុងភេទជាគ្រហស្ថ ក្នុងសេចក្ដីនេះមានរឿងដូច្នេះ ។ បន្ទាប់មកក្នុងកាលជាក្រោយ ព្រះសាស្ដាប្រថាប់នាវត្តជេតពនវិហារ កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះនាងខេមាថេរីក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកា អ្នកមានបញ្ញាច្រើន ដូច្នេះ ៕*

**អដ្ឋកថាសូត្រទី ២ ចប់**

# អដ្ឋកថា សូត្រទី ៣
# ប្រវត្តិ ព្រះនាងឧប្បលវណ្ណាថេរី

ក្នុងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ឧប្បលវណ្ណា** បានដល់ ព្រះថេរីមានឈ្មោះយ៉ាងនេះ ក៏ព្រោះប្រកបដោយពណ៌សម្បុរដូចផ្កាឧប្បល ។

បានឮថា ឧប្បលវណ្ណាថេរីនេះ ក្នុងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ក្រោយមកទៅកាន់សម្នាក់ព្រះសាស្តា មួយអន្លើដោយមហាជន កំពុងស្តាប់ធម៌ ឃើញព្រះសាស្តាស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកាខាងមានឫទ្ធិ ទើបថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ប្រាថ្នាតំណែងនោះ ។ នាងធ្វើកុសលដរាបដល់អស់ជីវិត អន្ទោលក្នុងទេវតា និងមនុស្ស កាលព្រះពុទ្ធព្រះនាមកស្សបៈកើតឡើង នាងក៏បដិសន្ធិក្នុងព្រះរាជនិវេសន៍នៃព្រះរាជាព្រះនាមកិកិ នាក្រុងពារាណសី ជាព្រះធីតាមួយអង្គ ក្នុងវាំងធីតា ៧ អង្គ ប្រព្រឹត្តព្រហ្មចរិយៈអស់ ២ ម៉ឺនឆ្នាំ ធ្វើបរិវេណថ្វាយភិក្ខុសង្ឃ កើតក្នុងទេវលោក ចុតិអំពីទេវលោកនោះ មកកាន់មនុស្សលោកទៀត កើតក្នុងលំនៅរបស់មនុស្សដែលធ្វើការងារដោយដៃចិញ្ចឹមជីវិត ក្នុងតំបន់មួយ ។ ថ្ងៃមួយ នាងទៅកាន់ខ្ទមឯស្រែ តាមផ្លូវនាងឃើញឈូករីកអំពីព្រហាម ក្នុងស្រះមួយ ចុះកាន់ស្រះនោះហើយ ក៏បេះផ្កាឈូកនោះ មួយអន្លើដោយស្លឹក ដើម្បីដាក់លាជ ក្តិចកួរស្រូវសាលីក្បែរភ្លឺស្រែ អង្គុយក្នុងខ្ទមលីងលាជ រាប់បាន ៥០០ គ្រាប់ ខណៈនោះ ព្រះបច្ចេកពុទ្ធមួយអង្គ ចេញអំពីនិរោធ-

សមាបត្តិ ត្រង់ភ្នំគន្ធមាទន៍ មកប្រាកដក្បែរនាង ។ នាងឃើញព្រះបច្ចេកពុទ្ធ ក៏កាន់ផ្កាឈូក មួយអន្លើដោយលាជអំពីខ្ទម ដាក់លាជក្នុងបាត្ររបស់ព្រះបច្ចេកពុទ្ធ បិទបាត្រដោយផ្កាឈូកប្រគេន ។ គ្រានោះ ព្រះបច្ចេកពុទ្ធនិមន្តទៅបានបន្តិច នាងក៏គិតថា ធម្មតាបព្វជិត មិនត្រូវការផ្កាឡើយ អញនឹងទៅយកផ្កាមកប្រដាប់ ហើយទៅយកផ្កាអំពីដៃព្រះបច្ចេកពុទ្ធ ហើយគិតទៀតថា បើលោកមិនត្រូវការផ្កាសោត លោកនឹងមិនដាក់ផ្កានោះលើបាត្រឡើយ លោកពិតជាត្រូវការ ហើយដាក់លើបាត្រទៀត សូមខមាទោសហើយ ធ្វើសេចក្តីប្រាថ្នាថា បពិត្រលោកម្ចាស់ ដោយផលានិសង្សនៃលាជទាំងនេះ ខ្ញុំសូមមានបុត្រស្មើនឹងចំនួនគ្រាប់លាជ ដោយផលានិសង្សនៃផ្កាឈូក សូមផ្កាឈូកផុសឡើងគ្រប់ជំហានរបស់ខ្ញុំ ក្នុងទីដែលខ្ញុំកើតហើយ ។ ខណៈដែលនាងកំពុងឃើញនោះឯង ព្រះបច្ចេកពុទ្ធទៅកាន់ភ្នំគន្ធមាទន៍តាមអាកាស ដាក់ផ្កាឈូកនោះសម្រាប់ជូតជើងក្បែរជណ្តើរ ដែលព្រះបច្ចេកពុទ្ធទាំងឡាយជន់ក្នុងញកភ្នំនន្ទមូលកៈ ដោយផលនៃទាននោះ នាងបដិសន្ធិក្នុងទេវលោក ។ ចាប់តាំងអំពីកាលដែលនាងកើត ផ្កាឈូកធំ ក៏ផុសឡើងគ្រប់ជំហានរបស់នាង ។

នាងចុតិអំពីទេវលោកនោះហើយ ក៏កើតក្នុងផ្កាឈូកក្នុងស្រះមួយ ក្បែរជើងភ្នំ ។ តាបសនោះទៅកាន់ស្រះអំពីព្រលឹម ដើម្បីលុបមុខ ឃើញផ្កានោះហើយក៏គិតថា ផ្កានេះធំជាងផ្កាដទៃៗ ផ្កាដទៃៗ រីក ផ្កានេះក្រពុំ គង់មានហេតុក្នុងផ្កានោះ ហើយទើបចុះទឹកចាប់ផ្កានោះ ។ គ្រាន់តែតាបសចាប់

ប៉ុណ្ណោះ ផ្កាក៏រីក ។ តាបសឃើញទារិកាដេកខាងក្នុងផ្កា មានសេចក្ដីស្រឡាញ់ ដូចកូនស្រី តាំងអំពីបានជួប ទើបនាំទៅកាន់បណ្ណសាលាទាំងផ្កាឈូក ឲ្យដេក លើគ្រែ ។ ខណៈនោះ ដោយបុញ្ញានុភាពរបស់នាង ទឹកដោះក៏កើតត្រង់ ម្រាមមេដៃ ។ តាបសនោះ កាលផ្កាឈូកនោះក្រៀម ក៏នាំយកផ្កាឈូក ដទៃមកជំនួស ឲ្យទារិកានោះដេកលក់ ។ តាំងអំពីទារិកានោះអាចរត់លេង ទៅមកបាន ផ្កាឈូកក៏ផុសទ្រគ្រប់ៗ ជំហាន ។ ពណ៌សម្បុរនៃសរីរៈរបស់ នាងដូចផ្កាឈូក ។ ទារិកានោះមិនទាន់ចម្រើនវ័យ ពណ៌សម្បុរមិនដល់ពណ៌ សម្បុរទេវតា តែក្រៃលែងជាងពណ៌សម្បុរមនុស្ស ។ កាលឥសីបិតាទៅ ស្វែងរកផ្លែឈើ ទារិកានោះក៏ត្រូវទុកចោលត្រង់បណ្ណសាលា ។

លុះចម្រើនវ័យហើយ ថ្ងៃមួយ កាលឥសីបិតា ទៅស្វែងរកផលាផល ព្រានព្រៃម្នាក់ ឃើញនាងក៏គិតថា ឈ្មោះថា មនុស្សរូបរាងយ៉ាងនេះមិនមាន អញនឹងសាកសួរនាង ហើយអង្គុយរង់ចាំការមករបស់តាបស ។ កាលបិតា ត្រឡប់មក នាងក៏ដើរទៅទទួលសម្រែកអំពីដៃរបស់តាបសនោះដោយខ្លួនឯង ហើយសម្តែងវត្តដែលខ្លួនធ្វើដល់តាបស ដែលអង្គុយហើយ ។ គ្រានោះ នាយ ព្រានព្រៃ ក៏ដឹងថា នាងជាមនុស្ស ទើបថ្វាយបង្គំតាបស ហើយអង្គុយចុះ តាបសទទួលដោយផ្លែឈើតូចធំ មួយអន្ទើដោយទឹក ហើយសួរថា នែបុរស អ្នកស្នាក់នៅក្នុងទីនេះ ឬក៏ទៅ ព្រានព្រៃឆ្លើយថា ខ្ញុំនឹងទៅ នៅក្នុងទីនេះនឹង ធ្វើអ្វីបាន តាបសសំណូមពរថា ហេតុដែលអ្នកឃើញនេះ កុំនិយាយឡើយ។ ព្រានទទួលថា បើលោកម្ចាស់ មិនបំណង ខ្ញុំនឹងពោលធ្វើអ្វី ហើយថ្វាយបង្គំ

តាបស ធ្វើមែកឈើ ស្នាមជើង និងនិមិត្តសញ្ញាដើមឈើ ទុកក្នុងកាល ដែលនឹងមកទៀត ក៏ចៀសចេញទៅ ។

នាយព្រានព្រៃនោះ ទៅកាន់ក្រុងពារាណសីគាល់ព្រះរាជា ។ ព្រះរាជាត្រាស់សួរថា ហេតុអ្វី ទើបមក ។ ព្រានក្រាបទូលថា បពិត្រទេវៈ ទូលបង្គំជាព្រានព្រៃ ជួបឥត្ថីរតនៈដែលគួរអស្ចារ្យត្រង់ជើងភ្នំ ទើបមកគាល់ ហើយទូលរឿងទាំងអស់ថ្វាយ ។ ព្រះរាជាស្តាប់ពាក្យរបស់ព្រានព្រៃនោះហើយប្រញាប់យាងទៅកាន់ជើងភ្នំ បោះព្រះពន្លាស្នាក់ក្នុងទីមិនឆ្ងាយ ទើបទៅជាមួយព្រានព្រៃ និងពួករាជបុរសដទៃៗ យាងទៅទីនោះ ក្នុងកាលតាបសកំពុងឆាន់ភត្ត ទ្រង់អភិវាទធ្វើបដិសណ្ឋារៈ ហើយប្រថាប់គង់ ព្រះរាជាទ្រង់ដាក់គ្រឿងបរិក្ខារ សម្រាប់អ្នកបួសទុកទៀបបាទជើងតាបស ត្រាស់ថា បពិត្រលោកម្ចាស់ ពួកខ្ញុំនឹងធ្វើអ្វីមួយ ក៏នឹងទៅ តាបសទូលថា សូមយាងទៅចុះ ។ ព្រះរាជាត្រាស់ថា បពិត្រលោកម្ចាស់ ខ្ញុំនឹងទៅ បានឮថា បរិស័ទដែលជាសត្រូវនៅក្បែរ លោកម្ចាស់មានបរិស័ទនោះ ឈ្មោះថា ជាអ្នកធ្វើឲ្យការបដិបត្តិយឺតយូរដល់អ្នកបួសទាំងឡាយ សូមបរិស័ទនោះទៅជាមួយខ្ញុំចុះ ។ តាបសទូលថា ចិត្តរបស់មនុស្សអាក្រក់ពេក ស្រីនេះ នឹងនៅកណ្តាលពួកមនុស្សបានដូចម្តេច ។ ព្រះរាជាត្រាស់ថា តាំងអំពីខ្ញុំពេញចិត្តនាង ក៏នឹងតាំងទុកក្នុងតំណែងជាធំជាងពួកមនុស្សដទៃៗ ទំនុកបម្រុង ។ តាបសស្តាប់ព្រះរាជតម្រាស់ហើយ ក៏ហៅធីតាដោយឈ្មោះដែលតាំងទុកអំពីកំណើតថា បទុមវតីកូន ។ ដោយពាក្យហៅត្រឹមតែមួយមាត់ នាងក៏ចេញអំពីសាលាស្លឹក

ឈរថ្វាយបង្គំបិតា ។ ទើបឥសីពោលនឹងនាងថា កូនចម្រើនវ័យហើយ មិនអាចនៅក្នុងទីនេះបានដោយផាសុកឡើយ តាំងអំពីព្រះរាជាទ្រង់ជួបហើយ ចូរកូនទៅជាមួយព្រះរាជាចុះ ។ នាងទទួលពាក្យបិតាថា ចា៎ះ លោកឪពុក ថ្វាយបង្គំបិតាហើយ ដើរយំទៅ ។ ព្រះរាជាទ្រង់ព្រះតម្រិះថា អញត្រូវចងចិត្តបិតារបស់ស្រីនេះ ទើបដាក់នាងលើគំនរកហាបណៈ ហើយទ្រង់ធ្វើអភិសេក ។

តាំងអំពីព្រះរាជា ទ្រង់នាំព្រះនាងមកដល់នគរ ទ្រង់មិនសម្លឹងមើលស្រីដទៃឡើយ ទ្រង់អភិរម្យជាមួយនាងប៉ុណ្ណោះ ។ ស្រីដទៃៗ ក៏ច្រណែនបំណងនឹងធ្វើនាងឲ្យបែកពីព្រះរាជា ទើបនាំគ្នាក្រាបទូលព្រះរាជាថា បពិត្រមហារាជ ស្រីនេះមិនមែនមនុស្សទេ ផ្កាឈូកទាំងឡាយ ដែលប្រាកដក្នុងទីពួកមនុស្សត្រាច់ទៅ ទ្រង់ជួបហើយ មិនមែនឬ ស្រីនេះជាយក្ខិនីពិត សូមទ្រង់បណ្ដេញវាទៅចុះ ។ ព្រះរាជាទ្រង់ស្ដាប់ពាក្យរបស់ស្ត្រីទាំងនោះ ក៏បានត្រឹមតែនៅស្ងៀម ។ គាប់ជួនសម័យនោះ ជាយដែនមានការបះបោរ ព្រះនាងបទុមវតី ក៏ទ្រង់ព្រះគភ៌ចាស់ ព្រោះដូច្នោះ ទើបទ្រង់ទុកព្រះនាងក្នុងព្រះនគរ យាងទៅជាយដែន ។ គ្រានោះ ទើបស្ត្រីទាំងនោះឲ្យសំណូកអ្នកបម្រើរបស់ព្រះនាងថា នាងចូរនាំទារករបស់ព្រះនាងដែលប្រសូតហើយចេញទៅ យកអង្កត់ឧសមួយលាបឈាម ហើយដាក់ក្បែរៗ ព្រះទែន ។ មិនយូរប៉ុន្មានព្រះនាងបទុមវតីក៏ប្រសូតព្រះមហាបទុមកុមារ ដែលនៅក្នុងព្រះគភ៌មួយព្រះអង្គ ។ ក្រៅអំពីនោះ ទារក ៤៩៩ អង្គ ក៏កើតដោយសំសេទជៈ ក្នុងខណៈដែលព្រះមហាបទុមកុមារ ប្រសូតចាកព្រះគភ៌របស់ព្រះមាតាហើយ

ផ្ទំ ខណៈនោះ ស្រីបម្រើដឹងថា ព្រះនាងបទុមវតីមិនទាន់មានស្មារតី ក៏យកកំណាត់ឈើមួយលាបឈាម ដាក់ក្បែរៗ ហើយឲ្យសញ្ញាដល់ស្រីទាំងនោះ ស្រីទាំង ៥០០ នាក់ ក៏ទទួលទារកម្នាក់មួយអន្លើៗ ទៅកាន់សម្នាក់ពួកជាងក្រឡឹង ឲ្យនាំជន្ទាប់ទាំងឡាយមកហើយ ឲ្យទារកដេកក្នុងជន្ទាប់នោះ ធ្វើត្រាជាគ្រឿងចំណាំខាងក្រៅ ចំណែកព្រះនាងបទុមវតីដឹងព្រះកាយហើយ សួរស្រីបម្រើនោះថា ខ្ញុំប្រសូតបុត្រឬ នាងស្រីនោះពោលគំហកថា ព្រះនាងនឹងបានទារកអំពីណា មានតែទារកដែលចេញអំពីព្រះគភ៌ព្រះនាងនេះហើយ ក៏ដាក់កំណាត់ឈើដែលប្រឡាក់ឈាម ត្រង់ព្រះភក្ត្រ ។ ព្រះនាងទតឃើញហើយ ក៏ទោសមនស្ស ត្រាស់ថា នាងចូរប្រញាប់ពុះកំណាត់ឈើនោះចេញទៅ បើអ្នកដទៃឃើញខ្មាស់គេ ។ ស្រីនោះស្តាប់រាជសវនីយ៍ ធ្វើជាបំណងល្អ ក៏ពុះកំណាត់ឈើ ហើយដាក់ក្នុងចង្ក្រាន ។

ចំណែកព្រះរាជាត្រឡប់អំពីជាយដែនហើយ រង់ចាំឫក្សល្អ បោះព្រះពន្លាស្នាក់នៅខាងក្រៅព្រះនគរ កាលនោះ ស្ត្រី ៥០០ នាក់ ក៏មកទទួលព្រះរាជា ក្រាបទូលថា បពិត្រសម្មតិទេព ទ្រង់មិនជឿខ្ញុំម្ចាស់ទាំងឡាយថា ខ្ញុំម្ចាស់ទូលហាក់ដូចមិនមានហេតុ សូមទ្រង់សាកសួរស្រីបម្រើព្រះមហេសីមើលចុះ ព្រះទេវីប្រសូតដុំឈើ ។ ព្រះរាជាសាកសួរហេតុនោះហើយ ទ្រង់ព្រះតម្រិះថា ព្រះនាងគង់មិនមែនជាតិមនុស្សពិត ដូច្នេះហើយ ទ្រង់និរទេសព្រះនាងចេញទៅអំពីព្រះរាជនិវេសន៍ លុះព្រះនាងយាងចេញអំពីព្រះរាជ-និវេសន៍ប៉ុណ្ណោះ ផ្កាឈូកទាំងឡាយក៏អន្តរធានទៅ ព្រះសរីរៈក៏មានពណ៌

ថមថយទៅ ព្រះនាងទ្រង់យាងទៅតាមផ្លូវមួយព្រះអង្គឯង ។ កាលនោះស្រី ដែលចម្រើនដោយវ័យម្នាក់ ឃើញព្រះនាង ក៏កើតសេចក្តីស្រឡាញ់ដូចកូន ស្រី ទើបពោលថា នាងទៅណាហ្ន៎ ។ ព្រះនាងត្រាស់ថា ខ្ញុំជាអ្នកដំណើរ កំពុងដើររកទីលំនៅ ។ ស្រីចាស់ជរាពោលថា មកនៅក្នុងទីនេះចុះ ហើយឲ្យ ទីលំនៅ រៀបចំអាហារឲ្យសោយ ។

កាលព្រះនាងនៅក្នុងទីនោះ ដោយទំនងនេះ ស្រី ៥០០ ក៏រួមចិត្តគ្នា ក្រាបទូលព្រះរាជាថា បពិត្រព្រះមហារាជ កាលព្រះអង្គបោះព្រះពន្លា ខ្ញុំម្ចាស់ មានសេចក្តីប្រាថ្នាថា បើទេវៈឈ្នះសង្គ្រាមត្រឡប់មក នឹងលេងឧទកកីឡា ធ្វើពលីកម្មដល់ទេវតាប្រចាំគង្គា សូមទ្រង់ប្រកាសឲ្យជ្រាបរឿងនេះ ។ ព្រះ រាជាសប្បាយព្រះហឫទ័យ ដោយពាក្យទូលស្នើរបស់ស្ត្រីទាំងនោះ យាងទៅ លេងឧទកកីឡា ។ ស្ត្រីទាំងនោះកាន់ជន្ទាប់ដែលបិទយ៉ាងជិត ទៅកាន់ស្ទឹង គ្របបិទបាំងជន្ទាប់ទាំងនោះ ធ្វើជាធ្លាក់ទឹក ហើយបោះជន្ទាប់ទាំងឡាយចោល ជន្ទាប់ទាំងនោះមកជួបជុំគ្នាហើយ ជាប់ត្រង់សំណាញ់ដែលសន្ទឹងខាងក្រោម ខ្សែទឹក ។ បន្ទាប់អំពីនោះ ក្នុងកាលដែលព្រះរាជាទ្រង់លេងឧទកកីឡាស្រេច ហើយ រាជបុរសទាំងឡាយក៏លើកសំណាញ់ឡើង ឃើញជន្ទាប់ទាំងនោះ ទើបនាំទៅព្រះរាជដំណាក់ ព្រះរាជាទតឃើញជន្ទាប់ទាំងឡាយ ទើបត្រាស់ សួរថា អ្វីក្នុងជន្ទាប់ ពួករាជបុរសក្រាបទូលថា មិនទាន់ដឹងទេ ព្រះរាជាទ្រង់ ឲ្យបើកជន្ទាប់ទាំងនោះពិនិត្យមើល ទ្រង់ឲ្យបើកជន្ទាប់ជាក់ព្រះមហាបទុម- កុមារមុនគេ ក្នុងថ្ងៃនោះ ព្រះកុមារទាំងនោះក៏ផ្ទំក្នុងជន្ទាប់ទាំងឡាយ ទឹកដោះ

ក៏កើតត្រង់ម្រាមមេដៃដោយបុញ្ញប្ញទ្ធិ សក្កទេវរាជឲ្យចារឹកអក្សរដាក់ខាងក្នុងជន្ទាប់ ដើម្បីកុំឲ្យព្រះរាជាសង្ស័យថា ព្រះកុមារទាំងនេះប្រសូតក្នុងផ្ទៃរបស់ព្រះនាងបទុមវតី ជាឱរសរបស់ព្រះបាទពារាណសី ស្ត្រី ៥០០ នាក់ ជាសត្រូវរបស់ព្រះនាងបទុមវតី ដាក់កុមារទាំងនោះក្នុងជន្ទាប់ ហើយបោះទៅក្នុងទឹក សូមព្រះរាជាជ្រាបហេតុនេះ លុះបើកជន្ទាប់ ព្រះរាជាទ្រង់អានអក្សរទាំងឡាយ ទតឃើញទារកទាំងឡាយ ទ្រង់លើកព្រះមហាបទុមកុមារឡើងត្រាស់ថា ចូរប្រញាប់ទឹមរថថ្ងៃនេះ ខ្ញុំនឹងទៅក្នុងព្រះនគរ ធ្វើឲ្យជាទីស្រឡាញ់សម្រាប់មេផ្ទះពួកខ្លះ ហើយក៏ឡើងកាន់ប្រាសាទ ទ្រង់ដាក់ថង់ទ្រព្យ ១០០០ កហាបណៈលើ-កដំរី ឲ្យវាយស្គរប្រកាសថា អ្នកណាជួបនាងបទុមវតី អ្នកនោះចូរទទួលថង់ទ្រព្យ ១០០០ កហាបណៈនេះ ។

ព្រះនាងបទុមវតី បានឮប្រកាសនោះហើយ បានឲ្យសញ្ញាដល់ម្ដាយថា បពិត្រអ្នកម៉ែ សូមម៉ែទទួលថង់ទ្រព្យ ១០០០ កហាបណៈអំពីកដំរីចុះ ។ ស្រីចំណាស់ពោលថា ខ្ញុំមិនហ៊ានទទួលយកទ្រព្យច្រើននោះបានទេ ។ ព្រះនាងកាលម្ដាយបដិសេធ ២-៣ ដង ក៏ត្រាស់ថា អ្នកកុំពោលថ្វី ទទួលចុះ ។ ស្រីចាស់គិតថា កូនរបស់អញប្រហែលជាឃើញនាងបទុមវតី ព្រោះដូច្នោះទើបព្រមទទួល ។ ទើបស្រីជរានោះដើរទៅទទួលថង់ទ្រព្យ ១០០០ ។ ខណៈនោះ មនុស្សទាំងឡាយនាំគ្នាសួរស្ត្រីជរានោះថា លោកយាយឃើញនាងបទុមវតីទេវឬ ។ ស្រីជរាឆ្លើយថា ខ្ញុំមិនឃើញទេ តែកូនស្រីរបស់ខ្ញុំឃើញ ។ មនុស្សទាំងនោះសួរថា កូនស្រីរបស់លោកយាយនៅទីណា ហើយក៏ដើរទៅ

ជាមួយស្រីជរានោះ ចាំព្រះនាងបទុមវតីបាន ក៏នាំគ្នាក្រាបទៀបបាតជើងទាំង ២ ក្នុងកាលនោះ ស្រីជរានោះ ក៏ចន្ទុលថា នេះព្រះនាងបទុមវតីទេវី ហើយពោលថា នេះជាកម្មធ្ងន់របស់ស្ត្រីហ្ន៎ សូម្បីមហេសីរបស់ព្រះរាជាយ៉ាងនេះ គង់នៅប្រាសចាកការរក្សា ក្នុងទីដែលមានសភាពបែបនេះ ។ រាជបុរសទាំងនោះយកវាំងននស មកបាំងជានិវេសន៍របស់ព្រះនាងបទុមវតី រៀបចំការពារក្បែរទ្វារ រួចក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជូនសុវណ្ណសិវិកា គឺវមាសទៅទទួល ។ ព្រះនាងប្រាប់ថា ខ្ញុំមិនទៅយ៉ាងនេះទេ បើពួកអ្នកក្រាលកម្រាលដ៏វិចិត្រដោយសំពត់សម្បុកឈើយ៉ាងល្អ តាំងអំពីលំនៅរបស់ខ្ញុំ រហូតដល់ព្រះរាជនិវេសន៍ បាំងពិតានដែលវិចិត្រដោយផ្កាយមាសខាងលើ ហើយបញ្ជូនអាភរណៈសព្វយ៉ាង ដើម្បីប្រដាប់ទៅ ខ្ញុំនឹងដើរដោយជើង អ្នកនគរនឹងឃើញសម្បត្តិរបស់ខ្ញុំយ៉ាងនេះ ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរធ្វើតាមការគាប់ចិត្តរបស់នាងបទុមវតី ។ បន្ទាប់អំពីនោះ ព្រះនាងបទុមវតីព្រះតម្រិះថា អញនឹងប្រដាប់គ្រឿងអលង្ការគ្រប់យ៉ាង ដើរទៅកាន់ព្រះរាជ-និវេសន៍ ហើយយាងចុះកាន់ផ្លូវ ។ គ្រានោះ ផ្កាឈូកទាំងឡាយក៏ជ្រែកកម្រាលដ៏វិចិត្រ ដោយសំពត់សម្បុកឈើយ៉ាងល្អ ផុសឡើងក្នុងទីគ្រប់ជំហានព្រះបាទរបស់ព្រះនាង ។ ព្រះនាងកាលសម្តែងសម្បត្តិរបស់ព្រះនាងដល់មហាជនហើយ ឡើងកាន់ព្រះរាជនិវេសន៍ ប្រទានគ្រឿងកម្រាលដ៏វិចិត្រទាំងអស់ ជាថ្លៃការចិញ្ចឹមដល់ស្រីជរានោះ ។

ព្រះរាជាឲ្យហៅស្ត្រី ៥០០ នាក់មក ហើយត្រាស់ថា នែទេវី ខ្ញុំឲ្យស្រី

ទាំងនេះជាទាសីដល់នាង ។ ព្រះនាងទូលថា សាធុ ខ្ញុំម្ចាស់នឹងឲ្យគេប្រកាសទូទាំងព្រះនគរឲ្យបានជ្រាបថា ស្រីទាំងនេះ ព្រះរាជាព្រះរាជទានដល់ខ្ញុំម្ចាស់ហើយ ។ ព្រះរាជាក៏ឲ្យវាយស្គរប្រកាសថា ស្រី ៥០០ នាក់ ប្រទូស្តនាងបទុមវតី យើងឲ្យជាទាសីរបស់នាងមួយអង្គឯង ។ ព្រះនាងបទុមវតីនោះជ្រាបថា អ្នកនគរនោះកំណត់ដឹងថា ស្រីទាំងនោះជាទាសីហើយ ទើបទូលសួរព្រះរាជាថា បពិត្រទេវៈ ខ្ញុំម្ចាស់នឹងធ្វើទាសីរបស់ខ្ញុំម្ចាស់ឲ្យជាអ្នកជា បានឬទេ ។ ព្រះរាជាត្រាស់ថា បើនាងត្រូវការក៏ជាការល្អ ។ ព្រះនាងក្រាបទូលថា សូមទ្រង់ឲ្យហៅអ្នកវាយស្គរប្រកាសទៀតថា ពួកទាសីដែលទ្រង់ព្រះរាជទានដល់ព្រះនាងបទុមវតី ព្រះនាងធ្វើឲ្យជាអ្នកជាទាំង ៥០០ នាក់ហើយ ។ កាលស្រីទាំងនោះជាអ្នកជាហើយ ព្រះនាងក៏ប្រគល់ឱរស ៤៩៩ ឲ្យស្រីទាំងនោះមើលថែ ចំណែកព្រះនាងទទួលមើលចំពោះព្រះមហាបទុមកុមារប៉ុណ្ណោះ។ កាលដល់វេលាព្រះរាជកុមារទាំងនោះទ្រង់លេងបាន ព្រះរាជាឲ្យសាងទីលានសម្រាប់លេងផ្សេងៗ ក្នុងព្រះរាជឧទ្យាន ។ ព្រះរាជកុមារទាំងនោះ មានជន្មវស្សាបាន ១៦ ឆ្នាំ គ្រប់ព្រះអង្គចុះលេងក្នុងមង្គលបោក្ខរណី ដែលដេរដាសដោយផ្កាឈូកក្នុងព្រះរាជឧទ្យាន ទ្រង់ឃើញផ្កាឈូករីកថ្មី ត្របកចាស់ជ្រុះអំពីទង ក៏ពិចារណាឃើញថា ផ្កាឈូកនេះមិនមានចិត្ត គង់ជួបនូវជរាបែបនេះ នឹងពោលទៅថ្វីដល់សរីរៈរបស់ពួកយើងហ្ន៎ សរីរៈនេះ ក៏គង់នឹងមានគតិយ៉ាងនេះដូចគ្នា ហើយទ្រង់ទាញយកជាអារម្មណ៍ ព្រះរាជបុត្រគ្រប់អង្គ បានកើតបច្ចេកពុទ្ធញាណ ហើយនាំគ្នាក្រោកឡើង អង្គុយពត់ភ្នែនក្នុង

ត្របកឈូក ។ សម័យនោះ ពួករាជបុរសដែលទៅជាមួយព្រះរាជកុមារទាំងនោះ ដឹងថា រសៀលណាស់ហើយ ទើបទូលថា បពិត្រព្រះអយ្យបុត្រ សូមទ្រង់ជ្រាបកាលរបស់ព្រះអង្គចុះ ។ ព្រះរាជកុមារទាំងអស់ក៏គង់ស្ងៀម ។ រាជបុរសទាំងនោះក៏នាំគ្នាទៅក្រាបទូលព្រះរាជាថា បពិត្រទេវៈ ព្រះរាជកុមារទាំងឡាយប្រថាប់គង់ក្នុងត្របកឈូក កាលពួកទូលបង្គំក្រាបទូល ក៏ទ្រង់មិនបន្ទឺវាចាឡើយ ។ ព្រះរាជាត្រាស់ថា ពួកអ្នកចូរឲ្យរាជបុត្រទាំងនោះគង់តាមចិត្តចុះ ។ ព្រះរាជកុមារទាំងនោះ បានទទួលការរក្សាពេញមួយយប់ទល់ភ្លឺ ក៏គង់ប្រថាប់ក្នុងត្របកឈូកទំនងនោះឯង រហូតដល់អរុណរះ ។ ពួករាជ-បុរសក៏ត្រឡប់ទៅ ទើបនាំគ្នាចូលគាល់ទូលថា សូមទេវៈទាំងឡាយទ្រង់ជ្រាបកាលចុះ ។ ព្រះរាជកុមារគ្រប់អង្គត្រាស់ថា ពួកអាត្មាមិនមែនទេវៈ ពួកអាត្មាជាព្រះបច្ចេកពុទ្ធ ។ ពួកជនទាំងនោះក្រាបទូលថា បពិត្រអយ្យបុត្រទាំងឡាយ ទ្រង់ត្រាស់ព្រះតម្រាស់ធ្ងន់ ធម្មតាព្រះបច្ចេកពុទ្ធទាំងឡាយ មិនដូចទ្រង់ទេ ត្រូវមានសក់ និងពុកម៉ាត់ ពុកចង្កា ២ អង្គុលី មានបរិក្ខារ ៨ ដណ្ដប់កាសាវពស្ត្រ ។ ព្រះរាជកុមារទាំងនោះ យកព្រះហស្តស្ដាំស្ទាបព្រះសីសៈ រំពេចនោះឯង យាវាសភេទក៏អន្តរធានទៅ ក្លាយជាបុគ្គលមានបរិក្ខារ ៨ ដណ្ដប់ព្រះកាសាវពស្ត្រ ហើយយាងទៅកាន់ញកភ្នំនន្ទមូលក៍ ទាំងមហាជនកំពុងឃើញនោះឯង ។

ចំណែកព្រះនាងបទុមវតីក៏ទ្រង់សោយសោកក្នុងព្រះហឫទ័យថា អញមានកូនច្រើន តែក៏ព្រាត់ប្រាសគ្នាទៅ ។ ទ្រង់សោយព្រះវិលាល័យដោយ

ព្រះរោគនោះឯង កើតក្នុងស្ថានរបស់បុគ្គលដែលធ្វើការដោយដៃចិញ្ចឹមជីវិត ក្នុងតំបន់ ក្បែរទ្វារក្រុងរាជគ្រឹះ ។ បន្ទាប់មក នាងមានស្វាមី ថ្ងៃមួយ កំពុងនាំបបរទៅឲ្យប្តី ឃើញព្រះបច្ចេកពុទ្ធ ៨ អង្គ ក្នុងចំនួនបុត្រទាំងនោះរបស់ខ្លួន កំពុងហោះទៅក្នុងកាលស្វែងរកអាហារ ទើបប្រញាប់ទៅប្រាប់ប្តីថា សូមមើលព្រះបច្ចេកពុទ្ធ ជួយនិមន្តលោកមក យើងនឹងប្រគេនអាហារ ។ ប្តីពោលថា ឈ្មោះថា ពួកបក្សីក៏ហើរទៅយ៉ាងនោះ ទុំះមិនមែនព្រះបច្ចេកពុទ្ធទេ ។ ព្រះបច្ចេកពុទ្ធទាំងនោះ ក៏ចុះក្នុងទីមិនឆ្ងាយអំពីជនទាំង ២ នោះ ដែលកំពុងសន្ទនាគ្នា ស្រីនោះក៏ប្រគេនភោជន គឺបាយ និងសម្លគោកសម្រាប់ខ្លួនក្នុងថ្ងៃនោះ ដល់ព្រះបច្ចេកពុទ្ធទាំងនោះ ហើយនិមន្តថា ស្អែកនេះ សូមលោកម្ចាស់ទាំង ៨ អង្គ ទទួលភត្តរបស់ខ្ញុំផង ។ ព្រះបច្ចេកពុទ្ធទាំងនោះពោលថា ប្រពៃហើយ ឧបាសិកា នាងមានសក្ការៈ និងអាសនៈ ៨ ប៉ុណ្ណោះក៏ល្មម ឃើញព្រះបច្ចេកពុទ្ធដទៃៗ ក៏ចូរគ្រប់គ្រងចិត្តរបស់នាង ។ ស្អែកឡើងនាងក៏ក្រាលអាសនៈ ៨ អង្គុយរៀបចំសក្ការៈសម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គ ។ ព្រះបច្ចេកពុទ្ធទាំងឡាយដែលទទួលនិមន្ត ទើបឲ្យសញ្ញាដល់ព្រះបច្ចេកពុទ្ធក្រៅអំពីនោះថា លោកនិទ្ទុក្ខទាំងឡាយ ថ្ងៃនេះ កុំទៅទីដទៃឡើយ ទាំងអស់គ្នា ជួយគ្នាសង្គ្រោះញោមស្រីរបស់ពួកលោកចុះ ។ ស្តាប់ពាក្យរបស់ព្រះបច្ចេកពុទ្ធ ៨ អង្គនោះហើយ គ្រប់អង្គក៏ហោះទៅព្រមគ្នា ប្រាកដនៅត្រង់ទ្វារផ្ទះរបស់មាតា ។ សូម្បីនាងឃើញព្រះបច្ចេកពុទ្ធច្រើនជាងសញ្ញាដែលបានទទួលគ្រាដំបូង ក៏មិនបានញាប់ញ័រ ។ និមន្តគ្រប់អង្គចូលទៅក្នុងផ្ទះ

ឲ្យគង់លើអាសនៈ ។ កាលព្រះបច្ចេកពុទ្ធកំពុងគង់តាមលំដាប់ អង្គទី ៩ ក៏និម្មិតអាសនៈ ៨ បន្ថែមទៀត ខ្លួនឯងគង់លើអាសនៈដែលថ្វាយ ។ ផ្ទះក៏រីកប៉ុនអាសនៈដែលបន្ថែមឡើង ។ ព្រះបច្ចេកពុទ្ធគ្រប់អង្គ គង់យ៉ាងនោះហើយ ស្រីនោះក៏ថ្វាយសក្ការៈដែលរៀបចំ សម្រាប់ព្រះបច្ចេកពុទ្ធ ៨ អង្គ ហេតុគ្រប់គ្រាន់ ដល់ព្រះបច្ចេកពុទ្ធ ៥០០ អង្គ ហើយទើបនាំយកផ្កាឧប្បល ៨ ដែលនៅក្នុងដៃដាក់ទៀបព្រះបាទរបស់ព្រះបច្ចេកពុទ្ធដែលនិមន្តមកប៉ុណ្ណោះ ពោលអធិដ្ឋានថា បពិត្រលោកម្ចាស់ ពណ៌សម្បុរកាយរបស់ខ្ញុំ សូមដូចពណ៌ខាងក្នុងនៃផ្កាឧប្បលនេះ ក្នុងទីដែលខ្ញុំកើតហើយនោះឯង ព្រះបច្ចេក-ពុទ្ធទាំងឡាយ អនុមោទនាដល់មាតាហើយ ក៏ទៅកាន់ភ្នំគន្ធមាទន៍ ។

ស្រីនោះធ្វើកុសលដរាបដល់អស់ជីវិត ចុតិអំពីភពនោះហើយ កើតក្នុងទេវលោក ក្នុងពុទ្ធុប្បាទកាលនេះ ក៏បដិសន្ធិក្នុងត្រកូលសេដ្ឋី ។ ព្រោះនាងមានពណ៌សម្បុរដូចផ្កាឧប្បល ទើបម្ដាយឪពុកដាក់ឈ្មោះថា ឧប្បល-វណ្ណា ។ លុះនាងចម្រើនវ័យ ព្រះរាជាក្នុងជម្ពូទ្វីប ក៏បញ្ជូនមនុស្សទៅកាន់សម្នាក់សេដ្ឋីដើម្បីសូមនាង មិនមានព្រះរាជាអង្គណាដែលមិនបញ្ជូនមនុស្សទៅ ។ បន្ទាប់អំពីនោះ សេដ្ឋីគិតថា អញមិនអាចចងចិត្តមនុស្សគ្រប់គ្នាបានទេ អញនឹងធ្វើឧបាយមួយ ទើបហៅកូនស្រីមកសួរថា នាងបួសឬទេ ។ ព្រោះហេតុដែលនាងកើតក្នុងភពចុងក្រោយ ពាក្យរបស់ឪពុក ប្រៀបដូចប្រេងចម្រាញ់ ១០០ ដងស្រោចលើក្បាល ។ ព្រោះហេតុនោះ ទើបនាងពោលនឹងឪពុកថា ខ្ញុំបួសបាន ។ ទើបសេដ្ឋីនោះធ្វើសក្ការៈដល់នាង ហើយនាំទៅ

*កាន់សម្នាក់ភិក្ខុនី ឲ្យបួសកាលនាងបួសថ្មីៗ ដល់វេន ( វារៈ ) ក្នុងរោងឧបោសថ នាងអុជប្រទីប បោសរោងឧបោសថ កាន់យកនិមិត្តត្រង់អណ្ដាតប្រទីប សម្លឹងមើលរឿយៗ ក៏ធ្វើឈាន មានតេជោកសិណជាអារម្មណ៍ ឲ្យឈានកើតឡើង ហើយធ្វើឈាននោះឲ្យជាបាទ ក៏សម្រេចអរហត្ត ។ ព្រមគ្នានឹងអរហត្តផលនោះឯង ក៏ជាអ្នកជំនាញក្នុងការសម្ដែងឫទ្ធិផ្សេងៗ ។ បន្ទាប់មក ក្នុងថ្ងៃដែលព្រះសាស្ដា ទ្រង់ធ្វើយមកប្បាដិហារ្យ នាងក៏បន្លឺសីហនាទថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់នឹងធ្វើបាដិហារ្យថ្វាយ ។ ព្រះសាស្ដា ទ្រង់ធ្វើរឿងនេះឲ្យជាអត្ថុប្បត្តិហេតុ ប្រថាប់គង់ក្នុងជេតពនមហាវិហារ កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីនេះទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា ជាអ្នកមានឫទ្ធិនោះឯង ៕*

**អដ្ឋកថាសូត្រទី ៣ ចប់**

# អដ្ឋកថា សូត្រទី ៤
# ប្រវត្តិ ព្រះនាងបដាចារាថេរី

ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា **វិនយ-ធរានំ យទិទំ បដាចារា** លោកសម្ដែងថា បដាចារាថេរីជាកំពូលជាងពួកភិក្ខុនីសាវិកាខាងទ្រទ្រង់វិន័យ ។

បានឮមកថា ព្រះថេរីនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី បន្ទាប់មក កំពុងស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលទ្រទ្រង់វិន័យ ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងធ្វើកុសលដរាបអស់ជីវិត អន្ទោលក្នុងទេវតា និងមនុស្ស កាលព្រះពុទ្ធព្រះនាមកស្សបៈ នាងបដិសន្ធិក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកិកិ ជាធីតាមួយអង្គក្នុងចំណោមបងប្អូនស្រី ៧ អង្គ ប្រព្រឹត្តព្រហ្មចរិយៈអស់ ២ ម៉ឺនឆ្នាំ សាងបរិវេណថ្វាយភិក្ខុសង្ឃ កើតក្នុងទេវលោកទៀត សោយសម្បត្តិមួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ បដិ-សន្ធិក្នុងត្រកូលសេដ្ឋី នាក្រុងសាវត្ថី ។

បន្ទាប់មក នាងចម្រើនវ័យ បានធ្វើការស្រឡាញ់ជាមួយអ្នកបម្រើម្នាក់ក្នុងផ្ទះ ។ ក្រោយមក កាលជិតមានស្វាមី ដែលមិនមានជាតិស្មើគ្នា ទើបបានធ្វើការណាត់ជាមួយបុរសដែលស្រឡាញ់គ្នានោះថា តាំងអំពីថ្ងៃនេះទៅ អ្នកនឹងមិនបានឃើញខ្ញុំ ទោះបីប្រហារ ១០០ ដង បើអ្នកស្រឡាញ់ខ្ញុំ ក៏ចូរនាំខ្ញុំទៅឥឡូវនេះឯង ។ បុរសនោះទទួលពាក្យថា យល់ព្រម ហើយកាន់

យកវត្ថុដែលមានតម្លៃជាប់ដៃសមគួរ នាំនាងចេញទៅ ៣-៤ យោជន៍អំពីព្រះនគរ អាស្រ័យនៅក្នុងភូមិមួយ ។ ក្នុងកាលក្រោយមក ក៏មានគភ៌ កាលគភ៌ចាស់ខែ ទើបពោលថា ទីនេះមិនសមគួរដល់យើងឡើយ ខ្ញុំនឹងទៅផ្ទះត្រកូល ។ បុរសជាប្តីក៏ពន្យារថា ថ្ងៃនេះនឹងទៅ ថ្ងៃនេះសឹមទៅ តែក៏មិនបានទៅ រហូតហួសកាល ។ នាងដឹងហេតុរបស់ប្តីនោះ គិតថា ប្តីនេះល្ងង់ខ្លៅទើបមិននាំយើងទៅ កាលប្តីនោះ ចេញទៅខាងក្រៅស្រុក ទើបដើរទៅម្នាក់ឯង ដោយបំណងត្រឡប់ទៅកាន់ត្រកូល ។ ប្តីត្រឡប់មក មិនឃើញនាងក្នុងផ្ទះ ទើបសួរបុគ្គលដែលស្និទ្ធស្នាល ដឹងថា នាងត្រឡប់ទៅកាន់ត្រកូល គិតថា នាងជាកុលធីតា អាស្រ័យអញ មិនមានទីពឹងឡើយ ទើបធ្វើដំណើរតាមស្នាមជើងរហូតទាន់ នាងក៏ប្រសូតបុត្រ ក្នុងចន្លោះផ្លូវនោះឯង ។ ពីរនាក់ប្តីប្រពន្ធប្រឹក្សាគ្នាថា ប្រយោជន៍ដែលយើងគប្បីដើរទៅ ក៏សម្រេចហើយក្នុងចន្លោះផ្លូវ ឥឡូវនេះ យើងនឹងទៅធ្វើអ្វី ទើបនាំគ្នាត្រឡប់ ។ នាងក៏តាំងគភ៌ទៀត ។ គប្បីធ្វើរឿងឲ្យពិស្តារតាមន័យមុននោះឯង ។ តែក្នុងរវាងផ្លូវគ្រាន់តែប្រសូតបុត្រ ពពកក៏ផ្តុំឡើងទាំង ៤ ទិស ទើបនាងពោលនឹងប្តីថា នែអ្នក នេះមិនមែនជាកាលមេឃភ្លៀងតាំងឡើងទាំង ៤ ទិស ចូរព្យាយាមធ្វើលំនៅសម្រាប់ខ្ញុំចុះ ។ ស្វាមីទទួលពាក្យថា ខ្ញុំនឹងធ្វើឥឡូវនេះ យកកំណាត់ឈើមកធ្វើខ្ទម គិតថា នឹងរកស្មៅមកប្រក់ ទើបច្រូតស្មៅត្រង់ដំបូកធំមួយ ។ ទីនោះ ពស់វែកដែលដេកក្នុងដំបូកក៏ខាំជើងបុរសនោះ ។ បុរសនោះក៏ដួលក្នុងទីនោះឯង ។ នាងគិតថា បន្តិចទៀត ប្តីនឹងមក រង់ចាំរហូតអស់រាត្រី ក៏

គិតទៀតថា ប្ដីអញគង់គិតថា អញនេះជាស្រីអនាថា ពឹងមិនបាន ហើយបោះបង់ចោលក្នុងផ្លូវគេចទៅហើយ កាលភ្លឺឡើង ទើបមើលតាមស្នាមជើង ឃើញប្ដីដួលត្រង់ជើងដំបូក ក៏សោកខ្សឹកខ្សួលថា ព្រោះតែអាត្មាអញ ទើបប្ដីស្លាប់ ហើយបីកូនតូចដោយដៃម្ខាង ដៃម្ខាងទៀត ដឹកដៃកូនច្បងដើរទៅតាមផ្លូវ ។ ក្នុងរវាងផ្លូវជួបស្ទឹងរាក់មួយខ្សែ គិតថា អញមិនអាចនាំកូនទៅតែម្ដងទាំង ២ នាក់បានឡើយ ទើបដាក់កូនធំទុកត្រង់ត្រើយអាយ នាំកូនតូចទៅត្រើយនាយ ឲ្យដេកលើកែបចាស់ៗ ចុះឆ្លងទឹក ដោយបំណងនឹងនាំកូនច្បងទៅ ។ ពេលនាងមកដល់កណ្ដាលស្ទឹង ក្អែងមួយក៏មកចាបកូនតូចទៅដោយសម្គាល់ថា ជាដុំសាច់ ។ នាងក៏យកដៃដេញក្អែង ។ កូនច្បងឃើញនាងធ្វើដៃយ៉ាងនេះ សម្គាល់ថា ម្ដាយហៅ ក៏ចុះឆ្លងស្ទឹង ធ្លាក់ទៅក្នុងក្រសែទឹក ។ កាលនាងឆ្លងទៅដល់ច្រាំងនោះឯង ក្អែងក៏ចាបយកកូនតូចនោះទៅ ។ នាងមានសេចក្ដីសោកជាកម្លាំង ក្នុងរវាងផ្លូវ ក៏ដើរច្រៀងរៀបរាប់ ដូច្នេះថា

**ឧភោ បុត្តា កាលកតា បន្ថេ មយ្ហំ បតី មតោ**

កូន ២ នាក់ក៏ស្លាប់ ប្ដីក៏ស្លាប់ហើយត្រង់ផ្លូវ ។

នាងយំរៀបរាប់យ៉ាងនេះ រហូតដល់ក្រុងសាវត្ថី ទៅរកជនដែលរាប់អានគ្នារបស់ត្រកូល កំណត់ផ្ទះរបស់ខ្លួនមិនបាន ដោយអំណាចសេចក្ដីសោក សាកសួរអ្នកស្រុកថា ត្រង់នេះមានត្រកូល ឈ្មោះនេះ ផ្ទះត្រកូលនោះនៅឯណា ។ ជនទាំងឡាយពោលថា នាងសាកសួរដល់ត្រកូលនោះធ្វើអ្វី លំនៅរបស់អ្នកទាំងនោះបាក់ហើយ ព្រោះខ្យល់ក្ដួច មនុស្សទាំងអស់ក្នុងផ្ទះនោះ

ស្លាប់បាត់ជីវិត គេដុតមនុស្សទាំងនោះ លើជើងថ្ករតែមួយ ទាំងតូច ទាំងធំ មើលចុះ ផ្សែងភ្លើងនៅប្រាកដនៅឡើយ ។ នាងបានស្តាប់ពាក្យប្រាប់ហើយ ក៏ពោលថា អ្នកនិយាយអ្វី ក៏ទ្រទ្រង់សំពត់របស់ខ្លួនមិនបាន ទំនងដូចគ្នានឹងថ្ងៃកើតនោះឯង ផ្គងដើមដៃទាំង ២ កន្ទក់កន្ទេញ ដើរទៅត្រង់ជើងថ្ករដុតពួកញាតិ យំរៀបរាប់ពិលាប រហូតគ្រប់គាថាថា

**ឧភោ បុត្តា កាលកតា បន្ថេ មយ្ហំ បតី មតោ**
**មាតា បិតា ច ភាតា ច ឯកចិតកស្មឹ ឌយ្ហរេ ។**

កូនទាំង ២ ក៏ស្លាប់ ប្តីខ្ញុំក៏ស្លាប់បង់ត្រង់កណ្តាលផ្លូវ មាតា
បិតា និងបងប្រុស គេក៏ដុតត្រង់ជើងថ្ករតែមួយ ។

ហើយបានហែកសំពត់ដែលអ្នកដទៃឲ្យ ឲ្យខ្ទេចទៀត ។ គ្រានោះមហាជន ក៏គ្រាច់ចោមរោមនាងក្នុងទីដែលប្រទះឃើញហើយ ទើបមនុស្សទាំងឡាយឲ្យឈ្មោះនាងថា **បដាចារា** ព្រោះបដាចារានេះ វៀរការស្លៀកសំពត់គ្រាច់ទៅ ព្រោះហេតុដែលប្រាកដថា នាងមានអាការដែលមិនមានការខ្មាស ព្រោះជាអ្នកអាក្រាតកាយ ដូច្នោះ ទើបមនុស្សទាំងឡាយឲ្យឈ្មោះនាងថា បដាចារា ព្រោះមានអាចារធ្លាក់ចុះហើយ ។ ថ្ងៃមួយ កាលព្រះសាស្តាកំពុងសម្តែងធម៌ដល់មហាជន នាងក៏ចូលទៅក្នុងវិហារ ឈរខាងក្រោយបរិស័ទ ព្រះសាស្តាទ្រង់ផ្សាយព្រះមេត្តា ត្រាស់ថា ម្នាលប្អូនស្រី ចូរត្រឡប់បានសតិ ម្នាលប្អូនស្រី ចូរត្រឡប់បានសតិចុះ ។ ព្រោះស្តាប់ព្រះពុទ្ធតម្រាស់ ហិរិឱត្តប្បៈមានកម្លាំង ក៏មានស្មារតីមក ។ នាងក៏អង្គុយត្រង់

*ផែនដីនោះឯង ។ បុរសដែលឈរមិនឆ្ងាយក៏បោះសំពត់ស្លៀកទៅឲ្យ ។ នាងស្លៀកសំពត់នោះហើយ ក៏អង្គុយស្តាប់ធម៌ ។ ព្រោះចរិយារបស់នាង ទើបព្រះសាស្តាត្រាស់ព្រះគាថា ក្នុងធម្មបទដូច្នេះថា*

**ន សន្តិ បុត្តា តាណាយ ន បិតា នបិ ពន្ធវា**
**អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា ។**
**ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ**
**និព្វានគមនំ មគ្គំ ខិប្បមេវ វិសោធយេ ។**

*កាលបុគ្គលត្រូវមច្ចុគ្របសង្កត់ហើយ កូនទាំងឡាយ មិនមានដើម្បីជាទីពឹង បិតា ក៏មិនមាន ទាំងផៅពង្ស ក៏មិនមានដើម្បីជាទីពឹងឡើយ សេចក្តីទីពឹងក្នុងញាតិទាំងឡាយ ក៏មិនមាន បណ្ឌិតដឹងអំណាចប្រយោជន៍នេះហើយ គួរជាអ្នកសង្រួមក្នុងសីល គួរប្រញាប់ប្រញាល់ជម្រះផ្លូវ ជាទីទៅកាន់ព្រះនិព្វានឲ្យបាន ។*

*ចប់ព្រះគាថា នាងក៏តាំងនៅក្នុងសោតាបត្តិផលទាំងដែលឈរ ទើបចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំ ហើយសូមបួស ។ ព្រះសាស្តាទ្រង់ទទួលការបួសរបស់នាងថា ចូរទៅកាន់សម្នាក់ភិក្ខុនី បួសចុះ ។ កាលនាងបួសហើយ មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត រៀនពុទ្ធវចនៈ ជាអ្នកជំនាញក្នុងវិនយបិដក ក្រោយមក ព្រះសាស្តាគង់ប្រថាប់ក្នុងវត្តជេតពនវិហារ កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាបដាចារាថេរីទុក*

ក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលទ្រទ្រង់វិន័យ ។

អដ្ឋកថាសូត្រទី ៨ ចប់

## អដ្ឋកថា សូត្រទី ៩
## ប្រវត្តិ ព្រះនាងធម្មទិន្នាថេរី

ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា **ធម្មកថិកានំ** លោកសម្ដែងថា ព្រះនាងធម្មទិន្នាថេរី ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលជាធម្មកថិក ។

បានឮថា កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងស្ថានរបស់បុគ្គលដែលត្រូវអាស្រ័យគេ ក្នុងក្រុងហង្សវតី ធ្វើកុសលក្រៃលែងឡើងដល់ព្រះសុជាតត្ថេរអគ្គសាវក របស់ព្រះមានព្រះភាគព្រះនាមបទុមុត្តរៈ រួចប្រាថ្នាតំណែងនោះ នាងធ្វើកុសលដរាបដល់អស់ជីវិត កើតក្នុងស្ថានសួគ៌ ។ ន័យគ្រប់យ៉ាង គប្បីជ្រាបដោយអំណាចអភិនីហាររបស់ព្រះនាងខេមាថេរីខាងដើម ។ កាលព្រះពុទ្ធព្រះនាមផុស្សៈ នាងក៏នៅក្នុងផ្ទះរបស់មនុស្សធ្វើការ ដែលត្រូវតែងតាំងទុកក្នុងតំណែងជាធំក្នុងរឿងទានរបស់ ៣ នាក់បងប្អូនដែលមានមាតាផ្សេងគ្នា ត្រូវប្រាប់ថា ចូរឲ្យមួយ តែក៏ឲ្យពីរ នាងថ្វាយទានគ្រប់យ៉ាង មិនថយចុះឡើយយ៉ាងនេះ ។ កន្លងទៅ ៩២ កប្ប កាល

ព្រះពុទ្ធព្រះនាមកស្សបៈ នាងក៏បដិសន្ធិក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកិកិ ជារាជធីតាមួយអង្គ រវាងបងប្អូន ៧ អង្គ ប្រព្រឹត្តព្រហ្មចរិយៈអស់ ២ ម៉ឺនឆ្នាំ សាងបរិវេណថ្វាយភិក្ខុសង្ឃ អន្ទោលក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងត្រកូលមួយ ។

ខាងក្រោយ នាងមានផ្ទះ ជាភរិយារបស់វិសាខសេដ្ឋី ធម្មតា វិសាខ-សេដ្ឋីជាសម្លាញ់របស់ព្រះបាទពិម្ពិសារ ទៅគាល់ព្រះទសពលជំបូងជាមួយព្រះបាទពិម្ពិសារ អង្គុយស្តាប់ធម៌ហើយ តាំងនៅក្នុងសោតាបត្តិផល បន្ទាប់មក ធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ។ ថ្ងៃនោះ វិសាខសេដ្ឋីនោះ ត្រឡប់មកកាន់ផ្ទះហើយ កាលនាងធម្មទិន្នាដែលឈរត្រង់ក្បាលជណ្តើរហុចដៃមកក៏មិនចាប់ដៃឡើងប្រាសាទឡើយ កំពុងបរិភោគ ក៏មិនប្រាប់ថា ចូរឲ្យវត្ថុនេះ ចូរនាំវត្ថុនេះមក ។ នាងធម្មទិន្នាកាន់វែកបម្រើ គិតថា សេដ្ឋីនេះ កាលអញហុចដៃឲ្យតោង ក៏មិនតោង កាលបរិភោគ ក៏មិនពោលអ្វី អញមានខុសអ្វីឬហ្ន៎ កាលសេដ្ឋីបរិភោគហើយ ទើបនាងសួរថា អយ្យបុត្រ ខ្ញុំមានទោសកំហុសអ្វីឬ សេដ្ឋីពោលថា ធម្មទិន្នា នាងមិនមានទោសអ្វីទេ តែពីថ្ងៃនេះទៅខ្ញុំមិនគួរអង្គុយ មិនគួរឈរ មិនគួរឲ្យនាំអាហារមកទំពា មកបរិភោគក្បែរៗនាង ដោយការត្រេកអរបានទេ បើនាងបំណងទ្រព្យប៉ុនណា ចូរយកទៅប៉ុណ្ណោះត្រឡប់ទៅត្រកូលដើមចុះ ។ នាងពោលថា អយ្យបុត្រ បើដូច្នេះ ខ្ញុំក៏មិនយកក្បាលទូលសំរាម ដែលប្រៀបដូចទឹកមាត់ ដែលអ្នកស្តោះចោលហើយទៅ សូមអនុញ្ញាតឲ្យខ្ញុំបួសចុះ ។ វិសាខសេដ្ឋីពោលថា សាធុ ធម្ម-

ទិន្នា ហើយក្រាបទូលព្រះរាជា យកវមាសសែងធម្មទិន្នាទៅកាន់សម្នាក់ភិក្ខុនី ដើម្បីបួស ។ នាងបួសហើយ គិតថា អំពីមុនសេដ្ឋីនេះនៅត្រង់កណ្តាលផ្ទះ គង់ធ្វើទីបំផុតទុក្ខបាន តាំងអំពីបានបួសហើយ អញក៏គួរធ្វើទីបំផុតទុក្ខបាន ទើបចូលទៅរកឧបជ្ឈាយ៍ អាចារ្យ ពោលថា បពិត្រអ្នកនាងម្ចាស់ ចិត្តរបស់ខ្ញុំបង្អោនទៅក្នុងទីដែលធ្លាប់ទៅរឿយៗ ខ្ញុំនឹងទៅកាន់អាវាសជិតស្រុក ។ ព្រះថេរីទាំងឡាយមិនអាចហាមចិត្តនាងបាន ព្រោះនាងចេញបួសអំពីត្រកូលធំ ទើបនាំនាងទៅរកភូមិស្រុក ។ ព្រោះនាងញ៉ាំញីសង្ខារបានក្នុងអតីតកាល មិនយូរប៉ុន្មាន នាងក៏សម្រេចអរហត្ត មួយអន្លើដោយបដិសម្ភិទា ។

គ្រានោះ ព្រះធម្មទិន្នាថេរីគិតថា កិច្ចរបស់អាត្មាអញដល់ទីបំផុតហើយ នៅក្នុងទីនេះបានប្រយោជន៍អ្វី អញនឹងទៅកាន់ក្រុងរាជគ្រឹះ ពួកញាតិជាច្រើនអាស្រ័យអញ នឹងធ្វើបុណ្យទាំងឡាយ ហើយក៏នាំព្រះថេរីទាំងឡាយ ចូលកាន់ព្រះនគរ ។ វិសាខឧបាសកដឹងថានាងត្រឡប់មក ក៏ប្រញាប់ទៅ សង្ស័យថា ប្រហែលនាងអផ្សុកទេដឹង វេលាល្ងាចក៏ចូលទៅកាន់សម្នាក់នាង ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង គិតថា នឹងសួរដល់ភាវៈដែលនាងអផ្សុកមិនសមគួរ ទើបសួរបញ្ហាដោយអំណាចបញ្ចក្ខន្ធជាដើម ។ ព្រះនាងធម្មទិន្នាថេរីក៏វិសជ្ជនាបញ្ហា ដែលវិសាខឧបាសកសួរហើយ ដូចយកដាវកាត់ដើមឈូក ដូច្នោះ ។ ឧបាសកដឹងថា ធម្មទិន្នាថេរីមានបញ្ញាចាស់ក្លា ទើបសួរបញ្ហាដោយអាការគ្រប់យ៉ាង ក្នុងមគ្គ ៣ តាមលំដាប់ ក្នុងឋានៈដែលខ្លួនសម្រេចហើយ និងសួរបញ្ហាក្នុងអរហត្តមគ្គ ដោយអំណាចការរៀន ព្រះនាង

ធម្មទិន្នាថេរីក៏ដឹងថា ឧបាសកមានវិស័យត្រឹមអនាគាមិផលប៉ុណ្ណោះ គិតថា ឥឡូវនេះ ឧបាសករំលងវិស័យរបស់ខ្លួន ទើបធ្វើឲ្យឧបាសកនោះត្រឡប់ ពោលថា នែវិសាខ អ្នកមិនអាចកំណត់ទីបំផុតនៃបញ្ហាទាំងឡាយបានទេ នែវិសាខ អ្នកនៅប្រាថ្នាក្នុងព្រហ្មចរិយៈដែលឈមចុះកាន់ព្រះនិព្វាន មានព្រះនិព្វានជាទីទៅខាងមុខ មានព្រះនិព្វានជាទីបំផុត នែវិសាខ អ្នកចូរទៅគាល់ព្រះមានព្រះភាគ ទូលសួរសេចក្តីនោះ ព្រះមានព្រះភាគទ្រង់ព្យាករយ៉ាងណា គប្បីចាំទុកយ៉ាងនោះ ។ វិសាខឧបាសក ចូលទៅគាល់ព្រះសាស្តា ក៏ក្រាបទូលន័យនៃបុច្ឆា និងវិសជ្ជនាថ្វាយគ្រប់ប្រការ ។ ព្រះសាស្តាស្តាប់ពាក្យរបស់វិសាខឧបាសកនោះហើយ ត្រាស់ថា ធីតារបស់តថាគត មិនមានតណ្ហាក្នុងខន្ធទាំងឡាយ ទាំងជាអតីត បច្ចុប្បន្ន និងអនាគត ហើយត្រាស់ព្រះគាថាក្នុងធម្មបទ ដូច្នេះថា

**យស្ស បុរេ ច បច្ឆា ច មជ្ឈេ ច នត្ថិ កិញ្ចនំ**
**អកិញ្ចនំ អនាទានំ តមហំ ព្រូមិ ព្រាហ្មណំ ។**

បុគ្គលណា មិនមានសេចក្តីកង្វល់ ក្នុងកាលមុនផង ក្នុងកាលជាខាងក្រោយផង ក្នុងកាលជាកណ្តាលផង តថាគតហៅបុគ្គលដែលជាអ្នកមិនមានកង្វល់ មិនមានសេចក្តីប្រកាន់នោះ ថាជាព្រាហ្មណ៍ ។

បន្ទាប់អំពីនោះ ក៏ប្រទានសាធុការដល់ព្រះនាងធម្មទិន្នាថេរី រួចត្រាស់នឹងវិសាខឧបាសកថា ម្នាលវិសាខ ធម្មទិន្នាភិក្ខុនីជាបណ្ឌិត ធម្មទិន្នាភិក្ខុនី

មានបញ្ញាច្រើន ម្នាលវិសាខ បើអ្នកគប្បីសួរសេចក្ដីនោះនឹងតថាគតៗ គប្បីព្យាករយ៉ាងនោះ ដូចធម្មទិន្នាភិក្ខុនីបានព្យាករហើយ សេចក្ដីនៃអត្ថនោះ ក៏យ៉ាងនោះ អ្នកចូរធ្វើសេចក្ដីនោះយ៉ាងនោះចុះ ។ រឿងនេះ តាំងឡើងដោយប្រការនេះ ។ បន្ទាប់មក ព្រះសាស្ដាប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ កាលទ្រង់ស្ថាបនាភិក្ខុនី ក្នុងតំណែងផ្សេងៗ តាមលំដាប់ ទ្រង់នាំចូឡវេទល្លសូត្រនេះឯង ឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាព្រះថេរី ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកាដែលជាធម្មកថិក ក្នុងព្រះសាសនា ។

**អដ្ឋកថា សូត្រទី ៥ ចប់**

## អដ្ឋកថា សូត្រទី ៦
## ប្រវត្តិ ព្រះនាង នន្ទាថេរី

ក្នុងសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ឈាយីនំ យទិទំ នន្ទា** លោកសម្ដែងថា នន្ទាថេរីជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលត្រេកអរក្នុងឈាន ។

បានឮមកថា ព្រះនាងនន្ទាថេរីនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈកើតឡើង នាងបដិសន្ធិក្នុងត្រកូល នាក្រុងហង្សវតី ។ បន្ទាប់មក កំពុងស្ដាប់ធម្មកថា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ

ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលត្រេកអរក្រៃលែងក្នុងឈាន ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ បន្ទាប់អំពីនោះ នាងក៏អន្ទោលក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប បដិសន្ធិក្នុងព្រះគភ៌របស់ព្រះនាងមហាបជាបតិគោតមី មុនព្រះសាស្តានៃយើងកើតឡើង ។ ព្រះញាតិបានថ្វាយព្រះនាមថា នន្ទា ហៅថា រូបនន្ទា ។ បន្ទាប់មក ព្រះនាងបានឈ្មោះថា ជនបទកល្យាណី ព្រោះមានព្រះសិរីស្អាតល្អ ។ កាលព្រះទសពលនៃយើង ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណហើយ យាងមកក្រុងកបិលពស្តុតាមលំដាប់ ទ្រង់ឲ្យព្រះនន្ទ និងព្រះរាហុលបួសហើយទ្រង់ចៀសចេញទៅហើយ ។ ក្នុងកាលព្រះបាទសុទ្ធោទនមហារាជបរិនិព្វានហើយ ព្រះនាងជ្រាបថា ព្រះនាងមហាបជាបតិគោតមី និងព្រះមាតារបស់ព្រះរាហុលស្តេចចេញសាងព្រះផ្នួសក្នុងសម្នាក់ព្រះសាស្តា ហើយព្រះតម្រិះថា តាំងអំពីព្រះមាតាមហាបជាបតិគោតមី និងព្រះមាតាព្រះរាហុលទ្រង់បួសហើយ ខ្ញុំក៏មានការក្នុងទីនេះ ទើបទៅសម្នាក់ព្រះនាងមហាជាបតិគោតមី ព្រះនាងបួសហើយ ។ តាំងអំពីថ្ងៃដែលព្រះនាងបួស ដឹងថា ព្រះសាស្តាទ្រង់តិះដៀលរូប ទើបមិនទៅគាល់ព្រះសាស្តា ដល់វារៈទទួលឱវាទ ក៏បញ្ជូនភិក្ខុនីរូបដទៃទៅហើយឲ្យនាំព្រះឱវាទមក ។

ព្រះសាស្តាទ្រង់ជ្រាបថា ព្រះនាងស្រវឹងក្នុងព្រះរូបឆោម ទើបត្រាស់ថា ភិក្ខុនីទាំងឡាយត្រូវមកទទួលឱវាទដោយខ្លួនឯង បញ្ជូនភិក្ខុនីទៅជំនួសមិនបាន បន្ទាប់អំពីនោះ ព្រះនាងរូបនន្ទា កាលមិនឃើញផ្លូវដទៃ ក៏ទៅទទួល

ព្រះឱវាទទាំងមិនប្រាថ្នា ។ ព្រះសាស្តា ទ្រង់និមិត្តរូបស្រីម្នាក់ដោយពុទ្ធឫទ្ធិ ដោយអំណាចចរិតរបស់ព្រះនាង ទ្រង់ធ្វើឲ្យដូចស្រីនោះ ចាប់ផ្ចិតស្លឹកត្នោត បក់ថ្វាយ ។ ព្រះនាងរូបនន្ទាឃើញរូបស្រីនោះហើយ គិតថា អាត្មាអញ ស្រវឹងដោយមិនមែនហេតុ ទើបមិនមក ស្រីនេះ ជាអ្នកស្និទ្ធស្នាលក្នុង សម្នាក់ព្រះសាស្តា រូបរបស់អាត្មាអញមិនដល់ចម្រៀកទី ១៦ នៃរូបរបស់ ស្រីនេះ អាត្មាអញមិនដឹងឡើយ ទើបមិនមកអស់កាលយូរ កាន់យកឥត្ថី- និមិត្តនោះឯង ឈរពិនិត្យមើល ។ ព្រោះព្រះនាងសម្បូរដោយបុព្វហេតុ យ៉ាងនេះ ទើបព្រះសាស្តាត្រាស់ព្រះគាថា ក្នុងធម្មបទថា **អដ្ឋីនំ នគរំ កតំ** ធ្វើឲ្យជាគំនរនៃឆ្អឹងទាំងឡាយជាដើម រួចត្រាស់ព្រះសូត្រថា

**ចរំ វា យទិ វា តិដ្ឋំ និសិន្នោ ឧទ វា សយំ**

ដើរក្តី ឈរក្តី អង្គុយក្តី ដេកក្តីជាដើម ។

ព្រះនាងតាំងការអស់ទៅ សូន្យទៅក្នុងរូបនោះឯង សម្រេចអរហត្ត រឿងនេះក្នុងទីនេះ លោកមិនបានធ្វើឲ្យពិស្តារ ព្រោះដូចគ្នានឹងរឿងរបស់ព្រះ នាងខេមាថេរី តាំងអំពីនោះមក ព្រះនាងរូបនន្ទាថេរី ក៏បានសម្រេចធុរៈរវាង ភិក្ខុនីដែលត្រេកអរក្រៃលែងក្នុងឈាន ក្រោយមក ព្រះសាស្តាប្រថាប់គង់ នាជេតពនវិហារ កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ ស្ថាបនាព្រះនាងនន្ទាថេរី ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនី- សាវិកាដែលត្រេកអរក្នុងឈាន ។៚

**អដ្ឋកថា សូត្រទី ៦ ចប់**

# អដ្ឋកថាសូត្រទី ៧
# ប្រវត្តិ ព្រះនាងសោណាថេរី

ក្នុងសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា **អារទ្ធ-វីរិយានំ យទិទំ សោណា** លោកសម្តែងថា ព្រះនាងសោណាថេរី ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលប្រារព្ធសេចក្តីព្យាយាម ។

បានឮថា ព្រះនាងសោណាថេរី ក្នុងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងបដិសន្ធិក្នុងត្រកូលមួយ ក្នុងក្រុងហង្សវតី ។ បន្ទាប់មក កំពុងស្តាប់ធម៌របស់ព្រះសាស្តា ឃើញព្រះសាស្តាកំពុងស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកាដែលប្រារព្ធសេចក្តីព្យាយាម ។ ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងអន្ទោលទៅក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងសាវត្ថី ។ ចំណោរតមក នៅក្នុងឃរាវាសវិស័យ មានកូនប្រុស និងកូនស្រីច្រើន ក៏ឲ្យកូនទាំងអស់តាំងនៅក្នុងឃរាវាសវិស័យរៀងៗ ខ្លួន ចាប់តាំងអំពីកាលនោះ កូនទាំងនោះគិតថា ស្រីនេះនឹងធ្វើអ្វីដល់អញ ក៏មិនសម្គាល់ស្រីដែលមកកាន់សម្នាក់ខ្លួនថាជាម្តាយ ។ នាងសោណាមានកូនច្រើន ដឹងថាពួកកូនមិនគោរពខ្លួន គិតថា អញនឹងធ្វើអ្វីដោយឃរាវាសវិស័យ ដូច្នេះហើយទើបចេញបួស គ្រានោះ ភិក្ខុនីទាំងឡាយដាក់ទណ្ឌកម្មនាងថា ភិក្ខុនីរូបនេះមិនដឹងវត្ត ធ្វើកិច្ចដែលមិនសមគួរ ។ ពួកកូនប្រុសកូនស្រីឃើញនាងត្រូវទណ្ឌកម្ម ក៏នាំគ្នាចំអកឡកឡឺយ ក្នុងទីដែលឃើញថា ស្រីនេះមិនដឹងសូម្បីត្រឹមតែសិក្ខាមកទល់ថ្ងៃនេះ នាងបានឮវាចារបស់កូនប្រុសស្រីទាំងនោះ ក៏

កើតសេចក្ដីសង្វេគ គិតថា អញគួរធ្វើការជម្រះគតិរបស់ខ្លួន ទើបស្វាធ្យាយអាការ ៣២ ក្នុងទីដែលអង្គុយក្ដី ក្នុងទីដែលឈរក្ដី ក្នុងកាលមុនប្រាកដឈ្មោះថា សោណាថេរីអ្នកមានកូនច្រើន យ៉ាងណា ខាងក្រោយ ក៏ប្រាកដឈ្មោះថា ព្រះនាងសោណាថេរី ជាអ្នកប្រារព្ធព្យាយាមច្រើន ថ្ងៃមួយ ពួកភិក្ខុនីទៅវិហារ ប្រាប់ថា អ្នកនាងម្ចាស់សោណាដាំទឹកប្រគេនភិក្ខុនីសង្ឃផង នាងក៏ដើរចង្ក្រមក្នុងរោងភ្លើង មុនទឹកពុះ ទន្ទេញអាការ ៣២ ចម្រើនវិបស្សនា ។ ព្រះសាស្ដាប្រថាប់គង់ក្នុងព្រះគន្ធកុដិ ត្រាស់ព្រះគាថា មួយអន្ទើនឹងការបញ្ចេញឱភាសដូច្នេះថា

**យោ ច វស្សសតំ ជីវេ  អបស្សំ ធម្មមុត្តមំ**
**ឯកាហំ ជីវិតំសេយ្យោ  បស្សតោ ធម្មមុត្តមំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញធម៌ដ៏ខ្ពង់ខ្ពស់
ការរស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញធម៌ដ៏
ខ្ពង់ខ្ពស់ ប្រសើរជាង ។

ចប់ព្រះគាថា នាងក៏សម្រេចអរហត្ត គិតថា អាត្មាអញសម្រេចអរហត្តហើយ អ្នកដែលដើរមក មិនពិចារណាមុន ពោលពាក្យណាមួយមើលងាយអាត្មាអញ ក៏គប្បីបាននូវបាបដ៏ច្រើន ព្រោះហេតុនោះ អាត្មាអញគួរធ្វើហេតុដែលគេកំណត់ដឹងបាន ទើបលើកកំសៀវទឹកឡើងដាក់លើចង្ក្រានមិនដុតភ្លើងខាងក្រោម ពួកភិក្ខុនីមកឃើញតែចង្ក្រាន មិនឃើញភ្លើងក៏ពោលថា ពួកយើងប្រាប់ឲ្យស្រីចាស់នេះដាំទឹកប្រគេនភិក្ខុនីសង្ឃថ្ងៃនេះ នាងក៏មិន

ដាក់ភ្លើងក្នុងចង្ក្រាន ទើបពោលថា ពួកភិក្ខុនីត្រូវការងូតទឹក ដោយទឹកដែលកម្តៅដោយភ្លើងឬ សូមកាន់យកទឹកអំពីភាជនៈ ហើយងូតចុះ ។ ទើបភិក្ខុនីទាំងនោះទៅ ដោយសម្គាល់ថា នឹងមានហេតុក្នុងរឿងនេះ ។ យកដៃលូកក្នុងទឹក ក៏ដឹងថា ទឹកក្តៅ ទើបនាំក្អមទឹកមួយមកដាក់ទឹក ។ ទឹកដែលដាក់ហើយ ក៏ពេញវិញ ។ ខណៈនោះ ភិក្ខុនីទាំងអស់ក៏ដឹងថា នាងតាំងនៅក្នុងអរហត្ត ភិក្ខុនីដែលមានវស្សាខ្ចីជាងក៏ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន សូមខមាទោសថា បពិត្រអ្នកនាងម្ចាស់ ពួកខ្ញុំមិនពិចារណា ហើយពោលបៀតបៀន សូមអ្នកនាងម្ចាស់ អត់ទោសដល់ពួកខ្ញុំផងចុះ ។ ឯពួកព្រះថេរីដែលចាស់ជាង ក៏អង្គុយប្រហោង សុំខមាទោសថា ចូរអ្នកនាងម្ចាស់អត់ទោសផងចុះ ។ ចាប់តាំងអំពីនោះ គុណរបស់ព្រះថេរី ក៏ប្រាកដទូទៅថា ព្រះថេរីសូម្បីបួសឯចាស់ ក៏តាំងនៅក្នុងអគ្គផល ក្នុងកាលមិនយូរឡើយ ព្រោះជាអ្នកប្រារព្ធសេចក្តីព្យាយាម ។ ក្រោយមក ព្រះសាស្តាប្រថាប់គង់ក្នុងជេតពនមហាវិហារ កាលទ្រង់ស្ថាបនាពួកភិក្ខុនីក្នុងតំណែងផ្សេងៗ តាមលំដាប់ទើបទ្រង់ស្ថាបនាព្រះនាងសោណាថេរី ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកា ជាអ្នកប្រារព្ធព្យាយាម ដូច្នេះ ៕

## អដ្ឋកថាសូត្រទី ៧ ចប់

# អដ្ឋកថា សូត្រទី ៨

## ប្រវត្តិ ព្រះនាង សកុលាថេរី

ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា **ទិព្វចក្ខុកានំ យទិទំ សកុលា** លោកសម្ដែងថា ព្រះសកុលាថេរី ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលមានចក្ខុទិព្វ ។

បានឮថា ព្រះនាងសកុលាថេរីនេះ ក្នុងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតឡើងក្នុងត្រកូលមួយ បន្ដមក ស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាកំពុងស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលមានទិព្វចក្ខុ ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នានូវតំណែងនោះ ។ នាងអន្ទោលក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ នាក្រុងសាវត្ថី បន្ទាប់មក ស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា បាននូវសទ្ធា ហើយក៏បួស មិនយូរប៉ុន្មាន ក៏សម្រេចអរហត្ត ។ តាំងអំពីនោះមក នាងជាអ្នកជំនាញក្នុងទិព្វចក្ខុ ។ ក្រោយមក ព្រះសាស្ដាប្រថាប់គង់ក្នុងជេតពនវិហារ កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងឯតទគ្គៈផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះថេរីនេះ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលមានទិព្វចក្ខុ ដូច្នេះ ៕

**អដ្ឋកថាសូត្រទី ៨ ចប់**

# អដ្ឋកថា សូត្រទី ៩

# ប្រវត្តិ ព្រះនាង ភទ្ទាកុណ្ឌលកេសាថេរី

ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា **ខិប្បាភិញ្ញានំ** លោកសម្តែងថា ព្រះនាងភទ្ទាកុណ្ឌលកេសាថេរី ជាកំពូលជាងពួកភិក្ខុនីដែលជាសាវិកា ត្រាស់ដឹងរហ័ស ។

បានឮថា ព្រះនាងភទ្ទាកុណ្ឌលកេសានេះ ក្នុងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី ស្តាប់ធម៌របស់ព្រះមុនីហើយ ឃើញព្រះសាស្តាស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកា ដែលត្រាស់ដឹងរហ័ស ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ នាងអន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប កាលព្រះពុទ្ធព្រះនាមកស្សបៈ កើតជាព្រះធីតាមួយអង្គ ក្នុងរវាងបងប្អូន ៧ អង្គ ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកិកិ សមាទានសីល ១០ ប្រព្រឹត្តកុមារីព្រហ្មចរិយៈ អស់ ២ ម៉ឺនឆ្នាំ សាងបរិវេណថ្វាយសង្ឃ អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទយើងនេះ បដិសន្ធិក្នុងត្រកូលសេដ្ឋីក្រុងរាជគ្រឹះ ។ ឪពុកម្តាយដាក់ឈ្មោះថា ភទ្ទា ។

ថ្ងៃមួយ កូនបុរោហិតក៏កើតក្នុងនគរនោះ កាលកុមារនោះកើត អាវុធទាំងឡាយ ក៏ភ្លឺផ្លេកពេញព្រះនគរ តាំងអំពីព្រះរាជនិវេសន៍ជាដើមទៅ ។ បុរោហិតក៏ទៅកាន់រាជត្រកូលទាំងព្រឹក ទូលសួរព្រះរាជាដល់ការផ្ទំជាសុខ ។ ព្រះរាជាត្រាស់ថា នែលោកអាចារ្យ ខ្ញុំដេកជាសុខបានអំពីណា ខ្ញុំឃើញអាវុធទាំងឡាយក្នុងព្រះរាជនិវេសន៍ មានពន្លឺប្រាលភ្លៅ ក្នុងថ្ងៃនេះ ពិតជា

ជួបនូវភ័យឬ ។ បុរោហិតក្រាបទូលថា បពិត្រមហារាជ សូមទ្រង់កុំព្រះតម្រិះព្រោះសេចក្តីនោះជាបច្ច័យឡើយ អាវុធទាំងឡាយ មិនមែនមានពន្លឺតែក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គប៉ុណ្ណោះឡើយ ក្នុងនគរទាំងមូល ក៏យ៉ាងនេះ ។ ព្រះរាជាសួរថា នែលោកអាចារ្យ សេចក្តីនេះ ព្រោះហេតុអ្វី អាចារ្យទូលថា ក្នុងផ្ទះរបស់ទូលបង្គំ ក្មេងប្រុសកើតដោយឫក្សចោរ គេជាសត្រូវក្នុងព្រះនគរ ។ នុ៎ះជាបុព្វនិមិត្តរបស់កុមារនោះ តែទ្រង់មិនមានអន្តរាយទេ បើទ្រង់បំណង សូមទ្រង់សម្លាប់ចោលចុះ ព្រះរាជាត្រាស់ថា បើមិនបៀតបៀនខ្ញុំ មិនចាំបាច់សម្លាប់ទេ ។ បុរោហិតគិតថា កូនអញកើតមកយកឈ្មោះមកផង ទើបដាក់ឈ្មោះថា សត្តុកៈ ។ នាងកទ្ទាធំចម្រើនវ័យក្នុងផ្ទះសេដ្ឋី ។ សត្តុកៈធំចម្រើនវ័យក្នុងផ្ទះបុរោហិត ។ តាំងអំពីកុមារអាចរត់លេងទៅមកបាន គេនាំវត្ថុដែលគេជួបក្នុងទីដែលរត់ទៅមកទុកពេញផ្ទះមាតាបិតា ។ ឪពុកម្តាយពោលនឹងកុមារ រាប់ពាន់ហេតុ ក៏ហាមប្រាមមិនបាន ។ បន្ទាប់មក ឪពុកម្តាយដឹងថា ឃាត់កុមារមិនបានដោយអាការទាំងពួង ទើបឲ្យសំពត់ខៀវ ២ ផ្ទាំងដល់កុមារ ឲ្យគ្រឿងឧបករណ៍កាត់ទី-ត និងសីឃាតកយន្តទុកក្នុងដៃ ហើយកាត់កាល់ចោលទៅ ដោយពោលថា ចូរកូនចិញ្ចឹមជីវិតដោយការងារប្រភេទនេះចុះ ។ តាំងអំពីនោះមក កុមារបោះសីឃាតកយន្ត ( តម្កក់សម្រាប់ថ្កក់ឡើង ) ឡើងទៅលើប្រាសាទរបស់ត្រកូលទាំងឡាយ កាត់ទី-ត លួចទ្រព្យដែលទុកក្នុងត្រកូលដទៃ ដូចទ្រព្យដែលខ្លួនឯងរកទុកហើយ ក៏ទៅ ។ ក្នុងនគរទាំងមូល ឈ្មោះថា ផ្ទះមួយដែលមិនមាន

ប្រយោជន៍មិនមាន ។ ថ្ងៃមួយ ព្រះរាជាយាងទៅក្នុងព្រះនគរដោយរាជរថ ទើបត្រាស់សួរនាយសារថីថា ហេតុដូចម្តេចហ្ន៎ ទើបក្នុងផ្ទះនោះៗ ក្នុងនគរនេះ ប្រាកដមានប្រហោងទាំងនោះ ។ សារថីក្រាបទូលថា បពិត្រទេវៈ ក្នុងនគរនេះ មានចោរឈ្មោះសត្តុកៈ គាត់ជញ្ជាំងលួចទ្រព្យរបស់ត្រកូលទាំងឡាយ ។ ទើបព្រះរាជាប្រើឲ្យហៅភ្នាក់ងាររក្សានគរមក ហើយត្រាស់សួរថា បានឮថា ក្នុងនគរនេះ មានចោរឈ្មោះនេះ ហេតុអ្វី ទើបឯងមិនចាប់វា ។ នាយភ្នាក់ងាររក្សានគរក្រាបទូលថា បពិត្រទេវៈ ពួកទូលបង្គំមិនអាចចាប់ចោរនោះព្រមទាំងភស្តុតាងបានទេ ។ ព្រះរាជាបញ្ជាថា បើថ្ងៃនេះ ឯងជួបចោរនោះ ចូរចាប់ បើមិនចាប់ យើងនឹងដាក់អាជ្ញា ។ នាយភ្នាក់ងាររក្សានគរទទួលថា ព្រះករុណាថ្លៃវិសេស ទេវៈ ។ នាយភ្នាក់ងាររក្សានគរបញ្ជាឲ្យពួកមនុស្សក្នុងនគរទាំងមូល ដើរស្វែងរកចាប់ចោរដែលគាត់ជញ្ជាំងលួចទ្រព្យ មួយអន្លើដោយភស្តុតាងនោះបាន នាំទៅបង្ហាញដល់ព្រះរាជា ។ ព្រះរាជាបញ្ជាថា ចូរនាំចោរនេះចេញទៅតាមទ្វារខាងត្បូងហើយ ប្រហារជីវិតបង់ ។ នាយភ្នាក់ងាររក្សានគរ ទទួលស្នងព្រះរាជឱង្ការហើយ វាយចោរនោះម្តង ៤ កន្ទ្វង់ អស់ ១០០០ ដង ឲ្យចាប់ខ្នងនាំទៅតាមទ្វារ ទិសខាងត្បូង ។

សម័យនោះ នាងកញ្ញាសេដ្ឋីធីតា បើកសីហបញ្ជរមើល ព្រោះសំឡេងកោលាហលរបស់មហាជន ឃើញចោរសត្តុកៈត្រូវនាំទៅសម្លាប់ ក៏យកដៃរឹតដើមទ្រូង ដេកផ្កាប់មុខលើដំណេកដ៏មានសិរី នាងជាធីតាទោលរបស់ត្រកូលនោះ ។ ដោយហេតុនោះ ទើបពួកញាតិរបស់នាងមិនអាច អត់ធន់

ឃើញមុខ ដែលស្រពាប់ស្រពោនតិចតួចបាន ។ គ្រានោះ មាតាឃើញនាង ដេកលើដំណេក ទើបសួរនាងថា នែកូន កូនកើតអ្វី នាងឆ្លើយត្រង់ៗ ថា ខ្ញុំជួបចោរដែលគេកំពុងនាំទៅសម្លាប់ បើបានគេ ទើបរស់នៅបាន បើខ្ញុំមិនបាន ការស្លាប់ប៉ុណ្ណោះប្រសើរ ។ មាតាបិតាលួងលោមដោយប្រការផ្សេងៗ ក៏មិនអាចឲ្យនាងយល់ព្រមបាន ទើបកំណត់ថា រស់នៅល្អជាងស្លាប់ ។ គ្រានោះ ទើបបិតារបស់នាង ចូលទៅរកនាយក្អាក់ងាររក្សានគរ ឲ្យប្រាក់ ១០០០ កហាបណៈ ហើយប្រាប់ថា កូនស្រីរបស់ខ្ញុំ មានចិត្តប្រតិព័ទ្ធក្នុងចោរ ចូរអ្នកដោះលែងចោរនេះ ដោយវិធីណាមួយចុះ ។ នាយក្អាក់ងាររក្សានគរទទួលថាបាន ហើយនាំចោរពន្យារឲ្យយឺតយូរ ទៅផ្លូវនេះខ្លះ ផ្លូវនោះខ្លះ រហូតដល់ថ្ងៃលិច ។ កាលព្រះអាទិត្យលិចហើយ ក៏ឲ្យនាំចោរម្នាក់អំពីពួកចោរចេញមក ធ្វើចោរនោះឲ្យជាចោរសត្តុកៈ ដោះលែងចោរសត្តុកៈអំពីចំណង នាំទៅកាន់ផ្ទះសេដ្ឋី ហើយយកចំណងចងចោរម្នាក់ទៀត នាំខ្លួនចេញទៅតាមទ្វារទិសខាងត្បូង ប្រហារជីវិត ។ ពួកទាសៈរបស់សេដ្ឋីនាំចោរសត្តុកៈមកកាន់ផ្ទះសេដ្ឋី ។ សេដ្ឋីឃើញហើយ គិតថា អញនឹងធ្វើចិត្តរបស់កូនស្រីឲ្យពេញ ទើបឲ្យពួកទាសៈ នាំទឹកក្រអូបងូតឲ្យចោរសត្តុកៈ ហើយតាក់តែងគ្រឿងប្រដាប់ដោយអាភរណៈគ្រប់ប្រភេទ នាំខ្លួនទៅកាន់ប្រាសាទ ។ នាងកុណ្ឌលកេសីគិតថា ការត្រិះរិះរបស់អញពេញបរិបូណ៌ហើយ ទើបតែងខ្លួនឲ្យស្រស់ត្រកាលដោយអលង្ការច្រើនប្រភេទរង់ចាំបម្រើ ។

ចោរសត្តុកៈលុះកន្លងទៅបាន ២-៣ ថ្ងៃ គិតថា គ្រឿងប្រដាប់របស់

នាងនឹងជារបស់អញ អញគួរកាន់យកគ្រឿងអាភរណៈនេះ ដោយឧបាយណាមួយ ដូច្នេះហើយ លុះដល់ពេលអន្ទុយជិតគ្នាយ៉ាងមានសេចក្តីសុខ ទើបពោលនឹងនាងភទ្ទាថា ខ្ញុំមានរឿងដែលត្រូវពោលមួយ ។ សេដ្ឋីធីតាសប្បាយចិត្ត ហាក់ដូចបានលាភរាប់ពាន់ ទើបឆ្លើយថា នៃអ្នក យើងស្និទ្ធស្នាលគ្នាហើយ អ្នកចូរប្រាប់មកចុះ ចោរពោលថា នាងគិតថា ចោរនេះបានជីវិតមក ព្រោះអាស្រ័យអញ តែខ្ញុំកាលត្រូវចាប់ប៉ុណ្ណោះ បានបន់ទេវតាដែលស្ថិតនៅត្រង់ភ្នំទម្លាក់ចោរថា បើខ្ញុំបានជីវិត ខ្ញុំនឹងថ្វាយពលិកម្មដល់អ្នក ខ្ញុំបានជីវិតព្រោះអាស្រ័យទេវតានោះ ចូរនាងប្រញាប់រៀបចំគ្រឿងពលិកម្មចុះ ។ នាងភទ្ទាគិតថា អញនឹងធ្វើឲ្យគាត់ពេញចិត្ត បញ្ជាឲ្យចាត់ចែងគ្រឿងពលិកម្ម ប្រដាប់ដោយគ្រឿងអលង្ការគ្រប់ប្រភេទ ឡើងអន្ទុយក្នុងរថជាមួយគ្នា ទៅកាន់ជ្រោះទម្លាក់ចោរ ជាមួយនឹងស្វាមី ផ្តើមឡើងភ្នំទៅ ដោយគិតថា នឹងធ្វើពលិកម្មដល់ទេវតាប្រចាំភ្នំ ។ ចោរសត្តុកៈគិតថា កាលឡើងទាំងអស់គ្នាហើយ អញនឹងមិនមានឱកាសកាន់យកគ្រឿងអាភរណៈរបស់នាងបាន ទើបឲ្យនាងភទ្ទានោះ កាន់យកភាជនៈដែលជាជន្លាយឡើងលើភ្នំ ។ ចោរនិយាយវាចាធ្វើជាពោលជាមួយនឹងនាងភទ្ទាជជែកគ្នាទៅ ដោយហេតុនោះ ទើបនាងមិនដឹងបំណងរបស់ចោរ ។ ពេលនោះ ទើបចោរពោលនឹងនាងថា ភទ្ទាប្អូន នាងចូរដោះសំពត់ដណ្តប់របស់នាងចេញ ហើយយកគ្រឿងអលង្ការដែលតាក់តែងចងជាបង្វេចទុកក្នុងទីនេះ ។ នាងសួរថា នៃអ្នក ខ្ញុំមានកំហុសអ្វីឬ ។ ចោរពោលថា នែនាងល្ងង់ នាងធ្វើសេចក្តីសម្គាល់ថា ខ្ញុំមកដើម្បីធ្វើ

ពលិកម្មឬ តាមពិត ខ្ញុំនឹងខ្វះប្រើម ថ្វាយដល់ទេវតានេះ តែខ្ញុំមានបំណង នឹងកាន់យកគ្រឿងអាភរណៈរបស់នាង ដោយអាងពលិកម្ម ទើបមក ។ នាងពោលថា នែអ្នក គ្រឿងប្រដាប់ជារបស់នរណា ខ្លួនខ្ញុំជារបស់អ្នកណា ចោរពោលថា ខ្ញុំមិនដឹង គ្រឿងអលង្ការរបស់នាងជាចំណែកមួយ របស់ខ្ញុំ ជាចំណែកមួយ នាងពោលថា សាធុ តែសូមឲ្យអ្នកធ្វើបំណងរបស់ប្អូនមួយ ឲ្យបរិបូណ៌ចុះ សូមអ្នកឲ្យប្អូនបានឱបរឹតអ្នកទាំងខាងមុខ និងខាងក្រោយ ដោយទំនងដែលតែងខ្លួនយ៉ាងនេះឯង ចោរទទួលថា បាន ។ នាងដឹងថា ចោរទទួលហើយ ក៏ឱបខាងមុខ ហើយធ្វើជាឱបខាងក្រោយ ទើបច្រានចោរ ធ្លាក់ជ្រោះទៅ ។ កាលចោរធ្លាក់ទៅ ក៏បែកខ្ទេចខ្ទីទៅក្នុងអាកាសនោះឯង ។ ទេវតាដែលអាស្រ័យត្រង់ភ្នំឃើញអាការដែលនាងធ្វើ ឲ្យចោរបែកខ្ទេចខ្ទី ទើបបានពោលគាថា ដោយបំណងសរសើរដូច្នេះថា

ន ហិ សព្វេសុ ឋានេសុ    បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ    តត្ថ តត្ថ វិចក្ខណា
ន សោ សព្វេសុ ឋានេសុ    បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថីបិ បណ្ឌិតា ហោតិ    លហុំ អត្ថំ វិចិន្តិតា ។

ប្រុសមិនមែនឈ្មោះថា បណ្ឌិត ក្នុងហេតុទាំងអស់ទេ សូម្បី ស្រីសោះ តែជាអ្នកមានឧបាយវាងវៃ ក្នុងហេតុនោះ ៗ ក៏ ឈ្មោះថា បណ្ឌិតបាន ។

ប្រុសមិនមែនឈ្មោះថា បណ្ឌិត ក្នុងហេតុទាំងអស់ទេ សូម្បី

ស្រីសោះ តែជាអ្នកគិតឃើញនូវប្រយោជន៍រហ័ស ក៏ឈ្មោះ
ថា បណ្ឌិតដែរ ។

លំដាប់នោះ ទើបនាងកុណ្ឌលកេសាគិតថា អញមិនអាចត្រឡប់ទៅផ្ទះដោយទំនងនេះបានឡើយ អញទៅអំពីនេះហើយ នឹងបួសយ៉ាងណាមួយ ទើបទៅកាន់អារាមរបស់ពួកនិគ្រន្ថសូមបព្វជ្ជានឹងពួកនិគ្រន្ថ ។ ពេលនោះ ពួកនិគ្រន្ថទាំងនោះពោលនឹងនាងថា នឹងបួសដោយទំនងណា ។ នាងពោលថាវត្ថុណាជារបស់ឧត្តមក្នុងបព្វជ្ជារបស់លោក សូមលោកធ្វើវត្ថុនោះឯង ពួកនិគ្រន្ថទទួលថា សាធុ ហើយយកជាងត្នោតដកសក់របស់នាង ហើយឲ្យបួស ។ កាលសក់ដុះឡើងទៀត ក៏ដុះឡើងជារង្វង់មូលដូចកុណ្ឌលជាជុំដុះឡើងមក ។ ព្រោះហេតុនោះ ទើបនាងមានឈ្មោះថា កុណ្ឌលកេសា ។ នាងរៀនសិប្បៈគ្រប់យ៉ាងក្នុងទីដែលខ្លួនបួសហើយ កាលជ្រាបថា គុណវិសេសក្រៃលែងជាងនេះរបស់ពួកនិគ្រន្ថទាំងនេះមិនមាន ទើបត្រាច់ទៅកាន់គាមនិគមរាជធានីបណ្ឌិតមានក្នុងទីណា ក៏ទៅក្នុងទីនោះ ហើយរៀនសិប្បៈ ដែលបណ្ឌិតទាំងនោះដឹងគ្រប់យ៉ាងអស់ ។ បន្ទាប់មក មនុស្សទាំងឡាយដែលអាចលើកវាទៈជាមួយនាងបាន មិនមាន ព្រោះនាងជាអ្នកសិក្សាមកក្នុងទីដ៏ច្រើន ។ នាងមិនឃើញបុគ្គលណាដែលអាចពោលនឹងខ្លួនបាន ចូលទៅកាន់ស្រុកណាក្តី និគមណាក្តី ក៏ធ្វើពំនូកខ្សាច់ត្រង់ទ្វារស្រុក ឬនិគមនោះ ហើយដោតមែកព្រីងលើពំនូកខ្សាច់នោះឯង ឲ្យសញ្ញាដល់ក្មេងៗ ដែលឈរក្នុងទីជិតដោយពោលថា អ្នកណាអាចលើកវាទៈរបស់ខ្ញុំបាន អ្នកនោះចូរជាន់មែកឈើនេះ សូម្បី

អស់មួយសប្តាហ៍ ក៏មិនមានអ្នកណាជាន់ឡើយ ហើយនាងក៏យកមែកឈើនោះចៀសចេញទៅ ។

ក្នុងសម័យនោះ ព្រះមានព្រះភាគនៃយើង កើតឡើងហើយក្នុងលោក ទ្រង់អាស្រ័យក្រុងសាវត្ថី ប្រថាប់គង់ត្រង់វត្តជេតពន នាងកុណ្ឌលកេសា ក៏ទៅដល់ក្រុងសាវត្ថីដោយលំដាប់ កាលចូលទៅខាងក្នុងនគរហើយ ក៏ដោតមែកព្រីងលើគំនរខ្សាច់ដូចមុននោះឯង ហើយឲ្យសញ្ញាដល់ពួកក្មេង ទើបចូលទៅ ។

ក្នុងសម័យនោះ កាលភិក្ខុសង្ឃចូលទៅហើយ ទើបព្រះធម្មសេនាបតីចូលទៅកាន់នគរមួយអង្គឯងប៉ុណ្ណោះ ឃើញមែកព្រីងលើផ្នូកខ្សាច់ហើយ សួរថា ព្រោះហេតុអ្វី ទើបគេដោតព្រីងនេះ ពួកក្មេងប្រាប់ហេតុនោះដោយសព្វគ្រប់ ទើបលោកពោលថា អើ ក្មេងទាំងឡាយ បើដូច្នោះ ពួកអ្នកចូរចាប់យកមែកព្រីងនេះចេញ ហើយជាន់ចុះ ។

បណ្តាក្មេងទាំងនោះ ក្មេងពួកខ្លះស្តាប់ពាក្យព្រះថេរៈហើយ មិនហ៊ានជាន់ ពួកខ្លះជាន់ភ្លាមនោះឯង ធ្វើឲ្យបែកខ្ទេចខ្ទីទៅ ។

នាងកុណ្ឌលកេសាបរិភោគអាហារហើយ ដើរចេញទៅ ឃើញមែកឈើត្រូវជាន់ ទើបសួរថា នេះជាការធ្វើរបស់នរណា ទើបពួកក្មេងប្រាប់ការដែលព្រះធម្មសេនាបតីឲ្យពួកគេធ្វើដល់នាង ។ ទើបនាងគិតថា ព្រះថេរៈនេះ បើមិនដឹងកម្លាំងរបស់ខ្លួន នឹងមិនហ៊ានឲ្យជាន់មែកឈើនេះ ព្រះថេរៈនេះ ពិតជាធំ ពិតប្រាកដ សូម្បីតែអញញុំាងពួកក្មេងៗ ឲ្យស្អាតមិនបាន ។

អញគួរចូលទៅខាងក្នុងស្រុកនោះឯង ហើយឲ្យសញ្ញាដល់ពួកបរិស័ទ ដូច្នេះហើយ បានធ្វើដូច្នោះ ។ គប្បីជ្រាបថា ក្នុងនគរដែលជាទីអាស្រ័យនៃត្រកូល ៨ ម៉ឺនត្រកូល មនុស្សទាំងអស់នោះឯង តែងស្គាល់ដោយអំណាច មានការប្រៀបធៀបគ្នា ។ ចំណែកព្រះថេរៈ ធ្វើកត្តកិច្ចស្រេចហើយ ទើបអង្គុយត្រង់គល់ឈើមួយ ពេលនោះ នាងកុណ្ឌលកេសានេះ មានមហាជនចោមរោម ដើរទៅកាន់សម្នាក់របស់ព្រះថេរៈ ធ្វើបដិសណ្ឋារៈហើយ ឈរក្នុងទីសមគួរ នាចំណែកម្ខាង សួរថា បពិត្រលោកម្ចាស់ លោកម្ចាស់ឲ្យជាន់មែកឈើនេះឬ ព្រះសារីបុត្រពោលថា ពិតហើយ អាត្មាឲ្យជាន់នោះឯង នាងកុណ្ឌលកេសាពោលថា បើដូច្នោះ ខ្ញុំ និងលោកម្ចាស់ នឹងលើកវាទៈគ្នា ព្រះសារីបុត្រពោលថា បាន ។ នាងកុណ្ឌលកេសាពោលថា បពិត្រលោកម្ចាស់ អ្នកណាសួរអ្នកណាឆ្លើយ ព្រះសារីបុត្រពោលថា សេចក្តីពិតសំណួរធ្លាក់ដល់អាត្មា តែចូរនាងសួរធម៌ដែលនាងដឹងចុះ ។

នាងសួរលទ្ធិតាមដែលខ្លួនចេះមកទាំងអស់នោះឯង តាមដែលព្រះថេរៈយល់ព្រម ព្រះថេរៈក៏ពោលដោះស្រាយបានទាំងអស់ ។ កាលនាងសួរហើយសួរទៀត រហូតអស់ ទើបនៅស្ងៀម ។ លំដាប់នោះ ទើបព្រះថេរៈពោលនឹងនាងថា នាងសួរអាត្មាអស់ហើយ អាត្មាក៏នឹងសួរនាងមួយប្រស្នាចុះ នាងកុណ្ឌលកេសាពោលថា សូមលោកម្ចាស់សួរចុះ ។

ព្រះសារីបុត្រពោលថា អ្វីឈ្មោះថា មានតែមួយ ។ នាងកុណ្ឌលកេសា ប្រាប់ថា បពិត្រលោកម្ចាស់ ខ្ញុំមិនជ្រាបទេ ។ ព្រះសារីបុត្រពោលថា

នាងមិនដឹងហេតុត្រឹមប៉ុណ្ណោះ នាងនឹងដឹងអ្វីដទៃបាន ។

នាងក្រាបទៀបបាទាទាំង ២ របស់ព្រះថេរៈ សូមថា ខ្ញុំសូមដល់លោកម្ចាស់ជាសរណៈរបស់ខ្ញុំ ។ ព្រះសារីបុត្រពោលថា កុំដល់អាត្មាជាសរណៈឡើយ អគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោកប្រថាប់នៅត្រង់វិហារជិតៗនេះឯង ចូរនាងដល់ព្រះអង្គជាសរណៈចុះ ។ នាងកុណ្ឌលកេសាពោលថា ខ្ញុំនឹងធ្វើយ៉ាងនោះ ។

លុះពេលល្ងាច ក្នុងវេលាដែលព្រះសាស្ដាទ្រង់សម្ដែងធម៌ ទើបទៅកាន់សម្នាក់របស់ព្រះសាស្ដា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយបានឈរនៅក្នុងទីដ៏សមគួរ នាចំណែកម្ខាង ។ ព្រះសាស្ដា ត្រាស់ព្រះគាថាក្នុងធម្មបទ តាមសមគួរដល់ចរិយារបស់នាង ដែលធ្លាប់ពិចារណាឃើញសង្ខារដែលទុក្ខបៀតបៀនហើយតទៅថា

**សហស្សមបិ ចេ គាថា អនត្ថបទសញ្ហិតា**
**ឯកំ គាថាបទំ សេយ្យោ យំ សុត្វា ឧបសម្មតិ ។**

បើគាថាសូម្បីមួយ ១០០០ ជាគាថា ប្រកបដោយបទឥតប្រយោជន៍ គាថានោះ ពុំប្រសើរឡើយ អ្នកណាស្ដាប់បទនៃគាថាណាហើយ រមែងស្ងប់រម្ងាប់បាន បទនៃគាថានោះ សូម្បីតែមួយបទ ក៏ឈ្មោះថា ប្រសើរជាង ។

ក្នុងវេលាចប់គាថា ក្នុងខណៈឈរនោះឯង ក៏បានសម្រេចអរហត្តមួយអន្លើដោយបដិសម្ភិទា ទើបទូលសូមបព្វជ្ជា ។ ព្រះសាស្ដា ទ្រង់ទទួល

ឲ្យនាងបព្វជ្ជាហើយ ។ នាងទៅកាន់សម្នាក់ភិក្ខុនីបួសហើយ ។ ក្នុងកាលតមក កើតការសន្ទនាគ្នាឡើង ក្នុងកណ្តាលបរិស័ទ ៤ ថា នាងភទ្ទាកុណ្ឌលកេសានេះ ធំក្រៃលែងហ្ន៎ សម្រេចអរហត្តក្នុងវេលាចប់គាថាត្រឹម ៤ បទ ។ ព្រះសាស្តា ទ្រង់ធ្វើហេតុនោះឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់ស្ថាបនាព្រះថេរីទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកា ដែលត្រាស់ដឹងរហ័ស ដោយប្រការដូច្នេះ ។

## អដ្ឋកថា សូត្រទី ៩ ចប់

## អដ្ឋកថា សូត្រទី ១០
## ប្រវត្តិ ព្រះនាងភទ្ទាកាបិលានីថេរី

ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ ដោយបទថា **បុព្វេនិវាសំ អនុស្សរន្តីនំ** លោកសម្តែងថា ព្រះនាងភទ្ទាកាបិលានីថេរី ជាកំពូលជាងពួកភិក្ខុនីសាវិកា ខាងមានបុព្វេនិវាសញ្ញាណ តាមរឭកខន្ធសន្តានដែលធ្លាប់អាស្រ័យក្នុងកាលមុនបាន ។

បានឮថា កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងផ្ទះ នៃត្រកូលនាក្រុងហង្សវតីស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តាហើយឃើញ ព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូបទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើសភិក្ខុនីសាវិកា

ខាងមានបុព្វេនិវាសញ្ញាណ ទើបធ្វើកុសលកម្មឲ្យក្រៃលែងឡើង ប្រាថ្នានូវតំណែងនោះ ។ នាងវិលស្លាប់វិលកើតក្នុងទេវតា និងមនុស្សទាំងឡាយ កាលព្រះពុទ្ធមិនទាន់កើតឡើង បដិសន្ធិក្នុងត្រកូល នាពារាណសី ធ្វើការទាស់ទែងជាមួយប្អូនស្រីរបស់ខ្លួន កាលប្អូនស្រីនោះ ថ្វាយបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ ក៏គិតថា ស្រីនេះប្រគេនបិណ្ឌបាតដល់ព្រះបច្ចេកពុទ្ធ នឹងឲ្យអញធ្លាក់នៅក្នុងអំណាចរបស់ខ្លួន ដូច្នេះហើយ ទើបទទួលបាត្រអំពីដៃរបស់ព្រះបច្ចេកពុទ្ធ ចាក់អាហារចោល យកភក់ដាក់ពេញបាត្រ ហើយប្រគេន ។ មហាជននាំគ្នាតិះដៀលថា នាងនេះជាស្រីពាល និយាយគ្នាថា នាងទាស់ជាមួយស្រីណា មិនធ្វើអ្វីដល់ស្រីនោះ ព្រះបច្ចេកពុទ្ធធ្វើអ្វីខុសចំពោះនាងឬ ។ នាងខ្មាសសម្តីរបស់មនុស្សទាំងនោះ ទើបទទួលបាត្រមកជាថ្មី ចាក់ភក់ចេញ យកលម្អិតក្រអូប ដុសឲ្យស្អាត ដាក់មធុរស ៤ យ៉ាង រហូតពេញ ហើយដាក់បាត្រ ដែលមានពណ៌ថ្លា ដោយសប្បិមានពណ៌ដូចផ្កាឈូកដាក់លើដៃរបស់ព្រះបច្ចេកពុទ្ធ ហើយតាំងសេចក្តីប្រាថ្នាថា បិណ្ឌបាតនេះ កើតមានពន្លឺផូរផង់ យ៉ាងណា សូមឲ្យសរីរៈរបស់ខ្ញុំ មានពន្លឺផូរផង់យ៉ាងនោះចុះ ។ រឿងទាំងអស់ គប្បីជ្រាបតាមន័យដែលពោលហើយ ក្នុងរឿងរបស់ព្រះមហាកស្សបត្ថេរចុះ ។

ឯព្រះមហាកស្សបត្ថេរកាន់យកផ្លូវខាងស្តាំ ទៅកាន់គល់ជ្រៃឈ្មោះពហុបុត្តកៈ ដែលជាសម្នាក់របស់ព្រះទសពល ។ នាងភទ្ទកាបិលានីកាន់យកផ្លូវខាងឆ្វេង ទៅកាន់អារាមរបស់ពួកបរិព្វាជក ព្រោះហេតុដែលការបួស

មាតុគ្រាម ព្រះមានព្រះភាគទ្រង់មិនបានអនុញ្ញាត លុះកាលព្រះនាងមហា-បជាបតីគោតមីបានបព្វជ្ជាហើយ ទើបនាងបានបព្វជ្ជាឧបសម្បទាក្នុងសម្នាក់របស់ព្រះថេរី ក្នុងកាលបន្ទមក ធ្វើវិបស្សនាកម្មដ្ឋានបាន សម្រេចអរហត្តទើបជាអ្នកមានជំនាញ ក្នុងបុព្វេនិវាសញ្ញាណ ។ លំដាប់នោះ ព្រះសាស្ដាប្រថាប់គង់ក្នុងវត្តជេតពន កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះថេរីនេះក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា អ្នកមានបុព្វេនិវាសញ្ញាណ ដោយប្រការដូច្នេះឯង ។

**អដ្ឋកថា សូត្រទី ១០ ចប់**

## អដ្ឋកថា សូត្រទី ១១

## ប្រវត្តិ ព្រះនាង ភទ្ទាកច្ចានាថេរី

ក្នុងសូត្រទី ១១ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **មហាភិញ្ញា-បត្តានំ** លោកសម្ដែងថា ព្រះនាងភទ្ទាកច្ចានា ជាកំពូលជាងពួកភិក្ខុនី-សាវិកា ដែលសម្រេចអភិញ្ញាធំ ។ សេចក្ដីពិត សម្រាប់ព្រះពុទ្ធមួយអង្គមានបុគ្គលដែលសម្រេចអភិញ្ញាធំ ៤ រូប សាវ័កដ៏សេស មិនសម្រេចឡើយ ។ ព្រោះសាវ័កដ៏សេស អាចរឭកជាតិបានត្រឹមតែមួយសែនកប្បប៉ុណ្ណោះ ក្រៅលែងជាងនេះ រឭកមិនបានឡើយ ។ តែបុគ្គលដែលសម្រេច

អភិញ្ញាធំ រមែងរឭកជាតិបានមួយអសង្ខេយ្យ និងមួយសែនកប្ប ។ ក្នុងសាសនារបស់ព្រះសាស្តានៃយើង ជន ៤ រូប គឺអគ្គសាវក ២ រូប ព្រះពាកុលត្ថេរ ១ រូប ព្រះនាងភទ្ទាកច្ចានាថេរីអាចរឭកជាតិបានប្រមាណប៉ុណ្ណោះ ព្រោះដូច្នោះ ទើបព្រះថេរីឈ្មោះថា ជាកំពូលជាងពួកភិក្ខុនីសាវិកាខាងមានអភិញ្ញាធំ ព្រះនាងមានព្រះនាមថា ភទ្ទាកច្ចានា ព្រោះពណ៌សម្បុរនៃសរីរៈរបស់ព្រះនាងនោះ ល្អដូចមាសដែលល្អបំផុត ។ ព្រោះដូច្នោះ ទើបព្រះនាងរាប់បានថាជាមនុស្សស្អាតដោយពិត នេះជាព្រះនាមរបស់ព្រះមាតានៃព្រះរាហុល ។

ព្រះនាងកាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ក្នុងកាលបន្ទាប់មក ស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូប ក្នុងតំណែងឯតទគ្គៈ ជាកំពូលនៃពួកភិក្ខុនីសាវិកា ដែលសម្រេចអភិញ្ញាធំ ទើបធ្វើកុសលឲ្យក្រៃលែងឡើងប្រាថ្នាតំណែងនោះ ។ នាងវិលវល់ស្លាប់កើតក្នុងទេវតា និងមនុស្សលោក អស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងព្រះរាជនិវេសន៍របស់ព្រះបាទសុប្បពុទ្ធ ។ ពួកព្រះញាតិថ្វាយព្រះនាមថា ភទ្ទាកច្ចានា ។ ព្រះនាងចម្រើនវ័យ បានអភិសេកជាមហេសីរបស់ព្រះពោធិសត្វ ។ បន្ទាប់មក ព្រះនាងបានប្រសូតព្រះឱរសព្រះនាមថា រាហុលកុមារ ។ ក្នុងថ្ងៃដែលរាហុលកុមារប្រសូតហើយ ព្រះពោធិសត្វចេញសាងព្រះផ្នួស ទ្រង់សម្រេចព្រះសព្វញ្ញុតញ្ញាណត្រង់គល់ពោធិព្រឹក្ស កាលធ្វើការអនុគ្រោះសត្វលោក យាង

មកដល់ក្រុងកបិលពស្តុ ដោយលំដាប់ ទ្រង់បានធ្វើការសង្គ្រោះព្រះញាតិ ។ បន្ទាប់មក កាលព្រះបាទសុទ្ធោទនមហារាជបរិនិព្វានហើយ ព្រះនាងមហាបជាបតីគោតមី មួយអន្លើដោយមាតុគ្រាម ៥០០ សូមបព្វជ្ជាក្នុងសម្នាក់របស់ព្រះសាស្តា ។ មាតានៃរាហុលក្តី ព្រះនាងរូបនន្ទាជនបទកល្យាណីក្តី ក៏នាំគ្នាទៅកាន់សម្នាក់ព្រះថេរី បួសហើយ ។ ចាប់តាំងអំពីបួសហើយ ប្រាកដឈ្មោះថា ភទ្ទាកច្ចានាថេរី ។ បន្ទាប់មក នាងចម្រើនវិបស្សនា សម្រេចអរហត្តហើយ ជាអ្នកជំនាញក្នុងអភិញ្ញាទាំងឡាយ អន្តយពត់ក្នែនតែម្តង រឭកជាតិបានដល់ទៅមួយអសង្ខេយ្យ និងមួយសែនកប្ប ដោយការរឭកម្តងប៉ុណ្ណោះ ។ កាលគុណរបស់នាងប្រាកដច្បាស់ហើយ ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពន ទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយក្នុងតំណែងឯតទគ្គៈផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីនេះទុកក្នុងតំណែងឯតទគ្គៈជាកំពូលជាងភិក្ខុនីសាវិកា ដែលសម្រេចអភិញ្ញាធំ ដូច្នេះ ។

## អដ្ឋកថា សូត្រទី ១១ ចប់

# អដ្ឋកថា សូត្រទី ១២
# ប្រវត្តិ ព្រះនាង កិសាគោតមីថេរី

ក្នុងសូត្រទី ១២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **លូខចីវរធរានំ** លោកសម្តែងថា ព្រះនាងកិសាគោតមី ជាកំពូលនៃភិក្ខុនីសាវិកា ដែលទ្រទ្រង់សំពត់បង្សុកូល ដែលប្រកបដោយភាពសៅហ្មងដូច្នេះ នាងឈ្មោះថា គោតមី តែគេតែងហៅថា កិសាគោតមី ព្រោះជាអ្នកមានរូបរាងស្គមបន្តិច ។

ព្រះថេរីនេះ កាលព្រះសម្មាសម្ពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី ស្តាប់ធម្មទេសនារបស់ព្រះសាស្តាហើយ ឃើញព្រះសាស្តាទ្រង់ស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា ខាងទ្រទ្រង់សំពត់សៅហ្មង ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ នាងអន្ទោលទៅក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលក្រីក្រមួយ ក្នុងក្រុងសាវត្ថី លុះចម្រើនវ័យហើយ ក៏ទៅកាន់ការគ្រប់គ្រងផ្ទះ ។ ពួកជនក្នុងត្រកូលនោះមើលងាយនាងថា ជាកូនស្រីរបស់ត្រកូលក្រីក្រ ។ បន្ទាប់មក នាងប្រសូតបុត្របានម្នាក់ ។ ពេលនោះ ទើបជនទាំងឡាយលើកតម្កើងនាង ។ កូនរបស់នាង តាំងនៅក្នុងវ័យល្មមរត់ទៅរត់មកបាន ក៏ស្លាប់ សេចក្តីសោកក៏បានកើតឡើងដល់នាង ។ នាងគិតថា អាត្មាអញដាច់លាភ និងសក្ការៈក្នុងផ្ទះនេះហើយ តាំងអំពីកាលដែលកូនអញកើតមក ទើបបានសក្ការៈ ទើបជនទាំងនេះព្យាយាមដើម្បីចោលកូនរបស់អញខាងក្រៅ ដូច្នេះ ទើបបីបុត្រដាក់ត្រង់ចង្កេះ ត្រាច់ទៅតាមលំដាប់ទ្វារផ្ទះ ដោយពោលថា សូម

ពួកអ្នកឲ្យថ្នាំដល់កូនរបស់ខ្ញុំផងចុះ ដូច្នេះ ។ ពួកមនុស្សក្នុងទីដែលឃើញហើយ នាំគ្នាផ្ទាត់ម្រាមដៃ ធ្វើការចំអកថា ថ្នាំសម្រាប់មនុស្សស្លាប់ នាងធ្លាប់ឃើញទីណា ។ នាងមិនបានយល់អត្ថនៃពាក្យរបស់ជនទាំងនោះឡើយ ។ សម័យនោះ អ្នកមានបញ្ញាម្នាក់ឃើញនាងហើយ គិតថា ស្រីនេះ ពិតជាមានចិត្តរវើរវាយ ព្រោះសោកសង្រេងដល់កូន ថ្នាំសម្រាប់កូនរបស់នាង អ្នកដទៃមិនដឹងឡើយ ព្រះទសពលប៉ុណ្ណោះ ទ្រង់ជ្រាប ដូច្នេះហើយ ទើបពោលយ៉ាងនេះថា នែនាង ថ្នាំសម្រាប់កូននាង អ្នកដទៃមិនដឹងឡើយ ព្រះទសពលជាអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោក ប្រថាប់នៅក្នុងវិហារជិតៗ នេះឯង ចូរនាងទៅទូលសួរចុះ ។ នាងគិតថា ជននេះនិយាយពិត ទើបបីកូនទៅឈរត្រង់ខាងចុងបរិស័ទ ក្នុងកាលព្រះតថាគតប្រថាប់គង់លើពុទ្ធាសនៈ ហើយក្រាបទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ប្រទានថ្នាំដល់កូនខ្ញុំម្ចាស់ផងចុះ ដូច្នេះ ។

ព្រះសាស្តា ទ្រង់ឃើញឧបនិស្ស័យរបស់នាងហើយ ត្រាស់ថា ម្នាលគោតមី នាងមកទីនេះដើម្បីថ្នាំ ឈ្មោះថា ជាការល្អ នាងចូរទៅកាន់នគរត្រាច់ទៅឲ្យពេញព្រះនគរ តាំងអំពីចុងស្រុកទៅ ក្នុងផ្ទះណា មិនធ្លាប់មានមនុស្សស្លាប់ ចូរនាំយកគ្រាប់ស្ពៃអំពីផ្ទះនោះមក ដូច្នេះ នាងទូលថា សាធុ ដូច្នេះ មានចិត្តត្រេកអរ ចូលទៅខាងក្នុងនគរ លុះដល់ផ្ទះទី ១ នោះឯងក៏ពោលថា ព្រះទសពលទ្រង់ត្រាស់ឲ្យរកគ្រាប់ស្ពៃ ដើម្បីប្រយោជន៍ជាថ្នាំដល់កូនរបស់ខ្ញុំ សូមពួកអ្នកឲ្យគ្រាប់ស្ពៃដល់ខ្ញុំចុះ ដូច្នេះ ។ ពួកមនុស្សទាំង-

ឡាយបានមកឲ្យនាង ដោយពោលថា អញ្ជើញយកចុះគោតមី នាងគោតមី ពោលថា ខ្ញុំមិនអាចទទួលដោយទំនងនេះ ក្នុងផ្ទះនេះ មិនធ្លាប់មានមនុស្ស ស្លាប់ទេឬ អ្នកស្រុកពោលថា នែនាងគោតមី នាងនិយាយអ្វី អ្នកណាអាច រាប់មនុស្សស្លាប់ក្នុងផ្ទះនេះបាន នាងគោតមីពោលថា បើដូច្នោះ មិនបាច់ទេ ព្រះទសពលទ្រង់ឲ្យខ្ញុំទទួលគ្រាប់ស្ពៃនោះអំពីផ្ទះ ដែលមិនធ្លាប់មានមនុស្ស ស្លាប់ ។

នាងដើរទៅកាន់ផ្ទះទី ៣ ដោយទំនងនេះឯង ហើយគិតថា ក្នុងនគរ ទាំងមូល ក៏នឹងមានទំនងដូចគ្នា ព្រះពុទ្ធទ្រង់អនុគ្រោះដោយប្រយោជន៍ ទ្រង់ នឹងឃើញហេតុនេះ ដូច្នេះ បាននូវសេចក្តីសង្វេគ ចេញទៅខាងក្រៅនគរ នោះឯង ទៅកាន់ព្រៃខ្មោច យកដៃចាប់កូន ហើយពោលថា នែកូន ម្តាយ គិតថា ការស្លាប់នេះ កើតឡើងដល់ឯងប៉ុណ្ណោះ តែសេចក្តីស្លាប់នេះ មិន មែនមានដល់កូនតែម្នាក់ទេ នេះជាធម្មតា មានដល់មហាជនទូទៅ ដូច្នេះ ហើយ ទើបចោលកូនចូលក្នុងព្រៃខ្មោច ហើយពោលគាថានេះថា

**ន គាមធម្មោ និគមស្ស ធម្មោ**
**ន ចាបិយំ ឯកកុលស្ស ធម្មោ**
**សព្វស្ស លោកស្ស សទេវកស្ស**
**ឯសោវ ធម្មោ យទិទំ អនិច្ចតា ។**

អនិច្ចតាធម៌នេះ នឹងថាជាធម៌សម្រាប់ស្រុកមួយក៏ទេ ជាធម៌ សម្រាប់និគមមួយក៏ទេ ជាធម៌សម្រាប់ត្រកូលមួយក៏ទេ ធម៌

ទុំះឯង សម្រាប់លោក ព្រមទាំងទេវលោកទាំងអស់ ។

កាលពោលយ៉ាងនេះហើយ នាងបានទៅកាន់សម្នាក់របស់ព្រះសាស្តា ។ ព្រះសាស្តាត្រាស់ថា ម្នាលគោតមី នាងបានគ្រាប់ស្ពៃហើយឬ នាងពោលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមិនមានការដែលត្រូវប្រើគ្រាប់ស្ពៃទៀតឡើយ សូមទ្រង់ប្រទានទីពឹងដល់ខ្ញុំម្ចាស់ចុះ ។

សម័យនោះ ព្រះសាស្តាត្រាស់គាថាក្នុងធម្មបទដល់នាងថា

**តំ បុត្តបសុសម្មត្តំ ព្យាសត្តមនសំ នរំ**
**សុត្តំ គាមំ មហោឃោវ មច្ចុ អាទាយ គច្ឆតិ ។**

មច្ចុ គឺសេចក្តីស្លាប់ តែងនាំយកនរជន អ្នកប្រវឹងជ្រប់ក្នុងកូន និងសត្វចិញ្ចឹម មានចិត្តជាប់ជំពាក់ក្នុងអារម្មណ៍ផ្សេងៗនោះ ដូចជំនន់ទឹកធំ នាំយកអ្នកស្រុកកំពុងដេកលក់ ។

ចប់គាថា ក្នុងជំហរនោះឯង នាងតាំងនៅក្នុងសោតាបត្តិផល ទូលសូមបព្វជ្ជាហើយ ។ ព្រះសាស្តាទ្រង់អនុញ្ញាតការបំពេញបព្វជ្ជាដល់នាង ។ នាងធ្វើប្រទក្សិណព្រះសាស្តា ៣ ជុំ ថ្វាយបង្គំហើយ ទៅកាន់សម្នាក់ភិក្ខុនី បានបព្វជ្ជា និងឧបសម្បទាហើយ មិនយូរប៉ុន្មាន ធ្វើកម្មក្នុងយោនិសោមនសិការ ចម្រើនវិបស្សនា លំដាប់នោះ ព្រះសាស្តាបានត្រាស់ព្រះគាថា មួយអន្លើនឹងការបញ្ចេញឱភាសដល់នាងថា

**យោ ច វស្សសតំ ជីវេ អបស្សំ អមតំ បទំ**
**ឯកាហំ ជីវិតំ សេយ្យោ បស្សតោ អមតំ បទំ ។**

បុគ្គលណា រស់នៅ ១០០ ឆ្នាំ មិនឃើញផ្លូវព្រះនិព្វាន ការ
រស់នៅសូម្បីតែ ១ ថ្ងៃ របស់លោកអ្នកឃើញផ្លូវព្រះនិព្វាន
ប្រសើរជាង ។

ចប់ព្រះគាថា នាងក៏សម្រេចអរហត្ត ជាអ្នកឧក្រិដ្ឋក្នុងការប្រើប្រាស់បរិក្ខារ ដណ្តប់ចីវរ ៣ ដែលប្រកបដោយសេចក្តីសៅហ្មង ត្រាច់ទៅ ។ តមក ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពន កាលទ្រង់ស្ថាបនាពួកភិក្ខុនីទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីនេះ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងភិក្ខុនីសាវិកា ជាអ្នកទ្រទ្រង់ចីវរសៅហ្មង ។

**អដ្ឋកថាសូត្រទី ១២ ចប់**

## អដ្ឋកថា សូត្រទី ១៣
## ប្រវត្តិ ព្រះនាង សិគាលមាតាថេរី

ក្នុងសូត្រទី ១៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សទ្ធាធិមុត្តានំ** លោកសម្តែងថា ព្រះនាងសិគាលមាតាថេរី ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលរួចផុតអំពីកិលេសដោយសទ្ធា ។

បានឮមកថា កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី កាលស្តាប់ធម៌របស់ព្រះសាស្តា ឃើញព្រះសាស្តា ទ្រង់

ស្ថាបនាភិក្ខុនីមួយរូប ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកភិក្ខុនីសាវិកា ដែលផុតចាកកិលេសដោយសទ្ធា ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងអន្ទោលទៅក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋី ក្រុងរាជគ្រឹះ បានប្ដីមានត្រកូលជាតិស្មើគ្នា ប្រសូតបុត្រម្នាក់ ។ ជនទាំងឡាយដាក់ឈ្មោះឲ្យកូនរបស់នាងថា សិគាលកុមារ ។ ព្រោះហេតុនោះឯង នាងក៏មានឈ្មោះថា សិគាលមាតា ។ ថ្ងៃមួយ នាងស្ដាប់ធម្មកថារបស់ព្រះសាស្ដាហើយ បាននូវសទ្ធា ទៅកាន់សម្នាក់របស់ព្រះសាស្ដា បព្វជ្ជាហើយ តាំងអំពីបួស ត្រឡប់បាននូវសទ្ធិន្ទ្រិយ មានប្រមាណក្រៃលែង ។ នាងទៅកាន់វិហារដើម្បីស្ដាប់ធម៌ កំពុងឈរមើលព្រះសិរីសម្បត្តិរបស់ព្រះទសពលនោះឯង ព្រះសាស្ដាទ្រង់ជ្រាបថា នាងជាអ្នកតាំងមាំក្នុងលក្ខណៈនៃសទ្ធាហើយ ទ្រង់សម្ដែងធម៌ជាទីតាំងនៃសេចក្ដីជ្រះថ្លា ទ្រង់ធ្វើឲ្យជាទីសប្បាយនោះឯង ព្រះថេរីនោះក៏ធ្វើសទ្ធាលក្ខណៈឲ្យជាធុរៈបានសម្រេចអរហត្តហើយ គ្រានោះ ព្រះសាស្ដាប្រថាប់គង់ក្នុងជេតពន កាលទ្រង់ស្ថាបនាភិក្ខុនីទាំងឡាយ ក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាព្រះថេរីនេះ ក្នុងតំណែងជាកំពូលជាងភិក្ខុនីសាវិកា ដែលផុតចាកកិលេសដោយសទ្ធា ដោយប្រការដូច្នេះ ៕៚

**អដ្ឋកថា សូត្រទី ១៣ ចប់**

**ប្រវត្តិភិក្ខុនីសាវិកា ១៣ អង្គ ចប់**

**វគ្គទី ៥ ចប់**

# ឯតទគ្គបាលិ

# វគ្គទី ៦

[ ១៥១ ] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសកអ្នកដល់សរណៈជាបឋម ដែលជាសាវ័ករបស់តថាគត ស្រេចនឹងតបុស្សពាណិជ និងភល្លិកពាណិជប្រសើរជាងគេ ។ ពួកឧបាសកជាទាយក ( អ្នកឲ្យទាន ) ស្រេចនឹងសុទត្តគហបតី គឺអនាថបិណ្ឌិកសេដ្ឋី ។ ពួកឧបាសកជាធម្មកថិក ស្រេចនឹងចិត្តគហបតី ដែលនៅក្នុងស្រុកមច្ឆិកសណ្ឌ ។ ពួកឧបាសកអ្នកសង្គ្រោះបរិសទ្យឲ្យដោយសង្គហវត្ថុ ៤ ប្រការ ស្រេចនឹងហត្ថកអាឡវកៈ ។ ពួកឧបាសកអ្នកឲ្យភោជនមានរសដ៏ឧត្តម ស្រេចនឹងមហានាមសក្កៈ ។ ពួកឧបាសកអ្នកឲ្យភោជនជាទីគាប់ចិត្ត ស្រេចនឹងឧគ្គគហបតីអ្នកនៅក្នុងក្រុងវេសាលី ។ ពួកឧបាសកអ្នកបម្រើសង្ឃ ស្រេចនឹងឧគ្គតគហបតី ។ ពួកឧបាសកអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងសូរអម្ពដ្ឋ ។ ពួកឧបាសកអ្នកញុំាងបុគ្គលឲ្យជ្រះថ្លា ស្រេចនឹងជីវកកោមារភច្ច ។ ពួកឧបាសកអ្នកចេះនិយាយឲ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹងនកុលបិតាគហបតី ។

*វគ្គទី ៦ ចប់*

# អដ្ឋកថា សូត្រទី ១

# ប្រវត្តិ តបុស្សៈ និងភល្លិក ឧបាសក

*[ ១៥១ ] ក្នុងសូត្រទី ១ វគ្គទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **បឋមំ សរណំ គច្ឆន្តានំ** *លោកសម្ដែងថា ឈ្មួញ ២ នាក់ គឺតបុស្សៈ ១ ភល្លិកៈ ១ ជាកំពូលជាងពួកឧបាសក ដែលដល់សរណៈមុនមនុស្សទាំងពួង ។*

*បានឮថា ឈ្មួញទាំង ២ នេះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ គាត់បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ។ ចំណោរតមក បានស្ដាប់ធម្មទេសនារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសក ២ នាក់ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសក ដែលដល់សរណៈដំបូង ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ ជនទាំង ២ អន្ទោលស្លាប់កើតក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប កើតក្នុងផ្ទះកុដុម្ពិកៈ ក្នុងអសិតញ្ជនគរ មុនព្រះពោធិសត្វនៃយើងទ្រង់សម្រេចសព្វញ្ញុតញ្ញាណ បងប្រុសឈ្មោះតបុស្សៈ ប្អូនប្រុសឈ្មោះភល្លិកៈ ។ សម័យតមក ពួកគាត់នៅគ្រប់គ្រងផ្ទះ ទឹមរទេះ ៥០០ ធ្វើការលក់ដូរបន្តៗ មកអស់កាលយូរ ។*

*សម័យនោះ ព្រះពោធិសត្វនៃយើងទ្រង់សម្រេចសព្វញ្ញុតញ្ញាណ គង់ប្រថាប់ត្រង់គល់ពោធិព្រឹក្ស ៧ សប្ដាហ៍ក្នុងសប្ដាហ៍ទី ៨ គង់ប្រថាប់ត្រង់គល់កែស ។ សម័យនោះ ឈ្មួញទាំង ២ នោះ បានមកដល់ទីនោះ មួយអន្ទើដោយរទេះប្រមាណ ៥០០ ។ ម្ដាយរបស់ឈ្មួញនោះ កើតជាទេវតានៅផ្ទុំទីនោះ ក្នុងអត្តភាពជាប់តគ្នា ៥ ជាតិ ។ នាងគិតថា ឥឡូវនេះ ព្រះពុទ្ធ*

គួរបានទទួលភត្តាហារ ព្រោះបន្ទាំពីនេះទៅ ទ្រង់មិនមានអាហារ មិនអាច ទ្រទ្រង់ព្រះជន្មបានឡើយ ម្យ៉ាងទៀត កូនរបស់អញទាំង ២ នេះ ក៏ទៅតាម ទីនេះ ។ ថ្ងៃនេះ កូនអញទាំង ២ គួរបានថ្វាយបិណ្ឌបាតដល់ព្រះពុទ្ធទាំងឡាយ ដូច្នេះហើយ ទើបបានធ្វើគោដែលទឹមដោយរទេះទាំង ៥០០ ឈប់មិនធ្វើ ដំណើរទៅ ។ ពួកគេពោលថា នេះអ្វីហ្ន៎ នេះអ្វីហ្ន៎ ទើបនាំគ្នាពិនិត្យមើល និមិត្តផ្សេងៗ ។ ពេលនោះ ទេវតានោះដឹងថា ជនទាំង ២ លំបាក ទើបចូល សណ្ឋិតក្នុងរាងកាយរបស់បុរសម្នាក់ ហើយពោលថា ព្រោះហេតុអ្វី ទើបពួក អ្នកត្រូវលំបាក មិនមានយក្ខដទៃបៀតបៀន មិនមានខ្មោចបិសាចបៀតបៀន មិនមាននាគបៀតបៀនពួកអ្នកទេ តែខ្ញុំជាមាតារបស់ពួកអ្នកក្នុងអត្តភាពទី ៥ កើតជាភុម្មទេវតានៅក្នុងទីនេះ នុ៎ះហ្ន៎ ព្រះទសពលប្រថាប់គង់ត្រង់គល់កែស ពួកអ្នកចូរថ្វាយបិណ្ឌបាតដំបូងដល់ទ្រង់ចុះ ដូច្នេះ ។ ជនទាំង ២ ស្តាប់ពាក្យ របស់នាងហើយ មានចិត្តត្រេកអរ យកសដូវផង់ និងសដូវដុំ ដាក់ថាស មាសនាំទៅកាន់សម្នាក់របស់ព្រះសាស្តា ក្រាបទូលថា សូមទ្រង់ទទួល ភាជនៈនេះចុះ ព្រះសាស្តា ទ្រង់ប្រមើលមើលអាចិណ្ណបដិបត្តិរបស់ព្រះពុទ្ធ ទាំងឡាយ ក្នុងអតីតហើយ ។ លំដាប់នោះ មហារាជទាំង ៤ បង្អោនបាត្រ ៤ ដែលធ្វើដោយថ្មដល់ទ្រង់ ។ ព្រះសាស្តាត្រាស់ថា ចូរផលច្រើនសម្រេច ដល់អ្នកទាំង ២ ចុះ ហើយទ្រង់អធិដ្ឋានបាត្រទាំង ៤ ឲ្យជាបាត្រ ១ ប៉ុណ្ណោះ ។ ក្នុងគ្រានោះ ទើបឈ្មួញទាំង ២ នោះ កាន់យកសដូវផង់ និង សដូវដុំដាក់ក្នុងបាត្រ ព្រះតថាគត ក្នុងកាលដែលទ្រង់សោយស្រេចហើយ

ថ្វាយទឹក ក្នុងកាលស្រេចភត្តកិច្ចហើយ ថ្វាយបង្គំ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។

សម័យនោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់ជនទាំង ២ ។ ក្នុងវេលាចប់ទេសនា ជនទាំង ២ តាំងនៅក្នុងសរណៈ គឺ **ទ្វេវាចិក** ដែលបន្លឺវាចាដល់ព្រះពុទ្ធ និងព្រះធម៌ទាំង ២ ប៉ុណ្ណោះ ថ្វាយបង្គំព្រះសាស្តាហើយ មានបំណងនឹងទៅកាន់នគររបស់ខ្លួន ទើបក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រទានចេតិយសម្រាប់បូជាដល់ខ្ញុំព្រះអង្គចុះ ។ ព្រះសាស្តាទ្រង់យកព្រះហស្តស្តាំស្ទាបព្រះសិរសៈ ហើយប្រទានព្រះកេសធាតុ ៨ សរសៃដល់ជនទាំង ២ ជនទាំង ២ នោះ ដាក់ព្រះកេសធាតុទុកក្នុងប្រអប់មាស នាំទៅកាន់នគររបស់ខ្លួន ឲ្យបញ្ចុះព្រះកេសធាតុរបស់ព្រះពុទ្ធ ទាំងដែលទ្រង់មានព្រះជន្មទុកត្រង់ទ្វារអសិតញ្ជននគរ ក្នុងថ្ងៃឧបោសថក៏មានរស្មីពណ៌ខៀវផ្សាយចេញអំពីព្រះចេតិយ ។ រឿងនេះកើតឡើងដោយទំនងនេះ ក្នុងកាលបន្ទាប់មក ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពន កាលទ្រង់ស្ថាបនាឧបាសកទាំងឡាយ ទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាជនទាំង ២ នេះទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងឧបាសកទាំងឡាយ ដែលដល់សរណៈមុន ។

## អដ្ឋកថាសូត្រទី ១ ចប់

# អដ្ឋកថា សូត្រទី ២
# ប្រវត្តិ សុទត្ត អនាថបិណ្ឌិកគហបតី

*ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **ឆាយការបំ** *លោកសម្ដែងថា អនាថបិណ្ឌិកគហបតី ឈ្មោះសុទត្តៈ ជាកំពូលជាងពួកឧបាសក ដែលត្រេកអរក្នុងទាន ។*

*បានឮថា កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ គហបតីនោះ កើតនៅក្នុងត្រកូលមួយ នាក្រុងហង្សវតី ស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសកម្នាក់ ក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសកផ្នែកខាងថ្វាយទាន ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ គាត់អន្ទោលទៅក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ មកកើតក្នុងផ្ទះរបស់សុមនសេដ្ឋី ក្រុងសាវត្ថី ។ ជនទាំងឡាយ ដាក់ឈ្មោះឲ្យថា សុទត្តៈ បន្ទាប់មក គាត់តាំងនៅក្នុងយាវាសវិស័យ ជាអ្នកឲ្យទាន ជាទានបតី ទើបមានឈ្មោះថា អនាថបិណ្ឌិក គឺជាឈ្មោះដែលគាត់បានប្រាថ្នា ព្រោះគុណនោះឯង ។ គាត់មានរទេះ ៥០០ ផ្ទុកទំនិញទៅកាន់ផ្ទះរបស់សេដ្ឋីដែលជាសម្លាញ់របស់ខ្លួន ក្នុងក្រុងរាជគ្រឹះ ។ បានដំណឹងថា ព្រះមានព្រះភាគកើតឡើងហើយក្នុងទីនោះ ក្នុងវេលាទៀបភ្លឺចូលទៅគាល់ព្រះសាស្ដាតាមផ្លូវដែលបើក ដោយអំណាចរបស់ទេវតា ស្ដាប់ធម៌ហើយ តាំងនៅក្នុងសោតាបត្តិផល ក្នុងថ្ងៃទី ២ ថ្វាយមហាទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន កាន់យកបដិញ្ញារបស់ព្រះសាស្ដា ដើម្បីយាងមកកាន់ក្រុងសាវត្ថីក្នុងផ្លូវ ៤៥ យោជន៍ ក្នុងរវាងផ្លូវ បានឲ្យទានទ្រព្យរាប់*

សែន សាងវិហារក្នុងរាល់មួយយោជន៍ ក្រាលវត្តជេតពនដោយកម្រាលមានតម្លៃរាប់កោដិ ទិញដីដោយទ្រព្យ ១៨ កោដិ សាងវិហារដោយទ្រព្យ ១៨ កោដិ លុះវិហារស្រេចហើយ ឲ្យទានតាមដែលត្រូវការដល់បរិស័ទ ៤ ក្នុងវេលាមុនអាហារ និងក្រោយអាហារ ធ្វើការឆ្លងវិហារ ដោយទ្រព្យ ១៨ កោដិ ។ ការឆ្លងវិហារស្រេចបាច់អស់កាល ៩ ខែ ។ អាចារ្យពួកខ្លះពោលថា អស់កាល ៥ ខែ ។ តែការឈ្លោះគ្នានៃអាចារ្យទាំងពួងនោះមិនមាន ។ គាត់លះទ្រព្យ ៥៤ កោដិ ដោយអាការយ៉ាងនេះ ធ្វើទានបែបនេះឲ្យប្រព្រឹត្តទៅក្នុងផ្ទះរបស់ខ្លួនអស់កាលជានិច្ច ។ រាល់ៗ ថ្ងៃ មានសលាកភត្ត ៥០០ សម្រាប់ មានបក្ខិកភត្ត ៥០០ សម្រាប់ មានសលាកយាគូ ៥០០ សម្រាប់ មានបក្ខិយាគូ ៥០០ សម្រាប់ មានធុវភត្ត ៥០០ សម្រាប់ មានសលាកភត្តសម្រាប់ភិក្ខុអាគន្តុកៈ ៥០០ សម្រាប់ មានភត្តសម្រាប់ភិក្ខុដែលត្រៀមធ្វើដំណើរ ៥០០ សម្រាប់ មានភត្តសម្រាប់ភិក្ខុឈឺ ៥០០ សម្រាប់ មានភត្តសម្រាប់អ្នកមើលថែភិក្ខុឈឺ ៥០០ សម្រាប់ មានអាសនៈ ៥០០ សម្រាប់ ក្រាលទុកជាប្រចាំក្នុងផ្ទះនោះឯង ។ កាលបើដូច្នោះ ក្នុងកាលបន្ទាប់មក ព្រះសាស្តាគង់ប្រថាប់ក្នុងវត្តជេតពន កាលទ្រង់ស្ថាបនាឧបាសកទាំងឡាយ ក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាលោក ក្នុងតំណែងឯតទគ្គៈជាកំពូលជាងឧបាសកទាំងឡាយ ខាងថ្វាយទាននោះឯង ។

**អដ្ឋកថាសូត្រទី ២ ចប់**

# អដ្ឋកថា សូត្រទី ៣

# ប្រវត្តិ ចិត្តគហបតី

ក្នុងសូត្រទី ៣ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ធម្មកថិកានំ** លោកសម្តែងថា ចិត្តគហបតីជាកំពូលជាងពួកឧបាសកដែលជាធម្មកថិក ។

បានឮថា កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ គាត់កើតឡើងក្នុងត្រកូលមួយ នាក្រុងហង្សវតី បន្ទាប់មក បានស្តាប់ធម្មកថា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងឧបាសកដែលជាធម្មកថិក ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ គាត់អន្ទោលទៅក្នុងទេវតា និងមនុស្សអស់សែនកប្ប កាលព្រះពុទ្ធព្រះនាមកស្សបៈ គាត់កើតឡើងក្នុងផ្ទះនៃព្រានម្រឹគ បន្ទាប់មក ក្នុងកាលដែលគាត់អាចធ្វើការងារក្នុងព្រៃបាន ថ្ងៃមួយ កាលភ្លៀងធ្លាក់ កាន់យកលំពែងទៅដើម្បីសម្លាប់ម្រឹគ ចូលទៅព្រៃ លំពុងគយគន់រកម្រឹគ ឃើញភិក្ខុមួយរូបដណ្តប់សំពត់បង្សុកូលទទូសីសៈ អង្គុយលើផ្ទាំងថ្ម ត្រង់ញកភ្នំដែលកើតឯងមួយកន្លែង កើតសញ្ញាឡើងថា លោកម្ចាស់អង្គនេះ គង់ធ្វើសមណធម៌មួយព្រះអង្គឯង ដូច្នេះ ប្រញាប់ទៅផ្ទះ ឲ្យអាំងសាច់ដែលបានមកអំពីម្សិលមិល ទុកលើចង្ក្រានមួយ ដាំបាយត្រង់ចង្ក្រានមួយ ឃើញភិក្ខុ ២ រូបត្រាច់បិណ្ឌបាត ទើបទទួលបាត្ររបស់លោក និមន្តឲ្យគង់លើអាសនៈដែលរៀបចំទុក ឲ្យទទួលអាហារហើយ ប្រាប់អ្នកដទៃថា ពួកអ្នកចូរអង្គាសលោកម្ចាស់ ខ្លួនគាត់ដាក់បាយក្នុងថ្នាំង យកស្លឹកឈើគ្របមាត់ថ្នាំង ដើរទៅតាមផ្លូវ ក៏បេះផ្កាច្រើនប្រភេទដល់ទីដែលព្រះថេរៈគង់ លើកថ្នាំងទុកក្នុងទីសមគួរ នាចំណែកម្ខាង ហើយពោល

ថា សូមលោកម្ចាស់សង្គ្រោះខ្ញុំផងចុះ ទទួលបាត្រព្រះថេរៈមកហើយ ដាក់បាយរហូតពេញ ហើយទុកក្នុងដៃព្រះថេរៈ បូជាព្រះថេរៈដោយផ្កាដែលចម្រុះពណ៌ទាំងនោះ ឈរក្នុងទីសមគួរ នាចំណែកម្ខាងពោលថា ក្នុងទីដែលខ្ញុំកើតហើយ សូមបណ្ណាការ ១០០០ មកដល់ខ្ញុំ សូមភ្លៀងផ្កា ៥ ពណ៌ធ្លាក់ចុះមក ដូចការបូជាដោយផ្កា មួយអន្លើនឹងបិណ្ឌបាតមានរសឆ្ងាញ់ ធ្វើចិត្តឲ្យត្រេកអរ ដូច្នោះ ព្រះថេរៈឃើញឧបនិស្ស័យរបស់គាត់ហើយ ឲ្យកម្មដ្ឋានមានអាការ ៣២ ជាអារម្មណ៍ ។ គាត់ធ្វើកុសលដរាបដល់អស់ជីវិត កើតក្នុងទេវលោក ។ ក្នុងទីកើត ភ្លៀងផ្កាទិព្វធ្លាក់មកតាមផែនដី ប្រមាណស្មើក្បាលជង្គង់ ទាំងខ្លួនឯងសោត ក៏ប្រកបដោយយសក្រៃលែងជាងទេវតាអន្លើដទៃៗ ។

គាត់អន្ទោលក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ ក៏កើតក្នុងត្រកូលសេដ្ឋី ក្នុងនគរមច្ឆិកាសណ្ឌៈ ដែនមគធៈ កាលគាត់កើត ភ្លៀងផ្កា ៥ ពណ៌ ធ្លាក់ចុះតាមខេត្ត មានប្រមាណត្រឹមក្បាលជង្គង់ពេញព្រះនគរ កាលនោះ មាតាបិតារបស់គាត់គិតថា កូនរបស់អញនាំឈ្មោះខ្លួនឯងមកផង ក្នុងថ្ងៃកើត ពេញនគរ ក៏វិចិត្រដោយផ្កា ៥ ពណ៌ ទើបឲ្យឈ្មោះថា ចិត្តកុមារ ។ បន្ទាប់មក គាត់តាំងនៅក្នុងយាវាសវិស័យ កាលបិតាអនិច្ចកម្មទៅ ក៏បានតំណែងសេដ្ឋីក្នុងនគរនោះ ។ សម័យនោះ ព្រះថេរៈឈ្មោះថា មហានាមក្នុងចំនួនព្រះថេរៈបញ្ចវគ្គិយ ទៅដល់មច្ឆិកាសណ្ឌនគរ ចិត្តគហបតីជ្រះថ្លាក្នុងឥរិយាបថរបស់លោក ទើបទទួលបាត្រ នាំមកកាន់ផ្ទះ

បូជាដោយបិណ្ឌបាត លោកឆាន់ស្រេចហើយ ក៏នាំទៅកាន់សួនឈ្មោះអម្ពាដការាម សាងលំនៅប្រគេនព្រះថេរៈក្នុងទីនោះ កាន់ប្តេជ្ញាដើម្បីលោកទទួលបិណ្ឌបាតក្នុងផ្ទះរបស់ខ្លួនជានិច្ច ។ ព្រះថេរៈឃើញឧបនិស្ស័យរបស់ចិត្តគហបតីនោះ កាលសម្តែងធម៌ ទើបសម្តែងចំពោះសឡាយតនវិភង្គប៉ុណ្ណោះ ។ មិនយូរប៉ុន្មាន ចិត្តគហបតីក៏សម្រេចព្រះអនាគាមិផល ។ ព្រោះខ្លួនមានការពិចារណាឃើញសង្ខារ ដែលទុក្ខគ្របសង្កត់ហើយក្នុងភពមុន ។ ថ្ងៃមួយព្រះឥសិទត្តត្ថេរមកក្នុងទីនោះ កាលឆាន់ស្រេចក្នុងផ្ទះរបស់សេដ្ឋីហើយ ត្រូវព្រះថេរៈមហានាម មិនអាចស្រាយប្រស្នានិមន្តទុក ទើបវិសជ្ជនាបញ្ហាដល់ឧបាសក ។ កាលលោកជ្រាបថា ជាសម្លាញ់កាលនៅជាគ្រហស្ថ គិតថាឥឡូវនេះ មិនគួរនៅក្នុងទីនេះ ទើបចៀសទៅតាមសប្បាយ ។ ស្អែកឡើង ទើបគហបតីអារាធនាព្រះមហាកស្សបត្ថេរ ដែលជាអ្នកចម្រើនដោយវ័យ ដើម្បីធ្វើឥទ្ធិប្បាដិហារ្យ ។ ព្រះថេរៈក៏សម្តែងបាដិហារ្យដែលសម្រេចដោយតេជោសមាបត្តិ គិតថា ឥឡូវនេះ មិនសមគួរនៅក្នុងទីនេះ ហើយចៀសចេញទៅតាមសប្បាយ ។

បន្ទាប់មក អគ្គសាវកទាំង ២ មានភិក្ខុ ១០០០ រូប ជាបរិវារ ទៅកាន់អម្ពាដការាម ។ សេដ្ឋីគហបតីក៏ត្រៀមសក្ការៈយ៉ាងធំ សម្រាប់ព្រះអគ្គសាវកទាំង ២ នោះ ។ ព្រះសុធម្មត្ថេរ កាលបៀតបៀនចិត្តគហបតីនោះ ទើបជេរសេដ្ឋីដោយវាទៈថា នាយនំត្រៀបល្ង ត្រូវសេដ្ឋីនោះបណ្តេញហើយ ទៅកាន់សម្នាក់ព្រះសាស្តា បាននូវឱវាទ តាំងនៅក្នុងឱវាទព្រះទសពល សូម

ខមាទោសចិត្តគហបតីហើយ នៅក្នុងអម្ពាដកការាមនោះឯង ចម្រើនវិបស្សនាហើយ សម្រេចអរហត្ត ។ គ្រានោះ ឧបាសកគិតថា អញមិនជួបព្រះទសពលមកអស់កាលយូរហើយ តែបើអញទៅគាល់ព្រះសាស្តា មិនគួរទៅដៃទទេ ទើបឲ្យវាយស្គរប្រកាសថា ជនពួកណាបំណងនឹងគាល់ព្រះទសពល ជនទាំងនោះ ចូរយករទេះ ៥០០ ផ្ទុកប្រេង ទឹកឃ្មុំ ទឹកអំពៅ មកជាមួយខ្ញុំចុះ មានបរិស័ទ ២០០០ ហោមរោមទៅគាល់ព្រះសាស្តា ។ តាមផ្លូវគ្រប់ៗមួយយោជន៍ ពួកទេវតាក៏នាំគ្នាតាំងគ្រឿងបណ្ណាការ ។ ចិត្តគហបតីនោះ ទៅកាន់សម្នាក់ព្រះសាស្តា ថ្វាយបង្គំព្រះសាស្តាដោយបញ្ចង្គប្រតិស្ឋាន ។ គ្រានោះ ភ្លៀងផ្កា ៥ ពណ៌ ក៏ធ្លាក់ចុះមកអំពីអាកាស ។ ព្រះសាស្តាត្រាស់សឡាយតនវិភង្គប្រោសមនុស្សទាំងនោះ តាមអធ្យាស្រ័យរបស់ចិត្តគហបតី ។ កាលចិត្តគហបតីនោះ ថ្វាយទានដល់ព្រះទសពលត្រឹមកន្លះខែ អង្ករ ប្រេង ទឹកឃ្មុំ ទឹកអំពៅជាដើមដែលនាំមក អំពីផ្ទះរបស់ខ្លួនក៏មិនអស់ ។ គ្រឿងបណ្ណាការដែលអ្នកក្រុងរាជគ្រឹះបញ្ជូនទៅ ក៏នៅគ្រប់គ្រាន់ ។ ចិត្តគហបតីនោះ គាល់ព្រះសាស្តាហើយ កាលនឹងត្រឡប់ទៅនគររបស់ខ្លួន ក៏បានថ្វាយវត្ថុគ្រប់យ៉ាង ដែលនាំមកដោយរទេះទាំងឡាយដល់ភិក្ខុសង្ឃ ។ ពួកទេវតាក៏នាំគ្នាធ្វើរតនៈ ៧ ពេញរទេះដែលទទេ ។ ក្នុងរវាងមហាជនកើតពាក្យពោលឡើងថា ចិត្តគហបតីមានការធ្វើសក្ការៈ និងការរាប់អានពិតហ្ន៎ ព្រះសាស្តាទ្រង់ស្តាប់រឿងនោះ ទើបត្រាស់ព្រះគាថា ក្នុងព្រះធម្មបទ ដូច្នេះថា

**សទ្ធោ សីលេន សម្បន្នោ យសោ ភោគសមប្បិតោ**

**យំ យំ បទេសំ ភជតិ តត្ថ តត្ថេវ បូជិតោ ។**

បុគ្គលអ្នកមានសទ្ធា បរិបូណ៌ដោយសីល ស្គប់ស្គល់ដោយយស និងភោគសម្បត្តិ គប់រកប្រទេសណាៗ គេតែងបូជាក្នុងប្រទេសនោះៗ ។

តាំងអំពីនោះមក ចិត្តគហបតីនោះ មានឧបាសកជាអរិយសាវ័ក ៥០០ នាក់ចោមរោមត្រាច់ទៅ ។ ក្រោយមក ព្រះសាស្តាកាលទ្រង់ស្ថាបនាពួកឧបាសកទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទ្រង់ធ្វើកថាឈ្មោះចិត្តសំយុត្តឲ្យជាអត្ថុប្បត្តិហេតុ រួចហើយ ទើបទ្រង់ស្ថាបនាឧបាសកនោះ ក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសកដែលជាធម្មកថិក ដូច្នេះ ។៚

**អដ្ឋកថា សូត្រទី ៣ ចប់**

# អដ្ឋកថា សូត្រទី ៤

## ប្រវត្តិ ហត្ថកអាឡវកឧបាសក អ្នកក្រុងអាឡវី

ក្នុងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ចតូហិ សង្គហ-វត្ថូហិ** លោកសម្តែងថា ហត្ថកអាឡវកឧបាសក ជាកំពូលជាងពួកឧបាសកដែលសង្គ្រោះបរិស័ទ ដោយសង្គហវត្ថុ ៤ យ៉ាង ។

បានឮថា ហត្ថកអាឡវកឧបាសកនេះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ

គាត់កើតក្នុងត្រកូលមួយ នាក្រុងហង្សវតី បន្ទាប់មក ស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ ដែលប្រកបដោយសង្គហវត្ថុ ៤ ទុកក្នុងតំណែងឯតទគ្គៈ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នានូវតំណែងនោះ ។ គាត់អន្ទោលក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងព្រះរាជនិវេសន៍របស់ព្រះបាទអាឡវកៈ ក្រុងអាឡវី ដែនអាឡវី ស្អែកឡើង ក៏ត្រូវបញ្ជូនខ្លួនទៅឲ្យអាឡវកយក្ខ មួយអន្ទើដោយថាសអាហារ ក្នុងរឿងនោះ មានរឿងពោលតាមលំដាប់ដូច្នេះ

បានឮថា ថ្ងៃមួយ ព្រះបាទអាឡវកៈប្រពាតព្រៃបាញ់សត្វ ទ្រង់ដេញតាមម្រឹគមួយ សម្លាប់បានហើយ កាត់ជា ២ កំណាត់ ចងត្រង់ចុងធ្នូរែកត្រឡប់មក មានព្រះវរកាយហត់នឿយ ព្រោះខ្យល់ និងកម្តៅថ្ងៃ ទើបយាងចូលទៅប្រថាប់គង់ត្រង់គល់ជ្រៃ ដែលមានម្លប់ត្រជាក់ ។ ខណៈនោះ ព្រះរាជាបន្ទោបង់នូវការនឿយលំបាកមួយស្របក់ហើយ យាងចេញមក ទេវតា ( យក្ខ ) ដែលអាស្រ័យនៅត្រង់ដើមជ្រៃ ក៏ចាប់ព្រះហស្ត ព្រមទាំងពោលថា ឈប់ ឈប់ អ្នកត្រូវជាអាហាររបស់ខ្ញុំ ។ ព្រោះត្រូវចាប់យ៉ាងមាំ ព្រះរាជាទ្រង់ក៏មិនឃើញឧបាយដទៃ ទើបត្រាស់ថា ខ្ញុំនឹងបញ្ជូនថាសអាហារ និងមនុស្សម្នាក់ ដល់អ្នករាល់ថ្ងៃ ទ្រង់យាងត្រឡប់ចូលព្រះនគរហើយ ។ តាំងអំពីនោះមក ក៏ទ្រង់បញ្ជូនថាសអាហារ ព្រមដោយមនុស្សម្នាក់អំពីគុក ។ ដោយទំនងនេះឯង កាលមនុស្សក្នុងគុកអស់ហើយ ពួកមនុស្សចាស់ៗ ក៏ត្រូវ

ចាប់បញ្ជូនទៅ ការតក់ស្លុតក៏កើតក្នុងភូមិស្រុក ។ ពួករាជបុរសចាប់បុគ្គល នោះមិនបានហើយ ក៏ផ្តើមចាប់កូនក្មេង ។ តាំងអំពីនោះមក ម្តាយរបស់ក្មេង និងស្រីមានគភ៌ ក្នុងព្រះនគរ ក៏នាំគ្នាទៅកាន់រដ្ឋដទៃ ។

សម័យនោះ ព្រះសាស្តាទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញឧបនិស្ស័យនៃមគ្គផល ៣ របស់អាឡវកកុមារ ទ្រង់ព្រះតម្រិះថា កុមារនេះ ធ្វើសេចក្តីប្រាថ្នាអស់មួយសែនកប្ប ចុតិអំពីទេវលោកហើយ កើតក្នុងព្រះរាជនិវេសន៍របស់ព្រះបាទអាឡវកៈ ព្រះរាជាកាលមិនបានអ្នកដទៃ ក៏ចាប់ព្រះរាជកុមារ មួយអន្លើនឹងថាសអាហារបញ្ជូនទៅក្នុងថ្ងៃស្អែកនេះ ដូច្នេះហើយ ក្នុងវេលាល្ងាច ទើបទ្រង់ក្លែងព្រះអង្គទៅកាន់លំនៅរបស់អាឡវកយក្ខ សុំយក្ខឈ្មោះគន្ទព្វដែលជាអ្នកយាមទ្វារ ដើម្បីចូលទៅកាន់លំនៅយក្ខ ។ គន្ទព្វយក្ខនោះទូលថា បពិត្រព្រះមានព្រះភាគ សូមទ្រង់ចូលទៅចុះ ចំណែកខ្ញុំព្រះអង្គមិនប្រាប់អាឡវកយក្ខ មិនគួរពិត ទើបទៅកាន់សម្នាក់អាឡវកយក្ខដែលទៅកាន់សមាគមយក្ខ ដែលនៅក្នុងហិមវន្តប្រទេស ។ សូម្បីព្រះសាស្តាចូលទៅដល់លំនៅហើយ ក៏ប្រថាប់គង់លើបល្ល័ង្ក គឺទីអង្គុយរបស់អាឡវកយក្ខ ។ សម័យនោះ សាតាគិរយក្ខ និងហេមវតយក្ខ កំពុងទៅកាន់សមាគមយក្ខ រំលងខាងលើលំនៅរបស់អាឡវកយក្ខ កាលមិនទាន់ទៅដល់ក៏គិតថា ហេតុអ្វីហ្ន៎ ឃើញព្រះសាស្តាប្រថាប់គង់ក្នុងភពរបស់អាឡវកយក្ខ ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយ ទើបទៅកាន់សមាគមយក្ខ ប្រកាសសេចក្តីត្រេកអរដល់អាឡវកយក្ខថា សម្លាញ់អាឡវៈ អ្នកមានលាភ

ធំហើយ ដែលព្រះអគ្គបុគ្គលក្នុងលោក ព្រមទាំងទេវលោកប្រថាប់គង់ក្នុងលំនៅរបស់អ្នក ចូរអ្នកទៅស្តាប់ធម៌ក្នុងសម្នាក់ព្រះសាស្តាចុះ ។ អាឡវកយក្ខ ស្តាប់ពាក្យនៃយក្ខទាំង ២ នោះហើយ ក៏គិតថា យក្ខទាំង ២ នេះពោលថា សមណត្រងោលមួយរូបអង់អាច អង្គុយលើបល្ល័ង្ករបស់អញ ក៏មិនពេញចិត្ត ក្រេវក្រោធ ពោលថា ថ្ងៃនេះ ខ្ញុំ និងសមណៈរូបនេះ នឹងត្រូវធ្វើសង្គ្រាមគ្នា ពួកអ្នកចូរជាសម្លាញ់ខ្ញុំក្នុងសង្គ្រាមនោះ ហើយក៏លើកជើងម្ខាងជាន់លើកំពូលភ្នំ ចម្ងាយប្រមាណ ៦០ យោជន៍ ភ្នំនោះក៏បែកជា ២ ផ្នែក បន្ទាប់អំពីនេះ គប្បីពោលរឿងសង្គ្រាមរបស់អាឡវកយក្ខឲ្យពិស្តារ ។

អាឡវកយក្ខសូម្បីច្បាំងជាមួយព្រះតថាគត ដោយអាការផ្សេងៗ មួយយប់ទល់ភ្លឺ ក៏មិនអាចធ្វើអ្វីបាន ទើបចូលទៅរកព្រះសាស្តា សួរប្រស្នា ៨ ព្រះសាស្តាក៏ទ្រង់វិសជ្ជនា ។ ចប់ទេសនា អាឡវកយក្ខតាំងនៅក្នុងសោតាបត្តិផល ។ សប្បុរសបំណាងនឹងពោលដោយពិស្តារ គប្បីមើលក្នុងអដ្ឋកថាអាឡវកសូត្រ ។ ស្អែកឡើង លុះអរុណរះ កាលនាំអាហារទៅ ពួករាជបុរសមិនឃើញកុមារដែលគួរចាប់ពេញព្រះនគរ ទើបក្រាបទូលដល់ព្រះរាជា។ ព្រះរាជាត្រាស់ថា នែបា កុមារមាននៅក្នុងទីមិនគួរបានមិនមែនឬ ពួកគេក្រាបទូលថា យ៉ាងនោះឯងព្រះអង្គ ថ្ងៃនេះ មានរាជឱរសប្រសូតក្នុងរាជត្រកូល ។ ទើបព្រះរាជាត្រាស់ថា ចូរបានាំយកទៅ បើខ្ញុំនៅមានជីវិតនឹងបានកូនទៀត ចូរបញ្ជូនក្មេងនោះទៅ មួយអន្លើដោយថាសអាហារ កាលព្រះទេវីកំពុងទ្រង់ព្រះកន្សែង រាជបុរសទាំងនោះនាំកុមារទៅដល់លំនៅរបស់អាឡវកយក្ខ មួយ

អន្ទើដោយថាសអាហារ ពោលថា សូមមេត្តាទទួលចំណែករបស់អ្នកទៅ ។ អាឡវកយក្ខស្តាប់ពាក្យរបស់បុរសទាំងនោះហើយ ក៏នឹកខ្មាស ព្រោះខ្លួនជាអរិយសាវកហើយ បានត្រឹមតែអង្គុយឈ្ងោកមុខ ។ គ្រានោះ ព្រះសាស្តាត្រាស់នឹងអាឡវកយក្ខថា ម្នាលអាឡវកៈ ឥឡូវនេះ អ្នកមិនមានកិច្ចដែលនឹងត្រូវខ្មាស ចូរបីទារក ហើយដាក់ក្នុងដៃតថាគតចុះ ។ ពួករាជបុរសក៏ដាក់អាឡវកកុមារក្នុងដៃអាឡវកយក្ខៗ ក៏លើកកុមារដាក់ក្នុងព្រះហស្តព្រះទសពល ។ ឯព្រះសាស្តាទ្រង់ទទួលហើយ ក៏ដាក់ក្នុងដៃអាឡវកយក្ខវិញ ។ អាឡវកយក្ខ ក៏លើទារកដាក់ក្នុងដៃរបស់ពួករាជបុរស ។ ព្រោះកុមារនោះចេញអំពីដៃមួយ ទៅកាន់ដៃមួយទៀត ដូចពោលមកនេះ ទើបនាំគ្នាថ្វាយព្រះនាមកុមារនោះថា ហត្ថកអាឡវកៈ ។ គ្រានោះ រាជបុរសទាំងនោះសប្បាយចិត្ត នាំព្រះកុមារនោះទៅកាន់សម្នាក់ព្រះរាជាៗ ទតឃើញព្រះកុមារនោះ ទ្រង់យល់ក្នុងព្រះហឫទ័យថា ថ្ងៃនេះ អាឡវកយក្ខ មិនទទួលថាសអាហារ ទើបត្រាស់សួរថា ហេតុអ្វី ទើបពួកអ្នកនាំគ្នាមកយ៉ាងនេះ ។ ពួករាជបុរសក្រាបទូលថា បពិត្រទេវៈ ការត្រេកអរ និងការចម្រើន មានដល់រាជត្រកូលហើយ ព្រះសាស្តាប្រថាប់គង់ក្នុងភពរបស់អាឡវកយក្ខ ទ្រង់ទូន្មានអាឡវកយក្ខឲ្យតាំងនៅក្នុងភាវៈជាឧបាសក ទ្រង់ប្រោសឲ្យអាឡវកយក្ខ ឲ្យព្រះកុមារដល់ពួកទូលបង្គំ ។ ព្រះសាស្តា ទ្រង់ក៏ឲ្យអាឡវកយក្ខកាន់បាត្រចីវរ ទ្រង់បែរព្រះភក្ត្រមកកាន់នគរអាឡវី ។ អាឡវកយក្ខនោះ កាលចូលកាន់ព្រះនគរ ក៏នឹកខ្មាស គិតនឹងត្រឡប់ ។ ព្រះសាស្តាទ្រង់ទតហើយ ត្រាស់

សួរថា ម្នាលអាឡវកយក្ខ អ្នកខ្លាចឬ ។ អាឡវកយក្ខទូលថា បពិត្រព្រះមានព្រះភាគ អ្នកនគរអាស្រ័យខ្ញុំព្រះអង្គ ម៉ែ កូនក្តី ប្រពន្ធក្តី នាំគ្នាស្លាប់អស់ ពួកគេឃើញខ្ញុំព្រះអង្គហើយ នឹងប្រហារដោយអង្កត់ឧសខ្លះ ដុំដីខ្លះ ធ្នូខ្លះ ព្រោះហេតុនោះ ទើបខ្ញុំព្រះអង្គត្រឡប់ក្រោយ ។ ព្រះសាស្តាត្រាស់លួងលោមថា ម្នាលអាឡវកៈ មិនមានទេ បើអ្នកទៅជាមួយតថាគតក៏នឹងអស់ភ័យ មក ទៅទាំងអស់គ្នា ប្រថាប់ឈរត្រង់ដងព្រៃមិនឆ្ងាយអំពីព្រះនគរ ។ ព្រះបាទអាឡវកៈ ទ្រង់នាំអ្នកនគរចេញទៅទទួលព្រះសាស្តា ។ ព្រះសាស្តាក៏ទ្រង់សម្តែងធម៌ប្រោសបរិស័ទដែលមកដល់ ។ ចប់ទេសនា ពួកសត្វ ៨ ម៉ឺន ៤ ពាន់ ក៏នាំគ្នាផឹកអមតៈ ។ អ្នកអាឡវីទាំងនោះ នាំគ្នាទៅកាន់លំនៅរបស់អាឡវកយក្ខ ក្នុងដងព្រៃនោះឯង រៀបចំពលិកម្មរាល់ឆ្នាំ សូម្បីអាឡវកយក្ខ ក៏សង្គ្រោះអ្នកស្រុកដោយការរក្សាប្រកបដោយធម៌ ។

អាឡវកកុមារនោះចម្រើនវ័យហើយ ស្តាប់ព្រះធម្មទេសនារបស់ព្រះមុនីហើយ ក៏ចាក់ធ្លុះមគ្គ និងផល ៣ មានឧបាសកជាអរិយសាវក ៥០០ នាក់ ចោមរោមត្រាច់ទៅគ្រប់វេលា ។ ថ្ងៃមួយ គាត់ចូលទៅគាល់ព្រះសាស្តាមួយអន្លើដោយឧបាសក ៥០០ នាក់ ថ្វាយបង្គំហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្តាទតឃើញឧបាសកមានវិន័យល្អ ទើបត្រាស់សួរថា អាឡវកៈ អ្នកមានបរិស័ទច្រើន អ្នកសង្គ្រោះបរិស័ទដូចម្តេច ។ ឧបាសកក្រាបទូលថា បពិត្រព្រះមានព្រះភាគ បើគេត្រេកអរដោយការឲ្យ ខ្ញុំព្រះអង្គក៏សង្គ្រោះដោយទាន បើគេត្រេកអរដោយការពោលវាចាគួរស្រឡាញ់

*ខ្ញុំព្រះអង្គក៏សង្គ្រោះដោយបិយវាចា បើគេត្រេកអរឲ្យជួយធ្វើកិច្ចដែលកើតឡើងឲ្យសម្រេច ខ្ញុំព្រះអង្គក៏សង្គ្រោះដោយការជួយធ្វើកិច្ចដែលកើតឡើងឲ្យស្រេចទៅ បើគេត្រេកអរដោយការដាក់ខ្លួនស្មើគ្នា ខ្ញុំព្រះអង្គក៏សង្គ្រោះដោយការដាក់ខ្លួនស្មើគ្នា ។ រឿងដែលកើតឡើងយ៉ាងនេះ ។ បន្ទាប់មក ព្រះសាស្តាប្រថាប់ក្នុងវត្តជេតពន កាលតែងតាំងទុកនូវពួកឧបាសកទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាហត្ថកអាឡវកឧបាសក ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសកដែលសង្គ្រោះបរិស័ទ ដោយសង្គហវត្ថុ ៤ ។*

**អដ្ឋកថា សូត្រទី ៤ ចប់**

## អដ្ឋកថា សូត្រទី ៥
## ប្រវត្តិ ព្រះបាទមហានាមសក្យៈ

*ក្នុងសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **បណីតទាយិកានំ** *លោកសម្តែងថា ព្រះបាទមហានាមសក្យៈ ជាកំពូលជាងពួកឧបាសក ដែលថ្វាយទានមានរសប្រណីត ។*

*បានឮថា ព្រះបាទមហានាមសក្យៈនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ លោកកើតក្នុងត្រកូលមួយ ក្នុងក្រុងហង្សវតី កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ*

ជាកំពូលជាងពួកឧបាសក ដែលថ្វាយទានមានរសប្រណីត ។ ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ លោកអន្ទោលក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងរាជត្រកូល ស្តេចសក្យៈក្រុងកបិលពស្តុ ។ ចម្រើនវ័យហើយ តាំងនៅក្នុងសោតាបត្តិផល ដោយការគាល់ព្រះទសពលលើកទី ១ ប៉ុណ្ណោះ ។ សម័យមួយ ព្រះសាស្តាទ្រង់ចាំវស្សាក្នុងស្រុកវេរញ្ជាហើយ ចូលទៅក្រុងកបិលពស្តុដោយលំដាប់ ប្រថាប់ក្នុងនិគ្រោធារាម ស្តេចមហានាមទ្រង់ជ្រាបថា ព្រះសាស្តាយាងមក ទើបចូលទៅគាល់ ថ្វាយបង្គំហើយ ប្រថាប់គង់ក្នុងទីសមគួរ នាចំណែកម្ខាងក្រាបទូលព្រះសាស្តាយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំព្រះអង្គបានឮមកថា ភិក្ខុសង្ឃលំបាកដោយការត្រាច់បិណ្ឌបាត ក្នុងស្រុកវេរញ្ជា សូមទ្រង់ប្រទានបដ្ឋាឲ្យខ្ញុំព្រះអង្គទំនុកបម្រុងភិក្ខុសង្ឃអស់កាល ៤ ខែចុះ ខ្ញុំព្រះអង្គនឹងដាក់ឱជៈចូលទៅក្នុងសរីរៈរបស់ភិក្ខុសង្ឃ ។ ព្រះសាស្តាទ្រង់ទទួលដោយតុណ្ហីភាព ស្តេចមហានាមទ្រង់ជ្រាបថា ព្រះមានព្រះភាគទ្រង់ទទួលហើយ តាំងអំពីថ្ងៃរះឡើង ក៏ទំនុកបម្រុងភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយភោជនដ៏ប្រណីត និងរបស់មានរសឆ្ងាញ់ ៤ ប្រភេទជាដើម ទទួលបដ្ឋាទំនុកបម្រុង ៤ ខែទៀត ជា ៨ ខែ ហើយទទួលបដ្ឋាទំនុកបម្រុង ៤ ខែទៀត ឈ្មោះថា ទ្រង់ទំនុកបម្រុងពេញមួយឆ្នាំ ។ ព្រះសាស្តាមិនបានប្រទានបដ្ឋា ទទួលអាគន្តុកនាច្រើនជាងនោះ ។ ឯស្តេចមហានាមក៏ទ្រង់ធ្វើសក្ការៈដល់ភិក្ខុសង្ឃ ដែលមកដល់បន្ទាប់ៗ ដោយទំនងនេះឯង ។ ព្រះគុណទាំង

នោះរបស់ព្រះបាទមហានាម ក៏ខ្ចរខ្ចាយទៅពេញជម្ពូទ្វីប ។ រឿងកើតឡើងយ៉ាងនេះឯង ។ តមក ព្រះសាស្ដាប្រថាប់គង់ក្នុងវត្តជេតពនមហាវិហារ ទើបទ្រង់ស្ថាបនាព្រះបាទមហានាមសក្យៈ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសកដែលថ្វាយ ទានមានរសប្រណីត ដូច្នេះ ។៚

## អដ្ឋកថា សូត្រទី ៥ ចប់

## អដ្ឋកថា សូត្រទី ៦
## ប្រវត្តិ ឧគ្គគហបតី អ្នកក្រុងវេសាលី

ក្នុងសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **មនាបទាយកានំ** លោកសម្ដែងថា ឧគ្គគហបតីអ្នកក្រុងវេសាលី ជាកំពូលជាងពួកឧបាសកដែលថ្វាយភោជនជាទីគាប់ចិត្ត ។

បានឮថា ឧគ្គគហបតីនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ លោកកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសកម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសកដែលថ្វាយភោជនជាទីគាប់ចិត្ត ធ្វើកុសលឲ្យក្រៃលែងឡើងទៅប្រាថ្នាតំណែងនោះ ។ លោកអន្ទោលក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋី ក្រុងវេសាលី ។ ក្នុងកាល

ដែលគាត់កើតមានឈ្មោះមិនពិតប្រាកដ ។ តែបន្ទាប់មក រាងកាយរបស់គាត់ខ្ពស់ឡើង ស្រស់សង្ហាដូចសសរគោលដែលរចនាហើយ ដូចផ្ទាំងសំពត់ដែលវិចិត្រដោយផ្កាដែលគេលើកឡើង ។ គុណទាំងឡាយរបស់គាត់ក៏ខ្ពស់ខ្ពង់ទៅ ទើបគាត់ឈ្មោះថា ឧគ្គសេដ្ឋី ព្រោះរូបរាង និងគុណទាំង ២ នេះខ្ពស់ខ្ពង់ទៅ ឧគ្គគហបតីនោះតាំងនៅក្នុងសោតាបត្តិផល ដោយការគាល់ព្រះទសពលម្តងប៉ុណ្ណោះ បន្ទាប់មក ធ្វើឲ្យជាក់ច្បាស់នូវមគ្គ និងផល ៣ ។ វេលាដែលគាត់ជរា ទៅកាន់ទីកំបាំង អង្គុយគិតរកវត្ថុណាមួយ ជាទីស្រឡាញ់ ជាទីគាប់ចិត្តរបស់ខ្លួន នឹងថ្វាយវត្ថុនោះឯងដល់ព្រះទសពល អញបានស្តាប់ពាក្យនេះក្នុងទីចំពោះព្រះភក្ត្ររបស់ព្រះសាស្តាថា បុគ្គលឲ្យរបស់ដែលពេញចិត្ត រមែងបានរបស់ដែលពេញចិត្ត ដូច្នេះ ។ កាលនោះ លោកត្រិះរិះយ៉ាងនេះថា ព្រះសាស្តាទ្រង់ជ្រាបចិត្តរបស់អញឬហ្ន៎ គប្បីយាងមកកាន់ទ្វារនិវេសន៍ ។ ព្រះសាស្តាទ្រង់ជ្រាបចិត្តរបស់គាត់ មានភិក្ខុសង្ឃចោមរោម មកប្រាកដត្រង់ទ្វារនិវេសន៍មួយរំពេច ។ លោកជ្រាបថា ព្រះសាស្តាយាងមកហើយ ក៏ត្រេកអរក្រៃលែង ដើរទៅកាន់សម្នាក់ព្រះទសពល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ហើយទទួលបាត្ររបស់ព្រះសាស្តា អារាធនាឲ្យយាងចូលទៅកាន់ផ្ទះ ហើយឲ្យព្រះសាស្តាប្រថាប់គង់លើពុទ្ធាសនៈដែលល្អ ដែលបានរៀបចំហើយ ឲ្យភិក្ខុសង្ឃអង្គុយលើអាសនៈដ៏សេស ហើយអង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ដោយអាហាររសដ៏ប្រសើរផ្សេងៗ លុះស្រេចកត្តកិច្ច អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលយ៉ាងនេះថា បពិត្រព្រះមានព្រះភាគ ខ្ញុំ

ព្រះអង្គបានស្តាប់មកចំពោះព្រះភក្ត្រ ឈ្មោះថា ទទួលមកចំពោះព្រះភក្ត្រព្រះមានព្រះភាគថា បុគ្គលឲ្យរបស់ដែលគាប់ចិត្ត រមែងបានរបស់ដែលគាប់ចិត្ត ដូច្នេះ បពិត្រព្រះអង្គដ៏ចម្រើន វត្ថុណាមួយ ដែលគាប់ចិត្តរបស់ខ្ញុំព្រះអង្គ វត្ថុនោះៗ ខ្ញុំព្រះអង្គថ្វាយដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ធ្វើព្រះសាស្តាឲ្យទ្រង់ជ្រាបហើយ រាប់តាំងអំពីនោះទៅ ក៏ថ្វាយវត្ថុដែលគាប់ចិត្ត ដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ រឿងទាំងអស់ មកក្នុងឧគ្គសូត្រ បញ្ចកនិបាតឯណោះ ។ រឿងនេះកើតឡើងយ៉ាងនេះ ។

បន្ទាប់មក ក្នុងកាលជាក្រោយ ព្រះសាស្តាប្រថាប់នៅនាវត្តជេតពនមហាវិហារ ទើបទ្រង់ស្ថាបនាឧបាសកនោះទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសក ដែលថ្វាយភោជនជាទីគាប់ចិត្ត ដូច្នេះ ។

**អដ្ឋកថា សូត្រទី ៦ ចប់**

# អដ្ឋកថា សូត្រទី ៧

# ប្រវត្តិ ឧគ្គតគហបតី អ្នកហត្ថិគាម

ក្នុងសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **សង្ឃុបដ្ឋាកានំ** លោកសម្តែងថា ឧគ្គតគហបតីអ្នកស្រុកហត្ថិគាម ជាកំពូលជាងពួកឧបាសក ដែលឧបដ្ឋាកភិក្ខុសង្ឃ ។

បានឮថា ឧគ្គគហបតីនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ គាត់កើតក្នុងត្រកូលមួយ ក្នុងក្រុងហង្សវតី បន្ទាប់មក ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសក ដែលជាសង្ឃុបដ្ឋាក ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ លោកវិលវល់ក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតឡើងក្នុងត្រកូលសេដ្ឋីស្រុកហត្ថិគាម ។ ពួកញាតិបានដាក់ឈ្មោះថា ឧគ្គតកុមារ ។ បន្ទាប់មក តាំងនៅក្នុងយាវាសវិស័យ បិតាអនិច្ចកម្មទៅ ក៏បានតំណែងសេដ្ឋី ។ សម័យនោះ ព្រះសាស្តាទ្រង់មានភិក្ខុសង្ឃចោមរោម ទ្រង់ចារិកទៅដល់ស្រុកហត្ថិគាម ប្រថាប់នៅក្នុងឧទ្យាននាគកវ័ន ។ គ្រានោះ ឧគ្គតសេដ្ឋីនេះស្រវឹងស្រាអស់ ៧ ថ្ងៃ ត្រូវពួកអ្នករបាំចោមរោម ទៅកាន់ឧទ្យាននាគកវ័នដើម្បីបម្រើ កាលឃើញព្រះទសពល ក៏កើតហិរិឱត្តប្បៈដ៏មានកម្លាំង ។ កាលចូលគាល់ព្រះសាស្តា ការស្រវឹងស្រាក៏អន្តរធានទៅ ។ គាត់ថ្វាយបង្គំព្រះសាស្តាហើយ អង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ គ្រានោះ ព្រះសាស្តាទ្រង់សម្តែងធម៌ដល់គាត់ ។ ចប់ទេសនាក៏បានសម្រេចមគ្គ និងផល ៣ តាំងអំពីនោះមក គាត់ក៏លះអ្នករបាំ ដោយពោលថា ពួកអ្នកចូរទៅតាមការគាប់ចិត្តចុះ ។ ជាអ្នកត្រេកអរក្រៃពេកក្នុងទាន ថ្វាយទានដល់ភិក្ខុសង្ឃប៉ុណ្ណោះ ។ ទេវតាមករកក្នុងរាត្រី ហើយប្រាប់ដល់សេដ្ឋីថា នែគហបតី ភិក្ខុអង្គនោះមានវិជ្ជា ៣ ភិក្ខុអង្គនោះមានអភិញ្ញា ៦ ភិក្ខុអង្គនោះមានសីល ភិក្ខុអង្គនោះអង្គនោះទ្រុស្តសីល ។ គាត់ស្តាប់ពាក្យនៃ

ទេវតានោះហើយ ក៏ដឹងគុណតាមសេចក្ដីពិតមុននោះឯង ។ តែគាត់នៅតែប្រគេនទេយ្យធម៌ដោយចិត្តស្មើនោះឯង សូម្បីអង្គុយក្នុងសម្នាក់ព្រះសាស្ដាក៏ពោលតែគុណនោះឯង ។ បន្ទាប់មកព្រះសាស្ដាប្រថាប់គង់ក្នុងជេតពនមហាវិហារ ទ្រង់ស្ថាបនាគហបតីនោះ ទុកក្នុងតំណែងឯតទគ្គៈ ជាលំពូលជាងពួកឧបាសក ដែលជាអ្នកឧបដ្ឋាកភិក្ខុសង្ឃ ដូច្នេះ ។

## អដ្ឋកថា សូត្រទី ៧ ចប់

# អដ្ឋកថា សូត្រទី ៨
# ប្រវត្តិ សូរអម្ពដ្ឋឧបាសក

ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អវេច្ចប្បសន្នានំ** លោកសម្ដែងថា បុរពន្ទសេដ្ឋីឧបាសក ជាកំពូលជាងពួកឧបាសកអរិយសាវ័ក ដែលជ្រះថ្លាមិនកម្រើក ។

បានឮមកថា ឧបាសកនេះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ គាត់កើតក្នុងត្រកូលមួយ នាក្រុងហង្សវតី ស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសកម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសកដែលជ្រះថ្លាមិនញាប់ញ័រ ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ គាត់អន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុង

ពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលសេដ្ឋី ពួកញាតិដាក់ឈ្មោះថា បុរពន្ធ ។ បន្ទាប់មក គាត់ចម្រើនវ័យហើយ តាំងនៅក្នុងឃរាវាសវិស័យ ជាឧបដ្ឋាក របស់ពួកតិរ្ថិយ ។

គ្រានោះ ព្រះសាស្តាទ្រង់ប្រមើលមើលលោកក្នុងពេលទៀបភ្លឺ ទ្រង់ឃើញហេតុនៃសោតាបត្តិមគ្គរបស់គាត់ ទើបទៅដល់ទ្វារនិវេសន៍ ក្នុងវេលាបិណ្ឌបាត ។ គាត់ឃើញព្រះទសពល គិតថា ព្រះសមណគោតមទ្រង់កើតក្នុងត្រកូលធំ និងជាបុគ្គលដែលមហាជនស្គាល់យ៉ាងល្អក្នុងលោក ដោយហេតុនោះ ការមិនទៅក្នុងឋានៈរបស់ព្រះគោតមនោះ មិនសមគួរ ។ ទើបគាត់ចូលទៅកាន់សម្នាក់ព្រះសាស្តា ក្រាបត្រង់ព្រះយុគលបាទ ទទួលបាត្រ ហើយអារាធនាឲ្យចូលទៅកាន់ផ្ទះ និមន្តឲ្យប្រថាប់គង់លើបល្ល័ង្កដែលមានតម្លៃច្រើន ថ្វាយភិក្ខា កាលស្រេចភត្តកិច្ច ទើបអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ។ ព្រះសាស្តាទ្រង់សម្តែងធម៌តាមអំណាចចរិយារបស់បុគ្គលនោះ ចប់ទេសនាក៏តាំងនៅក្នុងសោតាបត្តិផល ។ ព្រះសាស្តាទ្រង់ទូន្មានគាត់ហើយ ក៏យាងទៅកាន់វត្តជេតពនមហាវិហារ ។ លំដាប់នោះ មារគិតថា បុរពន្ធនេះជាសម្បត្តិរបស់អញ តែព្រះសាស្តាយាងទៅផ្ទះគេក្នុងថ្ងៃនេះ ទ្រង់បានធ្វើឲ្យមគ្គប្រាកដ ព្រោះស្តាប់ធម៌របស់ព្រះសាស្តាឬហ្ន៎ ដើម្បីឲ្យដឹងថា គេផុតចាកវិស័យរបស់អញ ឬមិនផុត ទើបនិម្មិតរូបដូចព្រះទសពល ទ្រទ្រង់ចីវរផង ទ្រទ្រង់បាត្រផង យាងដោយអាកប្បកិរិយារបស់ព្រះពុទ្ធនោះឯង ទ្រទ្រង់នូវព្រះលក្ខណៈ ៣២ ប្រការ ប្រថាប់ឈរក្បែរទ្វារផ្ទះរបស់បុរពន្ធឧបាសក ។ បុរពន្ធឧបា-

សកព្ទថា ព្រះទសពលត្រឡប់មកទៀត ក៏គិតថា ធម្មតាការយាងទៅបែប មិនពិតប្រាកដរបស់ព្រះពុទ្ធទាំងឡាយ មិនមានឡើយ ហេតុអ្វីហ្ន៎ ទើបទ្រង់យាងមក ដូច្នេះហើយ ទើបចូលទៅកាន់សម្នាក់ព្រះពុទ្ធអង្គ ដោយសម្គាល់ថាជាព្រះទសពល ថ្វាយបង្គំហើយ ឈរក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទ្រង់ធ្វើភត្តកិច្ចស្រេចហើយក្នុងផ្ទះរបស់ខ្ញុំ ព្រះអង្គ ទ្រង់អាស្រ័យហេតុដូចម្តេច ទើបយាងត្រឡប់មកទៀត មារពោលថា ម្នាលបុរពន្ន តថាគតពោលធម៌មិនទាន់ពិចារណា ហើយពោលទៅដោយប្រការមួយមាន ពិតហើយ តថាគតពោលថា បញ្ចក្ខន្ធមិនទៀង ជាទុក្ខ ជាអនត្តាទាំងអស់ តែសេចក្តីពិត មិនមែនទាំងអស់ទេ ព្រោះថា ខន្ធពួកខ្លះដែលទៀង មាំទាំ ស្ថិតស្ថេរមាន ។ ពេលនោះ បុរពន្នឧបាសកគិតថា រឿងនេះជារឿងធ្ងន់ក្រៃលែង ដោយធម្មតា ព្រះពុទ្ធទាំងឡាយត្រាស់ពាក្យបែកជា ២ មិនមាន ។ ទើបពិចារណាថា មារជាសត្រូវរបស់ព្រះទសពល បុគ្គលនេះជាមារពិត ទើបពោលថា អ្នកជាមារឬ ។ វាចាដែលព្រះអរិយសាវកពោល ហាក់ដូចជាយកពូថៅកាប់មារនោះ ។ ព្រោះហេតុនោះ មារមិនអាចតាំងនៅក្នុងភាវៈបាន ទើបពោលថា មែនហើយ បុរពន្ន យើងជាមារ។ ទើបបុរពន្នឧបាសកចន្ទុល ពោលថា មាររាប់រយរាប់ពាន់ ក៏មកធ្វើសទ្ធារបស់ខ្ញុំឲ្យញាប់ញ័រមិនបានដែរ ។ ព្រះទសពលមហាគោតម កាលទ្រង់សម្តែងធម៌ដល់ខ្ញុំ ក៏ទ្រង់សម្តែងធម៌ជាស់ឲ្យភ្ញាក់រឭកថា សង្ខារទាំងពួងមិនទៀង ។ អ្នកកុំឈរក្បែរទ្វារផ្ទះរបស់ខ្ញុំឡើយ មារស្តាប់ពាក្យរបស់បុរពន្នឧបាសកនោះ

ហើយ ក៏ខ្វាតថយក្រោយ មិនអាចចរចាបាន អន្តរធានទៅក្នុងទីនោះឯង ។ បុរពន្ធឧបាសក ពេលល្ងាច ក៏ចូលទៅគាល់ព្រះសាស្តា ក្រាបទូលកិរិយាដែលមារធ្វើហើយ ទូលថា បពិត្រព្រះអង្គដ៏ចម្រើន មារព្យាយាមធ្វើសទ្ធារបស់ខ្ញុំព្រះអង្គឲ្យកម្រើក ។ ព្រះសាស្តាទ្រង់ធ្វើហេតុនោះឯង ឲ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់ស្ថាបនាបុរពន្ធឧបាសកទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសក ដែលជ្រះថ្លាមិនញាប់ញ័រនោះឯង ។៚

## អដ្ឋកថាសូត្រទី ៨ ចប់

# អដ្ឋកថាសូត្រទី ៩
# ប្រវត្តិ ពេទ្យជីវកកោមារភច្ច

ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **បុគ្គលប្បសន្នានំ** លោកសម្តែងថា ពេទ្យជីវកកោមារភច្ច ជាកំពូលជាងពួកឧបាសក ដែលប្រកបដោយសេចក្តីជ្រះថ្លាក្នុងបុគ្គល ។

បានឮថា ទេព្យជីវកនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសកម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសកដែលជ្រះថ្លាក្នុងបុគ្គល ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នានូវ

តំណែងនោះ ។ លោកអន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់ស្ត្រីឈ្មោះសាសវតី[១] អាស្រ័យរូបចិញ្ចឹមជីវិត អាស្រ័យអភយរាជកុមារ ក្នុងក្រុងរាជគ្រឹះ ។ ឈ្មោះថា ស្ត្រីអាស្រ័យរូបចិញ្ចឹមជីវិត ក្នុងកាលប្រសូត បើជាកូនប្រុស ក៏បោះបោល បើជាកូនស្រី ក៏ចិញ្ចឹម ។ ដូច្នោះ ទើបនាងយកចង្អេរដាក់កុមារបោលត្រង់គំនរសំរាម ។ គ្រានោះ អភយរាជកុមារយាងទៅកាន់ទីគាល់ ទតឃើញកុមារនោះ ទើបត្រាស់សួរថា នែអ្នក អ្វីនុ៎ះ ទើបក្អែកចោមរោមខ្សៀវខ្សារ ទ្រង់បានបញ្ជូនរាជបុរសទៅ កាលគេក្រាបទូលថា បពិត្រព្រះអង្គ នុ៎ះជាទារក ព្រះរាជាត្រាស់សួរថា នែអ្នក នៅរស់ឬ ។ ទ្រង់បានឮថា នៅរស់ ទើបឲ្យនាំទៅចិញ្ចឹមក្នុងបុរីរបស់ព្រះអង្គ ។ គេនាំគ្នាថ្វាយព្រះនាមថា ជីវក ។ លុះអាយុបាន ១៦ ឆ្នាំ ក៏ទៅកាន់នគរតក្កសិលា រៀនវិជ្ជាពេទ្យ បានលាភសក្ការៈ អំពីរាជសម្នាក់របស់ព្រះបាទពិម្ពិសារ បានធ្វើព្រះរោគរបស់ព្រះបាទចណ្ឌប្បជ្ជោតឲ្យជាសះស្បើយ ទ្រង់ក៏បញ្ជូនអង្គរ ៥០០ រទេះ កហាបណៈ ១៦០០០ និងគូសំពត់ដែនសិវី ដែលមានតម្លៃកាត់ថ្លៃមិនបានផង សំពត់បរិវារចំនួន ១០០០ ផង ព្រះរាជទានដល់ពេទ្យជីវកនោះ ។ គ្រានោះ ព្រះសាស្តាអាស្រ័យក្រុងរាជគ្រឹះ គង់ប្រថាប់ត្រង់ភ្នំគិជ្ឈកូដ ។ ពេទ្យជីវកប្រកបភេសជ្ជៈ ថ្វាយដល់ការបន្ទោបង់ក្នុងព្រះវរកាយ ដែលមានធាតុសន្សំហើយ ដល់ព្រះសាស្តា គិតថា បច្ច័យ ៤ ចំពោះជារបស់អញមាន

១- ក្នុងទីខ្លះជាសាលវតី ។

ដូច្នេះ ទើបអាពាធនាឲ្យព្រះសាស្តា ប្រថាប់នៅក្នុងវិហាររបស់ខ្លួន ផ្សំថ្នាំថ្វាយ បង្អោនគូសំពត់នោះថ្វាយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ប្រើប្រាស់គូសំពត់នេះ ហើយបានថ្វាយសំពត់ ១០០០ ផ្ទាំង ដែលបានមក មួយអន្លើជាមួយគូសំពត់នោះដល់ព្រះភិក្ខុសង្ឃ ។ នេះជាសេចក្តីសង្ខេប ក្នុងរឿងពេទ្យជីវកកោមារភច្ចនេះ ។ ចំណែកដោយពិស្តារ រឿងពេទ្យជីវកមកហើយ ក្នុងខន្ធកវិន័យ ។ បន្ទាប់មក ព្រះសាស្តាគង់ប្រថាប់នៅក្នុងវត្តជេតពន ទើបទ្រង់ស្ថាបនាពេទ្យជីវកកោមារភច្ចទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសក ដែលជ្រះថ្លាក្នុងបុគ្គល ដូច្នេះ ។l

**អដ្ឋកថា សូត្រទី ៩ ចប់**

# អដ្ឋកថា សូត្រទី ១០
# ប្រវត្តិ នកុលបិតាគហបតី

ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **វិស្សាសិកានំ** លោកសម្តែងថា នកុលបិតាគហបតី ជាកំពូលជាងពួកឧបាសក ដែលពោលពាក្យសម្តែងសេចក្តីស្និទ្ធស្នាល ។

បានឮមកថា គហបតីនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ កើតក្នុងត្រកូល នាក្រុងហង្សវតី កំពុងស្តាប់ព្រះធម្មទេសនារបស់ព្រះសាស្តា ឃើញ

ព្រះសាស្តាទ្រង់ស្ថាបនា ឧបាសកម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាង ពួកឧបាសកដែលស្និទ្ធស្នាល ក៏ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែង នោះ ។ លោកអន្ទោលក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទ កាលនេះ កើតក្នុងត្រកូលសេដ្ឋី ក្នុងនគរសុង្សុមារគិរី ដែនភគ្គៈ ព្រះសាស្តា កាលភិក្ខុសង្ឃហែហមរោមហើយ ទ្រង់ចារិកទៅដល់នគរនោះ ប្រថាប់នៅត្រង់ ភេសកឡាវ័ន ។ គ្រានោះ នកុលបិតាគហបតីនេះ ក៏ទៅគាល់ព្រះសាស្តា មួយអន្លើដោយពួកអ្នកស្រុកសុង្សុមារគិរីនគរ ដោយការគាល់មួងប៉ុណ្ណោះ គាត់ និងភរិយាក៏កើតសេចក្តីសម្គាល់ថា ព្រះទសពលជាកូនរបស់ខ្លួន ទើបក្រាប ចុះត្រង់ព្រះយុគលបាទរបស់ព្រះសាស្តា ក្រាបទូលថា នែកូន អ្នកបោះបង់ ពុក និងម៉ែទៅអស់កាលមានប្រមាណប៉ុណ្ណោះ ត្រាច់ទៅក្នុងទីណា បានឮថា នកុលបិតាគហបតីនោះ ក្នុងជាតិមុនៗ បានជាបិតាព្រះទសពល ៥០០ ជាតិ បានជាឪពុកមា ៥០០ ជាជីតា ៥០០ ជាតិ ជាអ៊ំ ៥០០ ជាតិ ។ នកុល- មាតាក៏បានជាម្តាយ ៥០០ ជាតិ ជាមីង ៥០០ ជាតិ ជាយាយ ៥០០ ជាតិ ជាអ៊ំ ៥០០ ជាតិ ។ ដូច្នោះ ព្រោះមានសេចក្តីស្រឡាញ់ជាប់តាមមកអស់ កាលយូរ លុះឃើញព្រះទសពលសម្គាល់ថាកូន ទើបអត់ធន់មិនបាន ។ ព្រះ សាស្តាទ្រង់មិនបានត្រាស់ថា ចូរចៀសចេញទៅ ដរាបណាចិត្តរបស់ជនទាំង ២ នោះមិនទាន់ជឹងខ្លួន ។ លុះជនទាំង ២ នោះបានសតិតាមធម្មតាហើយ ព្រះសាស្តាទ្រង់ជ្រាបអាសយៈ គឺអធ្យាស្រ័យរបស់ពួកសត្វ ដែលដាក់ចិត្ត ជាកណ្តាល ហើយទ្រង់សម្តែងធម៌ ។ កាលចប់ទេសនា ជនទាំង ២ ក៏តាំង

នៅក្នុងសោតាបត្តិផល ។

បន្ទាប់មក កាលទ្រង់ព្រះជរា ព្រះសាស្តាក៏បានយាងទៅកាន់នគរ ដែនភគ្គៈទៀត ។ ជនទាំង ២ នោះដឹងថា ព្រះសាស្តាយាងមក ក៏ចូលទៅគាល់ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន អារាធនាដើម្បីសោយក្នុងថ្ងៃស្អែក ។ ស្អែកឡើង ក៏អង្គាសភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានដោយភោជនមានរសផ្សេងៗក្នុងនិវេសន៍របស់ខ្លួន ព្រះសាស្តាសោយស្រេច ក៏ចូលទៅក្បែរអង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ កាលអង្គុយស្រេចបាច់ហើយ ទើបនកុលបិតាក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ និងនកុលមាតាគហបតានីរៀបការនឹងគ្នា តាំងអំពីកំលោះក្រមុំ ខ្ញុំព្រះអង្គបានដឹងថា នកុល-មាតាគហបតានីប្រព្រឹត្តក្រៅចិត្ត សូម្បីផ្លូវចិត្តឡើយ ដូច្នោះ នាងនឹងប្រព្រឹត្តក្រៅចិត្តតាមកាយបានអំពីណា ខ្ញុំព្រះអង្គប្រាថ្នាជួបគ្នានិងគ្នា ទាំងក្នុងបច្ចុប្បន្នទាំងក្នុងភពខាងមុខ ។ នកុលមាតាគហបតានីក៏ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ និងនកុលបិតាគហបតីរៀបការនឹងគ្នា តាំងអំពីកំលោះក្រមុំ ខ្ញុំព្រះអង្គមិនបានដឹងថា នកុលបិតាគហបតីប្រព្រឹត្តក្រៅចិត្តសូម្បីផ្លូវចិត្ត ដូច្នោះ គាត់នឹងប្រព្រឹត្តក្រៅចិត្តតាមផ្លូវកាយបានអំពីណា ខ្ញុំព្រះអង្គប្រាថ្នាជួបគ្នានិងគ្នាក្នុងបច្ចុប្បន្នផង ក្នុងចំណែកខាងមុខផង ។ ចំណេរតមក ព្រះសាស្តាគង់ប្រថាប់ក្នុងវត្តជេតពនមហាវិហារ កាលទ្រង់ស្ថាបនាពួកឧបាសកទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទ្រង់ធ្វើរឿងរបស់ជនទាំង ២ ឲ្យ

*ជាអគ្គុប្បត្តិហេតុ ហើយទ្រង់ស្ថាបនានកុលបិតាគហបតី ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងឧបាសកដែលជាសង្គ្រោះ ដូច្នេះ ។*

**អដ្ឋកថា សូត្រទី ១០ ចប់**

**ឯតទគ្គៈបាលិវគ្គទី ៦ ចប់**

# ឯតទគ្គបាលិ

## វគ្គទី ៧

[ ១៥២ ] ម្នាលភិក្ខុទាំងឡាយ បណ្តាពួកឧបាសិកាអ្នកដល់នូវសរណជាបឋម ដែលជាសាវិការបស់តថាគត ស្រេចនឹងនាងសុជាតាសេនានិធីតា ប្រសើរជាងគេ ។ ពួកឧបាសិកាជាទាយិកា ( អ្នកឲ្យទាន ) ស្រេចនឹងនាងវិសាខាមិគារមាតា ។ ពួកឧបាសិកាអ្នកចេះដឹងច្រើន ស្រេចនឹងនាងខុជ្ជុត្តរា។ ពួកឧបាសិកាអ្នកនៅដោយមេត្តា ស្រេចនឹងនាងសាមាវតី។ ពួកឧបាសិកាអ្នកមានឈាន ស្រេចនឹងនាងឧត្តរានន្ទមាតា ។ ពួកឧបាសិកាអ្នកឲ្យទានផ្ចិតផ្ចង់ ស្រេចនឹងនាងសុប្បវាសាកោលិយធីតា ។ ពួកឧបាសិកាអ្នកបម្រើជំងឺ ស្រេចនឹងនាងសុប្បិយាឧបាសិកា ។ ពួកឧបាសិកាអ្នកជ្រះថ្លាមិនកម្រើក ស្រេចនឹងនាងកាតិយានី ។ ពួកឧបាសិកាអ្នកចេះធ្វើឲ្យអ្នកដទៃស្និទ្ធស្នាល ស្រេចនឹងនាងនកុលមាតាគហបតានី ។ ពួកឧបាសិកាអ្នកជ្រះថ្លាតាមពាក្យដែលឮតៗគ្នា ស្រេចនឹងកាលីឧបាសិកាកុររឃរិកា ។

វគ្គទី ៧ ចប់

អដ្ឋានបាលិ

# អដ្ឋកថា សូត្រ ទី ១

# ប្រវត្តិ នាងសុជាតាសេនិយធីតា

[ ១៥២ ] ក្នុងសូត្រទី ១ នៃឧបាសិកាបាលី គប្បីជ្រាបវិនិច្ឆ័យដូច្នេះ បទថា **បឋមំ សរណំ គច្ឆន្តីនំ** សេចក្ដីថា ធីតារបស់សេនិយៈ ឈ្មោះសុជាតា ជាកំពូលជាងពួកឧបាសិកា ដែលតាំងនៅក្នុងសរណៈមុនគេបង្អស់ ។

កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងត្រកូល នាក្រុងហង្សវតី បន្ទាប់មក នាងស្ដាប់ធម្មកថារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកា ដែលដល់សរណៈមុនឧបាសិកាទាំងពួង ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងអន្ទោលក្នុងទេវតា និងមនុស្សអស់សែនកប្ប កើតក្នុងត្រកូលរបស់កុដុម្ពិកៈឈ្មោះសេនិយៈ នាតំបន់ឧរុវេលាសេនានិគម មុនព្រះសាស្ដាកើតឡើង ចម្រើនវ័យហើយ បានធ្វើសេចក្ដីប្រាថ្នាទុកត្រង់គល់ជ្រៃមួយដើមថា បើខ្ញុំមានគ្រួសារនឹងបុគ្គលដែលស្មើគ្នា បានកូនប្រុសក្នុងផ្ទៃដំបូង នឹងធ្វើពលិកម្មប្រចាំឆ្នាំ សេចក្ដីប្រាថ្នារបស់នាង ក៏សម្រេច ។

កាលព្រះមហាសត្វទ្រង់ធ្វើទុក្ករកិរិយាអស់ ៦ ឆ្នាំ ក្នុងថ្ងៃវិសាខបុណ្ណមី នាងគិតថា នឹងធ្វើពលិកម្មអំពីព្រលឹម ទើបភ្ញាក់ឡើងក្នុងពេលទៀបភ្លឺនៃរាត្រី ប្រើឲ្យគេរឹតទឹកដោះគោ ។ ពួកកូនគោក៏មិនទៅកាន់យកកន្សោមដោះរបស់ពួកមេគោ ។ លុះយកភាជនៈថ្មីចូលទៅក្បែរដោះ តំណក់ទឹកដោះក៏ហូរដោយធម្មតាឯង ។ នាងសុជាតាឃើញការអស្ចារ្យនោះ ក៏កាន់យកទឹកដោះដោយដៃឯង ដាក់ភាជនៈថ្មី ចាប់ផ្ដើមចម្អិន ។ កាលមធុបាយាសកំពុងចម្អិន ពពុះ

ធំៗ ក៏ប៉ោងឡើង វិលជុំវិញទៅស្តាំ ។ តំណក់មធុបាយាសបន្តិច ក៏មិនខ្ចាត បេញខាងក្រៅឡើយ ។ មហាព្រហ្មបាំងឆត្រ ស្តេចលោកបាលទាំង ៤ កាន់ព្រះខ័នធ្វើការរក្សា សក្កទេវរាជយកឧសមកដុតភ្លើង ។ ពួកទេវតានាំឱជៈក្នុងទ្វីប ៤ មកដាក់ក្នុងមធុបាយាសនោះ ។ ក្នុងថ្ងៃនោះឯង នាងសុជាតាឃើញហេតុអស្ចារ្យទាំងនេះ ទើបហៅនាងបុណ្ណទាសីមកប្រាប់ថា នែបុណ្ណៈថ្ងៃនេះ ទេវតារបស់ខ្ញុំ គួរជ្រះថ្លាពន់ពេក អស់កាលមានប្រមាណប៉ុណ្ណេះ ខ្ញុំមិនធ្លាប់ឃើញការអស្ចារ្យបែបនេះឡើយ នាងចូរប្រញាប់ទៅបដិបត្តិទេវស្ថាន ។ នាងបុណ្ណទាសីទទួលពាក្យថា សាធុ ខ្មីឃ្មាតប្រញាប់ទៅកាន់គល់ឈើ ។ ឯព្រះពោធិសត្វវេលចាំកាលស្វែងរកអាហារ ក៏យាងទៅប្រថាប់គង់ទាមណ្ឌលដើមឈើអំពីព្រលឹម ។ នាងបុណ្ណៈដើរទៅដើម្បីបោសសម្អាតគល់ឈើ ក៏មកប្រាប់នាងសុជាតាថា ទេវតាប្រថាប់គង់នៅក្រោមដើមឈើហើយ ។ នាងសុជាតាពោលថា អើនាង បើនាងនិយាយពិត នាងមិនចាំបាច់ធ្វើទាសីទៀតឡើយ ហើយប្រដាប់គ្រឿងអលង្ការគ្រប់យ៉ាង រៀបចំមធុបាយាសយ៉ាងល្អដាក់ក្នុងថាសមាស ដែលមានតម្លៃមួយសែន យកថាសមួយទៀតបិទ ហើយខ្ចប់ដោយសំពត់ស សំយុងកម្រងផ្កាទុកជុំវិញ លើកឡើងដើរទៅជួបមហាបុរស ក៏កើតបីតិខ្លាំងក្លា បង្អោនខ្លួនចុះ តាំងអំពីទីដែលឃើញ ដាក់ថាសមាសអំពីក្បាល បើកថាសហើយ ដាក់មធុបាយាស ព្រមទាំងថាសមាសទុកក្នុងព្រះហស្តរបស់ព្រះមហាបុរស ថ្វាយបង្គំហើយ ពោលថា សូមមនោរថរបស់លោកម្ចាស់ សម្រេចដូចមនោរថរបស់ខ្ញុំ ដែលសម្រេចហើយចុះ

ហើយក៏ចៀសចេញទៅ ។ ព្រះពោធិសត្វយាងទៅកាន់ច្រាំងស្ទឹងនេរញ្ជរា ទ្រង់ដាក់ថាសមាសត្រង់មាត់ច្រាំង ទ្រង់ស្រង់ទឹកហើយឡើងមក ទ្រង់ពូតជាពំនូត បាន ៤៩ ដុំ សោយមធុបាយាសហើយ ទ្រង់បណ្តែតថាសមាសក្នុងស្ទឹង ទ្រង់ឡើងកាន់ពោធិមណ្ឌលដ្ឋានតាមលំដាប់ ទ្រង់សម្រេចសព្វញ្ញុតញ្ញាណ ប្រថាប់នៅនាពោធិមណ្ឌលដ្ឋាន កន្លងទៅ ៧ សប្តាហ៍ ទ្រង់ប្រកាសធម្មចក្រដ៏ប្រសើរ ក្នុងព្រៃឥសិបតនមិគទាយវ័ន ទ្រង់ឃើញឧបនិស្ស័យកុមារឈ្មោះយស កូនរបស់នាងសុជាតា ទើបយាងទៅប្រថាប់គង់ត្រង់គល់ឈើមួយដើម យសកុលបុត្រឃើញស្រីបម្រើដេកបើកសរីរៈក្នុងលំដាប់បន្ទាប់អំពីពាក់កណ្តាលរាត្រី កើតសេចក្តីសង្វេគ ពោលថា វឹកវរហ្ន៎ ជាប់ជំពាក់ហ្ន៎ ហើយចេញអំពីនិវេសន៍ ដើរទៅកាន់សម្នាក់ព្រះសាស្តា ក្រៅព្រះនគរ ស្តាប់ធម្មទេសនាហើយ សម្រេចមគ្គផល ៣ ខណៈនោះ ឪពុករបស់គេដើរតាមស្នាមជើងចូលទៅគាល់ព្រះមានព្រះភាគ ទូលសួររឿងរបស់យសកុលបុត្រ ។ ព្រះសាស្តាទ្រង់បិទបាំងយសកុលបុត្រ ទ្រង់សម្តែងធម៌ ។ ចប់ទេសនា គហបតីតាំងនៅក្នុងសោតាបត្តិផល ។ ចំណែកយសសម្រេចអរហត្ត ។ ព្រះមានព្រះភាគត្រាស់នឹងយសថា ចូរជាភិក្ខុចុះ ។ រំពេចនោះឯង យាវាសភេទរបស់គេ ក៏អន្តរធានទៅ ជាអ្នកទ្រទ្រង់បាត្រ និងចីវរដែលសម្រេចដោយឫទ្ធិ ។ មាតារបស់លោកក៏និមន្តព្រះសាស្តា ។ ព្រះសាស្តាទ្រង់មានព្រះយសកុលបុត្រជាបច្ឆាសមណៈ យាងទៅកាន់ផ្ទះរបស់សេដ្ឋីនោះ សោយភត្តាហារស្រេចហើយ ក៏ទ្រង់សម្តែងធម៌ប្រោស ។ ចប់

*ទេសនា នាងសុជាតាដែលជាមាតា និងកិរិយាចាស់របស់ព្រះយស ក៏តាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃនោះ នាងសុជាតា និងកូនប្រសាស្រី តាំងនៅក្នុងតេវាចិកសរណៈ គឺដល់នូវព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ជាគម្រប់ ៣ ជាសរណៈ ។ នេះជាសេចក្តីសង្ខេប ក្នុងរឿងនេះ ។ ឯដោយពិស្តារក្នុងរឿងនេះ មកហើយក្នុងខន្ធកៈ ។ ខាងក្រោយមក ព្រះសាស្តាកាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនាឧបាសិកាទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាដែលដល់សរណៈ ដូច្នេះ ។*

**អដ្ឋកថា សូត្រទី ១ ចប់**

# អដ្ឋកថា សូត្រទី ២
# ប្រវត្តិ នាងវិសាខា មិគារមាតា

*ក្នុងសូត្រទី ២ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **ទាយិកានំ** *លោកសំដែងថា នាងវិសាខាមិគារមាតា ជាកំពូលជាងពួកឧបាសិកាដែលត្រេកអរក្រៃលែងក្នុងការថ្វាយទាន ។*

*បានឮមកថា នាងវិសាខានោះ កាលព្រះពុទ្ធព្រះនាមថាបទុមុត្តរៈ នាងកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី បន្ទាប់មក កំពុងស្តាប់ធម្មទេសនារបស់*

ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ ទុកក្នុងតំណែងជាឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាដែលត្រេកអរក្នុងការថ្វាយទាន ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងអន្ទោលក្នុងទេវតា និងមនុស្សអស់សែនកប្ប កាលព្រះពុទ្ធព្រះនាមកស្សបៈ កើតជាព្រះរាជធីតាពៅនៃព្រះរាជធីតា ៧ អង្គ ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទកិកិ សម័យនោះព្រះរាជធីតាបងប្អូន ៧ អង្គ គឺនាងសមណី សមណគុត្តា ភិក្ខុនី ភិក្ខុទាសិកា ធម្មា សុធម្មា និងព្រះនាងសង្ឃទាសីជាគម្រប់ ៧ ។ ព្រះរាជធីតាទាំងនោះក្នុងឥឡូវនេះ គឺព្រះនាងខេមា ឧប្បលវណ្ណា បដាចារា គោតមី ធម្មទិន្នា មហាមាយា និងនាងវិសាខា ជាគម្រប់ ៧ ។

ព្រះរាជធីតាទាំងនោះ ព្រះនាងសង្ឃទាសីអន្ទោលក្នុងទេវតា និងមនុស្សអស់មួយពុទ្ធន្តរ ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងគភ៌របស់នាងសុមនទេវី ភរិយាធំរបស់ធនញ្ជយសេដ្ឋី កូនរបស់មេណ្ឌកសេដ្ឋី ក្នុងភទ្ទិយនគរ ដែនអង្គៈ មាតាបិតាបានដាក់ឈ្មោះថា វិសាខា ។ លុះនាងបានអាយុ ៧ ឆ្នាំ ព្រះទសពលទ្រង់ឃើញនិស្ស័យសម្បត្តិរបស់សេលព្រាហ្មណ៍ និងពួកសត្វដែលត្រាស់ដឹងដទៃៗ មានភិក្ខុសង្ឃជាបរិវារ ចារិកទៅដល់នគរនោះ ក្នុងដែននោះ ។

ក្នុងសម័យនោះ មេណ្ឌកគហបតី ជាប្រធានរបស់អ្នកមានបុណ្យច្រើន ៥ នាក់ គ្រប់គ្រងតំណែងសេដ្ឋី ។ ពួកអ្នកមានបុណ្យច្រើន ៥ នាក់ គឺមេណ្ឌកសេដ្ឋី ១ ភរិយារបស់គាត់ឈ្មោះចន្ទបទុមា ១ កូនរបស់គាត់ឈ្មោះ

ធនញ្ជ័យ ១ ភរិយារបស់ធនញ្ជ័យឈ្មោះសុមនទេវី ១ ខ្ញុំបម្រើនរបស់មេណ្ឌកសេដ្ឋីឈ្មោះបុណ្ណៈ ១ ។ មិនមែនមេណ្ឌកសេដ្ឋីតែម្នាក់ប៉ុណ្ណោះទេ ក្នុងព្រះរាជាណាចក្ររបស់ព្រះបាទពិម្ពិសារ ក៏មានបុគ្គលដែលមានភោគសម្បត្តិ រាប់មិនអស់ ៥ នាក់ គឺជោតិកៈ ១ ជដិល ១ មេណ្ឌកៈ ១ បុណ្ណៈ ១ កាកពលិយៈ ១ ។ បណ្ដាជនទាំង ៥ នោះ មេណ្ឌកសេដ្ឋីដឹងថា ព្រះទសពលមកដល់នគររបស់ខ្លួន ទើបហៅកុមារីវិសាខាកូនស្រីធនញ្ជយសេដ្ឋី ដែលជាកូនមកហើយ ប្រាប់យ៉ាងនេះថា នែនាង ជាមង្គល ចៅក្ដី តាក្ដី ចូរនាំរទេះ ៥០០ មួយអន្លើដោយក្មេងស្រី ៥០០ បរិវារ ៥០០ ចូរធ្វើការទទួលព្រះទសពល ។ នាងស្ដាប់ពាក្យរបស់ជីតា ក៏បដិបត្តិតាម ។ ព្រោះនាងជាអ្នកឈ្លាសក្នុងហេតុ និងមិនមែនហេតុ នាងក៏ទៅដោយយាន តាមដែលយានអាចទៅបាន ហើយក៏ចុះអំពីយាន ដើរទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ ឈរក្នុងក្នុងទីសមគួរ នាចំណែកម្ខាង ។ គ្រានោះ ព្រះសាស្ដាទ្រង់សម្ដែងធម៌ប្រោស ដោយអំណាចចរិយារបស់នាង ។ ចប់ទេសនា នាងក៏តាំងនៅក្នុងសោតាបត្តិផល មួយអន្លើដោយក្មេងស្រី ៥០០ នាក់ សូម្បីមេណ្ឌកសេដ្ឋីក៏ចូលទៅគាល់ ថ្វាយបង្គំព្រះសាស្ដាហើយ អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្ដា ទ្រង់សម្ដែងធម៌ប្រោសដោយអំណាចចរិយារបស់សេដ្ឋីនោះ ។ ចប់ទេសនា មេណ្ឌកសេដ្ឋីតាំងនៅក្នុងសោតាបត្តិផល អារាធនាព្រះសាស្ដាដើម្បីសោយក្នុងថ្ងៃស្អែក ។ ស្អែកឡើងក៏អង្គាសភិក្ខុសង្ឃ មានព្រះសម្ពុទ្ធជាប្រធាន ដោយអាហារដ៏ប្រណីតក្នុងនិវេសន៍របស់

ខ្លួន ថ្វាយមហាទាន ដោយឧបាយនោះអស់កន្លះខែ ។ ព្រះសាស្តាប្រថាប់នៅក្នុងភទ្ទិយនគរ តាមពុទ្ធអធ្យាស្រ័យហើយ ក៏ចៀសចេញទៅ គប្បីវិសជ្ជនាកថាមគ្គដទៃបន្ទាប់អំពីនេះ ហើយពោលរឿងការកើតរបស់នាងវិសាខា ។

ពិតហើយ ក្នុងក្រុងសាវត្ថី ព្រះបាទកោសលទ្រង់បញ្ជូនសាសន៍ទៅកាន់សម្នាក់របស់ព្រះបាទពិម្ពិសារថា ក្នុងអាណាខេត្តរបស់ទូលបង្គំ ត្រកូលដែលបានភោគសម្បត្តិរាប់មិនអស់មិនមានឡើយ ត្រកូលដែលបានភោគ-សម្បត្តិ រាប់មិនអស់របស់ទ្រង់មាន សូមទ្រង់បញ្ជូនត្រកូល ដែលមានភោគ-សម្បត្តិ រាប់មិនអស់មកឲ្យទូលបង្គំផងចុះ ។ ព្រះរាជាទ្រង់ប្រឹក្សាជាមួយពួកអមាត្យ ។ ពួកអមាត្យប្រឹក្សាថា មិនអាចបញ្ជូនត្រកូលធំៗ ទៅបានទេ តែយើងនឹងបញ្ជូនចំពោះបុត្រសេដ្ឋីម្នាក់ទៅ ទើបសូមធនញ្ជយសេដ្ឋីដែលជាកូនមេណ្ឌកសេដ្ឋី ។ ព្រះរាជាទ្រង់ស្តាប់ពាក្យប្រឹក្សារបស់អមាត្យទាំងនោះ ក៏ទ្រង់បញ្ជូនធនញ្ជយសេដ្ឋីទៅ ។ កាលនោះ ព្រះបាទកោសលព្រះរាជទានតំណែងសេដ្ឋីឲ្យនៅក្នុងនគរសាកេតខាងចុងក្រុងសាវត្ថី ៧ យោជន៍ ។ ក្នុងក្រុងសាវត្ថី កូនរបស់មិគារសេដ្ឋីឈ្មោះបុណ្ណវឌ្ឍនកុមារចម្រើនវ័យហើយ ។ ខណៈនោះ ឪពុករបស់គេដឹងថា កូនរបស់អញធំចម្រើនវ័យហើយ ជាសម័យដែលត្រូវពាក់ព័ន្ធដោយយកវាសវិស័យ ទើបបញ្ជូនមនុស្សទាំង-ឡាយ ដែលឈ្លាសក្នុងហេតុ និងមិនមែនហេតុទៅ ដោយប្រាប់ថា ពួកអ្នកចូរស្វែងរកទារិកាក្នុងត្រកូល ដែលមានជាតិស្មើនឹងយើង មនុស្សទាំងនោះមិនឃើញទារិកាដែលត្រូវចិត្តខ្លួន ក្នុងក្រុងសាវត្ថី នាំគ្នាទៅកាន់នគរសាកេត ។

ថ្ងៃមួយនោះឯង នាងវិសាខា មានស្រី ៥០០ នាក់ មានវ័យស្រករគ្នាចោមរោម នាំគ្នាទៅកាន់បឹងធំមួយ ដើម្បីលេងនក្ខត្តឫក្ស មនុស្សទាំងនោះត្រាច់ទៅខាងក្នុងនគរ ក៏មិនឃើញស្រីដែលត្រូវចិត្តខ្លួន ទើបឈរក្រៅទ្វារក្រុង ខណៈនោះ ភ្លៀងក៏ធ្លាក់ ។ ក្មេងស្រីដែលចេញទៅជាមួយនាងវិសាខា ក៏ប្រញាប់ចូលសាលា ព្រោះខ្លាចសើមដោយភ្លៀង ។ មនុស្សទាំងនោះ មិនឃើញស្រីតាមដែលប្រាថ្នា ក្នុងរវាងក្មេងស្រីទាំងនោះ ។ តែនាងវិសាខានៅខាងក្រោយបង្អស់នៃក្មេងស្រីទាំងនោះ មិនខ្លាចភ្លៀងដែលកំពុងធ្លាក់ សើមហើយចូលទៅកាន់សាលា ព្រោះមិនប្រញាប់ប្រញាល់ ។ មនុស្សទាំងនោះឃើញនាងហើយ គិតថា ស្រីនេះស្អាតក្រៃលែងជាងស្រីដទៃៗ ស្រីរូបនេះជាវត្ថុដែលស្រីពួកខ្លះតាក់តែងដូចជាងធ្វើរថ តាក់តែងរថ ដូច្នោះ ទើបពោលថា យើងនឹងដឹងថា ស្រីនេះនិយាយពីរោះឬទេ ។ ដូច្នោះ ពោលនឹងនាងថា នៃនាង នាងមើលទៅហាក់ដូចជាស្រីដែលមានវ័យចាស់ ដូច្នោះ ។ ទើបនាងសួរថា ពួកលោកឃើញអ្វី ទើបពោល មនុស្សទាំងនោះឆ្លើយថា ស្រីដទៃដែលលេងជាមួយនាង ប្រញាប់ចូលសាលា ព្រោះខ្លាចសើមដោយភ្លៀង ចំណែកនាង ដូចស្រីចាស់ មិនប្រញាប់ប្រញាល់មក មិនខ្លាចសំពត់សើម បើដំរី ឬសេះ ដេញតាមនាងយ៉ាងនេះ នាងធ្វើដូចម្តេច នាងពោលថា ឈ្មោះថា សំពត់ រកបានមិនលំបាក ក្នុងត្រកូលរបស់ខ្ញុំរកបានងាយ ឯស្រីដែលចម្រើនវ័យហើយ ដូចទំនិញដែលគេលក់ បើដៃ ឬជើងបាក់ទៅ មនុស្សទាំងឡាយឃើញស្រីដែលមានសរីរៈខ្វះខាត ក៏រង្កៀស ស្តោះទឹកមាត់ចេញ

ទៅ ព្រោះហេតុនោះ ទើបខ្ញុំដើរសន្សឹមៗ មក ។

មនុស្សទាំងនោះគិតថា ឈ្មោះថា ស្រីក្នុងជម្ពូទ្វីបនេះមិនមាន ដែលអាចប្រៀបស្មើនឹងទារិកានេះ រូបក្តី វាចាក្តី ដឹងហេតុ និងមិនមែនហេតុ ហើយទើបពោល ដូច្នេះហើយ ក៏បោះកម្រងផ្កាទៅលើនាង ។ ខណៈនោះ នាងវិសាខាគិតថា អញមិនធ្លាប់អ្នកណាហួងហែងមកអំពីមុន តែឥឡូវនេះ អញត្រូវគេហួងហែងហើយ ទើបអង្គុយចុះត្រង់ផែនដី ដោយអាការដែលត្រូវគេនាំទៅហើយ គ្រានោះ មនុស្សទាំងឡាយ ទើបនាំវាំងននមកបាំងនាងត្រង់ទីនោះឯង ។ នាងដឹងថា គេបិទបាំង ក៏មានពួកទាសីចោមរោមត្រឡប់ទៅផ្ទះ ។ មនុស្សរបស់មិគារសេដ្ឋីទាំងនោះ ក៏នាំគ្នាទៅកាន់សម្នាក់ធនញ្ជយសេដ្ឋី មួយអន្លើជាមួយនាង កាលសេដ្ឋីសួរថា នែបា ពួកអ្នកជាអ្នកស្រុកណា ក៏ឆ្លើយថា ពួកខ្ញុំជាមនុស្សរបស់មិគារសេដ្ឋី ក្រុងសាវត្ថី បានឮថាក្នុងផ្ទះរបស់លោកមានទារិកាចម្រើនវ័យហើយ ទើបគាត់បញ្ជូនពួកខ្ញុំមក ។ ធនញ្ជយសេដ្ឋីពោលថា ប្រពៃហើយ បា សេដ្ឋីរបស់ពួកអ្នកប្រៀបធៀបជាមួយខ្ញុំមិនបានដោយភោគសម្បត្តិក៏ពិត តែក៏ប្រៀបធៀបគ្នាបានដោយជាតិ ។ ធម្មតាមនុស្សដែលដល់ព្រមដោយអាការគ្រប់យ៉ាងរកបានលំបាក ។ ពួកអ្នកចូរទៅប្រាប់សេដ្ឋីថា ខ្ញុំព្រមទទួល ។ មនុស្សទាំងនោះស្តាប់ពាក្យធនញ្ជយសេដ្ឋីនោះហើយ ក៏វិលទៅកាន់ក្រុងសាវត្ថី ប្រាប់សេចក្តីត្រេកអរ និងសេចក្តីចម្រើនដល់មិគារសេដ្ឋី ហើយពោលថា បពិត្រលោកម្ចាស់ ពួកយើងបានទារិកាក្នុងផ្ទះរបស់ធនញ្ជយសេដ្ឋីហើយ ។ មិគារសេដ្ឋីនោះឮដូច្នោះ ក៏ត្រេក-

អរ ពោលថា ពួកយើងបានទារិកាក្នុងផ្ទះរបស់មហាត្រកូល ទើបបញ្ជូនដំណឹងទៅប្រាប់ធនញ្ជយសេដ្ឋីថា ឥឡូវនេះ យើងនឹងនាំទារិកាមក សូមធ្វើកិច្ចដែលគួរធ្វើមក ធនញ្ជយសេដ្ឋីក៏បញ្ជូនដំណឹងតបទៅមិគារសេដ្ឋីថា រឿងនេះ មិនមែនជាការៈសម្រាប់ខ្ញុំទេ សូមសេដ្ឋីធ្វើកិច្ចដែលគួរធ្វើសម្រាប់ខ្លួនចុះ ។ ទើបមិគារសេដ្ឋីចូលទៅគាល់ព្រះបាទកោសល ក្រាបទូលថា បពិត្រទេវៈ ក្មេងស្រីមានកិរិយាជាមង្គលដល់ខ្ញុំព្រះអង្គមានមួយរូប ក្មេងស្រីនោះឈ្មោះវិសាខា ធីតារបស់ធនញ្ជយសេដ្ឋី ខ្ញុំព្រះអង្គនាំមកឲ្យដល់បុណ្ណវឌ្ឍនកុមារទាសៈរបស់ព្រះអង្គ សូមទ្រង់មេត្តាអនុញ្ញាតឲ្យខ្ញុំព្រះអង្គទៅនគរសាកេតចុះ ។ ព្រះរាជាត្រាស់ថា ល្អណាស់ សេដ្ឋី សូម្បីខ្ញុំ ក៏គួរតែមកដែរមិនមែនឬ ។ សេដ្ឋីក្រាបទូលថា បពិត្រទេវៈ ខ្ញុំព្រះអង្គអាចឲ្យបុគ្គលដូចទ្រង់យាងទៅបានដូចម្តេច ។ ព្រះរាជាមានព្រះបំណងសង្គ្រោះត្រកូលធំ ទ្រង់ទទួលថា ណ្ហើយចុះ លោកសេដ្ឋី ខ្ញុំនឹងមកដែរ ក៏យាងទៅកាន់នគរសាកេតជាមួយនឹងមិគារសេដ្ឋី ។

ធនញ្ជយសេដ្ឋីដឹងថា មិគារសេដ្ឋីនាំព្រះបាទកោសលមកដែរ ទើបចេញទៅទទួល នាំព្រះរាជាទៅកាន់និវេសន៍របស់ខ្លួន ។ រំពេចនោះឯង ក៏រៀបចំលំនៅ និងកម្រងផ្កា គ្រឿងក្រអូបជាដើមសព្វគ្រប់ សម្រាប់ព្រះរាជា សម្រាប់អាហាររបស់ព្រះរាជា សម្រាប់មិគារសេដ្ឋី ដឹងកិច្ចគ្រប់យ៉ាងដោយខ្លួនឯងថា វត្ថុនេះគួរបានដល់បុគ្គលនេះ វត្ថុនេះគួរបានដល់បុគ្គលនេះ ។ ជននោះៗ ក៏គិតថា លោកសេដ្ឋីធ្វើសក្ការៈដល់យើងប៉ុណ្ណោះ ។ ថ្ងៃមួយ ព្រះ

រាជាទ្រង់បញ្ជូនដំណឹងទៅធនញ្ជយសេដ្ឋីថា លោកសេដ្ឋីមិនអាចចិញ្ចឹមពួកយើងបានយូរឡើយ ចូរលោកសេដ្ឋីកំណត់កាលដែលស្រីនេះទៅចុះ ។ ធនញ្ជយ-សេដ្ឋីក៏បញ្ជូនដំណឹងថ្វាយព្រះរាជាថា ឥឡូវនេះ រដូវភ្លៀងមកដល់ហើយ ទាហានរបស់ព្រះអង្គនឹងត្រាច់ទៅអស់ ៤ ខែមិនបាន កិច្ចណាមួយគួរនឹងបាន កិច្ចទាំងអស់នោះ ជាភារៈរបស់ទូលបង្គំ សូមទេវៈមេត្តាយាងទៅក្នុងកាលដែលទូលបង្គំបញ្ជូនធីតាទៅតែម្យ៉ាងចុះ ។ តាំងអំពីនោះមក នគរសាកេត ហាក់ដូចជាតំបន់ដែលមានការរងារនក្ខត្តឫក្សជានិច្ច ។ កន្លងទៅ ៣ ខែដោយអាការយ៉ាងនេះ ។ គ្រឿងប្រដាប់ឈ្មោះមហាលតាបសាធន៍សម្រាប់ធីតារបស់ធនញ្ជយសេដ្ឋី ក៏មិនទាន់សម្រេច ។ គ្រានោះ ពួកភ្នាក់ងារដែលប្រចាំការ ក៏មកប្រាប់ធនញ្ជយសេដ្ឋីថា ឈ្មោះថា វត្ថុដែលមិនមានសម្រាប់ជនទាំងនោះមិនមាន តែឧសសម្រាប់ដាំស្លឲ្យទាហានមិនគ្រប់គ្រាន់ ទើបធនញ្ជយសេដ្ឋីប្រាប់ថា នែបា ទៅរើរោងដំរី រោងសេះយកឈើមកចម្អិនអាហារចុះ ។ គ្រាដាំស្លយ៉ាងនេះអស់កន្លះខែ បន្ទាប់អំពីនោះ ពួកម្ចាស់ភ្នាក់ងារមកប្រាប់ទៀតថា ឧសមិនគ្រប់គ្រាន់ទេ ។ ធនញ្ជយសេដ្ឋីក៏បញ្ជាថា នែបា រដូវនេះរកឧសមិនបានទៀតឡើយ ពួកអ្នកចូរបើកឃ្លាំងសំពត់ យកសំពត់សាច់គ្រោតគ្រាតមករុំជារមូរ ជ្រលក់ក្នុងធុងប្រេង ដុតចម្អិនអាហារចុះ ។ ដាំស្លធ្វើដោយទំនងបែបនេះអស់ ៤ ខែ បន្ទាប់អំពីនោះ ធនញ្ជយសេដ្ឋី ដឹងថា គ្រឿងប្រដាប់មហាលតាបសាធន៍សម្រាប់ធីតាស្រេចហើយ ទើបប្រាប់ថា ស្អែកនេះ ខ្ញុំនឹងបញ្ជូនធីតាទៅ ទើបហៅធីតាចូលមកអង្គុយជិត ឲ្យឱវាទថា

នៃកូន ធម្មតាស្រី នៅក្នុងត្រកូលប្ដី គួរសិក្សាមារយាទយ៉ាងនេះៗ ។ មិគា-
រសេដ្ឋីអង្គុយខាងក្នុងបន្ទប់ ក៏បានឮឱវាទរបស់ធនញ្ជយសេដ្ឋី ។ ធនញ្ជយ-
សេដ្ឋីឲ្យឱវាទយ៉ាងនេះថា នៃកូន ធម្មតាស្រីនៅក្នុងត្រកូលបិតារបស់ស្វាមី
ភ្លើងក្នុងមិនគប្បីនាំចេញ ភ្លើងក្រៅមិនគប្បីនាំចូល គប្បីឲ្យដល់អ្នកដែលឲ្យ
មិនគប្បីឲ្យដល់អ្នកដែលមិនឲ្យ គប្បីឲ្យដល់អ្នកដែលឲ្យផង ដល់អ្នកដែល
មិនឲ្យផង គប្បីអង្គុយជាសុខ គប្បីបរិភោគជាសុខ គប្បីដេកជាសុខ គប្បី
បម្រើភ្លើង គប្បីឱនលំទោន ចំពោះទេវតាខាងក្នុង កាលឲ្យឱវាទ ១០ យ៉ាង
នេះហើយ ស្អែកឡើងក៏ប្រជុំមេកងគ្រប់កង ហើយតែងតាំងកុដុម្ពិកៈ ៨ នាក់
ក្នុងពួកសេនារបស់ព្រះរាជា ជានាយផ្នែកជានា ហើយពោលថា បើការខុស
កើតដល់កូនស្រីរបស់ខ្ញុំ ក្នុងទីដែលទៅហើយសោត ពួកអ្នកគប្បីវិនិច្ឆ័យ
ហើយឲ្យតាក់តែងធីតាដោយគ្រឿងអលង្ការមហាលតាបសាធន៍ មានតម្លៃ ៩
កោដិ ប្រើទ្រព្យ ៥៤ រទេះ ជាមូលតម្លៃ សម្រាប់គ្រឿងលម្អិតក្រអូប
សម្រាប់គ្រឿងផ្សំផ្ងូតទឹក ឲ្យទាសីរូបស្អាត ៥០០ នាក់ រងចាំប្រតិបត្តិ ក្នុង
វេលាដើរផ្លូវដល់ធីតា ។ រថទឹមដោយសេះអាជានេយ្យ ៥០០ គ្រឿងសក្ការៈ
គ្រប់យ៉ាង មួយមុខមួយរយៗ ឲ្យដំណឹងព្រះបាទកោសល និងមិគារសេដ្ឋី
ជ្រាបហើយ វេលាធីតាទៅ ហៅក្មាក់ងារដែលគ្រប់គ្រងក្រោលគោមក ប្រាប់
ថា នៃបា ក្នុងទីដែលកូនស្រីខ្ញុំទៅហើយ ចូរត្រៀមគោដើម្បីកូនស្រីខ្ញុំត្រូវការ
ផឹកទឹកដោះ ឲ្យរៀបចំគោបម្រើ ដើម្បីធីតាខ្ញុំត្រូវការទឹម ព្រោះហេតុនោះ
ពួកអ្នកគប្បីបើកទ្វារក្រោល ក្នុងផ្លូវដែលកូនស្រីខ្ញុំទៅ យកគោបម្រើ ៨

ដែលធាត់ល្អ ជាអ្នកនាំហ្វូងគោ ដល់ញកក្តាំឈ្មោះនោះ មានគោប្រមាណ ៣ គាវុត កាលគោដល់ទីនោះហើយ គប្បីវាយស្គរជាសញ្ញាឲ្យបិទ ។ ជនទាំងនោះទទួលពាក្យរបស់សេដ្ឋីថា សាធុ ហើយបដិបត្តិតាមពាក្យនោះ ។ កាលទ្វារក្រោលបើកហើយ មេគោដែលធាត់ចេញទៅ លុះទ្វារបិទ ពួកគោដែលបន្ទឹកល្អ គោដែលមានកម្លាំង និងគោកាច ក៏លោតផ្លោះចេញទៅខាងក្រៅ ហើយដើរតាមផ្លូវទៅ ព្រោះកម្លាំងបុណ្យរបស់នាងវិសាខា ។

គ្រានោះ វេលាដល់ក្រុងសាវត្ថី នាងវិសាខាគិតថា អញនឹងអង្គុយក្នុងយានដែលបិទបាំងចូលទៅ ឬឈរលើរថចូលទៅល្អហ្ន៎ ខណៈនោះ នាងត្រិះរិះថា កាលអញចូលទៅដោយយានដែលបិទបាំង សេចក្តីវិសេសរបស់គ្រឿងអលង្ការមហាលតាបសាធន៍ ក៏នឹងមិនមានអ្នកដឹងទូទៅ នាងបង្ហាញខ្លួនពេញនគរ ឈរលើរថ ចូលទៅកាន់ព្រះនគរ ។ អ្នកក្រុងសាវត្ថីឃើញសម្បត្តិរបស់នាងវិសាខា ហើយនាំគ្នាពោលថា ឮថា ស្រីនេះឈ្មោះនាងវិសាខា សម្បត្តិបែបនេះ ក៏សមគួរដល់នាងនោះឯង នាងចូលទៅកាន់ផ្ទះមិគារសេដ្ឋីដោយសម្បត្តិធំ ដោយប្រការដូច្នេះ ។ ក្នុងថ្ងៃដែលនាងមកដល់ អ្នកក្រុងទូទៅ ក៏បញ្ជូនគ្រឿងបណ្ណាការតាមកម្លាំងអាចទៅ ដោយពោលថា ធនញ្ជយសេដ្ឋីរបស់យើង បានធ្វើសក្ការៈធំដល់បុគ្គលដែលមកដល់នគររបស់ខ្លួន ។ នាងវិសាខាបញ្ជាឲ្យយកគ្រឿងបណ្ណាការ ធ្វើយតបនឹងអ្នកក្រុងបញ្ជូនទៅ ទូទៅក្នុងត្រកូលគ្នានិងគ្នា ក្នុងនគរនោះឯង ។

សម័យនោះ លំដាប់ដែលជាចំណែកនៃរាត្រី មេសេះដែលធ្លាតមួយ

កើតកូន ទើបនាងប្រើឲ្យពួកទាសីកាន់គប់ភ្លើងទៅទីនោះ ឲ្យផ្ទិតទឹកក្តៅដល់មេសេះ ប្រើប្រេងលាបខ្លួនឲ្យមេសេះ ហើយត្រឡប់ទៅលំនៅរបស់ខ្លួន ។ ចំណែកមិគារសេដ្ឋីធ្វើការចូងអាវាហមង្គលដល់កូនអស់ ៧ ថ្ងៃ មិនដាក់ចិត្តក្នុងព្រះតថាគត សូម្បីប្រថាប់នៅវិហារជិតៗ ថ្ងៃគម្រប់ ៧ អញ្ជើញអ្នកបួសអាក្រាតឲ្យអង្គុយពេញនិវេសន៍ បញ្ជូនដំណឹងប្រាប់នាងវិសាខាថា ធីតារបស់ខ្ញុំចូរមកថ្វាយបង្គំព្រះអរហន្តទាំងឡាយ នាងជាព្រះអរិយសាវិកាថ្នាក់សោតាបន្ន បានស្តាប់ថា ព្រះអរហន្តទាំងឡាយ ដូច្នេះ ក៏មានចិត្តត្រេកអរដើរទៅកាន់ទីអង្គុយរបស់អ្នកបួសអាក្រាតទាំងនោះ សម្លឹងមើលអ្នកបួសអាក្រាតទាំងនោះហើយ គិតថា អ្នកបួសអាក្រាតទាំងនេះ មិនមែនព្រះអរហន្ត ទើបតិះដៀលថា ហេតុអ្វី ទើបលោកឪពុកហៅខ្ញុំមកកាន់សម្នាក់របស់បុគ្គលដែលវៀរចាកហិរិឱត្តប្បៈ ដូច្នេះហើយ ក៏ត្រឡប់ទៅលំនៅរបស់ខ្លួន ។ អ្នកបួសអាក្រាតឃើញនាងហើយ ក៏តិះដៀលសេដ្ឋីរំពេចនោះឯងថា លោកគហបតី លោករកស្រីដទៃមិនបានឬ ហេតុអ្វី ទើបលោកអញ្ជើញស្រីនេះ ដែលជាសាវិការបស់ព្រះសមណគោតម ជាមេកាឡកណ្ណីធំ ឲ្យចូលទៅក្នុងផ្ទះ ចូរប្រញាប់នាំស្រីនោះចេញទៅអំពីផ្ទះនេះ ។ លំដាប់នោះ សេដ្ឋីគិតថា អញមិនអាចបណ្តេញស្រីនេះចេញទៅ អំពីផ្ទះតាមពាក្យរបស់អ្នកបួសអាក្រាតទាំងនេះបានទេ ព្រោះស្រីនេះជាធីតានៃត្រកូលធំ ទើបពោលថា លោកអាចារ្យទាំងឡាយ ឈ្មោះថា ស្រីក្រមុំទាំងឡាយ គប្បីធ្វើទាំងដឹងខ្លះទាំងមិនដឹងខ្លះ សូមពួកលោកស្ងប់ស្ងៀមសិនចុះ ហើយក៏បញ្ជូនអ្នកបួស

អាក្រាតត្រឡប់ទៅ អង្គុយលើសេនាសនៈធំ ដែលនាងវិសាខាកាន់ស្វាបព្រា មាសអង្គាស បរិភោគមធុបាយាសមានទឹកតិច ក្នុងថាសមាស ។

គ្រានោះ ព្រះថេរៈអ្នកសមាទានបិណ្ឌបាតជាវត្ត ត្រាច់ទៅបិណ្ឌបាត មកដល់ទ្វារផ្ទះរបស់សេដ្ឋី ។ នាងវិសាខាឃើញព្រះថេរៈហើយ គិតថា មិន គួរប្រាប់ឪពុកប្តី ដូច្នេះ ទាំងដែលសេដ្ឋីនោះឃើញព្រះថេរៈនោះ ដែលមិន ទាន់ចាកចេញទៅ គង់ឈរនៅយ៉ាងនោះ ។ តែសេដ្ឋីនោះជាបុគ្គលពាល សូម្បីឃើញព្រះថេរៈ ក៏ធ្វើដូចជាមិនឃើញ ឱនមុខបរិភោគមធុបាយាស រឿយៗ ទៅ ។ នាងវិសាខាក៏ដឹងបានថា បិតារបស់ស្វាមីអញឃើញព្រះថេរៈ ក៏មិនធ្វើអាការថាឃើញ ទើបចូលទៅរកព្រះថេរៈ ពោលថា បពិត្រលោក ម្ចាស់ សូមនិមន្តទៅខាងមុខចុះ បិតារបស់ស្វាមីខ្ញុំកំពុងបរិភោគរបស់ចាស់ ។ សេដ្ឋីនោះ កាលនិគ្រន្ថពោលគ្រាមុន ក៏អត់ធន់បាន តែក្នុងខណៈដែលនាង វិសាខាពោលថា បរិភោគរបស់ចាស់ ក៏ដាក់ដៃបញ្ជាថា ពួកឯងចូរនាំបាយាស នេះចេញទៅអំពីទីនេះ ចូរនាំស្រីនេះចេញទៅអំពីផ្ទះនេះ ព្រោះថា ស្រីនេះធ្វើ ឲ្យយើងឈ្មោះថា ជាអ្នកបរិភោគរបស់មិនស្អាត ក្នុងផ្ទះមង្គលបែបនេះ ។ តែ ក្នុងនិវេសន៍នោះឯង ជាទាសៈ និងកម្មករជាដើមទាំងអស់ ជាសម្បត្តិរបស់ នាងវិសាខា មិនមានបុគ្គលណាម្នាក់អាចចាប់ដៃ ឬជើងនាងបាន ដោយហោច សូម្បីតែពោលដោយមាត់ក៏មិនមាន ។ នាងវិសាខាស្តាប់ពាក្យរបស់បិតាក្មេក ហើយ ពោលថា បពិត្រលោកឪពុក ពួកខ្ញុំមិនចេញទៅ ដោយហេតុមាន ប្រមាណប៉ុណ្ណោះទេ ខ្ញុំក៏លោកមិនបាននាំមកអំពីកំពង់ទឹក ដូចពួកកុម្ភទាសី

ធម្មតាពួកធីតាដែលមាតាបិតានៅមានជីវិត រមែងមិនចេញទៅដោយហេតុមានប្រមាណប៉ុណ្ណេះទេ ។ ម្យ៉ាងទៀត ហេតុមានប្រមាណប៉ុណ្ណេះឯង ក្នុងថ្ងៃដែលខ្ញុំមកក្នុងទីនេះ បិតារបស់ខ្ញុំក៏ឲ្យហៅកុដុម្ពិកៈ ៨ នាក់មកប្រាប់ថា បើកំហុសកើតព្រោះកូនស្រីរបស់ខ្ញុំ ពួកអ្នកចូរជួយវិនិច្ឆ័យ ហើយប្រគល់នាងខ្ញុំក្នុងដៃកុដុម្ពិកៈ ៨ នាក់នោះ សូមលោកឪពុកហៅកុដុម្ពិកៈ ៨ នាក់នោះឲ្យវិនិច្ឆ័យកំហុស ឬមិនមែនកំហុសរបស់ខ្ញុំទេ ។ គ្រានោះ សេដ្ឋីគិតថា ស្រីម្នាក់នេះនិយាយល្អ ទើបហៅកុដុម្ពិកៈ ៨ នាក់មកប្រាប់ថា ស្រីនេះហៅខ្ញុំដែលអង្គុយក្នុងផ្ទះមង្គល ក្នុងថ្ងៃគម្រប់ ៧ ថា ជាអ្នកបរិភោគរបស់មិនស្អាត ។ ទើបកុដុម្ពិកៈ ៨ នាក់នោះសួរនាងថា បានឮថា នាងនិយាយយ៉ាងនេះពិតឬ នាងឆ្លើយថា ឪពុកក្មេករបស់នាងខ្ញុំ ត្រូវការបរិភោគរបស់មិនស្អាតឯង តែខ្ញុំមិនបានពោលឲ្យធ្ងើយ៉ាងនោះ ។ ចំណែកកាលព្រះថេរៈដែលបិណ្ឌបាតជាវត្តមួយរូប ឈរជិតទ្វារផ្ទះ ឪពុករបស់ខ្ញុំកំពុងបរិភោគមធុ-បាយាសមានទឹកតិច មិនអើពើក្នុងព្រះថេរៈនោះឡើយ ដោយហេតុនេះ ទើបខ្ញុំពោលពាក្យប៉ុណ្ណេះថា បពិត្រលោកម្ចាស់ សូមនិមន្តទៅខាងមុខចុះ បិតាក្មេករបស់ខ្ញុំ មិនធ្វើបុណ្យក្នុងអត្តភាពនេះ កំពុងបរិភោគរបស់ចាស់ ។ ទើបកុដុម្ពិកៈ ៨ នាក់ពោលថា នាងមិនមានកំហុសក្នុងសេចក្តីនេះ ធីតារបស់យើងពោលមានហេតុ ហេតុអ្វី ទើបលោកក្រោធទៅវិញ ។ សេដ្ឋីពោលថា នែបា កំហុសនោះមិនមាន ក៏ហើទៅចុះ តែក្មេងស្រីនេះ ក្នុងថ្ងៃដែលមក ក៏មិនឲ្យការយកចិត្តទុកដាក់ក្នុងកូនខ្ញុំ បានទៅកាន់ទីដែលខ្លួនឯងប្រាថ្នា ។

កុដុម្ពិកៈ ៨ នាក់សួរថា បានឮថា សេចក្តីនោះពិតឬ ។ នាងឆ្លើយថា ខ្ញុំមិនទៅទីដែលខ្លួនគាប់ចិត្តទេ នៅតែក្នុងផ្ទះមួយនេះ កាលមេសេះដែលឆ្លាតកើតកូន ខ្ញុំគិតថា មិនធ្វើសូម្បីការដាក់ចិត្ត ហើយអង្គុយព្រងើយកន្តើយ មិនសមគួរ ទើបឲ្យពួកទាសីកាន់គប់ភ្លើងចោមរោម ទៅកាន់ទីនោះ ទើបប្រើឲ្យរក្សាមេសេះដែលកើតកូន ។ កុដុម្ពិកៈ ៨ នាក់ពោលថា ធីតារបស់ខ្ញុំបានធ្វើកិច្ចកម្ម ដែលពួកទាសីត្រូវធ្វើក្នុងផ្ទះ លោកឃើញទោសអ្វីក្នុងសេចក្តីនេះ សេដ្ឋីពោលថា នែបា នុ៎ះជាគុណ ក៏ហើទៅចុះ តែឪពុករបស់ក្មេងស្រីនេះ កាលឲ្យឱវាទក្នុងថ្ងៃដែលមកក្នុងទីនេះ ក៏ពោលថា ភ្លើងក្នុងមិនគួរនាំចេញ ។ កុដុម្ពិកៈ ៨ នាក់សួរនាងថា សេចក្តី នោះពិតឬ ។ នាងឆ្លើយថា បិតារបស់ខ្ញុំមិនបានពោលដល់ភ្លើងនោះទេ តែអាថ៌កំបាំងណារបស់ស្រី មានម្តាយក្មេកជាដើមកើតឡើងខាងក្នុងនិវេសន៍ រឿងកំបាំងនោះ មិនគួរប្រាប់ដល់ទាសា និងទាសី ព្រោះថា រឿងបែបនោះ មានតែការរីកសាយចេញទៅជាជម្លោះ ព្រោះហេតុនោះ បិតារបស់ខ្ញុំសំដៅសេចក្តីនេះ ទើបពោល ។ សេដ្ឋីពោលថា សេចក្តីនោះយ៉ាងនោះ ក៏ហើទៅចុះ តែបិតារបស់ក្មេងស្រីនេះពោលថា ភ្លើងក្រៅ មិនគួរនាំចូលទៅខាងក្នុង កាលភ្លើងក្នុងរលត់ទៅហើយ ខ្ញុំមិននាំភ្លើងខាងក្រៅចូលមកបានឬ ។ កុដុម្ពិកៈ ៨ នាក់សួរនាងថា សេចក្តីនោះពិតយ៉ាងនោះឬ ។ នាងឆ្លើយថា ឪពុករបស់ខ្ញុំ មិនបានពោលសំដៅដល់ភ្លើងនោះទេ តែកំហុសឯណា ដែលពួកទាសៈ និងកម្មករនិយាយគ្នា កំហុសនោះ មិនគួរប្រាប់ដល់បុគ្គលដែលជាអ្នកខាងក្នុង ។បេ។ ពាក្យណា

បិតាពោលថា គប្បីឲ្យដល់បុគ្គលដែលឲ្យប៉ុណ្ណោះ ពាក្យនោះ លោកក៏ពោលសំដៅដល់ថា គប្បីឲ្យដល់ពួកអ្នកដែលខ្ចីគ្រឿងឧបករណ៍ ហើយនាំមកសងវិញប៉ុណ្ណោះ ។ ពាក្យថា **យេ ច ទេន្តិ** លោកក៏ពោលសំដៅដល់ថា មិនគប្បីឲ្យដល់ពួកជនដែលខ្ចីគ្រឿងឧបករណ៍ប្រើ ហើយមិននាំមកសងវិញ ។ ឯពាក្យនេះថា **ទទន្តស្សាបិ អទទន្តស្សាបិ ទាតព្វំ** លោកពោលសំដៅដល់កាលញាតិមិត្រធ្លាក់ក្រីក្រមកដល់ហើយ ទោះបីគេអាចតបស្នង ឬមិនអាចតបស្នងក៏ដោយ ក៏គួរឲ្យទាំងអស់ ។ ពាក្យថា **សុខំ និសីទិតព្វំ** លោកពោលសំដៅដល់ បើខ្ញុំឃើញមាតាបិតាក្មេកហើយ មិនគួរអង្គុយព្រងើយ គួរក្រោកឡើង ពាក្យថា **សុខំ ភុញ្ជិតព្វំ** លោកពោលសំដៅដល់ មិនបរិភោគមុនមាតាបិតាក្មេក និងប្ដី គួរអង្គាសលោកទាំងនោះហើយ ដឹងថាលោកបានហើយ ឬមិនទាន់បាន សឹមខ្លួនឯងបរិភោគឯក្រោយ ។ ពាក្យថា **សុខំ និបជ្ជិតព្វំ** លោកសំដៅដល់សេចក្ដីនេះថា មិនគប្បីឡើងលើដំណេកហើយដេកមុនមាតាបិតាក្មេក និងប្ដី ត្រូវធ្វើវត្តបដិបត្តិដែលគួរធ្វើដល់លោកទាំងនោះហើយ ខ្លួនឯង សឹមដេកឯក្រោយ ។ ពាក្យថា **អគ្គិ បរិចរិតព្វោ** លោកពោលសំដៅដល់សេចក្ដីនេះថា គួរឃើញមាតាបិតាផង ស្វាមីផង ដូចជាគំនរភ្លើង និងដូចស្ដេចពស់ ។ សេដ្ឋីពោលថា ជាគុណាប៉ុណ្ណោះក៏ដោយចុះ តែបិតារបស់ក្មេងស្រីនេះ ឲ្យឱនលំទោនទេវតាខាងក្នុង ប្រយោជន៍អ្វីរបស់ឱវាទនេះ ។ កុដុម្ពិកៈ ៨ នាក់សួរនាងថា សេចក្ដីនោះយ៉ាងនោះឬ ។ នាងឆ្លើយថា ពិតហើយ អ្នកទាំងឡាយ ឪពុកខ្ញុំពោលពាក្យនេះ បំណងយ៉ាង

នេះ តាំងអំពីយើងនៅគ្រប់គ្រងផ្ទះតាមបវេណី ឃើញអ្នកបួសមកដល់ទ្វារផ្ទះរបស់ខ្លួនហើយ ប្រគេនរបស់ទំពា របស់បរិភោគ ដែលមាននៅក្នុងផ្ទះដល់ពួកអ្នកបួសហើយ ទើបខ្លួនឯងគួរបរិភោគ ។ គ្រានោះ ទើបកុដុម្ពិកៈទាំងនោះសួរសេដ្ឋីនោះថា លោកមហាសេដ្ឋី លោកឃើញពួកអ្នកបួសហើយមិនពេញចិត្តថា មិនគួរឲ្យឬ ។ លោកសេដ្ឋីសម្ងឹងមិនឃើញពាក្យឆ្លើយដទៃ ទើបអង្គុយឱនមុខ ។

គ្រានោះ ទើបពួកកុដុម្ពិកៈសួរសេដ្ឋីនោះថា កំហុសដទៃរបស់ធីតា ខ្ញុំមានទៀតឬ ។ សេដ្ឋីឆ្លើយថា មិនមានទេបា ។ កុដុម្ពិកៈសួរថា ចុះព្រោះហេតុអ្វី ទើបលោកបណ្តេញធីតា ដែលមិនមានទោសចេញទៅអំពីផ្ទះដោយមិនមែនហេតុ ។ ខណៈនោះ នាងវិសាខាពោលថា មិនគួរទៅតាមពាក្យរបស់បិតាក្មេកខ្ញុំឡើយ តែថ្ងៃដែលខ្ញុំមក ឪពុកខ្ញុំប្រគល់ខ្ញុំទុកក្នុងដៃរបស់ពួកអ្នក ដើម្បីជម្រះទោស ថ្ងៃនេះ ខ្ញុំទៅបានតាមប្រាថ្នាហើយ ទើបប្រាប់ពួកទាសី និងទាសៈ ឲ្យធ្វើការត្រៀមរៀបចំយានជាដើម ។ គ្រានោះសេដ្ឋីនាំកុដុម្ពិកៈទៅ ពោលនឹងនាងថា នែនាង ឪពុកមិនដឹង ទើបពោល ចូរអត់ទោសឲ្យឪពុកចុះ នាងពោលថា បពិត្រលោកឪពុក ខ្ញុំគប្បីអត់ទោសបានតែខ្ញុំជាធីតារបស់សេដ្ឋី ដែលជ្រះថ្លាមិនញាប់ញ័រក្នុងព្រះពុទ្ធសាសនា ខ្ញុំវៀរភិក្ខុសង្ឃមិនបាន បើខ្ញុំបានទំនុកបម្រុងភិក្ខុសង្ឃតាមគាប់ចិត្តរបស់ខ្ញុំ ខ្ញុំនឹងនៅ ។ សេដ្ឋីពោលថា នែនាង ចូរនាងទំនុកបម្រុងពួកសមណៈរបស់នាងតាមគាប់ចិត្ត ដូច្នោះ ទើបនាងវិសាខាឲ្យនិមន្តព្រះទសពល អារាធនាឲ្យភិក្ខុ-

សង្ឃ មានព្រះពុទ្ធជាប្រធាន គង់ពេញនិវេសន៍ក្នុងថ្ងៃស្អែក ។ បរិស័ទរបស់អ្នកបួសអាក្រាតដឹងថា ព្រះសាស្តាស្តេចយាងទៅផ្ទះមិគារសេដ្ឋី ក៏ទៅទីនោះ នាំគ្នាអង្គុយព័ទ្ធផ្ទះ ។ នាងវិសាខាឲ្យទឹកទក្ខិណោទក ហើយបញ្ជូនដំណឹងប្រាប់ថា សក្ការៈគ្រប់យ៉ាងរៀបចំទុកហើយ សូមលោកឪពុកក្មេករបស់ខ្ញុំ អញ្ជើញមកអង្គាសព្រះទសពល ។ សេដ្ឋីនោះស្តាប់ពាក្យរបស់នាងវិសាខាហើយ ក៏ពោលថា ធីតារបស់ខ្ញុំ ចូរអង្គាសព្រះសម្មាសម្ពុទ្ធចុះ ។ នាងវិសាខាកាលអង្គាសព្រះទសពល ដោយកត្តាហារដ៏លើសផ្សេងៗ ហើយកាលស្រេចភត្តកិច្ច ក៏បញ្ជូនដំណឹងទៅថា សូមបិតាក្មេករបស់ខ្ញុំ អញ្ជើញមកស្តាប់ធម្មកថារបស់ព្រះទសពល ។ សម័យនោះ សេដ្ឋីនោះក៏ទៅដើម្បីបំណងនឹងស្តាប់ធម្មកថាថា ឥឡូវនេះ បើការមិនទៅ ជាហេតុមិនសមគួរក្រៃលែង ពួកអ្នកបួសអាក្រាតក៏ពោលថា គាត់ កាលស្តាប់ធម៌របស់សមណគោតម ក៏ចូរអង្គុយស្តាប់ក្រៅវាំងននទៅមុន ហើយក៏នាំគ្នាទៅមុន បាំងវាំងនន ។ មិគារសេដ្ឋីទៅអង្គុយខាងក្រៅវាំងនន ។

ព្រះសាស្តា ទ្រង់ព្រះតម្រិះថា ទោះសេដ្ឋីអង្គុយក្រៅវាំងននក្តី ក្រៅជញ្ជាំងក្តី ក្រៅជុំថ្មក្តី ក្រៅភ្នំចក្រវាលក្តី តថាគតឈ្មោះថា ពុទ្ធៈ អាចធ្វើគេឲ្យបានឮសំឡេងរបស់តថាគតបាន ទើបត្រាស់ធម្មកថា ប្រៀបបីដូចចាប់អង្រួនដើមស្វាយឲ្យផ្លែមានពណ៌ដូចមាសជ្រុះ ដូច្នោះ ចប់ទេសនា សេដ្ឋីតាំងនៅក្នុងសោតាបត្តិផល លើកវាំងននឡើង ថ្វាយបង្គំបាទារបស់ព្រះសាស្តា ដោយបញ្ចង្គប្រតិស្ឋាន ក្នុងសម្នាក់ព្រះសាស្តានោះឯង ក៏ស្ថាបនា

នាងវិសាខាទុកក្នុងតំណែងមាតារបស់ខ្លួនថា នែនាង ចូរនាងជាមាតារបស់ខ្ញុំ តាំងអំពីថ្ងៃនេះទៅ ។ តាំងអំពីនោះមក ទើបនាងវិសាខាមានឈ្មោះថា មិគារមាតា ។

ថ្ងៃមួយ សម័យនក្ខត្តឫក្ស ដើរទៅក្នុងព្រះនគរ នាងវិសាខាក៏គិតថា មិនមានប្រយោជន៍ ក្នុងការនៅក្នុងព្រះនគរ ទើបហែហមដោយទាសី ទៅស្តាប់ធម្មកថារបស់ព្រះសាស្តា តែក៏គិតថា ទៅកាន់សម្នាក់ព្រះសាស្តាទាំងសភាពមានគ្រឿងគ្របដណ្តប់មិនគួរ ទើបដោះគ្រឿងប្រដាប់មហាលតាបសាធន៍ចេញ ដាក់ក្នុងដៃទាសី ចូលទៅគាល់ព្រះសាស្តា ថ្វាយបង្គំហើយអង្គុយក្នុងទីសមគួរ នាចំណែកម្ខាង ព្រះសាស្តាត្រាស់ធម្មកថា ។ ចប់ធម្មទេសនារបស់ព្រះសាស្តា ទើបនាងថ្វាយបង្គំព្រះទសពល ហើយឆ្ពោះទៅកាន់ព្រះនគរ ទាសីនោះមិនទាន់កំណត់ទីដែលនាងទុកគ្រឿងប្រដាប់ ទើបដើរត្រឡប់ទៅរកគ្រឿងប្រដាប់ ។ ខណៈនោះ ទើបនាងវិសាខាសាកសួរទាសីនោះថា នាងដាក់គ្រឿងប្រដាប់ទីណា ។ ទាសីឆ្លើយថា ត្រង់បរិវេណព្រះគន្ធកុដិ ។ នាងវិសាខាពោលថា ណ្ហើយចុះ ចូរទៅនាំមក រាប់តាំងអំពីនាងដាក់របស់ទុកត្រង់បរិវេណព្រះគន្ធកុដិហើយ ការនាំរបស់ត្រឡប់មក មិនគួរដល់ខ្ញុំ ព្រោះហេតុនោះ ខ្ញុំនឹងលះគ្រឿងប្រដាប់មហាលតាបសាធន៍នោះ ធ្វើជាទណ្ឌកម្ម តែកាលគ្រឿងប្រដាប់នោះនៅទំនេរ លោកម្ចាស់ទាំងឡាយក៏គន់កន្ទល់ ។ ស្អែកឡើង ព្រះសាស្តា មានភិក្ខុសង្ឃជាបរិវារ និមន្តដល់ទ្វារនិវេសន៍របស់នាងវិសាខា ។ ក្នុងនិវេសន៍រៀបចំអាសនៈទុកជាប្រចាំ នាង

វិសាខាទទួលបាត្ររបស់ព្រះមុនី អារាធនាឲ្យទ្រង់ចូលកាន់ផ្ទះ ឲ្យប្រថាប់គង់លើអាសនៈដែលរៀបចំទុកហើយនោះឯង ។ កាលព្រះសាស្តាសោយស្រេចហើយ ក៏នាំគ្រឿងប្រដាប់នោះទៅទុកក្បែរបាទារបស់ព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ថ្វាយគ្រឿងប្រដាប់នេះដល់ទ្រង់ ព្រះសាស្តាឃាត់ថា ឈ្មោះថា គ្រឿងអលង្ការមិនសមគួរដល់អ្នកបួសទាំងឡាយឡើយ ។ នាងវិសាខាក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹង តែខ្ញុំព្រះអង្គនឹងចំណាយគ្រឿងប្រដាប់នេះ យកទ្រព្យមកសាងព្រះគន្ធកុដិដែលជាលំនៅសម្រាប់ទ្រង់ ។ គ្រានោះ ព្រះសាស្តាក៏ទទួលដោយតុណ្ហីភាព ។ នាងវិសាខាចំណាយគ្រឿងប្រដាប់នោះ យកទ្រព្យ ៩ កោដិមកសាងព្រះគន្ធកុដិ ដែលជាទីប្រថាប់សម្រាប់ព្រះតថាគត ក្នុងវិហារឈ្មោះបុព្វារាមដែលប្រដាប់ដោយបន្ទប់ ១០០០ ។

និវេសន៍របស់នាងវិសាខា ពេលព្រឹក ក៏ដេរដាសដោយសំពត់កាសាវពស្ត្រ ដេរដាសដោយអ្នកស្វែងរកបុណ្យ ក្នុងផ្ទះរបស់នាងវិសាខានោះ ក៏រៀបចំទានសព្វបែបយ៉ាង ដូចក្នុងផ្ទះរបស់អនាថបិណ្ឌិកសេដ្ឋីដែរ ។ នាងវិសាខា ពេលព្រឹក ក៏ធ្វើអាមិសសង្គហៈដល់ព្រះភិក្ខុសង្ឃ ។ ខាងក្រោយអំពីអាហារ ក៏ឲ្យអ្នកដើរព្រៃកាន់យកភេសជ្ជៈ និងនាំអដ្ឋបានទៅកាន់វិហារប្រគេនដល់ភិក្ខុសង្ឃ ស្តាប់ធម្មទេសនារបស់ព្រះសាស្តា ហើយក៏ត្រឡប់មក ។ ក្រោយមក ព្រះសាស្តាកាលទ្រង់ស្ថាបនា ពួកឧបាសិកាទុកក្នុង

*តំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនានាងវិសាខាមិគារមាតាទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាដែលថ្វាយទាន ។*

## អដ្ឋកថា សូត្រទី ២ ចប់

# អដ្ឋកថា សូត្រទី ៣-៤

# ប្រវត្តិ នាងខុជ្ជុត្តរា និងនាងសាមាវតី

*ក្នុងសូត្រទី ៣ និងសូត្រទី ៤ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា* **ពហុស្សុតានំ យទិទំ ខុជ្ជុត្តរា មេត្តាវិហារីនំ យទិទំ សាមាវតី** *លោកសម្តែងថា នាងខុជ្ជុត្តរាជាកំពូលជាងពួកឧបាសិកា ដែលជាពហូសូត ។ នាងសាមាវតីជាកំពូលជាងពួកឧបាសិកា ដែលមានប្រក្រតីនៅដោយមេត្តា ។*

*បានឮថា នាងទាំង ២ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ បដិសន្ធិក្នុងត្រកូលមួយ នាក្រុងហង្សវតី ។ បន្ទាប់មក គិតគ្នាថា នឹងស្តាប់ធម្មកថារបស់ព្រះសាស្តា ទើបនាំគ្នាទៅវិហារ ។ នាងទាំង ២ នោះ នាងខុជ្ជុត្តរា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ ទុកក្នុងតំណែងឯតទគ្គៈជាងពួកឧបាសិកាអរិយសាវិកា ជាពហូសូត ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងសាមាវតីឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាអរិយសាវិកាអ្នកនៅដោយមេត្តា*

ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ កាលស្ត្រីទាំង ២ ធ្វើកុសលដរាបដល់អស់ជីវិត កើតក្នុងទេវលោក អន្ទោលទៅក្នុងទេវតា និងមនុស្សនោះឯងអស់មួយសែនកប្ប ។

គ្រានោះ មុនព្រះសាស្តានៃយើងកើតឡើង ។ អហិវាតរោគកើតឡើងក្នុងដែនអល្លកប្បៈ ក្នុងផ្ទះមួយ មានមនុស្ស ១០ នាក់ខ្លះ ២០ នាក់ខ្លះ ៣០ នាក់ខ្លះ ក៏ស្លាប់ព្រមៗ គ្នានោះឯង ចំណែកបុគ្គលដែលទៅក្រៅដែនក៏រួចផុតជីវិត ។ បុរសម្នាក់ដឹងរឿងនោះហើយ ក៏នាំបុត្រ និងភរិយារបស់ខ្លួនទៅក្រៅដែននោះ ដោយបំណងនឹងទៅដែនដទៃ ។ គ្រានោះ ស្បៀងធ្វើដំណើរដែលយកមកអំពីផ្ទះរបស់បុរសនោះក៏អស់ទៅ ដោយមិនទាន់ឆ្លងផុតផ្លូវកន្តារ ។ កម្លាំងកាយរបស់ពួកគេក៏ថមថយ ។ មាតាបីបុត្រទៅម្តង បិតាក៏បីបុត្រទៅម្តង ។ គ្រានោះ បិតារបស់បុត្រនោះគិតថា កម្លាំងកាយរបស់អញថមថយហើយ អញនឹងបីកូនដើរទៅ គង់មិនអាចឆ្លងកន្តារទៅបាន បុរសនោះមិនឲ្យភរិយាដឹង ឲ្យកូនអង្គុយ ធ្វើអាកប្បកិរិយាហាក់ដូចជាទៅរកទឹក ហើយក៏ដើរទៅម្នាក់ឯង ។ គ្រានោះ ភរិយានោះឈររង់ចាំ ចាំមិនឃើញកូនក្នុងដៃ ក៏ទ្រហោយំ ពោលថា កូនខ្ញុំទៅណា បុរសនោះពោលលួងលោមថា នាងត្រូវការបុត្រធ្វើអ្វី បើយើងនៅមានជីវិត ក៏នឹងបានកូនទៀត នាងពោលថា បុរសនេះចិត្តអាក្រក់ពេកហ្ន៎ ទើបពោលថា អ្នកទៅចុះ ខ្ញុំមិនទៅជាមួយអ្នកទេ បុរសពោលថា នែនាង ខ្ញុំមិនទាន់ពិចារណា បានធ្វើទៅហើយ ចូរអត់ទោសនោះដល់ខ្ញុំចុះ ហើយក៏បីកូនទៅ ។ មនុស្សទាំងនោះ ឆ្លងផ្លូវកន្តារនោះហើយ

វេលាល្ងាចក៏ដល់ផ្ទះអ្នកចិញ្ចឹមគោម្នាក់ ។

ថ្ងៃនោះ ផ្ទះអ្នកចិញ្ចឹមគោចម្អិនបាយាសដែលមានទឹកតិច ឃើញមនុស្ស ទាំងនោះ ក៏គិតថា ជនទាំងនេះ ប្រហែលជាស្រេកឃ្លានពន់ពេក ទើបយក បាយាសដាក់ពេញភាជនៈធំ រោយសប្បិមួយបាយឲ្យទៅ កាលមនុស្សទាំង នោះបរិភោគបាយាសនោះ ភរិយាក៏បរិភោគល្មមប្រមាណ ឯបុរសបរិភោគ លើសប្រមាណ មិនអាចឲ្យភ្លើងធាតុរំលាយបាន ក៏ធ្វើកាលកិរិយាក្នុងកាល បច្ឆិមយាម ។ កាលគាត់ធ្វើកាលកិរិយាហើយ ព្រោះនៅមានសេចក្តីអាល័យ ក្នុងមនុស្សទាំងនោះ ទើបបដិសន្ធិក្នុងពោះឆ្កែ ក្នុងផ្ទះរបស់អ្នកចិញ្ចឹមគោ ។ មិន យូរប៉ុន្មានសុនខក៏កើតកូន អ្នកចិញ្ចឹមគោឃើញឆ្កែនោះ មានលក្ខណៈស្អាតបាត ក៏ទំនុកបម្រុងដោយដុំបាយ ទើបនាំសុនខ ដែលកើតសេចក្តីស្រឡាញ់ក្នុងខ្លួន ត្រាច់ទៅជាមួយគ្នា ។ ថ្ងៃមួយ ព្រះបច្ចេកពុទ្ធមួយអង្គមកដល់ទ្វារផ្ទះរបស់ អ្នកចិញ្ចឹមគោ ក្នុងវេលាស្វែងរកអាហារ អ្នកចិញ្ចឹមគោនោះឃើញព្រះ បច្ចេកពុទ្ធនោះហើយ ក៏ប្រគេនអាហារ កាន់យកបដិញ្ញារបស់ព្រះបច្ចេកពុទ្ធ ដែលនឹងនៅអាស្រ័យខ្លួន ។ ព្រះបច្ចេកពុទ្ធក៏អាស្រ័យក្នុងដងព្រៃមួយ មិន ឆ្ងាយអំពីត្រកូលអ្នកចិញ្ចឹមគោ ។ អ្នកចិញ្ចឹមគោ ទៅកាន់សម្នាក់ព្រះបច្ចេក- ពុទ្ធ ក៏នាំឆ្កែនោះទៅដែរ វាយដើមឈើ ឬផ្ទាំងថ្មដើម្បីដេញសត្វសាហាវក្នុង លំនៅសត្វសាហាវ ក្នុងរវាងផ្លូវ ឆ្កែនោះកំណត់អាការធ្វើរបស់អ្នកចិញ្ចឹមគោ នោះ។ ថ្ងៃមួយ អ្នកចិញ្ចឹមគោ អង្គុយក្នុងសម្នាក់របស់ព្រះបច្ចេកពុទ្ធ ពោលថា បពិត្រលោកម្ចាស់ ខ្ញុំមិនបានមករាល់ថ្ងៃ តែឆ្កែនេះចេះ ដោយសញ្ញា គឺឆ្កែ

នេះមកហើយ សូមលោកម្ចាស់និមន្តមកកាន់ទ្វារផ្ទះរបស់ខ្ញុំចុះ ។ ថ្ងៃមួយ អ្នកចិញ្ចឹមគោនោះក៏បញ្ជូនឆ្កែនោះទៅ ដោយពោលថា អ្នកចូរនាំព្រះបច្ចេកពុទ្ធមក ឆ្កែនោះស្តាប់ពាក្យរបស់នាយគោបាលនោះ ក៏ទៅក្នុងវេលាកត្តកាល យកដើមទ្រូងក្រាបទៀបបាទារបស់ព្រះបច្ចេកពុទ្ធៗ ដឹងថា ឆ្កែនេះមកកាន់សម្នាក់លោកហើយ ក៏កាន់បាត្រចីវរ ធ្វើដំណើរទៅ តែលោកជកពិសោធឆ្កែនោះ ទើបនិមន្តទៅផ្លូវដទៃ ឆ្កែក៏ឈររាំងពីមុខ កៀងឲ្យទៅផ្លូវផ្ទះអ្នកចិញ្ចឹមគោ ក្នុងទីណាអ្នកចិញ្ចឹមគោវាយដើមឈើ ឬដុំថ្មដើម្បីដេញសត្វកាចឆ្កែដល់ទីនោះហើយ ក៏បន្លឺសំឡេងព្រុសខ្លាំងៗ ដោយសំឡេងរបស់ខ្លួន សត្វសាហាវទាំងឡាយក៏គេចទៅ សូម្បីព្រះបច្ចេកពុទ្ធក៏ឲ្យដុំបាយត្រជាក់មួយដុំដល់ឆ្កែ ក្នុងកាលដែលលោកឆាន់ស្រេចហើយ ឆ្កែនោះក៏ស្រឡាញ់ក្រៃលែងក្នុងព្រះបច្ចេកពុទ្ធ ដោយការចង់បានដុំបាយ ។ អ្នកចិញ្ចឹមគោប្រគេនសំពត់ល្មមនឹងធ្វើចីវរបាន ៣ ផ្ទាំង ដល់ព្រះបច្ចេកពុទ្ធអស់ត្រៃមាសហើយ ពោលថា បើលោកម្ចាស់ពេញចិត្ត ក៏សូមនៅក្នុងទីនេះឯង តែបើមិនពេញចិត្ត ក៏សូមទៅតាមសប្បាយ ព្រះបច្ចេកពុទ្ធសម្តែងអាការថា នឹងទៅ នាយគោបាលក៏តាមជូនព្រះបច្ចេកពុទ្ធ ហើយត្រឡប់ ឆ្កែដឹងថា ព្រះបច្ចេកពុទ្ធទៅទីដទៃក៏កើតសេចក្តីសោកដ៏ខ្លាំងក្លា ព្រោះសេចក្តីស្រឡាញ់ បេះដូងក៏បែក ស្លាប់ទៅកើតក្នុងស្ថានសួគ៌ជាន់តាវត្តិង្ស ។ ដោយសត្វកាចគេចទៅ ព្រោះឆ្កែនោះធ្វើសំឡេងខ្លាំង ក្នុងកាលទៅជាមួយព្រះបច្ចេកពុទ្ធ សំឡេងរបស់ទេវបុត្រនោះ កាលពោលជាមួយពួកទេវតាដទៃ ក៏លុបសំឡេងទេវតាទាំងនោះអស់

ដោយហេតុនោះឯង ទើបទេវបុត្រនោះបានឈ្មោះថា ឃោសកទេវបុត្រ ។ កាលឃោសកទេវបុត្រនោះសោយសម្បត្តិក្នុងតាវត្តិង្ស ព្រះរាជាព្រះនាមថាឧទេនសោយរាជសម្បត្តិក្នុងក្រុងកោសម្ពី នាទីកដីមនុស្ស រឿងរបស់ព្រះបាទឧទេនគប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងអដ្ឋកថាពោធិរាជកុមារសូត្រនោះឯង ។

កាលព្រះបាទឧទេននោះសោយរាជ្យ ឃោសកទេវបុត្រ ក៏ចុតិបដិសន្ធិក្នុងគភ៌របស់ស្ត្រីដែលអាស្រ័យរូបចិញ្ចឹមជីវិតម្នាក់ ក្នុងក្រុងកោសម្ពី កន្លងទៅ ១០ ខែ នាងក៏ប្រសូតបុត្រ ដឹងថាជាប្រុស ក៏ដាក់ចូលត្រង់គំនរសំរាម ។ ខណៈនោះ អ្នកធ្វើការរបស់កោសម្ពិកសេដ្ឋី កំពុងដើរទៅកាន់ផ្ទះសេដ្ឋីអំពីព្រហាម សង្ស័យថា នុ៎ះជាអ្វីហ្ន៎ដែលពួកក្អែកកំពុងចោមរោម ក៏ចូលទៅ ឃើញទារកគិតថា ទារកនេះមានបុណ្យ ទើបបញ្ជូនទារកទុកក្នុងដៃបុរសម្នាក់ ឲ្យនាំទៅកាន់ផ្ទះខ្លួន ហើយក៏ទៅកាន់ផ្ទះសេដ្ឋី ចំណែកសេដ្ឋីកំពុងទៅកាន់រាជត្រកូល ក្នុងពេលចូលគាល់ ជួបបុរោហិតក្នុងរវាងផ្លូវ ក៏សួរថា ថ្ងៃនេះផ្កាយឫក្សអ្វី បុរោហិតនោះឈរត្រង់នោះឯង គណនាហើយ ពោលថាផ្កាយឫក្សឈ្មោះនោះ ទារកកើតតាមផ្កាយនេះ ក្នុងថ្ងៃនេះ នឹងបានតំណែងសេដ្ឋីក្នុងនគរនេះ សេដ្ឋីនោះស្តាប់ពាក្យរបស់បុរោហិតនោះហើយ ក៏ប្រញាប់បញ្ជូនមនុស្សទៅកាន់ផ្ទះថា បុរោហិតនេះមិនពោលពាក្យបែកជា ២ ឡើយ ស្រីមេផ្ទះមានគភ៌ចាស់របស់ពួកយើងមាន ពួកអ្នកចូរពិនិត្យមើលថា ប្រសូតហើយឬនៅ មនុស្សទាំងនោះទៅពិនិត្យមើលហើយ ក៏ពោលថា បពិត្រលោក

ម្ចាស់ ស្រីមានគភ៌ចាស់នោះ មិនទាន់ប្រសូតទេ ។ ទើបសេដ្ឋីពោលថា បើដូច្នោះ ពួកអ្នកចូរទៅរកទារកដែលកើតក្នុងថ្ងៃនេះ ក្នុងនគរនេះ មនុស្សទាំងនោះ ស្វែងរកក៏ឃើញទារកនោះក្នុងផ្ទះរបស់អ្នកធ្វើការឲ្យសេដ្ឋីនោះ ហើយប្រាប់ដល់សេដ្ឋី ។ សេដ្ឋីពោលថា នែអ្នក បើដូច្នោះ ពួកអ្នកចូរទៅហៅអ្នកធ្វើការងារនោះមក មនុស្សទាំងនោះ ក៏ហៅអ្នកធ្វើការនោះមក សេដ្ឋីសួរថា បានឮថា ផ្ទះរបស់អ្នក មានទារកឬ បុរសនោះឆ្លើយថា មាន លោកម្ចាស់ សេដ្ឋីប្រាប់ថា អ្នកចូរឲ្យទារកនោះដល់ខ្ញុំចុះ ។ បុរសនោះពោលថា ឲ្យមិនបានទេ លោកម្ចាស់ ។ សេដ្ឋីពោលថា អ្នកទទួលទ្រព្យ ១០០០ ហើយឲ្យខ្ញុំចុះ ។ អ្នកធ្វើការនោះគិតថា ទារកនេះរស់ ឬស្លាប់ សេចក្តីនេះដឹងបានលំបាក ដូច្នេះ ទើបទទួលទ្រព្យ ១០០០ ហើយឲ្យទារកទៅ ។

លំដាប់នោះ សេដ្ឋីគិតថា បើប្រពន្ធអញប្រសូតកូនស្រី ក៏នឹងធ្វើទារកនេះឲ្យជាបុត្រ បើប្រសូតកូនប្រុស នឹងធ្វើទារកនេះឲ្យស្លាប់ ។ កាលគិតហើយ ក៏ចិញ្ចឹមទារកទុកក្នុងផ្ទះ គ្រានោះ ភរិយារបស់សេដ្ឋីនោះ ក៏ប្រសូតកូនប្រុស ខុសគ្នា ២-៣ ថ្ងៃប៉ុណ្ណោះ ។ បន្ទាប់អំពីនោះ សេដ្ឋីក៏គិតឲ្យពួកគោជាន់ទារកនោះឲ្យស្លាប់ ទើបប្រាប់ថា ពួកអ្នកចូរយកទារកនេះទៅដាក់ឲ្យដេកត្រង់ទ្វារក្រោល មនុស្សទាំងឡាយ ក៏ឲ្យទារកនោះដេកត្រង់ទ្វារក្រោលនោះ ។ គ្រានោះ គោឧសភៈមេហ្វូងចេញទៅមុន ឃើញទារកនោះ ក៏ឈរក្រុងទុកក្នុងរវាងជើងទាំង ៤ ដោយគិតថា គោដទៃៗ កុំបីជាន់ទារកនេះឡើយ ។ ដោយអាការយ៉ាងនេះ ខណៈនោះ អ្នកចិញ្ចឹមគោជួបទារកនោះ

គិតថា កុមារនេះសូម្បីតែសត្វតិរច្ឆាន ក៏គង់ស្គាល់គុណ ពិតជាអ្នកមានបុណ្យច្រើន អញនឹងចិញ្ចឹមទារកនោះ ហើយនាំទៅកាន់ផ្ទះខ្លួន ។

ចំណែកសេដ្ឋី ដឹងថា ទារកនោះមិនទាន់ស្លាប់ បានឮថា អ្នកចិញ្ចឹមគោនាំទៅ ក៏ឲ្យទ្រព្យ ១០០០ ហើយឲ្យចោលត្រង់ព្រៃខ្មោច ។ វេលានោះ អ្នកចិញ្ចឹមពពែក្នុងផ្ទះសេដ្ឋី អាស្រ័យព្រៃខ្មោច នាំមេពពែទៅ ពពែកូនខ្ចីមួយ ព្រោះបុណ្យរបស់ទារក ក៏គេចអំពីផ្លូវទៅឲ្យទឹកដោះទារក ហើយក៏ទៅវាត្រឡប់អំពីទីនោះ ក៏ទៅឲ្យទឹកដោះទារកនោះឯង អ្នកចិញ្ចឹមពពែគិតថា មេពពែនេះគេចអំពីទីនេះទៅអំពីព្រលឹម ព្រោះហេតុអ្វីហ្ន៎ ទើបដើរទៅមើលឃើញទារកនោះ គិតថា ទារកនេះមានបុណ្យច្រើន សូម្បីតែសត្វតិរច្ឆានក៏គង់ដឹងគុណ អញនឹងចិញ្ចឹមទារកនេះ ហើយនាំទៅផ្ទះ ។ ចំណែកសេដ្ឋីក៏ឲ្យពិនិត្យមើលទៀតថា ទារកនោះស្លាប់ ឬមិនស្លាប់ ដឹងថា អ្នកចិញ្ចឹមពពែទទួលទុក ក៏ឲ្យទ្រព្យ ១០០០ ប្រាប់ថា ស្អែកនេះ កូនទាយរទេះម្នាក់នឹងចូលទៅកាន់នគរនេះ ពួកអ្នកចូរនាំទារកនេះទៅទុកត្រង់ផ្លូវរទេះ កង់រទេះនោះនឹងកិនយ៉ាងនេះ ពួកគោក្នុងរទេះដំបូងរបស់ក្រុមរទេះ ក្រឡេកឃើញទារកដែលដាក់ក្នុងផ្លូវរទេះនោះ ក៏ឈរយកជើងទាំង ៤ ក្រុង ដូចសសរការពារដូច្នោះ ។ នាយក្រុមរទេះសង្ស័យថា ន៎ុះជាអ្វីហ្ន៎ ក៏ដឹងហេតុដែលគោទាំងនោះឈប់ ឃើញទារកហើយ យល់ថា ទារកមានបុណ្យច្រើន គួរចិញ្ចឹមទុកទើបនាំទៅហើយ ។

ចំណែកសេដ្ឋីឲ្យអង្កេតមើលថា ក្មេងនោះស្លាប់ ឬមិនស្លាប់ត្រង់ផ្លូវ

រទេះ ដឹងថា នាយរទេះទទួលទៅ ក៏ឲ្យទ្រព្យ ១០០០ យកអំពីនាយរទេះនោះ ឲ្យបោះក្នុងជ្រោះក្នុងទីមិនឆ្ងាយអំពីព្រះនគរ ។ ទារកនោះ កាលធ្លាក់ទៅក្នុងជ្រោះនោះ ក៏ធ្លាក់ត្រង់រោងជាងផែងដែលធ្វើការងាររបស់ពួកជាងផែង រោងជាងផែងនោះបានជាសម្ផស្សដូចសំឡី ១០០ ជាន់ ដោយអានុភាពបុណ្យរបស់ទារកនោះ ។ គ្រានោះ មេជាងផែងយល់ថា ទារកនេះមានបុណ្យគួរចិញ្ចឹមទុក ទើបនាំទារកនោះទៅផ្ទះ ។

សេដ្ឋីឲ្យស្វែងរកក្នុងទីដែលទារកធ្លាក់ជ្រោះ ថាស្លាប់ ឬមិនស្លាប់ ដឹងថា មេជាងផែងទទួលទុក ក៏ឲ្យទ្រព្យ ១០០០ ដល់មេជាងផែងនោះ ឲ្យនាំទារកមក ។ បន្ទាប់មក កូនរបស់សេដ្ឋីក្តី ទារកនោះក្តី ទាំង ២ នាក់ក៏ធំធាត់ ។

សេដ្ឋីក៏ពិចារណាដល់ឧបាយដែលនឹងឲ្យកុមារឃោសកស្លាប់ ទើបទៅផ្ទះជាងឆ្នាំងរបស់ខ្លួន ពោលរឿងសម្ងាត់ថា នែបា ផ្ទះខ្ញុំ មានក្មេងត្រកូលថោកទាបម្នាក់ គួរធ្វើអ្វីមួយឲ្យក្មេងនោះស្លាប់ ស្មូនឆ្នាំងនោះ ក៏បិទត្រចៀកទាំង ២ ពោលថា មិនគួរពោលពាក្យធ្ងន់បែបនេះ បន្ទាប់អំពីនោះ សេដ្ឋីគិតថា នាយស្មូនឆ្នាំងនេះ នឹងមិនធ្វើដោយមិនបានអ្វី ទើបពោលថា ណ្ហើយចុះ បា ចូរយកទ្រព្យ ១០០០ ធ្វើការងារនេះឲ្យសម្រេច ។ ឈ្មោះថាសំណូក រមែងទម្លាយវត្ថុដែលទម្លាយបានដោយលំបាក ព្រោះហេតុនោះ ទើបនាយស្មូនឆ្នាំងនោះបានទ្រព្យ ១០០០ ហើយ ក៏ទទួលហើយ ពោលថា បពិត្រលោកម្ចាស់ ខ្ញុំនឹងដុតភ្លើងឡក្នុងថ្ងៃឈ្មោះនោះ សូមលោកម្ចាស់បញ្ជូន

ទារកនោះមកក្នុងថ្ងៃនោះ វេលានោះ ។ ឯសេដ្ឋីទទួលពាក្យរបស់ស្មូនឆ្នាំង នោះហើយ រាប់អំពីថ្ងៃនោះ ដឹងថា ថ្ងៃដែលស្មូនឆ្នាំងណាត់ទុកដល់ហើយ ក៏ហៅនាយឃោសកមកប្រាប់ថា នែកូន ឪពុកត្រូវការកាជនៈច្រើន ក្នុងថ្ងៃឈ្មោះនោះ បាចូរទៅរកនាយស្មូនឆ្នាំង ប្រាប់ថា បានឮថា មានការងារដែលឪពុកខ្ញុំពោលទុកម្យ៉ាង ថ្ងៃនេះ សូមលោកធ្វើការងារនោះឲ្យសម្រេច ។ នាយឃោសកទទួលពាក្យរបស់សេដ្ឋីនោះថា សាធុ ហើយក៏ចេញទៅ ។ ខណៈនោះ ក្នុងវាងផ្លូវ កូនរបស់សេដ្ឋីកំពុងលេងបោះឡូ ទើបប្រញាប់ទៅពោលថា នែបង ខ្ញុំកំពុងលេងជាមួយពួកក្មេងៗ ត្រូវគេឈ្នះប៉ុណ្ណេះ សូមបងយកឈ្នះឲ្យខ្ញុំ ។ ឃោសកពោលថា ឥឡូវនេះ ឱកាសរបស់បងមិនមាន ឪពុកប្រើបងទៅរកស្មូនឆ្នាំង ដោយកិច្ចប្រញាប់ ។ កូនសេដ្ឋីពោលថា នែបង ខ្ញុំនឹងទៅជំនួស សូមបងលេងជាមួយពួកក្មេងទាំងនេះ នាំជោគត្រឡប់មកឲ្យដូច្នោះ ។ ឃោសកកុមារពោលថា បើដូច្នោះ ឯងទៅចុះ ហើយប្រាប់ដំណឹងដែលបិតាប្រាប់ដល់ខ្លួនដល់ប្អូនប្រុសនោះ ហើយលេងជាមួយពួកក្មេងៗ ។ កុមារនោះទៅរកស្មូនឆ្នាំង ហើយប្រាប់ដំណឹងនោះ ។ នាយស្មូនឆ្នាំងពោលថា អើ ល្អណាស់ ខ្ញុំនឹងធ្វើការងារឲ្យសម្រេច ហើយឲ្យកុមារនោះចូលទៅក្នុងបន្ទប់ យកកាំបិតដ៏មុត កាត់ជាចម្រៀកតូចធំ ដាក់ឆ្នាំងបិទមាត់ឆ្នាំង ហើយដុតភ្លើង ដុតឆ្នាំង នាយឃោសកលេងឈ្នះ ក៏អង្គុយរង់ចាំប្អូនមក ដឹងថា ប្អូនយឺតយូរ ក៏ទៅកាន់ចំណែកមួយនៃផ្ទះជាងឆ្នាំង រកមើលក្នុងទីណាមួយ ក៏មិនឃើញ គិតថា ប្អូនគង់នឹងត្រឡប់ទៅផ្ទះហើយ ទើបត្រឡប់ទៅផ្ទះ ។

សេដ្ឋីឃើញកុមារដើរមកអំពីចម្ងាយ ក៏សង្ស័យថា នឹងមានហេតុអ្វីឬហ្ន៎ ឯ អញប្រាប់វាឲ្យទៅរកស្មូនឆ្នាំង ដើម្បីសម្លាប់វាឲ្យស្លាប់ ឥឡូវនេះ ក្មេងនេះ នៅមកក្នុងទីនេះទៀត ។ កុមារមកដល់ ទើបសួរថា ឯងមិនទៅរកជាងឆ្នាំង ទេឬ ទើបឃោសកកុមារប្រាប់ហេតុដែលខ្លួនត្រឡប់ និងហេតុដែលប្អូនប្រុស ទៅ សេដ្ឋីស្តាប់ពាក្យនោះហើយ ហាក់ដូចផែនដីធំបាក់សង្កត់រាប់រយជង ចិត្ត រវើរវាយថា ឯងនិយាយរឿងអ្វីយ៉ាងនេះ ហើយក៏ប្រញាប់ទៅរកស្មូនឆ្នាំង ពោលដោយពាក្យដែលមិនគួរពោល ក្នុងសម្នាក់អ្នកដទៃថា មើលចុះអ្នក មើលចុះអ្នក ស្មូនឆ្នាំងពោលថា លោកម្ចាស់ ឲ្យមើលអ្វី ការងារនោះ សម្រេចទៅហើយ បន្ទាប់អំពីនោះ សេដ្ឋីនោះក៏ត្រឡប់ទៅផ្ទះ ។

តាំងអំពីនោះមក រោគផ្លូវចិត្តកើតដល់សេដ្ឋីនោះ សម័យនោះ សេដ្ឋី នោះស៊ីមិនបាន ដោយរោគផ្លូវចិត្តនោះ គិតថា គួរឃើញការវិនាសរបស់ សត្រូវនៃកូនអញ ដោយឧបាយណាមួយ ទើបសរសេរលិខិតមួយច្បាប់ ហៅនាយឃោសកមកប្រាប់ដោយមាត់ថា ឯងចូរកាន់យកសំបុត្រនេះ ទៅរក អ្នកធ្វើការងាររបស់ឪពុកដែលមាននៅក្នុងស្រុកឈ្មោះនោះ ចូរប្រាប់ថា សូម អ្នកប្រញាប់ប្រញាល់ធ្វើរឿងដែលមាននៅក្នុងសំបុត្រ ក្នុងរវាងផ្លូវចូលទៅផ្ទះ សេដ្ឋីម្នាក់ ឈ្មោះគាមិកសេដ្ឋីសម្លាញ់របស់ឪពុក បរិភោគអាហារហើយ គប្បីទៅ ហើយបានប្រគល់សំបុត្រឲ្យទៅ ឃោសកនោះថ្វាយបង្គំសេដ្ឋីហើយ ទទួលសំបុត្រចេញទៅ រវាងផ្លូវទៅដល់លំនៅរបស់គាមិកសេដ្ឋីហើយ សួរ ដល់ផ្ទះរបស់សេដ្ឋី ឈរសំពះគាមិកសេដ្ឋីនោះ ដែលអង្គុយខាងក្រៅខ្លោង

ទ្វារ កំពុងឲ្យដាងកោរពុកមាត់ ហើយគាត់សួរថា នែបា បាមកអំពីណា ទើប ឆ្លើយថា បពិត្រលោកឪពុក ខ្ញុំជាកូនកោសម្ពិកសេដ្ឋី ។ គាមិកសេដ្ឋីនោះ ក៏ត្រេកអរពោលថា កូនសេដ្ឋីសម្លាញ់ខ្ញុំ ។ ខណៈនោះ ទាសីម្នាក់របស់កូន ស្រីសេដ្ឋី នាំផ្កាមកឲ្យធីតាសេដ្ឋី លំដាប់នោះ ទើបសេដ្ឋីពោលនឹងទាសី នោះថា ចូរផ្អាកការងារនោះសិន ចូរលាងជើងកូនឃោសក រៀបចំទីដេកឲ្យ ។ ទាសីនោះធ្វើតាមពាក្យប្រាប់នោះ ហើយទៅផ្សារនាំផ្កាមកឲ្យធីតាសេដ្ឋី ។ ធីតា សេដ្ឋីឃើញទាសីនោះ ក៏សម្គុតថា ថ្ងៃនេះ នាងយឺតយូរពេក ក្រោធហើយ ពោលថា នាងរវល់ធ្វើអ្វីក្នុងទីនោះ មកទល់នឹងពេលនេះ ។ ទាសីពោលថា បពិត្រអ្នកនាង ខ្ញុំមិនធ្លាប់ឃើញបុរសកំលោះរូបស្អាតដូច្នេះឡើយ គេជា កំលោះម្នាក់ កូនសេដ្ឋីសម្លាញ់បិតារបស់អ្នកនាង ខ្ញុំមិនអាចពោលដល់រូប សម្បត្តិរបស់គាត់បាន ខ្ញុំកំពុងនាំផ្កាមក លោកសេដ្ឋីប្រើឲ្យខ្ញុំលាងជើងបុរស កំលោះនោះ ឲ្យរៀបចំទីដេក ដោយហេតុនោះ ទើបខ្ញុំយឺតយូរ ។ ធីតាសេដ្ឋី នោះធ្លាប់ជាភរិយារបស់កំលោះនោះ ក្នុងអត្តភាពទី ៤ ព្រោះហេតុនោះ តាំង អំពីបានស្តាប់ពាក្យរបស់ទាសីនោះ ក៏មិនដឹងខ្លួនថា ឈរ មិនដឹងខ្លួនថា អង្គុយ នាំទាសីនោះទៅកាន់ទីដែលនាយឃោសកដេក សម្លឹងមើលឃោសក ដែលកំពុងដេកលក់ ឃើញសំបុត្រត្រង់ជាយសំពត់ សង្ស័យថា នុ៎ះសំបុត្រ អ្វី មិនដាស់ឲ្យក្រាក់ ដកយកសំបុត្រមកអាន ក៏ដឹងថា បុរសកំលោះនេះកាន់ សំបុត្រសម្លាប់ខ្លួន ទៅដោយខ្លួនឯង ទើបហែកសំបុត្រនោះ កាលកំលោះ នោះមិនទាន់ភ្ញាក់ ក៏សរសេរសំបុត្រថ្មីថា ខ្ញុំបញ្ជូនកូនទៅកាន់សម្នាក់អ្នក

គាមិកសេដ្ឋីសម្លាញ់ខ្ញុំ មានកូនស្រីចម្រើនវ័យហើយ ចូរអ្នកប្រញាប់ប្រមូលទ្រព្យ ដែលកើតក្នុងអាណាបរិវេណរបស់យើង កាន់យកធីតារបស់គាមិកសេដ្ឋី ធ្វើការមង្គលដល់កូនរបស់ខ្ញុំ ដោយទ្រព្យគ្រប់យ៉ាង មួយមុខមួយរយៗ កាលមង្គលចប់ហើយ ចូរបញ្ជូនដំណឹងឲ្យខ្ញុំដឹងថា ការងារមង្គលចប់ហើយ ដោយវិធីនេះ ខ្ញុំនឹងដឹងកិច្ចដែលគប្បីធ្វើដល់អ្នកក្នុងទីនេះ ដាក់ត្រាសំបុត្រនោះហើយ ចងទុកត្រង់ជាយសំពត់ដូចមុន បុរសកំលោះនោះនៅក្នុងផ្ទះគាមិកសេដ្ឋីនោះមួយថ្ងៃហើយ ស្អែកឡើង ក៏លាសេដ្ឋីទៅកាន់ផ្ទះរបស់អ្នកធ្វើការប្រគល់សំបុត្រឲ្យ អ្នកធ្វើការអានសំបុត្រហើយ ក៏ឲ្យប្រជុំអ្នកស្រុក ពោលថា អ្នកទាំងឡាយ កុំស៊ីចិត្តខ្ញុំឡើយ ម្ចាស់របស់យើង បញ្ជូនដំណឹងមកកាន់សម្នាក់យើងថា ចូរនាំទារិកាមកដោយទ្រព្យមួយមុខមួយរយៗ ដល់កូនច្បងរបស់គាត់ ពួកអ្នកចូរប្រញាប់ប្រមូលទ្រព្យដែលកើតក្នុងទីនេះមក ហើយរៀបចំវិធីមង្គលគ្រឿងសក្ការៈគ្រប់យ៉ាង ហើយបញ្ជូនដំណឹងដល់គាមិកសេដ្ឋីឲ្យទទួលហើយ ឲ្យយល់ព្រមការងារមង្គល ដោយទ្រព្យគ្រប់យ៉ាង មួយមុខមួយរយៗ ហើយបញ្ជូនសំបុត្រដល់កោសម្ពិកសេដ្ឋីថា ពួកយើងដឹងដំណឹងក្នុងសំបុត្រដែលលោកម្ចាស់បញ្ជូនមកហើយ ក៏ធ្វើកិច្ចយ៉ាងនេះៗ ស្រេចហើយ ។

សេដ្ឋីស្តាប់ដំណឹងនោះហើយ ដូចត្រូវដុតហើយក្នុងគំនរភ្លើង ដូច្នោះដល់នូវការកើតរោគធ្លាក់លោហិត ព្រោះអំណាចដែលគិតថា ឥឡូវនេះ អញវិកវរហើយ ដូច្នេះ ក៏ឲ្យមនុស្សហៅនាយឃោសកនោះ ដោយគិតនឹងធ្វើឧបាយឯណានីមួយ តាំងចិត្តថា នឹងធ្វើឃោសកមិនឲ្យជាម្ចាស់ទ្រព្យសម្បត្តិ

របស់ខ្លួន តាំងអំពីរៀបអាពាហ៍ពិពាហ៍ស្រេចហើយ ក៏បញ្ជូនដំណឹងទៅថា ហេតុអ្វី ទើបកូនរបស់ខ្ញុំនៅខាងក្រៅ ចូរប្រញាប់ត្រឡប់មកចុះ កាលឃោសក ស្តាប់ដំណឹងហើយ ក៏គិតនឹងទៅ ធីតាសេដ្ឋីគិតថា ប្តីនេះល្ងង់ខ្លៅ មិនដឹងថា សម្បត្តិនេះ អាស្រ័យអញទើបបាន អញគួរធ្វើអ្វីមួយ ហើយក៏ធ្វើឧបាយ ហាមក្នុងការទៅរបស់ឃោសកៈ បន្ទាប់អំពីនោះ ទើបពោលនឹងប្តីថា សូម អ្នកកុំប្រញាប់ប្រញាល់ពេកឡើយ ខ្ញុំនឹងទៅផ្ទះរបស់ត្រកូល ធម្មតាបុគ្គល ទៅ គួរត្រៀមរៀបចំការងាររបស់ខ្លួនហើយ សឹមទៅ ។ ចំណែកកោសម្ពិក-សេដ្ឋី ដឹងថា កូននោះយឺតយូរ បញ្ជូនដំណឹងទៅទៀតថា ហេតុអ្វី ទើបកូន យឺតយូរ យើងកើតរោគធ្លាក់លោហិត គួរអ្នកមកជួបយើងខណៈដែលរស់ នៅ ។ គ្រានោះ ធីតាសេដ្ឋីក៏ប្រាប់ដល់ស្វាមីនោះថា សេដ្ឋីនោះមិនមែនបិតា របស់អ្នកទេ អ្នកកុំសម្គាល់ជាបិតា សេដ្ឋីនោះបញ្ជូនសំបុត្រដល់អ្នកដែលធ្វើ ការដើម្បីឲ្យគេសម្លាប់អ្នក ទើបខ្ញុំប្តូរសំបុត្រនោះ សរសេរសេចក្តីថ្មី ធ្វើ សម្បត្តិនេះឲ្យកើតដល់អ្នក សេដ្ឋីនោះហៅអ្នកទៅបំណងនឹងធ្វើអ្នក មិនឲ្យជា កូនទេតើ អ្នកចូររង់ចាំការស្លាប់របស់សេដ្ឋីនោះចុះ ។

សម័យនោះ ឃោសកមិនទៅការដែលសេដ្ឋីនោះរស់នៅ លុះជ្រាបថា គាត់ធ្ងន់ខ្លាំងហើយ ទើបទៅនគរកោសម្ពី ធីតាសេដ្ឋីក៏ឲ្យសញ្ញាខាងក្រៅដល់ ប្តីនោះថា អ្នកកាលចូលទៅ ក៏ចាត់ការរក្សាទុកពេញផ្ទះ សឹមចូលទៅ ខ្លួនឯង ក៏ទៅមួយអន្លើនឹងកូនសេដ្ឋី លើកដើមដៃទាំង ២ ឡើងធ្វើជាយំសោកក្បែរ សេដ្ឋី ដែលដេកនៅក្នុងទីផ្សៀងទៅខាងងងឹត យកក្បាលបោកត្រង់ដើមទ្រូង

សេដ្ឋីនោះ ក៏ធ្វើកាលកិរិយាដោយការបោកនោះឯង ព្រោះគាត់អស់កម្លាំង យោសកធ្វើសរីរកិច្ចរបស់បិតា ធ្វើសំណូកដល់អ្នកជិតស្និទ្ធថា ពួកអ្នកចូរប្រាប់ថា ខ្ញុំជាកូនរបស់សេដ្ឋី បន្ទាប់អំពីថ្ងៃនោះ ៧ ថ្ងៃ ព្រះរាជាទ្រង់ព្រះតម្រិះថា គួរឲ្យបុគ្គលម្នាក់ៗ ដែលគួរដល់តំណែងសេដ្ឋី ទើបទ្រង់បញ្ជូនមនុស្សទៅពិនិត្យមើលថា សេដ្ឋីមានកូន ឬមិនមានកូន ។ ពួកអ្នកជិតស្និទ្ធនឹងសេដ្ឋីក៏ក្រាបទូលព្រះរាជាថា សេដ្ឋីមានបុត្រ ។ ព្រះរាជាទ្រង់ទទួលហើយ ក៏បានព្រះរាជទានតំណែងសេដ្ឋីនោះដល់យោសក គាត់ក៏ឈ្មោះថា យោសកសេដ្ឋី ។ គ្រានោះ ភរិយាក៏ពោលនឹងស្វាមីថា នែអ្នក អ្នកកើតមកក៏ថោកទាប ខ្ញុំក៏កើតក្នុងត្រកូលលំបាក យើងបានសម្បត្តិក៏ដោយអំណាចកុសល ដែលយើងធ្វើក្នុងកាលមុន ឥឡូវនេះ យើងក៏នឹងធ្វើកុសល ។ ស្វាមីក៏ទទួលថា សាធុ ប្អូនស្រី ក៏លះទ្រព្យ ១០០០ កហាបណៈរាល់ថ្ងៃ តម្កល់ទានជាប្រចាំ ។

ពេលនោះ បណ្តាជនទាំង ២ នោះ នាងខុជ្ជុត្តរា ចុតិអំពីទេវលោក បដិសន្ធិក្នុងគភ៌របស់មេដោះ ក្នុងផ្ទះរបស់យោសកសេដ្ឋី កាលកើត នាងមានរាងគម ដូច្នោះ ទើបមនុស្សទាំងឡាយដាក់ឈ្មោះថា ខុជ្ជុត្តរា ។

ឯនាងសាមាវតីចុតិអំពីទេវលោកហើយ បដិសន្ធិក្នុងផ្ទះរបស់ភទ្ទវគ្គិយសេដ្ឋី ក្នុងដែនភទ្ទវតិយៈ ។ បន្ទាប់មក នគរនោះកើតឆាតកភ័យ មនុស្សទាំងឡាយខ្វាចក្នុងការលំបាក ទើបបែកខ្ញែកគ្នាទៅ ។ គ្រានោះ ភទ្ទវតិយសេដ្ឋីនេះ ប្រឹក្សានឹងភរិយាថា នែនាង ឆាតកភ័យនេះមិនទាន់ប្រាកដខាងក្នុង

យើង នឹងទៅរកឃោសកសេដ្ឋីសម្លាញ់យើង ក្នុងក្រុងកោសម្ពី សម្លាញ់នោះឃើញយើង នឹងមិនស្គាល់ ។ បានឮថា សេដ្ឋីនោះបានជាសម្លាញ់ដែលមិនធ្លាប់ឃើញដល់ឃោសកនោះ ព្រោះហេតុនោះ ទើបពោលយ៉ាងនេះ ។ ភទ្ទវតិយសេដ្ឋីនោះឲ្យមនុស្សដ៏សេសត្រឡប់ហើយ ក៏នាំភរិយា និងធីតាធ្វើដំណើរទៅក្រុងកោសម្ពីទាំង ៣ នាក់ ជួបនូវទុក្ខដ៏ច្រើនក្នុងរវាងផ្លូវ ក៏ដល់ក្រុងកោសម្ពីតាមលំដាប់ អាស្រ័យនៅត្រង់សាលាមួយខ្នង ។ ឯឃោសកសេដ្ឋីឲ្យគេរៀបចំមហាទានដល់ពួកមនុស្សកំព្រា អ្នកដើរផ្លូវឆ្ងាយ វណិព្វក និងយាចក ក្បែរទ្វារផ្ទះរបស់ខ្លួន ។ លំដាប់នោះ ភទ្ទវតិយសេដ្ឋីនេះក៏គិតថា អញមិនអាចបង្ហាញខ្លួនដល់សេដ្ឋីសម្លាញ់ ដោយភេទរបស់មនុស្សកំព្រានេះបានឡើយ កាលរាងកាយជាប្រក្រតី យើងស្លៀកដណ្តប់ល្អហើយ សឹមទៅជួបលោក សេដ្ឋីទាំង ២ នាក់ក៏បញ្ជូនធីតាទៅរោងទានរបស់ឃោសកសេដ្ឋីដើម្បីនាំអាហារមកឲ្យខ្លួន ធីតានោះក៏កាន់ភាជនៈទៅរោងទាន ឈរខ្មាសក្នុងឱកាសមួយ អ្នកចាត់ការទាន ឃើញនាងក៏គិតថា អ្នកដទៃៗ ធ្វើសំឡេងខ្លាំង ដូចអ្នកប្រមង់ដណ្តើមទិញ និងលក់ត្រីក្នុងទីប្រជុំចំពោះមុខគ្នា ។ បានហើយ ក៏ទៅ ចំណែកក្មេងស្រីនេះ ប្រហែលជាកុលធីតា ព្រោះដូច្នោះ ឧបធិសម្បទា ទើបមាន ។ បន្ទាប់ពីនោះ ទើបសួរថា នែនាង ហេតុអ្វី ទើបមិនទទួលជាមួយអ្នកដទៃ ។ នាងឆ្លើយថា លោកឪពុក ខ្ញុំនឹងធ្វើការដណ្តើមគ្នាយ៉ាងនេះ ចូលទៅបានដូចម្តេច ។ បុរសនោះសួរថា នែនាង ពួកនាងមានប៉ុន្មាននាក់ នាងឆ្លើយថា ៣ នាក់ ។ ទើបគាត់ឲ្យដុំបាយ ៣ ដុំ នាងឲ្យបាយ

នោះដល់មាតាបិតា ឪពុកឃ្លានមកយូរហើយ បរិភោគលើសប្រមាណ ក៏ស្លាប់ ។ ស្អែកឡើង នាងក៏ទៅទទួលបាយ ២ ដុំប៉ុណ្ណោះ ថ្ងៃនោះ ភរិយាសេដ្ឋីក៏ស្លាប់បន្ទាប់អំពីពាក់កណ្តាលយប់ ព្រោះលំបាកដោយអាហារ និងព្រោះសោយសោកដល់សេដ្ឋីដែលស្លាប់ ។ ថ្ងៃស្អែកឡើង សេដ្ឋីធីតាក៏ទទួលដុំបាយ ១ ដុំប៉ុណ្ណោះ មេការអ្នកចាត់ចែងទាន ពិចារណាមើលកិរិយារបស់នាង ទើបសួរថា នែនាង ថ្ងៃដំបូង នាងទទួលដុំបាយ ៣ ដុំ បន្ទាប់មកទទួល ២ ដុំ ថ្ងៃនេះ ទទួលដុំបាយមួយដុំប៉ុណ្ណោះ មានរឿងអ្វីកើតឡើងឬ ទើបនាងតំណាលហេតុការណ៍នោះ ។ បុរសនោះសួរថា នែនាង នាងជាអ្នកស្រុកណា ។ នាងក៏និទានហេតុការណ៍ដោយសព្វគ្រប់ បុរសនោះពោលថា នែនាង បើដូច្នោះ នាងក៏ជាធីតាសេដ្ឋីរបស់យើង យើងមិនមានក្មេងស្រីដទៃៗ នាងចូរជាធីតាយើង តាំងអំពីឥឡូវនេះ ហើយទទួលនាងជាធីតា ។

នាងបានឮសំឡេងខ្លាំងអឺងកងក្នុងរោងទានក៏សួរថា លោកឪពុក ហេតុអ្វីទើបសំឡេងខ្លាំងលាន់ឮ ដូច្នេះ បុរសនោះឆ្លើយថា នែនាងក្នុងរវាងមនុស្សច្រើន មិនអាចធ្វើសំឡេងតិចបានទេ ។ នាងពោលថា លោកឪពុកខ្ញុំដឹងឧបាយក្នុងរឿងនេះ ។ បុរសនោះសួរថា គួរធ្វើដូចម្តេច នាងប្រាប់ថា ពួកយើងធ្វើរបងជុំវិញ ទុកទ្វារ ២ តាំងភាជនៈខាងក្នុង ឲ្យមនុស្សចូលទៅតាមទ្វារ ១ ទទួលអាហារហើយ ឲ្យចេញទៅតាមទ្វារ ១ ។ គាត់ទទួលថា ល្អណាស់ ហើយឲ្យធ្វើយ៉ាងនោះ តាំងអំពីថ្ងៃរះឡើង រាប់តាំងអំពីនោះមករោងទានក៏មានសំឡេងស្ងប់ស្ងាត់ទៅ ។ បន្ទាប់អំពីនោះ ឃោសកសេដ្ឋីមិន

បានឮសំឡេងអឺងកងក្នុងរោងទានមកអំពីមុន ។ គ្រានោះ កាលមិនបានឮសំឡេងនោះ ទើបហៅអ្នកចាត់ចែងទានមកសួរថា ថ្ងៃនេះ អ្នកឲ្យទានហើយឬ បុរសនោះឆ្លើយថា ឲ្យហើយ លោកម្ចាស់ ។ សេដ្ឋីសួរថា បើដូច្នោះហេតុអ្វី ទើបមិនមានសំឡេងខ្លាំងក្នុងរោងទានដូចអំពីមុន ។ បុរសនោះឆ្លើយថា មែនហើយ លោកម្ចាស់ ខ្ញុំមានកូនស្រីម្នាក់ ខ្ញុំធ្វើតាមឧបាយដែលនាងប្រាប់ ទើបធ្វើរោងទានមិនឲ្យមានសំឡេង ។ សេដ្ឋីសួរថា អ្នកមិនមានកូនស្រី អ្នកបានកូនស្រីមកអំពីណា ។ អ្នកចាត់ការទាននោះ តំណាលរឿងដែលធីតាមកគ្រប់យ៉ាងដល់សេដ្ឋី ព្រោះមិនអាចបោកបញ្ឆោតបាន ។ សេដ្ឋីពោលថា នែបា ហេតុអ្វី ទើបធ្វើកម្មធ្ងន់បែបនេះ មិនប្រាប់រឿងធីតាដែលនៅក្នុងសម្នាក់ខ្លួនដល់ខ្ញុំ អស់កាលយូរមានប្រមាណប៉ុណ្ណេះ អ្នកប្រញាប់នាំនាងមកក្នុងផ្ទះរបស់ខ្ញុំ មនុស្សអ្នកឲ្យទាននោះ ស្តាប់ពាក្យសេដ្ឋីហើយ ក៏ឲ្យនាំនាងមក ទាំងដែលខ្លួនមិនប្រាថ្នា ដូច្នោះ ។ តាំងអំពីនោះមក សេដ្ឋីក៏តាំងនាងក្នុងតំណែងជាធីតា គិតថា នឹងទទួលព្រលឹងធីតា ទើបចាត់ស្រី ៥០០ ដែលមានវ័យស្រករគ្នាអំពីត្រកូលដែលមានជាតិ ប្រហាក់ប្រហែលគ្នាមកជាបរិវាររបស់នាង ។

ថ្ងៃមួយ ព្រះបាទឧទេនទ្រង់ទតព្រះនគរ ឃើញនាងសាមាវតីនោះ មានស្រីក្រមុំទាំងនោះចោមរោមលេង ត្រាស់សួរថា ក្មេងនេះរបស់អ្នកណា ទ្រង់បានឮថា ជាកូនរបស់ឃោសកសេដ្ឋី ត្រាស់សួរថា មិនមានប្តីឬ កាលគេទូលថា មិនមានប្តីទេ ទើបត្រាស់ថា ពួកអ្នកចូរប្រាប់សេដ្ឋីថា ព្រះរាជាមាន

ព្រះរាជបំណាងក្នុងធីតារបស់អ្នក ។ សេដ្ឋីស្តាប់ហើយ ប្រាប់ថា ខ្ញុំមិនមានក្មេងស្រីដទៃៗ មិនអាចឲ្យធីតាតែមួយនៅជាមួយប្តីបានទេ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ បញ្ជាឲ្យសេដ្ឋី និងភរិយា នៅខាងក្រៅផ្ទះ ឲ្យបិទទ្វារវាយត្រាគ្រប់ខ្នងផ្ទះ ។ នាងសាមាវតីទៅលេងខាងក្រៅផ្ទះ លុះត្រឡប់មកឃើញមាតាបិតាអង្គុយខាងក្រៅផ្ទះ ទើបសួរថា បពិត្រអ្នកម៉ែ លោកឪពុកហេតុអ្វី ទើបមកអង្គុយទីនេះ សេដ្ឋី និងភរិយាប្រាប់ហេតុនោះ ទើបនាងពោលថា អ្នកម្តាយ លោកឪពុកកុំទូលតបនឹងព្រះរាជាយ៉ាងនោះឡើយ ឥឡូវនេះសូមទូលយ៉ាងនេះថា ធីតារបស់ខ្ញុំមិនអាចនៅម្នាក់ឯងជាមួយស្វាមីបានទេ បើព្រះអង្គទ្រង់ឲ្យស្រី ៥០០ នាក់បរិវាររបស់នាងនៅដែរ ទើបនាងនៅបាន ។ សេដ្ឋីពោលថា ល្អណាស់ កូន ឪពុកមិនដឹងចិត្តរបស់នាង ទើបសេដ្ឋី និងភរិយាក្រាបទូលយ៉ាងនោះ ព្រះរាជាទ្រង់ជ្រះថ្លាក្រៃលែង ត្រាស់ថា មនុស្ស ១០០០ នាក់ក៏ដោយចុះ ចូរនាំមកទាំងអស់ គ្រានោះ ទើបសេដ្ឋី និងភរិយានាំធីតានោះ មានស្រី ៥០០ នាក់ជាបរិវារទៅកាន់ព្រះរាជនិវេសន៍ ដោយមង្គលនក្ខត្តឫក្សដ៏ចម្រើន ព្រះរាជាទ្រង់ធ្វើស្រី ៥០០ ជាបរិវាររបស់នាង ហើយទ្រង់ធ្វើអភិសេកឲ្យនាងនៅក្នុងប្រាសាទមួយ ។

សម័យនោះ ក្នុងក្រុងកោសម្ពី សេដ្ឋី ៣ នាក់ គឺឃោសកសេដ្ឋី កុក្កុដសេដ្ឋី និងបាវារិកសេដ្ឋី ជាសម្លាញ់នឹងគ្នា ។ សេដ្ឋីទាំង ៣ នាក់ ក៏ទំនុកបម្រុងតាបស ៥០០ រូប ឯពួកតាបសក៏នៅក្នុងសម្នាក់សេដ្ឋីទាំង ៣ នាក់នោះ ៤ ខែ ក្នុងព្រៃហិមពាន្ត ៨ ខែ ។ ថ្ងៃមួយ តាបសទាំងនោះ មក

អំពីព្រៃហិមពាន្ត ស្រេកឃ្លានលំបាកក្នុងផ្លូវកន្តារច្រើន ទើបនាំគ្នាទៅកាន់ដើមជ្រៃធំមួយដើម បំណងនឹងទទួលការសង្គ្រោះអំពីសម្នាក់ទេវតា ដែលស្ថិតនៅក្នុងដើមជ្រៃធំនោះ ហើយអង្គុយ ។ ទេវតាក៏លាដៃដែលប្រដាប់ដោយគ្រឿងប្រដាប់គ្រប់យ៉ាង បង្ហូរប្រគេននូវទឹកបាន ដែលគួរផឹកជាដើម ដល់តាបសទាំងនោះ ជួយបន្ទោបង់នូវសេចក្តីលំបាកបាន តាបសទាំងនោះភ្ញាក់ផ្អើលព្រោះអានុភាពរបស់ទេវតា ទើបសួរថា នែទេវតា អ្នកធ្វើកម្មដូចម្តេចហ្ន៎ ទើបបានសម្បត្តិនេះ ។ ទេវតាប្រាប់ថា ព្រះមានព្រះភាគព្រះនាមថា **ពុទ្ធ** ទ្រង់កើតហើយក្នុងលោក ឥឡូវនេះ ទ្រង់ប្រថាប់នៅក្នុងក្រុងសាវត្ថី គហបតីឈ្មោះអនាថបិណ្ឌិកឧបដ្ឋាកទ្រង់ ថ្ងៃឧបោសថ អនាថបិណ្ឌិកសេដ្ឋីនោះ ឲ្យតម្លៃអាហារប្រចាំថ្ងៃកម្មកររបស់ខ្លួនហើយ ឲ្យអ្នកទាំងនោះរក្សាឧបោសថ ខ្ញុំចូលទៅដើម្បីអាហារព្រឹក នាពេលថ្ងៃមួយ មិនឃើញកម្មករណាម្នាក់ធ្វើការឡើយ ទើបខ្ញុំសួរថា ហេតុអ្វី ថ្ងៃនេះកម្មករទាំងឡាយមិនធ្វើការ ទើបមនុស្សទាំងឡាយប្រាប់រឿងនោះដល់ខ្ញុំ កាលបើដូច្នោះ ទើបខ្ញុំពោលថា ឥឡូវនេះ កន្លងទៅពាក់កណ្តាលថ្ងៃហើយ ខ្ញុំអាចធ្វើឧបោសថបានកន្លះថ្ងៃបានឬហ្ន៎ បន្ទាប់ពីនោះ មនុស្សទាំងឡាយក៏ប្រាប់ដល់សេដ្ឋី ហើយសេដ្ឋីពោលថា ធ្វើពាក់កណ្តាលថ្ងៃក៏បាន ខ្ញុំស្តាប់ពាក្យនោះហើយ ក៏សមាទានឧបោសថកន្លះថ្ងៃ ធ្វើកាលកិរិយាក្នុងថ្ងៃនោះឯង ហើយបានសម្បត្តិនេះ ។ កាលនោះ តាបសទាំងនោះកើតបីតិ និងបាមោជ្ជថា បានឮថា ព្រះពុទ្ធកើតឡើងហើយក្នុងលោក បំណងនឹងទៅអំពីទីនោះ កាន់ក្រុងសាវត្ថី ក៏គិតថា

ពួកសេដ្ឋីដែលឧបដ្ឋាកអាត្មាអញ មានឧបការៈច្រើន អញនឹងប្រាប់រឿងនោះ ដល់សេដ្ឋីទាំងនោះ ទើបនាំគ្នាទៅកាន់ក្រុងកោសម្ពី ពួកសេដ្ឋីធ្វើសក្ការៈស្និទ្ធស្នាលដ៏ច្រើន ទើបប្រាប់ថា ពួកយើងនឹងទៅក្នុងថ្ងៃនេះឯង ។ ពួកសេដ្ឋីជំទាស់ថា បពិត្រលោកម្ចាស់ ពួកលោកម្ចាស់ប្រញាប់ណាស់ឬ កាលពីមុនលោកម្ចាស់នៅ ៤-៥ ខែ ហើយទើបទៅ ឥសីក៏ប្រាប់រឿងនោះ ។ កាលពួកសេដ្ឋីពោលថា បពិត្រលោកម្ចាស់ បើយ៉ាងនោះ ពួកខ្ញុំក៏ទៅដែរ ក៏ប្រាប់ថា ពួកយើងនឹងនាំគ្នាទៅ សូមលោកម្ចាស់ ធ្វើដំណើរសន្សឹមៗ ចុះ ហើយទៅដល់ក្រុងសាវត្ថី បួសក្នុងសម្នាក់ព្រះមានព្រះភាគ ហើយសម្រេចអរហត្ត ។

ឯសេដ្ឋីទាំងនោះ មានរទេះ ៥០០ ជាបរិវារ ដល់ក្រុងសាវត្ថី ក្នុងកាលជាក្រោយ បោះជំរំស្នាក់នៅក្នុងទីមិនឆ្ងាយអំពីវត្តជេតពនមហាវិហារ ចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ។ ព្រះសាស្ដាទ្រង់សម្ដែងធម៌ដោយអំណាចចរិយា របស់មនុស្សទាំងនោះ ចប់ទេសនា សេដ្ឋីទាំង ៣ ក៏តាំងនៅក្នុងសោតាបត្តិផល និមន្តដើម្បីសោយក្នុងថ្ងៃស្អែក ។ ស្អែកឡើង ថ្វាយមហាទានដល់ភិក្ខុសង្ឃមានព្រះពុទ្ធ ជាប្រធាន ដោយទំនងនេះឯង ។ ថ្វាយខន្ធាវារភត្តទាន គឺទានរបស់អ្នកបោះជំរំអស់កន្លះខែ ទើបទូលអារាធនាព្រះសាស្ដាដើម្បីយាងទៅកាន់នគររបស់ខ្លួន ។ ព្រះសាស្ដាត្រាស់ថា ព្រះតថាគតទាំងឡាយត្រេកអរក្នុងទីស្ងាត់ ដូច្នេះ ។ សេដ្ឋីទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គដឹងហើយ ហើយក្រាបទូលថា សូមទ្រង់យាងមកតាមសាសន៍ដែល

ពួកខ្ញុំព្រះអង្គបញ្ជូនមកចុះ ថ្វាយបង្គំព្រះសាស្តា ប្រទក្សិណ ៣ ជុំ ហើយត្រឡប់ទៅនគររបស់ខ្លួនទាំង ៣ នាក់ ក៏ឲ្យសាងព្រះវិហារក្នុងឧទ្យានរបស់ខ្លួន វិហារដែលឃោសកសេដ្ឋីសាង ឈ្មោះឃោសិតារាម ដែលកុក្កុដសេដ្ឋីសាង ឈ្មោះកុក្កុដារាម ដែលបាវារិកសេដ្ឋីសាង ឈ្មោះបាវារិកម្ពវនវិហារ ។ សេដ្ឋីទាំងនោះ សាងវិហារស្រេចហើយ បញ្ជូនទូតទៅទូលព្រះសាស្តាថា សូមព្រះសាស្តាយាងមកនគរនេះ ដើម្បីសង្គ្រោះពួកខ្ញុំព្រះអង្គចុះ ។

ព្រះសាស្តាទ្រង់ព្រះតម្រិះថា នឹងយាងទៅក្រុងកោសម្ពី មានភិក្ខុសង្ឃច្រើនជាបរិវារ យាងចេញចារិក ទ្រង់ឃើញឧបនិស្ស័យអរហត្តនៃមាគណ្ឌិយព្រាហ្មណ៍ក្នុងរវាងផ្លូវ ទើបវៀរការទៅក្រុងកោសម្ពី ទ្រង់ទៅកាន់និគមឈ្មោះកម្មាសធម្ម ដែនកុរុ ។ សម័យនោះ មាគណ្ឌិយព្រាហ្មណ៍បម្រើភ្លើងក្រៅស្រុក មួយយប់ទល់ភ្លឺ ស្អែកឡើង ទើបចូលមកក្នុងស្រុក ។ ព្រះសាស្តាទ្រង់ចូលទៅបិណ្ឌបាតក្នុងស្រុក ធ្វើដំណើរបញ្ច្រាស់ទិសគ្នា បង្ហាញព្រះកាយដល់មាគណ្ឌិយព្រាហ្មណ៍ ។ មាគណ្ឌិយព្រាហ្មណ៍នោះ ឃើញព្រះទសពលក៏គិតថា អញស្វែងរកកំលោះដែលសមគ្នានឹងរូបសម្បត្តិកូនស្រីរបស់អញអស់កាលមានប្រមាណប៉ុណ្ណេះ កាលរូបសម្បត្តិមាន អញក៏ប្រាថ្នាការបួស បុគ្គលនេះកាន់យកភេទនេះដូចគ្នា តែបព្វជិតនេះល្អគួរសរសើរ សមជាមួយកូនស្រីអញពិតៗ ទើបប្រញាប់ប្រញាល់ទៅផ្ទះ ។ បានឮថា ព្រាហ្មណ៍នោះ ជាវង្សបព្វជិតមួយមកអំពីមុន ដោយហេតុនោះ គ្រាន់តែឃើញបព្វជិតប៉ុណ្ណោះ ទើបចិត្តរបស់គាត់បង្អោនទៅ ។ ព្រាហ្មណ៍ពិភាក្សាជាមួយនាង

ព្រាហ្មណីថា នែប្អូនស្រី ខ្ញុំប្រាថ្នាការបួសយ៉ាងនេះ ខ្ញុំមិនធ្លាប់ឃើញបព្វជិតបែបនេះសោះ ជាភេទព្រាហ្មណ៍ មានពណ៌សម្បុរដូចមាស សមនឹងកូនស្រីយើងពិតៗ ចូរប្រញាប់តែងខ្លួនកូនស្រីរបស់យើងចុះ ។ កាលនាងព្រាហ្មណីកំពុងតែងខ្លួនកូនស្រី ព្រះសាស្តាទ្រង់ទុកចេតិយ គឺស្នាមព្រះបាទក្នុងទីដែលគាត់ជួបទ្រង់ ។ ទ្រង់យាងចូលទៅក្នុងព្រះនគរ ។ ខណៈនោះ ព្រាហ្មណ៍នាំធីតា និងនាងព្រាហ្មណីមកកាន់ទីនោះ ពិនិត្យមើលជុំវិញ ព្រោះគាត់មកក្នុងកាលដែលព្រះសាស្តាចូលទៅក្នុងភូមិស្រុក មិនឃើញព្រះទសពល ក៏ជេរនាងព្រាហ្មណីថា ការធ្វើរបស់នាង ឈ្មោះថា មិនល្អមិនមានឡើយ តែព្រោះនាងធ្វើឲ្យយឺតយូរ ទើបបព្វជិតនោះចេញទៅបាត់ ។ ព្រាហ្មណ៍ពិនិត្យមើលទីព្រះសាស្តាយាងទៅថា បព្វជិតទៅហើយក៏ដោយចុះ តែទៅក្នុងទិសណា ឬក៏ទៅក្នុងទិសនេះ ក៏ជួបចេតិយ គឺស្នាមព្រះបាទ ពោលថា នែនាងដ៏ចម្រើននេះស្នាមជើងបុរសនោះ គេពិតជាទៅផ្លូវនេះ ។ ខណៈនោះ នាងព្រាហ្មណីឃើញចេតិយ គឺស្នាមព្រះបាទរបស់ព្រះសាស្តា គិតថា តាព្រាហ្មណ៍នេះល្ងង់ពិតហ្ន៎ មិនដឹងអត្ថ សូម្បីត្រឹមតែគម្ពីររបស់ខ្លួន ទើបធ្វើការចំអក ពោលនឹងព្រាហ្មណ៍នោះថា នែព្រាហ្មណ៍ អ្នកល្ងង់ដល់ម៉្លេះហើយ នៅមកនិយាយថាអញនឹងឲ្យកូនស្រីដល់បុរសដែលមានសភាពបែបនេះឬ ព្រោះថា ធម្មតាស្នាមជើងរបស់បុរសដែលមានរាគៈជ្រលក់ហើយ ទោសៈប្រទូស្តហើយ មោហៈវង្វេងហើយ មិនមែនយ៉ាងនេះទេ មើលចុះព្រាហ្មណ៍ នេះជាស្នាមជើងរបស់ព្រះសព្វញ្ញុពុទ្ធ ជាអ្នកមានដំបូលបើកហើយក្នុងលោក ។

**រត្តស្ស ហិ ឧក្កុដិកំ បទំ ភវេ**
**ទុដ្ឋស្ស ហោតិ អវកឌ្ឍិតំ បទំ**
**មូឡ្ហស្ស ហោតិ សហសានុបីឡិតំ**
**វិវដច្ឆទស្ស ឥទមីទិសំ បទំ ។**

*ពិតហើយ ស្នាមជើងរបស់បុគ្គលដែលត្រូវរាគៈជ្រលក់ហើយ រមែងជាស្នាមជើងកំពុង ស្នាមជើងរបស់បុគ្គលដែលត្រូវទោសៈប្រទូស្តហើយ គប្បីជាស្នាមជើងដែលធូន់ខាងចុង ស្នាមជើងរបស់បុគ្គលដែលត្រូវមោហៈឲ្យវង្វេងហើយ គប្បីជាស្នាមជើងដែលធូន់ខាងកែងជើង នេះជាស្នាមជើងរបស់បុគ្គល ដែលមានដំបូលបើកហើយនោះឯង ។*

កាលនាងព្រាហ្មណីពោលប៉ុណ្ណោះ ព្រាហ្មណ៍នោះក៏មិនស្តាប់ បែរជាស្តីបន្ទោសថា ជាស្រីមាត់រឹងរឿយៗ ទៅ ។ កាលពីរនាក់ប្តីប្រពន្ធជជែកគ្នានោះឯង ព្រះតថាគតយាងទៅបិណ្ឌបាត មួយអន្លើដោយភិក្ខុសង្ឃ សោយស្រេចហើយ ទើបចេញទៅក្បែរផ្លូវដែលព្រាហ្មណ៍អាចឃើញបាន ។ ព្រាហ្មណ៍ឃើញព្រះសាស្តាអំពីចម្ងាយ ក៏សប្បាយចិត្ត ញញឹមញញែម ប្រាប់នាងព្រាហ្មណីថា បុរសនេះ គឺបុគ្គលនោះ ទើបឈរត្រង់ព្រះភក្ត្រ ទូលថា បព្វជិតដ៏ចម្រើន ខ្ញុំដើររកអ្នកតាំងអំពីព្រឹក ។ ក្នុងជម្ពូទ្វីបនេះ មិនមានស្ត្រីណាមានរូបស្អាត ស្មើនឹងកូនស្រីរបស់ខ្ញុំឡើយ សូម្បីបុរសក៏មិនមានអ្នកណាមានរូបស្អាតដូចអ្នក ខ្ញុំឲ្យធីតារបស់ខ្ញុំ ដើម្បីអ្នកបានមើលថែ អ្នកទទួលនាងចុះ ។

គ្រានោះ ទើបព្រះសាស្ដាត្រាស់នឹងព្រាហ្មណ៍ថា ម្នាលព្រាហ្មណ៍ សូម្បីតែពួកទេពធីតា ក្នុងស្ថានសួគ៌ជាន់កាមាវចរ មានរូបល្អលើស មានពណ៌សម្បុរផ្សេងៗ គ្នា មកឈរក្នុងសម្នាក់ ពោលពាក្យដើម្បីលួងលោមតថាគតៗ គង់មិនប្រាថ្នា នឹងពោលថ្វីដល់ធីតារបស់អ្នក ថាតថាគតនឹងទទួល កាលត្រាស់ហើយ ទើបត្រាស់ព្រះគាថានេះថា

**ទិស្វាន តណ្ហំ អរតិញ្ច រាគំ**
**នាហោសិ ឆន្ទោ អបិ មេថុនស្មឹ**
**កិមេវិទំ មុត្តករីសបុណ្ណំ**
**បាទាបិ នំ សម្ផុសិតុំ ន ឥច្ឆេ ។**

អើក៏សេចក្ដីប្រាថ្នាក្នុងមេថុនមិនមាន ( ដល់តថាគត ) ព្រោះឃើញនាងតណ្ហា នាងអរតី និងនាងរាគា ( ដែលជាធីតានៃមារ ) សោះទៅហើយ ធ្វើម្ដេចឡើយ តថាគតនឹងមានសេចក្ដីប្រាថ្នាក្នុងមេថុន ព្រោះឃើញនូវរូបរបស់ទារិកា ដែលពោរពេញដោយមូត្រ និងករីសនេះ តថាគតមិនត្រូវការដើម្បីប៉ះពាល់នូវធីតារបស់អ្នកនោះសូម្បីតែដោយជើងឡើយ ។

នាងមាគណ្ឌិយាគិតថាធម្មតាមនុស្សដែលមិនត្រូវការពោលបដិសេធថា កុំឡើយ តែប៉ុណ្ណោះក៏គួរ បព្វជិតនេះធ្វើសរីរៈរបស់អញ ឲ្យពេញទៅដោយឧច្ចារបស្សាវៈ ហើយពោលទៀតថា សូម្បីតែជើងក៏មិនប្រាថ្នានឹងប៉ះ អញកាលបានតំណែងធំណាមួយ នឹងមើលចំណុចចុងបញ្ចប់របស់បព្វជិតនោះ ហើយ

ចងអាឃាតទុក ។ ព្រះសាស្តាទ្រង់មិនបានដាក់ព្រះហឫទ័យក្នុងនាង ទ្រង់ផ្តើមព្រះធម្មទេសនាប្រោសព្រាហ្មណ៍ ដោយអំណាចចរិយារបស់គាត់ ចប់ទេសនា ពីរនាក់ប្តីប្រពន្ធក៏តាំងនៅក្នុងអនាគាមិផល ហើយត្រិះរិះថា ឥឡូវនេះ អាត្មាអញ មិនត្រូវការគ្រប់គ្រងផ្ទះ ហើយទើបឲ្យមាគណ្ឌិយព្រាហ្មណ៍ដែលជាមាទទួលកូនស្រី ទាំងពីរនាក់ក៏បួស ហើយសម្រេចអរហត្ត ។ គ្រានោះ ព្រះបាទឧទេន ទ្រង់បានធ្វើការពោលចរចាជាមួយមាគណ្ឌិយព្រាហ្មណ៍ដែលជាឪពុកមា ហើយទ្រង់នាំទារិកាមាគណ្ឌិយាមកកាន់ព្រះរាជនិវេសន៍ដោយព្រះរាជានុភាព ទ្រង់អភិសេក ព្រះរាជទានប្រាសាទមួយដោយឡែកដើម្បីព្រះនាងមាគណ្ឌិយា និងស្ត្រីបរិវារ ៥០០ ។

ចំណែកព្រះសាស្តា ទ្រង់ចារិកដោយលំដាប់ មកដល់ក្រុងកោសម្ពី ។ សេដ្ឋី ៣ នាក់ ដឹងថាព្រះសាស្តាយាងមក ទើបចេញទៅទទួល ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងទីសមគួរនាចំណែកម្ខាង ក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន វិហារទាំង ៣ នេះ ខ្ញុំព្រះអង្គសាងឧទ្ទិសចំពោះព្រះអង្គ សូមទ្រង់ទទួលវិហារទាំងឡាយ ដើម្បីសង្គ្រោះសង្ឃដែលចារិកមកអំពីទិសទាំង ៤ ចុះ ។ ព្រះមានព្រះភាគ ទ្រង់ទទួលវិហារ ។ សេដ្ឋីទាំងនោះ ក៏អារាធនាព្រះសាស្តាដើម្បីសោយអាហារក្នុងថ្ងៃស្អែក ថ្វាយបង្គំហើយ ក៏ត្រឡប់មកផ្ទះ ។ ឯព្រះនាងមាគណ្ឌិយាជ្រាបថា ព្រះសាស្តាយាងមក ទើបឲ្យហៅពួកអ្នកលេង អ្នកកាត់ប្រហោងមកហើយ ឲ្យឈ្នួលដល់អ្នកលេងទាំងនោះ ត្រាស់ថា ពួកឯងចូរជេរព្រះគោតមដោយទំនងយ៉ាងនេះ

ហើយបញ្ជូនទៅ ។ អ្នកលេងទាំងនោះក៏ជេរព្រះសាស្ដា មួយអន្ទើដោយ ភិក្ខុសង្ឃ ក្នុងកាលដែលទ្រង់យាងចូលក្នុងស្រុក ដោយពាក្យសម្រាប់ជេរ មាន បែបផ្សេងៗ ។ ព្រះអានន្ទក្រាបទូលព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន យើងមិនគួរនៅក្នុងទីដែលគេជេរបែបនេះ គួរទៅនគរដទៃ ។ ព្រះមានព្រះភាគ ត្រាស់ថា ម្នាលអានន្ទ ធម្មតាព្រះតថាគតមិនញាប់ញ័រដោយលោកធម៌ ៨ ប្រការ សំឡេងជេរនេះ នឹងមិនប្រព្រឹត្តទៅលើស ៧ ថ្ងៃឡើយ ទណ្ឌៈណា មួយនឹងធ្លាក់លើពួកអ្នកជេរនោះឯង អ្នកកុំត្រិះរិះថ្វីឡើយ ។ ឯសេដ្ឋីទាំង ៣ ក្នុងនគរនោះ ទូលឲ្យព្រះមានព្រះភាគយាងចូលទៅដោយសក្ការៈដ៏ធំ ថ្វាយ មហាទាន ។ សេដ្ឋីទាំងនោះកំពុងថ្វាយទានជាប់គ្នាទៅ ក៏កន្លងកាលទៅមួយ ខែ គ្រានោះ សេដ្ឋីទាំងនោះក៏ត្រិះរិះយ៉ាងនេះថា ធម្មតាព្រះពុទ្ធទាំងឡាយ ទ្រង់ កើតមកដើម្បីអនុគ្រោះលោកទាំងពួង អញនឹងឲ្យឱកាសដល់មនុស្សដទៃខ្លះ ។ ទើបសេដ្ឋីក្រុងកោសម្ពីនោះ ឲ្យឱកាសដល់ប្រជាជន តាំងអំពីនោះមក ទើប អ្នកក្រុងទាំងឡាយថ្វាយមហាទាន ដោយរៀបចំជាខ្សែស្រឡាយមនុស្សរួម ថ្នល់ ខ្សែស្រឡាយមនុស្សរួមគណៈ ។

ថ្ងៃមួយ ព្រះសាស្ដា មានភិក្ខុសង្ឃចោមរោម ក៏ប្រថាប់គង់ក្នុងផ្ទះ របស់មេជាងអ្នកក្រងផ្កា ។ ខណៈនោះ នាងខុជ្ជុត្តរាស្រីបម្រើរបស់ព្រះនាង សាមាវតី នាំកហាបណៈ ៨ ទៅកាន់ផ្ទះនោះ ដើម្បីផ្កា ។ នាយមាលាការ ឃើញនាង ក៏ពោលថា នែឧត្តរា ខ្ញុំមិនមានពេលធ្វើផ្កាឲ្យនាងទេ ខ្ញុំអង្គាសភិក្ខុ សង្ឃ មានព្រះពុទ្ធជាប្រធាន ចូរនាងធ្វើជាសម្លាញ់ក្នុងការអង្គាសផងចុះ ។

ដោយអាការយ៉ាងនេះ តាំងអំពីនេះទៅ នាងក៏ផុតចាកការខ្វល់ខ្វាយ ទទួលបម្រើអ្នកដទៃ ។ បន្ទាប់អំពីនោះ នាងខុជ្ជុត្តរាបរិភោគអាហារដែលខ្លួនបានហើយ ក៏ធ្វើការខ្វល់ខ្វាយក្នុងរោងអាហារ ដើម្បីព្រះសម្ពុទ្ធ ។ នាងរៀនធម៌ដែលព្រះសាស្តាត្រាស់ដោយអំណាចឧបនិសន្នកថាបានទាំងអស់ លុះស្តាប់អនុមោទនាហើយ ក៏តាំងនៅក្នុងសោតាបត្តិផល នាងឲ្យកហាបណៈ ៤ ក្នុងថ្ងៃដទៃៗ ទទួលផ្កាទាំងឡាយ ហើយក៏ទៅ តែក្នុងថ្ងៃនោះ មិនកើតចិត្តគិតចង់បានក្នុងទ្រព្យអ្នកដទៃឡើយ ព្រោះជាអ្នកឃើញសច្ចៈហើយ ទើបឲ្យទាំង ៨ កហាបណៈ ហើយដាក់ផ្កាពេញកំប្រោង នាំទៅកាន់សម្នាក់ព្រះនាងសាមាវតី ។ លំដាប់នោះ ព្រះនាងត្រាស់សួរនាងថា នែឧត្តរា ក្នុងថ្ងៃមុនៗ នាងនាំផ្កាមកមិនច្រើនឡើយ តែថ្ងៃនេះ ផ្កាច្រើន ព្រះរាជារបស់យើងទ្រង់ជ្រះថ្លាក្រៃលែងឡើងឬ ។ នាងមិនបិទបាំងកម្មដែលខ្លួនធ្វើអំពីមុន ព្រោះជាអ្នកមិនពោលកុហក ប្រាប់រឿងទាំងអស់ហើយ កាលឆ្លើយនឹងពាក្យសួរថា ព្រោះហេតុអ្វី ទើបថ្ងៃនេះនាំមកច្រើន ទើបពោលយ៉ាងនេះថា ថ្ងៃនេះ ខ្ញុំស្តាប់ធម៌របស់ព្រះទសពល ធ្វើឲ្យជាក់ច្បាស់នូវអមតធម៌ហើយ ហេតុនោះទើបខ្ញុំមិនកុហក ព្រះនាងម្ចាស់ ។ ស្ត្រីទាំងឡាយស្តាប់ពាក្យនោះហើយពោលថា នែឧត្តរា ចូរនាងឲ្យអមតធម៌ ដែលនាងបានហើយ ដល់ពួកខ្ញុំផងហើយនាំគ្នាលាដៃចេញ សូមគ្រប់ៗ គ្នា ។ ទើបនាងពោលថា នែនាងទាំងឡាយ ឲ្យរបៀបនោះមិនបានទេ តែខ្ញុំនឹងសម្តែងធម៌ដល់នាង តាមទំនងដែលព្រះសាស្តាត្រាស់ហើយ ។ កាលហេតុរបស់ខ្លួនមាន ពួកនាងនឹងបានធម៌

នោះ ។ ស្រ្តីទាំងនោះពោលថា នែឧត្តរា បើយ៉ាងនោះ ចូរពោលចុះ ។ នាង ពោលថា ពោលយ៉ាងនោះមិនបានទេ សូមរៀបចំអាសនៈខ្ពស់ដល់ខ្ញុំ ពួកនាងអង្គុយអាសនៈទាប ។ ស្រីទាំង ៥០០ នាក់នោះ ក៏ឲ្យអាសនៈដែលខ្ពស់ដល់នាងខុជ្ជុត្តរា ឯខ្លួនឯង អង្គុយអាសនៈទាប ។ នាងខុជ្ជុត្តរាតាំងនៅក្នុងសេក្ខប្បដិសម្ភិទា សម្តែងធម៌ដល់ស្ត្រីទាំងនោះ ។ ចប់ទេសនា ស្ត្រីទាំងអស់មានព្រះនាងសាមាវតីជាប្រធាន ក៏តាំងនៅក្នុងសោតាបត្តិផល ។ តាំងអំពីនោះមក ស្ត្រីទាំងនោះឈប់ឲ្យនាងខុជ្ជុត្តរាធ្វើនាទីជាអ្នកបម្រើ ហើយពោលថា នាងទៅស្តាប់ធម្មកថារបស់ព្រះសាស្តា ហើយនាំមកសម្តែងឲ្យពួកយើងស្តាប់ចុះ ។ តាំងអំពីនោះមក នាងខុជ្ជុត្តរាក៏បានធ្វើយ៉ាងនោះ ។

សួរថា ព្រោះហេតុអ្វី ទើបនាងខុជ្ជុត្តរានេះកើតជាទាសី ឆ្លើយថា បានឮមកថា នាងខុជ្ជុត្តរានេះ ក្នុងសាសនាព្រះពុទ្ធព្រះនាមកស្សបៈ បានឲ្យសាមណេរីមួយរូបធ្វើការបម្រើខ្លួន ដោយកម្មនោះ ទើបនាងកើតជាទាសីរបស់អ្នកដទៃដល់ទៅ ៥០០ ជាតិ ។ សួរថា ព្រោះហេតុអ្វី ទើបជាស្រីគម ឆ្លើយថា បានឮថា កាលព្រះពុទ្ធមិនទាន់កើតឡើង នាងនៅក្នុងរាជនិវេសន៍របស់ព្រះបាទក្រុងពារាណសី ឃើញព្រះបច្ចេកពុទ្ធមួយអង្គប្រចាំរាជត្រកូល គមខ្នង ទើបធ្វើការចំអកចំពោះមុខដល់ពួកស្រីដែលនៅជាមួយខ្លួន ដើរធ្វើអាការជាមនុស្សគម ។ ព្រោះហេតុនោះ ទើបនាងកើតជាស្រីគម ។ សួរថា នាងធ្វើបុណ្យអ្វី ទើបជាអ្នកមានបញ្ញា ឆ្លើយថា បានឮថា កាលព្រះពុទ្ធមិនទាន់កើតឡើង នាងកើតហើយ ក្នុងព្រះរាជនិវេសន៍របស់ព្រះបាទក្រុងពារាណសី ឃើញព្រះ

បច្ចេកពុទ្ធ ៨ អង្គ កាន់បាត្រដែលពេញដោយបាយាសក្តៅអំពីនិវេសន៍ដើរទៅ ពោលថា បពិត្រលោកម្ចាស់ សូមលោកម្ចាស់ឈប់ត្រង់នោះសិន រួចសឹមទៅ ទើបដោះកងដៃមាស[១] ៨ កងប្រគេនទៅ ដោយផលនៃកម្មនោះ ទើបនាងជាអ្នកមានបញ្ញា ។

គ្រានោះឯង ស្ត្រី ៥០០ ជាបរិវាររបស់នាងសាមាវតី ចាក់ធ្លុះសច្ចៈហើយ ក៏មិនបានទៅសម្នាក់របស់ព្រះសាស្តា គាល់ព្រះពុទ្ធតាមកាលដែលសមគួរឡើយ ព្រោះព្រះរាជាទ្រង់មិនមានសទ្ធា ។ ព្រោះហេតុនោះ កាលព្រះទសពលទ្រង់ព្រះរាជដំណើរតាមមាគ៌ា កាលបង្អួចទាំងឡាយមិនគ្រប់គ្រាន់ ស្រីទាំងនោះ ក៏ចោះប្រហោងក្នុងបន្ទប់របស់ខ្លួន មើលព្រះសាស្តា ។

ថ្ងៃមួយ ព្រះនាងមាគណ្ឌិយាធ្វើដំណើរអំពីប្រាសាទរបស់នាង ទៅកាន់លំនៅរបស់ស្ត្រីទាំងនោះ ឃើញប្រហោងនៃបន្ទប់ ទើបសួរថា នេះប្រហោងអ្វី ស្ត្រីទាំងនោះ មិនដឹងរឿងការចងអាឃាតក្នុងព្រះសាស្តារបស់ព្រះនាងមាគណ្ឌិយា ទើបទូលថា ព្រះសាស្តាយាងមកព្រះនគរនេះ ពួកខ្ញុំឈរត្រង់នោះ នឹងឃើញនឹងបូជាព្រះសាស្តា នាងមាគណ្ឌិយគិតថា ស្ត្រីទាំងនេះ ជាឧបដ្ឋាយិការបស់ព្រះសមណគោតមនោះ អញនឹងដឹងកិច្ចដែលគប្បីធ្វើដល់ស្រីទាំងនេះ ហើយទៅក្រាបទូលព្រះរាជាថា បពិត្រមហារាជ ស្ត្រីទាំងនេះ មួយអន្លើនឹងព្រះនាងសាមាវតីប្រាថ្នានឹងចេញទៅខាងក្រៅ ពួកនាងនឹងធ្វើជីវិតរបស់ព្រះអង្គឲ្យទិវង្គតក្នុង ២-៣ ថ្ងៃទៀត ។ ព្រះរាជាទ្រង់មិនជឿថា ស្ត្រីទាំងនោះនឹងធ្វើយ៉ាង

១- ក្នុងទីខ្លះថាកងដៃភ្លុក ។

នោះ ។ កាលព្រះនាងមាគណ្ឌិយាទូលទៀត ក៏ទ្រង់មិនជឿនោះឯង ។ គ្រានោះ កាលព្រះនាងក្រាបទូលអស់ ៣ ដង ព្រះរាជាក៏នៅតែមិនជឿ ទើបព្រះនាងមាគណ្ឌិយាក្រាបទូលថា បពិត្រព្រះមហារាជ បើទ្រង់មិនជឿ សូមទ្រង់យាងទៅលំនៅរបស់ស្រីទាំងនោះ ហើយពិនិត្យមើល ។ ព្រះរាជាយាងទៅឃើញប្រហោងក្នុងបន្ទប់ទាំងឡាយ ត្រាស់សួរថា នេះប្រហោងអ្វី ស្រីទាំងនោះក្រាបទូលសេចក្តីនោះ ទ្រង់ក៏មិនក្រោធខឹងនឹងស្រីទាំងនោះ មិនត្រាស់អ្វីឡើយ គ្រាន់តែប្រាប់ឲ្យបិទប្រហោងទាំងនោះប៉ុណ្ណោះ។ ព្រះនាងមាគណ្ឌិយាត្រាស់ថា ព្រះនាងសាមាវតី និងបរិវារមិនជាប់ជំពាក់ ឬស្រឡាញ់ក្នុងព្រះអង្គកាលបន្តួចមិនគ្រប់គ្រាន់ ទើបចោះប្រហោងទាំងនោះ ធ្វើឱកាសសម្លឹងមើលព្រះគោតមដែលយាងទៅតាមមាគ៌ា ។ តាំងអំពីនោះមក ទើបព្រះរាជាឲ្យធ្វើបង្អួចក្នែកក្រួចក្នុងប្រាសាទរបស់ស្រីទាំងនោះ ។

ព្រះនាងមាគណ្ឌិយានោះ មិនអាចធ្វើព្រះរាជាឲ្យពិរោធដោយហេតុនោះបាន ទើបក្រាបទូលថា បពិត្រទេវៈ ស្ត្រីទាំងនោះមានសេចក្តីស្រឡាញ់ ឬមិនមានសេចក្តីស្រឡាញ់ក្នុងទ្រង់ យើងនឹងដឹងទាំងអស់គ្នា សូមទ្រង់បញ្ជូនមាន់ ៨ ទៅឲ្យស្ត្រីទាំងនោះ អាំងថ្វាយព្រះអង្គចុះ ។ ព្រះរាជាទ្រង់ស្តាប់ពាក្យនោះហើយ បញ្ជាថា ចូរអាំងមាន់ទាំងនេះបញ្ជូនមក ។ ទ្រង់បញ្ជូនមាន់ ៨ ដល់នាងសាមាវតីអរិយសាវិកា ដែលជាសោតាបន្ន ដឹងថា មាន់នៅរស់នឹងអាំងបានដូចម្តេច ទើបបដិសេធថា កុំឡើយ ខ្ញុំមិនប្រាថ្នាសូម្បីតែយកដៃប៉ះ ។ ព្រះនាងមាគណ្ឌិយាក្រាបទូលថា សេចក្តីនោះសូមលើកទុកចុះ សូមទ្រង់ឲ្យ

មាន់ទាំងនេះ ដើម្បីអាំងថ្វាយព្រះគោតម ។ ព្រះរាជាក៏ទ្រង់ធ្វើយ៉ាងនោះ ។ ព្រះនាងមាគណ្ឌិយាឲ្យមនុស្សសម្លាប់មាន់ក្នុងរវាងផ្លូវហើយ បញ្ជូនទៅដោយប្រាប់ថា សូមព្រះនាងសាមាវតីសម្លាប់មាន់ទាំងនេះ ថ្វាយព្រះគោតម ។ ព្រះនាងសាមាវតីនោះ ព្រោះយល់ព្រះហឫទ័យយ៉ាងនោះ និងព្រោះមានព្រះហឫទ័យទោរទន់ចំពោះព្រះទសពល ទើបសម្លាប់បញ្ជូនទៅថ្វាយដល់ព្រះទសពល ។ ព្រះនាងមាគណ្ឌិយាទូលថា បពិត្រមហារាជ សូមទតចុះ ដូច្នេះក៏មិនអាចធ្វើព្រះរាជាឲ្យពិរោធបាន ដោយហេតុមានប្រមាណប៉ុណ្ណោះឡើយ ។

ព្រះបាទឧទេននេះ ប្រថាប់នៅក្នុងលំនៅរបស់បណ្ដានាងទេវីទាំងនោះមួយអង្គៗ ៧ ថ្ងៃ ឯព្រះនាងមាគណ្ឌិយានេះ ឲ្យមនុស្សយកកូនពស់វែកមួយដាក់ក្នុងបំពង់ឫស្សី ទុកក្នុងលំនៅរបស់ខ្លួន ។ ព្រះរាជាយាងទៅទីណាមួយក៏ទ្រង់កាន់ពិណាឈ្មោះហត្ថិកន្តៈ ។ កាលព្រះរាជាយាងមករកខ្លួន ព្រះនាងមាគណ្ឌិយាក៏ដាក់ពស់នោះក្នុងពិណា បិទប្រហោង ។ ហើយក្រាបទូលព្រះរាជា ក្នុងកាលដែលទ្រង់ទៅរកនាងសាមាវតីថា ឈ្មោះថា នាងសាមាវតីនៅខាងព្រះសមណគោតម មិននៅខាងព្រះអង្គឡើយ ធ្វើការណាមួយ ក៏គិតតែឲ្យទោសព្រះអង្គប៉ុណ្ណោះ សូមទ្រង់កុំប្រមាទ ។ ព្រះរាជាទ្រង់កាន់យកទីលំនៅរបស់ព្រះនាងសាមាវតី ប្រថាប់ ៧ ថ្ងៃ ហើយយាងកាន់និវេសន៍របស់ព្រះនាង មាគណ្ឌិយា ៧ ថ្ងៃ ។ កាលព្រះរាជាកំពុងយាងមក ព្រះនាងមាគណ្ឌិយាធ្វើជាពោលថា បពិត្រមហារាជ ព្រះនាងសាមាវតី មិនចាប់កំហុសរបស់ព្រះអង្គទេឬ ទទួលពិណាអំពីព្រះហស្ដរបស់ព្រះរាជាមកអង្រួន

ត្រាស់ថា បពិត្រមហារាជ អ្វីនៅក្នុងនេះ ហើយធ្វើឱកាសឲ្យពស់ចេញទៅ ស្រែកថា ពស់នៅខាងក្នុង ហើយបោលពិណាគេចទៅ ។ ពេលនោះ ព្រះរាជាទ្រង់ភ័យខ្លាច ដោយសេចក្ដីក្រេវក្រោធ ដូចភ្លើងឆេះព្រៃឫស្សី ដូច្នោះ និងដូចចង្ក្រានឆេះអំបិល ដូច្នោះ ប្រាប់ថា ចូរហៅសាមាវតី និងបរិវារមក ។ ពួករាជបុរសក៏ទៅហៅ ។ ព្រះនាងសាមាវតី នាងជ្រាបថា ព្រះរាជាពិរោធ ទើបឲ្យសញ្ញាដល់ពួកស្ត្រីទាំងនោះថា ព្រះរាជាទ្រង់បំណងសម្លាប់ពួកយើង ទើបហៅមក ថ្ងៃនេះ ពួកយើងចូរផ្សាយមេត្តាចំពោះព្រះរាជាអស់ថ្ងៃនេះ ។ ព្រះរាជាទ្រង់ហៅស្រីទាំងនោះឲ្យឈរតម្រៀបគ្នា ហើយទ្រង់ចាប់មហាធ្នូ ទ្រង់ស៊កព្រួញដែលលាបដោយថ្នាំពិស ឈរទាញធ្នូពេញកម្លាំង ។ ខណៈនោះ ស្រីទាំងនោះ មានព្រះនាងសាមាវតីជាប្រធាន នាំគ្នាផ្សាយមេត្តាចំពោះ ។ ព្រះរាជាក៏មិនអាចលែងធ្នូឲ្យរបូតទៅបាន ។ ញើសហូរចេញអំពីព្រះកាយៗ រីង ទឹកមាត់ហូរចេញអំពីព្រះឱស្ឋ ទ្រង់មិនឃើញទីពឹងដែលគប្បីបាន ។ គ្រានោះ ព្រះនាងសាមាវតីក្រាបទូលព្រះរាជាថា បពិត្រមហារាជ ទ្រង់លំបាកឬ ព្រះរាជាត្រាស់ថា ពិតហើយទេវី ខ្ញុំលំបាកណាស់ សូមនាងជាទីពឹងរបស់ខ្ញុំចុះ ព្រះនាងសាមាវតីក្រាបទូលថា សាធុ សូមទ្រង់ដាក់ធ្នូចុះ ។ ព្រះរាជាក៏ទ្រង់បដិបត្តិតាម ព្រះនាងអធិដ្ឋានថា សូមព្រួញរបូតអំពីដៃរបស់ព្រះរាជា ខណៈនោះ ព្រួញក៏របូត ។ សម័យនោះឯង ព្រះរាជាទ្រង់មុជចុះទៅក្នុងទឹក ឡើងមកទាំងព្រះកេសាសើម ព្រះភូសាសើម ក្រាបចុះទៀបបាទានាងសាមាវតី ត្រាស់ថា ចូរអត់ទោសឲ្យខ្ញុំចុះ ខ្ញុំមិនបានពិចារណា ក៏ធ្វើកម្មនោះ

តាមពាក្យរបស់ជនដែលធ្វើឲ្យយើងបែកគ្នា ។ ព្រះនាងត្រាស់ថា បពិត្រទេវៈ ខ្ញុំអត់ទោសថ្វាយព្រះអង្គ ។ ព្រះរាជាត្រាស់ថា សេចក្តីនេះ ជាការអត់ទោសឲ្យខ្ញុំហើយ ។ ហើយត្រាស់ទៀតថា តាំងអំពីថ្ងៃនេះតទៅ ពួកនាងថ្វាយទានដល់ព្រះទសពលបានតាមដែលត្រូវការ ។ ខាងក្រោយភត្ត ទៅកាន់វិហារ ស្តាប់ធម្មកថាបាន ខ្ញុំនឹងឲ្យការរក្សាដល់នាង ។ ព្រះនាងក្រាបទូលថា បពិត្រទេវៈ បើដូច្នោះ តាំងអំពីថ្ងៃនេះទៅ សូមទ្រង់សំណូមពរភិក្ខុមួយអង្គមកទូន្មានធម៌ដល់ពួកខ្ញុំចុះ ។ ព្រះរាជាទៅកាន់សម្នាក់ព្រះសាស្តា កាលទ្រង់សំណូមពរ ទ្រង់ក៏សូមព្រះអានន្ទត្ថេរ ។ ចាប់តាំងអំពីនោះ ស្ត្រីទាំងនោះឲ្យនិមន្តព្រះថេរៈមកហើយ ធ្វើសក្ការៈគោរពរាប់អាន រៀនធម៌ក្នុងសម្នាក់ព្រះថេរៈ ក្នុងកាលដែលលោកឆាន់ស្រេចហើយ ។ ថ្ងៃមួយ ស្រីទាំងនោះជ្រះថ្លាក្នុងអនុមោទនារបស់ព្រះថេរៈ បានថ្វាយឧត្តរាសង្គ ៥០០ ផ្ទាំងដល់ព្រះថេរៈ ។ បានឮថា ក្នុងជាតិមុន ព្រះថេរៈបានថ្វាយចម្រៀកសំពត់ប៉ុនបាតដៃមួយអន្ទើដោយម្ជុលមួយ ដល់ព្រះបច្ចេកពុទ្ធមួយព្រះអង្គ ក្នុងចីវរកាល ។ ដោយផលនៃម្ជុល ព្រះថេរៈនោះបានជាអ្នកមានបញ្ញាច្រើនក្នុងអត្តភាពនេះ និងបានសំពត់ ៥០០ តាមទំនងនេះ ដោយផលនៃចម្រៀកសំពត់ ។ តាំងអំពីនោះ ព្រះនាងមាគណ្ឌិយា មិនឃើញកិច្ចដែលគប្បីធ្វើដទៃ ទើបក្រាបទូលថា បពិត្រមហារាជ ពួកយើងទៅព្រះឧទ្យានជាមួយគ្នាចុះ ព្រះរាជាទ្រង់អនុញ្ញាតថា ល្អណាស់ ទេវី ដូច្នេះហើយ ទើបព្រះនាងហៅឪពុកមាមកប្រាប់ថា ពេលពួកខ្ញុំទៅឧទ្យាន ចូរទៅកាន់លំនៅរបស់ព្រះនាងសាមាវតី ហើយបន្ទាំង

នាងសាមាវតី ព្រមទាំងបរិវារខាងក្នុង ប្រាប់ថា ជាព្រះតម្រាស់របស់ព្រះរាជា ហើយបិទទ្វារឲ្យជាប់ យកចំបើងមកដាក់ ហើយដុតនិវេសន៍ចោល នាយមាគណ្ឌិយាស្តាប់ពាក្យព្រះនាងហើយ ក៏ធ្វើតាមព្រះនាងប្រាប់គ្រប់ប្រការ ។ ថ្ងៃនោះ ស្ត្រីទាំងអស់មិនអាចចូលសមាបត្តិបាន ព្រោះអានុភាពរបស់ឧបបីឡកកម្មដែលធ្វើទុកក្នុងជាតិមុន ក៏ឆេះជាគំនរផេះព្រមគ្នាទាំងអស់ ពួកទាហានរក្សាស្ត្រីទាំងនោះក៏ទៅគាល់ ក្រាបទូលថា បពិត្រទេវៈ មនុស្សទាំងឡាយបានធ្វើកម្មឈ្មោះនេះ ។ ព្រះរាជាទ្រង់សាកសួរថា អ្នកណាធ្វើ ក៏ទ្រង់ដឹងថាព្រះនាងមាគណ្ឌិយាប្រើឲ្យមនុស្សធ្វើ ទើបហៅព្រះនាងមក ត្រាស់ថា នាងធ្វើកម្មបានល្អហើយ នាងធ្វើកម្មដែលខ្ញុំកំពុងធ្វើ នែនាងដ៏ប្រសើរ ការព្យាយាមដើម្បីសម្លាប់ខ្ញុំ ដែលកើតឡើង នឹងកើតឡើងហើយ ត្រូវទម្លាយហើយ ខ្ញុំនឹងឲ្យសម្បត្តិដល់នាង នាងចូរហៅញាតិរបស់នាងមក ។ ព្រះនាងស្តាប់ព្រះរាជតម្រាស់ហើយ ក៏ឲ្យហៅមនុស្សដែលមិនមែនញាតិ ធ្វើឲ្យជាញាតិមកហើយ ។ ព្រះរាជាទ្រង់ជ្រាបថា មនុស្សទាំងអស់ថា មនុស្សទាំងអស់ ប្រជុំគ្នាព្រមហើយ ក៏ឲ្យជីករណ្តៅកប់មនុស្សទាំងនោះត្រឹម-ក ត្រង់លានព្រះរាជវាំង ហើយឲ្យទម្លាយក្បាលដែលផុសឡើងមកដោយនង្គ័លដែកដ៏ធំ ឲ្យកាត់ព្រះនាងមាគណ្ឌិយាឲ្យជាកំណាត់តូចធំ ចៀនក្នុងខ្ទះនំ ។

សួរថា កម្មដែលព្រះនាងសាមាវតី និងបរិវារត្រូវឆេះក្នុងភ្លើង ព្រោះកម្មដូចម្តេច ឆ្លើយថា បានឮមកថា ព្រះនាងសាមាវតីនោះ កាលព្រះពុទ្ធមិនទាន់កើតឡើង លែងទឹកក្នុងស្ទឹងគង្គាជាមួយស្ត្រី ៥០០ នោះឯង ឈរខាង

ក្រៅកំពង់ទឹក ក៏រវោ ឃើញបណ្ណសាលារបស់ព្រះបច្ចេកពុទ្ធក្នុងទីមិនឆ្ងាយ មិនពិនិត្យមើលខាងក្នុង ហើយនាំគ្នាដុតភ្លើងអាំង ខាងក្នុងបណ្ណសាលា ព្រះបច្ចេកពុទ្ធគង់ចូលសមាបត្តិ ។ ស្ត្រីទាំងនោះ កាលអណ្តាតភ្លើងថមថយ ទើបឃើញព្រះបច្ចេកពុទ្ធ គិតថា ពួកយើងធ្វើកម្មអ្វីហ្ន៎ ព្រះបច្ចេកពុទ្ធអង្គនេះ ជាភិក្ខុប្រចាំរាជត្រកូល ព្រះរាជាទ្រង់ឃើញហេតុនេះ ទ្រង់នឹងពិន័យពួកយើង ដូច្នេះ គួរពួកយើងធ្វើឈាបនកិច្ចព្រះអង្គឲ្យសម្រេចរៀបរយទៅចុះ ទើបដាក់ឧសដទៃៗ ដុតភ្លើង កាលអណ្តាតភ្លើងថមថយ ព្រះបច្ចេកពុទ្ធចេញអំពីសមាបត្តិ រលាស់ចីវរហើយ ហោះទៅកាន់អាកាស ទាំងដែលស្ត្រីទាំងនោះ កំពុងឃើញនោះឯង ។ ស្រីទាំងនោះឆេះក្នុងនរកដោយកម្មនោះ ហើយក៏ដល់នូវការវិនាស គ្រានេះ ដោយវិបាកកម្មដែលសេសសល់ ។ ក្នុងបរិស័ទ ៤ កើតការសន្ទនាឡើងថា នាងខុជ្ជុត្តរាដែលជាពហូសូត តាំងនៅក្នុងអត្តភាពជាស្ត្រីពោលធម៌ដល់ស្ត្រី ៥០០ នាក់ ឲ្យតាំងនៅក្នុងសោតាបត្តិផល ឯព្រះនាងសាមាវតី ផ្សាយមេត្តាឃាត់ព្រួញដែលព្រះរាជាទ្រង់ពិរោធខ្ជួនបាន មហាជនក៏ពោលគុណរបស់ព្រះនាង ។ រឿងកើតឡើងយ៉ាងនេះ ។ បន្ទាប់មកព្រះសាស្តាប្រថាប់គង់ក្នុងជេតពនវិហារ ទ្រង់ធ្វើហេតុនោះឯង ឲ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់ស្ថាបនានាងខុជ្ជុត្តរា ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងឧបាសិកាអរិយសាវិកា ដែលជាពហូសូត ។ ទ្រង់ស្ថាបនាព្រះនាងសាមាវតីទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងឧបាសិកា ដែលមានប្រក្រតីនៅដោយមេត្តា ដូច្នេះ ។៚

# អដ្ឋកថា សូត្រទី ៥

# ប្រវត្តិ នាងឧត្តរា នន្ទមាតា

ក្នុងសូត្រទី ៥ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **ឈាយីនំ** លោកសម្តែងថា នាងឧត្តរានន្ទមាតា ជាលំពូលជាងពួកឧបាសិកា ដែលត្រេកអរក្នុងឈាន ។

បានឮមកថា នាងឧត្តរានោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី ស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ ក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាសាវិកា ដែលជាអ្នកត្រេកអរក្នុងឈាន ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ ។ នាងអន្ទោលក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ បដិសន្ធិក្នុងគភ៌របស់ភរិយាបុណ្ណសេដ្ឋី អាស្រ័យសុមនសេដ្ឋី ក្នុងក្រុងរាជគ្រឹះ ។ មាតាបិតាដាក់ឈ្មោះថា ឧត្តរា ។ ក្នុងថ្ងៃធ្វើងនក្ខត្តឫក្សមួយ រាជគហសេដ្ឋីហៅនាយបុណ្ណៈមក ពោលថា នៃបុណ្ណៈ នក្ខត្តឫក្ស ឬឧបោសថនឹងធ្វើអ្វីឲ្យដល់អ្នកក្រីក្របាន កាលបើដូច្នោះអ្នកចូរប្រាប់មកថា អ្នកនឹងទទួលទ្រព្យថ្លៃឈ្នួលក្នុងថ្ងៃលេងនក្ខត្តឫក្ស ឬលេងនក្ខត្តឫក្ស ឬនាំគោមានកម្លាំង ផាល និង នង្គ័លទៅភ្ជួរស្រែ នាយបុណ្ណៈពោលថា លោកម្ចាស់ ខ្ញុំនឹងពិភាក្សាជាមួយប្រពន្ធខ្ញុំសិន ទើបដឹងហើយប្រាប់រឿងនោះដល់ភរិយា ។ ភរិយាពោលថា ធម្មតាសេដ្ឋីជាឥស្សរជន វាចារបស់គាត់ពោលជាមួយអ្នក រមែងប្រពៃ ចំណែកអ្នកកុំលះបង់ការធ្វើស្រែរបស់ខ្លួនឡើយ ។ នាយបុណ្ណៈនោះស្តាប់ពាក្យភរិយាហើយ ក៏ទៅដើម្បី

នាំគ្រឿងឧបករណ៍ទៅភ្ជួរស្រែ ។ ថ្ងៃនោះ ព្រះសារីបុត្រចេញអំពីនិរោធ-សមាបត្តិ គិតថា ថ្ងៃនេះ អាត្មាអញគួរធ្វើការសង្គ្រោះអ្នកណា ក៏ឃើញឧបនិស្ស័យរបស់នាយបុណ្ណៈនេះ ក្នុងពេលស្វែងរកភិក្ខា កាន់បាត្រ និងចីវរទៅកាន់ទីដែលនាយបុណ្ណៈភ្ជួរស្រែ បង្ហាញខ្លួនក្នុងទីមិនឆ្ងាយ ។ នាយបុណ្ណៈឃើញព្រះថេរៈ ក៏ឈប់ភ្ជួរ ចូលទៅរកព្រះថេរៈ ថ្វាយបង្គំដោយបញ្ចង្គប្រតិស្ឋាន ។ ព្រះថេរៈសម្លឹងមើលគាត់ ហើយសួរដល់ទឹកដែលប្រើបាន ។ គាត់គិតថា លោកម្ចាស់អង្គនេះប្រហែលជាត្រូវការខ្ពុរមាត់ ទើបប្រញាប់ទៅអំពីទីនោះ នាំឈើស្ទន់ ធ្វើឲ្យជាកប្បិយ សមគួរហើយ ប្រគេនព្រះថេរៈ កាលព្រះថេរៈកំពុងទំពាឈើស្ទន់ ក៏នាំធម្មក្រក ឆ្នាំងត្រងទឹក និងបាត្រចេញហើយ ដាក់ទឹកពេញ ហើយនាំមក ។ ព្រះថេរៈក៏ខ្ពុរមាត់ និមន្តស្វែងរកអាហារ ។

នាយបុណ្ណៈគិតថា ព្រះថេរៈក្នុងថ្ងៃដទៃៗ មិននិមន្តផ្លូវនេះ តែថ្ងៃនេះប្រហែលជានិមន្តដើម្បីសង្គ្រោះអញ ឱហ្ន៎! ភរិយារបស់អញគប្បីដាក់អាហារដែលនាំមកឲ្យអញក្នុងបាត្រព្រះថេរៈ ។ គ្រានោះ ភរិយារបស់គាត់គិតថា ថ្ងៃនេះ ជាថ្ងៃនក្ខត្តឫក្ស ទើបរៀបចំរបស់ទំពា របស់បរិភោគ ដោយទំនង់ដែលខ្លួនបាន កាន់ទៅអំពីព្រលឹម មកកាន់ទីដែលប្តីភ្ជួរស្រែ ក្នុងរវាងផ្លូវ ជួបព្រះថេរៈ គិតថា អញជួបព្រះថេរៈក្នុងថ្ងៃដទៃៗ ទេយ្យធម៌មិនមាន កាលមានទេយ្យធម៌ អញក៏មិនជួបលោកម្ចាស់ តែថ្ងៃនេះ ទាំង ២ យ៉ាងមានព្រមហើយ អញនឹងចាត់ចែងចំណែករបស់ប្តីនាំមកជាថ្មី នឹងប្រគេនអាហារ

ចំណែកនេះដល់ព្រះថេរៈជាមុន ធ្វើទានឲ្យប្រកបដោយចេតនាទាំង ៣ ហើយ ដាក់ភោជនចូលក្នុងបាត្រព្រះសារីបុត្រ ហើយពោលថា ខ្ញុំសូមរួចចាកជីវិតក្រីក្រក្នុងលោកនេះ ដោយទានយ៉ាងនេះចុះ ។ ព្រះថេរៈក៏ធ្វើអនុមោទនាដល់នាងថា សូមអធ្យាស្រ័យរបស់នាងពេញចុះ ។ ត្រឡប់អំពីទីនោះហើយ ក៏ទៅវិហារ ។ នាងក៏ត្រឡប់មកផ្ទះម្តងទៀត ហើយរៀបចំអាហារសម្រាប់ប្តី នាំទៅកាន់ទីដែលប្តីភ្ជួរស្រែ ខ្លាចប្តីក្រោធ ទើបពោលថា នែអ្នក ថ្ងៃនេះសូមអត់ធ្មត់មួយថ្ងៃចុះ ។ បុណ្ណៈសួរថា ព្រោះហេតុអ្វី នាងឆ្លើយថា ថ្ងៃនេះខ្ញុំកំពុងនាំអាហារមកសម្រាប់អ្នក រវាងផ្លូវជួបព្រះថេរៈ ទើបដាក់អាហារចំណែកអ្នកក្នុងបាត្រព្រះថេរៈ ត្រឡប់ទៅផ្ទះម្តងទៀត ចម្អិនអាហារ ហើយនាំមកក្នុងកាលឥឡូវនេះ ។ បុរសនោះពោលថា នាងធ្វើត្រូវចិត្តពិត សូម្បីខ្ញុំក៏ប្រគេនឈើជម្រះ និងទឹកខ្ពុរមាត់ដល់ព្រះថេរៈ អំពីព្រលឹមដែរ ថ្ងៃនេះជាជោគរបស់យើងពិតហ្ន៎ របស់ទាំងអស់ដែលយើងប្រគេនព្រះថេរៈ ក៏កើតជាសម្បត្តិនៃយើងទាំងអស់ ។ ជនទាំង ២ ក៏មានចិត្តដូចគ្នាតែមួយ ។

គ្រានោះ នាយបុណ្ណៈបរិភោគអាហារស្រេចហើយ ក៏យកក្បាលកើយភ្លៅភរិយា ដេកមួយស្របក់ ខណៈនោះ ក៏លក់ទៅ គាត់ដេកលក់បន្តិចទៅ ហើយក៏ភ្ញាក់ឡើង សម្លឹងមើលទីដែលភ្ជួរ មើលហើយមើលទៀត ហាក់ដូចជាពេញទៅដោយផ្កាឈូកធំ ទើបគាត់ពោលនឹងភរិយាថា នែនាង នុ៎ះជាអ្វីហ្ន៎ ថ្ងៃនេះ ទីដែលភ្ជួរនេះប្រាកដជាមាសទៅបាន ។ ភរិយាពោលថា នែអ្នក ថ្ងៃនេះ ព្រោះហត់នឿយអស់មួយថ្ងៃ ប្រហែលជាភ្នែកស្រវាំងក៏ថាបាន ។ បុណ្ណៈ

ពោលថា នែនាង បើនាងមិនជឿ ក៏ចូរមើលឯងចុះ ។ វេលានោះ ភរិយា សម្លឹងមើល ហើយក៏ពោលថា អ្នកនិយាយពិត វាប្រហែលជាយ៉ាងនោះ នាយបុណ្ណៈក្រោកឡើង ចាប់ឈើវាយត្រង់អាចម៍បំណះ ។ ដីអាចម៍បំណះ ហាក់ដូចជាគ្រាប់មូលៗ កប់នៅក្នុងដីអាចម៍បំណះនោះ ។ គាត់ហៅភរិយាមក ពោលថា នែនាង បើអ្នកដទៃៗ ព្រោះពូជ ពូជក៏ឲ្យផលក្នុងកាល ៣-៤ ខែ ចំណែកផលទានដែលឲ្យថ្ងៃនេះ ដោយពូជ គឺសទ្ធា ដែលយើងដាំក្នុងព្រះ សារីបុត្តត្ថេររបស់យើង ។ ក្នុងផ្ទៃដីប្រមាណមួយករីសនេះ មាសទំហំប៉ុនផ្លែ កន្ទួតព្រៃ ឈ្មោះថា មិនមែនមាស មិនមានឡើយ ។ ភរិយាពោលថា ឥឡូវ នេះ យើងនឹងធ្វើដូចម្ដេច ។ នាយបុណ្ណៈពោលថា នែនាង ខ្ញុំមិនអាចនាំ មាសទាំងនេះ ទៅស៊ីបានទេ ហើយដាក់មាសពេញថាស ដែលភរិយានាំមក ទុកក្នុងទីនោះ ឲ្យភរិយានាំទៅ ។ ពួករាជបុរសក្រាបទូលព្រះរាជាថា មនុស្ស ម្នាក់ឈរកាន់ថាសដាក់មាស ។ ព្រះរាជាត្រាស់ឲ្យហៅចូលទៅ ត្រាស់សួរថា នែបា អ្នកបានមកអំពីណា ។ គាត់ក្រាបទូលថា បពិត្រទេវៈ ក្នុងទីដែល ទូលបង្គំភ្ជួរស្រែមួយកន្លែង សូមទ្រង់បញ្ជូនមនុស្សទៅឲ្យជញ្ជូនមាសដែល កើតហើយទាំងអស់មក ព្រះរាជាត្រាស់ថា អ្នកឈ្មោះអ្វី គាត់ទូលថា ទូល បង្គំឈ្មោះបុណ្ណៈ ។ ព្រះរាជាត្រាស់ថា នែអ្នក ចូរទឹមរទេះជញ្ជូនមាសមក អំពីទីដែលនាយបុណ្ណៈភ្ជួរស្រែ ។ ពួករាជបុរសទៅជាមួយពួករទេះ ពោល ថា បុណ្យរបស់ព្រះរាជា កាន់យកដុំមាសទៅ ដុំមាសដែលកាន់យកនោះ ក៏ ក្លាយជាដុំដី ។ រាជបុរសទាំងនោះក្រាបទូលព្រះរាជាៗ ត្រាស់ថា នែបា បើ

ដូច្នោះ ពួកអ្នកចូរទៅ ពោលថា ជាបុណ្យរបស់នាយបុណ្ណៈ ហើយកាន់យកមាស ។ វត្ថុដែលកាន់យកក៏ជាមាសទាំងអស់ ។ រាជបុរសទាំងនោះ ក៏នាំមាសទាំងអស់នោះមកគរទុកត្រង់លានព្រះរាជវាំង កម្ពស់ប្រមាណស្មើចុងត្នោត ។ ព្រះរាជាឲ្យហៅឈ្មួញមក ត្រាស់សួរថា ក្នុងផ្ទះអ្នកណាមានមាសប៉ុណ្ណេះខ្លះ ។ ពួកឈ្មួញក្រាបទូលថា បពិត្រទេវៈ របស់បុគ្គលណាម្នាក់ ក៏មិនមាន ។ ត្រាស់ប្រឹក្សាថា យើងគួរធ្វើអ្វីដល់ម្ចាស់ទ្រព្យទាំងនេះ រាជបុរសក្រាបទូលថា គួរតាំងគាត់ជាធនសេដ្ឋីចុះ ។ ព្រះរាជាត្រាស់ថា បើដូច្នោះពួកអ្នកចូរតែងតាំងបុណ្ណៈ ឈ្មោះថា ធនសេដ្ឋីក្នុងនគរនេះ ។ ហើយព្រះរាជទានរបស់ទាំងអស់នោះដល់នាយបុណ្ណៈនោះប៉ុណ្ណោះ ព្រះរាជទានតំណែងសេដ្ឋីដល់គាត់ក្នុងថ្ងៃនោះឯង សេដ្ឋីនោះ កាលធ្វើមង្គល ក៏បានថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ៧ ថ្ងៃ ក្នុងថ្ងៃទី ៧ កាលព្រះទសពលទ្រង់ធ្វើការអនុមោទនា ក្នុងកត្តទានបុណ្ណសេដ្ឋីក្តី ភរិយាក្តី កូនស្រីក្តី ទាំងអស់ ក៏តាំងនៅក្នុងសោតាបត្តិផល ។

ខាងក្រោយ រាជគហសេដ្ឋីដឹងថា បុណ្ណសេដ្ឋីមានកូនស្រីចម្រើនវ័យហើយ ទើបបញ្ជូនសាសន៍ទៅកាន់ផ្ទះរបស់បុណ្ណសេដ្ឋីនោះ សូមកូនស្រីដើម្បីកូនប្រុសខ្លួន ។ បុណ្ណសេដ្ឋីនោះ ស្តាប់សាសន៍រាជគហសេដ្ឋីនោះហើយ ក៏បញ្ជូនសាសន៍ឆ្លើយតបទៅថា ខ្ញុំមិនឲ្យធីតាទេ ។ ឯសុមនសេដ្ឋី ( រាជគហ-សេដ្ឋី ) បញ្ជូនសាសន៍ទៅថា អ្នកអាស្រ័យផ្ទះខ្ញុំ ឥឡូវនេះ ក៏ក្លាយជាឥស្សរ-ជនភ្លាមៗ ហើយមិនឲ្យធីតាដល់ខ្ញុំឬ ។ បន្ទាប់អំពីនោះ បុណ្ណសេដ្ឋីក៏ឆ្លើយ

ថា លោកពោលដល់តែភាពសេដ្ឋីរបស់លោកមុនប៉ុណ្ណោះ ឈ្មោះថា បុរស លោកមិនគួរកំណត់ថា ត្រូវតែជាយ៉ាងនេះទៅគ្រប់កាលនោះឡើយ សេចក្តីពិត ខ្ញុំអាចទទួលយកពួកបុរស ដែលមានសភាពយ៉ាងនោះ ធ្វើជាទាសៈក៏បាន តែខ្ញុំមិនអាចខ្ពើមរអើមដល់ជាតិ និងគោត្ររបស់អ្នកបានទេ ។ ម្យ៉ាងទៀត កូនស្រីរបស់ខ្ញុំក៏ជាអរិយសាវិកាដែលជាព្រះសោតាបន្ន ធ្វើការបូជាដោយផ្កា មានតម្លៃច្រើនកហាបណៈរាល់ៗ ថ្ងៃ ខ្ញុំមិនបញ្ជូនធីតាទៅកាន់ផ្ទះមនុស្សមិច្ឆាទិដ្ឋិដូចលោកទេ ។ រាជគហសេដ្ឋីដឹងថា បុណ្ណសេដ្ឋីបដិសេធយ៉ាងនោះ ក៏បញ្ជូនសាសន៍ទៅទៀតថា សូមកុំទម្លាយការស្និទ្ធស្នាលចាស់របស់យើងឡើយ យើងនឹងឲ្យផ្កាមានតម្លៃ ២ កហាបណៈរាល់ៗ ថ្ងៃ ដល់កូនប្រសាររបស់ខ្ញុំ ។ បុណ្ណសេដ្ឋីក៏ទទួលយល់ព្រម ហើយបញ្ជូនធីតាទៅផ្ទះរបស់រាជគហសេដ្ឋីនោះ ។ ថ្ងៃមួយ នាងឧត្តរាធីតារបស់បុណ្ណសេដ្ឋីនោះពោលនឹងស្វាមីរបស់ខ្លួនយ៉ាងនេះថា ខ្ញុំធ្វើឧបោសថកម្មមួយខែ ៨ ថ្ងៃ ក្នុងផ្ទះត្រកូលរបស់ខ្ញុំ ឥឡូវនេះ បើលោកទទួលឲ្យនូវការយល់ព្រម ខ្ញុំក៏គប្បីអធិដ្ឋានអដ្ឋឧបោសថ ។ ស្វាមីនោះពោលថា ខ្ញុំយល់ព្រមមិនបានទេ ហើយមិនទទួលពាក្យ ។ នាងមិនអាចធ្វើស្វាមី នោះឲ្យយល់បានក៏នៅស្ងៀម គិតថា អញនឹងអធិដ្ឋានអដ្ឋឧបោសថខាងក្នុងវស្សាទៀត កាលនោះ នាងសូមឱកាស ក៏មិនបានឱកាសទៀតនោះឯង ។ ខាងក្នុងវស្សាកន្លងទៅ ២ ខែកន្លះ សល់កន្លះខែទៀត ទើបនាងបញ្ជូនដំណឹងទៅប្រាប់ដល់ឪពុកថា ខ្ញុំត្រូវលោកឪពុកអ្នកម្តាយបញ្ជូនទៅឃុំឃាំង ក្នុងទីឃុំឃាំងអស់កាលយូរប៉ុណ្ណោះ

ហើយ សូម្បីអធិដ្ឋានឧបោសថត្រឹមតែមួយថ្ងៃក៏មិនបាន សូមបញ្ជូនកហាបណៈ ដល់ខ្ញុំ ១៥០០០ កហាបណៈចុះ ។ មាតាបិតាដឹងដំណឹងធីតាហើយ ក៏មិនសួរថា ព្រោះហេតុអ្វី បញ្ជូនប្រាក់ទៅឲ្យហើយ នាងឧត្តរាទទួលកហាបណៈទាំងនោះហើយ ។ មានស្រីធ្វើឲ្យនគរស្អាតឈ្មោះសិរិមា នៅក្នុងនគរនោះ ទើបឲ្យហៅនាងមក ហើយពោលថា នែសិរិមា ខ្ញុំនឹងអធិដ្ឋានអដ្ឋឧបោសថអស់កន្លះខែ សូមនាងទទួលកហាបណៈ ១៥០០០ កហាបណៈនេះ ហើយបម្រើសេដ្ឋីបុត្រអស់កាលកន្លះខែនេះ ។ នាងសិរិមាក៏ទទួលថា ល្អណាស់នាង ។ តាំងអំពីនោះមក កូនសេដ្ឋីគិតថា អញនឹងសោយសុខជាមួយនាងសិរិមា ទើបអនុញ្ញាតឲ្យនាងឧត្តរាទទួលឧបោសថកម្មអស់កន្លះខែ ។ នាងឧត្តរាដឹងថា ស្វាមីទទួលយល់ព្រមហើយ មានពួកទាសីចោមរោម រៀបចំគ្រឿងទំពា គ្រឿងឆាន់ដោយដៃឯងអំពីព្រលឹម រាល់ៗ ថ្ងៃ កាលព្រះសាស្តាទ្រង់ធ្វើកត្តកិច្ចស្រេចហើយ យាងទៅវិហារហើយ ក៏អធិដ្ឋានអដ្ឋឧបោសថឡើងប្រាសាទដ៏ប្រសើរ អង្គុយរឭកដល់សីលរបស់ខ្លួន ។ វេលាកន្លងទៅកន្លះខែ ដោយអាការយ៉ាងនេះ ក្នុងថ្ងៃដាក់ឧបោសថ ទើបនាងចាត់ចែងបបរ និងរបស់ទំពាជាដើមអំពីព្រលឹម ។

សម័យនោះ កូនសេដ្ឋីឈរលើប្រាសាទដ៏ប្រសើរជាមួយនាងសិរិមា បើកបង្អួចមើលទ្រព្យតាមលំដាប់ នាងឧត្តរាក្រឡេកមើលទៅត្រង់បន្ទោះបង្អួច ។ កូនសេដ្ឋីសម្លឹងមើលនាងឧត្តរា គិតថា ស្រីនេះគង់កាន់យកកំណើតអំពីនរកហ្ន៎ លះសម្បត្តិយ៉ាងនេះហើយ ជាអ្នកប្រឡាក់ដោយធ្យូងឆ្នាំង

ប្រឡូកប្រឡាំនៅក្នុងចន្លោះទាសីទាំងឡាយ មិនគួរដល់ហេតុ ហើយធ្វើការញញឹម ។ នាងឧត្តរាជ្រាបសេចក្តីដែលកូនសេដ្ឋីនោះប្រមាថ គិតថា កូនសេដ្ឋីនេះ ឈ្មោះថា ជាបុគ្គលល្ងង់ខ្លៅ គង់សម្គាល់ថា សម្បត្តិរបស់ខ្លួននៅជាថាវរៈគ្រប់កាល ដូច្នេះហើយ ខ្លួនឯងក៏ធ្វើការញញឹមដែរ ខណៈនោះ នាងសិរិមាក៏ក្រោធ ហើយបរិភាសថា នាងទាសីនេះ កាលអញឈរ ក៏នៅតែធ្វើការញញឹមជាមួយនឹងប្តីរបស់អញយ៉ាងនេះ ទើបចុះរះ ចុះអំពីប្រាសាទ ។ ដោយអាកប្បកិរិយា ដែលមករបស់នាងសិរិមានោះឯង នាងឧត្តរាក៏ជ្រាបថា ស្រីល្ងង់នេះ នៅក្នុងផ្ទះនេះត្រឹមតែកន្លះខែ ក៏កើតសេចក្តីសម្គាល់ថា ផ្ទះនេះជារបស់អញម្នាក់ឯង ដូច្នេះ ក្លាមនោះឯង ក៏ឈរចូលឈាន មានមេត្តាជាអារម្មណ៍ ។ ឯនាងសិរិមាក៏មកក្នុងចន្លោះទាសីទាំងឡាយ ចាប់បោយពេញដោយប្រេងក្តៅក្នុងខ្ទះចៀននំ ស្រោចលើក្បាលនាងឧត្តរា ។ ដោយការផ្សាយមេត្តាឈាន ប្រេងក្តៅដែល នាងសិរិមាស្រោចលើក្បាលនាងឧត្តរាក៏ហូរធ្លាក់ទៅ ដូចទឹកដែលស្រោចលើស្លឹកឈូក ដូច្នោះ ។

ខណៈនោះ ទាសីទាំងឡាយ ដែលឈរក្បែរនាងសិរិមា ឃើញហេតុនោះហើយ ក៏បរិភាសនាងសិរិមានោះចំពោះមុខថា នៃស្រីដ៏ប្រសើរ នាងទទួលតម្លៃពីដៃចៅហ្វាយរបស់ខ្ញុំ មកនៅក្នុងផ្ទះនេះ នៅព្យាយាមប្រៀបធៀបនឹងចៅហ្វាយរបស់ពួកខ្ញុំឬ ។ គ្រានោះ នាងសិរិមាដឹងខ្លួនជាអាគន្តុកៈមកម្តងម្កាល ក៏ទៅអំពីទីនោះ ហើយក្រាបទៀបបាតជើងនាងឧត្តរា ពោលថា បពិត្រអ្នកនាង ខ្ញុំមិនបានពិចារណា ធ្វើកម្មយ៉ាងនេះ សូមអត់ទោសឲ្យខ្ញុំ

ចុះ ។ នាងឧត្តរាពោលថា សិរិមា ខ្ញុំអត់ទោសឲ្យក្នុងឋានៈនេះមិនបានទេ ខ្ញុំជាកូនស្រីមានឪពុក ខ្ញុំនឹងអត់ទោសឲ្យ លុះណាតែព្រះទសពលទ្រង់អត់ទោសឲ្យនាងប៉ុណ្ណោះ ។

ព្រះសាស្តា មានភិក្ខុជាបរិវារ យាងមកប្រថាប់លើអាសនៈ ដែលរៀបចំទុកក្នុងនិវេសន៍របស់នាងឧត្តរា ។ ទើបនាងសិរិមា ទៅក្រាបទៀបព្រះយុគលបាទព្រះសាស្តា ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់ធ្វើកំហុសណាមួយក្នុងរវាងនាងឧត្តរា នាងពោលថា បើទ្រង់អត់ទោសឲ្យ ខ្ញុំក៏អត់ទោសឲ្យ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់មេត្តាអត់ទោសដល់ខ្ញុំព្រះអង្គដែលកំពុងសូមខមាទោសផងចុះ ព្រះមានព្រះភាគត្រាស់ថា ម្នាលសិរិមា តថាគតអត់ទោសឲ្យ ។ ពេលនោះ នាងសិរិមានោះ ក៏ទៅសូមឲ្យនាងឧត្តរាអត់ទោសឲ្យ ។ ក្នុងថ្ងៃនោះ នាងសិរិមាស្តាប់អនុមោទនាកត្ថាទានរបស់ព្រះទសពលថា

**អក្កោធេន ជិនេ កោធំ អសាធុំ សាធុនា ជិនេ**
**ជិនេ កទរិយំ ទានេន សច្ចេនាលិកវាទិនំ ។**

បុគ្គលគប្បីផ្ចាញ់មនុស្សក្រោធ ដោយសេចក្តីមិនក្រោធ
គប្បីផ្ចាញ់មនុស្សអសប្បុរស ដោយសប្បុរស គប្បីផ្ចាញ់
មនុស្សកំណាញ់ ដោយការឲ្យ គប្បីផ្ចាញ់មនុស្ស
និយាយពាក្យមិនពិត ដោយពាក្យពិត ។

កាលចប់ព្រះគាថា ក៏តាំងនៅក្នុងសោតាបត្តិផល និមន្តព្រះទសពល

ថ្វាយមហាទានក្នុងថ្ងៃស្អែក ។ រឿងនេះកើតឡើងយ៉ាងនេះ ។ ក្រោយមក ព្រះសាស្ដាប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនានាងឧត្តរានន្ទមាតា ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាខាងចូលឈាន ដូច្នេះ ។ល។

**អដ្ឋកថា សូត្រទី ៥ ចប់**

## អដ្ឋកថាសូត្រទី ៦

## ប្រវត្តិ នាងសុប្បវាសា កោលិយធីតា

ក្នុងសូត្រទី ៦ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **បណីតទាយិកានំ** លោកសម្ដែងថា ព្រះនាងសុប្បវាសាកោលិយធីតាជាកំពូលជាងពួកឧបាសិកា ដែលថ្វាយរបស់មានរសប្រណីត ។

បានឮមកថា ព្រះនាងសុប្បវាសាកោលិយធីតានោះ កាលព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្ដាប់ព្រះធម្មទេសនារបស់ព្រះសាស្ដា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលលើសឧបាសិកាដែលថ្វាយរបស់មានរសប្រណីត ធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នានូវតំណែងនោះ ។ នាងអន្ទោលទៅក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុង

ត្រកូលក្សត្រ នគរកោលិយៈ ទើបពួកញាតិថ្វាយព្រះនាមថា សុប្បវាសា ។ ចម្រើនវ័យហើយ អភិសេកជាមួយសក្យកុមារមួយអង្គ ។ ដោយការចូលគាល់លើកទី ១ ប៉ុណ្ណោះ ស្តាប់ធម្មកថារបស់ព្រះសាស្តា ក៏តាំងនៅក្នុងសោតាបត្តិផល បន្ទាប់មក ព្រះនាងប្រសូតព្រះឱរស ព្រះនាមថាសីវលី រឿងនៃព្រះសីវលីនោះ បានពោលពិស្តារហើយខាងដើម ។ ថ្ងៃមួយ នាងថ្វាយភោជនដ៏ប្រណីត មានរសផ្សេងៗ ដល់ព្រះភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន ។ ព្រះសាស្តា លុះសោយស្រេចហើយ កាលទ្រង់ធ្វើអនុមោទនា ទ្រង់សម្តែងធម៌នោះដល់ព្រះនាងសុប្បវាសាថា ម្នាលនាងសុប្បវាសា អរិយសាវិកាថ្វាយភោជន ឈ្មោះថា ឲ្យឋានៈទាំង ៥ ដល់ពួកបដិគ្គាហក គឺឲ្យអាយុ ឲ្យវណ្ណៈ ឲ្យសុខ ឲ្យពល ឲ្យបដិភាណ ។ បុគ្គលឲ្យអាយុ រមែងមានចំណែកនៃអាយុទាំងដែលជារបស់ទិព្វ ទាំងដែលជារបស់មនុស្ស ។បេ។ បុគ្គលឲ្យបដិភាណ រមែងជាអ្នកមាន ចំណែកនៃបដិភាណជារបស់ទិព្វផង ជារបស់មនុស្សផង ។ រឿងនេះកើតឡើងយ៉ាងនេះ ។ បន្ទាប់មក ក្នុងកាលឯក្រោយ ព្រះសាស្តាទ្រង់ប្រថាប់គង់នាវត្តជេតពនមហាវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាព្រះនាងសុប្បវាសាកោលិយធីតា ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាដែលថ្វាយរបស់មានរសប្រណីត ដូច្នេះ ។

## អដ្ឋកថាសូត្រទី ៦ ចប់

# អដ្ឋកថា សូត្រទី ៧
# ប្រវត្តិ នាងសុប្បិយាឧបាសិកា

ក្នុងសូត្រទី ៧ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **គិលានុបដ្ឋាកានំ** លោកសម្ដែងថា នាងសុប្បិយាឧបាសិកា ជាកំពូលជាងពួកឧបាសិកាដែលឧបដ្ឋាកភិក្ខុអ្នកមានជំងឺ ។

បានឮមកថា នាងសុប្បិយាឧបាសិកានេះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតឡើងក្នុងត្រកូលមួយ នាក្រុងហង្សវតី បន្ទាប់មក ស្ដាប់ព្រះធម្មទេសនា ឃើញព្រះសាស្ដាទ្រង់ស្ថាបនាឧបាសិកាម្នាក់ ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងឧបាសិកា ដែលឧបដ្ឋាកភិក្ខុឈឺ ទើបធ្វើកុសលឲ្យក្រៃលែងឡើងប្រាថ្នាតំណែងនោះ នាងអន្ទោលទៅមកក្នុងទេវតា និងមនុស្សអស់មួយសែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ក្នុងក្រុងពារាណសី ឪពុកម្ដាយដាក់ឈ្មោះនាងថា សុប្បិយា ។ ចំណោរតមក ព្រះសាស្ដាមានភិក្ខុសង្ឃជាបរិវារ បានយាងទៅកាន់ក្រុងពារាណសី ។ ដោយការគាល់លើកទី ១ ប៉ុណ្ណោះ នាងស្ដាប់ធម៌ហើយ តាំងនៅក្នុងសោតាបត្តិផល ។ ថ្ងៃមួយ នាងទៅកាន់វិហារដើម្បីស្ដាប់ធម៌ ចារិកទៅក្នុងវិហារ ជួបភិក្ខុឈឺមួយរូប ថ្វាយបង្គំហើយ ធ្វើការទទួល សួរថា លោកម្ចាស់ គួរបានអ្វី ។ ភិក្ខុឈឺឆ្លើយថា គួរបានអាហារមានរសជាតិសាច់ ។ នាងពោលថា ណ្ហើយចុះ លោកម្ចាស់ ខ្ញុំនឹងបញ្ជូនមកប្រគេន ថ្វាយបង្គំព្រះថេរៈហើយ ចូលទៅកាន់ក្រុង ថ្ងៃស្អែកឡើង ក៏បញ្ជូនទាសីទៅផ្សារដើម្បីត្រូវការបវត្តមំសៈ ( សាច់ដែលគេលក់ក្នុងផ្សារ ) ទាសីនោះ រកបវត្តមំសៈពេញក្រុងមិនបាន

ក៏ប្រាប់នាងថា រកមិនបានឡើយ ។ ឧបាសិកាគិតថា អញបានប្រាប់ដល់លោកម្ចាស់ថា នឹងបញ្ជូនសាច់ទៅប្រគេន បើមិនបញ្ជូនទៅ លោកម្ចាស់កាលមិនបានអំពីទីដទៃ ក៏នឹងលំបាក អញគួរធ្វើសាច់ណាមួយ បញ្ជូនទៅប្រគេន ហើយចូលបន្ទប់ ចៀរសាច់ភ្លៅឲ្យដល់ទាសី ប្រាប់ថា នាងចូរយកសាច់នេះ ចម្អិនដោយគ្រឿងផ្សំ នាំទៅវិហារ ប្រគេនដល់លោកម្ចាស់ បើលោកម្ចាស់សួរដល់ ក៏ចូរប្រាប់ថា ខ្ញុំឈឺ ។ ទាសីនោះក៏បានធ្វើយ៉ាងនោះ ។

ព្រះសាស្តាទ្រង់ជ្រាបហេតុនោះ ស្អែកឡើង ក្នុងវេលាស្វែងរកភត្ត ក៏មានភិក្ខុសង្ឃជាបរិវារ ទ្រង់យាងទៅកាន់ផ្ទះរបស់ឧបាសិកា នាងដឹងថា ព្រះតថាគតយាងមក ទើបប្រឹក្សានឹងប្តីថា បពិត្រអយ្យបុត្រ ខ្ញុំមិនអាចទៅគាល់ព្រះសាស្តាបាន សូមអ្នកទៅក្រាបទូលយាងព្រះសាស្តាឲ្យចូលផ្ទះ ហើយគង់ប្រថាប់ចុះ ។ ស្វាមីនោះក៏បានធ្វើយ៉ាងនោះ ។ ព្រះសាស្តាត្រាស់សួរថា តើនាងសុប្បិយាទៅណា ស្វាមីក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន នាងមានជំងឺ ។ ព្រះមានព្រះភាគត្រាស់ថា ចូរហៅនាងមកចុះ នាងគិតថា ព្រះសាស្តាទ្រង់សង្គ្រោះដល់សត្វលោកទាំងពួង ទ្រង់ជ្រាបហេតុរបស់អញ ទើបត្រាស់ហៅ ទើបក្រោកឡើងអំពីគ្រែយ៉ាងរហ័ស ។ គ្រានោះ ដោយពុទ្ធានុភាព ដំបៅនាង ក៏ដុះឡើងមួយរំពេច ស្បែករៀបក៏ស្មើ ពណ៌សម្បុរក៏ផូរផង់ជាងមុន ។ ខណៈនោះ ឧបាសិកាក៏ញញឹម បានថ្វាយបង្គំព្រះទសពលដោយបញ្ចង្គប្រតិស្ឋាន អង្គុយក្នុងទីដ៏សមគួរ នាចំណែកម្ខាង ។ ព្រះសាស្តាទ្រង់ព្រះតម្រិះថា ឧបាសិកានេះ មិនសប្បាយ ព្រោះហេតុអ្វី ទើបត្រាស់សួរ

ទើបនាងតំណាលរឿងដែលខ្លួនធ្វើគ្រប់យ៉ាងថ្វាយ ។ ព្រះសាស្តាសោយស្រេចហើយ យាងទៅកាន់វិហារ ទ្រង់ប្រជុំភិក្ខុសង្ឃ ហើយទ្រង់តិះដៀលភិក្ខុនោះយ៉ាងច្រើន ទ្រង់បញ្ញត្តសិក្ខាបទ ។ រឿងនេះ កើតឡើងយ៉ាងនេះ ។ ក្រោយមក ព្រះសាស្តាប្រថាប់គង់ក្នុងវត្តជេតពនវិហារ កាលទ្រង់ស្ថាបនាពួកឧបាសិកាទុកក្នុងតំណែងផ្សេងៗ តាមលំដាប់ ទើបទ្រង់ស្ថាបនានាងសុប្បិយាឧបាសិកាទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាដែលឧបដ្ឋាកភិក្ខុអ្នកមានជំងឺ ដូច្នេះ ។៚

**អដ្ឋកថាសូត្រទី ៧ ចប់**

# អដ្ឋកថា សូត្រទី ៨
# ប្រវត្តិ នាងកាតិយានី

ក្នុងសូត្រទី ៨ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អវេច្ចប្បសន្នានំ** លោកសំដែងថា នាងកាតិយានី ជាកំពូលជាងពួកឧបាសិកា ដែលប្រកបដោយសេចក្តីជ្រះថ្លាមិនកម្រើក ដែលខ្លួនសម្រេចហើយ ។

បានឮមកថា នាងកាតិយានីនោះ កាលព្រះពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតឡើងក្នុងត្រកូលមួយ នាក្រុងហង្សវតី ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាដែលជ្រះថ្លា

មិនកម្រើក ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នាតំណែងនោះ នាងអន្ទោល ក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងកុររ-យរនគរ បិតាឲ្យឈ្មោះថា កាតិយានី ។

បន្ទាប់មក នាងចម្រើនវ័យ ជាសម្លាញ់ ជាមិត្រជិតស្និទ្ធរបស់នាង កាឡី អ្នកកុររឃរនគរ ។ កាលនោះ ព្រះកោដិកណ្ណសោណត្ថេរ ត្រូវមាតា អង្វរថា សូមកូនពោលធម៌ដល់ញោមដោយទំនង ដែលព្រះទសពលត្រាស់ ចុះ ក៏អង្គុយលើអាសនៈ ដែលគេតាក់តែងហើយក្នុងនគរ លុះដល់ពេល យប់ ផ្ដើមទេសនា ធ្វើមាតាឲ្យជាអរិយកាយសក្ខី ។ សម័យនោះ នាង កាតិយានីឧបាសិកានេះ ទៅជាមួយនាងកាឡី ឈរស្ដាប់ធម៌ខាងចុងបរិស័ទ ។ គ្រានោះ ចោរ ៩០០ នាក់ ជីកឧម្មង្គអំពីជ្រុងម្ខាងក្នុងនគរ កំណត់សញ្ញា ដែលធ្វើក្នុងពេលថ្ងៃហើយ ទៅដល់ត្រង់ផ្ទះនាងកាតិយានីឧបាសិកានេះ ។ បណ្ដាចោរទាំងនោះ មេចោរមិនចូលទៅជាមួយចោរទាំងនោះទេ ទៅកាន់ទី សម្ដែងធម៌របស់ព្រះសោណត្ថេរ ដើម្បីស៊ើបមើលថា បរិស័ទទាំងនេះ ប្រជុំ គ្នាធ្វើអ្វីហ្ន៎ កាលឈរខាងចុងបរិស័ទ ក៏ឈរខាងក្រោយនាងកាតិយានី-ឧបាសិកានេះ ។ កាលនោះ ទើបនាងកាតិយានីហៅទាសីមកប្រាប់ថា នែ នាង នាងចូរទៅផ្ទះ យកប្រទីបប្រេងមក ខ្ញុំនឹងអុជប្រទីបធ្វើឲ្យភ្លឺ ហើយ ស្ដាប់ធម៌ ។ ទាសីនោះទៅផ្ទះ អុជប្រទីប ជួបពួកចោរជីកឧម្មង្គ ក៏មិនកាន់ យកប្រទីបប្រេងមក មកប្រាប់ម្ចាស់របស់ខ្លួនថា បពិត្រអ្នកម៉ែ ពួកចោរជីក ឧម្មង្គក្នុងផ្ទះ ។ មេចោរស្ដាប់ពាក្យទាសីនោះហើយ គិតថា បើស្រីនេះជឿ

ពាក្យទាសីនេះ ហើយទៅផ្ទះសោត អញនឹងយកដាវកាត់នាងឲ្យដាច់ជា ២ កំណាត់ក្នុងទីនេះឯង បើស្រីនេះស្តាប់ធម៌ ដោយនិមិត្តដែលនាងកាន់យក ហើយនោះឯង អញនឹងសងទ្រព្យដែលចោររឹបអូស ។ ឯនាងកាតិយានី ស្តាប់ពាក្យទាសីហើយ ក៏ពោលថា នែនាង នាងកុំធ្វើសំឡេងខ្លាំងឡើយ ឈ្មោះថា ពួកចោរ កាលលួច ក៏លួចតែទ្រព្យដែលខ្លួនឃើញប៉ុណ្ណោះឯង ចំណែកខ្ញុំស្តាប់ធម៌ ដែលកើតឡើងដោយកម្រក្នុងថ្ងៃនេះ នាងកុំធ្វើអន្តរាយដល់ធម៌ឡើយ ។ មេចោរស្តាប់នាង ក៏គិតថា ពួកយើងនាំគ្នាលួចទ្រព្យក្នុងផ្ទះរបស់ស្រីដែលមាំទាំដោយអធ្យាស្រ័យបែបនេះ ធរណីនឹងស្រូបពិត ។ រំពេចនោះឯង មេចោរក៏ទៅបញ្ជាឲ្យយកទ្រព្យដែលលួចទៅហើយមកវិញ ហើយពួកចោរក៏នាំគ្នាទៅស្តាប់ធម៌ខាងចុងបរិស័ទ ។ ឯនាងកាតិយានីឧបាសិកា ចប់ទេសនារបស់ព្រះថេរៈ ក៏តាំងនៅក្នុងសោតាបត្តិផល ។ គ្រានោះ កាលអរុណរះឡើង មេចោរក៏ទៅក្រាបទៀបបាទាឧបាសិកា ពោលថា បពិត្រអ្នកម្តាយ សូមអត់ទោសឲ្យដល់ពួកខ្ញុំទាំងអស់ផងចុះ ។ នាងសួរថា ពួកអ្នកធ្វើអ្វីដល់ខ្ញុំឬ មេចោរនោះក៏ប្រាប់ទោសដែលខ្លួនធ្វើទាំងអស់ ។ នាងពោលថា នែអ្នក ខ្ញុំអត់ទោសឲ្យពួកអ្នក ។ មេចោរពោលថា ទោះជាអ្នកម្តាយអត់ទោសឲ្យដល់ខ្ញុំហើយ តែសូមមេត្តាឲ្យពួកខ្ញុំបួសក្នុងសម្នាក់កូនអ្នកម្តាយផងចុះ ។ នាងក៏នាំពួកចោរទាំងអស់ ទៅបួសក្នុងសម្នាក់ព្រះកោដិកណ្ណ-សោណត្ថេរ ។ មនុស្សទាំងនោះ បួសក្នុងសម្នាក់ព្រះថេរៈហើយ ក៏សម្រេចអរហត្តគ្រប់រូប ។ រឿងនេះកើតឡើងយ៉ាងនេះ ។ ក្រោយមក ព្រះសាស្តា

ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ស្ថាបនាឧបាសិកាក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនានាងកាតិយានីឧបាសិកាទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកាអរិយសាវិកា ដែលជ្រះថ្លាមិនកម្រើក ដូច្នេះ ។

## អដ្ឋកថា សូត្រទី ៨ ចប់

# អដ្ឋកថា សូត្រទី ៩

# ប្រវត្តិ នាងនកុលមាតា គហបតានី

ក្នុងសូត្រទី ៩ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **វិស្សាសិកានំ** លោកសម្តែងថា នកុលមាតាគហបតានី ជាកំពូលជាងពួកឧបាសិកាអរិយសាវិកា អ្នកពោលពាក្យស្និទ្ធស្នាល ពាក្យដែលគប្បីពោលក្នុងរឿងនេះ មានន័យដូចបានពោលហើយ ក្នុងឧបាសកបាលីខាងដើមនោះឯង ។ គប្បីជ្រាបរឿងនកុលមាតា ដោយប្រៀបធៀបក្នុងឧបាសកបាលីនោះឯង ។

## អដ្ឋកថាសូត្រទី ៩ ចប់

# អដ្ឋកថា សូត្រទី ១០
# ប្រវត្តិ នាងកាឡីឧបាសិកា អ្នកស្រុក កុររឃរនគរ

ក្នុងសូត្រទី ១០ គប្បីជ្រាបវិនិច្ឆ័យដូចតទៅនេះ បទថា **អនុស្ស-វប្បសន្នានំ** លោកសម្តែងថា នាងកាឡីឧបាសិកា អ្នកកុររឃរនគរ ជាកំពូលជាងពួកឧបាសិកាដែលប្រកបដោយសេចក្តីជ្រះថ្លា ដែលកើតឡើងដោយស្តាប់តៗ គ្នាមក ។

បានឮមកថា នាងកាឡីឧបាសិកានោះ កាលព្រះសម្ពុទ្ធព្រះនាមបទុមុត្តរៈ នាងកើតឡើងក្នុងត្រកូលមួយ នាក្រុងហង្សវតី កំពុងស្តាប់ធម្មកថារបស់ព្រះសាស្តា ឃើញព្រះសាស្តាទ្រង់ស្ថាបនាឧបាសិកាម្នាក់ទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកា ដែលជ្រះថ្លាដោយស្តាប់តៗ គ្នាមក ទើបធ្វើកុសលឲ្យក្រៃលែងឡើង ប្រាថ្នានូវតំណែងនោះ ។ នាងអន្ទោលក្នុងទេវតា និងមនុស្សអស់សែនកប្ប ក្នុងពុទ្ធុប្បាទកាលនេះ កើតក្នុងត្រកូលមួយ ក្នុងក្រុងរាជគ្រឹះ ពួកញាតិបានតាំងឈ្មោះនាងថា កាឡី ។ នាងចម្រើនវ័យហើយ មានប្តីក្នុងកុររឃរនគរ ។ គ្រានោះ ដោយការនៅរួមគ្នា ទើបនាងមានគភ៌ ។ នាងមានគភ៌គ្រប់កំណត់ហើយ គិតថា ការប្រសូតបុត្រក្នុងផ្ទះរបស់អ្នកដទៃមិនសមគួរ ទើបទៅកាន់កុររឃរនគររបស់ខ្លួន បន្ទាប់អំពីកណ្តាលយប់ ស្តាប់ពាក្យសាតាគិរិយក្ខ និងហេមវតយក្ខ ដែលឈរក្នុងអាកាស លើប្រាសាទរបស់ខ្លួន ពោលពណ៌នាគុណព្រះរតនត្រ័យ កើតសេចក្តីជ្រះថ្លា ដែលបានឮសំឡេងសរសើរគុណព្រះរតនត្រ័យ ក៏តាំងនៅក្នុងសោតាបត្តិផល ដោយមិនទាន់បានគាល់ព្រះសាស្តានៅឡើយ បន្ទាប់មក

*នាងក៏ប្រសូតបុត្រ ។ រឿងទាំងអស់ពោល ទុកពិស្តារហើយខាងដើម ។ សម័យតមក ព្រះសាស្តាប្រថាប់គង់កណ្តាលជំនុំសង្ឃ នាវត្តជេតពនវិហារ កាលទ្រង់ស្ថាបនាឧបាសិកាទាំងឡាយទុកក្នុងតំណែងផ្សេងៗ ទើបទ្រង់ស្ថាបនាឧបាសិកានេះទុកក្នុងតំណែងឯតទគ្គៈ ជាកំពូលជាងពួកឧបាសិកា ដែលជ្រះថ្លាដោយស្តាប់តៗ គ្នាមក ដូច្នោះ ។*

**អដ្ឋកថាសូត្រទី ១០ ចប់**

**ឧបាសិកាបាលិ ចប់**

*អដ្ឋកថាអង្គុត្តរនិកាយ ឈ្មោះមនោរថបូរណី ប្រកបដោយសូត្រ*

*មានប្រមាណប៉ុណ្ណោះ*

# ក្បាលទី ២៥

# សុត្តន្តបិដក បាលីប្រែ -៤០

## សន្ទឹកចង្អុលប្រាប់មាតិកា

មាតិកា លេខទំព័រ

### រូបាទិវគ្គទី ១


រូបាទិវគ្គ ...... ...... ...... ...... ២

អដ្ឋកថារូបាទិវគ្គ ...... ...... ...... ...... ៥

អត្ថរបស់ឯវិសេសពួជាដើម ...... ...... ...... ...... ៨


### នីវរណាបហានវគ្គទី ២


អត្ថរបស់រូបសព្ទជាដើម ...... ...... ...... ...... ៣៧

រឿងព្រះឧម្មត្តកចិត្តត្ថេរ ...... ...... ...... ...... ៣៩

រឿងភិក្ខុកំលោះ និងស្រីស្នំ ...... ...... ...... ...... ៤០

រឿងក្អាមមាស ...... ...... ...... ...... ៤២

រឿងសំឡេងពិណ ...... ...... ...... ...... ៤៩

រឿងក្លិនរបស់ភិក្ខុ ១ រូប ...... ...... ...... ...... ៥០

នីវរណបហានវគ្គ ...... ...... ...... ...... ៥២

អដ្ឋកថានីវរណបហានវគ្គ ...... ...... ...... ...... ៥៦

រឿងព្រះមាលកតិស្សត្ថេរ ...... ...... ...... ...... ៦៨

រឿងព្រះមាលយទេវត្ថេរ ...... ...... ...... ...... ៧២

រឿងព្រះតិស្សភូតត្ថេរ ...... ...... ...... ...... ៧៤

រឿងព្រះមហាសិវត្ថេរ ...... ...... ...... ...... ៧៦

រឿងព្រះមហាតិស្សត្ថេរ ...... ...... ...... ...... ៧៨

រឿងភិក្ខុ ៦០ រូប ...... ...... ...... ...... ៨០

រឿងព្រះតិស្សៈក្នុងចិត្តលបពិត ...... ...... ...... ...... ៨២

អកម្មនិយវគ្គទី ៣

អកម្មនិយវគ្គ ...... ...... ...... ...... ៩៤

អដ្ឋកថាអកម្មនិយវគ្គ ...... ...... ...... ...... ៩៧

អទន្តវគ្គទី ៤

អទន្តវគ្គ ...... ...... ...... ...... ១០៣

អដ្ឋកថាអទន្តវគ្គ ...... ...... ...... ...... ១០៦

បណិហិតអច្ឆវគ្គទី ៥

បណិហិតអច្ឆវគ្គ ...... ...... ...... ...... ១០៩

អដ្ឋកថាបណិហិតអច្ឆវគ្គ ...... ...... ...... ...... ១១៣

អច្ឆរាសង្ឃាតវគ្គទី ៦

អច្ឆរាសង្ឃាតវគ្គ ...... ...... ...... ...... ១២៤

អដ្ឋកថាអច្ឆរាសង្ឃាតវគ្គ ...... ...... ...... ...... ១២៧

វីរិយារម្ភាទិវគ្គទី ៧

វីរិយារម្ភាទិវគ្គ ...... ...... ...... ...... ១៤៩

អដ្ឋកថា វីរិយារម្ភាទិវគ្គ ...... ...... ...... ...... ១៥៣

អប្បិច្ឆកថា ...... ...... ...... ...... ១៥៤

រឿងព្រះមជ្ឈន្តិកត្ថេរ ...... ...... ...... ...... ១៥៦

សន្តោសកថា ...... ...... ...... ...... ១៥៩

កល្យាណមិត្តតាទិវគ្គទី ៨

កល្យាណមិត្តតាទិវគ្គ ...... ...... ...... ...... ១៦៦

អដ្ឋកថាកល្យាណមិត្តតាទិវគ្គ ...... ...... ...... ...... ១៧០

បមាទាទិវគ្គទី ៩

បមាទាទិវគ្គ ...... ...... ...... ...... ១៧៧

អដ្ឋកថាបមាទាទិវគ្គ ...... ...... ...... ...... ១៨១

ទុតិយបមាទាទិវគ្គទី ១០

ទុតិយបមាទាទិវគ្គ ...... ...... ...... ...... ១៨២

អដ្ឋកថាទុតិយបមាទាទិវគ្គ ...... ...... ...... ...... ១៨៩

អន្តរធានមាន ៥ យ៉ាង ...... ...... ...... ...... ១៩២

អធម្មវគ្គទី ១១

អធម្មវគ្គ ...... ...... ...... ...... ២០៣

អដ្ឋកថាអធម្មវគ្គ ...... ...... ...... ...... ២០៦

អនាបត្តិវគ្គទី ១២

អនាបត្តិវគ្គ ...... ...... ...... ...... ២០៧

អដ្ឋកថាអនាបត្តិវគ្គ ...... ...... ...... ...... ២០៩

ឯកបុគ្គលបាលិវគ្គទី ១៣

ឯកបុគ្គលបាលិវគ្គ ...... ...... ...... ...... ២១០

អដ្ឋកថាឯកបុគ្គលវគ្គ ...... ...... ...... ...... ២១៣

បុច្ឆាមាន ៥ យ៉ាង ...... ...... ...... ...... ២២៤

តថាគត ៨ យ៉ាង ...... ...... ...... ...... ២២៦

ពុទ្ធៈ ៤ យ៉ាង ...... ...... ...... ...... ២៤៦

អនុត្តរិយៈទាំង ៦ ...... ...... ...... ...... ២៥០

ឯតទគ្គបាលិវគ្គទី ៤

ឯតទគ្គបាលិវគ្គទី ១

ឯតទគ្គបាលិវគ្គទី ១ ...... ...... ...... ...... ២៦១

អដ្ឋកថា ឯតទគ្គបាលិវគ្គ ...... ...... ...... ...... ២៦២

អត្ថរបស់ អគ្គ សព្ទ ...... ...... ...... ...... ២៦២

ប្រវត្តិព្រះអញ្ញាកោណ្ឌញ្ញត្ថេរ ...... ...... ...... ...... ២៧៩
ប្រវត្តិព្រះសារីបុត្រ និងព្រះមហាមោគ្គល្លានត្ថេរ ...... ...... ...... ...... ២៩៨
ប្រវត្តិព្រះមហាកស្សបត្ថេរ ...... ...... ...... ...... ៣១៨
ប្រវត្តិព្រះអនុរុទ្ធត្ថេរ ...... ...... ...... ...... ៣៥១
ប្រវត្តិព្រះភទ្ទិយកាលិគោធាបុត្តត្ថេរ ...... ...... ...... ...... ៣៦៤
ប្រវត្តិព្រះលកុណ្ឌកភទ្ទិយត្ថេរ ...... ...... ...... ...... ៣៦៧
ប្រវត្តិព្រះបិណ្ឌោលភារទ្វាជត្ថេរ ...... ...... ...... ...... ៣៧០
ប្រវត្តិព្រះបុណ្ណមន្តានីបុត្តត្ថេរ ...... ...... ...... ...... ៣៧៤
ប្រវត្តិព្រះមហាកច្ចាយនត្ថេរ ...... ...... ...... ...... ៣៨២

## ឯតទគ្គបាលិវគ្គទី ២

ឯតទគ្គបាលិវគ្គទី ២ ...... ...... ...... ...... ៣៨៩
ប្រវត្តិព្រះចូឡបន្ថកត្ថេរ និងព្រះមហាបន្ថកត្ថេរ ...... ...... ...... ...... ៣៩០
ប្រវត្តិព្រះសុភូតិត្ថេរ ...... ...... ...... ...... ៤០៥
ប្រវត្តិព្រះសុភូតិត្ថេរ ...... ...... ...... ...... ៤០៦
ប្រវត្តិព្រះរេវតត្ថេរ ...... ...... ...... ...... ៤១០
ប្រវត្តិព្រះកង្ខារេវតត្ថេរ ...... ...... ...... ...... ៤១៩
ប្រវត្តិព្រះសោណកោឡិវិសត្ថេរ ...... ...... ...... ...... ៤២១
ប្រវត្តិព្រះសោណកុដិកណ្ណត្ថេរ ...... ...... ...... ...... ៤២៩
ប្រវត្តិព្រះសីវលិត្ថេរ ...... ...... ...... ...... ៤៣៧
ប្រវត្តិព្រះវក្កលិត្ថេរ ...... ...... ...... ...... ៤៤៦

## ឯតទគ្គបាលិវគ្គទី ៣

ឯតទគ្គបាលិវគ្គទី ៣ ...... ...... ...... ...... ៤៥០
ប្រវត្តិព្រះរាហុលត្ថេរ ...... ...... ...... ...... ៤៥១
ប្រវត្តិព្រះរដ្ឋបាលត្ថេរ ...... ...... ...... ...... ៤៥២

ប្រវត្តិព្រះរាហុល និងព្រះរដ្ឋបាល ...... ...... ...... ...... ៤៥២
ប្រវត្តិព្រះកោណ្ឌធានត្ថេរ ...... ...... ...... ...... ៤៦៥
ប្រវត្តិព្រះវង្គីសត្ថេរ ...... ...... ...... ...... ៤៧៤
ប្រវត្តិព្រះឧបសេនវង្គន្តបុត្តត្ថេរ ...... ...... ...... ...... ៤៨០
ប្រវត្តិព្រះទព្វមល្លបុត្តត្ថេរ ...... ...... ...... ...... ៤៨៤
ប្រវត្តិព្រះបិលិន្ទវច្ឆត្ថេរ ...... ...... ...... ...... ៤៨៩
ប្រវត្តិព្រះពាហិយទារុចីរិយត្ថេរ ...... ...... ...... ...... ៤៩៣
ប្រវត្តិព្រះកុមារកស្សបត្ថេរ ...... ...... ...... ...... ៤៩៩
ប្រវត្តិព្រះមហាកោដ្ឋិកត្ថេរ ...... ...... ...... ...... ៥០២

**ឯតទគ្គបាលិវគ្គទី ៤**

ឯតទគ្គបាលិវគ្គទី ៤ ...... ...... ...... ...... ៥០៤
ប្រវត្តិព្រះអានន្ទត្ថេរ ...... ...... ...... ...... ៥០៥
ប្រវត្តិព្រះឧរុវេលកស្សបត្ថេរ ...... ...... ...... ...... ៥២០
ប្រវត្តិព្រះកាឡុទាយិត្ថេរ ...... ...... ...... ...... ៥២៥
ប្រវត្តិព្រះពក្កុលត្ថេរ ...... ...... ...... ...... ៥៣០
ប្រវត្តិព្រះសោភិតត្ថេរ ...... ...... ...... ...... ៥៣៧
ប្រវត្តិព្រះឧបាលិត្ថេរ ...... ...... ...... ...... ៥៣៩
ប្រវត្តិព្រះនន្ទកត្ថេរ ...... ...... ...... ...... ៥៤១
ប្រវត្តិព្រះនន្ទត្ថេរ ...... ...... ...... ...... ៥៤៤
ព្រះវត្តិព្រះមហាកប្បិនត្ថេរ ...... ...... ...... ...... ៥៤៨
ប្រវត្តិព្រះសាគតត្ថេរ ...... ...... ...... ...... ៥៥៧
ប្រវត្តិព្រះរាធត្ថេរ ...... ...... ...... ...... ៥៦២
ប្រវត្តិព្រះមោឃរាជត្ថេរ ...... ...... ...... ...... ៥៦៧

**ឯតទគ្គបាលិវគ្គទី ៥**

ឯតទគ្គបាលិវគ្គទី ៥ ...... ...... ...... ...... ៥៧៥
ប្រវត្តិព្រះនាងមហាបជាបតីគោតមីថេរី ...... ...... ...... ...... ៥៧៦
ប្រវត្តិព្រះនាងខេមាថេរី ...... ...... ...... ...... ៥៨២
ប្រវត្តិព្រះនាងឧប្បលវណ្ណាថេរី ...... ...... ...... ...... ៥៨៧
ប្រវត្តិព្រះនាងបដាចារាថេរី ...... ...... ...... ...... ៦០១
ប្រវត្តិព្រះនាងធម្មទិន្នាថេរី ...... ...... ...... ...... ៦០៦
ប្រវត្តិព្រះនាងនន្ទាថេរី ...... ...... ...... ...... ៦១០
ប្រវត្តិព្រះនាងសោណាថេរី ...... ...... ...... ...... ៦១៣
ប្រវត្តិព្រះនាងសកុលាថេរី ...... ...... ...... ...... ៦១៦
ប្រវត្តិព្រះនាងភទ្ទាកុណ្ឌលកេសាថេរី ...... ...... ...... ...... ៦១៧
ប្រវត្តិព្រះនាងភទ្ទាកាបិលានីថេរី ...... ...... ...... ...... ៦២៧
ប្រវត្តិព្រះនាងភទ្ទាកច្ចានាថេរី ...... ...... ...... ...... ៦២៩
ប្រវត្តិព្រះនាងកិសាគោតមីថេរី ...... ...... ...... ...... ៦៣២
ប្រវត្តិព្រះនាងសិគាលមាតាថេរី ...... ...... ...... ...... ៦៣៦

### ឯតទគ្គបាលិវគ្គទី ៦

ឯតទគ្គបាលិវគ្គទី ៦ ...... ...... ...... ...... ៦៣៨
ប្រវត្តិតបុស្សៈ និងភល្លិកឧបាសក ...... ...... ...... ...... ៦៣៩
ប្រវត្តិសុទត្តអនាថបិណ្ឌិកគហបតី ...... ...... ...... ...... ៦៤២
ប្រវត្តិចិត្តគហបតី ...... ...... ...... ...... ៦៤៤
ប្រវត្តិហត្ថកអាឡវកឧបាសកអ្នកក្រុងអាឡវី ...... ...... ...... ...... ៦៤៨
ប្រវត្តិព្រះបាទមហានាមសក្យៈ ...... ...... ...... ...... ៦៥៤
ប្រវត្តិឧគ្គគហបតីអ្នកក្រុងវេសាលី ...... ...... ...... ...... ៦៥៦
ប្រវត្តិឧគ្គតគហបតីអ្នកហត្ថិគាម ...... ...... ...... ...... ៦៥៨
ប្រវត្តិសូរអម្ពដ្ឋឧបាសក ...... ...... ...... ...... ៦៦០

ប្រវត្តិពេទ្យជីវកកោមារភច្ច ...... ...... ...... ...... ៦៦៣
ប្រវត្តិនកុលបិតាគហបតី ...... ...... ...... ...... ៦៦៥

### ឯតទគ្គបាលិវគ្គទី ៧

ឯតទគ្គបាលិវគ្គទី ៧ ...... ...... ...... ...... ៦៦៩
ប្រវត្តិនាងសុជាតាសេនិយធីតា ...... ...... ...... ...... ៦៧០
ប្រវត្តិនាងវិសាខាមិគារមាតា ...... ...... ...... ...... ៦៧៣
ប្រវត្តិនាងខុជ្ជុត្តរា និងនាងសាមាវតី ...... ...... ...... ...... ៦៩២
ប្រវត្តិនាងឧត្តរានន្ទមាតា ...... ...... ...... ...... ៧២៧
ប្រវត្តិនាងសុប្បវាសាកោលិយធីតា ...... ...... ...... ...... ៧៣៦
ប្រវត្តិនាងសុប្បិយាឧបាសិកា ...... ...... ...... ...... ៧៣៨
ប្រវត្តិនាងកាតិយានី ...... ...... ...... ...... ៧៤០
ប្រវត្តិនាងនកុលមាតាគហបតានី ...... ...... ...... ...... ៧៤៣
ប្រវត្តិនាងកាឡីឧបាសិកាអ្នកស្រុកកុររឃរនគរ ...... ...... ...... ៧៤៤